# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## បារាជិក ៤

## បឋមភាគ ១

# សមន្តប្បាសាទិកា

## អដ្ឋកថា  វិនយបិដក

## មហាវិភង្គ

## បារាជិក ៤

## បឋមភាគ ១

ឈ្មោះសៀវភៅ **សមន្តបាសាទិកា អដ្ឋកថាវិនយបិដក បារាជិក**

**ភាគ ១**

ប្រែដោយ **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

ប្រែផ្ទៀងផ្ទាត់ដោយ **ភិក្ខុ-សាមណេរ វត្តនិគ្រោធវ័ន "គល់ទទឹង"**

| | |
|---|---|
| ភិក្ខុ គូ សុភាព | ភិក្ខុ តុន ប៊ុនសាយ |
| ភិក្ខុ ភួង សុវណ្ណ | ភិក្ខុ សឹម ស៊ីសាមុត |
| ភិក្ខុ ឈូក សុមន | សាមណេរ នៅ ហៃឡុន |
| ភិក្ខុ ឈឹម ហ៊ាន | សាមណេរ សឿន សាន |

កាលបរិច្ឆេទ ព.ស. ២៥៥៣

ស្ថានទីធ្វើ ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន "គល់ទទឹង" ភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល

ISBN 9789996306068



ភិក្ខុ អគ្គធីរោ គង់_សុមិត្ត

# ជីវប្រវត្តិសង្ខេប

ភិក្ខុ គង់-សុមិត្ត អាយុ៣៥ឆ្នាំ គង់នៅវត្តនិគ្រោធវ័នគល់ទទឹង ។

ញោមប្រុសឈ្មោះ គង់-តិក( ស្លាប់ ) ញោមស្រីឈ្មោះ ហុក-តាង

កើតថ្ងៃព្រហស្បតិ៍៩កើត ខែមិគសិរ ឆ្នាំថោះ ព.ស.២៥១៩ ។ មានបងប្អូន ៧ នាក់ គឺប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ ។ ក្នុងកុមារបានចូលរៀនសាលារដ្ឋ ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡយលឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។ ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទា ជាភិក្ខុភាវៈ ។

ព.ស. ២៥៤០ មកគង់នៅវត្តនិគ្រោធវ័ន រៀនធម៌វិន័យ ។ ព.ស. ២៥៤១ ចេញទៅគង់នៅវត្តខេមវ័ន( ខេត្តកំពង់ចាម ) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌វិន័យ ។

ព.ស. ២៥៤៦ បួសជាសាមណេរវិញ ឧបជ្ឈាយ៍ព្រះនាម យឹ ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុក គៀនស្វាយ ខេត្តកណ្តាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។

ព.ស. ២៥៤៧ បំពេញជាភិក្ខុភាវៈ បានជួយបង្រៀននិងខិតខំរៀបចំអដ្ឋកថា និងសៀវភៅធម៌វិន័យជាច្រើនទៀត រហូតមក ។

# ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ

ព្រះសម្ពុទ្ធជាម្ចាស់ដ៏មានជោគ ទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតក្រុងវេរញ្ជា ជាមួយនឹងភិក្ខុសង្ឃមានប្រមាណច្រើនចំនួន ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍បានចូលទៅលើកពាក្យចោទប្រកាន់ ចំពោះព្រះដ៏មានព្រះភាគ មានពាក្យជាដើមថា "ព្រះគោតមមិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់គ្រាំគ្រាជាព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឱ្យអង្គុយលើអាសនៈ(ក៏ព្រះអង្គមិនធ្វើ)" ព្រះដ៏មានព្រះភាគទ្រង់ញ៉ាំងព្រាហ្មណ៍នោះ ឱ្យជ្រះថ្លាហើយ និងប្រកាសខ្លួនជាឧបាសក ដល់ព្រះត្រ័យសរណគមន៍ស្មើដោយជីវិត រួចក៏អារាធនាឱ្យទ្រង់ចាំវស្សាជិតស្រុកវេរញ្ជានោះមួយអន្លើដោយភិក្ខុសង្ឃ ។

ក្នុងវស្សានោះ ស្រុកវេរញ្ជាកើតអំណត់អត់បាយ ព្រះដ៏មានព្រះភាគ និងព្រះភិក្ខុសង្ឃឆាន់បាយក្រៀមរបស់ពួកឈ្មួញសេះ ។ ព្រះមហាមោគ្គល្លានទូលសូមសម្តែងឫទ្ធិប្រែត្រឡប់ផែនដី ដើម្បី បានឱជារសដែលកើតឡើងអំពីស្រទាប់នៃផែនដី និងទូលសូមនាំភិក្ខុទៅបិណ្ឌបាត

ឯឧត្តរកុរុទ្វីប, តែព្រះដ៏មានព្រះភាគទ្រង់មិនអនុញ្ញាត ។ ចំណែកព្រះសារីបុត្រ ក៏ក្រាបទូលសួរអំពីសាសនារបស់ព្រះពុទ្ធទាំងឡាយ ដែលឋិតនៅមិនបានយូរ និងដែលឋិតនៅបានយូរ, ព្រះដ៏មានព្រះភាគក៏ទ្រង់សម្តែងសាសនារបស់ព្រះពុទ្ធទាំង ៦ ព្រះអង្គមានព្រះពុទ្ធព្រះនាមវិបស្សីជាដើម ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ ក្រោកចាកអាសនៈហើយ ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះដ៏មានព្រះភាគ ហើយក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ៗ គួរបញ្ញត្តិសិក្ខាបទ គួរសម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ព្រោះកិច្ចដូច្នេះហើយ ជាហេតុនឹងឱ្យព្រហ្មចរិយធម៌ឋិតនៅអស់កាលអង្វែងទៅ" ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន ម្នាលសារីបុត្ត អ្នកចូរបង្អង់សិន តថាគតឯងសឹងដឹងកាលគួរក្នុងកិច្ចដែលនឹងបញ្ញត្តសិក្ខាបទជាដើមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្តាក៏មិនទាន់បញ្ញត្តសិក្ខាបទ មិនទាន់សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយត្រឹមនោះ ម្នាលសារីបុត្ត ក៏ធម៌ទាំងឡាយខ្លះ ដែលជាទី

តាំងនៃអាសវៈ មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលណា ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយក្នុងកាលនោះ ដើម្បីនឹងការពារពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងនោះប៉ុណ្ណោះ ម្នាលសារីបុត្ត សង្ឃនៅមិនទាន់មានភិក្ខុបួសចាស់វស្សាច្រើនគ្នាត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមនោះ ម្នាលសារីបុត្តម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើនមានភិក្ខុបួសចាស់វស្សាច្រើនគ្នា ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នឹងមានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាំងនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់បាននូវសេចក្ដីចម្រើនមានគ្នាច្រើនត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃក្នុងសាសនានេះ ត្រឹមនោះ ម្នាលសារីបុត្ត ម្យ៉ាងទៀត សង្ឃបានដល់នូវសេចក្ដីចម្រើនមានគ្នាច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងសាសនានេះក្នុងកាលនោះ ទើបព្រះសាស្ដាបញ្ញត្តសិក្ខាបទ សម្ដែងអាណាបាតិមោក្ខដល់សាវកទាំងឡាយ ដើម្បីការពារពាំងនូវធម៌ទាំងឡាយ

ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះក្នុងកាលនោះឯង ម្នាលសារីបុត្ត សង្ឃមិនទាន់ដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏នៅមិនទាន់មានប្រាកដចំពោះសង្ឃត្រឹមនោះ ម្នាលសារីបុត្ត លុះសង្ឃបានដល់នូវសេចក្តីចម្រើនដោយលាភសក្ការៈដ៏ប្រសើរក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃក្នុងកាលនោះដែរ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ សម្តែងអាណាបាតិមោក្ខដល់សាវកទាំងឡាយដើម្បីការពារពាំងនូវធម៌ដែលជាទីតាំងនៃអាសវៈទាំងអម្បាលនោះ ក្នុងកាលនោះឯង ម្នាលសារីបុត្ត ពីព្រោះ(ឥឡូវ)ភិក្ខុសង្ឃនៅមិនទាន់មានពុត(ហ៊ានលបលួចធ្វើអាក្រក់)នៅឡើយ មិនទាន់មានទោសមោះមៃនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង ស្ទុស្ទឹងតែផូរផង់ផ្ចង់ចិត្តឋិតនៅក្នុងធម៌មានខ្លឹមនៅឡើយ ម្នាលសារីបុត្ត ក៏បណ្តាភិក្ខុទាំង ៥០០ រូបនេះ ភិក្ខុដែលមានមគ្គផលយ៉ាងទាបចុងគេបំផុតនោះ ក៏គង់បានសម្រេចត្រឹមថ្នាក់សោតៈ ជាបុគ្គលទៀងទាត់ លែងធ្លាក់ទៅក្នុងអបាយភូមិហើយ នឹងបានត្រាស់ដឹងមគ្គផលត ៗទៅទៀតជាប្រាកដ" ។

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ចប់

# ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ

## ឃោសកុមារកើតឡើង និងការសិក្សាត្រៃវេទ

រាប់អំពីកាលនៃការបរិនិព្វានរបស់ព្រះមានព្រះភាគ កន្លងទៅហើយបាន ៩៥៦ ព្រះវស្សា ។ ព្រះរាជាមួយព្រះអង្គទ្រង់ព្រះនាមថា មហានាម បានគ្រងរាជ្យសម្បត្តិ ប្រកបដោយទសពិធរាជធម៌ក្នុងលង្កាទ្វីប ។ បានឮថា ក្នុងសម័យនោះឯង មានព្រាហ្មណ៍ មាណពម្នាក់ កើតនៅក្នុងត្រកូលព្រាហ្មណ៍មួយ បិតាឈ្មោះ **កេសី** ជារាជបុរោហិត មាតាឈ្មោះ **កេសិនី** មានលំនៅស្ថិតនៅក្នុងទីជិតនៃពោធិមណ្ឌល (កន្លែងត្រាស់ដឹងរបស់ព្រះសម្ពុទ្ធ) ក្នុងមជ្ឈិមប្រទេសជម្ពូទ្វីប ។

ក៏ព្រោះក្នុងវេលាដែលមាណពនោះប្រសូតមក ពួកបរិវាររបស់ព្រាហ្មណ៍ មានទាសនិងកម្មករជាដើម បញ្ចេញសំឡេង សម្ដែងភាពត្រេកអររីករាយយ៉ាងគឹកកង ដូច្នោះ ទើបគេដាក់ឈ្មោះឱ្យកុមារនោះថា **ឃោសៈ** ។ ទីខ្លះក៏ពោលថា មាណពនោះ កើតនៅក្នុងឃោសគ្រាម ទើបដាក់ឈ្មោះឱ្យថា ឃោសៈ ។ ឃោសៈមាណពនោះ ជាអ្នកដឹងវិជ្ជានិងក្បួនសិល្បៈទាំងពួងយ៉ាងជំនាញ ចេះចប់ត្រៃវេទយ៉ាងប្រាកដក្នុងលទ្ធិ បានត្រាច់ទៅដើម្បីសាកសួរ និងដោះស្រាយបញ្ហាវិជ្ជាសិល្បៈ ក្នុងស្រុកនិគមជនបទ រាជធានីទាំងឡាយ ក្នុងជម្ពូទ្វីប ។

ដឹងថា មានសមណព្រាហ្មណ៍ ដែលជាបណ្ឌិតនៅក្នុងទីណា ៗ ក៏ចូលទៅធ្វើការសាកប្ញាក្នុងទីនោះ ៗ បណ្ឌិតដទៃ (នោះ) ៗ មិនអាចឆ្លើយនូវបញ្ហាដែលមាណពនោះ សួរបានឡើយ តែមាណពនោះ អាចឆ្លើយនូវបញ្ហារបស់បណ្ឌិតទាំងនោះ ៗ ដែលសួរហើយបាន ។

## ឃោសមាណពជួបនឹងព្រះរេវតត្ថេរ

មាណពនោះ ត្រាច់សន្ធត់ពេញ ទូទាំងជម្ពូទ្វីបដោយអាការយ៉ាងនេះ រហូតមកដល់វត្តមួយ (ក៏បានស្នាក់នៅក្នុងបរិវេណវត្តនោះ) ។ ក៏ក្នុងវត្តនោះ មានភិក្ខុនៅច្រើនរូប ព្រះរេវតៈ(ឬធម្មឃោសៈ) ជាសង្ឃត្ថេររបស់ភិក្ខុទាំងនោះ ជាព្រះមហាខីណាស្រពបានសម្រេចបដិសម្ភិទា អាចញាំញីបរប្បវាទបាន ។ គ្រានោះ កាលវេលាអាធ្រាត្រ ព្រាហ្មណ៍មាណព បានបរិវត្តបាតញ្ជលី (ស្វាធ្យាយ) នូវមន្តឱ្យមានបទបរិបូណ៌ និងឱ្យជាបរិមណ្ឌល ព្រះថេរៈស្តាប់នូវសំឡេងព្រាហ្មណ៍ស្វាធ្យាយមន្ត ក៏ជ្រាបថា "ព្រាហ្មណ៍នេះជាអ្នកមានបញ្ញាច្រើន" (រួចទើប) គិតថា "បើយើងទូន្មានឱ្យមករាប់អានព្រះពុទ្ធសាសនាបាន នឹងជាការល្អ" ទើបហៅព្រាហ្មណ៍នោះមក រួចសួរថា "ម្នាលព្រាហ្មណ៍ អ្នកណាហ្នឹ៎ស្រែកជាសំឡេងដូចលា" ។ ឃោសៈព្រាហ្មណ៍នោះសួរថា "នែបព្វជិតដ៏ចម្រើន លោកដឹងនូវសំឡេងរបស់ពួកលាឬ ?" ព្រះថេរៈតបថា "យើង

ដឹង” ។ ព្រាហ្មណ៍នោះ ទើបសួរព្រះថេរៈក្នុងគណ្ឋិដ្ឋាន (គឺមន្តដែលយល់បាន លំបាក) ទាំងឡាយក្នុងគម្ពីរត្រៃវេទ ទាំងគម្ពីរឥតិហាសជាគម្ពីរ ទី៥ ដែលខ្លួនឯងសម្លឹងមិនឃើញន័យឡើយ ទាំងអាចារ្យរបស់ខ្លួន ក៏មិនឃើញមកហើយផង ដែលព្រះថេរៈនោះ ដោយប្រក្រតីក៏ជាអ្នកចេះចប់ត្រៃវេទហើយ មកដល់ឥឡូវនេះ ជាអ្នកបានសម្រេចនូវបដិសម្ភិទាទៀត ព្រោះហេតុនោះ សេចក្តីលំបាកក្នុងការឆ្លើយនូវបញ្ហាទាំងនោះ ទើបមិនមានដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈឆ្លើយនូវបញ្ហាទាំងនោះបានភ្លាម ។ ហើយពោលនឹងព្រាហ្មណ៍នោះថា “នែព្រាហ្មណ៍ដ៏ចំរើន អ្នកសាកសួរយើងមកច្រើនហើយ ឥឡូវនេះ យើងនឹងសាកសួរនូវបញ្ហាកម្មនឹងអ្នកមួយ អ្នកនឹងឆ្លើយបញ្ហារបស់យើងបានឬទេ ?” ព្រាហ្មណ៍តបថា “ខ្ញុំនឹងឆ្លើយមន្តនោះប្រគេនបាន លោកម្ចាស់ចូរសួរមកចុះ” ទើបព្រះថេរៈសួរនូវបញ្ហាក្នុងគម្ពីរអភិធម្ម ចិត្តយមកៈ[១]នេះថា “**យស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ តស្ស ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ យស្ស វា បន ចិត្តំ និរុជ្ឈិស្សតិ ន ឧប្បជ្ជិស្សតិ តស្ស ចិត្តំ ឧប្បជ្ជតិ ន និរុជ្ឈតិ**, : ចិត្តរបស់បុគ្គលណា រមែងកើតឡើង រមែងមិនរលត់ ចិត្តរបស់បុគ្គលនោះ នឹងរលត់ នឹងមិនកើតឡើង ឬក៏ចិត្តរបស់បុគ្គលណា នឹងរលត់ នឹងមិនកើត

---

១. អភិ. យម. យមកវគ្គ. ៩១. ១/១ ។

ឡើង ចិត្តរបស់បុគ្គលនោះ រមែងកើតឡើង រមែងមិនរលត់"[១] ។

ព្រាហ្មណមាណពនោះ មិនអាចនឹងឆ្លើយបាន មិនថា លើ ឬក្រោម ទើបសួរថា "បពិត្រលោកម្ចាស់ដ៏ចំរើន មន្តនេះឈ្មោះមន្តអ្វី ?" ព្រះថេរៈតបថា "ម្នាលព្រាហ្មណ៍ មន្តនេះ ឈ្មោះថា ពុទ្ធមន្ត" ។ ព្រាហ្មណ៍សួរថា "លោកម្ចាស់ដ៏ចម្រើន ឱ្យមន្តនេះដល់ខ្ញុំព្រះករុណាបានដែរឬទេ ?" ព្រះថេរៈតបថា "ម្នាលព្រាហ្មណ៍ យើងឱ្យ (មន្តនេះ) ដល់អ្នកបាន លុះត្រាតែអ្នកបួសជាបព្វជិតដូចយើង" ។

## មាណពបួស ប្រាកដឈ្មោះ ព្រះពុទ្ធឃោសៈ

ឃោសៈព្រាហ្មណ៍ដែលបុព្វហេតុ (គឺកុសលក្នុងកាលមុន) ទាំងឡាយជាស់តឿនហើយ ទើបសូមបព្វជ្ជា ដើម្បីត្រូវការមន្ត ព្រះថេរៈទើឱ្យព្រាហ្មណ៍បព្វជ្ជាឧបសម្បទាហើយ ឱ្យរៀនព្រះត្រៃបិដកពុទ្ធវចនៈ ភិក្ខុនោះ ក៏យល់ដឹងអត្ថធម៌របស់ព្រះត្រៃបិដកថា "នេះជាឯកាយមគ្គ (ដំណើរផ្លូវដ៏ឯក ប្រសើរជាផលទិចាស់របស់ខ្លួន)" (តមក) ក៏បានជាអ្នកប្រាកដច្បាស់ក្នុងលោក ដូច

---

១. ពាក្យថា *រមែងកើតឡើង* គឺនៅក្នុងឧប្បាទខណៈ, ពាក្យថា *រមែងមិនរលត់* គឺមិនទាន់ដល់និរោធឬភង្គខណៈ ។ ចិត្តក្នុងទីនេះ សំដៅដល់បច្ឆិមចិត្ត គឺចុតិចិត្ត របស់ព្រះអរហន្ត ខណៈចិត្តរបស់ព្រះអរហន្តកំពុងប្រព្រឹត្តទៅ ឈ្មោះថា រមែងកើតឡើង រមែងមិនរលត់ កាលដល់ភង្គខណៈហើយ ចុតិចិត្តនោះ ក៏នឹងរលត់ និងមិនមានចិត្តដទៃកើតឡើងតទៅទៀត ។

ពន្លឺភ្លើង ដូចពន្លឺព្រះចន្ទ ដូចពន្លឺព្រះអាទិត្យ ដោយការដែលលោកបានព្យាករណ៍ពោលឆ្លើយបញ្ហាព្រះធម៌ដ៏ជ្រាលជ្រៅដល់ជនទាំងឡាយ ដូចជាពុទ្ធព្យាករណ៍, ភិក្ខុឃោសៈ ទើបបានប្រាកដនាមថា "ព្រះពុទ្ធឃោសៈ" ព្រោះល្បីផ្សាយទៅក្នុងផ្ទៃផែនដីដូចព្រះពុទ្ធអង្គ ។

## ព្រះថេរៈបញ្ជូនឱ្យទៅប្រែគម្ពីរអដ្ឋកថា

ព្រះពុទ្ធឃោសៈនោះ ជាអ្នកនៅក្នុងវិហារនោះ បានតែងបករណ៍ឈ្មោះញាណោទ័យទុកក្នុងវិហារហើយ ផ្ដើមតែងអដ្ឋកថា ព្រះអភិធម្មសង្គណី និងអដ្ឋកថាច្បាប់ឈ្មោះអដ្ឋសាលិនី ព្រះថេរៈឃើញដូច្នោះទើបប្រាប់ថា "ម្នាលអាវុសោពុទ្ធឃោសៈ ក្នុងជម្ពូទ្វីបនេះ មានតែគម្ពីរព្រះត្រៃបិដកបាលីប៉ុណ្ណោះ អដ្ឋកថារបស់ព្រះត្រៃបិដកនោះ និងថេរវាទ (គឺពាក្យដែលព្រះថេរៈក្នុងសម័យសង្គីតិ ពោលទុកជាច្បាប់) មិនមាន តែអដ្ឋកថាព្រះត្រៃបិដកដែលឡើងកាន់សង្គីតិទាំង៣លើក ជាពាក្យដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងទុក និងព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមចងក្រងទុកហើយ ឯព្រះមហិន្ទត្ថេរត្រួតមើលកថាមគ្គ (សម្ដែងផ្លូវនៃពាក្យដែលពោលទុក)ហើយ (រួបរួមមក) តែងទុកដោយភាសាសីហឡៈ កំពុងប្រព្រឹត្តទៅនៅក្នុងសីហឡទ្វីប ចូរលោកទៅកាន់សីហឡទ្វីបនោះ ត្រួតមើលឱ្យសព្វអន្លើហើយ បកប្រែមកជាភាសាមគធ

បាន អដ្ឋកថានោះ នឹងនាំមកនូវប្រយោជន៍សុខដល់មនុស្សលោកទាំងពួង" ។

កាលព្រះថេរណែនាំយ៉ាងនោះ ព្រះពុទ្ធឃោសៈ ជាអ្នកមានបញ្ញាច្រើន ក៏កើតបីតិសោមនស្ស ក្រាបទូលលាព្រះឧបជ្ឈាយ៍ និងភិក្ខុសង្ឃ បានធ្វើដំណើរទៅកាន់កំពង់ទឹកដោយលំដាប់ឡើង ទូកទៅជួបព្រះពុទ្ធទត្តត្ថេរតាមផ្លូវដែលមកដល់កណ្តាលសមុទ្រ ក៏បាននិយាយប្រាស្រ័យគ្នា ហើយធ្វើដំណើរបន្តទៅដរាបដល់កំពុង ក្រុងលង្កា ក្នុងកាលនោះ ព្រះបាទមហានាម គ្រប់គ្រងរាជ្យក្នុងលង្កាទ្វីប ។

## តែងបករណ៍ ឈ្មោះវិសុទ្ធិមគ្គ

ព្រះពុទ្ធឃោសៈ និមន្តទៅជួបព្រះសង្ឃក្នុងវិហារ ក្រុងអនុរាធបុរី ហើយទើបទៅកាន់សំណាក់ព្រះសង្ឃបាលត្ថេរ ដែលគង់នៅក្នុងមហាបធានឃរៈ បានស្តាប់(ជ្រាបសេចក្តី) អដ្ឋកថាភាសាសីហឡៈ និងថេរវាទទាំងពួងហើយ ជឿទុកចិត្តថា "នេះឯងជាព្រះពុទ្ធាធិប្បាយរបស់ព្រះធម្មសាមិត្រពិត" ទើបទៅកាន់ទីប្រជុំសង្ឃ ក្នុងវិហារនោះ ដើម្បីសូមគម្ពីរធ្វើអដ្ឋកថាព្រះត្រៃបិដក ក៏បានពោលសូមថា "សូមលោកម្ចាស់ទាំងឡាយ មេត្តាឱ្យសៀវភៅគម្ពីរទាំងឡាយដល់ខ្ញុំព្រះករុណាដើម្បីធ្វើអដ្ឋកថា" ។ ដើម្បីសាកល្បង សមត្ថភាពរបស់

លោក ទើបភិក្ខុសង្ឃឱ្យគាថា ២ បទ ហើយពោលថា "លោកចូរសម្ដែងសមត្ថភាពក្នុងគាថា ២ បទនេះ យើងទាំងឡាយ បានឃើញសមត្ថភាពរបស់លោកហើយ នឹងប្រគល់ ច្បាប់គម្ពីរឱ្យទាំងអស់" ព្រះពុទ្ធឃោសមើលបាលីព្រះត្រៃបិដក និងអដ្ឋកថារបស់ព្រះត្រៃបិដកនោះហើយ ទើបព្រះថេរៈរួបរួមព្រះត្រៃបិដកព្រមទាំងអដ្ឋកថាដោយសង្ខេប តែងបករណ៍ ឈ្មោះ វិសុទ្ធិមគ្គឡើង ក្នុងមហាវិហារនេះឯង ។

គ្រានោះ ទេវតា[១]មានបំណង ដើម្បីនឹងប្រកាសថ្វីដៃរបស់លោកឱ្យប្រាកដ ក្នុងមហាជន ទើបបណ្ដាលឱ្យសៀវភៅគម្ពីរច្បាប់ (ដែលលោកសរសេររួចហើយ) ឱ្យអន្តរធានបាត់ទៅ ទើបលោកសរសេរឡើងថ្មីមួយច្បាប់ទៀត ទេវតាក៏បណ្ដាលឱ្យអន្តរធានបាត់ទៅទៀត ទើបលោកសរសេរឡើងថ្មីលើកទី ៣ ទៀត ក៏បាន ចប់សព្វគ្រប់ទៀត ក្នុងគ្រានោះ ព្រះពុទ្ធឃោសៈនិមន្តព្រះសង្ឃ ដែលជាអ្នកឆ្លាសក្នុងធម៌របស់ព្រះសម្ពុទ្ធឱ្យមកប្រជុំគ្នា ក្នុងទីជិតមហាពោធិព្រឹក្ស (ប្រទេសលង្កា) ប្រារព្ធនឹងអានបករណ៍វិសុទ្ធិមគ្គនោះ (ឱ្យសង្ឃស្ដាប់) ស្រាប់តែទេវតាដែលបំបាំងសៀវភៅនោះ នាំសៀវភៅទាំងពីរចប់នោះ មកប្រគេនសងវិញព្រមក្នុងខណៈនោះ ទើបបានជាសៀវភៅវិសុទ្ធិមគ្គ

---
១. ខ្លះថា ព្រះសង្ឃ ។

បីចប់ឡើង ក៏បានប្រគល់សៀវភៅទាំងបីចប់ ទៅព្រះភិក្ខុសង្ឃ, ភិក្ខុសង្ឃឱ្យអានសៀវភៅទាំងបីចប់ ព្រមគ្នា ការខុសគ្នាំងភ្លាត់បីចប់នោះ ដោយគណ្ឋៈក្តី ដោយអក្ខរៈក្តី ដោយបទក្តី ដោយព្យញ្ជនៈក្តី ដោយអត្ថក្តី ដោយការសរសេរមុន ក្រោយក្តី ដោយវាទៈទាំងឡាយមានថេរវាទជាដើមក្តី ដោយព្រះបាលីទាំងឡាយក្តី មិនមានឡើយ បានឮថា កាលគម្ពីរវិសុទ្ធិមគ្គ ទាំង ៣ ដែលព្រះពុទ្ធឃោសៈធ្វើរួចស្រេចហើយយ៉ាងនោះ ទេវតាទាំងឡាយ បាននាំគ្នាធ្វើសាធុការ សម័យនោះភិក្ខុច្រើនពាន់ប្រជុំ គ្នានៅក្នុងវិហារ ឃើញការអស្ចារ្យនោះហើយ ក៏នាំគ្នាសរសើរឱ្យសាធុការ ប្រកាសប្រាប់គ្នាសុសសាយទៅថា "នេះព្រះពោធិសត្វ មេត្រីមកកើត ដោយឥតសង្ស័យ"[១] ។

## បកប្រែអដ្ឋកថាព្រះត្រៃបិដក មកជាភាសាមគធៈ

ចំណែកស្តេចផែនដី ទ្រង់បានស្តាប់ដំណឹងនោះ ក៏ស្តេចចេញពីព្រះនគរព្រមទាំងរាជបរិវារទៅកាន់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយ ទ្រង់នមស្ការព្រះពុទ្ធឃោសៈ និមន្តឱ្យទទួលនូវចង្ហាន់នៅក្នុងរាជវាំងជាប្រចាំរហូតដល់ការតែងគម្ពីរចប់ ព្រះថេរៈ ទទួលនិមន្តដោយតុណ្ហីភាព ។

ព្រះភិក្ខុសង្ឃឃើញសមត្ថភាពរបស់ព្រះថេរៈហើយ ទើបប្រគល់សៀវភៅ

១. នេះជាការឃើញអស្ចារ្យរបស់ភិក្ខុទាំងឡាយទេ មិនប្រាកដជាព្រះមេត្រីឡើយ ។

ព្រះត្រៃបិដកបាលី ព្រមទាំងសៀវភៅអដ្ឋកថាសីហឡៈឱ្យដល់ព្រះថេរៈ, ព្រះថេរៈទទួលសៀវភៅគម្ពីរទាំងអស់ទៅទុកក្នុងប្រាសាទ ឈ្មោះថា បធានឃរៈ ដែលតាំងនៅខាងត្បូងនៃមហាវិហារ ប្រែអដ្ឋកថាទាំងអស់ធ្វើជាអដ្ឋកថាព្រះត្រៃបិដកក្នុងភាសាមគធ ដែលជាមូលភាសា (គឺភាសាដើម) ។

ក៏អដ្ឋកថាសីហឡៈនោះ មាន ៣ ភាគ គឺ មហាអដ្ឋកថា ១ បច្ចរិយអដ្ឋកថា ១ កុរុន្ទីអដ្ឋកថា ១ ។

អដ្ឋកថាដែលឡើងកាន់មហាសង្គីតិ ព្រះមហិន្ទត្ថេរនាំមកតែងទុកក្នុងភាសាសីហឡៈ ឈ្មោះថា **មហាអដ្ឋកថា** ។

មានផ្ទះផែមួយខ្នង មានឈ្មោះហៅក្នុងភាសាសីហឡៈថា បច្ចរិយៈ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងផ្ទះផែនោះ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

មានវិហារមួយកន្លែង ឈ្មោះកុរុន្ទីវិហារ ។ អដ្ឋកថាដែលភិក្ខុទាំងនោះប្រជុំគ្នាធ្វើក្នុងវិហារនោះ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទដែលព្រះថេរៈជំនាន់មុនមានព្រះថេរិកាចារ្យ (អាចារ្យធំ) ជាដើមកាន់យកន័យព្រះបាលីតែងទុក ឈ្មោះថា **ថេរវាទ** ។

ព្រះពុទ្ធឃោសៈ ប្រែកុរុន្ទីអដ្ឋកថាភាសាសីហឡៈ ធ្វើអដ្ឋកថាព្រះវិន័យបិដក ឈ្មោះសមន្តបាសាទិកា ក្នុងភាសាមគធៈហើយ តពីនោះក្នុងសុត្តន្តបិដក បកប្រែមហាអដ្ឋកថាអំពីភាសាសីហឡៈ តាំងជាអដ្ឋកថាទីឃនិកាយ

ឈ្មោះសុមង្គលវិលាសិនី, ជាអដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី, ជាអដ្ឋកថាសំយុត្តនិកាយ ឈ្មោះ សារត្ថបកាសិនី, និងជាអដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី, តពីនោះ ក្នុងអភិធម្មបិដក បកប្រែបច្ចរិយអដ្ឋកថាអំពីភាសាសីហឡ: តាំងជាអដ្ឋកថាបករណ៍ធម្មសង្គណី ឈ្មោះអដ្ឋសាលិនីក្នុងភាសាមគធ: ជាអដ្ឋកថាបករណ៍វិភង្គ ឈ្មោះសម្មោហវិនោទនី និងជាអដ្ឋកថា ៥ បករណ៍ ឈ្មោះបរមត្ថទីបនី ។

ព្រះពុទ្ឋឃោសៈ ធ្វើអដ្ឋកថាសីហឡៈទាំងអស់ឱ្យជាអដ្ឋកថា ព្រះត្រៃបិដក ក្នុងភាសាមគធៈ ដែលជាមូលភាសាដូចពោលមកហើយដូច្នោះ អដ្ឋកថានោះឯង បាននាំមកនូវប្រយោជន៍សុខដល់ពពួកជន ក្នុងប្រទេសដទៃ ៗទាំងពួងយ៉ាងច្រើនសន្ធឹកសន្ធាប់ហើយ រស់នៅរហូតដល់អស់អាយុ ទើបទៅកាន់ទេវលោកនោះឯង ។

កាលដែលបានបកប្រែអដ្ឋកថាព្រះត្រៃបិដក ចប់សព្វគ្រប់ហើយ ផែនដីក៏កក្រើកញ័រ (ជាអស្ចារ្យ) អដ្ឋកថាព្រះត្រៃបិដក ដែលព្រះថេរៈ ធ្វើដូចពោលមកនេះ គឺបកប្រែចប់សព្វ គ្រប់ តែក្នុងរយៈកាល ១ ឆ្នាំប៉ុណ្ណោះ ។

លុះបកប្រែរួចហើយ ព្រះពុទ្ឋឃោសៈ ប្រាថ្នាដើម្បីនឹងបាន មកថ្វាយបង្គំព្រះមហាពោធិព្រឹក្ស ទើបក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ត្រឡប់មកជម្ពូទ្វីបវិញ ។

*ព្រះរាជាមហានាម ទ្រង់គ្រងផែនដីអស់ ១២ ឆ្នាំ ទ្រង់ធ្វើបុណ្យច្រើនយ៉ាង ដោយប្រការផ្សេង ៗហើយ ស្តេចក៏ទៅកាន់បរលោកតាមយថាកម្ម ។ ចំណែកព្រះពុទ្ធឃោសត្ថេរនោះ បានរចនាអដ្ឋកថានៃព្រះត្រៃបិដកទុក បានសាងប្រយោជន៍ដ៏សមគួរដល់សត្វលោកជាច្រើន តាំងនៅរហូតគ្រប់អាយុខ័យ ក៏បានទៅកាន់ឋានតាវត្តិង្សហើយ ដូច្នេះឯង ។*

## សេចក្តីប្រាថ្នារបស់ព្រះពុទ្ធឃោសត្ថេរ

យំ សិទ្ធំ ឥមិនា បុញ្ញំ    យំ ចញ្ញំ បសុតំ មយា
ឯតេន បុញ្ញកម្មេន    ទុតិយេ អត្តសម្ភវេ
តាវតឹសេ បមោទេន្តោ    សីលាចារគុណេ រតោ
អលគ្គោ បញ្ចកាមេសុ    បត្វា បឋមំ ផលំ
អន្តិមេ អត្តភាវម្ហិ    មេត្តេយ្យំ មុនិបុង្គវំ
លោកគ្គបុគ្គលំ នាថំ    សព្វសត្តហិតេ រតំ
ទិស្វាន តស្ស ធីរស្ស    សុត្វា សទ្ធម្មទេសនំ
អធិគន្ត្វា ផលំ អគ្គំ    សោភេយ្យំ ជិនសាសនន្តិ ។

បុណ្យណា ដែលសម្រេចហើយដោយការធ្វើនេះ និងបុណ្យដទៃណា ដែលខ្ញុំបានខ្វល់ខ្វាយទុក ដោយអំណាចនៃបុណ្យនោះ ក្នុងអត្តភាពទី២ សូមឱ្យខ្ញុំរីករាយក្នុងឋានតាវត្តិង្ស ត្រេកអរក្នុងគុណគឺសីលនិងអាចារៈ មិនជាប់ជំពាក់ក្នុងកាមគុណទាំង ៥ បានសម្រេចអរិយផលទី ១ (សោតាបត្តិផល) ក្នុងអត្តភាពចុងបំផុត សូមឱ្យខ្ញុំបានជួបព្រះអារ្យមេត្រី ព្រះមុនីដ៏ប្រសើរ ជាបុគ្គលចម្បងក្នុងលោក ជាព្រះលោកនាថ ទ្រង់ពេញព្រះទ័យក្នុងការជួយសត្វលោកទាំងពួង សូមឱ្យខ្ញុំបានស្តាប់ព្រះសទ្ធម្មរបស់ព្រះមុនីអង្គនោះ ដែលទ្រង់ជាអ្នកប្រាជ្ញា ហើយបានសម្រេចអរិយផលជាន់ខ្ពស់ (អរហត្តផល) ញុំាំងព្រះសាសនារបស់ព្រះជិនស្រីឱ្យល្អស្អាត ដោយប្រការដូច្នេះហោង ។

ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ចប់

## ឧប្បត្តិកថា

សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ ជាស្នាដៃរបស់ព្រះពុទ្ធឃោសាចារ្យ

ប្រទេសខ្មែរយើងនេះ មានគម្ពីរព្រះត្រៃបិដកចប់សព្វគ្រប់ ដែលក្រុមជំនុំ បានរៀបចំឡើងជាភាសាបាលីផង ភាសាខ្មែរផង ខ្ញុំមានចិត្តសោមនស្សរីករាយ ហើយក៏រៀបចំប្រែអដ្ឋកថាព្រះវិន័យនេះ ឱ្យមកជាភាសាខ្មែរផង ដើម្បីបានការយល់ដឹងក្នុងផ្នែកព្រះវិន័យរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរយើង ដែលកំពុង តែប្រឹងប្រែងសិក្សាព្រះវិន័យ ។

ខ្ញុំបានសសេរពាក្យបញ្ចូលថែម, គឺ ពាក្យខ្លះយកអំពីបិដក តាមដែល អដ្ឋកថាចង្អុលប្រាប់ផង មិនប្រាប់ផង ដោយមានលេខយោងបញ្ជាក់, ពាក្យខ្លះ មិនមានក្នុងបាលីអដ្ឋកថាទេ ថែមដោយបំណងដើម្បីបញ្ជាក់សេចក្ដីប៉ុណ្ណោះ, ម្យ៉ាងទៀត បានដាក់លេខឃ្នាបតាមបិដក ដើម្បីងាយដឹងថា នេះជាសេចក្ដីពន្យល់ ក្នុងបិដកត្រង់លេខឃ្នាបនេះ ។ តែដោយសមត្ថភាពរបស់ខ្ញុំព្រមទាំងក្រុមប្រឹក្សា តិចតួច សៀវភៅនេះក៏នៅមានសេចក្ដី និងអក្ខរៈ ខុសភ្លាំងភ្លាត់នៅឡើយ ដោយអចេតនា សូមមេត្តាជួយសម្រួលដោយអនុគ្រោះផងចុះ ។

បុណ្យដែលកើតអំពីការព្យាយាមសាងសៀវភៅនេះ សូមចែកដល់អ្នកសិក្សាទាំងឡាយផង ។ សូមអ្នកសិក្សាទាំងឡាយ ទទួលអនុមោទនាត្រេកអរនូវបុណ្យនេះ ដោយមហាកុសលសោមនស្សរីករាយ ដែលប្រកបដោយបញ្ញា ឱ្យបានគ្រប់ ៗគ្នា សូមអនុមោទនា !!! ។

សូមឱ្យកុលបុត្រខ្មែរ ខិតខំសិក្សាព្រះធម៌វិន័យ ឱ្យកើតបញ្ញាយល់ដឹង ហើយទ្រទ្រង់សិក្ខាឱ្យបានមាំមួន ឱ្យបានតាំងនៅក្នុងភាពជាអ្នកខ្លាសបាប សង្រួម ប្រយ័ត្នដើម្បីកម្ចាត់បង់នូវបាបចេញ លាងជម្រះមន្ទិលសៅហ្មងក្នុងចិត្ត បំពាក់ អលង្ការ គឺព្រះសទ្ធម្ម ធ្វើខ្លួនឱ្យមានគុណតម្លៃ ឱ្យប្រសើរ ឱ្យផុតពីទុក្ខកង្វល់ នាំខ្លួនឱ្យដល់ឋានសុខសាន្ត ។

ខ្ញុំសូមប្រាថ្នាឱ្យមានបញ្ញាទ្រទ្រង់ព្រះធម៌ព្រះវិន័យ សូមឱ្យបានផុតពីក្តី អន្តរាយទាំងពួង និងបានសម្រេចតាមគោលបំណងដ៏ល្អ ជាពិសេសឱ្យបានដល់ ទីបំផុតទុក្ខ គឺ ព្រះនិព្វាន ដោយឆាប់រហ័សហោង ។

# អក្សរសង្ខេប និងអក្សរពេញ

## បិដក

| អក្សរសង្ខេប | អក្សរពេញនៃបិដក | | | ភាគ |
|---|---|---|---|---|
| វិន. បារា. | វិន័យបិដក | ខុទ្ទកនិកាយ | បារាជិក | ភាគ ១ |
| វិន. សង្ឃា. | វិន័យបិដក | ខុទ្ទកនិកាយ | សង្ឃាទិសេស | ភាគ ២ |
| វិន. និស្ស. | វិន័យបិដក | ខុទ្ទកនិកាយ | និស្សគ្គិយ | ភាគ ៣ |
| វិន. បាចិ. | វិន័យបិដក | ខុទ្ទកនិកាយ | បាចិត្តិយ | ភាគ ៤ |
| វិន. ភិក្ខុនី. | វិន័យបិដក | ខុទ្ទកនិកាយ | ភិក្ខុនីវិភង្គ | ភាគ ៥ |
| វិន. មហា. | វិន័យបិដក | ខុទ្ទកនិកាយ | មហាវគ្គ | ភាគ ៦-៨ |
| វិន. ចុល្ល. | វិន័យបិដក | ខុទ្ទកនិកាយ | ចុល្លវគ្គ | ភាគ ៩-១១ |
| វិន. បរិ. | វិន័យបិដក | ខុទ្ទកនិកាយ | បរិវារៈ | ភាគ ១២-១៣ |
| ទីឃ. សីល. | សុត្តន្តបិដក | ទីឃនិកាយ | សីលក្ខន្ធវគ្គ | ភាគ ១៤-១៥ |
| ទីឃ. មហា. | សុត្តន្តបិដក | ទីឃនិកាយ | មហាវគ្គ | ភាគ ១៦-១៧ |
| ទីឃ. បាដិ. | សុត្តន្តបិដក | ទីឃនិកាយ | បាដិកវគ្គ | ភាគ ១៨-១៩ |
| មជ្ឈិ. មូល. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មូលបណ្ណាសក | ភាគ ២០-២២ |
| មជ្ឈិ. មជ្ឈិ. | សុត្តន្តបិដក | មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក | ភាគ ២៣-២៥ |
| មជ្ឈិ. ឧប. | សុត្តន្តបិដក | មជ្ឈិមនិកាយ | ឧបរិបណ្ណាសក | ភាគ ២៦-២៨ |
| សំយុ. សគា. | សុត្តន្តបិដក | សំយុត្តនិកាយ | សគាថវគ្គ | ភាគ ២៩-៣០ |
| សំយុ. និទា. | សុត្តន្តបិដក | សំយុត្តនិកាយ | និទានវគ្គ | ភាគ ៣១-៣២ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| សំយុ. ខន្ធ. | សុត្តន្តបិដក | សំយុត្តនិកាយ | ខន្ធវារវគ្គ | ភាគ ៣៣-៣៤ |
| សំយុ. សឡា. | សុត្តន្តបិដក | សំយុត្តនិកាយ | សឡាយតនវគ្គ | ភាគ ៣៥-៣៦ |
| សំយុ. មហា. | សុត្តន្តបិដក | សំយុត្តនិកាយ | មហាវារវគ្គ | ភាគ ៣៧-៣៩ |
| អង្គុ. ឯក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកនិបាត | ភាគ ៤០ |
| អង្គុ. ទុក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទុកនិបាត | ភាគ ៤០ |
| អង្គុ. តិក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | តិកនិបាត | ភាគ ៤១ |
| អង្គុ. ចតុ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ចតុកនិបាត | ភាគ ៤២-៤៣ |
| អង្គុ. បញ្ច. | សុត្តន្តបិដក | អង្គុត្តរនិកាយ | បញ្ចកនិបាត | ភាគ ៤៤-៤៥ |
| អង្គុ. ឆក្ក. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឆក្កនិបាត | ភាគ ៤៦ |
| អង្គុ. សត្ត. | សុត្តន្តបិដក | អង្គុត្តរនិកាយ | សត្តកនិបាត | ភាគ ៤៧ |
| អង្គុ. អដ្ឋ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | អដ្ឋកនិបាត | ភាគ ៤៨ |
| អង្គុ. នវ. | សុត្តន្តបិដក | អង្គុត្តរនិកាយ | នវកនិបាត | ភាគ ៤៩ |
| អង្គុ. ទស. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ទសកនិបាត | ភាគ ៥០-៥១ |
| អង្គុ. ឯកា. | សុត្តន្តបិដក | អង្គុត្តរនិកាយ | ឯកាទសកនិបាត | ភាគ ៥១ |
| ខុទ្ទ. បាឋ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ខុទ្ទកបាឋ | ភាគ ៥២ |
| ខុទ្ទ. ធម្ម. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ធម្មបទ | ភាគ ៥២ |
| ខុទ្ទ. ឧទា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឧទាន | ភាគ ៥២ |
| ខុទ្ទ. ឥតិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ឥតិវុត្តក | ភាគ ៥៣ |
| ខុទ្ទ. សុត្ត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | សុត្តនិបាត | ភាគ ៥៤ |

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | | ភាគ |
|---|---|---|---|---|
| ខុទ្ទ. វិមា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | វិមានវត្ថុ | ភាគ ៥៥ |
| ខុទ្ទ. បេត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បេតវត្ថុ | ភាគ ៥៦ |
| ខុទ្ទ. ថេរ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរគាថា | ភាគ ៥៦. ៥៧. |
| ខុទ្ទ. ថេរី. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ថេរីគាថា | ភាគ ៥៧ |
| ខុទ្ទ. ជាត. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ជាតក | ភាគ ៥៨-៦៣ |
| ខុទ្ទ. មហា. | សុត្តន្តបិដក | ខុទ្ទកនិកាយ | មហានិទ្ទេស | ភាគ ៦៤-៦៦. |
| ខុទ្ទ. ចូឡ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចូឡនិទ្ទេស | ភាគ ៦៧. ៦៨. |
| ខុទ្ទ. បដិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ | ភាគ ៦៩-៧១. |
| ខុទ្ទ. អប្ប. | សុត្តន្តបិដក | ខុទ្ទកនិកាយ | អប្បទាន | ភាគ ៧២-៧៦ |
| ខុទ្ទ. ពុទ្ធ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ពុទ្ធវង្ស | ភាគ ៧៦ |
| ខុទ្ទ. ចរិ. | សុត្តន្តបិដក | ខុទ្ទកនិកាយ | ចរិយាបិដក | ភាគ ៧៦ |
| អភិ. សង្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធម្មសង្គណី | ភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្មបិដក | ខុទ្ទកនិកាយ | វិភង្គ | ភាគ ៨០-៨២. |
| អភិ. ធាតុ. | អភិធម្មបិដក | ខុទ្ទកនិកាយ | ធាតុកថា | ភាគ ៨៣. |
| អភិ. បុគ្គ. | អភិធម្មបិដក | ខុទ្ទកនិកាយ | បុគ្គលបញ្ញត្តិ | ភាគ ៨៣. |
| អភិ. កថា. | អភិធម្មបិដក | ខុទ្ទកនិកាយ | កថាវត្ថុ | ភាគ ៨៤-៩០ |
| អភិ. យម. | អភិធម្មបិដក | ខុទ្ទកនិកាយ | យមក | ភាគ ៩១-៩៣. |
| អភិ. បដ្ឋា. | អភិធម្មបិដក | ខុទ្ទកនិកាយ | មហាបដ្ឋាន | ភាគ ៩៤-១១០ |

# អដ្ឋកថា

| អក្សរសង្ខេប | អក្សរពេញនៃអដ្ឋកថា | | |
|---|---|---|---|
| សមន្ត. ពាហិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ពាហិរនិទាន |
| សមន្ត. វេរ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | វេរញ្ជកណ្ឌ |
| សមន្ត. បារា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បារាជិកកណ្ឌ |
| សមន្ត. សង្ឃា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | សង្ឃាទិសេស |
| សមន្ត. និស្ស. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | និស្សគ្គិយ |
| សមន្ត. បាចិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បាចិត្តិយ |
| សមន្ត. មហា. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | មហាវគ្គ |
| សមន្ត. ចុល្ល. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | ចុល្លវគ្គ |
| សមន្ត. បរិ. | សមន្តប្បាសាទិកា | អដ្ឋកថានៃវិនយ | បរិវារៈ |
| សុមង្គ. សីល. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | សីលក្ខន្ធវគ្គ |
| សុមង្គ. មហា. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | មហាវគ្គ |
| សុមង្គ. បាដិ. | សុមង្គលវិលាសិនី | អដ្ឋកថានៃទីឃនិកាយ | បាដិកវគ្គ |
| បបញ្ច. មូល. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មូលបណ្ណាសក |
| បបញ្ច. មជ្ឈិ. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសក |
| បបញ្ច. ឧប. | បបញ្ចសូទនី | អដ្ឋកថានៃមជ្ឈិមនិកាយ | ឧបរិបណ្ណាសក |
| សារត្ថ. សគា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សគាថវគ្គ |
| សារត្ថ. និទា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | និទានវគ្គ |
| សារត្ថ. ខន្ធ. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | ខន្ធវារវគ្គ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| | | | |
|---|---|---|---|
| សារត្ថ. សឡា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | សឡាយតនវគ្គ |
| សារត្ថ. មហា. | សារត្ថប្បកាសិនី | អដ្ឋកថានៃសំយុត្តនិកាយ | មហាវារវគ្គ |
| មនោរ. ឯក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកនិបាត |
| មនោរ. ទុក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទុកនិបាត |
| មនោរ. តិក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | តិកនិបាត |
| មនោរ. ចតុ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ចតុកនិបាត |
| មនោរ. បញ្ច. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | បញ្ចកនិបាត |
| មនោរ. ឆក្ក. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឆក្កនិបាត |
| មនោរ. សត្ត. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | សត្តកនិបាត |
| មនោរ. អដ្ឋ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | អដ្ឋកនិបាត |
| មនោរ. នវ. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | នវកនិបាត |
| មនោរ. ទស. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ទសកនិបាត |
| មនោរ. ឯកា. | មនោរថបូរណី | អដ្ឋកថានៃអង្គុត្តរនិកាយ | ឯកាទសកនិបាត |
| បរត្ថ. បាឋ. | បរមត្ថជោតិកាយ | អដ្ឋកថានៃខុទ្ទកនិកាយ | ខុទ្ទកបាឋ |
| អដ្ឋ. ធម្ម. | ធម្មបទដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ធម្មបទគាថា |
| បរត្ថ. ឧទា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឧទាន |
| បរត្ថ. ឥតិ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ឥតិវុត្តក |
| បរត្ថ. សុត្ត. | បរមត្ថជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | សុត្តនិបាត |
| បរត្ថ. វិមា. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | វិមានវត្ថុ |
| បរត្ថ. បេត. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | បេតវត្ថុ |

## អក្សរសង្ខេប អក្សរពេញនៃអដ្ឋកថា

| | | | |
|---|---|---|---|
| បរត្ថ. ថេរ. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរគាថា |
| បរត្ថ. ថេរី. | បរមត្ថទីបនី | អដ្ឋកថានៃខុទ្ទកនិកាយ | ថេរីគាថា |
| អដ្ឋ. ជាត. | ជាតកដ្ឋកថា | អដ្ឋកថានៃខុទ្ទកនិកាយ | ជាតក |
| សទ្ធម្ម. មហា. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | មហានិទ្ទេស |
| សទ្ធម្ម. ចូឡ. | សទ្ធម្មប្បជោតិកា | អដ្ឋកថានៃខុទ្ទកនិកាយ | ចូឡនិទ្ទេស |
| សទ្ធម្ម. បដិ. | សទ្ធម្មប្បកាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | បដិសម្ភិទាមគ្គ |
| វិសុទ្ធ. អប្ប. | វិសុទ្ធជនវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | អប្បទាន |
| មធុរ. ពុទ្ធ. | មធុរត្ថវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ពុទ្ធវង្ស |
| បរម. ចរិ. | វិមលវិលាសិនី | អដ្ឋកថានៃខុទ្ទកនិកាយ | ចរិយា |
| អដ្ឋសា. សង្គ. | អដ្ឋសាលិនី | អដ្ឋកថានៃព្រះអភិធម្ម | ធម្មសង្គណី |
| សម្មោហ. វិភ. | សម្មោហវិនោទនី | អដ្ឋកថានៃព្រះអភិធម្ម | វិភង្គ |
| បរម. បញ្ច. | បរមត្ថទីបនី | អដ្ឋកថានៃព្រះអភិធម្ម | បញ្ចបករណ៍ |
| វិសុ. សីល. | វិសុទ្ធិមគ្គ | សីលនិទ្ទេស | ភាគ ១ |
| វិសុ. សមាធិ. | វិសុទ្ធិមគ្គ | សមាធិនិទ្ទេស | ភាគ ២ |
| វិសុ. បញ្ញា. | វិសុទ្ធិមគ្គ | បញ្ញានិទ្ទេស | ភាគ ៣ |
| ថៃ. | អដ្ឋកថាថៃ | | |
| ភូមា. | ឆដ្ឋសង្គាយនាភូមា | | |

គប្បីជ្រាបលេខ ដែលនៅបន្ទាប់ពីអក្សរសង្ខេប ដូច្នេះ គឺ លេខខាងដើមជាលេខភាគនៃគម្ពីរ លេខកណ្តាលជាលេខឃ្លាប លេខខាងចុងជាលេខទំព័រ ។

ឧទាហរណ៍ ៤. ៤៧៦/៤៧៨ គឺ ភាគទី ៤ ឃ្លាបទី ៤៧៦ ទំព័រទី ៤៧៨ ។

# បញ្ជីមាតិកា

**មាតិកា** **ទំព័រ**

ហេតុដែលព្រះពុទ្ធទ្រង់បញ្ញត្តសិក្ខាបទ ... ... ... ... ... ក
ប្រវត្តិរបស់ព្រះពុទ្ធឃោសាចារ្យ ... ... ... ... ... ... ង
ឧបក្រមកថា ... ... ... ... ... ... ... ... ... ... ... ឋ
អក្សរសង្ខេប និងអក្សរពេញ ... ... ... ... ... ... ឍ
បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ម

## មាតិកាបារាជិកកណ្ឌ

### ១, មេថុនធម្មសិក្ខាបទវណ្ណនា

រឿងសុទិន្នភិក្ខុ ... ... ... ... ... ... ... ... ... ... ១
អត្ថាធិប្បាយឈ្មោះស្រុកនិងឈ្មោះបុត្រសេដ្ឋី ... ... ... ១
សុទិន្នកលន្ទបុត្រទៅដើម្បីស្តាប់ធម៌ ... ... ... ... ... ៣
សុទិន្នកលន្ទបុត្របានស្តាប់ធម៌ហើយគិតនឹងបួស ... ... ៥
សុទិន្នកលន្ទបុត្រទូលសូមបព្វជ្ជាចំពោះព្រះមានព្រះភាគ ៨
មាតាបិតាមិនអនុញ្ញាតឱ្យសុទិន្នបួស ... ... ... ... ... ១០
សម្លាញ់ទៅហាមមិនឱ្យសុទិន្នបួសមិនសម្រេច ... ... ១៤
សម្លាញ់ទៅសូមអនុញ្ញាតមាតាបិតាឱ្យសុទិន្នបួស ... ... ១៥

**មាតិកា** **ទំព័រ**

មាតាបិតាអនុញ្ញាតឱ្យសុទិន្នបុត្រប្រុសបួស ... ... ... ១៦
ព្រះពុទ្ធបង្គាប់ឱ្យភិក្ខុបំបួសសុទិន្នកលន្ទបុត្រ ... ... ... ១៧
ញាតិរបស់សុទិន្នភិក្ខុ ក្នុងក្រុងវេសាលីមានសម្បត្តិច្រើន ២០
ញាតិនាំភត្តាហារទៅប្រគេនសុទិន្នភិក្ខុ ៦០ ថាស ... ... ២១
អធិប្បាយរឿងនំផ្អូម ... ... ... ... ... ... ... ... ២៣
សុទិន្នភិក្ខុបួសបាន ៨ ឆ្នាំ នាងទាសីចាំអវយវៈខ្លះបាន ២៥
ពួកបព្វជិតមិនអង្គុយឆាន់ក្នុងទីមិនសមគួរដូចអ្នកសូមទាន ២៧
បិតាតិះដៀលសុទិន្នភិក្ខុថា ឆាន់នំផ្អូមដូចផឹកទឹកអម្រឹត ... ២៨
បិតាប្រគល់ទ្រព្យដើម្បីឱ្យសុទិន្នត្រូវសឹក ... ... ... ៣២
បិតាបង្គាប់ភរិយាចាស់មកលួងឱ្យសុទិន្នភិក្ខុសឹក ... ៣៦
មាតាអង្វរឱ្យសុទិន្នភិក្ខុ បង្កើតពូជទុក ... ... ... ... ... ៣៩
ស្ត្រីឈប់មានរដូវ ក៏តាំងគភ៌ ... ... ... ... ... ... ... ៤០
ទ្រង់បញ្ញត្តិបឋមបារាជិកក្នុងព្រះវស្សាទី ២០ ... ... ... ៤២
ហេតុដែលឱ្យស្ត្រីតាំងគភ៌មាន ៧ យ៉ាង ... ... ... ... ៤៤
ទេវតាប្រកាសសេចក្តីអាក្រក់ ... ... ... ... ... ... ៤៨
បុត្រប្រុសរបស់សុទិន្នភិក្ខុមានឈ្មោះថា ពីជកៈ ... ... ៥១
មាតានិងពីជកទារកបួសហើយបានសម្រេចព្រះអរហត្ត ... ៥២
សុទិន្នភិក្ខុក្តៅក្រហាយចិត្តព្រោះប្រព្រឹត្តអាក្រក់ ... ... ... ៥២

## មាតិកា ទំព័រ


ពួកភិក្ខុជាសម្លាញ់សួរសុទិន្នភិក្ខុដល់សេចក្តីស្គមស្គាំង ... ៥៦

ពួកភិក្ខុសម្លាញ់ឃើញកម្មនោះឱ្យកើតសេចក្តីក្តៅក្រហាយបាន ៥៨

អត្ថាធិប្បាយឈ្មោះព្រះនិព្វាន ៩ បទ ... ... ... ... ... ៦១

ភិក្ខុទាំងឡាយក្រាបទូលរឿងសុទិន្នភិក្ខុសេពមេថុនធម្ម ... ៦៥

ព្រះមានព្រះភាគទ្រង់តិះដៀលសុទិន្នភិក្ខុ ... ... ... ... ៦៦

អត្ថាធិប្បាយកម្មដែលមិនគួរដល់សមណៈជាដើម ... ... ៦៧

សុទិន្នភិក្ខុជាអ្នកដំបូងក្នុងការសេពមេថុនធម្ម ... ... ... ៧៤

អ្នកមិនសង្រួមជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ ៤ ... ... ៧៥

អ្នកសង្រួមមិនជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ ៤ ... ... ៧៧

អ្នកតាំងនៅក្នុងសំវរៈជាអ្នកមិនសន្សំកិលេសទាំងពួង ... ៧៨

ប្រយោជន៍នៃការបញ្ញត្តិសិក្ខាបទ ១០ យ៉ាង ... ... ... ៨១

អធិប្បាយប្រយោជន៍ការបញ្ញត្តិសិក្ខាបទ ១០ អយ៉ាង ... ៨២

ព្រះសទ្ធម្ម ៣ យ៉ាង ... ... ... ... ... ... ... ... ... ៨៧

ទ្រង់បញ្ញត្តិបឋមបារាជិកសិក្ខាបទ ... ... ... ... ... ... ៨៩

អនុប្បញ្ញត្តិទី១ រឿងស្វាញី.

សិក្ខាបទទាំងអស់ មានទោស ២ យ៉ាង ... ... ... ... ៩៥

អនុប្បញ្ញត្តិទី២ រឿងពួកភិក្ខុវជ្ជីបុត្រ

រឿងទ្រង់ហាមមិនឱ្យភិក្ខុដែនវជ្ជីបុត្របព្វជ្ជាឧបសម្បទា ១០១

**មាតិកា** **ទំព័រ**


វិន័យ ៤ យ៉ាង ... ... ... ... ... ... ... ... ... ... ១០៤
អត្ថាធិប្បាយវិន័យ ៤ យ៉ាង ... ... ... ... ... ... ... ១០៤
វិធីសង្កេតពិនិត្យសូត្រនិងសុត្តានុលោមជាដើម ... ... ១០៦
ព្រះវិន័យធរប្រកបដោយលក្ខណៈ ៣ យ៉ាង ... ... ... ១១៣
អត្ថាធិប្បាយលក្ខណៈ ៣ របស់ព្រះវិន័យធរ ... ... ... ១១៤
លំដាប់អាចារ្យតាំងពីព្រះឧបាលីថេរៈជាដើមមក ... ... ១១៧
ព្រះវិន័យធរវិនិច្ឆ័យអធិករណ៍គួរត្រួតមើលឋានៈ ៦ យ៉ាង ១១៨
អត្ថាធិប្បាយឋានៈ ៦ យ៉ាង ... ... ... ... ... ... ... ១១៩
វិធីវិនិច្ឆ័យអធិករណ៍ ... ... ... ... ... ... ... ... ... ១២១
ភិក្ខុដែលមានសីលមិនបរិសុទ្ធិ កម្មដ្ឋានមិនចម្រើន ... ១២៣
អត្ថាធិប្បាយសិក្ខាបទវិភង្គបឋមបារាជិក ... ... ... ... ១២៥
អត្ថាធិប្បាយអត្ថន័យនៃភិក្ខុសព្ទជាដើម ... ... ... ... ១២៨
ឧបសម្បទា ៨ យ៉ាង ... ... ... ... ... ... ... ... ១៣៤
អត្ថាធិប្បាយឧបសម្បទា ៨ យ៉ាង ... ... ... ... ... ១៣៥
អត្ថាធិប្បាយអធិសីល អធិចិត្ត អធិបញ្ញា ... ... ... ១៤៣
អត្ថាធិប្បាយបទថា សិក្ខានិងសាជីវ ... ... ... ... ... ១៤៧
អត្ថាធិប្បាយវិធីលាសិក្ខា ... ... ... ... ... ... ... ... ①④⑧
ភិក្ខុស្រែកប្រកាសលាសិក្ខាក៏បាន ... ... ... ... ... ... ១៦៣

**មាតិកា** **ទំព័រ**

លាសិក្ខាបញ្ចូលនាមព្រះពុទ្ធជាវេវចនៈ ... ... ... ... ១៦៨
វិធីលាសិក្ខាបញ្ចូលពាក្យវេវចនៈព្រះធម៌ ... ... ... ... ១៦៩
វិធីលាសិក្ខាបញ្ចូលពាក្យវេវចនៈព្រះសង្ឃ ... ... ... ... ១៧២
អត្ថាធិប្បាយវិធីពោលលាសិក្ខាទូទៅ ... ... ... ... ... ១៧៤
លាសិក្ខានឹងអ្នកវិកលចរិតជាដើមមិនបាន ... ... ... ... ១៨៨
អត្ថាធិប្បាយអត្ថន័យនៃមេថុនធម្ម ... ... ... ... ... ... ១៩៤
ឥត្ថីនិមិត្តបានឋាន ៥ បុរិសនិមិត្តបានឋាន៦ ... ... ... ១៩៨
ភិក្ខុពណ៌នាមេថុនកថា គួរលើកពុទ្ធគុណ ... ... ... ... ១៩៩
អនុប្បញ្ញត្តិវារៈ
កំណត់សត្វដែលជាវត្ថុនៃបារាជិកជាដើម ... ... ... ... ២០១
អត្ថាធិប្បាយប្រភេទសត្វផ្សេង ៗ ... ... ... ... ... ... ២០២
បារាជិកស័ព្ទប្រព្រឹត្តទៅក្នុងសិក្ខាបទជាដើម ... ... ... ២០៣
អត្ថាធិប្បាយសេចក្តីក្នុងព្រះគាថា ... ... ... ... ... ... ២០៦
មគ្គដែលជាវត្ថុនៃបារាជិករួម ៣០ ... ... ... ... ... ២០៩
ភិក្ខុត្រូវអ្នកដទៃចាប់បង្ខំហើយត្រេកអរជាបារាជិក ... ... ២១០
ចតុក្កៈ ២៦៩ ដ៏សេស ... ... ... ... ... ... ... ... ២១៥
មគ្គរបស់មនុស្សស្រីមាន ២៧ ចតុក្កៈ ... ... ... ... ២១៦
រឿងព្រះវិន័យធរ ២ រូប ... ... ... ... ... ... ... ... ២១៨

**មាតិកា** **ទំព័រ**

រឿងអន្តេវាសិកសួរបញ្ហាវិន័យព្រះថេរៈ ... ... ... ... ២១៩

អង្គជាតមានស្រោម និងមិនមានស្រោម ... ... ... ... ២២៦

រឿងព្រះរាជានិងចោរអ្នកជាសត្រូវចំពោះភិក្ខុជាដើម ... ២២៩

សត្រូវសម្លាប់ភិក្ខុបួងសួងទេវតាដើម្បីសម្រេចការងារ ... ២៣១

រឿងភិក្ខុសេពមេថុនធម្មតាមទ្វារមគ្គនិងមិនមែនមគ្គ ... ២៣២

ភិក្ខុសេពមេថុនធម្មនឹងភិក្ខុដេកលក់ ... ... ... ... ... ២៣៣

ភិក្ខុបដិបត្តិខុសមិនដឹង មិនត្រេកអរ មិនត្រូវអាបត្តិ ... ២៣៤

មិនជាអាបត្តិដល់ភិក្ខុឆ្កួតនិងមានចិត្តរវើរវាយ ... ... ... ២៣៨

សមុដ្ឋាននៃការកើតអាបត្តិ មាន ៦ យ៉ាង ... ... ...

អធិប្បាសិក្ខាបទជាសចិត្តកៈនិងអចិត្តកៈ ... ... ... ... ២៣៩

អធិប្បាយសិក្ខាបទដែលជាកាយកម្មជាដើម ... ... ... ២៣៩

វិនីតវត្ថុបឋមបារាជិក ឧទានគាថា ... ... ... ... ... ... ២៤២

រឿងនន្ទមាណពសេពមេថុនធម្មក្នុងឧប្បលវណ្ណាថេរី ... ២៤៥

រឿងភិក្ខុក្លាយភេទជាស្រី ... ... ... ... ... ... ... ... ២៤៧

ត្រូវអាបត្តិព្រោះដេករួមនឹងភិក្ខុក្លាយភេទ ... ... ... ... ២៥០

វិធីបដិបត្តិនឹងភិក្ខុនីអ្នកមានក្លាយភេទ ... ... ... ... ... ២៥១

វិធីបដិបត្តិក្នុងគ្រឿងបរិក្ខារផ្សេង ៗ ... ... ... ... ... ២៥៣

ដាច់ប្រគេនព្រោះហេតុ ៧ យ៉ាង ... ... ... ... ... ... ២៥៥

**មាតិកា** **ទំព័រ**


រឿងភិក្ខុ ៥ រូប នៅក្នុងព្រៃខ្មោច ... ... ... ... ... ២៦០
ភិក្ខុសេពមេថុនធម្មក្នុងស្រីប្រេតជាដើមជាបារាជិក ... ... ២៦២
រឿងភិក្ខុបើកទ្វារសិង ... ... ... ... ... ... ... ... ... ២៧០
អធិប្បាយទ្វារយ៉ាងណាគួរបិទនិងមិនគួរបិទ ... ... ... ២៧២


## ២, អទិន្នាទានសិក្ខាបទវណ្ណនា


រឿងព្រះធនិយៈកុម្ភការបុត្រ ... ... ... ... ... ... ... ២៧៩
ភិក្ខុចាំវស្សាមិនមានសេនាសនៈពិន័យអាបត្តិទុក្កដ ... ... ២៨២
ន័យអាបត្តិទុក្កដដល់ភិក្ខុដែលសាងកុដិដោយដីសុទ្ធ ... ២៩០
ព្រះមានព្រះភាគទ្រង់ត្រាស់ឱ្យទម្លាយកុដិជាអកប្បិយៈ ... ២៩១
សេចក្តីណែនាំរឿងការប្រើឆត្រនិងចីវរ ... ... ... ... ២៩៣
វិធីបោកនិងជ្រលក់ចីវរ ... ... ... ... ... ... ... ... ២៩៤
បរិក្ខារដែលគួរប្រើនិងមិនគួរប្រើ ... ... ... ... ... ... ២៩៦
បំពង់ថ្នាំភ្នែកដែលគួរប្រើនិងមិនគួរប្រើ ... ... ... ... ២៩៨
ស្រោមកូនសោនិងបរិក្ខារបន្តិចបន្តួច ... ... ... ... ... ២៩៨
សេនាសនៈដែលខុសគួរទម្លាយចេញ ... ... ... ... ... ៣០១
ធនិយភិក្ខុផ្តើមសាងកុដិឈើ ... ... ... ... ... ... ... ៣០៣

វស្សការព្រាហ្មណ៍ដាក់ទោសអ្នករក្សាឈើ ... ... ... ៣០៤

ឡ

## បញ្ជីមាតិកាអដ្ឋកថាមហាវិភង្គ

**មាតិកា** **ទំព័រ**

ប្រជាជនពោលទោសតិះដៀលពួកសមណសក្យបុត្រ ... ៣០៩
ទ្រង់ប្រជុំសង្ឃបញ្ញត្តសិក្ខាបទ ... ... ... ... ... ... ៣១១
ព្រះពុទ្ធគ្រប់អង្គពិន័យទោសដល់បារាជិកត្រឹមមួយបាទឡើង ៣១៤
អនុប្បញ្ញត្តិ
អត្ថាធិប្បាយស្រុកដែលមានខ្ទមមួយខ្ទង់ជាដើម ... ... ៣១៦
អត្ថាធិប្បាយខេត្តឧបចារស្រុកនិងផ្ទះជាដើម ... ... ... ៣១៨
អត្ថាធិប្បាយកំណត់ខេត្តព្រៃ ... ... ... ... ... ... ... ៣២៣
អត្ថាធិប្បាយវត្ថុដែលម្ចាស់របស់មានកម្មសិទ្ធិ ... ... ... ៣២៤
អត្ថាធិប្បាយសង្ខាតស័ព្ទចុះក្នុងអត្ថតតិយាវិភត្តិ ... ... ៣២៦
អត្ថាធិប្បាយបទមាតិកា ៦ បទ ... ... ... ... ... ... ៣២៧
អត្ថាធិប្បាយកិរិយានៃការលួច ៦ យ៉ាង ... ... ... ... ៣២៨
បញ្ចកៈ ៥ ពួក រួមជាអវហារ ២៥ ... ... ... ... ... ៣៣២
សាហត្ថិកបញ្ចកៈ មានអវហារ ៥ យ៉ាង ... ... ... ... ៣៣៣
បុព្វបយោគបញ្ចកៈ មានអវហារ ៥ យ៉ាង ... ... ... ៣៣៤
ថេយ្យាវហារបញ្ចកៈ មានអវហារ ៥ យ៉ាង ... ... ... ៣៣៥
អត្ថាធិប្បាយឋានៈ ៥ ប្រការ ... ... ... ... ... ... ៣៣៦
រឿងភិក្ខុលួចចីវរព្រះវិន័យធរកាត់សេចក្ដីថា មិនជាអាបត្តិ ៣៣៧

ព្រះវិន័យធរគួរមើលមើលតម្លៃនិងការប្រើប្រាស់ ... ... ៣៤២

## មាតិកាអទិន្នាទានបារាជិកសិក្ខាបទ




| មាតិកា | ទំព័រ |
|---|---|
| អត្ថាធិប្បាយទ្រព្យដែលគួរដល់ទុតិយបារាជិក ... ... ... | ៣៤៥ |
| អត្ថាធិប្បាយអាបត្តិដែលជាបុព្វបយោគនៃទុតិយបារាជិក | ៣៤៩ |
| អាបត្តិទុក្កដ ៨ យ៉ាង ... ... ... ... ... ... ... ... | ៣៥៤ |
| អត្ថាធិប្បាយពាក្យថា ទុក្កដនិងថុល្លច្ច័យ ... ... ... ... | ៣៥៨ |
| ការលួចទ្រព្យឱ្យឃ្លាតចាកឋាន ៦ យ៉ាង ... ... ... ... | ៣៦១ |
| អត្ថធិប្បាយភិក្ខុលួចបឺតទឹកដោះថ្លាជាដើម ... ... ... ... | ៣៦៩ |
| អត្ថាធិប្បាយពាក្យថា ភិន្ទិត្វា ជាដើម ... ... ... ... ... | ៣៧៧ |
| ទ្រព្យដែលឋិតនៅលើគោក ... ... ... ... ... ... ... | ៣៨០ |
| ទ្រព្យដែលនៅក្នុងអាកាស ... ... ... ... ... ... ... | ៣៨១ |
| ទ្រព្យដែលស្ថិតនៅលើផ្ទៃ ... ... ... ... ... ... ... | ៣៨៦ |
| ទ្រព្យដែលឋិតនៅក្នុងទឹក ... ... ... ... ... ... ... ... | ៣៩៣ |
| សម័យក្រោយពុទ្ធកាលពួកជនជីកស្រះចិញ្ចឹមត្រី ... ... | ៣៩៨ |
| ការចាប់យកត្រីដែលគេចិញ្ចឹម ... ... ... ... ... ... | ៣៩៨ |
| ទ្រព្យដែលឋិតនៅក្នុងទូក ... ... ... ... ... ... ... ... | ៤០១ |
| ទ្រព្យដែលឋិតនៅក្នុងយាន ... ... ... ... ... ... ... | ៤០៥ |
| ទ្រព្យឋិតនៅក្នុងភារៈ ... ... ... ... ... ... ... ... ... | ៤១០ |
| ទព្យដែលឋិតនៅក្នុងសួន ... ... ... ... ... ... ... ... | ៤១៤ |

ទ្រព្យសូម្បីដែលឋិតនៅក្នុងវិហារ ... ... ... ... ... ... ៤១៩

អា

បញ្ជីមាតិកាអដ្ឋកថាមហាវិភង្គ

មាតិកា ទំព័រ

ភណ្ឌៈដែលឋិតនៅក្នុងស្រែ ... ... ... ... ... ... ... ៤២០
ក្នុងទ្រព្យដែលឋិតនៅក្នុងផ្ទៃដី ... ... ... ... ... ... ... ៤២៥
ទ្រព្យដែលឋិតនៅក្នុងព្រៃ ... ... ... ... ... ... ... ... ៤២៦
ទ្រព្យគឺទឹក ... ... ... ... ... ... ... ... ... ... ... ៤៣១
ឈើជម្រះធ្មេញ ... ... ... ... ... ... ... ... ... ... ៤៣៦
ដើមឈើម្ចាស់ព្រៃ ... ... ... ... ... ... ... ... ... ៤៣៨
ទ្រព្យដែលមានអ្នកនាំទៅ ... ... ... ... ... ... ... ... ៤៤០
បញ្ញើ ទ្រព្យដែលគេផ្ញើ ... ... ... ... ... ... ... ... ៤៤៥
ចោរលួចភណ្ឌសង្ឃក្នុងឃ្លាំង ពិន័យជាសំណាងដល់ភិក្ខុ
អ្នករក្សាគយ ទីហូតពន្ធដារ ... ... ... ... ... ... ... ៤៦៦
សត្វមានជីវិត ... ... ... ... ... ... ... ... ... ... ៤៧១
បុគ្គលជាទាសៈ ៣ ពួក. ... ... ... ... ... ... ... ... ៤៧២
សត្វគ្មានជើង. ... ... ... ... ... ... ... ... ... ... ៤៧៥
សត្វមានជើងពីរ. ... ... ... ... ... ... ... ... ... ... ៤៧៧
សត្វមានជើងបួន ... ... ... ... ... ... ... ... ... ... ៤៧៨
សត្វមានជើងច្រើន ... ... ... ... ... ... ... ... ... ៤៨១
ភិក្ខុកំណត់របស់ឱ្យគេលួច. ... ... ... ... ... ... ... ៤៨១

ភិក្ខុរក្សាទ្រព្យដែលគេផ្ញើ ... ... ... ... ... ... ... ... ៤៨៣

## មាតិកាអទិន្នាទានបារាជិកសិក្ខាបទ



**មាតិកា** **ទំព័រ**

ការបបួលគ្នាលួច ... ... ... ... ... ... ... ... ... ... ៤៨៤
ភិក្ខុច្រើនរូបបបួលគ្នាទៅលួចទ្រព្យត្រូវអាបត្តិគ្រប់រូប ... ៤៨៤
សង្កេតកម ... ... ... ... ... ... ... ... ... ... ... ៤៨៨
និមិត្តកម្ម ... ... ... ... ... ... ... ... ... ... ... ... ៤៩០
ការបង្គាប ... ... ... ... ... ... ... ... ... ... ... ៤៩០
ពណ៌នាបទភាជនីយ៍ ... ... ... ... ... ... ... ... ... ៤៩៧
អាការ ៦ យ៉ាងដែលឱ្យភិក្ខុត្រូវអាបត្តិបារាជិ ... ... ... ៤៩៨
អត្ថាធិប្បាយក្នុងអនាបត្តិវារ ... ... ... ... ... ... ... ៤៩៩
បកិណ្ណកៈមានសមុដ្ឋានជាដើម ... ... ... ... ... ... ៥០៦
អត្ថាធិប្បាយឧទានគាថា ក្នុងវិនីតវត្ថុ ... ... ... ... ... ៥០៧
ការផ្លាស់ប្តូរស្លាក ... ... ... ... ... ... ... ... ... ... ៥១២
អត្ថាធិប្បាយអវហារ ៥ យ៉ាង ... ... ... ... ... ... ៥១២
អត្ថាធិប្បាយភណ្ឌបរិកប្ប ... ... ... ... ... ... ... ៥១៣
អត្ថាធិប្បាយឱកាសបរិកប្ប ... ... ... ... ... ... ... ៥១៥
អត្ថាធិប្បាយបដិច្ឆន្នាវហារ ... ... ... ... ... ... ... ៥១៧
អត្ថាធិប្បាយកុសាវហារ ... ... ... ... ... ... ... ... ៥១៩
ប្រារព្ធរឿងទូទៅ ... ... ... ... ... ... ... ... ... ... ៥២១

គាថាសរុបទុតិយបារាជិកសិក្ខាបទ ... ... ... ... ... ៥៥៧



បញ្ជីមាតិកាអដ្ឋកថាមហាវិភង្គ

**មាតិកា** **ទំព័រ**

## ៣, មនុស្សវិគ្គហសិក្ខាបទវណ្ណនា

អធិប្បាយរឿងក្រុងវេសាល ... ... ... ... ... ... ... ៥៥៨
ព្រះមានព្រះភាគទ្រង់សម្ដែងអសុភកម្មដ្ឋានដល់ពួកភិក្ខុ ... ៥៦០
បឋមជ្ឈានមានលក្ខណៈ ១០ និងសេចក្ដីល្អ ៣ ... ... ៥៦២
ទ្រង់មិនហាមភិក្ខុសម្លាប់គ្នា ព្រោះឃើញកម្មចាស់ ... ... ៥៦៧
មាតិកាតតិយបារាជិក មនុស្សវិគ្គហសិក្ខាបទវណ្ណនា ... ៥៥៨
ពួកភិក្ខុសម្លាប់ខ្លួនឯងនិងពឹងឱ្យអ្នកដទៃសម្លាប់ ... ... ៥៧២
មិគលណ្ឌិកៈសម្លាប់ភិក្ខុហើយកើតសេចក្ដីក្ដៅក្រហាយចិត្ត ៥៧៤
ទេវតាជួយលួងលោមមិគលណ្ឌិកៈឱ្យសម្លាប់ភិក្ខុតទៅ ... ៥៦៦
មិគលណ្ឌិកៈសម្លាប់ភិក្ខុតទៅមួយថ្ងៃ ១ រូបដល់ ៦០ រូប ៥៧៨
ព្រះមានព្រះភាគទ្រង់ជ្រាបថា ភិក្ខុសង្ឃស្រោលស្តើងទៅ ៥៧៩
ព្រះអានន្ទទូលឱ្យសម្ដែងកម្មដ្ឋានដទៃ ... ... ... ... ... ៥៨០
ព្រះមានព្រះភាគត្រាស់ប្រាប់អានាបានស្សតិដល់ពួកភិក ... ៥៨២
អត្ថាធិប្បាយវិធីអប់រំសតិ ៣២ យ៉ាង ... ... ... ... ៥៩៦
មតិខ្យល់ដកដង្ហើមចូលនិងចេញ តាមអដ្ឋកថាវិន័យ
និងព្រះសូត្រ ... ... ... ... ... ... ... ... ... ... ... ៥៩៨.

មាតិកាមនុស្សវិគ្គហបារាជិកសិក្ខាបទ ឱ

| មាតិកា | ទំព័រ |
|---|---|


ភិក្ខុកំណត់កម្មដ្ឋានហើយ កាយសង្ខារទើបស្ងប់ ... ... ៦០៥
កាយសង្ខារក្នុងឈានជាន់ខ្ពស់រមែងល្អិតទៅតាមលំដាប ៦០៨
កុលបុត្រនឹងរៀនកម្មដ្ឋានត្រូវបំពេញសីលឱ្យបរិសុទ្ធ ... ៦១៤
កម្មដ្ឋាន ២ ព្រមទាំងអធិប្បាយ ... ... ... ... ... ... ៦១៧
គួររៀនកម្មដ្ឋានក្នុងសំណាក់ពុទ្ធឱរសរហូតដល់អ្នកបានឈាន ៦១៩
កម្មដ្ឋានមានសន្ធិគឺ ទីតភ្ជាប់ ៥ យ៉ាង ... ... ... ... ៦២០
វិធីមនសិការអានាបានស្សតិកម្មដ្ឋាន ៨ យ៉ាង ... ... ៦២២
អធិប្បាយវិធីរាប់ខ្យល់ដកដង្ហើមចូលចេញ ... ... ... ៦២៣
អធិប្បាយខាងដើមកណ្ដាលនិងទីបំផុតខ្យល់ដកដង្ហើម ... ៦២៦
សេចក្ដីឧបមាដូចមនុស្សពិការយោលទោង ... ... ... ៦២៨
សេចក្ដីឧបមាដូចអ្នករក្សាទ្វារ ... ... ... ... ... ... ... ៦២៩
ការកំណត់ខ្យល់ដកដង្ហើមប្រៀបដូចរណារ ... ... ... ៦៣០
ឧបាយជាហេតុនាំអានាបានស្សតិកម្មដ្ឋានមក ... ... ... ៦៣៥
Fm’- ៣ យ៉ាងមានបរិបូណ៌កម្មដ្ឋានទើបដល់អប្បនា ... ៦៤០
ចិត្តរមែងតាំងមាំជាសមាធិដោយអង្គ ២ ... ... ... ... ៦៤២
ឧបាយរក្សាអានាបានស្សតិកម្មដ្ឋាន ... ... ... ... ... ៦៤៣
ប្រជុំសន្និរទ្រង់បញ្ញត្តតតិយបារាជិកសិក្ខាបទ ... ... ... ៦៥៩

ភិក្ខុឆព្វគ្គិយពណ៌នាគុណនៃសេចក្ដីស្លាប់ ... ... ... ... ៦៦០



បញ្ជីមាតិកាអដ្ឋកថាមហាវិភង្គ

**មាតិកា** **ទំព័រ**

អធិប្បាយសញ្ចិច្ចស័ព្ទ ... ... ... ... ... ... ... ... ៦៦៣
អធិប្បាយបឋមចិត្តរបស់អ្នកចុះកាន់គភ៌ ... ... ... ... ៦៦៤
ជីវិតិន្ទ្រិយបច្ចុប្បន្នមាន ៣ ខណៈ ... ... ... ... ... ៦៦៨
ប្រយោគនៃការសម្លាប់ ៦ យ៉ាង ... ... ... ... ... ... ៦៧០
អធិប្បាយវត្ថុដែលជាគ្រឿងប្រហារ ... ... ... ... ... ៦៧៤
អធិប្បាយមាតិកាក្នុងបទភាជនី ... ... ... ... ... ... ៦៨០
ភិក្ខុសម្លាប់មាតាបិតាជាដើមជាអនន្តរិយកម្មនិងបារាជិក ៦៨៣
ភិក្ខុសម្លាប់មាតាបិតាជាដើមក្នុងគំនរចំបើងមិនត្រូវបារាជិក ៦៨៥
ភិក្ខុសម្លាប់បិតាក្នុងសមរភូមិប្រយុទ្ធជាបារាជិកនិងជាបិតុឃាត ៦៨៦
ឋានៈ ៥ និង ៦ ព្រមទាំងអត្ថាធិប្បាយ ... ... ... ... ៦៨៨
អធិប្បាយវត្ថុដែលត្រូវសម្លាប់ ... ... ... ... ... ... ៦៨៩
អធិប្បាយកាលដែលបង្គាប់ឱ្យធ្វើការសម្លាប់ ... ... ... ៦៩០
អធិប្បាយឱកាសដែលបង្គាប់ឱ្យធ្វើការសម្លាប់ ... ... ... ៦៩១
អធិប្បាយអាវុធដែលជាគ្រឿងដៃប្រើឱ្យសម្លាប់ ... ... ៦៩១
អធិប្បាយឥរិយាបថដែលបង្គាប់ឱ្យធ្វើការសម្លាប់ ... ... ៦៩២
អធិប្បាយកិរិយាវិសេសដែលបង្គាប់ឱ្យសម្លាប ... ... ៦៩៣
ការបង្គាប់ទូត ... ... ... ... ... ... ... ... ... ... ៦៩៤

អាណត្តិកបយោគរឿងបន្តាប់ទូតបន្ត … … … … … ៦៩៦



មាតិកា ទំព័រ


រឿងដែលមិនកំបាំង សម្គាល់ថា ដែលកំបាំង … … … ៧០៣

អធិប្បាយការពណ៌នាសេចក្តីស្លាប់ដោយកាយ … … ៧០៤

អធិប្បាយពណ៌នាសេចក្តីស្លាប់ដោយទូតនិងសំបុត្រ … ៧០៦

អធិប្បាយការជីករណ្តៅឱ្យមនុស្សធ្លាក់ស្លាប់ … … … ៧០៩

មតិព្រះថេរៈពីររូបក្នុងការជីករណ្តៅ … … … … … ៧១៣

ការដាក់អន្ទាក់របស់ភិក្ខុ … … … … … … … … ៧១៥

ការប្រើអន្ទប់ដាក់សត្វរបស់ភិក្ខុ … … … … … … ៧១៧

កប់សស្ត្រាទុកក្នុងវត្ថុសម្រាប់ផ្អែក … … … … … … ៧១៧

លបដាក់ថ្នាំពិសទុកក្នុងភេសជ្ជៈ … … … … … … ៧២២

កប់វុធទុកក្រោមគ្រែ ឬតាំង … … … … … … … ៧២៣

ការបន្តប់ម្រូង … … … … … … … … … … ៧២៤

ការបន្តប់ថ្នាំពិសទុកជាដើម … … … … … … … ៧២៦

ការនាំរូបនិងសំឡេងជាដើមចូលទៅ … … … … … ៧២៧

ការនាំធម្មារម្មណ៍ចូលទៅ … … … … … … … … ៧២៩

អនាបត្តិវារ … … … … … … … … … … … ៧៣១

តតិយបារាជិកសិក្ខាបទ មានសមុដ្ឋាន … … … … ៧៣២

រឿងពណ៌នាសេចក្តីស្លា … … … … … … … … ៧៣៣

រឿងភិក្ខុអន្ទយសន្ទត់ក្មេងស្លាប ... ... ... ... ... ... ៧៣៤



បញ្ជីមាតិកាអដ្ឋកថាមហាវិភង្គ

**មាតិកា** **ទំព័រ**


រឿងភិក្ខុធ្វើអង្រែជួលបោកត្រូវក្មេងស្លាប់ ... ... ... ... ៧៣៦

រឿងភិក្ខុជាបុត្រប្រាប់ភិក្ខុជាបិតាឱ្យជួលស្លាប់ ... ... ... ៧៣៦

រឿងភិក្ខុឆាន់បិណ្ឌបាតលាយថ្នាំពិសស្លាប់ ... ... ... ... ៧៣៧

រឿងភិក្ខុសាកល្បងថ្នាំពិស ... ... ... ... ... ... ... ៧៣៩

រឿងភិក្ខុចងរនៅ ... ... ... ... ... ... ... ... ... ... ៧៤០

រឿងភិក្ខុទម្លាក់ខ្លួនពីលើភ្នំចុះក្នុងជ្រោះសង្កត់ជាងតម្បាញស្លាប់ ៧៤១

រឿងភិក្ខុឆព្វគ្គិយប្រមៀលថ្មលេងសង្កត់អ្នកខ្វាលគោស្លាប់ ៧៤៣

រឿងភិក្ខុធ្វើថ្នាំឱ្យស្រីមានគភ៌នឹងសហាយស្ទន់ធ្លាក់ទៅជាដើម ៧៤៤ .

រឿងភិក្ខុធ្វើថ្នាំឱ្យស្រីអារមានបុត្រស្លាប់ ... ... ... ... ៧៤៥

ភិក្ខុមិនគួរធ្វើថ្នាំដល់ជនដទៃតែគួរធ្វើឱ្យសហធម្មិកទាំង៥ ៧៤៦

ភិក្ខុគួរធ្វើថ្នាំឱ្យជន ១០ ពួក ... ... ... ... ... ... ... ៧៤៨

ភិក្ខុគួរធ្វើថ្នាំឱ្យដល់អ្នក ៥ ពួក ... ... ... ... ... ... ៧៥០

រឿងព្រះមហាបទុមត្ថេរសន្ទនារឿងថ្នាំព្យាបាលរោគ ... ៧៥១

រឿងសូត្រព្រះបរិត្ត ... ... ... ... ... ... ... ... ... ៧៥២

រឿងអនាមដ្ឋបិណ្ឌបាត ... ... ... ... ... ... ... ... ៧៥៤

រឿងបដិសណ្ឋារៈ ... ... ... ... ... ... ... ... ... ៧៥៥

រឿងព្រះអភយត្ថេរធ្វើបដិសណ្ឋារៈនឹងអភ័យចោរ ... ... ៧៥៦

ព្រះថេរៈត្រូវពួកភិក្ខុលើកទោស … … … … … … ៧៥៨



មាតិកាឧត្តរិមនុស្សធម្មបារាជិកសិក្ខាបទ

មាតិកា ទំព័រ


រឿងភិក្ខុឆព្វគ្គិយចាក់ក្រឡេកភិក្ខុសត្តរវគ្គិយជាដើម … ៧៥៩

រឿងភិក្ខុសម្លាប់យក្ខ ត្រូវថុល្លច្ច័យ … … … … … ៧៦០

រឿងបញ្ជូនភិក្ខុទៅកាន់ទីមានសត្វកាចនិងយក្ខកាច … … ៧៦១

រឿងភិក្ខុចំភិក្ខុជាសត្រូវបានប្រាកដទើបសម្លាប់ … … … ៧៦៣

រឿងខ្មោចចូលស្ថិតភិក្ខុ … … … … … … … … ៧៦៤

រឿងភិក្ខុកាត់ដើមឈើ … … … … … … … … ៧៦៥

រឿងភិក្ខុឆព្វគ្គិយដុតព្រៃ … … … … … … … … ៧៦៦

រឿងភិក្ខុបង្គាប់ពេជ្ឈឃាតឱ្យប្រហារតែមួយដង … … ៧៦៧

រឿងភិក្ខុបង្គាប់ឱ្យបុរសកំបុតផឹកខាញ់ស្លាប់ … … … ៧៦៩

រឿងថ្នាំគ្រាំពិសេសឈ្មោះលោណសោចិរកៈ … … … ៧៦៩


## ៤, ឧត្តរិមនុស្សធម្មសិក្ខាបទវណ្ណនា


រឿងពួកភិក្ខុចាំវស្សាមាត់ស្ទឹងវគ្គុមុទា … … … … … ៧៧១

អធិប្បាយស័ព្ទកិរិយាអនាគត … … … … … … … ៧៧៣

ទ្រង់ត្រាស់សួរពួកភិក្ខុដែលនៅមាត់ស្ទឹងវគ្គុមុទា … … ៧៧៥

ចោរខាងក្រៅសាសនាត្រាច់ប្លន់ស្រុកជាយដែនជាដើម … ៧៧៦

មហាចោរក្នុងសាសនាត្រាច់ញាំញីសិក្ខាបទ ... ... ... ៧៧៨
មហាចោរក្នុងព្រះសាសនាមាន ៥ ពួក ... ... ... ... ៧៨១

ឬ

បញ្ជីមាតិកាអដ្ឋកថាមហាវិភង្គ

**មាតិកា** **ទំព័រ**

ពន្យល់អត្ថនៃនិគមគាថា ... ... ... ... ... ... ... ... ៧៨៩
បឋមបញ្ញត្តិចតុត្ថបារាជិក ... ... ... ... ... ... ... ... ៧៩៤
អនុប្បញ្ញត្តិចតុត្ថបារាជិក ... ... ... ... ... ... ... ... ៧៩៤
ហេតុដែលឱ្យជឿមានឋានៈ ៦ យ៉ាង ... ... ... ... ... ៧០២
អត្ថាធិប្បាយឋានៈ ៦ យ៉ាង ... ... ... ... ... ... ... ៧០៤
សួរដល់បដិបទាដែលអាងថា សម្រេចធម៌ ... ... ... ៧០៦
អធិប្បាយបទភាជនី ... ... ... ... ... ... ... ... ... ៨១១
សុទ្ធិកមហាវារ ... ... ... ... ... ... ... ... ... ... ៨២០
វត្ថុកាមវារកថា ... ... ... ... ... ... ... ... ... ... ៨៣០
បច្ចយប្បដិសំយុត្តវារកថា ... ... ... ... ... ... ... ៨៣២
ចតុត្ថបារាជិកសិក្ខាបទ មានសមុដ្ឋាន ៣ ... ... ... ... ៨៣៥
រឿងសម្គាល់ថា បានសម្រេច ... ... ... ... ... ... ៨៣៥
រឿងតាំងកតិកាចៀសទៅ ... ... ... ... ... ... ... ... ៨៤៣
រឿងព្រះមហាមោគ្គល្លានឃើញអដ្ឋិសង្ខលិកប្រេត ... ... ៨៤៦
មំសបេសីប្រេត ... ... ... ... ... ... ... ... ... ... ៨៥៣
រឿងមំសបិណ្ឌប្រេត ... ... ... ... ... ... ... ... ... ៨៥៤

រឿងនិច្ឆវីប្រេត … … … … … … … … … … ៨៥៤
រឿងអសិលោមប្រេត … … … … … … … … … ៨៥៤



មាតិកា ទំព័រ

រឿងសត្តិលោមប្រេត … … … … … … … … … ៨៥៥
រឿងឧសុលោមប្រេត … … … … … … … … … ៨៥៥
រឿងសូចិលោមប្រេត … … … … … … … … … ៨៥៦
រឿងសូចិលោមប្រេតទី ២ … … … … … … … ៨៥៧
រឿងអណ្ឌភារប្រេត … … … … … … … … … ៨៥៨
រឿងបរទារិកប្រេត … … … … … … … … … ៨៥៨
រឿងមង្គុលិស្រីប្រេត … … … … … … … … … ៨៥៩
រឿងឱក្កិលិនីស្រីប្រេត … … … … … … … … ៨៦០
រឿងចោរឃាតប្រេត … … … … … … … … … ៨៦១
រឿងព្រះភិក្ខុប្រេតជាដើម … … … … … … … … ៨៦២
រឿងស៊ឹងតបោទា … … … … … … … … … … ៨៦២
រឿងការច្បាំង … … … … … … … … … … ៨៦៤
រឿងដំរីចុះទឹក … … … … … … … … … … ៨៦៥
រឿងព្រះសោភិតៈ … … … … … … … … … ៨៦៧
បទសរុបបារាជិក … … … … … … … … … … ៨៧០
ពន្យល់ពាក្យថា សមន្តប្បាសាទិកា … … … … … ៨៧៤

អធិដ្ឋានគាថារបស់ព្រះថេរៈដែលបានរចនា ... ... ... ៨៧៤

ចប់ មាតិកាបារាជិកកណ្ឌ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# បារាជិក ៤

## ១. មេថុនធម្មសិក្ខាបទវណ្ណនា

### រឿងសុទិន្នភិក្ខុ

[១០] ខាងមុខអំពីវេរញ្ជកណ្ឌនេះទៅ ពាក្យថា តេន ខោ បន សមយេន វេសាលិយា អវិទូរេ កលន្ទគាមោ ហោតិ : ក្នុងសម័យនោះឯង មានស្រុកមួយឈ្មោះកលន្ទ នៅមិនឆ្ងាយប៉ុន្មានអំពីក្រុងវេសាលី មានសេចក្តីជាក់ច្បាស់ដោយច្រើន ។ ព្រោះដូច្នោះខ្ញុំព្រះករុណានឹងវៀរការពណ៌នាតាមលំដាប់បទចេញ នឹងពណ៌នាតែបទដែលមានពាក្យសមគួរនឹងពោលប៉ុណ្ណោះ ។

### អត្ថាធិប្បាយឈ្មោះស្រុកនិងឈ្មោះបុត្រសេដ្ឋី

ស្រុកដែលបានឈ្មោះថា កលន្ទគ្រាម ក៏ដោយអំណាចនៃសត្វកន្ធែនទាំងឡាយ ដែលហៅថា កលន្ទកៈ ។

បទថា កលន្ទបុត្តោ សេចក្តីថា (សុទិន្ន) ជាបុត្ររបស់កលន្ទសេដ្ឋី ដែលមានទ្រព្យ ៤០ កោដិ ដែលបានឈ្មោះដោយអំណាចនៃ

ស្រុក ដែលព្រះរាជទានសន្តតិឱ្យ ។ ក៏ព្រោះមនុស្សស្តម្បីពួកជាទៃ ដែលមានឈ្មោះថា កលន្ទៈ មាននៅក្នុងស្រុកនោះ, ដូច្នោះ លោកទើបពោលថា កលន្ទបុត្រ ហើយពោលជាដែលទុកទៀតថា សេដ្ឋីបុត្រ ។

បទថា **សម្ពហុលេហិ** : **ច្រើននាក់** គឺ ច្រើនសន្ធឹក ។

បទថា **សហាយកេហិ** : **សម្លាញ់ទាំងឡាយ** សេចក្តីថា ជនអ្នកឈ្មោះថា សម្លាញ់ ព្រោះអត្ថថា ទៅរួមគ្នា គឺ ចូលដល់សុខនិងទុក្ខជាមួយគ្នា ។ សម្លាញ់ទាំងឯង ឈ្មោះថា **សហាយកា** ( សុទិន្នកលន្ទបុត្របានទៅក្រុងវេសាលី ) ជាមួយនឹងសម្លាញ់ទាំងនោះ ។

បទថា **សទ្ធឹ** : **ជាមួយនឹង** គឺ ជាពួកតែមួយ ។

ពីរបទថា **កេនចិទេវ ករណីយេន** : **ដោយកិច្ចការអ្វីមួយ** សេចក្តីថា ដោយកិច្ចយ៉ាងណាមួយ មានការលក់ដូរទំនិញ ការឱ្យខ្ចី និងការទារបំណុលជាដើម ។ អាចារ្យពួកខ្លះពោលថា ដោយកិច្ចគឺការលេងកីឡាដែលជានក្ខត្តឫក្សក្នុងខែកត្តិក ( គឺ ខែ១២ ) ដូច្នេះខ្លះ ។ ពិតមែនព្រះមានព្រះភាគ ស្តេចទៅដល់នគរវេសាលីក្នុងជុណ្ហបក្ខ ( ខាងខ្នើត ) នៃខែកត្តិក ។ មួយទៀត ក្នុងនគរវេសាលីនេះ មានការលេងកីឡា ដែលជានក្ខត្តឫក្សប្រចាំខែកត្តិកយ៉ាងឱឡារិក, សុទិន្នកលន្ទបុត្រនោះ គប្បីជ្រាបថា ទៅ ( កាន់នគរវេសាលី ) ដើម្បីលេងកីឡានក្ខត្តឫក្សនោះ ។

## សុទិន្នកលន្ទបុត្រទៅដើម្បីស្តាប់ធម៌

បទថា អទ្ទសា ខោ : ក៏ទៅប្រទះបានឃើញ សេចក្តីថា សុទិន្នកលន្ទបុត្រនោះ បានឃើញយ៉ាងណា ? បានឃើញយ៉ាងនេះគឺ ៖

បានឮថា សុទិន្ននោះ បានឃើញមហាជនអ្នកបរិភោគអាហារព្រឹកសម្រេចហើយ ដណ្តប់សំពត់ស មានដៃកាន់ផ្កាឈើរបស់ក្រអូប និងគ្រឿងលាប ចេញចាកព្រះនគរទៅ ដើម្បីគាល់ព្រះពុទ្ធ និងដើម្បីស្តាប់ធម៌ ទើបសួរមហាជនថា "ពួកលោកនឹងទៅឯណា" ។

មហាជនឆ្លើយថា "នឹងទៅដើម្បីគាល់ព្រះពុទ្ធ និងដើម្បីស្តាប់ធម៌" ។

សុទិន្នពោលថា "បើដូច្នោះ សូម្បីខ្ញុំក៏នឹងទៅ" ហើយទៅបានឃើញព្រះមានព្រះភាគដែលបរិស័ទទាំង ៤ ហែហមហើយ ទ្រង់កំពុងសម្តែងធម៌ ដោយព្រះសូរសៀងដ៏ពីរោះដូចសំឡេងព្រហ្ម ។ ព្រោះហេតុនោះ ព្រះឧបាលីថេរៈទើបបានពោលទុកថា "សុទិន្នកលន្ទបុត្រ ក៏ទៅប្រទះបានឃើញព្រះអង្គមានបរិស័ទគាល់ត្រៀបត្រា កំពុងគង់សម្តែងធម៌" ។

បទថា ទិស្វានស្ស កាត់បទជា ទិស្វាន អស្ស ប្រែថា លុះឃើញហើយ គឺព្រោះបានឃើញ( សេចក្តីរំពឹងនេះបានមាន ) ដល់គេ ។

បទថា ឯតទហោសិ : ក៏មានសេចក្តីត្រិះរិះ សេចក្តីថា សេចក្តី

រំពឹងនេះ បានមានដល់សុទិន្នអ្នកជាកូនកុលបុត្រ (កុលបុត្រអ្នកគួរត្រាស់ដឹង) អ្នកដែលបុព្វេកតបុញ្ញតាជាស់តឿន ។

សួរថា សេចក្តីរំពឹងនេះ បានមានហើយយ៉ាងណា ?

ឆ្លើយថា បានមានថា ដូចម្តេចហ្ន៎ យើងទឹងគប្បីបានស្តាប់ធម៌ខ្លះ ។

បណ្តាបទទាំងនោះ បទថា យន្នូន : គួរតែ នោះជាបទសម្តែងដល់សេចក្តីរំពឹង ។

បានឮថា សុទិន្ននោះ បានកើតសេចក្តីរំពឹងឡើងយ៉ាងនេះថា "បរិស័ទនេះមានចិត្តស្ងប់ចុះទៅតែមួយស្តាប់ធម៌ណា, ឱហ្ន៎ សូម្បីយើងក៏គប្បីស្តាប់ធម៌នោះ" ។

បើនិងមានអាចារ្យអ្នកតវ៉ាថា "ក្នុងពាក្យថា គ្រានោះឯង សុទិន្នកលន្ទបុត្រចូលទៅដោយមកបរិស័ទនោះ ព្រោះហេតុអ្វី ទើបព្រះឧបាលីថេរៈ មិនពោលទុកថា ចូលទៅគាល់ដោយមកដែលព្រះមានព្រះភាគប្រថាប់ តែត្រឡប់ពោលថា ចូលទៅតាមមកដែលបរិស័ទនោះនៅ ?"

ឆ្លើយថា "ពិតមែន បរិស័ទពួកធំ មានពួកជនជាអ្នកមានសក្តិធំ ៗ នៅអង្គុយហែហមព្រះមានព្រះភាគហើយ, សុទិន្នកលន្ទបុត្រនេះមកខាងក្រោយគេ មិនអាចនឹងចូលទៅអង្គុយគាល់ព្រះមានព្រះភាគ ក្នុងបរិស័ទនោះបាន, តែក៏អាចចូលទៅអង្គុយក្នុងទីមួយកន្លែងជិតបរិស័ទបាន,

ព្រោះដូច្នោះ សុទិន្នកលន្ទបុត្រនោះ ក៏ចូលទៅរកបរិស័ទនោះឯង ។ ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបបានពោលថា "គ្រានោះ សុទិន្នកលន្ទបុត្រ ក៏ចូលទៅកាន់ទីដែលបរិស័ទអង្គុយនោះ" ។

## សុទិន្នកលន្ទបុត្របានស្តាប់ធម៌ហើយគិតនឹងបួស

ប្រែបទថា ឯកមន្តំ និសិន្នស្ស ខោ សុទិន្នស្ស កលន្ទបុត្តស្ស ឯតទហោសិ : កាលសុទិន្នកុមារកលន្ទបុត្រ បានអង្គុយនៅក្នុងទីមួយដ៏សមគួរហើយ សេចក្តីថា សេចក្តីរំពឹងនេះ មិនបានមានដល់សុទិន្នកលន្ទបុត្រដែលត្រឹមតែថា អង្គុយហើយប៉ុណ្ណោះទេ, តាមការពិតក៏សេចក្តីរំពឹងនោះ បានមានដល់សុទិន្នកលន្ទបុត្រនោះ ដែលអង្គុយហើយក្នុងទីសមគួរម្ខាងនុ៎ះឯង ព្រោះបានស្តាប់ធម្មកថា បន្តិចបន្តួចដែលប្រកបដោយត្រៃសិក្ខា របស់ព្រះមានព្រះភាគ, ព្រោះហេតុនោះ លោកព្រះឧបាលីថេរៈ ទើបពោលទុកថា សេចក្តីរំពឹងនេះ បានមានដល់សុទិន្នកលន្ទបុត្រអ្នកអង្គុយនៅហើយក្នុងទីសមគួរម្ខាង ។

សួរថា សេចក្តីរំពឹងនេះ បានមានហើយយ៉ាងណា ?

ឆ្លើយថា បានមានថា ដោយអាការណា ៗ (យើងទើបនឹងដឹងទូទៅដល់ធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ) ដូច្នេះជាដើម ។

ក្នុងពាក្យថា យថា ជាដើមនោះ មានការពោលដោយសង្ខេបដូចតទៅនេះ ៖

យើងនឹងដឹងទូទៅ ដល់ធម៌ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយដោយអាការណា ៗ, សេចក្ដីរំពឹងយ៉ាងនេះ រមែងមានដល់យើង អ្នកពិចារណាដោយអាការនោះ ៗ ។ ព្រហ្មចរិយ គឺ ត្រៃសិក្ខា ឈ្មោះថា ដែលបុគ្គល (អ្នកនៅគ្រប់គ្រងផ្ទះ) នឹងគប្បីប្រព្រឹត្តឱ្យបរិបូណ៌ដោយចំណែកតែមួយ ព្រោះនឹងត្រូវធ្វើមិនឱ្យដាច់ជាកំណាត់ សូម្បីរហូតដល់អស់មួយថ្ងៃ ហើយគប្បីឱ្យបន្តរហូតដល់ចរិមកចិត្ត[១] (គឺ ចិត្តដែលឃ្លាតចាកភព) និងឈ្មោះថា ដែលបុគ្គល (អ្នកនៅគ្រប់គ្រងផ្ទះ) នឹងគប្បីប្រព្រឹត្តឱ្យបរិសុទ្ធដោយចំណែកតែមួយ ព្រោះនឹងត្រូវធ្វើមិនឱ្យសៅហ្មង ដោយមន្ទិលគឺ កិលេសសូម្បីរហូតដល់អស់មួយថ្ងៃ ហើយគប្បីឱ្យបន្តរហូតដល់ ចរិមកចិត្ត (គឺ ចិត្តដែលឃ្លាតចាកភព) ។

បទថា សង្ខលិខិតំ : ដូចជាស័ង្ខដែលគេខាត់ហើយ សេចក្ដីថា នឹងគប្បីបដិបត្តិឱ្យដូចជាស័ង្ខដែលដុសខាត់ហើយគឺ ឱ្យមានចំណែកប្រៀបដូចស័ង្ខដែលខាត់ហើយ ។

១. សារត្ថ. ចរិមកចិត្ត សំដៅដល់ចុតិចិត្ត គឺ ចិត្តឃ្លាតចាកភព សំដៅដល់ដរាបរលត់ជីវិត ។

ច្រើនបទថា ឥធំ ន សូករំ អគារំ អជ្ឈាវសតា ៖ បើខ្ញុំនៅជាគ្រហស្ថគ្រប់គ្រងផ្ទះនោះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ សេចក្ដីថា ដែលបុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ នឹងប្រព្រឹត្តព្រហ្មចរិយនេះឱ្យបរិបូណ៌ដោយចំណែកតែមួយ ឱ្យបរិសុទ្ធិដោយចំណែកតែមួយ ដូចស័ង្ខដែលគេខាត់ហើយ ជារបស់មិនងាយធ្វើបាន ដូចម្ដេចហ្ន៎ យើងនឹងគប្បីកោរសក់និងពុកមាត់ គ្រងគឺ ស្លៀកដណ្ដប់សំពត់កាសាវៈ ព្រោះជារបស់ជ្រលក់ហើយដោយរសនៃទឹកអម្ចត់ ដែលជារបស់សមគួរដល់បព្វជិតអ្នកប្រព្រឹត្តព្រហ្មចរិយ ហើយចេញចាកផ្ទះបួសជាបព្វជិត ។

ក៏ព្រោះកសិកម្មនិងពាណិជ្ជកម្មជាដើម ដែលជាប្រយោជន៍ដល់ផ្ទះលោកហៅថា អគារិយៈ ក្នុងបទថា អណាគារិយំ នេះ ។ និងកសិកម្មពាណិជ្ជកម្មជាដើមនោះ រមែងមិនមានក្នុងបព្វជ្ជា ព្រោះហេតុនោះ បព្វជ្ជាបណ្ឌិតគប្បីដឹងថា អនាគារិយោ ការបព្វជ្ជាដែលមិនមានផ្ទះនោះ ។

បទថា បព្វជេយ្យំ ប្រែថា គប្បីបួស គឺ គប្បីចូលដល់ ។

## សុទិន្នកលន្ទបុត្រទូលសូមបព្វជ្ជាចំពោះព្រះមានព្រះភាគ

ប្រែនបទថា **អចិរវុដ្ឋិតាយ បរិសាយ យេន ភគវា តេនុបសង្កមិ :** កាលបើពួកពុទ្ធបរិស័ទក្រោកទៅអស់ហើយភ្លាម ក៏ចូលទៅគាល់ព្រះមានព្រះភាគ សេចក្ដីថា សុទិន្ន កាលបរិស័ទមិនទាន់ក្រោកទៅ ក៏មិនទាន់បានទូលសូមបព្វជ្ជាចំពោះព្រះមានព្រះភាគ ។ ព្រោះហេតុអ្វី ? ព្រោះក្នុងបរិស័ទនោះ ញាតិសាលោហិត មិត្តនិងអាមាត្យរបស់សុទិន្ននោះ មានច្រើន, ពួកញាតិជាដើមទាំងនោះ នឹងគប្បីនិយាយថា "អ្នកជាបុត្របណ្ដូលចិត្តម្នាក់របស់មាតាបិតា, អ្នកមិនបានដើម្បីនឹងបួស" ដូច្នេះហើយ គប្បីចាប់សូម្បីត្រង់ដើមដៃទាញចេញទៅ, ក្នុងវេលានោះ សុទិន្នគិតថា "អន្តរាយនឹងមានដល់បព្វជ្ជា" ទើបក្រោកឡើងដើរទៅបានបន្តិច ព្រមនឹងបរិស័ទទាំងឯង ហើយវិលត្រឡប់មកទៀត ដោយការអាងលេសនៃសរីរកិច្ចយ៉ាងណាមួយ ចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសូមបព្វជ្ជា ។ ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបពោលទុកថា "ឯសុទិន្នកលន្ទបុត្រ កាលបើពួកពុទ្ធបរិស័ទក្រោកទៅអស់ហើយភ្លាម ក៏ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំព្រះអង្គដោយគោរព រួចអង្គុយក្នុងទីមួយដ៏សមគួរ ។ លុះសុទិន្នកលន្ទបុត្រ អង្គុយនៅក្នុងទីមួយ

ដ៏សមគួរហើយ ក៏ក្រាបទូលព្រះអង្គថា 'សូមទ្រង់ព្រះមេត្តាប្រោស ធម៌ដែលព្រះអង្គសម្តែងហើយ ដោយដំណើរយ៉ាងណា ៗ ខ្ញុំព្រះអង្គបានយល់តាមដំណើរទាំងនោះដែរហើយ ប៉ុន្តែបើខ្ញុំព្រះអង្គនៅជាគ្រហស្ថគ្រប់គ្រងផ្ទះ (យ៉ាងនេះ) ក៏មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌ឱ្យបរិបូណ៌តែម្យ៉ាង ឱ្យបរិសុទ្ធិតែម្យ៉ាង ដូចជាស័ង្ខដែលគេខាត់ហើយនោះទេ, បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចង់កោរសក់ និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់ជ្រលក់ទឹកអម្ចត់ ហើយចេញចាកផ្ទះមកបួសប្រតិបត្តិក្នុងផ្នួស ដែលគ្មានប្រយោជន៍ដោយកិច្ចការក្នុងផ្ទះ (នោះណាស់) សូមព្រះមានជោគ ទ្រង់បំបួសខ្ញុំព្រះអង្គផង'" ។ ក៏ព្រោះចាប់តាំងពីរាហុលកុមារបព្វជ្ជាមក ព្រះមានព្រះភាគក៏ទ្រង់មិនបំបួសបុត្រដែលមាតាបិតាមិនអនុញ្ញាត, ព្រោះដូច្នោះ ទើបត្រាស់សួរសុទិន្ននោះថា "ម្នាលសុទិន្ន មាតាបិតាអនុញ្ញាតឱ្យលោកចេញចាកផ្ទះមកបួសជាបព្វជិតហើយឬ ?"

[១១] ខាងមុខតាំងអំពីព្រះពុទ្ធតម្រាស់នេះទៅ បណ្ឌិតគប្បីជ្រាបសេចក្តីទៅតាមផ្លូវព្រះបាលីនុ៎ះឯង យ៉ាងនេះ ក្នុងបទថា តំ ករណីយំ តីរេត្វា : បានសម្រេចកិច្ចការនោះហើយ នេះ ។ (សុទិន្នកលន្ទបុត្រនោះ) ឱ្យករណីយកិច្ចនោះសម្រេចអស់ ដោយការលះបោលធុរៈនុ៎ះឯង ។ ពិតមែន ទឹកចិត្តរបស់សុទិន្នកលន្ទបុត្រ អ្នកមានឆន្ទៈខ្លាំងក្លាក្នុង

ការបព្វជ្ជា មិនបានបង្អោនទៅក្នុងធុរៈកិច្ចទាំងឡាយ មានប្រកបការលក់ដូរទំនិញ ការឱ្យខ្ចី និងទារបំណុលជាដើម ឬក្នុងការលេងនក្ខត្តឫក្សទេ ។

## មាតាបិតាមិនអនុញ្ញាតឱ្យសុទិន្នបួស

ក៏ក្នុងបទថា អម្ម តាត នេះ មានវិនិច្ឆ័យដូច្នេះ ៖

សុទិន្នកលន្ទបុត្រហៅមាតាថា **អម្ម** ម៉ែ (និង) ហៅបិតាថា **តាត** ឪពុក ។

ពីរបទថា ត្វំ ខោសិ កាត់បទជា **ត្វំ ខោ អសិ** ប្រែថា បាឯងជា (បុត្រតែមួយ) គឺ អ្នកឯងប៉ុណ្ណោះ ជា (បុត្រដ៏ជាទីពេញចិត្តរបស់យើង) ។

បទថា ឯកបុត្តកោ : ជាបុត្រឯក សេចក្ដីថា ជាបុត្រតែមួយពិត ៗ គឺ បងប្រុស ឬប្អូនប្រុសអ្នកដទៃរបស់អ្នកឯងមិនមាន ។

មួយទៀត ក្នុងបទថា ឯកបុត្តកោ នេះ កាលមាតាបិតាគួរនឹងពោលថា **ឯកបុត្តោ** តែពោលថា **ឯកបុត្តកោ** ក៏ដោយអំណាចសេចក្ដីអាណិត ។

បទថា បិយោ : ជាទីស្រឡាញ់ គឺ អ្នកឱ្យកើតបីតិ ។

បទថា មនាបោ : ជាទីពេញចិត្ត គឺ អ្នកចម្រើនចិត្ត ។

បទថា សុខេធិតោ : ធ្លាប់បីតនៅក្នុងសេចក្ដីសុខ គឺ អ្នករុងរឿងមកដោយសេចក្ដីសុខ ។ អធិប្បាយថា អ្នកចម្រើនមកដោយសេចក្ដីសុខ ។

បទថា សុខបរិហាដោ : មានអ្នកទំនុកបម្រុងឱ្យបានសេចក្ដីសុខ សេចក្ដីថា អ្នកដែលពួកជនចិញ្ចឹមបីបាច់មកដោយសេចក្ដីសុខ គឺ តាំងពីវេលាកើតមកហើយ ក៏មានភីលៀងនាងមេដោះទាំងឡាយ ផ្ទាស់ប្ដូរបផ្ទេរគ្នាឱបបីពរ តែងលេងដោយវត្ថុគ្រឿងលេង ក្នុងកាលនៅជាកុមារតូច ៗ មានស្ពះទិនរថជាដើម ដែលភីលៀងជាដើមឱ្យបរិភោគភោជនាហារដែលមានរសឆ្ងាញ់ល្អ ឈ្មោះថា អ្នកដែលពួកជនចិញ្ចឹមបីបាច់មកដោយសេចក្ដីសុខ ។

ប្រើនបទថា ន ត្វំ តាត សុទិន្ន កិញ្ចិ ទុក្ខស្ស ជានាសិ : ឯសុទិន្នកូន បាឯងមិនដែលស្គាល់ទុក្ខបន្តិចបន្តួចសោះឡើយ សេចក្ដីថា នៃកូនសុទិន្ន អ្នកឯង រមែងមិនដឹងចំណែកតូចនៃទុក្ខណា ៗ សូម្បីត្រឹមតែតិចតួចឡើយ ។ ម្យ៉ាងទៀត អធិប្បាយថា អ្នកឯង រមែងមិនបានសោយអ្វី ៗ ដោយសេចក្ដីទុក្ខ ។ ពាក្យថា ទុក្ខស្ស នេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថតតិយាវិភត្តិ ។ ក៏សេចក្ដីដឹងប្រព្រឹត្តទៅក្នុងអត្ថ គឺសេចក្ដីសោយ ។

ម្យ៉ាងទៀត អធិប្បាយថា អ្នកឯង រមែងរលឹកដល់ទុក្ខអ្វី ៗ មិនបាន ៗ ពាក្យថា **ទុក្ខស្ស** នេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ ក៏សេចក្តីដឹងប្រព្រឹត្តទៅក្នុងអត្ថ គឺ សេចក្តីរលឹក ។

សូម្បីក្នុងវិកប្បទាំងពីរ គប្បីឃើញការលុបវិភត្តិដែលស្មើគ្នានៃបទខាងដើម ដោយបទខាងចុងចេញ ។ ពាក្យតាមដែលពោលមកហើយទាំងអស់នោះ អ្នកសិក្សាគួរជ្រាបតាមគម្ពីរសព្ទសាស្ត្រ ។

ប្រើនបទថា **មរណេនបិ មយន្តេ អកាមកា វិនា ភវិស្សាម : ទោះបីបាឯងស្លាប់ក្តី យើងក៏មិនចង់ព្រាត់ប្រាសចាកបាឯងដែរ** សេចក្តីថា សូម្បីយើងទាំងពីរ នៅមានជីវិត អ្នកឯងនឹងគប្បីស្លាប់សោត, សូម្បីដោយសេចក្តីស្លាប់របស់អ្នកឯងនោះ យើងទាំងពីរ ក៏មិនត្រូវការ គឺមិនប្រាថ្នា ឈ្មោះថា នឹងមិនព្រមវៀរ (ឱ្យអ្នកឯងស្លាប់) តាមសេចក្តីពេញចិត្តរបស់ខ្លួន, អធិប្បាយថា យើងទាំងពីរនឹងប្រសព្វសេចក្តីព្រាត់ប្រាស់ចាកអ្នកឯងមិនបាន ។

ប្រើនបទថា **កឹ បន មយំ តំ : យើង...បាឯង...ម្តេចបាន** សេចក្តីថា កាលជាដូច្នោះ ក៏ហេតុអ្វីហ្ន៎ នឹងជាហេតុឱ្យយើងទាំងពីរអនុញ្ញាតឱ្យអ្នកឯង ដែលនៅមានជីវិត (ចេញបួសជាបព្វជិត) ។ ម្យ៉ាងទៀត ក្នុងបទថា **កឹ បន មយំ តំ** នេះ គប្បីឃើញសេចក្តីយ៉ាង

នេះថា ក៏ព្រោះហេតុអ្វីហ្ន៎ យើងទាំងពីរ ទើបនឹងព្រមអនុញ្ញាតឱ្យអ្នកឯងដែលនៅមានជីវិត ។

បទថា តត្ថេវ : ក្នុងទីនោះឯង សេចក្ដីថា (សុទិន្នកលន្ទបុត្រនោះ ដេកចុះ) ក្នុងស្ថានទីដែលគេឈរ ដែលមាតាបិតាមិនអនុញ្ញាតឱ្យគេបួសនោះឯង ។

បទថា អនន្តរហិតាយ : ប្រាសចាកគ្រឿងកម្រាល សេចក្ដីថា លើផ្ទៃដីដែលមិនបានក្រាលដោយកម្រាលអ្វី ៗ ។

[១២] បទថា បរិចារេហិ : និងឱ្យគេបម្រើហើយ សេចក្ដីថា អ្នកឯងចូរឱ្យពួកអ្នកច្រៀង អ្នករាំ និងអ្នកបាំជាដើម បម្រើចំពោះខ្លួនហើយ ចូរឱ្យឥន្ទ្រិយ (គឺ រាងកាយគ្រប់ចំណែក) ប្រព្រឹត្តទៅ គឺ ឱ្យសញ្ចរទៅតាមសប្បាយ រួមនឹងសម្លាញ់ទាំងឡាយ ក្នុងពួកអ្នកច្រៀងជាដើមទាំងនោះ, អធិប្បាយថា អ្នកឯងចូរនាំអ្នកជាដើម ចូលមក មក

មកនេះនិងតាមមកនេះចុះ ។

ម្យ៉ាងទៀត បទថា បរិចារេហិ សេចក្ដីថា អ្នកឯងចូរឱ្យពួកអ្នកច្រៀងអ្នករាំ និងអ្នកបាំជាដើម បម្រើចំពោះខ្លួនហើយ ចូរលេង គឺ

ចូរចូលទៅសមាគម បានដល់ ចូររីករាយរួមនឹង នឹង សម្លាញ់ទាំងឡាយចុះ, មានពាក្យអធិប្បាយទុកថា ចូរចកឡេចុះ ដូច្នេះខ្លះ ។

ពីរបទថា កាមេ បរិភុញ្ជន្តោ : ចូរបរិភោគកាម សេចក្តីថា អ្នកឯងចូរបរិភោគភោគទ្រព្យទាំងឡាយ រួមនឹងបុត្រ និងភរិយារបស់ខ្លួនចុះ ។

ពីរបទថា បុញ្ញានិ ករោន្តោ : ធ្វើបុណ្យចុះ សេចក្តីថា អ្នកឯងចូរប្រារព្ធព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃហើយ បំពេញកុសលធម៌ទាំងឡាយ ដែលជាគ្រឿងជម្រះមកសុគតិឱ្យបរិសុទ្ធិដោយល្អ មានការបំពេញទានជាដើមចុះ ។

ពីរបទថា តុណ្ហី អហោសិ : ក៏ស្ងៀមនៅ សេចក្តីថា សុទិន្នកលន្ទបុត្រ ដើម្បីកាត់ភាពជាប់ជំពាក់ដោយការនិយាយចរចា ទើប ទើប ចបានវៀរការសន្ទនាប្រាស្រ័យចេញ ។

## សម្លាញ់ទៅហាមមិនឱ្យសុទិន្នបួសមិនសម្រេច

[១៣] គ្រានោះ មាតាបិតារបស់សុទិន្ន និយាយ (លួងលោម) ដល់ ៣ ដង កាលមិនបានសូម្បីត្រឹមតែពាក្យតប ទើបបង្គាប់ឱ្យហៅពួកសម្លាញ់ (របស់គេ) មកហើយបង្គាប់ថា សុទិន្នអ្នកជាសម្លាញ់របស់

ពួកលោកនោះ មានសេចក្ដីប្រាថ្នានឹងបួស ពួកលោកចូរជួយហាមគេផង ។ សម្លាញ់សម្លាញ់ទាំងនោះចូលទៅរកគេហើយ ក៏បាននិយាយ (អង្វរ) ដល់ ៣ ដង តែសុទិន្នក៏បានស្ងៀមព្រងើយស្ងៀមចំពោះ (មុខ) សម្លាញ់ទាំងនោះ ។ ព្រោះហេតុនោះ លោកព្រះឧបាលីថេរៈទើបបានពោលទុកថា អថខោ សុទិន្នស្ស កលន្ទបុត្តស្ស សហាយកា ។បេ ។ តុណ្ហី អហោសិ : លំដាប់នោះឯង ពួកសម្លាញ់សុទិន្នកលន្ទបុត្រ ។ល ។ សុទិន្នកលន្ទបុត្រ ក៏ស្ងៀមនៅ ។

## សម្លាញ់ទៅសូមអនុញ្ញាតមាតាបិតាឱ្យសុទិន្នបួស

គ្រានោះ ពួកសម្លាញ់របស់សុទិន្ននោះ បានមានសេចក្ដីរំពឹងដូច្នេះថា "បើថា សុទិន្ន កាលមិនបានបួស នឹងស្លាប់, នឹងមិនមានគុណអ្វី, តែមាតាបិតា នឹងបានឃើញគេដែលបួសហើយម្ដងម្កាល, សូម្បីពួកយើងក៏នឹងបានឃើញ, មួយទៀត ដែលឈ្មោះថា ការបួសនោះ ជាភារៈធ្ងន់, អ្នកបួសនឹងត្រូវកាន់បាត្រ ដើរត្រាច់បិណ្ឌបាតរាល់ ៗថ្ងៃ, ព្រហ្មចរិយៈមានការដេកម្ដង ឆាន់ម្ដង ជាកិច្ចដែលធ្វើបានលំបាកយ៉ាងក្រៃលែង, និងសុទិន្ននេះ ជាអ្នកនៅក្មេងខ្ចី ជាជាតិជនអ្នកក្រុង, គេកាលមិនអាចនឹងប្រព្រឹត្តព្រហ្មចរិយៈនោះបាន ក៏នឹងវិលត្រឡប់មកកាន់ផ្ទះនេះទៀតតែម្ដង,

ណ្ហើយចុះ ពួកយើង នឹងសូមឱ្យមាតាបិតារបស់គេអនុញ្ញាតឱ្យគេបួសចុះ” ។ សម្លាញ់ទាំងនោះ ក៏បានធ្វើដូចយ៉ាងនោះហើយឯង ។

## មាតាបិតាអនុញ្ញាតឱ្យសុទិន្នបុត្រប្រុសបួស

ចំណែកមាតាបិតា ក៏បានអនុញ្ញាតឱ្យគេបួស ។ ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបបានពោលទុកថា អថខោ សុទិន្នស្ស កលន្ទបុត្តស្ស សហាយកា យេន សុទិន្នស្ស កលន្ទបុត្តស្ស មាតាបិតរោ : គ្រានោះ ឯង មាតាបិតាទាំងឡាយ របស់សុទិន្នកលន្ទបុត្រនៅក្នុងទីណា សំឡាញ់ទាំងឡាយ របស់សុទិន្នកលន្ទបុត្រ ។បេ ។ [១៤] អនុញ្ញាតោសិ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយ : អ្នកឯងមាតាបិតាព្រមព្រៀងអនុញ្ញាតឱ្យចេញចាកផ្ទះបួសក្នុងព្រះសាសនាហើយ ។

បទថា ហដ្ឋោ : មានចិត្តរីករាយ គឺ អ្នកត្រេកអរហើយ ។

បទថា ឧទគ្គោ : ដូចជាអណ្ដែតឡើង គឺ អ្នកមានកាយ និងចិត្តរំភើបឡើងដោយអំណាចបីតិ ។

បទថា គតិថាហំ : ពីរបីថ្ងៃ គឺ អស់ថ្ងៃបន្តិចបន្តួច ។

ពីរបទថា ពលំ គាហេត្វា : សម្រាកយកកម្លាំង សេចក្តីថា សុទិន្នកលន្ទបុត្រនោះ កាលបរិភោគភោជនាហារដែលសប្បាយ និង បរិហាររាងកាយដោយកិច្ចមានការអប់ និងផ្ងូតទឹកជាដើម ឱ្យកើតកម្លាំង កាយហើយថ្វាយបង្គំមាតាបិតា លាពពួកញាតិអ្នកមានមុខពេញដោយទឹក ភ្នែក ហើយចូលទៅគាល់ព្រះមានព្រះភាគដរាបដល់ទីគង់នៅ ។ល។ បានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់បំបួសខ្ញុំព្រះអង្គផងចុះ" ។

## ព្រះមានព្រះភាគបង្គាប់ឱ្យភិក្ខុបំបួសសុទិន្នកលន្ទបុត្រ

ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុមួយរូប អ្នកត្រាច់បិណ្ឌបាតជាវត្ត ដែលឈរគាល់នៅក្នុងទីជិតមកថា "ម្នាលភិក្ខុ បើដូច្នោះ លោកចូរឱ្យ សុទិន្នបព្វជ្ជា និងឧបសម្បទាចុះ" ។

ភិក្ខុនោះ ទូលទទួលចំពោះព្រះមានព្រះភាគថា "ល្អណាស់ ព្រះ អង្គ" ហើយ បានឱ្យសុទិន្នកលន្ទបុត្រ (ដែលព្រះជិនស្រីទ្រង់ប្រទានជា សទ្ធិវិហារិក) បព្វជ្ជា និងឧបសម្បទាហើយ ។ ព្រោះហេតុនោះ ទើប

ព្រះឧបាលីថេរៈពោលទុកថា "សុទិន្នកលន្ទបុត្រ បានបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគហើយ" ។

មួយទៀត វៀរលែងតែក្នុងអធិការពោលពីសុទិន្នភិក្ខុបានទទួលបព្វជ្ជា និងឧបសម្បទានេះចេញ ការបព្វជ្ជានិងឧបសម្បទា ព្រះអដ្ឋកថាចារ្យទាំងឡាយ ក៏បានពោលទុកហើយក្នុងអដ្ឋកថាទាំងពួង ។ ចំណែកខ្ញុំព្រះករុណានឹងពោល (បព្វជ្ជានិងឧបសម្បទានោះ) ក្នុងខន្ធកៈដោយអំណាចនៃព្រះបាលីតាមដែលតាំងទុកហើយនោះឯង មិនមែនពោលតែបព្វជ្ជា និងឧបសម្បទាក្នុងខន្ធកៈតែម៉្យាងប៉ុណ្ណោះទេ សូម្បីពាក្យដទៃណាដែលគួរពោលក្នុងខន្ធកៈក្តី ក្នុងគម្ពីរបរិវារក្តី ដែលព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលទុកហើយក្នុងវិភង្គ ខ្ញុំព្រះករុណានឹងពោលពាក្យនោះទុកក្នុងទីនោះ ៗឯងទាំងអស់ ។ ពិតមែន កាលខ្ញុំព្រះករុណាពោលតាមដែលអធិប្បាយមកយ៉ាងនេះ ការពណ៌នា ក៏ឈ្មោះថា ខ្ញុំព្រះករុណាធ្វើហើយដោយលំដាប់នៃព្រះបាលីតែម្តង ។ ព្រោះហេតុនោះ អ្នកសិក្សាទាំងឡាយ ដែលមានសេចក្តីត្រូវការដោយការវិនិច្ឆ័យនោះ ៗ ត្រូវតមើលវិន័យសំវណ្ណនានេះ ដោយលំដាប់ព្រះបាលីនោះឯង ក៏នឹងដឹងការវិនិច្ឆ័យដ៏សេសបានល្អ ដូច្នេះឯង ។

បទថា អចិរូបសម្បន្នោ : បានឧបសម្បទាហើយមិនយូរប៉ុន្មាន គឺ សុទិន្នភិក្ខុនោះ ជាអ្នកឧបសម្បទាហើយមិនយូរ មានពាក្យអធិប្បាយថា ដោយកាលមិនយូរពេកទេ តាំងពីឧបសម្បទាមកទុំះឯង ។

បទថា ឯវរូបេ : មានសភាពយ៉ាងនេះ គឺ មានចំណែកយ៉ាងនេះ បានដល់ មានជាតិយ៉ាងនេះ ។

បទថា ធុតគុណេ : ធុតង្គគុណ បានដល់ គុណដែលជាគ្រឿងកម្ចាត់កិលេស ។

ពីរបទថា សមាទាយ វត្តតិ : ប្រព្រឹត្តសមាទាន សេចក្ដីថា (សុទិន្នភិក្ខុនោះ) សមាទានគឺ ទទួលយក ប្រព្រឹត្ត ត្រាច់ទៅ ។

ពីរបទថា អារញ្ញិកោ ហោតិ : ជាអ្នកនៅក្នុងព្រៃ សេចក្ដីថា ហាម សេនាសនៈក្នុងស្រុកចេញហើយ ជាអ្នកពេញចិត្តនៅព្រៃជាវត្ត ដោយអំណាចសមាទានអារញ្ញិកធុតង្គ ។

បទថា បិណ្ឌបាតិកោ : ប្រព្រឹត្តបិណ្ឌបាត សេចក្ដីថា ហាមភត្ត ១៤ យ៉ាង ដោយការហាមអតិរេកលាភចេញហើយ ជាអ្នកពេញចិត្តត្រាច់បិណ្ឌបាតជាវត្ត ដោយអំណាចសមាទានបិណ្ឌបាតិកធុតង្គ ។

បទថា **បិណ្ឌចារិកោ** : ប្រើប្រាស់សំពត់បង្សុកូល សេចក្ដីថា ហាមគហបតីចីវរចេញហើយ ជាអ្នកពេញចិត្តទ្រទ្រង់សំពត់បង្សុកូលជាវត្ត ដោយអំណាចសមាទានបង្សុកូលិកធុតង្គ ។

បទថា **សបទានចារិកោ** : ត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះ សេចក្ដីថា ហាមការត្រាច់ស្មាក់ស្មើរចេញហើយ ជាអ្នកពេញចិត្តត្រាច់តាមលំដាប់ប្រកមកជាវត្ត គឺ ចូលទៅដើម្បីភិក្ខាតាមលំដាប់ផ្ទះ ដោយអំណាចសមាទានសបទានចារិកធុតង្គ ។

បទថា **វជ្ជិគាមំ** : ក្នុងស្រុកវជ្ជី សេចក្ដីថា ( សុទិន្នភិក្ខុនោះចូលអាស្រ័យ ) ពួកអ្នកស្រុកវជ្ជី ឬពួកអ្នកស្រុកក្នុងដែនវជ្ជី ។

## ញាតិរបស់សុទិន្នភិក្ខុ ក្នុងក្រុងវេសាលីមានសម្បត្តិច្រើន

[១៥] ក្នុងពាក្យជាដើមថា **អឌ្ឍា មហទ្ធនា** មានវិនិច្ឆ័យដូច្នេះ ៖

( ញាតិទាំងឡាយរបស់យើងក្នុងក្រុងវេសាលី ) ឈ្មោះថា **អឌ្ឍា** : ជាអ្នកស្តុកស្តម ព្រោះមានគ្រឿងឧបភោគ និងឧបករណ៍នៃគ្រឿងបរិភោគច្រើន ។ មានពាក្យអធិប្បាយថា ពិតមែន គ្រឿងឧបភោគ និង

ឧបករណ៍នៃគ្រឿងឧបភោគ របស់ញាតិទាំងនោះ ៗ មានច្រើន គឺ មានក្រាស់ក្រែល ទាំងជាវត្ថុមានសារៈផង ។

ឈ្មោះថា **មហទ្ធនា : មានទ្រព្យច្រើន** ព្រោះមានទ្រព្យដែលកប់ទុកច្រើន ។

បទថា **មហាភោគោ : មានភោគច្រើន** ឈ្មោះថា អ្នកមានភោគៈច្រើន ព្រោះមានភោគៈ គឺ វត្ថុដែលជាស្បៀង (សម្រាប់ចាយវាយ) ប្រចាំថ្ងៃច្រើន ។

ឈ្មោះថា **បហូតជាតរូបរជតា : មានមាសប្រាក់ច្រើន** ព្រោះក្រៅអំពីគ្រឿងឧបភោគដទៃ ក៏នៅមានមាសនិងប្រាក់ទុំះឯងច្រើនណាស់ ។

ឈ្មោះថា **បហូតវិត្តូបករណោ : មានឧបករណ៍ច្រើន** ព្រោះមានឧបករណ៍នៃទ្រព្យដែលជាគ្រឿងប្រដាប់ ដែលធ្វើបីតិបាមោជ្ជឱ្យកើតមានច្រើនណាស់ ។ គប្បីជ្រាបថា ជាអ្នកមានទ្រព្យ និងអង្ករច្រើនណាស់ ព្រោះទ្រព្យ និងអង្ករដែលផ្លាស់ប្តូរគ្នា ដោយអំណាចការទិញលក់ មានចំនួនច្រើន ។

ពីរបទថា **សេណាសនំ សំសាមេត្វា : រៀបចំសេនាសនៈ** សេចក្តីថា រក្សាសេនាសនៈទុកហើយ អធិប្បាយថា ចាត់តាំង

សេនាសនៈនោះទុកយ៉ាងរៀបរយ ដោយប្រការដែលសេនាសនៈនឹងមិនវិនាសបាត់បង់ ។

## ញាតិនាំភត្តាហារទៅប្រគេនសុទិន្នភិក្ខុ ៦០ ថាស

ពីរបទថា **សដ្ឋិមត្តេ ថាលិបាកេ : ប្រមាណហុកសិបថាស** សេចក្ដីថា (ញាតិទាំងឡាយរបស់សុទិន្នភិក្ខុ នាំភត្តាហារទៅប្រគេនសុទិន្នភិក្ខុ) មានប្រមាណ ៦០ ថាស ដោយកំណត់នៃការគណនា ។

ក៏បណ្ដាភត្ត ៦០ ថាសនេះ ចំពោះតែមួយថាស ៗ ដាក់ភត្តល្មមដល់ភិក្ខុ ១០ រូប ភត្តសូប្បទាំងអស់នោះ ភិក្ខុ ៦០០ រូបល្មមឆ្អែត ។

ក្នុងពីរបទថា **ភត្តាភិហារំ អភិហរឹសុ : នាំនូវភោជន** នេះ មានវិគ្រោះដូច្នេះ ៖

អាហារដែលឈ្មោះថា **អភិហារ** ព្រោះអត្ថថា ដែលបុគ្គលនាំទៅចំពោះ ។ នាំអ្វីទៅ ? នាំភត្តទៅ ។ អភិហារ គឺ ភត្តនុ៎ះឯង ឈ្មោះថា ភត្តាភិហារ ។ នូវភត្តាភិហារនោះ ។

បទថា **អភិហរឹសុ : នាំ** សេចក្ដីថា ញាតិទាំងឡាយនាំភត្តាហារទៅទុកចំពោះមុខ ។ អធិប្បាយថា កាន់យកហើយ បានទៅកាន់សំណាក់របស់សុទិន្នភិក្ខុនោះ ។

សួរថា ភត្តនោះ មានប្រមាណប៉ុនណា ?

ឆ្លើយថា មាន ៦០ ថាស ។ ព្រោះហេតុនោះ ទើបព្រះឧបាលីថេរៈពោលទុកថា "ពួកញាតិទាំងនោះ ក៏នាំនូវភោជនប្រមាណ ៦០ សម្រាប់ទៅប្រគេនសុទិន្នភិក្ខុដ៏មានអាយុ" ។

ពីរបទថា **ភិក្ខូនំ វិស្សជ្ជេត្វា : ចែកចាយដល់ភិក្ខុទាំងឡាយ** សេចក្ដីថា សុទិន្នភិក្ខុនោះ មានសេចក្ដីប្រាថ្នានឹងត្រាច់ទៅតាមលំដាប់ប្រកមកដោយខ្លួនឯង ព្រោះជាអ្នកកាន់ត្រាច់បិណ្ឌបាតជាវត្តយ៉ាងឧក្រិដ្ឋ ទើបបានលះបង់ គឺ ប្រគេន (ភត្តាហារមានប្រមាណ ៦០ ថាសនោះ) ដើម្បីជារបស់ឆាន់ដល់ភិក្ខុទាំងឡាយ ។ ពិតមែន លោកដ៏មានអាយុនេះដាក់ចិត្តថា ភិក្ខុទាំងឡាយនឹងបានលាភ និងយើងក៏មិនលំបាកដោយបិណ្ឌបាតហើយទើបមក ដើម្បីប្រយោជន៍នោះឯង ។ ព្រោះដូច្នោះ សុទិន្នភិក្ខុនោះកាលធ្វើកិច្ចដែលសមគួរដល់ការមករបស់ខ្លួន ទើបបានលះបង់ដល់ភិក្ខុទាំងឡាយ ចំណែកខ្លួនឯងក៏ចូលទៅបិណ្ឌបាត ។ នាងទាសីរបស់ពួកញាតិ ឈ្មោះថា ញាតិទាសី ។

## អធិប្បាយរឿងនំផ្អូម

បទថា **អាភិទោសិកំ : ផ្អូម** បានដល់ នំកុម្មាសដែលរក្សាទុកយូរ គឺ កន្លងទៅបានមួយយប់ហើយ ជារបស់ផ្អូម ។

ក្នុងបទថា **អាភិទោសិកំ** នោះ មានសេចក្តីចំពោះបទដូចតទៅនេះ ៖

នំកុម្មាស ដែលឈ្មោះថា **អភិទោសៈ** ព្រោះអត្ថថា ត្រូវទោសគឺផ្អូមគ្របសង្កត់ ។ អភិទោសៈនុ៎ះឯង ឈ្មោះថា អាភិទោសិកៈ ។ ម្យ៉ាងទៀត សញ្ញា គឺអាភិទោសិកៈនេះ ជាសញ្ញាគឺ ឈ្មោះនៃនំកុម្មាស ដែលកន្លងទៅបានមួយយប់ហើយ ។ នូវនំកុម្មាស ឈ្មោះអាភិទោសិកៈនោះ ។

បទថា **កុម្មាសំ : នំកុម្មាស** បានដល់ នំកុម្មាសដែលគេធ្វើដោយអង្ករស្រូវជំណើប ។

ពីរបទថា **ឆឌ្ឌេតុកាមា ហោតិ : មានប្រាថ្នាដើម្បីចោល** សេចក្តីថា នំកុម្មាសនោះ ជារបស់មិនគួរបរិភោគ ដោយហោចទៅសូម្បីពួកទាសនិងកម្មករ ទាំងដល់ហ្វូងគោ ព្រោះដូច្នោះ នាងទាសីទើបមានបំណងនឹងចាក់នំកុម្មាសនោះ ចោលទៅខាងក្រៅ ដូចចាក់សម្រាមចោលដូច្នោះ ។

បទថា **សចេ តំ** កាត់បទជា **សចេ ឯតំ : បើនំនោះ** ។

សុទិន្នភិក្ខុ ហៅទាសីរបស់ញាតិថា នែប្អូនស្រី ដោយអំណាច អរិយវោហារ ។

បទថា ឆឌ្ឌនីយធម្មំ : ជារបស់ចោលហើយ គឺ មានការត្រូវចោលជាសភាព ។ មានពាក្យអធិប្បាយទុកថា នែប្អូនស្រី បើរបស់នោះ មានការនឹងត្រូវចោលក្នុងខាងក្រៅជាធម្មតា គឺ ជារបស់ដែលគេលះបង់សេចក្ដីហួងហែងហើយសោត នាងចូរគៀរចូលក្នុងបាត្ររបស់យើងនេះចុះ ។

សួរថា ក៏បព្វជិត រមែងបាន ដើម្បីនឹងនិយាយយ៉ាងនេះឬ ? មិនជាវិញ្ញត្តិ (ការសូម) ឬបយុត្តវាចា (វាចានិយាយសូមជាប់ដោយបច្ច័យ) ឬ ? ឆ្លើយថា មិនជា (ទាំងពីរយ៉ាង) ។

សួរថា ព្រោះហេតុអ្វី ទើបមិនជាវិញ្ញត្តិ ?

ឆ្លើយថា ព្រោះជារបស់ដែលគេលះបង់សេចក្ដីហួងហែងហើយ ។

ពិតមែន នឹងនិយាយថា លោកចូរឱ្យ គឺ ចូរនាំវត្ថុដែលមានការនឹងត្រូវចោលជាធម្មតា គឺ ជារបស់ដែលគេលះបង់សេចក្ដីហួងហែងហើយ ដែលពួកម្ចាស់របស់មិនមានសេចក្ដីស្តាយទាំងអស់ មកគៀរចូលក្នុងបាត្រនេះចុះ ដូច្នេះ ក៏គួរ ។ ពិតមែន សូម្បីព្រះរដ្ឋបាលភិក្ខុ ដែលប្រព្រឹត្តអរិយវង្សយ៉ាងល្អប្រសើរ ក៏បាននិយាយថា លោកចូរគៀរនំកុម្មាសដែលមាន ដែលនឹងត្រូវចោលជាធម្មតាចុះក្នុងបាត្ររបស់យើង

នេះចុះ ។ ព្រោះដូច្នោះ របស់វត្ថុណាមានការត្រូវបោលជាធម្មតាបែបនេះ គឺ របស់វត្ថុដទៃមានឫសឈើផ្លែឈើនិងភេសជ្ជៈក្នុងព្រៃជាដើម ដែលមិនមានអ្នកណាហួងហែងក្ដី ភិក្ខុគួរឱ្យនាំវត្ថុនោះទាំងអស់មក ហើយឆាន់បានតាមសប្បាយ មិនគួរនឹងរង្កៀស ។

## សុទិន្នភិក្ខុបួសបាន ៨ ឆ្នាំ នាងទាសីចាំអវយវៈខ្លះបាន

បទថា **ហត្ថានំ** : នូវដៃ សេចក្ដីថា នាងទាសីរបស់ញាតិ បានកាន់យកគ្រឿងដៃទាំងពីររបស់សុទិន្នភិក្ខុ ដែលបង្អោនបាត្រចូលទៅដើម្បីទទួលភិក្ខា តាំងពីកដៃទៅ ។

បទថា **បាទានំ** : នូវជើង សេចក្ដីថា នាងទាសីរបស់ញាតិបានកាន់យកគ្រឿងជើងទាំងពីរចាប់ផ្ដើមតាំងពីជាយសំពត់ស្បៀកទៅ ។

បទថា **សរស្ស** : **សំឡេង** សេចក្ដីថា កាលសុទិន្នភិក្ខុ បញ្ចេញវាចាថា "នែប្អូនស្រីបើរបស់នោះ" ដូច្នេះជាដើម នាងទាសីរបស់ញាតិក៏ចាំសំឡេង (របស់លោក) បាន ។

ពីរបទថា **និមិត្តំ អគ្គហេសិ** : **បានស្គាល់ជាក់ច្បាស់** សេចក្ដីថា នាងទាសីរបស់ញាតិបានកាន់យកគឺ ចាំបាន សំដៅសេចក្ដីថា កំណត់អាការដែលខ្លួនធ្លាប់សង្កេតបានក្នុងគ្រាដែលលោកនៅជាគ្រហស្ថ ។

ពិតមែន សុទិន្នភិក្ខុបួសក្នុងវស្សាទី ១២ របស់ព្រះមានព្រះភាគ ក្នុងវស្សាទី ២០ របស់ព្រះមានព្រះភាគ បានចូលទៅបិណ្ឌបាតឯត្រកូលញាតិខ្លួនឯង មានវស្សាបាន ៨ តាំងពីបួសមក ។ ព្រោះហេតុនោះ នាងទាសីរបស់ញាតិនោះ ឃើញលោកហើយទើបចាំមិនបាន តែកាន់យកក្រយៅ ( និមិត្ត ) បានដោយប្រការដូច្នេះ ។

ប្រើនបទថា សុទិន្នស្ស មាតរំ ឯតទវោច : ក៏និយាយនឹងមាតារបស់សុទិន្ន សេចក្តីថា នាងទាសីរបស់ញាតិ មិនអាចនឹងនិយាយពាក្យជាដើមថា "លោកម្ចាស់ លោកឫហ្ន៎ គឺ សុទិន្នភិក្ខុជានាយរបស់ខ្ញុំព្រះករុណាម្ចាស់" ដូច្នេះ នឹងបុត្រប្រុសជានាយ ( របស់ខ្លួន ) ដែលចូលបួសហើយ ដោយសេចក្តីគោរពក្រៃលែង ទើបប្រញាប់ត្រឡប់ចូលទៅក្នុងផ្ទះ ហើយបានប្រាប់ដំណឹងនេះចំពោះមាតារបស់សុទិន្នភិក្ខុ ។

សព្ទថា យគ្ឃេ : បពិត្រអ្នកម្ចាស់ ជានិបាត ចុះក្នុងអត្ថនៃពាក្យពោលប្រាប់ ។

សព្ទថា ជេ : នែហង ដែលមាននៅក្នុងបទថា សចេ ជេ សច្ចំ : នែហង បើហងឯងនិយាយពាក្យពិតមែន នេះ ជានិបាតចុះក្នុងអត្ថនៃពាក្យហៅ ។ ពិតណាស់ ជនទាំងឡាយក្នុងប្រទេសនោះ រមែងស្រែកហៅស្រីបម្រើដោយភាសាយ៉ាងនោះ ។ ព្រោះហេតុនោះ ក្នុងពាក្យថា

សចេ ផេ សច្ចំ នេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា នាងទាសីដ៏ចម្រើន បើនាងឯងនិយាយពិតសោត ។

## ពួកបព្វជិតមិនអង្គុយឆាន់ក្នុងទីមិនសមគួរដូចអ្នកសូមទាន

ពីរបទថា អញ្ញតរំ កុឌ្ឌមូលំ : ប្របជញ្ជាំងសាលា១ សេចក្ដីថា បានឮថា ក្នុងប្រទេសនោះក្នុងផ្ទះរបស់ពួកជនអ្នកជាទានបតី មានសាលាឆាន់, និងក្នុងសាលាឆាន់នេះ គេក៏ចាត់ចែងក្រាលអាសនៈទុក ទាំងបានតម្កល់ទឹកឆាន់ និងទឹកប្រើប្រាស់ទុកសព្វគ្រប់ ។ បព្វជិតទាំងឡាយកាលត្រាច់ទៅបិណ្ឌបាតហើយ (ត្រឡប់មក) អង្គុយឆាន់ក្នុងសាលានោះ បើប្រាថ្នានឹងទទួលយកភត្តាហារ ក៏ទទួលយកភត្តាហាររបស់ពួកជនអ្នកជាទានបតីដែលនៅមាន ។

ព្រោះដូច្នោះ សូម្បីស្ថានទីនោះ គួរជ្រាបថា បានដល់ ក្បែរជញ្ជាំងផ្ទះមួយកន្លែងជិតសាលាឆាន់នេះ នៃត្រកូលមួយ ។ ពិតមែនបព្វជិតទាំងឡាយ រមែងមិនអង្គុយឆាន់ក្នុងស្ថានដែលមិនសមគួរ ដូចពួកមនុស្សកំព្រានោះឡើយ ។

សព្ទថា **អត្ថិ** ដែលមាននៅក្នុងបទថា **អត្ថិ នាម តាត** នេះ ជានិបាតចុះក្នុងអត្ថថា មាន, និងសព្ទថា **នាម** (ដែលមានក្នុងបទនោះ) ។ ក៏ជានិបាតចុះក្នុងអត្ថនៃពាក្យសួរ និងក្នុងអត្ថនៃសេចក្តីមើលងាយ ។

**បិតាតិះដៀលសុទិន្នភិក្ខុថា ឆាន់ទំផ្អូមដូចផឹកទឹកអម្រឹត**

ពិតមែន លោកពោលពាក្យអធិប្បាយនេះទុកថា (បិតានិយាយនឹងសុទិន្នភិក្ខុជាបុត្រប្រុសថា) "សុទិន្នកូន ទ្រព្យរបស់យើង ក៏នៅមានដែរមែនឬ ? ពួកយើងដែលមានកូនឯងជាបុត្រប្រុស មកអង្គុយឆាន់នំកុម្មាសដែលរក្សាទុកកន្លងមួយយប់នៅក្នុងទីដូច្នេះ នឹងគប្បីត្រូវពួកជនគេតិះដៀលថា ជាអ្នកមិនមានទ្រព្យមែនឬ ? ។

មួយទៀត សុទិន្នកូន បិតាក៏នៅមានជីវិតដែរ មែនឬ ? បិតាដែលមានឯងជាបុត្រប្រុស មកអង្គុយឆាន់នំកុម្មាសផ្អូមក្នុងទីដូច្នេះ និងត្រូវពួកជនគេតិះដៀលថា (មានបិតា) ស្លាប់ហើយមិនមែនឬ ? ។ មួយទៀត សុទិន្នកូន កូនឯងសម្គាល់ថា សមណគុណដែលកូនឯងបានព្រោះអាស្រ័យសាសនាមាននៅខាងក្នុងសន្តានចិត្តរបស់កូនឯង ដែលចម្រើនធំធាត់មកដោយរសនៃអាហារដ៏ល្អ កូនឯងនៅតែមិនរអើម ឆាន់នំកុម្មាសផ្អូម ដែលជារបស់គួរខ្ពើមរអើមនេះ ដូចផឹកទឹកអម្រឹតដូច្នោះ" ។

ក៏គហបតីនោះ ព្រោះត្រូវសេចក្តីទុក្ខបៀតបៀន កាលមិនអាចនឹងនិយាយរៀបរាប់សេចក្តីនោះឱ្យបរិបូណ៌បាន ទើបបានពោលពាក្យត្រឹមតែប៉ុណ្ណេះថា "**អត្ថិ នាម តាត សុទិន្ន អាភិទោសិកំ កុម្មាសំ បរិភុញ្ជិស្សសិ** : នែសុទិន្នកូន យើងជាអ្នកមានទ្រព្យច្រើន ថ្វីក៏លោកមកឆាន់នំកុម្មាសផ្អូមវិញ" ។

ចំណែកក្នុងពាក្យថា **អត្ថិ នាម តាត** ជាដើមនេះ អាចារ្យអ្នកគិតអក្សរទាំងឡាយ បានពោលលក្ខណៈនេះទុកដូច្នេះគឺ ៖

កាលមានអត្ថិសព្ទនៅក្នុងទីជិត (គឺនៅបទខាងមុខ) បណ្ឌិតទាំងឡាយទើបបានតែងពាក្យអនាគតកាលនោះទុកដូច្នេះថា **បរិភុញ្ជិស្សសិ** ដោយអំណាចសេចក្តីដែលមិនគួរជឿ និងអត់ទ្រាំមិនបាន ។

សេចក្តីនៃពាក្យអនាគតកាលនោះ មានដូច្នេះ គឺ ៖

ពាក្យថា "**អត្ថិ ឆាម តាត សុទិន្ន អាភិទោសិកំ កុម្មាសំ បរិភុញ្ជិស្សសិ** : **នែសុទិន្នកូន យើងជាអ្នកមានទ្រព្យច្រើន ថ្វីក៏លោកមកឆាន់ នំកុម្មាសផ្អូមវិញ**" មានអត្ថន័យថា ពុកមិនជឿ ទាំងអត់ទ្រាំនូវការឆាន់នេះ សូម្បីដែលឃើញប្រចក្ស ។

ពីរបទថា **តត្ថាយំ**[១] **អាភិទោសិកោ** : (**នំកុម្មាស**)**ផ្អូមនេះ** (**អាត្មាបាន**)**ពីផ្ទះនោះមក** សេចក្តីថា នំកុម្មាសផ្អូមនេះ អាត្មាបានមកពី

ផ្ទះរបស់ញោមនោះ ។ បាលីថា **តតោយំ ខ្វះ** ។ អាចារ្យពួកខ្វះសូត្រថា **តទាយំ ខ្វះ**, ពាក្យនោះមិនល្អ ។

ប្រើនបទថា **យេន សកបិតុ និវេសនំ : លំនៅបិតារបស់ខ្លួននៅក្នុងទីណា** សេចក្តីថា និវេសន៍នៃបិតារបស់ខ្លួន គឺ នៃបិតារបស់ខ្លួនតាំងនៅទីណា ព្រះថេរៈជាអ្នកប្រដៅផាយ ទើបបានទៅ(កាន់និវេសន៍នោះ) ព្រោះសេចក្តីស្រឡាញ់ក្នុងបិតានុ៎ះឯង ។

បទថា **អធិវាសេសិ : ទទួលនិមន្ត** សេចក្តីថា សូម្បីព្រះថេរៈជាអ្នកកាន់បិណ្ឌបាតជាវត្តយ៉ាងតឹងរឹងក៏ដោយ តែក៏នៅដាក់ចិត្តថា "បើយើងនឹងមិនទទួលសូម្បីភត្តាហារម្តងសោត, ពួកញាតិទាំងនោះ ក៏នឹងក្តៅក្រហាយក្នុងចិត្តយ៉ាងក្រៃលែង ទើបបានទទួលពាក្យអារាធនាដើម្បីអនុគ្រោះដល់ពួកញាតិ ។

---

១. ឆដ្ឋ. និងថៃ. តតាយំ; ឱ. តត្រាយំ ។

[១៦] បទថា **ឧបុញ្ញាបេត្វា : ឱ្យបង្ហាប់** គឺ បង្គាប់ឱ្យបូកនូវលាន ។

ក្នុងពីរបទថា **ឯកំ ហិរញ្ញស្ស : ប្រាក់១គំនរ** នេះ កហាបណៈគួរជ្រាបថា ប្រាក់ ។

មនុស្សប្រុសមិនខ្ពស់ពេក មិនទាបពេក ខ្នាតកណ្ដាល គប្បីជ្រាបថា បុរស ។

បទថា **តិរោករណីយំ : បាំងពីខាងក្រៅ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ, សេចក្ដីថា បិទបាំង ( គំនរទ្រព្យនោះ ) ទុកជុំវិញដោយរនាំងរាំងនន ម្យ៉ាងទៀត ជនទាំងឡាយ តែងធ្វើរនាំងទុកខាងក្រៅ ដោយរនាំងរាំងននោះ ហេតុនោះ រនាំងរាំងនននោះ ទើបឈ្មោះថា **តិរោករណីយំ** សេចក្ដីថា ចាត់ចែងរនាំងរាំងនននោះបាំងទុកដោយព័ទ្ធជាវង់ជុំវិញ ។

បទថា **តេន ហិ : បើដូច្នោះ** សេចក្ដីថា ព្រោះហេតុដែលសុទិន្នកូនយើង នឹងមកក្នុងថ្ងៃនេះ ។

សព្ទថា **ហិ** ជានិបាត ចុះក្នុងអត្ថត្រឹមតែថា ធ្វើបទឱ្យពេញ ។

ន័យមួយទៀត សព្ទថា **តេន** សូម្បីនេះ ជានិបាតចុះក្នុងអត្ថនៃពាក្យអញ្ជើញនុ៎ះឯង ។

ក្នុងបទថា **បុព្វណ្ហសមយំ : ក្នុងវេលាព្រឹក** នេះ លោកមិនបានពោលពាក្យប្រកាសវេលា ទុកក្នុងព្រះបាលី ក៏ពិតមែនហើយ, តែក៏គួរជ្រាបអធិប្បាយថា កាលគេប្រកាសវេលាហើយនុ៎ះឯង ព្រះថេរៈក៏បានទៅ ។

## បិតាប្រគល់ទ្រព្យដើម្បីឱ្យសុទិន្នត្រេកសឹក

បិតារបស់សុទិន្នភិក្ខុ បើកគំនរទ្រព្យទាំង ២ បង្ហាញប្រាប់ថា "សុទិន្នកូន នេះទ្រព្យមាតារបស់កូន" ជាដើម ។

បទថា **មាតុ : របស់មាតា** បានដល់ របស់ស្រីដែលឱ្យកើត ។

បទថា **មត្តិកំ : ទ្រព្យ** បានដល់ ទ្រព្យដែលមានមកអំពីខាងមាតា ។ អធិប្បាយថា ទ្រព្យចំណែកនេះ លោកយាយបានប្រគល់ឱ្យមាតារបស់កូនឯង ដែលមកកាន់ផ្ទះនេះ ។

ញោមបិតាពោលតិះដៀល(មតិកខាងស្រី) ដោយពាក្យថា **ឥត្ថិកាយ ឥត្ថីធនំ : សម្បត្តិដើមខាងស្រី** ទ្រព្យឈ្មោះថា ដែលត្រកូលខាងស្រីបានមក ដើម្បីប្រយោជន៍ដល់គ្រឿងលំអិតសម្រាប់ផ្លូតទឹកជាដើម ដែលជាគ្រឿងប្រើប្រាស់របស់ស្រីនុ៎ះឯង មានប្រមាណប៉ុនណា, កូនឯងចូរត្រួតមើលបរិមាណទ្រព្យខាងម្ដាយនោះជាមុនសិន ។

ម្យ៉ាងទៀត មានពាក្យអធិប្បាយថា សុទិន្នកូន នេះទ្រព្យមាតារបស់ឪពុក, ក៏ឯទ្រព្យនោះ ជាសម្បត្តិពីដើមចំណែកមាតា បិតាមិនបានឱ្យទុក គឺ ជារបស់ មាតាកូនឯងប៉ុណ្ណោះ ។

ក្នុងបទថា **អត្ថិកាយ ឥត្ថីធនំ : សម្បត្តិដើមខាងស្រី** នៅមាននេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា ក៏ទ្រព្យនេះ ប្រមូលបានមកដោយកសិកម្ម (និង) ពាណិជ្ជកម្មក៏មិនមែន ម្យ៉ាងទៀត ទ្រព្យចំណែកខាង

ស្រីគប្បីបានមក ឈ្មោះថា ឥត្ថីធនំ (ទ្រព្យខាងស្រី), គឺថា ទ្រព្យចំណែកខាងស្រីឯណា ដែលខាងស្រីអ្នកចេញពីត្រកូលញាតិ ទៅកាន់ត្រកូលស្វាមី គប្បីបានមកដើម្បីប្រយោជន៍ដល់គ្រឿងលំអិតសម្រាប់ផ្លូតទឹកជាដើម, ទ្រព្យចំណែកនោះក៏មានប្រមាណប៉ុណ្ណោះ ។

ប្រើនបទថា **អញ្ញំ បេត្តិកំ អញ្ញំ បិតាមហំ : នៅមានទ្រព្យសម្បត្តិដើមខាងប្រុសរបស់បិតា និងមត៌ករបស់ជីតាផ្សេងទៀត** សេចក្ដីថា ក៏ទ្រព្យចំណែកណាដែលជាមត៌ករបស់បិតា និងជីតាទាំងឡាយរបស់ឪពុក, ទ្រព្យចំណែកនោះ ក៏ជាចំណែកដទៃផ្សេងទៀត, ដែលគេកប់ទុក និងដែលប្រកបការជួញដូរ ក៏មាននៅច្រើនណាស់ ។

មួយទៀត បទថា **បិតាមហំ** ដែលមាននៅក្នុងពីរបទថា **បេត្តិកំ បិតាមហំ** នេះគួរជ្រាបថា ធ្វើការលុបបច្ច័យនៃតទ្ធិតចេញ ។ ម្យ៉ាងទៀត បាលីថា **បេតាមហំ** ដូច្នេះក៏មាន ។

ប្រើនបទថា **លព្ភា តាត សុទិន្ន ហីនយាវត្តិត្វា : សុទិន្នកូនបើលោកបានសឹកចេញជាគ្រហស្ថមកហើយ** សេចក្ដីថា សុទិន្នកូន កូនគួរលះភេទបព្វជិតដែលខ្ពង់ខ្ពស់ ដែលជាទង់ជ័យនៃព្រះអរិយៈចេញហើយត្រឡប់មក ដើម្បីភាពជាគ្រហស្ថដែលជាភេទថោកទាប នឹងគប្បីបានប្រើ

ប្រាស់ គឺ ទីងបានដើម្បីបរិភោគ ភោគសម្បត្តិ, កូនខ្វាចរាជអាជ្ញា ទើបបួសក៏មិនមែន ទាំងត្រូវកូនឯងចៀសបំណុលក៏មិនមែនឡើយ ។

ក៏ពាក្យថា តាត : ព្រោម ដែលមាននៅក្នុងបទថា តាត ន ឧស្សហាមិ នេះ សុទិន្នភិក្ខុនិយាយ (នឹងបិតា) ព្រោះសេចក្តីស្រឡាញ់អាស្រ័យផ្ទះ មិនមែននិយាយ ព្រោះតេជនៃសមណៈទេ ។

បទថា ន ឧស្សហាមិ : **អាត្មាមិនឧស្សាហ៍** គឺ អាត្មាមិនអាច ។

បទថា ន វិសហាមិ : **អាត្មាមិនហ៊ានទេ** បានដល់ អាត្មាមិនព្រម គឺ មិនមានសមត្ថភាព ។

ក៏ពាក្យថា វទេយ្យាម ខោ តំ គហបតិ : **គហបតិ អាត្មាភាពនឹងជម្រាបព្រោមបន្តិច** នេះ សុទិន្នភិក្ខុនិយាយ (នឹងបិតា) ព្រោះតេជនៃសមណៈ ។

បទថា ឆាតិកឡេយ្យាសិ : **ព្រោមអត់ទោសឱ្យអាត្មាភាព** សេចក្តីថា សេចក្តីស្រឡាញ់យ៉ាងណារបស់ព្រោម ដែលឋិតនៅហើយក្នុងអាត្មា, ព្រោមមិនគួរកាត់ផ្តាច់សេចក្តីស្រឡាញ់យ៉ាងនោះចេញ ដោយអំណាចសេចក្តីក្រោធ ។ មានពាក្យអធិប្បាយថា បើថា ព្រោមមិនគប្បីក្រោធសោត ។

លំដាប់នោះ លោកសេដ្ឋីមានចិត្តរីករាយ ដោយនឹកក្នុងចិត្តថា "បុត្រប្រុសរបស់យើង ប្រហែលជាមានបំណងចង់ធ្វើការសង្គ្រោះដល់យើងទេដឹង" ទើបបាននិយាយថា "និយាយចុះ សុទិន្នកូន" ។

សព្ទថា **តេនហិ :** **បើដូច្នោះ** ជានិបាត មានរូបស្រដៀងវិភត្តិ ចុះក្នុងអត្ថនៃពាក្យអញ្ជើញ ។

បទថា **តតោ និទានំ :** **ព្រោះតែទ្រព្យទាំងនោះជាហេតុ** គប្បីជ្រាបការអាទេស តំ បឋមាវិភត្តិ យ៉ាងនេះ គឺ តំ និទានំ តំ ហេតុកំ ជាតោ ។ និងក្នុងសមាសបទនោះមិនមានការលុប តោ បច្ច័យ ។

ភ័យមានរាជភ័យជាដើម ដែលលោកពោលទុកដោយន័យមានជាដើមថា ព្រះរាជាទាំងឡាយ ទ្រង់នឹងមិនរឹបអូសយកភោគសម្បត្តិរបស់យើង ឬយ៉ាងណា ឈ្មោះថា ភយក្តិ, អធិប្បាយថា ចិត្តភ័យខ្លាច ។

កាយញាប់ញ័រ(ក្តី) កាយក្រើក(ក្តី) សាច់បេះដូងលោតកន្ទ្រាក់(ក្តី) របស់បុគ្គលអ្នកត្រូវព្រះរាជាឬចោរដាក់ទណ្ឌកម្ម ដោយបញ្ជាថា "អ្នកឯងត្រូវតែឱ្យទ្រព្យ"ដូច្នេះ ឈ្មោះថា ឆម្ភិតត្តៈ (សេចក្តីតក់ស្លុត) ។

ព្រឺរោម គឺ មានចុងបះឡើងខាងលើ ក្នុងកាលមានភ័យកើតឡើង ឈ្មោះថា លោមហំស (ព្រឺរោម) ។

ការរក្សាយ៉ាងម៉ឺងម៉ាត់ ទាំងខាងក្នុងទាំងខាងក្រៅ ទាំងថ្ងៃទាំងយប់

ឈ្មោះថា អារក្ខា (ការថែរក្សា) ។

## បិតាបង្គាប់ភរិយាចាស់មកល្បួងឱ្យសុទិន្នភិក្ខុសឹក

ពីរបទថា តេនហិ វធុ : នែនាងក្រមុំ បើដូច្នោះ សេចក្តីថា សេដ្ឋីគហបតី កាលសម្តែងទ្រព្យហើយ ក៏មិនអាចទឹងល្បួងបុត្រប្រុសដើម្បីឱ្យសឹកដោយខ្លួនឯងបាន ទើបសម្គាល់ថា ឥឡូវនេះ ចំណងរបស់មនុស្សប្រុស ដូចមាតុគ្រាមមិនមាន ទើបបានហៅបុរាណទុតិយិកាភរិយារបស់សុទិន្នភិក្ខុនោះមកបង្គាប់ថា **តេនហិ វធុ** ជាដើម ។

បទថា បុរាណទុតិយិកំ : **ស្រីជាគូអំពីដើម** បានដល់ ស្រីជាគម្រប់ពីរដែលជាភរិយាពីអតីត គឺស្រីជាគូក្នុងកាលមុន គឺ ក្នុងកាលដែលសុទិន្នភិក្ខុនៅជាគ្រហស្ថ ។ អធិប្បាយថា បានដល់ ភរិយាធ្លាប់ជាស្រីរួមការសេពសុខដែលអាស្រ័យផ្ទះមកហើយ ។

បទថា តេនហិ : បើដូច្នោះ សេចក្តីថា ព្រោះហេតុដែលមិនមានចំណង (យ៉ាងដទៃ) ដូចមាតុគ្រាម ។

ពីរបទថា បាទេសុ គហេត្វា : បានប្រវាឱបជើងទាំងពីរ សេចក្តីថា ភរិយាចាស់បានចាប់ជើងទាំងពីរ (របស់សុទិន្នភិក្ខុ) ។ បទថា បាទេសុ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ ។ ម្យ៉ាងទៀត

សេចក្ដីថា ភរិយាចាស់បានចាប់សុទិន្នភិក្ខុនោះត្រង់ជើងទាំងពីរ ។

សួរថា ព្រោះហេតុអ្វី ទើបភរិយាចាស់បានពោលនឹងសុទិន្នភិក្ខុយ៉ាងនេះថា "បពិត្រអយ្យបុត្រ លោកប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុនៃស្រីអប្សរទាំងឡាយណា ស្រីអប្សរទាំងឡាយនោះ មានទ្រង់ទ្រាយប្រពៃ ដូចម្ដេចទៅ ?"

ឆ្លើយថា ព្រោះបានឮថា ក្នុងកាល ( បន្ទាប់ពីព្រះនន្ទបួស ) នោះ ពួកជនអ្នកមិនស្គាល់គុណនៃបព្វជ្ជា គ្រាឃើញខត្តិយកុមារខ្លះ ព្រាហ្មណកុមារខ្លះ សេដ្ឋីបុត្តខ្លះ ជាច្រើន ដែលនាំគ្នាលះមហាសម្បត្តិ ហើយចេញបួស ទើបសន្ទនាគ្នាឡើងថា ព្រោះហេតុអ្វី បានជាខត្តិយកុមារជាដើមទាំងនោះចេញបួស គ្រានោះ ជនពួកដទៃក៏និយាយគ្នាថា ខត្តិយកុមារជាដើមទាំងនោះចេញបួស ព្រោះហេតុនៃនាងទេពអប្សរទាំងឡាយ ដែលជាទេពធីតាបំរើ ។ ពាក្យនោះ ជាពាក្យដែលជនទាំងនោះបានឱ្យឮសុសសាយទៅហើយ ( តាមរឿងព្រះនន្ទនោះ ) ។ ភរិយាចាស់របស់សុទិន្នភិក្ខុនេះ បានកាន់យកពាក្យនោះ ទើបបានពោលយ៉ាងនោះ ។

ព្រះថេរៈ កាលនឹងជំទាស់ពាក្យរបស់ភរិយាចាស់នោះ ទើបបានពោលថា **ន ខោ អហំ ភគិនិ** : នែប្អូនស្រី អាត្មាមិនបានប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីស្រីអប្សរទាំងនោះទេ ។

បទថា សមុទាចរតិ : គ្រាន់តែហៅ សេចក្ដីថា រមែងហៅ គឺ រមែងពោល ។

ច្រើនបទថា តត្ថេវ មុច្ឆិតា បបតា : ក៏ជ្រប់ដួលដេកក្នុងទីនោះឯង សេចក្ដីថា ភរិយាចាស់ឃើញសុទិន្នភិក្ខុនោះហៅខ្លួនដោយពាក្យថា ប្អូនស្រី ទើបគិតនៅក្នុងចិត្តថា "ឥឡូវនេះ សុទិន្នភិក្ខុនេះមិនត្រូវការយើង, បានសម្គាល់យើងអ្នកជាភរិយាពិត ៗ ដូចក្មេងស្រីអ្នកដេកនៅក្នុងផ្ទៃមាតាតែមួយជាមួយគ្នានឹងខ្លួន" ក៏កើតសេចក្ដីសោកជាខ្លាំង ហើយដួលសន្លប់នៅក្នុងទីនោះឯង ។

ច្រើនបទថា មា នោ វិហេឋយិត្ថ : កុំធ្វើអាត្មាឱ្យលំបាកពេកឡើយ សេចក្ដីថា សុទិន្នភិក្ខុពោលនឹងញោមបិតាថា ញោម កុំបង្ហាញទ្រព្យនិងបញ្ចូនមាតុគ្រាមមកបៀតបៀនអាត្មាឡើយ, ពិតមែន វាចានោះធ្វើសេចក្ដីលំបាកឱ្យដល់ពួកបព្វជិត ។

## មាតាអង្វរឱ្យសុទិន្នភិក្ខុ បង្កើតពូជទុក

មាតារបស់សុទិន្នភិក្ខុ បាននិមន្តសុទិន្នភិក្ខុទុកក្នុងការអភិរម្យ ដោយសេចក្ដីថា "បើដូច្នេះ" ដែលមាននៅក្នុងបទនេះថា "សុទិន្នកូន បើដូច្នេះ សូមលោកអាណិតគ្រាន់តែឱ្យពូជបន្ដិចចុះ" គឺ មាតាបាននិយាយថា បើកូន

នៅត្រកូលអរទេីងប្រព្រឹត្តព្រហ្មចរិយសោត, សូមកូនប្រព្រឹត្តអង្គុយបរិញាន នៅលើអាកាសចុះ, ប៉ុន្តែថា កូនចូរឱ្យបុត្រប្រុសម្នាក់ ដែលនឹងជាពូជសម្រាប់បន្តវង្សត្រកូលរបស់យើង ។

ប្រើនបទថា មា នោ អបុត្តកំ សាបតេយ្យំ លិច្ឆវយោ អតិហរាបេសុំ : កុំឱ្យពួកស្តេចលិច្ឆវីមករឹបជាន់យកទ្រព្យសម្បត្តិជារបស់យើង ដែលជាត្រកូលឥតមានកូននោះឡើយ សេចក្តីថា មាតារបស់សុទិន្នភិក្ខុនិយាយថា ព្រោះហេតុដែលពួកយើងនៅក្នុងរជ្ជសម័យនៃស្តេចលិច្ឆវីអ្នកជាគណរាជ្យ, ដោយកាលកន្លងផុតទៅនៃបិតារបស់កូនស្តេចលិច្ឆវីទាំងនោះនឹងបង្គាប់ឱ្យរឹបអូសយកទ្រព្យមត៌កនេះ គឺ ទ្រព្យសម្បត្តិរបស់ពួកយើង ដែលមានច្រើនសន្ធឹកសន្ធាប់យ៉ាងនេះ ដែលមិនមានបុត្រ គឺ ដែលវៀរចាកបុត្រ ដែលនឹងរក្សាទ្រព្យរបស់ត្រកូលទុក នាំទៅកាន់ព្រះរាជឃ្លាំងរបស់ព្រះអង្គជាមិនខាន, ដូច្នោះ, កុំឱ្យស្តេចលិច្ឆវីទាំងនោះចេញបញ្ជាមករឹបអូស គឺ ចូរកុំឱ្យចេញបញ្ជាមករឹបអូសយកទ្រព្យសម្បត្តិនោះទៅឡើយ ។

សួរថា ព្រោះហេតុអ្វី សុទិន្នភិក្ខុ ទើបបានពោលយ៉ាងនេះថា "ញោម បើគ្រាន់តែធ្វើកិច្ចប៉ុណ្ណេះ អាត្មាអាចធ្វើឱ្យបាន ?"

ឆ្លើយថា បានឮថា សុទិន្នភិក្ខុនោះ គិតថា "យើងប៉ុណ្ណោះ នឹង

ជាម្ចាស់ទ្រព្យមត៌ករបស់មាតាជាដើមទាំងនោះ, មិនមានអ្នកណាដទៃ, សូម្បីមាតាជាដើមទាំងនោះ ក៏នឹងតាមចងយើងជានិច្ច ដើម្បីត្រូវការឱ្យរក្សាទ្រព្យមត៌ក, ព្រោះហេតុនោះ យើងនឹងមិនបានដើម្បីជាអ្នកមានសេចក្ដីខ្វល់ខ្វាយតិច បំពេញសមណធម៌, ចំណែកលោកទាំងនេះ កាលបានចៅប្រុសហើយក៏នឹងវៀរចាក (ការតាមចងយើង), តអំពីនោះ យើងក៏នឹងបានបំពេញសមណធម៌តាមសប្បាយ, កាល (លោក) សម្លឹងឃើញន័យនេះ ទើបបានពោលយ៉ាងនោះ ។

## ស្ត្រីឈប់មានរដូវ ក៏តាំងគភ៌

[១៧] ពាក្យថា **បុប្ផំ** : **ផ្កា** នេះ ជាឈ្មោះនៃលោហិតដែលកើតឡើងក្នុងវេលាដែលមាតុគ្រាមមានរដូវ ។ ពិតមែន ក្នុងវេលាដែលមាតុគ្រាមមានរដូវ គ្រាប់ពកមានពណ៌ក្រហមតាំងឡើងក្នុងស្ថានទីដែលតាំងគភ៌ (ក្នុងស្បូន) ហើយចម្រើនឡើងដល់ ៧ ថ្ងៃក៏បែកទៅ ។ លោហិតក៏ហូរចេញចាកពកឈាមដែលបែកនោះ ។ ពាក្យថា **បុប្ផំ** នោះ ជាឈ្មោះនៃលោហិតនោះ ។

មួយទៀត លោហិតនោះជារបស់មានកម្លាំង នៅហូរចេញច្រើនត្រឹមណា, បដិសន្ធិ (របស់សត្វអ្នកកើតក្នុងគភ៌) សូម្បីដែលបិតាឱ្យទុក

ហើយ ក៏តាំងនៅមិនបានត្រឹមនោះ, គឺ រមែងហូរចេញព្រមទាំងទោស (មន្ទិលនៃលោហិត) នុ៎ះឯង, ក៏កាលទោស (មន្ទិលនៃលោហិត) ហូរចេញហើយ បដិសន្ធិ (របស់សត្វអ្នកកើតក្នុងគភ៌) ដែលបិតាឲ្យទុកហើយក្នុងវត្ថុ (កន្ស្រោមស្បូន) ដែលបរិសុទ្ធិ ក៏តាំងឡើងបានដោយឆាប់រហ័ស ។

ពីរបទថា បុប្ផំសា ឧប្បជ្ជតិ : **ផ្កាគឺឈាមរបស់នាងកើតឡើងហើយ** សេចក្តីថា គ្រាប់ឈាមកើតឡើងដល់កិរិយាចាស់របស់សុទិន្នភិក្ខុនោះហើយ ។ គប្បីជ្រាបការលុបបទសំយោគ ព្រមទាំងការលុប អ អក្សរ[1] ចេញ ។

ច្រើនបទថា បុរាណទុតិយិកាយ ពាហាយំ គហេត្វា : **ហើយក៏ចាប់ដៃនាងបុរាណទុតិយិកា** សេចក្តីថា សុទិន្នភិក្ខុមានអាយុចាប់កិរិយាចាស់នោះត្រង់ដើមដៃទាំងពីរនោះ ។

ពីរបទថា អប្បញ្ញត្តេ សិក្ខាបទេ : **ព្រោះសិក្ខាបទព្រះអង្គមិនទាន់បានបញ្ញត្ត** សេចក្តីថា ព្រោះបឋមបារាជិកសិក្ខាបទ ទ្រង់មិនទាន់បានបញ្ញត្តទុក ។

---

(១) បទថា បុប្ផំសា នេះ កាត់បទជា បុប្ផំ អស្សា លុប អ អក្សរដើម និង លុប ស ដែលជាអក្សរស្ទួនចេញ ទើបសន្ធិគ្នាចូលជា បុប្ផំសា ។

## ទ្រង់បញ្ញត្តិបឋមបារាជិកក្នុងព្រះវស្សាទី ២០

បានឮថា ក្នុងបឋមពោធិកាលនៃព្រះមានព្រះភាគ ភិក្ខុទាំងឡាយបានផ្គង ព្រះហឫទ័យឱ្យទ្រង់ត្រេកអរហើយរហូតអស់ ២០ ឆ្នាំ មិនបានធ្វើអជ្ឈាចារ (ការប្រព្រឹត្តល្មើស) បែបនេះ (ឱ្យកើតឡើងឡើយ) ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកអជ្ឈាចារនោះឯង ទើបត្រាស់ព្រះសូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុបានញុំាងចិត្តថាគតឱ្យត្រេកអរក្នុងសម័យមួយហើយ"[១] ។

គ្រានោះ ព្រះមានព្រះភាគ កាលទ្រង់មិនសម្លឹងឃើញអជ្ឈាចារ (សេចក្តីប្រព្រឹត្តល្មើសដូច្នោះរបស់ភិក្ខុទាំងឡាយ) ទើបមិនបានទ្រង់បញ្ញត្តិបារាជិក ឬ សង្ឃាទិសេស តែបានទ្រង់បញ្ញត្តិកងអាបត្តិតូច ៗ ដ៏សេសទុកត្រឹមតែ ៥ កងប៉ុណ្ណោះក្នុងរឿងនោះ ៗ ព្រោះហេតុនោះ ព្រះ

១. មជ្ឈិ. មូល. កកចូបមសូត្រ. ២១. ៣/៦ ។

ឧបាលីថេរៈ ទើបបានពោលទុកថា ព្រោះសិក្ខាបទ ទ្រង់មិនទាន់បានបញ្ញត្តិទុក ។

បទថា អនាទីនវទស្សោ : យល់ឃើញថាមិនមានទោស សេចក្តីថា សុទិន្នភិក្ខុ កាលមិនឃើញសិក្ខាបទដែលព្រះមានព្រះភាគទ្រង់

បញ្ញត្តិសិក្ខាបទ បញ្ញាក់ដល់ទោសទុកក្នុងកាលនេះ ទើបជាអ្នកមានសេចក្ដីសម្គាល់ (ក្នុងការសេពមេថុនធម្មនោះ) ថា មិនមានទោស ។ ពិតមែន បើសុទិន្នភិក្ខុនេះបានដឹងថា វត្ថុនេះមិនគួរធ្វើ ឬថា វត្ថុដែលធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បីមូលឆេទ ដូច្នេះមែននោះ, កុលបុត្រអ្នកបួសដោយសទ្ធា សូម្បីនឹងត្រូវអស់ជីវិតទៅ ព្រោះមានកម្មនោះជាហេតុក៏នឹងមិនគប្បីធ្វើ, តែលោកកាលមិនសម្លឹងឃើញទោសក្នុងការសេពមេថុនធម្មនេះ ទើបបានជាអ្នកមានសេចក្ដីសម្គាល់ថា មិនមានទោស ។ ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបបានពោលទុកថា ជាអ្នកមានសេចក្ដីឃើញថា មិនមានទោស ។

បទថា **បុរាណទុតិយិកាយ : ដោយនាងបុរាណទុតិយកា** នេះ ជាសត្តមីវិភត្តិ ។

បទថា **អភិវិញ្ញាបេសិ : ហើយញ៉ាំងឱ្យសម្រេច** គឺ ឱ្យប្រព្រឹត្តទៅហើយ ។

ពិតមែន សូម្បីការឱ្យប្រព្រឹត្តទៅ លោកហៅថា **វិញ្ញាបនា** ព្រោះញ៉ាំងកាយវិញ្ញត្តិឱ្យកម្រើកញ័រ ។ ក៏សុទិន្នភិក្ខុនេះ បណ្ឌិតគប្បីជ្រាបថា បានធ្វើការញ៉ាំងកាយវិញ្ញត្តិឱ្យកម្រើកញ័រដល់ ៣ ដង ដើម្បីសេចក្ដីផ្ដន់ចិត្តបំណងនឹងឱ្យតាំងគភ៌ ។

ច្រើនបទថា **សា តេន គច្ឆំ គណ្ហិ : នាងក៏មានគភ៌ដោយមេថុនសេវនៈ** នោះ សេចក្តីថា សូម្បីកិរិយាចាស់របស់សុទិន្នភិក្ខុនោះ ក៏តាំងគភ៌ព្រោះអជ្ឈាចារនោះឯង មិនបានតាំងគភ៌ដោយប្រការដទៃទេ ។

## ហេតុដែលឱ្យស្ត្រីតាំងគភ៌មាន ៧ យ៉ាង

សួរថា ក៏ការតាំងគភ៌ រមែងតាំងបាន សូម្បីដោយប្រការយ៉ាងដទៃឬ ?

ឆ្លើយថា រមែងតាំងបាន ។

សួរថា តើការតាំងភគ៌បាននោះ មានហេតុប៉ុន្មានយ៉ាង ?

ឆ្លើយថា មានហេតុ ៧ យ៉ាងគឺ ព្រោះការស្ទាបអង្អែលកាយ ១ ព្រោះការចាប់សំពត់ (ស្លៀកដណ្តប់) ១ ព្រោះការផឹកទឹកអសុចិ ១ ព្រោះការស្ទាបអង្អែលផ្ចិត (របស់ស្ត្រី) ១ ព្រោះការសម្លឹងមើលរូប ១ ព្រោះសំឡេង ១ ព្រោះក្លិន ១ ។

ពិតមែន ស្ត្រីទាំងឡាយ ពួកខ្លះជាអ្នកមានសេចក្តីតម្រេកត្រេកអរដោយឆន្ទរាគៈក្នុងវេលាដែលខ្លួនមានរដូវ សូម្បីកាលត្រេកអរការដែលបុរសចាប់ដៃ ចាប់ផ្នួងសក់ និងការស្ទាបអង្អែលអវយវៈតូចធំ (របស់ខ្លួន) រមែងតាំងគភ៌បាន ។ ការតាំងគភ៌ រមែងមានព្រោះការស្ទាប

អង្គែលកាយ ដោយអាការយ៉ាងនេះ ។

មួយទៀត រឿងនាងភិក្ខុនី ដែលជាភរិយាចាស់របស់ព្រះឧទាយីថេរៈថា "នាងភិក្ខុនីនោះ ក៏បានយកទឹកអសុចិរបស់ឧទាយីនោះបន្តិចដាក់ក្នុងមាត់ យកបន្តិចដាក់ក្នុងអង្គជាត ។ នាងភិក្ខុនីនោះ ក៏មានគភ៌ដោយសារទឹកអសុចិនោះ"(១) ។ ការតាំងគភ៌ រមែងតាំងបាន ព្រោះការចាប់សំពត់ (ស្លៀកដណ្តប់) ដោយអាការយ៉ាងនេះ ។

មេម្រឹគដែលជាមាតារបស់មិគសិង្គតាបស បានមកកាន់ស្ថានទីបន្ទោបង់បស្សាវៈរបស់តាបស ក្នុងវេលាដែលខ្លួនមានរដូវ ហើយបានផឹកទឹកបស្សាវៈ ដែលមានទឹកសម្ភពលាយ ។ មេម្រឹគនោះ ក៏តាំងគភ៌ ហើយបានកើតកូនមកជាមិគសិង្គតាបស ព្រោះហេតុដែលខ្លួនផឹកទឹកបស្សាវៈនោះ ។(២) ការតាំងគភ៌ រមែងតាំងបាន ព្រោះការផឹកទឹកអសុចិដោយអាការយ៉ាងនេះ ។

(១) វិន. និស្ស. ៣. ៤២/៣៤ ។ (២) អដ្ឋកថា មិគសិង្គជាតក ។

មួយទៀត ស្តេចសក្កៈទ្រង់ជ្រាបហេតុដែលមាតាបិតារបស់ព្រះសាមតាបសពោធិសត្វខ្វាក់ភ្នែក មានព្រះប្រាថ្នានឹងប្រទានបុត្រ (ដល់លោកទាំងពីរនោះ) ទើបទ្រង់ត្រាស់ចំពោះទុកុលបណ្ឌិត (អ្នកជាបិតារបស់ព្រះសាមតាបសពោធិសត្វនោះ) ថា មេថុនធម្មគួរដល់លោកទាំង

ពីរឬ ?

ទុកូលកបណ្ឌិត ទូលថា អាត្មាភាពទាំងពីរ បួសជាឥសីហើយ មិនមានសេចក្ដីត្រូវការដោយមេថុនធម្មនោះ ។

ស្ដេចសក្កៈ ទ្រង់ត្រាស់ថា បើដូច្នោះ ក្នុងវេលាដែលនាងបារិកាតាបសិនីនេះមានរដូវ លោកគប្បីយកម្រាមដៃស្ទាបអង្អែលផ្ចិត (របស់នាង) ចុះ ។

ទុកូលកបណ្ឌិតនោះ បានធ្វើដូចយ៉ាងនោះហើយ ។ នាងបារិកាតាបសិនីនោះ ក៏តាំងគភ៌ ហើយប្រសូតទារកឈ្មោះសាមតាបស ព្រោះហេតុដែលស្ទាបអង្អែលផ្ចិតនោះ ។(១) ការតាំងគភ៌ រមែងតាំងបាន ព្រោះការស្ទាបអង្អែលផ្ចិត ដោយអាការយ៉ាងនេះ ។ ដោយន័យនេះឯង គួរជ្រាបរឿងមណ្ឌព្យមាណព(២) និងរឿងព្រះបាទចណ្ឌបជ្ជោត ។

---

(១) អដ្ឋកថា សុវណ្ណសាមជាតក. ។ (២) អដ្ឋកថា មាតង្គជាតក. ។

សួរថា ការតាំងគភ៌ រមែងតាំងបាន ព្រោះការសម្លឹងមើល (រូប) យ៉ាងណា ?

ឆ្លើយថា ស្ត្រីពួកខ្លះក្នុងលោកនេះ ក្នុងវេលាដែលខ្លួនមានរដូវ កាលមិនបានការស្ទាបអង្អែលជាមួយនឹងបុរស ទើបចូលទៅក្នុងផ្ទះ

សម្លឹងមើលប្រុស ដោយអំណាចសេចក្ដីតម្រេកពេញចិត្ត( ហើយក៏តាំងគភ៌ ) ដូចនាងស្នំក្នុងវាំង ដូច្នោះ ។ នាង រមែងតាំងគភ៌ ព្រោះការសម្លឹងមើលប្រុសនោះ ។ ការតាំងគភ៌ រមែងតាំងបាន ព្រោះការសម្លឹងមើលរូប ដោយអាការយ៉ាងនេះ ។

មួយទៀត បណ្ដាសត្វកុកទាំងឡាយ ឈ្មោះថា សត្វកុកឈ្មោល រមែងមិនមាន ។ កុកញីទាំងនោះ ក្នុងវេលាដែលខ្លួនមានរដូវ កាលបានស្ដាប់សំឡេងផ្គរហើយ រមែងតាំងគភ៌ សូម្បីមេមាន់ទាំងឡាយទោះច្រើនក៏ដោយ ក្នុងកាលខ្លះ បានស្ដាប់សំឡេងមាន់ឈ្មោលតែមួយរងាវ ក៏រមែងតាំងគភ៌បាន ។ សូម្បីមេគោទាំងឡាយ កាលបានស្ដាប់សំឡេងគោឧសុភៈ (គោឈ្មោល) ហើយ ក៏រមែងតាំងគភ៌ដូចគ្នាដែរ ។ ការតាំងគភ៌ រមែងតាំងបាន ព្រោះសំឡេង ដោយអាការយ៉ាងនេះ ។

មួយទៀត មេគោទាំងឡាយទ្រុំះឯង ក្នុងកាលខ្លះ រមែងតាំងគភ៌បាន ព្រោះក្លិនរបស់គោឈ្មោល, ការតាំងគភ៌ រមែងកើតបាន ព្រោះក្លិន ដោយអាការយ៉ាងនេះ ។

ចំណែកក្នុងរឿងនេះ ភរិយាចាស់របស់សុទិន្នភិក្ខុនេះ រមែងតាំងគភ៌ ព្រោះអជ្ឈាចារ ដូចដែលព្រះមានព្រះភាគ ទ្រង់សំដៅយកត្រាស់ទុកថា ៖

"ម្នាលភិក្ខុទាំងឡាយ លុះតែកាលណាមាតាបិតាមកប្រជុំគ្នាផង មាតាជាស្ត្រីមានរដូវផង សត្វដែលគួរកើតក៏មានប្រាកដក្នុងឱកាសនោះផង, លុះប្រជុំហេតុទាំង ៣ ប្រការនេះឯង ទើបសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាបាន"(១) ។

## ទេវតាប្រកាសសេចក្ដីអាក្រក់

[១៨] ប្រើនបទថា ភុម្មា ទេវា សទ្ទមនុស្សាវេសុំ : ទេវតាទាំងឡាយ ញុំាងសំឡេងឱ្យឮទូទៅឡើងទៅ សេចក្ដីថា ធម្មតាបុគ្គលអ្នកធ្វើអំពើអាក្រក់ ក្នុងលោក មិនដែលកំបាំងទេ(២) ។ ពិតមែន អ្នកធ្វើអំពើអាក្រក់នោះ រមែងដឹងនូវ អំពើអាក្រក់របស់ខ្លួននោះ មុនអ្នកដទៃ

១. មជ្ឈិ. មូល. ២២. ៩២/១៨០ ។ (២) អង្គ. តិក. ៤១. ៤១/១១៨ ; ខុទ្ទ. ជាត. សីលវិមំសជាតក. ៥៨. ៥១៨/១៩០ ។

ទាំងអស់, តពីនោះ អារក្ខទេវតាទាំងឡាយ រមែងដឹង, ខាងក្រោយតមកទេវតា សូម្បីពួកដទៃអ្នកដឹងចិត្ត របស់បុគ្គលដទៃ ក៏ រមែងដឹង, ព្រោះហេតុនោះ ភុម្មទេវតាទាំងឡាយ អ្នកអាស្រ័យនៅក្នុងព្រៃស្រោងទាំងអស់ ដែលជាអ្នកដឹងចិត្តរបស់បុគ្គលដទៃ បានប្រទះឃើញអជ្ឈាចារ្យនោះ

របស់សុទិន្នភិក្ខុនោះ ក៏បានញុំាងសំឡេងឱ្យបន្លឺលាន់ឮទៅ គឺ បានបញ្ចេញសំឡេង ដោយអាការដែលទេវតាសូម្បីពួកដទៃទៀតបានឮ ។

សួរថា បានឮថា យ៉ាងណា ?

ឆ្លើយថា បានឮដូច្នេះ "ម្នាលគ្នាយើងទាំងឡាយ ពួកភិក្ខុមិនដែលរឹកររ មិនដែលមានទោស, (ឥឡូវនេះ) សុទិន្នកលន្ទបុត្រ ធ្វើសេចក្តីរឹកររ និងទោសឱ្យកើតឡើងហើយ" ។ សេចក្តីនៃពាក្យថា មិនដែលរឹករ ជាដើមនោះ បណ្ឌិតគប្បីជ្រាបដោយន័យដូចដែលខ្ញុំព្រះករុណាពោលទុកហើយក្នុងវេរញ្ជកណ្ឌនុ៎ះឯង ។

មួយទៀត ក្នុងពាក្យថា ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា : ចាតុម្មហារាជិកាទេវតាទាំងឡាយ ឮសំឡេងភុម្មទេវតាទាំងនោះ នេះ គប្បីជ្រាបលំដាប់ដូច្នេះថា អាកាសដ្ឋទេវតាទាំងឡាយ បានស្តាប់សំឡេងពួកភូម្មទេវតាហើយ, ទេវតាជាន់ចាតុមហារាជទាំងឡាយ បានស្តាប់សំឡេងពួកអាកាសដ្ឋទេវតាហើយ ដូច្នេះជាដើម ។

បទថា ព្រហ្មកាយិកា : ពួកព្រហ្ម សេចក្តីថា ព្រហ្មសូម្បីទាំងអស់ វៀរលែងតែពួកអសញ្ញីសត្វនិងពួកអរូបាវចរសត្វចេញ គប្បីជ្រាបថា បានស្តាប់ហើយ និងកាលបានស្តាប់ហើយ ក៏បានបន្លឺសំឡេងឱ្យលាន់ឮហើយ ។

ប្រើនបទថា ឥតិហ តេន ខណេន : ដោយ ១ ខណៈនោះឯង សេចក្ដីថា ខណៈជាមួយគ្នានៃអជ្ឈាចាររបស់សុទិន្នភិក្ខុនោះ ដោយអាការយ៉ាងនេះ ។

ពីរបទថា តេន មុហុត្តេន : ១ រំពេចនោះ សេចក្ដីថា មួយភ្លែតនៃអជ្ឈាចារទន្ទុំះឯង ។

ពីរបទថា យាវ ព្រហ្មលោកា : ដរាបដល់ព្រហ្មលោក សេចក្ដីថា ( សំឡេងបានឮសុសសាយឡើងទៅហើយ ) ដរាបដល់ព្រហ្មលោកជាន់អកនិដ្ឋៈ ។

បទថា អព្ភុគ្គញ្ឆិ : ក៏កងរំពងឡើងទៅ ប្រែថា បានឮសុសសាយឡើងទៅហើយ គឺ បានតាំងឡើងហើយ ។ សេចក្ដីថា មានសំឡេងទ្រហឹងអ៊ឹងអាប់ព្រមគ្នាហើយ ។

## បុត្រប្រុសរបស់សុទិន្នភិក្ខុមានឈ្មោះថា ពីជកៈ

ពីរបទថា បុត្តំ វិជាយិ : ទើបសម្រាលនូវកូនប្រុសមួយ សេចក្ដីថា ភរិយាចាស់របស់សុទិន្នភិក្ខុបានឱ្យបច្ឆិមភវិកសត្វ អ្នកដូចទឹង

ពុម្ពមាសកើតហើយ ។

ប្រែបទថា **ពីជកោតិ ឆាមំ អកំសុ** : **តាំងឈ្មោះថា ពីជក** សេចក្ដីថា ពួកសម្លាញ់របស់លោកសុទិន្នភិក្ខុមិនព្រមឱ្យតាំងឈ្មោះដទៃ គឺបាននាំគ្នាតាំងឈ្មោះថា "ពីជកៈ" (ចៅពីជក៍) ដោយយល់ឃើញថា "ទារកនោះ ចូរមានឈ្មោះថា "ចៅពីជក៍" ប៉ុណ្ណោះ, ព្រោះហេតុនៃពាក្យដែលយាយបានពោលសូមទុកថា "សូមលោកអាណិតគ្រាន់តែឱ្យពូជបន្តិចចុះ" ដូច្នេះ ប្រាកដច្បាស់ហើយ ។ ពួកសម្លាញ់ ក៏បានតាំងឈ្មោះឱ្យដល់មាតាបិតានៃពីជកទារកនោះ ដោយអំណាចឈ្មោះបុត្រប្រុសដូចគ្នា ។

ពាក្យថា **តេ អបរេន សមយេន** : **លុះសម័យខាងក្រោយមកអ្នកទាំងនោះ** នេះលោកពោលសំដៅយកចៅពីជក៍និងមាតារបស់ចៅពីជក៍ ។

## មាតានិងពីជកទារកបួសហើយបានសម្រេចព្រះអរហត្ត

បានឮថា ក្នុងវេលាដែលពីជកៈមានអាយុបាន ៧-៨ ខួប មាតារបស់លោកបានបួសក្នុងសំណាក់នាងភិក្ខុនី និងពីជកទារកនោះ ក៏បានបួសនៅក្នុងសំណាក់របស់ភិក្ខុ បានអាស្រ័យសព្រហ្មចារីអ្នកជាកល្យាណ

មិត្ត ក៏បានតាំងនៅក្នុងព្រះអរហត្តហើយ ។ ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបបានពោលទុកថា "អ្នកទាំងពីរនោះ បានចេញចាកផ្ទះ ហើយបួសក្នុងភេទជាបុគ្គលអ្នកមិនមានប្រយោជន៍ដល់ការផារក្នុងផ្ទះ ហើយបានធ្វើឱ្យច្បាស់នូវព្រះអរហត្តផល" ។ បព្វជ្ជារបស់មាតានិងបុត្រ បានមានផលហើយដោយប្រការដូច្នេះ ។

## សុទិន្នភិក្ខុក្តៅក្រហាយចិត្តព្រោះប្រព្រឹត្តអាក្រក់

[១៩] ចំណែកបិតារបស់ពីជកទារកនោះ ត្រូវសេចក្តីវិប្បដិសារគ្របសង្កត់ ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបបានពោលពាក្យថា អថខោ អាយស្មតោ សុទិន្នស្ស អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ : គ្រានោះ សេចក្តីសង្ស័យ និងសេចក្តីក្តៅក្រហាយស្តាយក្រោយ ក៏កើតដល់សុទិន្នដ៏មានអាយុ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា អហុទេវ : កើតមាន គឺ បានមានហើយនោះ ។ ទ អក្សរធ្វើការភ្ជាប់បទ ។ សេចក្តីថា បានមានហើយនោះពិតមែន ។

ការតាមដុតពេលក្នុងខាងក្រោយ ដែលមានអជ្ឈាចារជាហេតុឈ្មោះថា សេចក្តីក្តៅក្រហាយ ។ សូម្បីពាក្យថា វិប្បដិសារោ ក៏ជា

ឈ្មោះនៃការតាមដុតពេលជាខាងក្រោយនោះឯង ។

ពិតមែន ការតាមដុតពេលក្នុងខាងក្រោយនោះ លោកហៅថា កុក្កុច្ចៈ ( សេចក្តីក្តៅក្រហាយ ) ដោយភាពជាកិរិយាដែលបណ្ឌិតគួរស្អប់ ព្រោះភាពជាកម្មដែលអ្នកដឹងទាំងឡាយ មិនគប្បីធ្វើ, លោកហៅថា វិប្បដិសារ ( សេចក្តីក្តៅក្រហាយ ) ជាសេចក្តីរលឹកខុសទៅ ព្រោះអាស្រ័យអជ្ឈាចារនោះ ព្រោះមិនអាចនឹងហាមអជ្ឈាចារដែលខ្លួនធ្វើហើយបាន ។

ប្រើនបទថា អលាភា វត មេ : **អាត្មាអញពេញហៅជាឥតលាភ** សេចក្តីថា មិនមែនលាភរបស់យើងហ្នំ ។ មានអធិប្បាយថា ដែលឈ្មោះថា សេចក្តីមិនបានគុណទាំងឡាយ មានឈានជាដើមទាំងនោះ មិនមែនលាភរបស់យើង ទាំងមិនមែនលាភរបស់អ្នកដទៃ ។

ប្រើនបទថា ន វត មេ លាភា : **លាភមិនមានដល់អាត្មាអញទេ** សេចក្តីថា គុណគឺ បព្វជ្ជា សរណគមន៍និងការសមាទានសិក្ខាសូម្បីពួកណា ដែលយើងបានចំពោះហើយ, គុណគឺ បព្វជ្ជាជាដើមសូម្បីទាំងនោះ ឈ្មោះថា មិនមែនលាភរបស់យើងឡើយ ព្រោះមានអជ្ឈាចារសៅហ្មង ។

ប្រើនបទថា ទុល្លទ្ធំ វត មេ : **ភាពជាមនុស្ស ពេញហៅអាត្មា**

អញបានដោយអាក្រក់ សេចក្ដីថា ព្រះសាសនានេះ សូម្បីដែលយើងបានហើយ ក៏ឈ្មោះថា យើងបានអាក្រក់ ។

ច្រើនបទថា **ន វត មេ សុលទ្ធំ : មិនមែនអាត្មាអញបានដោយល្អទេ** សេចក្ដីថា ព្រះសាសនានេះ យើងបានមិនល្អដូចកុលបុត្រពួកដទៃគេបានហ្ន៎ ។ ព្រោះហេតុអ្វី ? ព្រោះហេតុយើងបួសក្នុងព្រះធម៌វិន័យដែលព្រះមានព្រះភាគ ត្រាស់ទុកល្អហើយយ៉ាងនេះ មិនអាចនឹងប្រព្រឹត្តព្រហ្មចរិយៈឱ្យបរិបូណ៌បរិសុទ្ធបាន ដរាបរហូតដល់អស់ជីវិតនោះឯង ។

បទថា **ព្រហ្មចរិយំ : ព្រហ្មចរិយធម៌** បានដល់ មគ្គព្រហ្មចរិយដែលលោកសង្គ្រោះដោយត្រៃសិក្ខា ។

ពីរបទថា **កិសោ អហោសិ : ក៏ទៅជាស្គម** សេចក្ដីថា សុទិន្នភិក្ខុនោះ កាលមិនអាចនឹងទំពាស៊ីឬឆាន់អាហារ ទើបបានស្គមស្គាំង គឺ មានសាច់និងលោហិតតូច ។

បទថា **ឧប្បណ្ឌុប្បណ្ឌុកជាតោ : កើតទៅជារោគលឿងស្លេកស្លាំង** បានដល់ ភាពជាអ្នកមានសម្បុរលឿង ៗ កើតឡើង គឺ ជាអ្នកមានចំណែកប្រៀបដូចស្លឹកឈើលឿង ។

បទថា **ធមនិសណ្ឋតគត្តោ : មានខ្លួនរវាមដោយសរសៃ** បាន

ដល់ អ្នកមានខ្លួនរវើមរវាមដោយជួរសរសៃនុ៎ះឯង ព្រោះភាពជាអ្នកមានសាច់និងលោហិតអស់ទៅ ។

បទថា អន្តោមនោ : មានចិត្តក្រៀមក្រំ បានដល់ អ្នកមានសេចក្ដីគិតតាំងនៅខាងក្នុងនុ៎ះឯង (អ្នកមានរឿងក្នុងចិត្ត) ដោយអំណាចសេចក្ដីទុក្ខព្រួយដល់រឿងនោះ ។ មួយទៀត សត្វលោកសូម្បីទាំងអស់ ឈ្មោះថា ជាអ្នកមានចិត្តនៅខាងក្នុងនុ៎ះឯង (គិតនៅតែក្នុងចិត្ត) ដោយអំណាចការប្រព្រឹត្តទៅ អាស្រ័យហទយៈវត្ថុ ។

បទថា លីនមនោ : ទ្រមឹងទ្រមើយ បានដល់ អ្នកលះបោលធុរៈ គឺ អ្នកមិនមានសេចក្ដីខ្វល់ខ្វាយក្នុងឧទ្ទេស បរិបុច្ឆា កម្មដ្ឋាន អធិសីល អធិចិត្ត អធិបញ្ញា និងការបំពេញវត្តនិងបដិវត្ត ។ ឈ្មោះថា អ្នកមានចិត្តខ្ជិលច្រអូស ព្រោះអត្ថថា ចិត្តរបស់អ្នកនោះខ្ជិលច្រអូស គឺ បែរត្រឡប់ដោយអំណាចសេចក្ដីខ្ជិលច្រអូសដោយពិតតែម្ដង ។

បទថា ទុក្ខី : កើតទុក្ខ បានដល់ អ្នកមានទុក្ខ ព្រោះទុក្ខមកចិត្ត ។

បទថា ទុម្មនោ : តូចចិត្ត បានដល់ អ្នកមានចិត្តដែលទោសប្រទូស្តហើយ ឬអ្នកមានចិត្តខុសរូប ព្រោះភាពជាអ្នកត្រូវទោមនស្សគ្របសង្កត់ ។

បទថា បជ្ឈាយិ : សញ្ជប់សញ្ជឹង សេចក្ដីថា សុទិន្នភិក្ខុ គិតដល់អំពើអាក្រក់ដែលខ្លួនធ្វើហើយនោះ ៗ ដោយអំណាចសេចក្ដីក្ដៅក្រហាយ (សោកសៅ) ដូចលាឈ្មោលដែលគេឃាត់ចេញពីភារៈហើយ (សោកសៅ) ដូច្នោះ ។

## ពួកភិក្ខុជាសម្លាញ់សួរសុទិន្នភិក្ខុដល់សេចក្ដីស្គមស្គាំង

ពីរបទថា សហាយកា ភិក្ខូ : ភិក្ខុទាំងឡាយជាសម្លាញ់ សេចក្ដីថា ភិក្ខុទាំងឡាយ អ្នកសួរដល់សេចក្ដីសុខសប្បាយ ដែលជាអ្នកជិតជិតរបស់សុទិន្នភិក្ខុ ឃើញសុទិន្នភិក្ខុនោះ មានសភាពយ៉ាងនោះ ដែលបណ្ដែតបណ្ដោយឱ្យថ្ងៃនិងយប់កន្លងទៅ ដោយធម៌ជាគ្រឿងយឺតយូរ គឺ ការប្រែបួកប្រែបល់នៅដោយពួក ទើបបានពោលពាក្យនេះចំពោះសុទិន្នភិក្ខុនោះ ។

បទថា បីណិន្ទ្រិយោ : មានឥន្ទ្រិយពេញលេញ សេចក្ដីថា អ្នកមានឥន្ទ្រិយមានចក្ខុជាដើមពេញប្រៀប ព្រោះឱកាសដែលជាទីតាំងនៃប្រសាទសម្បូរណ៍ ។

សព្ទថា ទានិ ដែលមាននៅក្នុងពាក្យថា សោទានិ ត្វំ : ឥឡូវនេះ លោក នេះ ជានិបាត ។ លោកពោលអធិប្បាយទុកថា សោ បទ

តំ : ក៏អ្នកមានអាយុនោះ (ទៅជាស្គមស្គាំង) ។

ច្រើនបទថា **កច្ចិ នោ តុំ** គឺ **កច្ចិ នុ តុំ** : លោក(មិនសូវត្រេកអរហើយបេះតែនឹងប្រព្រឹត្តព្រហ្មចរិយធម៌ទៅ) ទេឬអ្វី ?

បទថា **អនភិរតោ** : មិនសូវត្រេកអរ គឺ អ្នកមានសេចក្ដីអផ្សុក, អធិប្បាយថា អ្នកប្រាថ្នាភាពជាគ្រហស្ថ ។

ព្រោះហេតុនោះ សុទិន្នភិក្ខុ កាលនឹងជំទាស់ សេចក្ដីមិនត្រេកអរនោះឯង ទើបពោលថា អាវុសោទាំងឡាយ សេចក្ដីពិត មិនមែនថា ខ្ញុំព្រះករុណានឹងមិនត្រេកអរ(ប្រព្រឹត្តព្រហ្មចរិយ) ។ អធិប្បាយថា ក៏ខ្ញុំព្រះករុណាត្រេកអរតែម្ដងក្នុងការបម្រើនកុសលធម៌ដ៏ក្រៃលែង ។

ច្រើនបទថា **អត្ថិ មេ បាបកម្មំ កតំ** : **ខ្ញុំបានធ្វើបាបកម្ម** សេចក្ដីថា បាបកម្មយ៉ាងណាមួយដែលខ្ញុំព្រះករុណាធ្វើទុក មាននៅ គឺខ្ញុំព្រះករុណាបានទទួល បានដល់ មានប្រាកដដល់ខ្ញុំព្រះករុណាជានិច្ចកាល ដូចមាននៅចំពោះមុខដូច្នោះ ។

បន្ទាប់អំពីនោះ សុទិន្នភិក្ខុ កាលនឹងប្រកាស (បង្ហាញ) បាបកម្មដែលខ្លួនធ្វើហើយនោះ (ដល់ពួកភិក្ខុសម្លាញ់) ទើបបានពោលពាក្យជាដើមថា **បុរាណទុតិយិកាយ** : **នឹងស្ត្រីបុរាណទុតិយិកា** ដូច្នេះ ។

## ពួកភិក្ខុសម្លាញ់ឃើញកម្មនោះឱ្យកើតសេចក្ដីក្ដៅក្រហាយបាន

ប្រើនបទថា អលំ ហិ តេ អាវុសោ សុទិន្ន កុក្កុច្ចាយ : អាវុសោសុទិន្ន ល្មមឱ្យលោកសង្ស័យមែន សេចក្ដីថា អាវុសោ សុទិន្ន បាបកម្មនោះរបស់លោក ល្មមគ្រប់គ្រាន់ គឺ អាចនឹងឱ្យលោកក្ដៅក្រហាយបាន ។ មានពាក្យអធិប្បាយថា ជារបស់អាចនឹងឱ្យកើតសេចក្ដីក្ដៅក្រហាយបាន ។

ក្នុងពាក្យថា យំ ត្វំ : លោក ណា ជាដើម គប្បីជ្រាបការភ្ជាប់សេចក្ដីដូច្នេះថា លោកនឹងមិនអាចប្រព្រឹត្តព្រហ្មចរិយ ព្រោះសេចក្ដីអាក្រក់ណា, សេចក្ដីអាក្រក់នោះរបស់លោកល្មមដែលនឹងឱ្យលោកក្ដៅក្រហាយបាន ។

តពីនោះ ពួកភិក្ខុជាសម្លាញ់ កាលនឹងទូន្មានសុទិន្នភិក្ខុនោះ ទើបបានពោលពាក្យជាដើមថា ននុ អាវុសោ ភគវតា : ម្នាលអាវុសោ ដែលព្រះមានព្រះភាគ ដូច្នេះ ។

បណ្ដាបទទាំងនោះ សព្ទថា ននុ ជានិបាត ចុះក្នុងអត្ថអនុមតិនិងតិះដៀល ។

បទថា អនេកបរិយាយេន : ដោយការប្រព្រឹត្តទៅជុំវិញមិន

មែនមួយ បានដល់ ដោយហេតុមិនមែនតែម្យ៉ាង ។

បទថា វិភាគាយ : ដើម្បីឱ្យប្រាសចាកភាគៈ ដើម្បីប្រាសចាកសេចក្ដីតម្រេក ។

ពីរបទថា ន សភាគាយ : មិនមែនដើម្បីឱ្យប្រកបដោយភាគៈ សេចក្ដីថា មិនមែនដើម្បីសេចក្ដីតម្រេកដោយភាគៈ ។ អធិប្បាយថា ពិតមែន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងហើយ ដើម្បីប្រយោជន៍នៃការបន្ទោបង់សេចក្ដីតម្រេកនោះថា សត្វទាំងឡាយ បានស្ដាប់ធម៌របស់យើងនេះ ហើយនឹងបន្ទោបង់សេចក្ដីតម្រេក គឺ នឹងមិនត្រេកអរក្នុងភពនិងភោគសម្បត្តិទាំងពួង ។ ក្នុងបទទាំងពួងក៏មានន័យនោះ ។

ក៏ពាក្យថា វិសំយោគាតិ កិលេសេហិ វិសំយុជ្ជនត្ថាយ នេះ ដែលមាននៅក្នុងបទថា វិសំយោគាយ ជាដើមនេះ ត្រឹមតែជាការពោលដោយន័យអប ។

បទថា វិសំយោគាយ : ដើម្បីឱ្យប្រាសចាកកិលេស ជាគ្រឿងប្រកប សេចក្ដីថា ដើម្បីប្រាសចាកការប្រកបដោយកិលេសទាំងឡាយ ។

ពីរបទថា ន សំយោគាយ : មិនមែនសម្ដែងដើម្បីតម្រូវទៅរកកិលេស ជាគ្រឿងប្រកបទេ សេចក្ដីថា មិនមែនដើម្បីការប្រកប

ដោយកិលេសទាំងឡាយ ។

បទថា អនុទ្ធានាឆាយ : ដើម្បីមិនឱ្យប្រកាន់មាំ សេចក្តីថា ដើម្បីមិនប្រកាន់មាំ ។

ពីរបទថា នោ សឧទ្ធានាឆាយ : មិនមែនសម្តែងដើម្បីឱ្យប្រកាន់មាំទេ សេចក្តីថា មិនមែនដើម្បីប្រកាន់មាំ ។

ច្រើនបទថា តត្ថ ឆាម តុំ : មិនមែនឬ សេចក្តីថា កាលធម៌នោះ (ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដើម្បីទម្លាយសេចក្តីតំរេក លោក (នៅតែគិតដើម្បីសេចក្តីតំរេកទៀត)ឬ ។

ពីរបទថា សរាគាយ ចេតេស្សសិ : អ្នកឯងត្រឡប់ចូលចិត្តក្នុងធម៌នោះថា ឱ្យប្រកបដោយរាគៈវិញ សេចក្តីថា លោកនៅតែគិត លោកនៅត្រិះរិះ ដើម្បីមេថុនធម្ម ដែលប្រព្រឹត្តទៅព្រមដោយសេចក្តីតម្រេកឬ ? អធិប្បាយថា លោកនឹងនៅតែព្យាយាមដើម្បីត្រូវការមេថុនធម្មនោះឬ ? ក្នុងបទទាំងពួង ក៏មានន័យនោះ ។

## អត្ថាធិប្បាយឈ្មោះព្រះនិព្វាន ៩ បទ

បទទាំង ៩ មានរាគវិរាគៈជាដើម ព្រះមានព្រះភាគទ្រង់សំដៅយកព្រះនិព្វានដែលជាលោកុត្តរធម៌ដែលប្រាសចាកវដ្តៈនុ៎ះឯង ត្រាស់ទុក

ដដែលទៀត ។ ព្រោះហេតុនោះ សូម្បីកាលព្រះអង្គត្រាស់ថា រាគវិរាគាយក្តី មទនិម្មទនាយក្តី បណ្ឌិតគប្បីឃើញសេចក្តីយ៉ាងនេះប៉ុណ្ណោះថា "ដើម្បីប្រយោជន៍ដល់ព្រះនិព្វាន" ។

ពិតមែន ព្រះនិព្វាន ព្រះមានព្រះភាគត្រាស់ហៅថា "ធម៌ជាទីបន្ទោបង់រាគៈ" ព្រោះហេតុថា រាគៈមកដល់ គឺ ប្រារព្ធ បន្តអាស្រ័យព្រះនិព្វាននោះហើយ រមែងប្រាសចាកទៅ គឺ មិនមាន ។

មួយទៀត ព្រះនិព្វាន ទ្រង់ហៅថា ធម៌ជាទីស្វាងស្រវឹង ព្រោះហេតុថា សេចក្តីស្រវឹងទាំងឡាយ មានសេចក្តីស្រវឹងដោយអំណាចមានះនិងសេចក្តីស្រវឹងក្នុងបុរសជាដើមមកដល់ព្រះនិព្វាននោះហើយ រមែងជាការដែលស្វាងទៅមិនជាសេចក្តីអាល័យគឺ បញ្ចកាមគុណ មកដល់ព្រះនិព្វានហើយ រមែងដល់សេចក្តីស្វាងពីស្រវឹង គឺសាបសូន្យទៅ ។

មួយទៀត ព្រះនិព្វាន ទ្រង់ហៅថា ធម៌ជាទីអស់សេចក្តីស្រេកឃ្លាន ព្រោះការស្រេកឃ្លានក្នុងកាមទាំងពួង មកដល់ព្រះនិព្វាននោះហើយ រមែងដល់ការអស់ទៅ គឺការសាបសូន្យទៅ ។

មួយទៀត ព្រះនិព្វាន ទ្រង់ហៅថា ធម៌ជាទីដកអាល័យ ព្រោះថាអាល័យគឺបញ្ចកាមគុណ មកដល់ព្រះនិព្វាននោះហើយ រមែងដល់នូវការដកចេញទៅ ។

មួយទៀត ព្រះនិព្វាន ទ្រង់ហៅថា ធម៌ជាទីដាច់សូន្យនៃវដ្តៈ ព្រោះហេតុថា វដ្តៈ មាន ៣ ភូមិ មកដល់ព្រះនិព្វាននោះហើយ រមែងដាច់សូន្យទៅ ។

មួយទៀត ព្រះនិព្វាន ទ្រង់ហៅថា ធម៌ជាទីអស់តណ្ហា, ធម៌ជាទីប្រាសចាករាគៈ ធម៌ជាទីរលត់ ព្រោះហេតុថា តណ្ហា មកដល់ព្រះនិព្វាននោះហើយ រមែងដល់សេចក្តីអស់ទៅ រមែងប្រាសទៅ និង រមែងរលត់ទៅដោយប្រការទាំងពួង ។

មួយទៀត ព្រះនិព្វាននោះ ទ្រង់ហៅថា និព្វាន ព្រោះហេតុថា ចេញទៅគឺ ចេញផុតពីតណ្ហា ដែលបានរាប់ហារថា វានៈ ព្រោះចង គឺចងឆ្វាក់ បានដល់ ដេរភ្ជាប់កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ទុក ដើម្បីសេចក្តីមានភាពជាបន្ត ៗ ទៅ ដូច្នេះឯង ។

ច្រើនបទថា **កាមានំ បហានំ អក្ខាតំ : កិរិយាលះបង់នូវកាមទាំងឡាយ តថាគតបានសម្តែងហើយ** មានសេចក្តីថា ការលះវត្ថុកាមនិងកិលេសកាមទាំងឡាយ ព្រះមានព្រះភាគ ត្រាស់ទុកហើយមិនមែនឬ ?

ពីរបទថា **កាមសញ្ញានំ បរិញ្ញា : ការកំណត់ដឹងនូវសេចក្តីសំគាល់ក្នុងកាមទាំងឡាយ** មានសេចក្តីថា ការកំណត់ដឹងនូវអត្ថន័យក្នុងកាមសញ្ញាទាំងអស់ មាន ៣ យ៉ាង ដោយអំណាចញាតបរិញ្ញា (កំណត់

ដឹងដោយការដឹង ) តីរណបរិញ្ញា ( កំណត់ដឹងដោយការពិចារណា ) និង បហានបរិញ្ញា ( កំណត់ដឹងដោយការលះបង់ ) ព្រះមានព្រះភាគត្រាស់ហើយមិនមែនឬ ?

បទថា **កាមបិបាសានំ :** **នូវសេចក្តីស្រេកឃ្លានក្នុងកាមទាំងឡាយ** មានសេចក្តីថា ការកម្ចាត់សេចក្តីស្រេកឃ្លានក្នុងកាមទាំងឡាយ ឬការចង់ផឹកកាមទាំងឡាយ ព្រះមានព្រះភាគ ត្រាស់ហើយមិនមែនឬ ?

បទថា **កាមវិតក្កានំ :** **នូវសេចក្តីត្រិះរិះក្នុងកាមទាំងឡាយ** មានសេចក្តីថា ការដកវិតក្កៈទាំងឡាយដែលជាប់ដោយកាមចេញ ព្រះមានព្រះភាគ ត្រាស់ហើយមិនមែនឬ ?

បទថា **កាមបរិឡាហានំ :** **នូវសេចក្តីក្តៅក្រហាយអន្ទះអន្ទែងក្នុងកាមទាំងឡាយ** មានសេចក្តីថា សេចក្តីស្ងប់រម្ងាប់នៃភាពក្តៅក្រហាយ ដែលកើតឡើង ដោយអំណាចសេចក្តីតម្រេក ដែលប្រកបដោយបញ្ចកាមគុណ បានដល់ សេចក្តីអន្ទះអន្ទែងខាងក្នុងព្រះមានព្រះភាគត្រាស់ហើយមិនមែនឬ ?

លោកុត្តរមគ្គ គ្រឿងធ្វើសេចក្តីអស់កិលេស ព្រះមានព្រះភាគត្រាស់ទុកហើយក្នុងស្ថាន ៥ ទាំងនេះ ។ តែមគ្គដែលលាយគ្នាទាំងលោកិយៈនិងលោកុត្តរៈ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ត្រាស់

ទុកហើយក្នុង៣ ស្ថានដំបូងនៃស្ថានទាំងអស់ ។

ពាក្យថា នេតំ អាវុសោ : ម្នាលអាវុសោ កម្មដ៏លាមករបស់លោកនេះ ជាដើម មានសេចក្តីថា ម្នាលអ្នកមានអាយុ កម្មលាមកនោះរបស់លោក រមែងមិនប្រព្រឹត្តទៅដើម្បីសេចក្តីជ្រះថ្លានៃជនទាំងឡាយអ្នកមិនទាន់ជ្រះថ្លា គឺ ដើម្បីប្រយោជន៍ដល់សេចក្តីជ្រះថ្លារបស់ជនទាំងឡាយអ្នកបែបនោះឬ ?

បទថា អថខ្វេតំ កាត់បទជា អថខោ ឯតំ ។ បាលីថា អថខ្វេតំ ក៏មាន ។

បទថា អញ្ញថត្តាយ : ឱ្យទាស់ចិត្តគំនិតទៅវិញទេតើ មានសេចក្តីថា (កម្មលាមកនោះរបស់លោក) រមែងប្រព្រឹត្តទៅ ដើម្បីកម្មដទៃក្រៅពីសេចក្តីជ្រះថ្លា គឺ ដើម្បីសេចក្តីក្តៅក្រហាយ ។ អធិប្បាយថា រមែងធ្វើសេចក្តីក្តៅក្រហាយដល់ជនទាំងឡាយ អ្នកមានសទ្ធាដែលមិនទាន់បានមកដោយមគ្គថា យើងទាំងឡាយជ្រះថ្លាហើយក្នុងព្រះធម៌វិន័យឈ្មោះសូម្បីដូច្នេះ ដែលមានពួកភិក្ខុដែលបដិបត្តិអាក្រក់ ។

ចំណែកសេចក្តីជ្រះថ្លា របស់ជនទាំងឡាយអ្នកមានសទ្ធាមកហើយដោយមគ្គ ជារបស់មិនញាប់ញ័រដោយរឿងដូច្នេះ ឬដោយរឿងដែលខ្លាំងក្លាក្រៃលែងជាងនេះ ដូចភ្នំសិនេរុ មិនញាប់ញ័រដោយខ្យល់

ដូច្នោះ ។ ព្រោះហេតុនោះ ភិក្ខុជាសម្លាញ់ទាំងនោះ ទើបពោលថា ដើម្បីការប្រាកដដោយប្រការដទៃនៃជនពួកខ្លះ ។

## ភិក្ខុទាំងឡាយក្រាបទូលរឿងសុទិន្នភិក្ខុសេពមេថុនធម្ម

ពាក្យថា ភគវតោ ឯតមត្ថំ អារោចេសុំ **: នាំគ្នាក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ** មានសេចក្តីថា ភិក្ខុជាសម្លាញ់ពួកនោះ បានក្រាបទូល គឺ បានក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគ, ក៏ឯកាលក្រាបទូល មិនបានក្រាបទូល ដើម្បីប្រាថ្នានឹងឱ្យខ្លួនជាទីស្រឡាញ់ទេ, មិនបានទូលដើម្បីប្រាថ្នានឹងធ្វើសេចក្តីញុះញង់ទេ, មិនបានទូល ដើម្បីត្រូវការផ្គួនទោស របស់លោកអ្នកមានអាយុនោះទេ, មិនបានទូលដើម្បីប្រាប់ទោសដែលគួរតិះដៀលទេ, ដោយបំណងថា ព្រះមានព្រះភាគ ទ្រង់ស្តាប់សេចក្តីនេះហើយ នឹងមិនឱ្យសុទិន្នភិក្ខុនេះ គង់នៅក្នុងព្រះសាសនា នឹងឱ្យអូសទាញលោកចេញទៅ ទើបបានទូលក៏ទេ, ការពិតនោះ បានទូលដោយបំណងថា ព្រះមានព្រះភាគ កាលទ្រង់ជ្រាបសេចក្តីវិនាសនេះ ដែលកើតឡើងក្នុងព្រះសាសនាហើយ នឹងទ្រង់បញ្ញត្តិសិក្ខាបទ នឹងទ្រង់តាំងព្រំប្រទល់ គឺ អាជ្ញាទុក ។

## ព្រះមានព្រះភាគទ្រង់តិះដៀលសុទិន្នភិក្ខុ

[២០] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ឯតស្មឹ និទានេ ឯតស្មឹ បករណេ** : **ព្រោះរឿងនេះ ព្រោះដំណើរនេះ** នេះ តទៅ ៖

សេចក្តីល្មើសអជ្ឈាចាររបស់សុទិន្នភិក្ខុ គប្បីជ្រាបថា លោកពោលថា ជានិទានទិងជាបករណ៍ ព្រោះជាហេតុនៃការបញ្ញត្តិសិក្ខាបទ ។ ពិតមែនហេតុ លោកហៅថា និទាននិងបករណ៍ ព្រោះជាទីប្រគល់ឱ្យនូវផលរបស់ខ្លួន គឺញុំាំងផលឱ្យបែរទៅ ដូចសម្តែងថា អញ្ជើញកាន់យកផលនោះចុះ និងព្រោះហេតុដែលចាប់ផ្តើមធ្វើ គឺ ប្រារព្ធដើម្បីនឹងធ្វើផលនោះ ឬថា ចាត់ចែងផលនោះតែម្តង ។

ប្រើនបទថា **វិគរហិ ពុទ្ធោ ភគវា** : **ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀល** មានសេចក្តីថា ព្រះមានព្រះភាគទ្រង់តិះដៀល គឺ ទ្រង់តិះដៀល (សុទិន្នភិក្ខុ) នោះ ដូចយ៉ាងបុគ្គលដ៏ប្រសើរ កាលនឹងសម្តែងគុណនិងទោស របស់ជនទាំងឡាយអ្នកសមគួរដល់គុណនិងទោស ក៏តិះដៀល និងសរសើរ ដូច្នោះ ។

ពិតមែន ព្រោះទ្រង់ឃើញបុគ្គល អ្នកធ្វើការប្រព្រឹត្តកន្លងសីលសេចក្តីគិត រមែងមិនកើតឡើងដល់ព្រះមានព្រះភាគថា "អ្នកនេះជាអ្នកប្រាកដដោយជាតិ ឬ ដោយគោត្រ ឬដោយភាពជាបុត្ររបស់អ្នកមានត្រកូល ឬដោយគណ្ឋៈ (ការសិក្សា) ឬដោយធុតង្គវត្ត ជាអ្នកមាន

យស, តថាគតសមគួរនឹងរក្សាបុគ្គលដូច្នេះទុក” ព្រោះទ្រង់ឃើញបុគ្គលអ្នកមានគុណមានសីលជាទីស្រឡាញ់ ចិត្តដែលគិតនិងបិទបាំងគុណរបស់គេមិនបានកើតឡើងឡើយ, ការពិត ព្រះអង្គ រមែងតិះដៀល បុគ្គលដែលគួរតិះដៀល ប៉ុណ្ណោះ រមែងសរសើរបុគ្គលដែលគួរសរសើរប៉ុណ្ណោះ, និងសុទិន្នភិក្ខុនេះ ជាអ្នកសមគួរតិះដៀល , ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់តាំងនៅក្នុងលក្ខណៈរបស់អ្នករឹងប៉ឹង មានព្រះហឫទ័យមិនលំអៀងទ្រង់បានតិះដៀលសុទិន្នភិក្ខុនោះ ដោយព្រះពុទ្ធតម្រាស់ថា **អននុច្ឆវិកំ** ជាដើម ។

## អត្ថាធិប្បាយកម្មដែលមិនគួរដល់សមណៈជាដើម

ក្នុងពាក្យថា **អននុច្ឆវិកំ អននុលោមិកំ អប្បដិរូបំ អស្សាមណកំ :** **មិនសមគួរ មិនត្រូវទំនង មិនត្រូវបែប មិនមែនជារបស់សមណៈ** នោះ មានការពណ៌នាសេចក្ដីដូចតទៅនេះ ៖

ម្នាលមោឃបុរស អ្នកជាមនុស្សទទេ កម្មដែលអ្នកធ្វើហើយមិនសមគួរដល់ធម៌ដែលធ្វើភាពជាសមណៈ ឬដល់មគ្គផលនិព្វាន និងសាសនា គឺ មិនប្រព្រឹត្តទៅតាម បានដល់ មិនស្រេបទៅតាមពណ៌សម្បុរ គឺ សម្រស់ បានដល់ ភាពល្អនៃធម៌ទាំងនោះ, តាមសេចក្ដីពិត ជាកម្ម

ឃ្លាតឆ្ងាយពីធម៌ទាំងនោះវិញទេ, ក៏ព្រោះភាពជារបស់មិនសមគួរនុ៎ះឯង កម្មនោះទើបឈ្មោះថា ជារបស់មិនត្រឹមត្រូវ គឺ មិនអនុលោមដល់ធម៌ទាំងនោះ, តាមការពិត ជារបស់ទាស់គ្នា គឺ តាំងនៅក្នុងភាពជាសត្រូវគ្នា, ព្រោះភាពជារបស់មិនត្រឹមត្រូវនុ៎ះឯង កម្មនោះទើបចាត់ជាកម្មមិនសម គឺ មិនជាកម្មសមគ្នា ដូចគ្នា ត្រូវចំណែកគ្នាទេ, តាមការពិត ជារបស់មិនដូចគ្នា ក៏មិនត្រូវចំណែកគ្នាតែម្តង, ក៏ព្រោះភាពជារបស់មិនសមគ្នានុ៎ះឯង កម្មនោះទើបចាត់ជា មិនមែនរបស់សម្រាប់សមណៈ គឺ មិនជាកម្មរបស់ពួកសមណៈ, ព្រោះកម្មដែលមិនជារបស់សម្រាប់សមណៈ កម្មនោះទើបចាត់ជាអកប្បិយ, ពិតមែន កម្មណាមិនមែនកម្មរបស់សមណៈ, កម្មនោះ រមែងមិនសមគួរដល់សមណៈទាំងនោះ, ព្រោះភាពដែលកម្មជាអកប្បិយ កម្មនោះទើបចាត់ជា មិនគួរធ្វើ, ពិតមែន កម្មណា មិនសមគួរដល់ពួកសមណៈ, សមណៈទាំងឡាយ រមែងមិនធ្វើកម្មនោះ ។ តែកម្មនេះ ដែលលោកធ្វើហើយ, ម្នាលមោឃបុរស ព្រោះហេតុនោះ កម្មដែលមិនសមគួរ មិនត្រឹមត្រូវ មិនសមហេតុ មិនមែនកិច្ចរបស់សមណៈ ជាអកប្បិយ មិនគួរធ្វើ ឈ្មោះថា (ជាកម្ម)ដែលលោកធ្វើហើយ ។

ពាក្យថា កថំ ហិ នាម : គួរបើដែរ មានសេចក្តីថា ព្រោះ

ហេតុឈ្មោះអ្វីហ្ន៎ ? មានពាក្យអធិប្បាយថា លោកសម្លឹងឃើញហេតុឈ្មោះអ្វីហ្ន៎ ?

លំដាប់នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសេចក្តីមិនមានហេតុ ទើបត្រាស់ពាក្យថា **ឆន្ន មឃា មោឃបុរិស : នែមោឃបុរស ធម៌ដែលតថាគត** ជាដើមខាងមុខ ។ ពាក្យទាំងអស់មានសេចក្តីដូចពោលហើយនុ៎ះឯង ។

កម្មលាមក ដែលសុទិន្នភិក្ខុនោះធ្វើហើយ កាលឱ្យផល រមែងជាកម្មមានវិបាកជាទុក្ខយ៉ាងក្រៃលែង, ព្រោះហេតុនោះ ឥឡូវនេះ កាលនឹងទ្រង់ពោលបន្ទោសសុទិន្នភិក្ខុដោយព្រះហឫទ័យប្រកបដោយសេចក្តីអាណិត ដូចមាតាបិតាអ្នកមានសេចក្តីអាណិត ពោលបន្ទោសបុត្រដែលធ្វើខុសហើយ ដូច្នោះ ទើបត្រាស់ពាក្យថា **វរន្តេ មោឃបុរិស អាសីវិសស្ស ឃោរវិសស្ស មុខេ អង្គជាតំ បក្ខិត្តំ ន ត្វេវ មាតុគាមស្ស អង្គជាតេ អង្គជាតំ បក្ខិត្តំ : ម្នាលមោឃបុរស អ្នកឯងដាក់អង្គជាតទៅក្នុងមាត់អាសិរពិស ជាសត្វមានពិសក្លៀវក្លាប្រសើរជាង អ្នកឯងដាក់អង្គជាតទៅក្នុងអង្គជាតរបស់មាតុគ្រាមមិនប្រសើរឡើយ** ជាដើម ដើម្បីសម្តែងវិបាកនោះដល់សុទិន្នភិក្ខុនោះ ។

ក្នុងពាក្យថា វរន្តេ មោឃបុរិស ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ពិសរបស់ពស់នោះ រមែងជ្រាបសាយរហ័ស គឺ ឆាប់ ហេតុនោះ ពស់នោះ ទើបឈ្មោះថា **អាសីវិសៈ** (មានពិសជ្រាបរហ័ស) ពិសរបស់ពស់នោះ ដ៏ពន្លឹក គឺ កាចសាហាវ ហេតុនោះ ពស់នោះ ទើបឈ្មោះថា **ឃោរវិសៈ** (មានពិសដ៏ពន្លឹក) ។ នៃអាសិរ្វិស ដែលមានពិសជ្រាបរហ័ស មានពិសខ្លាំងក្លានោះ ។ គប្បីភ្ជាប់បទនេះថា **បក្ខិត្តំ** ដោយបទថា **វរំ** នេះ ។ អង្គជាតិ ដែលលោកស៊កចូលទៅក្នុងមាត់នៃពស់មានពិសជ្រាបសាយរហ័ស ដូច្នេះប្រសើរជាង ។ អធិប្បាយថា បើអង្គជាតិដែលលោកស៊កចូលទៅសោត, គប្បីជារបស់ប្រសើរជាង គឺគប្បីជាការល្អ ជាការប្រពៃ ជាការប្រពៃហើយ ។

បទថា **ន ត្វេវ** : **អ្នកឯង ... មិន(ប្រសើរ)ឡើយ** មានសេចក្តីថា មិនប្រសើរឡើយ គឺ មិនជាការល្អឡើយ មិនជាការប្រពៃឡើយ បានដល់ មិនជាការប្រពៃហើយតែម្តង ។ ក្នុងគ្រប់ ៗ បទក៏ន័យនេះ ។

បទថា **កណ្ហសប្បស្ស** : **ពស់វែក** បានដល់ ពស់ពណ៌ខ្មៅ ។

បទថា **អង្គារកាសុយា** : **ក្នុងគំនររងើកភ្លើង** ប្រែថា ក្នុងរណ្តៅដែលពេញដោយរងើកភ្លើង ឬក្នុងគំនររងើកភ្លើង ។

បទថា **អាទិត្តាយ** : **ដែលឆេះ** បានដល់ ដែលភ្លើងឆេះសព្វហើយ គឺ មានពន្លឺអណ្តាតភ្លើងឆេះសន្ធោសន្ធៅហើយ ។

បទថា សម្បជ្ជលិតាយ : ប្រាលរន្ទាល បានដល់ រុងរោចន៍ គឺ បញ្ចេញអណ្តាតភ្លើងឡើងដោយជុំវិញគ្រប់ទីកន្លែង ។

បទថា សញ្ជោតិភូតាយ[១] : ភ្លឺ បានដល់ មានពន្លឺ ។ មានពាក្យអធិប្បាយថា មានការកើតឡើងនៃពន្លឺដូចគ្នាតែមួយអំពីអណ្តាតភ្លើងដែលឆេះសន្ធោសន្ធៅឡើងដោយជុំវិញទាំងអស់ ។

ក្នុងពាក្យថា តំ កិស្ស ហេតុ : ហេតុអ្វី បានជាតថាគតពោលដូច្នោះ នេះ បើនឹងមានអ្នកសួរ សួរថា ពាក្យដែលតថាគតពោលថាប្រសើរជាង តើមានហេតុនៃអ្វី គឺ ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះគប្បីប្រសព្វសេចក្តីស្លាប់ អធិប្បាយថា អ្នកណាគប្បីស៊កអង្គកំណើតចូលទៅក្នុងមាត់ពស់ជាដើមនោះ, អ្នកនោះគប្បីប្រសព្វសេចក្តីស្លាប់ ។

---

១. ភូមា. សជោតិភូតាយ ។

ច្រើនបទថា ឥតោនិទានញ្ច ខោ ។បេ។ ឧបបជ្ជេយ្យ : ចំណែកខាងភិក្ខុដែលដាក់អង្គជាតទៅក្នុងអង្គជាតមាតុគ្រាម ។ល។ ត្រូវទៅកើត មានសេចក្តីថា បុគ្គលអ្នកធ្វើការស៊កអង្គកំណើត ចូលក្នុងអង្គកំណើតរបស់មាតុគ្រាមនោះ គប្បីចូលដល់នរកដែលមានការធ្វើនេះ

ជាហេតុ ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងផលកម្មមានទោសច្រើន យ៉ាងនោះ ហើយទើបទ្រង់តិះដៀលសុទិន្នភិក្ខុនោះ ទ្រង់មិនបានតិះដៀលប្រាថ្នាឱ្យសុទិន្នភិក្ខុនោះប្រសព្វសេចក្តីទុក្ខទេ ។

ច្រើនបទថា **តត្ថ ឆាម តុំ** : **កាលបើកម្មទាំងនោះ** សេចក្តីថា កាលកម្មយ៉ាងនោះ គឺ បែបនោះ សូម្បីជារបស់មានទោសច្រើនយ៉ាងនេះ លោក (ក៏ឈ្មោះថា បានត្រូវអសទ្ធម្មដែលជាធម៌របស់អ្នកស្រុក ជាមារយាទរបស់មនុស្សថោកទាប) ។

សព្ទថា **យំ** ដែលមាននៅក្នុងពាក្យថា **យំ តុំ** នេះ ជានិបាតចុះក្នុងអត្ថនៃការមើលងាយ ។ បទថា **តុំ** ជាវេវចនៈនៃ **តំ** សព្ទ ។ លោកពោលអធិប្បាយទុកសូម្បីដោយបទទាំងពីរថា បានដល់ សេចក្តីមើលងាយ គឺ សេចក្តីមើលងាយយ៉ាងណាមួយ ។

បទថា **អសទ្ធម្មំ** : **ធម៌នៃបុគ្គលដែលមិនស្ងប់** បានដល់ ធម៌របស់អសប្បុរស គឺ មនុស្សថោកទាប អធិប្បាយថា ដែលមនុស្សថោកទាបទាំងនោះ គប្បីសេព ។

បទថា **គាមធម្មំ** : **ជាធម៌របស់អ្នកស្រុក** បានដល់ ធម៌របស់ពួកអ្នកស្រុក, មានពាក្យអធិប្បាយថា ជាធម៌របស់ពួកជនអ្នកនៅក្នុង

ស្រុក ។

បទថា **វសលធម្មំ** : **ជាធម៌របស់មនុស្សថោកថយ** សេចក្ដីថា ជាមារយាទរបស់ពួកជន ជាមនុស្សថោកទាប ព្រោះអត្ថថា បង្ហូរចេញ គឺ បញ្ចេញចោល នូវបាបធម៌ បានដល់ របស់ពួកបុរសអាក្រក់ ថោកទាប ។ ម្យ៉ាងទៀត ធម៌ជាហេតុហូរចេញនៃកិលេស ឈ្មោះថា វសលធម៌ ។

បទថា **ទុដ្ឋុល្លំ** : **អាក្រក់** បានដល់ ជារបស់អាក្រក់ និងជារបស់គ្រោតគ្រាត ដែលត្រូវកិលេសប្រទូសរ៉ាយ, មានពាក្យអធិប្បាយថា ជារបស់មិនសុខុម គឺ មិនល្អិតល្អន់ ។

បទថា **ឧទកន្តិកំ** : **មានកិច្ចដោយទឹកជាទីបំផុត** សេចក្ដីថា មេថុនធម្ម ឈ្មោះថា មានទឹកជាទីបំផុត ព្រោះអត្ថថា កិច្ចជាប់ដោយទឹកជាទីបំផុត គឺ ជាអវសាននៃមេថុនធម្មនោះ ។ នូវមេថុនធម្មដែលមានទឹកជាទីបំផុតនោះ ។

បទថា **រហស្សំ** : **ជាធម៌លាក់លៀម** បានដល់ ជាកម្មកំបាំង គឺ កើតឡើងក្នុងឱកាសដែលបិទបាំង ។ ពិតមែន ធម៌នេះ អ្នកណា ៗ មិនអាចនឹងធ្វើឱ្យបើកចំហ គឺ មិនអាចនឹងធ្វើក្នុងវិស័យដែលបុគ្គលពួកដទៃទៀតនឹងឃើញបាន ព្រោះជាកម្មគួរខ្មើម ។ ព្រោះហេតុនោះ ព្រះមានព្រះ

ភាគ ទើបត្រាស់ថា ជាកម្មកំបាំង ។

បទថា ទ្វយទ្វយសមាបត្តិ : ជាធម៌របស់ជនពីរ ៗនាក់ ប្រែថា ដែលជនពីរនាក់ ៗ គប្បីប្រព្រឹត្តរួមគ្នា បាលីថា ទ្វយំ ទ្វយំ សមាបត្តិ ក៏មាន ។ អាចារ្យពួកខ្លះសូត្រថា ទយទយសមាបត្តិ ដូច្នេះខ្លះ ។ ពាក្យនោះ មិនល្អ ។ គប្បីប្រកបបទថា សមាបជ្ជិស្សសិ : តែងប្រជុំធ្វើតាមតែប្រទះ នោះ ចូលដោយនាមសព្ទដែលលោកពោលទុកក្នុងបទថា តត្ថ ឆាម តុំ នេះថា សមាបជ្ជិស្សសិ នាម : លោកក៏បានឈ្មោះថា តែងប្រជុំធ្វើតាមតែប្រទះ (គឺបានត្រូវអសទ្ធម្ម) ។

## សុទិន្នភិក្ខុជាអ្នកដំបូងក្នុងការសេពមេថុនធម្ម

ព្រះមានព្រះភាគ ទ្រង់ប្រាថ្នាសំដៅយកព្រះសាសនា ត្រាស់ថា "ម្នាលមោឃបុរស (ក្នុងសាសនានេះ) មានតែអ្នកឯងហើយ ជាអ្នកធ្វើអកុសលខាងដើមនៃអកុសលធម៌ទាំងឡាយមានប្រមាណច្រើន ហៅថា ជាអ្នកផ្ដើមធ្វើមុនគេ" ។ មានពាក្យអធិប្បាយថា អ្នករាប់ថា ជាអ្នកផ្ដើមធ្វើមុនគេ ព្រោះជាមនុស្សខាងដើមនៃបុគ្គលទាំងឡាយ ឬអកុសលធម៌ទាំងឡាយជាច្រើនក្នុងព្រះសាសនានេះ ព្រោះធ្វើមុនបុគ្គលទាំងពួង គឺ ជាអ្នកឱ្យមក បានដល់ បង្ហាញនូវឧបាយ ព្រោះជាអ្នកដើរមកនោះមុន

បុគ្គលទាំងពួង ។

ពិតមែន ក្នុងពាក្យថា ពហុន្នំ ខោ : មានប្រមាណច្រើន ជាដើមនេះ មានសេចក្ដីប្រាថ្នាដូច្នេះថា បុគ្គលជាច្រើន បានលេសនេះហើយ កំណាត់តាមកិរិយារបស់លោក នឹងធ្វើអកុសលធម៌មានប្រការផ្សេង ៗ មានសេពមេថុនធម្មនឹងមេស្វាជាដើម ។

បទថា អនេកបរិយាយេន : ដោយការប្រព្រឹត្តទៅជុំវិញមិនមែនមួយ គឺ ដោយហេតុជាច្រើន ដែលត្រាស់ហើយដោយន័យជាដើមថា អនន្ទុច្ចវិកំ : មិនសមគួរ នេះ ។

## អ្នកមិនសង្រួមជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ ៤

ច្រើនបទថា ទុព្ភរតាយ ។បេ ។ កោសជ្ជស្ស អវណ្ណំ ភាសិត្វា : ទ្រង់សម្ដែងទោសនៃការចិញ្ចឹមក្រ ។ល ។ និងសេចក្ដីខ្ជិលប្រអូស មានសេចក្ដីថា ត្រាស់ទោស គឺ អំពើដែលគួរតិះដៀល បានដល់ កម្មដែលគួរតិះដៀលនៃអសំវរៈដែលជាទីតាំងនៃទោសទាំងឡាយមានភាពជាអ្នកលំបាកចិញ្ចឹមជាដើម ។

ពិតមែន ខ្ទនរបស់បុគ្គល អ្នកតាំងនៅក្នុងសេចក្ដីមិនសង្រួមរមែងដល់ភាពជាសភាពដែលចិញ្ចឹមក្រ និងថែទាំរក្សាក្រ, ព្រោះហេតុ

នោះ អសំវរៈ លោកទើបហៅថា ការចិញ្ចឹមក្រ និងថែទាំរក្សាក្រ ។

មួយទៀត ខ្លួនរបស់បុគ្គលអ្នកតាំងនៅក្នុងសេចក្តីមិនសង្រួម រមែងដល់ភាពជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ ៤ និងបានបច្ច័យទាំងឡាយ សូម្បីមានប្រមាណប៉ុនភ្នំសិនេរុហើយ ក៏នៅតែជាអ្នកមិនសន្តោស, ព្រោះហេតុនោះ អសំវរៈលោកទើបហៅថា ជាអ្នកប្រាថ្នាច្រើន និងជាអ្នកមិនសន្តោស ។

មួយទៀត ខ្លួនរបស់បុគ្គលអ្នកតាំងនៅក្នុងសេចក្តីមិនសង្រួម រមែងប្រព្រឹត្តទៅដើម្បីសេចក្តីប្រឡូកប្រឡំដោយពួកគណៈ និងដើម្បីសេចក្តីប្រឡាក់ប្រឡូសដោយកិលេស ទាំងរមែងជាសភាពប្រព្រឹត្តទៅតាមសេចក្តីខ្ជិលច្រអូស គឺ ប្រព្រឹត្តទៅដើម្បីញ៉ាំងវត្ថុជាទីតាំងនៃសេចក្តីខ្ជិលច្រអូស ៨ យ៉ាង ឱ្យបរិបូណ៌,[១] ព្រោះហេតុនោះ អសំវរៈ លោកទើបហៅថា ការប្រឡូកប្រឡំ និងសេចក្តីខ្ជិលច្រអូស ។

---

(១) អង្គ. អដ្ឋ. ៤៨. ៥/៣៣៩ ។

## អ្នកសង្រួមមិនជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ ៤

ច្រើនបទថា សុភរតាយ ។បេ។ វីរិយារម្ភស្ស វណ្ណំ ភាសិត្វា : ទ្រង់សម្តែងនូវគុណនៃការដែលគេចិញ្ចឹមងាយ ។ល។

និងការប្រារព្ធព្យាយាម មានសេចក្ដីថា ទ្រង់សរសើរគុណនៃសំវរៈ ដែលជាទីតាំងនៃគុណទាំងឡាយ មានភាពជាអ្នកចិញ្ចឹមងាយជាដើម ។

ពិតមែន ខ្លួនរបស់បុគ្គលអ្នកលះបង់អសំវរៈ ហើយតាំងនៅក្នុងសំវរៈ រមែងជាសភាពដែលចិញ្ចឹមងាយ ថែទាំរក្សាងាយ រមែងដល់ភាពជាអ្នកប្រាថ្នាតិច គឺ អស់ចំណង់ក្នុងបច្ច័យ ៤ និង រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសន្ដោស ៣ យ៉ាង ដោយអំណាចនៃយថាលាភសន្ដោស យថាពលសន្ដោស និងយថាសារុប្បសន្ដោស ក្នុងបច្ច័យមួយមុខ ៗ ព្រោះហេតុនោះ សំវរៈ លោកទើបហៅថា ភាពជាអ្នកចិញ្ចឹមងាយ ភាពជាអ្នកថែទាំរក្សាងាយ **សេចក្ដីប្រាថ្នាតិច និងសេចក្ដីសន្ដោស** ។

មួយទៀត ខ្លួនរបស់បុគ្គលអ្នកលះបង់អសំវរៈ តាំងនៅក្នុងសំវរៈ រមែងប្រព្រឹត្តទៅដើម្បីភាពជាអ្នកផូរផង់ និងភាពជាអ្នកកម្ចាត់នូវកិលេសចេញ, ព្រោះហេតុនោះ សំវរៈលោកទើបហៅថា **ចិត្តផូរផង់ និងការកម្ចាត់នូវកិលេស** ។

មួយទៀត ខ្លួនរបស់បុគ្គលអ្នកលះបង់អសំវរៈ ហើយតាំងនៅក្នុងសំវរៈ មិនចូលទៅជិតកាយទុច្ចរិត និងវចីទុច្ចរិត ដែលមិននាំឱ្យកើតសេចក្ដីជ្រះថ្លា គឺ មិនជាទីតាំងនៃសេចក្ដីជ្រះថ្លា មិនស្ងប់ មិនរៀបរយនៃកាយនិងវាចា និងមិនចូលទៅជិតអកុសលវិតក្កៈ ៣ ដែលមិននាំ

ចិត្តឱ្យកើតសេចក្ដីថ្លាផូរផង់ គឺ មិនជាទីតាំងនៃសេចក្ដីថ្លាផូរផង់នៃចិត្តមិនស្ងប់ មិនរៀបរយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីបរិបូណ៌នៃកាយសុចរិត វចីសុចរិត និងកុសលវិតក្កៈ ៣ ដែលខុសប្លែកពីការមិនសង្រួមនោះឯង ដែលនាំឱ្យកើតសេចក្ដីជ្រះថ្លា គឺ ជាទីតាំងនៃសេចក្ដីជ្រះថ្លា ស្ងប់រៀបរយ, ព្រោះហេតុនោះ សំវរៈ លោកទើបហៅថា ភាពជាអាការឱ្យកើតសេចក្ដីជ្រះថ្លា ។

## អ្នកតាំងនៅក្នុងសំវរៈ ជាអ្នកមិនសន្សំកិលេសទាំងពួង

មួយទៀត ខុទ្ទរបស់បុគ្គលអ្នកលះបង់អសំវរៈ តាំងនៅក្នុងសំវរៈ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកវដ្ដៈ ដែលកើតពីការមិនសន្សំកិលេសទាំងពួង និងដើម្បីសេចក្ដីបរិបូណ៌នៃវត្ថុជាទីតាំងនៃវិរិយារម្ភៈ ៨ យ៉ាង[១] ព្រោះហេតុនោះ សំវរៈ លោកទើបហៅថា "សេចក្ដីមិនសន្សំនិងការប្រារព្ធសេចក្ដីព្យាយាម" ដូច្នេះឯង ។

១. មនោរ. អដ្ឋ. ៤៨. ៩៦/៣៤៣ ។

ពាក្យថា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ : ដ៏ល្មមសមគួរដល់សិក្ខាបទនោះ ដល់សំវរៈនោះ ចំពោះភិក្ខុទាំងឡាយ សេចក្ដីថាទ្រង់ធ្វើព្រះធម្មទេសនាក្រៅផ្ទៃរឿង ដែលរួចផុតអំពីបាលី មិនជាប់ដោយ

សុត្តន្ត:ដែលបដិសំយុត្តដោយសំវរប្បហាន: ដែលសមគួរនឹងអនុលោមដល់សិក្ខាបទ ដែលទ្រង់បញ្ញត្តិក្នុងកាលឥឡូវនេះ ទាំងសមគួរ និងអនុឡោមដល់សំវរ:ដែលត្រាស់ដោយធម៌ទាំងឡាយ មានភាពជាអ្នកចិញ្ចឹមឆាយជាដើម ដល់ភិក្ខុទាំងឡាយដែលប្រជុំគ្នាហើយក្នុងស្ថានទីនោះ ។

បានឮថា ព្រះមានព្រះភាគ ប្រៀបដូចអ្នកតែងរបៀបផ្កាឈើ ៥ ពណ៌, ប្រៀបដូចជាងចាត់ចែងក្នុងកែវ កាលនឹងទ្រង់គម្រាមបុគ្គលទាំងឡាយ អ្នកពេញចិត្តក្នុងអសំវរ: ប្រាថ្នានឹងហាមឃាត់ដោយវដ្តភ័យ ដែលមានក្នុងសម្បរាយភព នឹងទ្រង់សម្តែងទោសច្រើនប្រការ នឹងទ្រង់ញ៉ាំងបុគ្គលអ្នកប្រាថ្នាការសិក្សាតាំងនៅក្នុងសំវរ: ពួកខ្លះឱ្យប្រតិស្ឋាននៅក្នុងព្រះអរហត្ត, ពួកខ្លះឱ្យតាំងនៅក្នុងអនាគាមិផលសកទាគាមិផល និងសោតាបត្តិផល, នឹងទ្រង់ញ៉ាំងបុគ្គលទាំងឡាយសូម្បីអ្នកប្រាសចាកឧបនិស្ស័យឱ្យប្រតិស្ឋានក្នុងមកសួគ, ទើបទ្រង់ធ្វើធម្មទេសនា ឱ្យមានទីឃនិកាយជាប្រមាណខ្លះ ឱ្យមានមជ្ឈិមនិកាយជាប្រមាណខ្លះ ក្នុងស្ថានទាំងឡាយដូច្នេះ ។ ព្រះឧបាលីថេរ: សំដៅយកធម៌ទេសនានោះ ទើបពោលពាក្យនេះថា ទ្រង់ធ្វើធម្មីកថា ដែលសមគួរដល់សិក្ខាបទនិងសំវរ:នោះ ដែលសមគួរដល់សិក្ខាបទ និងសំវរ:នោះដល់ភិក្ខុទាំងឡាយ ។

បទថា តេន ហិ : **បើដូច្នោះ** មានសេចក្តីថា ព្រោះអជ្ឈាចារ្យនោះ របស់សុទិន្នភិក្ខុដែលជាហេតុ ។

ក្នុងបទថា សិក្ខាបទំ : **សិក្ខាបទ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ដែលឈ្មោះថា **សិក្ខា** ព្រោះអត្ថថា ជាគុណជាតដែលបុគ្គលគប្បីសិក្សា ។ ដែលឈ្មោះថា បទ ព្រោះអត្ថថា ជាមកជាគ្រឿងដែលបុគ្គលគប្បីដល់ ។ មកជាគ្រឿងដែលបុគ្គលគប្បីដល់នៃសិក្ខាឈ្មោះថា សិក្ខាបទ ។ សេចក្តីថា ឧបាយនៃការបានសិក្ខា ។

ម្យ៉ាងទៀត មានពាក្យអធិប្បាយថា ធម្មជាតិជាមូល គឺ ជាទីអាស្រ័យជាទីពុំនាក់នៃសិក្ខា ។ ពាក្យថា **សិក្ខាបទ** នោះ ជាឈ្មោះនៃការសង្រួមចាកមេថុនដោយវៀរចាកមេថុន ។ ពិតមែន មេថុនសំវរៈ លោកប្រាថ្នាយកថា សិក្ខាបទ ក្នុងទីនេះ ព្រោះភាពជាមកនៃធម៌ គឺ សីល វិបស្សនា ឈាន និងមគ្គ ពោលគឺ សិក្ខាដទៃចាកមេថុនសំវរៈនោះ ដោយអំណាចនៃសេចក្តីដូចពោលហើយ ។

ក៏ឯសេចក្តីនេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងវិភង្គនៃសិក្ខាបទ ។ ម្យ៉ាងទៀត សូម្បីពាក្យដែលសម្តែងសេចក្តីនោះ គប្បីជ្រាបថា "ជាសិក្ខាបទ" ពិតមែន សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនេះថា បណ្តាពួកទាំងនោះ ពួកនាមពួកបទ ពួកភាសា ពួកព្យញ្ជនៈ

យ៉ាងណា, យ៉ាងនោះ ឈ្មោះថា សិក្ខាបទ ។

មួយទៀត កាលលោកពោលថា "អនភិជ្ឈា ជាធម្មបទ" មានអត្ថាធិប្បាយថា "អនភិជ្ឈា ជាចំណែកធម៌មួយ" នេះយ៉ាងណា, សូម្បីក្នុងទីនេះក៏យ៉ាងនោះ កាលលោកពោលថា "សិក្ខាបទ" នឹងគប្បីជ្រាបសេចក្ដីថា "ចំណែកនៃសិក្ខា គឺ ប្រទេសមួយនៃសិក្ខា" ដូច្នេះ ក៏បាន ។

## ប្រយោជន៍នៃការបញ្ញត្តិសិក្ខាបទ ១០ យ៉ាង

ច្រើនបទថា ទស អត្ថវសេ បដិច្ច : ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង មានសេចក្ដីថា នឹងអាស្រ័យ គឺ សំដៅយកប្រារព្ធអំណាចនៃហេតុ គឺ ប្រយោជន៍ពិសេស ១០ យ៉ាង ដែលនឹងគប្បីបាន ព្រោះហេតុបញ្ញត្តិសិក្ខាបទ ។ មានពាក្យអធិប្បាយថា សម្លឹងឃើញសេចក្ដីសម្រេចប្រយោជន៍ពិសេស ១០ យ៉ាង ។ ឥឡូវនេះ ព្រះមានព្រះភាគ នឹងសម្ដែងអំណាចប្រយោជន៍ ១០ យ៉ាងនោះ ទើបត្រាស់ពាក្យថា សង្ឃសុដ្ឋុតាយ : ដើម្បីសេចក្ដីល្អដល់សង្ឃ ជាដើម ។

## អធិប្បាយប្រយោជន៍ការបញ្ញត្តិសិក្ខាបទ ១០ យ៉ាង

បណ្ដាអំណាចប្រយោជន៍ ១០ យ៉ាងនោះ ដែលឈ្មោះថា សេចក្ដីឃើញប្រពៃរបស់សង្ឃ បានដល់ ការដែលសង្ឃព្រមទទួលថា

ល្អ ; គឺ ការដែលសង្ឃទទួលព្រះតម្រាស់ថា "ល្អណាស់ ព្រះអង្គ" ដូចក្នុងអនាគតស្ថានដែលថា "ល្អណាស់ សម្មតិទេព" ពិតមែន ភិក្ខុណា ព្រមទទួលព្រះតម្រាស់របស់ព្រះតថាគត, ការព្រមទទួលព្រះតម្រាស់នោះរបស់ភិក្ខុនោះ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលយូរ ។ ព្រោះហេតុនោះ កាលព្រះមានព្រះភាគទ្រង់ធ្វើឱ្យច្បាស់នូវសេចក្ដីនេះថា "តថាគតនឹងសម្ដែងទោសក្នុងការមិនព្រមទទួល និងអានិសង្សក្នុងការព្រមទទួល ហើយទើបបញ្ញត្តិ (សិក្ខាបទ) គឺ មិនញាំញីដោយពលការ ដើម្បីឱ្យសង្ឃព្រមទទួលពាក្យរបស់តថាគតថា "ល្អណាស់ ព្រះអង្គ" ដូច្នេះ ទើបត្រាស់ពាក្យថា "ដើម្បីសេចក្ដីយើញប្រពៃនៃសង្ឃ" ។

បទថា **សង្ឃផាសុតាយ** : **ដើម្បីនៅសប្បាយដល់សង្ឃ** គឺ ដើម្បីសេចក្ដីសប្បាយនៃសង្ឃ, អធិប្បាយថា ដើម្បីប្រយោជន៍ដល់សេចក្ដីនៅជាសុខ ដោយការរស់នៅរួមគ្នា ។

ច្រើនបទថា **ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ** : **ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយ ដែលមិនអៀនខ្មាស** សេចក្ដីថា បុគ្គលអ្នកទ្រុស្តសីល ឈ្មោះថា បុគ្គលដែលប្រដៅក្រ, ភិក្ខុពួកណា ស្ងប់ដែលភិក្ខុទាំងឡាយនឹងឱ្យដល់ភាពជាអ្នកប្រដៅងាយ រមែងដល់បានដោយ

លំបាក, កំពុងធ្វើការល្មើស ឬធ្វើហើយ រមែងមិនខ្មាស, ដើម្បីប្រយោជន៍ដល់ការគ្រប់សង្កត់ភិក្ខុទាំងនោះ ។

ពិតមែន ភិក្ខុទាំងនោះ កាលសិក្ខាបទមិនមាន នឹងបៀតបៀនសង្ឃដោយពាក្យថា រឿងអ្វីដែលពួកលោកឃើញមកហើយ រឿងអ្វីដែលពួកលោកបានស្តាប់មកហើយ វត្ថុអ្វីដែលពួកខ្ញុំព្រះករុណាធ្វើហើយ ពួកលោកលើកអាបត្តិណា ព្រោះវត្ថុអ្វីឡើងគ្រប់សង្កត់ពួកខ្ញុំព្រះករុណា, ក៏កាលសិក្ខាបទមាននៅប្រាកដ សង្ឃនឹងអាងសិក្ខាបទហើយ គ្រប់សង្កត់ភិក្ខុទាំងនោះ ដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនា ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ដើម្បីគ្រប់សង្កត់ពួកបុគ្គលដែលប្រដៅក្រ ។

ប្រើនបទថា **បេសលានំ ភិក្ខូនំ ផាសុវិហារាយ** : ដើម្បីនៅជាសុខស្រួលដល់ភិក្ខុទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ គឺដើម្បីប្រយោជន៍ដល់សេចក្តីនៅសុខសប្បាយរបស់ភិក្ខុដែលមានសីលជាទីស្រឡាញ់ ។ ពិតមែន ភិក្ខុទាំងឡាយ អ្នកមានសីលជាទីស្រឡាញ់ មិនដឹងវត្ថុដែលគួរធ្វើនិងមិនគួរធ្វើ វត្ថុដែលមានទោសនិងមិនមានទោស កំណត់ព្រំប្រទល់នៃការព្យាយាមដើម្បីសេចក្តីបរិបូណ៌នៃត្រៃសិក្ខា, កាលមានសេចក្តីសង្ស័យ រមែងលំបាក រមែងក្តៅក្រហាយ, តែកាលដឹងវត្ថុ

ដែលគួរធ្វើនិងមិនគួរធ្វើ វត្ថុដែលមានទោសនិងមិនមានទោស កំណត់ព្រំប្រទល់នៃការព្យាយាម ដើម្បីសេចក្ដីបរិបូណ៌នៃត្រៃសិក្ខាហើយ រមែងមិនលំបាក រមែងមិនក្ដៅក្រហាយ ។ ព្រោះហេតុនោះ ការបញ្ញត្តិសិក្ខាបទ ទើបប្រព្រឹត្តទៅដើម្បីនៅសុខសប្បាយរបស់ពួកភិក្ខុនោះ ។

ម្យ៉ាងទៀត ការគ្របសង្កត់បុគ្គលដែលប្រដៅក្រទាំងឡាយនោះឯងជាការនៅសុខសប្បាយនៃភិក្ខុនោះ ។ ព្រោះថា ឧបោសថក៏តាំងនៅមិនបាន បវារណាក៏តាំងនៅមិនបាន សង្ឃកម្មទាំងឡាយក៏ប្រព្រឹត្តទៅមិនបាន សេចក្ដីសាមគ្គីក៏មិនមាន ព្រោះអាស្រ័យពួកបុគ្គលអ្នកទ្រុស្តសីល ។ ភិក្ខុទាំងឡាយមានអារម្មណ៍តែមួយមិនបាន ក៏មិនអាចប្រកបនូវឧទ្ទេស បរិបុច្ឆា, និងកម្មដ្ឋានជាដើមបាន ។ ក៏កាលពួកបុគ្គលអ្នកទ្រុស្តសីលត្រូវគ្របសង្កត់ចេញហើយ នូវឧបទ្វវៈ សូម្បីទាំងអស់នេះមិនមានសល់, កាលនោះពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ រមែងនៅជាសុខសប្បាយ ។

ក្នុងពាក្យថា "ដើម្បីសេចក្ដីនៅជាសុខសប្បាយរបស់ភិក្ខុទាំងឡាយអ្នកមានសីលជាទីស្រឡាញ់" នេះបណ្ឌិតគប្បីជ្រាបអធិប្បាយ ២ ន័យដោយប្រការដូច្នេះ ។

ពាក្យថា "ដើម្បីការពារអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន" អធិប្បាយថា ទុក្ខពិសេសមានការវាយដោយបាតដៃ វាយដោយដំបង កាត់ដៃកាត់ជើង សេចក្ដីខូចកេរ្តិ៍ឈ្មោះ សេចក្ដីសាបសូន្យ

យសនិងសេចក្តីក្តៅក្រហាយ ជាដើម ដែលបុគ្គលមិនតាំងនៅក្នុងសំវរៈ នឹងគប្បីដល់ក្នុងអត្តភាពនេះឯង ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន ។ ដើម្បីការពារ គឺ បិទបាំងមកមកនៃអាសវៈដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននេះ ដោយប្រការដូច្នេះ ។

ពាក្យថា "ដើម្បីកម្ចាត់អាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងសម្បរាយភព" មានសេចក្តីថា ទុក្ខពិសេសមានបាបកម្មដែលខ្លួនធ្វើហើយជាមូល ដែលបុគ្គលអ្នកមិនតាំងនៅក្នុងសំវរៈ នឹងគប្បីដល់ក្នុងនរកជាដើមក្នុងសម្បរាយភព ឈ្មោះថា អាសវៈដែលប្រព្រឹត្តទៅក្នុងសម្បរាយភព, ដើម្បីប្រយោជន៍ដល់ការកម្ចាត់ មានពាក្យអធិប្បាយថា ដើម្បីប្រយោជន៍ដល់ការរម្ងាប់ គឺ ដើម្បីប្រយោជន៍ដល់ការចូលទៅស្ងប់អាសវៈដែលប្រព្រឹត្តទៅក្នុងសម្បរាយភពទាំងនេះ ។

ពាក្យថា **អប្បសន្នានំ វា បសាទាយ : ដើម្បីញ៉ាំងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាឡើង** មានសេចក្តីថា កាលមានសិក្ខាបទបញ្ញត្តិ ជនជាបណ្ឌិតទាំងឡាយ សូម្បីមិនជ្រះថ្លា បានជ្រាបសិក្ខាបទបញ្ញត្តិ ឬ បានឃើញភិក្ខុទាំងឡាយបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្តិ រមែងដល់សេចក្តីជ្រះថ្លាថា "ធម៌ពួកណាហ្ន៎ ជាទីតាំងនៃតម្រេក ជាទីតាំងនៃការទាស់ចិត្ត និងជាទីតាំងនៃសេចក្តីវង្វេងភ្លេចរបស់

មហាជនក្នុងលោក, សមណសក្យបុត្រទាំងនេះ រមែងនៅឆ្ងាយចាកធម៌ទាំងនោះ, ពួកលោកធ្វើកម្មដែលគេធ្វើបានលំបាកហ្ន៎ ធ្វើកិច្ចដ៏ធ្ងន់ហ្ន៎” ដូច្នេះ ដូចព្រាហ្មណ៍ដែលជាមិច្ឆាទិដ្ឋិដឹងត្រៃវេទ បានឃើញគម្ពីរព្រះវិនយបិដកហើយជ្រះថ្លា ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា អប្បសន្នានំ វា បសាទាយ ។

ពាក្យថា បសន្នានំ វា ភិយ្យោភាវាយ : ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាហើយ ឱ្យរឹងរឹតតែជ្រះថ្លាច្រើនឡើង មានសេចក្តីថា កុលបុត្រទាំងឡាយសូម្បីជ្រះថ្លាក្នុងព្រះសាសនា បានជ្រាបសិក្ខាបទបញ្ញត្តិ ឬបានឃើញភិក្ខុទាំងឡាយ បដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្តិទុក រមែងជ្រះថ្លាក្រៃលែងឡើង ៗថា “ឱ លោកម្ចាស់ពួកណា តាមរក្សាវិន័យសំវរៈដែលជាព្រហ្មចរិយៈ មានភត្តតែមួងរហូតដល់អស់ជីវិតជាការប្រព្រឹត្តប្រសើរ, លោកម្ចាស់ទាំងនោះ ជាអ្នកមានប្រក្រតីធ្វើកម្មដែលធ្វើបានលំបាក” ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បសន្នានំ វា ភិយ្យោភាវាយ ។

## ព្រះសទ្ធម្ម ៣ យ៉ាង

ពាក្យថា សទ្ធម្មដ្ឋិតិយា : ដើម្បីឱ្យតម្កល់នៅមាំនៃព្រះសទ្ធម្ម

មានសេចក្តីថា សទ្ធម្មមាន ៣ យ៉ាង គឺ បរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ អធិគមសទ្ធម្ម ១ ។ បណ្តាសទ្ធម្ម ៣ យ៉ាងនោះ ដែលឈ្មោះថា បរិយត្តិសទ្ធម្ម បានដល់ ពុទ្ធវចនៈសូម្បីទាំងអស់រួបរួមក្នុងព្រះត្រៃបិដក ។ ដែលឈ្មោះថា បដិបត្តិសទ្ធម្ម បានដល់ ធម៌នេះ គឺ ធុតង្គគុណ ១៣ ខន្ធកវត្ត ១៤ មហាវត្ត ៨២ សីល សមាធិ និង វិបស្សនា ។ ដែលឈ្មោះថា អធិគមសទ្ធម្ម បានដល់ ធម៌នេះ គឺ អរិយមគ្គ ៤ សាមញ្ញផល ៤ និព្វាន ១ ។ កាលមានសិក្ខាបទបញ្ញត្តិ ភិក្ខុទាំងឡាយ រមែងរៀនសិក្ខាបទនិងវិភង្គនៃសិក្ខាបទនោះ និងពុទ្ធវចនៈដទៃដើម្បីបំភ្លឺសេចក្តីនៃសិក្ខាបទ និងវិភង្គនោះ និងកាលបដិបត្តិសិក្ខាបទតាមដែលទ្រង់បញ្ញត្តិទុក រមែងសម្រេចលោកុត្តរធម៌ ដែលខ្លួននឹងគប្បីបំពេញវត្តបដិបត្តិហើយសម្រេចបានដោយការបដិបត្តិ, ព្រោះហេតុនោះ សទ្ធម្មសូម្បីទាំងអស់នោះ ទើបឈ្មោះថា ជាសភាពមានសេចក្តីតាំងនៅអស់កាលយូរ ដោយសិក្ខាបទបញ្ញត្តិ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា សទ្ធម្មដ្ឋិតិយា ។

ពាក្យថា វិនយានុគ្គហាយ : ដើម្បីអនុគ្រោះដល់ព្រះវិន័យ មានសេចក្តីថា ពិតមែន កាលមានសិក្ខាបទបញ្ញត្តិវិន័យទាំង ៤ យ៉ាង គឺ សំវរៈវិន័យ ១ បហានវិន័យ ១ សមថវិន័យ ១ បញ្ញត្តិវិន័យ ១

រមែងជាការដែលទ្រង់អនុគ្រោះ គឺ ឧបត្ថម្ភទុកយ៉ាងល្អ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **វិនយានុគ្គហាយ** ។ ក៏បទទាំងអស់នោះឯង គប្បីប្រកបនឹងពាក្យនេះថា តថាគតនឹងបញ្ញត្តិសិក្ខាបទ ។ ប្រកបបទដើមនិងបទចុងបង្អស់ ក្នុងបណ្ដាបទទាំងនោះ ដូច្នេះថា តថាគតនឹងបញ្ញត្តិសិក្ខាបទ ដើម្បីសេចក្ដីឃើញប្រពៃរបស់សង្ឃ ។ល ។ តថាគតនឹងបញ្ញត្តិសិក្ខាបទ ដើម្បីសេចក្ដីអនុគ្រោះវិន័យ ។

មួយទៀត ព្រះមានព្រះភាគទ្រង់ធ្វើសង្ខលិកន័យយ៉ាងនេះថា "ដើម្បីសេចក្ដីល្អដល់សង្ឃ យ៉ាងណា យ៉ាងនោះក៏ដើម្បីសេចក្ដីសប្បាយដល់សង្ឃ, សេចក្ដីសប្បាយដល់សង្ឃយ៉ាងណា យ៉ាងនោះ ក៏ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស" និងទ្រង់ធ្វើវិធីប្រកប ១០ ដង មានបទមួយ ៗ ជាយ៉ាងនេះថា "ដើម្បីសេចក្ដីល្អដល់សង្ឃ យ៉ាងណា យ៉ាងនោះ ក៏ដើម្បីសេចក្ដីសប្បាយដល់សង្ឃ, ដើម្បីសេចក្ដីល្អដល់សង្ឃ យ៉ាងណា យ៉ាងនោះ ក៏ដើម្បីសង្កត់សង្កិននូវបុគ្គលទាំងឡាយដែលមិនអៀនខ្មាស" ដូច្នេះ ហើយត្រាស់ពាក្យណាទុកក្នុងគម្ពីរបរិវារៈថា

ក្នុងបករណ៍សម្ដែងអំណាចប្រយោជន៍ (នេះ) បណ្ឌិត
ត្រូវដឹងថា មានអត្ថមួយរយ មានធម៌មួយរយ និរុត្តិពីរ

រយ និងញាណបួនរយ[១] ។

ពាក្យទាំងអស់នោះ គប្បីជ្រាបក្នុងបទថា សង្ឃសុដ្ឋុតាយ ជាដើមនេះ ។ តែពាក្យនោះឯង នឹងមានច្បាស់ក្នុងគម្ពីរបរិវារឯណោះ ព្រោះដូច្នោះ ខ្ញុំព្រះករុណា ទើបមិនពណ៌នាក្នុងទីនេះ ។

## ទ្រង់បញ្ញត្តិបឋមបារាជិកសិក្ខាបទ

លុះព្រះមានព្រះភាគទ្រង់សម្ដែងអានិសង្សនៃការបញ្ញត្តិសិក្ខាបទទុកយ៉ាងនោះហើយ កាលទ្រង់បង្ហាញប្រាប់កិច្ចដែលភិក្ខុទាំងឡាយគួរធ្វើក្នុងសិក្ខាបទនោះ ទើប ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសម្ដែងនូវសិក្ខាបទនេះដូច្នេះថា" ។

ព្រះអង្គត្រាស់អធិប្បាយទុកយ៉ាងណា ?

ត្រាស់អធិប្បាយទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសម្ដែង ត្រូវរៀនសូត្រ ត្រូវចងចាំ និងត្រូវប្រាប់ដល់បុគ្គល

---

១. វិន. បរិ. បករណៈ. ១៣. ៩៧/១១៦ ។

ពួកដទៃ នូវសិក្ខាបទនេះ គឺ ដែលមានអានិសង្សដែលតថាគតសម្ដែងហើយយ៉ាងនេះ ក្នុងបាដិមោក្ខុទ្ទេសយ៉ាងនេះ ។ ពិតមែន ច សព្ទក្នុងពាក្យថា ឯវញ្ច បន នេះ មានការនាំសេចក្ដីលើសមកជាអត្ថ ព្រោះ

ដូច្នោះ សេចក្តីនេះ រមែងជាការដែលលោកនាំមកហើយ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងពាក្យដែលព្រះអង្គត្រាស់ទុកថា សិក្ខាបទនេះ ទើបត្រាស់ថា ភិក្ខុណាមួយសេពមេថុនធម្ម, (ភិក្ខុនោះ) ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។ កាលព្រះអង្គទ្រង់បញ្ញត្តិបឋមបារាជិក ឱ្យរឹងមាំ ដោយអំណាចមូលឆេទយ៉ាងនោះហើយ សូម្បីរឿងស្វាញីដទៃទៀត ក៏កើតឡើងដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ ដើម្បីសម្តែងរឿងស្វាញីដែលកើតឡើងនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ទើបបានពោលពាក្យនេះទុកថា ក៏សិក្ខាបទនេះ រមែងជាការដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយ ដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។ អធិប្បាយសេចក្តីនៃពាក្យនោះថា សិក្ខាបទនេះ រមែងជាការដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយយ៉ាងនេះ ដល់ភិក្ខុទាំងឡាយ និងរឿងដទៃនេះ ក៏បានកើតឡើងហើយ ។

ចប់ បឋមបញ្ញត្តិកថា

## អនុប្បញ្ញត្តិទី១ រឿងស្វាញី

[២១] ឥឡូវនេះ ដើម្បីសម្តែងរឿងដទៃដែលកើតឡើង ព្រះ

ធម្មសង្គាហកត្ថេរទាំងឡាយក៏បានពោលពាក្យជាដើមថា តេន ខោ បន សមយេន : សម័យនោះ ។ ក្នុងពាក្យថា តេន ខោ បន សមយេន ជាដើមនោះ មានការពណ៌នាបទដែលមិនទាន់ជាក់ច្បាស់ដូចតទៅនេះ ៖

ពីរបទថា មក្កដឹ អាមិសេន : មេស្វា ដោយអាមិស សេចក្ដីថា ពួកសត្វតិរច្ឆានជាច្រើន មានម្រឹគ សត្វក្ងោក មាន់ និងស្វាជាដើម មិនមានសេចក្ដីរង្កៀស ព្រោះអានុភាពនៃគុណមានខន្តិនិងមេត្តាជាដើម របស់ភិក្ខុទាំងឡាយ ក្នុងព្រៃមហាវ័ន រមែងដើរទៅក្នុងផ្ទះជាទីបំពេញព្យាយាម ។ មានពាក្យអធិប្បាយថា ភិក្ខុមួយរូប យកអាមិស មានបបរបាយ និងរបស់ទំពាជាដើម គឺ សង្គ្រោះនាងស្វាមួយ ក្នុងបណ្ដាសត្វតិរច្ឆានជាដើមទាំងនោះ ។

បទថា ឥស្សា ជាសត្តមីវិភត្តិ ។

បទថា បដិសេវតិ : សេព សេចក្ដីថា រមែងជាអ្នកសេពដោយច្រើន ។ វត្តមានាវិភត្តិ រមែងចុះក្នុងអត្ថថា បចុរ គឺ ច្រើន ។

ពីរបទថា សោ ភិក្ខុ : ភិក្ខុនោះ បានដល់ ភិក្ខុដែលសេពមេថុនធម្មនោះ ។

ពីរបទថា សេនាសនចារិកំ អាហិណ្ឌន្តា : ដើរទៅកាន់

សេនាសនចារិក សេចក្តីថា ភិក្ខុអាគន្តុកៈទាំងនោះ មកគាល់ព្រះពុទ្ធបាន អាគន្តុកភត្តពីព្រឹក ធ្វើភត្តកិច្ចរួចស្រេចហើយបបួលគ្នាថា "ពួកយើងនឹង មើលស្ថានទីនៅរបស់ភិក្ខុទាំងឡាយ" ហើយក៏និមន្តទៅ ។ ព្រោះហេតុ នោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ទើបពោលថា សេនាសនចារិកំ អាហិណ្ឌន្តា ។

## ស្វាញីសម្តែងរបស់កំបាំងដល់ភិក្ខុអាគន្តុកៈ

ប្រែបទថា យេន តេ ភិក្ខូ តេនុបសង្កមិ : ក៏ចូលទៅត្រង់ កន្លែងដែលភិក្ខុនោះនៅ មានសេចក្តីថា ធម្មតាសត្វតិរច្ឆានទាំងឡាយ កាលបានធ្វើសេចក្តីជិតដិតនឹងភិក្ខុមួយរូបហើយ ក៏ញ៉ាំងសេចក្តីគិតដូច្នោះ នុ៎ះឯង ឱ្យកើតឡើង សូម្បីក្នុងពួកភិក្ខុដទៃផង ។ ព្រោះដូច្នោះ ស្វាញីនោះ ទើបបានចូលទៅរកភិក្ខុទាំងនោះ ដរាបដល់ទីនៅ, រួចហើយ ក៏បានសម្តែងវិការនោះសូម្បីដល់ភិក្ខុទាំងនោះ ដូចគ្នានឹងសម្តែងដល់ភិក្ខុ ដែលខ្លួនជិតដិត ដូច្នោះ ។

បទថា ឆេប្បំ បានដល់ នង្គុដ្ឋ : កន្ទុយ ។

បទថា ឱឌ្ឌិសិ : ពើង[១] គឺ ដាក់ទុកត្រង់មុខ ។

ពីរបទថា និមិត្តម្បិ អកាសិ : ធ្វើនូវនិមិត្តផង សេចក្តីថា ភិក្ខុ

អាគន្តុកៈទាំងនោះ រមែងដឹងសេចក្តីត្រូវការមេថុន ដោយសេចក្តីកំណត់យ៉ាងណា ដោយកិរិយាយ៉ាងណា, ស្វាញីនោះ ក៏បានធ្វើនិមិត្តនោះដោយសេចក្តីកំណត់ និងកិរិយានោះ ៗ ។

ពីរបទថា សោ ភិក្ខុ : ភិក្ខុនោះ សេចក្តីថា នេះជាវិហារ (ទីនៅ) របស់ភិក្ខុណា, (ភិក្ខុនោះ រមែងសេពមេថុនធម្មក្នុងស្វាញីនេះដោយមិនបាច់សង្ស័យឡើយ ។)

ពីរបទថា ឯកមន្តំ និលីយឹសុ : ទើបនាំគ្នាពួនចាំមើលក្នុងទីកំបាំង១ សេចក្តីថា ភិក្ខុអាគន្តុកៈទាំងនោះបានពួននៅក្នុងឱកាស១កន្លែង ។

ពីរបទថា សច្ចំ អាវុសោ : នែអាវុសោទាំងឡាយ (ក៏)ពិតមែនហើយ សេចក្តីថា ភិក្ខុនោះ ព្រោះត្រូវពួកភិក្ខុអាគន្តុកៈចោទឡើងដោយបានឃើញកម្មដែលលោកធ្វើនោះ យ៉ាងប្រចក្សភ្នែក ដូចចាប់ចោរបានព្រមទាំងរបស់កណ្តាលដូច្នោះ កាលមិនអាចនឹងនិយាយពាក្យជាដើមថា "ខ្ញុំព្រះករុណាធ្វើកម្មអាក្រក់អ្វីឬ ?" ទើបនិយាយទទួលថា "អាវុសោទាំងឡាយ ... ពិតមែនហើយ"

ច្រើនបទថា ននុ អាវុសោ តថេវ តំ ហោតិ : ភិក្ខុទាំងឡាយ

---

១. ប្រែថា អេន លោត ក៏មាន ។

នោះពោលថា នៃអាវុសោ សិក្ខាបទដែលព្រះអង្គបញ្ញត្តចំពោះមនុស្សស្រី ក៏ដូចសត្វតិរច្ឆានដែរ មិនមែនឬ សេចក្តីថា នៃអាវុសោ សូម្បីក្នុងសត្វតិរច្ឆានញី សិក្ខាបទនោះ រមែងដូចគ្នានឹងក្នុងមនុស្សស្រីដែរ មិនមែនឬ ។ (នៃអាវុសោ កាលភិក្ខុសុទិន្នសេពមេថុនធម្មក្នុងមនុស្សស្រី សិក្ខាបទ រមែងមានយ៉ាងណា, កាលអាវុសោ សេពមេថុនធម្មសូម្បីក្នុងសត្វតិរច្ឆានញី សិក្ខាបទនោះ ក៏រមែងមានយ៉ាងនោះដូចគ្នា មិនមែនឬ ?) ។ ពិតមែន ការសម្លឹងមើលក្តី ចាប់ត្រូវក្តី ស្ទាបអង្អែលក្តី ប៉ះពាល់ក្តី ជជុសក្តី នូវមនុស្សស្រី ជាអំពើអាក្រក់ទាំងអស់, កិរិយាមានការសម្លឹងមើលជាដើមនោះទាំងអស់ សូម្បីនូវសត្វតិរច្ឆានញី ក៏ជាអំពើអាក្រក់ដូចគ្នា ; ក្នុងមនុស្សស្រីនិងសត្វតិរច្ឆានញីនេះ នឹងមានអ្វីប្លែកគ្នា ? លោកបានអាងលេសក្នុងឋានដែលមិនមែនលេសនោះឯង ។

[២២] ប្រើនបទថា អន្តមសោ តិរច្ឆានគតាយបិ បារាជិកោ ហោតិ អសំវាសោ : ដោយហោចទៅ សូម្បីនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវអាបត្តិបារាជិក រកសំវាសគ្មាន សេចក្តីថា ព្រះមានព្រះភាគបានទ្រង់ធ្វើសិក្ខាបទឱ្យមាំឡើងទៀតថា "ភិក្ខុណាមួយសេពមេថុនធម្មដោយហោចទៅ សូម្បីនឹងសត្វតិរច្ឆានញី ភិក្ខុនោះត្រូវបារាជិក"ដូចគ្នា ។

## សិក្ខាបទទាំងអស់ មានទោស ២ យ៉ាង

ពិតមែន សិក្ខាបទមាន ២ យ៉ាង គឺ លោកវជ្ជៈ (មានទោសមកលោក) ១ បណ្ណត្តិវជ្ជៈ (មានទោសមកព្រះបញ្ញត្តិ) ១ ។

បណ្ដាទោស ២ យ៉ាងនោះ សិក្ខាបទណា ក្នុងចំណែកសចិត្តកៈ មានចិត្តជាអកុសលសុទ្ធ ៗ, សិក្ខាបទនោះ ឈ្មោះថា ជាលោកវជ្ជៈ ដ៏សេសជាបណ្ណត្តិវជ្ជៈ ។

បណ្ដាទោស២ យ៉ាងនោះ អនុប្បញ្ញត្តិក្នុងសិក្ខាបទដែលជាលោកវជ្ជៈ កាលកើតឡើង ការពារ បិទទ្វារ កាត់ក្រសែ ធ្វើឱ្យមាំឡើងជាងមុន រមែងកើតឡើង ។ ចំណែកអនុប្បញ្ញត្តិនេះថា "វៀរលែងតែសម្គាល់ថាខ្លួនបានត្រាស់ដឹង"[១] "លើកលែងតែយល់សប្តិ"[២] ព្រះមានព្រះភាគត្រាស់ទុក ព្រោះមិនមានការប្រព្រឹត្តកន្លង និងព្រោះជាអព្វោហារិក ។ ក្នុងសិក្ខាបទដែលជាបណ្ណត្តិវជ្ជៈ កាលភិក្ខុមិនទាន់បាន ធ្វើការប្រព្រឹត្តកន្លងអនុប្បញ្ញត្តិ កាលកើតឡើងធ្វើឱ្យធូរថយចុះ ដោះលែងចេញ បើកទ្វារឱ្យធ្វើមិនឱ្យជាអាបត្តិត ៗទៅ រមែងកើតឡើង ដូចអនុប្បញ្ញត្តិក្នុងគណភោជនសិក្ខាបទនិងបរម្បរភោជនសិក្ខាបទ ដូច្នោះ ។

---

១. វិន. បារា. ឧត្តិមនុស្សធម្ម. ១. ២៣២/២៩៩ ។

២. វិន. សង្ឃា. សុក្កវិស្សដ្ឋិ. ២. ២/៧ ។

ចំណែកអនុប្បញ្ញត្តិបែបនេះថា "ដោយហោចទៅ (ប្រាប់) សូម្បីតែ

ស្រីដែលបុរសគប្បីនៅរួមអស់ទូទៅមួយរំពេចនោះ”[១] ឈ្មោះថា មានគតិដូចព្រះបញ្ញត្តិតែម្តង ព្រោះកើតឡើងក្នុងកាលភិក្ខុធ្វើការប្រព្រឹត្តកន្លងហើយ ។ ក៏ព្រោះបឋមសិក្ខាបទនេះ ជាលោកវជ្ជៈ មិនមែនជាបណ្ណត្តិវជ្ជៈ ; ព្រោះដូច្នោះ អនុប្បញ្ញត្តិនេះ ក៏ការពារបិទទ្វារ កាត់ក្រសែ បានដល់ ធ្វើឱ្យមាំឡើងជាងអំពីដើមទៀត រមែងកើតឡើង ។

កាលព្រះមានព្រះភាគ ទ្រង់ប្រមូលរឿងសូម្បីទាំងពីរមក ហើយបញ្ញត្តិបឋមបារាជិក ធ្វើឱ្យមាំឡើងជាងអំពីដើម ដោយអំណាចមូលឆេទយ៉ាងនោះ សូម្បីរឿងភិក្ខុវជ្ជីបុត្រដទៃទៀតក៏កើតឡើង ដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ ដើម្បីសម្តែងនូវការកើតឡើងនៃរឿងភិក្ខុវជ្ជីបុត្រនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ទើបបានពោលពាក្យនេះថា ក៏សិក្ខាបទនេះ រមែងជាការដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយដល់ភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។ អធិប្បាយសេចក្តីនៃពាក្យនោះថា សិក្ខាបទនេះ រមែងជាការដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិហើយយ៉ាងនេះដល់ភិក្ខុទាំងឡាយ និងរឿងសូម្បីដទៃនេះ ក៏បានកើតឡើង ។

ចប់ មក្កដីវត្ថុកថា ។

---

១. វិន. សង្ឃា. សញ្ចរិត្ត. ២. ១២៦/១៣៣ ។

## អនុប្បញ្ញត្តិទី២ រឿងពួកភិក្ខុវជ្ជីបុត្រ

[២៣] ឥឡូវនេះ ដើម្បីសម្តែងរឿងសូម្បីដទៃដែលកើតឡើងហើយ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ទើបបានពោលពាក្យជាដើមថា **តេន ខោ បន សមយេន : សម័យនោះ ។** សូម្បីក្នុងពាក្យថា **តេន ខោ បន សមយេន** ជាដើមនោះ មានការពណ៌នាបទដែលមិនទាន់ជាក់ច្បាស់ដូចតទៅនេះ ៖

បទថា **វេសាលិកា : នៅក្នុងក្រុងវេសាលី** បានដល់ អ្នកមានប្រក្រតីនៅក្រុងវេសាលី ។

បទថា **វជ្ជិបុត្តកា : ពួកវជ្ជីបុត្រ** បានដល់ អ្នកជាបុត្ររបស់ត្រកូលក្នុងក្រុងវេសាលីនាដែនវជ្ជី ។

បានឮថា ឧបទ្ទវៈ ទោស សេចក្តីចង្រៃដែលបានកើតឡើងក្នុងព្រះសាសនាទាំងអស់នោះ បានកើតឡើងហើយ ព្រោះអាស្រ័យភិក្ខុវជ្ជីបុត្រ ។ ពិតមែន សូម្បីភិក្ខុទេវទត្ត បានពួកភិក្ខុវជ្ជីបុត្រជាបក្ខពួកហើយ ទើបទម្លាយសង្ឃ ។ ក៏ពួកភិក្ខុវជ្ជីបុត្រទាំងឯង បានសម្តែងសត្ថុសាសនាក្រៅធម៌ក្រៅវិន័យ ក្នុងកាលព្រះមានព្រះភាគបរិព្វានបាន ១០០ ឆ្នាំ បណ្តាភិក្ខុវជ្ជីបុត្រពួកនោះឯង សូម្បីភិក្ខុទាំងនេះ ពួកខ្លះសូម្បីទ្រង់បញ្ញត្តិសិក្ខាបទហើយយ៉ាងនេះក៏បានស្រង់ទឹកតាមសេចក្តីត្រូវការ ។ល។ បានសេព

មេថុនធម្មតាមសេចក្តីត្រូវការ ដោយប្រការដូច្នេះ ។

ក្នុងបទថា **ញាតិព្យសនេនបិ : សេចក្តីព្រាត់ប្រាសចាកញាតិខ្លះ** នេះ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា "សេចក្តីវិនាស សេចក្តីព្រាត់ប្រាស់ សេចក្តីខាត់ខាយ សេចក្តីទម្លាយ សេចក្តីបាត់បង់" ទាំងអស់នេះមានអត្ថន័យដូចគ្នា ។ សេចក្តីព្រាត់ប្រាស់នៃពួកញាតិ ឈ្មោះថា ញាតិព្យសនៈ ។ ព្រោះ សេចក្តីព្រាត់ប្រាស់នៃញាតិនោះ (ពាល់ត្រូវហើយ) ។ អធិប្បាយថា "ព្រោះការវិនាសនៃញាតិដែលមានការដាក់រាជអាជ្ញា ត្រូវរោគបៀតបៀន សេចក្តីស្លាប់និងសេចក្តីព្រាត់ប្រាស់ជានិមិត្ត (ពាល់ត្រូវហើយ) ។" សូម្បីក្នុងបទទី ២ ក៏ន័យនេះ ។ ចំណែកក្នុងបទទី ៣ រោគដែលធ្វើ សេចក្តីមិនមានរោគឱ្យវិនាសទៅទុំះឯង ឈ្មោះថា រោគព្យសនៈ ។ ពិត មែន រោគនោះ រមែងធ្វើសេចក្តីមិនមានរោគឱ្យព្រាត់ប្រាស់ទៅ គឺ ខាយ ទៅ បានដល់ ឱ្យវិនាសទៅ ព្រោះហេតុនោះ ទើបឈ្មោះថា ព្យសនៈ ។ សេចក្តីព្រាត់ប្រាស់ គឺ រោគ ឈ្មោះថា រោគព្យសនៈ ។ ព្រោះសេចក្តី ព្រាត់ប្រាស់ គឺ រោគនោះ (ពាល់ត្រូវហើយ) ។

បទថា **ផុដ្ឋា : ប្រទះ** គឺ ពាល់ត្រូវ បានដល់ គ្របសង្កត់ ។ អធិប្បាយថា អ្នកប្រកបព្រមហើយ ។

ច្រើនបទថា ន មយំ ភន្តេ អានន្ទ ពុទ្ធគរហិនោ : បពិត្រព្រះអានន្ទដ៏ចម្រើន យើងខ្ញុំទាំងឡាយមិនមែនជាអ្នកតិះដៀលព្រះពុទ្ធ មានសេចក្តីថា ព្រះអានន្ទដ៏ចម្រើន ពួកខ្ញុំព្រះករុណា មិនបានតិះដៀលព្រះពុទ្ធ គឺ មិនបានពោលទោសព្រះពុទ្ធ មិនបានពោលទោសព្រះធម៌ មិនបានពោលទោសព្រះសង្ឃ ។

ពីរបទថា អត្តគរហិនោ មយំ : យើងខ្ញុំទាំងឡាយជាអ្នកតិះដៀលតែខ្លួនឯង សេចក្តីថា ពួកខ្ញុំព្រះករុណា តិះដៀលខ្លួនឯងប៉ុណ្ណោះ គឺ ពោលទោសរបស់ខ្លួន ។

បទថា អលក្ខិកា : ពេញជាមនុស្សឥតសំណាងវាសនា គឺ អ្នកអស់សិរី ។

បទថា អប្បបុញ្ញា : ពេញជាមនុស្សឥតបុណ្យ គឺ អ្នកមានបុណ្យតិច ។

ច្រើនបទថា វិបស្សកា កុសលានំ ធម្មានំ : គង់នឹងបានឃើញកុសលធម៌ទាំងឡាយ មានសេចក្តីថា ពួកខ្ញុំព្រះករុណានឹងគប្បីជាអ្នកឃើញច្បាស់នូវកុសលធម៌ទាំងឡាយ ដែលព្រះមានព្រះភាគទ្រង់ចែកទុកហើយក្នុងអារម្មណ៍ ៣៨ ប្រការ ។ អធិប្បាយថា ចេញចាកអារម្មណ៍នោះ ៗ ហើយ នឹងឃើញច្បាស់ធម៌ទាំងនោះតែម្តង ។

បទថា **បុព្វរត្តាបររត្តំ** : រាត្រីមុននិងរាត្រីក្រោយ សេចក្ដីថា ខាងដើមនៃរាត្រី ឈ្មោះថា រាត្រីមុន, ខាងចុងនៃរាត្រី ឈ្មោះថា រាត្រីក្រោយ, មានពាក្យអធិប្បាយថា បឋមយាម និងបច្ឆិមយាម ។

បទថា **ពោធិបក្ខិកានំ** : ដែលជាចំណែកនៃពោធិញ្ញាណ គឺ មាននៅក្នុងចំណែកនៃបញ្ញាគ្រឿងត្រាស់ដឹង ។ អធិប្បាយថា ជាឧបការៈដល់អរហត្តមគ្គញ្ញាណ ។

បទថា **ភាវនានុយោគំ** : ខំប្រឹងប្រកបព្យាយាម ឱ្យចម្រើន សេចក្ដីថាប្រកបជាប់ជានិច្ច ក្នុងការចម្រើន (ពោធិបក្ខិយធម៌) ។

ពីរបទថា **អនុយុត្តា វិហរេយ្យាម** សេចក្ដីថា ពួកខ្ញុំព្រះករុណាលះគិហិបលិពោធ និងអាវាសបលិពោធហើយ នឹងគប្បីជាអ្នកប្រកបខ្វល់ខ្វាយ មិនមានកិច្ចដទៃនៅក្នុងសេនាសនៈដែលស្ងាត់ ។

បទថា **ឯវមាវុសោ** : អើ អាវុសោ សេចក្ដីថា កាលព្រះថេរៈមិនជ្រាបអធ្យាស្រ័យរបស់លោកទាំងនោះ បានស្ដាប់ការគម្រាមយ៉ាងច្រើន (ពាក្យអង្វរ) នេះ របស់ភិក្ខុទាំងនោះហើយ ទើបសម្គាល់ថា "បើលោកទាំងនេះ នឹងជាអ្នកដូច្នេះសោត, ក៏ជាការល្អ" ហើយទទួលពាក្យថា "បាន លោកដ៏មានអាយុទាំងឡាយ" ។

## រឿងទ្រង់ហាមមិនឲ្យភិក្ខុដែនវជ្ជីបុត្របព្វជ្ជាឧបសម្បទា

សូម្បីពីរបទថា អដ្ឋានំ អនវកាសោ : មិនមែនជាហេតុ មិនមែនជាឱកាសឡើយ នេះ ជាព្រះតម្រាស់ដែលត្រាស់ហាមហេតុ ។

ពិតមែន ហេតុ លោកហៅថា "ឋានៈ និងឱកាស" ព្រោះជាទីតាំងនៃផល ដោយការដែលផលនោះប្រព្រឹត្តទៅជាប់ដោយហេតុនោះ និងព្រោះហេតុនោះ ក៏ជាឱកាសនៃផលនោះ ដោយការដែលហេតុនោះប្រព្រឹត្តទៅជាប់ដោយផលនោះ ។ ព្រះមានព្រះភាគកាលទឹងទ្រង់ហាមហេតុនោះ ទើបត្រាស់ថា អដ្ឋានមេតំ អានន្ទ អនវកាសោ : ម្នាលអានន្ទ អំពើរនុ៎ះ មិនមែនជាហេតុ មិនមែនជាឱកាសឡើយ ជាដើមសេចក្ដីថា ឋានៈ ឬឱកាសនេះមិនមាន ។

ពាក្យថា យំ តថាគតោ : តថាគត (ជក)ដោយអំពើណា គឺមិនមែនឱកាស ពាក្យថា ឋានៈ ឬឱកាសនេះមិនមាន ។

ពីរបទថា យំ តថាគតោ : តថាគត (ដក)ដោយអំពើណា សេចក្ដីថា ព្រះតថាគតនឹងគប្បីដកបារាជិកសិក្ខាបទ ដែលបញ្ញត្តិហើយដល់សាវកទាំងឡាយ ព្រោះហេតុនៃពួកវជ្ជី ឬពួកភិក្ខុវជ្ជីបុត្រ ដោយហេតុណា, ហេតុនោះ មិនមាន ។ ពិតណាស់ ប្រសិនបើព្រះមានព្រះ

ភាគនឹងគប្បីប្រទានឧបសម្បទាដល់ភិក្ខុវជ្ជីបុត្រទាំងនេះ អ្នកទូលសូមថា "ខ្ញុំព្រះករុណាទាំងឡាយ គប្បីបានឧបសម្បទា" ដូច្នេះ មែន, កាលបើយ៉ាងនោះ ព្រះអង្គក៏នឹងគប្បីដកបារាជិកសិក្ខាបទដែលទ្រង់បញ្ញត្តិទុកថា "ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន" (យ៉ាងពិតប្រាកដ) ។ តែព្រោះហេតុដែលព្រះអង្គមិនដកសិក្ខាបទដែលទ្រង់បញ្ញត្តិទុកហើយនោះ ដូច្នោះទើបត្រាស់ថា "អំពើនុ៎ះ មិនមែនជាហេតុ" ជាដើម ។

[២៤] ក្រើនបទថា សោ អាគតោ ន ឧបសម្បាទេតព្វោ **:** **បើភិក្ខុនោះមក** (សូមឧបសម្បទានឹងសង្ឃទៀត) **សង្ឃមិនត្រូវឱ្យឧបសម្បទាឡើយ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់មានសេចក្ដីអនុគ្រោះ ។ ពិតមែន ទ្រង់ជ្រាបថា ក៏បើពួកវជ្ជីបុត្រនោះ មកហើយយ៉ាងនេះ គប្បីបានទទួលឧបសម្បទាសោត, លោកគប្បីជាអ្នកមិនមានសេចក្ដីគោរពក្នុងសាសនា, តែលោកតាំងនៅក្នុងភូមិរបស់សាមណេរហើយ នឹងជាអ្នកមានសេចក្ដីគោរព ហើយនឹងធ្វើប្រយោជន៍ខ្លួនបាន ទើបត្រាស់ថា "បើភិក្ខុនោះមក (សូមឧបសម្បទានឹងសង្ឃទៀត) សង្ឃមិនត្រូវឱ្យឧបសម្បទាឡើយ" ។

ក្រើនបទថា សោ អាគតោ ឧបសម្បាទេតព្វោ **: បើភិក្ខុនោះមក** (សូមបួសទៀត) **សង្ឃគប្បីឱ្យឧបសម្បទាចុះ** សេចក្ដីថា ព្រះ

មានព្រះភាគទ្រង់ជ្រាបហើយថា "ភិក្ខុនោះមកហើយយ៉ាងនេះ តាំងនៅក្នុងភាវៈជាភិក្ខុ នឹងជាអ្នកមានសេចក្តីគោរពក្នុងសាសនា ព្រោះលោកមានសីលមិនទាន់វិបត្តិ, លោកកាលនៅមានឧបនិស្ស័យ នឹងសម្រេចប្រយោជន៍ខ្ពស់បំផុត ក្នុងកាលមិនយូរឡើយ ទើបត្រាស់ថា "លោកនោះមកហើយ គប្បីឱ្យឧបសម្បទាចុះ" ។

លុះព្រះមានព្រះភាគទ្រង់សម្តែងភិក្ខុវជ្ជីបុត្រ អ្នកមិនគួរឱ្យឧបសម្បទា និងអ្នកគួរឱ្យឧបសម្បទា ក្នុងបណ្តាពួកភិក្ខុវជ្ជីបុត្រដែលសេពមេថុនធម្ម មកហើយយ៉ាងនេះ មានព្រះបំណងនឹងប្រមូលរឿងទាំង ៣ មក ហើយទ្រង់បញ្ញត្តិសិក្ខាបទឱ្យបរិបូណ, ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងសិក្ខាបទនេះយ៉ាងនេះ" ហើយបានទ្រង់បញ្ញត្តិសិក្ខាបទឱ្យបរិបូណ៌យ៉ាងនេះថា ៖

យោ បន ភិក្ខុ ។បេ ។ អសំវាសោ : ភិក្ខុណាមួយ ដល់ព្រមដោយសិក្ខានិងសាជីវៈ (ដែលព្រះតថាគតបញ្ញត្តហើយ) សម្រាប់ភិក្ខុទាំងឡាយ ហើយមិនពោលលាសិក្ខា មិនធ្វើឱ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយ ហើយសេពមេថុនធម្ម ដោយហោចទៅសូម្បីតែនឹងសត្វតិរច្ឆានញី ភិក្ខុនោះ ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន ។

## វិន័យ ៤ យ៉ាង

[២៥] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់ចែកសេចក្តីនៃសិក្ខាបទនោះ ទើបត្រាស់ពាក្យជាដើមថា **យោ បនាតិ យោ យាទិសោ** : ត្រង់ពាក្យថា ណាមួយ គឺថា តាមតែភិក្ខុរូបណាមួយ ។

ក៏ព្រះវិន័យធរ អ្នកប្រាថ្នាភាពជាអ្នកឆ្លាតក្នុងសិក្ខាបទវិភង្គនៃសិក្ខាបទនោះ និងវិន័យវិនិច្ឆ័យទាំងអស់ គួរជ្រាបវិន័យ ៤ យ៉ាង ។

ពិតមែន ព្រះធម្មសង្គាហកមហាថេរៈទាំងឡាយ អ្នកមានឫទ្ធិច្រើនក្នុងកាលមុន បាននាំវិន័យ ៤ យ៉ាងចេញផ្សព្វផ្សាយហើយ ។

វិន័យ ៤ យ៉ាងដូចម្តេច ?

វិន័យ ៤ យ៉ាង គឺ សុត្ត សុត្តានុលោម អាចរិយវាទ អត្តនោមតិ ដែលព្រះនាគសេនត្ថេរសំដៅយកពោលទុក (ក្នុងមិលិន្ទបញ្ហា) ថា "មហាបពិត្រ សេចក្តីដែលកុលបុត្រគប្បីទទួលដោយបទខាងដើមនោះឯងដោយរស ដោយភាព ជាវង្សនៃអាចារ្យ ដោយសេចក្តីអធិប្បាយ" ។

## អត្ថាធិប្បាយវិន័យ ៤ យ៉ាង

ពិតមែន បណ្តាពាក្យទាំងនេះ ពាក្យថា **អាហច្ចបទ** លោកប្រាថ្នាយកសុត្ត ។ ពាក្យថា **រស** លោកប្រាថ្នាយកសុត្តានុលោម ។ ពាក្យថា

អាចរិយវង្ស លោកប្រាថ្នាយកអាចរិយវាទ ។ ពាក្យថា អធិប្បាយ លោកប្រាថ្នាយកអត្តនោមតិ ។

បណ្តាវិន័យ ៤ យ៉ាងនោះ ដែលឈ្មោះថា សុត្ត បានដល់ បាលីក្នុងវិនយបិដកទាំងមូល ។

ដែលឈ្មោះថា សុត្តានុលោម បានដល់ មហាប្រទេស ៤ ដែល ព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា ៖

( ១ ) ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលតថាគតមិនបាន ហាមទុកថា របស់នេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះ មិនគួរដល់អ្នកទាំងឡាយឡើយ ។

( ២ ) ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបានហាម ទុកថា របស់នេះមិនគួរ បើរបស់នោះអនុលោមចូលរបស់គួរ ឃាត់ របស់មិនគួរ របស់នោះ គួរដល់អ្នកទាំងឡាយ

( ៣ ) ម្នាលភិក្ខុទាំងឡាយ របស់ណា ដែលតថាគតមិនបាន អនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួរ របស់នោះ មិនគួរដល់អ្នកទាំងឡាយឡើយ

( ៤ ) ម្នាលភិក្ខុទាំងឡាយ របស់ណាដែលតថាគតមិនបាន អនុញ្ញាតទុកថា របស់នេះគួរ បើរបស់នោះអនុលោមចូលរបស់គួរ

យាត់របស់មិនគួរ របស់នោះ គួរដល់អ្នកទាំងឡាយ ។[(១)]

ដែលឈ្មោះថា អាចរិយវាទ បានដល់ ច្បាប់អដ្ឋកថា ដែលញុំាងវិនិច្ឆ័យផ្ទេរឿងឲ្យប្រព្រឹត្តទៅក្រៅពីបាលី ដែលព្រះអរហន្ត ៥០០ អង្គជាធម្មសង្គាហកៈតាំងទុក ។

ដែលឈ្មោះថា អត្តនោមតិ បានដល់ ពាក្យដែលផុតពីសុត្តសុត្តានុលោម និងអាចរិយវាទ ពោលតាមអាការដែលប្រាកដដោយអនុមាន គឺ ដោយសេចក្ដីយល់ឃើញរបស់ខ្លួន ដោយការកាន់យកន័យដោយការកាន់យកសេចក្ដី ។ ន័យមួយទៀត ថេរវាទសូម្បីទាំងអស់ដែលមកក្នុងអដ្ឋកថានៃព្រះសូត្រ ព្រះអភិធម្ម និងព្រះវិន័យ ឈ្មោះថាអត្តនោមតិ ។

## វិធីសង្កេតពិនិត្យសូត្រនិងសុត្តានុលោមជាដើម

តែកុលបុត្រ អ្នកអាងអត្តនោមតិនោះពោល មិនគួរនឹងប្រកាន់ឲ្យមាំហើយពោលទេ គួរកំណត់ហេតុប្រៀបធៀបបាលីជាមួយសេចក្ដី និងសេចក្ដីជាមួយបាលីហើយសិន សឹមពោល ។ អត្តនោមតិ គួរសង្កេតពិនិត្យមើលក្នុងអាចរិយវាទ បើត្រូវគ្នានិងសមគ្នាក្នុងអាចរិយវាទនោះ

---

១. វិន. មហា. ភេសជ្ជក្ខន្ធកៈ. ៧. ១៤០/៣៧៨ ។

សោត, ទើបគួរកាន់យក បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក ។

ពិតមែន ដែលឈ្មោះថា អត្តនោមតិនេះ នៅជាសេចក្ដីមានកម្លាំងខ្សោយជាងគេ ។ អាចរិយវាទមានកម្លាំងជាងអត្តនោមតិ ។ សូម្បីអាចរិយវាទក៏គួរសង្កេតពិនិត្យមើល ក្នុងសុត្តានុលោម កាលត្រូវគ្នាសមគ្នាពិត ក្នុងសុត្តានុលោមនោះ ទើបគួរកាន់យក, ចំណែកដែលមិនត្រូវគ្នា មិនសមគ្នាមិនគួរកាន់យក ។ ព្រោះថា សុត្តានុលោម ជារបស់មានកម្លាំងជាងអាចរិយវាទ ។ សូម្បីសុត្តានុលោម ក៏គួរសង្កេតពិនិត្យមើលក្នុងសូត្រ កាលត្រូវគ្នា សមគ្នាពិត ក្នុងសូត្រនោះ ទើបគួរកាន់យក, ចំណែកដែលមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក ។ ព្រោះថា សូត្រប៉ុណ្ណោះជារបស់មានកម្លាំងជាងសុត្តានុលោម ។ ពិតមែន សូត្រជារបស់ដែលអ្នកណា ៗ មិនអាចជំទាស់បាន ដូចជាសង្ឃដែលធ្វើ (សង្គាយនា) ដូចជាកាលដែលព្រះពុទ្ធទាំងឡាយទ្រង់នៅមានព្រះជន្ម ។ ព្រោះដូច្នោះ កាលណាភិក្ខុពីររូប សាកច្ឆាគ្នា, សកវាទីអាងសូត្រពោល, បរវាទីអាងសុត្តានុលោមពោល កាលនោះ ទាំងពីររូបនោះ មិនគួរនិយាយដៀមដាមគ្នា ឬតិះដៀលគ្នា គួរសង្កេតពិនិត្យសុត្តានុលោមក្នុងសូត្រ បើត្រូវគ្នា សមគ្នា គួរកាន់យក, បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក, គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះ ។

បើសកវាទីនេះ អាងសូត្រពោល, បរវាទីអាងអាចរិយវាទពោលសោត, សូម្បីទាំងពីររូបនោះ ក៏មិនគួរនិយាយជៀមជាមគ្នា ឬតិះជៀលគ្នា គួរសង្កេតពិនិត្យអាចរិយវាទក្នុងសូត្រ បើត្រូវគ្នា សមគ្នា គួរកាន់យក ។ កាលអាចរិយវាទ មិនត្រូវគ្នានិងមិនសមគ្នា ទាំងជាសេចក្ដីដែលគួរតិះជៀល ក៏មិនគួរកាន់យក, គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះ ។

បើសកវាទីនេះ អាងសូត្រពោល, បរវាទី អាងអត្តនោមតិពោលសោត, សូម្បីទាំងពីររូបនោះ ក៏មិនគួរនិយាយជៀមជាមគ្នា ឬតិះជៀលគ្នា គួរសង្កេតពិនិត្យអត្តនោមតិក្នុងសូត្រ បើត្រូវគ្នា សមគ្នា គួរកាន់យក, បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក ; គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះ ។

បើសកវាទីនេះ អាងសុត្តានុលោមពោល, បរវាទី អាងសូត្រពោលសោត, គួរសង្កេតពិនិត្យសូត្រក្នុងសុត្តានុលោម បើត្រូវគ្នាសមគ្នា ប្រាកដមកក្នុងបាលីឡើងកាន់សង្គីតិទាំង ៣ លើក ទើបគួរកាន់យក, បើមិនប្រាកដដូចយ៉ាងនោះ មិនត្រូវគ្នា មិនសមគ្នា ជាពាហិរកសូត្រ សិលោកសោលក ឬសូត្រដែលគួរតិះជៀលដទៃ ៗ ដែលមកអំពីបណ្ដាសូត្រទាំងឡាយ មានគុឡ្ហវេស្សន្តរគុឡ្ហវិន័យ និងគុឡ្ហវេទល្ល:ជាដើម យ៉ាងណាមួយ មិនគួរកាន់យក; គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។

បើសកវាទីនេះ អាងសុត្តានុលោមពោល, បរវាទី អាងអាចរិយវាទពោលសោត, គួរសង្កេតពិនិត្យអាចរិយវាទក្នុងសុត្តានុលោម, បើត្រូវគ្នា សមគ្នា គួរកាន់យក, បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក ; គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។

បើសកវាទីនេះ អាងសុត្តានុលោមពោល, បរវាទី អាងអត្តនោមតិពោលសោត, គួរសង្កេតពិនិត្យអត្តនោមតិ ក្នុងសុត្តានុលោម បើត្រូវគ្នា សមគ្នា គួរកាន់យក, បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក ; គួរតាំងនៅក្នុងសុត្តានុលោមប៉ុណ្ណោះ ។

ក៏បើសកវាទីនេះ អាងអាចរិយវាទពោល, បរវាទីអាងសូត្រពោលសោត, គួរសង្កេតពិនិត្យសូត្រក្នុងអាចរិយវាទ បើត្រូវគ្នាសមគ្នា គួរកាន់យក ។ (សូត្រដែលគួរតិះដៀល)ក្រៅនេះ មិនគួរកាន់យក, គួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។

បើសកវាទីនេះ អាងអាចរិយវាទពោល, បរវាទីអាងសុត្តានុលោមពោលសោត, គួរសង្កេតពិនិត្យសុត្តានុលោមក្នុងអាចរិយវាទ កាលត្រូវគ្នាសមគ្នាពិត ទើបគួរកាន់យក, កាលមិនត្រូវគ្នា សមមិនគ្នាពិត ក្រៅនេះមិនគួរកាន់យក, គួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។

បើសកវាទីនេះ អាងអាចរិយវាទពោល, បរវាទីអាងអត្តនោម

តិពោលសោត, គួរសង្កេតពិនិត្យអត្តនោមតិក្នុងអាចរិយវាទ បើត្រូវគ្នាសមគ្នា គួរកាន់យក, បើមិនត្រូវគ្នា មិនសមគ្នា មិនគួរកាន់យក, គួរតាំងនៅក្នុងអាចរិយវាទប៉ុណ្ណោះ ។ ការកាន់យក(មតិ) របស់ខ្លួនទុំះឯង គួរធ្វើឱ្យមានកម្លាំង (ឱ្យមានពាក្យអាង) ។

មួយទៀត បើសកវាទីនេះ អាងអត្តនោមតិពោល, បរវាទីអាងសូត្រពោល សោត, គួរសង្កេតពិនិត្យសូត្រក្នុងអត្តនោមតិ, បើត្រូវគ្នា សមគ្នា គួរកាន់យក ។ សូត្រដែលគួរតិះដៀលក្រៅនេះ មិនគួរកាន់យក, គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។

បើសកវាទីនេះ អាងអត្តនោមតិពោល, បរវាទីអាងសុត្តានុលោមពោលសោតគួរសង្កេតពិនិត្យសុត្តានុលោមក្នុងអត្តនោមតិ កាលត្រូវគ្នាសមគ្នាពិត គួរកាន់យក ។ ក្រៅនេះមិនគួរកាន់យក, គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។

បើសកវាទីនេះ អាងអត្តនោមតិពោល, បរវាទីអាងអាចរិយវាទពោលសោត, គួរសង្កេតពិនិត្យអាចរិយវាទក្នុងអត្តនោមតិ បើត្រូវគ្នាសមគ្នា គួរកាន់យក ។ អាចរិយវាទដែលគួរតិះដៀលក្រៅនេះ មិនគួរកាន់យក, គួរតាំងនៅក្នុងអត្តនោមតិប៉ុណ្ណោះ ។ ការកាន់យក(មតិ) របស់ខ្លួនទុំះឯង គួរធ្វើឱ្យមានកម្លាំង (ឱ្យមានពាក្យអាង) ។ មួយទៀត

មិនគួរនិយាយជៀមជាម ឬតិះដៀលក្នុងទីទាំងពួង ដោយប្រការដូច្នេះ ។

មួយទៀត បើសកវាទីនេះ ពោលអាងថា ជាកប្បិយ បរវាទី ពោលអាងថា ជាអកប្បិយ គួរសង្កេតពិនិត្យវត្ថុនោះ ៗ ក្នុងសូត្រនិងសុត្តានុលោម បើវត្ថុនោះជាកប្បិយ, គួរតាំងនៅក្នុងវត្ថុដែលជាកប្បិយ បើវត្ថុនោះ ជាអកប្បិយ, ក៏គួរតាំងនៅក្នុងវត្ថុដែលជាអកប្បិយ ។

បើសកវាទីនេះ ចង្អុលបង្ហាញហេតុ និងពាក្យវិនិច្ឆ័យជាច្រើនអំពីសូត្រជាគ្រឿងសាធកវត្ថុដែលជាកប្បិយ ដល់ចំណែកបរវាទីនោះសោត, បរវាទីមិនជួបហេតុ, ក៏គួរតាំងនៅក្នុងវត្ថុដែលជាកប្បិយ ។

បើបរវាទី ចង្អុលបង្ហាញហេតុ និងពាក្យវិនិច្ឆ័យជាច្រើនអំពីសូត្រជាគ្រឿងសាធកវត្ថុដែលជាអកប្បិយដល់ចំណែកសកវាទីនោះសោត, សកវាទីនោះ មិនគួរប្រកាន់មាំតាំងនៅថា ការកាន់យកមតិរបស់ខ្លួន (ត្រូវចំណែកតែមួយ) គួរព្រមទទួលថា ល្អណាស់ ហើយតាំងនៅក្នុងវត្ថុដែលជាអកប្បិយប៉ុណ្ណោះ ។ បើថា ស្រមោលនៃហេតុរបស់ទាំងពីរចំណែក រមែងប្រាកដច្បាស់សោត, សេចក្តីទាំងពីរចំណែកដែលជំទាស់នុ៎ះឯង ជាការល្អ, តែគួរតាំងនៅក្នុងវត្ថុដែលជាអកប្បិយ ។ សេចក្តីពិតកាលមកដល់វិន័យហើយ ដែលភិក្ខុបរិស័ទ គួរអាស្រ័យការពិចារណាដល់វត្ថុដែលគួរនិងមិនគួរការពារទុក គួរធ្វើការប្រកាន់ឱ្យមាំ គួរកាត់

ក្រសែចេញ, គួរតាំងនៅក្នុងភាពជាអ្នកជូនទុំឯង ។

មួយទៀត បើសកវាទីនេះ ពោលអាងថា ជាអកប្បិយ, បរវាទី ពោលអាងថា ជាកប្បិយ, គួរសង្កេតពិនិត្យវត្ថុនោះ ៗ ក្នុងសូត្រនិងសុត្តានុលោម បើវត្ថុនោះជាកប្បិយ, គួរតាំងនៅក្នុងវត្ថុដែលជាកប្បិយ, បើវត្ថុនោះជាអកប្បិយ, គួរតាំងនៅក្នុងវត្ថុដែលជាអកប្បិយ ។

បើសកវាទីនេះ ចង្អុលបង្ហាញដល់វត្ថុដែលជាអកប្បិយ ដោយសូត្រពាក្យវិនិច្ឆ័យនិងហេតុយ៉ាងច្រើនសោត, បរវាទីមិនបានជួបហេតុ, គួរតាំងនៅក្នុងវត្ថុដែលជាអកប្បិយ ។

បើបរវាទី ចង្អុលបង្ហាញដល់វត្ថុដែលជាកប្បិយ ដោយសូត្រពាក្យវិនិច្ឆ័យ និងហេតុជាច្រើនសោត, សកវាទីនេះ មិនបានជួបហេតុ, គួរតាំងនៅក្នុងវត្ថុដែលជាកប្បិយ ។ បើថា ស្រមោលនៃហេតុ សូម្បីរបស់ទាំងពីរចំណែក រមែងប្រាកដច្បាស់សោត, មិនគួរលះបង់ការកាន់យក ( មតិ ) របស់ខ្លួន ។ ឧទាហរណ៍ថា ក្នុងវត្ថុដែលជាកប្បិយនឹងអកប្បិយ និងក្នុងវត្ថុដែលជាអកប្បិយនឹងកប្បិយ លោកពោលវិនិច្ឆ័យនេះទុកហើយ យ៉ាងណា, ក្នុងវាទៈថា ជាអនាបត្តិនិងអាបត្តិក្តី ក្នុងវាទៈថា ជាអាបត្តិនិងអនាបត្តិក្តី ក្នុងវាទៈថា ជាលហុកាបត្តិនិងគរុកាបត្តិក្តី ក្នុងវាទៈថា ជាគរុកាបត្តិនិងលហុកាបត្តិក្តី ក៏គួរជ្រាបវិនិច្ឆ័យ យ៉ាងនោះ ។

ពិតមែន ក្នុងវាទៈដែលថា ជាអនាបត្តិនិងអាបត្តិជាដើមនេះ មានសេចក្តីផ្សេងគ្នាក្នុងហេតុត្រឹមតែឈ្មោះប៉ុណ្ណោះ, ក្នុងន័យនៃការប្រកបសេចក្តីមិនមានសេចក្តីផ្សេងគ្នាទេ, ព្រោះដូច្នោះ ការប្រកបសេចក្តី ទើបលោកមិនធ្វើឱ្យពិស្តារ ។ កាលកើតពាក្យវិនិច្ឆ័យដល់វត្ថុដែលជាកប្បិយនិងអកប្បិយជាដើមយ៉ាងនេះហើយ ចំណែកណា បានជួបហេតុជាច្រើនក្នុងសូត្រ សុត្តានុលោម អាចរិយវាទ និងអត្តនោមតិ, គួរតាំងនៅក្នុងវាទៈរបស់ចំណែកនោះ ។ មួយទៀត ទាំងពីរចំណែក កាលមិនបានជួបហេតុនិងពាក្យវិនិច្ឆ័យ ដោយប្រការទាំងពួង មិនគួរលះចោលសូត្រ គួរតាំងនៅក្នុងសូត្រប៉ុណ្ណោះ ដូច្នេះឯង ។ ព្រះវិន័យធរអ្នកប្រាថ្នាភាពជាអ្នកឆ្លាតក្នុងសិក្ខាបទ វិភង្គនៃសិក្ខាបទនោះ និងវិន័យវិនិច្ឆ័យទាំងអស់ គួរជ្រាបវិន័យ ៤ យ៉ាងនេះ ដូចពណ៌នាមក ដូច្នេះ ។

## ព្រះវិន័យធរប្រកបដោយលក្ខណៈ ៣ យ៉ាង

ក៏ឯបុគ្គលអ្នកទ្រទ្រង់វិន័យ សូម្បីគ្រាជ្រាបវិន័យ ៤ យ៉ាងនេះហើយ ក៏គួរជាអ្នកប្រកបដោយលក្ខណៈ ៣ ។ ពិតមែន លក្ខណៈនៃព្រះវិន័យធរ ៣ យ៉ាងគួរប្រាថ្នា ។ លក្ខណៈ ៣ យ៉ាង ដូចម្តេច ? លក្ខណៈ ៣ យ៉ាង គឺ ៖

ពាក្យថា "សូត្ររបស់ព្រះវិន័យធរនោះ ជាពុទ្ធវចនៈដែលមកត្រឹមត្រូវ ចាំស្ទាត់រត់មាត់ដោយប្រពៃ កាត់សេចក្តីបានស្រួលតាមសុត្តៈនិងព្យញ្ជនៈ"[១] នេះជាលក្ខណៈទីមួយ ។ ពាក្យថា "ជាអ្នកតាំងមាំក្នុងវិន័យ មិនរំភើប"[២] នេះជាលក្ខណៈ ទីពីរ ។ ពាក្យថា "ព្រះវិន័យធរនោះបានរៀនតំណអាចារ្យ ហើយនឹងយកចិត្តទុកដាក់ ពិចារណាដោយល្អ"[៣] នេះជាលក្ខណៈទីបី ។

## អត្ថាធិប្បាយលក្ខណៈ ៣ របស់ព្រះវិន័យធរ

ក្នុងពាក្យថា សុត្តញ្ច ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

វិន័យបិដកទាំងអស់ឈ្មោះថា សូត្រ, សូត្រនោះរបស់ព្រះវិន័យធរនោះ ជាពុទ្ធវចនៈដែលមកត្រឹមត្រូវ គឺ មកដោយល្អ ។

បទថា សុប្បវត្តិតំ : ចាំស្ទាត់រត់មាត់ដោយប្រពៃ បានដល់ប្រព្រឹត្តទៅដោយល្អ គឺ ជំនាញ ចាំរត់មាត់ ។

ប្រើនបទថា សុវិនិច្ឆិតំ សុត្តសោ អនុព្យញ្ជនសោ[៤] : កាត់

---

១-២. វិន. បរិ. ឧបាលិបញ្ហា. ១៣. ២៧១/២៩៩ ។ ៣. វិន. បរិ. ឯកុត្តរិក. ១៣. ៦៣/៦៤ ។ ៤. បិដកខ្មែរ. អនុព្យញ្ជនសោ ។

សេចក្តីបានស្រួលតាមសុត្តៈ និងព្យញ្ជនៈ បានដល់ ដែលវិនិច្ឆ័យរៀបរយ គឺ ដែលខ្លួនកាត់សេចក្តីសង្ស័យ រៀនយកទុក ដោយបាលីបរិបុច្ឆានិងអដ្ឋកថា ។

ច្រើនបទថា វិនយេ ខោ បន ឋិតោ ហោតិ ជាអ្នកតាំងមាំក្នុងវិន័យ មិនរំភើប សេចក្តីថា ព្រះវិន័យធរនោះជាអ្នកតាំងមាំក្នុងព្រះវិន័យដោយភាពជាលជ្ជីភិក្ខុ ។ ពិតមែន អលជ្ជីភិក្ខុសូម្បីជាពហុស្សូត ព្រោះខ្លួនជាអ្នកធ្ងន់ក្នុងលាភ ក៏ក្លែងពោលឱ្យខុសបទបញ្ញត្តិ សម្តែងសត្ថុសាសនាក្រៅធម៌ក្រៅវិន័យ រមែងធ្វើឧបទ្រវៈច្រើនយ៉ាងក្នុងព្រះសាសនា គឺបង្កឱ្យកើតសង្ឃភេទខ្លះ សង្ឃរាជីខ្លះ ។ ចំណែកភិក្ខុលជ្ជី ជាអ្នកច្រើនរង្កៀស ប្រាថ្នាការសិក្សា សូម្បីព្រោះហេតុនៃជីវិត ក៏មិនក្លែងពោលឱ្យខុសបទបញ្ញត្តិ រមែងសម្តែងចំពោះធម៌ ចំពោះវិន័យប៉ុណ្ណោះ គឺ ធ្វើសត្ថុសាសនាឱ្យជាទីគោរពតាំងនៅ ។

ពិតមែន ព្រះមហាថេរៈទាំងឡាយក្នុងកាលមុន បញ្ចេញវាចាថា "ក្នុងអនាគតកាល ភិក្ខុលជ្ជីនឹងរក្សាទុក" ដូច្នេះជាដើម ៣ ដង ។ ក៏ភិក្ខុណា ជាលជ្ជី ដូចពោលមកហើយនោះ ភិក្ខុនោះ កាលមិនលះបង់មិនប្រព្រឹត្តកន្លងវិន័យ ជាអ្នកតាំងមាំ គឺ រឹងមាំនៅក្នុងវិន័យ ដោយភាពជាលជ្ជីភិក្ខុ ដូច្នេះឯង ។

បទថា អសំហិរោ : មិនរំភើប សេចក្តីថា បុគ្គលណា ត្រូវអ្នកដទៃសួរដោយបាលីដោយខាងទាបឬខាងខ្ពស់ ដោយលំដាប់បទ ឬអដ្ឋកថា រមែងញាប់ញ័រ រសាប់រសល់ មិនអាចតាំងនៅមាំបាន រមែងស្រេបតាមពាក្យដែលអ្នកដទៃពោល ចោលវាទៈរបស់ខ្លួនចេញ កាន់យកវាទៈរបស់អ្នកដទៃ អ្នកនោះ ឈ្មោះថា អ្នកស្រេពចស្រេពិល ។ ចំណែកបុគ្គលណា ត្រូវអ្នកដទៃសួរដោយបទខាងក្រោមនិងខាងលើ ឬដោយលំដាប់បទក្នុងបាលីក្តី ក្នុងអដ្ឋកថាក្តី រមែងមិនញាប់ញ័រ មិនរសាប់រសល់ ប្រៀបដូចយកដង្កៀបចាប់រោមម្តងមួយសរសៃ ៗ ដូច្នោះ ចន្អុលបង្ហាញចំពោះគេថា "ខ្ញុំព្រះករុណាពោលយ៉ាងនេះ, អាចារ្យទាំងឡាយរបស់ខ្ញុំព្រះករុណា ក៏ពោលយ៉ាងនេះ" ។ មួយទៀត បាលីនិងវិនិច្ឆ័យបាលី តាំងនៅក្នុងបុគ្គលណា មិនដល់នូវការអស់ទៅសូន្យទៅ ដូចខ្លាញ់រាជសីហ៍ដែលដាក់ទុកក្នុងភាជនៈមាស មិនដល់នូវការអស់ទៅដូច្នោះ, បុគ្គលនេះ លោកហៅថា អ្នកមិនស្រេពចស្រេពិល ។

ច្រើនបទថា អាចរិយបរម្បរា ខោ បនស្ស សុគ្គហិតា ហោតិ : ព្រះវិន័យធរនោះបានរៀនតំណអាចារ្យ សេចក្តីថា លំដាប់នៃព្រះថេរៈ គឺ លំដាប់វង្ស ជាលំដាប់ដែលព្រះវិន័យធរនោះចាំបានយ៉ាងត្រឹមត្រូវ ។

បទថា សូមនសិកតា : ហើយនឹងយកចិត្តទុកដាក់ បានដល់

ធ្វើឱ្យសប្បាយចិត្តយ៉ាងល្អ តែល្មមទឹក ក៏ប្រាកដបាន ដូចប្រទីបដែលឆេះធ្លោរ ដូច្នោះ ។

បទថា សូបធារិតា : ពិចារណាដោយល្អ បានដល់ ពិចារណាដោយល្អ គឺ ពិចារណាដោយការបន្តជាប់គ្នានៃខាងដើមនិងខាងចុងដោយផលនិងដោយហេតុ ។

## លំដាប់អាចារ្យតាំងពីព្រះឧបាលីថេរៈជាដើមមក

បុគ្គលលះមតិរបស់ខ្លួនហើយជាអ្នកពោលសេចក្ដីបរិសុទ្ធិនៃអាចារ្យ គឺ នាំលំដាប់អាចារ្យ បានដល់ របៀបនៃព្រះថេរៈទាំងអស់យ៉ាងនេះ គឺ អាចារ្យរបស់ខ្ញុំព្រះករុណារៀនយកក្នុងសំណាក់របស់អាចារ្យឈ្មោះឯណោះ, អាចារ្យនោះរៀនយកក្នុងសំណាក់អាចារ្យឈ្មោះឯណោះ, ទៅតាំងទុកដរាបឱ្យដល់ពាក្យថា "ព្រះឧបាលីថេរៈ រៀនយកក្នុងសំណាក់របស់ព្រះពុទ្ធ ។

"អាចារ្យជាបន្ត ៗ មក បាននាំសូម្បីអំពីព្រះឧបាលីថេរៈនោះមក គឺ បាននាំលំដាប់នៃអាចារ្យ បានដល់ របៀបនៃព្រះថេរៈទាំងអស់ ដរាបឱ្យដល់អាចារ្យរបស់ខ្លួន ហើយតាំងទុកយ៉ាងនេះថា "ព្រះឧបាលីថេរៈរៀនមកក្នុងសំណាក់របស់ព្រះសម្មាសម្ពុទ្ធ, ព្រះទាសកត្ថេរ រៀនមកក្នុងសំណាក់របស់ព្រះឧបាលីថេរៈជាឧបជ្ឈាយ៍ របស់ខ្លួន, ព្រះសោណកត្ថេរ

រៀនមកក្នុងសំណាក់របស់ព្រះទាសកត្ថេរជាឧបជ្ឈាយ៍របស់ខ្លួន, ព្រះសិគ្គវត្ថេររៀនមកក្នុងសំណាក់របស់ព្រះសោណកត្ថេរ ជាឧបជ្ឈាយ៍របស់ខ្លួន, ព្រះមោគ្គលីបុត្រតិស្សត្ថេរ រៀនមកក្នុងសំណាក់របស់ព្រះសិគ្គវត្ថេរ និងព្រះចណ្ឌវជ្ជីថេរៈជាឧបជ្ឈាយ៍របស់ខ្លួន ។

"ពិតមែន លំដាប់នៃអាចារ្យ ដែលព្រះវិន័យធររៀនយកហើយយ៉ាងនេះ លោករមែងចាំបានយ៉ាងត្រឹមត្រូវ តែកាលមិនអាចនឹងរៀនយកយ៉ាងនោះ ក៏គួររៀនយកត្រឹមតែ ២-៣ លំដាប់ក៏ល្អម ។ ពិតមែនដោយន័យចុងបំផុត គួរជ្រាបដូចអាចារ្យ និងអាចារ្យរបស់អាចារ្យពោលបាលីនិងបរិបុច្ឆា ដូច្នោះ ។

## ព្រះវិន័យធរវិនិច្ឆ័យអធិករណ៍គួរត្រួតមើលឋានៈ ៦ យ៉ាងមុន

ក៏ឯព្រះវិន័យធរអ្នកប្រកបព្រមដោយលក្ខណៈ ៣ យ៉ាងនេះហើយ កាលសង្ឃប្រជុំគ្នាដើម្បីវិនិច្ឆ័យរឿង និងរឿងក៏ឈានចុះហើយទាំងអ្នកចោទនិងអ្នកជាប់ចោទក៏ឱ្យការណ៍ហើយ កាលនឹងនិយាយមិនគួរប្រញាប់កាត់សេចក្តីភ្លាមទេ គួរត្រួតមើលឋានៈទាំង ៦ មុនសិន ។

ឋានៈ ៦ យ៉ាង ដូចម្តេច ? ឋានៈ ៦ យ៉ាងនោះគឺ ៖

គួរត្រួតមើលរឿង១ ត្រួតមើលមាតិកា១ ត្រួតមើលបទភាជនី១ ត្រួតមើលតិកបរិច្ឆេទ១ ត្រួតមើលអន្តរាបត្តិ១ ត្រួតមើលអនាបត្តិ១ ។

## អត្ថាធិប្បាយឋានៈ ៦ យ៉ាង

ពិតមែន ព្រះវិន័យធរ សូម្បីកាលត្រួតមើលរឿង រមែងឃើញអាបត្តិយ៉ាងណាមួយ យ៉ាងនេះគឺ "ភិក្ខុ(ដែលមានចីវរបាត់)នោះ ត្រូវបិទបាំង(រាងកាយ) ដោយស្មៅឬស្លឹកឈើហើយសឹមមក, មិនត្រូវដើរមកទាំងអាក្រាតកាយឡើយ, ភិក្ខុឯណាមក(ទាំងអាក្រាត) ភិក្ខុនោះត្រូវអាបត្តិទុក្កដ"(១) ។ ព្រះវិន័យធរនោះ កាលនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

លោកសូម្បីកាលត្រួតមើលមាតិកា រមែងឃើញបណ្តាអាបត្តិ ៥ កងណាមួយ ដោយន័យជាដើមថា "ភិក្ខុពោលពាក្យកុហកដោយដឹងខ្លួនត្រូវអាបត្តិបាចិត្តិយ"(២) ។ "កាលលោកនាំសូត្រនោះមកអាងហើយនឹងរម្ងាប់អធិករណ៍នោះបាន ។

លោកសូម្បីកាលត្រួតមើលបទភាជនី រមែងឃើញបណ្តាអាបត្តិ៧ កងណាទីមួយ ដោយន័យមានជាដើមថា "សេពមេថុនធម្ម ចំពោះសរីរៈដែលសត្វមិនទាន់ស៊ី ត្រូវអាបត្តិបារាជិក, សេពមេថុនធម្មចំពោះសរីរៈដែលសត្វស៊ីហើយដោយច្រើន ត្រូវអាបត្តិថុល្លច្ច័យ"(៣) ។ កាលលោក

---

១. វិន. និស្ស. ៣. ៥៤/៥៤ ។ ២. វិន. និស្ស. ៣. ១៧៣/២២៣ ។
៣. វិន. បរិ. ១២. ២៤៤/១២៦ ។

នាំសូត្រពីបទភាជនីមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

លោក សូម្បីកាលត្រួតមើលតិកបរិច្ឆេទ រមែងឃើញការកំណត់តិកសង្ឃាទិសេសខ្លះ តិកបាចិត្តិយខ្លះ តិកទុក្កដខ្លះ អាបត្តិយ៉ាងណាមួយខ្លះ ។ កាលលោក នាំសូត្រមកពីបាលីតិកបរិច្ឆេទនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

លោក សូម្បីកាលត្រួតមើលអន្តរាបត្តិ នឹងឃើញអន្តរាបត្តិដែលមាននៅក្នុងចន្លោះនៃសិក្ខាបទយ៉ាងនេះ គឺ ភិក្ខុលើកឡើងនូវគប់ភ្លើង (ធ្លាក់ទៅត្រង់ទីនោះវិញ) ត្រូវអាបត្តិទុក្កដ ។ កាលលោកនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

សូម្បីកាលលោកត្រួតមើលអនាបត្តិ នឹងឃើញអនាបត្តិដែលលោកសម្តែងទុកហើយក្នុងសិក្ខាបទនោះ ៗ យ៉ាងនេះថា ម្នាលភិក្ខុ អ្នកឯងមិនត្រូវអាបត្តិទេ ព្រោះមិនត្រេកអរ, មិនមានថេយ្យចិត្ត, មិនមានបំណងឱ្យស្លាប់ទេ, មិនមានបំណងនឹងពោលអួត មិនមានបំណងនឹងឱ្យអសុចិឃ្លាតចេញ មិនក្លែង មិនដឹង ព្រោះមិនមានសតិ ។ កាលលោកនាំសូត្រនោះមកអាងហើយ នឹងរម្ងាប់អធិករណ៍នោះបាន ។

ពិតមែន ភិក្ខុណា ជាអ្នកឆ្លាតក្នុងវិន័យ ៤ យ៉ាង ដល់ព្រមដោយលក្ខណៈ ៣ បានត្រួតមើលឋានៈ ៦ យ៉ាងនេះហើយ នឹងរម្ងាប់

អធិករណ៍បាន ។ ការវិនិច្ឆ័យ (អធិករណ៍)របស់ភិក្ខុនោះអ្នកណា ៗ នឹងជំទាស់មិនបាន រមែងដូចគ្នានឹងវិនិច្ឆ័យដែលព្រះពុទ្ធគង់ប្រថាប់វិនិច្ឆ័យដោយខ្លួនឯង ។

## វិធីវិនិច្ឆ័យអធិករណ៍

ប្រសិនបើភិក្ខុខ្លះ ធ្វើការប្រព្រឹត្តកន្លងសិក្ខាបទហើយ ចូលទៅរកភិក្ខុដែលឆ្លាតក្នុងការវិនិច្ឆ័យនោះ យ៉ាងនោះហើយ គប្បីសួរដល់សេចក្តីវង្វៀសសង្ស័យរបស់ខ្លួនសោត, ភិក្ខុអ្នកឆ្លាតក្នុងការវិនិច្ឆ័យនោះ គួរកំណត់ឱ្យល្អ បើជាអនាបត្តិ, ក៏គួរប្រាប់ថា ជាអនាបត្តិ, តែបើជាអាបត្តិក៏គួរប្រាប់ថា ជាអាបត្តិ, បើអាបត្តិនោះជាទេសនាគាមិនី ក៏គួរប្រាប់ថាជាទេសនាគាមិនី, បើជាវុដ្ឋានគាមិនី ក៏គួរប្រាប់ថា ជាវុដ្ឋានគាមិនី, បើឆាយាបារាជិកប្រាកដដល់ភិក្ខុដែលឆ្លាតក្នុងការវិនិច្ឆ័យនោះសោត, មិនគួរប្រាប់ថា ជាអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ការប្រព្រឹត្តកន្លងមេថុនធម្ម និងការប្រព្រឹត្តកន្លងឧត្តរិមនុស្សធម្មជារបស់គ្រោតគ្រាត ។ ចំណែកការល្មើសអទិន្នាទាន និងមនុស្សវិគ្គហ:ជារបស់សុខុមមានចិត្តផ្លាស់ប្តូររហ័ស, ភិក្ខុរមែងត្រូវវិតិក្កម:ទាំងពីរនោះ ដោយអាការសុខុមតែម្តង (និង) រមែងរក្សាទុកដោយអាការសុខុម (ដូចគ្នា) ។ ព្រោះហេតុនោះ ភិក្ខុដែលត្រូវសួរចំពោះសេចក្តីវង្វៀសសង្ស័យ ដែល

មានការប្រព្រឹត្តកន្លងនោះជាទីតាំងដោយពិសេស មិនគួរនិយាយថា ត្រូវអាបត្តិ បើអាចារ្យលោកនៅមានជីវិតសោត, ក្រោយអំពីនោះ ភិក្ខុដែលឆ្លាតក្នុងការវិនិច្ឆ័យនោះ គួរបញ្ជូនភិក្ខុនោះទៅថា "លោកចូរសួរអាចារ្យរបស់ខ្ញុំព្រះករុណាមើលចុះ" ។

បើលោកត្រឡប់មកទៀតប្រាប់ថា "អាចារ្យរបស់លោក គន់មើលអំពីព្រះសូត្រ ព្រះវិន័យហើយប្រាប់ខ្ញុំព្រះករុណាថា ជាសតេកិច្ឆា ( ល្មមកែខៃបាន )", ក្នុងកាលនោះ ភិក្ខុដែលឆ្លាតក្នុងការវិនិច្ឆ័យនោះ គួរនិយាយនឹងលោកថា "ល្អណាស់ ៗ លោកចូរធ្វើតាមដែលអាចារ្យនិយាយ" ។ ក៏បើអាចារ្យរបស់លោកមិនមានសោត, តែព្រះថេរៈដែលរៀនរួមគ្នា មាន, គប្បីបញ្ជូនលោកទៅកាន់សំណាក់របស់ព្រះថេរៈនោះ ដោយបង្គាប់ថា "ព្រះថេរៈដែលរៀនរួមនឹងខ្ញុំព្រះករុណាជាគណបាមោក្ខ មាន", លោកចូរទៅសួរលោកមើលចុះ ។ សូម្បីកាលព្រះថេរៈនោះវិនិច្ឆ័យថាជាសតេកិច្ឆា ក៏គួរប្រាប់នឹងលោកថា "ល្អណាស់, លោកចូរធ្វើតាមពាក្យសូមរបស់ព្រះថេរៈនោះឱ្យល្អចុះ" ។ បើសូម្បីព្រះថេរៈអ្នករៀនសូត្ររួមគ្នា របស់លោកមិនមានសោត, មានតែភិក្ខុដែលជាអន្តេវាសិក ដែលជាបណ្ឌិត, គប្បីបញ្ជូនលោកទៅកាន់សំណាក់របស់ភិក្ខុអ្នកជាអន្តេវាសិកនោះ ដោយបង្គាប់ថា "លោកចូរទៅសួរភិក្ខុកម្លោះរូបឯណោះមើល

ចុះ” ។ សូម្បីកាលភិក្ខុដែលជាអន្តេវាសិកនោះ វិនិច្ឆ័យថា ជាសតេកិច្ឆា ក៏គួរនិយាយនឹងលោកថា “ល្អណាស់, លោកចូរធ្វើតាមពាក្យរបស់ភិក្ខុនោះឱ្យល្អ” ។ បើស្រមោលបារាជិកទុំៈឯង ប្រាកដសូម្បីដល់ភិក្ខុកម្លោះសោត, សូម្បីដែលភិក្ខុកម្លោះនោះ ក៏មិនគួរប្រាប់ភិក្ខុដែលត្រូវអាបត្តិថា “លោកត្រូវអាបត្តិបារាជិក” ។

## ភិក្ខុដែលមានសីលមិនបរិសុទ្ធិ កម្មដ្ឋានមិនចម្រើន

ពិតមែន ការកើតឡើងនៃព្រះពុទ្ធ ជារបស់បានដោយក្រ, ការបព្វជ្ជា និង ការឧបសម្បទា ជារបស់បានដោយក្រក្រៃលែងជាងនោះ ។ តែព្រះវិន័យធរគួរនិយាយយ៉ាងនេះថា “លោក ចូរបោសសំអាតឱកាសដែលស្ងៀមស្ងាត់ ហើយអង្គុយសម្រាកពេលថ្ងៃជម្រះសីល ឱ្យបរិសុទ្ធិ ចូរមនសិការអាការ ៣២ ចុះ” ។ បើសីលរបស់ភិក្ខុនោះមិនធ្លុះធ្លាយសោត, កម្មដ្ឋាន រមែងបន្ត, សង្ខារទាំងឡាយ ក៏ជារបស់ប្រាកដច្បាស់ឡើង, ចិត្តក៏ជាឯកគ្គតា ដូចបានសម្រេចឧបចារនិងអប្បនាសមាធិដូច្នោះ, សូម្បីថ្ងៃទឹងកន្លងទៅហើយក៏ដោយ លោកក៏មិនជ្រាប ។ ក្នុងវេលាថ្ងៃកន្លងទៅ លោកមកកាន់ទីឧបដ្ឋាកហើយ គួរនិយាយយ៉ាងនេះថា ការប្រព្រឹត្តទៅនៃចិត្តរបស់លោក តើយ៉ាងណា ? ក៏កាលលោកប្រាប់ការ

ប្រព្រឹត្តទៅនៃចិត្តហើយ គួរនិយាយនឹងលោកថា "ដែលឈ្មោះថាបព្វជ្ជាមានសេចក្ដីបរិសុទ្ធិនៃចិត្តជាប្រយោជន៍, លោកកុំប្រមាទ បំពេញសមណធម៌ចុះ" ។

ចំណែកភិក្ខុណា មានសីលដាច់, កម្មដ្ឋានរបស់ភិក្ខុនោះ រមែងមិនបន្ត, ចិត្ត រមែងរំជើបរំជួល គឺ ត្រូវភ្លើងគឺ សេចក្ដីក្ដៅក្រហាយដុតរោល ដូចត្រូវចាក់ដោតដោយជន្លួញ ដូច្នោះ, ភិក្ខុនោះ រមែងក្រោកឡើងក្នុងខណៈនោះតែម្ដង ដូចអង្គុយនៅលើដុំថ្មក្ដៅ ដូច្នោះ ។ លោកមកហើយសួរថា "តើការប្រព្រឹត្តទៅនៃចិត្តរបស់លោកយ៉ាងណា ?" កាលលោកប្រាប់ការប្រព្រឹត្តទៅនៃចិត្តហើយ គួរនិយាយថា "ធម្មតាបុគ្គលអ្នកធ្វើអំពើអាក្រក់ក្នុងលោក មិនដែលកំបាំងទេ[១] ពិតមែន បុគ្គលអ្នកធ្វើសេចក្ដីអាក្រក់ រមែងដឹងដោយខ្លួនឯងមុនអ្នកដទៃទាំងអស់, តពីនោះ អារក្ខទេវតាទាំងឡាយ សមណព្រាហ្មណ៍និងទេវតាពួកដទៃ អ្នកដឹងចិត្តរបស់បុគ្គលដទៃ រមែងដឹង (សេចក្ដីអាក្រក់) របស់លោក, ឥឡូវនេះ លោកចូរស្វែងរកសេចក្ដីសួស្ដីដល់ខ្លួនឯងចុះ" ។

វិន័យកថា ៤ យ៉ាង និងលក្ខណៈកថា ជាដើមរបស់ព្រះវិន័យធរ ចប់

(១) អង្គុ. តិក. ៤១. ៤១/១១៨ ។

# អត្ថាធិប្បាយសិក្ខាបទវិភង្គបឋមបារាជិក

ឥឡូវនេះ ខ្ញុំនឹងពណ៌នាសេចក្ដីវិភង្គនៃសិក្ខាបទតទៅ ៖

ក្នុងពាក្យថា **យោ បនាតិ យោ យាទិសោ** ជាដើម ដែលព្រះមានព្រះភាគត្រាស់ទុក មានវិនិច្ឆ័យដូចតទៅនេះ ៖

ពីរបទថា **យោ បន** ជាបទដែលគួរចែក ។ បទជាដើមថា **យោ យាទិសោ** ជាបទចែកនៃបទថា **យោ បន** នោះ ។ ក៏ក្នុងពីរបទថា **យោ បន** នេះ ស័ព្ទថា **បន** ត្រឹមតែថា ជានិបាត, បទថា **យោ** ជាបទប្រាប់សេចក្ដី, និងបទថា **យោ**នោះ សម្ដែងបុគ្គលដោយមិនចំពោះខ្លួន ; ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងអត្ថនៃបទថា **យោ** នោះ ទើបត្រាស់ចំពោះ **យោ** ស័ព្ទ ដែលសម្ដែងបុគ្គលដោយមិនចំពោះខ្លួន ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងបទថា **យោ បន** នេះយ៉ាងនេះ ។

បទថា **យោ បន** មានពាក្យអធិប្បាយថា **យោ កោចិ** ប្រែថា អ្នកណាម្នាក់ ។ ក៏បុគ្គលដែលឈ្មោះថា អ្នកណាម្នាក់នោះ រមែងប្រាកដដោយអាការណាមួយ ក្នុងភេទ ការប្រកប ជាតិ ឈ្មោះ គោត្រ សីល វិហារធម៌ គោចរ និងវ័យ ដោយពិតប្រាកដ; ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ប្រកាសប្រភេទនោះ ដើម្បីឱ្យស្គាល់បុគ្គលនោះ

ដោយអាការយ៉ាងនោះ ទើបត្រាស់ពាក្យថា យាទិសោជាដើម ។

ក្នុងពាក្យថា **យាទិសោ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

បទថា យាទិសោ : **តាមតែភិក្ខុរូបណា** មានសេចក្ដីថា ពោលដោយ អំណាចភេទ ទីងជាបុគ្គលយ៉ាងណាឬ ដូច្នោះក៏ដោយ គឺ ទីងជាអ្នកខ្ពស់ ឬអ្នកទាប ខ្មៅ ឬស ឬមានសម្បុរលឿង ស្គមឬធាត់ក៏ដោយ ។

បទថា យថាយុត្តោ : **ដែលប្រកបក្នុងកម្មយ៉ាងណា** មានសេចក្ដីថា ពោលដោយអំណាចការប្រកប ទោះជាអ្នកប្រកបដោយការងារយ៉ាងណាមួយ ក៏ដោយ គឺ ជាអ្នកប្រកបដោយនវកម្ម ឬប្រកបដោយឧទ្ទេស ឬប្រកបដោយធុរៈក្នុងទីនៅក៏ដោយ ។

បទថា យថាជច្ចោ : **មានជាតិយ៉ាងណា** មានសេចក្ដីថា ពោលដោយអំណាចជាតិ ទោះជាអ្នកមានជាតិយ៉ាងណា ឬជាអ្នកមានជាតិយ៉ាងនោះក៏ដោយ គឺ ទោះជាក្សត្រិយ៍ ឬជាព្រាហ្មណ៍ឬជាវេស្ស ជាសូទ្រក៏ដោយ ។

បទថា យថានាមោ : **មានឈ្មោះយ៉ាងណា** មានសេចក្ដីថា ពោលដោយអំណាចឈ្មោះ ទោះជាអ្នកមានឈ្មោះយ៉ាងណា ឬមានឈ្មោះយ៉ាងនោះក៏ដោយ គឺ ឈ្មោះថា ពុទ្ធរក្ខិត ឬឈ្មោះធម្មរក្ខិត ឬ

ឈ្មោះសង្ឃរក្ខិតក៏ដោយ ។

បទថា **យថាគោត្តោ** : **មានគោត្រយ៉ាងណា** មានសេចក្តីថា ពោលដោយអំណាចគោត្រ ទោះជាអ្នកមានគោត្រយ៉ាងណា ឬមានគោត្រយ៉ាងនោះ ឬពោលអំពីគោត្រយ៉ាងណាមួយក៏ដោយ គឺ ទោះជាកច្ចានគោត្រ ឬវាសេដ្ឋគោត្រ ឬកោសិយគោត្រក៏ដោយ ។

បទថា **យថាសីលោ** : **មានប្រក្រតីយ៉ាងណា** មានសេចក្តីថា ក្នុងប្រក្រតីទាំងឡាយ ទោះជាអ្នកមានយ៉ាងណាជាប្រក្រតី ឬថា ជាអ្នកមានយ៉ាងនោះជាប្រក្រតីក៏ដោយ គឺថា ទោះជាអ្នកមាននវកម្មជាប្រក្រតី ឬមានឧទ្ទេសជាប្រក្រតី ឬ មានធុរៈក្នុងទីលំនៅជាប្រក្រតី ក៏ដោយ ។

បទថា **យថាវិហារី** : **មានគ្រឿងនៅយ៉ាងណា** មានសេចក្តីថា សូម្បីក្នុងធម៌ជាគ្រឿងនៅទាំងឡាយ ទោះជាអ្នកមានយ៉ាងណាជាគ្រឿងនៅ ឬថា ជាអ្នកមានយ៉ាងនោះជាគ្រឿងនៅក៏ដោយ គឺថា ទោះជាអ្នកមាននវកម្មជាគ្រឿងនៅ ឬមានឧទ្ទេសជាគ្រឿងនៅ ឬថា មានធុរៈក្នុងទីលំនៅជាគ្រឿងនៅក៏ដោយ ។

បទថា **យថាគោចរោ** : **មានគោចរយ៉ាងណា** មានសេចក្តីថា សូម្បីក្នុងគោចរទាំងឡាយសោត ទោះជាអ្នកមានយ៉ាងណាជាគោចរ ឬថា មានយ៉ាងនោះជាគោចរក៏ដោយ គឺ ថា ទោះជាអ្នកមាននវកម្មជាគោចរ

ឬមានឧទ្ទេសជាគោចរ ឬមានធុរៈក្នុងទីលំនៅជាគោចរក៏ដោយ ។

ចំណែកក្នុងបទថា ថេរោ វា : ភិក្ខុជាថេរៈក្តី ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ទីងជាអ្នកណា ឬថា ជាអ្នកនោះ ក្នុងបណ្តាអ្នកចម្រើនដោយវ័យជាដើមក៏ដោយ, គឺ អធិប្បាយថា ទោះជាព្រះថេរៈ ព្រោះមានវស្សាគ្រប់ ១០ ឬថា ជា អ្នកថ្មី ព្រោះមានវស្សាខ្វះ៥ ឬថា ទោះជាអ្នកកណ្តាល ព្រោះមានវស្សាលើសជាង ៥ ក៏ដោយ ។ តាមការពិត បុគ្គលទាំងអស់នោះ ព្រះមានព្រះភាគត្រាស់ក្នុងអត្ថនេះថា យោ បទ : ណាមួយ ។

## អត្ថាធិប្បាយអត្ថន័យនៃភិក្ខុសព្ទជាដើម

[២៦] ក្នុងភិក្ខុនិទ្ទេស មានវិនិច្ឆ័យដូច្នេះ ៖

អ្នកណា រមែងសូម ហេតុនោះ អ្នកនោះ ឈ្មោះថា អ្នកសូម ។ អធិប្បាយថា ទោះជាបានក៏ដោយ មិនបានក៏ដោយ រមែងសូមដោយវិធីសូមយ៉ាងប្រសើរ ។ ឈ្មោះថា អ្នកអាស្រ័យការត្រាច់សូម ព្រោះជាអ្នកអាស្រ័យការដើរសូម ដែលព្រះពុទ្ធជាដើមទ្រង់អាស្រ័យហើយ ។ ពិតមែន បុគ្គលអ្នកណាម្នាក់លះគំនរភោគៈតិចឬច្រើន ចេញចាកផ្ទះបួសមិនមានផ្ទះ, បុគ្គលនោះ ឈ្មោះថា អាស្រ័យការត្រាច់សូម ព្រោះលះការ

ចិញ្ចឹមជីវិតដោយកសិកម្ម និងគោរក្ខកម្មជាដើមចេញ ព្រមទទួលកាន់ភេទនុំះឯង ព្រោះដូច្នោះ ទើបឈ្មោះថា ភិក្ខុ ។

ម្យ៉ាងទៀត សូម្បីឆាន់ភត្តដែលគេនាំមកដោយសង្វេ្រកនៅក្នុងវិហារ ក៏ឈ្មោះថា អាស្រ័យការត្រាច់សូម ព្រោះមានសេចក្តីរស់នៅជាប់ដោយអ្នកដទៃ ព្រោះដូច្នោះ ទើបឈ្មោះថា ភិក្ខុ ។

ម្យ៉ាងទៀត ឈ្មោះថា អាស្រ័យការត្រាច់សូម ព្រោះជាអ្នកកើតឧស្សាហ៍ក្នុងបព្វជ្ជា អាស្រ័យភោជន គឺ ដុំបាយដែលរកបានដោយកម្លាំងស្មង ព្រោះដូច្នោះ ទើបឈ្មោះថា ភិក្ខុ ។

អ្នកណា រមែងទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវកាត់ហើយ ព្រោះធ្វើតម្លៃផស្សរះនិងពណ៌ឱ្យខូចទៅ ហេតុនោះ អ្នកនោះ ឈ្មោះថា អ្នកទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវកាត់ហើយ ។ បណ្តាការធ្វើតម្លៃឱ្យខូចទៅជាដើមនោះ គប្បីជ្រាបការធ្វើតម្លៃឱ្យខូចទៅ ព្រោះកាត់ដោយសាស្ត្រា ។ ពិតមែន ផ្ទាំងសំពត់សូម្បីមានតម្លៃរាប់ពាន់ ដែលគេយកកាំបិតកាត់ឱ្យជាចម្រៀកតូចធំហើយ រមែងមានតម្លៃវិនាសទៅ គឺ មានតម្លៃមិនដល់សូម្បីពាក់កណ្តាលតម្លៃដើម ។ គប្បីជ្រាបការធ្វើផស្សរះឱ្យខូចទៅព្រោះដេរដោយអំបោះ ។ ពិតមែន ផ្ទាំងសំពត់សូម្បីដែលមានសម្ផស្សជាសុខដែលត្រូវដេរដោយអំបោះហើយ រមែងមានសម្ផ័ស្សខូចទៅ គឺ ដល់ភាព

ជាសំពត់ដែលមានសម្ផស្សរឹងគ្រោតគ្រាត ។

គប្បីជ្រាបការធ្វើពណ៌ឱ្យខូចទៅ ព្រោះស្រអាប់ដោយស្នឹមម្ចូលជាដើម ។ ពិតមែន ផ្ទាំងសំពត់សូម្បីបរិសុទ្ធិល្អ តាំងពីធ្វើការដោយម្ជុលទៅហើយ រមែងមានពណ៌ខូចទៅ គឺ រមែងលះបង់ពណ៌ដើមទៅ ព្រោះស្នឹមម្ជុល និង ព្រោះទឹកដែលជាមន្ទិលដែលកើតអំពីញើសដៃ និងព្រោះការជ្រលក់និងធ្វើកប្បៈក្នុងទីបំផុត ។ អ្នកណាឈ្មោះថា អ្នកទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវទម្លាយហើយ ព្រោះទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវទម្លាយដោយអាការ ៣ យ៉ាង ដូចអធិប្បាយមកហើយនោះ ហេតុនោះ អ្នកនោះ ឈ្មោះថា ភិក្ខុ ។

ម្យ៉ាងទៀត អ្នកណា ឈ្មោះថា អ្នកទ្រទ្រង់ផ្ទាំងសំពត់ដែលត្រូវកាត់ហើយ ព្រោះត្រឹមតែថា ទ្រទ្រង់សំពត់កាសាវៈទាំងឡាយ ដែលមិនដូចគ្នានឹងសំពត់របស់គ្រហស្ថ ហេតុនោះ អ្នកនោះ ឈ្មោះថា ភិក្ខុ ។

បទថា សមញ្ញាយ : ព្រោះហេតុតែវោហារថា សមណៈ សេចក្ដីថា ដោយបញ្ញត្តិ គឺ ដោយវោហារ ។ ពិតមែន បុគ្គលខ្លះរមែងប្រាកដថា ជាភិក្ខុ ដោយសមញ្ញាប៉ុណ្ណោះ ។ ពិតដូច្នោះមែន ក្នុងកិច្ចនិមន្តជាដើម មនុស្សទាំងឡាយ កាលរាប់ចំនួនភិក្ខុនោះ រាប់យកទាំងពួកសាមណេរចូលផង ហើយនិយាយថា ភិក្ខុចំនួនមួយរយរូប, ភិក្ខុចំនួនមួយ

ពាន់រូប ។

បទថា **បដិញ្ញាយ** : ព្រោះបានប្តេជ្ញា គឺ ដោយសេចក្តីបដិញ្ញារបស់ខ្លួនឯង ។ ពិតមែន បុគ្គលខ្លះរមែងប្រាកដថា ជាភិក្ខុសូម្បីដោយសេចក្តីបដិញ្ញា ។ គប្បីជ្រាបសេចក្តីបដិញ្ញាថា ជាភិក្ខុ នោះកើតប្រាកដបានដូចក្នុងប្រយោគជាដើមយ៉ាងនេះថា សួរថា ក្នុងទីនេះ ជាអ្នកណា ? ឆ្លើយថា "លោកដ៏មានអាយុ ខ្ញុំព្រះករុណា ជាភិក្ខុ" ។ ក៏សេចក្តីបដិញ្ញានេះ ជាសេចក្តីបដិញ្ញាដែលប្រកបដោយធម៌ ដែលព្រះអានន្ទត្ថេរបានពោលទុកហើយ ។ មួយទៀត ដោយចំណែកនៃរាត្រីសូម្បីពួកភិក្ខុដែលទ្រុស្តសីល ដើរតាមមកមក កាលត្រូវសួរថា "តើជាអ្នកណានៅក្នុងទីនេះ ?" ក៏ឆ្លើយថា "ពួកខ្ញុំព្រះករុណា ជាភិក្ខុ" ដូច្នេះដើម្បីប្រយោជន៍ដល់បដិញ្ញាដែលមិនប្រកបដោយធម៌ មិនមែនជាការពិត ។

បទថា **ឯហិភិក្ខុ** : ព្រោះសម្រេចជាឯហិភិក្ខុ សេចក្តីថា អ្នកដល់ភាពជាភិក្ខុ គឺ ឧបសម្បទាដោយឯហិភិក្ខុ ដោយត្រឹមតែព្រះតម្រាស់របស់ព្រះមានព្រះភាគ យ៉ាងនេះថា "អ្នកចូរមកជាភិក្ខុចុះ" ឈ្មោះថាភិក្ខុ ។ ពិតមែន ព្រះមានព្រះភាគ ទតឃើញបុគ្គលដែលដល់ព្រមដោយឧបនិស្ស័យ ដើម្បីជាឯហិភិក្ខុ ទើបទ្រង់លាតព្រះហស្តខាងស្តាំដែលមាន

ពណ៌ដូចមាស ចេញចាកចន្លោះបង្រ្កួលចីវរដែលមានពណ៌ក្រហម បញ្ចេញព្រះសូរសៀងកងរំពងដូចសំឡេងព្រហ្ម ត្រាស់ហៅថា “អ្នកចូរមកជាភិក្ខុចុះ, សាសនធម៌តថាគតពោលល្អហើយ អ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីនឹងធ្វើនូវព្រះនិព្វានជាទីបំផុតនៃកងទុក្ខដោយប្រពៃចុះ”[១] ។ ព្រមនឹងព្រះតម្រាស់របស់ព្រះមានព្រះភាគនោះឯង ភេទគ្រហស្ថ (របស់អ្នកសម្ដីងឧបសម្បទានោះ) អន្តរធានទៅ, បព្វជ្ជានិងឧបសម្បទាក៏សម្រេច, អ្នកនោះជាអ្នកកោរសក់ស្លៀកដណ្ដប់សំពត់កាសាវៈ គឺស្លៀក(សំពត់អន្តរវាសក) មួយផ្ទាំង ដណ្ដប់ (សំពត់ឧត្តរាសង្គៈ) មួយផ្ទាំង ពាក់(សំពត់សង្ឃាដិ)ទុកលើនឹងចង្កួយស្មាមួយផ្ទាំង មានបាត្រដីដែលមានពណ៌ដូចផ្កាឧប្បលខៀវ ប្រដាប់ទុកត្រង់ស្មាខាងឆ្វេង ។ ភិក្ខុនោះលោកកំណត់ចំពោះដោយបរិក្ខារ ៨ ដែលពាក់ស៊ុកចូលត្រង់រាងកាយ ដែលព្រះបូរាណាចារ្យពោលទុកយ៉ាងនេះថា ៖

> បរិក្ខារទាំងនេះគឺ ត្រៃចីវរ បាត្រ កាំបិតតូច ម្ជុល និងសំពត់វត្ថពន្ធចង្កេះ ព្រមទាំងសំពត់តម្រងទឹក ជាគម្រប់ ៨ រមែងគួរដល់ភិក្ខុដែលប្រកបសេចក្ដីព្យាយាម ។

> ជាអ្នកដល់ព្រមដោយឥរិយាបថ ដូចព្រះថេរៈ ៦០ វស្សា មាន

១. វិន. មហា. មហាខន្ធក. ៦. ១៧/៣៧ ។

ព្រះពុទ្ធជាអាចារ្យ មានព្រះពុទ្ធជាព្រះឧបជ្ឈាយ៍ ឈរថ្វាយបង្គំព្រះសម្មាសម្ពុទ្ធនៅតែម្តង ។

ពិតមែន ក្នុងបឋមពោធិកាល ព្រះមានព្រះភាគ ទ្រង់ឱ្យកុលបុត្រឧបសម្បទា ដោយឯហិភិក្ខុឧបសម្បទានុ៎ះឯង ក្នុងមួយរយៈកាល ។ និងភិក្ខុដែលឧបសម្បទា ដោយវិធីយ៉ាងនេះ មានចំនួន ១.៣៤១ រូប ។ គឺ យ៉ាងណា ? គឺ មានចំនួនដូច្នេះ ៖

ព្រះបញ្ចវគ្គិយត្ថេរ ៥ យសកុលបុត្រ ១ សម្លាញ់ដែលជាបរិវាររបស់លោក ៥៤ ភទ្ទវគ្គិយ ៣០ បុរាណជដិល ១,០០០ បរិព្វាជករួមជាមួយព្រះអគ្គសាវកទាំងពីរ ២៥០ ព្រះអង្គុលិមាលត្ថេរ ១ (រួមជា ១,៣៤១ រូប) សមពិត ដូចពាក្យដែលព្រះអដ្ឋកថាចារ្យ ពោលទុកក្នុងអដ្ឋកថាថា ៖

ភិក្ខុ ១, ៣០០ រូប និងពួកដទៃ៤០ រូបទៀត ទាំងព្រះថេរៈ
អ្នកមានបញ្ញា ១ រូប ទៀត, ភិក្ខុទាំងអស់នោះ លោក
ពោលថា ជាឯហិភិក្ខុ ។

ភិក្ខុទាំងនោះ ជាឯហិភិក្ខុ តែមួយពួក ក៏ទេ, សូម្បីពួកដទៃក៏នៅមានច្រើនទៀត ។ គឺ យ៉ាងណា ? គឺ មានចំនួនជាដើមយ៉ាងនេះថា សេលព្រាហ្មណ៍ទាំងបរិវារមានចំនួន ៣០០ ព្រះមហាកប្បិនទាំងបរិវារ

មានចំនួន ១,០០០ កុលបុត្រក្នុងក្រុងកបិលភស្តុមានចំនួន ១០,០០០ ពួកបារាយនិកព្រាហ្មណ៍ (ព្រាហ្មណ៍អ្នកស្វែងរកទីពឹងក្នុងភពខាងមុខ) មានចំនួន ១៦,០០០ (រួម ២៧,៣០០ រូប ។) តែភិក្ខុទាំងនោះ ព្រះអដ្ឋកថាចារ្យមិនបានពោលទុក ព្រោះព្រះឧបាលីថេរៈ មិនបានសម្តែងទុកក្នុងបាលីព្រះវិន័យបិដក ។ ភិក្ខុទាំងនេះ ព្រះអដ្ឋកថាចារ្យពោលទុក ក៏ព្រោះលោកព្រះឧបាលីថេរៈសម្តែងទុក ក្នុងបាលីព្រះវិន័យបិដកនោះហើយ ។ (ព្រះអដ្ឋកថាចារ្យពោលពាក្យទុកក្នុងអដ្ឋកថា) ថា ៖

ភិក្ខុទាំងអស់សូម្បីទាំងនេះ គឺ ២៧,០០០រូប និង ៣០០ រូប, ភិក្ខុទាំងអស់នោះលោកពោលថា ជាឯហិភិក្ខុ ។

## ឧបសម្បទា ៨ យ៉ាង

ប្រើនបទថា តីហិ សរណគមនេហិ ឧបសម្បន្នោ : ព្រោះបានឧបសម្បទាដោយសរណៈគមន៍ ៣ មានសេចក្តីថា អ្នកឧបសម្បទាដោយត្រៃសរណគមន៍ ដែលបញ្ចេញវាចាពោល ៣ ដង ដោយន័យជាដើមថា ពុទ្ធំ សរណំ គច្ឆាមិ : ខ្ញុំសូមដល់នូវព្រះពុទ្ធជាទីពឹងទីរលឹក ។ ពិតមែន ដែលឈ្មោះថា ឧបសម្បទា នេះ មាន ៨ យ៉ាង គឺ ឯហិភិក្ខុឧបសម្បទា១ សរណគមនឧបសម្បទា១ ឱវាទបដិគ្គហណឧបសម្បទា១ បញ្ហាព្យាករណឧបសម្បទា១ គរុធម្មបដិគ្គហណឧបសម្បទា

១ ទូតេនឧបសម្បទា១ អដ្ឋវាចិកាឧបសម្បទា១ ញត្តិចតុត្ថកម្មឧបសម្បទា១ ។

## អត្ថាធិប្បាយឧបសម្បទា ៨ យ៉ាង

ក្នុងឧបសម្បទាទាំង ៨ យ៉ាងនោះ ឯហិភិក្ខុឧបសម្បទា និងសរណគមនឧបសម្បទា ខ្ញុំព្រះករុណាបានពោលរួចហើយ ។

ដែលឈ្មោះថា ឱវាទបដិគ្គហណឧបសម្បទា បានដល់ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់ព្រះមហាកស្សបត្ថេរ ដោយការទទួលនូវឱវាទយ៉ាងនេះថា "ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ហិរិនិងឱត្តប្បៈដ៏ក្លៀវក្លា អាត្មាអញបានតម្កល់ទុកក្នុងភិក្ខុចាស់ទាំងឡាយ ក្នុងភិក្ខុថ្មីទាំងឡាយ ក្នុងភិក្ខុកណ្តាលទាំងឡាយ ម្នាលកស្សប អ្នកគួរសិក្សាយ៉ាងនេះឯង ។ ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងស្តាប់នូវធម៌ដែលប្រកបដោយកុសលណានីមួយ, ហើយធ្វើនូវធម៌ទាំងអស់នោះឱ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ផ្ចង់ចិត្តទាំងពួង ផ្ទៀងត្រចៀកចាំស្តាប់ធម៌ ម្នាលកស្សប អ្នកគួរសិក្សាយ៉ាងនេះចុះ ។ ម្នាលកស្សប ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា "កាយគតាសតិរបស់អាត្មា

អញ ប្រកបដោយសេចក្ដីសុខ មិនទាន់សាបសូន្យនៅឡើយ ម្នាលកស្សប អ្នកគប្បីសិក្សាយ៉ាងនេះឯង”[១] ។

ដែលឈ្មោះថា បញ្ហាព្យាករណឧបសម្បទា បានដល់ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់សោបាកសាមណេរ ។ បានឮថា ព្រះមានព្រះភាគ ត្រាស់សួរបញ្ហាជាប់ដោយអសុភ ១០ ចំពោះសោបាកសាមណេរ ដែលចង្រ្កមតាមព្រះអង្គនៅក្នុងបុព្វារាមថា “ម្នាលសោបាក: ធម៌ទាំងនេះ គឺ ឧទ្ធុមាតកសញ្ញាក្ដី រូបសញ្ញាក្ដី មានអត្ថផ្សេងគ្នា មានព្យញ្ជនៈផ្សេងគ្នា ឬមានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ” សោបាកសាមណេរនោះ ទូលដោះស្រាយបញ្ហាទាំងនោះបាន ។ ព្រះមានព្រះភាគ ទ្រង់ប្រទានសាធុការដល់លោក ហើយត្រាស់សួរថា លោកបានប៉ុន្មានវស្សាហើយ សោបាក: ? សាមណេរទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះករុណាបាន ៧ វស្សា ។

ព្រះមានព្រះភាគ មានព្រះហឫទ័យដែលសោបាកសាមណេរឱ្យត្រេកអរថា សោបាក:អ្នកដោះស្រាយបញ្ហាស្មើនឹងសព្វញ្ញុតញ្ញាណរបស់តថាគត ហើយទើបទ្រង់អនុញ្ញាតឱ្យឧបសម្បទា ។ នេះឈ្មោះថា បញ្ហាព្យាករណឧបសម្បទា ។

---

(១) សំយុ. និទា. ៣២. ១៩២/១៧០ ។

ដែលឈ្មោះថា គរុធម្មបដិគ្គហណឧបសម្បទា បានដល់ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់ព្រះនាងមហាបជាបតី ដោយការទទួលគរុធម៌ ៨ ។[(១)]

ដែលឈ្មោះថា ទូតេន ឧបសម្បទា បានដល់ ឧបសម្បទាដែលទ្រង់អនុញ្ញាតដល់នាងអឌ្ឍកាសីគណិកា ។[(២)]

ដែលឈ្មោះថា អដ្ឋវាចិកា ឧបសម្បទា បានដល់ ឧបសម្បទារបស់នាងភិក្ខុនីដោយកម្ម ២ ទាំងនេះ គឺ ញត្តិចតុត្ថកម្មផ្នែកភិក្ខុនីសង្ឃ ញត្តិចតុត្ថកម្មផ្នែកភិក្ខុសង្ឃ ។[(៣)]

ដែលឈ្មោះថា ញត្តិចតុត្ថកម្មឧបសម្បទា បានដល់ ឧបសម្បទារបស់ភិក្ខុទាំងឡាយក្នុងកាលសព្វថ្ងៃនេះ ។[(៤)]

មានពាក្យពោលអធិប្បាយថា អ្នកដែលឧបសម្បទាហើយ ក្នុងបណ្ដាឧបសម្បទា ៨ យ៉ាងទាំងនេះ ដោយឧបសម្បទានេះ ដែលទ្រង់អនុញ្ញាតហើយ យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជា និងឧបសម្បទាដោយត្រៃសរណគមន៍ទាំងឡាយនេះ"[(៥)] ។

---

១. វិន. ចុល្ល. ១១. ១៨០/២៦៦ ។ ២. វិន. ចុល្ល. ១១. ២៥៩/៣៣២ ។
៣. វិន. ចុល្ល. ១១. ២៣៨/៣១៣ ។ ៤. វិន. មហា. ៨. ៩៣/២១២ ។
៥. វិន. មហា. មហាខន្ធក. ៦. ៣៤/៧១ ។

បទថា ភទ្រោ : ព្រោះហេតុជាអ្នកចម្រើន បានដល់ មិនថោកទាប ។ ពិតមែន សេក្ខបុគ្គលទាំងឡាយមានកល្យាណបុថុជ្ជនជាដើម ដរាបដល់ជាព្រះអរហន្ត រមែងដល់ការរាប់ថា ភិក្ខុដែលចម្រើនព្រោះប្រកបដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណទស្សនៈដែលចម្រើន ។

បទថា សារោ : ព្រោះមានសារធម៌ មានសេចក្ដីថា សេក្ខកល្យាណបុថុជ្ជននោះ គប្បីជ្រាបថា ភិក្ខុអ្នកមានសារៈ ព្រោះប្រកបដោយសារៈទាំងឡាយ មានសីលសារៈជាដើមទាំងនោះឯងប្រៀបដូចសំពត់ពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ដូច្នោះ ។ ម្យ៉ាងទៀត ព្រះខីណាស្រពប៉ុណ្ណោះ គប្បីជ្រាបថា ជាអ្នកមាន សារៈ ព្រោះជាអ្នកប្រាសចាកស្រោយ គឺកិលេស ។

បទថា សេក្ខោ : ព្រោះជាអ្នកសិក្សា មានសេចក្ដីថា ព្រះអរិយបុគ្គល ៧ ពួក និងទាំងកល្យាណបុថុជ្ជន តែងសិក្សាសិក្ខាបទ ៣ ព្រោះហេតុនោះ ទើបចាត់ជាសេក្ខបុគ្គល ។ ក្នុងសេក្ខបុគ្គលទាំងនោះ អ្នកណាមួយគប្បីជ្រាបថា ជាភិក្ខុសេក្ខៈ ។ ដែលឈ្មោះថា អសេក្ខបុគ្គល ព្រោះមិនត្រូវសិក្សា ។ ព្រះខីណាស្រព លោកហៅថា អសេក្ខបុគ្គល ព្រោះកន្លងសេក្ខធម៌ចេញ តាំងនៅក្នុងផលកំពូលលើស មិនមាន

សិក្ខាដែលនឹងត្រូវសិក្សាឱ្យក្រៃលែងជាងនោះ ។

ពីរបទថា **សមគ្គេន សង្ឃេន : ដោយសង្ឃដែលព្រមព្រៀង ហើយ** មានសេចក្ដីថា ដោយសង្ឃ ឈ្មោះថា ចូលដល់ភាពជាអ្នកព្រមព្រៀងគ្នាក្នុងកម្មមួយយ៉ាង ព្រោះភិក្ខុដែលចូលកម្ម ក្នុងកម្មដែលនឹងគប្បីធ្វើដោយសង្ឃបញ្ចវគ្គ ដោយបរិយាយយ៉ាងទាបបំផុត បានមកគ្រប់ចំនួន ព្រោះបាននាំឆន្ទៈរបស់ពួកភិក្ខុដែលគួរដល់ឆន្ទៈមកហើយ និងព្រោះពួកភិក្ខុដែលនៅក្នុងទីចំពោះមុខគ្នាមិនជំទាស់ ។

បទថា **ញត្តិចតុត្ថេន : ដោយញត្តិចតុត្ថ** មានសេចក្ដីថា ដែលនឹងគប្បីធ្វើដោយអនុស្សាវនា ៣ ដង ញត្តិ ១ ដង ។

បទថា **កម្មេន : កម្មវាចា** គឺ វិន័យកម្មដែលប្រកបដោយធម៌ ។

បទថា **អកុប្បេន : ដែលមិនកម្រើក** សេចក្ដីថា ចូលដល់ភាពជាកម្មដែលអ្នកណា ៗ គប្បីឱ្យកម្រើកមិនបាន គឺ ដែលអ្នកណា ៗ គប្បីជំទាស់មិនបាន ព្រោះដល់ព្រមដោយវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុស្សាវនាសម្បត្តិ សីមាសម្បត្តិ និងបរិសសម្បត្តិ ។

បទថា **ឋានារហេន : សមគួរដល់ហេតុ** គឺ គួរដល់ហេតុ បានដល់ គួរដល់សត្ថុសាសនា ។

ឈ្មោះថា ឧបសម្បន្ន : បានឧបសម្បទា គឺ មកដល់ អធិប្បាយថា សម្រេចភាវៈដែលខ្ពស់បំផុត ។ ភាពជាភិក្ខុជាភាវៈដ៏ខ្ពស់ ។ ពិតមែន បុគ្គលនោះ លោកហៅថា ឧបសម្បន្ន ព្រោះមកដល់ភាពជាភិក្ខុនោះ ដោយកម្មតាមដែលពោលហើយ ។

ក៏ក្នុងអធិការនេះ មកពីញត្តិចតុត្ថកម្មតែម្យ៉ាងប៉ុណ្ណោះ ។ តែក្នុងទីនេះ គួរនាំសង្ឃកម្មទាំង ៤ មកពោលទុកដោយពិស្ដារ ។ ពាក្យនោះទាំងអស់លោកពោលហើយក្នុងអដ្ឋកថាទាំងឡាយ ។ សង្ឃកម្មទាំងនោះគឺ អបលោកនកម្ម ញត្តិកម្ម ញត្តិទុតិយកម្ម ញត្តិចតុត្ថកម្ម បណ្ឌិតគប្បីរៀងទុកតាមលំដាប់ ហើយនាំបាលីមកពោលដោយពិស្ដារ អំពីពីគម្ពីរខន្ធកៈ និងកម្មវិភង្គក្នុងទីបំផុតនៃគម្ពីរបរិវារ ។ ខ្ញុំព្រះករុណា នឹងពណ៌នាសង្ឃកម្មទាំងនោះក្នុងកម្មវិភង្គ ក្នុងទីបំផុតនៃគម្ពីរបរិវារនុ៎ះឯង ។ ព្រោះថាកាលមានការពណ៌នាយ៉ាងនោះ បឋមបារាជិកវណ្ណនា នឹងមិនជាការធ្ងន់ទៅ ។ និងការពណ៌នាព្រះបាលីតាមដែលតាំងទុក ក៏នឹងជាវណ្ណនាដែលដឹងគ្នាបានងាយ ។ ទាំងឋានៈពួកនោះ នឹងជារបស់មិនសាបសូន្យ ។ ព្រោះដូច្នោះ ខ្ញុំព្រះករុណានឹងធ្វើការពណ៌នាទៅតាមបទប៉ុណ្ណោះ ។

បទថា តត្រ : ទាំងនោះ មានសេចក្ដីថា បណ្ដាភិក្ខុទាំងឡាយដែលពោលដោយន័យមានពាក្យថា អ្នកសូម ជាដើមទាំងនោះ ។

ពីរបទថា យ្វាយំ ភិក្ខុ កាត់បទជា យោ អយំ ភិក្ខុ : ភិក្ខុណា នេះ ។

ពាក្យថា សមគ្គេន សង្ឃេន ។បេ ។ ឧបសម្បន្នោ : ដែលបានឧបសម្បទា ដោយញត្តិចតុត្ថកម្មវាចា ដ៏សមគួរដល់ហេតុដែលមិនមានវិបត្តិកម្រើក ដោយសង្ឃដែលព្រមព្រៀងហើយ មានសេចក្តីថា បណ្តាឧបសម្បទា ៨ អ្នកឧបសម្បទាហើយដោយញត្តិចតុត្ថកម្មប៉ុណ្ណោះ ។

ពាក្យថា អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខុ : ភិក្ខុនេះតថាគតសំដៅយកក្នុងអត្ថនេះ មានសេចក្តីថា ភិក្ខុនេះប្រាថ្នាយកថា ភិក្ខុ ក្នុងអត្ថថា សេពមេថុនធម្មហើយ រមែងជាអ្នកចាលចាញ់នេះ ។

ចំណែកភិក្ខុសព្ទក្រៅនេះមានថា ភិក្ខុកោ : ជាអ្នកសូម ជាដើម ត្រាស់ដោយអំណាចការពង្រីកសេចក្តី ។ និងក្នុងពាក្យថា ភិក្ខុកោ ជាដើមនោះ សព្ទមានជាដើមថា អ្នកសូម ត្រាស់ដោយអំណាចភាសា ។ ពីរបទនេះថា ជាភិក្ខុដោយសមញ្ញា, ជាភិក្ខុដោយសេចក្តីបដិញ្ញា, ត្រាស់ដោយអំណាចការហៅ ។

បទថា ឯហិភិក្ខុ ត្រាស់ដោយអំណាចវិធីឧបសម្បទាដែលកុលបុត្របានហើយ ដោយមានព្រះពុទ្ធជាឧបជ្ឈាយ៍ ។ សរណគមនភិក្ខុ

ត្រាស់ដោយអំណាចអ្នកឧបសម្បទាហើយក្នុងកាលកម្មវាចា មិនទាន់កើតឡើង ។ ស័ព្ទជាដើមថា **ដ៏ចម្រើន** គប្បីជ្រាបថា ត្រាស់ដោយអំណាចគុណ ។

[២៧] ព្រះមានព្រះភាគ មិនបានទ្រង់ចែកបទនេះថា **ភិក្ខូនំ** ទុកក្នុងកាលឥឡូវនេះឡើយ ព្រោះមិនមានសេចក្ដីដែលប្លែក កាលនឹងទ្រង់សម្ដែងសិក្ខានិងសាជីវៈ ព្រោះជាហេតុឱ្យភិក្ខុដល់ព្រមហើយ ទើបជាអ្នកឈ្មោះថា ដល់ព្រមដោយសិក្ខានិងសាជីវៈរបស់ភិក្ខុទាំងឡាយ ទើបត្រាស់ថា **សិក្ខា** ជាដើម ។ ក្នុងពាក្យថា **សិក្ខា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា សិក្ខា ព្រោះអត្ថថា ដែលកុលបុត្រគប្បីសិក្សា ។

បទថា តិស្សោ : ៣ ជាសង្ខ្យាកំណត់ការគណនា ។

បទថា អធិសីលសិក្ខា មានអត្ថវិគ្រោះថា សីលក្រៃលែង គឺខ្ពស់បំផុត ហេតុនោះទើបឈ្មោះថា អធិសីល ។ អធិសីលនោះ ជាសិក្ខា ព្រោះដែលកុលបុត្រគប្បីសិក្សា ព្រោះហេតុនោះ ទើបឈ្មោះថា អធិសីលសិក្ខា ។ ក្នុងអធិចិត្តសិក្ខា និងអធិបញ្ញាសិក្ខាក៏ន័យនោះ ។

## អត្ថាធិប្បាយអធិសីល អធិចិត្ត អធិបញ្ញា

សួរថា ក៏ក្នុងអធិការនេះ សីលដូចម្តេច ? អធិសីល ដូចម្តេច ? ចិត្ត ដូចម្តេច ? អធិចិត្ត ដូចម្តេច ? បញ្ញាដូចម្តេច ? អធិបញ្ញា ដូចម្តេច ?

ខ្ញុំព្រះករុណានឹងឆ្លើយតទៅ ៖

សីល មានអង្គ ៥ និងអង្គ ១០ ឈ្មោះថា សីលប៉ុណ្ណោះមុន ។ ពិតមែន សីលនោះ កាលព្រះពុទ្ធ ឧប្បត្តិឡើងហើយក៏ដោយ នៅមិនបានឧប្បត្តិឡើងក៏ដោយ ប្រព្រឹត្តទៅនៅក្នុងលោក ។ កាលព្រះពុទ្ធឧប្បត្តិឡើងហើយ ព្រះពុទ្ធទាំងឡាយក្តី ព្រះសាវកទាំងឡាយក្តី រមែងដឹកនាំមហាជនឱ្យសមាទានក្នុងសីលនោះ ។ កាលព្រះពុទ្ធ មិនទាន់បានឧប្បត្តិឡើង ព្រះបច្ចេកពុទ្ធ សមណព្រាហ្មណ៍ពួកកម្មវាទីប្រព្រឹត្តប្រកបដោយធម៌ ព្រះបាទចក្រពត្តិមហារាជ និងព្រះមហាពោធិសត្វ រមែងដឹកនាំមហាជនឱ្យសមាទាន (ក្នុងសីលនោះ) ។ ពួកសមណព្រាហ្មណ៍អ្នកជាបណ្ឌិតក៏សមាទាន (សីលនោះ) សូម្បីដោយខ្លួនឯង ។ សមណព្រាហ្មណ៍ជាដើមទាំងនោះ កាលបំពេញកុសលធម៌នោះឱ្យបរិបូណ៌ហើយ រមែងសោយសម្បត្តិក្នុងពួកទេវនិងក្នុងពួកមនុស្ស ។

ចំណែកបាតិមោក្ខសំវរសីល លោកហៅថា អធិសីល ។ ពិតមែន

បាតិមោក្ខសំវរសីលនោះ ជាសីលដ៏ក្រៃលែង និងខ្ពស់បំផុតជាងបណ្តា លោកិយសីលទាំងអស់ ដូចព្រះអាទិត្យក្រៃលែងជាងពន្លឺទាំងឡាយ ដូចភ្នំសិណេរុខ្ពស់ជាងភ្នំទាំងឡាយដូច្នោះ រមែងប្រព្រឹត្តទៅបានចំពោះក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅពុទ្ធុប្បាទកាលមិនប្រព្រឹត្តទៅទេ ។ ដោយថា សត្វដទៃមិនអាចលើកបញ្ញត្តិនោះឡើងតាំងទុកបាន ។ ក៏ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ ទ្រង់កាត់ក្រសែមកនៃការប្រព្រឹត្តវិនាសអស់ពីមកកាយទ្វារនិងវចីទ្វារបានដាច់ខាត ដោយប្រការទាំងពួងហើយ ទើបទ្រង់បញ្ញត្តិសីលសំវរៈនោះទុក ដែលសមគួរដល់ការប្រព្រឹត្តកន្លងនោះ ៗ ។

មួយទៀត សីលដែលសម្បយុត្តដោយមគ្គនិងផលប៉ុណ្ណោះ ឈ្មោះថា សីលដ៏ក្រៃលែងជាងបាតិមោក្ខសំវរ ។ តែសីលដែលសម្បយុត្តដោយមគ្គនិងផលនោះ លោកមិនបានប្រាថ្នាយកក្នុងអធិការនេះ ។ ព្រោះថា ភិក្ខុដែលដល់ព្រមដោយសីលនោះ មិនសេពមេថុនធម្មទេ ។ កាមាវចរកុសលចិត្ត ៨ និងសមាបត្តិចិត្ត ៨ ចំណែកលោកិយរួមចូលតែមួយគប្បីជ្រាបថា ចិត្តប៉ុណ្ណោះ ។ និងក្នុងកាលដែលព្រះពុទ្ធឧប្បត្តិឡើង ឬមិនឧប្បត្តិឡើងចិត្តនោះក៏ប្រព្រឹត្តទៅ ការដឹកនាំនិងការសមាទាន ក៏គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងសីលនុ៎ះឯង ។

ចំណែកសមាបត្តិចិត្ត ៨ ដែលជាបាទនៃវិបស្សនា លោកហៅថា

អធិចិត្ត ។ ពិតមែន អដ្ឋសមាបត្តិចិត្តនោះ ជាចិត្តដ៏ក្រៃលែងនិងខ្ពស់បំផុតជាងលោកិយចិត្តទាំងអស់ ដូចអធិសីលក្រៃលែងជាងបណ្ដាសីលទាំងឡាយ ដូច្នោះ និងមាននៅចំពោះក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ក្រៅពុទ្ធុប្បាទកាល មិនមានទេ ។ម៉្យាងទៀត ចិត្តដែលសម្បយុត្តដោយមគ្គនិងផលនោះ លោកមិនបានប្រាថ្នាយកក្នុងអធិការនេះ ។ ព្រោះថា ភិក្ខុដែលដល់ព្រមដោយចិត្តនោះមិនសេពមេថុនធម្មទេ ។

មួយទៀត កម្មស្សកតាញាណ (ញាណដឹងថា សត្វមានកម្មជារបស់ខ្លួន) ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា ទានដែលឱ្យហើយមានផល ការបូជាធំមានផល ឈ្មោះថា បញ្ញា ។ ពិតមែន កាលព្រះពុទ្ធឧប្បត្តិឡើងហើយក៏ដោយ មិនបានឧប្បត្តិឡើងក៏ដោយ បញ្ញានោះ ប្រព្រឹត្តទៅនៅក្នុងលោក ។ កាលព្រះពុទ្ធឧប្បត្តិឡើងហើយ ព្រះពុទ្ធទាំងឡាយក្ដី ព្រះសាវកទាំងឡាយក្ដី រមែងដឹកនាំមហាជនឱ្យសមាទានក្នុងបញ្ញានោះ ។ កាលព្រះពុទ្ធមិនទាន់បានឧប្បត្តិឡើង ព្រះបច្ចេកពុទ្ធសមណព្រាហ្មណ៍ ពួកកម្មវាទីប្រព្រឹត្តប្រកបដោយធម៌ ព្រះបាទចក្រពត្តិមហារាជ និងព្រះមហាពោធិសត្វ រមែងដឹកនាំមហាជនឱ្យសមាទាន (ក្នុងបញ្ញានោះ) ។ សត្វទាំងឡាយ អ្នកជាបណ្ឌិតក៏សមាទាន សូម្បីដោយខ្លួនឯង ។ ពិតមែន អង្កុរទេវបុត្រ (កាលជាមនុស្ស) បានថ្វាយ

មហាទានអស់មួយម៉ឺនឆ្នាំ ។ វេលាមព្រាហ្មណ៍ ព្រះវេស្សន្តរ និងពួកមនុស្សជាបណ្ឌិតដទៃជាច្រើន ក៏បានថ្វាយមហាទានហើយ ។ វេលាមព្រាហ្មណ៍ជាដើមទាំងនោះ កាលបំពេញកុសលធម៌នោះឱ្យបរិបូណ៌ហើយ ក៏បានសោយសម្បត្តិក្នុងពួកទេវតា និងក្នុងពួកមនុស្ស ។

ចំណែកវិបស្សនាញាណ ដែលជាគ្រឿងកំណត់អាការ គឺត្រៃលក្ខណ៍ លោកហៅថា អធិបញ្ញា ។ ពិតមែន អធិបញ្ញានោះ ជាបញ្ញាដ៏ក្រៃលែង និងខ្ពស់បំផុតជាងបណ្ដាលោកិយបញ្ញាទាំងអស់ ដូចអធិសីលនិងអធិចិត្ត ក្រៃលែងនិងខ្ពស់បំផុតជាងបណ្ដាសីលនិងចិត្តទាំងឡាយ ដូច្នោះ ក្រៅពុទ្ធុប្បាទកាលមិនប្រព្រឹត្តទៅក្នុងលោកទេ ។ ក៏បញ្ញាដែលសម្បយុត្តដោយមគ្គនិងផលទុំះឯង ជាបញ្ញាដ៏ក្រៃលែងសូម្បីជាងវិបស្សនាញាណនោះ ។ តែបញ្ញាដែលសម្បយុត្តដោយមគ្គនិងផលនោះ លោកមិនបានប្រាថ្នាយកក្នុងអធិការនេះ ។ ព្រោះថា ភិក្ខុដែលដល់ព្រមដោយបញ្ញានោះ មិនសេពមេថុនធម្មទេ ដូច្នេះឯង ។

បទថា តត្រ គឺ បណ្ដាសិក្ខាទាំង ៣ ទាំងនោះ ។

ច្រើនបទថា យា អយំ អធិសីលសិក្ខា : សិក្ខាណាដែលហៅថា អធិសីលសិក្ខា បានដល់ អធិសីលសិក្ខានេះ ពោលគឺបាតិមោក្ខសីល ។

## អត្ថាធិប្បាយបទថា សិក្ខានិងសាជីវ

[២៨] ពីរបទថា ឯតំ សាជីវន្នាម : សិក្ខាបទដែលព្រះមានព្រះភាគបានបញ្ញត្តិហើយនុ៎ះ មានសេចក្ដីថា សិក្ខាបទនោះ សូម្បីទាំងពួងដែលព្រះមានព្រះភាគ ទ្រង់តាំងទុកក្នុងព្រះវិន័យ នេះហៅថា សាជីវ ព្រោះហេតុថា ជាការរស់នៅរួមគ្នា គឺ រស់នៅតែម្យ៉ាងដូចគ្នា រស់នៅត្រូវចំណែកគ្នា ប្រព្រឹត្តត្រូវចំណែកគ្នា នៃភិក្ខុទាំងឡាយ អ្នកផ្សេងគ្នាដោយប្រភេទ មានប្រទេសជាតិនិងគោត្រផ្សេង ៗ គ្នាជាដើម ។

ពីរបទថា តស្មឹ សិក្ខតិ : ភិក្ខុដែលសិក្សាក្នុងសិក្ខាបទ មានសេចក្ដីថា ភិក្ខុធ្វើសិក្ខាបទនោះ ឱ្យជាទីពុំនាក់នៃចិត្តហើយ កំណត់ពិចារណាដោយចិត្តថា យើងសិក្សាសមគួរដល់សិក្ខាបទឬមិនសិក្សាហ្ន៎ ? ក៏ភិក្ខុនេះ ឈ្មោះថា សិក្សានៅក្នុងសិក្ខាបទ ពោលគឺ សាជីវនោះតែម្យ៉ាងប៉ុណ្ណោះ ក៏ទេ សូម្បីក្នុងសិក្ខា ក៏ឈ្មោះថា សិក្សាផង ។

ចំណែកពីរបទថា តស្មឹ សិក្ខតិ ព្រះមានព្រះភាគត្រាស់ដោយអំណាចបទដែលរៀងជាលំដាប់គ្នាថា ឯតំ សាជីវន្នាម : ហៅថា សាជីវៈនោះ នេះ ។ បទថា តស្មឹ សិក្ខតិ នោះ ព្រះអង្គត្រាស់យ៉ាងនោះ ក៏ពិតមែនហើយ, តែសេចក្ដីក្នុងបទថា តស្មឹ សិក្ខតិ នេះ គប្បីឃើញថា កាលញ៉ាំងសិក្ខាឱ្យបរិបូណ៌, ឈ្មោះថា សិក្សានៅក្នុង

សិក្ខានោះ និងកាលមិនប្រព្រឹត្តកនូវ ឈ្មោះថា សិក្សានៅក្នុងសិក្ខាបទនោះ យ៉ាងនេះ, សូម្បីបទថា តេន វុច្ចតិ សាជីវសមាបន្នោ : តថាគតហៅអ្នកដល់ព្រមដោយសាជីវ: ដោយហេតុនោះឯង នេះ ក៏ត្រាស់ដោយអំណាចនៃបទថា សាជីវ ដែលជាលំដាប់ដូចគ្នាដែរ ។ ភិក្ខុនោះសូម្បីដល់ព្រមនូវសិក្ខា ព្រោះហេតុណា, ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបដោយសេចក្តីប្រាថ្នាថា ដល់ព្រមដោយសិក្ខាខ្លះ ។ ដោយថាកាលមានសេចក្តីប្រាថ្នាយ៉ាងនោះ បទភាជនៈនៃបទថា សិក្ខាសាជីវសមាបន្នោ នេះ ជាការពេញបរិបូណ៌ ។

## អត្ថាធិប្បាយវិធីលាសិក្ខា

[២៩] ច្រើនបទថា សិក្ខំ អបច្ចក្ខាយ ទុព្វល្យំ អនាវិកត្វា : មិនពោលលាសិក្ខា មិនធ្វើឱ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយមានសេចក្តីថា មិនពោលាសិក្ខាផង មិនប្រកាសភាពជាអ្នកទុព្វលផង ។ សូម្បីកាលធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលហើយ សិក្ខាមិនទាន់ឈ្មោះថាពោលលាឡើយ, តែកាលពោលលាសិក្ខាហើយ ភាពជាអ្នកទុព្វលរមែងជាការដែលធ្វើឱ្យច្បាស់ផង, ព្រោះហេតុនោះ ដោយបទថា ទុព្វល្យំ អនាវិកត្វា នេះ ទើបមិនបានសេចក្តីពិសេសអ្វី ៗ ។ ក៏ឧទាហរណ៍ថា

ដោយពាក្យថា ពីរយប់ ដែលព្រះមានព្រះភាគត្រាស់ទុកថា គប្បីសម្រេចការដេករួម ពីរបីយប់ ដូច្នេះ បណ្ឌិតក៏មិនបានសេចក្ដីពិសេសអ្វី ៗ ។ ពាក្យថា ពីរយប់នេះ ព្រះអង្គត្រាស់ដោយភាពជាពាក្យពីរោះរណ្ដំដោយព្យញ្ជនៈ ដោយភាពជាពាក្យជាប់ព្រះឱស្ឋ ដោយអំណាចលោកវោហារតែម្យ៉ាង សេចក្ដីនេះយ៉ាងណា, សូម្បីពាក្យថា មិនបានធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល នេះ ក៏យ៉ាងនោះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដោយភាពជាពាក្យស្រួលពោល ដោយភាពជាពាក្យពីរោះរណ្ដំ ដោយព្យញ្ជនៈ ដោយភាពជាពាក្យជាប់ព្រះឱស្ឋ ។

មួយទៀត ព្រះមានព្រះភាគ រមែងទ្រង់សម្ដែងធម៌ព្រមទាំងអត្ថទាំងព្យញ្ជនៈ, ព្រោះដូច្នោះ ទើបទ្រង់ញ៉ាំងអត្ថឱ្យដល់ព្រមដោយបទថា មិនពោលលាសិក្ខានេះ ញ៉ាំងព្យញ្ជនៈឱ្យដល់ព្រមដោយបទ មិនធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលនេះ ។ ពិតមែន បទនៃសេចក្ដីដែលពោលចំពោះបទតែមួយ ប្រាសចាកបទនៅជុំវិញចេញហើយ រមែងមិនពីរោះ ប្រៀបដូចព្រះរាជាអ្នកប្រាសចាកបរិវារ និងបុរសអ្នកប្រាសចាកសំពត់និងអលង្ការ រមែងមិនស្រស់ល្អ ដូច្នោះ ។ តែបទសេចក្ដីនោះ រមែងពីរោះព្រមដោយបទជិត ដែលជាបទហែហម ល្មមសមគួរដល់សេចក្ដី ។

មួយទៀត ការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលយ៉ាងណាមួយ រមែង

ជាសេចក្តីនៃការពោលលាសិក្ខា; ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់សំដៅយកការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលយ៉ាងណាមួយ ដែលជាសេចក្តីបាននោះ កាលនឹងទ្រង់ខែសេចក្តីនៃបទថា មិនពោលលាសិក្ខា ទើបត្រាស់ថា មិនបានធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល ។

ក្នុងពាក្យថា មិនពោលលាសិក្ខា មិនបានធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល នោះបើនឹងគប្បីមានពាក្យសួរថា ការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលទាំងអស់ មិនទាន់ជាការពោលលាសិក្ខា ; ព្រោះហេតុនោះ ព្រះមានព្រះភាគគួរត្រាស់បទថា "មិនបានធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល" ដូច្នេះជាមុន ហើយទើបត្រាស់បទថា "មិនពោលលាសិក្ខា" ដើម្បីកំណត់សេចក្តីនៃបទថា មិនធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល នោះ ។

ឆ្លើយថា ក៏ពាក្យនោះ មិនគួរពោលទេ ព្រោះហេតុអ្វី ? ព្រោះមិនមានលំដាប់នៃសេចក្តី ។ ពិតមែន ព្រោះព្រះមានព្រះភាគបានត្រាស់ទុកថា **សិក្ខាសាជីវសមាបន្នោ** ដូច្នេះ សេចក្តីរមែងជាការដែលព្រះអង្គត្រាស់ហើយតាមលំដាប់ ក្នុងកាលត្រាស់ថា ខនដល់ព្រមនូវសិក្ខាណា, មិនពោលលាសិក្ខានោះ មិនមែនដោយប្រការដទៃទេ ព្រោះហាតុនោះ ពាក្យថា **សិក្ខំ អប្បច្ចក្ខាយ** នេះឯង ព្រះមានព្រះភាគទើបត្រាស់មុន ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងពាក្យថា មិនពោលលាសិក្ខា,

មិនធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល នេះ តាមសមគួរដល់លំដាប់ខ្លះ ។

គប្បីជ្រាបយ៉ាងណា ?

គប្បីជ្រាបយ៉ាងនេះ ក្នុងបទថា ដល់ព្រមដោយសិក្ខានិងសាជីវៈ នេះ ភិក្ខុដល់ព្រមនូវសិក្ខាណា, មិនពោលលាសិក្ខានោះ និងដល់ព្រមនូវសាជីវណា, មិនធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលក្នុងសាជីវនោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសេចក្តីប្លែកគ្នា និងសេចក្តីមិនប្លែកគ្នានៃការពោលលាសិក្ខា និងការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល និងលក្ខណៈនៃការពោលលាសិក្ខា ទើបត្រាស់ពាក្យជាដើមថា **អត្ថិ ភិក្ខវេ :** ម្នាលភិក្ខុទាំងឡាយ (កិរិយាដែលភិក្ខុបានធ្វើឱ្យជាក់ច្បាស់នូវភាវៈជាអ្នកមានកម្លាំងថយហើយ សិក្ខា ហៅថា ភិក្ខុបានពោលលាហើយ )ក៏មាន ។ ក្នុងពាក្យនោះ ២ បទថា **អត្ថិ ភិក្ខវេ** ជាដើមជាបទមាតិកា ។

[៣០] ព្រះមានព្រះភាគកាលនឹងទ្រង់ចែកបទមាតិកា ២ នោះ ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ នោះតើដូចម្តេច** ជាដើម ។ ក្នុងពាក្យថា **កថញ្ច** ជាដើមនោះ មានការពណ៌នាបទដែលនៅមិនច្បាស់លាស់ដូចតទៅនេះ ៖

បទថា **កថំ : តើដូចម្តេច** បានដល់ ដោយអាការណា ?

បទថា ទុព្វល្យាវិកម្មញ្ច : កិរិយាដែលភិក្ខុបានធ្វើឱ្យជាក់ច្បាស់នូវភាវៈ ជាអ្នកមានកម្លាំងថយហើយ បានដល់ ការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលផង ។

បទថា ឥធ : ក្នុងនេះ គឺ ក្នុងសាសនានេះ ។

បទថា ឧក្កណ្ឋិតោ : អផ្សុក សេចក្ដីថា អ្នកដល់ភាពជាអ្នកនៅលំបាកក្នុងសាសនានេះ ព្រោះសេចក្ដីនឿយណាយ ។ មួយទៀតមានពាក្យអធិប្បាយថា អ្នកមានចិត្តវេវវាយមិនមានអារម្មណ៍តម្កល់មាំអើតកឡើង ដោយគិតថា "យើងនឹងទៅថ្ងៃនេះ, យើងនឹងទៅថ្ងៃស្អែកនេះ, យើងនឹងទៅអំពីទីនេះ, យើងនឹងទៅក្នុងទីនេះ" ។

បទថា អនភិរតោ : មិនរីករាយ បានដល់ អ្នកប្រាសចាកសេចក្ដីត្រេកអរក្នុងសាសនា ។

ពីរបទថា សាមញ្ញា ចវិតុកាមោ : ចង់ចេញចាកសមណភាព បានដល់ អ្នកប្រាថ្នានឹងចៀសចេញពីភាពជាសមណៈទៅ ។

បទថា ភិក្ខុភាវំ : នឹងភាពខ្ទង់ជាភិក្ខុ គឺ ដោយភាពជាភិក្ខុ ។ បទថា ភិក្ខុភាវំ នេះ ជាទុតិយាវិភត្តិ ប្រព្រឹត្តទៅក្នុងអត្ថនៃតតិយាវិភត្តិ ។ ចំណែកលក្ខណៈដែលសមគួរព្រះមានព្រះភាគត្រាស់ ដោយតតិយាវិភត្តិតែម្ដង ក្នុងពាក្យថា គប្បីខ្ពើមរអើមដោយសាកសព ដែលប្រដាប់ទុក

ត្រង់-ក ដូច្នេះជាដើម ។

បទថា **អដ្ដិយមានោ :** នឿយណាយ មានសេចក្ដីថា ប្រព្រឹត្ត ខ្ពួន ដូចជាខ្លាចរអា គឺត្រូវបៀតបៀន ដល់សេចក្ដីលំបាក ។ មួយទៀត អធិប្បាយថា ជាអ្នកដែលភាវៈជាភិក្ខុនោះរុកកួន បៀតបៀន ។

បទថា **ហរាយមានោ :** ធុញទ្រាន់ បានដល់ កាលខ្មាស ។

បទថា **ជិគុច្ឆមានោ :** ខ្ពើមរអើម បានដល់ អ្នកស្អប់ខ្ពើមភាព ជាភិក្ខុនោះ ដូចស្អប់របស់ស្មោគគ្រោក ដូច្នោះ ។

បទថា **គិហិភាវំ បដ្ឋយមានោ :** ប្រាថ្នាភាពជាគ្រហស្ថ ជា ដើម មានសេចក្ដីច្បាស់ហើយ ។

ស័ព្ទថា **យន្នូន :** បើដូច្នោះ ក្នុងពាក្យថា យន្នូនាហំ ពុទ្ធំ បច្ចក្ខេយ្យំ **:** បើដូច្នោះ មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ នេះជានិបាត សម្ដែងសេចក្ដីរំពឹង ។ មានពាក្យអធិប្បាយដូច្នេះថា បើយើងគប្បីលះ បង់ព្រះពុទ្ធចេញ, ការលះបង់ព្រះពុទ្ធនេះ គប្បីជាការល្អរបស់យើងហ្ន៎ ។

ពីរបទថា **វទតិ វិញ្ញាបេតិ :** និយាយឱ្យគេដឹង មានសេចក្ដីថា ភិក្ខុអផ្សុកនោះ បញ្ចេញវាចាពោលសេចក្ដីនេះ ដោយព្យញ្ជនៈទាំងនេះ ឬពួកដទៃ ទិងញ៉ាំងបុគ្គលដែលខ្លួនប្រាប់ឱ្យដឹងច្បាស់ គឺ ឱ្យយល់ ។

បិ អក្សរក្នុងបទថា **ឯវម្បិ :** យ៉ាងនេះឯង នេះ មានការប្រមូល

សេចក្តីខាងលើមកជាអត្ថ ។ ការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល និងសិក្ខាមិនជាការពោលលា រមែងមានសូម្បីដោយប្រការយ៉ាងនេះ, ការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល និងសិក្ខាមិនជាការពោលលា សូម្បីដោយប្រការដទៃ ក៏នៅមានទៀត ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល និងការមិនពោលលាសិក្ខា សូម្បីដោយប្រការយ៉ាងដទៃនោះ ទើបត្រាស់ពាក្យថា **អថ វា បន :** មួយវិញទៀត ជាដើម ។ ពាក្យនោះទាំងអស់ ដោយសេចក្តីច្បាស់លាស់តែម្តង ។ តែគប្បីជ្រាបវិនិច្ឆ័យដោយបទដូច្នេះ ៖

តាំងពីដើមទៅ ១៤ បទទាំងនេះ គឺ :

| | | |
|---|---|---|
| ពុទ្ធំ | បច្ចក្ខាមិ | ខ្ញុំគប្បីលះបង់ព្រះពុទ្ធ |
| ធម្មំ | ” | ” ព្រះធម៌ |
| សង្ឃំ | ” | ” ព្រះសង្ឃ |
| សិក្ខំ | ” | ” សិក្ខា |
| វិនយំ | ” | ” វិន័យ |
| បាដិមោក្ខំ | ” | ” បាដិមោក្ខ |
| ឧទ្ទេសំ | ” | ” ឧទ្ទេស |

ឧបជ្ឈាយ៍ បច្ចក្ខេយ្យំ ខ្ញុំគប្បីលះបង់ឧបជ្ឈាយ៍
អាចរិយំ ” ” អាចារ្យ
សទ្ធិវិហារិកំ ” ” ភិក្ខុសទ្ធិវិហារិក
អន្តេវាសិកំ ” ” ភិក្ខុអន្តេវាសិក
សមានុបជ្ឈាយកំ ” ” ភិក្ខុអ្នករួមឧបជ្ឈាយ៍
សមានាចរិយកំ ” ” ភិក្ខុអ្នករួមអាចារ្យ
សព្រហ្មចារឹ ” ” ភិក្ខុសព្រហ្មចារី

ព្រះមានព្រះភាគត្រាស់ក្នុងវារៈពោលអំពីធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលនេះ ដោយអាការគឺ ការពោលលា ៨ បទទាំងនេះ គឺ ៖

គិហី អស្សំ ខ្ញុំគប្បីជាគ្រហស្ថ
ឧបាសកោ ” ខ្ញុំគប្បីជាឧបាសក
អារាមិកោ ” ខ្ញុំគប្បីជាអារាមិកៈ
សាមណេរោ ” ខ្ញុំគប្បីជាសាមណេរ
តិត្ថិយោ ” ខ្ញុំគប្បីជាតិរ្ថិយ
តិត្ថិយសាវកោ ” ខ្ញុំគប្បីជាសាវកតិរ្ថិយ
អស្សមណោ ” ខ្ញុំគប្បីជាអ្នកមិនមែនសមណៈ
អសក្យបុត្តិយោ ” ខ្ញុំគប្បីជាអ្នកមិនមែនសក្យបុត្រ

ព្រះមានព្រះភាគត្រាស់ដោយអាការគឺ កំណត់ភាវៈដោយបទថា អស្សំ នេះ នៃបណ្ដាបទទាំងឡាយមានបទថា គិហី អស្សំ : ខ្ញុំគប្បីជាគ្រហស្ថជាដើម ។

២២ បទដែលប្រកបដោយបទថា "យន្នូនាហំ : បើដូច្នោះ មានតែខ្ញុំ"នេះ ព្រះអង្គត្រាស់ហើយ ដូចពណ៌នាមកដូច្នេះ ។ ដូចជាថា ២២ បទ ដែលប្រកបដោយបទថា យន្នូនាហំនេះ ព្រះអង្គត្រាស់ហើយយ៉ាងណា ២២ បទ ដែលប្រកបដោយបទមួយ ៗ ក្នុងបណ្ដាបទទាំងនេះគឺ ៖

**យទិ បនាហំ ពុទ្ធំ បច្ចក្ខេយ្យំ** — បើមែន មានតែខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។ល ។[១]

**អថាហំ ពុទ្ធំ បច្ចក្ខេយ្យំ** — កាលបើហេតុយ៉ាងនេះ មានពិតមែន ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។ល ។

១. ដែលបោយ្យាលទុកទាំង ៤ កន្លែងនោះ ឱ្យថែមដូចក្នុងបាលីវិន័យបិដក បារាជិក. ១. ៤៤/៤៥ ដូច្នេះ គឺ យទិ បនាហំ ពុទ្ធំ បច្ចក្ខេយ្យំ, យទិ បនាហំ ធម្មំ បច្ចក្ខេយ្យំ ដរាបដល់ យទិ បនាហំ អសក្យបុត្តិយោ អស្សំ (២២ បទ) អថាហំ ពុទ្ធំ បច្ចក្ខេយ្យំ, អថាហំ ធម្មំ បច្ចក្ខេយ្យំ ដរាបដល់ អថាហំ អសក្យបុត្តិយោ អស្សំ (២២ បទ) ហន្ទាហំ ពុទ្ធំ ចក្ខេយ្យំ, ហន្ទាហំ ធម្មំ បច្ចក្ខេយ្យំ ដរាបដល់ ហន្ទាហំ អសក្យបុត្តិយោ អស្សំ (២២ បទ) ហោតិ មេ ពុទ្ធំ បច្ចក្ខេយ្យំ, ហោតិ មេ ធម្មំ បច្ចក្ខេយ្យំ ដរាបដល់ ហោតិ មេ អសក្យបុត្តិយោ អស្សំ (២២ បទ) ។

**ហន្ទាហំ ពុទ្ធំ បច្ចក្ខេយ្យំ** ណ្ហើយចុះ ខ្ញុំត្រូវតែលះបង់ព្រះពុទ្ធ ។ល ។

**ហោតុ មេ**[១] **ពុទ្ធំ បច្ចក្ខេយ្យំ** ហេតុរបស់ខ្ញុំ លើកទុកសិនចុះ ខ្ញុំត្រូវលះបង់ព្រះពុទ្ធ ។ល ។

ព្រះអង្គក៏ត្រាស់ហើយយ៉ាងនោះ, រួមទាំងអស់ ទើបជា ១១០ បទ ដោយប្រការដូច្នេះ ។

បន្ទាប់អំពីពីរបទថា **ហោតុ មេ** ជាដើមនោះទៅ មាន ១៧ បទ មានជាដើមថា **មាតរំ សរាមិ** ខ្ញុំរកមាតា, ដែលប្រព្រឹត្តទៅដោយន័យសម្តែងវត្ថុដែលខ្ទនគួររលឹកដល់ ។

បណ្តាបទទាំងនោះ បទថា **ខេត្តំ** បានដល់ ចំការស្រូវសាលីជាដើម ។

បទថា **វត្ថុ** បានដល់ ស្ថានទីកើតឡើងនៃស្មៅ ស្លឹកឈើ បន្លែ និងផ្លែឈើតូចធំ ។

បទថា **សិប្បំ** បានដល់ សិល្បៈរបស់ជាងផ្នាំងនិងជាងតម្បាញជាដើម ។

តពី ១៧ បទនោះទៅ មាន ៩ បទ មានជាដើមថា "មាតា មេ

---

១. ថៃ. ភូមា. **ហោតិ មេ** : ខ្ញុំមានសេចក្តីត្រិះរិះ ។

អត្ថិ, សា មយា បោសេតព្វា : មាតារបស់ខ្ញុំមាន, មាតានោះ ខ្ញុំត្រូវតែចិញ្ចឹម" ដែលប្រព្រឹត្តទៅដោយអំណាចសម្ដែងភាពជាអ្នកមានកង្វល់ និងមានការជាប់ជំពាក់ ។

តពី ៩ បទនោះទៅ មាន ១៦ បទ មានជាដើមថា "មាតា មេ អត្ថិ, សា មំ បោសេស្សតិ : មាតារបស់ខ្ញុំមាន, មាតានោះ នឹងចិញ្ចឹមខ្ញុំ" ដែលប្រព្រឹត្តទៅដោយអំណាចសម្ដែងដល់បុគ្គលអ្នកជាទីអាស្រ័យ និងអ្នកជាទីពុំនាក់ ។

តពី ១៦ បទនោះទៅ មាន ៨ បទ មានជាដើមថា ទុក្ករំ ព្រហ្មចរិយជាភាវៈ ដែលធ្វើបានលំបាក ដែលប្រព្រឹត្តទៅដោយការសម្ដែងដល់សេចក្ដីដែលព្រហ្មចរិយ មានការឆាន់អាហារតែមួយពេល និងដេកតែមួយជងជាភាវៈដែលធ្វើបានលំបាក ។

បណ្ដាបទទាំងនោះ ដោយបទថា ទុក្ករំ : (អំពើនេះ) កម្របុគ្គលនឹងធ្វើបាន មានសេចក្ដីថា ភិក្ខុអផ្សុកនោះ រមែងសម្ដែងសេចក្ដីដែលព្រហ្មចរិយធ្វើបានលំបាក ព្រោះធ្វើកិច្ចវត្តទាំងឡាយ មានការឆាន់អាហារតែមួយពេលជាដើម ។

ដោយបទថា ន សុករំ : (អំពើនេះ) បុគ្គលមិនមែនងាយនឹងធ្វើបានទេ មានសេចក្ដីថា រមែងជំទាស់សេចក្ដីដែលព្រហ្មចរិយជាភាវៈ

ដែលធ្វើបានងាយ ។ ក្នុងពីរពាក្យថា ទុច្ចរំ (អំពើនេះ)បុគ្គលប្រព្រឹត្តបានដោយកម្រ, ន សុចរំ (អំពើនេះ)បុគ្គលមិនមែនប្រព្រឹត្តបានដោយងាយទេ, នេះ គប្បីជ្រាបន័យយ៉ាងនោះ ។

ដោយបទថា ន ឧស្សហាមិ : ខ្ញុំមិនអាច(នៅក្នុងភេទបព្វជិតបាន)ទេ រមែងសម្តែងការដែលខ្លួនមិនមានសេចក្តីឧស្សាហ៍គឺ ភាពដែលខ្លួនមិនអាច ក្នុងការធ្វើកិច្ចវត្តមានការឆាន់តែមួយជងជាដើមនោះ ។

ដោយបទថា ន វិសហាមិ : ខ្ញុំមិនហ៊ាន(នៅក្នុងភេទបព្វជិតបាន)ទេ រមែងសម្តែងដល់ភាពដែលខ្លួនមិនមានសេចក្តីអត់ធន់ (ក្នុងការធ្វើកិច្ចវត្តមានការឆាន់តែមួយជងជាដើមនោះ) ។

ដោយបទថា ន រមាមិ : ខ្ញុំមិនត្រេកអរ(នឹងភេទបព្វជិត)ទេ រមែងសម្តែងការមិនមាននៃសេចក្តីត្រេកអរ ។

ដោយបទថា នាភិរមាមិ : ខ្ញុំមិនពេញចិត្ត(នឹងភេទបព្វជិត)ទេ រមែងសម្តែងការមិនមាននៃសេចក្តីត្រេកអរក្រៃលែង ។

[៣១] ក៏ ៥០ បទទាំងនេះ និង ១១០ បទខាងដើម ទើបរួមជា ១៦០ បទ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ ក្នុងវារៈពោលអំពីការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលដោយន័យដូចពោលមកហើយនោះ ។

ពាក្យថា កថញ្ច ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ នោះ តើដូចម្តេច

ច ជាដើមទាំងអស់ សូម្បីក្នុងវារៈពោលអំពីការពោលលាសិក្ខា ដោយសេចក្តីច្បាស់លាស់ហើយតែម្តង តែគួរជ្រាបវិនិច្ឆ័យដោយបទដូច្នេះ ៖

១៤ បទ ដែលប្រព្រឹត្តទៅជាមួយនឹងសេចក្តីសម្ព័ន្ធពាក្យពោលលាសិក្ខាទាំងនេះ គឺ ៖

| | | |
|---|---|---|
| ពុទ្ធំ | បច្ចក្ខាមិ | ខ្ញុំលះបង់ព្រះពុទ្ធ |
| ធម្មំ | ” | ខ្ញុំលះបង់ព្រះធម៌ |
| សង្ឃំ | បច្ចក្ខាមិ | ខ្ញុំលះបង់ព្រះសង្ឃ |
| សិក្ខំ | ” | ខ្ញុំលះបង់សិក្ខា |
| វិនយំ | ” | ខ្ញុំលះបង់វិន័យ |
| បាដិមោក្ខំ | ” | ខ្ញុំលះបង់បាដិមោក្ខ |
| ឧទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេស |
| ឧបជ្ឈាយំ | ” | ខ្ញុំលះបង់ឧបជ្ឈាយ៍ |
| អាចរិយំ | ” | ខ្ញុំលះបង់អាចារ្យ |
| សទ្ធិវិហារិកំ | ” | ខ្ញុំលះបង់សទ្ធិវិហារិក |
| អន្តេវាសិកំ | ” | ខ្ញុំលះបង់អន្តេវាសិក |
| សមានុបជ្ឈាយកំ | ” | ខ្ញុំលះបង់អ្នករួមឧបជ្ឈាយ៍ |
| សមានុចរិយកំ | ” | ខ្ញុំលះបង់អ្នករួមអាចារ្យ |
| សព្រហ្មចារឹ | ” | ខ្ញុំលះបង់សព្រហ្មចារិយ |

ព្រះមានព្រះភាគត្រាស់ហើយ សូម្បីក្នុងវារៈពោលពីការពោលាសិក្ខានេះ ។

មួយទៀត ពាក្យថា **វទតិ វិញ្ញាបេតិ** ក្នុងបទទាំងអស់ មានសេចក្តីដូចតទៅនេះ ៖

ភិក្ខុដែលអផ្សុកនោះ បញ្ចេញវាចាពោល និងញ៉ាំងបុគ្គលដែលខ្លួនប្រាប់ឱ្យដឹងច្បាស់គឺ ប្រកាសឱ្យបានឮ បានដល់ ឱ្យយល់ ដោយការបញ្ចេញវាចានោះឯងថា ភិក្ខុនេះមានសេចក្តីប្រាថ្នានឹងលះសាសនា នឹងផុតពីសាសនា នឹងលះភាពជាភិក្ខុ ទើបបញ្ចេញពាក្យនេះ ។

ក៏បើភិក្ខុនេះ មានសេចក្តីប្រាថ្នានឹងពោលថា **ពុទ្ធំ បច្ចក្ខាមិ** តែធ្វើបទត្រឡប់គ្នាចេញហើយ គប្បីពោលថា **បច្ចក្ខាមិ ពុទ្ធំ** ឬគប្បីពោលសេចក្តីនោះដោយបណ្តាភាសារបស់ជនអ្នកមិលក្ខៈភាសាណាមួយ, ឬមានសេចក្តីប្រាថ្នានឹងពោលថា **ពុទ្ធំ បច្ចក្ខាមិ** តែគប្បីពោលដោយរំលងលំដាប់ថា **ធម្មំ បច្ចក្ខាមិ** ឬថា **សព្រហ្មចារី បច្ចក្ខាមិ** នេះប្រៀបដូចក្នុងវិភង្គនៃឧត្តរិមនុស្សធម៌ គឺ ភិក្ខុដែលមានសេចក្តីប្រាថ្នានឹងពោលថា "**បឋមំ ឈានំ សមាបជ្ជាមិ** : ខ្ញុំបានចូលកាន់បឋមជ្ឈាន" តែពោលថា "**ទុតិយំ ឈានំ សមាបជ្ជាមិ** : ខ្ញុំចូលទុតិយជ្ឈាន" ដូច្នេះសូម្បីយ៉ាងណា, បើភិក្ខុដែលអផ្សុកនោះនឹងប្រាប់ដល់អ្នកណា, អ្នកនោះ

រមែងដឹងពាក្យនិយាយសូម្បីមានប្រមាណប៉ុណ្ណេះថា ភិក្ខុនេះមានសេចក្តីប្រាថ្នានឹងលះភាពជាភិក្ខុទើបបានពោលសេចក្តីនេះ, ដែលឈ្មោះថា ការពោលខុសភ្លាត់ រមែងមិនមាន, ការពោលដូច្នោះ ក៏ឈានចុះកាន់ខេត្តតែម្តង, សិក្ខាក៏រមែងជាការពោលលាហើយ ដូច្នោះ ។ ភិក្ខុនោះ រមែងជាអ្នកឃ្លាតចាកសាសនាតែម្តង ដូចសត្វអ្នកឃ្លាតចាកភាពជាស្តេចសក្កៈ ឬចាកភាពជាព្រហ្ម ដូច្នោះ ។

មួយទៀត បើភិក្ខុពោលដោយពាក្យកំណត់អតីតកាល និងអនាគតកាលថា ពុទ្ធំ បច្ចក្ខឹ ក្តី ពុទ្ធំ បច្ចក្ខិស្សាមិ ក្តី ពុទ្ធំ បច្ចក្ខេយ្យំ ក្តី បញ្ជូនទូតទៅក្តី បញ្ជូនដំណឹងទៅក្តី ឆ្លាក់ (សរសេរ) អក្សរទុកក្តី ប្រាប់សេចក្តីនោះដោយមេដៃក្តី សិក្ខា រមែងមិនជាការពោលលា ។ ចំណែកការអួតឧត្តរិមនុស្សធម៌ រមែងដល់ទីបំផុត សូម្បីដោយមេដៃ ។ ការពោលលាសិក្ខា រមែងដល់ទីបំផុត ក៏ចំពោះកាលភិក្ខុបញ្ចេញវាចា ដែលសម្បយុត្តដោយចិត្តក្នុងសំណាក់របស់សត្វអ្នកជាជាតិមនុស្សប៉ុណ្ណោះ ។

ម្យ៉ាងទៀត ភិក្ខុ កាលបញ្ចេញវាចាប្រកាសឱ្យអ្នកដទៃដឹង បើប្រាប់ចំពោះបុគ្គលម្នាក់ថា បុគ្គលនេះប៉ុណ្ណោះចូរដឹង និងបុគ្គលនោះឯងដឹងសេចក្តីប្រាថ្នារបស់លោកនោះសោត, សិក្ខា ក៏ជាការពោលលា ។ បើបុគ្គលនោះមិនដឹង, តែអ្នកដទៃដែលឈរក្នុងទីជិតដឹង, សិក្ខា រមែង

មិនជាការពោលលា ។ បើថា ភិក្ខុនោះប្រាប់ចំពោះ សូម្បីបុគ្គលពីរនាក់ ក្នុងទីដែលមនុស្សពីរនាក់ឈរថា "ខ្ញុំប្រាប់ដល់បុគ្គលទាំងពីរនាក់នេះ" ដូច្នេះ, បណ្តាអ្នកទាំងពីរនោះ កាលម្នាក់ដឹងក៏ដោយ ដឹងទាំងពីរនាក់ក៏ដោយ សិក្ខារមែងជាការពោលលា ។ ការពោលលាសិក្ខាសូម្បីក្នុងបុគ្គលច្រើននាក់ បណ្ឌិតក៏គួរជ្រាបដូចអធិប្បាយមកហើយនោះ ។

## ភិក្ខុស្រែកប្រកាសលាសិក្ខាក៏បាន

មួយទៀត បើថា ភិក្ខុដែលត្រូវសេចក្តីមិនត្រេកអរបៀតបៀនខ្លាចក្រែងភិក្ខុទាំងឡាយអ្នកជិតជិតគ្នា (ហាមឃាត់) ពោលថា **ពុទ្ធំ បច្ចក្ខាមិ** ស្រែកប្រកាសសំឡេងខ្លាំងដោយប្រាថ្នាថា អ្នកណា ៗចូរដឹង, បើថា មានអ្នកធ្វើការងារនៅក្នុងព្រៃ ឬបុរសជាទៃអ្នកដឹងលទ្ធិសាសនាឈរក្នុងទីមិនឆ្ងាយ បានឮសំឡេងរបស់ភិក្ខុនោះ ក៏យល់ថា សមណៈនេះអផ្សុក ប្រាថ្នាភាពជាគ្រហស្ថឃ្លាតចាកសាសនាហើយ ដូច្នេះ, សិក្ខាជាការពោលលាពិត ។ ប៉ុន្តែថា ក្នុងខណៈនោះឯង ការពោលលាសិក្ខាមិនមុន មិនក្រោយ ជាការដែលដឹងបានលំបាក ។ ដូចពួកមនុស្សក្នុងលោក ដោយប្រក្រតីធម្មតា ស្តាប់ពាក្យនិយាយហើយ រមែងដឹងបានយ៉ាងណា, បើថា អ្នកដែលធ្វើការងារនៅក្នុងព្រៃជាដើមនោះ រមែងដឹង

បានក្នុងសម័យដែលគិតនឹកសោត, សិក្ខាក៏រមែងជាការពោលលាហើយដូច្នោះ ។ បើក្នុងកាលខាងក្រោយគេសង្ស័យថា ភិក្ខុនេះនិយាយអ្វី ? គិតយូរ ទើបយល់, សិក្ខា រមែងមិនជាការពោលលា ។ ពិតមែន ការពោលលាសិក្ខានេះផង អក្ខតាពេចនសិក្ខាបទ ទុដ្ឋុល្លវាចសិក្ខាបទ អត្តកាមសិក្ខាបទទុដ្ឋទោសសិក្ខាបទ និងភូតារោចនសិក្ខាបទទាំងឡាយខាងមុខផង មានកំណត់សេចក្តីដូចគ្នា រមែងដល់ទីបំផុត ក្នុងកាលអ្នកស្តាប់ដឹងសេចក្តីបាន ក្នុងសម័យដែលនឹកគិតនុ៎ះឯង ។ កាលអ្នកស្តាប់សង្ស័យនៅថា ភិក្ខុនេះ និយាយអ្វី ? គិតយូរ ៗ ទើបយល់សេចក្តីបាន, សិក្ខាបទទាំង ៥ នោះ មិនទាន់ដល់ទីបំផុត ។ ឧទាហរណ៍ថា វិនិច្ឆ័យនេះលោកពោលទុកក្នុងបទថា **ពុទ្ធំ បច្ចក្ខាមិ** យ៉ាងណា, ក្នុងបទទាំងពួងក៏គួរជ្រាបវិនិច្ឆ័យ យ៉ាងនោះ ។ ក៏ព្រោះសិក្ខា រមែងជាការភិក្ខុពោលលាក្នុងកាលណា, ក្នុងកាលនោះ សូម្បីភិក្ខុមិនពោលពាក្យជាដើមថា **យន្នូនាហំ ពុទ្ធំ បច្ចក្ខេយ្យំ** ភាពជាអ្នកទុព្វល ក៏រមែងជាការធ្វើឱ្យច្បាស់ហើយ ; ហេតុដូច្នោះ ក្នុងទីបំផុតនៃបទសូម្បីទាំងអស់ ព្រះមានព្រះភាគទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ការធ្វើឱ្យច្បាស់នូវភាវនៃខ្លួន ជាបុគ្គលមានកម្លាំងថយ ទាំងសិក្ខាក៏ហៅថា ភិក្ខុ បានពោលលាហើយ" ។

បន្ទាប់ពី ១៤ បទនោះទៅ ក្នុងបទថា គិហីតិ មំ ធារេហិ : លោកចូរចាំទុកនូវខ្ញុំថា ជាគ្រហស្ថចុះ នេះ មានវិនិច្ឆ័យដូច្នេះ ៖

បើថា ភិក្ខុដែលអផ្សុកនោះពោលថា

"គិហី ភវិស្សាមិ ខ្ញុំនឹងជាគ្រហស្ថ" ដូច្នេះក្តី

"គិហី ហោមិ ខ្ញុំប្រាកដជាគ្រហស្ថ" ដូច្នេះក្តី

"គិហី ជាតោម្ហិ ខ្ញុំកើតជាគ្រហស្ថហើយ" ដូច្នេះក្តី

"គិហិម្ហិ ខ្ញុំរមែងជាគ្រហស្ថ" ដូច្នេះក្តី

សិក្ខា មិនឈ្មោះថា ពោលលា ។ ក៏បើពោលថា

"អជ្ជ បដ្ឋាយ គិហីតិ មំ ធារេហិ តាំងពីថ្ងៃនេះទៅ លោកចូរចាំខ្ញុំថា ជាគ្រហស្ថ" ដូច្នេះក្តី

"អជ្ជ បដ្ឋាយ គិហីតិ មំ ជានាហិ តាំងពីថ្ងៃនេះទៅ លោកចូរដឹងខ្ញុំថា ជាគ្រហស្ថ" ដូច្នេះក្តី

អជ្ជ បដ្ឋាយ គិហីតិ មំ សញ្ជានាហិ តាំងពីថ្ងៃនេះទៅ លោកចូរសំគាល់ខ្ញុំថា ជាគ្រហស្ថ ដូច្នេះក្តី

អជ្ជ បដ្ឋាយ គិហីតិ មំ មនសិករោហិ តាំងពីថ្ងៃនេះទៅ លោកចូរធ្វើទុកក្នុងចិត្ត ខ្ញុំថា ជាគ្រហស្ថ ដូច្នេះក្តី

ឬពោលដោយវោហាររបស់ជនអរិយកៈ(អ្នកស្រុកមគធៈ) ឬវោហាររបស់ជនមិលក្ខៈក្តី កាលលោកពោលសេចក្តីនោះយ៉ាងនេះហើយ បើអ្នកដែលខ្លួនប្រាប់យល់, សិក្ខាក៏រមែងជាការពោលលា ។

ក្នុង៧ បទ មានថា **ឧបាសកោ** ជាដើមសូម្បីដ៏សេស ក៏ន័យនោះ ។ ក៏ ៨ បទទាំងនេះ និង ១៤ បទខាងដើម ទើបរួមជា ២២ បទ ដូច្នេះឯង ។ បន្ទាប់ពី ៨ បទនោះទៅ លោកពោលប្រមូល ១៤ បទខាងដើមនុ៎ះឯងចូលដោយ ៤ បទទាំងនេះ គឺ អលំ មេ : **ខ្ញុំមិនត្រូវការ**, កិន្នុ មេ : **ប្រយោជន៍អ្វីដល់ខ្ញុំ**, ន មមត្ថោ : **សេចក្តីត្រូវការនៃខ្ញុំមិនមាន**, សុមុត្តាហំ : **ខ្ញុំរួចស្រឡះហើយ**, ទើបជា ៥៦ បទ ។

បណ្តាបទទាំងនោះ បទថា អលំ **មិនត្រូវការ** បានដល់ លើកទុកសិនចុះ, អធិប្បាយថា ល្មមហើយ ។

បទថា កិន្នុ មេ : **ប្រយោជន៍អ្វីដល់ខ្ញុំ** សេចក្តីថា កិច្ចអ្វីរបស់ខ្ញុំ ? គឺ កិច្ចអ្វីដែលខ្ញុំគួរធ្វើ ? អធិប្បាយថា កិច្ចអ្វី ដែលខ្ញុំនឹងគប្បីធ្វើឱ្យសម្រេច ?

បទថា ន មមត្ថោ : **សេចក្តីត្រូវការនៃខ្ញុំមិនមាន** សេចក្តីថា

ខ្ញុំមិនមានសេចក្ដីត្រូវការ ។

បទថា **សុមុត្តាហំ** កាត់បទជា **សុមុត្តោ អហំ : ខ្ញុំរួចស្រឡះហើយ** គឺ ខ្ញុំផុតល្អហើយ (ចាកព្រះពុទ្ធ) ។

ពាក្យដ៏សេសក្នុង៥៦ បទនេះ មានន័យដូចពោលមកហើយតែម្ដង ។ ក៏ ៥៦ បទទាំងនេះ និង ២២ បទខាងដើម ទើបរួមជា ៧៨ បទ លោកពោលទុកដោយសរុបប៉ុណ្ណោះ ដោយប្រការយ៉ាងនេះ ។ ក៏ព្រោះការពោលលាសិក្ខា រមែងពោលបាន សូម្បីដោយពាក្យជាវេវចនៈនៃបទដែលជាខេត្តទាំងនោះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យថា **យានិ វា បនញ្ញានិបិ** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **យានិ វា បនញ្ញានិបិ : ម្យ៉ាងទៀត ពាក្យទាំងឡាយណា** សូម្បីដទៃ សេចក្ដីថា វៀរលែងតែបទដែលមកក្នុងបាលីថា **ពុទ្ធំ** ជាដើមចេញហើយ ពាក្យវេវចនៈពួកដទៃណាហ្នឹងនៅមានទៀត ។

បទថា **ពុទ្ធវេវចនានិ វា : ជាពាក្យផ្លាស់ប្ដូរគ្នាដោយព្រះពុទ្ធក្ដី** បានដល់ ព្រះនាមដោយបរិយាយនៃព្រះពុទ្ធ ។ល។ ឬនាមដោយបរិយាយនៃអ្នកមិនមែនព្រះសក្យបុត្រ ។

បណ្ដាព្រះនាម ដែលជាវេវចនៈនៃព្រះពុទ្ធជាដើមទាំងនោះ ព្រះនាមទាំងពាន់មកហើយក្នុងវណ្ណបដ្ឋាន(១) ព្រះនាមមួយរយមកហើយក្នុងឧបាលីគាថា(២) និង ព្រះនាមយ៉ាងដទៃដែលបានដោយព្រះគុណ គប្បីជ្រាបថា ជាវេវចនៈនៃព្រះពុទ្ធ ។ ឈ្មោះនៃព្រះធម៌សូម្បីទាំងអស់ គប្បីជ្រាបថា ជាវេវចនៈនៃព្រះធម៌ ។

ក្នុងវេវចនៈនៃព្រះសង្ឃជាដើមទាំងអស់ ក៏ន័យនោះ ។

## ពោលលាសិក្ខាដោយបញ្ចូលនាមព្រះពុទ្ធជាវេវចនៈ

ក៏ក្នុងព្រះនាមដែលជាវេវចនៈនៃព្រះពុទ្ធជាដើមនេះ មានយោជនាដូចតទៅនេះ ៖

ការពោលលាដោយពាក្យថា ពុទ្ធំ **បច្ចក្ខាមិ** មិនមែនជាការពោលលាដោយវេវចនៈតាមដែលពោលឡើយ ។ ការពោលលាជាដើមយ៉ាងនេះ គឺ ៖

សម្មាសម្ពុទ្ធំ **បច្ចក្ខាមិ** ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់ត្រាស់ដឹងប្រពៃដោយ

---

(១) វណ្ណបដ្ឋាន សម្ដែងពុទ្ធគុណផ្នែកមហាសង្ឃិក ពួកមហាយាន ; ក្នុងពុទ្ធគុណគាថាវលីក៏មាន (២) ឧបាលីវាទសូត្រ មជ្ឈិ. មជ្ឈិ. ២៣ ៨២/១៣១ ។ កងពុទ្ធគាថាវលី មាន ១២២៥ គាថា ។

ព្រះអង្គឯង ។

| | | |
|---|---|---|
| អនន្តពុទ្ធី | បច្ចក្ខាមិ | ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់មានការត្រាស់ដឹងមិនមានទីបំផុត ។ |
| អនោមពុទ្ធី | ” | ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់មានការត្រាស់ដឹងមិនថោកថយ ។ |
| ពោធិប្បញ្ញាណំ | ” | ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់មានការត្រាស់ដឹងជាគ្រឿងប្រាកដ ។ |
| ធីរំ | ” | ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់មានប្រាជ្ញាខ្ជាប់ខ្ជួន ។ |
| វិគតមោហំ | ” | ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់មានមោហៈទៅប្រាសហើយ ។ |
| បភិន្នខិលំ | ” | ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់មានបង្គោលបាក់បែកហើយ ។ |
| វិជិតវិជយំ | ” | ខ្ញុំលះបង់ព្រះពុទ្ធ ទ្រង់បានឈ្នះមារហើយ ។ |

ចាត់ជាការពោលលាសិក្ខាដោយពាក្យវេវចនៈនៃព្រះពុទ្ធ ។

## វិធីលាសិក្ខាដោយបញ្ចូលពាក្យវេវចនៈព្រះធម៌

ការពោលលាដោយពាក្យថា ធម្មំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយវេវចនៈតាមដែលពោលឡើយ ។

ឈ្មោះសូម្បីនៃព្រះធម្មក្ខន្ធ ៗ មួយ ក្នុងបណ្តាប្រាំបីម៉ឺនបួនពាន់ព្រះធម្មក្ខន្ធ (ទាំងនេះ) គឺ ៖

ស្វាក្ខាតំ ធម្មំ បច្ចក្ខាមិ ខ្ញុំលះបង់ព្រះធម៌ ដែលព្រះមានព្រះភាគត្រាស់សម្តែងហើយដោយល្អ ។

សន្ទិដ្ឋិកំ ធម្មំ " ខ្ញុំលះបង់ព្រះធម៌ ដែលអ្នកបានសម្រេចដឹងពិតឃើញពិតដោយបច្ចវេក្ខណញ្ញាណដោយខ្លួនឯង ។

អកាលិកំ ធម្មំ " ខ្ញុំលះបង់ព្រះធម៌ ដែលឱ្យនូវផលមិនរង់ចាំកាល ។

ឯហិបស្សិកំ ធម្មំ " ខ្ញុំលះបង់ព្រះធម៌ ដែលគួរនឹងហៅបុគ្គលឱ្យចូលមក មើលបាន ។

ឱបនយិកំ ធម្មំ " ខ្ញុំលះបង់ព្រះធម៌ ដែលព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃភាវនា

បច្ចត្តំ វេទិតព្វំ វិញ្ញូហិ ធម្មំ បច្ចក្ខាមិ ខ្ញុំពោលលានូវព្រះធម៌ដែលឧត្តមជិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បីឃើញ

ច្បាស់ក្នុងចិត្តនៃខ្លួន ។

អសង្ខតំ ធម្មំ បច្ចក្ខាមិ ខ្ញុំលះបង់ព្រះធម៌ ដែលបច្ច័យមិនបានតាក់តែង
វិរាគំ ធម្មំ " ខ្ញុំលះបង់ព្រះធម៌ ដែលប្រាសចាករាគៈ ។
និរោធំ ធម្មំ " ខ្ញុំលះបង់ព្រះធម៌ ដែលរលត់អស់ ។
អមតំ ធម្មំ " ខ្ញុំលះបង់ព្រះធម៌ ដែលជាអមតៈ ។
ទីឃនិកាយំ " ខ្ញុំលះបង់ទីឃនិកាយ ។
ព្រហ្មជាលំ " ខ្ញុំលះបង់ព្រហ្មជាលសូត្រ
មជ្ឈិមនិកាយំ " ខ្ញុំលះបង់មជ្ឈិមនិកាយ ។
មូលបរិយាយំ " ខ្ញុំលះបង់មូលបរិយាយសូត្រ ។
សំយុត្តនិកាយំ " ខ្ញុំលះបង់សំយុត្តនិកាយ ។
អង្គុត្តរនិកាយំ " ខ្ញុំលះបង់អង្គុត្តរនិកាយ ។
ជាតកនិកាយំ " ខ្ញុំលះបង់ជាតកនិកាយ ។
អភិធម្មំ " ខ្ញុំលះបង់ព្រះអភិធម្ម
កុសលំ ធម្មំ " ខ្ញុំលះបង់កុសលធម៌
អកុសលំ ធម្មំ " ខ្ញុំលះបង់អកុសលធម៌
អព្យាកតំ ធម្មំ " ខ្ញុំលះបង់អព្យាកតធម៌
សតិបដ្ឋានំ " ខ្ញុំលះបង់សតិបដ្ឋាន

សមប្បធានំ " ខ្ញុំលះបង់សម្មប្បធាន
ឥទ្ធិបាទំ បច្ចក្ខាមិ ខ្ញុំលះបង់ឥទ្ធិបាទ
ឥន្ទ្រិយំ " ខ្ញុំលះបង់ឥន្ទ្រិយ
ពលំ " ខ្ញុំលះបង់ពលៈ
ពោជ្ឈង្គំ " ខ្ញុំលះបង់ពោជ្ឈង្គ
មគ្គំ " ខ្ញុំលះបង់មគ្គ
ផលំ " ខ្ញុំលះបង់ផល
និព្វានំ " ខ្ញុំលះបង់ព្រះនិព្វាន

ចាត់ជាវេវចនៈនៃព្រះធម៌ពិតតែម្តង ។

ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃព្រះធម៌ ដូច ពណ៌នាមកដូច្នេះ ។

## វិធីលាសិក្ខាដោយបញ្ចូលពាក្យវេវចនៈព្រះសង្ឃ

ការពោលលាដោយពាក្យថា សង្ឃំ បច្ចក្ខាមិ មិនមែនការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃព្រះសង្ឃយ៉ាងនេះគឺ ៖

សុបដិបន្នំ សង្ឃំ បច្ចក្ខាមិ ខ្ញុំលះបង់ព្រះសង្ឃដែលបដិបត្តិប្រពៃ

| | | | |
|---|---|---|---|
| ឧជុបដិបន្នំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលបដិបត្តិត្រង់ |
| ញាយបដិបន្នំ | សង្ឃំ | បច្ចក្ខាមិ | ខ្ញុំលះបង់ព្រះសង្ឃដែលបដិបត្តិដើម្បីត្រាស់ដឹង |
| សាមីចិបដិបន្នំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលបដិបត្តិដ៏សមគួរ |
| ចតុប្បុរិសយុគំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលជាគូនៃបុរសមានបួនគូ |
| អដ្ឋបុរិសបុគ្គលំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលជាបុរសបុគ្គលមាន ៨ |
| អាហុនេយ្យំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលគួរទទួលបច្ច័យ |
| បាហុនេយ្យំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលគួរនាំមកបូជា |
| ទក្ខិណេយ្យំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលគួរទទួលទក្ខិណាទាន |
| អញ្ជលិករណីយំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលគួរធ្វើអញ្ជលីកម្ម |
| អនុត្តរំ បុញ្ញក្ខេត្តំ | ” | ” | ខ្ញុំលះបង់ព្រះសង្ឃដែលជាស្រែបុណ្យរបស់ ( លោក ) មិនមានស្រែបុណ្យដទៃក្រៃលែងជាង ។ |

## អត្ថាធិប្បាយវិធីពោលលាសិក្ខាទូទៅ

ការពោលលាដោយពាក្យថា សិក្ខំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈ នៃសិក្ខាយ៉ាងនេះ គឺ ៖

ភិក្ខុសិក្ខំ បច្ចក្ខាមិ ខ្ញុំលះបង់សិក្ខារបស់ភិក្ខុ
ភិក្ខុនីសិក្ខំ " ខ្ញុំលះបង់សិក្ខារបស់ភិក្ខុនី
អធិសីលសិក្ខំ " ខ្ញុំលះបង់អធិសីលសិក្ខា
អធិចិត្តសិក្ខំ " ខ្ញុំលះបង់អធិចិត្តសិក្ខា
អធិបញ្ញាសិក្ខំ " ខ្ញុំលះបង់អធិបញ្ញាសិក្ខា ។

ការពោលលាដោយពាក្យថា វិនយំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈនៃវិន័យ មានជាដើមយ៉ាងនេះគឺ ៖

ភិក្ខុវិនយំ បច្ចក្ខាមិ ខ្ញុំលះបង់វិន័យរបស់ភិក្ខុ
ភិក្ខុនីវិនយំ " ខ្ញុំលះបង់វិន័យរបស់នាងភិក្ខុនី
បឋមំ បារាជិកំ " ខ្ញុំលះបង់បឋមបារាជិក

ទុតិយំ " " ខ្ញុំលះបង់ទុតិយបារាជិក

តតិយំ " " ខ្ញុំលះបង់តតិយបារាជិក

ចតុត្ថំ " បច្ចក្ខាមិ ខ្ញុំលះបង់ចតុត្ថបារាជិក

សង្ឃាទិសេសំ " ខ្ញុំលះបង់សង្ឃាទិសេស

ថុល្លច្ចយំ " ខ្ញុំលះបង់ថុល្លច្ច័យ

បាចិត្តិយំ " ខ្ញុំលះបង់បាចិត្តិយៈ

បាដិទេសនីយំ " ខ្ញុំលះបង់បាដិទេសនីយៈ

ទុក្កដំ " ខ្ញុំលះបង់ទុក្កដ

ទុព្ភាសិតំ " ខ្ញុំលះបង់ទុព្ភាសិត ។

ការពោលលាដោយពាក្យថា បាដិមោក្ខំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈនៃបាដិមោក្ខយ៉ាងនេះគឺ ៖

ភិក្ខុបាដិមោក្ខំ បច្ចក្ខាមិ ខ្ញុំលះបង់ភិក្ខុបាដិមោក្ខ

ភិក្ខុនីបាដិមោក្ខំ " ខ្ញុំលះបង់ភិក្ខុនីបាដិមោក្ខ ។

ការពោលលាដោយពាក្យថា ឧទ្ទេសំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈនៃឧទ្ទេស មានជាដើមយ៉ាងនេះគឺ ៖

| | | |
|---|---|---|
| ភិក្ខុបាតិមោក្ខុទ្ទេសំ | បច្ចក្ខាមិ | ខ្ញុំលះបង់ភិក្ខុបាតិមោក្ខុទ្ទេស |
| បឋមំ បាតិមោក្ខុទ្ទេសំ | ” | ខ្ញុំលះបង់បាដិមោក្ខុទ្ទេសទី ១ |
| ទុតិយំ បាតិមោក្ខុទ្ទេសំ | បច្ចក្ខាមិ | ខ្ញុំលះបង់បាតិមោក្ខុទ្ទេសទី ២ |
| តតិយំ ” | ” | ខ្ញុំលះបង់បាតិមោក្ខុទ្ទេសទី ៣ |
| ចតុត្ថំ ” | ” | ខ្ញុំលះបង់បាតិមោក្ខុទ្ទេសទី ៤ |
| បញ្ចមំ ” | ” | ខ្ញុំលះបង់បាតិមោក្ខុទ្ទេសទី ៥ |
| សម្មាសម្ពុទ្ធុទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះសម្មាសម្ពុទ្ធ |
| អនន្តពុទ្ធិឧទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះអនន្តពុទ្ធិ |
| អនោមពុទ្ធិឧទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះអនោមពុទ្ធិ |
| ពោធិប្បញ្ញាណុទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះពោធិបញ្ញាណ |
| ធីរុទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះធីរ |
| វិគតមោហុទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះវិគតមោហៈ |
| បភិន្នខិលុទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះបភិន្នខិល |
| វិជិតវិជយុទ្ទេសំ | ” | ខ្ញុំលះបង់ឧទ្ទេសនៃព្រះវិជិតវិជ័យ ។ |

ការពោលលាដោយពាក្យថា ឧបជ្ឈាយំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈនៃឧបជ្ឈាយ៍យ៉ាងនេះគឺ ៖

| | |
|---|---|
| យោ មំ បព្វាជេសិ | ភិក្ខុណា ឱ្យខ្ញុំបព្វជ្ជា |
| យោ មំ ឧបសម្បាទេសិ | ភិក្ខុណា ឱ្យខ្ញុំឧបសម្បទា |
| យស្ស មូលេនាហំ បព្វជិតោ | ខ្ញុំបព្វជ្ជាហើយ ព្រោះមានភិក្ខុណាជាប្រធាន |
| យស្ស មូលេនាហំ ឧបសម្បន្នោ | ខ្ញុំឧបសម្បទាហើយ ព្រោះមានភិក្ខុណាជាប្រធាន |
| យស្ស មូលិកា មយ្ហំ បព្វជ្ជា | បព្វជ្ជារបស់ខ្ញុំមានភិក្ខុណាជាប្រធាន |
| យស្ស មូលិកា មយ្ហំ ឧបសម្បទា | ឧបសម្បទារបស់ខ្ញុំមានភិក្ខុណាជាប្រធាន |
| តាហំ បច្ចក្ខាមិ | ខ្ញុំលះបង់ភិក្ខុនោះ ។ |

ការពោលលាដោយពាក្យថា **អាចរិយំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈនៃអាចារ្យយ៉ាងនេះគឺ ៖

| | |
|---|---|
| យោ មំ បព្វាជេសិ | ភិក្ខុណាឱ្យខ្ញុំបព្វជ្ជា |
| យោ មំ អនុស្សាវេសិ | ភិក្ខុណាសូត្រប្រកាសខ្ញុំ |
| យាហំ និស្សាយ វសាមិ | ខ្ញុំនៅអាស្រ័យភិក្ខុណា |
| យាហំ ឧទ្ទិសាបេមិ | ខ្ញុំឱ្យភិក្ខុណាសម្ដែងឧទ្ទេសឱ្យ |

យាហំ បរិបុច្ឆាមិ ខ្ញុំសាកសួរឧទ្ទេសចំពោះភិក្ខុណា
យោ មំ ឧទ្ទិសតិ ភិក្ខុណាសម្តែងឧទ្ទេសដល់ខ្ញុំ
យោ មំ បរិបុច្ឆាបេតិ ភិក្ខុណាអនុញ្ញាតឱ្យខ្ញុំសួរឧទ្ទេស
តាហំ បច្ចក្ខាមិ ខ្ញុំលះបង់ភិក្ខុនោះ ។

ការពោលលាដោយពាក្យថា សទ្ធិវិហារិកំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈ នៃសទ្ធិវិហារិកយ៉ាងនេះ គឺ ៖

យាហំ បព្វាជេសឹ ខ្ញុំឱ្យសាមណេរណាបព្វជ្ជា
យាហំ ឧបសម្បាទេសឹ ខ្ញុំឱ្យភិក្ខុណាឧបសម្បទា
មយ្ហំ មូលេន យោ បព្វជិតោ សាមណេរណាបព្វជ្ជាហើយ ព្រោះមានខ្ញុំជាប្រធាន
មយ្ហំ មូលេន យោ ឧបសម្បន្នោ ភិក្ខុណាឧបសម្បទាហើយ ព្រោះមានខ្ញុំជាប្រធាន
មយ្ហំ មូលិកា យស្ស បព្វជ្ជា បព្វជ្ជារបស់សាមណេរណា មានខ្ញុំជាប្រធាន
មយ្ហំ មូលិកា យស្ស ឧបសម្បទា ឧបសម្បទារបស់ភិក្ខុណា មានខ្ញុំជាប្រធាន

| | |
|---|---|
| តាហំ បច្ចក្ខាមិ | ខ្ញុំលះបង់សាមណេរ និងភិក្ខុនោះ ។ |

ការពោលលាដោយពាក្យថា **អន្តេវាសិកំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃអន្តេវាសិកយ៉ាងនេះគឺ ៖

| | |
|---|---|
| យាហំ បព្វាជេសឹ | ខ្ញុំឱ្យសាមណេរណាបព្វជ្ជា |
| យាហំ អនុស្សាវេសឹ | ខ្ញុំសូត្រប្រកាសឱ្យភិក្ខុណា |
| យោ មំ និស្សាយ វសតិ | ភិក្ខុណានៅអាស្រ័យខ្ញុំ |
| យោ មំ ឧទ្ទិសាបេតិ | ភិក្ខុណាឱ្យខ្ញុំសម្តែងឧទ្ទេសឱ្យ |
| យោ មំ បរិបុច្ឆតិ | ភិក្ខុណាសាកសួរឧទ្ទេសចំពោះខ្ញុំ |
| យស្សាហំ ឧទ្ទិសាមិ | ខ្ញុំសម្តែងឧទ្ទេសដល់ភិក្ខុណា |
| យាហំ បរិបុច្ឆាបេមិ | ខ្ញុំអនុញ្ញាតឱ្យភិក្ខុណាសាកសួរឧទ្ទេស |
| តំ បច្ចក្ខាមិ | ខ្ញុំលះបង់ភិក្ខុនោះ ។ |

ការពោលលាដោយពាក្យថា **សមានុបជ្ឈាយកំ បច្ចក្ខាមិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃអ្នករួមឧបជ្ឈាយ៍យ៉ាងនេះ គឺ ៖

| | |
|---|---|
| មយ្ហំ ឧបជ្ឈាយោ យំ បព្វាជេសិ, | ឧបជ្ឈាយ៍របស់ខ្ញុំ ឱ្យសាមណេរណាបព្វជ្ជាហើយ |

| | |
|---|---|
| យំ ឧបសម្បាទេសិ, | ឱ្យភិក្ខុណាឧបសម្បទាហើយ |
| យោ តស្ស មូលេន បព្វជិតោ, | សាមណេរណាបព្វជ្ជាហើយក្នុងសំណាក់របស់ឧបជ្ឈាយ៍នោះ |
| យោ តស្ស មូលេន ឧបសម្បន្នោ, | ភិក្ខុណាឧបសម្បទាហើយ ក្នុងសំណាក់របស់ឧបជ្ឈាយ៍នោះ |
| យស្ស តម្មូលិកា បព្វជ្ជា, | បព្វជ្ជារបស់សាមណេរណា មានឧបជ្ឈាយ៍នោះ ជាប្រធាន |
| យស្ស តម្មូលិកា ឧបសម្បទា | ឧបសម្បទារបស់ភិក្ខុណា មានឧបជ្ឈាយ៍នោះជាប្រធាន |
| តំ បច្ចក្ខាមិ | ខ្ញុំលះបង់ភិក្ខុនោះ ។ |

ការពោលលាដោយពាក្យថា សមានាចរិយកំ បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃភិក្ខុអ្នករួមអាចារ្យយ៉ាងនេះ គឺ ៖

| | |
|---|---|
| មយ្ហំ អាចរិយោ យំ បព្វាជេសិ, យំ អនុសាវេសិ, | អាចារ្យរបស់ខ្ញុំឱ្យសាមណេរណាបព្វជ្ជា ហើយសូធ្យប្រកាសឱ្យភិក្ខុណា |
| យោ តំ និស្សាយ វសតិ, | ភិក្ខុណានៅអាស្រ័យអាចារ្យនោះ |
| យោ តំ ឧទ្ទិសាបេតិ បរិបុច្ឆតិ, | ភិក្ខុណាឱ្យអាចារ្យនោះសម្តែង |

| | |
|---|---|
| | ឧទ្ទេស ឱ្យសាកសួរឧទ្ទេស |
| យស្ស មេ អាចរិយោ ឧទ្ទិសតិ, | អាចារ្យរបស់ខ្ញុំសម្តែងឧទ្ទេសដល់ភិក្ខុណា |
| យំ បរិបុច្ឆាបេតិ | អនុញ្ញាតឱ្យភិក្ខុណាសាកសួរឧទ្ទេស |
| តំ បច្ចក្ខាមិ | ខ្ញុំលះបង់ភិក្ខុនោះ ។ |

ការពោលលាដោយពាក្យថា សព្រហ្មចារី បច្ចក្ខាមិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃភិក្ខុសព្រហ្មចរិយយ៉ាងនេះ គឺ ៖

**យេនាហំ សទ្ធឹ អធិសីលំ សិក្ខាមិ, អធិចិត្តំ សិក្ខាមិ, អធិបញ្ញំ សិក្ខាមិ តំ បច្ចក្ខាមិ**

ខ្ញុំសិក្សាអធិសីល សិក្សាអធិចិត្ត សិក្សាអធិបញ្ញា រួមជាមួយភិក្ខុណា ខ្ញុំលះបង់ភិក្ខុសព្រហ្មចរិយនោះ ។

ការពោលលាដោយពាក្យថា គិហីតិ មំ ធារេហិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបានដោយពាក្យវេវចនៈនៃគ្រហស្ថយ៉ាងនេះ គឺ ៖

| | | | |
|---|---|---|---|
| **អាគារិកោតិ** | **មំ** | **ធារេហិ** | លោកចូរចាំខ្ញុំទុកថា ជាអ្នកគ្រប់គ្រងផ្ទះ |
| **កស្សកោតិ** | ” | ” | លោកចូរចាំខ្ញុំទុកថា ជាអ្នកស្រែ |

វាណិជោតិ " " លោកចូរចាំខ្ញុំទុកថា ជាឈ្មួញ
គោរក្ខោតិ " " លោកចូរចាំខ្ញុំទុកថា ជាអ្នកចិញ្ចឹមគោ
ឱគល្លកោតិ " " លោកចូរចាំខ្ញុំទុកថា ជាមនុស្សកំព្រា
មោលិពទ្ធោតិ " " លោកចូរចាំខ្ញុំទុកថា ជាអ្នកទុកផ្នួងសក់
កាមគុណិកោតិ " " លោកចូរចាំខ្ញុំទុកថា ជាអ្នកប្រាថ្នាកាមគុណ

ការពោលលាដោយពាក្យថា ឧបាសកោតិ មំ ធារេហិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃឧបាសកយ៉ាងនេះគឺ ៖

ទ្វេវាចិកោ ឧបាសកោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាឧបាសក អ្នកបញ្ចេញវាចា ២

តេវាចិកោតិ ឧបាសកោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាឧបាសកដែល មានវាចា ៣

ពុទ្ធំ សរណគមនិកោ ឧបាសកោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាឧបាសក អ្នកចូលដល់ព្រះពុទ្ធជាទីពឹង

ធម្មំ សរណគមនិកោ ឧបាសកោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាឧបាសក អ្នកដល់ព្រះធម៌ ជាទីពឹង

សង្ឃំ សរណគមនិកោ ឧបាសកោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា

ជាឧបាសក អ្នកដល់ព្រះសង្ឃជាទីពឹង,

**បញ្ចសិក្ខាបទិកោ ឧបាសកោតិ មំ ធារេហិ** លោកចូរចាំខ្ញុំទុកថា ជាឧបាសកអ្នករក្សាសិក្ខាបទ ៥

**ទសសិក្ខាបទិកោ ឧបាសកោតិ មំ ធារេហិ** លោកចូរចាំខ្ញុំទុកថា ជាឧបាសកអ្នករក្សាសិក្ខាបទ ១០ ។

ការពោលលាដោយពាក្យថា **អារាមិកោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃអារាមិកៈ (អ្នករក្សាវត្តឬអ្នករក្សាសួន) យ៉ាងនេះគឺ ៖

**កប្បិយការកោតិ មំ ធារេហិ** លោកចូរចាំខ្ញុំទុកថា ជាកប្បិយការក

**វេយ្យាវច្ចករោតិ** " " លោកចូរចាំខ្ញុំទុកថា ជាវេយ្យាវច្ចករ

**អប្បហរិតការកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាអ្នកចោលរបស់ស្រស់ខៀវ, (អ្នកជម្រះ ឬកាត់ស្មៅ)

**យាគុភាជកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាអ្នកចែកបបរ

**ផលភាជកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាអ្នកចែកផ្លែឈើ

**ខជ្ជកភាជកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាអ្នកចែករបស់ទំពាស៊ី

ការពោលលាដោយពាក្យថា **សាមណេរោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ៗ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃសាមណេរយ៉ាងនេះគឺ ៖

**កុមារកោតិ មំ ធារេហិ** លោកចូរចាំខ្ញុំទុកថា ជាសាមណេរក្មេង
**ចេដកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាសាមណេរតូច
**បេដកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាសាមណេរកណ្តាល
**មោឡិគល្លោតិ** " " លោកចូរចាំខ្ញុំទុកថា ជាសាមណេរធំ
**សមណុទ្ទេសោតិ** " " លោកចូរចាំខ្ញុំទុកថា ជាសមណុទ្ទេស, (គឺ សាមណេរមានអាយុគ្រប់ហើយ តែមិនឧបសម្បទា)

ការពោលលាដោយពាក្យថា **តិត្ថិយោតិ មំ ធារេហិ** មិនមែនជាការពោលលាដោយពាក្យវេវចនៈ ៗ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃតិរ្ថិយយ៉ាងនេះគឺ ៖

**និគ្គណ្ឋោតិ មំ ធារេហិ** លោកចូរចាំខ្ញុំទុកថា ជានិគ្រន្ថ
**អាជីវកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាជាអាជីវក
**តាបសោតិ** " " លោកចូរចាំខ្ញុំទុកថា ជាតាបស
**បរិព្វាជកោតិ** " " លោកចូរចាំខ្ញុំទុកថា ជាបរិព្វាជក

បណ្ឌរង្គោតិ " " លោកចូរចាំខ្ញុំទុកថា ជាអ្នកស្លៀកពាក់ស

ការពោលលាដោយពាក្យថា តិត្ថិយសាវកោតិ មំ ធារេហិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃសាវកតិរ្ថិយយ៉ាងនេះ គឺ ៖

និគណ្ឋសាវកោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាសាវករបស់និគ្រន្ថ អាជីវក តាបស បរិព្វាជ កបណ្ឌ រង្គសាវកោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាសាវករបស់អាជីវក តាបស បរិព្វាជក និងអ្នកស្លៀកពាក់ស ។

ការពោលលាដោយពាក្យថា អស្សមណោតិ មំ ធារេហិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ការពោលលាសិក្ខា រមែងពោលបាន ដោយពាក្យវេវចនៈនៃអ្នកមិនមែនសមណៈយ៉ាងនេះ គឺ ៖

ទុស្សីលោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាអ្នកទ្រុស្តសីល ។

បាបធម្មោតិ " " " ជាអ្នកមានធម៌លាមក, អសុចិ

សង្កស្សរសមាចារោតិ " " " ជាអ្នកមិនស្អាត និងមានសមាចារដែលតាមរលឹកដោយសេចក្តីរង្កៀស

បដិច្ឆន្នកម្មន្តោតិ " " " ជាអ្នកមានការងារបិទបាំង

អស្សមណោ សមណបដិញ្ញោតិ " " " ជាអ្នកមិនមែនសមណៈ តែបដិញ្ញាថា ជាសមណៈ

អព្រហ្មចារី ព្រហ្មចារិបដិញ្ញោតិ " " " ជាអ្នកប្រព្រឹត្តមិន

ប្រសើរ ក៏ប្ដេជ្ញា ថា ជាអ្នកប្រព្រឹត្ត
ប្រសើរ

អន្តោបូតីតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា ជាអ្នកស្អុយខាងក្នុង
អវស្សុតោតិ ” ” ” ជាអ្នកដែលរាគៈជោគជំហើយ
កសម្ពុជាតោតិ ” ” ” ជាអ្នកដូចសម្រាម
កោណ្ឌោតិ ” ” ” ជាមនុស្សអាក្រក់

ការពោលលាដោយពាក្យថា អសក្យបុត្តិយោតិ មំ ធារេហិ មិនមែនជាការពោលលាដោយពាក្យវេវចនៈ ។ ការពោលលាសិក្ខាមែងពោលបាន ដោយ ពាក្យវេវចនៈនៃអ្នកមិនមែនផៅពង្សព្រះសក្យបុត្រមានជាដើមយ៉ាងនេះ គឺ ៖

ន សម្មាសម្ពុទ្ធបុត្តោតិ មំ ធារេហិ លោកចូរទ្រង់ចាំ ខ្ញុំទុកថា មិនមែន
ជាបុត្ររបស់ព្រះសម្មាសម្ពុទ្ធ
ន អនន្តពុទ្ធិបុត្តោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា មិនមែនជាបុត្រ
របស់ព្រះអនន្តពុទ្ធិ
ន អនោមពុទ្ធិបុត្តោតិ ” ” លោកចូរចាំខ្ញុំទុកថា មិនមែនជា
បុត្ររបស់ព្រះអនោមពុទ្ធិ
ន ពោធិបញ្ញាណបុត្តោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា មិនមែនជា

បុត្ររបស់ពោធិបញ្ញាណ

ន ធីរបុត្តោតិ " " " មិនមែនជាបុត្ររបស់ព្រះធីរ

ន វិគតមោហនបុត្តោតិ មំ ធារេហិ លោកចូរចាំខ្ញុំទុកថា មិនមែនជាបុត្ររបស់ព្រះវិគតមោហៈ

ន បភិន្នខិលបុត្តោតិ " " " មិនមែនជាបុត្ររបស់ព្រះបភិន្នខិល

ន វិជិតវិជយបុត្តោតិ " " " មិនមែនជាបុត្ររបស់ព្រះវិជិតវិជ័យ

ច្រើនបទថា តេហិ អាការេហិ តេហិ លិង្គេហិ តេហិ និមិត្តេហិ : ដែលជាអាការៈ ដែលជាភេទ ដែលជានិមិត្ត សេចក្តីថា (ភិក្ខុ រមែងពោលឱ្យអ្នកដទៃដឹង) ដោយពាក្យវេវចនៈនៃព្រះរតនត្រ័យមានព្រះពុទ្ធជាដើមទាំងនោះ គឺ ដែលត្រាស់ទុកដោយន័យមានជាដើមថា ពាក្យវេវចនៈនៃព្រះពុទ្ធក្តី ៗ ពិតមែន ពាក្យវេវចនៈទាំងឡាយ លោកហៅថា អាការ ព្រោះជាហេតុនៃការពោលលាសិក្ខា, ហៅថា ភេទ ព្រោះសម្តែងទ្រង់ទ្រាយនៃព្រះពុទ្ធជាដើម ឬ ព្រោះសេចក្តីសមរម្យដល់ការពោលលាសិក្ខានុ៎ះឯង, ហៅថា និមិត្ត ព្រោះជាហេតុឱ្យដឹងការពោលលាសិក្ខា ដូចអុជខ្មៅទាំងឡាយមានអាចម៍រុយជាដើម (ប្រជ្រុយ)

របស់ពួកមនុស្ស ដូច្នោះ ។

ព្រះមានព្រះភាគ ត្រាស់កំណត់ពិតប្រាកដទៅថា **ឯវំ ខោ ភិក្ខវេ** : ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ដូច្នេះជាដើម ព្រោះហេតុនៃការពោលលាសិក្ខាយ៉ាងដទៃ ក្រៅពីហេតុដែលពោលហើយនេះមិនមាន ។ ពិតមែន ក្នុងពាក្យថា **ឯវំ ខោ** នេះ មានអធិប្បាយដូច្នេះថា ការធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វល និងការពោលលាសិក្ខា រមែងពោលបាន ដោយអាការយ៉ាងនេះឯង ហេតុដទៃក្រៅពីនេះ មិនមានទេ ។

## លាសិក្ខានឹងអ្នកវិកលចរិតជាដើមមិនបាន

[៣២] លុះព្រះមានព្រះភាគ ទ្រង់សម្ដែងលក្ខណៈនៃការពោលលាសិក្ខាយ៉ាងនេះហើយ ដើម្បីសេចក្ដីមិនភន់ច្រឡំក្នុងការមិនពោលលា និងដើម្បីសម្ដែងសេចក្ដីវិបត្តិនៃលក្ខណៈការពោលលាសិក្ខានោះឯង ដោយអំណាចនៃបុគ្គលជាដើម ទើបត្រាស់ពាក្យថា **កថញ្ច ភិក្ខវេ អប្បច្ចក្ខាតា** : ម្នាលភិក្ខុទាំងឡាយ មិនបានពោលលានោះ តើដូចម្ដេច ដូច្នេះជាដើម ។ ក្នុងពាក្យថា **អប្បច្ចក្ខាតា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា **យេហិ អាការេហិ** ជាដើម មានន័យដូចពោលហើយនុ៎ះឯង ។

បទថា **ឧម្មត្តកោ** : **ភិក្ខុជាមនុស្សឆ្កួត** បានដល់ ភិក្ខុឆ្កួតព្រោះត្រូវយក្ខ ចូលស្កិត ឬឆ្កួតព្រោះប្រម៉ាត់កម្រើក គឺ ភិក្ខុដែលមានសញ្ញាវិបរិតរូបណាមួយ ។ ភិក្ខុឆ្កួតនោះ បើពោលលា(សិក្ខា) សោត, សិក្ខាមិនជាការពោលលា ។

បទថា **ឧម្មត្តកស្ស** : **នៃបុគ្គលឆ្កួត** បានដល់ ភិក្ខុឆ្កួតយ៉ាងនោះដូចគ្នា ។ ពិតមែន បើបកតត្តភិក្ខុ ពោលលាសិក្ខាក្នុងសំណាក់របស់ភិក្ខុឆ្កួតយ៉ាងនោះសោត, ភិក្ខុឆ្កួតមិនយល់, សិក្ខារមែងមិនជាការពោលលា ។

ភិក្ខុឆ្កួតព្រោះត្រូវយក្ខចូលស្កិត លោកហៅថា ភិក្ខុដែលមានចិត្តរវើរវាយ ។ មួយទៀត ពាក្យថា ភិក្ខុឆ្កួតព្រោះត្រូវយក្ខចូលស្កិត ឬភិក្ខុឆ្កួតព្រោះប្រម៉ាត់កម្រើក លោកពោលទុកហើយក្នុងបទដើម ដោយភាពជាភិក្ខុឆ្កួតស្មើគ្នា ។ សេចក្ដីប្លែកគ្នានៃភិក្ខុឆ្កួតសូម្បីទាំងពីរនឹងមានច្បាស់ក្នុងអនាបត្តិវារ ។ ភិក្ខុដែលមានចិត្តរវើរវាយយ៉ាងនោះ ពោលលា(សិក្ខា), សិក្ខា រមែងមិនជាការពោលលាឡើយ ។ សិក្ខាសូម្បីដែលបកតត្តភិក្ខុពោលលាហើយ ក្នុងសំណាក់របស់ភិក្ខុឆ្កួត ព្រោះត្រូវយក្ខចូលស្កិតនោះ កាលភិក្ខុឆ្កួតនោះមិនយល់ ក៏មិនជាការពោលលា ។

បទថា **វេទនដ្ដោ** : **ភិក្ខុដែលវេទនាកំពុងគ្របសង្កត់** បានដល់ ភិក្ខុដែលទុក្ខវេទនាដ៏មានកម្លាំងពាល់ត្រូវហើយ គឺ អ្នកត្រូវសេចក្ដីសន្លប់

បាត់ស្មារតីគ្របសង្កត់ហើយ ។ សិក្ខាដែលភិក្ខុត្រូវវេទនាបៀតបៀនផ្ចាញ់ផ្ចាលនោះ សូម្បីពោលលាហើយ ក៏រមែងមិនជាការពោលលា ។ សិក្ខាសូម្បីដែលភិក្ខុពោលលាហើយក្នុងសំណាក់របស់ភិក្ខុដែលត្រូវវេទនាគ្របសង្កត់នោះ កាលភិក្ខុដែលត្រូវវេទនាគ្របសង្កត់នោះ មិនយល់ ក៏មិនជាការពោលលា ។

ពីរបទថា ទេវតាយ សន្តិកេ : ក្នុងសំណាក់ទេវតា សេចក្តីថា សិក្ខាដែលភិក្ខុពោលលាហើយក្នុងសំណាក់របស់ទេវតា ចាប់ផ្តើមតាំងពីភុម្មទេវតាទៅដរាបដល់អកនិដ្ឋទេវតា រមែងមិនជាការពោលលា ។

បទថា តិរច្ឆានគតស្ស : ក្នុងសំណាក់តិរច្ឆាន សេចក្តីថា សិក្ខាដែលភិក្ខុពោលលាហើយក្នុងសំណាក់របស់នាគមាណពក្តី សុបណ្ណមាណពក្តី ឬក្នុងសំណាក់របស់ទេវតា ពួកកិន្នរ ដំរី និងស្វាជាដើម ពួកណាមួយក្តី រមែងមិនជាការពោលលាឡើយ ។

សិក្ខា ដែលភិក្ខុពោលលាក្នុងសំណាក់របស់បណ្តាភិក្ខុឆតជាដើមទាំងនោះ រមែងមិនជាការពោលលាពិត ព្រោះ (ភិក្ខុឆតជាដើមនោះ) មិនយល់ ។ ដែលពោលលាក្នុងសំណាក់របស់ទេវតា ក៏រមែងមិនជាការពោលលា (ដូចគ្នា) ព្រោះ (ទេវតា) ដឹងរហ័ស ។ ឈ្មោះថា ពួកទេវតាដែលមានបដិសន្ធិជាត្រៃហេតុ មានបញ្ញាច្រើន រមែងដឹងអ្វីលឿន

រហ័ស ។ ក៏ដែលឈ្មោះថា ចិត្តនេះ រមែងជាធម្មជាតិប្រព្រឹត្តទៅរហ័ស; ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់យល់ក្នុងព្រះទ័យថា សេចក្តីវិនាសរបស់បុគ្គល (ភិក្ខុ)ដែលមានចិត្តត្រឡប់ត្រឡិន កុំមានរហ័សពេក ព្រោះអំណាចចិត្តនោះឡើយ ទើបទ្រង់ហាមការលាសិក្ខាក្នុងសំណាក់របស់ទេវតាទុក ។ ចំណែកក្នុងពួកមនុស្ស មិនមានកំណត់ទុក, សិក្ខាដែលភិក្ខុពោលលាក្នុងសំណាក់របស់អ្នកណាមួយ អ្នកជាសភាគគ្នា (គឺបុរស) ក៏ដោយអ្នកជាវិសភាគគ្នា (គឺមាតុគ្រាម) ក៏ដោយ ជាគ្រហស្ថក៏ដោយ ជាបព្វជិតក៏ដោយដែលយល់ (អ្នកដឹងក្តី) រមែងជាការពោលលាហើយពិត ។ បើថា អ្នកនោះ មិនយល់សោត, សិក្ខា ក៏រមែងមិនជាការពោលលាឡើយ ។

ព្រះមានព្រះភាគ នឹងទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ពាក្យថា **អរិយកេន : ដោយអរិយភាសា** ជាដើម ។ ក្នុងពាក្យថា **អរិយកេន** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

វោហាររបស់ជនអរិយៈ ឈ្មោះថា អរិយកៈ បានដល់ ភាសារបស់អ្នកមគធៈ ។ វោហារដែលមិនមែនរបស់ជនអរិយៈយ៉ាងណាមួយ ឈ្មោះថា មិលក្ខកៈ បានដល់ វោហាររបស់អ្នកអន្ធទមិឡ (អ្នកខ្មៅ) ជាដើម ។

ច្រើនបទថា សោ ចេ ន បដិវិជានាតិ : បើជននោះ មិនដឹងច្បាស់ទេ សេចក្តីថា (បើជនអរិយកៈឬមិលក្ខកៈនោះ)មិនយល់ថាភិក្ខុនោះ និយាយសេចក្តី ឈ្មោះនេះ ព្រោះសេចក្តីដែលខ្លួនមិនដឹងក្នុងភាសាដទៃ ឬព្រោះសេចក្តីដែលខ្លួនមិន ឆ្លាតក្នុងពុទ្ធសម័យ, សិក្ខារមែងមិនជាការពោលលា ។

បទថា ទវាយ[១] : ជាល្បែងលេង សេចក្តីថា ភិក្ខុដែលមានសេចក្តីប្រាថ្នានឹងនិយាយយ៉ាងណាមួយដោយរហ័ស តែនិយាយទៅដោយរហ័សថា "ខ្ញុំលះបង់ព្រះពុទ្ធ" ដូច្នេះ (ឈ្មោះថា ភិក្ខុលះបង់សិក្ខាដោយពោលលេង ឬពោលរហ័ស) ។

បទថា រវាយ : ដោយភ្លាត់មាត់ បានដល់ ដោយការនិយាយភ្លាត់ ។

បើមានអ្នកសួរថា ភិក្ខុគិតថា យើងនឹងនិយាយយ៉ាងណាមួយដូច្នេះ តែនិយាយទៅម្យ៉ាងទៀត គឺ និយាយថា យើងពោលលាព្រះពុទ្ធ[២] ដូច្នេះ ពាក្យនិយាយដែលនិយាយនេះនឹងពាក្យនិយាយដែលមានពីមុន[៣] មានសេចក្តីប្លែកគ្នាយ៉ាងណា ?

---

(១) សារត្ថទីបនី. ពោលទុកថា ទវាតិ សហសា : បទថា ទវា ប្រែថា ដោយ

រហ័ស ។

(២) សារត្ថទីបនី. អញ្ញំ ភណិស្សាមីតិ អញ្ញំ ភណន្តោ ពុទ្ធំ បច្ចក្ខាមីតិ ភណតិ ។

(៣) អត្ថយោជនា. បុរិមេន ភណនេន សទ្ធិ ឥមស្ស ភណនស្ស កោ វិសេសោតិ បុច្ឆកោ ចេ បុច្ឆតី. ។

ឆ្លើយថា សូម្បីអ្នកឆ្លាតនិយាយពាក្យមុនភ្លាត់ទៅជាពាក្យដទៃ ក៏ដោយអំណាចសេចក្តីរហ័ស តែបុគ្គលអ្នកភ្លាំងភ្លាត់តាំងចិត្តថា យើងនឹងនិយាយមួយយ៉ាងភ្លាត់ទៅនិយាយមួយយ៉ាងដទៃ នេះ ក៏ព្រោះសេចក្តីដែលខ្លួនជាអ្នក អបរិប្រាជ្ញា ជាអ្នកល្ងង់ខ្លៅ ។

ពីរបទថា អសាវេតុកាមោ សាវេតិ : ភិក្ខុមិនប្រាថ្នាឱ្យអ្នកដទៃឮ តែបែរជាឱ្យឮវិញ សេចក្តីថា ភិក្ខុប្រាប់ សាកសួររៀនសូត្រ ធ្វើការស្វាធ្យាយ ពណ៌នាបាលីនៃសិក្ខាបទនេះ ភិក្ខុនេះ ហៅថា អ្នកមិនប្រាថ្នានឹងប្រកាស តែប្រកាសឱ្យបានឮ ។

ច្រើនបទថា សាវេតុកាមោ ន សាវេតិ : ភិក្ខុប្រាថ្នាឱ្យអ្នកដទៃឮ តែបែរជាមិនឱ្យឮវិញ សេចក្តីថា ភិក្ខុដែលធ្វើឱ្យច្បាស់ភាពជាអ្នកទុព្វលហើយលះបង់សិក្ខា តែមិនបញ្ចេញវាចា ភិក្ខុនេះហៅថា អ្នកប្រាថ្នានឹងប្រកាស តែមិនប្រកាសឱ្យបានឮ ។

ពីរបទថា អវិញ្ញុស្ស សាវេតិ : ភិក្ខុពោលលាសិក្ខាក្នុងសំណាក់

មនុស្សដែលមិនដឹងសេចក្ដីច្បាស់ សេចក្ដីថា ប្រកាសដល់មនុស្សជរាដែលដូចជារូបគំនូរ ឬអ្នកអប្បបញ្ញា ដែលមិនឆ្លាតក្នុងលទ្ធិ (សាសនា) ឬពួកក្មេងអ្នកស្រុក នៅមិនទាន់ដឹងសេចក្ដី ។

ពីរបទថា **វិញ្ញុស្ស ន សាវេតិ : ភិក្ខុមិនពោលលាសិក្ខាឱ្យឮដល់មនុស្សដែលដឹងសេចក្ដីច្បាស់** សេចក្ដីថា មិនប្រកាសដល់អ្នកឆ្លាតដែលអាចនឹងយល់បាន ។

ច្រើនបទថា **សព្វសោ វា បន : ម្យ៉ាងទៀត ពោលលាសិក្ខាឱ្យប ៗគ្រប់បទ** សេចក្ដីថា សិក្ខារមែងជាការពោលលាហើយ ដោយបរិយាយណា ក្នុងបណ្ដាពាក្យថា ពុទ្ធំ **បច្ចក្ខាមិ** ជាដើម តែលោកមិនបានធ្វើសូម្បីបរិយាយយ៉ាងណាមួយអំពីបរិយាយនោះ គឺ បញ្ចេញវាចាប្រកាសឱ្យបានឮទេ ។ ព្រះមានព្រះភាគ ទ្រង់កំណត់លក្ខណៈនៃការមិនពោលលាទុក ដោយពាក្យថា **ឯវំ ខោ : យ៉ាងនេះឯង** ជាដើម ។ ពិតមែន ក្នុងពាក្យថា **ឯវំ ខោ** ជាដើមនេះ មានអធិប្បាយដូច្នេះថា សិក្ខារមែងជាការដែលភិក្ខុមិនពោលលា ដោយអាការយ៉ាងនេះឯង មិនបានពោលដោយហេតុយ៉ាងដទៃទេ ។

## អត្ថាធិប្បាយអត្ថន័យនៃមេថុនធម្ម

[៣៣] ឥឡូវនេះ ដើម្បីទ្រង់សម្តែងសេចក្តីនៃបទថា មេថុនំ ធម្មំ បដិសេវេយ្យ : ហើយសេពមេថុនធម្ម ជាដើម ព្រះមានព្រះភាគ ទើបត្រាស់ពាក្យថា មេថុនធម្មោ នាម : ធម៌ដែលហៅថា មេថុន ជាដើម ។

ក្នុងពាក្យថា មេថុនធម្មោ នាម ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា មេថុនធម្មោ នាម នេះ ជាបទឧទ្ទេសនៃមេថុនធម្មដែល គួរអធិប្បាយ ។

ធម៌របស់ពួកអសប្បុរសទាំងឡាយ គឺ មនុស្សថោកទាប ឈ្មោះ ថា អសទ្ធម្ម ។ ធម៌ជាទីសេពរបស់ពួកអ្នកស្រុកឈ្មោះថា គាមធម៌ ។ ធម៌របស់ពួកមនុស្សថោកទាប ឈ្មោះថា វសលធម៌ ។ម្យ៉ាងទៀត ធម៌ ឈ្មោះថា ថោកទាបខ្ជួនឯងផ្ទុំឯង ព្រោះជាទីហូរចេញនៃកិលេស ព្រោះ ដូច្នោះ ទើបឈ្មោះថា វសលធម៌ ។

បទថា ទុដ្ឋុល្លំ : អំពើអាក្រក់ មានសេចក្តីថា ឈ្មោះថា ជាធម៌ អាក្រក់ ព្រោះជាធម៌ដែលកិលេសទាំងឡាយប្រទូសរ៉ាយហើយ និង ឈ្មោះថា ជាធម៌គ្រោតគ្រាត ព្រោះជាធម៌មិនល្អិត ព្រោះដូច្នោះ ទើប ឈ្មោះថា ធម៌អាក្រក់គ្រោតគ្រាត ។

មួយទៀត តាំងពីនេះទៅគប្បីផ្លាស់ពីរបទថា យោ សោ នេះ ធ្វើឱ្យជា យន្តំ ប្រកបក្នុង៣ បទថា យន្តំ ទុដ្ឋុល្លំ យន្តំ ឧទកន្តិកំ យន្តំ រហស្សំ : នោះគឺអំពើអាក្រក់ នោះគឺមានកិច្ចដោយទឹកជាទីបំផុត នោះគឺជាអំពើក្នុងទីកំបាំង ។

គប្បីជ្រាបយោជនាក្នុង៣ បទនេះ យ៉ាងនេះថា ការឃើញក្តី ការចាប់ក្តី ការស្ទាបអង្អែលក្តី ការពាល់ត្រូវក្តី ការត្រដុសក្តី ដែលជាបរិវាររបស់កម្មនោះ ចាត់ជាកម្មអាក្រក់ សូម្បីព្រោះហេតុនោះ កម្មនោះទើបចាត់ជាកម្មអាក្រក់ កម្មអាក្រក់នោះ ឈ្មោះថា មេថុនធម្ម ទឹកដែលបុគ្គលតែងកាន់យក ដើម្បីសេចក្តីស្អាតក្នុងទីបំផុតនៃកម្មនោះ ហេតុនោះកម្មនោះ ទើបឈ្មោះថា មានទឹកជាទីបំផុត កម្មមានទឹកជាទីបំផុតនុ៎ះឯងឈ្មោះថា ឧទកន្តិកៈ កម្មមានទឹកជាទីបំផុតនោះឈ្មោះថា មេថុនធម្ម កម្មនោះឈ្មោះថា ជាកម្មកំបាំង ព្រោះភាពជាកម្មដែលត្រូវធ្វើក្នុងទីកំបាំង គឺក្នុងឱកាសដែលបិទបាំង កម្មនោះ ឈ្មោះថា មេថុនធម្ម ។

កម្មនោះ ឈ្មោះថា ដែលមនុស្សជាគូ ៗ គប្បីនៅរួមគ្នា ព្រោះភាពជាកម្មដែលបុគ្គលគប្បីរួមជាគូ ៗ គ្នា ។ ក្នុងបទថា ទ្វយទ្វយ-សមាបត្តិ : ដែលជនពីរនាក់រួបរួមគ្នា នោះគប្បីជ្រាបយោជនាថា កម្ម

ដែលមនុស្សជាគូ ៗ គប្បីនៅរួមគ្នានោះ ឈ្មោះថា មេថុនធម្ម ។

កំឯក្នុងអធិការនេះ ព្រះមានព្រះភាគ ទ្រង់ពោលដដែលនូវធម៌ទាំងពួង មានអសទ្ធម្មជាដើមនោះមករួមក្នុងទីជាមួយគ្នា ទើបត្រាស់ថានេះ ឈ្មោះថា មេថុនធម្ម ។

សួរថា ព្រោះហេតុអ្វី អសទ្ធម្ម ទើបហៅថា មេថុនធម្ម ?

ឆ្លើយថា អសទ្ធម្មនោះ ជារបស់មនុស្សគូ មនុស្សតម្រេកហើយ អ្នកត្រេកអរខ្លាំងហើយ អ្នកដែលរាគៈជោគជំហើយ គឺ អ្នកដែលរាគៈរួបរឹតហើយ បានដល់ ជាធម៌របស់មនុស្សគូគ្នា ព្រោះហេតុនោះ ទើបហៅថា មេថុនធម្ម ។

[៣៤] បទថា **បដិសេវតិ នាម : ហៅថា សេព** នេះ ជាបទមាតិកា ដើម្បីសម្តែងអាការជាហេតុដែលព្រះអង្គត្រាស់ហៅបុគ្គលថាគប្បីសេពចំពោះ ក្នុងបទថា **បដិសេវេយ្យ** នេះ ។

ក្នុងបទថា **យោ និមិត្តេន និមិត្តំ : បុគ្គលណា ឱ្យនិមិត្តខ្លួនចូលទៅដោយនិមិត្តគេ** ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណាឱ្យនិមិត្តរបស់ខ្លួនចូលទៅមកនិមិត្តរបស់ស្រី គឺ ឱ្យអង្គជាតិរបស់ខ្លួនចូលទៅមកអង្គជាតិរបស់ស្រី ក្នុងឱកាសដែលសើម ខ្យល់

ពាល់ត្រូវមិនបាន ដោយប្រមាណយ៉ាងទាបបំផុត សូម្បីត្រឹមមួយគ្រាប់ល្ង ភិក្ខុនោះឈ្មោះថា រមែងសេពចំពោះ ដោយអាការត្រឹមតែប៉ុណ្ណេះ លោករមែងដល់ការបែកទម្លាយនៃសីល គឺ ជាបារាជិក ។

## ឥត្ថីនិមិត្តបានឋាន ៥ បុរិសនិមិត្តបានឋាន ៦

ក៏បណ្តានិមិត្តរបស់ស្ត្រីនិងបុរសនេះ ក្នុងនិមិត្តរបស់ស្ត្រី បានឋាន ៥ គឺ ខាងទាំង ៤ និងត្រង់កណ្តាល ។ ក្នុងនិមិត្តរបស់បុរសបានឋាន ៦ គឺ ខាងទាំង ៤ កណ្តាល និងចុង ។ ព្រោះហេតុនោះ ក្នុងនិមិត្តរបស់ស្ត្រី សូម្បីសើកអង្គជាតិចូលទៅមកក្រោម រមែងជាបារាជិក សើកចូលទៅអំពីខាងលើក្តី សើកចូលទៅមកខាងទាំងពីរក្តី សើកចូលទៅត្រង់កណ្តាល ផុតឋានទាំង ៤ ក្តី រមែងជាបារាជិក (ទាំងនោះ) ។ ចំណែកនិមិត្តនៃបុរស សូម្បីភិក្ខុសើកចូលទៅឱ្យត្រូវមកចំណែកក្រោម រមែងជាបារាជិក សើកចូលទៅឱ្យត្រូវមកចំណែកលើក្តី សើកចូលទៅឱ្យត្រូវមកខាងទាំងពីរក្តី សើកចូលទៅឱ្យត្រូវចំត្រង់កណ្តាល ដូចម្រាមដៃដែលងចូលហើយ រុកចូលដោយខ្នងកណ្តាលក្តី សើកចូលទៅឱ្យត្រូវមកចំណែកលើក្តី រមែងជាបារាជិក (ទាំងអស់) ។

បណ្ដានិមិត្តរបស់ស្ត្រីនិងបុរសនោះ សូម្បីកាលភិក្ខុស៊ិកអង្គជាតិចូលទៅឱ្យដូចទីងដងជញ្ជីង បានឋាន ៥ គឺ ខាងទាំង ៤ និងចុង[1] ។ សូម្បីកាលស៊ិកឱ្យងចូលទៅ ក៏បានឋាន ៥ គឺ ខាងទាំង ៤ ចំណែក

១. បាលីថា មជ្ឈំ : កណ្ដាល, គួរតែជា ចុង វិញ ព្រោះត្រង់; សូមពិនិត្យសេចក្ដីនេះ ។

ចុងនៃកណ្ដាល ។ ឋានសូម្បីទាំងអស់ក្នុងនិមិត្តរបស់បុរសមាន ១០ ដោយប្រការដូច្នេះ ។

ភិក្ខុស៊ិកក្រម៉ោងស្បែក[1] ឬដុំពក ដែលមានកាយប្រសាទនៅល្អ ដែលកើតនៅក្នុងនិមិត្ត (របស់ខ្លួន) ចូលទៅ (ក្នុងនិមិត្តរបស់ស្ត្រី) ជាអាបត្តិបារាជិក ។ ស៊ិកក្រម៉ោងស្បែកដែលជាក្រម៉ោង ដែលកើតនៅត្រង់អង្គជាតិ. ដែលស្លាប់ហើយ ឬដុំពកស្បែកដែលស្ងួត ដែលមានកាយប្រសាទខូចហើយចូលទៅ (ក្នុងនិមិត្តរបស់ស្ត្រី) ជាអាបត្តិទុក្កដ ។ សូម្បីកាលស៊ិករោម ឬចុងម្រាមដៃ និងម្រាមមេដៃចូលទៅ (ក្នុងនិមិត្តស្ត្រី) ដោយសេចក្ដីត្រេកអរក្នុងមេថុន ជាទុក្កដដូចគ្នា ។

## ភិក្ខុពណ៌នាមេថុនកថា គួររលឹកពុទ្ធគុណ

ក៏ដែលឈ្មោះថា មេថុនកថា នេះ គឺ កថា ដែលអាក្រក់គ្រោតគ្រាត ដែលជាកថា របស់ពួកអសប្បុរស ព្រោះដូច្នោះ ភិក្ខុកាលទីង

ពោលដល់ឋានៈនោះក្តី ឋានៈដទៃក្តី ឬឋានៈដូច្នេះក្នុងព្រះវិន័យ ក៏គួរឱ្យបដិកូលមនសិការ សមណសញ្ញានិងហិរិឱត្តប្បៈតាំងឡើងចំពោះមុខ ហើយឱ្យសេចក្តីគោរពកើតឡើងក្នុងព្រះសម្មាសម្ពុទ្ធ រំពឹងដល់ព្រះករុណា

---

១. សារត្ថទីបនី. ចម្មខីលន្តិ និមិត្តេ ឧដ្ឋិតចម្មមេវ. ឧណ្ណិគណ្ឌោតិបិ វទន្តិ ។

របស់ព្រះលោកនាថ ទ្រង់មានព្រះករុណារកអ្នកស្មើមិនបាន ហើយពោលចុះ ៗ គួររំពឹងដល់ព្រះករុណាគុណរបស់ព្រះលោកនាថយ៉ាងនេះថា ការពិត ព្រះមានព្រះភាគព្រះអង្គនោះ សូម្បីមានព្រះទ័យត្រឡប់ហើយចាកកាមទាំងឡាយ ដោយប្រការទាំងពួងទ្រង់អាស្រ័យសេចក្តីករុណាក្នុងសត្វទាំងឡាយ ដើម្បីសេចក្តីអាណិតពួកសត្វ ដើម្បីសេចក្តីអនុគ្រោះដល់លោក បានត្រាស់កថា ដូច្នេះទុក ដើម្បីត្រូវការបញ្ញត្តិសិក្ខាបទ ព្រះសាស្តា មានព្រះករុណាគុណពិតហ្ន៎ ដូច្នេះហើយ គប្បីពោលចុះ ៗ

មួយទៀត បើព្រះមានព្រះភាគ នឹងមិនគប្បីត្រាស់កថា ដូច្នេះដោយប្រការទាំងពួងសោត អ្នកណាហ្ន៎នឹងគប្បីដឹងបានថា ក្នុងឋានៈប្រមាណប៉ុណ្ណេះ ជាបារាជិក ក្នុងឋានៈប្រមាណប៉ុណ្ណេះ ជាថុល្លច្ច័យ ក្នុងឋានៈប្រមាណប៉ុណ្ណេះ ជាទុក្កដ ៗ ព្រោះហេតុនោះ ភិក្ខុកាលស្តាប់ក្តីពោលក្តី (នូវមេថុនកថានោះ) មិនគួរយកផ្ទិតបិតមាត់ អង្គុយសើច

វេហួតឃើញធ្មេញគ្នាទេ គួរពិចារណាថា ដល់ឋានៈដូច្នេះ សូម្បីព្រះសម្មាសម្ពុទ្ធក៏បានត្រាស់ហើយ ដូច្នេះ ជាអ្នកមិនខ្វាច ព្រោះហេតុដូច្នោះ ដល់ព្រមដោយហិរិឱត្តប្បៈ មានចំណែកប្រៀបដូចព្រះសាស្ដា ហើយគប្បីពោលចុះ ដូច្នេះឯង ។

ចប់មូលបញ្ញត្តិសិក្ខាបទ

## អនុប្បញ្ញត្តិវារៈ

## កំណត់សត្វដែលជាវត្ថុនៃបារាជិកជាដើម

[៣៥] ក្នុងវារៈនៃអនុប្បញ្ញត្តិ មានវិនិច្ឆ័យដូច្នេះ ៖

បទថា អន្តមសោ : យ៉ាងហោចទៅ គឺ ដោយកំណត់យ៉ាងទាបបំផុតទាំងអស់ ។

បទថា តិរច្ឆានគតាយបិ : សូម្បីដោយសត្វតិរច្ឆានញី សេចក្ដីថា ពួកសត្វដែលទៅហើយ (គឺអ្នកកើតហើយ) ក្នុងពួកសត្វតិរច្ឆានដោយអំណាចបដិសន្ធិ ។

ពីរបទថា បគេវ មនុស្សិត្ថិយា : នឹងបាច់និយាយទៅថ្វី ដល់ភិក្ខុដែលសេពមេថុនធម្មដោយមនុស្សស្រី សេចក្ដីថា (ភិក្ខុសេពមេថុនធម្មក្នុងសត្វតិរច្ឆានញី មិនមែនជាសមណៈ)ក្នុងស្រីជាជាតិមនុស្ស ក៏

រមែងមិនជាសមណៈដូចពីមុន ។ ក៏សត្វតិរច្ឆានញី ដែលជាវត្ថុនៃបារាជិកនុ៎ះឯង គួរកាន់យកថា សត្វតិរច្ឆាន ក្នុងបឋមបារាជិកនេះ មិនមែនសត្វតិរច្ឆានញីទាំងអស់ (សត្វតិរច្ឆានញីមិនមែនជាវត្ថុនៃបារាជិកទាំងអស់) ។ ក្នុងពាក្យថា **សត្វតិរច្ឆាន** នោះ មានកំណត់ (ប្រភេទសត្វ) ដូច្នេះ ។

បណ្តាពួកសត្វមិនមានជើង បានដល់ ពស់និងត្រី, និងបណ្តាពួកសត្វមានជើងពីរ បានដល់ មេមាន់, បណ្តាពួកសត្វមានជើងបួន បានដល់ ឆ្មាញី, សត្វតិរច្ឆានញីទាំងនេះ ជាវត្ថុនៃបារាជិក ។

## អត្ថាធិប្បាយប្រភេទសត្វផ្សេងៗ

បណ្តាសត្វមានពស់ជាដើមនោះ ទីឃជាតិដោយប្រភេទផ្សេង ៗ មានពស់ថ្លាន់ និងពស់វែកក្របីជាដើមសូម្បីទាំងអស់ លោកសង្គ្រោះចូលដោយ អហិ ស័ព្ទ ។ ព្រោះដូច្នោះបណ្តាទីឃជាតិទាំងឡាយ ទីឃជាតិដែលភិក្ខុអាចស៊កអង្គជាតិចូលទៅក្នុងបណ្តាមគ្គទាំង ៣ មគ្គណាមួយ ប្រមាណប៉ុនគ្រាប់ល្ង ជាវត្ថុនៃបារាជិក, ដ៏សេសគប្បីជ្រាបថា ជាវត្ថុនៃទុក្កដ ។ សត្វដែលកើតក្នុងទឹក ដោយប្រភេទផ្សេង ៗ មានត្រីអណ្តើក និងកង្កែបជាដើម សូម្បីទាំងអស់ លោកសង្គ្រោះចូលដោយ មច្ឆៈ ស័ព្ទ ។ ក្នុងសត្វដែលកើតក្នុងទឹកសូម្បីនោះ គប្បីជ្រាបថា ជាវត្ថុនៃបារាជិក និងជាវត្ថុនៃទុក្កដ ដោយន័យដូចពោលទុកហើយក្នុងទីឃជាតិ

ន៏ុះឯង ។ ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះ ៖

ដែលឈ្មោះថា កន្ធែបជាសត្វមានមាត់វែង, កន្ធែបទាំងនោះ មានសណ្ឋានមាត់ធំ ( វែង )តែមានប្រហោងមាត់ចង្អៀត ; ក្នុងសណ្ឋានមាត់នោះ ទើបមិនល្មមដល់ការសើកអង្គជាតិចូលទៅបាន, តែសណ្ឋានមាត់រមែងដល់ការរាប់ថា ដំបៅ, ព្រោះដូច្នោះ គប្បីជ្រាបមុខសណ្ឋាននោះថា ជាវត្ថុនៃថុល្លច្ច័យ ។

បក្សីជាតិច្រើនប្រភេទ មានក្អែកនិងកូនសត្វសាលិកាជាដើម សូម្បីទាំងអស់ លោកសង្គ្រោះចូលដោយ កុក្កុដី ស័ព្ទ ។ ក្នុងបក្សីជាតិសូម្បីនោះ គប្បីជ្រាបថា ជាវត្ថុនៃបារាជិកនិងវត្ថុនៃទុក្កដ ដោយន័យដូចដែលពោលហើយនុ៎ះឯង ។

ចតុប្បាទជាតិ ( សត្វមានជើងបួន ) មានកន្ធែន ស្កានិងទន្សេងជាដើមសូម្បីទាំងអស់ លោកសង្គ្រោះចូលដោយ មជ្ជារី ស័ព្ទ ។ សូម្បីក្នុងចតុប្បាទជាតិនោះ ក៏គប្បីជ្រាបថា ជាវត្ថុនៃបារាជិក និងជាវត្ថុនៃទុក្កដ ដោយន័យដូចដែលពោលហើយនុ៎ះឯង ។

## បារាជិកស័ព្ទប្រព្រឹត្តទៅក្នុងសិក្ខាបទជាដើម

[៣៦] បទថា បារាជិកោ : ភិក្ខុត្រូវអាបត្តិបារាជិក បានដល់

ចាលចាញ់ហើយ គឺ ដល់ហើយនូវសេចក្ដីចាលចាញ់ ។ ពិតមែន បារាជិក ស័ព្ទនេះ រមែងប្រព្រឹត្តទៅក្នុងសិក្ខាបទផង អាបត្តិផង បុគ្គលផង ។ ក្នុង៣ យ៉ាងនោះ បារាជិកស័ព្ទ ដែលប្រព្រឹត្តទៅក្នុងសិក្ខាបទ គប្បីជ្រាប (ក្នុងទីដែលមកខាងដើម) យ៉ាងនេះថា "អដ្ឋានមេតំ អានន្ទ អនវកាសោ យំ តថាគតោ វជ្ជីនំ វា វជ្ជិបុត្តកានំ វា ការណា សាវកានំ បារាជិកំ សិក្ខាបទំ បញ្ញត្តំ សមូហនេយ្យ : ម្នាលអានន្ទ តថាគតគប្បីដកសិក្ខាបទឈ្មោះបារាជិក ដែលតថាគតបាន បញ្ញត្តិហើយ ដល់សាវកទាំងឡាយ ព្រោះហេតុនៃជនអ្នកនៅក្នុងដែន វជ្ជីទាំងឡាយក្ដី ព្រោះហេតុនៃវជ្ជីបុត្តកភិក្ខុទាំងឡាយក្ដី ដោយអំពើណា អំពើនោះ មិនមែនជាហេតុ មិនមែនជាឱកាសឡើយ" ។

ដែលប្រព្រឹត្តទៅក្នុងអាបត្តិគប្បីជ្រាប (ក្នុងវិនីតវត្ថុ) យ៉ាងនេះថា "អាបត្តឹ ត្វំ ភិក្ខុ អាបន្នោ បារាជិកំ : ម្នាលភិក្ខុ អ្នកឯងត្រូវអាបត្តិ បារាជិកហើយ"(១) ដែលប្រព្រឹត្តទៅក្នុងបុគ្គល គប្បីជ្រាប (ក្នុងវិនីតវត្ថុនៃ ទុតិយបារាជិក) យ៉ាងនេះថា "ន មយំ បារាជិកា យោ អវហដោ សោ បារាជិកោ : ពួកយើងមិនត្រូវអាបត្តិបារាជិកទេ, លោកនាលួច បានមក, លោកនោះ ត្រូវអាបត្តិបារាជិក"(២) ។ តែអាចារ្យពួកខ្លះ ពោលថា បារាជិកស័ព្ទនេះ នៅប្រព្រឹត្តទៅក្នុងធម៌បានទៀត ដូចក្នុងទី

ដែលមកមានពាក្យថា "បារាជិកេន ធម្មេន អនុទ្ធំសេយ្យ : (ភិក្ខុ) ចោទភិក្ខុផងគ្នា ដោយអាបត្តិបារាជិក"(៣) ដូច្នេះជាដើម ។

តែព្រោះហេតុដែលក្នុងអាបត្តិ និងសិក្ខាបទទាំង ២ នោះ ក្នុងទីកន្លែងខ្លះ ព្រះមានព្រះភាគទ្រង់ព្រះប្រាថ្នាអាបត្តិថា ធម៌ កន្លែងខ្លះក៏ទ្រង់ព្រះប្រាថ្នាសិក្ខាបទតែម្តង ព្រោះដូច្នោះ ទើបមិនគួរនឹងពោលធម៌នោះទុកមួយផ្នែកទៀត ។

បណ្តាសិក្ខាបទ អាបត្តិនិងបុគ្គលនោះ, សិក្ខាបទ ព្រះមានព្រះភាគត្រាស់ថា បារាជិក ព្រោះហេតុដែលញ៉ាំងបុគ្គលអ្នកល្មើសឱ្យចាលចាញ់, ចំណែកអាបត្តិត្រាស់ថា បារាជិក ព្រោះហេតុដែលញ៉ាំងបុគ្គលអ្នកត្រូវឱ្យចាលចាញ់, ចំណែកបុគ្គលដែលត្រាស់ថា ជាបារាជិក ព្រោះហេតុថា ជាអ្នកចាញ់ គឺ ដល់ភាពបរាជ័យ ។ ពិតមែន សូម្បីក្នុងគម្ពីរបរិវារ ព្រះមានព្រះភាគ ក៏សំដៅចំពោះសេចក្តីនេះ ត្រាស់ថា ៖

បារាជិកន្តិ យំ វុត្តំ តំ សុណោហិ យថាតថំ
ចុតោ បរទ្ធោ ភដ្ឋោ ច សទ្ធម្មា ហិ និរង្កតោ
សំវាសោបិ តហឹ នត្ថិ តេនេតំ ឥតិ វុច្ចតិ ។

(១) វិន. បារា. មេថុនធម្ម. ១. ១/៤១ ។ (២) វិន. បារា. អទិន្នាទាន. ១. ១៦០/២០៩ ។ (៣) វិន. សង្ឃា. ២. ២៤៥/២៥៥ ។

សិក្ខាបទណា ដែលតថាគតហៅថា បារាជិក, ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសម្តែងតទៅនេះ ។ បុគ្គលដែលឃ្លាតខុស ភ្លាត់របូតចាកព្រះសទ្ធម្មទាំងឡាយហើយ, សំវាសមិនមានក្នុងបុគ្គលនោះឡើយ ព្រោះហេតុនោះ សិក្ខាបទនុ៎ះ តថាគតហៅថា បារាជិក ។(២)

---

(២) វិន. បរិ. គាថាសង្គណិក. ១៣. ១១៦/១៣៤ ។

## អត្ថាធិប្បាយសេចក្តីក្នុងព្រះគាថា

ក៏ក្នុងបរិវារៈគាថានេះ មានសេចក្តីដូចតទៅនេះ ៖

បុគ្គលអ្នកល្មើសសិក្ខាបទនោះ និងត្រូវអាបត្តិនោះ រមែងជាអ្នកឃ្លាត (ចាកព្រះសទ្ធម្ម), ពាក្យទាំងពួងដែលបណ្ឌិតគប្បីប្រកបយ៉ាងនេះ ។

ពីរបទថា តេន វុច្ចតិ : ព្រោះហេតុនោះ បានជាហៅថា មានសេចក្តីថា បុគ្គល រមែងជាអ្នកមិនមែនសមណៈ មិនមែនពួកផៅពង្សនៃសក្យបុត្រ របូតធ្លាក់ទៅ ដាច់ទៅ គឺ ចាលចាញ់ចាកសាសនា ព្រោះហេតុណា, ព្រោះហេតុនោះ បុគ្គលនោះ យើងទើបពោល ។

សួរថា តើពោលយ៉ាងណា ? ឆ្លើយថា ពោលថា ជាអ្នកចាលចាញ់ ។

[៣៧] ភិក្ខុទាំងឡាយ រមែងនៅរួមគ្នាក្នុងធម៌នេះ ហេតុនោះធម៌នេះទើបឈ្មោះថា សំវាស ។ ព្រះមានព្រះភាគត្រាស់ថា **សំវាសោ នាម : ហៅថា សំវាស** ដូច្នេះហើយ ទើបត្រាស់ពាក្យជាដើមថា **ឯកកម្មំ** ក៏ដើម្បីសម្តែងសំវាសនោះ ។

ក្នុងពាក្យថា **ឯកកម្មំ : សង្ឃកម្មជាមួយគ្នា** ជាដើមនោះ មានពាក្យអធិប្បាយព្រមទាំងយោជនា ដូចតទៅនេះ ៖

សង្ឃកម្មទាំង ៤ យ៉ាង ឈ្មោះថា កម្មជាមួយគ្នា ព្រោះភាពជាកម្មដែលភិក្ខុទាំងឡាយអ្នកជាបកតត្ត កំណត់ដោយសីមា នឹងគប្បីធ្វើរួមគ្នា ។ មួយទៀត បាដិមោក្ខុទ្ទេសទាំង ៥ យ៉ាង ឈ្មោះថា ឧទ្ទេសជាមួយគ្នា ព្រោះភាពជាឧទ្ទេសដែលនិងគប្បីសូត្រជាមួយគ្នា ។ ចំណែកសិក្ខាបទដែលទ្រង់បញ្ញត្តិហើយ ឈ្មោះថា **សមសិក្ខាតា** ព្រោះភាពជាសិក្ខាដែលលជ្ជីបុគ្គលសូម្បីទាំងពួងនឹងគប្បីសិក្សាស្មើគ្នា ។ លជ្ជីបុគ្គលសូម្បីទាំងពួង រមែងនៅរួមគ្នាក្នុងកម្មជាដើមទាំងនេះ, បុគ្គលសូម្បីតែម្នាក់នឹងប្រាកដក្នុងខាងក្រៅចាកកម្មជាដើមនោះ ក៏ទេ ; ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់រួមយកវត្ថុទាំងនោះ សូម្បីទាំងអស់ ត្រាស់ថា នេះឈ្មោះថា សំវាស ក្នុងព្រះបាលីនេះ ។ ក៏ឯសំវាសមានប្រការដូចពោលហើយនោះ មិនមានជាមួយបុគ្គលនោះ ; ព្រោះហេតុនោះ បុគ្គល

ដែលចាលចាញ់ព្រះអង្គទើបត្រាស់ថា "**អសំវាសោ** : រកសំវាសគ្មាន" ដូច្នេះឯង ។

[៣៨] លុះព្រះមានព្រះភាគចែកសិក្ខាបទ ដែលទ្រង់ឧទ្ទេស យ៉ាងនោះតាមលំដាប់បទហើយ ឥឡូវនេះ ទើបទ្រង់សម្តែងសត្វទាំងឡាយ ដែលមាននិមិត្តជាវត្ថុនៃបារាជិក ដោយន័យមានពាក្យថា ស្រី ៣ ពួក ជាដើម ហើយត្រាស់វត្ថុ ៣ ដោយន័យមានពាក្យថា មគ្គ ៣ នៃស្រីមនុស្សជាដើម ដើម្បីសម្តែងនិមិត្ត ដែលជាវត្ថុនៃបារាជិក ព្រោះហេតុដែលនិមិត្តស្រីតែម្យ៉ាងប៉ុណ្ណោះ ទើបជាវត្ថុនៃបារាជិកក៏មិនមែន និមិត្តស្រីមនុស្សប៉ុណ្ណោះទើបជាវត្ថុ ក៏មិនមែន ទាំងនិមិត្តសូម្បីនៃស្រីទាំងឡាយដែលតាក់តែងដោយមាសនិងប្រាក់ជាដើម ទើបជាវត្ថុប៉ុណ្ណោះ ក៏ទេដែរ ក្នុងពាក្យថា និមិត្តេន និមិត្តំ អង្គជាតេន អង្គជាតំ : **ឱ្យនិមិត្តខ្លួនចូលទៅដោយនិមិត្ត** (គេ), **ឱ្យអង្គកំណើត** (ខ្លួន) **ចូលទៅដោយអង្គកំណើត** (គេ) ដែលព្រះអង្គទ្រង់តាំងបទមាតិកានេះថា បដិសេវតិ នាម : **ហៅថា សេព** ដើម្បីសម្តែងអាការជាហេតុត្រាស់ថា គប្បីសេពចំពោះ ក្នុងបទថា បដិសេវេយ្យ : **ហើយសេព** នេះត្រាស់ទុកហើយ ។

ក្នុងពាក្យថា ស្រី ៣ ពួក ជាដើមនោះ មានសត្វ ១២ ពួក

ដែលជាទីអាស្រ័យនៃនិមិត្ត ដែលជាវត្ថុនៃបារាជិក គឺ ស្ត្រី ៣ ពួក ឧភតោព្យញ្ជនក ៣ ពួក បណ្ឌកៈ ៣ ពួក បុរស ៣ ពួក ។ ក្នុងសត្វទាំង ១២ ពួកនោះ ស្ត្រីនិងបុរសប្រាកដច្បាស់ហើយ ។ ប្រភេទរបស់បណ្ឌកៈនិងឧភតោព្យញ្ជនក នឹងមានប្រាកដក្នុងវណ្ណនានៃបព្វជ្ជាខន្ធកៈ ។ ចំណែកក្នុងពាក្យថា អ្នកសេពមេថុនធម្មចំពោះមគ្គ ៣ នៃស្រីមនុស្សនេះ គប្បីជ្រាបសេចក្តីថា ក្នុងមគ្គ ៣ នៃស្រីមនុស្ស ។ គប្បីជ្រាបយ៉ាងនេះគ្រប់ ៗ បទ ។

## មគ្គដែលជាវត្ថុនៃបារាជិករួម ៣០

ក៏មគ្គទាំងអស់នោះតែម្តង មាន ៣០ គត់ គឺ របស់ស្រីមនុស្សមានមគ្គ ៣ របស់ស្រីអមនុស្សមានមគ្គ ៣ របស់សត្វតិរច្ឆានញីមានមគ្គ ៣ រួមជា ៩, របស់មនុស្សឧភតោព្យញ្ជនកជាដើមមាន ៩ របស់មនុស្សបណ្ឌកៈជាដើមមាន ៦ ព្រោះចែកជាមួយពួក មគ្គ ២ ៗ, របស់មនុស្សប្រុសជាដើមមាន ៦ ដូចគ្នា ។

[៣៩] ភិក្ខុកាលសេពមេថុនធម្ម ស៊កអង្គជាតិរបស់ខ្លួនចូលទៅក្នុងបណ្តាមគ្គដែលដឹងខ្លួនថា ជានិមិត្តទាំងនោះមគ្គណាមួយ សូម្បីត្រឹមតែមួយគ្រាប់ល្ង រមែងត្រូវបារាជិក ។ តែព្រោះកាលនឹងត្រូវ រមែងត្រូវ

ដោយសេវនចិត្តប៉ុណ្ណោះ វៀរចាកសេវនចិត្តនោះ មិនត្រូវទេ; ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទឹងទ្រង់សម្តែងលក្ខណៈនោះ ទើបត្រាស់ព្រះតម្រាស់ថា "ភិក្ខុស្ស សេវនចិត្តំ ឧបដ្ឋិតេ : **ភិក្ខុមានចិត្តចង់សេពផ្តួចផ្តើមឡើង**" ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា ភិក្ខុស្ស : **ភិក្ខុ** បានដល់ ភិក្ខុដែលសេពមេថុន ។ ក្នុងពាក្យថា **សេវនចិត្តំ ឧបដ្ឋិតេ** នេះ ជាបឋមាវិភត្តិចុះក្នុងអត្ថសត្តមីវិភត្តិ ។ អធិប្បាយថា កាលសេវនចិត្តប្រាកដហើយ ។

ច្រើនបទថា វច្ចមគ្គំ អង្គជាតំ បវេសេន្តស្ស : **ហើយបញ្ចូលអង្គជាតរបស់ខ្លួនទៅកាន់ទ្វារវច្ចមគ្គ** សេចក្តីថា កាលភិក្ខុស៊កអង្គជាតិ គឺបុរិសនិមិត្តរបស់ខ្លួនចូលទៅមកមគ្គដែលឧច្ចារៈចេញទៅនោះ សូម្បីត្រឹមតែមួយគ្រាប់ល្ង ។

ពីរបទថា អាបត្តិ បារាជិកស្ស : **ត្រូវអាបត្តិបារាជិក** សេចក្តីថា អាបត្តិបារាជិក រមែងមានដល់ភិក្ខុនោះ ។ ម្យ៉ាងទៀត បទថា អាបត្តិ ប្រែថា រមែងមានការត្រូវ ។

បទថា បារាជិកស្ស បានដល់ ធម៌គឺ បារាជិក ។ ក្នុងគ្រប់ ៗ

បទ ក៏ន័យនេះឯង ។

## ភិក្ខុត្រូវអ្នកដទៃចាប់បង្ខំហើយត្រេកអរជាបារាជិក

[៤០] ព្រះមានព្រះភាគ គ្រាទ្រង់សម្ដែងអាបត្តិរបស់ភិក្ខុដែលស៊ក (អង្គជាតិរបស់ខ្លួន) ចូលទៅដោយសេវនចិត្តតែម្យ៉ាងយ៉ាងនោះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់រក្សាពួកកុលបុត្រអ្នកបួសដោយសទ្ធាជាអ្នកបដិបត្តិប្រពៃ មិនត្រេកអរស្ទួម្បីក្នុងកាលមានការស៊ក (អង្គជាតិ) ចូលទៅ (ក្នុងអង្គជាតិរបស់ខ្លួន) ដោយសេចក្ដីព្យាយាមរបស់អ្នកដទៃ ព្រោះហេតុដែលឈ្មោះថា ការស៊ក (អង្គជាតិ) ចូលទៅនោះ មិនមែនជាការស៊កចូលទៅដោយសេចក្ដីព្យាយាមរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះទេ រមែងជាការស៊កចូលទៅបាន សូម្បីដោយសេចក្ដីព្យាយាមរបស់អ្នកដទៃ និងកាលភិក្ខុត្រេកអរក្នុងការស៊ក (អង្គជាតិ) ចូលទៅដោយសេចក្ដីព្យាយាមរបស់អ្នកដទៃសូម្បីនោះក៏ជាអាបត្តិ, គឺ កាលភិក្ខុមានសេចក្ដីប្រកបព្រមដោយបដិសេវនចិត្តក៏ជាអាបត្តិ ក្រៅនេះមិនជាអាបត្តិ ទើបត្រាស់ព្រះតម្រាស់ថា "ភិក្ខុបច្ចត្ថិកា មនុស្សិត្ថី : ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី" ជាដើម ។

ក្នុងពាក្យថា **បច្ចត្ថិកា** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ពួកជនអ្នកឈ្មោះថា ជាសត្រូវ ព្រោះអត្ថថា ត្រូវការ គឺ ប្រាថ្នាជាបដិបក្ខ ។ សត្រូវទាំងឡាយ គឺ ពួកភិក្ខុ ឈ្មោះថា ភិក្ខុបច្ចត្ថិកា (ភិក្ខុដែលជាសត្រូវ) ។ ពាក្យថា ភិក្ខុបច្ចត្ថិកានោះ ជាឈ្មោះរបស់ពួកភិក្ខុដែលបន្តពៀរ ដែលជាវិសភាគគ្នា ។

ច្រើនបទថា **មនុស្សិត្ថិំ ភិក្ខុនោ សន្តិកេ អានេត្វា** : **នាំយកមនុស្សស្រី (១នាក់) មកកាន់សំណាក់ភិក្ខុ (១រូប)** សេចក្តីថា ពួកភិក្ខុដែលមានសេចក្តីប្រាថ្នានឹងធ្វើឱ្យភិក្ខុនោះវិនាស យកអាមិសលួងលោម ឬនិយាយដោយអំណាចមិត្តសន្ថវៈថា លោកចូរធ្វើកិច្ចនេះរបស់ពួកយើងចុះ ហើយនាំយកស្រីមនុស្សខ្លះអ្នកមកកាន់ឱកាសដែលជាទីនៅរបស់ភិក្ខុនោះ ក្នុងវេលារាត្រី ។

ច្រើនបទថា **វច្ចមគ្គេន អង្គជាតំ អភិនិសីទេន្តិ** : **ហើយបញ្ចូលអង្គជាត (ភិក្ខុនោះ) ទៅតាមទ្វារវច្ចមគ្គ (មនុស្សស្រីនោះ)** សេចក្តីថា ចាប់ភិក្ខុនោះត្រង់អវយវៈ មានដៃ ជើង និងសីសៈជាដើមយ៉ាងមាំ គឺ មិនឱ្យរើបំរាស់បាន ហើយ ឱ្យមនុស្សស្រីអង្គុយសង្កត់ គឺ ឱ្យប្រកបអង្គជាតិរបស់ភិក្ខុនោះ ដោយវច្ចមគ្គរបស់ស្រី ។

ក្នុងពាក្យថា សោ ចេ បវេសនំ សាទិយតិ បវិដ្ឋំ សាទិយតិ ឋិតំ សាទិយ តិឧទ្ធរណំ សាទិយតិ : បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូល ត្រេកអរនឹងអង្គជាតដែលចូលទៅស៊ប់ហើយ ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ មានវិនិច្ឆ័យដូច្នេះ ៖

សោ ចេ បវេសនំ សាទិយតិ : បើភិក្ខុនោះត្រេកអរនឹងអង្គជាតដែលកំពុងចូលក្តី គឺ ប្រសិនបើភិក្ខុនោះត្រេកអរគឺ ព្រមទទួលការស៊ក អង្គជាតិរបស់ខ្លួនចូលទៅក្នុងវច្ចមគ្គ (របស់ស្រី)គឺ លោកឱ្យសេវនចិត្ត ប្រាកដឡើងក្នុងខណៈនោះ ត្រេកអរ គឺ ព្រមទទួលការចូលទៅហើយ ។

បវិដ្ឋំ សាទិយតិ : ត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី គឺ ក្នុងវេលាដែលចូលទៅហើយ លោកក៏ឱ្យសេវនចិត្តប្រាកដឡើងទាំងត្រេកអរ គឺ ព្រមទទួលការឈប់ ។

ឋិតំ សាទិយ : ត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វារមគ្គនោះ) ក្តី គឺ ក្នុងវេលាដែលអង្គជាតិដល់ទី លោកក៏ឱ្យសេវនចិត្ត ប្រាកដឡើងក្នុងវេលាដែលបង្ហូរទឹកសុក្កៈ ទាំងត្រេកអរ គឺ ព្រមទទួលការដកចេញ ។

តិឧទ្ធរណំ សាទិយតិ : ត្រេកអរនឹងអង្គជាតដែលបន្ថយចេញ

ក្តី គឺ ក្នុងវេលាដែលនាំចេញ លោកក៏ឱ្យបដិសេវនចិត្តប្រាកដឡើង ។

ភិក្ខុកាលត្រេកអរក្នុងឋាន ៤ យ៉ាង ដូចអធិប្បាយមកហើយនេះ រមែងមិនបានដើម្បីនឹងនិយាយ (កែខ្លួន) ថា ដែលសមណៈជាអ្នកបន្តពៀរទាំងឡាយ ធ្វើកម្មនេះដល់យើងហើយ, រមែងត្រូវអាបត្តិបារាជិកតែម្តង ។ ឧទាហរណ៍ថា ភិក្ខុកាលត្រេកអរឋានទាំង ៤ នេះ រមែងត្រូវអាបត្តិ យ៉ាងណា, លោកមិនត្រេកអរឋានណាមួយដែលជាឋានដំបូងតែត្រេកអរ ៣ ឋានក្តី មិនត្រេកអរ ២ ឋាន តែត្រេកអរ ២ ឋានក្តី មិនត្រេកអរ ៣ ឋាន តែត្រេកអរតែមួយឋានក្តី រមែងត្រូវអាបត្តិដូចគ្នាដូច្នោះ ។

ចំណែកភិក្ខុ កាលមិនត្រេកអរដោយប្រការទាំងពួង សម្គាល់អង្គជាតិដូចចូលទៅកាន់មាត់អាសិរពិស ឬចូលទៅត្រង់រណ្តៅរងើកភ្លើង មិនត្រូវអាបត្តិទេ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "បើភិក្ខុមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅក្តី មិនត្រេកអរនឹងអង្គជាតដែលចូលស៊ប់ទៅហើយក្តី មិនត្រេកអរនឹងអង្គជាតដែលកំពុងស្ថិតនៅ (ក្នុងទ្វាមគ្គនោះ)ក្តី មិនត្រេកអរនឹងអង្គជាតដែលបន្ទយចេញក្តី មិនត្រូវអាបត្តិឡើយ" ។

ពិតមែន ព្រះមានព្រះភាគ កាលនឹងទ្រង់រក្សាបុគ្គល អ្នកចម្រើនវិបស្សនាបែបនេះ ៗ មិនមានសេចក្ដីហួងហែងក្នុងកាយនិងជីវិត សម្លឹងឃើញអាយតនៈទាំងពួង ដូចត្រូវភ្លើង ១១ កង ឱ្យឆេះសន្ធោសន្ធៅហើយ ទាំងសម្លឹងឃើញបញ្ចកាមគុណ ដូចជាពេជ្ឈឃាតដែលងាជាវឡើងហើយ ដូច្នោះ និងកាលទ្រង់ធ្វើការកម្ចាត់មនោរថនៃពួកដែលជាសត្រូវរបស់បុគ្គលអ្នកមិនត្រេកអរនោះ ទើបទ្រង់នាំចតុក្កៈមានជាដើមថា "ភិក្ខុដែលមិនត្រេកអរនឹងអង្គជាតដែលកំពុងចូលទៅ" នេះមកតាំងទុកដូច្នេះឯង ។

ចប់ ចតុក្កៈដំបូង

## ចតុក្កៈ ២៦៩ ដ៏សេស

លុះព្រះមានព្រះភាគសម្ដែងបឋមចតុក្កៈយ៉ាងនោះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងចតុក្កៈសូម្បីយ៉ាងដទៃ ដោយអំណាចមគ្គទាំង ៣ ពួកនោះ ព្រោះហេតុដែលពួកភិក្ខុជាសត្រូវនាំស្រីមកហើយ មិនមែនឱ្យអង្គុយសង្កត់តាមទ្វារវច្ចមគ្គតែម្យ៉ាងប៉ុណ្ណោះទេ តាមការពិត ឱ្យអង្គុយសង្កត់តាមទ្វារបស្សាវមគ្គខ្លះ តាមទ្វារមាត់ខ្លះ, និងសូម្បីកាលភិក្ខុដែលជាសត្រូវនាំស្រីមក ពួកខ្លះនាំស្រីដែលភ្ញាក់ដឹងខ្លួនមក ពួកខ្លះនាំស្រីដែល

កំពុងដេកលក់មក ពួកខ្លះនាំស្រីដែលស្រវឹងមក ពួកខ្លះនាំស្រីឆ្កួតមក ពួកខ្លះនាំស្រីដែលខ្វបស្មារតីមក, អធិប្បាយថា នាំស្រីដែលបញ្ជូនចិត្តទៅក្នុងអារម្មណ៍ដទៃ គឺ អ្នករវើរវាយមក, ពួកខ្លះនាំស្រីដែលស្លាប់ហើយមានទ្វារមគ្គសត្វមិនទាន់ស៊ីមក, អធិប្បាយថា នាំស្រីស្លាប់ដែលមាននិមិត្ត ដែលសត្វទាំងឡាយមានចចកជាដើមមិនទាន់បានស៊ីមក, ពួកខ្លះនាំស្រីស្លាប់ហើយ មានទ្វារមគ្គសត្វមិនទាន់ស៊ីដោយច្រើនមក; ស្រីស្លាប់ដែលឈ្មោះថា សត្វមិនទាន់ បានខាំស៊ីដោយច្រើន គឺ ត្រង់វច្ចមគ្គក្តី បស្សាវមគ្គក្តី មាត់ក្តី ដែលជានិមិត្ត មាន ឱកាសដែលសត្វមិនទាន់បានខាំស៊ីដោយច្រើនជាង; ពួកខ្លះនាំស្រីស្លាប់ដែលសត្វខាំស៊ីហើយ ដោយច្រើនមក; ស្រីស្លាប់ដែលឈ្មោះថា សត្វខាំស៊ីហើយដោយច្រើន គឺ អវយវៈ ត្រង់និមិត្តមានវច្ចមគ្គជាដើមត្រូវសត្វខាំស៊ីជាចំណែកច្រើន ដែលនៅមិនបានខាំស៊ី មានតិច; និងមិនមែននាំមកនូវនុស្សស្រីមតែម្យ៉ាងប៉ុណ្ណោះទេ តាមការពិត នាំអមនុស្សស្រីខ្លះ សត្វតិរច្ឆានញីខ្លះមក; ទាំងមិនមែនត្រឹមតែនាំមកចំពោះស្រី មានប្រការដូចពោលហើយម្យ៉ាងទេ; គឺនាំឧភតោព្យញ្ជនកខ្លះ បណ្ឌកៈខ្លះ មនុស្សប្រុសខ្លះមក; ទើបត្រាស់ពាក្យជាដើមថា "ពួកភិក្ខុជាសត្រូវនាំយកមនុស្សស្រី ដែលនៅភ្ញាក់ដឹងខ្លួនមក" ។

## មគ្គរបស់មនុស្សស្រីមាន ២៧ ចតុក្កៈ

ក្នុងពាក្យថា **ជាគរន្តិ** : ដែលនៅភ្ញាក់ដឹងខ្លួន ជាដើមនោះ ដើម្បីកុំឱ្យប្រឡំក្នុងព្រះបាលីបណ្ឌិតគប្បីជ្រាបចតុក្កៈដូចដែលពោលហើយដោយការគណនា ដូចដែលនឹងពោលតទៅនេះ ៖

ដោយអំណាចមគ្គទាំង ៣ របស់មនុស្សស្រីមាន ២៧ ចតុក្កៈ គឺ សុទ្ធិចតុក្កៈ (ចតុក្កៈពោលអំពីមគ្គសុទ្ធ ៗ) ៣, ជាគរន្តិចតុក្កៈ (ចតុក្កៈពោលអំពីស្រីដែលភ្ញាក់ ដឹងខ្លួន) ៣, សុត្តចតុក្កៈ (ចតុក្កៈពោលអំពីស្រីដែលដេកលក់) ៣, មត្តចតុក្កៈ (ចតុក្កៈពោលអំពីស្រីដែលស្រវឹង) ៣, ឧម្មត្តចតុក្កៈ (ចតុក្កៈពោលអំពីស្រីឆ្កួត) ៣, បមត្តចតុក្កៈ (ចតុក្កៈពោលអំពីស្រីដែលប្រមាទ) ៣, មតអក្ខាយិតចតុក្កៈ (ចតុក្កៈពោលអំពីស្រីស្លាប់ដែលសត្វមិនទាន់បានខាំស៊ី) ៣, យេភុយ្យេនអក្ខាយិតចតុក្កៈ (ចតុក្កៈពោលដោយនិមិត្តដែលសត្វមិនទាន់បានខាំស៊ីដោយច្រើន) ៣, យេភុយ្យេនខាយិតចតុក្កៈ (ចតុក្កៈថាដោយនិមិត្តដែលសត្វខាំស៊ីដោយច្រើន) ៣ ។

ដោយអំណាចមគ្គទាំង ៣ របស់អមនុស្សស្រី ក៏មាន ២៧ ចតុក្កៈដូចគ្នា, របស់សត្វតិរច្ឆានញី ក៏មាន ២៧ ចតុក្កៈដូចគ្នា; ក្នុងឥត្ថីវារៈ មាន ៨១ ចតុក្កៈ ដោយប្រការដូច្នេះ ។ និងក្នុងឧភតោ

ព្យញ្ជនកវារៈ ក៏មាន ៨១ ចតុក្កៈដូចក្នុងឥត្ថីវារៈ ។

ចំណែកក្នុងបណ្ឌកបុរិសវារៈ ដោយអំណាចមគ្គទាំង ២ ទើបមានចតុក្កៈ ពួកនីមួយ ៗ ៥៤ ចតុក្កៈ រួមសូម្បីទាំងអស់ មាន ២៧០ ចតុក្កៈ ដោយប្រការដូច្នេះ ។ ចតុក្កៈទាំងនោះ មានសេចក្ដីច្បាស់លាស់តែម្ដង ។

ក៏គ្រប់ ៗវារៈ បណ្ដាឋានៈទាំងនោះ ក្នុងឋានៈនេះថា ស្រីស្លាប់ដែលសត្វមិនបានខាំស៊ីដោយច្រើន និងដែលសត្វខាំស៊ីហើយដោយច្រើន មានវិនិច្ឆ័យដូច្នេះ ៖

## រឿងព្រះវិន័យធរ ២ រូប

បានឮថា ក្នុងកោះតម្ពបណ្ណិទ្វីបមានព្រះវិន័យធរពីររូប ជាព្រះថេរៈរួមអាចារ្យជាមួយគ្នា គឺ ព្រះឧបតិស្សត្ថេរ ១ ព្រះបុស្សទេវត្ថេរ ១ ។ ព្រះថេរៈទាំងពីររូបនោះ ក្នុងមានមហាភ័យ បានបរិហាររក្សាព្រះវិន័យបិដកទុក ។ បណ្ដាព្រះថេរៈទាំង ២ រូបនោះ ព្រះឧបតិស្សត្ថេរជាអ្នកឆ្លាតជាង ។ សូម្បីព្រះឧបតិស្សត្ថេរនោះ មានអន្តេវាសិកនៅ ២ រូប គឺ ព្រះមហាបទុមត្ថេរ ១ ព្រះមហាសុមត្ថេរ ១, បណ្ដាព្រះថេរៈ ២ រូប

នោះ ព្រះមហាសុមត្ថេរ បានស្តាប់ព្រះវិន័យបិដក ៩ ដង ។ ព្រះមហាបទុមត្ថេរ បានស្តាប់ដល់ ១៨ ដង គឺ បានស្តាប់រួមនឹងព្រះមហាសុមត្ថេរនោះ ៩ ដង និងបានស្តាប់ចំពោះម្នាក់ឯងផ្សេងដទៃទៀត ៩ ដង ។ បណ្តាព្រះថេរៈទាំង ២ រូបនោះ ព្រះមហាបទុមត្ថេរនេះឯង ជាអ្នកឆ្លាតជាង ។ បណ្តាលោកទាំង ២ រូបនោះព្រះមហាសុមត្ថេរ កាលស្តាប់ព្រះវិន័យបិដកដល់ ៩ ដងហើយ ក៏លះបោលអាចារ្យ បានទៅកាន់ទន្លេគង្គាឯត្រើយនាយ ។

គ្រានោះ ព្រះមហាបទុមត្ថេរ ពោលថា ព្រះវិន័យធរអ្នកលះបោលអាចារ្យដែលនៅមានជីវិតតែម្តង សម្គាល់ភាពដែលខ្លួនគប្បីស្នាក់នៅក្នុងទីដទៃ នេះជាអ្នកខ្ជិលក្លាពិតហ្ន៎ កាលអាចារ្យនៅមានជីវិត សូម្បីព្រះថេរៈរៀនព្រះវិន័យបិដក និងអដ្ឋកថា ច្រើនលើកហើយក៏ដោយ ក៏មិនគួរបោះបោលទេ គួរស្តាប់ជានិច្ចកាល គួរស្វាធ្យាយរាល់កន្លះឆ្នាំម្តង ។ ក្នុងកាលនៃភិក្ខុទាំងឡាយ អ្នកធ្ងន់ក្នុងព្រះវិន័យយ៉ាងនោះ ថ្ងៃមួយ ព្រះឧបតិស្សត្ថេរអង្គុយពណ៌នាបាលីប្រទេសនេះក្នុងបឋមបារាជិកសិក្ខាបទ ដល់ពួកអន្តេវាសិក ៥០០ រូប ដែលមានព្រះមហាបទុមត្ថេរជាប្រមុខ ។

## រឿងអន្តេវាសិកសួរបញ្ហាវិន័យព្រះថេរៈ

ពួកអន្ទេវាសិក សួរព្រះឧបតិស្សត្ថេរនោះថា បពិត្រលោកដ៏ចម្រើន ក្នុងសាកសពដែលសត្វមិនទាន់បានខាំស៊ីដោយច្រើន ជាបារាជិក ។ ក្នុងសាកសពដែលសត្វខាំស៊ីដោយច្រើន ជាថុល្លច្ច័យ, ក្នុងសាកសពដែលសត្វខាំស៊ីពាក់កណ្តាល តើជាអាបត្តិអ្វី ?

ព្រះថេរៈ ពោលថា អាវុសោ ធម្មតាថា ព្រះពុទ្ធទាំងឡាយ កាលនឹងទ្រង់បញ្ញត្តិបារាជិក ទ្រង់មិនបញ្ញត្តិឱ្យមានចំណែកទុកនៅសល់ទេ ទ្រង់រួបរួមយកខេត្តបារាជិកទាំងអស់មិនឱ្យមានចំណែកនៅសល់ឡើយ ទ្រង់កាត់ចន្លោះមកហើយបញ្ញត្តិបារាជិកក្នុងវត្ថុនៃបារាជិកតែម្តង, ពិតមែនសិក្ខាបទនេះ ជាលោកវជ្ជៈ មិនមែនជាបណ្ណត្តិវជ្ជៈ ; ព្រោះហេតុនោះបើថា ក្នុងសាកសពដែលសត្វខាំស៊ីពាក់កណ្តាលគប្បីជាបារាជិកសោត, ព្រះសម្មាសម្ពុទ្ធ ក៏គប្បីទ្រង់បញ្ញត្តិបារាជិកទុក, តែក្នុងសាកសពដែលសត្វខាំស៊ីពាក់កណ្តាលនេះ ឆាយាបារាជិកមិនប្រាកដ, ប្រាកដតែចំពោះថុល្លច្ច័យប៉ុណ្ណោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលទ្រង់បញ្ញត្តិបារាជិកទុកក្នុងសរីរៈដែលស្លាប់ហើយ ក៏ទ្រង់តាំងបារាជិកទុកក្នុងសាកសពដែលសត្វមិនទាន់បានខាំស៊ីដោយច្រើន, តពីសាកសពដែលសត្វមិនទាន់បានខាំស៊ីដោយច្រើននោះទៅ ទ្រង់បញ្ញត្តិថុល្លច្ច័យដើម្បីសម្តែងថា មិនមាន

បារាជិក ទើបទ្រង់តាំងថុល្លច្ច័យទុក ព្រោះសាកសពដែលសត្វខាំស៊ីហើយដោយច្រើន, បន្ទាប់ពីសាកសពដែលសត្វខាំស៊ីហើយដោយច្រើននោះទៅ គប្បីជ្រាបថា ដើម្បីសម្តែងថា មិនមានថុល្លច្ច័យ ។

ដែលឈ្មោះថា សាកសពដែលសត្វខាំស៊ីនិងមិនទាន់បានខាំស៊ីនោះ គួរយល់ចំពោះក្នុងសរីរៈដែលស្លាប់ហើយប៉ុណ្ណោះ មិនគួរយល់ក្នុងសរីរៈដែលនៅរស់ ។ ព្រោះថា ក្នុងសរីរៈដែលនៅរស់ កាលសាច់ឬសរសៃ សូម្បីមានប្រមាណប៉ុនខ្នងក្រចកនៅមាន រមែងជាបារាជិកតែម្តង ។ សូម្បីបើថា និមិត្តត្រូវសត្វខាំស៊ីហើយដោយប្រការទាំងពួងសម្បុរស្បែកមិនមាន, តែសណ្ឋាននិមិត្តនៅប្រាកដ, សម្រេចការសេក (អង្គជាតិ) ចូលទៅ, ជាបារាជិកដូចគ្នា ។ ក៏កាលនិមិត្តដែលត្រូវសត្វខាំស៊ីទាំងអស់ចេញ មិនឱ្យមានសណ្ឋាននិមិត្តនៅសល់ឡើយ ពន្លះជៀរចេញដោយជុំវិញ រមែងជាថុល្លច្ច័យ ដោយអំណាចការសង្គ្រោះថាជាដំបៅ ។ កាលភិក្ខុព្យាយាមត្រង់ដុំសាច់ ដែលធ្លាក់ចេញពីនិមិត្តនោះជាទុក្កដ ។

ចំណែកក្នុងសរីរៈដែលស្លាប់ហើយ បើថា សរីរៈទាំងអស់ ត្រូវសត្វខាំស៊ីហើយខ្លះ, មិនទាន់បានខាំស៊ីខ្លះ, តែមគ្គទាំង ៣ សត្វមិនទាន់បានខាំស៊ី, កាលភិក្ខុព្យាយាមក្នុងមគ្គទាំង ៣ នោះ រមែងជាបារាជិក ។

ក្នុងសរីរៈដែលសត្វមិនទាន់បានខាំស៊ីដោយច្រើនជាបារាជិកតែម្តង, ក្នុងសរីរៈដែលសត្វខាំស៊ីពាក់កណ្តាលនិងដែលខាំស៊ីហើយដោយច្រើន ជាថុល្លច្ច័យ ។ កាលភិក្ខុស៊ិកអង្គជាតិចូលទៅត្រង់ភ្នែក រន្ធច្រមុះ រន្ធត្រចៀក ប្រហោងពោះវៀន និងស្រោមអង្គជាតិ ឬត្រង់មុខដំបៅដែលត្រូវវះដោយសស្ត្រាជាដើម ក្នុងសរីរៈដែលនៅរស់របស់មនុស្សទាំងឡាយ ដោយសេចក្តីតម្រេកក្នុងមេថុន សូម្បីត្រឹមតែមួយគ្រាប់ល្ងក៏ជាថុល្លច្ច័យដូចគ្នា ។ កាលស៊ិកចូលទៅក្នុងអវយវៈទាំងឡាយមានក្លៀកជាដើមក្នុងសរីរៈដ៏សេស ជា ទុក្កដ ។ កាលស៊ិកចូលទៅក្នុងសាកសពត្រង់សរីរៈដែលនៅស្រស់ ក្នុងខេត្តនៃបារាជិក ជាបារាជិក, ក្នុងខេត្រដែននៃថុល្លច្ច័យ ជាថុល្លច្ច័យ, ក្នុងខេត្រដែននៃទុក្កដ ជាទុក្កដ ។ តែក្នុងកាលណា សរីរៈជារបស់ហើមប៉ោង រលេះរលួយ មានរុយក្បាលខៀវចោមរោម មានពួកដង្កូវរុលត្បុលចូល អ្នកណា ៗ មិនអាចសូម្បីនឹងចូលទៅជិតបាន ព្រោះជាសាកសពដែលមានខ្ទុះហូរចេញទូទៅចាកមុខដំបៅទាំង ៩ កន្លែង, ក្នុងកាលនោះ សរីរៈនោះ រមែងលះវត្ថុនៃបារាជិក និងវត្ថុនៃថុល្លច្ច័យចេញ, កាលភិក្ខុព្យាយាមក្នុងសរីរៈដូច្នោះកន្លែងណាមួយ ជាទុក្កដតែម្យ៉ាង ។ កាលព្យាយាមក្នុងច្រមុះរបស់សត្វតិរច្ឆានទាំងឡាយ (ដែលស្លាប់ហើយ) មានដំរី សេះ គោ ពពែ អូដ្ឋ

និងក្របីជាដើម ជាថុល្លច្ច័យ ។ កាលព្យាយាមក្នុងប្រហោងពោះវៀននិងស្រោមអង្គជាតិ ជាថុល្លច្ច័យដូចគ្នា ។ កាលព្យាយាមក្នុងភ្នែក ត្រចៀក និងមុខដំបៅរបស់សត្វតិរច្ឆានសូម្បីទាំងអស់ (ដែលស្លាប់ហើយ) ជាទុក្កដ, សូម្បីក្នុងសរីរៈដ៏សេសនេះ ក៏ជាទុក្កដដូចគ្នា ។ កាលព្យាយាមក្នុងសរីរៈដែលនៅស្រស់របស់សត្វតិរច្ឆាន ដែលស្លាប់ហើយ ក្នុងខេត្តដែននៃបារាជិក ជាបារាជិក, ក្នុងខេត្តដែននៃថុល្លច្ច័យ ជាថុល្លច្ច័យ, ក្នុងខេត្តដែននៃទុក្កដ ជាទុក្កដ ។ កាលព្យាយាមក្នុងសាកសពដែលហើបប៉ោង ស្អុយរលួយ ជាទុក្កដ ក្នុងទីគ្រប់កន្លែងដោយន័យដូចពោលហើយក្នុងខាងដើមនុ៎ះឯង ។ ភិក្ខុកាលមិនបានស៊ិកចូលប្រហោងពោះវៀន និងស្រោមអង្គជាតិរបស់បុរសដែលនៅរស់ចូលទៅដោយសេចក្តីតម្រេកក្នុងកាលស្ទាបអង្អែលកាយ ឬដោយសេចក្តីតម្រេកក្នុងមេថុន តែធ្វើនិមិត្តពាល់ត្រូវត្រង់និមិត្ត ជាទុក្កដ ។ កាលមិនបានស៊ិក (អង្គជាតិរបស់ខ្លួន) ចូលទៅក្នុងនិមិត្តរបស់ស្រី ដោយសេចក្តីតម្រេកក្នុងមេថុន តែធ្វើនិមិត្តនឹងនិមិត្តពាល់ត្រូវគ្នា ជាថុល្លច្ច័យ ។

ចំណែកក្នុងមហាអដ្ឋកថា លោកពោលថា ភិក្ខុពាល់ត្រូវនិមិត្តរបស់ស្រីដោយមាត់ ដោយសេចក្តីតម្រេកក្នុងមេថុន ជាថុល្លច្ច័យ ។ ព្រោះសេចក្តីមិនប្លែកគ្នានៃរឿងដែលកើតឡើងនេះថា "ពួកឆព្វគ្គិយភិក្ខុ

កាលមេគោទាំងឡាយកំពុងតែហែលឆ្លងទឹកស្ទឹងអចិរវតី ក៏ចាប់ស្នែងខ្លះ ចាប់ស្លឹកត្រចៀកខ្លះ ចាប់កន្ទុយខ្លះ ឡើងជិះខ្នងខ្លះ មានចិត្តតម្រេក ក៏ស្ទាបអង្គជាតគោខ្លះ"[១] ដូច្នេះ ព្រះមានព្រះភាគទើបត្រាស់ ក្នុងចម្មខន្ធកៈថា "ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត ភិក្ខុមិនត្រូវមានចិត្តត្រេកអរ ពាល់អង្គជាត មេគោឡើយ ភិក្ខុណាពាល់, ត្រូវអាបត្តិថុល្លច្ច័យ"[២] ។ បណ្ឌិតគួរប្រៀបធៀបពាក្យនោះ សូម្បីទាំងអស់មើលហើយ កាន់យកដោយអាការដែលមិនខុសចុះ ។

ក៏ពាក្យនោះ មិនខុសយ៉ាងណា ? មិនខុសយ៉ាងនេះ គឺ ៖

---

(១) វិន. មហា. ៧. ៦១/១៩២ ។ ២. វិន. មហា. ៧. ៦១/១៩៣ ។

បានឮថា ក្នុងពាក្យដែលលោកពោលទុកក្នុងមហាអដ្ឋកថា មុនថា ពាល់ត្រូវដោយមាត់ ដោយសេចក្តីតម្រេកក្នុងមេថុន មាត់គឺ និមិត្ត លោកប្រាថ្នាថា មាត់ ។ ក៏សេចក្តីនេះឯង បណ្ឌិតគប្បីជ្រាបថា ជាសេចក្តីអធិប្បាយក្នុងមហាអដ្ឋកថានោះ សូម្បីព្រោះលោកពោលថា ដោយសេចក្តីតម្រេកក្នុងមេថុន ។ ពិតមែន សេចក្តីព្យាយាមក្នុងមេថុន ដោយមាត់ធម្មតាក្នុងនិមិត្តរបស់ស្រីមិនមានទេ ។ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថា ព្រះមានព្រះភាគទ្រង់សំដៅយកភិក្ខុឆព្វគ្គិយអ្នកជិះខ្នង

(មេគោ) ហើយពាល់ត្រូវអង្គជាតិគោ ដោយអង្គជាតិ (របស់ខ្លួន) ដោយសេចក្ដីតម្រេកក្នុងមេថុន ទើបត្រាស់ថុល្លច្ច័យទុកសូម្បីក្នុងខន្ធកៈ ។ ពិតមែន កាលពាល់ត្រូវដោយប្រាថ្នាយ៉ាងដទៃ ជាទុក្កដ ។

ចំណែកអាចារ្យពួកខ្លះពោលទុកថា សូម្បីក្នុងខន្ធកៈ ព្រះមានព្រះភាគទ្រង់សំដៅយកអាការពាល់ត្រូវដោយមាត់ធម្មតា ទើបត្រាស់ថា ត្រូវអាបត្តិថុល្លច្ច័យ ព្រោះភាពជាកម្មដ៏គ្រោតគ្រាត, សូម្បីក្នុងអដ្ឋកថាលោកក៏កាន់ព្រះសូត្រដែលត្រាស់សំដៅដល់កម្មគ្រោតគ្រាតនោះឯង ទើបពោលថា ភិក្ខុពាល់ត្រូវដោយមាត់ធម្មតា ដោយសេចក្ដីតម្រេកក្នុងមេថុន ជាថុល្លច្ច័យ ដូច្នេះ ។ ព្រោះហេតុនោះ ក្នុងពាក្យវិនិច្ឆ័យទាំងពីរគួរកំណត់ឱ្យល្អហើយកាន់យកតែពាក្យវិនិច្ឆ័យដែលត្រឹមត្រូវជាង ។

តែអ្នកប្រាជ្ញទាំងឡាយ អ្នកដឹងព្រះវិន័យ រមែងសរសើរពាក្យវិនិច្ឆ័យដំបូង ។ ក៏កាលភិក្ខុដែលពាល់ត្រូវនិមិត្តរបស់ស្រី ដោយមាត់ធម្មតាក្ដី ដោយមាត់គឺនិមិត្តក្ដី ដោយសេចក្ដីតម្រេកក្នុងការស្ទាបអង្អែលកាយ ជាសង្ឃាទិសេស ។ កាលពាល់ត្រូវបស្សាវមគ្គរបស់សត្វតិរច្ឆានញី ដោយមាត់គឺ និមិត្តជាថុល្លច្ច័យ ដោយន័យដូចដែលពោលហើយនុ៎ះឯង កាលពាល់ត្រូវដោយសេចក្ដីតម្រេកក្នុងការស្ទាបអង្អែលកាយ ជាទុក្កដ ដូច្នេះឯង ។

បតុក្កៈ ២៦៩ ដ៏សេស ចប់

## អង្គជាតមានស្រោម និងមិនមានស្រោម

[៤១] ព្រះមានព្រះភាគ កាលទ្រង់នាំចតុក្កៈ ២៧០ មកហើយ ដើម្បីរក្សាភិក្ខុដែលបដិបត្តិ ដោយប្រការយ៉ាងនេះ ឥឡូវនេះ ទ្រង់បានទតឃើញថា ភិក្ខុបាបពួកណាក្នុងអនាគត នឹងក្លែងអាងលេសថា ឧបាទិន្នកៈ (គឺកាយិន្ទ្រិយដែលមានជីវិត)ណាមួយ ដែលឧបាទិន្នកៈ (គឺកាយិន្ទ្រិយដែលមានជីវិត) នឹងពាល់ត្រូវអង្គជាតិដែលទ្រប់ហើយនេះ មិនមានទេ, ក្នុងការដែលមិនពាល់ត្រូវនេះនឹងមានទោសយ៉ាងណា ?, ភិក្ខុបាបទាំងនោះ នឹងមិនមានទីពឹងក្នុងសាសនាយ៉ាងនេះ ដូច្នេះហើយ កាលនឹងទ្រង់សម្តែងចែកបណ្តាចតុក្កៈទាំង ២៧០ នោះ តែមួយចតុក្កៈ ដោយសេចក្តីផ្សេងគ្នានៃអង្គជាតិដែលទ្រាប់ហើយជាដើម ៤យ៉ាង ទើបត្រាស់ពាក្យថា ពួកភិក្ខុដែលជាសត្រូវ នាំមនុស្សស្រីមកក្នុងសំណាក់របស់ភិក្ខុ ហើយឱ្យអង្គុយសង្កត់អង្គជាតតាមទ្វារវច្ចមគ្គ បស្សាវមគ្គ មុខមគ្គរបស់ស្រីដែលមានស្រោមទ្រនាប់ របស់ភិក្ខុមិនមានស្រោមទ្រនាប់ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ក្នុងពីរបទជាដើមថា សន្ថតាយ អសន្ថតស្ស : ដែលគ្មានស្រោមទ្រនាប់(តាមទ្វារ) ដែលមានស្រោមទ្រនាប់ គប្បី

ជ្រាបយោជនាដោយន័យនេះថា ឱ្យអង្គុយសង្កត់អង្គជាតិរបស់ភិក្ខុដែលមិនមានស្រោមទ្រនាប់ ដោយវច្ចមគ្គ បស្សាវមគ្គ មុខមគ្គ របស់ស្រីដែលមានស្រោមទ្រនាប់ ។ បណ្ដាមគ្គទាំង ៣ មគ្គណាមួយរបស់ស្រី ដែលឈ្មោះថា មានស្រោមទ្រនាប់ ក្នុងបណ្ដាមគ្គដែលមានស្រោមទ្រនាប់និងមិនមានស្រោមទ្រនាប់ទាំងនោះ បានដល់ មគ្គដែលគេយកសំពត់ឬស្លឹកឈើសំបកធ្មៃឬស្បែក ឬបន្ទះសំណនិងសង្កសីជាដើម យ៉ាងណាមួយ រុំឬស៊កចូលទៅពាក់ទុកក្នុងខាងក្នុង ។ អង្គជាតិរបស់ប្រុសដែលឈ្មោះថា មានស្រោមទ្រនាប់នោះ បានដល់ អង្គជាតិដែលគេយកបណ្ដាវត្ថុយ៉ាងណាមួយ មានសំពត់ជាដើមទាំងនោះឯងមកពាក់ទុក ។

ក្នុងមគ្គទាំង៣នោះ អនុបាទិន្នកៈ (គឺ កាយិន្ទ្រិយដែលមិនមានចិត្តគ្រប់គ្រង )និងឧបាទិន្នកៈ (គឺ កាយិន្ទ្រិយដែលមានចិត្តគ្រប់គ្រង ) ប៉ះខ្ទប់គ្នាក៏ដោយ ឧបាទិន្នកៈនិងអនុបាទិន្នកៈប៉ះខ្ទប់គ្នាក៏ដោយ អនុបាទិន្នកៈនិងអនុបាទិន្នកៈប៉ះខ្ទប់គ្នាឯងក៏ដោយ ឧបាទិន្នកៈនិងឧបាទិន្នកៈប៉ះខ្ទប់គ្នាដោយខ្លួនឯងក៏ដោយ បើអង្គជាតិចូលទៅដល់ប្រទេស ដែលអាចារ្យទាំងឡាយពោលថា កាលអង្គជាតិចូលទៅហើយជាខេត្តនៃបារាជិក ដូច្នេះ សោត កាលភិក្ខុត្រេកអរគ្រប់ ៗ វារៈ ក្នុងខេត្តនៃបារាជិក ជាបារាជិក ក្នុងខេត្តនៃថុល្លច្ច័យ ជាថុល្លច្ច័យ ក្នុងខេត្តនៃទុក្កដ ជាទុក្កដតែម្ដង ។

បើនិមិត្តស្រីគេពាក់ស្រោមទុក កាលភិក្ខុប៉ះខ្ទប់ស្រោម ជាទុក្កដ ។ បើនិមិត្តរបស់ប្រុសគេពាក់ស្រោមទុក កាលភិក្ខុសិកស្រោមចូលទៅជាទុក្កដ ។ បើនិមិត្តទាំងពីរគេពាក់ស្រោមទុក កាលភិក្ខុប៉ះខ្ទប់ស្រោមនឹងស្រោម ជាទុក្កដ ។

បើគេយកបណ្តាវត្ថុមានបំពង់ឫស្សី និងបបុសជាដើមណា ៗ ពាក់ទុកក្នុងនិមិត្តរបស់ស្រី សូម្បីបើភិក្ខុសិក (អង្គជាត) ចូលទៅត្រូវចំណែកខាងក្រោមនៃវត្ថុដែលពាក់ទុកនោះ ត្រឹមតែមួយគ្រាប់ល្ង ជាបារាជិក បើសិកចូលទៅត្រូវចំណែកខាងលើក្តី ត្រូវម្ខាង ៗ បណ្តាខាងទាំងពីរក្តី ជាបារាជិក កាលសិកចូលទៅមិនឱ្យត្រូវខាងទាំង ៤ សូម្បីបើត្រូវផ្ទៃខាងក្នុងនៃឫស្សីនិងបបុសជាដើមនោះ ក៏ជាបារាជិក ។

ក៏បើថា សិកចូលទៅមិនឱ្យត្រូវទីខាងឬត្រង់ផ្ទៃ ឱ្យតាំងនៅក្នុងអាកាសតែម្យ៉ាងហើយនាំចេញ ជាទុក្កដ ពាល់ត្រូវស្រោមក្នុងខាងក្រៅជាទុក្កដដូចគ្នា ។ បណ្ឌិតគប្បីជ្រាបលក្ខណៈក្នុងគ្រប់ ៗ មគ្គមានវច្ចមគ្គជាដើម ដូចយ៉ាងដែលលោកពោលទុកក្នុងនិមិត្តស្រីដូច្នោះឯង ។

ចប់ សន្ថតចតុក្កៈបភេទកថា

[៤២-៤៣] ព្រះមានព្រះភាគ គ្រាត្រាស់ប្រភេទនៃសន្ថតចតុក្កៈ

យ៉ាងនោះហើយឥឡូវនេះ កាលទឹងទ្រង់សម្តែងប្រភេទនោះ (ដដែលទៀត) ព្រោះហេតុដែលពួកភិក្ខុជាសត្រូវ មិនមែនទឹងនាំជន មានមនុស្សស្រីជាដើមមកក្នុងសំណាក់របស់ភិក្ខុតែម្យ៉ាងទេ តាមការពិត នៅនាំសូម្បីភិក្ខុមកក្នុងសំណាក់របស់មនុស្សស្រីជាដើមទាំងនោះ ទើបទ្រង់នាំចតុក្កៈទាំងអស់នោះ មកសម្តែងដដែលទៀត ដោយន័យមានជាដើមថា ពួកភិក្ខុដែលជាសត្រូវនាំភិក្ខុមកក្នុងសំណាក់របស់មនុស្សស្រីដូច្នេះ ។ ក្នុងចតុក្កៈទាំងនោះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយន័យដូចដែលពោលមកហើយនោះឯង ។

*ចប់ការពណ៌នាសេចក្តីផ្សេងនៃចតុក្កៈ ដោយអំណាចភិក្ខុដែលជាសត្រូវ*

## រឿងព្រះរាជានិងចោរអ្នកជាសត្រូវចំពោះភិក្ខុជាដើម

[៨៤] ក៏ព្រោះពួកភិក្ខុដែលជាសត្រូវ រមែងធ្វើដូចដែលពោលមកហើយយ៉ាងនេះឯង សូម្បីឥស្សរជនមានព្រះរាជាដែលជាសត្រូវជាដើម ក៏ទ្រង់ធ្វើ ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទឹងទ្រង់សម្តែងប្រភេទសត្រូវនោះ ទើបត្រាស់ពាក្យថា រាជបច្ចត្ថិកាជាដើម ។

ក្នុងពាក្យថា **រាជបច្ចត្ថិកា :** ពួកស្តេចជាសត្រូវក្តី ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

សត្រូវទាំងឡាយ គឺ ព្រះរាជា ឈ្មោះថា **រាជបច្ចត្ថិកា** (ព្រះរាជាជាសត្រូវ) ក៏ព្រះរាជាទាំងនោះ ទ្រង់នាំមកដោយខ្លួនឯងខ្លះ ឱ្យអ្នកដទៃនាំមកខ្លះ (នូវមនុស្សស្រីជាដើម) គប្បីជ្រាបថា ទ្រង់នាំមកទាំងអស់នោះ ។ សត្រូវទាំងឡាយ គឺ ចោរ ឈ្មោះថា **ចោរបច្ចត្ថិកា** (ចោរដែលជាសត្រូវ) ។

បុរសអ្នកធ្វើការបោកប្រាស់នៅក្នុងក្រុង ដែលខ្វល់ខ្វាយក្នុងការលេងជាប់ដោយមេថុនក្តី អ្នកលេងស្រីនិងអ្នកលេងសុរាជាដើមក្តី ឈ្មោះថា **អ្នកលេង** ។ សត្រូវទាំងឡាយ គឺ អ្នកលេងឈ្មោះថា **ធុត្តបច្ចត្ថិកា** (អ្នកលេងដែលជាសត្រូវ) ។

ហទយៈ លោកហៅថា **គន្ធៈ** ។ ពួកសត្រូវដែលឈ្មោះថា **ឧប្បលគន្ធៈ** ព្រោះអត្ថថា វះយកហទយៈនោះ ។ សត្រូវទាំងឡាយ គឺ អ្នកកាត់បេះដូង ឈ្មោះថា **ឧប្បលគន្ធបច្ចត្ថិកា** ។

## សត្រូវសម្លាប់ភិក្ខុបួងសួងទេវតាដើម្បីសម្រេចការងារ

បានឮថា សត្រូវអ្នកកាត់បេះដូងទាំងនោះ មិនបានរស់នៅដោយកសិកម្ម និងពាណិជ្ជកម្មជាដើមទេ នាំគ្នាធ្វើចោរកម្ម មានការប្លន់អ្នកធ្វើដំណើរជាដើមចិញ្ចឹមបុត្រ និងភរិយា ។ គេទាំងនោះ កាលត្រូវការ

សេចក្ដីសម្រេចនៃការងាររបស់ស្រេន់ចំពោះពួកទេវតា ទើបបានឆ្វៀលយកហទយៈរបស់ពួកមនុស្សទៅ ដើម្បីបួងសួងដល់ទេវតាទាំងនោះ ។ ក៏ពួកមនុស្ស ជាអ្នករកបានលំបាករហូតអស់កាលទាំងពួង ចំណែកពួកភិក្ខុដែលស្នាក់នៅក្នុងព្រៃ រមែងរកបានងាយ ។ គេទាំងនោះចាប់យកភិក្ខុដែលមានសីលហើយ បានពិចារណាថា ឈ្មោះថា ការសម្លាប់អ្នកមានសីល រមែងជារបស់ធ្ងន់ ដើម្បីនឹងទម្លាយសីលភិក្ខុនោះ ឱ្យវិនាសទៅ ទើបនាំមនុស្សស្រីជាដើមមក ឬនាំភិក្ខុនោះទៅក្នុងសំណាក់របស់មនុស្សស្រីជាដើមនោះ ។

ក្នុងរឿងព្រះរាជាដែលជាសត្រូវជាដើមនេះ មានសេចក្ដីប្លែកគ្នាប៉ុណ្ណេះ ។ រឿងដ៏សេសគប្បីជ្រាបដោយន័យដូចដែលពោលហើយនុ៎ះឯង ។ និងគប្បីជ្រាបចតុក្កៈទាំងឡាយក្នុងវារៈសូម្បីទាំង ៤ នេះ ដោយន័យដូចដែលពោលហើយក្នុងភិក្ខុបច្ចត្ថិកាវារៈនុ៎ះឯង ។ តែក្នុងព្រះបាលីព្រះមានព្រះភាគត្រាស់ទុកហើយដោយសង្ខេប ។

ចប់ ប្រភេទនៃចតុក្កៈ ដោយអាការទាំងពួង

## រឿងភិក្ខុសេពមេថុនធម្មតាមទ្វារមគ្គនិងមិនមែនមគ្គ

[៤៥] ឥឡូវនេះ ដើម្បីសេចក្ដីមិនច្រឡំក្នុងពាក្យដែលព្រះមានព្រះ

ភាគត្រាស់ទុកថា កាលភិក្ខុសេពមេថុនធម្មក្នុងមគ្គទាំង៣ របស់មនុស្សស្រីជាដើម ព្រះឧបាលីថេរៈទើបពោលពាក្យថា **មគ្គេន មគ្គំ** ជាដើម ។

បណ្ដាបទទាំងនោះ ពីរបទថា **មគ្គេន មគ្គំ : ភិក្ខុញ៉ាំងមគ្គឱ្យចូលទៅដោយមគ្គ** សេចក្ដីថា ភិក្ខុស៊ិកអង្គជាតិរបស់ខ្លួនចូលទៅមកបណ្ដាមគ្គទាំង ៣ របស់ស្រី មគ្គណាមួយ ។ម្យ៉ាងទៀត បណ្ដាមគ្គទាំង ២ ដែលលាយគ្នា ភិក្ខុស៊ិកវច្ចមគ្គចូលទៅមកបស្សាវមគ្គ ឬស៊ិកបស្សាវមគ្គចូលទៅមកវច្ចមគ្គ ។

ពីរបទថា **មគ្គេន អមគ្គំ : ភិក្ខុញ៉ាំងអមគ្គឱ្យចូលទៅដោយមគ្គ** សេចក្ដីថា គ្រាស៊ិកចូលទៅមកបស្សាវមគ្គជាដើមហើយ ទើបដកចេញមកតាមដំបៅ ដោយជុំវិញនៃមគ្គនោះ ។

ពីរបទថា **អមគ្គេន មគ្គំ : ភិក្ខុញ៉ាំងមគ្គឱ្យចូលទៅដោយអមគ្គ** សេចក្ដីថា គ្រាស៊ិកចូលទៅតាមដំបៅដោយជុំវិញហើយ ទើបនាំចេញតាមមគ្គ ។

ពីរបទថា **អមគ្គេន អមគ្គំ : ភិក្ខុញ៉ាំងអមគ្គឱ្យចូលទៅដោយអមគ្គ** បណ្ដាដំបៅទាំង ២ ដែលលាយគ្នា កាលស៊ិកចូលទៅតាមដំបៅទីមួយហើយ ទើបនាំចេញតាមដំបៅទីពីរ ។ ក្នុងការកំណត់ថា ជាដំបៅ

គប្បីជ្រាបថា ជាចុល្លច្ច័យ ក្នុងទីគ្រប់កន្លែងដោយអំណាចអនុលោមតាមព្រះសូត្រនេះ ។

## ភិក្ខុសេពមេថុនធម្មជាមួយភិក្ខុដេកលក់

[៤៦] ឥឡូវនេះ ដើម្បីមិនឱ្យភាន់ច្រឡំក្នុងព្រះតម្រាស់ដែលទ្រង់ត្រាស់ទុកខាងមុខពាក្យថា កាលភិក្ខុមិនដឹង មិនត្រេកអរ មិនជាអាបត្តិ ទើបព្រះឧបាលីថេរៈពោលពាក្យថា "ភិក្ខុ សុត្តភិក្ខុម្ហិ : ភិក្ខុសេពមេថុនធម្មនឹងភិក្ខុផងគ្នា ដែលកំពុងដេកលក់" ជាដើម ។

ក្នុងពាក្យថា ភិក្ខុ ជាដើមនោះ មានអធិប្បាយដូចតទៅនេះ ៖

ភិក្ខុណាភ្ញាក់ឡើងហើយត្រេកអរ ភិក្ខុនោះនិយាយថា "លោករូបនេះ បដិបត្តិខុសក្នុងខ្ញុំព្រះករុណាដែលដេកលក់ ខ្ញុំព្រះករុណាមិនដឹងខ្លួន" រមែងមិនផុត (ចាកអាបត្តិ) ។ ក៏ក្នុងពីរបទថា ឧភោ នាសេតព្វា : សង្ឃត្រូវឱ្យវិនាស (ផ្សែកចេញ)ទាំងពីររូប នេះ សេចក្ដីថា ព្រះវិន័យធរគប្បីឱ្យនាសនៈចេញ សូម្បីទាំង ២ រូប ដោយលិង្គនាសនៈ ។

បណ្ដាអ្នកប្រទូសរ៉ាយ និងអ្នកត្រូវប្រទូសរ៉ាយទាំង ២ រូបនោះ អ្នកប្រទូសរ៉ាយមិនមានការធ្វើបដិញ្ញា តែអ្នកត្រូវប្រទូសរ៉ាយ ព្រះវិន័យ

ធរសាកសួរហើយ គប្បីឱ្យនាសនះចេញដោយពាក្យបដិញ្ញា បើលោកមិនត្រេកអរ មិនគួរឱ្យនាសនះ ។ សូម្បីក្នុងវារៈសាមណេរ ក៏ន័យនេះ ។

## អធិប្បាយអនាបត្តិវារៈ

[៤៧] ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងអាបត្តិនិងអនាបត្តិនោះ ៗ ក្នុងវារៈនោះ ៗ យ៉ាងនោះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងអនាបត្តិតែម្យ៉ាង ទើបត្រាស់ពាក្យថា **អនាបត្តិ អជានន្តស្ស** ជាដើម ។

ក្នុងពាក្យថា អជានន្តស្ស : **ភិក្ខុមិនដឹង** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុដែលឈ្មោះថា អ្នកមិនដឹងខ្លួននោះ បានដល់ អ្នកដែលឈានចុះកាន់សេចក្តីលក់យ៉ាងស៊ប់ រមែងមិនដឹងសូម្បីសេចក្តីព្យាយាមដែលអ្នកដទៃធ្វើហើយ ភិក្ខុបែបនោះ មិនជាអាបត្តិដូចភិក្ខុអ្នកទៅសម្រាកពេលថ្ងៃក្នុងព្រៃមហាវ័ន ជិតក្រុងវេសាលីដូច្នោះ ។ សមពិត ដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា *ភិក្ខុនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនដឹងទេ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលភិក្ខុអ្នកឯង កាលបើមិនដឹង មិនត្រូវអាបត្តិទេ ។*[១]

ភិក្ខុដែលឈ្មោះថា មិនត្រេកអរនោះ បានដល់ អ្នកដែលសូម្បី

រលើកជីវ៉ខនហើយ ក៏មិនត្រេកអរ, ភិក្ខុបែបនោះ មិនជាអាបត្តិ ដូចភិក្ខុដែលប្រញាប់ក្រោកឡើងភ្លាមក្នុងព្រៃមហាវ៉ន ជិតក្រុងវេសាលីនោះឯង ដូច្នោះ ។ សមពិត ដូចពាក្យដែលព្រះធម្មសង្គាហកាចារ្យពោលទុកថា ភិក្ខុនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនត្រេកអរទេ ។ ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា ម្នាលភិក្ខុ អ្នកឯង កាលបើមិនត្រេកអរ មិនត្រូវអាបត្តិទេ ។[២]

ភិក្ខុឆ្កួតព្រោះប្រម៉ាត់ (កម្រើក) ឈ្មោះថា ឆ្កួត ។ ពិតមែនប្រម៉ាត់មាន ២យ៉ាងគឺ ប្រម៉ាត់ដែលមានស្រោម១ ប្រម៉ាត់ដែលមិនមានស្រោម១ ។ ប្រម៉ាត់ដែលមិនមានស្រោម ជ្រួតជ្រាបពេញទូទាំងសព៌ាង្គ

១-២. វិន. បារា. មេថុនធម្មសិក្ខាបទ. ១. ៦៩/១២៦-៧ ។

កាយ ដូចលោហិតដូច្នោះ ។ កាលប្រម៉ាត់ដែលមិនមានស្រោមនោះកម្រើកពួកសត្វ រមែងមាន កម រមាស់ ដំនួចពិស និងសរីរៈញ័រ រន្ធត់ជាដើម ។ កម រមាស់ និងដំនួចពិសជាដើមទាំងនោះ នឹងបាត់បាន ព្រោះការលាបថ្នាំ ។ ចំណែកប្រម៉ាត់ដែលមានស្រោមតាំងនៅក្នុងស្រោមរបស់ប្រម៉ាត់ ។ កាលប្រម៉ាត់ដែលមានស្រោមនោះកម្រើកពួកសត្វ រមែងឆ្កួត ។

ភិក្ខុដែលមានសញ្ញាវិបល្លាស (មានសេចក្ដីចាំឃ្លៀងឃ្លាត) លះ

បង់ចោលនូវហិរិ និងឱត្តប្បៈចេញហើយ រមែងប្រព្រឹត្តកម្មដែលមិនសមគួរ ។ សូម្បីញាំញីសិក្ខាបទទាំងស្រាលនិងធ្ងន់ ក៏មិនដឹងខ្លួន ។ ឈ្មោះថា ជាអ្នកកែខៃមិនបាន សូម្បីព្រោះការផ្សំថ្នាំព្យាបាល ; ភិក្ខុឆ្កួតបែបនោះ មិនជាអាបត្តិ ។

ភិក្ខុឈ្មោះថា មានចិត្តរវើរវាយ បានដល់ អ្នកបញ្ចូនចិត្ត (ទៅតាមអារម្មណ៍) លោកហៅថា ឆ្កួតព្រោះយក្ខចូលស្កិត ។ បានឮថា ពួកយក្ខសម្តែងអារម្មណ៍ទាំងឡាយដែលគួរខ្លាច ឬស៊កដៃចូលមកមាត់ហើយ ច្របាច់ហទយរូប ធ្វើពួកសត្វឱ្យមានសញ្ញាវិបល្លាស ។ ភិក្ខុដែលមានចិត្តរវើរវាយបែបនោះមិនជាអាបត្តិ ។

ចំណែកសេចក្តីប្លែកគ្នានៃភិក្ខុឆ្កួតពីរទាំងនោះ មានដូចតទៅនេះ ៖

ភិក្ខុឆ្កួតព្រោះប្រម៉ាត់ (កម្រើក) ចាត់ថា ឆ្កួតរហូតដល់អស់កាលជានិច្ចតែម្តង មិនបានសញ្ញាតាមប្រក្រតី ។ ភិក្ខុឆ្កួតព្រោះយក្ខចូលស្កិត នៅត្រឡប់បានសញ្ញាតាមប្រក្រតីក្នុងពេលខ្លះ ៗ ។ តែក្នុងបឋមបារាជិកសិក្ខាបទនេះ ភិក្ខុឆ្កួតព្រោះប្រម៉ាត់ (កម្រើក)ក្តី ភិក្ខុឆ្កួតព្រោះយក្ខចូលស្កិតក្តី ចូរលើកទុក, ភិក្ខុណា វង្វេងភ្លេចសតិដោយប្រការទាំងពួង វត្ថុអ្វី ៗ ទោះជាភ្លើងក៏ដោយ មាសក៏ដោយ លាមកក៏ដោយ ខ្លឹមចន្ទន៍ក៏ដោយ ក៏មិនស្គាល់ រមែងដើរជាន់ដូចគ្នាទាំងអស់, ភិក្ខុឆ្កួត

បែបនោះ មិនជាអាបត្តិ តែកាលត្រឡប់បានសញ្ញាឡើងក្នុងពេលខ្លះ ៗ ហើយធ្វើទាំងដែលដឹង ជាអាបត្តិនោះឯង ។

ភិក្ខុឈ្មោះថា វសោប់វសល់ព្រោះវេទនានោះ បានដល់ អ្នកដែលគ្រាំគ្រា ព្រោះទុក្ខវេទនាលើសប្រមាណ រមែងមិនដឹងអ្វី ៗ, ភិក្ខុបែបនោះ មិនជាអាបត្តិ ។

ភិក្ខុឈ្មោះថា អាទិកម្មិកៈនោះ បានដល់ អ្នកជាខាងដើមក្នុងកម្មនោះ ៗ ។ ចំណែកក្នុងបឋមបារាជិកសិក្ខាបទនេះ សុទិន្នភិក្ខុត្រូវ ជាអាទិកម្មិកៈ, ព្រះថេរៈនោះ មិនត្រូវអាបត្តិ ។ ភិក្ខុទាំងឡាយដ៏សេសមានសមណៈអ្នកសេពមេថុនទីងមេស្វា និងភិក្ខុវជ្ជីបុត្រជាដើម ជាអាបត្តិតែម្តង ដូច្នេះឯង ។

ពណ៌នាបទភាជនី ចប់ ។

## បកិណ្ណកៈមានសមុដ្ឋានជាដើម

មួយទៀត ដើម្បីភាពជាអ្នកឆ្លាតក្នុងសិក្ខាបទនេះ គប្បីជ្រាបបកិណ្ណកៈនេះថា : សមុដ្ឋាន ១ កិរិយា ១ សញ្ញា ១ សចិត្តកៈ ១ លោកវជ្ជៈ ១ កម្មនិងកុសលព្រមដោយចេតនា ១ ។

ក្នុងបកិណ្ណកៈទាំងនោះ ដែលឈ្មោះថា សមុដ្ឋាននោះ បានដល់

សមុដ្ឋាននៃសិក្ខាបទមាន ៦ ដោយអំណាចប្រមូលទាំងអស់ ។ សមុដ្ឋានទាំងនោះ នឹងមានច្បាស់ក្នុងគម្ពីរបរិវារ ។ តែកាលពោលដោយសង្ខេបហើយ ដែលឈ្មោះថា សិក្ខាបទមានសមុដ្ឋាន ៦ ក៏មាន មានសមុដ្ឋាន ៤ ក៏មាន មានសមុដ្ឋាន ៣ ក៏មាន មានសមុដ្ឋានដូចកឋិនសិក្ខាបទក៏មាន មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទក៏មាន មានសមុដ្ឋានដូចធុរនិក្ខេបសិក្ខាបទក៏មាន ។

សូម្បីក្នុងសិក្ខាបទនោះសោត សិក្ខាបទខ្លះ កើតព្រោះធ្វើ, សិក្ខាបទខ្លះកើតព្រោះមិនធ្វើ, សិក្ខាបទខ្លះ កើតព្រោះធ្វើនិងមិនធ្វើ, សិក្ខាបទខ្លះពេលខ្លះកើតព្រោះធ្វើ និងពេលខ្លះកើតព្រោះមិនធ្វើ, សិក្ខាបទខ្លះ ពេលខ្លះកើតព្រោះធ្វើ និងពេលខ្លះកើតព្រោះធ្វើនិងមិនធ្វើ ។

## អធិប្បាយសិក្ខាបទជាសចិត្តកៈនិងអចិត្តកៈ

សូម្បីបណ្ដាសិក្ខាបទទាំងនោះ សិក្ខាបទដែលជាសញ្ញាវិមោក្ខក៏មាន ដែលជានោសញ្ញាវិមោក្ខក៏មាន ។ ក្នុងសិក្ខាបទ ដែលជាសញ្ញាវិមោក្ខនិងនោសញ្ញាវិមោក្ខទាំងនោះ សិក្ខាបទណា បានអង្គគឺ ចិត្តផង, សិក្ខាបទនោះ ជាសញ្ញាវិមោក្ខ, ក្រៅនេះ ជានោសញ្ញាវិមោក្ខ ។ សិក្ខាបទដែលជាអចិត្តកៈក៏មាន ដែលជាសចិត្តកៈក៏មានទៀត ។ សិក្ខាបទណា ត្រូវព្រម

ដោយចិត្តប៉ុណ្ណោះ សិក្ខាបទនោះ ជាសចិត្តកៈ ។ សិក្ខាបទណា សូម្បីវៀរចាកចិត្តក៏ត្រូវ, សិក្ខាបទនោះ ជាអចិត្តកៈ ។ សិក្ខាបទនោះសូម្បីទាំងអស់មាន ២ យ៉ាង គឺ ជាលោកវជ្ជៈ ១ ជាបណ្ណត្តិវជ្ជៈ ១ លក្ខណៈនៃសិក្ខាបទដែលជាលោកវជ្ជៈនិងបណ្ណត្តិវជ្ជៈនោះ បានពោលហើយ ។

## អធិប្បាយសិក្ខាបទដែលជាកាយកម្មជាដើម

មួយទៀត កាលពោលសូម្បីដោយអំណាចកម្ម កុសលនិងវេទនាហើយ បណ្តាសិក្ខាបទទាំងនេះ សិក្ខាបទដែលជាកាយកម្មក៏មាន ដែលជាវចីកម្មក៏មាន ។ ក្នុងកាយកម្មនិងវចីកម្មទាំងនោះ សិក្ខាបទណា ប្រព្រឹត្តទៅមកកាយទ្វារ សិក្ខាបទនោះ គប្បីជ្រាបថា ជាកាយកម្ម, សិក្ខាបទណា ប្រព្រឹត្តទៅមកវចីទ្វារ សិក្ខាបទនោះគប្បីជ្រាបថា ជាវចីកម្ម ។

មួយទៀត សិក្ខាបទដែលជាកុសលក៏មាន ដែលជាអកុសលក៏មាន ដែលជាអព្យាក្រិតក៏មាន ។ ពិតមែន ចិត្តដែលឱ្យកើតអាបត្តិមាន ៣២ ដួងប៉ុណ្ណោះ គឺ កាមាវចរកុសលចិត្ត ៨ អកុសលចិត្ត ១២ កាមាវចរកិរិយាចិត្ត ១០ អភិញ្ញាចិត្ត ២ ដោយកុសលនិងកិរិយា ។ ក្នុងចិត្តទាំងនោះ សិក្ខាបទណា ត្រូវដោយកុសលចិត្ត សិក្ខាបទនោះជាកុសល, សិក្ខាបទណាត្រូវដោយចិត្តក្រៅនេះ សិក្ខាបទនោះ ជាចំណែក

ក្រៅអំពីនេះ ។

មួយទៀត សិក្ខាបទមានវេទនា ៣ ក៏មាន មានវេទនា ២ ក៏មាន មានវេទនាតែមួយក៏មាន ។ ក្នុងសិក្ខាបទទាំងនោះ កាលត្រូវសិក្ខាបទណា ជាអ្នកប្រកបព្រមដោយវេទនា ៣ យ៉ាងណាមួយ ទើបត្រូវ, សិក្ខាបទនោះ គប្បីជ្រាបថា មានវេទនា ៣ ។ កាលភិក្ខុនឹងត្រូវសិក្ខាបទណា ជាអ្នកប្រកបព្រមដោយសុខ ឬជាអ្នកប្រកបព្រមដោយឧបេក្ខា ទើបត្រូវ, សិក្ខាបទនោះ គប្បីជ្រាបថា មានវេទនា ២ ។ កាលភិក្ខុនឹងត្រូវសិក្ខាបទណា ជាអ្នកប្រកបព្រមដោយទុក្ខវេទនាប៉ុណ្ណោះ ទើបត្រូវសិក្ខាបទនោះ គប្បីជ្រាបថា មានវេទនាតែមួយ ។

កាលបានជ្រាបបកិណ្ណកៈនេះ គឺ សមុដ្ឋាន១ កិរិយា១ សញ្ញា១ សចិត្តកៈ១ លោកវជ្ជៈ១ កម្មនិងកុសលព្រមដោយវេទនា១ យ៉ាងនេះហើយ គប្បីជ្រាបថា បណ្ដាបកិណ្ណកៈមានសមុដ្ឋានជាដើមនោះ សិក្ខាបទនេះពោលដោយសមុដ្ឋាន មានសមុដ្ឋានតែមួយ, ពោលដោយអំណាចអង្គ កើតដោយអង្គ ២ គឺ កើតព្រោះកាយនឹងចិត្ត, និងសិក្ខាបទនេះកើតព្រោះធ្វើ, ពិតមែន កាលធ្វើប៉ុណ្ណោះ ទើបត្រូវអាបត្តិនោះ ; ជាសញ្ញាវិមោក្ខ ព្រោះផុតដោយមិនមានកាមសញ្ញា ដែលបដិសំយុត្តដោយមេថុន, ពិតមែន ព្រះមានព្រះភាគ បានត្រាស់ថា មិនជាអាបត្តិ ដល់ភិក្ខុ

ដែលមិនរលឹកដឹងមិនត្រេកអរ ; ជាសចិត្តកៈ ព្រោះភិក្ខុត្រូវអាបត្តិនោះដោយចិត្តបដិសំយុត្តដោយមេថុនប៉ុណ្ណោះ វៀរចាកចិត្តមិនត្រូវ ; ជាលោកវជ្ជៈ ព្រោះទឹងគប្បីត្រូវអាបត្តិនោះដោយអំណាចរាគៈខ្លាំងក្លាប៉ុណ្ណោះ ; ជាកាយកម្ម ព្រោះកើតមកកាយទ្វារប៉ុណ្ណោះ, ចំណែកចិត្តត្រឹមតែជា ជាអង្គក្នុងសិក្ខាបទនេះ, ទឹងចាត់ជាកម្ម ដោយអំណាចចិត្តនោះមិនបាន ; ជាអកុសលចិត្ត ព្រោះគប្បីត្រូវអាបត្តិដោយលោភចិត្ត; មានវេទនា ២ ព្រោះថា ភិក្ខុមានសេចក្តីប្រកបព្រមដោយ សុខ ឬមានសេចក្តីប្រកបព្រមដោយឧបេក្ខា ទើបត្រូវអាបត្តិនោះ ។

ក៏ឯបកិណ្ណកៈទាំងពួងមានសមុដ្ឋានជាដើមនេះ រមែងសមក្នុងអាបត្តិ ។ តែក្នុងអដ្ឋកថាទាំងពួង លោកលើកឡើងសម្តែងដោយមាតិកាសិក្ខាបទ ; ព្រោះដូច្នោះ ទើបត្រូវពោលយ៉ាងនោះ ដូច្នេះឯង ។

## វិនីតវត្ថុបឋមបារាជិក ឧទានគាថា

[៤៨] សួរថា ពាក្យប្រព័ន្ធជាព្រះគាថាថា ៖

រឿងស្វាញី រឿងពួកវជ្ជីបុត្តភិក្ខុ រឿងភិក្ខុក្លែងភេទជាគ្រហស្ថ រឿងភិក្ខុអាក្រាត រឿងពួកភិក្ខុប្រព្រឹត្តតាមលទ្ធិតិរ្ថិយ ( ៧រឿង ) រឿងទារិកា រឿងឧប្បលវណ្ណាភិក្ខុនី រឿងជនផ្សេងគ្នាពីររូប គឺភិក្ខុក្លាយភេទជាស្រី និងភិក្ខុនីក្លាយភេទជាបុរស រឿងមាតា រឿងធីតា រឿងប្អូនស្រី រឿង

ប្រពន្ធ រឿងភិក្ខុខ្នងទន់ រឿងភិក្ខុមានអង្គជាតវែង រឿងស្នាមដំបៅពីរយ៉ាង រឿងរូបគំនូរ រឿងឈើចំឡាក់ជារូបធីតា រឿងភិក្ខុ ៥ រូបទាំងសុន្ទរភិក្ខុផង រឿងភិក្ខុ ៥ រូប នៅក្នុងព្រៃខ្មោច រឿងនាគញី រឿងយក្ខិនី រឿងស្រីប្រេត រឿងភិក្ខុខ្ទើយ រឿងភិក្ខុកើតរោគស្ពឹក រឿងចាប់មាតុគ្រាមប្រងនឹងសេព រឿងភិក្ខុ(ជាព្រះអរហន្ត) សិងលក់ក្នុងទីស្ងាត់ក្បែរក្រុងភទ្ទិយៈ រឿងភិក្ខុទាំងឡាយ ៤ រូបឯទៀតក្នុងក្រុងសាវត្ថី រឿង(ភិក្ខុ) អ្នកចំបាប់ ៣ រូបក្នុងក្រុងវេសាលី រឿងការុកច្ឆកភិក្ខុយល់សុបិនទិមិត្ត រឿងនាងសុបញ្ញា(៩រឿង) រឿងនាងសទ្ធា(៩រឿង) រឿងភិក្ខុនី រឿងសិក្ខមានា រឿងសាមណេរី រឿងស្រីផ្កាមាស រឿងមនុស្សខ្ទើយ រឿង(ស្ត្រី)គ្រហស្ថ រឿងភិក្ខុសេពគ្នានឹងគ្នា រឿងភិក្ខុបួសឯចាស់ រឿងសត្វម្រឹគ, ដូច្នេះ ទាំងនេះ តើយ៉ាងណា ?

វិសជ្ជនាថា ព្រះគាថាទាំងនេះ ឈ្មោះឧទានគាថានៃវិនីតវត្ថុ គឺរឿងនោះ ៗ ដែលព្រះមានព្រះភាគទ្រង់វិនិច្ឆ័យដោយព្រះអង្គឯង ដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយបានតាំងចិត្តទុកថា ព្រះវិន័យធរទាំងឡាយនឹងរៀនយករឿងទាំងនោះបានស្រួល ទើបបានតាំងទុក ។ ចំណែកវត្ថុគាថា ព្រះឧបាលីថេរៈបានតាំងចិត្តទុកថា ព្រះវិន័យធរទាំងឡាយ នឹងវិនិច្ឆ័យវិន័យតទៅ (ក្នុងអនាគត) ដោយលក្ខណៈនេះ ទើបបានតាំងទុក

ក្នុងកាលព្រះមានព្រះភាគទ្រង់នៅមានព្រះជន្មនុ៎ះឯង ។ ព្រោះដូច្នោះ ព្រះវិន័យធរគួរកំណត់លក្ខណៈដែលត្រាស់ទុកក្នុងវិនីតវត្ថុនេះឱ្យល្អ ហើយទើបវិនិច្ឆ័យបឋមសិក្ខាបទ ។ មួយទៀត ទុតិយបារាជិកជាដើម ក៏គួរវិនិច្ឆ័យដោយលក្ខណៈនៃទុតិយបារាជិកជាដើម ដែលត្រាស់ទុកហើយក្នុងវិនីតវត្ថុទាំងឡាយ, ពិតមែន វិនីតវត្ថុទាំងឡាយ រមែងជារឿងសម្រាប់ប្រៀបធៀប របស់ព្រះវិន័យធរទាំងឡាយ ដូចរូបដែលជាគោលប្រៀបធៀបរបស់ពួកអ្នកសិប្បកម្ម ដូច្នោះ ។

[៤៩-៥០] បណ្ដារឿងទាំងនោះ រឿងស្វាញី និងរឿងពួកវជ្ជីបុត្តភិក្ខុ ពីររឿងខាងដើម មានសេចក្ដីដូចដែលត្រាស់ទុកហើយក្នុងអនុប្បញ្ញត្តិនុ៎ះឯង ។

[៥១] ក្នុងរឿងក្លែងភេទជាគ្រហស្ថ ទី ៣ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **គិហិលិង្គេន** គឺ ជាអ្នកស្លៀកដណ្ដប់សំពត់សដូចគ្រហស្ថ ។

[៥២] ក្នុងរឿងភិក្ខុអាក្រាត ទី ៤ មិនមានពាក្យអ្វី ៗ ដែលគួរពោលទុក ។

[៥៣] ក្នុងរឿងប្រព្រឹត្តតាមលទ្ធិតិរ្ថិយ ស្លៀកសំពត់ ៧

ប្រភេទ បន្ទាប់ពីរឿងទី ៤ នោះទៅ មានវិនិច្ឆ័យដូច្នេះ ៖

សំពត់ដែលគេក្រងស្បូវភ្ជាំងធ្វើ ឈ្មោះថា សំពត់ក្រងដោយស្បូវ ។ សំពត់សំបកឈើរបស់ពួកតាបស ឈ្មោះថា សំពត់សំបកឈើ ។ សំពត់ដែលគេដេរធ្វើជាប់គ្នាជាបន្ទះ មានសណ្ឋានដូចបន្ទះក្តារ ឈ្មោះថា សំពត់ដែលធ្វើអំពីបន្ទះក្តារ ។ សំពត់កម្ពលដែលគេយកសរសៃសក់ (មនុស្ស) ធ្វើជាសរសៃអំបោះមកត្បាញ ឈ្មោះថា សំពត់ដែលត្បាញដោយសក់ ។ សំពត់កម្ពលដែលគេត្បាញដោយរោមកន្ទុយសត្វចាមរី ឈ្មោះថា សំពត់ត្បាញដោយរោមកន្ទុយសត្វ ។ សំពត់ដែលគេយករោមស្លាបសត្វមៀមមកធ្វើ ឈ្មោះថា សំពត់ដែលត្បាញដោយរោមស្លាបមៀម ។ ស្បែកម្រឹគព្រមទាំងរោមនិងក្រចក ឈ្មោះថា ស្បែកខ្លាដែលនៅមានទាំងរោមនិងក្រចក ។

[៥៤] ក្នុងរឿងទារិកា ទី ១២ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **សារត្តោ** : ក៏មានចិត្តត្រេកអរ បានដល់ អ្នកមានសេចក្តីតម្រេកដោយសេចក្តីតម្រេកក្នុងការស្ទាបអង្អែលកាយ ។ ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីតម្រេកនោះហើយ ទើបត្រាស់ថា ជាអាបត្តិសង្ឃាទិសេស ។

## រឿងនន្ទមាណពសេពមេថុនធម្មក្នុងឧប្បលវណ្ណាថេរី

[៥៥] ក្នុងរឿងឧប្បលវណ្ណាភិក្ខុនីទី ១៣ មានវិនិច្ឆ័យដូច្នេះ ៖ ព្រះថេរីនោះ ឈ្មោះថា ឧប្បលវណ្ណាជាធីតារបស់សេដ្ឋីក្នុងក្រុងសាវត្ថី សម្បូរណ៍ដោយអភិនិហារទាំងសែនកប្ប ។ សូម្បីដោយប្រក្រតីព្រះថេរីនោះ មានសម្បុរកាយ ពណ៌ស្រដៀងផ្កាឧប្បលខៀវ គួរមើលក្រៃលែងណាស់ ។ ក៏ព្រះថេរីនោះ រមែងរុងរឿងក្រៃលែងណាស់ ព្រោះមិនមានសេចក្តីក្តៅផ្សាដោយកិលេសក្នុងខាងក្នុង ។ នាងបានឈ្មោះថា ឧប្បលវណ្ណា ព្រោះសេចក្តីដែលនាងមានសម្បុរស្រស់ល្អនោះឯង ។

បទថា **បដិពទ្ធចិត្តោ** : **មានសេចក្តីប្រតិព័ទ្ធចាប់ចិត្ត** សេចក្តីថា មាណពនោះ មានចិត្តតម្រេកតាំងពីវេលានៅជាគ្រហស្ថ ។ បានឮថា នន្ទមាណពនោះ ជាប្រុសកម្លោះ ដែលជាញាតិរបស់ព្រះថេរីនោះ ។

ស័ព្ទថា **អថខោ** : **លុះដល់** ជានិបាត ចុះក្នុងអត្ថថា លំដាប់ មានពាក្យអធិប្បាយថា ក្នុងលំដាប់នៃព្រះថេរីអង្គុយលើគ្រែនុ៎ះឯង ។ ពិតមែន វេលាថ្ងៃ កាលបុគ្គលមកពីខាងក្រៅបិទទ្វារហើយអង្គុយ ងងឹតនឹងមានឡើង ។ អធិប្បាយថា មាណពនោះ បានធ្វើយ៉ាងនោះ រហូតដល់អស់វេលាដែលងងឹតនោះរបស់ព្រះថេរីនោះ មិនទាន់បាត់ទៅនុ៎ះឯង ។

បទថា **ទូសេសិ** : **ហើយប្រទូស្ត** បានដល់ បានប្រទូស្ត

ហើយ ។ ចំណែកព្រះថេរីជាអ្នកមិនមានទោស ចាប់ផ្ដើមតាំងសមណសញ្ញាមិនត្រេកអរ អង្គុយព្រងើយ មិនត្រេកអរ ត្រូវនន្ទមាណពស្មាបអង្អែលហើយ ដោយសេចក្ដីប្រាថ្នា អសទ្ធម្មសម្ផស្សដូចកងភ្លើងសរសេរថ្ម និងដង្កត់ឈើគគី ដូច្នោះ ។ ចំណែក នន្ទមាណពនោះ គ្រាន់ឱ្យសេចក្ដីពេញចិត្តរបស់ខ្លួនសម្រេចបរិបូណ៌ហើយក៏ទៅ ។

កាលនន្ទមាណព លះគន្លងនៃការឃើញរបស់ព្រះថេរីនោះប៉ុណ្ណោះ មហាប្រថពីនេះ សូម្បីនឹងអាចទ្រទ្រង់ភ្នំសិណេរុទុកបានក៏ដោយ ក៏ដូចជាមិនអាចនឹងទ្រទ្រង់បុរសអាក្រក់នោះ ដែលមានអត្តភាពប្រមាណមួយព្យាមទុកបាន ទើបបើកចន្លោះឱ្យហើយ ។ ខណៈនោះឯង គេបានដល់ ភាពជាវត្ថុសម្រាប់ដុតនៃអណ្ដាតភ្លើងក្នុងអវិចីហើយ ។ ព្រះមានព្រះភាគកាលទ្រង់ស្ដាប់រឿងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលមិនត្រេកអរមិនជាអាបត្តិ ទ្រង់សំដៅយកព្រះថេរី បានត្រាស់ព្រះគាថានេះក្នុងធម្មបទថា

វារិ បោក្ខរបត្តេវ អារគ្គេរិវ សាសបោ
យោ ន លិម្បតិ កាមេសុ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា មានចិត្តមិនបានជាប់នៅក្នុងកាមទាំងឡាយ ដូចទឹក (មិនជាប់) លើស្លឹកឈូក ឬដូចគ្រាប់ស្ពៃ (មិនជាប់)

លើចុងដែក ស្រួច តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។[១]

## រឿងភិក្ខុក្លាយភេទជាស្រី

[៥៦] ក្នុងរឿងភិក្ខុក្លាយភេទជាស្រីទី ១៤ មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា ឥត្ថីលិង្គំ បាតុភូតំ : ក្លាយភេទខ្លួនប្រែទៅជាស្រី សេចក្ដីថា កាលភិក្ខុនោះ ឈានចុះកាន់សេចក្ដីលក់ក្នុងវេលាពេលយប់ អវយវៈទាំងពួងមានពុកមាត់និងពុកចង្កាជាដើម ដែលជាទ្រង់ទ្រាយរបស់បុរសបាត់ទៅ ទ្រង់ទ្រាយរបស់ស្ត្រីកើតឡើងជំនួសវិញ ។

ច្រើនបទថា តំយេវ ឧបជ្ឈំ តំ ឧបសម្បទំ : នូវឧបជ្ឈាយ៍

(១) ខុទ្ទ. ធម្ម. ព្រាហ្មណវគ្គ. ៥២. ៣៦/១០៦ ។

នោះដដែល និងឧបសម្បទានោះដដែល សេចក្ដីថា តថាគតអនុញ្ញាតឧបជ្ឈាយ៍ដែលលោកធ្លាប់កាន់មកហើយក្នុងកាលមុនទុំះឯង (និង) ការឧបសម្បទាដែលសង្ឃធ្វើទុកក្នុងកាលមុនដូចគ្នា ។ អធិប្បាយថា មិនត្រូវកាន់ឧបជ្ឈាយ៍ថ្មី មិនត្រូវឱ្យឧបសម្បទាថ្មី ។

ពីរបទថា តានិ វស្សានិ : និងវស្សាទាំងនោះ សេចក្ដីថា តថាគតអនុញ្ញាតឱ្យរាប់វស្សាចាប់ផ្ដើមតាំងពីឧបសម្បទាជាភិក្ខុមកនោះ

៦៨ ។ អធិប្បាយថា មិនត្រូវធ្វើការរាប់វស្សាតាំងពីភេទត្រឡប់នេះទៅឡើយ ។

ពីរបទថា **ភិក្ខុនីហិ សង្គមិតុំ : និងឱ្យនៅរួមជាមួយនឹងភិក្ខុនីទាំងឡាយ** សេចក្ដីថា ទាំងតថាគតអនុញ្ញាតឱ្យភិក្ខុនីនោះទៅជាមួយគ្នា គឺ សមាគមគ្នា ព្រមព្រៀងគ្នានឹងភិក្ខុនីទាំងឡាយ ។ មានពាក្យអធិប្បាយត្រាស់ទុកដូច្នេះថា ឥឡូវនេះ នាងភិក្ខុនីនោះ មិនគួរនៅកណ្ដាលភិក្ខុទាំងឡាយ ចូរទៅកាន់សំណាក់នាងភិក្ខុនី ហើយនៅរួមនឹងនាងភិក្ខុនីចុះ ។

ច្រើនបទថា **យា អាបត្តិយោ ភិក្ខូនំ ភិក្ខូនីហិ សាធារណា : អាបត្តិណា ជារបស់ភិក្ខុ ដែលទូទៅដល់ភិក្ខុនីទាំងឡាយ** សេចក្ដីថា អាបត្តិពួកណា ជាទេសនាគាមិនីក៏ដោយ ជាវុដ្ឋានគាមិនីក៏ដោយ ដែលទូទៅដល់ភិក្ខុនីឯនាងភិក្ខុនីទាំងឡាយ ។

ច្រើនបទថា **តា អាបត្តិយោ ភិក្ខុនីនំ សន្តិកេ វុដ្ឋាតុំ : តថាគតអនុញ្ញាតនូវអាបត្តិទាំងនោះ ដើម្បីឱ្យភិក្ខុដែលក្លាយភេទជាស្រីនោះ នៅក្នុងសំណាក់ភិក្ខុនីទាំងឡាយ** សេចក្ដីថា តថាគតអនុញ្ញាតឱ្យធ្វើវិន័យកម្ម ដែលពួកភិក្ខុនីគប្បីធ្វើហើយចេញចាកអាបត្តិទាំងនោះ

សូម្បីទាំងអស់ ក្នុងសំណាក់របស់នាងភិក្ខុនីទាំងឡាយ ។

ប្រើនបទថា តាហិ អាបត្តីហិ អណាបត្តិ : ភិក្ខុនីនោះ មិនត្រូវអាបត្តិ ព្រោះអាបត្តិនោះឡើយ សេចក្តីថា ចំណែកអាបត្តិពួកណាមានសុក្កវិស្សដ្ឋិជាដើម របស់ពួកភិក្ខុ ដែលមិនទូទៅដោយនាងភិក្ខុនីទាំងឡាយ, មិនជាអាបត្តិដោយអាបត្តិទាំងនោះ គឺ អាបត្តិទាំងនោះ លោកក៏ចេញចាករួចហើយ ព្រោះភេទត្រឡប់នោះឯង ។ សូម្បីកាលភេទពីដើមត្រឡប់កើតឡើងទៀត គង់ជាអនាបត្តិដល់លោកដោយអាបត្តិទាំងនោះដូចគ្នា ។ វិនិច្ឆ័យបាលីក្នុងរឿងទី ១៤ នេះ មានប៉ុណ្ណេះសិន ។

ចំណែកវិនិច្ឆ័យផ្សេរឿងក្រៅពីបាលី មានដូចតទៅនេះ ៖

ចាប់ផ្តើមដំបូងក្នុងភេទពីរនេះ ភេទប្រុស ជាឧត្តមភេទ ភេទស្រីជាហីនភេទ; ព្រោះហេតុនោះ ភេទប្រុស ទើបឈ្មោះថា អន្តរធានទៅព្រោះអកុសលមានកម្លាំងខ្លាំងក្លា, ភេទស្រីប្រាកដឡើងជំនួស ព្រោះកុសលមានកម្លាំងថយចុះ ។ ចំណែកភេទស្រី នឹងអន្តរធានទៅ ឈ្មោះថា អន្តរធានទៅ ព្រោះអកុសលមានកម្លាំងថយចុះ, ភេទប្រុសប្រាកដឡើងជំនួសព្រោះកុសលមានកម្លាំងខ្លាំងក្លា ។ ភេទទាំងពីរអន្តរធានទៅព្រោះអកុសល, ត្រឡប់កើតឡើងព្រោះកុសល ដោយប្រការដូច្នេះ ។

## ត្រូវអាបត្តិព្រោះដេករួមនឹងភិក្ខុក្លាយភេទ

បណ្ដាភេទស្រីនិងភេទប្រុសនោះ បើភិក្ខុពីររូប ធ្វើការស្វាធ្យាយ ឬសន្ទនាធម៌ជាមួយគ្នា សិងលក់ទៅក្នុងផ្ទះមួយជាមួយគ្នា, ភេទស្រីប្រាកដដល់ភិក្ខុមួយរូប ជាអាបត្តិព្រោះដេករួមគ្នា សូម្បីដល់លោកទាំងពីរ ។ បើភិក្ខុដែលមានភេទត្រឡប់នោះភ្ញាក់ឡើង ឃើញប្រការប្លែកនោះរបស់ខ្លួនហើយ មានសេចក្ដីខ្វួចចិត្តគប្បីប្រាប់ដល់ភិក្ខុមួយរូបទៀតក្នុងពេលយប់តែម្ដង, លោកចូរជាអ្នកដែលភិក្ខុនោះគួរលួងលោមថា "កុំខ្វួចចិត្តឡើយ, នេះជាទោសរបស់វដ្ដៈផ្សេងដទៃ, ព្រះសម្មាសម្ពុទ្ធ ក៏បានត្រាស់ទុកហើយថា ទោះជាភិក្ខុឬភិក្ខុនីក៏ដោយ, ធម៌ដែលធម្មតាមិនបានកំណត់, មកសួគ៌ដែលធម្មតាមិនបានហាម" ។

## វិធីបដិបត្តិនឹងភិក្ខុនីអ្នកមានភេទត្រឡប់

ក៏ឯគ្រាលួងលោមហើយ គួរពោលយ៉ាងនេះថា "សមគួរនាងទឹងទៅកាន់សំណាក់ភិក្ខុនី, ភិក្ខុនីពួកខ្លះ ដែលជាសម្លាញ់បានឃើញម្ដងម្កាលរបស់នាងមានដែរឬ ?" បើនាងមានពួកភិក្ខុនីដូច្នោះ, គប្បីប្រាប់ថា "មាន" បើមិនមានគប្បីប្រាប់ថា "មិនមាន" ហើយគប្បីប្រាប់ភិក្ខុនោះថា "សូមលោកម្ចាស់អនុគ្រោះខ្ញុំព្រះករុណាចុះ, ចូរនាំខ្ញុំព្រះករុណាទៅកាន់

សំណាក់ភិក្ខុនីឥឡូវនេះឯង” ។ ភិក្ខុនោះ គប្បីនាំនាងទៅកាន់សំណាក់របស់នាងភិក្ខុនីទាំងឡាយ ដែលជាសម្លាញ់បានឃើញគ្នាមួងម្កាលរបស់នាង ឬជាសម្លាញ់ដែលបានឃើញគ្នាមួងម្កាលរបស់ខ្លួនក៏បាន កាលនឹងទៅ មិនគួរទៅតែម្នាក់ឯង គួរកាន់យកចង្កៀងនិងឈើច្រត់ ដោះការបបួលចេញ ទៅរួមនឹងភិក្ខុ ៤-៥ រូប ដោយនិយាយថា ពួកយើងនឹងទៅកាន់ស្ថានទីឈ្មោះឯណោះ ។

បើខាងក្រៅស្រុក មានវត្តនៅឆ្ងាយ ក៏មិនជាអាបត្តិក្នុងចន្លោះមកព្រោះគាមន្តរាបត្តិ (អាបត្តិព្រោះធ្វើដំណើរឆ្លងលង្វែកនៃស្រុកមួយ) នទីបរាបត្តិ (អាបត្តិព្រោះឆ្លងត្រើយម្ខាង) រត្តិវិប្បវាសាបត្តិ (អាបត្តិព្រោះនៅប្រាសចាកត្រៃចីវរមួយរាត្រី) និងគណឱហីយនាបត្តិ (អាបត្តិព្រោះនៅតែមួយរូបមិនគ្រប់គណៈ) ។ គ្រាទៅដល់សំណាក់របស់នាងភិក្ខុនីហើយ គប្បីពោលនឹងនាងភិក្ខុនីទាំងនោះថា នាងទាំងឡាយស្គាល់ភិក្ខុឈ្មោះឯណោះឬ ? ភិក្ខុនីទាំងឡាយ ឆ្លើយថា “ខ្ញុំព្រះករុណាស្គាល់លោកម្ចាស់” ។ ភិក្ខុទាំងនោះគប្បីពោលថា ភិក្ខុនោះ ប្រាកដជាភេទស្រី, សូមមេត្តាសង្គ្រោះនាងឥឡូវនេះចុះ ។ បើនាងភិក្ខុនីទាំងនោះពោលថា “ល្អណាស់ លោកម្ចាស់ ឥឡូវនេះ សូមឲ្យពួកខ្ញុំព្រះករុណាម្ចាស់ ក៏នឹងសូធ្យាយ នឹងស្តាប់ធម៌ សូមលោកម្ចាស់ទាំងឡាយចូរទៅ

ចុះ” ដូច្នេះហើយ ធ្វើសេចក្តីសង្គ្រោះ និងឱ្យរើកកាយត្រេកអរ ទាំងជាលជ្ជិនីអ្នកមានសេចក្តីសង្គ្រោះផង, លោកមិនគួរ[១] លះបោលនាងភិក្ខុនីទាំងនោះទៅក្នុងស្ថានទីដទៃ បើទៅក៏មិនផុតពីគាមន្តរាបត្តិ នទីបារាបត្តិ រត្តិវិប្បវាសាបត្តិ និងគណាឱហីយនាបត្តិ ។

មួយទៀត បើនាងភិក្ខុនីទាំងនោះ ជាលជ្ជិនី តែមិនមានសេចក្តីសង្គ្រោះ, រមែងបានដើម្បីនឹងទៅក្នុងស្ថានទីដទៃ ។ សូម្បីបើជាអលជ្ជិនី (ពេញមួយវត្ត) តែធ្វើសេចក្តីសង្គ្រោះ រមែងបានដើម្បីនឹងលះបោល សូម្បីនាងភិក្ខុនីទាំងនោះហើយចេញទៅក្នុងទីដទៃ ។ អាចារ្យពួកខ្លះពោលថា បើទាំងលជ្ជិនី ទាំងមានសេចក្តីសង្គ្រោះ តែមិនជាញាតិ, និងក្នុងស្រុកជិត ភិក្ខុនីពួកដទៃដែលជាញាតិ មាន ទាំងជាអ្នកទំនុកបំរុងផង,

---

(១). តា កោបេត្វាតិ តា បរិច្ចជិត្វា. សារត្ថទីបនី ២/១៥៩ ។

គួរទៅកាន់សំណាក់របស់ភិក្ខុនីសូម្បីទាំងនោះ កាលទៅហើយ បើខ្ជិនបដិបត្តិនិស្ស័យ (នៅកាន់និស្ស័យ) សូម្បីក្នុងកាលជាភិក្ខុ ក៏គួរកាន់និស្ស័យក្នុងសំណាក់របស់នាងភិក្ខុនីសមគួរ ។ មាតិកាក្តី វិន័យក្តី ដែលរៀនមកហើយ ក៏ជាការរៀនហើយដោយល្អមិនមានហេតុដែលនឹងត្រូវរៀនដដែលទៀត ។ បើក្នុងកាលនៅជាភិក្ខុ ភិក្ខុនោះ ជាអ្នកគ្រប់គ្រងបរិស័ទ, កុលបុត្រទាំងឡាយ ដែលឧបសម្បទាហើយក្នុងសំណាក់

របស់ភិក្ខុនោះឯង ក៏ជាការឧបសម្បទាប្រពៃហើយ, តែត្រូវកាន់និស្ស័យក្នុងសំណាក់របស់អាចារ្យរូបដទៃ ។ សូម្បីពួកអន្តេវាសិកអ្នកអាស្រ័យលោកនោះនៅក្នុងកាលមុន ក៏ត្រូវកាន់និស្ស័យក្នុងសំណាក់របស់អាចារ្យរូបដទៃ ។ សូម្បីសាមណេរអ្នកមានអាយុពេញបរិបូណ៌, ក៏ត្រូវកាន់ឧបជ្ឈាយ៍ ក្នុងសំណាក់របស់ភិក្ខុដទៃ ។

## វិធីបដិបត្តិក្នុងគ្រឿងបរិក្ខារផ្សេងៗ

មួយទៀត ត្រៃចីវរនិងបាត្រ ដែលភិក្ខុនោះអធិដ្ឋានទុកហើយក្នុងកាលនៅជាភិក្ខុ, រមែងដាច់អធិដ្ឋានទៅ, ត្រូវអធិដ្ឋានថ្មី ។ ភិក្ខុនី គួរឱ្យសំពត់ចោមពុង និងសំពត់ងូតទឹក ។ អតិរេកចីវរក្តី អតិរេកបាត្រក្តី ដែលភិក្ខុនោះ ធ្វើវិន័យកម្មរក្សាទុកហើយ សូម្បីទាំងអស់ រមែងលះវិន័យកម្មទៅត្រូវធ្វើថ្មី ។ សូម្បីភេសជ្ជៈមានប្រេងទឹកឃ្មុំនិងទឹកអំពៅ ដែលលោកទទួលប្រគេនទុកជាដើម រមែងដាច់ប្រគេនវិញ ។ បើក្លាយភេទក្នុងថ្ងៃទី ៧ អំពីថ្ងៃដែលទទួលប្រគេនទៅ, គួរទទួលប្រគេនថ្មី គួរឆាន់បាន ៧ ថ្ងៃ* ។ ចំណែកវត្ថុណាជារបស់ភិក្ខុដទៃ លោកទទួលប្រគេនទុកក្នុងវេលាជាភិក្ខុ, វត្ថុនោះមិនដាច់ប្រគេន ។ សូម្បីវត្ថុណាដែលជារបស់ទូទៅដល់ភិក្ខុពីររូបមិនទាន់បានបែងចែកបណ្ណ៉ាគ្នា បកតត្តភិក្ខុ រមែង

រក្សាវត្ថុនោះទុក ។ ចំណែកវត្ថុណា បានបែងចែកគ្នាហើយជារបស់លោកឯង, វត្ថុនោះ រមែងជាច់ប្រគេនទៅ ។ ពិតមែន សូម្បីព្រះមានព្រះភាគ ក៏ត្រាស់ពាក្យនេះទុកក្នុងគម្ពីរបរិវារថា ៖

ឧបសម្បន្នទទួលប្រេង ទឹកឃ្មុំ ទឹកអំពៅ និងទឹកដោះថ្លា ហើយទុកដាក់ដោយខ្លួនឯង ទុកជាមិនទាន់កន្លង ៧ ថ្ងៃនៅឡើយ កាលបើមានបច្ច័យហើយឆាន់ ត្រូវអាបត្តិ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។[១]

---

* សារត្ថទីបនី ភាគ ២ ថា. សត្តាហំ បរិភុញ្ជិតុំ វដ្ដតិ ។

(១) វិន. បរិ. សេទមោចនគាថា. ១៣. ៣៩៤/៤០៦ ។

## ដាច់ប្រគេនព្រោះហេតុ ៧ យ៉ាង

ពិតមែន ព្រះពុទ្ធវចនៈនេះ ព្រះមានព្រះភាគត្រាស់សំដៅយកភេទត្រឡប់ ។ ដែលឈ្មោះថា ការទទួលប្រគេន រមែងដាច់វិញ ព្រោះភេទត្រឡប់ ១ ព្រោះមរណភាព ១ ព្រោះលាសិក្ខា (ការសឹករបស់ភិក្ខុមិនត្រូវបារាជិក) ១ ព្រោះវិលទៅកាន់ភេទថោកទាប (ការសឹករបស់ភិក្ខុត្រូវ

បារាជិក ) ១ ព្រោះឱ្យដល់អនុបសម្បន្ន ១ ព្រោះមិនស្ដាយលះបង់ចេញ ១ ព្រោះត្រូវចោរដណ្ដើមយកទៅ ១ ព្រោះដូច្នោះ សូម្បីបើមានវត្ថុដែលទទួលប្រគេនរក្សាទុក នឹងជាចំណិតសម៉ក៏ដោយ វត្ថុទាំងអស់របស់នាង រមែងជាច់ប្រគេនវិញ ។ មួយទៀត វត្ថុណាមួយដែលជារបស់នាងភិក្ខុនីនោះទទួលប្រគេនហើយ ឬមិនទាន់បានទទួលប្រគេនក៏ដោយ ដែលរក្សាទុកក្នុងវិហាររបស់ភិក្ខុ, ភិក្ខុនីរូបនោះឯងជាធំនៃវត្ថុទាំងអស់ គួរឱ្យនាងនាំយកចេញទៅ ។ ចំណែកវត្ថុណាជារបស់ថាវរដែលជារបស់ចំណែកខ្លួននាងក្នុងវិហាររបស់ភិក្ខុនេះ ទោះជាសេនាសនៈ ឬដើមឈើដែលដាំទុកក៏ដោយ, នាងប្រាថ្នានឹងឱ្យវត្ថុទាំងនោះដល់បុគ្គលណា ក៏គប្បីឱ្យដល់បុគ្គលនោះ ។

បណ្ដាសម្មុតិ ១៣ យ៉ាង សម្មុតិដែលលោកបានក្នុងវេលាជាភិក្ខុ រមែងរម្ងាប់ទៅទាំងអស់ ។ ការកាន់សេនាសនៈក្នុងថ្ងៃចូលវស្សាដំបូងរមែងរម្ងាប់ទៅ ។ បើភេទត្រឡប់ក្នុងកាលលោកកាន់សេនាសនៈក្នុងថ្ងៃចូលវស្សាក្រោយហើយ និងភិក្ខុសង្ឃប្រាថ្នានឹងឱ្យលាភដែលកើតឡើងដល់លោក គួរអបលោកនៈឱ្យ ។ បើក្លាយភេទកាលកំពុងនៅបរិវាសដើម្បីអាបត្តិដែលបិទទុកទូទៅដល់នាងភិក្ខុនី, សង្ឃគប្បីឱ្យបក្ខមានត្តតែម្ដង ។ បើក្លាយភេទកំពុងប្រព្រឹត្តមានត្ត, គួរឱ្យបក្ខមានត្តដដែលទៀត ។

បើក្លាយភេទកាលប្រព្រឹត្តមានត្តហើយ, ពួកភិក្ខុនីគួរធ្វើអព្ភានកម្ម ។ បើកាលអកុសលវិបាកអស់ហើយ ក្លាយភេទត្រឡប់មកវិញថ្មីទៀតក្នុងកាលនៃបក្ខមានត្ត គប្បីឱ្យមានត្ត ៦ រាត្រីប៉ុណ្ណោះ ។ បើប្រព្រឹត្តបក្ខមានត្តសម្រេចហើយ ទើបក្លាយភេទត្រឡប់ត្រឡប់មកវិញ, ពួកភិក្ខុគប្បីធ្វើអព្ភានកម្មដូច្នេះឯង ។

ក្នុងរឿងក្លាយភេទរបស់នាងភិក្ខុនីក្នុងលំដាប់តទៅ គប្បីជ្រាបវិនិច្ឆ័យទាំងពួងតាមន័យដែលពោលហើយក្នុងរឿងនេះឯង ។ ចំណែកសេចក្តីដែលប្លែកគ្នាមានដូចតទៅនេះ ៖

សូម្បីបើក្នុងវេលាជាភិក្ខុនី មានសញ្ចរិតអាបត្តិដែលត្រូវហើយបិទទុក, មិនមានការឱ្យបរិវាស, គប្បីឱ្យមានត្ត ៦ រាត្រីតែម្តង ។ ភេទត្រឡប់កាលកំពុងប្រព្រឹត្តបក្ខមានត្ត, មិនត្រូវការដោយបក្ខមានត្តនោះ គប្បីឱ្យមានត្ត ៦ រាត្រីដូចគ្នា ។ បើភេទត្រឡប់កាលប្រព្រឹត្តមានត្តរួចហើយ, មិនត្រូវឱ្យមានត្តដដែលទៀត ភិក្ខុទាំងឡាយគប្បីឱ្យអព្ភាន ។ បើកាលភិក្ខុទាំងឡាយមិនទាន់ឱ្យមានត្ត ភេទក្លាយត្រឡប់មកវិញ, ពួកភិក្ខុនីគប្បីឱ្យបក្ខមានត្តនុ៎ះឯង ។ បើកំពុងប្រព្រឹត្តមានត្ត ៦ រាត្រី ភេទក្លាយត្រឡប់មកវិញទៀត, គប្បីឱ្យបក្ខមានត្តដូចគ្នា ។ តែកាលប្រព្រឹត្តមានត្តរួចហើយ ភេទក្លាយត្រឡប់មកវិញដូចដើម ពួកភិក្ខុនីគប្បីធ្វើអព្ភាន

កម្ម ។ មួយទៀត សូម្បីកាលនាងភិក្ខុនីនោះ តាំងនៅក្នុងភាពជាភិក្ខុក្នុងកាលភេទក្លាយត្រឡប់មកដូចដើមវិញហើយ អាបត្តិទាំងឡាយណាដែលរម្ងាប់ទៅហើយក្នុងកាលមុន អាបត្តិទាំងឡាយនោះ ជាការរម្ងាប់ដោយល្អតែម្តងនុ៎ះឯង ។

[៥៧] រឿងមាតា រឿងធីតា រឿងប្អូនស្រី រឿងប្រពន្ធ ទាំង ៤ រឿង តពីក្លាយភេទនេះទៅ មានជាដើមថា "**មាតុយា មេថុនំ ធម្មំ** : សេពមេថុនធម្មនឹងមាតា (របស់ខ្លួន)" ដូច្នេះ មានសេចក្តីច្បាស់លាស់ហើយទាំងនោះ ។

[៥៨] ក្នុងរឿងភិក្ខុខ្នងទន់ មានវិនិច្ឆ័យដូច្នេះ ៖

បានឮថា ភិក្ខុនោះធ្លាប់ជាអ្នករបាំ, ខ្នងរបស់លោកបានធ្វើការហ្វឹកហាត់មកហើយ ដើម្បីភាពជាអ្នកឆ្លាតក្នុងសិល្បៈ ទើបបានជាអវយវៈទន់ ។ ព្រោះដូច្នោះ លោកទើបអាចធ្វើកម្មយ៉ាងនោះបាន ។

ក្នុងរឿងភិក្ខុមានអង្គជាតយាវវែង មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនោះមានអង្គជាតិវែង ; ព្រោះដូច្នោះ លោកទើបហៅថា លម្ពី អ្នកមានអង្គជាតយាវវែង ។

[៥៩] រឿងស្នាមដំបៅពីរយ៉ាង បន្ទាប់ពីរឿងភិក្ខុមានអង្គជាតិយាវវែងនេះទៅ មានសេចក្តីជាក់ច្បាស់ហើយតែម្តង ។

[៦០] ក្នុងរឿងរូបគំនូរ មានវិនិច្ឆ័យដូច្នេះ ៖

រូបដែលធ្វើដោយចិត្រកម្ម ឈ្មោះថា លេបចិត្ត គឺ រូបគំនូរ ។

ក្នុងរឿងឈើចំឡាក់ជារូបធីតា មានវិនិច្ឆ័យដូច្នេះ ៖

រូបដែលគេធ្វើដោយឈើ ឈ្មោះថា តុក្កតាឈើ ។ កាលភិក្ខុព្យាយាមក្នុងរូបចិត្រកម្មនិងរូបតុក្កតាឈើទាំង ២នេះ ជាទុក្កដ មានឧបមាយ៉ាងណា, កាលព្យាយាមដោយសេចក្តីតម្រេកក្នុងមេថុនដែលនិមិត្តក្នុងរូបស្រីដែលជាអនុបាទិន្នកៈ (រូបដែលមិនមានចិត្តគ្រប់គ្រង) មានរូបធ្វើដោយភ្លុកដំរី រូបស្មូនទ្បនិងរូបលោហៈជាដើមស្មូម្បីពួកដទៃ អសុចិ នឹងឃ្លាតចេញឬមិនចេញក៏ដោយ ជាទុក្កដតែម្តង ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ស្មូម្បីកាលនឹងព្យាយាមដោយសេចក្តីតម្រេកក្នុងការស្ទាបអង្អែលកាយ ក៏ជាទុក្កដដូចគ្នាដែរ ។ តែកាលព្យាយាមដោយសេចក្តីតម្រេកក្នុងការបញ្ចេញ កាលអសុចិឃ្លាតចេញជាសង្ឃាទិសេស, កាលមិនឃ្លាតចេញ ជាថុល្លច្ច័យ ដូច្នេះឯង ។

[៦១] ក្នុងរឿងសុន្ទរភិក្ខុ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនេះ ឈ្មោះសុន្ទរ ជាក្មេងកម្លោះរបស់ត្រកូលក្នុងក្រុងរាជគ្រឹះ បួសដោយសទ្ធា ព្រោះលោកមានរាងកាយស្អាតល្អ ទើបបានទាមថា

សុន្ទរ ។ ស្រ្តីនោះ ប្រទះឃើញលោកកំពុងដើរទៅតាមថ្នល់ ក៏កើតឆន្ទរាគៈ ឡើងហើយបានធ្វើអាការដែលប្លែកនេះ ។ ចំណែកព្រះថេរៈជាព្រះអនាគាមី ; ព្រោះហេតុនោះ លោកទើបមិនត្រេកអរ ។ ដែលសភាពគឺសេចក្ដីមិនត្រេកអរនេះ មិនមែនវិស័យរបស់បុថុជ្ជនពួកដទៃ ។

[៦២] ក្នុងរឿងភិក្ខុ ៤ រូប បន្ទាប់ពីរឿងព្រះសុន្ទរនេះទៅ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុទាំងនោះ ជាអ្នកភ្លីភ្លើល្ងង់ខ្លៅទទួលពាក្យរបស់មាតុគ្រាម ហើយធ្វើតាមយ៉ាងនោះ ខាងក្រោយទើបមានសេចក្ដីរង្កៀសឡើង ។ ៣ រឿង មានរឿងសាកសពដែលសត្វមិនទាន់បានខាំស៊ីជាដើម មានសេចក្ដីច្បាស់លាស់ហើយទាំងនោះ ។

## រឿងភិក្ខុ ៥ រូប នៅក្នុងព្រៃខ្មោច

[៦៣] ក្នុងរឿងក្បាលខ្មោចដាច់ ២ រឿង មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា **វិវដ្ដកតេ**[១] **មុខេ** : ក្នុងមាត់ដែលបើកហា គឺ ក្នុងមាត់ដែលហាប្រហ ។ ភិក្ខុកាលស៊កអង្គជាតចូលទៅ (ក្នុងមាត់ដែលហាប្រហនោះ) បើស៊កចូលទៅឱ្យត្រូវខាងក្រោមក្ដី ខាងលើក្ដី ខាងទាំង

ពីរក្តី ជាបារាជិក ។ គ្រាសិកចូលទៅមិនត្រូវទាំង ៤ ខាង តែត្រូវពិតាន ខាងក្នុងជាបារាជិកដូចគ្នា ។ កាលមិនត្រូវទាំង ៤ ខាង និងពិតាន សិកឱ្យបិតទៅលើអាកាសប៉ុណ្ណោះ និងដកចេញ ជាទុក្កដ ។ មួយទៀត បើធ្មេញបិទជិតស្និទ្ធល្អ ខាងក្នុងមាត់ មិនមានប្រហោង និងធ្មេញត្រូវសាច់បបូរមាត់ខាងក្រៅបិទ កាលភិក្ខុសិកចូលទៅកាន់ឱកាស ដែលសើមដែលខ្យល់មិនពាល់ត្រូវ ក្នុងមាត់ដែលមានសាច់បបូរមាត់បិទទុកនោះ សូម្បីពាល់មួយ គ្រាប់ល្ង ជាបារាជិកដូចគ្នា ។ តែកាលព្យាយាមចំពោះត្រង់ធ្មេញ ដែលមានសាច់បបូរមាត់គេចៀរចេញទៅហើយ ជាថុល្លច្ច័យ ។ សូម្បីធ្មេញណា ដែលលៀនចេញទៅខាងក្រៅ មិនអាចនឹងបិទបបូរមាត់បាន, កាលភិក្ខុព្យាយាមត្រង់ធ្មេញនោះក្តី ព្យាយាមត្រង់អណ្តាតដែលលៀនចេញទៅខាងក្រៅក្តី ជាថុល្លច្ច័យដូចគ្នា ។ សូម្បីក្នុងសរីរៈដែលនៅមានជីវិត កាលព្យាយាមត្រង់អណ្តាតដែលលៀនចេញទៅខាងក្រៅ ជាថុល្លច្ច័យដូចគ្នា ។ តែបើផុតអណ្តាតដែលលៀនចេញទៅខាងក្រៅហើយ ទើបសិកអង្គជាតចូលទៅក្នុងមាត់ ជាបារាជិកដូចគ្នា ។ កាលសិកអង្គជាតិចូលទៅលើ-កផ្ទែកខាងក្រោម សូម្បីនៃសាកសពដែលមានក្បាលដាច់ ត្រូវពិតាន ជាបារាជិកដូចគ្នា ។

---

១. ថៃ. ភូមា. វដ្តកតេ ។

ក្នុងរឿងឆ្អឹង មានវិនិច្ឆ័យដូច្នេះ ៖

សូម្បីកាលភិក្ខុកំពុងដើរទៅកាន់សុសាន ( ព្រៃខ្មោច ) ជាទុក្កដ កាលរួបរួមឆ្អឹងមកទុកក្តី គរទុកក្តី ព្យាយាមត្រង់និមិត្តដោយសេចក្តីតម្រេកក្នុងមេថុនក្តី ព្យាយាមដោយសេចក្តីតម្រេកក្នុងការស្ទាបអង្អែលកាយក្តី អសុចិឃ្លាតចេញ ឬមិនឃ្លាតក៏ដោយ ជាទុក្កដទាំងអស់ តែកាលព្យាយាមដោយសេចក្តីតម្រេកក្នុងការបញ្ចេញ កាលអសុចិឃ្លាតចេញជាសង្ឃាទិសេស កាលមិនឃ្លាតចេញជាថុល្លច្ច័យ ។

[ ៦៤ ] ក្នុងរឿងនាគញី មានវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុសេពមេថុនធម្ម ក្នុងពួកសត្វទាំងពួង ទីងនាងនាគមាណវិកា ឬបណ្តានាងកិន្នរីជាដើមណាមួយក៏ដោយ ជាបារាជិក ។

ក្នុងរឿងនាងយក្ខិណី មានវិនិច្ឆ័យដូច្នេះ ៖

ទេវតាសូម្បីទាំងអស់ ក៏គឺ នាងយក្ខិណីនុ៎ះឯង ។

## ភិក្ខុសេពមេថុនធម្មក្នុងស្រីប្រេតជាដើមជាបារាជិក

ក្នុងរឿងស្រីប្រេត មានវិនិច្ឆ័យដូច្នេះ ៖

ប្រេតទាំងឡាយមាននិជ្ឈាមតណ្ហិកប្រេតជាដើម អ្នកណា ៗ មិនអាចសូម្បីទីងប៉ះពាល់បាន ។ តែនាងវិមានប្រេតទាំងឡាយ មាន

អកុសលកម្មរបស់នាងវិមានប្រេតពួកណា ឱ្យផលនៅក្នុងខាងកាឡបក្ខ នាងវិមានប្រេតទាំងនោះ រមែងបានសោយសម្បត្តិ ក្នុងខាងជុណ្ហបក្ខ ដូចទេវតា ដូច្នោះ ។ បើការឃើញ ការចាប់ ការស្ទាបអង្អែល ការពាល់ត្រូវ និងការប៉ះខ្ទប់ របស់ស្រីប្រេត ឬរបស់នាងយក្ខិណីបែបនោះប្រាកដបាន ជាបារាជិក ។ បើសូម្បីមិនមានការឃើញតែកិច្ចក្រៅនេះប្រាកដ ក៏ជាបារាជិកដូចគ្នា ។

ម្យ៉ាងទៀត ការឃើញនិងការចាប់ មិនប្រាកដ តែប្រេតធ្វើបុគ្គលនោះ(គឺ ភិក្ខុ) ឱ្យប្រាសចាកសញ្ញា (អស់សតិ) ដោយការស្ទាបអង្អែល ពាល់ត្រូវ និងប៉ះខ្ទប់ដែលប្រាកដ ឱ្យសម្រេចមនោរថរបស់ខ្លួនហើយក៏ទៅ សេចក្តីព្យាយាមនេះ ឈ្មោះថា មិនមែនវិស័យព្រោះដូច្នោះ ក្នុងទង្វើនេះ ទើបមិនជាអាបត្តិ ព្រោះមិនមែនវិស័យ ។

រឿងមនុស្សខ្ទើយ ប្រាកដច្បាស់ហើយឯង ។

[៦៥] ក្នុងរឿងភិក្ខុកើតរោគស្ពឹក មានវិនិច្ឆ័យដូច្នេះ ៖

បទថា **ឧបហតិន្ទ្រិយោ** : **មានឥន្ទ្រិយសាបសូន្យ(គឺមានរោគស្ពឹក)** សេចក្តីថា លោកមានកាយប្រសាទត្រូវរោគបៀតបៀនហើយរមែងមិនដឹងសុខ ឬ ទុក្ខ ដូចជផ្គត់ឈើនិងកំណាត់ឈើ ដូច្នោះ ។

សូម្បីកាលលោកមិនដឹង ក៏ជាអាបត្តិ ព្រោះអំណាចសេវនចិត្ត ។

[៦៦] ក្នុងរឿងចាប់មាតុគ្រាមប្រេងនឹងសេព មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណា គិតក្នុងចិត្តថា យើងនឹងសេពមេថុនធម្ម ទើបចាប់មាតុគ្រាមប្រាសចាកតម្រេកក្នុងមេថុនហើយ ជាអ្នកមានសេចក្តីវិប្បដិសារ ភិក្ខុនោះ ជាទុក្កដប៉ុណ្ណោះ ។ ព្រោះថា កិច្ចទាំងឡាយមានការចាប់ដៃជាដើម ជាបុព្វបយោគនៃមេថុនធម្ម រមែងតាំងនៅក្នុងទុក្កដ ដរាបណាដែលមិនទាន់ដល់ទីបំផុត កាលដល់ទីបំផុតហើយទើបជាបារាជិក ។ ពិតមែន ទុក្កដប៉ុណ្ណោះ ជិតចំពោះបឋមបារាជិក ។ ថុល្លច្ច័យ ក៏ជិតចំពោះបារាជិកសិក្ខាបទទាំង ៣ ក្រៅនេះ ។ ចំណែកភិក្ខុនេះ គប្បីជ្រាបថា ប្រាសចាកតម្រេកក្នុងមេថុនធម្មហើយ ត្រេកអរចំពោះការស្ទាបអង្អែលកាយ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ជាអាបត្តិសង្ឃាទិសេស ។

[៦៧] ក្នុងរឿងភិក្ខុ (ជាព្រះអរហន្ត) សិងលក់ក្នុងទីស្ងាត់ក្បែរក្រុងភទ្ទិយៈ មានវិនិច្ឆ័យដូច្នេះ ៖

នគរឈ្មោះថា ភទ្ទិយៈ ។ នគរនោះ ឈ្មោះថា ជាតិយាវន ក៏ព្រោះមានគុម្ពផ្កាម្លិះក្រាស់ ។ ព្រៃនោះមាននៅជិតឧបចារនៃព្រះនគរនោះ ។

ភិក្ខុនោះ សម្រាកសិងនៅត្រង់ព្រៃនោះ ហើយក៏លង់លក់យ៉ាងស្កប់ ព្រោះត្រូវខ្យល់ជួយបក់ផាត់នោះ ។ ភរិយ្គចិត្តមានក្រសែតែមួយប៉ុណ្ណោះត្រាច់ទៅ ។

ពីរបទថា កិលិន្នំ បស្សិត្វា : ឃើញសេចក្ដីសៅហ្មង សេចក្ដីថា ឃើញអង្គជាតិប្រឡាក់ប្រឡូសដោយអសុចិ ។

[៦៨] រឿងភិក្ខុទាំងឡាយ ៤ រូបឯទៀតក្នុងក្រុងសាវត្ថី បន្ទាប់ពីរឿងភិក្ខុក្រុងភទ្ទិយៈនេះទៅ គឺ រឿងដែលបដិសំយុត្តដោយសេចក្ដីត្រេកអរមាន ៤ រឿង និងរឿងមិនរលឹកដឹងខ្លួនមាន ១ រឿង មានសេចក្ដីច្បាស់លាស់ហើយតែម្ដង ។

[៦៩] ក្នុងរឿងមិនត្រេកអរទៀត ២ រឿង មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា សហសា វុដ្ឋាសិ : ក្រោកឡើងដោយរហ័ស សេចក្ដីថា ភិក្ខុនោះ ប្រញាប់ក្រោកឡើងភ្លាម ដូចត្រូវអាសិរពិសខាំ និងដូចត្រូវភ្លើងឆេះ ដូច្នោះ ។

ពីរបទថា អក្កមិត្វា បវត្តេសិ : ក៏ធាក់ប្រាន(ឱ្យស្រីនោះ)ខ្ទាតចេញទៅ សេចក្ដីថា ភិក្ខុដែលមិនប្រមាទចាប់ផ្ដើមចម្រើនវិបស្សនា មានសតិតាំងទុកចំពោះមុខ ប្រញាប់ក្រោកឡើងភ្លាម ធាក់ឱ្យប្រមៀលធ្លាក់ទៅលើផែនដី ។ កលប្រាណបុថុជ្ជនទាំងឡាយ គួររក្សាចិត្តទុក ក្នុង

ឋាន:បែបនេះ ។ ក៏ភិក្ខុនេះ ជាភិក្ខុមួយរូបក្នុងបណ្តាភិក្ខុជាកល្យាណបុថុជ្ជនទាំងនោះ ជាកំពូលនៃអ្នកច្បាំងក្នុងសង្គ្រាម ។

## រឿងភិក្ខុបើកទ្វារសិង

[៧០] ក្នុងរឿងបើកទ្វារសិង មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា ទិវា បដិសល្លិយន្តេន : កាលដែលសិងសម្ងំក្នុងវេលាថ្ងៃ សេចក្តីថា អ្នកសិងក្នុងពេលថ្ងៃ ។

ច្រើនបទថា ទ្វារំ សំវរិត្វា បដិសល្លិយិតុំ : ត្រូវបិទទ្វារហើយសឹមសិងសម្ងំចុះ សេចក្តីថា ដើម្បីឱ្យបិទទ្វារជាមុនទើបសិងបាន ។ ក៏ក្នុងរឿងបើកទ្វារសិងនេះ ក្នុងព្រះបាលីព្រះមានព្រះភាគមិនបានពិន័យអាបត្តិទុកថា ជាអាបត្តិឈ្មោះនេះ ក៏ពិតមែនហើយ តែថាព្រះថេរ:ទាំងឡាយ ក៏ពិន័យជាទុក្កដដល់ភិក្ខុដែលមិនបិទទ្វារមុនសិងព្រោះកាលរឿងកើតឡើង ព្រោះទោសដែលបើកទ្វារសិង ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ កាលដែលសិងសម្ងំក្នុងវេលាថ្ងៃ ត្រូវបិទទ្វារ ហើយសឹមសិងសម្ងំចុះ" ។

ពិតមែន ព្រះថេរ:ទាំងឡាយ មានព្រះឧបាលីថេរ:ជាដើម ជ្រាប

ព្រះបំណាំងរបស់ព្រះមានព្រះភាគហើយ ទើបបានតាំងអដ្ឋកថាទុក ។ ក៏ពាក្យដែលថា ជាទុក្កដដល់ភិក្ខុដែលមិនបិទទ្វារមុនសិន នេះ សម្រេចហើយសូម្បីដោយពាក្យនេះថា មានអាបត្តិដែលភិក្ខុត្រូវក្នុងពេលថ្ងៃ មិនត្រូវក្នុងពេលយប់ ។

## អធិប្បាយទ្វារគួរបិទនិងមិនគួរបិទ

សួរថា ក៏ទ្វារយ៉ាងណាគួរបិទ ? យ៉ាងណាមិនគួរបិទ ?

ឆ្លើយថា ទ្វារវិលដែលគេយកបណ្តាវត្ថុប្រភេទណាមួយ មានបន្ទះក្តារ បន្ទះឫស្សី កន្ទេលនិងស្លឹកឈើជាដើម ធ្វើជាសន្លឹកទ្វារហើយ ខាងក្រោមសឹកមេទ្វារទុកក្នុងតំណាប់ ខាងលើសឹកមេទ្វារក្នុងក្រវិលលើទ្រនុំឯងគួរបិទ ។ ទ្វារប្រភេទដទៃបែបនេះ គឺ ទ្វារគន្លឹះឈើនិងទ្វារបន្ទា ត្រង់ក្រោលគោ ទ្វារមានកង់រំកិលសម្រាប់ការពារផ្ទះក្នុងស្រុក ទ្វារកង់វិលដែលគេធ្វើប្រកបកូនកង់ ២-៣ ដែលទុកត្រង់ផែនក្តារ ឬត្រង់ប្រដីស (ត្បាញដោយរនាប) ទ្វារប្រដីសទល់ឡើងដែលគេធ្វើលើកចេញបានដូចយ៉ាងក្នុងរានផ្សារ ទ្វារបន្ទះក្តារដែលគេយកបន្ទះឫស្សីគួបទុក ២-៣ កន្លែង ធ្វើទុកត្រង់បណ្តុក្ដិ (ខ្ទមស្លឹកឈើ) ទ្វារាំងនន មិនគួរបិទ ។

ក៏ទ្វារវាំងននមួយប្រភេទប៉ុណ្ណោះ មិនធ្វើឱ្យត្រូវអាបត្តិ ក្នុងវេលាដែលភិក្ខុមានបាត្រក្នុងដៃ រុញប្រាទទ្វារនោះ ។ កាលរុញទ្វារដ៏សេសត្រូវអាបត្តិ ។ តែទ្វារវិលទុំះឯង ធ្វើឱ្យត្រូវអាបត្តិដល់ភិក្ខុដែលសិងក្នុងពេលថ្ងៃ ។ ទ្វារដ៏សេស កាលភិក្ខុបិទក៏ដោយ មិនបិទក៏ដោយហើយសិងអាបត្តិមិនមានទេ តែគួរបិទមុន ទើបសិង ប្រការនេះជាធម្មទំនៀម ។

សួរថា ក៏ទ្វារវិល រមែងជាការបិទល្អហើយ ដោយហេតុមានប្រមាណប៉ុនណា ?

ឆ្លើយថា កាលដាក់គន្លឹះនិងស្នៀតហើយ ក៏ជាការបិទដោយល្អតែម្ដង ។ មួយទៀត សូម្បីកាលដាក់ត្រឹមតែគន្លឹះហើយទឹងសិងក៏គួរ សូម្បីកាលដាក់ត្រឹមតែស្នៀតហើយ ទឹងសិងក៏គួរ សូម្បីកាលបិទល្មមឱ្យសន្លឹកទ្វារទល់គ្នាហើយ ទឹងសិងក៏គួរ សូម្បីកាលបិទបង្អើបទុកបន្តិចបន្តួចហើយ ទឹងសិងក៏គួរ ដោយវិធីយ៉ាងទាបបំផុត សូម្បីកាលបិទទ្វារបង្អើបទុកខ្វាតល្មមសីសៈស៊កចូលមិនបាន ទឹងសិង ក៏គួរដូច្នេះឯង ។

បើស្ថានទីនោះ ជាទីប្រើរបស់មនុស្សច្រើនគ្នា សូម្បីទឹងនិយាយចំពោះភិក្ខុ ឬសាមណេរថា "អាវុសោ ចូរជួយគ្នារក្សាទ្វារ" ហើយសិងក៏គួរ ។ បើសូម្បីទឹងធ្វើការតាំងចិត្តទុកថា "ភិក្ខុទាំងឡាយអ្នកអង្គុយធ្វើ

ចីវរកម្ម ឬកិច្ចយ៉ាងណាមួយ លោកទាំងនោះនឹងជួយរក្សាទ្វារនោះ” ដូច្នេះ ហើយសិង ក៏គួរ ។

ចំណែកក្នុងអដ្ឋកថាកុរុន្ទីពោលថា នឹងប្រាប់សូម្បីចំពោះឧបាសក ឬនឹងធ្វើការតាំងចិត្តទុកថា “ឧបាសកនេះនឹងជួយរក្សា ហើយសិង” ក៏គួរ នឹងប្រាប់ភិក្ខុនីឬមាតុគ្រាមតែម្យ៉ាង មិនគួរ ។

បើកូនកង់ឬក្រវិលលើទ្វារវិនាសអស់ទៅ ឬមិនតាំងនៅ(ក្នុងទីដើម) ទើបមិនអាចនឹងបិទបាន ក៏ម្យ៉ាងទៀត ដើម្បីប្រយោជន៍ដល់នវកម្ម គេធ្វើគំនរឥដ្ឋឬគំនរដីស្អិតជាដើមទុកខាងក្នុងទ្វារ ឬចងភ្ជាប់រានទុក ដោយមិនអាចនឹងបិទ (ទ្វារ) បាន ក្នុងអន្តរាយបែបនោះ សូម្បីនឹងមិនបិទទ្វារសិង ក៏គួរ ។ ក៏បើមិនមានសន្ទឹកទ្វារ ជាការបានខអាងពិត ។ កាលនឹងសិងខាងលើគួរលើកវាំងននឡើងទុក ទើបសិង ។ បើខាងលើវាំងនន មានឈើសម្រាប់ការពារទុក គួរការពារទុកទើបសិង ។ កាលនឹងសិងក្នុងបន្ទប់ នឹងបិទទ្វារឬទ្វារមុខមុខយ៉ាងណាមួយទុកហើយសិង ក៏គួរ ។ បើទីខាងទាំងពីរក្នុងផ្ទះមានជញ្ជាំងផ្ទែកតែមួយរួមគ្នា គេធ្វើទ្វារប្រើច្រើន, គួររក្សាទាំងពីរទ្វារ ។ ក្នុងប្រាសាទសូម្បី ៣ ជាន់ គួររក្សាទ្វារតែមួយប៉ុណ្ណោះ ។ បើភិក្ខុច្រើនរូប ត្រឡប់ពីត្រាច់

ភិក្ខាចារ ចូលទៅកាន់ប្រាសាទ ដូចលោហប្រាសាទ ដើម្បីសម្រាកពេលថ្ងៃ, ព្រះសង្ឃត្ថេរ គួរបង្គាប់អ្នករក្សាទ្វារថា ចូរជួយរក្សាទ្វារឬនឹងធ្វើសេចក្តីចងចិត្តទុកថា ការរក្សាទ្វារ ជាភារៈរបស់នាយទ្វារបាលនោះ ហើយគប្បីចូលទៅសិងចុះ ។ ភិក្ខុទាំងឡាយគួរធ្វើយ៉ាងនោះ ដូចគ្នាជរាបដល់ព្រះសង្ឃនវកៈ ។ អ្នកដែលចូលទៅមុនសូម្បីនឹងធ្វើសេចក្តីចងចិត្តទុកយ៉ាងនេះថា ដែលឈ្មោះថា ការរក្សាទ្វារ ជាភារៈរបស់អ្នកមកខាងក្រោយ ដូច្នេះ ក៏គួរ ។

កាលភិក្ខុមិនធ្វើការប្រាប់ ឬសេចក្តីចងចិត្តទុកទេ ហើយសម្រាកសិងខាងក្នុងបន្ទប់ដែលមិនបានបិទទ្វារ ឬខាងក្រៅបន្ទប់ ជាអាបត្តិ ។ សូម្បីក្នុងវេលាសិងក្នុងបន្ទប់ឬក្នុងខាងក្រៅបន្ទប់ ធ្វើសេចក្តីចងចិត្តទុកថា ដែលឈ្មោះថា ការរក្សាទ្វារ ក្នុងទ្វារធំ ជាភារៈរបស់នាយទ្វារបាល ដូច្នេះ ហើយសិង គួរដូចគ្នា ។ សូម្បីភិក្ខុអ្នកនឹងសិងក្នុងទីវាលស្រឡះ ( ទីគ្មានជញ្ជាំង ) ក្នុងស្ថានទីមានលោហប្រាសាទជាដើម គួរបិទទ្វារពិតតែម្តង ។

ក៏ក្នុងរឿងបិទទ្វារសិងនេះ មានសេចក្តីសង្ខេបដូចតទៅនេះ ៖

ការសម្រាកក្នុងពេលថ្ងៃនេះ លោកពោលទុកក្នុងស្ថានទីមានរបៀងដែលលោមព័ទ្ធដោយកំផែង ឬរបងយ៉ាងណាមួយ ។ ព្រោះដូច្នោះ កាល

ភិក្ខុដែលនឹងសិងក្នុងទីវាលគល់ឈើ ឬមណ្ឌបណាមួយ ដែលមានរបៀងគួរបិទទ្វារសិង សឹមសិង ។ បើជាបរិវេណធំ ដែលជាស្ថានទីជុំនុំរបស់មនុស្សពួកច្រើន ដូចលានមហាពោធិព្រឹក្សនិងលានលោហប្រាសាទ, ក្នុងស្ថានទីណា ទ្វារសូម្បីដែលគេបិទហើយ ក៏មិនតាំងនៅក្នុងទីដែលបិទ( គឺបិទបើក ៗ ) មនុស្សទាំងឡាយ កាលមិនបានទ្វារ ត្រូវឡើងតាមកំផែងផ្លោះទៅ, ក្នុងស្ថានទីនោះ មិនមានកិច្ចដែលនឹងត្រូវបិទ ( ទ្វារ ) ។

ភិក្ខុបើកទ្វារសិងរហូតទល់ភ្លឺ ក្រោកឡើងហើយក្នុងវេលាអរុណរះមិនជាអាបត្តិ ។ តែបើភ្ញាក់ហើយលក់ដដែលទៀតជាអាបត្តិ ។ ចំណែកភិក្ខុណាកំណត់ទុកតែម្តងថា កាលអរុណរះហើយនឹងក្រោកឡើង មិនបានបិទទ្វារសិងរហូតដល់ភ្លឺ តែក្រោកឡើងទាន់តាមកំណត់នុ៎ះឯង, ភិក្ខុនោះ ជាអាបត្តិតែម្តង ។ ចំណែកក្នុងអដ្ឋកថា មហាបច្ចរីលោកពោលទុកថា កាលសិងដោយអាការយ៉ាងនោះ មិនផុតពីទុក្កដព្រោះមិនអើពើ ។

## រឿងភិក្ខុបើកទ្វារសិង

[៧០] ក្នុងរឿងបើកទ្វារសិង មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា ទិវា បដិសល្លិយន្តេន : កាលដែលសិងសម្ងំក្នុងវេលាថ្ងៃ សេចក្តីថា អ្នកសិងក្នុងពេលថ្ងៃ ។

ច្រើនបទថា ទ្វារំ សំវរិត្វា បដិសល្លិយិតុំ : ត្រូវបិទទ្វារ ហើយសឹមសិងសម្ងំចុះ សេចក្ដីថា ដើម្បីឱ្យបិទទ្វារជាមុនទើបសិងបាន ។ ក៏ក្នុងរឿងបើកទ្វារសិងនេះ ក្នុងព្រះបាលីព្រះមានព្រះភាគមិនបានពិន័យអាបត្តិទុកថា ជាអាបត្តិឈ្មោះនេះ ក៏ពិតមែនហើយ តែថាព្រះថេរៈទាំងឡាយ ក៏ពិន័យជាទុក្កដដល់ភិក្ខុដែលមិនបិទទ្វារមុនសិង ព្រោះកាលរឿងកើតឡើង ព្រោះទោសដែលបើកទ្វារសិង ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ កាលដែលសិងសម្ងំក្នុងវេលាថ្ងៃ ត្រូវបិទទ្វារ ហើយសឹមសិងសម្ងំចុះ" ។

ពិតមែន ព្រះថេរៈទាំងឡាយ មានព្រះឧបាលីថេរៈជាដើម ជ្រាបព្រះបំណងរបស់ព្រះមានព្រះភាគហើយ ទើបបានតាំងអដ្ឋកថាទុក ។ ក៏ពាក្យដែលថា **ជាទុក្កដដល់ភិក្ខុដែលមិនបិទទ្វារមុនសិង** នេះ សម្រេចហើយស្តូវ្បីដោយពាក្យនេះថា មានអាបត្តិដែលភិក្ខុត្រូវក្នុងពេលថ្ងៃ មិនត្រូវក្នុងពេលយប់ ។

## អធិប្បាយទ្វារគួរបិទនិងមិនគួរបិទ

សួរថា ក៏ទ្វារយ៉ាងណាគួរបិទ ? យ៉ាងណាមិនគួរបិទ ?

ឆ្លើយថា ទ្វារវិលដែលគេយកបណ្ដាវត្ថុប្រភេទណាមួយ មានបន្ទះ

ក្តារ បន្ទះឫស្សី កន្ទេលនិងស្លឹកឈើជាដើម ធ្វើជាសន្លឹកទ្វារហើយ ខាងក្រោមសឹកមេទ្វារទុកក្នុងតំណាប់ ខាងលើសឹកមេទ្វារក្នុងក្រវិលលើទ្រុំឯង គួរបិទ ។ ទ្វារប្រភេទដទៃបែបនេះ គឺ ទ្វារគន្លឹះឈើនិងទ្វារបន្ទា ត្រង់ក្រោលគោ ទ្វារមានកង់វិលសម្រាប់ការពារផ្ទះក្នុងស្រុក ទ្វារកង់វិលដែលគេធ្វើប្រកបកូនកង់ ២-៣ ដែលទុកត្រង់ផែនក្តារ ឬត្រង់ប្រដឹស (ត្បាញដោយរនាប) ទ្វារប្រដឹសទល់ឡើងដែលគេធ្វើលើកចេញបាន ដូចយ៉ាងក្នុងរានផ្សារ ទ្វារបន្ទះក្តារដែលគេយកបន្ទះឫស្សីគួបទុក ២-៣ កន្លែង ធ្វើទុកត្រង់បណ្តុកជិ (ខ្ទមស្លឹកឈើ) ទ្វាររាំងនន មិនគួរបិទ ។

ក៏ទ្វាររាំងននមួយប្រភេទប៉ុណ្ណោះ មិនធ្វើឱ្យត្រូវអាបត្តិ ក្នុងវេលាដែលភិក្ខុមានបាត្រក្នុងដៃ រុញច្រានទ្វារនោះ ។ កាលរុញទ្វារដ៏សេសត្រូវអាបត្តិ ។ តែទ្វារវិលទ្រុំឯង ធ្វើឱ្យត្រូវអាបត្តិដល់ភិក្ខុដែលសិងក្នុងពេលថ្ងៃ ។ ទ្វារដ៏សេស កាលភិក្ខុបិទក៏ដោយ មិនបិទក៏ដោយហើយសិងអាបត្តិមិនមានទេ តែគួរបិទមុន ទើបសិង ប្រការនេះជាធម្មទំនៀម ។

សួរថា ក៏ទ្វារវិល រមែងជាការបិទល្អហើយ ដោយហេតុមានប្រមាណប៉ុនណា ?

ឆ្លើយថា កាលដាក់គន្លឹះនិងស្នៀតហើយ ក៏ជាការបិទដោយល្អតែ

ម្តង ៗ មួយទៀត សូម្បីកាលដាក់ត្រឹមតែគន្លឹះហើយនឹងសិងក៏គួរ សូម្បីកាលដាក់ត្រឹមតែស្នៀតហើយ នឹងសិងក៏គួរ សូម្បីកាលបិទល្មមឱ្យសន្លឹកទ្វារទល់គ្នាហើយ នឹងសិងក៏គួរ សូម្បីកាលបិទបង្អើបទុកបន្តិចបន្តួចហើយ នឹងសិងក៏គួរ ដោយវិធីយ៉ាងទាបបំផុត សូម្បីកាលបិទទ្វារបង្អើបទុកខ្នាតល្មមសីសៈសិកចូលមិនបាន នឹងសិង ក៏គួរដូច្នេះឯង ៗ

បើស្ថានទីនោះ ជាទីប្រើរបស់មនុស្សច្រើនគ្នា សូម្បីនឹងនិយាយចំពោះភិក្ខុ ឬសាមណេរថា "អាវុសោ ចូរជួយគ្នារក្សាទ្វារ" ហើយសិងក៏គួរ ៗ បើសូម្បីនឹងធ្វើការតាំងចិត្តទុកថា "ភិក្ខុទាំងឡាយអ្នកអង្គុយធ្វើចីវរកម្ម ឬកិច្ចយ៉ាងណាមួយ លោកទាំងនោះនឹងជួយរក្សាទ្វារនោះ" ដូច្នេះ ហើយសិង ក៏គួរ ៗ

ចំណែកក្នុងអដ្ឋកថាកុរុន្ទី ពោលថា នឹងប្រាប់សូម្បីចំពោះឧបាសក ឬនឹងធ្វើការតាំងចិត្តទុកថា "ឧបាសកនេះនឹងជួយរក្សា ហើយសិង" ក៏គួរ នឹងប្រាប់ភិក្ខុនី ឬមាតុគ្រាមតែម្យ៉ាង មិនគួរ ៗ

បើកូនកង់ឬក្រវិលលើទ្វារវិនាសអស់ទៅ ឬមិនតាំងនៅ(ក្នុងទីដើម) ទើបមិនអាចនឹងបិទបាន ក៏ម្យ៉ាងទៀត ដើម្បីប្រយោជន៍ដល់នវកម្ម គេធ្វើគំនរឥដ្ឋឬគំនរដីស្អិតជាដើមទុកខាងក្នុងទ្វារ ឬចងភ្ជាប់រាន

ទុក ដោយមិនអាចនឹងបិទ (ទ្វារ) បាន ក្នុងអន្តរាយបែបនោះ សូម្បីនឹងមិនបិទទ្វារសិង ក៏គួរ ។ ក៏បើមិនមានសន្លឹកទ្វារ ជាការបានខអាងពិត ។ កាលនឹងសិងខាងលើគួរលើករាំងននទ្បើងទុក ទើបសិង ។ បើខាងលើរាំងនន មានឈើសម្រាប់ការពារទុក គួរការពារទុក ទើបសិង ។ កាលនឹងសិងក្នុងបន្ទប់ នឹងបិទទ្វារឬទ្វារមុខមុខយ៉ាងណាមួយទុកហើយសិង ក៏គួរ ។ បើទីខាងទាំងពីរក្នុងផ្ទះមានជញ្ជាំងផ្ទែកតែមួយរួមគ្នា គេធ្វើទ្វារប្រើច្រើន, គួររក្សាទាំងពីរទ្វារ ។ ក្នុងប្រាសាទសូម្បី ៣ ជាន់ គួររក្សាទ្វារតែមួយប៉ុណ្ណោះ ។ បើភិក្ខុច្រើនរូប ត្រឡប់ពីត្រាច់ភិក្ខាចារ ចូលទៅកាន់ប្រាសាទ ដូចលោហប្រាសាទ ដើម្បីសម្រាកពេលថ្ងៃ, ព្រះសង្ឃត្ថេរគួរបង្គាប់អ្នករក្សាទ្វារថា ចូរជួយរក្សាទ្វារឬនឹងធ្វើសេចក្តីចងចិត្តទុកថា ការរក្សាទ្វារ ជាភារៈរបស់នាយទ្វារបាលនោះ ហើយគប្បីចូលទៅសិងចុះ ។ ភិក្ខុទាំងឡាយគួរធ្វើយ៉ាងនោះ ដូចគ្នាជាបដល់ព្រះសង្ឃនវកៈ ។ អ្នកដែលចូលទៅមុនសូម្បីនឹងធ្វើសេចក្តីចងចិត្តទុកយ៉ាងនេះថា ដែលឈ្មោះថា ការរក្សាទ្វារ ជាភារៈរបស់អ្នកមកខាងក្រោយ ដូច្នេះ ក៏គួរ ។

កាលភិក្ខុមិនធ្វើការប្រាប់ ឬសេចក្តីចងចិត្តទុកទេ ហើយសម្រាកសិងខាងក្នុងបន្ទប់ដែលមិនបានបិទទ្វារ ឬខាងក្រៅបន្ទប់ ជាអាបត្តិ ។

សូម្បីក្នុងវេលាសិងក្នុងបន្ទប់ឬក្នុងខាងក្រៅបន្ទប់ ធ្វើសេចក្តីចងចិត្តទុកថា ដែលឈ្មោះថា ការរក្សាទ្វារ ក្នុងទ្វារធំ ជាភារៈរបស់នាយទ្វារបាល ដូច្នេះ ហើយសិង គួរដូចគ្នា ។ សូម្បីភិក្ខុអ្នកនឹងសិងក្នុងទីវាលស្រឡះ ( ទីគ្មានជញ្ជាំង ) ក្នុងស្ថានទីមានលោហប្រាសាទជាដើម គួរបិទទ្វារពិតតែម្តង ។

ក៏ក្នុងរឿងបិទទ្វារសិងនេះ មានសេចក្តីសង្ខេបដូចតទៅនេះ ៖

ការសម្រាកក្នុងពេលថ្ងៃនេះ លោកពោលទុកក្នុងស្ថានទីមានរបៀងដែលលោមព័ទ្ធដោយកំផែង ឬរបងយ៉ាងណាមួយ ។ ព្រោះដូច្នោះ កាលភិក្ខុដែលនឹងសិងក្នុងទីវាលគល់ឈើ ឬមណ្ឌបណាមួយ ដែលមានរបៀង គួរបិទទ្វារសិន សឹមសិង ។ បើជាបរិវេណធំ ដែលជាស្ថានទីជំនុំរបស់មនុស្សពួកច្រើន ដូចលានមហាពោធិព្រឹក្សនិងលានលោហប្រាសាទ, ក្នុងស្ថានទីណា ទ្វារសូម្បីដែលគេបិទហើយ ក៏មិនតាំងនៅក្នុងទីដែលបិទ ( គឺបិទបើក ៗ ) មនុស្សទាំងឡាយ កាលមិនបានទ្វារ ត្រូវឡើងតាមកំផែងផ្លោះទៅ, ក្នុងស្ថានទីនោះ មិនមានកិច្ចដែលនិងត្រូវបិទ ( ទ្វារ ) ។

ភិក្ខុបើកទ្វារសិងរហូតទល់ភ្លឺ ក្រោកឡើងហើយក្នុងវេលាអរុណរះ មិនជាអាបត្តិ ។ តែបើភ្ញាក់ហើយលក់ដដែលទៀតជាអាបត្តិ ។ ចំណែកភិក្ខុណាកំណត់ទុកតែម្តងថា កាលអរុណរះហើយនឹងក្រោកឡើង មិន

បានបិទទ្វារសិងរហូតដល់ភ្លឺ តែក្រោកឡើងទាន់តាមកំណត់នុ៎ះឯង, ភិក្ខុនោះ ជាអាបត្តិតែម្តង ។ ចំណែកក្នុងអដ្ឋកថា មហាបច្ចរីលោកពោលទុកថា កាលសិងដោយអាការយ៉ាងនោះ មិនផុតពីទុក្កដព្រោះមិនអើពើ ។

ចំណែកភិក្ខុណា រក្សា (ព្យាបាល) ភិក្ខុអាពាធជាដើម ច្រើនរាត្រីតែម្តង ឬដើរមកឆ្ងាយ មានរាងកាយល្ហិតល្ហៃទាំងថ្ងៃ អង្គុយលើគ្រែហើយ លូមលើកជើងមិនទាន់ផុតពីផែនដីឡើយ ក៏សិងលក់ ព្រោះអំណាចសេចក្តីលក់ (គេចសន្លប់), ភិក្ខុនោះមិនជាអាបត្តិ ។ បើលោកឈានចុះកាន់ការលង់លក់ទាំងមិនដឹងខ្លួន លូមលើកជើងឡើងគ្រែ ក៏ជាអាបត្តិតែម្តង ។ កាលអង្គុយផ្អែកលក់ទៅមិនជាអាបត្តិ ។ ម្យ៉ាងទៀតភិក្ខុណា ដើរចង្រ្កមដោយតាំងចិត្តថា នឹងបន្ទោបង់សេចក្តីងងុយ ហើយដួលចុះ ប្រញាប់ក្រោកឡើងភ្លាម, សូម្បីភិក្ខុនោះក៏មិនជាអាបត្តិ ។ ចំណែកភិក្ខុណា ដួលចុះហើយ ដេកនៅក្នុងស្ថានទីនោះឯង មិនព្រមក្រោកឡើង, ភិក្ខុនោះ ជាអាបត្តិ ។

សួរថា តើភិក្ខុណាផុត (ពីអាបត្តិ) ភិក្ខុណាមិនផុត ?

ឆ្លើយថា ក្នុងអដ្ឋកថាមហាបច្ចរី លោកពោលទុកមុនថា អ្នកដែលសិងដោយបត់ទៅតែម្ខាងនុ៎ះឯង រមែងផុត, ចំណែកដែលលើក

ជើងផុតពីផែនដីហើយសិង នឹងជាអ្នកដែលត្រូវយក្ខចូលស្ថិតក៏ដោយ ជាអ្នកប្រាសចាកសញ្ញា (អស់សតិ) ក៏ដោយ រមែងមិនផុត ។

ក្នុងអដ្ឋកថាកុរុន្ទី លោកពោលទុកថា អ្នកដែលត្រូវចងឱ្យដេក ប៉ុណ្ណោះ រមែងផុត ។ ចំណែកក្នុងមហាអដ្ឋកថា ព្រះមហាបទុមត្ថេរ ពោលទុកថា ភិក្ខុណាដើរចង្ក្រមជួលសន្ទប់ចុះ ហើយលក់នៅក្នុងស្ថានទី នោះឯង, អាបត្តិ រមែងមិនប្រាកដដល់ភិក្ខុនោះ ព្រោះលោកមិនមាន អំណាច, តែអាចារ្យទាំងឡាយមិនបានពោលទុក; ព្រោះដូច្នោះ ទើបជា អាបត្តិតែម្តង ។ ចំណែកភិក្ខុ ២ រូប គឺ អ្នកដែលយក្ខចូលស្ថិត ១ អ្នកដែលត្រូវចងឱ្យដេក ១ រមែងផុតពីអាបត្តិពិត ។

[៧១] ក្នុងរឿងភារុកច្ឆកភិក្ខុយល់សុបិននិមិត្ត មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា **អនាបត្តិ សុបិនន្តេន : ឥតមានអាបត្តិអ្វីដោយ ចំណែកនៃយល់សប្តិនោះទេ** សេចក្តីថា ឈ្មោះថា មិនជាអាបត្តិព្រោះ ការយល់សប្តិដោយអាការយ៉ាងនេះ ព្រោះមិនមែនវិស័យ; ហេតុដូច្នោះ ទើបព្រះឧបាលីថេរៈបានវិនិច្ឆ័យរឿងនេះ សូម្បីដែលព្រះមានព្រះភាគមិន ទាន់ធ្លាប់ទ្រង់វិនិច្ឆ័យឡើយ ដោយការកាន់យកតាមន័យ ។ មួយទៀត សូម្បីព្រះមានព្រះភាគ កាលទ្រង់ស្តាប់ (រឿងដែលព្រះឧបាលីថេរៈ

វិនិច្ឆ័យនោះហើយ ) ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឧបាលីពោលទុកប្រពៃហើយ, ឧបាលីពោលដោះស្រាយបញ្ហានេះ ដូចធ្វើស្នាមជើងទុកក្នុងទីមិនមានស្នាមជើង ដូចសម្ដែងស្នាមជើងទុកក្នុងអាកាស ដូច្នោះ" ដូច្នេះហើយ ទើបទ្រង់តាំងព្រះថេរៈទុកក្នុងឯតទគ្គៈថា "ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកទ្រង់វិន័យដែលជាសាវករបស់តថាគត ឧបាលីនេះ ជាកំពូលលើភិក្ខុទាំងឡាយ" ។[១]

[៧២-៧៤] រឿងនាងសុបព្វា រឿងនាងសទ្ធា បន្ទាប់ពីរឿងភិក្ខុដែលក្រេងការរុក្ខនេះទៅ មានសេចក្ដីច្បាស់លាស់ហើយតែម្ដង ។

[៧៥-៧៦] ក្នុងរឿងទាំងឡាយ មានរឿងដឹកនាំបង្ខំឱ្យភិក្ខុសេពមេថុនធម្មក្នុងនាងភិក្ខុនីជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ស្ដេចលិច្ឆវីកុមារទាំងនោះ ទ្រង់ជាអ្នកខ្វល់ខ្វាយក្នុងការលេង បានធ្វើយ៉ាងនោះ ព្រោះអនាចាររបស់ខ្លួន ។ តាំងពីកាលនោះមក សេចក្ដី

---

(១) អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៩/៥៥ ។

វិនាសទើបបានកើតមានឡើងដល់ស្ដេចលិច្ឆវីទាំងឡាយ ព្រោះទ្រង់ធ្វើហេតុយ៉ាងនោះ ។

[៧៧] ក្នុងរឿងភិក្ខុដែលបួសក្នុងវ័យចាស់មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា **ធស្សនំ អគមាសិ : និមន្តទៅសួរ** សេចក្តីថា ភិក្ខុចាស់នោះ គិតថា នឹងសួរសុខទុក្ខកិរិយាចាស់នោះ ទើបបានទៅកាន់ផ្ទះ ព្រោះសេចក្តីអនុគ្រោះ ។ ខណៈនោះ នាងបានបង្ហាញដល់ភាពដែលខ្លួននិងពួកក្មេង ៗ មិនមានទីពឹង ឱ្យលោកស្តាប់ដោយប្រការផ្សេង ៗ និងជ្រាបថា ភិក្ខុចាស់នោះមិនមានការត្រេកអរ ទើបក្រោធហើយនិយាយថា "លោកចូរមក ចូរសឹកចុះ" ទើបបានចាប់លោកដោយកម្លាំងខ្លួន ។ ភិក្ខុចាស់បានថយត្រឡប់ទៅដើម្បីដោះខ្លួន ទើបបានដួលផ្ងារចុះ ព្រោះសេចក្តីជរាទុពលភាព ។ ខណៈនោះ នាងបានធ្វើតាមចិត្តរបស់ខ្លួនហើយ ។ តែភិក្ខុនោះជាព្រះអនាគាមី កាត់កាមរាគៈបានដាច់ហើយ ; ព្រោះដូច្នោះ ទើបលោកមិនត្រេកអរ ដូច្នេះឯង ។

[៧៨] រឿងសត្វម្រឹគ មានសេចក្តីច្បាស់លាស់ហើយតែម្តងដូច្នេះឯង ។

## ចប់ មេថុនធម្មសិក្ខាបទវណ្ណនា

# ២. អនិយ្យានសិក្ខាបទវណ្ណនា

ឥឡូវនេះ ដល់លំដាប់សំវណ្ណនាទុតិយបារាជិក ដែលព្រះជិនស្រីមិនមានបុគ្គលជាគម្រប់ពីរទ្រង់ប្រកាសហើយ, ព្រោះហេតុនោះ ពាក្យណាដែលនឹងគប្បីដឹងបានងាយ និងបានប្រកាសទុកហើយក្នុងខាងដើម, ការពណ៌នាទុតិយបារាជិកនោះ នឹងវៀរពាក្យនោះចេញទាំងអស់ ដូចតទៅនេះ ៖

## រឿងភិក្ខុធនិយកុម្ភការបុត្រ

[៧៩] និក្ខេបបទថា តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ : សម័យនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដទៀបក្រុងរាជគ្រឹះ ខ្ញុំព្រះករុណានឹងពោលតទៅ ៖

បទថា រាជគហេ : ទៀបក្រុងរាជគ្រឹះ បានដល់ ក្រុងដែលមានឈ្មោះយ៉ាងនោះ ។ ពិតមែន ក្រុងនោះហៅថា រាជគ្រឹះ ព្រោះជាក្រុងដែលព្រះរាជទាំងឡាយមានព្រះបាទមន្ធាតុ និងព្រះបាទមហាគោវិន្ទៈជាដើម ទ្រង់គ្រប់គ្រង ។ ក្នុងពាក្យថា រាជគ្រឹះ នេះ អាចារ្យទាំងឡាយពណ៌នាប្រការយ៉ាងដទៃខ្លះ ។ នឹងមានប្រយោជន៍អ្វី ដោយប្រការទាំង

នោះហ្ន៎ ? ។ ពាក្យថា រាជគ្រឹះ នេះ ជាឈ្មោះរបស់ក្រុងនោះ ។ តែក្រុងនោះជាក្រុងក្នុងសម័យពុទ្ធកាល និងចក្រពត្តិកាល ។ ក្នុងកាលដ៏សេស ជាក្រុងរហោស្ថានត្រូវយក្ខហួងហែង គឺ ជាព្រៃជាទីនៅរបស់ពួកយក្ខទាំងនោះ ព្រះឧបាលីថេរៈគ្រាសម្តែងគោចរគ្រាមយ៉ាងនោះហើយទើបសម្តែងស្ថានទីជាទីស្តេចប្រថាប់ ។

ពីរបទថា គិជ្ឈកូដេ បព្វតេ : លើភ្នំគិជ្ឈកូដ មានសេចក្តីថា ក៏ភ្នំនោះ គេហៅថា គិជ្ឈកូដ ព្រោះហេតុថា មានហ្វូងត្មាតនៅលើកំពូល ឬមានកំពូលស្រដៀងត្មាត ។

បទថា សម្ពហុលា : ភិក្ខុច្រើនរូប មានសេចក្តីថា ដោយបរិយាយនៃព្រះវិន័យ ភិក្ខុ ៣ រូបហៅថា ភិក្ខុច្រើន លើសជាងនោះហៅថា សង្ឃ ដោយបរិយាយនៃព្រះសូត្រភិក្ខុ ៣ រូប ក៏ហៅថា ៣ រូបទុំះឯង, បន្ទាប់ពី (៣រូប)នោះ (គឺ៤រូប) ឡើងទៅ ទើបហៅថា ភិក្ខុច្រើន ។ ភិក្ខុច្រើនក្នុងទីនេះគប្បីជ្រាបថា ច្រើន ដោយបរិយាយនៃព្រះសូត្រ ។

ជនទាំងឡាយ ដែលមិនធ្លាប់ស្គាល់គ្នា គឺ មិនមែនមិត្តដ៏ស្និទ្ធស្នាល លោកហៅថា មិត្រដែលធ្លាប់ឃើញគ្នាម្តងម្កាល ។ ពិតមែន ភិក្ខុទាំងនោះ លោកហៅថា សម្លាញ់ដែលធ្លាប់ឃើញគ្នា ព្រោះបានប្រទះ

ឃើញគ្នាក្នុងទីនោះ ៗ ។ ជនទាំងឡាយដែលធ្លាប់ស្គាល់គ្នា គឺ ជាសម្លាញ់ដ៏ស្និទ្ធស្នាល លោកហៅថា មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន ។ ពិតមែន ភិក្ខុទាំងនោះ បានគប់រកគ្នាហើយ គឺ កំពុងគប់រកគ្នាយ៉ាងល្អ លោកហៅថា មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន ព្រោះធ្វើសេចក្ដីស្និទ្ធស្នាលនៅរួមជាមួយគ្នា និងបរិភោគជាមួយគ្នា ។

បទថា ឥសិគិលិបស្សេ : ក្បែរជើងភ្នំឥសិគិលិ មានសេចក្ដីថា ភ្នំឈ្មោះឥសិគិលិ ទីជិតភ្នំនោះ ។

បានឮថា ពីអតីតកាលដ៏យូរលង់ ព្រះបច្ចេកពុទ្ធប្រមាណ ៥០០ អង្គ ត្រាច់ទៅបិណ្ឌបាតក្នុងជនបទទាំងឡាយ មានដែនកាសី និងកោសលជាដើម វេលាខាងក្រោយភត្តប្រជុំគ្នាត្រង់ភ្នំនោះ ញុំាងកាលឱ្យកន្លងទៅដោយសមាបត្តិ ។ មនុស្សទាំងឡាយ ឃើញលោកចូលទៅប៉ុណ្ណោះ មិនឃើញចេញ, ព្រោះហេតុនោះ ទើបនិយាយគ្នាថា ភ្នំនេះ លេបព្រះឥសីទាំងនេះ ។ ព្រោះអាស្រ័យហេតុនោះ ភ្នំនោះ ទើបឈ្មោះថា ឥសិគិលិ តែម្ដង ។ ទីក្បែរភ្នំនោះ គឺ ទីជិតជើងភ្នំ ។

ពីរបទថា តិណកុដិកាយោ ករិត្វា : ធ្វើកុដិប្រក់ដោយស្មៅ មានសេចក្ដីថា ធ្វើកុដិស្មៅ បានដល់ កុដិទាំងឡាយ ព្រមទាំងរបៀងមានស្មៅជាគ្រឿងប្រក់ ។

## ភិក្ខុចាំវស្សាមិនមានសេនាសនៈ ពិន័យអាបត្តិទុក្កដ

ភិក្ខុដែលចូលចាំវស្សា សូម្បីបដិបត្តិតាមបដិបទារបស់ព្រះនាលកៈ ក៏ត្រូវចាំវស្សាក្នុងសេនាសនៈព្រមទាំងរបៀង ដែលប្រក់ដោយគ្រឿងប្រក់ ៥ យ៉ាងណាមួយប៉ុណ្ណោះ ។ ពិតមែន ព្រះមានព្រះភាគបានត្រាស់ពាក្យនេះទុកថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនចូលវស្សាក្នុងទីវាលទេ ភិក្ខុណាចូល ត្រូវអាបត្តិទុក្កដ"[១] ។ ព្រោះដូច្នោះ ក្នុងវេលាជិតវស្សា បើបានសេនាសនៈ ការដែលបានយ៉ាងនោះ ទើបជាការល្អ បើមិនបានត្រូវស្វែងរកហត្ថកម្មធ្វើ កាលមិនបានហត្ថកម្ម គួរធ្វើដោយខ្លួនឯង ។ ចំណែកភិក្ខុអ្នកមិនមានសេនាសនៈ មិនគួរចូលចាំវស្សាឡើយ ។

ប្រការនេះជាធម៌ដែលសមគួរ ។ ព្រោះហេតុនោះ ភិក្ខុទាំងនោះទើបធ្វើ កុដិស្មៅកំណត់ទីសម្រាកពេលយប់ និងពេលថ្ងៃជាដើមទុកហើយ អធិដ្ឋានកតិកាវត្ត និងខន្ធកវត្ត សិក្សាក្នុងត្រៃសិក្ខា នៅចាំវស្សា ។

ពីរបទថា អាយស្មា ធនិយោ : ឈ្មោះធនិយដ៏មានអាយុ មានសេចក្តីថា មិនមែនតែព្រះថេរៈពួកនោះតែម្យ៉ាង សូម្បីព្រះធនិយៈដែលជាដើមបញ្ញត្តិនៃសិក្ខាបទនេះ ក៏បានធ្វើដូចគ្នា ។

---

១. វិន. មហា. ៧. ១៥៤៩ ។

បទថា **កុម្ភការបុត្តោ :** **ជាកូនស្មូនឆ្នាំង** គឺ ជាបុត្ររបស់ជាងឆ្នាំង, ពិតមែន ពាក្យថា ធនិយៈ ជាឈ្មោះរបស់លោក តែបិតារបស់លោក ជាជាងឆ្នាំង; ដោយហេតុនោះ លោកទើបពោលថា **ធនិយភិក្ខុដ៏មានអាយុជាកូនស្មូនឆ្នាំង** ។

ពីរបទថា **វស្សំ ឧបគច្ឆិ :** **ហើយចាំវស្សានៅនោះដែរ** សេចក្តីថា ព្រះធនិយៈធ្វើកុដិស្មៅ ហើយក៏ចាំវស្សាក្នុងទីកន្លែងតែមួយរួមគ្នានឹងព្រះថេរៈទាំងនោះឯង ។

ពីរបទថា **វស្សំ វុដ្ឋា :** **លុះចាំវស្សាហើយ** សេចក្តីថា ភិក្ខុទាំងនោះចូលចាំវស្សាក្នុងថ្ងៃបុរិមវស្សា ហើយបវារណាក្នុងថ្ងៃមហាបវារណា តាំងពីថ្ងៃបាដិបទ (១រោច)ទៅ លោកហៅថា អ្នកចេញវស្សាហើយ ។ ជាអ្នកចេញវស្សាហើយដោយវិធីយ៉ាងនោះ ។

ពីរបទថា **តិណកុដិយោ ភិន្ទិត្វា :** **ក៏រុះរើកុដិស្មៅនោះ** មានសេចក្តីថា ភិក្ខុទាំងនោះ មិនបានទម្លាយកុដិឱ្យខ្ទិចខ្ទីដោយការប្រហារនឹងឈើអន្លូងជាដើមទេ តែបានរុះរើស្មៅឈើនិងវល្លិជាដើមចេញ ដោយរបៀបវត្ត ។ ពិតមែន ភិក្ខុណា បានធ្វើកុដិទុកក្នុងទីបំផុតដែនវិហារ ភិក្ខុនោះ បើពួកអាវាសិកភិក្ខុមាន ក៏គួរពោលលាភិក្ខុម្ចាស់អាវាសទាំងនោះ គប្បីពោលថា “បើភិក្ខុណាអាចនៅថែរក្សាកុដិនេះបាន លោកចូរ

ប្រគល់ឱ្យដល់ភិក្ខុនោះឯង” ដូច្នេះ ហើយទើបចៀសចេញទៅ ។ បើភិក្ខុណា ធ្វើកុដិទុកក្នុងព្រៃ ឬមិនបានរក្សា ភិក្ខុនោះគិតថា “សេនាសនៈនឹងជារបស់ប្រើប្រាស់ដល់ភិក្ខុសូម្បីពួកដទៃ” គួររក្សាទុកសិន ទើបទៅ ។ អធិប្បាយថា ក៏ភិក្ខុទាំងនោះ សាងកុដិទុកក្នុងព្រៃហើយ កាលមិនបានអ្នករក្សា ក៏គប្បីប្រមូលគ្របទុក គឺ រួបរួមស្មៅនិងឈើទុក ។ មួយទៀត ស្មៅនិងឈើដែលរក្សាទុកហើយ សត្វទាំងឡាយមានកណ្ដៀរជាដើមនឹងមិនអាចស៊ីបាន ទាំងភ្លៀងក៏ស្រោចលើមិនបាន ដោយប្រការណា ក៏គួររក្សាទុកដោយប្រការនោះ គួរបំពេញគមិកវត្តឱ្យបរិបូណ៌ដោយគិតថា “ស្មៅនិងឈើនោះ នឹងជាឧបការៈដល់សព្រហ្មចារីទាំងឡាយ អ្នកមកដល់ស្ថានទីនេះ ហើយប្រាថ្នានឹងនៅ” ដូច្នេះ ទើបគួរចៀសចេញទៅ ។

ពីរបទថា ជនបទចារិកំ បក្កមឹសុ : ហើយចេញទៅកាន់ជនបទចារិក មានសេចក្ដីថា ភិក្ខុទាំងនោះ បានទៅកាន់ជនបទតាមសេចក្ដីពេញចិត្តរបស់ខ្លួន ៗ ពាក្យជាដើមថា “អាយស្មា ធនិយោ កុម្ភការបុត្តោ តត្ថេវ វស្សំ វសិ : ចំណែកខាងឯធនិយភិក្ខុដ៏មានអាយុ ជាកូនស្ដូនឆ្នាំង ក៏នៅតែក្នុងទីនោះអស់វស្សានរដូវ” មានសេចក្ដីច្បាស់លាស់តែម្ដង ។

បទថា យាវតតិយកំ : ដរាបអស់បីដង បានដល់ ដរាបអស់វារៈបីដង ។

បទថា អនវយោ : ឥតមានខ្វះខាត បានដល់ ជាអ្នកមិនខ្វះខាតឡើយ ៗ ។ លុប ឧ អក្សរចេញដោយអំណាចសន្ធិ ។ អធិប្បាយថា ជាអ្នកមានសិល្បៈបរិបូរណ៍មិនខ្វះខាតក្នុងការងារគ្រប់យ៉ាង ដែលពួកជាងផ្ទាំងគប្បីធ្វើ ។

បទថា សកេ : របស់ខ្លួន គឺ របស់ ៗ ខ្លួន ។

បទថា អាចរិយកេ : ក្នុងសំណាក់នៃគ្រូអាចារ្យ គឺ ក្នុងការងារនៃអាចារ្យ ។

បទថា កុម្ភការកម្មេ : ខាងការងារស្មូនផ្ទាំង បានដល់ ក្នុងការងាររបស់ពួកជាងផ្ទាំង ។ អធិប្បាយថា ក្នុងការងារដែលពួកជាងផ្ទាំងនឹងគប្បីធ្វើ ។ ដោយបទថា កុម្ភការកម្មេ នោះ ជាការលោកធនិយៈសម្តែងដល់ការងារនៃអាចារ្យរបស់ខ្លួន ដោយសរុប ។

បទថា បរិយោធាតសិប្បោ : ចេះប្រាកដក្នុងសិល្បសាស្ត្រ គឺជាអ្នកសម្រេចសិល្បៈ មានពាក្យអធិប្បាយថា សូម្បីកាលយើងមិនមានសេចក្តីខ្វះខាត យើងក៏ជាអ្នកមានសិល្បៈនឹងរកអ្នកដទៃផ្ទឹមមិនបាន ។

បទថា សព្វមត្តិកាមយំ : ឱ្យសុទ្ធដោយដីទាំងអស់ មានសេចក្តី

ថា ភិក្ខុធនិយៈនោះ ធ្វើគ្រឿងកុដិដ៏សេសទាំងអស់ មានប្រភេទ គឺ ជញ្ជាំង គ្រឿងប្រក់ និងគ្រឿងឈើជាដើម ឱ្យសម្រេចដោយដីទាំងអស់ វៀរលែងតែសន្ទះទ្វារ គន្លឹះទ្វារ និងសន្ទះបង្អួច ។

ច្រើនបទថា តិណញ្ច កដ្ឋញ្ច គោមយញ្ច សង្កឌ្ឍិត្វា តំ កុដិកំ បចិ : រួចហើយយកស្មៅ ឧស និងអាចម៍គោមកដុតកុដិនោះ (ដើម្បីឱ្យឆ្អិន) មានសេចក្ដីថា លោកម្ចាស់ធនិយៈធ្វើគ្រឿងផ្ទុះឱ្យសម្រេចដោយដីសុទ្ធ ហើយដុសខាត់ដោយបាតដៃ ធ្វើឱ្យស្ងួត ហើយយកដីក្រហមផ្សំដោយប្រេងបូកលាបឱ្យអស់គ្មានសល់រួចហើយ ទើបដាក់ទាំងខាងក្នុងនិងខាងក្រៅឱ្យពេញដោយស្មៅជាដើម ហើយដុតកុដិនោះ ឱ្យមានពណ៌ក្រហមឆ្អិនឆ្អៅយ៉ាងល្អ ។ ក៏ឯកុដិនោះ បានជារបស់ដុតហើយដោយអាការយ៉ាងនោះ ។

បទថា អភិរូបា : មានទ្រង់ទ្រាយល្អ បានដល់ មានរូបស្អាតល្អ ។

បទថា បាសាទិកា : គួរឱ្យជ្រះថ្លា បានដល់ នាំឱ្យកើតសេចក្ដីជ្រះថ្លា ។

បទថា លោហិតកា : មានពណ៌ក្រហម បានដល់ មានពណ៌ក្រហមច្រើន (ខ្មៅតិច ៗ) ។

បទថា គីកិណិកសទ្ទោ : សំឡេងកណ្តឹង បានដល់ សំឡេងរបស់ក្រុមកណ្តឹង ។ បានពួថា កណ្តឹងដែលគេធ្វើដោយរតនៈផ្សេង ៗ រមែងមានសំឡេង យ៉ាងណា កុដិនោះ ក៏មានសំឡេងយ៉ាងនោះ ព្រោះត្រូវខ្យល់ដែលបក់ចូលទៅតាមប្រហោងសន្ទឹកបង្អួចជាដើម ប៉ះខ្ទប់ហើយ ។ ដោយបទថា គីកិណិកសទ្ទោ នោះ ជាការលោកសម្តែងដល់កុដិនោះដែលឆ្អិនដោយល្អទាំងខាងក្នុងនិងខាងក្រៅ ។ ចំណែកក្នុងមហាអដ្ឋកថា លោកពោលទុកថា ភាជនៈសំរិទ្ធិ ឈ្មោះថា គីកិណិកៈ; ព្រោះដូច្នោះ ភាជនៈសំរិទ្ធិដែលមនុស្សគោះហើយ មានសំឡេងយ៉ាងណា កុដិនោះ ត្រូវខ្យល់ប៉ះខ្ទប់ហើយ ក៏មានសំឡេងយ៉ាងនោះ ។

ក្នុងពាក្យថា កឹ ឯតំ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ កុដិនោះឬអ្វី នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ព្រះមានព្រះភាគទ្រង់ជ្រាបហើយ ដើម្បីនឹងទ្រង់តាំងរឿងនោះទើបបានត្រាស់សួរ ។

ច្រើនបទថា ភគវតោ ឯតមត្ថំ អារោចេសុំ : ក៏ក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគ សេចក្តីថា ភិក្ខុទាំងឡាយ បានក្រាបទូលរឿងដែលព្រះធនិយៈធ្វើកុដិសម្រេចដោយដីសុទ្ធ ចំពោះព្រះមានព្រះភាគតាំងពីដើម ។

ពាក្យថា ករិស្សតិ : នឹងធ្វើ នេះ ក្នុងប្រយោគថា "កថំ ហិ នាម សោ ភិក្ខវេ ។បេ។ កុដិកំ ករិស្សតិ : ម្នាលភិក្ខុទាំងឡាយ ចុះហេតុដូចម្តេច ក៏បានជាមោឃបុរសនោះ ជាន់ដីដោយខ្លួនឯង ហើយធ្វើកុដិសុទ្ធដោយដីទាំងអស់ (ដូច្នោះ)" ជាពាក្យអនាគតចុះក្នុងអត្ថអតីត ។ មានពាក្យអធិប្បាយថា បានធ្វើហើយ ។ លក្ខណៈនៃការពោលកិរិយាអនាគតចុះក្នុងអត្ថអតីតនោះ អ្នកសិក្សាគួរស្វែងរកអំពីគម្ពីរសព្ទសាស្ត្រ ។

ក្នុងពាក្យថា "ន ហិ នាម ភិក្ខវេ តស្ស មោឃបុរិសស្ស បាណេសុ អនុទ្ទយា អនុកម្បា អវិហេសា ភវិស្សតិ : ម្នាលភិក្ខុទាំងឡាយ សេចក្តីករុណា សេចក្តីអនុគ្រោះ និងសេចក្តីមិនបៀតបៀនដល់ពួកសត្វមានជីវិត ទំនងជាមិនមានដល់មោឃបុរសនោះទេដឹង" នេះ មានវិនិច្ឆ័យដូច្នេះ ៖

ការតាមរក្សា ឈ្មោះថា អនុទ្ទយា : សេចក្តីករុណា ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងផ្នែកខាងដើមនៃមេត្តាដោយបទថា អនុទ្ទយា នោះ ។

ចិត្តញាប់ញ័រតាម ព្រោះទុក្ខរបស់អ្នកដទៃ ឈ្មោះថា អនុកម្បា : សេចក្តីអនុគ្រោះ ។

ការមិនបៀតបៀន ឈ្មោះថា **អវិហេសា** ។ ព្រះមានព្រះភាគ រមែងទ្រង់សម្ដែងចំណែកខាងដើមនៃករុណាដោយពីរបទថា **អនុកម្បា** និង **អវិហេសា** នោះ ។ ព្រះអដ្ឋកថាចារ្យ ពោលពាក្យអធិប្បាយទុកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលព្រះធនិយៈមោយបុរសនោះបៀតបៀន គឺ ធ្វើសត្វតូចតាចជាច្រើនឱ្យវិនាសទៅ ព្រោះជីកដី ប្របាច់ភក់និងបង្កាត់ភ្លើង ការអាណិត ការអនុគ្រោះ ការមិនបៀតបៀន សូម្បីត្រឹមតែចំណែកខាងដើមនៃមេត្តា និងករុណាក្នុងសត្វទាំងឡាយ ទាំងនោះ ឈ្មោះថា មិនមានឡើយ គឺ សេចក្ដីអាណិតជាដើមនោះ ឈ្មោះថា សូម្បីមានប្រមាណតិចក៏មិនមាន ។

ប្រើនបទថា មា បច្ឆិមា ជនតា បាណេសុ បាតព្យតំ អាបជ្ជតិ : កុំឱ្យបណ្ដាជនជាខាងក្រោយ បៀតបៀនបំផ្លាញដល់បាណជាតិទៀតឡើយ មានសេចក្ដីថា ពួកជនជំនាន់ក្រោយ កុំដល់សេចក្ដីបៀតបៀនពួកសត្វឡើយ ។ មានពាក្យអធិប្បាយថា ពួកជនជំនាន់ក្រោយសម្គាល់ថា "សូម្បីក្នុងសម័យពុទ្ធកាល ភិក្ខុទាំងឡាយបានធ្វើកម្មយ៉ាងនេះហើយ កាលភិក្ខុធ្វើបាណាតិបាតនៅក្នុងសត្វទាំងឡាយ ក្នុងឋានៈដូច្នេះ ក៏មិនមានទោស"ដូច្នេះ កាលសំដៅយកព្រះថេរៈនេះជាទិដ្ឋានុគតិ កុំសម្គាល់ក្នុងកម្មដែលទីងគប្បីបៀតបៀន គឺ ក្នុងការដែលសម្លាប់ពួកសត្វ ដូចដែលព្រះថេរៈធ្វើហើយនោះឡើយ ។

## ពិន័យអាបត្តិទុក្កដដល់ភិក្ខុដែលសាងកុដិដោយដីសុទ្ធ

លុះព្រះមានព្រះភាគ ទ្រង់តិះដៀលភិក្ខុធនិយៈយ៉ាងនោះហើយ ទើបទ្រង់ហាមការធ្វើកុដិដូច្នោះតទៅថា "ន ច ភិក្ខវេ សព្វមត្តិកាមយា កុដិកា កាតព្វា : ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវធ្វើកុដិឱ្យសុទ្ធដោយដីទាំងអស់ទេ" ក៏ឯគ្រាទ្រង់ហាមហើយ ទើបទ្រង់ពិន័យអាបត្តិទុក ព្រោះការធ្វើកុដិសម្រេចដោយដីសុទ្ធថា "យោ ករេយ្យ អាបត្តិ ទុក្កដស្ស : បើភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិទុក្កដ" ។ ព្រោះហេតុនោះ ភិក្ខុសូម្បីរូបណា កាលមិនទាន់ដល់សេចក្ដីបៀតបៀនពួកសត្វ ព្រោះកិច្ចមានការជីកដីជាដើម ធ្វើកុដិដូច្នោះ សូម្បីភិក្ខុនោះ ក៏ត្រូវទុក្កដ ។ តែកាលភិក្ខុធ្វើឱ្យពួកសត្វវិនាស ព្រោះកិច្ចមានការជីកដីជាដើម រមែងត្រូវអាបត្តិដែលលោកពិន័យទុក តាមវត្ថុដែលខ្លួនប្រព្រឹត្តកន្លងតែម្ដង ។ ភិក្ខុធនិយៈ ឈ្មោះថាមិនជាអាបត្តិ ព្រោះជាដើមបញ្ញត្តិក្នុងសិក្ខាបទនេះ ។ ភិក្ខុដ៏សេស ដែលប្រព្រឹត្តប្រព្រឹត្តកន្លងសិក្ខាបទក្ដី បានកុដិដែលអ្នកដទៃធ្វើហើយនៅក្នុងកុដិនោះក្ដី ជាទុក្កដដូចគ្នា ។ ចំណែកកុដិដែលសាងលាយដោយទព្វសម្ភារៈ នឹងជារបស់លាយដោយអាការណា ៗ ក៏ដោយ រមែងគួរ ។ កុដិដែលសម្រេចដោយដីសុទ្ធប៉ុណ្ណោះ មិនគួរ ។ សូម្បីកុដិនោះ ដែលធ្វើដោយឥដ្ឋ ដោយអាការប្រាកដដូចទីនៅដែលសាងដោយឥដ្ឋ ក៏គួរ ។

## ព្រះមានព្រះភាគទ្រង់ត្រាស់ឱ្យទម្លាយកុដិជាអកប្បិយៈ

ប្រើនបទថា ឯវំ ភន្តេតិ ខោ ។បេ។ តំ កុដិកំ ភិន្ទឹសុ : បពិត្រព្រះអង្គយ៉ាងនេះ រួចហើយកុដិនោះនៅទីណា នាំគ្នាចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ក៏វាយបំបាក់កុដិនោះទៅ សេចក្តីថា ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធតម្រាស់ហើយ ក៏យកឈើនិងថ្មទម្លាយកុដិនោះឱ្យខ្ទាត់ខ្ទាយហើយ ។

ក្នុងពាក្យថា អថខោ អាយស្មា ធនិយោ : គ្រានោះធនិយភិក្ខុដ៏មានអាយុ ជាដើម មានសេចក្តីសង្ខេបដូចតទៅនេះ ៖

ភិក្ខុធនិយៈ អង្គុយសម្រាកពេលថ្ងៃនៅក្នុងទីម្ខាង ទើបបានមកព្រោះសំឡេងនោះ ហើយសួរភិក្ខុទាំងនោះថា "នែអាវុសោទាំងឡាយ ចុះហេតុអ្វីបានជាពួក លោកនាំគ្នាមកវាយបំបាក់កុដិរបស់ខ្ញុំព្រះករុណា ដូច្នេះ ?" ហើយបានស្តាប់ថា "ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ឱ្យ(ពួកខ្ញុំព្រះករុណា)វាយបំបាក់" ទើបបានយល់ព្រម ព្រោះជាអ្នកប្រដៅងាយ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបបង្គាប់ឱ្យទម្លាយកុដិដែលព្រះថេរៈនេះ ធ្វើដោយសេចក្តីឧស្សាហ៍យ៉ាងធំក្រៃលែង ដើម្បីជាទីនៅរបស់ខ្លួន, សូម្បីការងារ(គឺ វត្ថុដូចទ្វារជាដើម) ដែលនៅប្រើការបាន ក្នុងកុដិនេះរបស់ព្រះថេរៈនោះ នៅមានមិនមែនឬ ?

ឆ្លើយថា នៅមាន ក៏ពិតមែនហើយ តែថា ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា “កុដិដែលព្រះធនិយៈធ្វើនេះ ជារបស់មិនសមគួរ” ទើបបង្គាប់ឱ្យទម្លាយកុដិនោះចេញ ត្រាស់ឱ្យភិក្ខុទាំងឡាយទៅទម្លាយចេញ ព្រោះថា ជាទង្វើរបស់តិរ្ថិយ ។

ក្នុងអធិការពោលអំពីការទម្លាយកុដិនេះ មានវិនិច្ឆ័យប៉ុណ្ណេះ ។ ចំណែកក្នុងអដ្ឋកថា អាចារ្យទាំងឡាយពោលហេតុច្រើនយ៉ាងសូម្បីដទៃមានជាដើមថា ដើម្បីសេចក្តីអាណិតសត្វដើម្បីត្រូវការរក្សាបាត្រនិងចីវរ ដើម្បីការពារភាពជាអ្នកមានសេនាសនៈច្រើន ។ ព្រោះដូច្នោះ សូម្បីក្នុងកាលឥឡូវនេះ ភិក្ខុណា ជាពហុស្សូត ដឹងព្រះវិន័យ ប្រទះឃើញភិក្ខុដទៃ អ្នកកាន់បរិក្ខារដែលជាអកប្បិយត្រាច់ទៅ គួរឱ្យលោកកាត់ ឬទម្លាយបរិក្ខារដែលមិនគួរនោះចេញ, អ្នកណា ៗ មិនបានដើម្បីលើកទោសភិក្ខុនោះឡើង គឺ ជំទាស់មិនបាន ចោទមិនបាន ឱ្យរ៉កមិនបាន ទាំងអ្នកណា ៗ មិនបានដើម្បីនឹងពោលទាមទាលោកថា “លោកធ្វើឱ្យបរិក្ខាររបស់ខ្ញុំព្រះករុណាវិនាសហើយ, ចូរឱ្យបរិក្ខារនោះដល់ខ្ញុំព្រះករុណាវិញ” ។

# បរិក្ខារក្រៅពីបាលី
## រឿងការប្រើឆត្រនិងចីវរ

ក្នុងអធិការពោលពីទុតិយបារាជិកនោះ មានវិនិច្ឆ័យបរិក្ខារដែលជាកប្បិយ និងអកប្បិយក្រៅអំពីបាលីដូចតទៅនេះ ៖

ជនពួកខ្លះ យកអំបោះបញ្ចពណ៌ដេរឆត្រស្លឹកត្នោតជាប់គ្នាទាំងខាងក្នុងខាងក្រៅ ហើយធ្វើឱ្យមានពណ៌រលោង, ឆត្របែបនោះមិនគួរ ។ តែនឹងយកអំបោះយ៉ាងណាមួយ ខៀវឬលឿងដែលមានពណ៌ដូចគ្នា ដេរជាប់គ្នាទាំងខាងក្នុងនិងខាងក្រៅ ឬនឹងចងឆ្អឹងឆត្រភ្ជាប់ដងឆត្រទុក គួរ ។ ក៏ឯការដេរនិងការចងរួមគ្នាទុកនោះ ដើម្បីធ្វើឱ្យរឹងមាំ ទើបគួរ ដើម្បីនឹងធ្វើឱ្យមានពណ៌ឆើតឆាយ មិនគួរ, ក្នុងស្លឹកឆត្រ នឹងឆ្លាក់រូបធ្មេញមង្ករ ឬរូបព្រះចន្ទពាក់កណ្ដាលជាប់ទុក មិនគួរ ។ ត្រង់ដងឆត្រ និងមានរូបឆ្នាំងទឹក ឬរូបសត្វកាច ដូចដែលគេធ្វើទុកក្នុងសសរផ្ទះ មិនគួរ ។ សូម្បីបើថា ត្រង់ដងឆត្រទាំងអស់ គេយកដែកចារសរសេរឆ្លាក់ក្បាច់ក្បូរទុកសោត, សូម្បីក្បាច់ក្បូរនោះ ក៏មិនគួរ ។ រូបឆ្នាំងទឹកក្ដី រូបសត្វកាចក្ដី គួរទម្លាយចោលសិន សឹមប្រើ គួរកោសក្បាច់ក្បូរសូម្បីនោះចេញ ឬយកអំបោះ ពាន់ដងចេញ ។ តែត្រង់គល់ដងនឹងមានសណ្ឋានដូចផ្សិតក្បាលពស់ គួរ ។ ពួក ជាងធ្វើឆត្រ យកខ្សែចងរង្វង់មូល

របស់ឆ្ពុចផ្ទៃតែ្រតង់ជង ដើម្បីការពារមិនឱ្យ រយីករយាក ព្រោះត្រូវខ្យល់បក់ ៗ ក្នុងទីដែលចង្រ្ទៃតនោះគេលើកតាំងដាក់ក្បាច់ ក្បូរទុក ដូចវល័យ( កម្រង ), ក្បាច់ក្បូរនោះ គួរ ៗ ពួកភិក្ខុយកអំបោះពណ៌ផ្សេង ៗ ដេរជារូបដូចនឹងរូបក្អែប ជាប់នឹងសំពត់បន្ថែមក្តី ធ្វើរូបប្លែក ៗដែលដេរដោយ ម្ជុលយ៉ាងណាមួយសូម្បីជទៃទុកក្តី រូបផ្កាសក់ ឬរូបប្រវាក់ទុកត្រង់ទីបំផុត ឬត្រង់ ជាយសំពត់អនុវាតចីវរក្តី ដើម្បីត្រូវការប្រដាប់ចីវរ វិធីដែលពោលមកហើយ នោះជាដើមទាំងអស់ រមែងមិនគួរ ៗ ការដេរដោយម្ជុលតាមប្រក្រតីនុ៎ះឯង ទើបគួរ ៗ គេធ្វើសំពត់ក្នុំ និងសំពត់អន្ទាក់ក្នុំទុក ៨ ជាយខ្វះ ១៦ ជាយខ្វះ, ដែលក្នុំនិងអន្ទាក់ក្នុំនោះ ក៏សម្តែងរូបផ្សេង ៗ មានរូបស្រទៀងចេតិយ រូបជំបង និងរូបឈើអន្ទូងជាដើមទុក, ដេរលើកជារូបភ្នែកក្តាមទុក; វិធីធ្វើទាំងអស់មិនគួរ នឹងធ្វើសំពត់កណ្តុំ និងអន្ទាក់កណ្តុំទុកត្រឹមតែ ៤ ជាយប៉ុណ្ណោះទើបគួរ ៗ

## វិធីបោកនិងជ្រលក់ចីវរ

អំបោះជាយ និងគំនួច ជារបស់ដែលដឹងបានលំបាកក្នុងកាលជ្រលក់ចីវរហើយសមគួរ ៗ នឹងដាក់ចីវរចុះក្នុងទឹកផ្សេង ៗ មានទឹកជូរផ្អែម ទឹកម្សៅ និងទឹកបាយជាដើម មិនគួរ, តែក្នុងវេលាធ្វើចីវរ នឹងដាក់ចុះដើម្បីជម្រះញើសដៃនិងស្នឹមម្ជុលជាដើម និងក្នុងវេលាដែលចីវរ

សៅហ្មងនឹងដាក់ចុះដើម្បីបោកគក់ឱ្យស្អាត ក៏គួរ នឹងដាក់របស់ក្រអូបអាចម៍ល័ក្ខឬប្រេងចុះក្នុងទឹកជ្រលក់ មិនគួរ ។ ភិក្ខុជ្រលក់ចីវរហើយ មិនគួរយកស័ង្ខ ឬកែវមណីឬវត្ថុយ៉ាងណាមួយខាត់ចីវរ មិនគួរលុតជង្គង់ទាំងពីរចុះលើផែនដី ហើយយកដៃទាំងពីរចាប់ចីវរញី សូម្បីត្រង់ស្នូកជ្រលក់, តែនឹងដាក់ចីវរទុកត្រង់ស្នូកជ្រលក់ ឬលើផែនក្តារ ហើយឱ្យចាប់ជាយទាំងពីររួមគ្នាទុក យកដៃជំ សមគួរ ។ សូម្បីការជំនោះ ក៏មិនគួរយកកែងដៃជំ ។ តែព្រះថេរៈក្នុងកាលមុនទាំងឡាយ មិនបានដាក់ចីវរទុក សូម្បីលើស្នូកជ្រលក់ឡើយគឺ មួយរូបយកដៃចាប់ចីវរឈរមួយរូបទៀត ដាក់ចីវរទុកលើដៃ ហើយទើបយកដៃជំ, ជំសរសៃអំបោះត្រង់ជាយចីវរ មិនគួរ ។ ក្នុងវេលាជ្រលក់រួចហើយ គួរកាត់ចេញ ។ ចំណែកអំបោះដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកយ៉ាងនេះថា “អនុជានាមិ ភិក្ខវេ កណ្ណសុត្តកំ : ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវខ្សែសម្រាប់ចងជាយចីវរ”[១] ដូច្នេះ ខ្សែនោះ គួរធ្វើឱ្យជាអន្ទាក់ចងទុកត្រង់អនុវាទ ដើម្បីប្រជាប់ចីវរទុកក្នុងវេលាជ្រលក់ ។ សូម្បីត្រង់កណ្ដុំនឹងមានក្បាច់ក្បូរឬកំនួចទុក ដើម្បីធ្វើឱ្យស្អាតល្អ មិនគួរ ត្រូវទម្លាយចេញជាមុន ទើបគួរប្រើប្រាស់ ។

១. វិន. មហា. ៨. ៥៣/១១៥ ។

# បរិក្ខារដែលគួរប្រើនិងមិនគួរប្រើ

ត្រង់បាត្រឬស្ដោកបាត្រ ទឹងយកដែកចារគូរឆ្លាក់ក្បាច់ក្បូរ ឬទឹងឆ្លាក់ទុកទាំងខាងក្នុងខាងក្រៅក៏ដោយ, ក្បាច់ក្បូរនោះ មិនគួរ ទឹងលើកបាត្រឡើងកាន់ភមរ (គ្រឿងក្រឡឹង) ខាត់ឱ្យរលើបរលោង ហើយទើបដុត ដោយគិតថា ទឹងធ្វើឱ្យមានពណ៌ដូចកែវមណី មិនគួរ ។ ចំណែកបាត្រដែលមានពណ៌ដូចប្រេង គួរ ។ និងថា ក្នុងជើងបាត្រ ដែលមានក្បាច់ប្រដាប់[១] មិនគួរ តែជារូបធ្មេញមង្ករ គួរ ។

ឆត្រ ធម្មក្រក ទឹងមានក្បាច់ក្បូរទុកខាងលើ ឬខាងក្រោម ឬខាងក្នុងបំពង់ធម្មក្រកក៏ដោយ មិនគួរ ។ តែធម្មក្រកនោះ ទឹងមានក្បាច់ក្បូរទុកត្រង់មាត់ឆត្រ គួរ ។

ដើម្បីទឹងឱ្យវត្ថពន្ធចង្កេះស្រស់ល្អ ទឹងដំអំបោះឱ្យប៉ោងឡើងជាពីរជងក្នុងទីនោះ ៗ គឺ ធ្វើឱ្យប៉ោងឡើងជាក្បាច់ភ្នែកក្ដាម ប្រការនោះ មិនគួរ ។ តែទីបំផុតទាំងពីរខាងទឹងដំឱ្យប៉ោងឡើងជាពីរជង ដើម្បីភាពរឹងមាំនៃជាយសំពត់ គួរ ។ ចំណែកត្រង់ជាយសំពត់ ទឹងធ្វើរូបប្លែក ៗយ៉ាងណាមួយទុក ទោះជារូបឆ្នាំងទឹកក៏ដោយ រូបធ្មេញមង្ករក៏ដោយ រូបក្បាលពស់ទឹកក៏ដោយ មិនគួរ ។ សូម្បីវត្ថពន្ធចង្កេះដែលគេសម្ដែងរូបភ្នែកដំរី

១. ក្នុងសារត្ថ. ភាគ ២ ។

ទុក ឬ ដែលគេធ្វើជារូបក្បាច់ក្បូរផ្កាឈើជាដើមទុកក្នុងទីនោះ ៗ មិនគួរ ។ តែនឹងធ្វើជាធ្នុងត្រី ឬជាស្លឹកល្មើ ឬជាផ្ទាំងសំពត់ដែលរលោងទុកត្រង់ ៗ ប៉ុណ្ណោះ ទើបគួរ ។ វត្ថពន្ធចង្កេះមានខ្សែតែមួយ សមគួរ, មាន ២-៣ សូម្បីដល់ ៤ ខ្សែ ក៏សមគួរ លើសជាងនោះទៅ មិនគួរ ។ វត្ថពន្ធចង្កេះដែលធ្វើដោយខ្សែមួយសរសៃប៉ុណ្ណោះ ទើបគួរ ។ ចំណែកដែលមានសណ្ឋានដូចខ្សែសង្វារ សូម្បីតែមួយសរសៃ ក៏មិនគួរ ។ តែជាយសូម្បីនឹងមានសណ្ឋានដូចសង្វារ ក៏គួរ ។ វត្ថពន្ធចង្កេះដែលគេយកខ្សែច្រើនសរសៃរួមចូលគ្នា ហើយយកខ្សែមួយសរសៃទៀតរុំផ្អបទុកគ្រប់ ៗ ចន្លោះ មិនគួរហៅថា ជាវត្ថពន្ធចង្កេះដែលមានខ្សែច្រើនសរសៃ ។ ការចងវត្ថពន្ធចង្កេះដែលមានខ្សែច្រើនសរសៃនោះ គួរ ។

ត្រង់ក្រវិលរបស់វត្ថពន្ធចង្កេះ និងមានរូបប្លែក ៗ យ៉ាងណាមួយមានរូបមណ្ឌល[1] ៨ ជាដើមមិនគួរ នឹងមានត្រឹមតែស្នាមល្មមជាគ្រឿងកំណត់ គួរ ។ ក្នុងជាយទាំងពីររបស់ក្រវិល គេធ្វើសូម្បីជារូបឆ្នាំងទឹកទុក ដើម្បីធ្វើឱ្យរឹងមាំ, រូបឆ្នាំងនេះ ក៏គួរ ។

---

១. មើលសារត្ថទីបនី ។

## បំពង់ថ្នាំភ្នែកដែលគួរប្រើនិងមិនគួរប្រើ

ត្រង់បំពង់ថ្នាំភ្នែក និងមានរូបស្រ្តី បុរស សត្វជើង ៤ និងរូបបក្សីក៏ដោយ នឹងមានរូបប្លែកផ្សេង ៗ មានប្រភេទជាដើមថា លាយផ្កាឈើ លាយវល្លិ ផ្ចេញមង្គរ មូត្រគោ និងរូបព្រះចន្ទពាក់កណ្តាលក៏ដោយ មិនគួរ ។ រូបត្រង់បំពង់ថ្នាំភ្នែក គួរ កោសឬកាត់ចេញ ឬយកអំបោះរុំបិទទុក ដោយអាការដែលរូបនឹងមិនប្រាកដ គប្បីប្រើប្រាស់ចុះ ។ ចំណែកបំពង់ថ្នាំភ្នែក ៤ ជ្រុង ៨ ជ្រុង ឬ ១៦ ជ្រុងត្រង់ ៗ ប៉ុណ្ណោះទើបគួរ ។ សូម្បីខាងក្រោមបំពង់ថ្នាំភ្នែកនោះ នឹងមានក្បាច់ក្បូរមូល ៗ ទុកត្រឹមតែ ២ ឬ ៣ កន្លែង ក៏គួរ ។ សូម្បីត្រង់កបំពង់ថ្នាំភ្នែកនោះ នឹងមានក្បាច់ក្បូរមូល ៗ ទុកត្រឹមតែ ១ កន្លែង ដើម្បីចងគម្របបិទ ក៏គួរ ។ សូម្បីត្រង់ចង្កឹះថ្នាំភ្នែក នឹងមាន ក្បាច់ក្បូរដែលមានពណ៌រលើង មិនគួរ ។ សូម្បីជង់បំពង់ថ្នាំភ្នែក នឹងមានក្បាច់ក្បូរ ដែលមានពណ៌រលើង ដោយអំបោះមានពណ៌ផ្សេង ៗ ប្រភេទណាមួយ មិនគួរ ។

## ស្រោមកូនសោនិងបរិក្ខារបន្តិចបន្តួច

សូម្បីស្រោមកូនសោ ក៏មានន័យយ៉ាងនេះដូចគ្នា ។ សោ កូនសោមានក្បាច់ដែលមានពណ៌រលើប មិនគួរ ។ ស្រោមកាំបិតកោរក៏ដូចគ្នា ។ មួយទៀត ស្រោមកាំបិតកោរនេះ នឹងជាប្រភេទណា ៗ ក៏ដោយ ដែល

ដេរដោយអំបោះតែមួយពណ៌យ៉ាងណាមួយ គួរ ។

សូម្បីដែកចារ នឹងមានពកកែវមូល ៗ ឬវត្ថុយ៉ាងដទៃដែលមានពណ៌រលើបរលោងក៏ដោយ មិនគួរ ។ ចំណែកត្រង់ក នឹងមានក្បាច់ក្បូរល្មមជាគ្រឿងកំណត់ (គឺ ជាទីសង្កេត) គួរ ។

សូម្បីកន្ត្រៃ នឹងដាក់ពកកែវឬពកប្រភេទណាមួយទុកក៏ដោយ មិនគួរ ។ ចំណែកជងនឹងមានក្បាច់ក្បូរល្មមជាគ្រឿងកំណត់ គួរ ។ កាំបិតកាត់ក្រចកដែលគេធ្វើឱ្យមានស្នាមឆូតទុកប៉ុណ្ណោះ; ព្រោះដូច្នោះការធ្វើឱ្យមានស្នាមគូសឆូតទុកនោះ រមែងគួរ ។

ត្រង់ឈើពូតភ្លើងឈ្មោលក្តី ត្រង់ឈើពូតភ្លើងញីក្តី ត្រង់កូនធ្នូក្តី ត្រង់ជងបំពង់ខាងលើ (ឈើពូតភ្លើងនោះ) ក្តី នឹងមានក្បាច់ក្បូរយ៉ាងណាមួយ ដូចក្បាច់ផ្កាឈើជាដើម ដែលមានពណ៌រលើង មិនគួរ ។ ចំណែកត្រង់កណ្តាលជងបំពង់ មានវង់មូល, ត្រង់វង្វង់នោះ នឹងមានត្រឹមតែក្បាច់ក្បូរល្មមជាគ្រឿងកំណត់ ក៏គួរ ។ ពួកជនធ្វើដង្កៀបសម្រាប់ជាគ្រឿងចាប់ម្ជុលទុក ។ ត្រង់ដង្កៀបសម្រាប់ចាប់ម្ជុលនោះ នឹងមានក្បាច់ក្បូរយ៉ាងណាមួយ ដូចនឹងធ្មេញមករជាដើម ដែលមានពណ៌រលើង មិនគួរ ។ តែធ្វើជាមាត់ដើម្បីចាប់ម្ជុល នឹងមានត្រឹមតែធ្មេញទុកក៏បាន, ធ្មេញមករនោះ រមែងគួរ ។

សូម្បីកាំបិតសម្រាប់កាត់ឈើស្ងួន់ នឹងមានក្បាច់ក្បូរយ៉ាងណាមួយ ដែលមានពណ៌រលើបរលោង មិនគួរ ត្រង់ខាងទាំងពីរ ឬមួយខាង ៗ (របស់កាំបិតនោះ) នឹងយកលោហៈដែលជាកប្បិយចងទុកជា ៤ ជ្រុង ឬ ៨ ជ្រុងត្រង់ ៗ ទុំះឯង ទើបគួរ ។

សូម្បីត្រង់ឈើប្រត់ នឹងមានក្បាច់ក្បូរយ៉ាងណាមួយ ដែលមានពណ៌រលើង មិនគួរ ។ ខាងក្រោម (ឈើប្រត់) នឹងមានក្បាច់មូល ៗ ទុកមួយកន្លែង ឬពីរកន្លែង និងខាងលើនឹងមានត្រឹមតែរូបផ្សិតក្បាលពស់ដែលនៅក្រពុំទុក ក៏គួរ ។

បណ្ដាភាជនៈប្រេង រូបដ៏សេសសូម្បីទាំងអស់ ដែលមានក្បាច់ក្បូរលើង (ដែលមាននៅ) ត្រង់ភាជនៈក្តី នាឡិក្តី សម្បកឃ្លោកក្តី ភាជនធ្វើអំពីខ្លឹមនៃដើមកន្ទួតព្រៃក្តី វៀររូបភាពស្ត្រី និងបុរសចេញ រមែងគួរ ។

ក្នុងបណ្ដាគ្រឿងប្រើផ្សេង ៗ ទាំងនេះ គឺ គ្រែ តាំង ពូក ខ្នើយ កម្រាលផែនដី គ្រណាត់ជូតជើង ពូកត្រង់ទីចង្រ្កម អំបោស ធុងចាក់សម្រាម ស្នូកជ្រលក់សំពត់ ប្រាយទឹកផឹក ឆ្នាំងទឹកផឹក គ្រឿងជូតជើង តាំងក្តារ ជើងរល័យ ជើងបាត្រធ្វើដោយកំណាត់ឈើ គម្របបាត្រស្លឹកត្នោត និងផ្លិតវីជនីនឹងមានក្បាច់ក្បូរដែលមានពណ៌រលើងមានលាយផ្កាឈើ

ជាដើមទាំងអស់ ក៏គួរ ។

ចំណែកក្នុងសេនាសនៈ ត្រង់សន្ទុះទ្វារនិងសន្ទុះបង្អួចជាដើម នឹងមានក្បាច់ក្បូរដែលមានពណ៌វលើង សូម្បីដែលសម្រេចដោយកែវទាំងអស់ ក៏គួរ ។ ក្នុងសេនាសនៈមិនមានក្បាច់ក្បូរអ្វី ៗ ដែលគួរហាមទុក វៀរតែសេនាសនៈដែលខុស ។

## សេនាសនៈដែលខុសគួរទម្លាយចេញ

សេនាសនៈដែលពួកភិក្ខុជារាជវល្លភ សាងទុកក្នុងសីមារបស់ពួកម្ចាស់សីមាដទៃ ហៅឈ្មោះថា សេនាសនៈខុស ។ ព្រោះដូច្នោះ ពួកភិក្ខុដែលសាងសេនាសនៈបែបនោះ ដែលភិក្ខុជាម្ចាស់របស់សីមា គប្បីជាស់តឿនថា "ពួកលោកកុំសាងសេនាសនៈទុកក្នុងសីមារបស់ពួកខ្ញុំព្រះករុណា" (បើ)មិនស្ដាប់នៅតែសាងទ្រុះឯង គប្បីជាស់តឿនដដែលទៀតថា "ពួកលោកកុំមកធ្វើយ៉ាងនេះ, កុំមកធ្វើអន្តរាយដល់ឧបោសថ និងបវារណារបស់ពួកខ្ញុំព្រះករុណា, កុំមកទម្លាយសេចក្ដីសាមគ្គី" សេនាសនៈសូម្បីដែលពួកលោកសាងទុកហើយ នឹងមិនតាំងនៅក្នុងស្ថានទីដែលពួកលោកសាងទុកហើយ បើនៅតែសាងដោយពលការទ្រុះឯង, វេលាណា ម្ចាស់របស់សីមាទាំងនោះ មានលជ្ជីបរិស័ទច្រើនឡើង ទាំងអាចបានពាក្យ

វិនិច្ឆ័យដែលប្រកបដោយធម៌, វេលានោះ គួរបញ្ជូនដំណឹងដល់ភិក្ខុទាំងនោះថា ចូរជញ្ជូនយកទីនៅរបស់ពួកលោកទៅចុះ បើកាលបញ្ជូនដំណឹងទៅដល់ ៣ លើកហើយ លោកទាំងនោះរុះរើទៅ ការរុះរើនោះជាការល្អ, បើមិនទាន់រុះរើទៅសោត, សេនាសនៈដ៏សេសគួរទម្លាយចេញ លើកទុកតែដើមពោធិព្រឹក្ស និងចេតិយ, និងកុំទម្លាយឱ្យជារបស់ដែលប្រើការមិនបាន ។ មួយទៀត គួរនាំវត្ថុផ្សេង ៗ មានគ្រឿងប្រក់ដំបូល គន្លឹះនិងឥដ្ឋជាដើមចេញទៅតាមលំដាប់ ហើយគួរបញ្ជូនដំណឹងដល់លោកទាំងនោះថា "ចូរជញ្ជូនសម្ភារៈរបស់ពួកលោកទៅចុះ" ។ បើជញ្ជូនចេញទៅសោត, ការជញ្ជូននោះជាការល្អ, បើមិនជញ្ជូនចេញទៅសោត, បើថាកាលសម្ភារៈទាំងនោះពុកផុយទៅ ព្រោះសន្សើម ភ្លៀងនិងកំដៅថ្ងៃក្ដៅជាដើមក្ដី ពួកចោរលួចយកទៅក្ដី ត្រូវភ្លើងឆេះក្ដី ពួកភិក្ខុដែលជាម្ចាស់របស់សីមា អ្នកណា ៗ នឹងពោលទោសមិនបាន ទាំងមិនបានដើម្បីនឹងទាមទារថា "ពួកលោកធ្វើឱ្យសម្ភារៈរបស់ពួកខ្ញុំព្រះករុណាវិនាសហើយ" ឬថា "ត្រូវពិន័យជាសំណងដល់ពួកលោក" ដូច្នេះ ។ ក៏កិច្ចណាដែលភិក្ខុម្ចាស់របស់ខេត្តសីមាធ្វើហើយ កិច្ចនោះ ជាការដែលពួកលោកធ្វើប្រពៃហើយតែម្ដង ដូច្នេះឯង ។

ចប់ បាលីមុត្តកវិនិច្ឆ័យ

# ធនិយភិក្ខុផ្ដើមសាងកុដិឈើ

[៨០] ក៏ដើម្បីសម្ដែងដល់សេចក្ដីរំពឹង និងសេចក្ដីឧស្សាហ៍ ដើម្បីសាងកុដិទៀតនុ៎ះឯងរបស់ព្រះធនិយៈ ក្នុងកាលកុដិត្រូវទម្លាយហើយយ៉ាងនោះ ព្រះធម្មសង្គាហកាចារ្យ ទើបបានពោលពាក្យថា **អថខោ អាយស្មតោ** ជាដើម ។

ក្នុងពាក្យថា អាយស្មតោ **: ដ៏មានអាយុ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

បទថា ទារុគហេ គណកោ **: បុរសអ្នកកាន់កាប់ថែរក្សាឈើក្នុងឃ្លាំងហ្លួង** បានដល់ អ្នករក្សាឈើក្នុងឃ្លាំងរបស់ស្ដេច ។

បទថា ទេវគហទារូនិ[១] **: ឈើព្រះរាជទ្រព្យ** បានដល់ ឈើដែលស្ដេចទ្រង់កាន់កាប់ទុក អធិប្បាយថា ឈើដែលព្រះរាជាទ្រង់បំរុងទុក ។

បទថា នគរបដិសង្ខារិកានិ **: សម្រាប់ជួសជុលព្រះនគរ** បានដល់ ឈើជាគ្រឿងឧបករណ៍ សម្រាប់ជួសជុលព្រះនគរ ។

ពីរបទថា អាបទត្ថាយ និក្ខិត្តានិ **: ដែលទុកសម្រាប់ការពារ**

១. ភូមា. ទេវគហទារូនិ ។

អន្តរាយ មានពាក្យអធិប្បាយថា បានដល់ ឈើដែលរក្សាទុកដើម្បីការពារសេចក្តីវិបត្តិនៃវត្ថុទាំងឡាយមានស៊ុមទ្វារ បន្ទាយព្រះរាជវាំង និងរោងដំរីជាដើម ព្រោះត្រូវភ្លើងឆេះ ព្រោះសេចក្តីចាស់ទ្រុឌទ្រោម ឬព្រោះការរុករានរបស់ព្រះរាជាដែលជាសត្រូវជាដើម ដែលលោកហៅថា អន្តរាយ ។

ពីរបទថា **ខណ្ឌាខណ្ឌិកំ ឆេទាបេត្វា** : **ឱ្យមនុស្សកាត់ជាកំណាត់តូចកំណាត់ធំ** សេចក្តីថា ព្រះធនិយៈកំណត់ប្រមាណកុដិរបស់ខ្លួនហើយ បង្គាប់ឱ្យធ្វើការកាត់ឈើត្រង់ចុងខ្លះ ត្រង់កណ្តាលខ្លះ ត្រង់គល់ខ្លះ ឱ្យជាកំណាត់តូចកំណាត់ធំ (ផ្ទុករទេះទៅសាងកុដិឈើហើយ) ។

## វស្សការព្រាហ្មណ៍ដាក់ទោសអ្នករក្សាឈើ

[៨១] ពាក្យថា **វស្សការ** ជាឈ្មោះរបស់ព្រាហ្មណ៍នោះ ។

បទថា **មគធមហាមត្តោ** : **ជាមហាមាត្យ** បានដល់ អាមាត្រធំ គឺ អ្នកប្រកបដោយឋានៈជាឥស្សរិយយសយ៉ាងធំ ក្នុងមគធរដ្ឋ ឬមហាអាមាត្ររបស់ស្តេចផែនដីមគធៈ មានអធិប្បាយថា ជាអាមាត្រធំ ។

បទថា **អនុសញ្ញាយមានោ** : **កាលដើរពិនិត្យត្រួតត្រាមើល** សេចក្តីថា វស្សការព្រាហ្មណ៍ ទៅត្រួតមើលក្នុងទីនោះ ៗ ។

ពាក្យថា **ភណេ** : **នែនាយ** ជាពាក្យរបស់ឥស្សរជនហៅអ្នក

ដែលតាំងនៅក្នុងឋានៈទាប ។

ពីរបទថា ពន្ធំ អាណាបេសិ[1] : ក៏ឱ្យមនុស្សទៅចាប់ចង ហើយនាំមក សេចក្តីថា ព្រាហ្មណ៍សូម្បីដោយប្រក្រតីក៏ជាអ្នកមានសេចក្តីប្រុស្សាក្នុងអ្នករក្សាឈើនោះឯងពិត, លុះគេបានស្តាប់ព្រះរាជតម្រាស់ថា "ចូរឱ្យមនុស្សនាំខ្លួនវាមក" ដូច្នេះ, តែព្រោះព្រះរាជាមិនបានទ្រង់ត្រាស់ថា "ចូរឱ្យហៅវាមក" ដូច្នោះ ទើបចងអ្នករក្សា ឈើនោះ ត្រង់ដៃនិងជើងទាំងពីរ ហើយគិតថា នឹងឱ្យដាក់ទោស ទើបឱ្យចងទុក ។

[៨២] ក្នុងពាក្យថា អទ្ទសា ខោ អាយស្មា ធនិយោ : ធនិយភិក្ខុដ៏មានអាយុ បានឃើញ នោះ សួរថា ព្រះធនិយៈបានឃើញអ្នករក្សាឈើ ត្រូវអ្នកឃុំឃាំងនាំទៅ ដោយអាការយ៉ាងណា ?

ឆ្លើយថា បានឮថា ធនិយភិក្ខុនោះ ជ្រាបថា ឈើដែលអ្នករក្សានាំទៅប្រគេនដោយលេសរបស់ខ្លួន គិតថា "អ្នករក្សានេះនឹងត្រូវសម្លាប់ ឬឃុំឃាំងអំពីរាជត្រកូល ព្រោះហេតុនៃឈើទាំងឡាយ ដោយមិនត្រូវសង្ស័យ" ទើបគិតឡើងក្នុងវេលានោះថា "យើងតែម្នាក់ប៉ុណ្ណោះ នឹងដោះលែងអ្នករក្សាឈើនោះ" ហើយដើរចាំស្តាប់ដំណឹងរបស់គេជានិច្ចកាលទុំះឯង ព្រោះដូច្នោះ ព្រះធនិយៈ ទើបបានទៅឃើញអ្នករក្សាឈើនោះក្នុង

១. ថៃ. ភូមា. អាណាបេសិ : បង្គាប់ហើយ ។

ខណៈនោះឯង ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យ ពោលទុកថា អនុសា ខោ អាយស្មា ធនិយោ : លំដាប់នោះ ធនិយភិក្ខុដ៏មានអាយុ ដូច្នេះជាដើម ។

ពីរបទថា ទារុដំ កិច្ចា : ព្រោះរឿងឈើ សេចក្ដីថា ព្រោះហេតុនៃឈើទាំងឡាយ ។

ពីរបទថា បុរាហំ ហញ្ញាមិ : គួរមក ខ្ញុំព្រះករុណាលំបាកមុនហើយ សេចក្ដីថា ខ្ញុំព្រះករុណានឹងត្រូវកម្ចាត់ចេញពីបុរី ។ អធិប្បាយថា លោកម្ចាស់ គួរទៅ(ជួយខ្ញុំព្រះករុណា) រហូតដល់អស់វេលាដែលខ្ញុំព្រះករុណាមិនទាន់បានត្រូវសម្លាប់ ។ សព្ទថា ឥង្ឃ : ហេតុនេះ ក្នុងពាក្យថា ឥង្ឃ ភន្តេ សរាបេហិ : ហេតុនេះ សូមលោករំលឹកខ្ញុំផងនេះជានិបាត ចុះក្នុងអត្ថថា ទាក់ទង ។

បទថា បឋមាភិសិត្តោ : កាលដែលទ្រង់ទើបបានអភិសេកនោះ សេចក្ដីថា កាលព្រះអង្គសោយរាជ្យតាំងពីដំបូង ។

ច្រើនបទថា ឯវរូបឹ វាចំ ភាសិតា : ទ្រង់មានព្រះបន្ទូល មានសភាពយ៉ាងនេះ មានសេចក្ដីថា កាលព្រះអង្គសោយរាជ្យមុនដំបូងនុ៎ះឯងបានទ្រង់ថ្លែងព្រះវាចាដូច្នេះថា "ទិន្នញ្ញេវ សមណព្រាហ្មណានំ តិណកដ្ឋោទកំ បរិភុញ្ជន្តុ : ស្មៅ ឈើ និងទឹក ខ្ញុំបានឱ្យហើយ ដល់

សមណៈនិងព្រាហ្មណ៍ទាំងឡាយ, សូមសមណៈនិងព្រាហ្មណ៍ទាំងឡាយ មេត្តាប្រើប្រាស់ចុះ” មានពាក្យអធិប្បាយថា សូមថ្វាយព្រះពរ ? ព្រះអង្គបានត្រាស់ព្រះវាចាណាទុក ព្រះវាចានោះ ព្រះអង្គត្រាស់ដោយខ្លួនឯង ឥឡូវនេះ ទ្រង់រលឹកបានឬទេ ?

បានពួថា ព្រះរាជាទាំងឡាយ ល្មមត្រឹមតែថា សោយរាជ្យសម្បត្តិប៉ុណ្ណោះ ក៏ទ្រង់ត្រាស់ ឱ្យត្រាច់វាយស្គរធម្មភេរីប្រកាសថា “ស្មៅ ឈើ និងទឹក ខ្ញុំបានឱ្យហើយ ដល់សមណៈនិងព្រាហ្មណ៍ទាំងឡាយ, សូមសមណៈនិងព្រាហ្មណ៍ទាំងឡាយ មេត្តាប្រើប្រាស់ចុះ” ដូច្នេះ, ព្រះធនិយត្ថេរនេះ ពោលសំដៅយកព្រះរាជតម្រាស់នោះ ។

ប្រើនបទថា តេសំ មយា សន្ធាយ ភាសិតំ : ស្មៅ ឈើ និងទឹក ដែលខ្ញុំនិយាយថា ឱ្យនោះ គឺ ឱ្យចំពោះសមណៈ និងព្រាហ្មណ៍ទាំងនោះ មានអធិប្បាយថា ញោមបានពោលពាក្យយ៉ាងនោះ សំដៅដល់ការនាំស្មៅឈើ និងទឹកទៅរបស់សមណព្រាហ្មណ៍ទាំងនោះ អ្នកមានសេចក្ដីរង្កៀស សូម្បីក្នុងហេតុបន្តិចបន្តួច ដែលជាអ្នកស្ងប់និងបណ្ដេតបាបហើយ មិនបានសំដៅដល់ការនាំទៅរបស់បុគ្គលដូចជាលោកម្ចាស់ទេ ។

ប្រើនបទថា តញ្ច ខោ អរញ្ញេ អបរិគ្គហិតំ : ព្រោះថា ស្មៅ ឈើ និងទឹកនោះឯង ដែលមាននៅក្នុងព្រៃ ឥតមានអ្នកហួងហែងឡើយ មានសេចក្ដីថា ព្រះបាទពិម្ពិសារ ទ្រង់សម្ដែងព្រះប្រាជ្ញាថា យ៉ាងនោះ

ញ្រោមពោលសំដៅយកស្មៅឈើនិងទឹកដែលអ្នកណា ៗ មិនបានហួងហែង ដែលមាននៅក្នុងព្រៃផ្សេងៗ ។

ក្នុងពាក្យថា "ថេយ្យេន ត្វំ មុត្តោសិ : លោករួចទោសហើយដោយសារគេម" នេះ មានវិនិច្ឆ័យដូច្នេះ ៖

គុណជាតិដូចជាគេម ឈ្មោះថា គេម, ក៏គេមនោះ គឺ អ្វី ? គឺ បញ្ញាភេទ ។ ព្រះបាទពិម្ពិសារ ត្រាស់អធិប្បាយទុកយ៉ាងណា ? ត្រាស់អធិប្បាយទុកយ៉ាងនេះគឺ ៖

ប្រៀបដូចពួកអ្នកលេងប្រឹក្សាគ្នាថា ពួកយើងនឹងស៊ីសាច់ហើយគប្បីចាប់ពពែដែលមានគេមដែលមានតម្លៃច្រើនទុក, បុរសអ្នកដឹងដោយល្អម្នាក់ ប្រទះឃើញពពែដែលត្រូវចាប់ទុកនោះ ទើបគិតថា "សាច់ពពែនេះ មានតម្លៃត្រឹមតែមួយកហាបណៈ, តែគេមរបស់វាគ្រប់ ៗ សរសៃមានតម្លៃច្រើនកហាបណៈ" ទើបបានឱ្យពពែ ២ ដែលមិនមានគេមទៅគេ ហើយទទួលយកពពែដែលមានគេមនោះទៅ, ដោយអាការយ៉ាងនេះពពែនោះ គប្បីរួចផុតដោយគេម ព្រោះអាស្រ័យបុរសអ្នកដឹងដោយល្អសេចក្តីនេះយ៉ាងណា, លោកម្ចាស់ក៏ជាយ៉ាងនោះដែរ ជាអ្នកគួរត្រូវសម្លាប់និងឃុំឃាំង ព្រោះធ្វើកម្មនេះ, តែព្រោះលោកម្ចាស់ មានទង់ជ័យព្រះអរហន្ត មានសភាវៈដែលសប្បុរសមិនគប្បីសម្លាប់បាន និងព្រោះលោកម្ចាស់បួសក្នុងព្រះសាសនា ទ្រទ្រង់ទុកនូវទង់ជ័យនៃព្រះអរហន្ត

ដែលជាបព្វជាភេទ ; ហេតុនោះ លោកម្ចាស់ទើបរួចខ្លួនដោយពោម គឺ បព្វជ្ជាភេទនេះ ដូចពពែរួចផុតដោយពោម ព្រោះអាស្រ័យបុរសអ្នកជីង ដោយល្អ ដូច្នោះ ។

## ប្រជាជនពោលទោសតិះដៀលពួកសមណសក្យបុត្រ

[៨៣] ពីរបទថា **មនុស្សា** **ឧជ្ឈាយន្តិ** : **មនុស្សទាំងឡាយពោលទោស** សេចក្តីថា កាលព្រះរាជាទ្រង់បញ្ជាទៅក្នុងបរិស័ទ មនុស្សទាំងឡាយក្នុងស្ថានទីនោះ ៗ កាលបានស្តាប់ព្រះរាជតម្រាស់ ទាំងចំពោះព្រះភក្ត្រ និងកំបាំងព្រះភក្ត្រហើយ រមែងសម្លឹងទោស គឺ មើលងាយបានដល់ កាលមើលងាយក៏សម្លឹងសម្លឹងមើលព្រះថេរៈនោះ, មួយទៀត សំដៅសេចក្តីថា រមែងគិតទៅមកអាក្រក់ ។

បទថា **ខីយន្តិ** : **តិះដៀល** សេចក្តីថា រមែងនិយាយ គឺ ផ្ចាញ់ផ្ចាលទោសរបស់ព្រះថេរៈនោះ ។

បទថា **វិបាចេន្តិ** : **បន្តុះបង្អាប់** សេចក្តីថា តែងរៀងឱ្យធំទូលាយចេញទៅ គឺផ្សាយដំណឹងឱ្យសុសសាយទៅក្នុងស្ថានទីគ្រប់កន្លែង ។ ក៏ឯអ្នកសិក្សាគួរជ្រាបសេចក្តីនេះ តាមជួរគម្ពីរសព្ទសាស្ត្រ ។

មួយទៀត ក្នុងពាក្យថា **ឧជ្ឈាយន្តិ** ជាដើមនេះ មានយោជនាដូច្នេះ គឺមនុស្សទាំងឡាយ កាលគិតដល់រឿងរ៉ាវជាដើមថា ព្រះសមណៈសក្យ

បុត្រទាំងនេះ ជាអ្នកមិនមានសេចក្ដីខ្មាស ដូច្នេះ ឈ្មោះថា **រមែងពោលទោស,** កាលពោលពាក្យជាដើមថា ព្រះសមណសក្យបុត្រទាំងនេះ មិនមានគុណជារបស់សមណៈ ដូច្នេះ ឈ្មោះថា **រមែងតិះដៀល,** កាលខ្សឹបខ្សាយដំណឹងធំទូលាយចេញទៅក្នុងស្ថានទីនោះ ៗ ជាដើមថា ព្រះសមណៈសក្យបុត្រទាំងនេះ ប្រាសចាកភាពជាសមណៈហើយ ដូច្នេះ ឈ្មោះថា **រមែងបន្តុះបង្អាប់** ។ សូម្បីតពីនេះទៅ ក៏គួរជ្រាបយោជនានៃបទទាំងនេះ តាមគួរដល់បទដែលមកហើយក្នុងទីនោះ ៗ ដោយន័យនេះ ។

បណ្ដាបទទាំងនោះ បទថា ព្រហ្មចារិនោ : ប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺ អ្នកប្រព្រឹត្តប្រសើរ, ភាពជាសមណៈ ឈ្មោះថា **សាមញ្ញៈ** ។ ភាពជាអ្នកប្រសើរ ឈ្មោះថា **ព្រហ្មញ្ញៈ** ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយទាំងអស់នោះឯង ។

ក្នុងពាក្យថា រញ្ញោ ទារូនិ : **ឈើរបស់ស្ដេច** ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

សេចក្ដីថា បានកាន់យកឈើរបស់ស្ដេច ដែលមិនបានព្រះរាជទាន ដូច្នេះ មានសេចក្ដីសម្ដែងទោសជាអត្ថ ។ មួយទៀត ដើម្បីសម្ដែងដល់ឈើដែលមិនបានព្រះរាជទាន ដែលព្រះធនិយៈបានកាន់យកហើយនោះ ទើបលោកពោលថា ឈើរបស់ស្ដេចជាដើម ។ ដែលអ្នកសិក្សា

ទាំងឡាយ កាលមិនវង្វេងភ្លេចសេចក្ដីផ្សេងនៃវចនៈ ក៏គួរជ្រាបសេចក្ដីដូចអធិប្បាយមកដូច្នេះឯង ។

## ទ្រង់ប្រជុំសង្ឃបញ្ញត្តិសិក្ខាបទ

ពីរបទថា **បុរាណវោហារិកោ មហាមត្តោ : មហាមាត្យ ពីដើមធ្លាប់ធ្វើជាចៅក្រមចាស់** មានសេចក្ដីថា មហាអាមាត្រដែលដល់ការរាប់ថា អ្នកពិភាក្សា ព្រោះត្រូវតែងតាំងទុកក្នុងវោហារ គឺ ការកាត់ក្ដីបណ្ដឹងក្នុងកាលមុនអំពីភាពជាភិក្ខុ គឺ ក្នុងវេលាជាគ្រហស្ថ ។

ប្រើនបទថា **អថខោ ភគវា តំ ភិក្ខុំ ឯតទវោច : វេលានោះព្រះអង្គទ្រង់មានព្រះបន្ទូលសួរភិក្ខុនោះ** អធិប្បាយសេចក្ដីថា ព្រះមានព្រះភាគ ទ្រង់រមែងជ្រាបសូម្បីនូវបញ្ញត្តិនៃលោកនៅដោយព្រះអង្គឯង ទ្រង់រមែងជ្រាបសូម្បីនូវព្រះបញ្ញត្តិនៃព្រះពុទ្ធក្នុងអតីតទាំងឡាយថា ព្រះពុទ្ធទាំងឡាយសូម្បីក្នុងកាលមុន រមែងទ្រង់បញ្ញត្តិបារាជិកដោយទ្រព្យប៉ុណ្ណេះ ថុល្លច្ច័យដោយទ្រព្យប៉ុណ្ណេះ ទុក្កដដោយទ្រព្យប៉ុណ្ណេះ សូម្បីកាលជាដូច្នោះ បើព្រះអង្គទ្រង់មិនប្រៀបធៀបនឹងអ្នកដែលដឹងបញ្ញត្តិនៃលោកពួកដទៃហើយ ទ្រង់បញ្ញត្តិបារាជិកដោយទ្រព្យត្រឹមមួយបាទ ក៏នឹងមានអ្នកពោលតិះដៀលព្រះអង្គ ព្រោះហេតុប៉ុណ្ណោះថា "ឈ្មោះថា សីលសំវរៈសូម្បីរបស់ភិក្ខុមួយរូប ក៏ប្រមាណមិនបាន រាប់មិនបានធំទូលាយ

ក្រៃលែងណាស់ ដូចមហាប្រថពី សមុទ្រ និងអាកាស, ព្រះមានព្រះភាគ ញ៉ាំងសីលសំវរៈនោះឱ្យវិនាស ដោយទ្រព្យត្រឹមមួយបាទ", អំពីនោះ ភិក្ខុទាំងឡាយ ដែលមិនដឹងកម្លាំងព្រះញាណរបស់ព្រះតថាគត ក៏គប្បី ញ៉ាំងសិក្ខាបទឱ្យកម្រើក សិក្ខាបទ សូម្បីដែលទ្រង់បញ្ញត្តិទុកហើយ ក៏ មិនគប្បីតាំងនៅក្នុងទីដែលគួរ, តែកាលទ្រង់ប្រៀបធៀបនឹងអ្នកដែលដឹង បញ្ញត្តិរបស់លោកហើយ ទើបទ្រង់បញ្ញត្តិសិក្ខាបទ ការតិះដៀលនោះ រមែងមិនមាន, រមែងមានតែអ្នកពោលយ៉ាងនេះដោយពិតថា "សូម្បីអ្នក គ្រប់គ្រងផ្ទះទាំងនេះ ក៏នៅសម្លាប់ចោរចោលខ្លះ ឃុំឃាំងទុកខ្លះ និរទេស ចេញខ្លះ ព្រោះទ្រព្យត្រឹមតែមួយបាទ, រឿងអ្វីដែលថា ព្រះមានព្រះភាគ នឹងទ្រង់មិនញ៉ាំងបព្វជិតឱ្យវិនាសចេញហ្ន៎ ព្រោះបព្វជិតមិនគួរលួចទ្រព្យ របស់អ្នកដទៃ សូម្បីត្រឹមតែស្មៅមួយសរសៃ" ភិក្ខុទាំងឡាយក៏នឹងដឹង កម្លាំងព្រះញាណរបស់ព្រះតថាគត និងសិក្ខាបទសូម្បីដែលទ្រង់បញ្ញត្តិទុក ហើយ ក៏នឹងមិនកម្រើកនឹងតាំងនៅក្នុងទីដែលគួរ ។ ព្រោះដូច្នោះ ទ្រង់ មានព្រះប្រាថ្នានឹងប្រៀបធៀបជាមួយអ្នកដែលដឹងបញ្ញត្តិក្នុងលោកហើយ ទើបទ្រង់បញ្ញត្តិ ទ្រង់មើលបរិស័ទគ្រប់ជំពូក គ្រានោះឯងព្រះមានព្រះភាគ ទ្រង់ទតឃើញភិក្ខុនោះគង់នៅក្នុងទីមិនឆ្ងាយបានត្រាស់ពាក្យនេះចំពោះភិក្ខុ នោះ (គឺ បានត្រាស់ពាក្យនេះ) ថា "ម្នាលភិក្ខុ ព្រះបាទពិម្ពិសារមាគធា សេនិយៈ ចាប់ចោរបានហើយ សម្លាប់ក្តី ឃុំឃាំងក្តី និរទេសក្តី ដោយ

របស់មានតម្លៃចំនួនប៉ុន្មាន” ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា មាគធោ : មាគធ: បានដល់ ជាធំនៃមនុស្សក្នុងដែនមគធ ។

បទថា សេនិយោ : សេនិយរាជ បានដល់ អ្នកដល់ព្រមដោយសេនា ។

ពាក្យថា ពិម្ពិសារោ : ព្រះបាទពិម្ពិសារ ជាព្រះនាមកភិធេយ្យរបស់ព្រះរាជាព្រះអង្គនោះ ។

បទថា បព្វាជេតិ វា : និរទេសក្តី មានសេចក្ដីថា ទ្រង់ឱ្យចៀសចេញទៅពីព្រំដែន ។ បទដ៏សេសក្នុងពាក្យនេះ មានសេចក្ដីងាយយល់ទាំងអស់ ។

ពីរបទថា បញ្ចមាសកោ បាទោ : ប្រាក់៥មាសក ជា១បាទ សេចក្ដីថា គ្រានោះ ក្នុងក្រុងរាជគ្រឹះ ២០ មាសក ស្មើមួយកហាបណៈ ; ព្រោះដូច្នោះ ប្រាំមាសកទើបជាមួយបាទ ។ ដោយលក្ខណៈនោះ ចំណែកទីបួនរបស់កហាបណៈគប្បីជ្រាបថា ជាមួយបាទ ក្នុងជនបទទាំងពួង ។ ក៏បាទនោះឯង គប្បីជ្រាបដោយអំណាចនៃនីលកហាបណៈរបស់បុរាណ មិនគប្បីជ្រាបដោយអំណាចនៃកហាបណៈ ក្រៅនេះ មានការទាមទាឱ្យបង់នូវកហាបណៈជាដើម ។

## ព្រះពុទ្ធគ្រប់អង្គពិន័យទោសដល់បារាជិកត្រឹមមួយបាទឡើង

សូម្បីព្រះពុទ្ធទាំងឡាយដែលកន្លងទៅហើយ ក៏ទ្រង់បញ្ញត្តិបារាជិកដោយទ្រព្យមួយបាទនោះ សូម្បីព្រះពុទ្ធទាំងឡាយនឹងមានក្នុងអនាគត ក៏នឹងទ្រង់បញ្ញត្តិបារាជិកដោយទ្រព្យមួយបាទនោះ ។ ពិតមែន ការផ្សេងគ្នាក្នុងវត្ថុបារាជិក ឬក្នុងបារាជិក របស់ព្រះពុទ្ធគ្រប់ព្រះអង្គ រមែងមិនមាន ។ វត្ថុនៃបារាជិក ៤ ក៏ដូចគ្នា, បារាជិក ៤ ក៏ដូចគ្នា មិនមានខ្វះ ឬលើសជាងនេះ ។ ព្រោះហេតុនោះ សូម្បីព្រះមានព្រះភាគ គ្រាទ្រង់តិះដៀលធនិយភិក្ខុហើយ កាលនឹងទ្រង់បញ្ញត្តិទុតិយបារាជិកដោយទ្រព្យមួយបាទនោះ ទើបត្រាស់ពាក្យថា យោ បន ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ : ភិក្ខុណាមួយ (កាន់យក)ទ្រព្យដែលគេមិនបានឱ្យ ដោយចំណែកនៃចិត្តលួច ជាដើម ។

កាលទុតិយបារាជិកដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិ ធ្វើឱ្យរឹងមាំដោយអំណាចនៃសេចក្តីជាច់មូលយ៉ាងនោះហើយ សូម្បីរឿងភិក្ខុដទៃទៀតដែលលួចបង្វេចទ្រព្យរបស់ជាងជ្រលក់ ក៏បានកើតឡើង ដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ ដើម្បីសម្តែងសេចក្តីកើតឡើងនៃរឿងនោះ ព្រះធម្មសង្គាហកាចារ្យ ទើបបានពោលពាក្យនេះទុកថា "សិក្ខាបទនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិហើយ ដល់ភិក្ខុទាំងឡាយ យ៉ាងនេះ" ។

សេចក្តីនៃរឿងនោះ និងសេចក្តីសម្ព័ន្ធគ្នានៃអនុប្បញ្ញត្តិ គប្បីជ្រាបដោយន័យដែលពោលទុកហើយក្នុងបឋមបារាជិកវណ្ណនានុ៎ះឯង ។ គ្រប់ ៗ សិក្ខាបទ បន្ទាប់ពីសិក្ខាបទនេះទៅ ក៏គប្បីជ្រាបដូចយ៉ាងក្នុងសិក្ខាបទនេះ ។ ពិតមែន ពាក្យណា ៗ ដែលខ្ញុំព្រះករុណាបានពោលទុកហើយពីខាងដើម ខ្ញុំព្រះករុណានឹងលះវៀរពាក្យនោះ ៗ ទាំងអស់ហើយពណ៌នាចំពោះពាក្យដែលមិនធ្លាប់មានអំពីខាងដើម ឱ្យក្រៃលែងឡើង ។ ក៏បើថា ខ្ញុំព្រះករុណានឹងពណ៌នាពាក្យដែលមានន័យដូចដែលពោលហើយនោះ ៗ ដដែលទៀត, កាលណា ខ្ញុំព្រះករុណានឹងដល់ការចប់ស្រេចនៃការពណ៌នាបានហ្ន៎ ? ព្រោះដូច្នោះ អ្នកសិក្សាទាំងឡាយ គួរកំណត់ពាក្យដែលពោលទុកហើយក្នុងកាលមុននោះ ៗ ទាំងអស់ឱ្យល្អហើយជ្រាបសេចក្តីនិងយោជនាក្នុងពាក្យនោះ ៗ ។ មួយទៀត ពាក្យយ៉ាងណាមួយ ដែលមិនទាន់ធ្លាប់មាន ទាំងមានសេចក្តីមិនទាន់ភ្លឺច្បាស់ ខ្ញុំព្រះករុណានឹងពណ៌នាពាក្យនោះទាំងអស់ ។

ចប់ បឋមបញ្ញត្តិ

# អនុប្បញ្ញត្តិ

[៨៤] ពីរបទថា រជកត្ថរណំ គន្ត្វា : នាំគ្នាទៅកាន់កំពង់របស់ជាងជ្រលក់ សេចក្ដីថា ទៅកាន់កំពង់ដែលហាលសំពត់របស់ជាងជ្រលក់ ។ ពិតមែន កំពង់នោះ ហៅថា កំពង់ហាលសំពត់របស់ជាងជ្រលក់ ព្រោះត្រង់កំពង់នោះ ជាកន្លែងពួកជាងជ្រលក់លាតសំពត់ហាលទុក ។

បទថា រជកភណ្ឌិកំ : បង្វិចសំពត់របស់ជាងជ្រលក់ បានដល់កញ្ចប់វត្ថុ ៗ ពួកជាងជ្រលក់ ។ វេលាល្ងាចពួកជាងជ្រលក់ កាលទីងត្រឡប់ចូលទៅកាន់ក្រុង ចងសំពត់ច្រើនផ្ទាំងរួមជាបង្វេច ៗ ទុក, ពួកភិក្ខុឆព្វគ្គិយ កាលជាងជ្រលក់ទាំងនោះមិនឃើញ ព្រោះសេចក្ដីធ្វេសប្រហែស ក៏បានលួចអធិប្បាយថា លួចយកកញ្ចប់មួយអំពីកញ្ចប់នោះទៅ ។

## អត្ថាធិប្បាយស្រុកដែលមានខ្ទមមួយខ្នងជាដើម

[៨៥] ពាក្យមានជាដើមយ៉ាងនេះ គាមោ ឆាម : ដែលឈ្មោះថា ស្រុក ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីសម្ដែងប្រភេទនៃស្រុកនិងព្រៃ ដែលព្រះអង្គត្រាស់ទុកហើយក្នុងពាក្យនេះថា អំពីស្រុកក្ដី អំពីព្រៃក្ដី ។

ក្នុងពាក្យថា **ឯកកុដិកោបិ គាមោ** : **ស្រុកដែលមានខ្ទមមួយក្តី** នោះ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងស្រុកណាមានខ្ទមមួយខ្នងប៉ុណ្ណោះ ឈ្មោះថា មានផ្ទះមួយខ្នងដូចក្នុងមលយជនបទ ស្រុកនេះ ឈ្មោះថា **ស្រុកមានខ្ទមមួយ** ។ ស្រុកពួកជទៃក៏គួរជ្រាបដោយន័យនោះ ។ ស្រុកណាជាអាវាសដែលយក្ខហួងហែង ព្រោះមិនមានពួកមនុស្សដោយប្រការទាំងពួង ឬពួកមនុស្សលំបាកនឹងត្រឡប់មកសូម្បីទៀត ដោយហេតុយ៉ាងណាមួយតែម្តង ក៏ចៀសចេញទៅពីស្រុកណា, ស្រុកនោះ ឈ្មោះថា **ឥតមនុស្ស** ។ ស្រុកណាដែលគេធ្វើកំផែងបូកដោយឥដ្ឋជាដើមទុក ដោយហោចទៅ សូម្បីលោមព័ទ្ធទុកដោយបន្ទានិងមែកឈើ, ស្រុកនោះ ឈ្មោះថា **មានរបងឬកំផែង** ។ ស្រុកណាដែលពួកមនុស្សមិនបានតាំងអាស្រ័យនៅ ដោយអំណាចជាស្ថានទីសម្រាករួមគ្នាដែលជិតថ្នល់ជាដើម តែសាងផ្ទះទុក ២-៣ ខ្នងហើយចូលអាស្រ័យនៅក្នុងទីនោះ ៗ ដូចគោដេកនៅក្នុងទីនោះ ៗ ២-៣ ក្បាលដូច្នោះ ស្រុកនោះ ឈ្មោះថា **ដែលគេទើបនៅថ្មីដូចជាគោឈរ** ជាដើម ។ បណ្តាពួកអ្នកជួញដោយស្នូង និងពួកអ្នករទេះជាដើម ពួកណាមួយ ឈ្មោះថា **សត្ថ** : ពួកឈ្មួញ ។ មួយទៀត ក្នុងសិក្ខាបទនេះ និគមក្តី ស្រុកក្តី គប្បីជ្រាបថា លោកកាន់យកដោយ គាមស័ព្ទទាំងនោះ ។

## អត្ថាធិប្បាយខេត្តឧបចារស្រុកនិងផ្ទះជាដើម

ពាក្យថា **គាមូបចារោ** : ឧបចារស្រុក ជាដើម ព្រះអង្គត្រាស់ដើម្បីសម្តែងការកំណត់ព្រៃ ។

ពីរបទថា **ឥន្ទខីលេ ឋិតស្ស** : ឈរប្រឰធរណីទ្វារស្រុក សេចក្តីថា បានដល់ បុរសអ្នកឈរត្រង់សសរខឿនរួមចូលខាងក្នុងនៃស្រុកដែលមានសសរខឿន ២ ដូចអនុរាធបុរី ដូច្នោះ ។ ពិតមែន សសរខឿនខាងក្រៅ នៃអនុរាធបុរីនោះ ដោយអភិធម្មន័យ រមែងដល់ការរាប់ថា ជាព្រៃ ។ មួយទៀត បានដល់ បុរសអ្នកឈរនៅត្រង់កណ្តាលនៃស្រុកដែលមានសសរខឿនតែមួយឬអ្នកឈរនៅត្រង់កណ្តាលនៃទ្វារស្រុក ។ ពិតមែន ក្នុងស្រុកណាមិនមានសសរខឿន, ត្រង់កណ្តាលនៃទ្វារស្រុក ក្នុងស្រុកនុ៎ះឯង ហៅថា សសរខឿន, ព្រោះហេតុនោះខ្ញុំព្រះករុណាទើបពោលទុកថា បានដល់ បុរសអ្នកឈរនៅត្រង់កណ្តាលនៃទ្វារស្រុក ។

បទថា **មជ្ឈិមស្ស** : កណ្តាល សេចក្តីថា បានដល់ មជ្ឈិមបុរស មិនមែនបុរសខ្នាតកណ្តាល គឺ មិនមែនបុរសអ្នកមានកម្លាំងតិចទេ ហើយក៏មិនមែនជាបុរសមានកម្លាំងច្រើនដែរ, មានពាក្យអធិប្បាយថា បានដល់ មជ្ឈិមបុរស ។

បទថា លេឌ្ឌុបាតោ : ទីធ្លាក់ចុះនៃដុំដីដែលចោលទៅ បានដល់ស្ថានទីធ្លាក់នៃដុំដីដែលគេមិនបានគ្រវែងទៅ ដូចជាមាតុគ្រាម ទឹងឱ្យពួកក្អែកហើរចៀសទៅ ទើបលើកដៃឡើងចោលដុំដីទៅត្រង់ ៗ ប៉ុណ្ណោះ និងដូចពួកភិក្ខុស្បង់ទឹកសាចទៅក្នុងឱកាសដែលកំណត់ខេត្តឧទកុក្ខេប តែគ្រវែងទៅដូចមនុស្សកម្លោះ ៗ ទឹងប្រឡងកម្លាំងរបស់ខ្លួនទើបលាតដៃចេញមកគ្រវែងដុំដីទៅ ដូច្នោះ ។ តែមិនគួរកំណត់យកកន្លែងដែលដុំដីធ្លាក់ហើយរមៀលទៅដល់ ។

ក៏ក្នុងពាក្យថា អបរិក្ខិត្តស្ស គាមស្ស ឃរូបចារេ ឋិតស្ស មជ្ឈិមស្ស បុរិសស្ស លេឌ្ឌុបាតោ : ទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្រែបឧបចារផ្ទះនៃស្រុកដែលឥតរបងឬកំផែង ចោលទៅ នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

មជ្ឈិមបុរស ដែលឈរត្រង់ទឹកធ្លាក់នៃសំយាបផ្ទះ បោះចង្អេរឬអង្រែឱ្យធ្លាក់ចុះ ឈ្មោះថា **ឧបចារផ្ទះ** ។ ក្នុងអដ្ឋកថាកុរុន្ទីលោកពោលទុកថា ទីដែលមជ្ឈិមបុរសឈរនៅត្រង់ឧបចារផ្ទះនោះ គ្រវែងដុំដីទៅធ្លាក់ចុះ ឈ្មោះថា **ឧបចារស្រុក** ។ សុម្បីក្នុងអដ្ឋកថាមហាបច្ចរី លោកក៏ពោលទុកដូច្នោះដែរ ។ មួយទៀត ក្នុងមហាអដ្ឋកថា លោកតាំងមាតិកាទុកថា ឈ្មោះថា ផ្ទះ ឈ្មោះថា ឧបចារផ្ទះ ឈ្មោះថា ស្រុក ឈ្មោះថា

**ឧបចារស្រុក** ហើយពោលថា ខាងក្នុងទីទឹកធ្លាក់នៃជាយស្បូវ ឈ្មោះថា **ផ្ទះ ។** ចំណែកទីធ្លាក់នៃទឹកលាងភាជនៈ ដែលមាតុគ្រាម ឈរនៅត្រង់ទ្វារសាចចុះមក និងទីធ្លាក់នៃចង្អេរ ឬអំបោស ដែលមាតុគ្រាមដូចគ្នា ឈរខាងក្នុងផ្ទះបោះចេញទៅខាងក្រៅតាមប្រក្រតី និងរបងលោមព័ទ្ធ ដែលគេតត្រង់ជ្រុងពីរផ្នែកខាងមុខផ្ទះ តាំងទ្វារគន្លឹះឈើទុកត្រង់កណ្ដាល ធ្វើទុកសម្រាប់ការពារពួកគោចូលទៅ សូម្បីទាំងអស់នេះ ឈ្មោះថា **ឧបចារផ្ទះ ។** ខាងក្នុងលេឌ្ឌុបាទរបស់មជ្ឈិមបុរស ដែលឈរត្រង់ឧបចារផ្ទះនោះ ឈ្មោះថា **ស្រុក ។** ខាងក្នុងលេឌ្ឌុបាតដទៃអំពីនោះ ឈ្មោះថា **ឧបចារស្រុក ។** ពាក្យដែលពោលទុកក្នុងមហាអដ្ឋកថានេះ រមែងជាប្រមាណក្នុងពាក្យនេះថា មជ្ឈិមបុរសឈរត្រង់ឧបចារផ្ទះនៃស្រុកដែលមិនបានលោមព័ទ្ធគ្រវែងដុំដីទៅធ្លាក់ ។ ឧទាហរណ៍ថា ពាក្យដែលលោកពោលទុកក្នុងមហាអដ្ឋកថានេះ រមែងជាប្រមាណក្នុងទីនេះយ៉ាងណា, អដ្ឋកថាវាទៈក្ដី ថេរវាទៈក្ដី ដែលខ្ញុំព្រះករុណានឹងពោលខាងនៅខាងមុខ ក៏គប្បីឃើញដោយភាពជាប្រមាណក្នុងទីទាំងពួង ដូច្នោះ ។

សួរថា ក៏ពាក្យដែលលោកពោលទុកក្នុងមហាអដ្ឋកថានេះ ប្រាកដដូចជាំទាស់នឹងព្រះបាលី ព្រោះក្នុងព្រះបាលី ព្រះអង្គត្រាស់ទុកត្រឹមតែៈប៉ុណ្ណេះថា មជ្ឈិមបុរស ដែលឈរត្រង់ឧបចារផ្ទះគ្រវែងដុំដីទៅធ្លាក់ ។ តែក្នុងមហាអដ្ឋកថា លោកធ្វើលេឌ្ឌុបាទនោះឱ្យដល់ការរាប់ថា ស្រុក

ហើយពោលឧបចារស្រុក បន្ទាប់លេណ្ឌុបាតនោះចេញទៅ ?

ខ្ញុំព្រះករុណានឹងឆ្លើយតទៅ ៖

ពាក្យទាំងអស់នុ៎ះឯង លោកពោលទុកក្នុងព្រះបាលីហើយ ។ ចំណែកសេចក្តីអធិប្បាយក្នុងព្រះបាលីនេះ អ្នកសិក្សាគួរជ្រាប ។ ក៏ឯសេចក្តីអធិប្បាយ ព្រះអដ្ឋកថាទាំងឡាយប៉ុណ្ណោះជ្រាបច្បាស់ ព្រោះហេតុនោះ លក្ខណៈនៃឧបចារផ្ទះ សូម្បីមិនបានត្រាស់ទុកក្នុងព្រះបាលីថា អ្នកឈរត្រង់ឧបចារផ្ទះ ដូច្នេះ លោកក៏កាន់យកដោយអំណាចនៃលក្ខណៈដែលពោលទុកក្នុងអដ្ឋកថា យ៉ាងណា, សូម្បីលក្ខណៈនៃឧបចារផ្ទះដ៏សេស ក៏គួរកាន់យកដូច្នោះ ។

ក្នុងសព្វថា គាមូបចារៈនោះ ក៏គួរជ្រាបន័យដូចតទៅនេះ ៖

ឈ្មោះថា ស្រុកក្នុងសិក្ខាបទនេះ មាន ២ ប្រភេទគឺ ស្រុកដែលមានរបងលោមព័ទ្ធ ១ ស្រុកដែលមិនមានរបងលោមព័ទ្ធ ១ ។ ក្នុងស្រុក ២ ប្រភេទនោះរបងលោមព័ទ្ធនុ៎ះឯង ជាខេត្តកំណត់របស់ស្រុកដែលមានរបងលោមព័ទ្ធ ។ ព្រោះហេតុនោះ ក្នុងព្រះបាលី ព្រះអង្គទើបមិនត្រាស់ខេត្តកំណត់ទុកជាផ្នែកមួយ តែបានត្រាស់ទុកថា "ដែលឈ្មោះថា ឧបចារស្រុក(នោះ) គឺ ទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្រែបធរណីទ្វារនៃស្រុកដែលមានរបងឬកំផែង ចោលទៅ" ។ ចំណែកខេត្តកំណត់ស្រុក នៃស្រុកដែលមិនបានលោមព័ទ្ធ ក៏គួរពោលទុកផង ។

ព្រោះដូច្នោះ ដើម្បីសម្ដែងខេត្តកំណត់ស្រុក នៃស្រុកដែលមិនបានព័ទ្ធរបងនោះ ព្រះអដ្ឋកថាទើបត្រាស់ទុកថា "ឬ (ដែលឈ្មោះថា ឧបចារស្រុកនោះ គឺ) ទីដែលធ្លាក់ចុះដុំដីរបស់មជ្ឈិមបុរសឈរប្រែបឧបចារផ្ទះនៃស្រុកដែលឥតរបង ឬកំផែងចោលទៅ" កាលសម្ដែងខេត្តកំណត់របស់ស្រុកទុកហើយនុ៎ះឯង លក្ខណៈនៃឧបចារស្រុក អ្នកណា ៗ ក៏អាចជ្រាបបាន ដោយន័យដូចដែលពោលទុកហើយក្នុងកាលមុនតែម្ដង; ព្រោះដូច្នោះ ព្រះអដ្ឋកថាទើបមិនត្រាស់ដដែលទៀតថា "មជ្ឈិមបុរសឈរត្រង់ឧបចារផ្ទះនោះ គប្បីវែងដុំដីទៅធ្លាក់" ទេ ។ ចំណែកអាចារ្យណា ពោលលេឌ្ឌុបាទរបស់មជ្ឈិមបុរស ឈរត្រង់ឧបចារផ្ទះនុ៎ះឯងថា ជាឧបចារស្រុក ដូច្នេះ ។ ឧបចារផ្ទះរបស់អាចារ្យនោះ រមែងស្របនឹងពាក្យថាស្រុក ។ ព្រោះហេតុនោះ វិភាគនេះ គឺ ផ្ទះ ឧបចារផ្ទះ ស្រុក ឧបចារស្រុក រមែងមិនលាយគ្នា ។ ចំណែកសេចក្ដីវិនិច្ឆ័យក្នុងផ្ទះ ឧបចារផ្ទះ ស្រុកនិងឧបចារស្រុកនេះ អ្នកសិក្សាគួរជ្រាបដោយសេចក្ដីមិនលាយគ្នា (ដូចដែលលោកពោលទុក) ក្នុងវិកាលេគាមប្បវេសនសិក្ខាបទជាដើម ។ ព្រោះដូច្នោះ ស្រុកនិងឧបចារស្រុកក្នុងអទិន្នាទានសិក្ខាបទនេះ អ្នកសិក្សាគួរប្រៀបធៀបបាលី និងអដ្ឋកថាហើយ ជ្រាបតាមន័យដែលពោលទុកហើយនុ៎ះឯង ។ មួយទៀត សូម្បីស្រុកណាកាលពីមុនជាស្រុកធំខាងក្រោយ កាលត្រកូលទាំងឡាយសាបសូន្យទៅ

ក្លាយជាស្រុកតូច ៗ, ស្រុកនោះគួរកំណត់ដោយលេឌ្ឌុបាទអំពីឧបចារផ្ទះ ដូចគ្នា ។ ចំណែកកំណត់ខេត្តពីដើមរបស់ស្រុកនោះ ទាំងដែលមានរបង លោមព័ទ្ធ ទាំងដែលមិនមានរបងលោមព័ទ្ធ ទឹងកាន់យកជាប្រមាណមិនបានឡើយ ដូច្នេះឯង ។

## អត្ថាធិប្បាយកំណត់ខេត្តព្រៃ

ព្រៃដ៏សេសក្នុងអទិន្នាទានសិក្ខាបទនេះ ។ វៀរស្រុកនិងឧបចារស្រុក ដែលមានលក្ខណៈតាមដែលលោកពោលទុកដូច្នេះថា ដែលឈ្មោះថា ព្រៃ គឺ វៀរស្រុកនិងឧបចារស្រុកចេញគប្បីជ្រាបថា ឈ្មោះថាព្រៃ ។ តែក្នុងគម្ពីរអភិធម្ម ព្រះមានព្រះភាគត្រាស់ទុកថា "ត្រង់ពាក្យថា ព្រៃ គឺទាំងអស់នុ៎ះ ដែលចេញផុតពីសសរគោលខាងក្រៅ ឈ្មោះថា ព្រៃ"[១] ។ ព្រះអង្គត្រាស់ទុកក្នុងអរញ្ញសិក្ខាបទថា "ពាក្យថា សេនាសនៈ ទាំងឡាយណា ដែលតាំងនៅក្នុងព្រៃ គឺសេនាសនៈដែលតាំងនៅក្នុងព្រៃ មានចម្ងាយពីស្រុក ៥០០ ជួរធ្នូកំណត់យ៉ាងជិតបំផុត"[២] ។ គប្បីជ្រាបថា

១. អភិ. វិភ. ឈានវិភង្គ. ៨១. ៣៦២/២៦២ ។ ២. វិន. និស្ស. ៣. ១៦៦/២១១; ៤. ៤១៤/៤២៨ បដិទេសនិយទី៤ ប្រែថា "ពាក្យថា សេនាសនៈទាំងឡាយណាមួយ ដែលមាននៅក្នុងព្រៃ គឺ ទីសេនាសនៈយ៉ាងជិតបំផុតត្រឹម ៥០០ ជង ធ្នូ (១,០០០ ម៉ែត្រ) អំពីស្រុក ហៅថា សេនាសនៈតាំងនៅក្នុងព្រៃ" ។

សេនាសនៈព្រៃនោះ រាប់ពីសរសេរខឿនចេញទៅមានប្រវែងចម្ងាយប្រមាណ ៥០០ ធ្នូរធ្នូ ដោយធ្នូរបស់អាចារ្យដែលលោកលើកឡើងហើយ ។

ព្រះមានព្រះភាគ កាលទឹងទ្រង់ចែកសេចក្ដីនៃពាក្យនេះថា អំពីស្រុកក្ដី អំពីព្រៃក្ដី ដោយន័យដូចដែលពោលទុកហើយក្នុងព្រះបាលីយ៉ាងនោះ ទើបទ្រង់សម្ដែងចំណែកទាំង ៥ ទុក ដើម្បីការពារសេចក្ដីអាងលេសនិងឱកាសរបស់ពួកបាបភិក្ខុថា ផ្ទះឧបចារផ្ទះ ស្រុកឧបចារស្រុក (និង) ព្រៃ ។ ព្រោះដូច្នោះ គប្បីជ្រាបថា កាលភិក្ខុលួចវត្ថុដែលមានម្ចាស់ តាំងពីមានតម្លៃមួយបាទឡើងទៅក្នុងផ្ទះក្ដី ឧបចារផ្ទះក្ដី ស្រុកក្ដី ឧបចារស្រុកក្ដី ព្រៃក្ដី ជាបារាជិកដូចគ្នា ។

## អត្ថាធិប្បាយវត្ថុដែលម្ចាស់មានកម្មសិទ្ធិ

ឥឡូវនេះ ដើម្បីសម្ដែងសេចក្ដីនៃពាក្យជាដើមថា គប្បីកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឱ្យ ដោយចំណែកនៃភាពជាចោរ ដូច្នេះទើបព្រះអង្គត្រាស់ថា **អទិន្នំ នាម** ជាដើម ។

ក្នុងពាក្យថា **អទិន្នំ នាម :** ដែលឈ្មោះថា ទ្រព្យដែលគេមិនបានឱ្យ ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងទន្តបោណសិក្ខាបទ សូម្បីវត្ថុជារបស់ខ្លួនដែលមិនបានទទួលប្រគេន ដែលជាកប្បិយ តែជារបស់ដែលមិនគួរទំពាស៊ី ហៅថា **របស់**

**ណាដែលគេមិនទាន់ឱ្យ** ។ តែក្នុងសិក្ខាបទនេះ វត្ថុយ៉ាងណាមួយ ដែលអ្នកដទៃហួងហែង ដែលមានម្ចាស់របស់ ហៅថា **វត្ថុដែលម្ចាស់របស់មិនបានឱ្យ** ។ វត្ថុនោះ ដែលម្ចាស់របស់ទាំងនោះមិនបានឱ្យ ដោយកាយឬវាចា ព្រោះហេតុនោះ ទើបឈ្មោះថា **វត្ថុដែលម្ចាស់របស់មិនបានឱ្យ** ។ ឈ្មោះថា **ដែលគេមិនទាន់បានលះបង់ឱ្យ** ព្រោះថា ម្ចាស់របស់មិនទាន់បានលះបង់ផុតពីដៃរបស់ខ្លួន ឬចាកទីដែលតាំងនៅពីដើម ។ ឈ្មោះថា **ដែលម្ចាស់របស់មិនទាន់ដាច់ចិត្តឱ្យ** ព្រោះថា សូម្បីទ្រព្យតាំងនៅក្នុងទីដើមហើយ តែម្ចាស់របស់ក៏មិនទាន់បានដាច់ចិត្ត ព្រោះមិនទាន់អស់សេចក្តីស្តាយ ឈ្មោះថា **ដែលម្ចាស់របស់នៅរក្សាទុក** ព្រោះជារបស់ដែលម្ចាស់នៅរក្សាទុក ដោយចាត់ចែងការរក្សា ។ ឈ្មោះថា **ដែលគេនៅគ្រប់គ្រងទុក** ព្រោះជារបស់ដែលម្ចាស់ទ្រព្យដាក់តម្កល់ក្នុងទីទាំងឡាយ មានទូជាដើមហើយគ្រប់គ្រង ។ ឈ្មោះថា **ដែលគេនៅប្រកាន់** ព្រោះជារបស់ដែលម្ចាស់នៅប្រកាន់កម្មសិទ្ធិថា “ជារបស់យើង”, ដោយសេចក្តីប្រកាន់ថា “របស់យើង”, ដោយអំណាចតណ្ហាថា “ទ្រព្យនេះរបស់យើង” ។ ឈ្មោះថា **គេនៅហួងហែង** ព្រោះថា ជារបស់ដែលជនពួកដទៃអ្នកជាម្ចាស់ទ្រព្យទាំងនោះនៅហួងហែង ដោយកិច្ចមានការមិនទាន់លះបង់ នៅរក្សា និងនៅគ្រប់គ្រងជាដើមទាំងនោះ ។ ទ្រព្យនោះ ឈ្មោះថា ដែលម្ចាស់របស់មិនបានឱ្យ ។

## អត្ថាធិប្បាយសង្ខាតស័ព្ទចុះក្នុងអត្ថតតិយាវិភត្តិ

ក្នុងបទថា ថេយ្យសង្ខាតំ : ដោយចំណែកនៃចិត្តលួច នេះ មានវិនិច្ឆ័យដូច្នេះ ៖

ចោរ ឈ្មោះថា អ្នកលួច, ភាវៈនៃអ្នកលួច ឈ្មោះថា ថេយ្យំ ។ បទថា ថេយ្យំ : នៃចិត្តលួច នេះ ជាឈ្មោះនៃចិត្តគិតនឹងលួច ។

ពីរបទថា សង្ខា សង្ខាតំ នោះ ជាសេចក្តីតែមួយដូចគ្នា ។ បទថា សង្ខាតំ : ដោយចំណែក នោះ ជាឈ្មោះនៃចំណែក ដូចសង្ខាតស័ព្ទក្នុងឧទាហរណ៍ទាំងឡាយថា "សញ្ញានិទានា ហិ បបញ្ចសង្ខា : ព្រោះធម៌ជាចំណែកនៃសេចក្តីយឺតយូរទាំងឡាយ មានសញ្ញាជាហេតុ"[១] ដូច្នេះជាដើម ។ ចំណែកនោះផង ភាពជាចោរផង ព្រោះដូច្នោះ ទើបឈ្មោះថា ថេយ្យសង្ខាតំ ។ អធិប្បាយថា ចំណែកនៃចិត្តមួយដែលជាចំណែកនៃចិត្តជាចោរ ។ ក៏ពាក្យថា ថេយ្យសង្ខាតំ នេះជាបឋមាវិភត្តិចុះក្នុងអត្ថនៃតតិយាវិភត្តិ; ព្រោះហេតុនោះ បណ្ឌិតគប្បីឃើញដោយសេចក្តីថា ថេយ្យសង្ខាតេន ប្រែថា ដោយចំណែកនៃភាពជាចោរដូច្នេះ ។

១. ខុទ្ទ. សុត្ត. ៥៤. ១០៥/២៩៥ ។

ក៏ភិក្ខុណា រមែងកាន់យក( ទ្រព្យដែលម្ចាស់មិនបានឱ្យ ) ដោយចំណែកនៃភាពជាចោរ, ភិក្ខុនោះ រមែងជាអ្នកមានចិត្តនៃភាពជាចោរ; ព្រោះដូច្នោះ ដើម្បីមិនអើពើដល់ព្យញ្ជនៈ សម្ដែងចំពោះតែសេចក្ដីប៉ុណ្ណោះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់បទភាជនៈនៃបទថា ថេយ្យសង្ខាតំ នោះទុកយ៉ាងនេះថា "ថេយ្យចិត្តោ អវហរណចិត្តោ : ភិក្ខុមានចិត្តជាអ្នកលួច គឺថា ភិក្ខុមានចិត្តគិតនឹងលួច" ដូច្នេះ ។

## អត្ថាធិប្បាយបទមាតិកា ៦ បទ

[៨៦] ក៏ក្នុងពាក្យថា អាទិយេយ្យ ហរេយ្យ អវហរេយ្យ ឥរិយាបថំ វិកោបេយ្យ ឋានា ចាវេយ្យ សង្កេតំ វីតិនាមេយ្យ : គប្បីចាប់យក គប្បីនាំទៅ គប្បីលួចយក គប្បីឱ្យកម្រើកឥរិយាបថ គប្បីឱ្យឃ្លាតចាកទី គប្បីឈានកន្លងទីដែលកំណត់ នេះ បណ្ឌិតគប្បីជ្រាបថា បទដំបូង "គប្បីចាប់យក" ព្រះមានព្រះភាគត្រាស់ដោយអំណាចការបន្លំយក, បទទី ២ "គប្បីនាំទៅ" ត្រាស់ដោយអំណាចនៃភិក្ខុដែលនាំយកទ្រព្យបុគ្គលពួកដទៃទៅ, បទទី ៣ "គប្បីលួចយក" ត្រាស់ដោយអំណាចនៃទ្រព្យដែលគេកប់ទុក, បទទី ៤ "គប្បីឱ្យកម្រើកឥរិយាបថ" ត្រាស់ដោយអំណាចនៃទ្រព្យដែលមានវិញ្ញាណ, បទ

ទី ៥ "**គប្បីឱ្យឃ្លាតចាកទី**" ត្រាស់ដោយអំណាចនៃទ្រព្យដែលគេរក្សាទុកលើគោកជាដើម, បទទី ៦ "**គប្បីឈានកន្លងទីដែលកំណត់**" ត្រាស់ដោយអំណាចនៃសេចក្តីកំណត់ចំណាំ ឬដោយអំណាចនៃដែនគយ ។

មួយទៀត ក្នុងពាក្យថា អាធិយេយ្យ ជាដើមនេះ ការប្រកបសេចក្តី រមែងមានដោយអំណាចវត្ថុតែមួយខ្លះ ដោយអំណាចវត្ថុផ្សេង ៗ ខ្លះ ។ ក៏ឯ សេចក្តីប្រកបដោយអំណាចវត្ថុតែមួយ រមែងប្រើបានដោយទ្រព្យដែលមានវិញ្ញាណប៉ុណ្ណោះ ។ សេចក្តីប្រកបដោយអំណាចវត្ថុផ្សេង ៗ រមែងប្រើបានដោយទ្រព្យដែលលាយគ្នាទាំងដែលមានវិញ្ញាណ ទាំងដែលមិនមានវិញ្ញាណ ។ បណ្តាសេចក្តីប្រកបដោយអំណាចវត្ថុតែមួយ និងវត្ថុផ្សេង ៗនោះ សេចក្តីប្រកបដោយអំណាចវត្ថុផ្សេង ៗ បណ្ឌិតគួរជ្រាបដោយន័យយ៉ាងនេះមុន ។

## អត្ថាធិប្បាយកិរិយានៃការលួច ៦ យ៉ាង

បទថា **អាធិយេយ្យ : គប្បីចាប់យក** សេចក្តីថា ភិក្ខុបន្ទំយកទីសួន ។ ត្រូវអាបត្តិទុក្កដ ។ ញ៉ាំងសេចក្តីសង្ស័យឱ្យកើតឡើងដល់ម្ចាស់របស់ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្ចាស់របស់ដាក់ធុរៈថា "សួននេះនឹងមិនជារបស់យើងទេ" ត្រូវអាបត្តិបារាជិក ។

បទថា ហរេយ្យ : គប្បីនាំទៅ សេចក្តីថា ភិក្ខុមានថេយ្យចិត្តនាំទ្រព្យរបស់អ្នកដទៃទៅស្ទាបអង្អែលភារៈលើសីសៈ ត្រូវអាបត្តិទុក្កដ ។ ធ្វើឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ដាក់ចុះមកកាន់-កត្រូវអាបត្តិបារាជិក ។

បទថា អវហរេយ្យ : គប្បីលួចយក សេចក្តីថា ភិក្ខុទទួលរបស់ដែលគេផ្ញើទុក កាលម្ចាស់របស់ទាមទារសូមមកវិញថា "ទ្រព្យដែលខ្ញុំព្រះករុណាផ្ញើទុកមាន ។ លោកចូរឱ្យទ្រព្យដល់ខ្ញុំព្រះករុណា" ពោលបដិសេធថា "អាត្មាមិនបានទទួលទុកទេ" ត្រូវអាបត្តិទុក្កដ ។ ញ៉ាំងសេចក្តីសង្ស័យឱ្យកើតឡើងដល់ម្ចាស់ ត្រូវអាបត្តិថុល្លច្ច័យ ។ ម្ចាស់ដាក់ធុរៈថា ភិក្ខុនេះ នឹងមិនឱ្យដល់យើងវិញទេ ត្រូវអាបត្តិបារាជិក ។

ពីរបទថា ឥរិយាបថំ វិកោបេយ្យ : គប្បីឱ្យកម្រើកឥរិយាបថ សេចក្តីថា ភិក្ខុគិតថា "យើងនឹងនាំរបស់ទៅព្រមទាំងមនុស្ស" ឱ្យឈានជំហានទីមួយទៅ ត្រូវអាបត្តិថុល្លច្ច័យ ឱ្យឈានជំហានទីពីរទៅ ត្រូវអាបត្តិបារាជិក ។

ពីរបទថា ឋានា ចាវេយ្យ : គប្បីឱ្យឃ្លាតចាកទី សេចក្តីថា ភិក្ខុមានថេយ្យចិត្ត ស្ទាបអង្អែលរបស់ដែលឋិតនៅលើគោក ត្រូវអាបត្តិទុក្កដ ។ ធ្វើឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ឱ្យឃ្លាតចាកទី ត្រូវ

អាបត្តិបារាជិក ។

ពីរបទថា សង្កេតំ វីតិនាមេយ្យ : គប្បីឈានកន្លងទីដែលកំណត់ សេចក្ដីថា ភិក្ខុញ៉ាំងជំហានទីមួយឱ្យឈានកន្លងហួសដែនកំណត់ទុកទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ឱ្យជំហានទីពីរឈានកន្លងទៅ ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត ញ៉ាំងជំហានទីមួយឱ្យឈានកន្លងដែនគយទៅ ត្រូវអាបត្តិថុល្លច្ច័យ ។ ញ៉ាំងជំហានទីពីរឱ្យឈានកន្លងទៅ ត្រូវអាបត្តិបារាជិក ដូច្នេះឯង ។ នេះជាសេចក្ដីប្រកបដោយអំណាចនានាភណ្ឌៈ ក្នុងបទថា អាទិយេយ្យ ជាដើមនេះ ។

ចំណែកសេចក្ដីប្រកបដោយអំណាចឯកភណ្ឌៈ គប្បីជ្រាបដូច្នេះ ៖

ទាសក្ដី សត្វតិរច្ឆានក្ដី ដែលមានម្ចាស់, ភិក្ខុបន្លំយកក្ដី នាំទៅក្ដី លួចទៅក្ដី ឱ្យឥរិយាបថកម្រើកក្ដី ឱ្យឃ្លាតចាកទីក្ដី ឱ្យឈានកន្លងនូវទីកំណត់ក្ដី ដោយន័យ មានបន្លំយកជាដើម តាមដែលពោលហើយ ។ នេះជាសេចក្ដីប្រកបដោយអំណាចឯកភណ្ឌៈ ក្នុងបទថា អាទិយេយ្យ ជាដើមនេះ ។

ម្យ៉ាងទៀត កាលបណ្ឌិតបរិយាយបទទាំងឡាយ ៦ ពួកនេះ គប្បីប្រមូលបញ្ចកៈ ៥ ពួកមកហើយសម្ដែងអវហារ ២៥ យ៉ាង ។ ព្រោះកាលបរិយាយយ៉ាងនេះ រមែងជាការបរិយាយអទិន្នាទានបារាជិកនេះ

ហើយដោយល្អ ៗ តែក្នុងទីនេះ អដ្ឋកថាទាំងពួង ស្អុគស្មាញ ស្រពេចស្រពិល មានវិនិច្ឆ័យលំបាកយល់ ៗ ពិតមែនហើយ ក្នុងបណ្ដាអដ្ឋកថាទាំងពួង ព្រះអដ្ឋកថាចារ្យ រួមអង្គនៃអវហារទាំងឡាយ សូម្បីដែលព្រះមានព្រះភាគត្រាស់ទុកហើយ ក្នុងព្រះបាលីដោយន័យថា "ភិក្ខុកាន់យកទ្រព្យដែលម្ចាស់គេមិនបានឱ្យ ដោយអាការ ៥ យ៉ាង ត្រូវអាបត្តិបារាជិក គឺ ទ្រព្យដែលអ្នកដទៃហួងហែងរក្សា"[១] ដូច្នេះជាដើម ក្នុងកន្លែងខ្លះ សម្ដែងទុកក្នុងបញ្ចកៈតែមួយ ៗ ក្នុងទីកន្លែងខ្លះសម្ដែងទុកពីរបញ្ចកៈ រួមនឹងអង្គ នៃអវហារទាំងឡាយដែលមកហើយថា "ឆហាការេហិ : ដោយអាការ ៦" ដូច្នេះ ៗ តែបញ្ចកៈទាំងនេះ រមែងមិនជាបញ្ចកៈទេ ៗ ព្រោះក្នុងបញ្ចកណា អវហារសម្រេចបានដោយបទមួយ ៗ បញ្ចកនោះ លោកហៅថា បញ្ចកៈ ៗ ក៏ក្នុងពាក្យថា បញ្ចហាការេហិ ជាដើមនេះ អវហារតែម្យ៉ាងប៉ុណ្ណោះ ដែលសម្រេចបានដោយបទសូម្បីទាំងអស់ ៗ ក៏បញ្ចកៈទាំងឡាយពួកណា ដែលលោកសំដៅយកក្នុង៦ បទ នោះ ខ្ញុំព្រះករុណាសម្ដែងទុកហើយ, តែខ្ញុំព្រះករុណា មិនបានប្រកាសអត្ថនៃបញ្ចកៈ សូម្បីទាំងអស់នោះទុក ៗ ក្នុងទីនេះ អដ្ឋកថាទាំងពួងស្អុគស្មាញ ស្រពេចស្រពិល មានវិនិច្ឆ័យ

១. វិន. បារា. អទិន្នាទាន. ១. ១២២/១៧៦ ។

យល់លំបាក ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ គប្បីកំណត់អវហារ ទាំង ២៥ ប្រការនេះ ដែលខ្ញុំព្រះករុណាប្រមូលបញ្ចកៈ៥ ពួកមកហើយ សម្ដែងទុកឱ្យល្អ ។

## បញ្ចកៈ ៥ ពួក រួមជាអវហារ ២៥

ដែលឈ្មោះថា បញ្ចកៈ ៥ គឺ ពួកនៃអវហារ ៥ ដែលកំណត់ដោយភណ្ឌៈផ្សេងគ្នាជាខាងដើម ១, ពួកនៃអវហារ ៥ ដែលកំណត់ដោយភណ្ឌៈតែមួយជា ខាងដើម ១, ពួកនៃអវហារ ៥ ដែលកំណត់ដោយអវហារដែលកើតហើយដោយដៃរបស់ខ្លួនជាខាងដើម ១, ពួកនៃអវហារ ៥ ដែលកំណត់ដោយបុព្វបយោគជាខាងដើម ១, ពួកនៃអវហារ ៥ ដែលកំណត់ដោយការលួចដោយអាការលួចជាខាងដើម ១ ។ បណ្ដាបញ្ចកៈទាំង ៥ នោះ នានាភណ្ឌបញ្ចកៈ និង ឯកភណ្ឌបញ្ចកៈ រមែងបានដោយអំណាចនៃបទទាំង(៥)នេះ គឺ អាទិយេយ្យ : គប្បីចាប់យក ១, ហរេយ្យ : គប្បីនាំទៅ ១, អវហរេយ្យ : គប្បីលួចយក ១, ឥរិយាបថំ វិកោបេយ្យ : គប្បីឱ្យកម្រើកឥរិយាបថ ១, ឋានា ចាវេយ្យ : គប្បីឱ្យឃ្លាតចាកទី ១, បញ្ចកៈទាំងពីរនោះ អ្នកសិក្សាគប្បីជ្រាបដោយន័យដូចដែលខ្ញុំព្រះករុណា

ប្រកបសម្ដែងទុកហើយក្នុងខាងដើមនុ៎ះឯង ។ ចំណែកបទទី ៦ ថា សច្ចេតំ វីតិនាមេយ្យ : គប្បីឈានកន្លងទីដែលកំណត់ នោះ ជារបស់ទូទៅដល់បរិកប្បាវហារ និងនិស្សគ្គិយាវហារ ។ ព្រោះដូច្នោះ គប្បីប្រកបបទទី ៦ នោះ ចូលដោយអំណាចបទដែលបាននៅក្នុងបញ្ចកៈទី ៣ និងទី ៥ ។ នានាភណ្ឌបញ្ចកៈ និងឯកភណ្ឌបញ្ចកៈ ខ្ញុំព្រះករុណាបានពោលទុកហើយ ។

## សាហត្ថិកបញ្ចកៈ មានអវហារ ៥ យ៉ាង

សាហត្ថិកបញ្ចកៈ ដូចម្ដេច ? គឺ សាហត្ថិកបញ្ចកៈ មានអវហារ ៥ យ៉ាងដូច្នេះ គឺ **សាហត្ថិកៈ** កាន់យកដោយដៃរបស់ខ្លួនឯង ១ **អាណត្តិកៈ** បង្គាប់បញ្ជា ១ **និស្សគ្គិយៈ** គ្រវែងវត្ថុបោលទៅ ១ **អត្ថសាធកៈ** ញុំាងអត្ថឱ្យសម្រេច ១ **ធុរនិក្ខេបៈ** ម្ចាស់ដាក់ធុរៈ ១ ។

បណ្ដាអវហារ ៥ យ៉ាងនោះ ដែលឈ្មោះថា **សាហត្ថិកៈ** បានដល់ ភិក្ខុលួចវត្ថុរបស់អ្នកដទៃ ដោយដៃរបស់ខ្លួនឯង ។ ដែលឈ្មោះថា **អាណត្តិកៈ** បានដល់ ភិក្ខុបង្គាប់បញ្ជាអ្នកដទៃថា ចូរលួចវត្ថុរបស់អ្នកឈ្មោះឯណោះ ។ ឈ្មោះថា **និស្សគ្គិយៈ** រមែងបានការប្រកបបទនេះថា គប្បីឱ្យកន្លងហួសខេត្តកំណត់ រួមជាមួយពាក្យនេះថា "ភិក្ខុឋិតនៅខាងក្នុងខេត្តរបស់គយ ហើយបោះផ្ដោងរបស់ឱ្យធ្លាក់ចុះទៅខាងក្រៅ

ខេត្តរបស់គយ ត្រូវអាបត្តិបារាជិក”[១] ដូច្នេះ ។ ដែលឈ្មោះថា **អត្តសាធកៈ** បានដល់ ភិក្ខុបង្គាប់បញ្ជាថា “លោកអាចលួចវត្ថុឈ្មោះឯណោះមកបាន ក្នុងវេលាណា ចូរលួចមកក្នុងវេលានោះ” ។ បណ្ដាភិក្ខុអ្នកបង្គាប់បញ្ជានិងភិក្ខុដែលលួច បើភិក្ខុដែលលួច មិនមានអន្តរាយក្នុងចន្លោះ លួចរបស់នោះមកបាន, ភិក្ខុអ្នកបង្គាប់បញ្ជា រមែងត្រូវអាបត្តិបារាជិកក្នុងខណៈដែលបង្គាប់នុ៎ះឯង ចំណែកភិក្ខុដែលលួច ត្រូវអាបត្តិបារាជិកក្នុងវេលាលួចបានហើយ នេះឈ្មោះថា **អត្តសាធកៈ** ។ ចំណែក **ធុរនិក្ខេបៈ** គប្បីជ្រាបដោយអំណាចទ្រព្យដែលគេផ្ញើទុក ដូច្នេះឯង ។ ពាក្យដែលអធិប្បាយមកនេះ ឈ្មោះថា សាហត្ថិកបញ្ចកៈ ។

## **បុព្វបយោគបញ្ចកៈ មានអវហារ ៥ យ៉ាង**

បុព្វបយោគបញ្ចកៈ ដូចម្ដេច ? គឺ បុព្វបយោគបញ្ចកៈ មានអវហារសួម្បីដទៃ ៥ យ៉ាងទៀត ដូច្នេះ គឺ **បុព្វបយោគ** ប្រកបក្នុងខាងដើម ១ **សហបយោគ** ប្រកបព្រមគ្នា ១ **សំវិធាវហារ** ការបបួលទៅលួច ១ **សង្កេតកម្ម** ការណាត់កំណត់គ្នា ១ **និមិត្តកម្ម** ការធ្វើនិមិត្ត ១ ។ បណ្ដាអវហារទាំង ៥ ពួកនោះ បុព្វបយោគ គប្បីជ្រាបដោយ

---

១. វិន. បារា. អទិន្នាទាន. ១. ១១០/១៦៩ ។

អំណាចបន្តាប់បញ្ញា ។ សហបយោគ គប្បីជ្រាបដោយអំណាចការឱ្យឃ្លាតចាកឋាន ។ ចំណែកអវហារទាំង ៣ ក្រៅនេះ គប្បីជ្រាបដោយន័យដែលមកហើយក្នុងព្រះបាលីនុ៎ះឯង ។ ពាក្យអធិប្បាយមកនេះ ឈ្មោះថា បុព្វបយោគបញ្ចកៈ ។

## ថេយ្យាវហារបញ្ចកៈ មានអវហារ ៥ យ៉ាង

ថេយ្យាវហារបញ្ចកៈ ដូចម្តេច ? គឺ **ថេយ្យាវហារបញ្ចកៈ** មានអវហារសូម្បីដទៃទៀត ៥ យ៉ាង ដូច្នេះ គឺ **ថេយ្យាវហារ** លួចដោយភាពជាចោរ ១ **បសយ្ហាវហារ** លួចដោយសេចក្តីសង្កត់សង្កិន ១ **បរិកប្បាវហារ** លួចតាមសេចក្តីកំណត់ទុក ១ **បដិច្ឆន្នាវហារ** លួចដោយកិរិយាបិទបាំង ១ **កុសាវហារ** លួចដោយការផ្លាស់ប្តូរស្លាក ១ ។

អវហារទាំង ៥ ពួកនោះ ខ្ញុំព្រះករុណានឹងពណ៌នាក្នុងរឿងការផ្លាស់ប្តូរស្លាក មួយរឿង (វិនីតខាងមុខ) ថា "មានភិក្ខុ ១ រូប កាលគេកំពុងចែកចីវរដើម្បីសង្ឃ មានថេយ្យចិត្តគិតលួច ហើយបានផ្លាស់ខ្នងលួចយកចីវរភិក្ខុដទៃ"[១] ដូច្នេះ ។ ពាក្យដែលអធិប្បាយមកនេះ ឈ្មោះថា ថេយ្យាវហារបញ្ចកៈ ។ គប្បីប្រមូលបញ្ចកៈទាំងឡាយពួកនេះហើយជ្រាបអវហារ ២៥ ប្រការទាំងនេះ ដោយប្រការដូច្នេះ ។

---

១. វិន. បារា. អទិន្នាទានសិក្ខាបទ. ១. ១៣៥/១៩២ ។

ក៏ឯព្រះវិន័យធរអ្នកឆ្លាតក្នុងបញ្ចក: ៥ ទាំងនេះ មិនគប្បីប្រញាប់វិនិច្ឆ័យអធិករណ៍ដែលកើតឡើងហើយ គប្បីត្រួតមើលឋាន: ៥ ប្រការដែលព្រះបូរាណាចារ្យទាំងឡាយសំដៅយកពោលទុកថា ៖

ព្រះវិន័យធរអ្នកឆ្លាត គប្បីសង្កេតពិនិត្យឋាន: ៥ ប្រការ គឺ វត្ថុ កាល: ទេស: តម្លៃ និងការប្រើប្រាស់ជាគម្រប់ ៥ ហើយគប្បីទ្រទ្រង់អត្ថរបស់ក្តីទុក ដូច្នេះ ។

## អត្ថាធិប្បាយឋាន: ៥ ប្រការ

បណ្តាឋាន:ទាំង ៥ នោះ ឋាន:ថា វត្ថុ បានដល់ ភណ្ឌ: ។ ក៏កាលភិក្ខុដែលលួច សូម្បីទទួលជាសត្យ:ថា ភណ្ឌ:ឈ្មោះនេះ ខ្ញុំព្រះករុណាលួចទៅពិត ព្រះវិន័យធរ កុំគប្បីលើកអាបត្តិឡើងពិន័យភ្លាម, គប្បីពិចារណាថា ភណ្ឌ:នោះមានម្ចាស់ឬមិនមានម្ចាស់ ។ សូម្បីក្នុងភណ្ឌ:ដែលមានម្ចាស់ ក៏គប្បីពិចារណាថា ម្ចាស់នៅមានអាល័យ ឬមិនមានអាល័យហើយ ។ បើភិក្ខុលួចក្នុងវេលាដែលម្ចាស់ទាំងនោះ នៅមានអាល័យ ព្រះវិន័យធរ គប្បីវាយតម្លៃពិន័យអាបត្តិ ។ បើលួចក្នុងវេលាដែលម្ចាស់មិនមានអាល័យ មិនគប្បីពិន័យអាបត្តិបារាជិក ។ តែកាលម្ចាស់ភណ្ឌ:ឱ្យនាំភណ្ឌ:មកសង គប្បីឱ្យភណ្ឌ:គេវិញ ។ យ៉ាងនេះជាការប្រពៃក្នុងរឿងនេះ ។

# រឿងភិក្ខុលួចចីវរ មិនជាអាបត្តិ

ក៏ដើម្បីសម្តែងសេចក្តីនេះ គួរនាំរឿងមកសាធកដូចតទៅនេះ ៖

បានឮថា ក្នុងរជ្ជកាលនៃព្រះបាទភាតិយរាជ មានភិក្ខុមួយរូបពាក់សំពត់កាសាវៈពណ៌លឿងប្រវែង ៧ ហត្ថ ទុកលើស្មាហើយចូលទៅកាន់លានព្រះចេតិយអំពីទិសទក្សិណ ដើម្បីបូជាព្រះមហាចេតិយ ។ ខណៈនោះឯង សូម្បីព្រះរាជាក៏ស្តេចមកដើម្បីថ្វាយបង្គំព្រះចេតិយ ។ វេលានោះ កាលកំពុងកៀរប្រមូលពួកជនទៅ ភាពច្រួលច្របល់នៃមហាជន ក៏បានមានឡើងហើយ ។

គ្រានោះឯង ភិក្ខុនោះ ត្រូវសភាពច្រួលច្របល់នៃមហាជនរុកកួនហើយ មើលមិនទាន់នូវសំពត់កាសាវៈ ដែលរបូតធ្លាក់ទៅអំពីស្មាឡើយក៏បានដើរចេញទៅ ។ ក៏ឯគ្រាដើរចេញទៅហើយ កាលមិនឃើញសំពត់កាសាវៈ ក៏ដាក់ធុរៈថា "អ្នកណា នឹងរកសំពត់កាសាវៈបានក្នុងកាលពួកជនច្រួលច្របល់បែបនេះ, ឥឡូវនេះ សំពត់កាសាវៈនោះ មិនមែនរបស់យើង" ដូច្នេះហើយក៏ដើរចេញទៅ ។ គ្រានោះ មានភិក្ខុដទៃដើរមកខាងក្រោយ បានឃើញសំពត់កាសាវៈនោះហើយក៏កាន់យកដោយថេយ្យចិត្តតែត្រឡប់មានសេចក្តីក្តៅក្រហាយ, កាលកើតសេចក្តីគិតឡើងថា "ឥឡូវនេះ យើងមិនជាសមណៈ, យើងនឹងសឹក" ហើយទើបគិតថា "នឹងសួរ

ព្រះវិន័យធរទាំងឡាយមើលសិន ទើបដឹងបាន", ក៏ដោយសម័យនោះ មានភិក្ខុដែលទ្រទ្រង់ព្រះបរិយត្តិទាំងពួង ឈ្មោះចូឡសុមនត្ថេរជាបាមោក្ខាចារ្យផ្នែកព្រះវិន័យ ស្នាក់នៅក្នុងមហាវិហារ ។ ភិក្ខុនោះចូលទៅរកព្រះថេរៈហើយថ្វាយបង្គំ សូមឱកាសហើយ ទើបបានទូលសួរនូវសេចក្តីសង្ស័យរបស់ខ្លួន ។ ព្រះថេរៈជ្រាបសេចក្តីនៃសំពត់កាសាវៈ ដែលភិក្ខុមកខាងក្រោយនោះកាន់យកក្នុងកាលពួកជនបែកគ្នាទៅហើយ គិតថា "គ្រានេះ ក៏មានឱកាសក្នុងការបានសំពត់កាសាវៈនេះ" ទើបបានពោលថា "បើលោកគប្បីនាំភិក្ខុម្ចាស់សំពត់កាសាវៈមកបានសោត; ខ្ញុំព្រះករុណាអាចធ្វើទីពឹងឱ្យដល់លោកបាន" ។ ភិក្ខុនោះឆ្លើយប្រាប់ថា "បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណានឹងឃើញលោកនោះបានយ៉ាងណា ?" ព្រះថេរៈបង្គាប់ថា "បើដូច្នោះ លោកចូរវាស់សំពត់កាសាវៈទាំងខាងបណ្តោយនិងខាងទទឹងហើយរក្សាទុក លុះរក្សាហើយចូរគន់រកមើលតាមលំដាប់វិហារខាងទិសទក្សិណ ហើយនាំភិក្ខុនោះមក" ។ លោករូបនោះ ធ្វើតាមពាក្យបង្គាប់នោះហើយ ក៏បានជួបភិក្ខុនោះ ហើយបាននាំមកកាន់សំណាក់ព្រះថេរៈ ។ ព្រះថេរៈសួរថា "នេះសំពត់កាសាវៈរបស់លោកឬ ?" ភិក្ខុម្ចាស់សំពត់ឆ្លើយប្រាប់ថា "មែនហើយលោកម្ចាស់" ព្រះថេរៈសួរថា "លោកធ្វើឱ្យធ្លាក់ក្នុងទីណា" ។ លោករូបនោះក៏ទូលប្រាប់រឿងទាំងអស់ហើយ ។ ព្រះថេរៈបានស្តាប់ការដាក់ធុរៈដែលលោកនោះធ្វើហើយ ទើប

សួរភិក្ខុដែលកាន់យកសំពត់ក្រៅនេះថា "លោកបានឃើញសំពត់ផ្ទាំងនេះទីណា ទើបបានកាន់យក ?"

សូម្បីភិក្ខុនោះ ក៏ទូលប្រាប់រឿងទាំងអស់ ។ តពីនោះ ទើបព្រះថេរៈពោលនឹងភិក្ខុដែលកាន់យកសំពត់នោះថា "បើលោកបានកាន់យកដោយចិត្តបរិសុទ្ធិហើយ, លោកក៏មិនគប្បីជាអាបត្តិឡើយ, តែព្រោះកាន់យកដោយថេយ្យចិត្ត ទើបលោកត្រូវអាបត្តិទុក្កដ, កាលលោកសម្តែងអាបត្តិទុក្កដនោះហើយ នឹងជាអ្នកមិនមានអាបត្តិ ។ មួយទៀត លោកចូរធ្វើសំពត់កាសាវៈផ្ទាំងនេះឱ្យជារបស់ខ្លួន ហើយប្រគេនដល់ភិក្ខុនោះវិញចុះ" ។ ភិក្ខុនោះបានប្រសព្វសេចក្តីស្រោលចិត្តជាយ៉ាងក្រៃលែង ដូចគ្នានឹងបានស្រោចដោយទឹកអម្រឹត ដូច្នោះ ។ ព្រះវិន័យធរគប្បីមិលមើលដល់វត្ថុយ៉ាងនេះ ។

ឋានៈថា **កាល** គឺ កាលដែលលួច ។ ដោយថា ភណ្ឌៈនោះ ៗ ពេលខ្លះមានតម្លៃល្មមសមគួរ ពេលខ្លះមានតម្លៃថ្លៃ ។ ព្រោះដូច្នោះ ភណ្ឌៈនោះ ព្រះវិន័យធរគប្បីពិន័យអាបត្តិតាមតម្លៃរបស់ក្នុងកាលដែលភិក្ខុលួច ។ គប្បីរមិលមើលដល់កាលយ៉ាងនេះ ។

ឋានៈថា **ប្រទេស** គឺ ប្រទេសដែលលួច ។ ក៏ភណ្ឌៈនោះ ភិក្ខុលួចក្នុងប្រទេសណា, ព្រះវិន័យធរគប្បីពិន័យអាបត្តិតាមតម្លៃរបស់ក្នុងប្រទេសនោះឯង ។ ដោយថា ក្នុងប្រទេសជាទីកើតរបស់ភណ្ឌៈ ភណ្ឌៈ

រមែងមានតម្លៃល្មមសមគួរ ក្នុងប្រទេសដទៃ រមែងមានតម្លៃថ្លៃ ។

ក៏ដើម្បីសម្តែងសេចក្តីសូម្បីនេះ គួរសាធករឿងដូចតទៅនេះ ៖

បានឮថា ក្នុងប្រទេសក្បែរឆ្នេរសមុទ្រ មានភិក្ខុមួយរូប បានផ្លែដូងមានសណ្ឋានល្អ ទើបបានក្រឡឹងធ្វើជាផ្តិលទឹក ដែលគួរពេញចិត្តដូចនឹងសំបកស័ង្ខ ហើយដាក់ទុកត្រង់ប្រទេសនោះឯង ទើបបានទៅកាន់ចេតិយគិរីវិហារ ។ គ្រានោះ មានភិក្ខុដទៃបានទៅកាន់ទីឆ្នេរសមុទ្រសម្រាកត្រង់វិហារនោះ ល្មមឃើញផ្តិលត្រឡោកនោះ ទើបបានកាន់យកដោយថេយ្យចិត្ត ហើយក៏មកកាន់ចេតិយគិរីវិហារនុ៎ះឯង ។ កាលលោករូបនោះឆាន់បបរយាគូនៅត្រង់ចេតយគិរីវិហារនោះ ភិក្ខុម្ចាស់ផ្តិលត្រឡោក បានឃើញផ្តិលត្រឡោកនោះ ទើបចូលទៅពោលថា "អាវុសោបានផ្តិលត្រឡោកនេះមកពីណា ?" ភិក្ខុដែលកាន់មកនោះឆ្លើយថា "ខ្ញុំព្រះករុណានាំមកពីទីមាត់សមុទ្រ" ។ ភិក្ខុម្ចាស់ផ្តិលត្រឡោកនោះ ពោលថា "ផ្តិលត្រឡោកនេះ មិនមែនរបស់អាវុសោ ; អាវុសោកាន់យកដោយភាពជាចោរ" ដូច្នេះហើយ ទើបបានទាញទៅកាន់ទីកណ្តាលសង្ឃ ។ ក្នុងចេតិយគិរីវិហារនោះ ភិក្ខុទាំងឡាយ ក៏មិនបានទទួលសេចក្តីជាក់ច្បាស់ ទើបបាននាំគ្នាត្រឡប់មកកាន់មហាវិហារ ។ លោកទាំងឡាយឱ្យវាយស្គរប្រកាសក្នុងមហាវិហារ ហើយធ្វើការប្រជុំជិត

មហាចេតិយចាប់ផ្ដើមវិនិច្ឆ័យ ។ ព្រះថេរៈអ្នកទ្រទ្រង់វិន័យទាំងឡាយ ក៏បានបញ្ញត្តិអវហារទុកហើយ ។

ក៏ឯភិក្ខុដែលឆ្លាតក្នុងព្រះវិន័យ ឈ្មោះអាភិធម្មិកគោទត្តត្ថេរ ក៏មាននៅក្នុងសន្និបាតនោះផង ។ ព្រះថេរៈនោះ ពោលយ៉ាងនេះថា "ភិក្ខុនេះលួចផ្តិលត្រឡោកនេះក្នុងទីណា ?" ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា "លោកលួចនៅក្នុងប្រទេសក្បែរមាត់សមុទ្រ" ។ ព្រះថេរៈសួរថា "ទីប្រទេសនោះ ផ្តិលត្រឡោកនេះ មានតម្លៃប៉ុន្មាន ?" ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា "មិនមានតម្លៃអ្វីទេ" ។

ព្រះថេរៈពោលថា "ពិតហើយ ទីប្រទេសនោះ ពួកប្រជាជនពុះដូងស៊ីសាច់ខាងក្នុងហើយក៏ចោលលលា, ក៏លលានោះសម្រេចប្រយោជន៍ជាឧស (ប៉ុណ្ណោះ)" ។ ព្រះថេរៈសួរតទៅថា "ហត្ថកម្មក្នុងផ្តិលត្រឡោកនេះ របស់ភិក្ខុនេះ មានតម្លៃប៉ុន្មាន ?" ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា "មានតម្លៃមួយមាសក ឬតិចជាងមួយមាសក" ។

ព្រះថេរៈសួរថា "ក៏មានក្នុងទីណាខ្លះ ដែលព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តិបារាជិកទុក ព្រោះតម្លៃមួយមាសក ឬតិចជាងមួយមាសកដែរទេ ?" កាលព្រះថេរៈពោលយ៉ាងនេះហើយ ក៏បានសាធុការព្រមគ្នាថា "ល្អណាស់ ៗ លោកម្ចាស់ពោលប្រពៃហើយ វិនិច្ឆ័យត្រឹមត្រូវល្អ

ហើយ" ។ ក៏គ្រានោះ សូម្បីព្រះបាទភាតិយរាជ ក៏ស្ដេចចេញចាកព្រះនគរដើម្បីថ្វាយបង្គំព្រះចេតិយ បានស្ដាប់សំឡេងនោះ ទើបត្រាស់សួរថា "នេះរឿងអ្វី" កាលបានស្ដាប់រឿងទាំងអស់តាមលំដាប់ហើយ ទើបទ្រង់ត្រាស់ឱ្យត្រាច់វាយស្គរប្រកាសក្នុងព្រះនគរថា "កាលយើងនៅមានជីវិត អធិករណ៍របស់ពួកភិក្ខុខ្លះ ពួកភិក្ខុនីខ្លះ ពួកគ្រហស្ថខ្លះ ដែលព្រះអាភិធម្មិកគោទត្តត្ថេរកាត់ក្ដីហើយ ជាការវិនិច្ឆ័យក្ដីដ៏យ៉ាងល្អត្រឹមត្រូវ យើងនឹងដាក់រាជអាជ្ញា ដល់អ្នកដែលមិនតាំងនៅក្នុងពាក្យកាត់ក្ដីរបស់លោកម្ចាស់" ។ គប្បីរមិលមើលដល់ប្រទេសយ៉ាងនេះ ។

## ព្រះវិន័យធរគួរមើលតម្លៃ និងការប្រើប្រាស់

បាទៈថា **តម្លៃ** គឺ តម្លៃរបស់ ។ ដោយថា ភណ្ឌៈថ្មី រមែងមានតម្លៃថ្លៃ, ខាងក្រោយ តម្លៃរមែងថយចុះបាន ។ ដូចបាត្រដែលដុតថ្មី រមែងមានតម្លៃគ្រប់ ៨ ឬ ១០ កហាបណៈ, ខាងក្រោយ បាត្រនោះមានប្រហោងធ្លុះ ឬត្រូវបោះនិងចំណងថ្នេរ រមែងមានតម្លៃតិច ដូច្នោះ ។ ព្រោះដូច្នោះ ព្រះវិន័យធរមិនគប្បីវាយតម្លៃដោយតម្លៃតាមប្រក្រតីស្មើទៅតែម្ដងទេ ។ គប្បីរមិលមើលដល់តម្លៃយ៉ាងនេះ ។

បាទៈថា **ការប្រើប្រាស់** គឺ ការប្រើប្រាស់ភណ្ឌៈ ។ ដោយថា

តម្លៃរបស់ភណ្ឌៈមានកាំបិតជាដើម សូម្បីតម្លៃរមែងថយចុះព្រោះការប្រើប្រាស់ ។ ព្រោះដូច្នោះ ព្រះវិន័យធរគួរពិចារណាយ៉ាងនេះ; គឺ បើភិក្ខុខ្លះលួចកាំបិតរបស់អ្នកណា ៗ មក ដែលមានតម្លៃបានមួយបាទ, បណ្ដាម្ចាស់របស់និងអ្នកមិនមែនម្ចាស់របស់កាំបិតទាំងនោះ ព្រះវិន័យធរគប្បីសួរម្ចាស់កាំបិតថា លោកទិញកាំបិតនេះមកដោយតម្លៃប៉ុន្មាន ? ម្ចាស់កាំបិត ឆ្លើយប្រាប់ថា "តម្លៃមួយបាទ លោកម្ចាស់" ។ ព្រះវិន័យធរសួរថា ក៏លោកទិញមកហើយរក្សាទុក ឬប្រើកាំបិតខ្លះ ។ បើម្ចាស់កាំបិតឆ្លើយប្រាប់ថា "ខ្ញុំព្រះករុណាប្រើកាត់ឈើស្ងន់ខ្លះ កាត់កំណាត់ឈើទឹកជ្រលក់ខ្លះ ឧសដុតបាត្រខ្លះ" ដូច្នេះសោត គ្រានោះ ព្រះវិន័យធរគប្បីជ្រាបថា តម្លៃដើមពីមុនរបស់កាំបិតនោះធ្លាក់ទៅហើយ កាំបិត រមែងមានតម្លៃធ្លាក់ទៅ យ៉ាងណា, ថ្នាំបន្តក់ភ្នែកក្ដី ឈើចង្កឹះថ្នាំបន្តក់ភ្នែកក្ដី កូនសោក្ដី រមែងមានតម្លៃធ្លាក់ទៅ ដូច្នោះ, សូម្បីព្រោះហេតុត្រឹមតែដុសខាត់ធ្វើឱ្យស្អាតដោយស្លឹកឈើ អង្កាម ឬដោយថ្មសំលៀងត្រឹមតែម្ដង ។ ដុំសំណ រមែងមានតម្លៃធ្លាក់ទៅព្រោះការកាត់ដោយធ្មេញមង្ករខ្លះ ព្រោះត្រឹមតែការដុសខាត់ខ្លះ, សំពត់ងូតទឹក រមែងមានតម្លៃធ្លាក់ទៅព្រោះការស្លៀកដណ្ដប់ត្រឹមតែម្ដងខ្លះ ព្រោះត្រឹមតែពាក់ទុកលើស្មាខ្លះ ឬលើសីសៈ ដោយប្រាថ្នាដល់ការប្រើប្រាស់ខ្លះ, វត្ថុទាំងឡាយមានអង្ករជា

ដើម រមែងមានតម្លៃធ្លាក់ចុះទៅ ព្រោះការអុំខ្លះ ព្រោះការរើសម្ពងមួយគ្រាប់ឬពីរគ្រាប់ចេញពីអង្ករជាដើមនោះខ្លះ ដោយហោចទៅ ព្រោះការរើសដុំថ្មនិងដុំគ្រួសចោលម្តងមួយដុំខ្លះ, វត្ថុទាំងឡាយមានទឹកដោះថ្លានិងប្រេងជាដើម រមែងមានតម្លៃធ្លាក់ទៅព្រោះការផ្លាស់ភាជនៈដទៃខ្លះ ដោយហោចទៅ ព្រោះត្រឹមតែរើសរុយ ឬស្រមោចក្រហមចោលចេញពីទឹកដោះថ្លាជាដើមនោះខ្លះ, ដុំស្ករអំពៅ រមែងមានតម្លៃធ្លាក់ទៅ សូម្បីព្រោះត្រឹមតែយកក្រចកចោះមើល ដើម្បីដឹងសេចក្តីមានរសផ្អែម ហើយកាន់យកតែបន្តិច ។ ព្រោះដូច្នោះ វត្ថុប្រភេទណាមួយ ដែលមានតម្លៃគ្រប់ ១ បាទ ដែលម្ចាស់របស់ធ្វើឱ្យមានតម្លៃចុះថយទៅ ព្រោះការប្រើប្រាស់ដោយន័យដូចដែលពោលហើយនុ៎ះឯង ព្រះវិន័យធរ មិនគួរពិន័យភិក្ខុដែលលួចភណ្ឌៈនោះដល់បារាជិក ។ គប្បីរមិលមើលដល់ការប្រើប្រាស់យ៉ាងនេះ ។

ព្រះវិន័យធរអ្នកឆ្លាត គប្បីសង្កេតពិនិត្យឋានៈ ៥ ទាំងនេះ យ៉ាងនេះហើយគប្បីទ្រង់ទុកនូវអត្ថក្តី គឺ គប្បីតាំងទុកនូវអាបត្តិឬអនាបត្តិ គរុកាបត្តិឬលហុបត្តិ ក្នុងស្ថានដែលគួរនុ៎ះឯង ។

វិនិច្ឆ័យបទទាំងនេះ គឺ បន្ទំ នាំយក លួច ឱ្យឥរិយាបថកម្រើក ឱ្យឃ្លាតចាកឋាន ឱ្យកន្លងហួសខេត្តកំណត់ចំណាំ ចប់ហើយ ។

# អត្ថាធិប្បាយទ្រព្យដែលគួរដល់ទុតិយបារាជិក

[៨៧] ឥឡូវនេះ ព្រះមានព្រះភាគ កាលទឹងទ្រង់ចែកបទមានពាក្យថា យថារូបេ អធិដ្ឋានេ : ព្រោះអទិន្នាទាន មានសភាពយ៉ាងណា ជាដើម ទើបត្រាស់ពាក្យថា យថារូបំ ឆាម : ដែលឈ្មោះថាមានសភាពយ៉ាងណា ជាដើមនេះ ។ ទឹងវិនិច្ឆ័យក្នុងពាក្យថា យថារូបំ ជាដើមនោះ ៖

ទ្រព្យមានតាមកំណើត ឈ្មោះថា ទ្រព្យមានសភាពបែបណា ។ ក៏ទ្រព្យមានតាមកំណើតនោះ រមែងមានតាំងពីមួយបាទឡើងទៅ; ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មួយបាទក្តី គួរដល់មួយបាទក្តី លើសជាងមួយបាទក្តី ។ ក្នុងស័ព្ទថា បាទជាដើមនោះ ព្រះមានព្រះភាគទ្រង់សម្តែងចំពោះអកប្បិយភណ្ឌៈ ប៉ុនចំណែកទី ៤ នៃកហាបណៈ ដោយបាទស័ព្ទ ទ្រង់សម្តែងកប្បិយភណ្ឌៈ បានតម្លៃមួយបាទ ដោយបាទារហស័ព្ទ ទ្រង់សម្តែង កប្បិយភណ្ឌៈ និងអកប្បិយភណ្ឌៈ សូម្បីទាំងពីរយ៉ាង ដោយអតិរេកបាទស័ព្ទ ។ វត្ថុល្មមដល់ទុតិយបារាជិកជាការដែលទ្រង់សម្តែងហើយ ដោយអាការទាំងពួង ដោយស័ព្ទត្រឹមតែប៉ុណ្ណោះ ។ ព្រះរាជានៃផែនដីទាំងអស់, គឺ ជាចក្រពត្តិក្នុងទ្វីបដូចព្រះបាទអសោក ឈ្មោះព្រះរាជាទូទាំងផែនដី ឬថា អ្នកណាសូម្បីដទៃ ដែល

ជាព្រះរាជាក្នុងទ្វីបណានីមួយ ដូចព្រះរាជាសីហឡ អ្នកនោះ ក៏ឈ្មោះថា ព្រះរាជាទូទៅទាំងផែនដី ។

ព្រះរាជាអ្នកជាធំចំពោះប្រទេសនៃទ្វីបណានីមួយ ដូចព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិជាដើម ឈ្មោះថា ព្រះរាជាចំពោះប្រទេស ។ ជនពួកណា គ្រប់គ្រងមណ្ឌលនីមួយ ៗ សូម្បីក្នុងប្រទេសនៃទ្វីបជនទាំងនោះ ឈ្មោះថា អ្នកគ្រប់គ្រងមណ្ឌល ។

ម្ចាស់របស់តំបន់តូច ៗ ក្នុងចន្លោះនៃព្រះរាជាពីរព្រះអង្គ ឈ្មោះថា អ្នកគ្រប់គ្រងចន្លោះដែន ។ អាមាត្រអ្នកវិនិច្ឆ័យក្តី ឈ្មោះថា អ្នកពិភាក្សា ។ អ្នកពិភាក្សាទាំងនោះ អង្គុយក្នុងសាលាធម្មសភា ពិភាក្សាទោសមានកាត់ដៃ និងជើងរបស់ពួកចោរជាដើម តាមសមគួរដល់កំហុស ។ ចំណែកជនពួកណាមានឋានន្តរជាអមាត្យឬរាជបុត្រ ជាអ្នកធ្វើខុស, អ្នកពិភាក្សា រមែងក្រាបទូលជនទាំងនោះដល់ព្រះរាជាមិនបានវិនិច្ឆ័យក្តីដែលធ្ងន់ដោយខ្លួនឯងទេ ។ អាមាត្រអ្នកធំដែលបានឋានន្តរឈ្មោះថា មហាអាមាត្យ ។ សូម្បីមហាអាមាត្រទាំងនោះ រមែងអង្គុយធ្វើរាជកិច្ច ក្នុងស្រុក ឬក្នុងនិគមនោះ ៗ ។

ដោយបទថា យេ វា បន : ពុំនោះសោ ពួកឥស្សរជនណា (នេះ) ព្រះមានព្រះភាគទ្រង់សម្តែងថា ជនពួកណាសូម្បីដទៃ ជាអ្នក

អាស្រ័យរាជត្រកូល ឬអាស្រ័យភាពជាធំរបស់ខ្លួនឯង រមែងបង្គាប់បញ្ជាបានដាច់ខាត, ជនទាំងអស់នោះ ចាត់ជាព្រះរាជាក្នុងអត្ថនេះ (៨៨) ។

បទថា **ហនេយ្យុំ** : គប្បីសម្លាប់ បានដល់ គប្បីវាយនិងគប្បីកាត់ ។

បទថា **បព្វាជេយ្យុំ** : គប្បីបំបរបង់ បានដល់ គប្បីនិរទេសចេញ ។ គប្បីជេរប្រទេចយ៉ាងនេះថា ឯងជាចោរ ដូច្នេះជាដើម ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគទើបត្រាស់ថា នោះជាការជេរ ។

[៨៩] ពីរបទថា **បុរិមំ ឧបាទាយ** : ប្រៀបធៀបនឹងភិក្ខុដែលមានក្នុងសិក្ខាបទមុន មានសេចក្ដីថា សម្ដីងដល់បុគ្គលអ្នកសេពមេថុនធម្ម ត្រូវអាបត្តិបារាជិក ។ ពាក្យដ៏សេសរាប់ថា ច្បាស់លាស់ហើយទាំងនោះ ព្រោះមានន័យដូចពោលហើយក្នុងខាងដើម និងព្រោះមានសេចក្ដីចំពោះបទងាយ ៗ ដូច្នេះឯង ។

[៩០] ព្រះមានព្រះភាគ គ្រាទ្រង់ចែកសិក្ខាបទដែលទ្រង់ឧទ្ទេសហើយ តាមលំដាប់បទយ៉ាងនោះហើយ ឥឡូវនេះ ទើបទ្រង់តាំងមាតិកាដោយន័យជាដើមថា **ភុម្មដ្ឋំ ថលដ្ឋំ** : ទ្រព្យស្ថិតនៅក្នុងដី ស្ថិតនៅលើគោក ហើយត្រាស់វិភង្គនៃបទភាជនីនោះ ដោយន័យមានពាក្យថា **ភុម្មដ្ឋំ នាម ភណ្ឌំ ភូមិយំ និក្ខិត្តំ ហោតិ** : ដែលឈ្មោះថា ទ្រព្យស្ថិតនៅ

ក្នុងដី គឺ ទ្រព្យដែលគេកប់លាក់ទុកក្នុងដី ជាដើម ដើម្បីសម្ដែងភណ្ឌៈ ដែលទីងគប្បីកាន់យក ដែលព្រះអដ្ឋកថាទ្រង់សម្ដែងការកាន់យកដោយសង្ខេប ដោយ ៦ បទ មានបទថា អាទិយេយ្យ ជាដើមហើយ ទ្រង់សម្ដែងដោយសង្ខេបដូចគ្នាថា "ទ្រព្យចំនួនមួយបាទ ឬទ្រព្យគួរដល់តម្លៃមួយបាទ ឬក្រៃលែងជាងមួយបាទឡើងទៅ" ដោយពិស្ដារ ដោយអាការដែលភណ្ឌៈនោះតាំងនៅក្នុងទីណា ៗ ទើបដល់សេចក្ដីកាន់យកបាន ដើម្បីបិទឱកាសនៃលេសរបស់បាបភិក្ខុទាំងឡាយក្នុងអនាគត ។

[៩១] វិនិច្ឆ័យកថា ព្រមដោយវណ្ណនាបទដែលមិនទាន់យល់ក្នុងពាក្យថា **និក្ខិត្តំ** ជាដើមនោះ គប្បីជ្រាបដូច្នេះ ៖

បទថា **និក្ខិត្តំ** : **កប់** បានដល់ ដែលកប់រក្សាទុកក្នុងផែនដី ។

បទថា **បដិច្ឆន្នំ** : **លាក់ទុក** បានដល់ ដែលគេបិទបាំងទុកដោយវត្ថុមានដីនិងឥដ្ឋជាដើម ។

ពាក្យថា **ភុម្មដ្ឋំ ភណ្ឌំ ។បេ។ គច្ឆតិ វា អាបត្តិ ទុក្កដស្ស** : ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចនូវទ្រព្យដែលស្ថិតនៅក្នុងដី ហើយស្វែងរកគ្នាឱ្យបានពីរនាក់ក្ដី ស្វែងរកចបក្ដី កញ្ច្រែក្ដី ដើរទៅតែម្នាក់ឯងក្ដី ត្រូវអាបត្តិទុក្កដ មានសេចក្ដីថា ភណ្ឌៈនោះ ដែលឈ្មោះថា តាំងនៅក្នុងផែនដី ព្រោះជារបស់ដែលគេកប់ ឬបិទបាំងតាំងទុកយ៉ាងនោះ ភិក្ខុណា

ជីវដោយឧបាយយ៉ាងណាមួយនោះ ជាអ្នកមានថេយ្យចិត្តថា យើងនឹងលួច ហើយក្រោកឡើងទៅក្នុងវេលារាត្រី ។ ភិក្ខុនោះ សូម្បីទៅមិនដល់ទីនៃភណ្ឌៈ រមែងត្រូវទុក្កដ ព្រោះកាយវិការ និងវចីវិការទាំងពួង ។

## អត្ថាធិប្បាយអាបត្តិដែលជាបុព្វបយោគ

សួរថា តើត្រូវយ៉ាងណា ?

ឆ្លើយថា ត្រូវយ៉ាងនេះ គឺ ៖

ពិតមែន ភិក្ខុនោះកាលក្រោកឡើង ដើម្បីត្រូវការនឹងលួចទ្រព្យនោះ ឱ្យអវយវៈតូចធំណា ៗ កម្រើកញ័រ រមែងត្រូវអាបត្តិទុក្កដ ព្រោះអវយវៈកម្រើកគ្រប់គ្រាទៅ រៀបចំសំពត់ស្បៀកនិងសំពត់ដណ្ដប់ ក៏ត្រូវទុក្កដគ្រប់ ៗ គ្រាដែលដៃកម្រើក ។ លោកតែមួយរូបមិនអាចនាំទ្រព្យដែលកប់ទុក ដែលមានចំនួនច្រើនចេញទៅបាន ទើបគិតថា យើងនឹងស្វែងរកសម្លាញ់ ដូច្នេះ ហើយដើរទៅកាន់សំណាក់របស់សម្លាញ់រូបខ្លះ ទើបបើកទ្វារ ក៏ត្រូវទុក្កដគ្រប់ជំហាន និងគ្រប់វារៈ ដែលដៃកម្រើក តែមិនជាអាបត្តិព្រោះបិទទ្វារ ឬព្រោះកាយកម្មនិងវចីកម្មយ៉ាងដទៃ ដែលមិនឧបត្ថម្ភដល់ការទៅ ។ លោកដើរទៅកាន់ឱកាស ដែលភិក្ខុនោះដេក ហើយហៅភិក្ខុនោះថា “លោកដែលមានឈ្មោះ....នេះ” បញ្ជាក់ប្រាប់នូវសេចក្ដីប្រាថ្នានោះឱ្យជ្រាប ទើបពោលបបួលថា “មកលោកទៅជាមួយគ្នា

ចុះ”, រមែងត្រូវទុក្កដគ្រប់ ៗ ពាក្យនិយាយ ។ ភិក្ខុនោះ ក្រោកឡើងតាមពាក្យបបួលរបស់លោក, សូម្បីលោករូបនោះ ក៏ជាទុក្កដ ។ កាលលោកក្រោកឡើងហើយ ប្រាថ្នានឹងដើរទៅកាន់សំណាក់របស់ភិក្ខុ( ដើមគំនិត )នោះ រៀបចំសំពត់ស្លៀកនិងសំពត់ដណ្ដប់ បិទទ្វារហើយដើរទៅជិតភិក្ខុ( ដើមគំនិត )នោះ ក៏ត្រូវទុក្កដ ព្រោះដែលចាប់និងជំហានគ្រប់ ៗ គ្រាទៅ ។ លោកនោះសួរភិក្ខុដើមគំនិតនោះថា “ភិក្ខុឈ្មោះឯណោះនិងឯណោះនៅទីណា ? លោកចូរហៅភិក្ខុឈ្មោះឯណោះ និងឯណោះមកចុះ” ដូច្នេះ ត្រូវទុក្កដគ្រប់ពាក្យនិយាយ ។ លុះឃើញគ្រប់រូបមកព្រមគ្នាហើយ ក៏ពោលបបួលថា “ខ្ញុំព្រះករុណាជួបរណ្ដៅទ្រព្យបែបនេះ នៅក្នុងស្ថានទីឈ្មោះឯណោះ, ចូរមកពួកយើងទៅយកទ្រព្យនោះ ហើយនឹងបំពេញបុណ្យ ហើយនឹងរស់នៅយ៉ាងសប្បាយ” ដូច្នេះ, ក៏ត្រូវទុក្កដគ្រប់ពាក្យនិយាយតែម្ដង ។ លោកបានសម្លាញ់យ៉ាងនោះហើយ ទើបស្វែងរកចប ក៏បើលោករូបនោះ មានចបសម្រាប់ខ្លួននៅសោត, ទើបពោលថា យើងនឹងនាំចបនោះមក ខណៈដើរទៅកាន់យកនិងនាំមករមែងត្រូវទុក្កដ ព្រោះដៃចាប់និងជំហានគ្រប់គ្រាទៅ ។ បើចបមិនមានក៏ទៅសូមភិក្ខុឬគ្រហស្ថអ្នកដទៃ និងកាលសូម នឹងនិយាយកុហកសូមថា “ចូរឱ្យចបដល់ខ្ញុំព្រះករុណា, ខ្ញុំព្រះករុណាត្រូវការចប, ខ្ញុំព្រះករុណាមាន

កិច្ចអ្វី ៗ ដែលនិងត្រូវធ្វើ, ធ្វើកិច្ចនោះសម្រេចហើយនឹងនាំមកឱ្យវិញ” ដូច្នេះ ត្រូវទុក្កដគ្រប់ពាក្យនិយាយ ។ បើមានប្រឡាយដែលនិងត្រូវជម្រះឱ្យស្អាតនៅសោត, លោកនឹងនិយាយសូម្បីពាក្យកុហកថា “ការងារដីក្នុងវត្តដែលនិងត្រូវធ្វើមាន”, ពាក្យនិយាយណា ៗ ដែលជាពាក្យកុហក, រមែងជាបាចិត្តិយ ព្រោះពាក្យនិយាយនោះ ៗ ។ តែក្នុងមហាអដ្ឋកថាលោកពិន័យទុក្កដ (ក្នុងពាក្យនិយាយ)ទាំងអស់នោះ ទាំងពាក្យពិតទាំងពាក្យកុហកនោះឯង ។ ពាក្យដែលពោលទុកក្នុងមហាអដ្ឋកថានោះ គប្បីជ្រាបថា សរសេរទុកដោយសេចក្ដីភ្លាំងភ្លាត់ ។ ដែលឈ្មោះថា ទុក្កដក្នុងឋាននៃបាចិត្តិយ ដែលជាបុព្វបយោគនៃអទិន្នាទាន មិនមានឡើយ ។ ក៏បើចបមិនមានដង, ភិក្ខុនិយាយថា នឹងធ្វើដង ហើយសំលៀងកាំបិតឬពូថៅ ចេញដើរទៅដើម្បីត្រូវការឈើដងចបនោះ, កាលទៅហើយក៏កាត់ឈើស្ងួត ចាំងឈូស រមែងត្រូវទុក្កដ ព្រោះដៃចាប់ និងគ្រប់ជំហានទៅ ។ លោកកាត់ឈើដែលនៅស្រស់ ត្រូវបាចិត្តិយ ។ បន្ទាប់អំពីនោះទៅក៏ត្រូវទុក្កដគ្រប់ប្រយោគ ។ តែក្នុងសង្ខេបអដ្ឋកថា និងមហាបច្ចរីលោកពិន័យទុក្កដទុកសូម្បីដល់ពួកភិក្ខុដែលស្វែងរកកាំបិត និងពូថៅដើម្បីត្រូវការកាត់ឈើនិងវល្លិដែលកើតនៅក្នុងទីនោះ ។ លោកពោលទុកក្នុងមហាបច្ចរីថា ក៏បើភិក្ខុទាំងនោះ មានសេចក្ដីគិតយ៉ាងនេះថា “ពួក

យើងកាលសូមកាំបិត ពូថៅ និងចប នឹងមានការសង្ស័យ ពួកយើងស្វែងរកឱ្យជួបរ៉ែដែកហើយ សឹមធ្វើ ដូច្នេះហើយ ក្រោយមក ទើបដើរទៅកាន់អណ្តូងរ៉ែដែក ហើយជីកផែនដី ដើម្បីត្រូវការរ៉ែដែក ។ កាលពួកលោកជីកផែនដីដែលជាអកប្បិយ ក៏ត្រូវបាចិត្តិយព្រមទាំងទុក្កដដ៏ច្រើន ។ ដូចជាថា ក្នុងបាលីប្រទេសនេះ បាចិត្តិយព្រមទាំងទុក្កដដ៏ច្រើន រមែងកើតបាន យ៉ាងណា ក្នុងបាលីប្រទេសគ្រប់កន្លែងក៏យ៉ាងនោះ ក្នុងឋានៈនៃបាចិត្តិយ រមែងមិនរួចផុតពីទុក្កដ ។ កាលពួកលោកជីកផែនដីដែលជាកប្បិយ ក៏ជាទុក្កដដ៏ច្រើនតែម្តង ។ ក៏គ្រាកាន់យករ៉ែហើយ តពីនោះ ក៏ត្រូវទុក្កដគ្រប់ប្រយោគ ព្រោះកិរិយាដែលធ្វើគ្រប់យ៉ាង ។ សូម្បីក្នុងការស្វែងរកបង្គី ក៏ត្រូវអាបត្តិទុក្កដ ព្រោះដៃចាប់និងជំហានតាមន័យដូចដែលពោលមកហើយនុ៎ះឯង ។ ត្រូវបាចិត្តិយ ព្រោះនិយាយកុហក ។ ព្រោះមានសេចក្តីប្រាថ្នានឹងធ្វើបង្គី ត្រូវបាចិត្តិយ ព្រោះកាត់វល្លិ ពាក្យទាំងអស់ដូចពណ៌នាមកដូច្នេះ គប្បីជ្រាបដោយន័យមុននុ៎ះឯង ។

ត្រង់បទថា គច្ឆតិ វា អាបត្តិ ទុក្កដស្ស : **ដើរទៅតែម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ** មានសេចក្តីថា ភិក្ខុដែលស្វែងរកសម្លាញ់ ចបនិងកញ្ជើបានហើយយ៉ាងនោះ ដើរទៅកាន់ទីរណ្តៅទ្រព្យ រមែងត្រូវទុក្កដ

គ្រប់ជំហាន ។ ក៏បើថា កាលលោកដើរទៅ កើតកុសលចិត្តឡើងថា យើងបានរណ្ដៅទ្រព្យនេះហើយ នឹងធ្វើពុទ្ធបូជា ធម្មបូជា ឬសង្ឃភត្ត ដូច្នេះហើយ មិនជាអាបត្តិព្រោះការដើរទៅដោយកុសលចិត្ត ។

សួរថា ព្រោះហេតុអ្វី ទើបមិនជាអាបត្តិ ?

ឆ្លើយថា ព្រោះព្រះមានព្រះភាគត្រាស់ទុកហើយថា "ភិក្ខុមានថេយ្យចិត្ត ត្រាច់ស្វែងរកសម្លាញ់ក៏ដោយ ស្វែងរកចប ឬកញ្ជើក៏ដោយ ដើរទៅក៏ដោយ ត្រូវអាបត្តិទុក្កដ" ដូច្នេះ ទើបមិនជាអាបត្តិដល់ភិក្ខុដែលមិនមានថេយ្យចិត្តក្នុងទីទាំងពួង ដូចក្នុងការដើរទៅកាន់ទីរណ្ដៅទ្រព្យនេះ ដូច្នោះ ។ ភិក្ខុឆៀងចូលចេញចាកមក ហើយធ្វើមកទុកដើម្បីត្រូវការដើរទៅកាន់រណ្ដៅទ្រព្យ កាត់ភូតគាមត្រូវបាចិត្តិយ កាត់ឈើស្ងួតត្រូវទុក្កដ ។

ពីរបទថា **តត្ថ ជាតកំ : ដែលកើតនៅក្នុងទីនោះ** គឺ ដែលកើតនៅលើឆ្នាំង ដែលកប់ទុកយូរហើយ ។

ពីរបទថា **កដ្ឋំ វា លតំ វា : ឈើឬវល្លិ** សេចក្ដីថា មិនមែនកាត់ចំពោះឈើនិងវល្លិតែម្យ៉ាងប៉ុណ្ណោះទេ កាលភិក្ខុកាត់រុក្ខជាតិមានស្មៅ ដើមឈើនិងវល្លិជាដើម ប្រភេទណាមួយ ដែលនៅស្រស់ក៏ដោយ ស្ងួតក៏ដោយ ជាទុក្កដដូចគ្នា ព្រោះប្រព្រឹត្តទៅដោយសេចក្ដីព្យាយាម ។

# អាបត្តិទុក្កដ ៨ យ៉ាង

ពិតមែន ព្រះថេរៈទាំងឡាយប្រមូលឈ្មោះទុក្កដ ៨ យ៉ាងនោះមកសម្តែងទុកក្នុងទីនេះហើយ គឺ បុព្វបយោគទុក្កដ ១ សហបយោគទុក្កដ ១ អនាមាសទុក្កដ ១ ទុរុបចិណ្ណទុក្កដ ១ វិន័យទុក្កដ ១ ញាតទុក្កដ ១ ញត្តិទុក្កដ ១ បដិស្សវទុក្កដ ១ ។ បណ្តាទុក្កដ ៨ យ៉ាងនោះ ទុក្កដដែលព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា "ភិក្ខុមានថេយ្យចិត្តថា អញនឹងលួចទ្រព្យដែលស្ថិតនៅក្នុងដី ហើយស្វែងរកគ្នាឱ្យបានពីរនាក់ក្តី ស្វែងរកចបក្តី កញ្ជើក្តី ដើរទៅតែម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ"[១] នេះ ឈ្មោះថា បុព្វបយោគទុក្កដ ។ ពិតមែន ក្នុងព្រះតម្រាស់ដែលត្រាស់ទុកនេះ ក្នុងឋានៈនៃទុក្កដក៏ជាទុក្កដ ក្នុងឋានៈនៃបាចិត្តិយ ក៏ជាបាចិត្តិយដោយពិត ។

ទុក្កដដែលព្រះអង្គត្រាស់ទុកដូច្នេះថា "ភិក្ខុកាត់នូវឈើ ឬវល្លិដែលកើតក្នុងទីនោះ ត្រូវអាបត្តិទុក្កដ"[២] នេះ ឈ្មោះថា សហបយោគទុក្កដ ។ ក្នុងព្រះតម្រាស់ដែលត្រាស់ទុកនេះ វត្ថុនៃបាចិត្តិយនិងវត្ថុនៃទុក្កដ ក៏តាំងនៅក្នុងឋានៈនៃទុក្កដដូចគ្នា ។ ព្រោះហេតុអ្វី ? ព្រោះការលួចប្រព្រឹត្តទៅព្រមនឹងសេចក្តីព្យាយាម ។

---

១-២. វិន. បារា. អទិន្នាទាន. ១. ៩១/១៥៥ ។

មួយទៀត ទុក្កដ ដែលព្រះអង្គពិន័យទុកដល់ភិក្ខុដែលចាប់ត្រូវតែនះ ១០ យ៉ាង ស្រូវ ៧ យ៉ាង និងគ្រឿងសស្ត្រាវុធជាដើមទាំងអស់[១] នេះ ឈ្មោះថា អនាមាសទុក្កដ ។

ទុក្កដ ដែលព្រះអង្គពិន័យទុកដល់ភិក្ខុដែលចាប់ពាល់បណ្ដាផ្លែឈើទាំងឡាយមានចេកនិងដូងជាដើម ជាផ្លែដែលកើតក្នុងទីនោះ[២] នេះ ឈ្មោះថា ទុរុបចិណ្ណទុក្កដ ។

មួយទៀត ទុក្កដដែលព្រះអង្គពិន័យទុកដល់ភិក្ខុដែលត្រាច់បិណ្ឌបាត មិនទទួលប្រគេន ឬមិនលាងបាត្រក្នុងកាលមានកម្ទេចធូលីធ្លាក់ចុះទៅក្នុងបាត្រ ក៏ទទួលភិក្ខាក្នុងបាត្រនោះ[៣] នេះឈ្មោះថា វិន័យទុក្កដ ។

ទុក្កដដែលថា "ភិក្ខុទាំងឡាយបានឮហើយ មិនពោល ( ហាម ) ត្រូវអាបត្តិទុក្កដ"[៤] នេះ ឈ្មោះថា ញាតទុក្កដ ។

ទុក្កដដែលត្រាស់ទុកថា "( កាលសង្ឃ ) សូធ្យញត្តិចប់ ( ភិក្ខុនោះ ) ត្រូវអាបត្តិទុក្កដ" ក្នុងបណ្ដាសមនុភាសនៈ ១១ យ៉ាង[៥] នេះ ឈ្មោះថា ញត្តិទុក្កដ ។

---

១-២. អដ្ឋ. សង្ឃា. ៣. ៥៨-៦១ កាយសំសគ្គ ។ ៣. សមន្ត. បាចិ. ទន្តបោណ ។ ៤. វិន. សង្ឃា. ២. ២៩៥/២៩៩ ។ ៥. សមន្ត. បរិ. ៧. ៨៧/១៩១ : ១១ គឺ ឧក្ខិត្តានុវត្តិកា ១ សង្ឃាទិសេសរបស់ភិក្ខុនី ៨ អរិដ្ឋសិក្ខាបទ ១ ចណ្ឌកាលីសិក្ខាបទ ឬសោភាវស្សសិក្ខាបទ ១ ។

ទុក្កដដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ បុរិមិកាវស្សារបស់ភិក្ខុនោះ ក៏មិនប្រាកដផង ភិក្ខុនោះត្រូវអាបត្តិទុក្កដ ព្រោះទទួលពាក្យបេ្តជ្ញាផង”[១] នេះឈ្មោះថា បដិសសវទុក្កដ ។

ចំណែកសហាបយោគទុក្កដ (គឺ ត្រូវទុក្កដ ព្រមដោយសេចក្តីព្យាយាម) ដូចតទៅនេះ ៖

ព្រោះហេតុនោះ ខ្ញុំព្រះករុណាទើបពោលថា កាលភិក្ខុកាត់រុក្ខជាតិមានស្មៅដើមឈើនិងវល្លិជាដើមប្រភេទណាមួយ ដែលនៅស្រស់ក៏ដោយ ស្ងួតក៏ដោយ ជាទុក្កដដូចគ្នា ព្រោះមានសេចក្តីព្យាយាម ។ ក៏បើសូម្បីកាលភិក្ខុនោះ កាត់រុក្ខជាតិមានស្មៅដើមឈើ និងវល្លិជាដើម ដែលកើតឡើងក្នុងទីនោះ លជ្ជីធម៌ រមែងឈានចុះសេចក្តីសំវេគកើតឡើង លោកសម្តែងទុក្កដ ព្រោះការកាត់ជាបច្ច័យហើយ រមែងផុតបាន ។

បើលោកមិនដាក់ធុរៈ នៅមានសេចក្តីខ្វះខ្វែងជីកដីនៅតែម្តងទុក្កដ ព្រោះការកាត់ រមែងរម្ងាប់ទៅ លោករមែងតាំងនៅក្នុងទុក្កដ ព្រោះការជីក ។ ព្រោះថា ភិក្ខុសូម្បីកាលជីកផែនដីជាអកប្បិយ រមែងត្រូវទុក្កដទុំះឯង ក្នុងអធិការពោលអំពីការជីកដីនេះ ព្រោះមានសេចក្តីព្យាយាម ។ ក៏បើលោកជីកក្នុងគ្រប់ទិសសម្រេចសព្វហើយ សូម្បីដរាប

---

១. វិន. មហា. ៧. ១៧/៥៨ ។

ដល់ទីតាំងផ្ទាំងទ្រព្យ លជ្ជីធម៌ឈានចុះ លោកសម្តែងទុក្កដ ព្រោះការជីក ជាបច្ច័យចេញហើយ រមែងផុត (ពីអាបត្តិ) បាន ។

បទថា វិយូហតិ វា : កកាយក្តី មានអត្ថន័យថា ក៏បើភិក្ខុនៅមានសេចក្តីខ្វះខ្វែងនៅដូចដើម កកាយអាចម៍ដី ធ្វើជាគំនរទុកក្នុងចំណែកមួយខាង ទុក្កដព្រោះការជីក រមែងរម្ងាប់ទៅ លោករមែងតាំងនៅក្នុងទុក្កដ ព្រោះការកកាយ ។ ក៏កាលលោកធ្វើអាចម៍ដីនោះឱ្យជាគំនរទុកក្នុងទីនោះ ៗ រមែងត្រូវទុក្កដគ្រប់ ? ប្រយោគ ។ តែបើលោកធ្វើជាកងទុកហើយដាក់ធុរៈចេញ ដល់លជ្ជីធម៌ សម្តែងទុក្កដ ព្រោះការកកាយចេញហើយ រមែងផុត(ពីអាបត្តិ) បាន ។

បទថា ឧទ្ធរតិ វា : គាស់ក្តី មានអត្ថន័យថា ក៏បើភិក្ខុនៅមានសេចក្តីខ្វះខ្វែងនៅកើបអាចម៍ដីឡើងឱ្យធ្លាក់ទៅក្នុងខាងក្រៅ ទុក្កដព្រោះការកកាយ រមែងរម្ងាប់ទៅ លោករមែងតាំងនៅក្នុងទុក្កដព្រោះការកើបបារឡើង ។ ក៏កាលលោកប្រើចបក៏ដោយ ដៃទាំងពីរក៏ដោយ បង្គីក៏ដោយ បាចអាចម៍ដីឱ្យធ្លាក់ទៅក្នុងទីនោះ ៗ រមែងត្រូវទុក្កដគ្រប់ប្រយោគ ។ តែបើលោកនាំអាចម៍ដីទាំងអស់ចេញទៅហើយ ដរាបដល់ធ្វើផ្ទាំងទ្រព្យឱ្យតាំងនៅលើគោក ហើយដល់លជ្ជីធម៌ កាលសម្តែងទុក្កដព្រោះការកើបបារឡើងចេញហើយ រមែងផុត(ពីអាបត្តិ)បាន ។ តែបើ

លោកនៅមានសេចក្ដីខ្វះខ្វែងនៅនុ៎ះឯង ចាប់ប៉ះឆ្នាំងទ្រព្យ ទុក្កដព្រោះការកើបបារឡើង រមែងរម្ងាប់ទៅ លោករមែងតាំងនៅក្នុងទុក្កដ ព្រោះការចាប់ប៉ះ (ឆ្នាំង) ។

ក៏ឯគ្រាចាប់ប៉ះហើយ ហើយដល់លជ្ជីធម៌ សម្ដែងទុក្កដព្រោះការចាប់ត្រូវចេញហើយ រមែងផុត (ពីអាបត្តិ) បាន ។ បើលោកនៅមានសេចក្ដីខ្វះខ្វែងតទៅធ្វើឆ្នាំងទ្រព្យឱ្យកម្រើក ទុក្កដព្រោះការចាប់ប៉ះ រមែងរម្ងាប់ទៅ លោក រមែងតាំងនៅក្នុងថុល្លច្ច័យ ដូចដែលព្រះអង្គត្រាស់ទុកថា "ធ្វើទ្រព្យនោះឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ" ដូច្នេះ ។

## អត្ថាធិប្បាយពាក្យថា ទុក្កដនិងថុល្លច្ច័យ

ទុក្កដនិងថុល្លច្ច័យសូម្បីទាំងពីរ ដែលត្រាស់ទុកក្នុងបាលីនោះ មានសេចក្ដីចំពោះពាក្យដូចតទៅនេះ ៖

បណ្ដាទុក្កដនិងថុល្លច្ច័យទាំងពីរនេះ គប្បីជ្រាបទុក្កដទីមួយជាមុន ការធ្វើអាក្រក់ គឺ ការធ្វើឱ្យខុសពីកិច្ចដែលព្រះសាស្ដាត្រាស់ ព្រោះដូច្នោះទើបឈ្មោះថា ទុក្កដ ។ ម្យ៉ាងទៀត ដែលឈ្មោះថា ទុក្កដ ព្រោះអត្ថវិគ្រោះសូម្បីយ៉ាងនេះខ្លះថា ការធ្វើអាក្រក់ គឺ កិរិយានោះខុសរូប រមែងមិនស្អាតត្រង់កណ្ដាលនៃកិរិយារបស់ភិក្ខុ ។ ពិតមែន សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនេះទុកថា

"សិក្ខាបទណា ដែលតថាគតហៅថា ទុក្កដ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសម្តែងតទៅនេះ ។ អំពើអាក្រក់ណា ទោះខុសក្តី ផ្តាំផ្ញើក្តី ភ្ញាំងភ្ញាត់ក្តី មនុស្សធ្វើអំពើបាបណាមួយ ទោះក្នុងទីចំពោះមុខក្តី ក្នុងទីកំបាំងមុខក្តី អ្នកប្រាជ្ញទាំងឡាយ តែងហៅថា អំពើអាក្រក់ ព្រោះហេតុដូច្នោះ សិក្ខាបទនោះ តថាគតហៅថា ទុក្កដ ។"(១)

ចំណែកវិតិក្កមៈក្រៅនេះ ឈ្មោះថា ថុល្លច្ច័យ ព្រោះជាកម្មគ្រោតគ្រាត និងព្រោះភាពជាទោស ។ ក៏សេចក្តីប្រកបគ្នាក្នុងពាក្យថា ថុល្លច្ច័យនេះ អ្នកសិក្សាគួរជ្រាបដូចក្នុងពាក្យថា "សម្បរាយេ ច ទុគ្គតិ : ទុគ្គតិក្នុងបរលោកក៏មាន"២ និង "យំ ហោតិ កដុកប្ផលំ : ដែលជាអំពើមានផលក្តៅក្រហាយ"៣ជាដើម ។ ពិតមែន បណ្តាទោសដែលទឹងគប្បីសម្តែងក្នុងសំណាក់របស់ភិក្ខុមួយរូប ទោសដែលគ្រោតគ្រាតស្មើដោយថុល្លច្ច័យនោះ រមែងមិនមាន; ព្រោះហេតុនោះ ខ្ញុំព្រះករុណាទើបពោលថា ដែលឈ្មោះថា ថុល្លច្ច័យ ព្រោះជាកម្មគ្រោតគ្រាត និងព្រោះភាពជាទោស ។ ពិតមែន ពាក្យនេះ ព្រះមានព្រះភាគបានត្រាស់ហើយថា

១. វិន. បរិ. គាថាសង្គណិក. ១៣. ១២៥/១៣៨ ។ ២. ខុទ្. សុត្ត. វសលសុត្ត. ៥៤. ១៣/៤៨ ។ ៣. ខុទ្. ធម្ម. ពាលវគ្គ. ៥២. ១៥/៣៥ ។

"សិក្ខាបទណា ដែលតថាគតហៅថា ថុល្លច្ច័យ ចូរអ្នកប្រុងស្តាប់សិក្ខាបទនោះ ដូចសម្តែងតទៅនេះ ។ ភិក្ខុណាសម្តែង (អាបត្តិ) ក្នុងទីជិតនៃភិក្ខុមួយរូប ឬក៏ភិក្ខុណាទទួលអាបត្តិនោះ ទោស (ទោសរបស់ភិក្ខុអ្នកទទួល) មិនមែនមានដូចជាភិក្ខុអ្នកសម្តែងនោះឡើយ ព្រោះហេតុដូច្នោះ សិក្ខាបទនុ៎ះ តថាគតហៅថា ថុល្លច្ច័យ ។"(១)

ក៏កាលភិក្ខុធ្វើផ្ទាំងឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យគ្រប់ប្រយោគ ។ ប៉ុន្តែថា លោកសូម្បីឱ្យកម្រើកហើយឈានចុះកាន់លជ្ជីធម៌ សម្តែងថុល្លច្ច័យចេញហើយ រមែងផុតបាន ។ ក៏អាបត្តិដែលកើតមុន ៗព្រោះការឱ្យកម្រើកនេះ រមែងរម្ងាប់ទៅ ចាប់ផ្តើមតាំងពីសហាបយោគទៅដោយពិត ។

ក្នុងអដ្ឋកថា ឈ្មោះកុរុន្ទីពោលថា ក៏ឯទុក្កដ និងបាចិត្តិយពួកណាក្នុងបុព្វបយោគ លោកសម្តែងសហាបយោគហើយឈានចុះកាន់លជ្ជីធម៌ហើយត្រូវទុក, ទុក្កដនិងបាចិត្តិយទាំងអស់នោះ គួរសម្តែង ។ ចំណែកទុក្កដ សូម្បីមានចំនួនច្រើន ព្រោះការកាត់ស្មៅ ដើមឈើ និងវល្លិជាដើមដែលកើតឡើងក្នុងទីនោះ ដែលជាសហាបយោគ រមែងរម្ងាប់ទៅ

១. វិន. បរិ. គាថាសង្គណិក. ១៣. ១២១/១៣៥ ។

ព្រោះដល់ការជីកដី ។ អាបត្តិទុក្កដព្រោះហេតុជីកដី តែមួយប៉ុណ្ណោះនៅមាន ទុក្កដសូម្បីច្រើនព្រោះការជីក រមែងរម្ងាប់ទៅ ព្រោះដល់ការកកាយ, អាបត្តិទុក្កដសូម្បីច្រើន ព្រោះការកកាយ រមែងរម្ងាប់ទៅ ព្រោះដល់ការកើបបារឡើង, អាបត្តិទុក្កដសូម្បីច្រើន ព្រោះការកើបបារឡើងរមែងរម្ងាប់ទៅ ព្រោះដល់ការចាប់ត្រូវ, អាបត្តិទុក្កដសូម្បីច្រើន ព្រោះការចាប់ត្រូវ រមែងរម្ងាប់ទៅ ព្រោះដល់ការឱ្យកម្រើក ។ ក៏ឯកាលលជ្ជីធម៌កើតឡើងក្នុងខណៈជីកដីជាដើម អាបត្តិសូម្បីនឹងមានច្រើន ក៏ដោយ លោកសម្តែងត្រឹមតែមួយប៉ុណ្ណោះ រមែងផុតបាន ។ ពិតមែនដែលឈ្មោះថា សេចក្តីរម្ងាប់នៃអាបត្តិដែលកើតឡើងមុននេះ មកហើយក្នុងសូត្រ ក្នុងអនុសាវនាទាំងឡាយនុ៎ះឯង យ៉ាងនេះថា ទុក្កដព្រោះញត្តិ ថុល្លច្ច័យ ព្រោះកម្មវាចាពីរលើក រមែងរម្ងាប់ទៅ ។ តែសេចក្តីរម្ងាប់នៃអាបត្តិដែលកើតឡើងមុនក្នុងទុតិយបារាជិកនេះ អ្នកសិក្សាគួរកាន់យកដោយប្រមាណនៃព្រះអដ្ឋកថាចារ្យ ដូច្នេះឯង ។

## ការលួចទ្រព្យឱ្យឃ្លាតចាកឋាន ៦ យ៉ាង

ច្រើនបទថា ឋានា ចាវេតិ អាបត្តិ បារាជិកស្ស : ឱ្យឃ្លាតចាកទីត្រូវអាបត្តិបារាជិក មានសេចក្តីថា ក៏ភិក្ខុណាសូម្បីញ៉ាំងឱ្យកម្រើកហើយ ក៏មិនឈានចុះកាន់លជ្ជីធម៌ឡើយ ញ៉ាំងឆ្នាំងទ្រព្យនោះឱ្យ

ឃ្លាតចាកឋាននៃផ្ទាំង ដោយហោចទៅ សូម្បីត្រឹមតែមួយសរសៃសក់, ភិក្ខុនោះត្រូវបារាជិកតែម្ដង ។ ក៏ការញ៉ាំងទ្រព្យឱ្យឃ្លាតចាកឋាន ក្នុងពាក្យថា ឋានា ចាវេតិ នេះ គប្បីជ្រាបដោយអាការ ៦ ។ អ្វីខ្លះ ?

១. ភិក្ខុចាប់មាត់ផ្ទាំងទាញរំកិលមកត្រង់មុខរបស់ខ្លួន ញ៉ាំងទីបំផុតខាងឯណោះ ឱ្យកន្លងឱកាសទីបំផុតខាងនេះដែលប៉ះត្រូវហើយ សូម្បីត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។

២. ភិក្ខុចាប់យ៉ាងនោះហើយ រុញទៅខាងមុខ ញ៉ាំងទីបំផុតខាងនេះ ឱ្យហួសឱកាសទីបំផុតខាងឯណោះប៉ះត្រូវហើយ សូម្បីត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។

៣. ភិក្ខុទាញទៅខាងឆ្វេង ញ៉ាំងទីបំផុតខាងស្ដាំ ឱ្យកន្លងឱកាសទីបំផុតខាងឆ្វេងប៉ះត្រូវហើយ សូម្បីត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។

៤. ភិក្ខុទាញទៅខាងស្ដាំ ញ៉ាំងទីបំផុតខាងឆ្វេងកន្លងឱកាសទីបំផុតខាងស្ដាំប៉ះត្រូវហើយ សូម្បីត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។

៥. ភិក្ខុលើកឡើងខាងលើ ឱ្យផុតពីផ្ទៃ សូម្បីត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។

៦. ភិក្ខុជីកដី សង្កត់ចុះខាងក្រោម ញ៉ាំងកណ្ដាប់មាត់ផ្ទាំងឱ្យកន្លង

ឱកាសដែលបាតឆ្នាំងប៉ះត្រូវហើយ សូម្បីត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។

ការឱ្យឃ្លាតចាកឋាន សម្រាប់ឆ្នាំងដែលតាំងនៅក្នុងឋានតែមួយ គប្បីជ្រាបដោយអាការ ៦ យ៉ាងនេះ ដោយប្រការដូច្នេះ ។ ក៏បើគេធ្វើអន្ទាក់ត្រង់កណ្តាប់មាត់ឆ្នាំងហើយបោះបង្គោលលោហៈ ឬបង្គោលឈើខ្លឹមមានគតីជាដើមចុះក្នុងផែនដី ហើយយកខ្សែប្រវាក់ចងឆ្វាក់ត្រង់បង្គោលនោះតាំងទុក ។ ឆ្នាំងដែលចងឆ្វាក់ដោយខ្សែមួយ ក្នុងទិសមួយ រមែងបានឋាន ២ ។ ចងឆ្វាក់ដោយខ្សែច្រើន ក្នុងទិស ២, ៣, ៤, រមែងបានឋាន ៣, ៤, ៥ ។ បណ្តាឆ្នាំងដែលចងឆ្វាក់ទុកត្រង់បង្គោលតែមួយជាដើមនោះ ភិក្ខុលើកបង្គោលជំបូងនៃឆ្នាំងដែលចងឆ្វាក់ទុកត្រង់បង្គោលតែមួយឡើងក្តី កាត់ប្រវាក់ក្តី ត្រូវអាបត្តិថុល្លច្ច័យ ។ ខាងក្រោយឱ្យឆ្នាំងឃ្លាតចាកឋាន សូម្បីត្រឹមតែមួយចុងសរសៃសក់ ដោយន័យតាមដែលពោលហើយនុ៎ះឯង ត្រូវអាបត្តិបារាជិក ។ បើលើកឆ្នាំងឡើងទីមួយ ត្រូវអាបត្តិថុល្លច្ច័យ ។ ខាងក្រោយឱ្យបង្គោលឃ្លាតចាកឋាន សូម្បីត្រឹមតែ១ចុងសរសៃសក់ក្តី កាត់ខ្សែក្តី ត្រូវអាបត្តិបារាជិក ។ ក្នុងការញ៉ាំងទីបំផុតសូម្បីនៃឆ្នាំងដែលចងឆ្វាក់ទុកត្រង់បង្គោល ២, ៣, ៤, ដើម ឱ្យឃ្លាតចាកឋានក៏ត្រូវបារាជិកដោយឧបាយ

នោះ ។ ក្នុងបង្គោលដ៏សេសទាំងឡាយ គប្បីជ្រាបថា ជាថុល្លច្ច័យ ។ បើមិនមានបង្គោល គេធ្វើរង្វង់កងទុកត្រង់ចុងប្រវាក់ ហើយទើបស៊កចូលទៅ ត្រង់ឫសឈើដែលកើតនៅក្នុងទីនោះ ។ ភិក្ខុលើកឆ្នាំងឡើងមុន ខាងក្រោយទើបកាត់ឫសឈើ ហើយនាំរង្វង់កងចេញ ត្រូវអាបត្តិបារាជិក ។ បើមិនកាត់ឫសឈើ តែធ្វើឱ្យរង្វង់កងរូតបង្ខិតទៅខាងឯណោះនិងខាងនេះ នៅរក្សា ។ សូម្បីមិនទាន់នាំចេញចាកឫសឈើ គ្រាន់តែយកដៃចាប់ធ្វើឱ្យផុតទៅក្នុងអាកាស ក៏ត្រូវអាបត្តិបារាជិក ។ សេចក្តីប្លែកគ្នាក្នុងអធិការពោលអំពីឆ្នាំង ដែលគេស៊កចូលទុកត្រង់ឫសឈើនេះមានប៉ុណ្ណេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។ ក៏ជនពួកខ្លះដាំដើមជ្រៃជាដើមទុកខាងលើឆ្នាំង ដើម្បីត្រូវការជាគ្រឿងសំគាល់ ។ ឫសឈើជាប់ប្រទាក់ឆ្នាំងតាំងនៅ ។ ភិក្ខុគិតថា នឹងកាត់ឫសឈើលួចឆ្នាំងទៅ កំពុងកាត់ត្រូវអាបត្តិទុក្កដគ្រប់ប្រយោគ ។ កាត់ហើយធ្វើឱកាសឱ្យឆ្នាំងឃ្លាតចាកឋាន សូម្បីត្រឹមតែ១ចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។ កាលកំពុងកាត់ឫសឈើនោះឯង ឆ្នាំងរបូតរមៀលទៅកាន់ទីទំនាប នៅរក្សាទុកសិន, លើកឡើងពីឋានដែលឆ្នាំងរមៀលទៅ ត្រូវអាបត្តិបារាជិក ។ បើកាលកាត់ឫសឈើទាំងឡាយហើយ ឆ្នាំងតាំងនៅបានដោយឫសតែមួយ និងភិក្ខុនោះគិតថា កាលកាត់ឫសឈើនេះ

ហើយឆ្នាំងនឹងធ្លាក់ទៅ ទើបកាត់ឫសឈើនោះ ល្មមកាត់ដាច់ ត្រូវអាបត្តិបារាជិក ។ ក៏បើឆ្នាំងតាំងនៅដោយឫសតែមួយប៉ុណ្ណោះដូចជ្រូកត្រូវចងទុកត្រង់អន្ទាក់ ដូច្នោះ ដែលជាប់អ្វី ៗ យ៉ាងដទៃមិនមាន, សូម្បីកាលឫសនោះល្មមកាត់ដាច់ហើយ ក៏ត្រូវអាបត្តិបារាជិក ។ បើគេដាក់ជុំថ្មផ្ទាំងធំសង្កត់ទុកពីលើឆ្នាំង, ភិក្ខុមានសេចក្តីប្រាថ្នានឹងយកកំណាត់ឈើគាស់ជុំថ្មនោះចេញ ទើបកាត់ដើមឈើដែលកើតនៅលើឆ្នាំងចោល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាត់ឈើជាដើមដែលកើតនៅជិតឆ្នាំងនោះហើយនាំមក មិនត្រូវអាបត្តិទុក្កដ ព្រោះដើមឈើជារបស់កើតនៅក្នុងទីនោះ តែកាលកាត់ឈើបែបនោះ ត្រូវអាបត្តិបាចិត្តិយ ។

ពីរបទថា **អត្តនោ ភាជនគតំ** : **ក្នុងភាជនរបស់ខ្លួន** មាន សេចក្តីថា ក៏បើភិក្ខុមិនអាចនឹងលើកយកឆ្នាំងឡើងបាន ទើបស៊កភាជនៈរបស់ខ្លួនចូលទៅ ដើម្បីទទួលយកទ្រព្យដែលនៅក្នុងឆ្នាំង មានថេយ្យចិត្តចាប់ត្រូវទ្រព្យខាងក្នុងឆ្នាំង គួរដល់តម្លៃ ៥ មាសកក៏ដោយ លើសជាង ៥ មាសកក៏ដោយ ត្រូវអាបត្តិទុក្កដ ។ ក៏ការកំណត់ ដែលលោកពោលទុកហើយក្នុងព្រះបាលីនេះ ដើម្បីកំណត់អាបត្តិបារាជិក ។ កាលភិក្ខុចាប់ត្រូវទ្រព្យសូម្បីតិចជាង ៥ មាសក ដោយថេយ្យចិត្ត ក៏ត្រូវទុក្កដដូចគ្នា ។

ក្នុងពាក្យថា **ផន្ទាបេតិ** : **ឱ្យកម្រើក** នេះ សេចក្តីថា ភិក្ខុ

ប្រមូលទ្រព្យឱ្យជាប់គ្នាហើយស៊កភាជនៈរបស់ខ្លួនចូលទៅ នៅត្រឹមណា, ភិក្ខុនោះលោកហៅថា ធ្វើឱ្យកម្រើក ត្រឹមនោះ ។ ម្យ៉ាងទៀត សូម្បីកាលរំកិលទៅឯណោះនិងឯនេះ ឈ្មោះថា ធ្វើឱ្យកម្រើកដូចគ្នា ។ ភិក្ខុនោះ រមែងត្រូវអាបត្តិថុល្លច្ច័យ ។ ក្នុងកាលណា ភិក្ខុកាត់ទ្រព្យជាប់គ្នាដាច់ហើយ ទ្រព្យដែលនៅក្នុងផ្ទាំង ក៏មាននៅក្នុងផ្ទាំងនុ៎ះឯង សូម្បីនៅក្នុងភាជនៈ ក៏មាននៅក្នុងភាជន៍ប៉ុណ្ណោះ ក្នុងកាលនោះ ទ្រព្យឈ្មោះថាមាននៅក្នុងភាជនៈរបស់ខ្លួនហើយ ។ កាលលោកធ្វើយ៉ាងនោះហើយ សូម្បីកាលមិនបាននាំភាជនៈចេញចាកផ្ទាំងក៏ដោយ ត្រូវអាបត្តិបារាជិក ។

ក្នុងពាក្យថា មុដ្ឋឹ វា ឆិន្ទតិ : កាត់ដាច់នូវក្តាប់ដៃ នេះ សេចក្តីថា កហាបណៈដែលរបូតចេញតាមប្រហោងម្រាមដៃហើយ នឹងមិនប៉ះកហាបណៈដែលនៅក្នុងផ្ទាំងដោយវិធីណា ភិក្ខុធ្វើការក្តាប់យកដោយវិធីនោះ ឈ្មោះថា កាត់ក្តាប់យក ។ សូម្បីភិក្ខុនោះ ក៏ត្រូវអាបត្តិបារាជិក ។

បទថា សុត្តារុឡ្ហំ : ដោតក្រងដោយខ្សែ បានដល់ ទ្រព្យដែលដោតក្រងទុកក្នុងអំបោះ ។ ពាក្យថា សុត្តារុឡ្ហំ នោះ ជាឈ្មោះរបស់គ្រឿងប្រដាប់ដែលដោតទុកក្នុងអំបោះខ្លះ ដែលសម្រេចដោយអំបោះខ្លះ ។ គ្រឿងប្រដាប់ទាំងឡាយ មានសង្វារជាដើម ដែលសម្រេចដោយ

មាសខ្លះក៏មាន ដែលសម្រេចដោយរូបិយៈខ្លះក៏មាន ដែលសម្រេចដោយអំបោះខ្លះក៏មាន, សូម្បីខ្សែអន្ទាំជាដើម ក៏ដល់ការសង្គ្រោះចូលក្នុងសន្ធារជាដើមនេះឯង ។ សំពត់សម្រាប់ជូតសីសៈ លោកហៅថា វេឋនៈ ។ ភិក្ខុមានថេយ្យចិត្តចាប់ត្រូវបណ្ដាទ្រព្យដែលដោតទុកក្នុងអំបោះជាដើមទាំងនោះយ៉ាងណាមួយ ត្រូវអាបត្តិទុក្កដ ។ ធ្វើឱ្យកម្រើក ត្រូវអាបត្តិថុល្លច្ច័យ ។ ចាប់ទីបំផុតសន្ធារហើយ មិនបានធ្វើឱ្យអណ្ដែតនៅក្នុងអាកាស ត្រឹមតែលើកឡើង (ប៉ុណ្ណោះ) ត្រូវអាបត្តិថុល្លច្ច័យ ។

ក៏ក្នុងបទថា ឃំសន្តោ នីហរតិ : កាលបើប៉ះទង្គិតរួចនាំយកចេញ នេះ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងសង្ខេបអដ្ឋកថា និងមហាបច្ចរីជាដើម លោកពោលទុកថា កាលភិក្ខុទាញនូវភណ្ឌដែលគេធ្វើឆ្នាំងពេញស្មើ ហើយតាំងទុកលើឆ្នាំងដែលពេញហើយក្ដី ឬទាញនូវភណ្ឌៈដែលគេធ្វើកំពូច ដាក់ចុងម្ខាងទុកត្រង់បាទឆ្នាំង ដាក់ចុងម្ខាងទុកត្រង់កណ្ដាប់មាត់ឆ្នាំងហើយក្ដី ត្រូវអាបត្តិថុល្លច្ច័យ ។ កាលឱ្យផុតពីមាត់ឆ្នាំង ត្រូវអាបត្តិបារាជិក ។ ចំណែកភណ្ឌៈណាដែលគេតម្កល់ទុកក្នុងឆ្នាំងដែលខ្វះ ឬក្នុងឆ្នាំងទទេ ចំពោះឱកាសដែលខ្វន (គឺ ភណ្ឌៈ)ពាល់ត្រូវ ជាឋានរបស់ភណ្ឌៈនោះ, ឆ្នាំងទាំងអស់មិនបានជាឋានទេ; ព្រោះហេតុនោះ កាលភិក្ខុសូម្បីទាញភណ្ឌៈ

នោះចេញទៅ កាលប្រមាណត្រឹមមួយចុងសរសៃសក់ផុតចាកឱកាសដែលភណ្ឌៈនោះតាំងនៅទៅ ជាអាបត្តិបារាជិកភ្លាម ។ តែកាលភិក្ខុលើកឡើងត្រង់ ៗ ចាកឆ្នាំងដែលពេញឬមិនពេញ កាលភណ្ឌៈនោះល្មមផុតចាកឱកាសទីបំផុតខាងក្រោមឆ្នាំងតាំងនៅហើយ ជាបារាជិក ។

ភណ្ឌៈយ៉ាងណាមួយ ដែលល្មមនឹងជាបារាជិក ដែលគេដាក់ទុកខាងក្នុងឆ្នាំងកាលភិក្ខុឱ្យកម្រើកនៅក្នុងឆ្នាំងទាំងអស់ និងកាលទាញគ្រឿងប្រដាប់មានសង្វារជាដើមចេញទៅ មិនទាន់ហួសកណ្តាប់មាត់ត្រឹមណា, នៅជាអាបត្តិថុល្លច្ច័យត្រឹមនោះឯង ។ ព្រោះថា ឆ្នាំងសូម្បីទាំងអស់ ជាឋានរបស់ភណ្ឌៈនោះ ។

ចំណែកក្នុងមហាអដ្ឋកថា លោកពោលទុកថា កន្លែងដែលគេតម្កល់ទុកប៉ុណ្ណោះជាឋាន, ឆ្នាំងទាំងអស់មិនបានជាឋានទេ; ព្រោះហេតុនោះ កាលភិក្ខុឱ្យផុតចាកឋានដើមដែលគេតាំងទុកទៅ សូម្បីត្រឹមតែ ១ចុងសរសៃសក់ ក៏ត្រូវអាបត្តិបារាជិកតែម្តងនោះឯង ។ ពាក្យនៃមហាអដ្ឋកថានោះ ជាប្រមាណ ។ ចំណែកពាក្យអដ្ឋកថាក្រៅនេះ លោកពោលតាមន័យនៃការមូរចីវរ ដែលពាក់នៅលើស្មារចីវររបស់ភិក្ខុដែលមិនបានធ្វើឱ្យទៅក្នុងអាកាស ។ ពាក្យដែលពោលទុកក្នុងសង្ខេបអដ្ឋកថាជាដើមនោះ មិនគួរកាន់យក ។ ព្រោះព្រះវិន័យធរគួរតាំងនៅក្នុងឋានៈដែលធ្ងន់ក្នុងកាលវិនិច្ឆ័យវិន័យដែលមកដល់ហើយ ។ សេចក្តីនេះ ជា

ធម្មតាក្នុងវិន័យ ។ ម្យ៉ាងទៀតថា ឆ្នាំងទាំងអស់ មិនជាឋាននៃភណ្ឌៈ ដែលឋិតនៅខាងក្នុងឆ្នាំងយ៉ាងណា, ពាក្យនៃសង្ខេបអដ្ឋកថាជាដើមនោះ បណ្ឌិតគប្បីជ្រាបដូច្នោះ ព្រោះបាលីថា "ធ្វើទ្រព្យឱ្យចូលទៅក្នុងភាជន៍របស់ខ្លួនក្តី កាត់នូវក្តាប់ដៃក្តី" ដូច្នេះឯង ។

## អត្ថាធិប្បាយភិក្ខុលួចបឺតទឹកដោះថ្លាជាដើម

ក្នុងមហាអដ្ឋកថា លោកពោលទុកថា កាលភិក្ខុផឹករបស់ដែលជាទឹកយ៉ាងណាមួយមានទឹកដោះថ្លាជាដើមនោះ កាលទឹកដោះថ្លាជាដើមនោះកំណត់ប្រមាណថា លោកផឹកហើយដោយប្រយោគតែមួយក៏ជាបារាជិក ។ តែក្នុងអដ្ឋកថាទាំងឡាយ មានមហាបច្ចរីជាដើម លោកសម្តែងវិភាគនេះទុកថា កាលភិក្ខុផឹកមិនដកមាត់ចេញ និងទឹកដោះថ្លាជាដើមដែលចូលទៅក្នុងបំពង់-ក មិនទាន់បាន ១ បាទ រួមជាមួយដែលនៅក្នុងមាត់ ទើបបាន ១ បាទ, នៅរក្សាទុកសិន, តែក្នុងវេលាដែលទឹកដោះថ្លាក្នុងមាត់ជាដើម ដែលខ្លួនកាត់ដាច់ពីគ្នាត្រឹមបំពង់កនុ៎ះឯង រមែងជាអាបត្តិបារាជិក ។ បើភិក្ខុកាត់ដោយការបិទបបូរមាត់ទាំងពីរខាង ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។ សូម្បីកាលផឹកដោយទងឧប្បលបំពង់ឫស្សីនិងបំពង់បបុសជាដើម បើទឹកដោះថ្លាដែលនៅក្នុងបំពង់កនុ៎ះឯងបានតម្លៃមួយបាទ ជាអាបត្តិ

បារាជិក ។ បើរូមជាមួយដែលនៅក្នុងមាត់ ទើបបានមួយបាទ, កាលទឹកដោះថ្លាជាដើមនោះ ត្រឹមតែភិក្ខុកំណត់កាត់ដោយបបូរមាត់ទាំងពីរខាងឱ្យជាប់ជាមួយនឹងទឹកដោះដែលនៅក្នុងទងឧប្បលជាដើមដាច់ពីគ្នា ជាបារាជិក ។ បើរូមជាមួយទឹកដោះថ្លាដែលនៅក្នុងទងឧប្បលជាដើម ទើបបានតម្លៃមួយបាទ ជាអាបត្តិបារាជិក ក្នុងកាលកំណត់ប្រមាណត្រឹមដែលភិក្ខុយកម្រាមដៃបិទទងឧប្បលខាងក្រោមជាដើមចេញ ។ តែកាលទឹកដោះក្នុងជាដើមដែលមានតម្លៃបានមួយបាទ មិនទាន់ហូរចូលទៅក្នុងបំពង់ក ទាំងក្នុងធាងឧប្បលជាដើម ទាំងក្នុងមាត់ សូម្បីមានតម្លៃលើសជាងមួយបាទ តែជារបស់ឋិតនៅជាប់គ្នា, នៅរក្សាសិននោះឯង ។ ពាក្យសូម្បីទាំងអស់ ដែលពោលក្នុងមហាបច្ចរីជាដើមនោះ រមែងសមន័យនេះថា "ធ្វើទ្រព្យឱ្យចូលទៅក្នុងភាជនៈរបស់ខ្លួនក្តី កាត់ដោយក្តាប់ដៃក្តី" ដូច្នេះ; ព្រោះហេតុនោះ (ពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាមានមហាបច្ចរីជាដើមនោះ) ជាពាក្យដែលលោកសម្តែងទុកប្រពៃហើយនោះឯង ។ ក្នុងកណ្ឌៈដែលជាប់គ្នា មានន័យប៉ុណ្ណោះឯង ។

ក៏បើភិក្ខុយកដៃក្តី បាត្រក្តី ភាជនៈយ៉ាងណាមួយ មានត្រឡោកជាដើមក្តី ជួសផឹក, ទឹកដោះថ្លាជាដើមនឹងគ្រប់តម្លៃមួយបាទក្នុងប្រយោគណា, កាលធ្វើប្រយោគនោះហើយ ត្រូវអាបត្តិបារាជិក ។ បើទឹកដោះថ្លា

ជាដើមជារបស់មានតម្លៃច្រើន ភិក្ខុអាចកាន់យកបានតម្លៃមួយបាទ សូម្បីដោយសំបកខ្យង ដោយប្រយោគត្រឹមតែមួយនោះឯង ក្នុងកាលលើកឡើងម្តងប៉ុណ្ណោះ ជាអាបត្តិបារាជិក ។

ម្យ៉ាងទៀត កាលភិក្ខុសង្កត់ភាជនៈឱ្យលិចចុះហើយជួសយក, ទឹកដោះថ្លាជាដើមនោះនៅជាប់គ្នាត្រឹមណា, នៅរក្សាត្រឹមនោះ ជាអាបត្តិបារាជិក ដោយការដាច់ចេញនៃកណ្តាប់មាត់ ឬដោយការលើកឡើង ។ ក៏ទឹកដោះថ្លាឬប្រេង ឬទឹកឃ្មុំ និងទឹកអំពៅដែលថ្លា ដូចប្រេងនុ៎ះឯង ភិក្ខុផ្អៀងផ្តាំងឱ្យហូរចូលភាជនៈរបស់ខ្លួន កាលណា, កាលនោះ ការដាច់គ្នា រមែងមិនមាន ព្រោះហេតុដែលវត្ថុទាំងនោះជារបស់ថ្លា; ព្រោះដូច្នោះ កាលទឹកដោះថ្លាជាដើមដែលបានតម្លៃមួយបាទ ត្រឹមតែហូរចេញចាកកណ្តាប់មាត់ ជាអាបត្តិបារាជិក ។ ចំណែកទឹកឃ្មុំនិងទឹកអំពៅដែលគេរម្ងាស់តាំងទុក ស្អិតស្រដៀងជ័រឈើ ជារបស់គួរទាញទៅមកបាន, កាលសេចក្តីរង្កៀសកើតឡើង ភិក្ខុអាចនាំត្រឡប់មកវិញបាន ព្រោះជារបស់ជាប់គ្នានុ៎ះឯង ។ ទឹកឃ្មុំនិងទឹកអំពៅប្រភេទនោះសូម្បីចេញចាកកណ្តាប់មាត់ចូលទៅក្នុងភាជនៈហើយ ក៏ឈ្មោះថា នៅរក្សា ព្រោះជារបស់ស្អិតជាប់គ្នាតែមួយ ចំណែកខាងក្រៅ គ្រាន់តែដាច់ចាកកណ្តាប់មាត់ហើយ ទើបត្រូវអាបត្តិបារាជិក ។ សូម្បីភិក្ខុណា យកសំពត់សំបកឈើ

យ៉ាងណាមួយ ឬរបស់ដទៃមានកំណាត់ស្បែកជាដើមប្រភេទណាមួយ ដែលនឹងបឺតទឹកដោះថ្លា ឬ ប្រេងបានតម្លៃមួយបាទយ៉ាងពិតប្រាកដ ដាក់ចុះក្នុងឆ្នាំងរបស់អ្នកដទៃដោយថេយ្យចិត្ត លួមផុតពីដៃ ភិក្ខុនោះក៏ត្រូវអាបត្តិបារាជិក ។

ក្នុងមហាអដ្ឋកថាលោកពោលទុកថា ភិក្ខុដឹងថា "ឥឡូវនេះ គេនឹងដាក់ប្រេង" មានថេយ្យចិត្តដាក់ភណ្ឌៈយ៉ាងណាមួយចុះក្នុងឆ្នាំងទទេ, បើភណ្ឌៈនោះនឹងបឺតបានតម្លៃ ៥ មាសក ក្នុងកាលប្រេងគេដាក់ឆ្នាំងនោះហើយ កាលភណ្ឌៈនោះត្រឹមតែថា បឺតប្រេងនោះហើយ ជាអាបត្តិបារាជិក ។ តែពាក្យនោះ រមែងទាស់នឹងពាក្យវិនិច្ឆ័យពោលអំពីការធ្វើប្រឡាយសូត្រឱ្យត្រង់ ក្នុងបឹងដែលរីងស្ងួត ក្នុងមហាអដ្ឋកថានោះឯង, ពិតមែន លក្ខណៈនៃអវហារក្នុងពាក្យនេះ មិនប្រាកដ; ព្រោះហេតុនោះទើបមិនគួរកាន់យក ។ ចំណែកក្នុងអដ្ឋកថាមហាបច្ចរីជាដើម លោកពិន័យជាអាបត្តិបារាជិក ក្នុងកាលលើកភណ្ឌៈនោះឡើង ។ ពាក្យនោះប្រើបាន ។ ភិក្ខុដាក់ភណ្ឌៈមានស្បែកជាដើម ក្នុងឆ្នាំងទទេរបស់អ្នកដទៃ ដើម្បីត្រូវការរក្សាបិទបាំងទុក កាលគេដាក់ប្រេងចុះក្នុងឆ្នាំងនោះហើយ (លោក) ខ្លាចថា បើអ្នកនេះនឹងជ្រាប គេនឹងចាប់យើង ទើបលើកភណ្ឌៈដែលបឺតប្រេងទុកហើយបានតម្លៃមួយបាទឡើង ដោយថេយ្យចិត្ត ត្រូវអាបត្តិបារាជិក លើកឡើងដោយចិត្តបរិសុទ្ធិ កាលអ្នកដទៃឱ្យនាំមក

ជាភណ្ឌទេយ្យ ។ អធិប្បាយថា វត្ថុណារបស់អ្នកដទៃបាត់ទៅ, ត្រូវសងតម្លៃរបស់វត្ថុនោះ ឬសងវត្ថុនោះឯង; ឈ្មោះថា ភណ្ឌទេយ្យ ។ បើមិនសង ត្រូវបារាជិកក្នុងកាលម្ចាស់របស់ដាក់ធុរៈ ។ តែបើអ្នកដទៃដាក់ទឹកដោះថ្លា ឬប្រេងចុះក្នុងឆ្នាំងរបស់ភិក្ខុនោះ, ភិក្ខុដែលជាម្ចាស់ឆ្នាំងនេះ ក៏ដាក់ភណ្ឌៈដែលទឹងបឹតប្រេងបានចុះសូម្បីក្នុងឆ្នាំងនោះ ដោយថេយ្យចិត្ត ជាបារាជិក តាមន័យដែលពោលហើយនុ៎ះឯង ។ ភិក្ខុដឹងថាទឹកដោះថ្លាឬប្រេងដែលអ្នកដទៃដាក់ទុកក្នុងឆ្នាំងទទេរបស់ខ្លួន ទើបដាក់ភណ្ឌៈចុះទៅដោយថេយ្យចិត្ត ជាអាបត្តិបារាជិកក្នុងខណៈដែលលើកឡើងតាមន័យមុនដូចគ្នា ។ មានចិត្តបរិសុទ្ធដាក់ចុះទៅ ខាងក្រោយទើបលើកឡើងដោយថេយ្យចិត្ត ជាអាបត្តិបារាជិកដូចគ្នា ។ មានចិត្តបរិសុទ្ធពិតលើកឡើងមិនជាអវហារ មិនជាសំណង ។ តែក្នុងមហាបច្ចរីពោលទុកត្រឹមតែអនាបត្តិប៉ុណ្ណោះ ។ ក្នុងកុរុន្ទីលោកពោលទុកថា ភិក្ខុខឹងក្រោធថា “ហេតុដូចម្ដេចបានជាលោកដាក់ប្រេងចុះក្នុងឆ្នាំងរបស់យើង” ដូច្នេះ ហើយលើកភណ្ឌៈឡើងចាក់ចោលទៅ មិនជាភណ្ឌៈទេយ្យ ។ ភិក្ខុប្រាថ្នានឹងឱ្យប្រេងហូរ ទើបចាប់ត្រង់កណ្ដាប់មាត់ផ្អៀងឆ្នាំងដោយថេយ្យចិត្ត កាលប្រេងហូរទៅបានតម្លៃគ្រប់ ១ បាទ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមានថេយ្យចិត្តពិត ធ្វើឆ្នាំងឱ្យបែកដោយគិតថា ប្រេងនឹងហូរចេញទៅ កាលប្រេងហូរទៅបានតម្លៃគ្រប់ ១បាទ ត្រូវអាបត្តិបារាជិក ។ ភិក្ខុមាន

ថេយ្យចិត្តនោះឯង ធ្វើឆ្នាំងឱ្យជាប្រហោងធ្លុះផ្ចាប់ផ្ចារឬផ្ចៀង ។ ក៏ឯពាក្យនេះជាឋានៈនៃចម្លល់, ព្រោះដូច្នោះ គួរសង្កេតឱ្យល្អ ។

ក៏ក្នុងពាក្យថា ផ្ចាប់ ជាដើមនេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ប្រហោងមាត់ចុះខាងក្រោមឈ្មោះថា ផ្ចាប់ ។ ប្រហោងមាត់ឡើងខាងលើ ឈ្មោះថា ផ្ចារ ។ ប្រហោងមាត់ទៅត្រង់ ៗ ដូចបោយ ឈ្មោះថា ផ្ចៀង ។ បណ្ដាការធ្វើផ្ចាប់ជាដើមនោះ កាលប្រេងបានតម្លៃគ្រប់ ១ បាទ ហូរចេញចាកខាងក្នុងប្រហោងដែលនៅខាងក្រោម ដែលខ្លួនធ្វើទុកចាប់ផ្ដើមតាំងពីខាងក្រៅ សូម្បីទឹងមិនហូរចេញទៅខាងក្រៅ ក៏ជាអាបត្តិបារាជិក ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ប្រេងល្មមហូរចេញទៅពីខាងក្នុងនោះប៉ុណ្ណោះ ក៏ឈ្មោះថា ហូរចេញទៅខាងក្រៅ នឹងរាប់ថា នៅខាងក្នុងឆ្នាំងមិនបាន គឺ មិនតាំងនៅក្នុងឆ្នាំង ។ កាលប្រេងបានតម្លៃគ្រប់ ១ បាទ ហូរចេញពីខាងក្រៅប្រហោងផ្ចាប់ទៅ ដែលខ្លួនធ្វើទុកចាប់ផ្ដើមតាំងពីខាងក្នុងជាអាបត្តិបារាជិក ។ កាលប្រេងបានតម្លៃគ្រប់ ១ បាទហូរចេញទៅចាកទីបំផុតខាងក្រៅរបស់ប្រហោងផ្ចា ដែលខ្លួនធ្វើទុកដោយអាការណា ៗ ក៏ដោយ ជាអាបត្តិបារាជិក ។ ក្នុងអដ្ឋកថាទាំងឡាយលោកពោលទុកថា ពិតមែន ប្រេងនោះ មិនទាន់ហូរពីខាងក្នុងទៅខាងក្រៅត្រឹមណា, ក៏ឈ្មោះថា នៅខាងក្នុងឆ្នាំងត្រឹមនោះឯង ។ ព្រះវិន័យ

ធរ គប្បីពិន័យ (អាបត្តិបារាជិក) ដោយអំណាចប្រេងដែលហូរចេញត្រង់កណ្តាលអំបែងនៃប្រហោងផ្សៀង ។ ក៏ពាក្យដែលពោលទុកក្នុងអដ្ឋកថាទាំងឡាយនោះ រមែងសមនឹងការទម្លាយទំនប់របស់ស្រះ ក្នុងកាលភិក្ខុធ្វើប្រហោងតាំងពីខាងក្នុងនិងខាងក្រៅ វៀរត្រង់កណ្តាលទុក ។ តែកាលភិក្ខុធ្វើប្រហោងចាប់ផ្តើមតាំងពីខាងក្នុងហើយ ព្រះវិន័យធរគួរពិន័យអាបត្តិដោយទីបំផុតប្រហោងខាងក្រៅ, កាលភិក្ខុធ្វើប្រហោងចាប់ផ្តើមតាំងពីខាងក្រៅហើយ គួរពិន័យដោយទីបំផុតប្រហោងខាងក្នុង; ពាក្យដែលលោកពោលទុកក្នុងប្រហោងផ្សៀងនេះ ដូចពណ៌នាមកនេះ ប្រើបាន ។

ក៏ភិក្ខុណា នាំចេញនូវជើងទ្រឬរង្វេលនៃឆ្នាំង ដោយថេយ្យចិត្តថា ឆ្នាំងនឹងរមៀលទៅ កាលឆ្នាំងរមៀលទៅ ជាអាបត្តិបារាជិក ។ មួយទៀត កាលភិក្ខុដឹងសេចក្តីដែលគេនឹងបង្ហូរប្រេងដាក់ ធ្វើស្នាមប្រេះ ឬប្រហោងនៃឆ្នាំងទទេទុកជាភណ្ឌទេយ្យ ដោយប្រមាណនៃប្រេងដែលហូរចេញក្នុងខាងក្រោយ ។ តែក្នុងអដ្ឋកថាទាំងឡាយ កន្លែងខ្លះលោកសរសេរទុកថា ជាអាបត្តិបារាជិក ដូច្នេះក៏មាន ។ នោះសរសេរទុកដោយសេចក្តីភាំងភ្លាត់ ។ ភិក្ខុធ្វើឈើឬថ្មឱ្យជារបស់ដែលខ្លួនចង់ទុកមិនល្អ ឬតម្កល់ឈើឬថ្មឱ្យជារបស់ដែលខ្លួនតម្កល់ទុកមិនល្អក្នុងខាងលើនៃ

ឆ្នាំងពេញ ដោយថេយ្យចិត្តថា វានឹងធ្លាក់ទៅបែក ប្រេងនឹងហូរចេញចាកឆ្នាំងនោះ ។ ឈើឬថ្មនោះ នឹងត្រូវធ្លាក់យ៉ាងពិតប្រាកដ កាលភិក្ខុធ្វើយ៉ាងនោះ ជាអាបត្តិបារាជិកក្នុងខណៈធ្វើរួច ។ ធ្វើយ៉ាងនោះ ខាងលើនៃឆ្នាំងទទេ ឈើ ឬថ្មនោះធ្លាក់ទៅបែក ក្នុងកាលដែលឆ្នាំងនោះពេញខាងក្រោយជាភណ្ឌទេយ្យ ។ ពិតមែន ក្នុងឋានៈដូច្នេះមិនទាន់ជាបារាជិកក្នុងខាងដើមតែម្ដង ព្រោះប្រយោគដែលភិក្ខុធ្វើហើយក្នុងកាលដែលរបស់មិនមាន ។ តែជាភណ្ឌទេយ្យ ព្រោះធ្វើរបស់ឱ្យខូច ។ កាលគេឱ្យនាំមកសង មិនឱ្យគេ ជាបារាជិក ព្រោះការដាក់ធុរៈនៃម្ចាស់របស់ទាំងឡាយ ។ ភិក្ខុធ្វើប្រឡាយឱ្យត្រង់ដោយថេយ្យចិត្តថា ឆ្នាំងនឹងរមៀលទៅ ឬទឹកនឹងញាំងប្រេងឱ្យហៀរឡើង ឆ្នាំងរមៀលទៅក៏ដោយ ប្រេងហៀរឡើងក៏ដោយ ជាបារាជិកក្នុងវេលាដែលធ្វើឱ្យត្រង់ ។ ពិតមែនប្រយោគដូច្នេះ ៗ ដល់សេចក្ដីសង្គ្រោះបានក្នុងបុព្វបយោគអវហារ ។ កាលប្រឡាយសួតដែលភិក្ខុធ្វើឱ្យត្រង់ទុកហើយ ទឹកហូរមកពេលក្រោយ ឆ្នាំងរមៀលទៅកក្ដី ប្រេងហៀរឡើងក្ដី, ជាភណ្ឌទេយ្យ ។ ព្រោះហេតុអ្វី ? ព្រោះមិនមានប្រយោគ គឺ ការឱ្យឃ្លាតចាកឋាន ។ លក្ខណៈនៃប្រយោគ គឺការឱ្យឃ្លាតចាកឋាននោះ នឹងមានច្បាស់ក្នុងទ្រព្យដែលឋិតនៅក្នុងទូក ។

# អត្ថាធិប្បាយពាក្យថា ភិន្ទិត្វា ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងឡាយមានបទថា តាឡេត្វា ភិន្ទតិ វា : ទម្លាយក្តី ក្នុងទីនោះ ជាដើម លោកពោលទុកក្នុងអដ្ឋកថា ដូច្នេះជាមុន ។

ពាក្យថា **ទម្លាយក្តី** នោះ ដោយអត្ថថា ដំទម្លាយដោយឈើអន្ទង ។

ពាក្យថា **ចាក់ចោលក្តី** នោះ ដោយអត្ថថា ចាក់ទឹកឬខ្សាច់ចុះក្នុងប្រេងឱ្យប្រេងហៀរឡើង ។

ពាក្យថា **ដុតចោលក្តី** នោះ ដោយអត្ថថា នាំឧសមកហើយញុំាងភ្លើងឱ្យឆេះ ។

ពាក្យថា **ធ្វើឱ្យជារបស់ប្រើប្រាស់មិនកើត** នោះ ដោយអត្ថថា ធ្វើឱ្យជារបស់គប្បីទំពាមិនបាន ឬគប្បីផឹកមិនបាន គឺ ញុំាងឧច្ចារៈឬបស្សាវៈ ឬថ្នាំពិសឬរបស់ជាកាកសំណល់ ឬសាកសពឱ្យធ្លាក់ចុះទៅ ។

ពាក្យថា **ត្រូវអាបត្តិទុក្កដ** នោះ ដោយអត្ថថា ជាទុក្កដព្រោះមិនមានការឱ្យឃ្លាតចាកឋាន ។ ញាណពិសេសនេះ ឈ្មោះថា ពុទ្ធវិស័យ ។ សូម្បីទឹងជាទុក្កដ ក៏ពិតហើយ តែកាលម្ចាស់របស់ឱ្យនាំមកឱ្យ ជាភណ្ឌទេយ្យ ។ ក្នុង៤ បទនោះ ពីរបទខាងដើមមិនសម ។ ព្រោះពីរបទនោះ ជាលក្ខណៈដូចគ្នានឹងការធ្វើស្នាមប្រេះរបស់ឆ្នាំងនិងការធ្វើប្រឡាយឱ្យត្រង់ ។ ចំណែកពីរបទខាងក្រោយ សូម្បីញុំាងវត្ថុឱ្យឃ្លាត

ចាកឋានក៏អាចធ្វើបាន ។ ព្រោះដូច្នោះ អាចារ្យពួកមួយ ទើបពោលវិនិច្ឆ័យក្នុងពាក្យនេះទុកយ៉ាងនេះ ។

បានឮថា ក្នុងអដ្ឋកថា ពាក្យថា ជាទុក្កដ ព្រោះមិនមានការឱ្យឃ្លាតចាកទី នេះ លោកពោលសំដៅយកពីរបទខាងក្រោយ ។ ពិតមែន ភិក្ខុមិនធ្វើការឱ្យឃ្លាតចាកឋានឡើយ គប្បីដុតចោលក្តី គប្បីធ្វើឱ្យជារបស់ប្រើប្រាស់មិនបានក្តី ដោយថេយ្យចិត្ត ឬព្រោះត្រូវការឱ្យវិនាសអស់, តែក្នុងពីរបទខាងដើម កាលភិក្ខុទម្លាយឬចាក់ដោយន័យដែលពោលហើយ ការឱ្យឃ្លាតចាកឋាន រមែងកើតបាន ; ព្រោះដូច្នោះ កាលធ្វើយ៉ាងនោះ ជាភណ្ឌទេយ្យ ព្រោះប្រាថ្នាទីងឱ្យវិនាសអស់ ជាបារាជិកដោយថេយ្យចិត្ត ដូច្នេះឯង ។

បើមានអ្នកជំទាស់ថា ពាក្យនោះ មិនប្រពៃ ព្រោះលោកពោលទុកក្នុងព្រះបាលីថា ត្រូវអាបត្តិទុក្កដ ។

គប្បីឆ្លើយថា នឹងជាពាក្យមិនប្រពៃក៏ទេ ព្រោះមានអត្ថដែលនឹងគប្បីកាន់យកដោយប្រការដទៃ ។

ពិតមែន ក្នុងផ្នែកនៃថេយ្យចិត្តក្នុងព្រះបាលី អាចារ្យពួកមួយពោលយ៉ាងនេះថា ពាក្យថា **ទម្លាយក្តី** នោះ ដោយអត្ថថា លាយដោយទឹក ពាក្យថា **ចាក់ក្តី** នោះ ដោយអត្ថថា ចាក់របស់កំជាក់ ឬឧច្ចារៈ ឬបស្សាវៈចុះក្នុងភេសជ្ជៈមានប្រេងជាដើមនោះ ដូច្នេះ ។

ចំណែកសារៈក្នុងពាក្យនេះ ដូចតទៅនេះ ៖

ភិក្ខុមិនប្រាថ្នានឹងឱ្យឃ្លាតចាកឋានឡើយ ទម្លាយតែម្យ៉ាង ដូចភិក្ខុដុតស្មៅក្នុងវិនីតវត្ថុ ។ តែភេសជ្ជៈមានប្រេងជាដើម រមែងហូរចេញបានព្រោះឆ្នាំងធ្លាយហើយ ។ ក៏ឬថា ក្នុងភេសជ្ជៈទាំងនោះ ភេសជ្ជៈណាជារបស់ស្ងួតរឹង ភេសជ្ជៈនោះ នឹងជាប់គ្នាតាំងនៅបាន ។ មួយទៀត ភិក្ខុមិនប្រាថ្នានឹងចាក់ប្រេងឡើយ ចាក់ទឹក ឬខ្សាច់ជាដើម ចុះក្នុងឆ្នាំងនោះតែម្យ៉ាង ។ តែប្រេងក៏ជាការភិក្ខុនោះចាក់ ព្រោះបានចាក់ទឹក ឬខ្សាច់ជាដើមនោះចុះទៅ ។ ព្រោះដូច្នោះ ដោយអំណាចវោហារ លោកទើបហៅថា ទម្លាយក្តី ចាក់ក្តី ។ អ្នកសិក្សាគប្បីកាន់យកសេចក្តីនៃបទទាំងនេះដូចពោលមកដូច្នេះ ។

ចំណែកក្នុងផ្នែកនៃភាពជាអ្នកប្រាថ្នានឹងឱ្យវិនាស ជាទុក្កដ ត្រឹមត្រូវសូម្បីដោយប្រការក្រៅនេះ ។ ពិតមែន កាលលោកពោលអធិប្បាយសេចក្តីនៅយ៉ាងនេះ បាលីនិងអដ្ឋកថា រមែងជាការលោកសង្កេតពិនិត្យពោលល្អហើយដោយខាងដើម និងខាងចុង ។ តែមិនគួរធ្វើសេចក្តីពេញចិត្ត សូម្បីដោយពាក្យអធិប្បាយត្រឹមតែប៉ុណ្ណោះ គប្បីចូលទៅអង្គុយជិតអាចារ្យទាំងឡាយ ហើយជ្រាបសេចក្តីវិនិច្ឆ័យឯង ។

ចប់ ទ្រព្យដែលឋិតនៅក្នុងផែនដី

## ទ្រព្យដែលឋិតនៅលើគោក

[៩២] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅលើគោក ។

ពីរបទថា ថលេ និក្ខិត្តំ : ដែលគេតម្កល់ទុកនៅលើគោក សេចក្តីថា បានដល់ ទ្រព្យដែលគេដាក់ទុកលើផ្ទៃក្តី លើផែនដីប្រាសាទនិងលើភ្នំជាដើមកន្លែងណាមួយ ដែលបិទបាំង ឬមិនបិទបាំងក្តី គប្បីជ្រាបថា ទ្រព្យដែលតម្កល់ទុកនៅលើគោក ។ ទ្រព្យនោះ បើគេធ្វើជាគំនរទុក គប្បីកាត់សេចក្តីតាមពាក្យវិនិច្ឆ័យដែលពោលទុកក្នុងការធ្វើទ្រព្យឱ្យនៅក្នុងភាជនៈ និងការក្តាប់កាត់យកក្នុងខាងក្នុងឆ្នាំង ។ បើទ្រព្យនោះជាប់ស្អិតជាដុំតែមួយ មានជ័រឈើស្អិតចាប់ភ្ជាប់គ្នាជាដើម គប្បីកាត់សេចក្តីតាមពាក្យវិនិច្ឆ័យ ដែលពោលទុកក្នុងទឹកឃ្មុំ និងទឹកអំពៅដែលរម្ងាស់ឆ្អិនហើយ ។ បើទ្រព្យជារបស់ធ្ងន់ ជាដុំលោហៈក្តី ដុំស្ករអំពៅក្តី វត្ថុមានប្រេងទឹកឃ្មុំនិងខ្លាញ់ជាដើមក្តី ដែលជាប់ដោយភារៈ គប្បីកាត់សេចក្តីតាមពាក្យវិនិច្ឆ័យដែលពោលទុកក្នុងការញ៉ាំងឆ្នាំងឱ្យឃ្លាតចាកឋាន និងគប្បីកំណត់សេចក្តីផ្សេងរបស់ឋាននៃវត្ថុ ដែលគេចងទុកដោយប្រពាក់ ។ ចំណែកភិក្ខុកាន់យកវត្ថុមានសំពត់បាវារ សំពត់កម្រាលផែនដី និងសំពត់សាដកជាដើម ដែលគេក្រាលទុក ទាញមកត្រង់ ៗ កាលជាយសំពត់ខាងឯណោះ កន្លងហួសឱកាសដែលជាយសំពត់ខាងនេះប៉ះត្រូវទៅ ត្រូវអាបត្តិបារាជិក ។

ក្នុងទិសទាំងអស់ ក៏គួរកំណត់ដោយអាការយ៉ាងនេះ ។ ភិក្ខុវេចកញ្ចប់ហើយលើកឡើង កាលធ្វើឱ្យអណ្តែតទៅក្នុងអាកាស ត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ដូច្នេះ ។

ចប់ ទ្រព្យដែលនៅលើគោក

## ទ្រព្យដែលនៅក្នុងអាកាស

[៩៣] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យស្ថិតនៅព្ធដ៏អាកាស ។ សម្រាប់សត្វក្ងោក គប្បីជ្រាបការកំណត់ឋានដោយអាការ ៦ យ៉ាង គឺ ខាងមុខកំណត់ដោយចុងចំពុះ ខាងក្រោយកំណត់ដោយចុងកន្ទុយ ខាងទាំង ២ កំណត់ដោយចុងស្លាប ខាងក្រោមកំណត់ដោយចុងក្រចកជើង ខាងលើកំណត់ដោយចុងសិរ ។ ភិក្ខុគិតថា នឹងចាប់សត្វក្ងោកដែលមានម្ចាស់ដែល(ហើរ)នៅក្នុងអាកាស ឈរខាងមុខ ឬលាតដៃចេញ ។ សត្វក្ងោកត្រដាងស្លាបនៅក្នុងអាកាសនុ៎ះឯង ទទះស្លាបហើយ(ឈប់ហើរ) នៅឈរ ជាអាបត្តិទុក្កដដល់ភិក្ខុនោះ, មិនឱ្យសត្វក្ងោកនោះកម្រើក យកដៃស្ទាបអង្អែល ជាទុក្កដដូចគ្នា, មិនឱ្យឃ្លាតចាកឋាន ឱ្យកម្រើក ជាថុល្លច្ច័យ ។ ចំណែកទីឯយកដៃចាប់ឬមិនចាប់ក៏ដោយ ឱ្យចុងកន្ទុយក

នូវហ្លួសឱកាសដែលចុងចំពុះពាល់ត្រូវ ឬឱ្យចុងចំពុះកន្លងហ្លួសឱកាសដែលចុងកន្ទុយពាល់ត្រូវ, បើសត្វក្ងោកនោះ បានតម្លៃមួយបាទសោត, ជាបារាជិក; មួយទៀត ឱ្យចុងស្លាបខាងស្តាំ កន្លងហ្លួសឱកាសដែលចុងស្លាបខាងឆ្វេងត្រូវ ឬឱ្យចុងស្លាបខាងឆ្វេង កន្លងហ្លួសឱកាសដែលចុងស្លាបខាងស្តាំពាល់ត្រូវ ក៏ជាបារាជិក ។

មួយទៀត ឱ្យចុងសិរ កន្លងហ្លួសឱកាសដែលចុងក្រចកជើងពាល់ត្រូវ ឬឱ្យចុងក្រចកជើងកន្លងហ្លួសឱកាសដែលចុងសិរពាល់ត្រូវ ក៏ជាបារាជិក ។ សត្វក្ងោកហើរទៅតាមអាកាស ចាប់ត្រង់បណ្តាអវយវៈមានសីសៈជាដើម យ៉ាងណា, អវយវៈនោះ ជាឋានរបស់សត្វក្ងោកនោះ ។

ព្រោះហេតុនោះ ភិក្ខុនោះសូម្បីកាលធ្វើសត្វក្ងោកនោះ ដែលទំនៅត្រង់ដៃឱ្យផាកវេរទៅខាងឯណោះនិងខាងនេះ ឈ្មោះថា ធ្វើឱ្យកម្រើកពិត ។ និងបើលោកយកដៃម្ខាងទៀតចាប់ឱ្យឃ្លាតចាកឋាន ជាបារាជិក ។ ភិក្ខុលូកដៃម្ខាងទៀតចូលទៅជិត, សត្វក្ងោកហើរចុះទៅទំលើដៃនោះដោយខ្លួនឯង មិនជាអាបត្តិ ។ ភិក្ខុមានថេយ្យចិត្ត ដឹងថា សត្វក្ងោកចាប់ត្រង់អវយវៈ ជំហានឈានដំបូង ជាថុល្លច្ច័យ, ឈានទីពីរ ជាបារាជិក ។ សត្វក្ងោកឈរនៅលើផែនដី រមែងបានឋាន ៣ ដោយអំណាចជើងទាំងពីរ និងកន្ទុយ ។ កាលភិក្ខុលើកសត្វក្ងោកនោះឡើង

ជាចុលច្ច័យ ដរាបដល់វេលាដែលហានសូម្បីត្រឹមតែហានមួយនៅពាល់ត្រូវផែនដី ។ កាលគ្រាន់តែថា សត្វក្ងោកនោះ ដែលភិក្ខុធ្វើឱ្យផុតពីផែនដី សូម្បីត្រឹមតែមួយចុងសរសៃសក់ ក៏ជាបារាជិក ។ ភិក្ខុលើកសត្វក្ងោកដែលនៅក្នុងទ្រុងឡើងព្រមទាំងទ្រុង ត្រូវអាបត្តិបារាជិក ។ តែបើសត្វក្ងោកនោះ មិនបាន តម្លៃគ្រប់ ១ បាទសោត, គប្បីពិន័យតាមតម្លៃគ្រប់ ៗ កន្លែង ។ ភិក្ខុមានថេយ្យចិត្ត ធ្វើសត្វក្ងោក ដែលត្រាច់នៅខាងក្នុងសួនឱ្យភ័យខ្លាច នាំវាដើរចេញទៅក្រៅសួនដោយជើងនោះឯង ឱ្យកន្លងហួសខេត្តដែលកំណត់នៃទ្វារ ត្រូវអាបត្តិបារាជិក ។ ពិតមែន ខាងក្នុងសួនជាហានរបស់សត្វក្ងោកនោះ ដូចក្រោលជាហានរបស់គោដែលនៅក្នុងក្រោល ដូច្នោះ ។ តែកាលភិក្ខុយកដៃចាប់ឱ្យវាហើរទៅក្នុងអាកាស សូម្បីខាងក្នុងសួន ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។ កាលភិក្ខុញ៉ាំងសត្វក្ងោកសូម្បីត្រាច់នៅក្នុងស្រុក ឱ្យកន្លងហួសរបងស្រុកទៅ ត្រូវអាបត្តិបារាជិក ។ មួយទៀត ក្ងោកដែលចេញទៅត្រាច់នៅក្នុងឧបចារស្រុក ឬឧបចារសួននោះឯង និងភិក្ខុមានថេយ្យចិត្ត ញ៉ាំងវាឱ្យភ័យខ្លាចដោយដំបង ឬដោយក្អៀង ធ្វើឱ្យវាបែរមុខតម្រង់ចូលព្រៃ ។ សត្វក្ងោកហើរទៅទំនៅខាងក្នុងស្រុក ឬខាងក្នុងសួន ឬលើដំបូល, នៅរក្សា ។ តែបើវាបែរមុខតម្រង់ចូលព្រៃហើរទៅក្តី ដើរទៅក្តី, កាលមិនមានកំណត់ថា "យើងឱ្យវាចូលព្រៃទៅហើយ" នឹងចាប់យក ត្រូវអាបត្តិបារាជិក ក្នុង

កាលត្រឹមតែវាហើរឡើងផុតផែនដី សូម្បីត្រឹមតែមួយចុងសរសៃសក់ ឬក្នុងវារៈជំហានទីពីរ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា កន្លែងដែលឈរប៉ុណ្ណោះ ជាឋានរបស់វាដែលចេញចាកស្រុកហើយ ។ សូម្បីក្នុងសត្វទាំងឡាយ មានសត្វទទាជាដើម ក៏គប្បីជ្រាបវិនិច្ឆ័យ ដូច្នេះឯង ។

បទថា **សាដកំ វា :** ជាសំពត់សាដកក្តី មានសេចក្តីថា សំពត់សាដកដែលរីងព្រោះទឹកបាយ ត្រូវកម្លាំងខ្យល់តួច កំពុងអណ្តែតទៅក្នុងអាកាស ដូចគេក្រាលទុកលើផែនដី ដែលមកត្រង់មុខ ភិក្ខុយកដៃចាប់ត្រង់ជាយសំពត់ម្ខាងដូចសំពត់ដែលគេ ក្រាលទុកលើផែនដីត្រូវខ្យល់បក់ផាត់ ដូច្នោះ, កាលមិនបានធ្វើឋានឱ្យកម្រើកទៅ ខាងឯណោះនិងខាងនេះឡើយ ត្រូវអាបត្តិទុក្កដ ព្រោះវៀរការដើរ, កាលមិនធ្វើឱ្យឃ្លាតចាកឋានរក្សានៅ, ជាថុល្លច្ច័យ ព្រោះធ្វើឱ្យកម្រើក, ឱ្យឃ្លាតចាកឋាន ត្រូវអាបត្តិបារាជិក ។ ក៏ការកំណត់ឋាននៃសំពត់សាដកនោះ គប្បីជ្រាបដោយអាការ ៦ យ៉ាង ដូចការកំណត់ឋាននៃសត្វក្ងោក ដូច្នោះ ។ ចំណែកសំពត់សាដកដែលមិនរីង លុមភិក្ខុចាប់ ត្រង់ជាយសំពត់ម្ខាងប៉ុណ្ណោះ ក៏ធ្លាក់ចុះទៅឋិតនៅលើផែនដីទាំងជាយទីពីរ, សំពត់សាដកនោះមានឋាន ២ គឺ ដៃ ១ ផែនដី ១ ។ ភិក្ខុធ្វើសំពត់សាដកនោះតាមដែលចាប់យកហើយនោះឯង ឱ្យឃ្លាតចាកប្រទេសនៃឱកាសដែលខ្លួនចាប់យកគ្រាដំបូង ត្រូវថុល្លច្ច័យ ខាងក្រោយ យកដៃទីពីរ ឬជើងលើក

ឡើងចាកផែនដី ត្រូវបារាជិក ។ មួយទៀត គ្រាជំបូង លើកឡើងចាក ផែនដី ត្រូវថុល្លច្ច័យ, ខាងក្រោយឱ្យឃ្លាតចាកប្រទេសនៃឱកាសដែលខ្លួន ចាប់យក ត្រូវអាបត្តិបារាជិក ។ ម្យ៉ាងទៀត ភិក្ខុកាលមិនលែងពីការចាប់ លូកដៃចុះ ទៅត្រង់ ៗ ធ្វើសំពត់ឱ្យនៅត្រង់ផែនដី ហើយយកដៃនោះឯង លើកឡើង ត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងសំពត់ជូតក្បាល ក៏គប្បី ជ្រាបវិនិច្ឆ័យដូច្នេះឯង ។

ច្រើនបទថា ហិរញ្ញំ វា សុវណ្ណំ វា ឆិជ្ជមានំ : ប្រាក់ក្តី មាសក្តី ដែលដាច់ មានសេចក្តីថា គ្រឿងប្រដាប់មានខ្សែកជាដើមរបស់ ពួកមនុស្សអ្នកតាក់តែងនៅក្តី ដុំមាសរបស់ពួកជាងមាសអ្នកកាត់ ចម្រៀកមាសក្តី ដាច់ធ្លាក់ទៅ ។ បើភិក្ខុមានថេយ្យចិត្ត យកដៃចាប់ គ្រឿងប្រដាប់ ឬដុំមាសដែលដាច់ធ្លាក់អណ្តែតមកមកអាកាសនោះ, ការ ចាប់យកនុ៎ះឯង ជាឋាន, យកដៃចេញចាកប្រទេសដែលខ្លួនចាប់យកត្រូវ បារាជិក ។ យកដៃលើកគ្រឿងប្រដាប់មានខ្សែកជាដើមដែលធ្លាក់ចុះទៅ ក្នុងចីវរ ត្រូវបារាជិក, មិនបានលើកឡើងឡើយ តែដើរទៅ ត្រូវបារាជិក ក្នុងជំហានទីពីរ ។ សូម្បីក្នុងគ្រឿងប្រដាប់មានខ្សែ-កជាដើម ដែលធ្លាក់ ចុះទៅក្នុងបាត្រ ក៏មានន័យយ៉ាងនេះឯង ។ យកដៃចាប់យកគ្រឿង ប្រដាប់មានខ្សែក ជាដើម ដែលធ្លាក់ចុះលើសីសៈ ត្រង់មុខ ឬត្រង់ជើង ត្រូវបារាជិក, មិនបានចាប់យកឡើយ តែដើរទៅត្រូវបារាជិកក្នុងជំហានទី

ពីរ គ្រឿងប្រដាប់ជាដើមនោះធ្លាក់ទៅក្នុងទីណា ៗ ចំពោះឱកាសដែលគ្រឿងប្រដាប់ជាដើមតាំងនៅក្នុងទីនោះ ៗ ជាឋានរបស់គ្រឿងប្រដាប់ជាដើមនោះ, អន្តរាយវៈទាំងអស់គឺ បាត្រ និងចីវរក្តី មិនបានជាឋានទេ ដូច្នេះឯង ។

ទ្រព្យដែលនៅក្នុងអាកាស ចប់

## ទ្រព្យដែលស្ថិតនៅលើផ្ទៃ

[៩៤] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលស្ថិតនៅលើផ្ទៃ ។ ភណ្ឌៈដែលគេទុកលើគ្រែនិងតាំងជាដើម ទោះជារបស់គួរចាប់ពាល់ក្តី មិនគួរចាប់ពាល់ក្តី កាលភិក្ខុចាប់ពាល់ដោយថេយ្យចិត្ត ជាទុក្កដ ។ ក៏ឯក្នុងភណ្ឌៈដែលគេទុកលើគ្រែនិងតាំងនេះ គួរជ្រាបវិនិច្ឆ័យតាមន័យដែលពោលទុកក្នុងភណ្ឌៈដែលឋិតនៅលើគោក ។

ចំណែកសេចក្តីប្លែកគ្នា គប្បីជ្រាបដូច្នេះ ៖

បើសំពត់សាដកដែលរឹងព្រោះទឹកបាយ ដែលគេក្រាលទុកលើគ្រែឬតាំង ត្រង់កណ្តាលមិនប៉ះត្រូវផ្ទៃគ្រែ ប៉ះត្រូវតែជើងគ្រែប៉ុណ្ណោះ, គប្បីជ្រាបឋានដោយអំណាចនៃជើងទាំង ៤ របស់គ្រែនោះ ។ ពិតមែនកាលសំពត់សាដកនោះ គ្រាន់តែភិក្ខុឱ្យកន្លងហួសឱកាសដែលប៉ះត្រូវខាងលើនៃជើងគ្រែប៉ុណ្ណោះ ក៏ជាបារាជិក ព្រោះហេតុឱ្យឈានកន្លង

នោះ ។ តែកាលភិក្ខុលួចទៅព្រមទាំងគ្រែ និងតាំង គប្បីជ្រាបឋាន ដោយអំណាចឱកាសដែលជើងគ្រែ និងតាំងឋិតនៅ ។

បទថា ចីវរវំសេ វា : ទ្រព្យដែលពាក់លើឈើស្នៀងសម្រាប់ពាក់ចីវរក្តី មានសេចក្តីថា លើស្នួរឬលើកំណាត់ឈើដែលគេចងតាំងទុកដើម្បីប្រយោជន៍ដល់ការពាក់ចីវរ ។ ចំពោះឱកាសដែលប៉ះត្រូវនឹងឱកាសដែលឋិតនៅ ជាឋាន របស់ចីវរដែលពាក់ទុកលើស្នួរនោះ ដែលយកជាយទុកខាងក្រៅ យកផ្នត់ទុកខាងក្នុង, ស្នួរចីវរទាំងអស់ មិនបានជាឋានទេ ។ ព្រោះហេតុនោះ កាលភិក្ខុចាប់ចីវរនោះត្រង់ផ្នត់ ទាញមកដោយថេយ្យចិត្ត ឱ្យឱកាសដែលឋិតនៅលើស្នួរផ្នែកខាងក្រៅ កន្លងហួសប្រទេសដែលស្នួរចីវរ ប៉ះត្រូវផ្នែកក្នុងទៅ ជាបារាជិក ដោយការទាញមកត្រឹមតែមួយធ្នាប់ ឬពីរធ្នាប់ប៉ុណ្ណោះ(តាមទំហំស្នួរ) ។ ន័យសូម្បីនៃភិក្ខុដែលចាប់ត្រង់ជាយទាញមក ក៏ដូចគ្នានេះ ។ តែកាលភិក្ខុរូតចុះខាងឆ្វេង ឬ ខាងស្តាំលើស្នួរចីវរនោះឯង កាលចីវរនោះត្រឹមតែកន្លងហួសឋាននៃជាយ ខាងស្តាំដោយជាយខាងឆ្វេង ឬត្រឹមតែកន្លងហួសឋាននៃជាយខាងឆ្វេងដោយជាយខាងស្តាំទៅ ជាបារាជិក ដោយការរូតទៅត្រឹមតែ ១០ ធ្នាប់ ឬ ១២ ធ្នាប់ប៉ុណ្ណោះ (តាមប្រវែងចីវរនៅបណ្តោយស្នួរ) ។ កាលភិក្ខុលើកឡើង ជាបារាជិក ដោយការលើកផុតឡើងត្រឹមតែមួយចុងសរសៃសក់ ។ កាលភិក្ខុ ស្រាយចីវរដែលគេយកខ្សែចងព្យួ

ទុក និងប៉ះត្រូវស្នួរចីវរឬមិនប៉ះត្រូវក៏ដោយ ជាថុល្លច្ច័យ, កាលស្រាយចេញហើយ ជាបារាជិក ។ ពិតមែន ចីវរនោះល្មមត្រឹមតែស្រាយចេញប៉ុណ្ណោះ រមែងដល់ការរាប់ថា ផុតពីឋាន ។ កាលភិក្ខុស្រាយចីវរដែលគេចងទុកត្រង់ស្នួរចេញ ជាថុល្លច្ច័យ, កាលចីវរនោះ ត្រឹមតែស្រាយចេញហើយ ក៏ត្រូវបារាជិក ។ កាលចីវរ ដែលគេធ្វើជាក្រវិលរក្សាទុក ភិក្ខុកាត់ក្រវិលចេញក្តី ស្រាយចេញក្តី ដោះចុងស្នួរម្ខាង ហើយរូតចេញក្តី ត្រូវថុល្លច្ច័យ, កាលក្រវិលនោះ គ្រាន់តែដាច់ក្តី គ្រាន់តែស្រាយចេញហើយក្តី គ្រាន់តែរូតចេញហើយក្តី ត្រូវបារាជិក ។ ភិក្ខុមិនបានធ្វើយ៉ាងនោះឡើយ រូតទៅ រូតមកលើស្នួរចីវរ, នៅរក្សាទុកសិន ។ ពិតមែនស្នួរចីវរសូម្បីទាំងអស់ជាឋានរបស់ក្រវិល ។ ព្រោះហេតុអ្វី ? ព្រោះកន្លែងចីវរឃ្លាតទៅលើស្នួរចីវរនោះជាធម្មតា ។ តែបើភិក្ខុយកដៃចាប់ចីវរនោះ ធ្វើឱ្យអណ្តែតទៅក្នុងអាកាស ត្រូវបារាជិក ។ ត្រឹមតែឱកាសដែលត្រូវនឹងឱកាសដែលឋិតនៅ ជាឋានរបស់ចីវរដែលគេពាក់ទុក ។ វិនិច្ឆ័យក្នុងចីវរប្រភេទនោះ គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងចីវរដែលបត់ពាក់ទុក ។ ចំណែកចីវរណា ជារបស់ប៉ះត្រូវផែនដីដោយជាយម្ខាង, ឋានចីវរនោះមាន ២ ឋាន ដោយអំណាចឱកាសដែលប៉ះស្នួរចីវរនិងផែនដី ។ ក្នុងចីវរដែលប៉ះផែនដីដោយជាយម្ខាងនោះ គប្បីជ្រាបវិនិច្ឆ័យ តាមន័យដែលពោលហើយក្នុងសំពត់សាដក

មិនរឹងទ្រនុំឯង ៗ សូម្បីក្នុងខ្សែស្បៀងចីវរ ក៏គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ឯង ៗ ចំណែកភណ្ឌៈដែលគេដាក់ព្យួរទុកលើទំពក់ ទោះជាផ្ទាំងថ្នាំក្តី ថង់ថ្នាំក្តី, បើតាំងនៅមិនប៉ះត្រូវជញ្ជាំងឬផែនដី, កាលភិក្ខុរូតខ្សែសម្រាប់បំពាក់ចេញ កាលភណ្ឌៈនោះត្រឹមតែចេញចាកចុងទំពក់ទៅ, ជាបារាជិក ៗ ខ្សែសម្រាប់ព្យួរជារបស់រឹង កាលភិក្ខុលើកឡើងព្រមទាំងផ្ទាំង ធ្វើឱ្យអណ្តែតទៅក្នុងអាកាស ទោះជាកាលខ្សែដែលពាក់នោះ មិនទាន់របូតចេញចាកចុងទំពក់ក៏ដោយ ក៏ជាបារាជិក ៗ ភណ្ឌៈជារបស់ជាប់នៅនឹងជញ្ជាំង, ភិក្ខុទាញភណ្ឌៈនោះចេញចាកចុងទំពក់គ្រាដំបូង ត្រូវថុល្លច្ច័យ, ដោះឱ្យផុតជញ្ជាំងជាខាងក្រោយ ត្រូវបារាជិក ៗ សូម្បីភិក្ខុដែលដោះឱ្យផុតពីជញ្ជាំងជាដំបូងហើយ ខាងក្រោយទើបនាំចេញចាកទំពក់ ក៏ដូចគ្នានេះ ៗ ក៏បើភិក្ខុមិនអាចដោះភណ្ឌៈដែលធ្ងន់ពេកបាន ទើបធ្វើភណ្ឌៈឱ្យប៉ះជាប់ជញ្ជាំងដោយខ្លួនឯង ហើយដោះចេញពីទំពក់, កាលភណ្ឌៈនោះ សូម្បីភិក្ខុមិនឱ្យឃ្លាតពីជញ្ជាំងក៏ដោយ គ្រាន់តែដោះចេញពីទំពក់បានប៉ុណ្ណោះ ក៏ត្រូវអាបត្តិបារាជិកដែរ, ព្រោះថា ឋានដែលខ្លួនធ្វើមិនចាត់ជាឋាន ៗ តែសម្រាប់ភណ្ឌៈដែលឋិតនៅលើផែនដីមាន ២ ឋានប៉ុណ្ណោះ ៗ វិនិច្ឆ័យក្នុងភណ្ឌៈដែលឋិតនៅលើផែនដីនោះ ខ្ញុំព្រះករុណាបានពោលទុកហើយ ៗ ក៏ឯភណ្ឌៈណា គេដាក់សង្រែក ព្យួរទុក, កាលភិក្ខុស្រាយភណ្ឌៈនោះចេញចាកសង្រែកក្តី ស្រាយភណ្ឌៈនោះទាំង

សង្រែកចេញចាកទំពក់ក្តី ជាបារាជិក ។ សូម្បីសេចក្តីផ្សេងគ្នានៃឋាន ក្នុងភណ្ឌៈ ដែលគេដាក់សង្រែកព្យួរទុកនេះ ក៏គប្បីជ្រាបដូចភណ្ឌៈដែលជាប់ជញ្ជាំងនិងផែនដី ។

ចម្រឹងដែលគេដំជាប់ជញ្ជាំងទុកត្រង់ ៗ ក្តី ខ្នែងដែលកើតក្នុងជញ្ជាំងនោះឯងក្តី ឈ្មោះថា **ភិត្តិខីលេ : លើចម្រឹងជញ្ជាំង** ។ ចំណែកនាគទន្ត ចម្រឹងដែលមានសណ្ឋានដូចភ្លុកដំរី ហៅថា ធ្មេញនាគ គេដំទុកត្រង់ជញ្ជាំងដូចគ្នា ។ ភណ្ឌៈដែលគេព្យួរទុកលើចម្រឹងជញ្ជាំងនិងធ្មេញនាគនោះ គប្បីជ្រាបវិនិច្ឆ័យតាមន័យដែលពោលហើយ ក្នុងភណ្ឌដែលព្យួរទុកលើទំពក់ ។ ក៏លំពែង ឬចម្រុង ឬស្នូរ ដែលគេលើកឡើង ពាក់ទុកលើចម្រឹងជញ្ជាំង ឬធ្មេញនាគ ២-៣ ដែលជាប់រៀងគ្នាជាលំដាប់ ភិក្ខុចាប់ត្រង់ចុង ឬត្រង់ដងទាញមក ត្រឹមតែឱកាសដែលចម្រឹងជញ្ជាំង ឬធ្មេញនាគណាមួយពាល់ត្រូវ កន្លងទៅប៉ុណ្ណោះ ត្រូវបារាជិក ។ ព្រោះថា ត្រឹមតែឱកាសដែលប៉ះត្រូវប៉ុណ្ណោះ រមែងជាឋានរបស់លំពែង ចម្រុង និងស្នូរទាំងនោះ, ចម្រឹងជញ្ជាំងឬធ្មេញនាគទាំងអស់ មិនចាត់ជាឋាន ។ ភិក្ខុឈរបែរមុខចូលជញ្ជាំង ចាប់ត្រង់កណ្តាលទាញមក ត្រឹមតែចំណែកផ្នែកក្រៅ កន្លងហួសឱកាសដែលចំណែកផ្នែកក្នុងពាល់ត្រូវ ត្រូវបារាជិក ។ សូម្បីកាលភិក្ខុរំកិលទៅខាងមុខ ក៏មានន័យដូចគ្នានេះ ។ កាលភិក្ខុយកដៃចាប់លើកឡើង ធ្វើឱ្យ

អណ្តែតទៅក្នុងអាកាស សូម្បីត្រឹមតែមួយចុងសក់ ត្រូវបារាជិក ។ ភិក្ខុទាញលំពែងជាដើមនោះដែលគេដាក់ទុកជាប់ជញ្ជាំង កោសជញ្ជាំងមក, កាលលោកឱ្យគល់កន្លងហួសឱកាសដែលចុង( លំពែង )ប៉ះត្រូវ ឬឱ្យចុងកន្លងហួស ឱកាសដែលគល់ប៉ះត្រូវទៅ ត្រូវបារាជិក ។ ភិក្ខុឈរបែរមុខចូលជញ្ជាំង ទាញមកឱ្យផ្នែកទីបំផុត ខាងជទែកន្លងហួសឱកាសដែលផ្នែកម្ខាងទៀតប៉ះត្រូវទៅ ត្រូវបារាជិក កាលលើកឡើងត្រង់ ៗ ។ ធ្វើឱ្យអណ្តែតទៅក្នុងអាកាសត្រឹមតែមួយចុងសក់ ត្រូវអាបត្តិបារាជិក ។

ពីរបទថា រុក្ខេ វា លគ្គិតំ : ដែលគេព្យួរទុកលើដើមឈើក្តីបានដល់ ភណ្ឌៈដែលគេលើកឡើងព្យួរទុកត្រង់ដើមត្នោតជាដើម ។ គប្បីជ្រាបវិនិច្ឆ័យតាមន័យដែលពោលហើយ ក្នុងភណ្ឌៈដែលព្យួរទុកលើទំពក់ជាដើម ។ ក៏ឯកាលភិក្ខុអង្រួនធ្លាយត្នោតដែលកើតនៅលើដើមត្នោតនោះ វត្ថុនៃបារាជិកនឹងពេញក្នុងផ្លែណា កាលផ្លែនោះគ្រាន់តែជ្រុះចាកទងត្រូវអាបត្តិបារាជិក ។ ភិក្ខុកាត់ធ្លាយត្នោត ត្រូវអាបត្តិបារាជិក ។ ចំណែកធ្លាយត្នោតដែលគេលើកឡើង យកចុងពាក់ទុកក្នុងបង្គាបស្លឹកបាន ២ ឋាន គឺ ឋានដែលពាក់ទុក ១ ឋានគឺ ទង ១ ។ វិនិច្ឆ័យក្នុង ២ ឋាននោះ គប្បីជ្រាបតាមន័យដែលពោលហើយ ។ ចំណែកភិក្ខុណាលើកចុងពាក់លើបង្គាបស្លឹកហើយទើបកាត់ ព្រោះខ្លាចថា "ល្មមកាត់ដាច់

ធ្លាក់ចុះមក ទីងលាន់ឮសំឡេងខ្លាំង ត្រឹមតែកាត់សម្រេច, ភិក្ខុនោះ ត្រូវអាបត្តិបារាជិក ។ ព្រោះថា ឋានដែលខ្លួនធ្វើ មិនចាត់ជាឋាន ។ ក្នុងផ្កានិងផ្លែរបស់ដើមឈើទាំងពួង គប្បីជ្រាបវិនិច្ឆ័យដោយឧបាយនេះ ។

ក្នុងពាក្យថា **បត្តាធារកេបិ : ទ្រព្យដែលគេតម្កល់ទុកលើជើងបាត្រក៏ដោយ** នេះ មានវិនិច្ឆ័យដូច្នេះ ៖

ទោះជាជើងឈើក្តី ជើងវេទ្ធង់កងក្តី ជើងកំណាត់ឈើក្តី ដែលតម្កល់បាត្រប្រភេទណាមួយ សូម្បីជាព្រំក៏ដោយ គ្រប់យ៉ាងដល់ការរាប់ថា ជើងទ្របាត្រទាំងអស់ ត្រឹមតែឱកាសដែលពាល់ត្រូវនុ៎ះឯង ជាឋានរបស់បាត្រដែលគេតាំងទុកលើជើងទ្របាត្រនោះ ។ ក្នុងជើងឈើរបស់បាត្រនោះ មានកំណត់ឋានដោយអាការ ៥ យ៉ាង ។ ភិក្ខុចាប់បាត្រដែលឋិតនៅលើជើងឈើនោះ ត្រង់កណ្តាប់មាត់ ហើយទាញទៅម្ខាងក្នុងបណ្តាទិសទាំង ៤ ក្នុងចំណែកខាងជទែកនូវហួស ឱកាសដែលចំណែកមួយខាង ៗ ប៉ះត្រូវទៅ ត្រូវអាបត្តិបារាជិក ។ កាលលើកឡើងខាងលើត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។ តែគប្បីឱ្យវាយតម្លៃរបស់ពិន័យអាបត្តិគ្រប់កន្លែង ។ សូម្បីកាលភិក្ខុលួចបាត្រទៅព្រមទាំងជើងទ្រ ក៏មានន័យនេះដូចគ្នា ដូច្នេះឯង ។

ទ្រព្យដែលឋិតនៅលើធ្មេ ចប់

## ទ្រព្យដែលឋិតនៅក្នុងទឹក

[៩៥] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅក្នុងទឹក ៖

ប្រើនបទថា **ឧទកេ និក្ខិត្តំ ហោតិ : ភណ្ឌដែលគេតម្កល់ទុកក្នុងទឹក** សេចក្តីថា ភណ្ឌៈដែលពួកជនខ្លាចរាជភ័យជាដើម ធ្វើឱ្យជារបស់បិទបាំងល្អហើយបណ្តាវត្ថុទាំងឡាយ មានភាជន៍ទង់ដែង និងលោហៈជាដើម ដែលមិនវិនាសទៅដោយទឹកជាធម្មតា ហើយរក្សាទុកក្នុងទឹកដែលទឹងថ្កល់ ក្នុងស្រះបោក្ខរណីជាដើម ។ ឱកាសដែលភណ្ឌៈនោះឋិតនៅ ជាឋានរបស់ទ្រព្យដែលឋិតនៅក្នុងទឹកនោះ, ទឹកទាំងអស់ មិនចាត់ជាឋានទេ ។

ប្រើនបទថា **គច្ឆតិ វា អាបត្តិ ទុក្កដស្ស : ដើរទៅតែម្នាក់ឯងក្តី ត្រូវអាបត្តិទុក្កដ** សេចក្តីថា កាលភិក្ខុដើរទៅក្នុងទឹកដែលមិនជ្រៅ ជាទុក្កដគ្រប់ ៗ ជំហាន ។ ក្នុងទឹកជ្រៅកាលធ្វើសេចក្តីព្យាយាមដោយដៃ ឬដោយជើងក្តី ធ្វើសេចក្តីព្យាយាមទាំងដៃនិងជើងក្តី ជាទុក្កដគ្រប់ប្រយោគ ។ សូម្បីក្នុងការមុជចុះនិងងើបឡើង ដើម្បីលួចយកឆ្នាំង ក៏មានន័យដូចគ្នានេះ ។ តែបើភិក្ខុឃើញភ័យយ៉ាងណាមួយ នឹងជាពស់ទឹកក្តី ត្រីកាចក្តី ខ្លាចហើយក៏ចៀសចេញទៅ ក្នុងចន្លោះ មិនជាអាបត្តិ ។ ក្នុងអាការមានចាប់ប៉ះត្រូវជាដើម គប្បីជ្រាបវិនិច្ឆ័យដោយ

ន័យដែលពោលហើយក្នុងឆ្នាំងដែលនៅក្នុងផែនដីនុ៎ះឯង ។

ចំណែកសេចក្ដីប្លែកគ្នា មានដូចតទៅនេះ ៖

ក្នុងកថាពោលអំពីភណ្ឌដែលតាំងនៅក្នុងផែនដីនោះ ភិក្ខុជីកអូសទៅលើផែនដី, ក្នុងកថានៃភណ្ឌនៅក្នុងទឹកទាំងនេះ ភិក្ខុសង្កត់ឱ្យលិចចុះក្នុងភក់ ។ សេចក្ដីកំណត់ឋាន រមែងកើតបានដោយអាការ ៦ ដោយប្រការដូច្នេះ ។ ក្នុងផ្កាឧប្បលជាដើម វត្ថុនៃបារាជិកនឹងគ្រប់ក្នុងផ្កាណា, កាលផ្កានោះត្រឹមតែភិក្ខុក្ដិចហើយ ត្រូវអាបត្តិបារាជិក ។ ក៏បណ្ដាជាតិផ្កាឈូកទាំងនេះ សំបកឈូកសូម្បីនៅម្ខាង ៗ នៃឧប្បលជាតិទាំងឡាយមិនទាន់ដាច់ទៅត្រឹមណា, នៅរក្សាត្រឹមនោះ ។ ចំណែកបទុមជាតិកាលទងដាច់ហើយ សរសៃខាងក្នុងសូម្បីមិនទាន់ដាច់ ក៏រក្សាទុកមិនបាន, ផ្កាឧប្បលជាដើមដែលម្ចាស់របស់កាត់ទុក, ផ្កាណា នឹងញ៉ាំងវត្ថុបារាជិកឱ្យគ្រប់បាន កាលផ្កានោះដែលភិក្ខុលើកឡើងហើយ ក៏ជាបារាជិក ។ ផ្កាឧប្បលជាដើម ជារបស់ដែលគេចងជាបាច់ ៗទុក, វត្ថុបារាជិកនឹងគ្រប់ក្នុងបាច់ណា, កាលបាច់នោះ ដែលភិក្ខុលើកឡើង ត្រូវបារាជិក ។ ផ្កាឧប្បលជាដើម ជារបស់ចងជាបាច់ធំទុក[១], កាលភិក្ខុធ្វើបាច់ធំនោះឱ្យឃ្លាតចាកឋាន ដោយអាការយ៉ាងណាមួយ នៃអាការ ៦ ត្រូវបារាជិក

១. ដីកាថា. ចងផ្កា១០ ជាបាច់ ហៅថា ហត្ថកៈ ចងជាបាច់ធំ ហៅថា ភារពទ្ធ ។

តាមន័យដែលពោលហើយក្នុងឆ្នាំងដែលឋិតនៅលើផែនដី ផ្កាឧប្បលជាដើម មានទងវែងដែលគេចងត្រង់ផ្កាឬត្រង់ទងឱ្យជាបាច់ ក្រោលស្មៅលើខ្សែ លើផ្ទៃទឹកតម្កល់ទុក ឬចងទុក, កំណត់ការឱ្យឃ្លាតចាកឋានផ្នែផ្កាឧប្បលជាដើមទាំងនោះ គប្បីជ្រាបដោយអាការ ៦ យ៉ាង គឺ ផ្នែកបណ្តោយ កំណត់ ដោយចុងផ្កានិងទីបំផុតទង ផ្នែកទទឹង កំណត់ដោយទីបំផុតទាំងពីរខាង ខាងក្រោម កំណត់ដោយឱកាសដែលតាំងនៅ ខាងលើកំណត់ដោយខ្នងនៃផ្កាដែលនៅខាងលើ ។ សូម្បីភិក្ខុណា ធ្វើទឹកឱ្យកម្រើក ឱ្យរលកកើតឡើង ញុំាងបាច់ផ្កាឈើដែលគេដាក់ទុកលើផ្ទៃទឹកឱ្យឃ្លាតចាកឋានដែលឋិតនៅពីដើម សូម្បីត្រឹមតែ១ចុងសរសៃសក់, ភិក្ខុនោះត្រូវបារាជិក ។ តែបើលោកកំណត់ចំណាំទុកថា ដល់ទីនេះហើយយើងនឹងកាន់យក ដូច្នេះ នៅរក្សាទុកសិន ។ កាលលោកលើកឡើងក្នុងទីដែលបាច់ផ្កាឈើអណ្តែតទៅដល់ហើយ ជាអាបត្តិបារាជិក ។ ទឹកទាំងអស់ជាឋានរបស់ផ្កាឈើដែលឡើងផុតទឹកហើយ ។ កាលភិក្ខុដកផ្កាឈើនោះ លើកឡើងត្រង់ ៗ កាលទីបំផុតរបស់ទងផុតចាកទឹកត្រឹមតែមួយចុងសរសៃសក់ ត្រូវអាបត្តិបារាជិក ។ ភិក្ខុចាប់ផ្កាឈើឱ្យទ្រេតទៅ ហើយទាញមកខាង ៗ ទើបដកឡើង, ទឹកមិនជាឋាន; កាលផ្កាឈើនោះ ត្រឹមតែភិក្ខុដកឡើងហើយ ក៏ត្រូវអាបត្តិបារាជិក ។ ក្នុងអដ្ឋកថា មហាបច្ចរីជាដើម លោកពោលពីរពាក្យនេះទុកថា ផ្កាឈើ

ដែលចងជាបាច់ ៗ គេចងទុកក្នុងទីជិតទឹក ឬត្រង់ដើមឈើ ឬត្រង់ជន្លត់ឈើ, កាលភិក្ខុមិនស្រាយចំណងចេញ ធ្វើឱ្យអណ្តែតទៅខាងណេះខាងណោះ ត្រូវអាបត្តិថុល្លច្ច័យ ។ កាលចំណងត្រឹមតែរបូតចេញ ត្រូវអាបត្តិបារាជិក ។ ភិក្ខុស្រាយចំណងមុនហើយនាំទៅ ពេលក្រោយ ក្នុងផ្កាឈើដែលគេចងទុកនេះ កំណត់ឋានដោយអាការ ៦ យ៉ាង ។

សម្រាប់ភិក្ខុដែលប្រាថ្នានឹងកាន់យកផ្កាបទុមក្នុងគុម្ពបទុម ព្រមទាំងគុម្ព គប្បីជ្រាបកំណត់ឋានខាងលើ និងផ្នែកទទឹង និងផ្នែកបណ្តោយដោយអំណាចនៃទឹកដែលទងផ្កា និងទងស្លឹកពាល់ត្រូវ ។ មួយទៀត កាលលោកមិនទាន់បានដកគុម្ពបទុមនោះឡើង តែទាញផ្កាឬស្លឹកមកចំពោះមុខខ្លួន ត្រូវអាបត្តិថុល្លច្ច័យ, លុះដកឡើង ត្រូវអាបត្តិបារាជិក ។ កាលលោកសូម្បីមិនញ៉ាំងទងផ្កា និងទងស្លឹកឱ្យឃ្លាតចាកឋាន ដកគុម្ពបទុមឡើងមុន ត្រូវអាបត្តិថុល្លច្ច័យ, កាលទងនៃផ្កានិងស្លឹកលោកឱ្យឃ្លាតចាកឋាន ក្នុងខាងក្រោយ ត្រូវអាបត្តិបារាជិក ។ ចំណែកភិក្ខុអ្នកកាន់យកផ្កាក្នុងគុម្ពបទុមដែលគេដកឡើងទុកហើយ គប្បីឱ្យវាយតម្លៃភណ្ឌៈពិន័យអាបត្តិ ។ សូម្បីក្នុងផ្កាដែលគេគរទុក ដែលចងទុកជាបាច់តូច និងដែលចងជាបាច់ធំដែលដាក់ខាងក្រៅស្រះ មានន័យដូចគ្នានេះ ។ ក្រអៅឈូកឬមើមឈូក វត្ថុបារាជិកគ្រប់ដោយក្រអៅ ឬមើមណា, កាលភិក្ខុដកក្រអៅឬមើមនោះឡើង ត្រូវអាបត្តិបារាជិក ។ ក៏ក្នុងក្រអៅ និងមើមឈូកនេះ គប្បី

កំណាត់ឋានដោយអំណាចឱកាសដែលភក់ប៉ះត្រូវ ។ ក្នុងមហាអដ្ឋកថានុ៎ះ ឯង លោកពោលទុកថា កាលភិក្ខុដកក្រអៅ និងមើមឈូកទាំងនោះឡើង សូម្បីសរសៃឫសដែលនៅមិនទាន់ដាច់ ក៏នៅរក្សា ។ ស្លឹកក្តី ផ្កាក្តី កើតត្រង់ថ្នាំងក្រអៅឈូកមាន សូម្បីស្លឹក និងផ្កានោះ ក៏នៅរក្សា ដូច្នេះ ក៏ឯត្រង់ពកក្រអៅឈូកមានបន្លា ដូចគ្រាប់មុនលើមុខរបស់ពួកមនុស្សកំពុងពេញវ័យកម្លោះក្រមុំ ដូច្នោះ បន្លានេះរក្សាមិនបាន ព្រោះមិនមែនជារបស់វែង ។ ពាក្យដ៏សេស មានន័យដូចពោលទុកហើយក្នុងផ្កាឧប្បលជាដើមនុ៎ះឯង ។ ទឹកទាំងអស់ ក្នុងជលាល័យទាំងឡាយ មានបឹងជាដើម ជាឋានរបស់ត្រី និងអណ្តើកដែលមានម្ចាស់ ។ ព្រោះហេតុនោះ ភិក្ខុណាយកសន្ទូចក្តី សំណាញ់ក្តី ទ្រូក្តី ដៃក្តី ចាប់យកត្រីដែលមានម្ចាស់ ក្នុងទីដែលគេនៅរក្សា, វត្ថុបារាជិក នឹងគ្រប់ដោយត្រីណា, កាលត្រីនោះ ដែលភិក្ខុលើកឡើងពីទឹកសូម្បីត្រឹមតែមួយចុងសរសៃសក់ ភិក្ខុនោះ ត្រូវអាបត្តិបារាជិក ។ ត្រីខ្លះកាលត្រូវចាប់ រត់ទៅទីឯណោះ និងទីឯណេះ លោតឡើងទៅកាន់អាកាស ធ្លាក់ចុះទៅត្រង់មាត់ច្រាំង, សូម្បីកាលភិក្ខុចាប់យកត្រីដែលនៅក្នុងអាកាស ឬដែលធ្លាក់ទៅត្រង់មាត់ច្រាំងនោះ ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។ កាលភិក្ខុចាប់យកសូម្បីអណ្តើកដែលវារទៅរកអាហារស៊ីខាងក្រៅម៉ាត់ស្រះ ក៏មានន័យដូចគ្នានេះ ។ ក៏កាលភិក្ខុ ឱ្យសត្វទឹកផុតពីទឹក ត្រូវអាបត្តិបារាជិក ។

## សម័យក្រោយពុទ្ធកាលពួកជនជីកស្រះចិញ្ចឹមត្រី

ជនទាំងឡាយក្នុងជនបទនោះ ៗ អាស្រ័យលូសម្រាប់បង្ហូរទឹករបស់ស្រះធំដែលទូទៅដល់ជនទាំងពួង ជីកប្រឡាយធំដូចស្ទឹងតូចដែលទូទៅដល់ជនទាំងពួងដូចគ្នា ។ ពួកគេបានជីកប្រឡាយតូច ៗ អំពីប្រឡាយធំនោះទៅ ហើយជីកជាអណ្ដូងទុកនៅចុងប្រឡាយ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់របស់ខ្លួន ៗ ។ និងជនទាំងនោះមានសេចក្ដីត្រូវការទឹកក្នុងវេលាណា ក្នុងវេលានោះ ទើបជម្រះប្រឡាយតូចក្នុងអណ្ដូង និងព្រែកឱ្យស្អាត ហើយបើកអូសម្រាប់បង្ហូរទឹកទៅ ។ ត្រីទាំងឡាយចេញចាកស្រះធំនោះ ព្រមជាមួយនឹងទឹក ទៅដល់អណ្ដូងដោយលំដាប់ហើយនៅ ។ បណ្ដាស្រះធំជាដើមនោះ ជនទាំងឡាយមិនហាមអ្នកដែលចាប់ត្រីក្នុងស្រះ និងប្រឡាយធំនោះ ។ តែមិនព្រម គឺ ហាមមិនឱ្យចាប់ត្រីទាំងឡាយដែលចូលទៅក្នុងប្រឡាយ និងអណ្ដូងទឹកតូច ៗ របស់ខ្លួន ៗ ។

## ការចាប់យកត្រីដែលគេចិញ្ចឹម

បណ្ដាស្រះជាដើមទាំងនោះ ភិក្ខុណាចាប់ត្រីក្នុងទីទាំងនោះ ក្នុងស្រះឬក្នុងប្រឡាយសម្រាប់បង្ហូរទឹក ឬ ក្នុងប្រឡាយធំ, ភិក្ខុនោះ ដែលព្រះវិន័យធរគប្បីឱ្យពិន័យអាបត្តិដោយអវហារ ។ តែកាលចាប់ត្រីដែលចូលទៅក្នុងប្រឡាយតូច ឬក្នុងអណ្ដូងហើយ គប្បីពិន័យអាបត្តិដោយ

អំណាចនៃតម្លៃត្រីដែលចាប់បាន ។ បើត្រីដែលកំពុងត្រូវចាប់ ពីប្រឡាយតូចនិងអណ្ដូងទឹកនោះ លោតឡើងទៅក្នុងអាកាស ឬធ្លាក់ចុះមកមាត់ច្រាំង, កាលភិក្ខុចាប់យកត្រីនោះ ដែលនៅក្នុងអាកាស ឬនៅលើមាត់ច្រាំងផុតពីទឹកហើយ អវហារ មិនមាន, ព្រោះហេតុអ្វី ? ព្រោះហេតុថា ជនទាំងនោះជាម្ចាស់របស់ត្រី ដែលនៅក្នុងទីហួងហែងរបស់ខ្លួនប៉ុណ្ណោះ ។ ពិតមែន កតិកា បែបនេះ ជាកតិកាក្នុងជនបទទាំងនោះ ។ សូម្បីក្នុងអណ្ដើក ក៏មានន័យនេះដូចគ្នា ។ បើត្រីដែលភិក្ខុកំពុងចាប់ហែលឡើងពីអណ្ដូងទៅចុះអូរ, សូម្បីភិក្ខុចាប់ត្រីនោះ ក្នុងអូរនោះ ក៏ជាអវហារពិត ។ តែមិនជាអវហារដល់ភិក្ខុចាប់ត្រីដែលហែលឡើងចាកប្រឡាយតូចទៅចុះប្រឡាយធំ និងដែលហែលឡើងចាកប្រឡាយទឹកនោះទៅចុះស្រះហើយ ។ ភិក្ខុយកគ្រាប់បាយបញ្ឆោតត្រីពីអណ្ដូងទៅឡើងប្រឡាយហើយចាប់យក, ជាអវហារដល់ភិក្ខុនោះពិត ។ តែមិនជាអវហារដល់ភិក្ខុដែលបញ្ឆោតឱ្យចេញពីប្រឡាយនោះ ទៅប្រឡាយធំហើយចាប់យក ។ ពួកជនខ្លះ នាំយកត្រីចាកទីសាធារណៈដល់ជនទាំងពួង កន្លែងខ្លះទុំះឯង ឃាំងចិញ្ចឹមទុកក្នុងអណ្ដូងទឹកឯក្រោយស្ងួន ហើយសម្លាប់មួយថ្ងៃ ៗ ២-៣ ដើម្បីប្រយោជន៍ដល់សម្លរាល់ថ្ងៃ ។ កាលភិក្ខុចាប់ត្រីបែបនោះ ដែលនៅក្នុងទឹក ឬលើអាកាស ឬមាត់ច្រាំងកន្លែងណាមួយ ជាអវហារពិត ។ សូម្បីក្នុងអណ្ដើក ក៏មានន័យដូចគ្នានេះ ។

ក៏ក្នុងវជ្ជវប្រាំង ក្រសែទឹកក្នុងទន្លេដាច់អស់ ទឹក រមែងឃាំងនៅក្នុងទឹកន្លែងទំនាបខ្លះ ។ មនុស្សទាំងឡាយពោយផ្លែឈើស្អុយរលួយ និងថ្នាំពិសជាដើមចុះ ដើម្បីឱ្យត្រីទាំងឡាយវិនាស ក្នុងទំនាបទឹកនោះហើយចេញទៅ ។ ត្រីទាំងឡាយ ស៊ីផ្លែឈើស្អុយរលួយ និងថ្នាំពិសជាដើមទាំងនោះ ហើយស្លាប់ផ្ងារពោះអណ្តែតនៅលើទឹក ។ ភិក្ខុណាទៅក្នុងទីនោះហើយ ចាប់យកដោយធ្វើទុកក្នុងចិត្តថា ម្ចាស់របស់មិនទាន់មកត្រឹមណា, យើងនឹងចាប់យកត្រី ទាំងនេះត្រឹមនោះ, ភិក្ខុនោះ ព្រះវិន័យធរគប្បីពិន័យអាបត្តិតាមតម្លៃ ។ កាលលោក កាន់យកដោយបង្សុកូលសញ្ញាមិនជាអវហារ ។ តែកាលម្ចាស់ត្រីឱ្យនាំមកជាភណ្ឌទេយ្យ ។ មនុស្សទាំងឡាយពោយថ្នាំពិសបំពុលត្រី ហើយនាំគ្នាត្រឡប់ទៅនាំភាជនៈមកដាក់ឱ្យពេញហើយ ។ ពួកគេនៅមានអាល័យថា ពួកយើងនឹងត្រឡប់មកសូម្បីទៀត ត្រឹមណា, ត្រីទាំងនោះ ចាត់ថា ជាត្រីមានម្ចាស់ត្រឹមនោះ ។ តែកាលណា ពួកគេអស់អាល័យ ចៀសចេញទៅដោយដាក់ចិត្តថា "ពួកយើង ល្មមហើយ", ចាប់តាំងពីនោះទៅ ជាទុក្កដដល់ភិក្ខុដែលកាន់យកដោយថេយ្យចិត្ត, មិនជាអាបត្តិដល់ភិក្ខុដែលមានបង្សុកូលសញ្ញា ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងជាតិសត្វទឹកសូម្បីគ្រប់ប្រភេទដូចក្នុងត្រីនិងអណ្តើក ។

ទ្រព្យដែលតាំងនៅក្នុងទឹក ចប់

## ទ្រព្យដែលឋិតនៅក្នុងទូក

[៩៦] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅក្នុងទូក ៖

ព្រះមានព្រះភាគកាលនឹងសម្ដែងទូកជាលំដាប់ដំបូងសិន ទើបត្រាស់ថា **នាវា នាម យាយ តរតិ** : គេឆ្លង(នូវទីមានទឹកមានស្ទឹងនិងទន្លេជាដើម) ដោយរបស់អ្វី របស់នោះ ឈ្មោះថា ទូក ដូច្នេះ ៗ ព្រោះហេតុនោះ ក្នុងអធិការពោលអំពីទ្រព្យនៅក្នុងទូកនេះ ដោយហោចទៅសូម្បីស្នូកជ្រលក់សំពត់ក្ដី សូម្បីបាច់ឫស្សី(ក្បូន)ក្ដី គប្បីជ្រាបថា ទូកទាំងអស់ ៗ ចំណែកក្នុងការសន្មតសីមា ទូកប្រចាំដែលគេជាប់ខាងក្នុងឬតដោយផែនក្ដារ ចាត់ធ្វើទុក ដោយកំណត់យ៉ាងទាបបំផុត ដាក់មនុស្សបាន ៣ នាក់ប៉ុណ្ណោះ ទើបប្រើបាន ៗ តែក្នុងអធិការពោលអំពីទ្រព្យនៅក្នុងទូកនេះ ផ្ទុកមនុស្សបានសូម្បីម្នាក់ លោកក៏ហៅថា ទូក ដូចគ្នា ៗ

ពីរបទថា **នាវាយ និក្ខិត្តំ** : ទ្រព្យដែលគេដាក់ទុកក្នុងឬលើទូកណ្ឌៈយ៉ាងណាមួយ ជាប់នឹងទូកក៏ដោយ មិនជាប់នឹងទូក ក៏ដោយ ឈ្មោះថា ភណ្ឌៈដែលរក្សាទុកក្នុងទូក ៗ លក្ខណៈការលួចភណ្ឌៈដែលរក្សាទុកក្នុងទូកនោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងភណ្ឌៈដែលឋិតនៅលើគោកនុ៎ះឯង ៗ ការស្វែងរកសម្លាញ់ ការដើរទៅ ការចាប់ត្រូវនិងការធ្វើឱ្យកម្រើក ក្នុងពាក្យជាដើមថា **នាវំ អវហរិស្សាមិ** : អញ

នឹងលួចយកទូក មានន័យដូចពោលហើយនុ៎ះឯង ។

ចំណែកក្នុងពាក្យថា ពន្ធនំ មោចេតិ : ស្រាយចំណង នេះ មានវិនិច្ឆ័យដូច្នេះ ៖

ទូកណា កាលស្រាយចំណងហើយ ក៏មិនទាន់ឃ្លាតចាកឋាន, ចំណងរបស់ទូកនោះ នៅស្រាយមិនចេញត្រឹមណា ជាអាបត្តិទុក្កដត្រឹមនោះ, តែកាលស្រាយចេញហើយ ជាអាបត្តិថុល្លច្ច័យក៏មាន ជាអាបត្តិបារាជិកក៏មាន ។ ពាក្យនោះ នឹងមានច្បាស់ខាងមុខ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។ ពណ៌នាចំពោះបាលីមានប៉ុណ្ណោះឯង ។

ចំណែកវិនិច្ឆ័យក្រៅបាលី ក្នុងរឿងភណ្ឌ ដែលនៅក្នុងទូកនេះ មានដូចតទៅនេះ ៖

សម្រាប់ទូកដែលចងចតទុកក្នុងត្រសែទឹកហូរ មានឋានតែមួយ គឺចំណងប៉ុណ្ណោះ ។ កាលចំណងនោះ ត្រឹមតែស្រាយចេញហើយ ត្រូវអាបត្តិបារាជិក ។ សេចក្តីប្រកបក្នុងចំណងនោះ បានពោលទុកក្នុងខាងដើមនុ៎ះឯង ។ ចំណែកក្នុងទូកដែលគេពន្លិចទុក លិចទៅតាំងនៅរហូតដល់ទីជម្រៅនៃទឹកណា ៗ ទីជម្រៅនៃទឹកនោះ ៗ ជាឋានរបស់ទូកនោះ ។ ព្រោះហេតុនោះ ។ កាលភិក្ខុស្ទាទូកនោះឡើងខាងលើក្តី សង្កត់ឱ្យលិចចុះក្នុងខាងក្រោមក្តី ឱ្យកន្លងហួសឱកាសដែលទូកពាល់ត្រូវក្នុង

ទិសទាំង ៤ ទៅក្តី ក៏ជាបារាជិកក្នុងខណៈដែលល្មមហួសទៅ ។ ទូកមិនបានចង ចតនៅតាមធម្មតារបស់ទូកក្នុងទឹកដែលនឹងថ្កល់ កាលភិក្ខុចាប់ទាញ ទៅខាងមុខក្តី ទៅខាងក្រោយក្តី ខាងឆ្វេងនិងខាងស្តាំក្តី កាលគ្រាន់តែចំណែកដែលឋិតនៅក្នុងទឹកម្ខាងទៀត កន្លងឱកាសដែលចំណែកមួយខាងពាល់ត្រូវទៅ ជាបារាជិក ។ កាលលើកខាងលើឱ្យផុតពីទឹកត្រឹមតែមួយចុងសរសៃសក់ ជាបារាជិក កាលសង្កត់ខាងក្រោមឱ្យកណ្តាប់មាត់កន្លងហួសឱកាសត្រង់ ផ្ទៃបាទទូកពាល់ត្រូវទៅ ជាបារាជិក ។ សម្រាប់ទូកដែលចងទុកមាត់ប្រាំងចតនៅក្នុងទឹកដែលនឹងថ្កល់ មានឋាន ២ គឺ ចំណង ១ ឱកាសដែលចត ១ ។ ភិក្ខុស្រាយទូកនោះចេញពីចំណងមុន ត្រូវថុល្លច្ច័យ, កាលខាងក្រោយឱ្យឃ្លាតចាកឋានដោយបណ្តាអាការ ៦ យ៉ាងណាមួយ ត្រូវអាបត្តិបារាជិក ។ សូម្បីក្នុងការឱ្យឃ្លាតចាកឋានមុន ស្រាយចំណងពេលក្រោយ ក៏មានន័យដូចគ្នានេះ ។ ឱកាសដែលពាល់ត្រូវ ជាឋានរបស់ទូកដែលលើកឡើងផ្ងារទុកលើគោក ។ កំណត់ឋានរបស់ទូកនោះ គប្បីជ្រាបដោយអាការ ៥ យ៉ាង ។ តែឱកាសត្រង់កណ្តាប់មាត់ពាល់ត្រូវប៉ុណ្ណោះ ជាឋានរបស់ទូកដែលគេដាក់ផ្កាប់ទុក ។ អ្នកសិក្សា គប្បីជ្រាបការកំណត់ឋានរបស់ទូកសូម្បីនោះទៅដោយអាការ ៥ យ៉ាង ហើយជ្រាបថា ជាអាបត្តិបារាជិកក្នុងកាលទូកត្រឹមតែកន្លងហួសឱកាសម្ខាងដែលពាល់ត្រូវ និងខាងលើទៅ

ត្រឹមតែមួយចុងសរសៃសក់ ។ ក៏ឯឱកាសដែលឈើកំណល់ពាល់ត្រូវប៉ុណ្ណោះ ជាឋានរបស់ទូកដែលគេអូស ឡើងគោកហើយដាក់លើឈើកំណល់ពីរកំណាត់ ។ ព្រោះដូច្នោះ វិនិច្ឆ័យក្នុងទូកដែលគេដាក់លើឈើកំណល់នោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងសំពត់សាជកសាច់រឹងដែលពាក់ទុកលើជើងគ្រែ និងក្នុងចម្រូង ស្នួរដែលគេពាក់ទុកលើជណ្ដើរកែវ ។ តែកាលទូកចងខ្សែទុក មិនមែនត្រឹមតែឱកាសដែលពាល់ត្រូវប៉ុណ្ណោះ ជាឋាននៃទូកដែលគេមិនទាន់បាន ស្រាយខ្សែដែលវែងប្រមាណ ៦០ ឬ ៧០ ព្យាម (១២០ឬ១៤០ម៉ែត្រ) ទុកឡើយ ហើយអូសមកឱ្យជាប់នឹងផ្ទៃដីតាំងទុកលើគោកព្រមទាំងខ្សែ, ពិតហើយ គប្បីជ្រាបថា ផ្ទៃកបណ្ដោយត្រឹមតែទីខាងក្រោយរបស់ឱកាសដែលទូកតាំងនៅលើផែនដី តាំងពីចុងខ្សែមកជាឋាន ចំណែកផ្ទៃកទទឹងប្រមាណទីបំផុតខាង ៗ នៃទូកនិងខ្សែដែលនៅលើផែនដី ជាឋាន ។ កាលភិក្ខុអូសទាញទូកនោះទៅតាមបណ្ដោយក្ដី តាមទទឹងក្ដី ល្មមត្រឹមតែឱ្យចំណែកដែលទល់ដី ម្ខាងទៀតកន្លងឱកាសដែលចំណែកមួយខាងប៉ះត្រូវ ជាអាបត្តិបារាជិក, កាលលើកឡើងខាងលើឱ្យផុតពីផែនដីព្រមទាំងខ្សែ ត្រឹមតែមួយចុងសរសៃសក់ ជាអាបត្តិបារាជិក ។

មួយទៀត ភិក្ខុណា មានថេយ្យចិត្ត ឡើងទៅកាន់ទូកដែលចតនៅត្រង់កំពង់ ប្រើថ្នោលឬច្រវាធ្វើឱ្យរសាត់ទៅ, ភិក្ខុនោះ ត្រូវអាបត្តិ

បារាជិក ។ តែបើភិក្ខុបើកឆត្រ ឬយកជើងទាំងពីរ ជាន់ចីវរ និងយកដៃទាំងពីរលើកត្រដាងឡើងធ្វើជាក្ដោងទូកឱ្យបាំងខ្យល់, ខ្យល់ខ្លាំងបក់មកនាំទូកទៅ, ទូកនោះជារបស់ដែលនាំទៅដោយខ្យល់ទុះឯង ។ អវហារមិនមានដល់បុគ្គល តែសេចក្ដីព្យាយាមមាន ។ ក៏សេចក្ដីព្យាយាមនោះមិនមែនជាសេចក្ដីព្យាយាមក្នុងការឱ្យឃ្លាត ចាកឋានទេ ។ ក៏បើទូកនោះរសាត់ទៅយ៉ាងនោះ ភិក្ខុបញ្ឈប់មិនឱ្យគ្រាច់ទៅតាមប្រក្រតី នាំទៅកាន់ទិសាភាគចំណែកដទៃ ត្រូវអាបត្តិបារាជិក ។ ទូកដែលគ្រាច់ទៅដល់កំពង់នៃស្រុកណាមួយ ដោយខ្លួនឯង ភិក្ខុមិនឱ្យឃ្លាតចាកឋានឡើយលក់ហើយក៏ទៅ, មិនជាអវហារឡើយ, តែជាភណ្ឌទេយ្យ ដូច្នេះឯង ។

ទ្រព្យដែលឋិតនៅក្នុងទូក ចប់

## ទ្រព្យដែលឋិតនៅក្នុងយាន

[៩៧] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅក្នុងយាន ៖

ព្រះមានព្រះភាគកាល នឹងទ្រង់សម្ដែងយានមុន ទើបត្រាស់ពាក្យជាដើមថា **យានំ នាម វយ្ហំ : អន្ទ្រីងស្នែង រថ រទេះ រថទ្រង់គ្រឿងឈ្មោះថា យាន** ។ ក្នុងពាក្យថា **វយ្ហំ** ជាដើមនោះមានវិនិច្ឆ័យដូច្នេះ ៖

យានដែលបិទបាំងដោយបន្ទះក្ដារទុកខាងលើ ដូចជាមណ្ឌបក៏

ដោយ ដែលគេធ្វើបិទហុំទុកទាំងអស់ក៏ដោយ ឈ្មោះថា អម្រឹង ស្នែង ៗ គ្រៃស្នែង គ្រៃដែលគេដាក់គន្លឹះដែលសម្រេចដោយមាស និង ប្រាក់ជាដើមទុកត្រង់ខាងទាំងពីរ ហើយធ្វើទុកដោយន័យដូចស្លាបគ្រុឌ, វេជនិងវេទេះប្រាកដច្បាស់ហើយឯង ៗ ភណ្ឌៈដែលមានវិញ្ញាណឬមិនមាន វិញ្ញាណ ដែលគេរក្សាទុកដោយអំណាចជាគំនរជាដើម ក្នុងបណ្តា គ្រៃស្នែងជាដើមទាំងនោះ កន្លែងណាមួយ កាលភិក្ខុឱ្យឃ្លាតចាកឋាន ដោយថេយ្យចិត្ត គប្បីជ្រាបថា ជាបារាជិក ដោយន័យដូចដែលពោល ទុកហើយក្នុងភណ្ឌៈដែលឋិតនៅក្នុងទូកនិងដែលឋិតនៅលើគោក ៗ

ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះ ៖

កាលភិក្ខុយកល្អីទទួលយកវត្ថុមានអង្ករជាដើម ដែលឋិតនៅក្នុង យាន សូម្បីកាលមិនលើកល្អីឡើង កាលទះល្អី ធ្វើឱ្យវត្ថុមានអង្ករ ជា ដើម ដែលជាប់គ្នា ខ្ទាយទៅ ជាអាបត្តិបារាជិក ៗ ន័យនេះ រមែង ប្រើបាន សូម្បីក្នុងវត្ថុដែលឋិតនៅលើគោកជាដើម ៗ កិច្ចទាំងឡាយ មានការត្រាច់រកសម្លាញ់ជាដើម ក្នុងពាក្យថា យើងនឹងលួចយាន មាន ន័យដូចដែលពោលហើយនុ៎ះឯង ៗ

ក៏ក្នុងពាក្យថា **ឋានា ចាវេតិ : ឃ្លាតចាកទី** នេះ គប្បីជ្រាប វិនិច្ឆ័យដូច្នេះ ៖

សម្រាប់យាន ដែលទឹមដោយគោ២ មានឋាន ១០ គឺ ជើងទាំង៨ របស់គោទាំង២ និងកង់២ ។ កាលភិក្ខុមានថេយ្យចិត្តឡើងរទេះនោះ អង្គុយលើទូករទេះបរទៅ ជាថុល្លច្ច័យ ក្នុងកាលគោទាំង២ លើកជើងឡើង, និងកាលឱកាសដែលកង់ទាំង២ ទល់ផែនដី កន្លងទៅត្រឹមតែមួយចុងសរសៃសក់ ជាបារាជិក ។ តែបើគោទាំង២ ដឹងថា អ្នកនេះមិនមែនម្ចាស់របស់យើងទេ ហើយរលាស់នឹមចោល មិនព្រមអូសទៅ ឈប់ក្តីបម្រាសចេញក្តី, នៅរក្សាទុកសិន កាលភិក្ខុចាប់គោទាំងពីរឱ្យឈរទន្ទឹមគ្នា ហើយពាក់នឹមទឹមឱ្យមាំ ចាក់ដោយជន្លួញ បរទៅទៀត ជាថុល្លច្ច័យ ក្នុងកាលគោទាំងនោះលើកជើងឡើង តាមន័យដែលពោលហើយនុ៎ះឯង, ជាបារាជិក ក្នុងកាលកង់វិលទៅ ។ បើសូម្បីក្នុងមកដែលមានភក់ កង់ម្ខាងជាប់នៅក្នុងភក់, គោទាញកង់ខាងទី២ បង្វិលឱ្យវិលទៅ ។ អវហារមិនទាន់មានទេ ព្រោះកង់ម្ខាងតាំងនៅជាប់ ។ តែកាលភិក្ខុចាត់គោទាំងពីរឱ្យឈរទន្ទឹមទៀត បើបរទៅ កាលកង់ដែលឋិតនៅ វិលកន្លងហួសឱកាសដែលពាល់ត្រូវទៅ ត្រឹមតែមួយចុងសរសៃសក់ ជាបារាជិក ។ និងគប្បីជ្រាបសេចក្តីផ្សេងគ្នានៃឋានរបស់យានដែលទឹម ដោយឧបាយនេះ គឺ យានដែលទឹមគោ៤ មានឋាន១៨, ដែលទឹមគោ៨ ដែលឋាន ៣៤ ។ ចំណែកយានណាដែលមិនបានទឹម គេប្រើជន្ទល់ត្រង់នឹមមួយ

និងជន្ទល់ខាងក្រោយ២ ដែលទល់ទុក, យាននោះ មានឋាន៥ ដោយអំណាចនៃជន្ទល់៣ និងកង់ទាំង២ ។ បើជន្ទល់ត្រង់ទឹម គេលាក់ជាបង្គាប់ផ្នែកខាងក្រោម មានឋាន៦ ។ ចំណែកយានដែលមិនបានទល់ទុកខាងក្រោយ ទល់តែត្រង់ទឹមប៉ុណ្ណោះ មាន ឋាន៣ខ្លះ ៤ខ្លះ ដោយអំណាចនៃជន្ទល់ ។ សម្រាប់យានដែលគេយកទឹមពាក់ទុកលើ ក្ដារឬលើឈើ មានឋាន៣ ។ យានដែលគេយកទឹមពាក់ទុកត្រង់ផែនដីក៏ដូចគ្នា ។ កាលភិក្ខុទាញឬលើកយាននោះ ឱ្យឃ្លាតចាកឋានទៅខាងមុខនិងខាងក្រោយជាថុល្លច្ច័យ, កាលឋានដែលកង់ទាំងពីរបេតនៅ កន្លងទៅត្រឹមតែមួយចុងសរសៃសក់ ក៏ជាបារាជិក ។ សម្រាប់យានដែលដោះកង់ចេញហើយយកចុងភ្លៅទាំង២ ពាក់ទុកលើឈើ មានឋាន២ ។ ភិក្ខុកាលទាញ ឬលើកយាននោះ ឱ្យកន្លងហួសឱកាសដែលពាល់ត្រូវទៅ ជាបារាជិក ។ យានដែលគេដាក់ទុកលើផែនដី មានឋាន៥ ដោយអំណាចនៃកន្លែងដែលទល់ទឹងទឹម និងឈើទល់ភ្លៅ៤ កំណាត់ ។ ភិក្ខុចាប់យាននោះត្រង់ទឹមទាញទៅ កាលទីបំផុតខាងក្រោយរបស់ជន្ទល់ភ្លៅ ហួសទីបំផុតខាងមុខទៅ ជាបារាជិក ។ កាលចាប់ត្រង់ជន្ទល់ភ្លៅទាញទៅ ញ៉ាំងទីបំផុតខាងមុខហួសទីបំផុតខាងក្រោយទៅ ត្រូវបារាជិក ។ កាលចាប់ត្រង់ខាង ៗទាញទៅ ឱ្យកន្លងហួសឋានទទឹងដែលជន្ទល់ភ្លៅតាំងនៅទុំះឯង ជា

បារាជិក ។ កាលចាប់ត្រង់កណ្ដាលលើកឡើង កាលផុតពីផែនដី ត្រឹមតែមួយចុងសរសៃសក់ ជាបារាជិក ។ បើមិនមានឈើជន្ទល់ភ្លៅ គេក៏ធ្វើប្រែកឱ្យប៉ុនគ្នា ហើយចោះត្រង់កណ្ដាលសិកចុងភ្លៅចូលទៅ ។ យាននោះ តាំងនៅប៉ះត្រូវផែនដីទាំងអស់ ដោយជុំវិញផែនដីខាងក្រោម ។ ក្នុងយាននោះគប្បីជ្រាបថា ជាបារាជិកដោយអំណាចកន្លងហួសឋានដែលប៉ះត្រូវ ទាំង៤ទិស និងខាងលើ ។ កង់ដែលគេយកជុំដាក់លើផ្ទៃផែនដីមានឋានតែមួយប៉ុណ្ណោះ ។ ការកំណត់កង់នោះ គប្បីជ្រាបដោយអាការ៥យ៉ាង កង់ដែលដាក់ឱ្យម្ខាងនៃកង់និងជុំប៉ះនឹងដី ( គឺផ្ដេកបះម្ខាង ) មានឋាន២ ។ កាលភិក្ខុយកជើងជាន់ចំណែកដែលតាំងឡើងនៃកង់ឱ្យត្រូវត្រង់ផ្ទៃ ហើយចាប់ត្រង់កាំឬត្រង់កង់លើកឡើង ទីដែលខ្លួនធ្វើ មិនចាត់ជាឋាន, ព្រោះហេតុនោះ កាលចំណែកដ៏សេស សូម្បីដែលតាំងនៅនោះគ្រាន់តែកន្លងទៅ ជាបារាជិក ។ សូម្បីកង់ដែលគេដាក់ផ្អែកជញ្ជាំងទុកក៏មានឋាន២ ។ បណ្ដាឋានទាំង២នោះ កាលភិក្ខុធ្វើឱ្យផុតពីជញ្ជាំងគ្រាដំបូង ជាថុល្លច្ច័យ, ខាងក្រោយក្នុងកាលលើកឡើងផុតពីផែនដីត្រឹមតែមួយចុងសរសៃសក់ ជាបារាជិក ។ តែកាលភិក្ខុធ្វើឱ្យផុតពីដីលើកដំបូង បើឋានដែលតាំងនៅត្រង់ជញ្ជាំង មិនកម្រើក ក៏មានន័យនេះឯង ។ បើកាលភិក្ខុចាប់ត្រង់កាំទាញទៅខាងក្រោម ទីបំផុតខាងលើនៃឱកាសដែល

តាំងប៉ះត្រូវជញ្ជាំង កន្ទុនហួសចុងចំណែកខាងក្រោម ជាបារាជិក ។ យានដែលកំពុងធ្វើដំណើរទៅម្ចាស់យានចុះចាកយានឆៀងចេញចាកមកទៅ ដោយករណីយ៍យ៉ាងណាមួយ បើមានភិក្ខុដទៃធ្វើដំណើរមក ឃើញយានទំនេរចាកការរក្សា ទើបគិតថា យើងនឹងលួចយកយាន ហើយឡើងជិះយាននោះ ។ គោទាំងឡាយនាំចៀសទៅ វៀរចាកសេចក្តីព្យាយាមរបស់ភិក្ខុតែម្តង មិនជាអវហារ ។ ពាក្យដ៏សេសដូច ដែលពោលទុកហើយក្នុងទូក ដូច្នេះឯង ។

ទ្រព្យដែលឋិតនៅក្នុងយាន ចប់

## ទ្រព្យឋិតនៅក្នុងភារៈ

[៩៨] បន្ទាប់ពីភណ្ឌៈដែលស្ថិតនៅក្នុងយាននេះទៅ ភារៈទុំះឯង ឈ្មោះថា ភារដ្ឋៈ (ភណ្ឌៈដែលឋិតនៅក្នុងភារៈ) ។ ភារៈនោះ ព្រះមានព្រះភាគទ្រង់សម្តែងទុក ៤ ប្រការដោយអំណាចនៃភារៈលើក្បាលជាដើម ។ ក្នុងភារៈនោះ គប្បីជ្រាបការកំណត់អវយវៈមានសីសៈជាដើម ដើម្បីសេចក្តីមិនច្រឡំក្នុងភារៈទាំងឡាយ មានភារៈលើក្បាលជាដើម ។ បណ្តាអវយវៈទាំងនោះ គប្បីជ្រាបការកំណត់សីសៈជាមុន; កញ្ចឹងកដែលនៅខាងមុខ ក្រយៅ(សក់កួច)ត្រង់ជាយសក់ របស់មនុស្សពួក

ខ្លះ មានខាងក្រោយក, សក់របស់មនុស្សពួកខ្លះ ដុះធ្លាក់ចុះមកដល់ខាងទាំងពីរនៃកញ្ចឹងកនុ៎ះឯង និងចំណែកខាងក្រោមនៃអវយវៈដែលហៅថា គុម្ពត្រចៀក ។ កំណត់ដូចពោលមកនេះ ជាកំណត់ខាងក្រោម ខាងលើអំពីកំណត់នោះឡើងទៅ គប្បីជ្រាបថា ជាសីសៈ ។ ភារៈដែលឋិតនៅក្នុងចន្លោះនេះ ឈ្មោះថា **សីសភារៈ** ភារៈលើក្បាល ។

បណ្ដាខាងទាំងពីរនៃកញ្ចឹងក ខាងក្រោមតាំងអំពីគុម្ពត្រចៀកចុះមក, ខាងលើ តាំងអំពីកែងដៃឡើងទៅ, ខាងក្រោមតាំងពីក្រយៅខាងក្រោយកញ្ចឹងក( នេះពីខាងក្រោយ ) និងកញ្ចឹងកចុះមក( នេះពីខាងមុខ ) ។

ខាងលើតាំងពីក្រយៅកណ្ដាលខ្នង និងត្រង់ចុងដង្ហើម ត្រង់កណ្ដាលទីកំណត់របស់ទ្រូងឡើងទៅ ឈ្មោះថា ក ។ ភារៈដែលឋិតនៅក្នុងចន្លោះនេះ ឈ្មោះថា **ខន្ធភារៈ** ភារៈតាំងនៅលើ ក ។

ចំណែកខាងក្រោម តាំងអំពីក្រយៅកណ្ដាលខ្នង និងចុងដង្ហើមចុះមក រហូតដល់ចុងក្រចកជើង នេះជាកំណត់នៃចង្កេះ ។ ភារៈដែលតាំងនៅត្រង់សរីរៈដោយជុំវិញក្នុងចន្លោះនេះ ឈ្មោះថា **កដិភារៈ** ភារៈនៅលើចង្កេះ ។

ចំណែកខាងក្រោមតាំងពីកែងដៃចុះមក ដរាបដល់ចុងក្រចកដៃ, នេះជាការកំណត់ នៃរបស់ដែលយួរ ។ ភារៈដែលឋិតនៅក្នុងចន្លោះនេះ ឈ្មោះថា **ឱលម្ពកភារៈ** ភារៈដែលយួរទៅ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យជាលំដាប់ទៅ ក្នុងពាក្យថា **សីសេ ភារំ : ភារៈដែលនៅលើក្បាល** ជាដើម ដូចតទៅនេះ ៖

ភិក្ខុណាដែលពួកម្ចាស់របស់មិនបានបង្គាប់ថា "លោកចូរកាន់យកភណ្ឌៈនេះ ទៅក្នុងទីនេះ" និយាយដោយខ្លួនឯងថា "លោកចូរប្រគល់ភណ្ឌៈឈ្មោះនេះឱ្យដល់ខ្ញុំ, ខ្ញុំនឹងនាំយកភណ្ឌៈរបស់ពួកលោកទៅ" ដូច្នេះ ហើយយកសីសៈទូលភណ្ឌៈរបស់ពួកជនទាំងនោះទៅ ស្ទាបអង្អែលភណ្ឌៈនោះដោយថេយ្យចិត្ត ត្រូវទុក្កដ ។ កាលមិនទាន់ឱ្យកន្លងខេត្តកំណត់សីសៈ តាមដែលពោលហើយឡើយ ត្រឹមតែទាញ រំកិលទៅខាងនេះ ៗ ខ្លះ ទាញត្រឡប់មកខ្លះ ត្រូវអាបត្តិថុល្លច្ច័យ, កាលភណ្ឌៈនោះល្មមលោកសម្រេតចុះកាន់ក សូម្បីពួកម្ចាស់របស់នឹងមានសេចក្តីគិតថា "ចូរនាំទៅចុះ" ដូច្នេះ ក៏ពិតមែន តែថាក៏ត្រូវបារាជិក ព្រោះខ្លួនមិនបានត្រូវពួកគេបង្គាប់ទុក ។ មួយទៀត កាលលោកសូម្បីមិនបានសម្រេតចុះកាន់ក តែលើកឱ្យផុតពីសីសៈ សូម្បីត្រឹមតែមួយចុងសរសៃសក់ ក៏ជាបារាជិក ។ មួយទៀត សម្រាប់ភារៈ២, មួយចំណែកតាំងនៅលើសីសៈ ចំណែកមួយតាំងនៅត្រង់ខ្នង ។ ក្នុងភារៈទាំង ២ នោះ គប្បីជ្រាបវិនិច្ឆ័យដោយអំណាចនៃឋាន ២ ។ តែការចង្អុលបង្ហាញនេះ បានប្រារព្ធដោយអំណាចនៃភារៈ មានភារៈលើក្បាលសុទ្ធ ៗ ជាដើមប៉ុណ្ណោះ ។

មួយទៀត សូម្បីក្នុងខន្ធភារៈជាដើម ក៏មានវិនិច្ឆ័យដូចដែលពោលទុកក្នុងភារៈលើក្បាលនេះឯង ។

ចំណែកក្នុងពាក្យថា ហត្ថេ ភារំ : នូវភារៈដែលនៅក្នុងដៃនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ភណ្ឌៈឈ្មួរទៅ ហៅថា ហត្ថភារៈ ព្រោះជារបស់ដែលកាន់ទៅដោយដៃ ។ ភារៈនោះទឹងជារបស់ដែលកាន់យកពីផ្ទៃផែនដីមុននោះឯង ឬទឹងជារបស់ដែលកាន់យកចាកសីសៈជាដើម ដោយចិត្តបរិសុទ្ធិក៏ដោយ រមែងដល់ការរាប់ថា ហត្ថភារៈ ដូចគ្នា ។ កាលភិក្ខុឃើញទីស្ងាត់ ដូច្នោះទើបដាក់ភារៈនោះចុះ លើផែនដី ឬក្នុងគុម្ពឈើជាដើម ដោយថេយ្យចិត្ត, កាលភារៈនោះគ្រាន់តែផុតពីដៃ ត្រូវអាបត្តិបារាជិក ។

ក៏ឯក្នុងពាក្យថា ភូមិតោ គណ្ហាតិ : **កាន់យកទ្រព្យអំពីផែនដីទៅ** មានវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុដាក់ភារៈទាំងនោះយ៉ាងណាមួយចុះ លើផ្ទៃផែនដីដោយចិត្តបរិសុទ្ធិ ព្រោះហេតុ មានអាហារព្រឹកជាដើម ហើយត្រឡប់លើកឡើងទៀតដោយថេយ្យចិត្ត សូម្បីត្រឹមតែមួយសរសៃសក់ ក៏ជាបារាជិកដូច្នេះឯង ។

ទ្រព្យដែលឋិតនៅក្នុងភារៈ ចប់

## ទ្រព្យដែលឋិតនៅក្នុងសួន

[៩៩] គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងទ្រព្យដែលឋិតនៅក្នុងសួនតទៅ ៖

ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងសួនជាមុន ទើបត្រាស់ថា "សួនផ្កាឈើ សួនផ្លែឈើ ឈ្មោះថា អារាម" ដូច្នេះ ។ បណ្ដាសួនទាំងនោះ សួនជាទីរីកនៃផ្កាឈើទាំងឡាយ មានផ្កា ម្លិះជាដើម ឈ្មោះថា **សួនផ្កាឈើ** ។ សួនជាទីបញ្ចេញនៃផ្លែឈើទាំងឡាយ មានផ្លែ ស្វាយជាដើម ឈ្មោះថា **សួនផ្លែឈើ** ។ វិនិច្ឆ័យកណ្ឌៈដែលគេរក្សាទុកសូម្បីក្នុងសួន ដោយឋាន ៤ មានន័យដូចពោលហើយ ក្នុងកណ្ឌៈដែលឋិតនៅក្នុងផ្ទៃផែនដីជាដើមនុ៎ះឯង ។

ចំណែកវិនិច្ឆ័យក្នុងកណ្ឌៈដែលកើតក្នុងសួននោះ គប្បីជ្រាបដូច្នេះ ៖

ឫសឈើប្រភេទណាមួយ មានស្បូវ និងស្លឹកគ្រៃជាដើម ឈ្មោះថា **មូលំ** ។ កាលភិក្ខុដកឫសនោះកាន់យកក្ដី កាន់យក ដែលគេដកទុកហើយក្ដី វត្ថុនៃបារាជិកនឹងពេញដោយឫសណា, កាលឫសនោះ ដែលលោកកាន់យកហើយ ជាបារាជិក ។ សូម្បីមើមជំឡូង ក៏សង្គ្រោះចូលដោយឫសដូចគ្នា ។ ក៏កាលភិក្ខុដកមើមជំឡូងឡើង ក្នុងកាលមើមជំឡូងនោះសូម្បីមានប្រមាណបន្តិចនៅមិនទាន់ដាច់ ជាអាបត្តិថុល្លច្ច័យ ។ ពាក្យដ៏សេស គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងក្រអៅឈូកនុ៎ះឯង ។

បទថា គច្ឆំ : សំបកឈើ បានដល់ សំបកឈើប្រភេទណាមួយ ដែលល្មមនឹងប្រើប្រកប ដើម្បីជាភេសជ្ជៈ ឬដើម្បីជាគ្រឿងជ្រលក់ ។ កាលភិក្ខុស្មោះសំបកឈើនោះកាន់យក ឬកាន់យកសំបកឈើដែលគេស្មោះទុកហើយ ជាអាបត្តិបារាជិក ដោយន័យដែលពោលទុកហើយក្នុងឫសឈើនុ៎ះឯង ។

បទថា បុប្ផំ : ផ្កាឈើ បានដល់ ផ្កាឈើប្រភេទណាមួយ មានផ្កាម្លិះលា និងម្លិះរួតជាដើម ។ កាលភិក្ខុបេះយកផ្កាឈើនោះ ឬកាន់យកផ្កាឈើដែលគេបេះទុកហើយ ជាបារាជិក ដោយន័យដូចដែលពោលទុកហើយក្នុងផ្កាឧប្បល និងផ្កាបទុមនុ៎ះឯង ។ ពិតមែន ជាផ្គាំ ទងផ្គាំ សូម្បីរបស់ផ្កាឈើទាំងឡាយ នៅមិនទាន់ដាច់ ក៏នៅរក្សា ។ តែសម្រាប់ផ្កាឈើពួកខ្លះ មានសរសៃនៅខាងក្នុងទង, សរសៃនោះរក្សាមិនបាន ។

បទថា ផលំ : ផ្លែឈើ បានដល់ ផ្លែឈើប្រភេទណាមួយ មានផ្លែស្វាយនិងផ្លែត្នោតជាដើម ។ វិនិច្ឆ័យសម្រាប់ភិក្ខុកាន់យកផ្លែឈើនោះចាកដើមឈើ ខ្ញុំព្រះករុណាបានពោលទុក ហើយក្នុងកថា ពោលអំពីភណ្ឌៈដែលពាក់ទុកលើដើមឈើ ។ ផ្លែឈើដែលគេយកចេញទៅតម្កល់ទុក សង្គ្រោះចូលដោយភណ្ឌៈដែលឋិតនៅលើផ្ទៃផែនដីជាដើមនុ៎ះឯង ។

ពីរបទថា អារាមំ អភិយុញ្ជតិ : ភិក្ខុចោទប្រកាន់យកសួនច្បារ

សេចក្តីថា ភិក្ខុពោលកុហកបន្ទំយកសួន ដែលជារបស់អ្នកដទៃថា "នេះជាសួនរបស់ខ្ញុំ" ដូច្នេះ ជាទុក្កដ ព្រោះជាប្រយោគនៃអទិន្នាទាន ។

ប្រើនបទថា **សាមិកស្ស វិមតី ឧប្បាទេតិ** : **ធ្វើឱ្យម្ចាស់សួនច្បាស់សង្ស័យ** មានសេចក្តីថា ភិក្ខុញុំាងសេចក្តីសង្ស័យឱ្យកើតឡើងដល់ម្ចាស់សួន ព្រោះភាពជាអ្នកឆ្លាតក្នុងការវិនិច្ឆ័យ ឬព្រោះអាស្រ័យអ្នកដែលមានកម្លាំងជាដើម ។ តើយ៉ាងណា ? គឺ តាមសេចក្តីពិត ម្ចាស់របស់ឃើញភិក្ខុនោះ ដែលជាអ្នកខ្វល់ខ្វាយក្នុងការវិនិច្ឆ័យនៅយ៉ាងនោះ ទើបគិតថា "យើងនឹងអាចធ្វើសួននេះឱ្យត្រឡប់ជារបស់យើងវិញ ឬមិនអាចទេហ្ន៎ ?" សេចក្តីសង្ស័យ កាលកើតឡើងដល់ម្ចាស់របស់នោះ រមែងឈ្មោះថា ដែលភិក្ខុនោះឱ្យកើតឡើងហើយ ដោយអាការដូចពោលមកនេះ ព្រោះហេតុនោះ ភិក្ខុនោះ រមែងត្រូវថុល្លច្ច័យ ។

ពីរបទថា **ធុរំ និក្ខិបតិ** : **ដាក់ធុរៈចុះ** មានសេចក្តីថា ក៏កាលណា ម្ចាស់របស់ដាក់ធុរៈចេញ ដោយគិតថា "ភិក្ខុនេះអាក្រក់ គប្បីធ្វើសូម្បីនូវអន្តរាយដល់ជីវិតនិងព្រហ្មចរិយៈរបស់យើង, ឥឡូវនេះ យើងមិនត្រូវការសួននេះទេ", កាលនោះ ភិក្ខុដែលបន្ទំ រមែងត្រូវបារាជិក ។ បើសូម្បីខ្លួននឹងជាអ្នកធ្វើការ ដាក់ធុរៈដោយខ្លួនឯងក៏ដោយ, តែបើម្ចាស់របស់ដាក់ធុរៈហើយក៏ដោយ ភិក្ខុដែលបន្ទំ មិនដាក់ធុរៈ នៅមានសេចក្តី

ឧស្សាហ៍ក្នុងការឱ្យវិញ ដោយគិតថា "យើងនឹងបៀតបៀនម្ចាស់សួននេះឱ្យធូន់ ហើយសម្តែងនូវអំណាចរបស់យើង តាំងម្ចាស់សួនអ្នកនេះទុកក្នុងភាពជាអ្នកទទួលស្តាប់ ហើយទើបនឹងឱ្យវិញ" ដូច្នេះ, នៅរក្សាទុកសិន ។ បើសូម្បីភិក្ខុដែលបន្ទំ កាលប្រដែងដណ្តើមយកហើយ ក៏ដាក់ធុរៈ ដោយគិតថា "ឥឡូវនេះ យើងនឹងមិនប្រគល់សួននោះឱ្យដល់ម្ចាស់សួននេះទេ" ចំណែកម្ចាស់សួនមិនព្រមដាក់ធុរៈទេ នៅត្រាច់ស្វែងរកបក្ខពួក ទាំងរង់ចាំវេលា ដោយគិតថា "យើងបានលជ្ជីបរិស័ទជាមុន ខាងក្រោយនឹងដឹង" ដូច្នេះ នៅជាអ្នកមានសេចក្តីឧស្សាហ៍ក្នុងការទទួលយកត្រឡប់វិញនោះឯង ក៏នៅរក្សានោះ ដោយពិត ។ តែកាលណា សូម្បីភិក្ខុដែលបន្ទំនោះដាក់ធុរៈដោយគិតថា "យើងនឹងមិនឱ្យវិញទេ" ទាំងម្ចាស់ក៏ដាក់ធុរៈដោយគិតថា "យើងនឹងមិនបានមកវិញទេ" ទាំងពីរចំណែកដាក់ធុរៈចុះ ដូចពោលមកនេះ; កាលនោះ ភិក្ខុដែលបន្ទំ ត្រូវអាបត្តិបារាជិក ។ តែបើភិក្ខុគ្រាបន្ទំហើយ ក៏ធ្វើការវិនិច្ឆ័យសេចក្តីដោយខ្លួនឯង កាលវិនិច្ឆ័យមិនទាន់សម្រេច ទាំងម្ចាស់សួនក៏មិនបានដាក់ធុរៈ ដឹងច្បាស់ថា "ខ្លួនមិនមែនម្ចាស់សួនឡើយ បានកាន់យកផ្កាឈើ ឬផ្លែឈើយ៉ាងណាមួយអំពីសួននោះ" ព្រះវិន័យធរគប្បីពិន័យអាបត្តិតាមតម្លៃវត្ថុ ។

បទថា **ធម្មញ្ចរន្តោ** : **ភិក្ខុធ្វើការវិនិច្ឆ័យ បានដល់** ភិក្ខុដែលបន្ទំធ្វើការកាត់ក្តីបណ្តឹងក្នុងពួកភិក្ខុ ឬក្នុងរាជត្រកូល ។

ពីរបទថា **សាមិកាំ បរាជេតិ : ចាញ់ម្ចាស់របស់** សេចក្ដីថា ភិក្ខុអ្នកបន្ទំនោះ ឱ្យរបស់រផ្ទាន់ដល់ពួកអ្នកពិភាក្សា ហើយអាងសាក្សីកោង រមែងឈ្នះម្ចាស់សួន ។

ពីរបទថា **អាបត្តិ ធារាជិកស្ស : ត្រូវអាបត្តិបារាជិក** សេចក្ដីថា មិនមែនជាបារាជិក ដល់ភិក្ខុដែលប្ដឹងផ្ដល់នេះតែម្យ៉ាងទេ ពួកភិក្ខុដែលពិភាក្សាកោងក្ដី អ្នកជាសាក្សីកោងក្ដី អ្នកក្លែងដំណើរក្ដីក្នុងការឱ្យសម្រេចប្រយោជន៍ដល់ភិក្ខុអ្នកប្ដឹងនោះ ក៏ជាបារាជិកទាំងអស់ ។ ក៏ក្នុងពាក្យថា ធម្មញ្ចរន្តោ នេះ គប្បីជ្រាបការបរាជ័យ ដោយអំណាចម្ចាស់របស់ដាក់ធុរៈប៉ុណ្ណោះ ។ ពិតមែន ម្ចាស់របស់មិនទាន់ដាក់ធុរៈ ចាត់ថាមិនទាន់បរាជ័យនៅឡើយ ។

ច្រើនបទថា **ធម្មិចរន្តោ បរជ្ជតិ : ភិក្ខុធ្វើការវិនិច្ឆ័យចាញ់** សេចក្ដីថា សូម្បីបើខ្លួនឯងបរាជ័យ ព្រោះពាក្យពិភាក្សាដែលប្រព្រឹត្តទៅដោយធម៌ ដោយវិន័យ ដោយសត្ថុសាសនៈ ។ សូម្បីដោយប្រការយ៉ាងនេះ ភិក្ខុដែលបន្ទំនោះ ត្រូវថុល្លច្ច័យ ព្រោះធ្វើការបៀតបៀនម្ចាស់របស់ដោយការពោលកុហកជាបច្ច័យ ដូច្នេះឯង ។

ទ្រព្យដែលឋិតនៅក្នុងសួន ចប់

## ទ្រព្យសម្បត្តិដែលឋិតនៅក្នុងវិហារ

[១០០] គប្បីជ្រាបវិនិច្ឆ័យក្នុងទ្រព្យសម្បត្តិដែលឋិតនៅក្នុងវិហារតទៅ ៖

ទ្រព្យដែលរក្សាទុក ដោយឋាន ៤ មានន័យដូចពោលហើយនុ៎ះឯង ។

ក៏វិនិច្ឆ័យសម្បត្តិក្នុងការបន្ទំយកក្នុងទ្រព្យដែលឋិតនៅ ក្នុងវិហារនេះ គប្បីជ្រាបដូច្នេះ ៖

កាលភិក្ខុបន្ទំយកវិហារក្តី បរិវេណក្តី អាវាសក្តី ទាំងធំ ទាំងតូចដែលគេប្រគេនពួកភិក្ខុឧទ្ទិសសង្ឃ មកពីទិសទាំង ៤ បន្ទំមិនឡើង, ទាំងមិនអាចដើម្បីដណ្តើមយកបាន ។ ព្រោះហេតុអ្វី ? ព្រោះមិនមានការដាក់ធុរៈនៃភិក្ខុទាំងពួង ។ ពិតមែន ភិក្ខុទាំងអស់ដែលនៅក្នុងទិសទាំង ៤ ធ្វើការដាក់ធុរៈក្នុងវិហារជាដើមដែលជារបស់សង្ឃនេះ មិនបាន ។ តែភិក្ខុអ្នកបន្ទំកាន់យកវត្ថុ ៗ គណៈ ដែលមានគណៈអ្នកពោលទីឃនិកាយជាដើម ឬរបស់បុគ្គលខ្លះ រមែងអាចធ្វើគណៈ និងបុគ្គលខ្លះទាំងនោះឱ្យដាក់ធុរៈបាន ព្រោះដូច្នោះ ក្នុងវត្ថុ ៗ គណៈ និងបុគ្គលខ្លះនោះ គប្បីជ្រាបវិនិច្ឆ័យ ដោយន័យដូចដែលពោលទុកហើយក្នុងសួនទុំ៖ឯង ។

ទ្រព្យដែលឋិតនៅក្នុងវិហារ ចប់

# ភណ្ឌៈដែលឋិតនៅក្នុងស្រែ

[១០១] គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងភណ្ឌៈដែលឋិតនៅក្នុងស្រែតទៅ ៖

ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងស្រែជាមុន ទើបត្រាស់ថា "ស្រូវទាំងឡាយ ៧ យ៉ាង មានស្រូវសាលីជាដើមក្ដី ផ្លែទាំងឡាយ មានសណ្ដែកបាយមាសជាដើមក្ដី ដុះក្នុងទីណា ទីនោះ ឈ្មោះថា ខេត្ត (ស្រែ)" ។ បណ្ដាបុព្វណ្ណជាតិជាដើមនោះ ស្រូវ ៧ ប្រភេទ មានស្រូវសាលីជាដើម ឈ្មោះថា បុព្វណ្ណជាតិ ។ ផ្លែទាំងឡាយមានសណ្ដែកបាយនិងសណ្ដែកបាយមាសជាដើម ឈ្មោះថា អបរណ្ណជាតិ ។ សូម្បីចំការអំពៅជាដើម ក៏សង្គ្រោះចូលក្នុងបទថា អបរណ្ណជាតិ នេះដូចគ្នា ។ ភណ្ឌៈដែលគេរក្សាទុកដោយឋាន ៤ សូម្បីក្នុងទ្រព្យដែលតាំងនៅក្នុងស្រែនេះ ក៏មានន័យដូចពោលហើយនុ៎ះឯង ។

ចំណែកក្នុងភណ្ឌៈដែលកើតឡើងក្នុងស្រែនោះ មានវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុបួតយកធញ្ញជាតិមានកួរស្រូវសាលីជាដើមក្ដី យកដៃនុ៎ះឯងក្ដិច ឬយកកណ្ដៀវប្រែតម្ដងមួយកួរ ៗ ក្ដី យករួមគ្នាម្ដងច្រើន ៗ ក្ដី វត្ថុបារាជិក នឹងគ្រប់ក្នុងគ្រាប់ ក្នុងកួរ ក្នុងកាប់ ឬក្នុងផ្លែមានសណ្ដែកបាយនិងសណ្ដែកបាយមាសជាដើមណា ៗ កាលគ្រាប់ជាដើមនោះ ៗ

ត្រឹមតែលោកឱ្យរបូតចាកទង ជាអាបត្តិបារាជិក ។ ចំណែកធាន្យជាតិ សរសៃក្តី សំបកក្តី ដែលនៅមិនដាច់សូម្បីមានប្រមាណតិច ក៏នៅរក្សា ។ ជញ្ជ្រាំងស្រូវ សូម្បីជារបស់វែង, ដើមរបស់កួរស្រូវ មិនទាន់របូតចាកជញ្ជ្រាំងស្រូវខាងក្នុងត្រឹមណា, នៅរក្សាត្រឹមនោះ កាលផ្ទៃខាងក្រោមរបស់ដើម របូតចេញចាកជញ្ជ្រាំងស្រូវហើយ សូម្បីត្រឹមតែមួយចុងសរសៃសក់ ព្រះវិន័យធរគប្បីពិន័យអាបត្តិដោយអំណាចតម្លៃវត្ថុ ។ ក៏កាលភិក្ខុប្រើកណ្តៀវប្រេចត្តាប់យក កាលដើមស្រូវនៅក្នុងក្តាប់ដៃសូម្បីដាច់ហើយក្នុងផ្នែកខាងក្រោម, បើកួរទាំងឡាយនៅជាប់ប្រទាក់គ្នានៅរក្សាទុកសិន ។ តែកាលលោករៀបចំ (ឱ្យស្អាត)លើកឡើង សូម្បីត្រឹមតែមួយចុងសរសៃសក់, បើវត្ថុបារាជិកគ្រប់ ជាអាបត្តិបារាជិក ។ ក៏ឯកាលភិក្ខុកាន់យកស្រូវដែលម្ចាស់ប្រេចដាក់ទុកព្រមទាំងចំបើង ឬធ្វើឱ្យអស់ទាំងចំបើង, វត្ថុបារាជិកនឹងគ្រប់ដោយកួរណា, កាលកួរនោះដែលលោកកាន់យកហើយ ជាបារាជិក ។ បើលោកកំណត់ចំណាំទុកថា យើងនឹងបែនស្រូវនេះ ហើយនឹងអុំកាន់យកតែគ្រាប់ស្រូវប៉ុណ្ណោះ ដូច្នេះ, នៅរក្សាទុកសិន ។ សូម្បីកាលលោកឱ្យឃ្លាតចាកឋាន ព្រោះការបែន និងអុំមិនទាន់ជាបារាជិក (ត្រឹមតែអាបត្តិទុក្កដ) ខាងក្រោយ កាលលោកត្រឹមតែចូកដាក់ភាជនៈ ក៏ជាបារាជិក ។ ចំណែកការបន្ទំយកក្នុងភណ្ឌៈដែលឋិតនៅក្នុងស្រែនេះ មានន័យដូចពោលហើយនុ៎ះឯង ។

ក្នុងការបន្ថិតបង្គោលជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា ផែនដីជារបស់កាត់ថ្លៃមិនបាន; ព្រោះហេតុនោះ ពួកម្ចាស់របស់ឃើញឬមិនឃើញក៏ដោយ បើថា ភិក្ខុធ្វើប្រទេសនៃផែនដី សូម្បីត្រឹមតែមួយ ចុងសរសៃសក់ឱ្យជារបស់ ៗ ខ្លួន ដោយបង្គោល ត្រឹមតែមួយប៉ុណ្ណោះ ទោះជាពួកម្ចាស់របស់ឃើញក្តី មិនឃើញក្តី ។ កាលបង្គោលនោះ នឹងចារឹកឈ្មោះ ឬមិនចារឹកក៏ដោយ លុះលោកបន្ថិត សម្រេច ក៏ជាបារាជិកដល់លោកផង ដល់ភិក្ខុទាំងពួងអ្នកមានធុរៈរួមនឹង លោកផង ៗ តែបើទីស្រែនោះ ជារបស់ដែលគប្បីកាន់យកបានដោយ បង្គោល ២ ដើម, បន្ថិតបង្គោលទី១ ត្រូវអាបត្តិថុល្លច្ច័យ, បន្ថិត បង្គោលទី២ ត្រូវអាបត្តិបារាជិក ។ បើជារបស់ដែលគប្បីកាន់យកបាន ដោយបង្គោល ៣ ដើម បន្ថិតបង្គោលទី១ ត្រូវអាបត្តិទុក្កដ, បន្ថិត បង្គោលទី២ ត្រូវអាបត្តិថុល្លច្ច័យ, បន្ថិតបង្គោលទី៣ ត្រូវអាបត្តិ បារាជិក ។ សូម្បីក្នុងបង្គោលច្រើនដើម ក៏គប្បីជ្រាបថា ត្រូវអាបត្តិ ទុក្កដ ដោយបន្ថិតបង្គោលមុន ៗ វៀរបង្គោលពីរខាងចុងបំផុត, បណ្តា បង្គោលពីរខាងចុងបំផុត ត្រូវអាបត្តិថុល្លច្ច័យព្រោះបង្គោលទី១ ត្រូវ អាបត្តិបារាជិកព្រោះបង្គោលមួយដទៃទៀត ដោយប្រការដូច្នេះ ។ ក៏ អាបត្តិបារាជិកនោះឯង រមែងមានដោយសេចក្តីដាក់ធុរៈរបស់ពួកម្ចាស់ ស្រែ ។ ក្នុងការបន្ថិតទាំងពួងមានការបន្ថិតខ្សែជាដើម ក៏យ៉ាងនេះ ។

បទថា **វជ្ជំ វា : ខែត្រក្តី** មានសេចក្តីថា ភិក្ខុមានសេចក្តីប្រាថ្នានឹងឱ្យអ្នកដទៃយល់ថា "ស្រែនេះជារបស់យើង" ចង់ឱ្យសន្និដ្ឋានក្តី ដាក់ឈើសណ្តុកចុះក្តី ត្រូវទុក្កដ កាលលោកធ្វើទុកក្នុងចិត្តថា "ឥឡូវនេះយើងនឹងធ្វើឱ្យជាស្រែរបស់ខ្លួនដោយ ២ ប្រយោគ" ជាថុល្លច្ច័យក្នុងប្រយោគទីមួយនៃប្រយោគទាំង ២ នោះ, ត្រូវអាបត្តិបារាជិកក្នុងប្រយោគទី ២ ។

បទថា **វតី វា : របងក្តី** មានសេចក្តីថា ភិក្ខុមានសេចក្តីប្រាថ្នានឹងធ្វើស្រែរបស់អ្នកដទៃឱ្យជាស្រែរបស់ខ្លួន ដោយអំណាចនៃការលោមព័ទ្ធ ទើបបោះបង្គោលចុះ ត្រូវទុក្កដគ្រប់ប្រយោគ, កាលប្រយោគមួយមិនទាន់សម្រេច ត្រូវអាបត្តិថុល្លច្ច័យ កាលប្រយោគនោះសម្រេចហើយជាបារាជិក ។ បើលោកមិនអាចធ្វើដោយប្រយោគមានប្រមាណប៉ុណ្ណោះ តែអាចធ្វើឱ្យជាស្រែរបស់ខ្លួនបាន ដោយលោមព័ទ្ធទុកដោយមែកឈើប៉ុណ្ណោះ សូម្បីក្នុងការដាក់មែកឈើចុះ ក៏មានន័យនេះដូចគ្នា ។ ភិក្ខុអាចដើម្បីនឹងលោមព័ទ្ធដោយវត្ថុយ៉ាងណាមួយ ធ្វើឱ្យជារបស់ ៗ ខ្លួនបាន ដោយប្រការយ៉ាងនេះ, ក្នុងវត្ថុនោះ ៗ គប្បីជ្រាបថា ត្រូវទុក្កដព្រោះប្រយោគខាងដើម, ជាថុល្លច្ច័យព្រោះប្រយោគមួយ បណ្តាប្រយោគពីរខាងចុង, ជាបារាជិកព្រោះប្រយោគក្រៅពីនេះ ។

បទថា **មរិយាទំ វា : ទំនប់ក្តី** មានសេចក្តីថា ភិក្ខុមានសេចក្តីប្រាថ្នានឹងឱ្យអ្នកដទៃដឹងស្រែរបស់អ្នកដទៃថា "នេះជាស្រែរបស់យើង" ទើបបង្ខិតភ្លឺស្រែរបស់ខ្លួនចូលទៅ ដោយធ្វើភ្លឺស្រែ (របស់ខ្លួន) ហួសស្រែរបស់អ្នកដទៃ ឬយកអាចម៍ដីនិងដីស្អិតជាដើមបន្ថែមធ្វើឱ្យទូលាយចេញទៅ ឬថា តាំងភ្លឺស្រែដែលនៅមិនបានធ្វើឡើង ត្រូវទុក្កដក្នុងប្រយោគដើម ៗ, ជាថុល្លច្ច័យព្រោះប្រយោគមួយ បណ្តាពីរប្រយោគខាងចុង, ជាបារាជិក ដោយប្រយោគក្រៅពីនេះ ដូច្នេះឯង ។

ទ្រព្យដែលឋិតនៅក្នុងស្រែ ចប់

## ក្នុងទ្រព្យដែលឋិតនៅក្នុងផ្ទៃដី

[១០២] គប្បីជ្រាបវិនិច្ឆ័យសូម្បីក្នុងទ្រព្យដែលឋិតនៅក្នុងដីតទៅ ៖ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងផ្ទៃដីមុន ទើបត្រាស់ថា "វត្ថុ ឆាម អារាមវត្ថុ វិហារវត្ថុ : ទីសួនច្បារនិងទីវត្ត ឈ្មោះថា វត្ថុ" ដូច្នេះ ។ បណ្តា ផ្ទៃដីសួនជាដើមនោះ ភូមិភាគដែលគេមិនបានដាំពូជ ដើមឈើដែលគួរដាំទុកឡើយ បោសសំអាតផ្ទៃដីទុកតែម្យ៉ាង ឬព័ទ្ធដោយកំផែង ៣ ប្រភេទណាមួយ ដើម្បីប្រយោជន៍ដល់សួនផ្កាឈើជាដើម ឈ្មោះថា អារាមវត្ថុ ភូមិភាគដែលគេតាំងទុក ដើម្បីប្រយោជន៍ដល់វិហារបរិវេណ និងអាវាសមួយ ៗ ដោយន័យនោះឯង ឈ្មោះថា វិហារវត្ថុ ។ ភូមិភាគសូម្បីណាក្នុងកាលមុន ជាអារាមនិងជាវិហារ, ខាងក្រោយ រហោស្ថានទៅ តាំងនៅត្រឹមតែជាភូមិភាគ មិនសម្រេចកិច្ចនៃអារាមនិងវិហារ ភូមិភាគសូម្បីនោះក៏សង្គ្រោះ ដោយការរួមចូលក្នុងអារាមវត្ថុនិងវិហារវត្ថុដូចគ្នា ។ ចំណែកវិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅក្នុងផ្ទៃដីសួននិងផ្ទៃដីវិហារនេះ ដូចដែលពោលហើយ ក្នុងស្រែទុំះឯង ដូច្នេះឯង ។

ទ្រព្យដែលឋិតនៅក្នុងផ្ទៃដី ចប់

[១០៣] ពាក្យដែលគួរនឹងពោលក្នុងភណ្ឌៈដែលឋិតនៅក្នុងស្រុក

ខ្ញុំព្រះករុណាបានពោលទុកហើយ ។

## ទ្រព្យដែលឋិតនៅក្នុងព្រៃ

[១០៤] វិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅក្នុងព្រៃ គប្បីជ្រាបដូច្នេះ ៖

ព្រះមានព្រះភាគ កាលទឹងទ្រង់សម្តែងព្រៃមុន ទើបត្រាស់ថា **អរញ្ញំ នាម យំ មនុស្សានំ បរិគ្គហិតំ ហោតិ តំ អរញ្ញំ** : ដែលឈ្មោះថា ព្រៃ បានដល់ ព្រៃដែលពួកមនុស្សហួងហែង ដូច្នេះ ។

ក្នុងពាក្យថា *អរញ្ញំ* នោះ មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា ព្រៃ សូម្បីដែលពួកមនុស្សហួងហែង ក៏មាន សូម្បីដែលមិនហួងហែងក៏មាន, ក្នុងអធិការនេះ លោកប្រាថ្នាយកព្រៃដែលគេហួងហែង មានការរក្សា ជាដែនដែលពួកមនុស្សមិនបានដើម្បីនឹងកាន់យកឈើ និងវល្លិជាដើម ដោយវៀរចាកមូលតម្លៃ; ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា "ដែលហៅថា ព្រៃ គឺទីណាដែលពួកមនុស្សហួងហែងរក្សា" ហើយត្រាស់ទៀតថា "ទីនោះឈ្មោះថា ព្រៃ" ដូច្នេះ ។

ដោយពាក្យថា ព្រៃនោះ លោកសម្តែងអត្ថន័យទុកដូច្នេះថា ភាពជាទីហួងហែងមិនចាត់ជាលក្ខណៈរបស់ព្រៃ, តែទីណាជាព្រៃដោយលក្ខណៈរបស់ខ្លួន និងពួកមនុស្សហួងហែង ទីនោះឈ្មោះថា ព្រៃក្នុងអត្ថន័យនេះ ។ វិនិច្ឆ័យក្នុងទ្រព្យដែលឋិតនៅក្នុងព្រៃនោះ ក៏ដូចដែលពោល

ហើយក្នុងទ្រព្យដែលឋិតនៅក្នុងសួនជាដើម ។

ក៏បណ្ដាទ្រព្យដែលកើតក្នុងព្រៃនោះ កាលដើមឈើដែលមានតម្លៃច្រើន សូម្បីត្រឹមតែមួយដើម ក្នុងព្រៃនេះ គ្រាន់តែភិក្ខុកាត់ដាច់ហើយក៏ជាបារាជិក ។ មួយទៀត បទថា លតំ វា នេះ ផ្ដៅក្ដី វល្លិក្ដី ក៏ឈ្មោះថា វល្លិទាំងអស់ ។ បណ្ដាផ្ដៅនិងវល្លិទាំងនោះ ផ្ដៅឬវល្លិណាជារបស់វែងដែលលយចេញទៅ ឬរុំព័ទ្ធដើមឈើធំនិងគុម្ពឈើលូនឡើងទៅ វល្លិនោះ ភិក្ខុកាត់គល់ហើយក្ដី ឬកាត់ចុងក្ដី មិនញុំាងអវហារឱ្យកើតឡើងបាន ។ តែកាលណាភិក្ខុកាត់ទាំងចុងទាំងគល់ កាលនោះរមែងញុំាងអវហារឱ្យកើតបាន បើវល្លិមិននៅរុំព័ទ្ធ(ដើមឈើ) ។ ចំណែកដែលនៅរុំព័ទ្ធ (ដើមឈើ) លុះភិក្ខុទាញបោចឱ្យចេញផុតពីដើមឈើ រមែងញុំាងអវហារឱ្យកើតបាន ។ ស្មៅក្ដី ស្លឹកឈើក្ដី ទាំងអស់នោះ លោកសង្គ្រោះចូលដោយសព្ទថា ស្មៅ ក្នុងបទថា តិណំ វា : ស្មៅក្ដី នេះ ភិក្ខុកាន់យកស្មៅនោះ ដែលអ្នកដទៃកាត់ទុកដើម្បីប្រយោជន៍ដល់គ្រឿងប្រក់ផ្ទះជាដើម ឬ ដែលខ្លួនឯងកាត់យក ព្រះវិន័យធរគប្បីពិន័យអាបត្តិតាមតម្លៃវត្ថុ និងពិន័យអាបត្តិ ចំពោះតែការកាន់យកស្មៅនិងស្លឹកឈើតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីកាន់យកសំបក និងក្រមរជាដើមយ៉ាងដទៃប្រភេទណាមួយ ក៏គប្បីពិន័យអាបត្តិតាមតម្លៃ

វត្ថុ ។ កាលភិក្ខុកាន់យកវត្ថុមានសំបកឈើជាដើម ដែលពួកម្ចាស់របស់នៅមានសេចក្ដីអាល័យ គប្បីពិន័យ អាបត្តិតាមតម្លៃវត្ថុ សូម្បីដើមឈើដែលគេចាំងចោលទុកយូរហើយ ក៏មិនគួរកាន់យក ។ ចំណែកដើមឈើណា ដែលគេកាត់ត្រង់ចុងនិងគល់ហើយ មែករបស់ដើមឈើនោះពុកផុយខ្លះ ក្រមរទាំងឡាយក៏របេះជ្រុះចេញខ្លះ, ទឹងកាន់យកដោយគិតថា "ដើមឈើនេះ ពួកម្ចាស់របស់លះចោលហើយ" ដូច្នេះ គួរ ។ សូម្បីដើមឈើដែលឆ្លាក់គ្រឿងសម្គាល់ទុក កាលណា គ្រឿងសំគាល់ត្រូវក្រមរជុះជិត កាលនោះ ទឹងកាន់យកគួរ ។ មនុស្សទាំងឡាយ កាត់ដើមឈើដើម្បីប្រយោជន៍ដល់ផ្ទះជាដើម កាលណា គេសាងផ្ទះជាដើមនោះរួចហើយ និងចូលនៅអាស្រ័យ, កាលនោះ សូម្បីឈើទាំងឡាយរមែងវិនាសអស់ទៅព្រោះភ្លៀងនិងកំដៅថ្ងៃ នៅក្នុងព្រៃ ។ ភិក្ខុប្រទះឃើញឈើសូម្បីដូច្នេះ ទឹងកាន់យកដោយគិតថា គេលះចោលហើយដូច្នេះ គួរ, ព្រោះហេតុអ្វី ? ព្រោះហេតុថា ឈើទាំងនោះម្ចាស់ព្រៃ (អ្នកកាន់កាប់ព្រៃឈើ) មិនមានឥស្សរៈ ។ ឈើទាំងឡាយដែលជនពួកណាឱ្យទេយ្យធម៌ (វត្ថុដែលគប្បីឱ្យតបស្នង) ដល់ម្ចាស់ព្រៃហើយទើបកាត់, ជនទាំងនោះឯង ជាឥស្សរៈនៃឈើទាំងនោះហើយ; ម្យ៉ាងទៀត ជនទាំងនោះក៏បោះបង់ឈើទាំងនោះហើយ ឈើជាដើមដែលកើត

ក្នុងព្រៃនោះ ក៏មិនមានអាល័យ (គឺមិនមានអ្នកហួងហែង) ព្រោះហេតុនោះ ភិក្ខុនឹងកាន់យកឈើដូច្នោះក៏គួរ ។ សូម្បីភិក្ខុណា ឱ្យទេយ្យធម៌ដល់អ្នករក្សាព្រៃឈើជាមុនហើយចូលព្រៃ ឱ្យកាន់យកឈើទាំងឡាយបានតាមសេចក្ដីពេញចិត្ត, ការដែលភិក្ខុនោះ សូម្បីនឹងមិនទៅកាន់ទីរក្សា (ទីត្រួតពិនិត្យ) របស់អ្នករក្សាព្រៃឈើទាំងនោះ ទៅដោយមកតាមដែលខ្លួនពេញចិត្ត ក៏គួរ ។ សូម្បីបើលោកកាលចូលទៅ មិនទាន់បានឱ្យទេយ្យធម៌ ធ្វើទុកក្នុងចិត្តថា កាលចេញមក នឹងឱ្យ ដូច្នេះ ឱ្យកាន់យកឈើទាំងឡាយ ហើយខណៈចេញមកឱ្យទេយ្យធម៌ដែលគួរឱ្យ ដល់ពួកអ្នករក្សាព្រៃឈើទាំងនោះហើយទៅ សមគួរពិត ។ សូម្បីបើលោកធ្វើសេចក្ដីចងចិត្តទុកហើយទើបទៅ កាលអ្នករក្សាព្រៃឈើទាមទារថា "លោកម្ចាស់ចូរឱ្យ" ឆ្លើយថា "អាត្មានឹងឱ្យ" កាលគេទាមទារទៀតថា "ចូរឱ្យ" គប្បីឱ្យតែម្ដង បើមានអ្នកណាមួយឱ្យទ្រព្យរបស់ខ្លួនហើយនិយាយ (នឹងអ្នករក្សាព្រៃ) ថា "ពួកលោកចូរឱ្យភិក្ខុទៅចុះ" ដូច្នេះ, ភិក្ខុនឹងទៅតាមហេតុអាងដែលខ្លួនបានហើយនោះឯង គួរ ។ តែបើអ្នកណាមួយមានជាតិជាឥស្សរៈ (ប្រធានធំ) មិនបានឱ្យទ្រព្យឡើយ ហាមថា "ពួកលោកកុំកាន់យកចំណែករបស់ពួកភិក្ខុ" ដូច្នេះ តែពួកអ្នករក្សាព្រៃឈើ និយាយថា "កាលពួកយើងមិនទទួលយករបស់ពួកភិក្ខុនិងពួក

តាបសហើយ តើនឹងបានអំពីទីណាហ្ន៎ ? ឱ្យចុះលោកម្ចាស់" ដូច្នេះ, ភិក្ខុគួរឱ្យដូចគ្នា ។ ចំណែកភិក្ខុណា កាលអ្នករក្សាព្រៃឈើដេកលក់ ឬវវល់ខ្វល់ខ្វាយក្នុងការលេង ឬចៀសទៅក្នុងទីណាមួយ សូម្បីហៅរកថា អើអ្នករក្សាព្រៃឈើនៅទីណា ? ដូច្នេះ គ្រាមិនជួប ទើបចេញទៅ, ភិក្ខុនោះ ជាភណ្ឌទេយ្យ ។ ចំណែកភិក្ខុណា គ្រាទៅដល់ស្ថានទីរក្សាហើយ តែមនសិការក្នុងព្រះកម្មដ្ឋានជាដើម ឬបញ្ជូនចិត្តទៅកាន់ទីដទៃ ទើបដើរហួសទៅ ព្រោះរលឹកមិនបាន, ភិក្ខុនោះ ជាភណ្ឌទេយ្យដូចគ្នា ។ សូម្បីភិក្ខុណាទៅដល់ស្ថានទីនោះហើយ មានចោរ ដំរី ម្រឹគកាច ឬមហាមេឃប្រាកដឡើង, កាលភិក្ខុនោះ ប្រញាប់ឆ្លងស្ថានទីនោះហួសទៅ ព្រោះត្រូវការនឹងផុតចាកឧបទ្រវៈនោះ, នៅរក្សាទុកសិន, តែក៏ជាភណ្ឌទេយ្យ ។ ដែលឈ្មោះថា ស្ថានទីរក្សាក្នុងព្រៃនេះ ជារបស់ធ្ងន់ណាស់ សូម្បីជាងដែនគយ ។ ពិតមែន ភិក្ខុកាលមិនឈានចូលទៅកាន់ព្រំប្រទល់នៃដែនគយ លបចៀសចេញទៅតាំងអំពីចម្ងាយ នឹងត្រូវត្រឹមតែទុក្កដប៉ុណ្ណោះ តែកាលលោកលបចៀសអំពីទីរក្សាក្នុងព្រៃនេះទៅដោយថេយ្យចិត្ត សូម្បីនឹងទៅតាមអាកាសក៏ដោយ ក៏ជាបារាជិកដោយពិត ព្រោះហេតុនោះ ភិក្ខុគប្បីជាអ្នកមិនប្រមាទក្នុងស្ថានទីរក្សាក្នុងព្រៃ ដូច្នេះឯង ។

ទ្រព្យដែលនៅក្នុងព្រៃ ចប់

## ទ្រព្យគឺទឹក

[១០៥] ក៏អ្នកសិក្សាគប្បីជ្រាបវិនិច្ឆ័យក្នុងទឹកដូច្នេះ ៖

បទថា **ភាជនគតំ : ដែលមាននៅក្នុងភាជនៈ** បានដល់ ទឹកដែលគេរួមទុកក្នុងភាជន៍ទាំងឡាយ មានក្អមទឹកជាដើម ក្នុងវេលាដែលរកទឹកបានលំបាក ។ ទឹកនោះគេរក្សាទុកក្នុងភាជន៍ណា កាលភិក្ខុផ្អៀងភាជន៍នោះ ធ្វើឱ្យជាប្រហោងធ្លុះកាន់យកក្តី ធ្វើទឹកដែលមាននៅក្នុងភាជន៍ទាំងនោះ និងក្នុងស្រះបោក្ខរណី និងអណ្តូង ចូលទៅកាន់ភាជន៍របស់ខ្លួន ក៏គប្បីជ្រាបវិនិច្ឆ័យដោយន័យដូចដែលពោលទុកក្នុងទឹកដោះថ្លានិងប្រេងនុំះឯង ។

ចំណែកក្នុងការទម្លាយទំនប់ទឹក មានវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុទម្លាយទំនប់ទឹក សូម្បីព្រមទាំងភូតគាម ដែលកើតឡើងក្នុងទំនប់នោះ ត្រូវទុក្កដ ព្រោះជាប្រយោគនៃអទិន្នាទាន ។ ក៏ឯទុក្កដនោះ រមែងត្រូវគ្រប់វារៈដែលទម្លាយ ។ ភិក្ខុឈរខាងក្នុងហើយបែរមុខទៅខាងក្រៅទម្លាយ ព្រះវិន័យធរគប្បីពិន័យអាបត្តិដោយចំណែកទីបំផុតខាងក្រៅ, កាលឈរខាងក្រៅ ហើយបែរមុខចូលទៅខាងក្នុងទម្លាយ គប្បីពិន័យអាបត្តិដោយចំណែកទីបំផុតខាងក្នុង, កាលលោកទម្លាយ បែរមុខទៅទាំងខាងក្នុងនិងខាងក្រៅ គឺ ឈរនៅត្រង់ពាក់កណ្តាលទម្លាយ

ទំនប់ទឹកនោះ គប្បីពិន័យអាបត្តិដោយចំណែកត្រង់កណ្តាល ។

ភិក្ខុធ្វើទំនប់ឱ្យទ្រុឌទ្រោមហើយ ទើបកៀងហ្វូងគោមកដោយខ្លួនឯង ឬប្រើឱ្យពួកក្មេងអ្នកស្រុកកៀងមកក៏ដោយ ។ ហ្វូងគោទាំងនោះនាំគ្នាយកក្រចកជើងទម្លាយទំនប់ ទំនប់រមែងជាការដែលភិក្ខុនោះឯងទម្លាយហើយ ។ ភិក្ខុធ្វើទំនប់ឱ្យទ្រុឌទ្រោមហើយ កៀងហ្វូងគោចូលទៅក្នុងទឹកក្តី ប្រើពួកក្មេងអ្នកស្រុកឱ្យកៀងចូលទៅក្តី, រលកដែលគោ ទាំងនោះធ្វើឱ្យកើតឡើងទម្លាយទំនប់ទៅ ។ ម្យ៉ាងទៀត ភិក្ខុនិយាយបបួលពួកក្មេងអ្នកស្រុកថា "ចូរនាំគ្នាលេងទឹកចុះ" ឬសំឡុតពួកក្មេងអ្នកលេងឱ្យភ័យខ្លាច, រលកដែលកើតឡើងនោះទម្លាយទំនប់ទៅ ។ ភិក្ខុកាត់ដើមឈើដែលកើតនៅខាងក្នុងទឹកខ្លួនឯង ឬប្រើឱ្យអ្នកដទៃកាត់ក៏ដោយ, រលកសម្បីដែលដើមឈើដួលចុះនោះ ធ្វើឱ្យតាំងឡើង ធ្លាយទំនប់ទៅ, ជាការដែលថា ភិក្ខុនោះឯង ជាអ្នកទម្លាយទំនប់ហើយ ។ ភិក្ខុធ្វើទំនប់ឱ្យទ្រុឌទ្រោមហើយ បិទទឹកដែលគេបង្ហូរចេញទៅ ឬបិទប្រឡាយសម្រាប់បង្ហូរទឹកចេញអំពីស្រះទៅ ដើម្បីត្រូវការរក្សាស្រះក្តី លើកភ្លឺ ឬចាត់ចែងប្រឡាយឱ្យត្រង់ ដោយអាការដែលទឹកហូរទៅពីទីដទៃ នឹងហូរចូលទៅក្នុងស្រះនេះបានក្តី ទំនប់ស្រះរបស់ខ្លួនដែលនៅខាងលើស្រះរបស់អ្នកដទៃនោះក្តី, ទឹកដែលជោជន់ហៀរឡើង ហូរគួចយកទំនប់ទៅ ទំនប់រមែងជាការដែលភិក្ខុនោះឯង ជាអ្នកទម្លាយទំនប់ទៅហើយ ។ ក្នុង

ទីទាំងពួង ព្រះវិន័យធរគប្បីពិន័យដោយអវហារ ល្មមសមគួរដល់តម្លៃទឹកដែលហូរចេញទៅ ។ សូម្បីកាលភិក្ខុបើកប្រឡាយសម្រាប់បង្ហូរទឹកចេញទៅ ក៏មានន័យនេះដូចគ្នា ។

មួយទៀត បើភិក្ខុនោះធ្វើទំនប់ឱ្យទ្រុឌទ្រោមហើយ ហ្វូងគោដែលដើរមកតាមធម្មតារបស់ខ្លួនទុំះឯង ឬពួកក្មេងអ្នកស្រុកដែល ( ភិក្ខុ ) មិនបានបង្គាប់ ជួយគ្នាដេញកៀងឱ្យឡើង ទៅយកក្រចកជើងទម្លាយទំនប់ក្តី ហ្វូងគោដែលពួកក្មេងអ្នកស្រុកមិនបានបង្គាប់ ជួយគ្នា ដេញកៀងឱ្យចុះទៅក្នុងទឹកតាមធម្មតារបស់ខ្លួនឯង ធ្វើឱ្យរលកកើតឡើងក្តី, ពួកក្មេងអ្នកស្រុកនាំគ្នាចូលទៅលេងទឹកដោយខ្លួនឯង ធ្វើឱ្យរលកតាំងឡើងក្តី, ដើមឈើ ( ដែលកើតនៅ ) ខាងក្នុងទឹក ដែលត្រូវជនពួកដទៃកាត់ជាប់ដួលចុះហើយ ធ្វើរលកឱ្យតាំងឡើង, រលកនោះ ៗ ទំលាយទំនប់ទៅក្តី, សូម្បីបើថា ភិក្ខុធ្វើទំនប់ឱ្យទ្រុឌទ្រោម ហើយបិទកន្លែងដែលគេបង្ហូរទឹកចេញទៅ ឬប្រឡាយសម្រាប់បង្ហូរទឹកនៃស្រះរងស្ងួត លើកភ្លឺ ឬបាត់ចែងប្រឡាយដែលស្ងួតឱ្យត្រង់មកទឹកហូរទៅទីដទៃ, ខាងក្រោយក្នុងកាលភ្លៀងធ្លាក់ ទឹកហូរប្រោះទម្លាយទំនប់ទៅ, ក្នុងទីគ្រប់ ៗ កន្លែង ជាភណ្ឌទេយ្យ ។ ចំណែកភិក្ខុណា ទម្លាយទំនប់បឹងរងស្ងួតក្នុងរដូវប្រាំងឱ្យត្រង់ចុះដរាបដល់ផែនដី, ខាងក្រោយក្នុងកាលភ្លៀងធ្លាក់ ទឹកដែលហូរមក

ម្តងហើយម្តងទៀត ក៏ហូរទៅអស់, ជាភណ្ឌទេយ្យដល់ភិក្ខុនោះ ។ សន្ទូងមានប្រមាណប៉ុនណា ដែលកើតឡើងព្រោះមានទឹកនោះជាបច្ច័យ, ភិក្ខុមិនសង កាលតម្លៃជំនួសស្មើតម្លៃមួយបាទឬច្រើនជាងមួយបាទអំពីសន្ទូង (ដែលខូច) នោះ ចាត់ថា មិនជាសមណៈ ព្រោះពួកម្ចាស់សន្ទូងដាក់ធុរៈ ។ តែពួកអ្នកស្រុកសូម្បីទាំងអស់ ជាឥស្សរៈនៃទឹកក្នុងបឹងទូទៅដល់ជនទាំងពួង គេនឹងស្ទូងសន្ទូងទាំងឡាយទុកខាងក្នុងបឹងនោះផង ។ ទឹកក៏ហូរចេញពីប្រឡាយធំអំពីបឹងទៅដោយត្រង់កណ្តាលស្រែ ដើម្បីរក្សាសន្ទូង ។ សូម្បីប្រឡាយធំនោះ ក៏ជាសាធារណៈដល់ជនទាំងពួង ក្នុងវេលាទឹកហូរសព្វកាល ។ ចំណែកពួកជនធ្វើប្រឡាយតូច ៗ ចេញពីប្រឡាយធំនោះ ហើយបង្ហូរទឹកឱ្យចូលទៅក្នុងស្រែរបស់ខ្លួន ៗ ។ មិនព្រមឱ្យអ្នកដទៃកាន់យកទឹកក្នុងប្រឡាយតូចរបស់ខ្លួននោះ, កាលមានទឹកតិចក្នុងរដូវប្រាំង ទើបបែងចែកទឹកឱ្យគ្នាតាមវារៈ ។ អ្នកណា កាលដល់វារៈទឹក មិនបានទឹក, សន្ទូងរបស់អ្នកនោះ រមែងស្វិតស្រពោនទៅ ។ ព្រោះហេតុនោះ អ្នកដទៃរមែងមិនបានទទួលយកទឹកក្នុងវារៈរបស់បុគ្គលទាំងឡាយដទៃទេ ។ បណ្តាប្រឡាយតូចជាដើមនោះ ភិក្ខុណា បង្ហូរទឹកចាកប្រឡាយតូច ឬអំពីស្រែរបស់ជនពួកដទៃ ឱ្យចូលទៅកាន់អណ្តូង ឬស្រែរបស់ខ្លួន ឬរបស់អ្នកដទៃដោយថេយ្យចិត្តក្តី ឱ្យទឹក

ហូរចូលទៅកាន់មាត់ព្រែក្ដី, ភិក្ខុនោះ ជាអវហារពិត ។ ចំណែកភិក្ខុណា គិតថា យូរ ៗ យើងនឹងមានទឹកត្រឹមតែមួយគ្រា និងសន្ទូងនេះក៏ស្វិតស្រពោន ទើបបិទមកហូររបស់ទឹកដែលកំពុងហូរចូលទៅក្នុងស្រែរបស់ពួកជនដទៃចេញ ហើយឱ្យហូរចូលទៅកាន់ស្រែរបស់ខ្លួន, ភិក្ខុនោះជាអវហារដូចគ្នា ។ ក៏បើថា កាលទឹកមិនទាន់ហូរចេញអំពីបឹង ឬមិនទាន់ហូរទៅដល់មាត់អណ្តូងរបស់ជនពួកដទៃ, ភិក្ខុធ្វើប្រឡាយស្ងួតនុ៎ះឯងទុកក្នុងទីនោះ ៗ ដោយអាការដែលទឹកកំពុងហូរមក នឹងមិនហូរចូលទៅក្នុងស្រែរបស់ជនពួកដទៃ ហូរចូលទៅតែក្នុងស្រែរបស់ខ្លួនប៉ុណ្ណោះ, កាលទឹកមិនទាន់ហូរចេញមក តែភិក្ខុបានបង្កើតទំនប់ទុកមុនហើយ ក៏ជាការលោកបង្កទំនប់ទុកល្អហើយ, កាលទឹកហូរចេញមកហើយ បើភិក្ខុបង្កទំនប់ ជាភណ្ឌទេយ្យ ។ សូម្បីកាលភិក្ខុទៅ កាន់បឹង ហើយបើកប្រឡាយសម្រាប់បង្ហូរទឹកចេញដោយខ្លួនឯង ឱ្យទឹកហូរចូល ទៅកាន់ស្រែរបស់ខ្លួន មិនជាអវហារ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ខ្លួនអាស្រ័យបឹងទើបបានធ្វើស្រែ ។ តែក្នុងអដ្ឋកថាកុរុន្ទីជាដើម ពោលថា ជាអវហារ ពាក្យដែលលោកពោលទុកនោះ រមែងមិនសមដោយលក្ខណៈនេះថា វត្ថុ កាលៈ ទេសៈជាដើម ។ ព្រោះហេតុនោះ ពាក្យដែលលោកពោលទុកក្នុងមហាអដ្ឋកថានុ៎ះឯងប្រពៃហើយ ដូច្នេះឯង ។

ទ្រព្យគឺទឹក ចប់

## ឈើជម្រះធ្មេញ

[១០៦] ឈើជម្រះធ្មេញ ដែលអ្នកសិក្សាគប្បីវិនិច្ឆ័យតាមការវិនិច្ឆ័យទុកក្នុងភណ្ឌៈតាំងនៅ ក្នុងសួន ។ ចំណែកសេចក្ដីប្លែកគ្នាក្នុងឈើជម្រះធ្មេញនេះ មានដូចតទៅនេះ ៖

វេយ្យាវច្ចករណា ជាអ្នកដែលសង្ឃចិញ្ចឹមទុកដោយតម្លៃឈ្នួល រមែងនាំឈើជម្រះធ្មេញមកប្រគេនរាល់ថ្ងៃ ឬតាមវារៈបក្ខទិនខែ, វេយ្យាវច្ចករនោះ នាំឈើ ជម្រះធ្មេញនោះមក សូម្បីកាត់ហើយ មិនទាន់ប្រគល់ប្រគេនភិក្ខុសង្ឃត្រឹមណា, ឈើជម្រះធ្មេញនោះ ក៏នៅជារបស់វេយ្យាវច្ចករនោះ ត្រឹមនោះ, ព្រោះហេតុនោះ ភិក្ខុកាលកាន់យកឈើជម្រះធ្មេញនោះដោយថេយ្យចិត្ត គប្បីពិន័យអាបត្តិតាមតម្លៃវត្ថុ ។ មួយទៀត មានរបស់គរុភណ្ឌដែលកើតឡើងក្នុងអារាមនោះ ។ ភិក្ខុកាលកាន់យករបស់គរុភណ្ឌសូម្បីនោះ ដែលភិក្ខុសង្ឃរក្សាឃុំគ្រង ក៏គប្បីពិន័យអាបត្តិតាមតម្លៃវត្ថុ ។ សូម្បីឈើជម្រះធ្មេញដែលកាត់ហើយ និងមិនទាន់បានកាត់ ដែលជារបស់គណៈ បុគ្គលនិងមនុស្សគ្រហស្ថក្ដី ក្នុងភណ្ឌៈដែលកើតឡើងក្នុងអារាម និងសួនជាដើម របស់គណៈ បុគ្គលនិងមនុស្សគ្រហស្ថទាំងនោះក្ដី ក៏មានន័យដូចគ្នា ។ សាមណេរទាំង

ឡាយ កាលនាំឈើជម្រះធ្មេញមកប្រគេនដល់ភិក្ខុសង្ឃតាមវារៈ រមែងនាំមកប្រគេនដល់អាចារ្យ និងឧបជ្ឈាយ៍ (របស់ខ្លួន)ៗ លោកទាំងនោះ គ្រាកាត់ឈើជម្រះធ្មេញនោះហើយ មិនទាន់ប្រគល់ប្រគេនសង្ឃត្រឹមណា, ឈើជម្រះធ្មេញនោះសូម្បីទាំងអស់ ក៏នៅជារបស់លោកទាំងនោះឯងត្រឹមនោះ, ព្រោះហេតុនោះ ភិក្ខុកាលកាន់យកឈើជម្រះធ្មេញសូម្បីនោះដោយថេយ្យចិត្ត ក៏គប្បីពិន័យអាបត្តិតាមតម្លៃវត្ថុ ៗ តែកាលណា សាមណេរទាំងនោះកាត់ឈើជម្រះធ្មេញហើយ បានប្រគល់ប្រគេនសង្ឃហើយ រក្សាទុកនៅក្នុងរោងឈើជម្រះធ្មេញ ដោយគិតក្នុងចិត្តថា “ភិក្ខុសង្ឃចូរប្រើប្រាស់តាមសប្បាយចុះ” ដូច្នេះ, តាំងអំពីកាលនោះទៅមិនជាអវហារ តែក៏គួរជ្រាបទំនៀម ៗ ពិតមែន ភិក្ខុណា ចូលទៅកណ្ដាលជំនុំសង្ឃរាល់ថ្ងៃ, ភិក្ខុនោះ គួរកាន់យកឈើជម្រះធ្មេញមួយថ្ងៃបានត្រឹមតែមួយប៉ុណ្ណោះ ៗ ចំណែកភិក្ខុណា មិនចូលទៅត្រង់កណ្ដាលជំនុំសង្ឃរាល់ថ្ងៃ សម្រាកក្នុងផ្ទះដែលបំពេញព្យាយាម នឹងប្រាកដខ្លួនបានតែក្នុងទីស្ដាប់ធម៌ ឬក្នុងរោងឧបោសថ; ភិក្ខុនោះគួរកំណត់ប្រមាណហើយរក្សាឈើជម្រះធ្មេញ ៤-៥ ដែលទុកក្នុងទីនៅរបស់ខ្លួនទំពាចុះ ៗ កាលឈើជម្រះធ្មេញទាំងនោះ អស់ទៅហើយ តែបើក្នុងរោងឈើជម្រះធ្មេញ នៅមានច្រើន ក៏គួរនាំមកទំពាបានទៀត, បើលោកមិនកំណត់

ប្រមាណ នៅតែនាំមកសោត, កាលឈើជម្រះធ្មេញទាំងនោះមិនទាន់អស់នៅឡើយ, តែក្នុងពេលអស់ទៅ; គ្រានោះ ព្រះថេរៈទាំងឡាយពួកខ្លះគប្បីនិយាយថា "ពួកភិក្ខុដែលនាំឈើជម្រះធ្មេញទៅ ចូរនាំមកវិញ", ពួកខ្លះពោលថា "ចូរទំពាទៅចុះ, ពួកសាមណេរនឹងនាំមកប្រគេនទៀត" ព្រោះហេតុនោះ ទើបគួរកំណត់ប្រមាណ ដើម្បីចៀសវាងការវិវាទគ្នា តែមិនមានទោសក្នុងការកាន់យក ។ សូម្បីភិក្ខុដែលនឹងធ្វើដំណើរ គួរដាក់ឈើជម្រះធ្មេញមួយ ឬពីរដើមក្នុងថង់យាមហើយទើបទៅ ដូច្នេះឯង ។

ឈើជម្រះធ្មេញ ចប់

## ដើមឈើម្ចាស់ព្រៃ

[១០៧] បទថា **វនប្បតិ** : **ដើមឈើ** បានដល់ ដើមឈើជាម្ចាស់នៃព្រៃ ពាក្យថា **វនប្បតិ** នោះ ជាឈ្មោះរបស់ដើមឈើដែលចម្រើនបំផុតក្នុងព្រៃ ។ ក៏ដើមឈើដែលពួកមនុស្សហួងហែងសូម្បីទាំងអស់ មានស្វាយ ខ្នុរសម្ល និងខ្នុរធម្មតាជាដើម លោកប្រាថ្នាយកក្នុងអធិការនេះ ។ ឬថា ពួកមនុស្សដាំម្រេច និងវល្លិជាដើមទុកត្រង់ដើមឈើណា, ដើមឈើនោះ កាលត្រូវភិក្ខុកាត់ បើសំបកក្តី សរសៃក្តី ក្រមរក្តី ស្រាយក្តី សូម្បីមួយដើម នៅជាប់ស្អិតគ្នានោះឯង ដួលចុះលើ

ផែនដី ក៏នៅរក្សាទុកសិន ។ ចំណែកដើមឈើណាសូម្បីត្រូវគាត់ដាច់ហើយ ក៏តាំងនៅត្រង់ ៗ នុ៎ះឯង ព្រោះមានវល្លិឬមែកឈើដោយជុំវិញទ្រទុក ឬកាលដួលចុះទៅមិនទាន់ដល់ផែនដី, ក្នុងដើមឈើនោះ មិនមានការគេចផុតទេ គឺ ជាអវហារតែម្តង ។ សូម្បីដើមឈើណា ដែលភិក្ខុយករណាកាត់ដាច់ហើយ ក៏តាំងនៅក្នុងទីនោះឯង ដូចជាមិនទាន់ដាច់ដូច្នោះ, សូម្បីក្នុងដើមឈើនោះ ក៏មានន័យនេះ ដូចគ្នា ។ ចំណែកភិក្ខុណា ធ្វើដើមឈើឱ្យខ្សោយកម្លាំង ខាងក្រោយទើបអង្រួនឱ្យដួលចុះក្តីឱ្យអ្នកដទៃអង្រួនក្តី កាត់ឈើដើមដទៃជិតដើមឈើនោះសង្កត់ចុះទុកឯងក្តីឱ្យអ្នកដទៃ កាត់សង្កត់ក្តី កៀងពួកស្វាឱ្យទៅឡើងលើដើមឈើនោះក្តីបង្គាប់អ្នកដទៃឱ្យកៀងឡើងទៅក្តី កៀងពួកជ្រើងឱ្យឡើងលើដើមឈើនោះក្តី បង្គាប់អ្នកដទៃឱ្យកៀងឡើងទៅក្តី ជ្រើងទាំងនោះ ធ្វើដើមឈើនោះឱ្យដួលចុះ; អវហារ រមែងមានដល់ភិក្ខុនោះដូចគ្នា ។ តែបើលោកធ្វើដើមឈើឱ្យខ្សោយកម្លាំងហើយ មានអ្នកដទៃដែលលោកមិនបានបង្គាប់ទេ អង្រួនដើមឈើនោះឱ្យដួលចុះក៏ដោយ យកដើមឈើសង្កត់ដោយខ្លួនឯងក៏ដោយ ពួកស្វាឬជ្រើងឡើង តោងតាមធម្មតារបស់ខ្លួនក៏ដោយមានអ្នកដទៃដែលលោកមិនបានបង្គាប់ ឡើងទៅដោយខ្លួនគេក៏ដោយ លោកកាប់ឆ្ការត្រោយមកមកនៃខ្យល់ដោយខ្លួនឯងក៏ដោយ, ខ្យល់ខ្លាំងបក់មកធ្វើ

ដើមឈើឱ្យដួលចុះ; ជាភណ្ឌទេយ្យ ក្នុងទីគ្រប់កន្លែង ។ ក៏ក្នុងអធិការនេះ ការបោសកាប់ឆ្ការមកមកនៃខ្យល់ក្នុងកាលខ្យល់ មិនទាន់បក់មកដល់ រមែងសមដោយកិច្ចទាំងឡាយ មានការចាត់ចែងប្រឡាយដែលរឹងសួតឱ្យត្រង់ជាដើម មិនសមដោយប្រការដទៃទេ ។ ភិក្ខុបោះដើមឈើហើយយកសស្រ្តាសៀតចូលក្តី បង្កាត់ភ្លើងដុតក្តី ដំឡើងដែលជាពិសទុកក្តី ជាហេតុឱ្យដើមឈើនោះផាប់ ជាភណ្ឌទេយ្យដូចគ្នា ដូច្នេះឯង ។

ដើមឈើម្ចាស់ព្រៃ ចប់

## ទ្រព្យដែលមានអ្នកនាំទៅ

[១០៨] ក្នុងភណ្ឌៈដែលមានអ្នកនាំទៅ មានវិនិច្ឆ័យដូច្នេះ ៖ ភណ្ឌៈដែលអ្នកដទៃនាំទៅ ឈ្មោះថា **ហរណកៈ** ។

ពីរបទថា **ថេយ្យចិត្តោ អាមសតិ** : ភិក្ខុមានថេយ្យចិត្តចាប់ពាល់ត្រូវទ្រព្យនោះ សេចក្តីថា ភិក្ខុឃើញជនដទៃអ្នកប្រើ ភារលើក្បាលជាដើមទូលយកវត្ថុដើរទៅ ហើយគិតនៅក្នុងចិត្តថា យើងនឹងដណ្តើមយកវត្ថុនោះទៅ ទើបប្រញាប់ទៅស្ទាបអង្អែល ត្រឹមតែការស្ទាបអង្អែលប៉ុណ្ណេះ លោកត្រូវអាបត្តិទុក្កដ ។

បទថា **ផន្ទាបេតិ** : ធ្វើទ្រព្យនោះឱ្យកម្រើក សេចក្តីថា ភិក្ខុធ្វើ

ការទាញមកនិងរុញទៅ តែម្ចាស់របស់មិនទាន់លែងចេញ, ព្រោះធ្វើឱ្យកម្រើកនោះ ត្រូវអាបត្តិថុល្លច្ច័យ ។

ពីរបទថា ឋានា ចាវេតិ : ធ្វើទ្រព្យនោះឱ្យឃ្លាតផុតចាកទី សេចក្ដីថា ភិក្ខុទាញមកឱ្យផុតពីដៃម្ចាស់ទ្រព្យ, ព្រោះហេតុដែលឱ្យផុតនោះ ត្រូវអាបត្តិបារាជិក ។ សូម្បីបើម្ចាស់ភណ្ឌៈក្រោកឡើងហើយវាយតប់ភិក្ខុនោះ បន្ទាប់ឱ្យដាក់ភណ្ឌៈនោះ ហើយទើបយកមកវិញ, ភិក្ខុនោះក៏ត្រូវអាបត្តិបារាជិក ព្រោះការកាន់យកគ្រាដំបូងនុ៎ះឯង ។ កាលភិក្ខុកាត់ឬដោះគ្រឿងអលង្ការពីសីសៈ ត្រចៀក ក ឬពីដៃកាន់យកល្មមត្រឹមតែលោកដោះឱ្យផុតអំពីអវយវៈមានសីសៈជាដើម ក៏ត្រូវអាបត្តិបារាជិក ។ តែលោកមិនបាននាំកងដៃឬគ្រឿងប្រដាប់ត្រង់ដៃចេញ ត្រឹមតែរូតទៅខាងចុងដៃ ឱ្យរំកិលទៅមក ៗ ឬធ្វើឱ្យផុតទៅក្នុងអាកាស, ក៏នៅរក្សាបាន ។ គ្រឿងប្រដាប់មានកងដៃជាដើម មិនឱ្យអាបត្តិបារាជិកកើតបានទេ ដូចជាកងដែលជាប់នឹងគល់ឈើ និងស្នួរចីវរដូច្នោះ ព្រោះហេតុអ្វី ព្រោះហេតុថា ដៃដែលពាក់គ្រឿងប្រដាប់មានវិញ្ញាណ, ពិតមែន គ្រឿងប្រដាប់មានកងដៃជាដើម ដែលពាក់នៅក្នុងចំណែកនៃអវយវៈដែលមានវិញ្ញាណ មិនទាន់នាំចេញផុតពីដៃត្រឹមណា ក៏នៅក្នុងដៃនោះឯងត្រឹមនោះ ។ ក្នុងវង់ចិញ្ចៀនដែលពាក់ម្រាមដៃ ក្នុងគ្រឿងប្រដាប់ជើង និងចង្កេះ ក៏មាន

ន័យនេះដូចគ្នា ។ ចំណែកភិក្ខុណា ប្រជែងដណ្តើមយកសំពត់សាដក ដែលអ្នកដទៃ ស្ទៀកដណ្តប់ និងអ្នកដទៃនោះ ក៏មិនលែងឱ្យរបូតចេញ ដោយរហ័ស ព្រោះមានសេចក្តីខ្មាស, ភិក្ខុដែលជាចោរទាញជាយម្ខាង, អ្នកដទៃ (ម្ចាស់សំពត់) ក៏ទាញជាយម្ខាងទៀត; នៅរក្សាទុកសិន ។ កាលសំពត់នោះត្រឹមតែផុតពីដៃរបស់អ្នកដទៃ ភិក្ខុនោះត្រូវអាបត្តិ បារាជិក ។ សូម្បីកាលសំពត់សាដកដែលភិក្ខុកំពុងទាញមកជាប់នៅក្នុងដៃ មួយចំណែក ឯមួយចំណែកនោះ បានតម្លៃគ្រប់ ១ បាទ ក៏ត្រូវអាបត្តិ បារាជិកដូចគ្នា ។

បទថា **សហភណ្ឌហារកំ** : ទ្រព្យព្រមទាំងអ្នកនាំទ្រព្យ សេចក្តីថា ភិក្ខុគិតថា "យើងនឹងនាំភណ្ឌៈព្រមទាំងបុគ្គលអ្នកនាំភណ្ឌៈ ទៅ" ដូច្នេះហើយ ទើបគម្រាមអ្នកនាំភណ្ឌៈទៅថា "ឯងចូរទៅអំពីទី នេះ" ។ បុគ្គលអ្នករោមភណ្ឌៈទៅនោះខ្លាច ទើបបានបែរមុខទៅកាន់ទិស តាមដែលភិក្ខុចោរប្រាថ្នា ឈានជើងម្ខាងទៅ ជាថុល្លច្ច័យ ដល់ភិក្ខុចោរ, ជាអាបត្តិបារាជិក ក្នុងជំហានទីពីរ ។

បទថា **ធាតាបេតិ** : ធ្វើរបស់គេឱ្យជ្រុះឬឱ្យធ្លាក់ចុះ សេចក្តីថា សូម្បីបើភិក្ខុដែលជាចោរ ឃើញអាវុធក្នុងដៃរបស់បុគ្គលអ្នកនាំភណ្ឌៈទៅ ជាអ្នកមានសេចក្តីខ្វល់ខ្វាយ ប្រាថ្នានឹងធ្វើឱ្យអាវុធធ្លាក់ទៅ ហើយកាន់

យកអាវុធនោះ ទើបថយចេញទៅនៅក្នុងចំណែកមួយខាងហើយសំឡុតធ្វើឱ្យអាវុធធ្លាក់ទៅ ល្មមត្រឹមតែអាវុធរបូតពីដៃរបស់អ្នកដទៃហើយ ក៏ត្រូវបារាជិក ។ ចំណែកពាក្យថា "ធ្វើទ្រព្យឱ្យធ្លាក់ទៅ ត្រូវអាបត្តិទុក្កដ" ជាដើម ព្រះអង្គត្រាស់ទុកហើយដោយអំណាចសេចក្ដីកំណត់ ។ ពិតមែន ភិក្ខុណាកំណត់ទុកថា "យើងនឹងធ្វើឱ្យវត្ថុធ្លាក់ទៅ ហើយនឹងកាន់យកវត្ថុដែលយើងពេញចិត្ត" ដូច្នេះ ហើយទើបធ្វើឱ្យធ្លាក់ទៅ, លោករូបនោះត្រូវទុក្កដ ព្រោះធ្វើឱ្យវត្ថុនោះធ្លាក់ទៅ និងព្រោះការចាប់ត្រូវវត្ថុនោះ, ត្រូវថុល្លច្ច័យ ព្រោះធ្វើឱ្យកម្រើក, ត្រូវបារាជិក ព្រោះធ្វើវត្ថុដែលមានតម្លៃគ្រប់ ១ បាទ ឱ្យឃ្លាតចាកឋាន ។ សូម្បីកាលភិក្ខុត្រូវបុគ្គលអ្នកជញ្ជូនភណ្ឌៈប្រទានឱ្យដួល ខាងក្រោយទើបលែងវត្ថុនោះចេញ ភាពជាសមណៈមិនមានឡើយ ។ ចំណែកភិក្ខុណា ឃើញបុគ្គលអ្នកជញ្ជូនវត្ថុកំពុងឈានដើរទៅ ទើបដេញតាម និយាយបណ្ដើរថា "ឈប់ ឈប់ដាក់វត្ថុចុះ" ធ្វើឱ្យគេដាក់វត្ថុចុះ, សូម្បីភិក្ខុនោះ ក៏ត្រូវអាបត្តិបារាជិកក្នុងកាលត្រឹមតែវត្ថុផុតទៅចាកដៃរបស់អ្នកជញ្ជូនទៅ ព្រោះពាក្យបង្គាប់នោះជាហេតុ ។ ចំណែកភិក្ខុណា និយាយថា "ឈប់ ៗ" តែមិនបាននិយាយថា "ដាក់វត្ថុចុះ", និងបុគ្គលអ្នកជញ្ជូនវត្ថុទៅ ក្រៅនេះ ទើបក្រឡេកមើលភិក្ខុដែលជាចោរនោះ ហើយគិតថា "បើភិក្ខុចោរនេះ តាម

មកទាន់យើង នឹងសម្លាប់យើងចោលក៏បាន” ជាអ្នកមានសេចក្ដីព្រួយបារម្ភនៅឡើយ ទើបបានលាក់វត្ថុនោះ ទុកក្នុងទីព្រៃស្ដុក ដោយគិតក្នុងចិត្តថា “យើងនឹងត្រឡប់មកកាន់យក” ដូច្នេះ ហើយចៀសទៅ, មិនទាន់ជាបារាជិក ព្រោះមានការធ្វើឱ្យធ្លាក់ជាបច្ច័យ, តែកាលភិក្ខុមកកាន់យកដោយថេយ្យចិត្ត ជាបារាជិកក្នុងខណៈលើកឡើង ។ ក៏បើភិក្ខុដែលជាចោរនោះ មានសេចក្ដីរំពឹងយ៉ាងនេះថា វត្ថុនេះកាលយើងធ្វើឱ្យធ្លាក់ទៅប៉ុណ្ណោះ ឈ្មោះថា បានធ្វើឱ្យជារបស់ ៗ យើងហើយ ក្នុងចន្លោះដែលរំពឹងនោះ ទើបកាន់យកវត្ថុនោះ ដោយសេចក្ដីសម្គាល់ថា “ជារបស់ខ្លួន”, នៅរក្សា ព្រោះការកាន់យក, តែជាភណ្ឌទេយ្យ ។ កាលម្ចាស់របស់និយាយថា “លោកចូរឱ្យមកវិញ” កាលមិនឱ្យ ជាបារាជិកក្នុងកាលម្ចាស់របស់ដាក់ធុរៈ ។ សូម្បីកាលភិក្ខុកាន់យកដោយបង្សុកូលសញ្ញាថា “ម្ចាស់ភណ្ឌៈនោះ ចោលវត្ថុនេះទៅហើយ, ឥឡូវនេះ វត្ថុនេះមិនមានអ្នកណាហួងហែងទេ” ដូច្នេះ ក៏មានន័យដូចគ្នានេះ ។

ក្នុងមហាអដ្ឋកថាលោកពោលទុកថា តែបើម្ចាស់របស់កំពុងសម្លឹងមើលដោយហេតុ ត្រឹមតែពាក្យដែលភិក្ខុចោរនិយាយថា “ឈប់ ឈប់” ប៉ុណ្ណោះ ឃើញភិក្ខុចោរនោះ ហើយដាក់ធុរៈចេញ ដោយគិតថា “ឥឡូវនេះ វត្ថុនេះមិនមែនជារបស់យើង” អស់សេចក្ដីហួងហែង លះចោល

ចៀសចេញទៅ, កាលភិក្ខុកាន់យកវត្ថុនោះដោយថេយ្យចិត្ត ត្រូវទុក្កដក្នុងកាលលើកឡើង, កាលម្ចាស់របស់ឱ្យនាំមកសងវិញ គប្បីសងវិញ, កាលមិនសងទេ ជាបារាជិក ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា គេលះបោលវត្ថុនោះ ដោយប្រយោគរបស់ភិក្ខុនោះ ។ តែក្នុងអដ្ឋកថាទាំងឡាយដទៃ មិនមានពាក្យពិចារណាឡើយ ។ វិនិច្ឆ័យសូម្បីក្នុងភិក្ខុដែលកាន់យកដោយសេចក្ដីសម្គាល់ថា ជារបស់ខ្លួនក្ដី ដោយបង្សុកូលសញ្ញាក្ដី ដោយន័យមុននុ៎ះឯង ក៏ដូចគ្នានេះឯង ។

ចប់ អ្នកនាំទ្រព្យទៅ

## ទ្រព្យដែលជាបញ្ញើ

[១០៩] គប្បីជ្រាបវិនិច្ឆ័យក្នុងរបស់ផ្ញើតទៅ ៖

សូម្បីក្នុងការពោលកុហកទាំងដែលដឹងខ្លួនថា "ខ្ញុំមិនបានទទួលទុកទេ" ដូច្នេះ ទើបត្រូវទុក្កដ ព្រោះជាបុព្វបយោគនៃអទិន្នាទាន ។ គង់ត្រូវទុក្កដនុ៎ះឯង សូម្បីដល់ភិក្ខុដែលពោលពាក្យជាដើមថា "លោកនិយាយអ្វី ? ពាក្យនេះមិនសមគួរដល់ខ្ញុំ, ទាំងមិនសមគួរដល់លោកផង" ។ ម្ចាស់ទ្រព្យកើតសេចក្ដីសង្ស័យឡើងថា "យើងបានប្រគល់ទ្រព្យទុកក្នុង

ដៃរបស់ភិក្ខុនេះ ក្នុងទីកំបាំង, មិនមានអ្នកដទៃណាដឹង, លោកនឹងឱ្យដល់យើង ឬមិនឱ្យហ្ន៎ ?” ជាថុល្លច្ច័យដល់ភិក្ខុ ។ ម្ចាស់ទ្រព្យឃើញសភាពដែលភិក្ខុនោះ ជាភិក្ខុសាហាវជាដើម ទើបដាក់ធុរៈថា “ភិក្ខុនេះនឹងមិនឱ្យដល់យើងវិញទេ” ។ បណ្ដាភិក្ខុនិងម្ចាស់ទ្រព្យនោះ បើភិក្ខុនេះនៅមានសេចក្ដីឧស្សាហ៍ក្នុងការឱ្យថា “យើងនឹងធ្វើឱ្យគេលំបាកហើយនឹងឱ្យ” នៅរក្សាទុកសិន ។ សូម្បីបើលោកមិនមានសេចក្ដីឧស្សាហ៍ក្នុងការឱ្យ, តែម្ចាស់ភណ្ឌៈ នៅមានសេចក្ដីឧស្សាហ៍ក្នុងការទទួល, នៅរក្សាដូចគ្នា ។ តែបើភិក្ខុមិនមានឧស្សាហ៍ក្នុងការឱ្យនោះ, ម្ចាស់ភណ្ឌៈដាក់ធុរៈថា “ភិក្ខុនេះ នឹងមិនឱ្យដល់យើង” ជាបារាជិកដល់ភិក្ខុ ព្រោះដាក់ធុរៈរបស់ទាំងពីរខាង ដោយប្រការដូច្នេះ ។ សូម្បីបើភិក្ខុនិយាយតែមាត់ថា “នឹងឱ្យ” តែចិត្តមិនចង់ឱ្យ, សូម្បីដូច្នោះ ក៏ជាបារាជិក ព្រោះម្ចាស់របស់ដាក់ធុរៈ តែមិនជាអាបត្តិដល់ភិក្ខុដែលញ៉ាំងភណ្ឌៈ ឈ្មោះថា របស់ផ្ញើនោះដែលជនពួកដទៃប្រគល់ទុកក្នុងដៃរបស់ខ្លួន ដើម្បីប្រយោជន៍ដល់ការឃុំគ្រងមិនឱ្យឃ្លាតចាកឋាន តែប្រទេសដែលខ្លួនមិនបានឃុំគ្រង នាំទៅដើម្បីត្រូវការរក្សាទុកក្នុងទីឃុំគ្រង ។ អវហារ រមែងមិនមានដល់ភិក្ខុដែលឱ្យឃ្លាតចាកឋានសូម្បីដោយថេយ្យចិត្ត ។ ព្រោះហេតុអ្វី ? ព្រោះជារបស់ដែលគេផ្ញើទុកក្នុងដៃរបស់ខ្លួន, តែជាភណ្ឌទេយ្យ ។ សូម្បីកាលភិក្ខុដែល

ប្រើប្រាស់ចេញដោយថេយ្យចិត្ត ក៏មានន័យដូចគ្នានេះ ។ ដល់ក្នុងការកាន់យកជារបស់ខ្លួនវិញ ក៏ដូចគ្នា ។ សូម្បីពាក្យថា ឆម្មំ ចរន្តោ ជាដើម ក៏មានន័យដូចពោលហើយដូចគ្នា ។ ពណ៌នាព្រះបាលីប៉ុណ្ណេះមុន ។

ចំណែកវិនិច្ឆ័យក្រៅព្រះបាលីក្នុងរបស់ផ្ញើនេះ លោកពោលទុកហើយដោយអំណាចនៃចតុក្កៈមានបត្តចតុក្កៈជាដើម យ៉ាងនេះ ៖

បានឮថា ភិក្ខុមួយរូប កើតសេចក្តីលោភឡើងក្នុងបាត្រដែលមានតម្លៃច្រើនរបស់អ្នកដទៃ ប្រាថ្នានឹងលួចបាត្រនោះ ទើបកំណត់កន្លែងដែលគេដាក់បាត្រនោះទុកបានយ៉ាងល្អ ហើយទើបដាក់បាត្រសូម្បីរបស់ខ្លួនទុកជិតបាត្រនោះតែម្តង ។ ក្នុងសម័យជិតភ្លឺ សូម្បីភិក្ខុនោះមកហើយទូលព្រះមហាថេរៈដែលកំពុងសិងលក់ យ៉ាងនេះថា "ខ្ញុំព្រះករុណាសូមថ្វាយបង្គំលោកម្ចាស់" ព្រះថេរៈសួរថា "នោះអ្នកណា ?" លោកទើបឆ្លើយថា "ខ្ញុំព្រះករុណាជាភិក្ខុអាគន្តុកៈ លោកម្ចាស់ ប្រាថ្នាលាទៅក្នុងពេលព្រឹកនេះឯង និងបាត្ររបស់ខ្ញុំព្រះករុណាមានខ្សែយោគដូច្នេះមានស្លាកដូច្នេះ ដាក់ទុកត្រង់ឯណោះ, ល្អណាស់ លោកម្ចាស់ ខ្ញុំព្រះករុណាគួរបានបាត្រនោះ", ព្រះថេរៈចូលទៅចាប់យកបាត្រនោះ, ជាបារាជិកដល់ភិក្ខុចោរ ក្នុងខណៈលើកឡើងតែម្តង ។ បើលោកខ្លាចហើយចៀសចេញទៅក្នុងកាលព្រះថេរៈមកហើយ សួរថា "លោកជាអ្នកណា មក

ខុសវេលា” ។ លោកត្រូវបារាជិកហើយ ទើបចៀសចេញទៅ ។ តែមិនជាអាបត្តិដល់ព្រះថេរៈ ព្រោះលោកមានចិត្តបរិសុទ្ធិ ។ ព្រះថេរៈធ្វើទុកក្នុងចិត្តថា “យើងនឹងចាប់យកបាត្រនោះ” តែចាប់យកបាត្រដទៃទៅ, សូម្បីក្នុងបាត្រនោះ ក៏មានន័យនេះដូចគ្នា ។ តែន័យនេះ រមែងសមគួរក្នុងកាលព្រះថេរៈចាប់យកបាត្រដទៃដែលដូចបាត្រនោះ ដូចរឿងមនុស្សដែលដូចគ្នានឹងអ្នកត្រូវបង្គាប់ ក្នុងមនុស្សវិគ្គហសិក្ខាបទដូច្នោះ ។ ចំណែកក្នុងកុរុន្ទី លោកពោលទុកថា គប្បីពិន័យអាបត្តិតាមវារៈនៃការឈានទៅ ។ ពាក្យដែលលោកពោលទុកក្នុងកុរុន្ទីនោះ រមែងសមក្នុងកាលព្រះថេរៈចាប់យកបាត្រដទៃ តែមិនដូចបាត្រនោះឡើយ ។ ព្រះថេរៈសម្គាល់ថា ជាបាត្រនោះតែបានចាប់យកបាត្ររបស់ខ្លួនឱ្យទៅ, មិនជាបារាជិកដល់ភិក្ខុដែលជាចោរ ព្រោះបាត្រនោះម្ចាស់ឱ្យហើយ, ព្រោះខ្លួនកាន់យកដោយចិត្តមិនបរិសុទ្ធិ ជាទុក្កដ ។ ព្រះថេរៈសម្គាល់ថា ជាបាត្រនោះ តែបានចាប់យកបាត្ររបស់ភិក្ខុដែលជាចោរនុ៎ះឯងឱ្យទៅ, សូម្បីក្នុងអធិការពោលអំពីការចាប់យកបាត្ររបស់ភិក្ខុដែលជាចោរឱ្យទៅនេះ មិនជាអាបត្តិបារាជិកដល់ភិក្ខុដែលជាចោរ ព្រោះបាត្រនោះជារបស់ខ្លួន, តែព្រោះខ្លួនកាន់យកដោយចិត្តមិនបរិសុទ្ធិ ក៏ត្រូវទុក្កដ ។ ជាអនាបត្តិដល់ព្រះថេរៈក្នុងទីទាំងពួង ។

ភិក្ខុដទៃទៀត គិតថា នឹងលួចបាត្រ ហើយសំពះព្រះថេរៈអ្នកកំពុងសិងលក់ យ៉ាងនុ៎ះដូចគ្នា, ត្រូវព្រះថេរៈសួរថា "អ្នកណា ?" ។ ភិក្ខុនោះឆ្លើយប្រាប់ថា "ខ្ញុំព្រះករុណាជាភិក្ខុឈឺ លោកម្ចាស់ សូមមេត្តាឱ្យបាត្រមួយដល់ខ្ញុំព្រះករុណាចុះ, ខ្ញុំព្រះករុណាទៅកាន់ទ្វារស្រុកហើយ នឹងនាំភេសជ្ជៈមក" ។ ព្រះថេរៈកំណត់ថា "ក្នុងទីនេះ មិនមានភិក្ខុឈឺ, នេះនឹងជាចោរ" ហើយនិយាយថា "ចូរនាំបាត្រនេះទៅ" បាននាំបាត្ររបស់ភិក្ខុជាគូពៀរវេររបស់ខ្លួនឱ្យទៅ, ជាបារាជិកដល់ភិក្ខុទាំងពីររូប ក្នុងខណៈដែលលើកឡើងនុ៎ះឯង ។ សូម្បីកាលព្រះថេរៈចាំបានល្អថា "ជាបាត្ររបស់ភិក្ខុគូពៀរវេរ" ហើយលើកបាត្ររបស់ភិក្ខុដទៃឡើងក៏មានន័យនេះដូចគ្នា ។ ក៏បើព្រះថេរៈចាំបានល្អថា "បាត្រនេះ របស់ភិក្ខុជាគូពៀរវេរ" តែបានលើកយកបាត្ររបស់ភិក្ខុដែលជាចោរនុ៎ះឯងឱ្យទៅ ជាបារាជិកដល់ព្រះថេរៈ ជាទុក្កដដល់ភិក្ខុដែលជាចោរ ដោយន័យដូចដែលពោលហើយនុ៎ះឯង ។ បើព្រះថេរៈសម្គាល់ថា "បាត្រនេះ របស់ភិក្ខុជាគូពៀរវេរ" ទើបឱ្យបាត្ររបស់ខ្លួនដល់ភិក្ខុចោរនោះ ទើបឱ្យបាត្ររបស់ខ្លួនទៅ, ជាទុក្កដទាំងពីររូប ដោយន័យដូចដែលពោលហើយនុ៎ះឯង ។ ព្រះមហាថេរៈមួយរូបនិយាយចំពោះភិក្ខុដែលឧបដ្ឋាកថា "លោកចូរកាន់យកបាត្រនិងចីវរ, យើងនឹងទៅបិណ្ឌបាតក្នុងស្រុកឈ្មោះ

ឯណោះ” ។ ភិក្ខុកម្លោះ កាន់យកដើរទៅខាងក្រោយព្រះថេរៈ ញុំាង ថេយ្យចិត្តឱ្យកើតឡើងហើយ បើបន្ទិតភារៈលើសីសៈចុះមកត្រង់ក មិន ជាបារាជិក ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា បាត្រនិងចីវរនោះ លោក កាន់ទៅតាមពាក្យបង្គាប់, តែបើលោកចេញចាកមកផ្លៀងចូលព្រៃទៅ, គប្បីពិន័យអាបត្តិតាមវារៈនៃការឈាន ។ បើលោកត្រឡប់បែរមុខទៅមក វិហារចៀសចេញទៅ ចូលវិហារហើយទើបទៅ ត្រូវអាបត្តិបារាជិកក្នុង ខណៈឈានកន្លងឧបចារទៅ ។ បើសូម្បីលោកបែរមុខកាន់ស្រុក គេចពី ស្ថានដែលព្រះមហាថេរៈផ្លាស់ប្ដូរសំពត់ស្លៀកដណ្ដប់ ជាអាបត្តិបារាជិក ក្នុងខណៈឈានកន្លងឧបចារស្រុកទៅ ។ តែបើទាំងពីររូប ត្រាច់បិណ្ឌ បាតឆាន់ហើយ ឬ កាន់យកចេញទៅ, ចំណែកព្រះថេរៈនិយាយចំពោះ ភិក្ខុកម្លោះរូបនោះសូម្បីទៀតថា “លោកចូរកាន់យកបាត្រនិងចីវរ យើង នឹងទៅកាន់វិហារ” ភិក្ខុកម្លោះរូបនោះ ក៏រំកិលភារៈលើសីសៈចុះមកត្រង់ កក្នុងស្ថានទីនោះ ដោយន័យមុនទុំះឯង នៅរក្សាទុកសិន បើគេចចាកមក ចូលព្រៃទៅ គប្បីពិន័យអាបត្តិតាមវារៈនៃការឈាន ។ លោកត្រឡប់ ហើយបែរមុខទៅកាន់ស្រុកទុំះឯង ចៀសចេញទៅ ជាបារាជិកក្នុងខណៈ ឈានកន្លងឧបចារស្រុកទៅ ។ លោកបែរមុខទៅកាន់វិហារខាងមុខចៀស ចេញទៅ តែមិនឈរមិនអង្គុយក្នុងវិហារ ចេញទៅដោយថេយ្យចិត្ត មិន

ទាន់ស្ងប់នុ៎ះឯង, ត្រូវអាបត្តិបារាជិកក្នុងខណៈឈានកន្លងឧបចារទៅ ។

ចំណែកភិក្ខុណា លោកមិនបានប្រើទេ ចាប់យកដោយខ្លួនឯង ជាបារាជិកដល់ភិក្ខុនោះ ព្រោះការរំកិលភារៈលើសីសៈចុះមកត្រង់កជាដើមពាក្យដ៏សេសដូចគ្នានឹងពាក្យមុននុ៎ះឯង ។ ចំណែកភិក្ខុណា ដែលព្រះថេរៈបង្គាប់ថា លោកចូរទៅកាន់វិហារឈ្មោះឯណោះហើយ បោកឬជ្រលក់ចីវរហើយចូរមក ដូច្នេះ ទទួលពាក្យថា សាធុ ហើយចាប់យកទៅ, មិនជាបារាជិកសូម្បីដល់ភិក្ខុនោះ ក្នុងការញ៉ាំងថេយ្យចិត្តឱ្យកើតឡើង ហើយរំកិលភារៈលើសីសៈចុះមកត្រង់កជាដើមក្នុងចន្លោះមក ។ ព្រោះគេចចេញចាកមក គប្បីពិន័យលោកដោយជំហាន ។ លោកទៅកាន់វិហារនោះហើយ ស្នាក់នៅក្នុងវិហារនោះឯង ប្រើប្រាស់ឱ្យចាស់គ្រាំគ្រាទៅដោយថេយ្យចិត្ត ឬថា ពួកចោរលួចយកចីវរនោះរបស់ព្រះថេរៈនោះទៅ មិនជាអវហារតែជាភណ្ឌទេយ្យ ។ សូម្បីកាលលោកចេញចាកវិហារនោះមក ក៏ន័យនេះឯង ។ ចំណែកភិក្ខុណាលោកមិនបានបង្គាប់កាលព្រះថេរៈធ្វើនិមិត្តហើយ ឬខ្លួនឯងកំណត់បាន ឃើញចីវរសៅហ្មងហើយ ទើបពោលថា "មេត្តាប្រគល់ចីវរចុះ លោកម្ចាស់ ខ្ញុំព្រះករុណានឹងទៅកាន់ស្រុកឯណោះ ជ្រលក់ហើយនឹងនាំមក" ដូច្នេះ ហើយចាប់យកទៅ ជាបារាជិកដល់ភិក្ខុនោះ ព្រោះការញ៉ាំងថេយ្យចិត្តឱ្យកើត

ឡើង ហើយរំកិលភារៈលើសីសៈចុះមកត្រង់កជាដើមក្នុងចន្លោះមក ។ ព្រោះហេតុអ្វី ? ព្រោះចីវរនោះ ខ្លួនកាន់យកដោយលោកមិនបានបង្គាប់ ។ កាលលោកគេចចេញអំពីមកក្ដី ត្រឡប់មកកាន់វិហារនោះឯងហើយឈានកន្លងដែនវិហារទៅក្ដី ក៏ជាបារាជិក ដែលមានន័យដូចពោលហើយនុ៎ះឯង ។ ក្នុងកាលថេយ្យចិត្តកើតឡើង សូម្បីកាលលោកទៅហើយកាន់ស្រុកនោះ ជ្រលក់ចីវរហើយត្រឡប់មក ក៏មានន័យនេះដូចគ្នា ។ តែបើលោកនៅក្នុងវិហារដែលខ្លួនទៅ ឬនៅក្នុងវិហារក្នុងចន្លោះមក ឬត្រឡប់មកកាន់វិហារ (ដើម) នោះឯងហើយមិនកន្លងដែនឧបចារក្នុងផ្នែកមួយនៃវិហារនោះទៅក្ដី ប្រើប្រាស់ឱ្យចាស់គ្រាំគ្រាទៅដោយថេយ្យចិត្តក្ដី ពួកចោរលួចចីវរនោះ របស់ភិក្ខុនោះទៅក្ដី ចីវរនោះវិនាសទៅដោយប្រការយ៉ាងណាមួយក្ដី ជាភណ្ឌទេយ្យ ។ តែកាលលោកឈានកន្លងឧបចារសីមាទៅ ជាបារាជិក ។ ចំណែកភិក្ខុណា កាលព្រះថេរៈធ្វើនិមិត្ត ទើបប្រាប់លោកថា "មេត្តាឱ្យចុះលោកម្ចាស់ ខ្ញុំព្រះករុណានឹងជ្រលក់មកប្រគេន" ដូច្នេះ ហើយទូលសួរថា ខ្ញុំព្រះករុណានឹងទៅជ្រលក់ទីណាលោកម្ចាស់ ចំណែកព្រះថេរៈពោលនឹងភិក្ខុនោះថា "លោកចូរទៅជ្រលក់ក្នុងទីដែលលោកប្រាថ្នាចុះ" ។ ភិក្ខុនេះ ឈ្មោះថាទូតដែលគេបញ្ជូនទៅ ។ ភិក្ខុនេះ សូម្បីកាលចៀសចេញទៅដោយ

ថេយ្យចិត្តក៏មិនគួរពិន័យដោយអវហារ ។ តែកាលលោកចៀសចេញទៅដោយថេយ្យចិត្តក្តី ធ្វើចីវរឱ្យវិនាសដោយការប្រើប្រាស់ ឬដោយប្រការដទៃក្តី រមែងជាភណ្ឌទេយ្យដូចគ្នា ។ ភិក្ខុផ្ញើបរិក្ខារយ៉ាងណាមួយទៅទុកក្នុងដៃរបស់ភិក្ខុដោយបង្គាប់ថា "លោកចូរឱ្យដល់ភិក្ខុឈ្មោះឯណោះ ក្នុងវិហារឯណោះ" ។ វិនិច្ឆ័យក្នុងកាលថេយ្យចិត្តកើតឡើង ដល់ភិក្ខុដែលទទួលបរិក្ខារនោះក្នុងទីទាំងពួង ដូចដែលពោលហើយក្នុងពាក្យនេះថា "លោកចូរទៅកាន់វិហារឈ្មោះឯណោះហើយបោកឬជ្រលក់ចីវរហើយចូរមក" ដូច្នេះ ។ ភិក្ខុមួយរូបទៀត ប្រាថ្នានឹងបញ្ជូន (បរិក្ខារ) ទៅ ទើបធ្វើនិមិត្តដោយន័យថា អ្នកណាហ្ន៎ នឹងទទួលទៅ ។ ក៏ក្នុងស្ថានទីនោះមានភិក្ខុមួយរូបពោលថា "មេត្តាឱ្យចុះ លោកម្ចាស់ ខ្ញុំព្រះករុណានឹងទទួលទៅ" ដូច្នេះហើយ ក៏ទទួលយក (បរិក្ខារនោះ)ទៅ ។ វិនិច្ឆ័យក្នុងកាលថេយ្យចិត្តកើតឡើងដល់ភិក្ខុដែលទទួលបរិក្ខារនោះ ក្នុងទីទាំងពួង ដូចដែលពោលទុកហើយក្នុងពាក្យនេះថា "មេត្តាឱ្យចីវរចុះ លោកម្ចាស់ ខ្ញុំព្រះករុណាទៅកាន់ស្រុកឈ្មោះឯណោះ ជ្រលក់ហើយ នឹងនាំមក" ដូច្នេះ ។

ព្រះថេរបានសំពត់ដើម្បីប្រយោជន៍ដល់ចីវរហើយ ក៏ផ្ញើទុកក្នុងត្រកូលឧបដ្ឋាក ។ បើអន្តេវាសិករបស់ព្រះថេរៈនោះ ប្រាថ្នានឹងលួចយក

សំពត់ទៅ ទើបទៅក្នុងត្រកូលនោះ ហើយនិយាយដូចខ្លួនត្រូវព្រះថេរៈប្រើឱ្យទៅថា "ន័យថា ពួកលោកចូរឱ្យសំពត់នោះចុះ" ។ ឧបាសិកាជឿពាក្យរបស់ភិក្ខុនោះហើយ បាននាំយកសំពត់ដែលឧបាសករក្សាទុកមកប្រគេនក្តី ឧបាសកឬអ្នកណា ៗដទៃ (ជឿពាក្យរបស់ភិក្ខុនោះហើយ) បាននាំយកសំពត់ដែលឧបាសិការក្សាទុកមកប្រគេនក្តី ។ ភិក្ខុនោះ ជាបារាជិកក្នុងខណៈដែលលើកឡើងនូវទ្រនុំឯង ។ តែបើពួកឧបដ្ឋាករបស់ព្រះថេរៈនិយាយថា "ពួកខ្ញុំនឹងប្រគេនសំពត់នេះដល់ព្រះថេរៈ" ហើយក៏រក្សាសំពត់របស់ខ្លួនទុក, បើអន្តេវាសិករបស់ព្រះថេរៈនោះ ប្រាថ្នានឹងលួចយកសំពត់នោះ ទើបទៅកាន់ត្រកូលនោះ ហើយនិយាយថា ន័យថា "ពួកលោកប្រាថ្នានឹងប្រគេនសំពត់ដល់ព្រះថេរៈ, ចូរឱ្យសំពត់នោះចុះ" ។ ឧបដ្ឋាកទាំងនោះ ក៏ជឿអន្តេវាសិករូបនោះ ហើយនិយាយថា "លោកដ៏ចម្រើន ពួកខ្ញុំព្រះករុណាតាំងចិត្តទុកថា 'និមន្តឱ្យលោកឆាន់ហើយ នឹងប្រគេន' ទើបបានរក្សាទុក, និមន្តលោកទទួលយកទៅចុះ" ហើយក៏ប្រគេនទៅ មិនជាបារាជិក ព្រោះសំពត់នោះពួកម្ចាស់របស់ប្រគេនហើយ តែជាអាបត្តិទុក្កដ ព្រោះលោកកាន់យកដោយចិត្តមិនបរិសុទ្ធិ និងជាភណ្ឌទេយ្យផង ។

ភិក្ខុដើរទៅកាន់ស្រុកប្រាប់ដល់ភិក្ខុថា អ្នកមានឈ្មោះនេះ នឹងប្រគេនសំពត់ងូតទឹកភ្លៀងដល់ខ្ញុំព្រះករុណា, លោកគប្បីទទួលយកសំពត់

នោះហើយរក្សាទុកផង ។ ភិក្ខុនោះទទួលថា "ល្អណាស់" ហើយរក្សាសំពត់សាដកដែលមានតម្លៃច្រើនដែលភិក្ខុនោះឱ្យទុក នឹងសំពត់សាដកដែលមានតម្លៃតិចដែលខ្លួនបានហើយ ភិក្ខុនោះមកហើយនឹងដឹងថា "សំពត់ដែលខ្លួនបានមានតម្លៃច្រើន" ឬមិនដឹងក៏ដោយ និយាយថា "លោកចូរឱ្យសំពត់ផ្លូតទឹកភ្លៀងដល់ខ្ញុំព្រះករុណាចុះ" លោកឆ្លើយថា "សំពត់សាដកដែលលោកបានមកមានសាច់គ្រោតគ្រាត, ចំណែកសំពត់សាដករបស់ខ្ញុំព្រះករុណាមានតម្លៃច្រើន, ទាំងពីរផ្ទាំងខ្ញុំព្រះករុណាបានរក្សាទុកក្នុងឱកាសឈ្មោះឯណោះហើយ, មេត្តាចូលទៅយកចុះ" ។ កាលភិក្ខុដែលទាមទារនោះ ចូលទៅយកសំពត់សាដកសាច់គ្រោតគ្រាតហើយ, ភិក្ខុក្រៅនេះ កាន់យកសំពត់សាដកមួយផ្ទាំងទៀត ជាបារាជិកក្នុងខណៈលើកឡើង ។ សូម្បីបើភិក្ខុដែលរក្សាសំពត់ទុកនោះ បានសរសេរឈ្មោះរបស់ខ្លួនទុកក្នុងសំពត់សាដករបស់ភិក្ខុដែលមកទាមទារនោះ និងឈ្មោះរបស់ភិក្ខុដែលមកទាមទារនោះ ទុកក្នុងសំពត់សាដករបស់ខ្លួន ហើយពោលថា "លោកចូរទៅមើលឈ្មោះ កាន់យកទៅចុះ" ដូច្នេះ ។ សូម្បីក្នុងសំពត់សាដកដែលពោលនោះ ក៏ន័យនេះដូចគ្នា ។

ចំណែកអាវាសិកភិក្ខុណា រក្សាសំពត់សាដកដែលខ្លួនឯងនិងភិក្ខុអាគន្តុកៈនោះបានមករួមគ្នាទុកហើយ និយាយចំពោះភិក្ខុអាគន្តុកៈនោះយ៉ាងនេះថា "សំពត់សាដកដែលលោកនិងខ្ញុំព្រះករុណាបានទាំងពីរផ្ទាំង

រក្សាទុកខាងក្នុងបន្ទប់, លោកចូរទៅជ្រើសរើសយកសំពត់ដែលលោកប្រាថ្នាចុះ” ។ និងភិក្ខុអាគន្តុកៈនោះ កាន់យកសំពត់សាដកសាច់គ្រោតគ្រាតដែលអាវាសិកភិក្ខុបានមកទុំះឯង ព្រោះសេចក្តីកោតក្រែង ។ ក្នុងភិក្ខុអាគន្តុកៈនិងម្ចាស់ទឹកន្លែងនោះ កាលអាវាសិកភិក្ខុកាន់យកសំពត់សាដកក្រៅនេះ នៅសល់អំពីដែលអាគន្តុកៈភិក្ខុជ្រើសរើសយកហើយមិនជាអាបត្តិ ។

ភិក្ខុអាគន្តុកៈ កាលពួកអាវាសិកភិក្ខុកំពុងធ្វើចីវរកម្ម រក្សាបាត្រនិងចីវរទុកក្នុងទីជិតយល់ថា “ពួកអាវាសិកភិក្ខុទាំងនោះ នឹងរក្សាទុកឱ្យ” ទើបទៅផ្ងូតទឹក ឬទៅក្នុងទីដទៃ ។ បើអាវាសិកភិក្ខុរក្សាបាត្រនិងចីវរនោះទុក, ការរក្សានោះជាការល្អ, បើមិនរក្សាទុកឱ្យ, កាលបាត្រនិងចីវរនោះវិនាសទៅ, ក៏មិនជាសំណង ។ សូម្បីបើភិក្ខុអាគន្តុកៈនោះ ពោលថា “ចូររក្សាបាត្រនិងចីវរនេះទុកចុះ លោកម្ចាស់” ហើយទៅ, និងអាវាសិកភិក្ខុក្រៅនេះមិនជ្រាប ព្រោះរវល់តែខ្វល់ខ្វាយក្នុងកិច្ច, គប្បីជ្រាបន័យដូចគ្នានេះ ។ សូម្បីបើអាវាសិកភិក្ខុទាំងនោះ ដែលភិក្ខុអាគន្តុកៈពោលថា “ចូររក្សាបាត្រនិងចីវរនេះទុកចុះ លោកម្ចាស់” បានបដិសេធថា “ពួកខ្ញុំព្រះករុណាកំពុងតែរវល់” និងភិក្ខុអាគន្តុកៈក្រៅនេះក៏គិតថា “លោកទាំងនេះនឹងរក្សាពិតប្រាកដ” មិនជាប់ចិត្តហើយចេញទៅ, គប្បីជ្រាបន័យដូចគ្នានេះ ។ តែបើអាវាសិកភិក្ខុត្រូវអាគន្តុកៈរូបនោះ

សូមអនុវរឬមិនសូមក៏ដោយ និយាយថា “ពួកខ្ញុំព្រះករុណានឹងរក្សាទុកដោយខ្លួនឯង, លោកចូរទៅចុះ” ដូច្នេះ ត្រូវរក្សាបាត្រនិងចីវរនោះទុក បើមិនរក្សាទុកសោត, កាលបាត្រនិងចីវរនោះវិនាសបាត់ទៅ រមែងជាសំណង ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា បាត្រនិងចីវរនោះពួកលោកទទួលទុកហើយ ។

ភិក្ខុណាជាភណ្ឌាគារិក (អ្នករក្សាឃ្លាំង) ជួនជាវេលាព្រឹកទ្រុំឯងបានប្រមូលបាត្រ និងចីវររបស់ភិក្ខុទាំងឡាយចុះទៅកាន់ប្រាសាទជាន់ក្រោម មិនបានបិទទ្វារ ទាំងមិនបានប្រាប់ដល់ភិក្ខុទាំងនោះ ត្រាច់ទៅភិក្ខាចារក្នុងទីឆ្ងាយ, បើពួកចោរលួចយកបាត្រនិងចីវរទាំងនោះទៅសោត, រមែងជាសំណងដល់លោកពិត ។

ចំណែកភិក្ខុភណ្ឌាគារិករូបណា ត្រូវពួកភិក្ខុពោលថា “លោកដ៏ចម្រើន លោកលើកបាត្រនិងចីវរមកចុះ ឥឡូវនេះ ដល់វេលាចាប់ស្លាក” ទើបសួរថា “ពួកលោកមកប្រជុំគ្នាហើយឬ ?”

កាលលោកទាំងនោះឆ្លើយប្រាប់ថា “មកប្រជុំព្រមគ្នាហើយ លោកម្ចាស់” ទើបបានជញ្ជូនយកបាត្រនិងចីវរចេញមកដាក់ទុក ហើយបិទទ្វារភណ្ឌាគារ (ចាក់សោរ) ហើយបង្គាប់ថា “ពួកលោកកាន់យកបាត្រនិងចីវរ ហើយជួយរក្សាទ្វារខាងក្រោមប្រាសាទខាងក្រោមសិន សឹមទៅ” ដូច្នេះ ហើយទៅ; ក៏ក្នុងពួកភិក្ខុទាំងនោះ ភិក្ខុមួយរូបមានជាតិខ្ជិល

ប្រអូស កាលភិក្ខុទាំងឡាយទៅ វល់តែជូតភ្នែកក្រោកឡើងខាងក្រោយ ដើរទៅកាន់ទីផ្លូតទឹក ឬទីលុបមុខ ។ ខណៈនោះពួកចោរប្រទះឃើញ ទើបចូលទៅលួចយកបាត្រនិងចីវររបស់ភិក្ខុនោះទៅ, ជាការដែលពួកចោរលួចទៅដោយល្អ, មិនជាសំណងដល់ភិក្ខុភណ្ឌាគារិក ។ សូម្បីបើភិក្ខុខ្លះមិនបានប្រាប់ដល់ភិក្ខុភណ្ឌាគារិកឡើយ ក៏រក្សាបរិក្ខាររបស់ខ្លួនទុកក្នុងភណ្ឌាគារ, សូម្បីកាលបរិក្ខារនោះបាត់ទៅ ក៏មិនជាសំណងដល់ភិក្ខុភណ្ឌាគារិក ។ តែបើភិក្ខុភណ្ឌាគារិក ឃើញបរិក្ខារនោះហើយ គិតថា "រក្សាទុកក្នុងទីមិនគួរ" ទើបយកទៅរក្សាទុកឱ្យ, កាលបរិក្ខារនោះវិនាសទៅ ជាសំណងដល់ភិក្ខុភណ្ឌាគារិករូបនោះ ។ បើភិក្ខុភណ្ឌាគារិក ដែលភិក្ខុអ្នករក្សាទុកពោលថា "ខ្ញុំព្រះករុណារក្សាបរិក្ខារឈ្មោះនេះទុកហើយ លោកម្ចាស់ មេត្តាជួយមើលឱ្យផង" ទទួលថា "បាន" ឬដឹងថា រក្សាទុកមិនល្អ ទើបរក្សាទុកក្នុងទីដទៃ, កាលបរិក្ខារនោះវិនាសទៅ ជាសំណងដល់ភិក្ខុភណ្ឌាគារិកនោះដូចគ្នា ។ តែកាលលោកបដិសេធថា ខ្ញុំព្រះករុណាមិនទទួលដឹង មិនជាសំណង ។ ចំណែកភិក្ខុណា កាលភិក្ខុភណ្ឌាគារិកឃើញនុ៎ះឯង រក្សាទុក ទាំងមិនឱ្យភិក្ខុភណ្ឌាគារិកទទួលដឹងបរិក្ខាររបស់ភិក្ខុនោះបាត់ទៅ ជាការវិនាសទៅដោយល្អ, បើភិក្ខុភណ្ឌាគារិក រក្សាបរិក្ខារនោះទុកក្នុងទីកន្លែងដទៃ, កាលវិនាសទៅជាសំណង ។

## ចោរលួចភណ្ឌសង្ឃក្នុងឃ្លាំង ពិន័យជាសំណងដល់ភិក្ខុអ្នករក្សា

បើភណ្ឌាគារិករក្សាល្អ បរិក្ខារទាំងពួងរបស់សង្ឃនិងរបស់ចេតិយ គេរក្សាទុកក្នុងភណ្ឌាគារនោះឯង ។ តែភិក្ខុភណ្ឌាគារិកជាអ្នកល្ងង់ មិនឆ្លាត បើកទ្វារចោល ហើយទៅក្នុងទីណាមួយដើម្បីស្តាប់ធម្មកថា ឬដើម្បីធ្វើកិច្ចអ្វីដទៃ ខណៈនោះពួកចោរឃើញហើយ លួចភណ្ឌៈទៅប៉ុន្មានណា ភណ្ឌៈប៉ុណ្ណោះជាសំណាងដល់លោកទាំងអស់ ។ កាលភណ្ឌាគារិកចេញពីភណ្ឌាគារទៅចង្រ្កមនៅខាងក្រៅ ឬបើកទ្វារទុកដើម្បីឱ្យរាងកាយទទួលអាកាស ឬអង្គុយធ្វើសមណធម៌ក្នុងភណ្ឌាគារនុ៎ះឯង ឬអង្គុយក្នុងភណ្ឌាគារនោះឯង ខ្វល់ខ្វាយដោយកម្មយ៉ាងណាមួយ ឬសូម្បីជាអ្នកឈឺបន្ទោបង់ឧច្ចារៈបស្សាវៈ កាលឧបចារក្នុងទីនោះឯងមាន តែទៅខាងក្រៅ ឬធ្វេសប្រហែសដោយអាការដទៃយ៉ាងណាមួយ, ពួកចោរបើកទ្វារ ឬចូលតាមទ្វារដែលបើកទុកនោះឯង ឬកាត់ទីតលួចភណ្ឌៈទៅប៉ុន្មានណា ព្រោះសេចក្តីធ្វេសប្រហែសរបស់លោកជាបច្ច័យ ភណ្ឌៈប៉ុណ្ណោះជាសំណាងដល់លោកទាំងអស់នោះឯង ។ ចំណែកអាចារ្យពួកខ្លះពោលថា ក្នុងវេជ្ជវក្តៅនឹងបើកបង្អួចដេក ក៏គួរ ។ តែកាលឈឺឧច្ចារៈបស្សាវៈហើយ ទៅក្នុងទីដទៃ ក្នុងកាលឧបចារនោះមិនមាន មិនមែនជាវិស័យ ព្រោះលោកតាំងនៅក្នុងចំណែកនៃភិក្ខុឈឺ; ព្រោះហេតុនោះ មិនជាសំណង ។

ចំណែកភិក្ខុណាត្រូវសេចក្តីក្តៅខាងក្នុងបៀតបៀន ទើបធ្វើទ្វារឱ្យជារបស់រក្សាល្អហើយចេញទៅខាងក្រៅ ។ និងពួកចោរចាប់ភិក្ខុនោះបានហើយបង្គាប់ថា "ចូរបើកទ្វារ" ។ លោកមិនគួរបើកដរាបដល់គ្រាទីបី ។ តែបើពួកចោរងាពូថៅជាដើម គម្រាមថា "បើលោកមិនព្រមបើក, ពួកយើងនឹងសម្លាប់លោកចោលផង នឹងទម្លាយទ្វារលួចបរិក្ខារចេញទៅផង" ។ លោកនឹងបើកឱ្យដោយធ្វើទុកក្នុងចិត្តថា "កាលយើងស្លាប់ សេនាសនៈរបស់សង្ឃក៏វិនាស មិនមានគុណឡើយ" ដូច្នេះ សមគួរ ។ សូម្បីក្នុងអធិការនេះ អាចារ្យពួកខ្លះពោលថា មិនមានសំណងព្រោះហួសវិស័យ ។ បើភិក្ខុអាគន្តុកៈរូបខ្លះ ចាក់សោ ឬបើកទ្វារទុក, ពួកចោរលួចភណ្ឌៈទៅប៉ុនណា ភណ្ឌៈប៉ុណ្ណោះជាសំណងដល់អាគន្តុកៈនោះទាំងអស់ ។ គន្លឹះយន្តនិងក្រវិលកូនសោ ជារបស់ដែលសង្ឃរៀបចំឱ្យដើម្បីប្រយោជន៍ដល់ការរក្សាភណ្ឌាគារ ។ ភណ្ឌាគារិកដាក់ត្រឹមតែគន្លឹះហើយដេក ។ ពួកចោរបើកចូលទៅលួចបរិក្ខារ ជាសំណងដល់លោកពិត ។ តែភណ្ឌាគារិកនោះ ដាក់គន្លឹះយន្ត និងក្រវិលកូនសោហើយដេក, បើពួកចោរមកគម្រាមថា "ចូរបើក" លោកគប្បីបដិបត្តិក្នុងពាក្យរបស់ពួកចោរនោះ តាមន័យមុននុ៎ះឯង ។ ក៏កាលភណ្ឌាគារិកនោះធ្វើការរក្សាយ៉ាងនោះហើយ ទើបដេក ។ បើពួកចោរទម្លាយជញ្ជាំងឬដំបូល ឬចូលមកក្រោមដី លួចរបស់ទៅ, មិនជាសំណងដល់លោក ។ បើព្រះថេរៈ

សូម្បីពួកដទៃនៅក្នុងភណ្ឌាគារ កាលទ្វារបើក លោកទើបកាន់យកបរិក្ខាររបស់ខ្លួន ៗ ទៅភណ្ឌាគារិកមិនប្រុងប្រយ័ត្នទ្វារ ក្នុងកាលព្រះថេរៈទាំងនោះទៅហើយ, បើរបស់អ្វី ៗ ក្នុងភណ្ឌាគារនោះត្រូវលួចទៅ, ជាសំណងដល់ភណ្ឌាគារិកប៉ុណ្ណោះ ព្រោះភណ្ឌាគារិកជាធំ ។ ចំណែកពួកព្រះថេរៈគប្បីជាបក្ខពួក ។ នេះជាសាមីចិកម្ម ក្នុងភណ្ឌាគារនោះ ។ តែបើភណ្ឌាគារិកប្រាប់ថា "សូមពួកលោកចូរឈរទទួលបរិក្ខាររបស់ពួកលោកខាងក្រៅចុះ កុំចូលមកឡើយ" ។ ក៏បណ្ដាភិក្ខុទាំងនោះ ព្រះថេរៈឡេះឡោះមួយរូប នៃពួកព្រះថេរៈទាំងនោះ ព្រមដោយសាមណេរនិងឧបដ្ឋាកទាំងឡាយ បើកភណ្ឌាគារចូលទៅអង្គុយនិងដេក, ភណ្ឌៈបាត់ទៅប៉ុនណា ជាសំណងដល់ព្រះថេរៈនោះទាំងអស់ ។

ចំណែកភណ្ឌាគារិកនិងព្រះថេរៈដ៏សេស គប្បីជាបក្ខពួក ។ បើភិក្ខុភណ្ឌាគារិកទុំះឯងនាំយកពួកសាមណេរឡេះឡោះ និងពួកអ្នកឧបដ្ឋាកទៅអង្គុយ និងដេកនៅក្នុងភណ្ឌាគារ, វត្ថុណាក្នុងភណ្ឌាគារនោះបាត់ទៅ, របស់ទាំងអស់នោះ ជាសំណងដល់ភិក្ខុភណ្ឌាគារិកប៉ុណ្ណោះ ។ ព្រោះហេតុនោះ ភិក្ខុភណ្ឌាគារិកនោះប៉ុណ្ណោះ គប្បីនៅក្នុងភណ្ឌាគារនោះ ។ ពួកភិក្ខុដ៏សេស គួរនៅក្នុងមណ្ឌប ឬគល់ឈើតែមិនគួរនៅក្នុងភណ្ឌាគារដោយប្រការដូច្នេះ ។

មួយទៀត ភិក្ខុពួកណា រក្សាបរិក្ខាររបស់ពួកភិក្ខុដែលជាសភាគ

គ្នាទុកក្នុងបន្ទប់នៅរបស់ខ្លួន ៗ កាលបរិក្ខារបាត់ទៅ ភិក្ខុពួកណារក្សាទុក, ជាសំណងដល់ភិក្ខុទាំងនោះឯង ។ ចំណែកភិក្ខុក្រៅនេះ គួរជាបក្ខពួក ។ តែបើសង្ឃបង្គាប់ឱ្យប្រគេនបាយយាគូនិងភត្ត ដល់ភិក្ខុភណ្ឌាគារិកក្នុងវិហារនុ៎ះឯង និងភិក្ខុភណ្ឌាគារិករូបនោះ ចូលទៅកាន់ស្រុក ដើម្បីត្រូវការភិក្ខាចារ, វត្ថុបាត់ទៅ រមែងជាសំណងដល់ភិក្ខុភណ្ឌាគារិករូបនោះឯង ។ សូម្បីភិក្ខុដែលទទួលនាទីចាំព្រះវិហារ ដែលពួកភិក្ខុអ្នកចូលទៅត្រាច់ភិក្ខាចារតាំងទុក ដើម្បីត្រូវការឱ្យរក្សាអតិរេកចីវរ កាលបានយាគូនិងភត្ត ឬអាហារដូចគ្នា ក៏នៅតែទៅភិក្ខាចារ, វត្ថុណាក្នុងវិហារនោះបាត់ទៅ, វត្ថុនោះទាំងអស់ជាសំណងដល់លោក ។ និងវត្ថុនោះប៉ុណ្ណោះ ទឹងជាសំណងតែម្យ៉ាងក៏ទេ, វត្ថុណាបាត់ទៅ ព្រោះសេចក្ដីប្រមាទរបស់ភិក្ខុដែលចាំវិហារនោះជាបច្ច័យ, វត្ថុនោះទាំងអស់ជាសំណងដល់លោក ដូចភិក្ខុភណ្ឌាគារិកដូច្នោះ (ដូចវត្ថុដែលបាត់ទៅព្រោះសេចក្ដីប្រមាទរបស់ភិក្ខុភណ្ឌាគារិក ជាសំណងដល់ភិក្ខុភណ្ឌាគារិកដូច្នោះ) បើជាវិហារធំ, កាលលោកដើរទៅដើម្បីរក្សានូវចំណែកដទៃ វត្ថុដែលរក្សាទុកក្នុងទីមួយទៀត ពួកចោរលួចយកទៅ រមែងមិនជាសំណង ព្រោះជាហេតុហួសវិស័យ ។ ក៏ក្នុងវិហារធំដូច្នោះ លោកគួររក្សាបរិក្ខារទាំងឡាយ ទុកក្នុងទីប្រជុំនៃភិក្ខុទាំងពួង ហើយអង្គុយត្រង់កណ្ដាលវិហារ ។ មួយទៀតគប្បីតាំងភិក្ខុទទួលនាទីចាំវិហារទុក ២-៣ រូប ។ បើសូម្បីកាលលោក

ទាំងនោះ មិនបានជាអ្នកប្រមាទ នៅចាំរក្សាខាងឯណោះនិងខាងនេះឯង វត្ថុអ្វីណាមួយបាត់ទៅ, ក៏មិនជាសំណាងដល់លោកទាំងនោះ ។ វត្ថុដែលពួកចោរចងភិក្ខុអ្នកទទួលនាទីរក្សាវិហារទុកហើយ លួចយកទៅក្តី វត្ថុដែលត្រូវចោរលួចទៅដោយមកដទៃ ក្នុងកាលភិក្ខុទទួលនាទីចាំវិហារដើរជ្រួសមកពួកចោរទៅក្តី មិនជាសំណាងដល់លោកទាំងនោះ ។ បើយាគូ និងភត្ត ឬអាហារដែលនឹងគប្បីប្រគេនក្នុងវិហារ មិនមានដល់ភិក្ខុដែលទទួលនាទីរក្សាវិហារ ។ នឹងតាំងស្លាកយាគូ ២-៣ ដែលមាននៅសល់អំពីលាភដែលភិក្ខុទាំងនោះគប្បីបាន និងសលាកភត្តល្មមដល់ភិក្ខុដែលចាំវិហារទាំងនោះ ក៏គួរ តែមិនគួរតាំងឱ្យជាប្រចាំ ។ ព្រោះថា ពួកអ្នកស្រុក និងមានសេចក្តីក្តៅចិត្តថា ពួកភិក្ខុដែលទទួលនាទីចាំវិហារប៉ុណ្ណោះ រមែងឆាន់ភត្តរបស់ពួកយើង ។ ព្រោះហេតុនោះ ទើបគួរផ្លាស់ប្តូរវារៈគ្នាតាំងទុក ។

បើពួកភិក្ខុដែលជាសភាគគ្នា របស់ភិក្ខុដែលទទួលនាទីចាំវិហារទាំងនោះ នាំស្លាកភត្តមកប្រគេន, ប្រការនោះក៏ជាការល្អ, បើមិនប្រគេន, គួរឱ្យភិក្ខុទាំងឡាយទទួលវារៈហើយឱ្យនាំមកប្រគេនចុះ ។ បើភិក្ខុដែលទទួលនាទីរក្សាវិហារ កាលបានទទួលស្លាកបាយយាគូ ២-៣ និងស្លាកភត្ត ៤-៥ តែម្តង ក៏នៅតែទៅភិក្ខាចារ ។ វត្ថុបាត់ទៅទាំងអស់ជាសំណាងដល់

លោក ដូចភិក្ខុភណ្ឌាគារិក ដូច្នោះ ។ បើភត្ត ឬតម្លៃឈ្នួលដើម្បីភត្ត របស់សង្ឃ ដែលនឹងគប្បីប្រគេនដល់ភិក្ខុដែលចាំវិហារមិនមាន ភិក្ខុទាំងឡាយទទួលយកតាមវារៈចាំវិហារហើយ ទើបឱ្យនិស្សិតរបស់ខ្លួន ៗ ជួយបដិបត្តិនឹងមិនទទួលយកវារៈដែលមកដល់ រមែងមិនបាន, គួរធ្វើដូចយ៉ាងដែលភិក្ខុពួកដទៃធ្វើដូច្នោះ ។ ប៉ុន្តែថា ភិក្ខុណា មិនមានសម្លាញ់ ឬមិនមានមិត្ត មិនមានភិក្ខុជាទីពេញចិត្តដែលនឹងនាំភត្តមកឱ្យ, ភិក្ខុទាំងឡាយ មិនគួរឱ្យវារៈដល់ភិក្ខុបែបនោះ ។ ភិក្ខុទាំងឡាយតាំងសូម្បីចំណែកណាទុកក្នុងវិហារ ដើម្បីប្រយោជន៍ជាស្បៀង ភិក្ខុដែលកាន់យកចំណែកនោះចិញ្ចឹមជីវិត ត្រូវតាំងនាទី ។ ភិក្ខុណាមិនទទួលយកចំណែកនោះចិញ្ចឹមជីវិត មិនគួរឱ្យភិក្ខុនោះទទួលវារៈ ។ ភិក្ខុទាំងឡាយតែងតាំងភិក្ខុទុកក្នុងវិហារ សូម្បីដើម្បីត្រូវការឱ្យរក្សាផ្លែឈើតូចធំ, គ្រាថែរក្សាគ្រប់គ្រងហើយក៏ចែកគ្នាឆាន់តាមកាលនៃផ្លែឈើ ។ ភិក្ខុដែលឆាន់ផ្លែឈើទាំងនោះ គួរតាំងឱ្យទទួលវារៈ ។ ភិក្ខុដែលមិនអាស្រ័យ (ផ្លែឈើនោះ) ចិញ្ចឹមជីវិត មិនគួរឱ្យទទួលវារៈ ។ ភិក្ខុទាំងឡាយនឹងតែងតាំងភិក្ខុទុក សូម្បីដើម្បីត្រូវការឱ្យរក្សាសេនាសនៈ គ្រែ តាំង និងកម្រាល, គួរតែងតាំងភិក្ខុដែលនៅក្នុងអាវាស, ចំណែកភិក្ខុដែលកាន់អព្ភោកាសិកធុតង្គក្តី អ្នកកាន់រុក្ខមូលិកធុតង្គក្តី មិនគួរឱ្យទទួលវារៈ ។

អាចារ្យពួកខ្លះពោលថា ភិក្ខុមួយរូបជាព្រះនវកៈនៅឡើយ, តែលោកជាពហុស្សូត បង្រៀនធម៌ឲ្យការសាកសួរ ពណ៌នាបាលីសម្ដែងធម្មកថាដល់ភិក្ខុជាច្រើន ទាំងជួយភារៈរបស់សង្ឃផង, ភិក្ខុនេះ កាលឆាន់លាភក្ដី នៅក្នុងអាវាសក្ដី មិនគួរឲ្យទទួលវារៈ, គប្បីដឹងថា ជាមនុស្សពិសេស ។ តែភិក្ខុដែលរក្សារោងឧបោសថ និងរោងព្រះបដិមា គួរឲ្យបាយយាគូនិងភត្តជាទេ្វគុណ អង្ករមួយនាឡិរាល់ថ្ងៃ ត្រៃចីវរប្រចាំឆ្នាំ និងកប្បិយភណ្ឌៈដែលមានតម្លៃ ១០ ឬ ២០ កហាបណៈ ។ ក៏បើកាលលោកបានទទួលបាយយាគូនិងភត្តនោះឯង វត្ថុអ្វីណាមួយ ក្នុងរោងឧបោសថ និងរោងព្រះបដិមានោះវិនាសទៅ ព្រោះសេចក្ដីប្រមាទ, ជាសំណងដល់លោកទាំងអស់ ។ តែវត្ថុដែលត្រូវពួកចោរចង្ខូនលោកទុកហើយ ប្រជែងដណ្ដើមយកទៅ ដោយកម្លាំង រមែងមិនជាសំណងដល់លោក ។ ការដែលនឹងឲ្យរក្សាសម្បត្តិរបស់ចេតិយព្រមដោយសម្បត្តិរបស់ចេតិយផងគ្នា ព្រមដោយសម្បត្តិរបស់សង្ឃក្នុងរោងឧបោសថជាដើមនោះ សមគួរ ។ តែការឲ្យលោករក្សាសម្បត្តិរបស់សង្ឃព្រមដោយសម្បត្តិរបស់ចេតិយ មិនគួរ ។ តែវត្ថុយ៉ាងណាមួយ ដែលជារបស់សង្ឃ រក្សាទុកជាមួយរបស់ចេតិយ, វត្ថុរបស់សង្ឃនោះ កាលឲ្យរក្សារបស់ចេតិយទុកហើយ ក៏ជាការរក្សាទុកហើយតែម្ដង ព្រោះដូច្នោះ កាល

ឱ្យរក្សាទុកយ៉ាងនោះគួរ ។ សូម្បីកាលភិក្ខុរក្សាស្ថានទីទាំងឡាយ មានរោងឧបោសថជាដើម តាមបក្ខវារៈ វត្ថុដែលបាត់ទៅ ព្រោះអំណាចសេចក្តីប្រមាទ រមែងជាសំណង ដូចគ្នា ដូច្នេះឯង ។

**គយ ទីហូតពន្ធដារ**

[១១០] ជនទាំងឡាយ កន្លងដែនភាសីចាកទីនោះ ហេតុនោះ ទីនោះ ឈ្មោះថា **សុង្កឃាតៈ** ទីសម្រាប់ហូតពន្ធ ។ ពាក្យថា **សុង្កឃាតៈ** នោះ ជាឈ្មោះរបស់ ដែនគយ ។ ពិតមែន ដែនគយនោះ លោកហៅថា សុង្កឃាដៈ ព្រោះហេតុដែលជនទាំងឡាយ កាលមិនបង់ពន្ធ នាំភណ្ឌដែលគួរដល់ភាសីចេញទៅអំពីទីនោះ ឈ្មោះថា ផ្តាច់ព័ន្ធ គឺ ញុំាងភាសីរបស់ព្រះរាជាឱ្យសាបសូន្យទៅ ។

ពីរបទថា **តត្រ បវិសិត្វា** : **ភិក្ខុចូលទៅក្នុងខេត្តគយនោះ** មានសេចក្តីថា ចូលទៅក្នុងដែនគយដែលព្រះរាជាទ្រង់ធ្វើកំណត់ខេត្តតាំងទុកក្នុងទីទាំងឡាយ មានភ្នំដាច់ជាដើមនោះ ។

ពីរបទថា **រាជគ្ឃំ ភណ្ឌំ** : **ទ្រព្យដ៏គួរដល់ព្រះរាជានឹងយកពន្ធបានដល់** ភណ្ឌៈដែលគួរដល់ព្រះរាជា ។ អធិប្បាយថា ភាសីមានតម្លៃ ៥ មាសក ឬលើសជាង ៥ មាសក ជារបស់ដែលខ្លួនគួរថ្វាយចំពោះព្រះរាជា អំពីភណ្ឌៈណា, ភណ្ឌៈ នោះ ។ បាលីថា **រាជគ្គំ ខ្លះ** ។

សេចក្ដីយ៉ាងនេះដូចគ្នា ។ ភិក្ខុមានថេយ្យចិត្ត គឺ ញ៉ាំងថេយ្យចិត្តឱ្យកើតឡើងថា យើងនឹងមិនបង់ពន្ធដល់ព្រះរាជាអំពីភណ្ឌៈនេះ ហើយស្ទាបអង្អែលពាល់ត្រូវភណ្ឌៈនោះ ត្រូវទុក្កដ, ចាប់យកចាកទីដែលដាក់ទុកដាក់ក្នុងថង់យាម ឬចងជាប់នឹងភ្លៅទុកក្នុងទីបិទបាំង ត្រូវថុល្លច្ច័យ, កិរិយាដែលឱ្យឃ្លាតចាកឋាន ឈ្មោះថា មិនទាន់មាន ព្រោះខេត្រដែននៃបារាជិកព្រះមានព្រះភាគទ្រង់កំណត់ដោយដែនគយ, ភិក្ខុញ៉ាំងជំហានទី ២ ឱ្យឈានឆ្លងខេត្តកំណត់ដែនភាស៊ីទៅ ត្រូវអាបត្តិបារាជិក ។

ពីរបទថា ពហិសុង្កឃាតំ[1] បាតេតិ : **បោះផ្លោងរបស់ឱ្យធ្លាក់ចុះទៅខាងក្រៅខេត្តរបស់គយ** មានសេចក្ដីថា ភិក្ខុឈរនៅខាងក្នុងនុ៎ះឯង ឃើញរាជបុរសទាំងឡាយ បញ្ជូនចិត្តទៅក្នុងទីដទៃ ទើបគ្រវែងទៅដើម្បីត្រូវការឱ្យធ្លាក់ទៅខាងក្រៅ បើភណ្ឌៈនោះ ជារបស់នឹងធ្លាក់ទៅបានពិតប្រាកដ គ្រាន់តែរបូតពីដៃ លោកត្រូវបារាជិក ។ បើភណ្ឌៈនោះ ប៉ះខ្ទប់ដើមឈើ ឬជង្គត់ឈើ ឬត្រូវកម្លាំងខ្យល់ខ្លាំងក្តួចឡើងធ្លាក់ចុះខាងក្នុងវិញ នៅរក្សាបាន ។ លោកចាប់យកគ្រវែងទៅទៀត ត្រូវបារាជិក តាមន័យដែលពោលហើយក្នុងកាលមុននុ៎ះឯង ។ បើភណ្ឌៈនោះធ្លាក់ត្រង់ផែនដី ហើយរមៀលចូលមកខាងក្នុងទៀត លោកត្រូវបារាជិកដូចគ្នា ។ ចំណែកក្នុងកុរុន្ទី និងសង្ខេបអដ្ឋកថាពោលថា បើភណ្ឌៈនោះធ្លាក់ខាង

ក្រៅ ឈប់ហើយរមៀលចូលទៅ លោកត្រូវបារាជិក បើមិនទាន់ឈប់ រមៀលចូលទៅ នៅរក្សាបាន ។ ភិក្ខុនៅខាងក្នុងប្រើដៃ ឬជើង ឬឈើ

១. ថៃ. ពហិ សុន្ថុយាជំ ។

ប្រត់ឆ្អឹះប្រមៀលទៅ ឬថាឱ្យអ្នកដទៃប្រមៀលទៅ, បើកណ្ឌៈនោះមិនឈប់ រមៀលចេញទៅ ត្រូវបារាជិក ។ កណ្ឌៈនោះឈប់ខាងក្នុងហើយទើបរមៀលចេញទៅខាងក្រៅ នៅរក្សាបាន ។ កណ្ឌៈដែលភិក្ខុដាក់ទុកខាងក្នុងដោយគិតថា នឹងរមៀលចេញទៅខ្លួនឯង ឬថា អ្នកដទៃនឹងឱ្យវារមៀលចេញទៅ ខាងក្រោយរមៀលទៅខ្លួនឯង ឬ អ្នកដទៃប្រមៀលចេញទៅខាងក្រៅ នៅរក្សាបានដូចគ្នា ។ តែក្នុងកណ្ឌៈដែលភិក្ខុដាក់ទុកដោយចិត្តបរិសុទ្ធិ និងរមៀលចេញទៅយ៉ាងនោះ មិនមានពាក្យដែលនឹងគប្បីពោលឡើយ ។ ភិក្ខុធ្វើកញ្ចប់ពីរកញ្ចប់ឱ្យជាប់គ្នាជាចំណងតែមួយដាក់ទុកចន្លោះដែនរបស់ដែនគយ សូម្បីថា តម្លៃភាស៊ីក្នុងកញ្ចប់ក្រៅនឹងបានតម្លៃមួយបាទ ក៏ពិតមែន តែជាកញ្ចប់ក្នុងនៅរក្សាទុកបាន ព្រោះជាប់ជាមួយគ្នានឹងកញ្ចប់ក្រៅនោះ ។ តែបើលោកផ្លាស់កញ្ចប់ដែលនៅខាងក្នុងទៅដាក់ទុកខាងក្រៅ ត្រូវបារាជិក ។ សូម្បីក្នុងអម្រែកដែលភិក្ខុធ្វើឱ្យជាប់តគ្នាដាក់ទុក ក៏មានន័យដូចគ្នា ។ តែបើកណ្ឌៈ នោះ ជារបស់មិនបានចងត្រឹមតែពាក់ទុកលើចុងអម្រែកប៉ុណ្ណោះ ជាបារាជិក ។ ភិក្ខុដាក់

ទុកក្នុងយាន ឬលើខ្នងសេះជាដើម ដែលកំពុងទៅ ដោយធ្វើទុកក្នុងចិត្តថា ភណ្ឌៈនេះនឹងត្រូវនាំចេញទៅក្នុងខាងក្រៅ កាលភណ្ឌៈនោះត្រូវនាំចេញទៅហើយ អវហារ រមែងមិនមាន សូម្បីកណ្ឌទេយ្យក៏មិនមាន ។ ព្រោះហេតុអ្វី ? ព្រោះព្រះរាជាត្រាស់ទុកថា "ចូរហូតពន្ធដល់អ្នកដែលចូលមកក្នុងទីនេះ", ពិតមែន ភណ្ឌៈនេះ ភិក្ខុតាំងទុកក្រៅដែនគយ និងលោកមិនបាននាំទៅ; ព្រោះដូច្នោះ ទើបមិនមានភណ្ឌទេយ្យ មិនជាបារាជិក ។ សូម្បីក្នុងភណ្ឌៈដែលដាក់ទុកក្នុងយានដែលចតនៅជាដើម កាលយានជាដើមនោះទៅ វៀរប្រយោគរបស់ភិក្ខុនោះសូម្បីកាលមានថេយ្យចិត្ត អវហាររមែងមិនមានដូចគ្នា ។ តែបើភិក្ខុដាក់ហើយ បរយានជាដើមទៅ ឱ្យកន្លងដែនគយក្តី ឈរខាងមុខហើយ ហៅថា "មកចុះវើយ" ដូច្នេះព្រោះសេចក្តីដែលខ្លួនសន្សំទុកក្នុងមន្តទាំងឡាយ មានមន្តហៅដំរីជាដើមក្តី ត្រូវអាបត្តិបារាជិក ក្នុងខណៈឈានកន្លងដែនទៅ ។ ក្នុងឯឡកលោមសិក្ខាបទ មិនជាអាបត្តិក្នុងឋានៈនេះ គឺ ភិក្ខុឱ្យអ្នកដទៃនាំរោមចៀមទៅ, ក្នុងសិក្ខាបទនេះជាបារាជិក ។ ក្នុងឯឡកលោមសិក្ខាបទនោះ ភិក្ខុដាក់រោមចៀមក្នុងយាន ឬភណ្ឌៈរបស់ជនដទៃអ្នកមិនដឹង ឱ្យឈានកន្លងបីយោជន៍ទៅ, រោមចៀមជានិស្សគ្គិយ ព្រោះហេតុនោះ ភិក្ខុត្រូវបាចិត្តិយ, ក្នុងសិក្ខាបទនេះមិនជាអាបត្តិទេ ។

កាលដែលភិក្ខុបង់ពន្ធត្រង់ដែនគយមុនហើយទើបទៅ គួរ ។

ភិក្ខុមួយរូប ធ្វើការតាំងចិត្តទុកហើយទៅ ដោយគិតថា "បើគេនឹងទាមទារថា 'លោកចូរឱ្យតម្លៃភាសី' យើងក៏នឹងឱ្យ, បើពួកគេមិនទាមទារ, យើងនឹងទៅ" ដូច្នេះ ។ ភ្នាក់ងារភាសីម្នាក់ បានឃើញភិក្ខុនោះ ទើបពោលថា "ភិក្ខុនេះ កំពុងទៅ, ពួកលោកចូរហៅតម្លៃភាសីភិក្ខុនោះ" ។ ភ្នាក់ងារភាសីម្នាក់ទៀត និយាយឡើងថា "បព្វជិតនឹងមានតម្លៃភាសីអំពីទីណាហ្ន៎ និមន្តទៅចុះ" ដូច្នេះ, ជាការបានខអាងភិក្ខុគួរទៅ ។ តែកាលភិក្ខុពោលថា "កាលមិនបង់ពន្ធហើយទៅ មិនគួរដល់ភិក្ខុទាំងឡាយ, ព្រោះហេតុនោះ ចូរហៅពន្ធចុះ ឧបាសក" ដូច្នេះក្តី កាលភ្នាក់ងារភាសីនិយាយថា "កាលយើងនឹងហៅតម្លៃពន្ធរបស់ភិក្ខុ ក៏នឹងត្រូវយកបាត្រនិងចីវរ និងមានប្រយោជន៍អ្វីដោយបាត្រនិងចីវរនោះ និមន្តទៅចុះ" ដូច្នេះក្តី ជាការបានខអាងតែម្តង ។

បើពួកភ្នាក់ងារភាសីដេកលក់ក្តី លេងបាស្កាក្តី ឬទៅក្នុងទីណា ៗ បាត់ក្តី, និងភាសីនេះ សូម្បីស្រែកប្រាប់ថា "ពួកអ្នកភាសី នៅទីណា ?" ក៏មិនប្រទះឃើញ, ជាការបានខអាងដូចគ្នា ។ សូម្បីបើភិក្ខុទៅដល់ដែនគយហើយ បញ្ជូនចិត្តទៅគិតដល់អ្វី ៗ ក្តី ស្វាធ្យាយក្តី តាមប្រកបមនសិការក្តី ត្រូវភយន្តរាយ មានចោរ ដំរី រាជសីហ៍ និងខ្លាធំជាដើម

ងើបរត់ដេញជាប់តាមទៅក្តី ឃើញមហាមេឃខ្មៅតាំងឡើងហើយ ប្រាថ្នានឹងចូលទៅកាន់សាលាខាងមុខក្តី កន្លងហួសស្ថានទីនោះទៅ; ជាការបានខអាងដូចគ្នា ។

ក្នុងពាក្យថា សង្គំ បរិហរតិ : ភិក្ខុនាំទ្រព្យរត់ពន្ធ នេះ លោកពោលទុកក្នុងអដ្ឋកថាកុរុន្ទីថា ទោះបីជាភិក្ខុឈានចូលឧបចារហើយលបចៀសទៅក៏ដោយ ក៏ជាអវហារតែម្តង ។ តែក្នុងមហាអដ្ឋកថា លោកពោលទុកថា កាលភិក្ខុសម្លឹងឃើញទោសតែម្យ៉ាងថា ពួករាជបុរសបៀតបៀនអ្នកគេចពន្ធ ដូច្នេះ ទើបឈានចូលកាន់ឧបចារហើយបង្វៀងទៅ ជាទុក្កដ, កាលមិនបានឈានចូលឡើយ តែបង្វៀងចៀសទៅ មិនជាអាបត្តិ ។ ពាក្យក្នុងមហាអដ្ឋកថានេះ រមែងសមដោយព្រះបាលី ។ ក្នុងដែនគយនេះ គួរកំណត់ឧបចារទុក ២ លេឌ្ឌុបាទ ដូច្នេះឯង ។

ទីហូតពន្ធ ចប់

## សត្វមានជីវិត

[១១១] បន្ទាប់ពីការពោលពីដែនគយនេះទៅ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងសត្វដែលមានជីវិត ដែលល្មមគួរដល់អវហារដោយចំណែកមួយ ទើបត្រាស់ថា មនុស្សប្បាណោ : សត្វ គឺមនុស្ស ជា

ដើម ។ កាលភិក្ខុលួចសត្វ គឺមនុស្សអ្នកនៅមានជីវិតសូម្បីនោះ ដែលជាអ្នកជា ( គ្មានបំណុល ) ទៅ រមែងមិនជាអវហារ ។ សូម្បីបុគ្គលជាអ្នកជាណា ត្រូវមាតាឬបិតាយកទៅបញ្ចាំទុក ឬសាមីខ្លួនឯងយកខ្លួនធានាទុក ហើយបានកាន់យកទ្រព្យ ៥០ ឬ ៦០ កហាបណៈទៅ, កាលភិក្ខុលួចយកបុគ្គលជាអ្នកជាសូម្បីអ្នកនោះទៅ ក៏មិនជាអវហារ ។ ចំណែកទ្រព្យ រមែងបន្ថែមការប្រាក់ឡើងក្នុងស្ថានទីដែលគេទៅហើយ ។ តែកាលភិក្ខុលួចទាសៈនុ៎ះឯង មានទាសៈដែលកើតក្នុងផ្ទះ ទាសៈលោះមកដោយទ្រព្យ និងទាសៈដែលត្រូវនាំមកជាឈ្លើយ រមែងជាអវហារ ។ ពិតមែនព្រះមានព្រះភាគ ទ្រង់សំដៅយកទាសដែលកើតក្នុងផ្ទះជាដើមនោះឯង ទើបត្រាស់ព្រះតម្រាស់នេះទុកថា "ទាណោ នាម មនុស្សប្បាណោ វុច្ចតិ : សត្វ គឺមនុស្ស ហៅថា សត្វមានជីវិត" ដូច្នេះ ។

## បុគ្គលជាទាសៈ ៣ ពួក

ក៏បណ្តាទាសៈទាំងនេះ ទាសដែលកើតក្នុងផ្ទៃរបស់នាងទាសី ក្នុងផ្ទះគប្បីជ្រាបថា អន្តោជាតកា : ទាសៈដែលកើតខាងក្នុង, ទាសដែលទិញមកដោយទ្រព្យ គប្បីជ្រាបថា ធនក្កីតកា : ទាសដែលលោះមកដោយទ្រព្យ, បុគ្គលដែលត្រូវកៀងប្រមូលមកអំពីប្រទេសផ្សេងហើយ

ចូលដល់ភាពជាទាស គប្បីជ្រាបថា **ការមរាធិត** : ទាសដែលត្រូវនាំមកជាឈ្លើយ ។

ភិក្ខុគិតថា "យើងនឹងលួចសត្វដែលមានជីវិតបែបនេះទៅ" ហើយស្ទាបអង្អែល ត្រូវទុក្កដ ។ កាលលោកចាប់ត្រង់ដៃ ឬជើងលើកឡើង ធ្វើឱ្យកម្រើក ត្រូវថុល្លច្ច័យ ។ លោកប្រាថ្នានឹងលើកចៀសចេញទៅឱ្យកន្លងហួសចាកស្ថានទីដែលឈរ សូម្បីត្រឹមតែមួយចុងសរសៃសក់ទៅ ត្រូវបារាជិក ។ លោកចាប់ត្រង់សក់ ឬត្រង់ដើមដៃទាំងពីរ ទាញទៅ គប្បីពិន័យតាមជំហាន ។ ភិក្ខុគិតថា "យើងនឹងនាំឱ្យដើរទៅ" គម្រាមឬវាយបណ្ដើរនិយាយថា "ឯងចូរទៅមកនេះ" ។ កាលគេទៅកាន់ទិសាភាគតាមដែលភិក្ខុនោះបង្គាប់ លោកត្រូវបារាជិកក្នុងជំហានទី ២ ។ សូម្បីភិក្ខុពួកណា មានឆន្ទៈរួមនឹងភិក្ខុនោះ ជាបារាជិក ក្នុងខណៈតែមួយដល់ភិក្ខុទាំងអស់នោះ ។ ភិក្ខុឃើញទាសៈហើយ សួរដល់សុខទុក្ខ ឬមិនសួរក៏ដោយ និយាយថា "ឯងចូរទៅ ចូរចៀសចេញទៅ នៅជាសុខចុះ" ។ បើទាសនោះចៀសចេញទៅសោត, លោកត្រូវបារាជិកក្នុងជំហានទី ២ ។

ភិក្ខុដទៃ និយាយចំពោះទាសនោះ អ្នកចូលមកកាន់សំណាក់របស់ខ្ញុំថា "ឯងចូរចៀសទៅ" ។ បើភិក្ខុទាំងរយរូប និយាយនឹងទាសអ្នកចូលមកកាន់សំណាក់របស់ខ្លួន ៗ តាមលំដាប់, ក៏ជាបារាជិកជាមួយ

គ្នាទាំងអស់ ។ ចំណែកភិក្ខុណា និយាយនឹងទាសដែលកំពុងរត់ចៀសចេញទៅទន្ទឹះឯងថា "អ្នកចូរចៀសចេញទៅ ដរាបណាដែលម្ចាស់ចាប់ឯងមិនបាន", ភិក្ខុនោះ មិនត្រូវអាបត្តិបារាជិក ។ តែបើលោកនិយាយចំពោះទាសដើរសន្សឹម ៗទៅ, និងទាសនោះក៏ដើរទៅយ៉ាងរហ័ស តាមពាក្យរបស់ភិក្ខុនោះ, ជាបារាជិក, កាលភិក្ខុឃើញទាស ចៀសចេញទៅកាន់ស្រុកឬប្រទេសដទៃហើយដេញឱ្យចៀសចេញទៅ សូម្បីចាកស្រុកឬប្រទេសនោះ ក៏ជាបារាជិកដូចគ្នា ។ ឈ្មោះថា អទិន្នាទាន រមែងផុតបានដោយបរិយាយ ។

ពិតមែន ភិក្ខុណា និយាយយ៉ាងនេះថា "លោកធ្វើអ្វីនៅទីនេះ ? លោកចៀសចេញទៅមិនគួរឬ ?"ក្តី ថា "ការដែលលោកទៅក្នុងទីណា ៗ ហើយ មានជីវិតរស់នៅយ៉ាងសប្បាយមិនគួរឬ ?"ក្តី ថា "ពួកទាសៈនិងទាសីនាំគ្នាចៀសចេញទៅកាន់ប្រទេសឈ្មោះឯណោះហើយ រមែងរស់នៅយ៉ាងសប្បាយ"ក្តី, និងគេបានស្តាប់ពាក្យនិយាយរបស់ភិក្ខុនោះហើយ ក៏ចៀសចេញទៅ, រមែងមិនជាអវហារ ។ ចំណែកភិក្ខុណា និយាយថា "ពួកអាត្មា នឹងទៅកាន់ប្រទេសឈ្មោះឯណោះ, អ្នកទៅក្នុងប្រទេសនោះហើយ រមែងរស់នៅយ៉ាងសប្បាយ, និងកាលពួកលោកទៅជាមួយពួកអាត្មា នឹងមិនមានសេចក្តីលំបាក ដោយស្បៀងតាមមកជាដើម សូម្បីក្នុងចន្លោះមក"ដូច្នេះហើយ នាំយកទាសដែលមកជាមួយខ្លួនទៅ, ដោយ

អំណាចនៃការធ្វើដំណើរ មិនមែនទៅដោយថេយ្យចិត្ត មិនជាអវហារឡើយ ។ កាលមានពួកចោរប្រាកដឡើងហើយក្នុងចន្លោះមក សូម្បីកាលភិក្ខុពោលថា "វើយ ពួកចោរប្រាកដឡើងហើយ ។ ឯងចូរប្រញាប់ចៀសចេញទៅ ចូរប្រញាប់មក ទៅជាមួយគ្នា" ដូច្នេះ អាចារ្យទាំងឡាយ ក៏មិនពិន័យជាអវហារ ព្រោះលោកពោលដើម្បីត្រូវការឱ្យផុតពីអន្តរាយអំពីចោរ ដោយប្រការដូច្នេះ ។

សត្វមានជីវិត ចប់

## សត្វគ្មានជើង

[១១២] បណ្ដាសត្វមិនមានជើងទាំងឡាយ ឈ្មោះថា ពស់មានម្ចាស់ គឺ ពស់ដែលពួកគ្រូចាប់ពស់ជាដើមចាប់ទុក កាលឱ្យលេងរមែងបានតម្លៃកន្លះបាទខ្លះ មួយបាទខ្លះ មួយកហាបណៈខ្លះ, សូម្បីកាលនឹងលែងវាចេញទៅ ក៏ទទួលយកប្រាក់និងមាសហើយ ទើបលែងចេញ ។ ម្ចាស់ពស់ទាំងនោះ ទៅកាន់ឱកាសដែលភិក្ខុខ្លះអង្គុយហើយដាក់ទ្រុងទុក ដេកលក់ទៅ ឬទៅក្នុងទីណាមួយ ។ បើភិក្ខុនោះចាប់ពាល់ទ្រុងនោះក្នុងស្ថានទីនោះ ដោយថេយ្យចិត្ត ត្រូវទុក្កដ ។ ធ្វើឱ្យកម្រើកត្រូវថុល្លច្ច័យ, ឱ្យឃ្លាតចាកឋាន ត្រូវបារាជិក ។ តែបើលោកបើកទ្រុងចេញហើយចាប់ពស់ត្រង់ក ត្រូវទុក្កដ, លើកពស់ឡើងត្រូវ

ថុល្លច្ច័យ, កាលលោកលើកឡើងឱ្យត្រង់ ៗ ល្មមកន្ទុយពស់ផុតពីផ្ទៃទ្រូងត្រឹមតែមួយចុងសរសៃសក់ ក៏ត្រូវបារាជិក ។ កាលលោកទាញអូសចេញទៅ ល្មមកន្ទុយពស់ផុតពីកណ្តាប់មាត់ ( ទ្រូង ) ទៅ ត្រូវបារាជិក លោកបើកមាត់ទ្រូងចេញបន្តិចហើយ វាយ ឬស្រែកហៅចេញឈ្មោះថា "វើយ ចូរលូនចេញមក" ហើយឱ្យលូនចេញ ត្រូវបារាជិក ។ លោកបើកចេញយ៉ាងនោះហើយ ទើបធ្វើសំឡេងកង្កែបស្រែក ឬសំឡេងកណ្តុរស្រែក ឬរោយលាចចុះក៏ដោយ ហើយស្រែកហៅចេញឈ្មោះ ឬផ្ទាត់ម្រាមដៃក៏ដោយ សូម្បីកាលពស់លូនចេញទៅ ដោយកិរិយាដែលធ្វើសំឡេងជាដើមយ៉ាងនោះ ក៏ត្រូវបារាជិក ។ កាលលោកមិនបានបើកមាត់ចេញ តែបានធ្វើកិរិយាយ៉ាងនោះពស់ឃ្លានខ្លាំង ទើបយកក្បាលត្បុលជញ្ជាំងទ្រូង ធ្វើប្រហោងហើយក៏លូនចៀសចេញទៅ ជាបារាជិកដូចគ្នា ។ តែកាលលោកបើកមាត់ទ្រូងចេញហើយ ពស់លូនចេញចៀសទៅដោយខ្លួនឯង រមែងជាភណ្ឌទេយ្យ ។ សូម្បីបើលោកបើកមាត់ចេញក៏ដោយ មិនបានបើកចេញក៏ដោយ តែបានធ្វើជាសំឡេងកង្កែបនិងសំឡេងកណ្តុរស្រែក ឬរោយលាចចុះតែម្យ៉ាងប៉ុណ្ណោះ មិនបានស្រែកហៅបញ្ចេញឈ្មោះ ឬមិនបានផ្ទាត់ម្រាមដៃ, ព្រោះឃ្លានខ្លាំង ពស់គិតថា នឹងស៊ីកង្កែបជាដើម ទើបលូនចៀសចេញទៅ ជាភណ្ឌទេយ្យដូចគ្នា ។ ត្រឹមកហើយ ក្នុងអធិការនេះ តែម្យ៉ាង ដោយស័ព្ទថា សត្វមិន

មានជើង ។ ក៏ពាក្យដែលគប្បីពោលក្នុងត្រីនេះ ខ្ញុំព្រះករុណាបានពោលទុកហើយក្នុងកណ្ឌៈតាំងនៅក្នុងទឹកនោះឯង ដូច្នេះ ។

សត្វមិនមានជើង ចប់

## សត្វមានជើងពីរ

[១១៣] បណ្តាសត្វជើងពីរទាំងឡាយ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងពួកសត្វ ជើង ២ ដែលអ្នកណា ៗ អាចលួចយកទៅបាន ទើបត្រាស់ពាក្យថា មនុស្សា បក្ខជាតា ៖ ពួកមនុស្ស ពួកសត្វស្លាបជាដើម ។ ចំណែកពួកទេវតា អ្នកណាមួយ មិនអាចលួចយកទៅបាន ។ ដែលឈ្មោះថា បក្សជាត ព្រោះអត្ថថា សត្វទាំងនោះមានស្លាបកើតហើយ ។ សត្វមានស្លាបទាំងនោះ មាន ៣ ពួក គឺ មានរោមជាស្លាបពួកមួយ មានស្បែកជាស្លាបពួកមួយ មានឆ្អឹងជាស្លាបពួកមួយ, បណ្តាសត្វទាំងនោះ សត្វក្ងោកនិងមាន់ជាដើម គប្បីជ្រាបថា មានរោមជាស្លាប, ប្រចៀវជាដើម គប្បីជ្រាបថា មានស្បែកជាស្លាប, សត្វត្រឡង់ជាដើមគប្បីជ្រាបថា មានឆ្អឹងជាស្លាប[១] ។ ចំណែកពាក្យដែលគប្បីពោលក្នុងសត្វជើង ២ នេះ ខ្ញុំព្រះករុណាបានពោលទុកហើយក្នុងកណ្ឌៈដែលនៅក្នុងអាកាស និងសត្វមានជីវិតនោះ ដូច្នេះឯង ។

សត្វមានជើងពីរ ចប់

---

១. ពួកមនុស្ស និងបក្សាជាតិទាំងអស់ មកក្នុងអធិការនេះតែម្យ៉ាង ដោយស័ព្ទថា សត្វជើងពីរ ។

## សត្វមានជើងបួន

[១១៤] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសត្វជើង ៤ តទៅ ៖

ប្រភេទនៃសត្វជើង ៤ ទាំងអស់ ដ៏សេសដែលមកក្នុងព្រះបាលី គប្បីជ្រាបថា បសុសត្វ សត្វចិញ្ចឹម ។ សត្វទាំងឡាយមានដំរីជាដើម ប្រាកដច្បាស់ហើយឯង ។ បណ្ដាសត្វមានដំរីជាដើមទាំងនោះ កាលភិក្ខុស្ទាបអង្អែលដំរីដោយថេយ្យចិត្ត ជាទុក្កដ, ធ្វើឱ្យកម្រើក ជាថុល្លច្ច័យ ។ ចំណែកភិក្ខុណា មានកម្លាំងច្រើន ប្រើសីសៈទូលយកកូនដំរីនៅតូច ត្រង់ផ្ចិតឡើងព្រោះសេចក្ដីស្រវឹងខ្លាំងឱ្យជើងទាំង ៤ និងប្រមោយផុតពីដីសូម្បីត្រឹមតែមួយចុងសរសៃសក់, ភិក្ខុនោះ ត្រូវបារាជិក ។ តែដំរីខ្លះគេចងទុកក្នុងរោងដំរី, ដំរីខ្លះឈរ មិនបានចងឡើយ, ដំរីខ្លះឈរខាងក្នុងទីនៅ, ដំរីខ្លះឈរក្នុងព្រះលានហ្លួង ។

បណ្ដាដំរីទាំងនោះ ដំរីដែលចងកទុកក្នុងរោងដំរី មានឋាន ៥ គឺ ចំណងត្រង់ក និងជើងទាំង ៤ សម្រាប់ដំរីដែលគេយកច្រវាក់ដែកចងទុកត្រង់ក និងត្រង់ជើងម្ខាង មានឋាន ៦ ។ ដំរីខ្សែដែលគេចងទុកត្រង់កនិងជើងទាំង ២ មានឋាន ៧ ។ គប្បីជ្រាបការធ្វើឱ្យកម្រើក និងឱ្យ

ឃ្លាតចាកឋាន ដោយអំណាចនៃឋានទាំងនោះ ។

ពេនដំរីទាំងអស់ ជាឋានរបស់ដំរីដែលគេមិនបានចងទុក, ជាបារាជិក ក្នុងកាលឲ្យឈានកន្លងចាកពេនដំរីនោះទៅ ។ ផ្ទៃដីខាងក្នុងទីនៅទាំងអស់នុ៎ះឯង ជាឋានរបស់ដំរីឈរខាងក្នុងទីនៅ, ជាបារាជិក ក្នុងកាលឲ្យកន្លងហួសទ្វារដែលជាទីនៅរបស់ដំរីនោះទៅ ។ ព្រះនគរទាំងអស់ជាឋានរបស់ដំរីដែលឈរនៅក្នុងព្រះរាជវាំង, ជាបារាជិក ក្នុងកាលឲ្យដំរីនោះកន្លងហួសទ្វារព្រះនគរទៅ ។ ស្ថានទីឈរនុ៎ះឯងជាឋានរបស់ដំរីដែលឈរខាងក្រៅព្រះនគរ ។ ភិក្ខុកាលលួចដំរីនោះទៅ គប្បីពិន័យដោយជំហាន ។ សម្រាប់ដំរីដែលដេកនៅ មានឋានតែមួយប៉ុណ្ណោះ ។ កាលភិក្ខុដេញឲ្យដំរីក្រោកឡើង ដោយថេយ្យចិត្ត លុះដំរីក្រោកឡើងហើយ ក៏ជាបារាជិក ។ សូម្បីសេះ ក៏មានវិនិច្ឆ័យដូចគ្នានេះឯង ។ តែបើសេះនោះត្រូវគេចងឆ្នាក់ទុកត្រង់ជើងទាំង ៤ ពិតមែន គប្បីជ្រាបថាមានឋាន ៨ ។ សូម្បីក្នុងអូដ្ឋ ក៏មានន័យដូច្នេះ ។ សូម្បីគោខ្លះជាសត្វដែលគេចងឃាំងទុកក្នុងផ្ទះ, ខ្លះឈរ មិនបានចងឡើយ ។ តែខ្លះ គេចងទុកក្នុងក្រោល, ខ្លះក៏ឈរមិនបានចងទុកឡើយ ។

បណ្ដាគោទាំងនោះ គោដែលគេចងឃាំងទុកក្នុងផ្ទះ មានឋាន ៥ គឺ ជើងទាំង ៤ និងចំណង ។ ពេនទាំងអស់ ជាឋានរបស់គោដែលមិនបានចង ។ គោដែលគេចងទុកក្នុងក្រោលក៏មានឋាន ៥ ។ ក្រោលទាំងអស់ ជាឋានរបស់គោដែលមិនបានចង ។ ភិក្ខុឲ្យគោនោះកន្លង

ហួសទ្វារក្រោលទៅ ត្រូវបារាជិក ។ កាលលោកទម្លាយក្រោលលួចទៅឱ្យកន្លងហួសទ្វារក្រោលទៅ ជាអាបត្តិបារាជិក ។ លោកបើកទ្វារចេញ ឬទម្លាយក្រោលហើយ ឈរខាងក្រៅ ហើយស្រែកហៅចេញឈ្មោះបន្ទាប់ឱ្យគោចេញមក ត្រូវបារាជិក ។ សូម្បីសម្រាប់ភិក្ខុដែលសម្តែងមែកឈើដែលកាច់បាក់ហើយ ឱ្យគោឃើញហើយហៅមក ក៏មានន័យដូចគ្នានុ៎ះឯង ។ លោកមិនបានបើកទ្វារ ក្រោលក៏មិនបានទម្លាយ ត្រឹមតែអង្រួនមែកឈើដែលកាច់បានហើយហៅគោមក ។ គោលោតចេញមកព្រោះសេចក្តីឃ្លានខ្លាំង ជាបារាជិកដូចគ្នា ។ តែបើកាលលោកបើកទ្វារចេញ ឬទម្លាយក្រោលហើយ គោក៏ចេញមកដោយខ្លួនឯង ជាភណ្ឌទេយ្យ ។ លោកបើកទ្វារ ឬមិនបានបើកក៏ដោយ ទម្លាយក្រោល ឬមិនបានទម្លាយក៏ដោយ គ្រាន់តែអង្រួនមែកឈើដែលកាច់បានតែម្យ៉ាងមិនបានហៅគោ ។ គោដើរចេញទៅឬលោតចេញទៅ ព្រោះសេចក្តីឃ្លានខ្លាំង, ជាភណ្ឌទេយ្យដូចគ្នា ។ គោដែលគេចងទុកកណ្តាលស្រុក ឈរមួយដេកមួយ ។ គោដែលឈរមានឋាន៥ ។ គោដែលដេកមានឋាន២ ។

គប្បីជ្រាបការធ្វើឱ្យកម្រើក និងឱ្យឃ្លាតចាកឋាន ដោយអំណាចនៃឋានទាំងនោះ ក៏ភិក្ខុណា មិនបានដេញគោដែលដេកឱ្យក្រោកឡើង តែសម្លាប់ក្នុងទីនោះឯង ជាភណ្ឌទេយ្យដល់ភិក្ខុនោះ ។ ក៏ស្រុកទាំងអស់ជាឋានរបស់គោឈរក្នុងស្រុកដែលបានប្រកបទ្វារលោមព័ទ្ធទុកយ៉ាងល្អ សម្រាប់គោដែលឈរ ឬដែលត្រាច់ទៅក្នុងស្រុកមិនបានលោមព័ទ្ធ ស្ថាន

ទីដែលវាជាន់ ដោយជើងទាំង ៤ នោះឯង ជាឋាន ។ សូម្បីក្នុងសត្វទាំងឡាយ មានលា និងបសុសត្វជាដើម ក៏មានវិនិច្ឆ័យដូចគ្នានេះឯង ។

សត្វមានជើងបួន ចប់

## សត្វមានជើងច្រើន

[១១៥] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្វមានជើងច្រើនតទៅ ៖

បើវត្ថុបារាជិកពេញដោយក្អែបតែមួយ កាលភិក្ខុលួចក្អែបនោះទៅដោយជើង ជាថុល្លច្ច័យ ៩៩ , ជាបារាជិកតែមួយ ។ ពាក្យដ៏សេសមានន័យដូចដែលពោលហើយនុ៎ះឯង ។

សត្វមានជើងច្រើន ចប់

## ភិក្ខុកំណត់របស់ឱ្យគេលួច

[១១៦] ដែលឈ្មោះថា ភិក្ខុអ្នកកំណត់របស់ឱ្យគេលួច ព្រោះអត្ថថា ប្រព្រឹត្តអាក្រក់ថោកទាប ។ លោកពោលអធិប្បាយថា រមែងតាមចូលទៅខាងក្នុងក្នុងស្ថានទីនោះ ៗ ។

បទថា ឱចរិត្វា : គយគន់ សេចក្តីថា វង់ចាំកំណត់ គឺ

ពិនិត្យមើលហើយ ។

បទថា **អាចិក្ខតិ** : **ហើយប្រាប់** សេចក្ដីថា ភិក្ខុក្លែងប្រាប់ទ្រព្យដែលរក្សាទុកមិនល្អ ក្នុងត្រកូលរបស់ជនដទៃឬក្នុងវិហារជាដើម ដែលមិនបានចាត់ការរក្សាទុកដល់ភិក្ខុដទៃអ្នកអាចនឹងធ្វើចោរកម្មបាន ។

ប្រើនបទថា **អាបត្តិ ឧភិន្នំ បារាជិកស្ស** : **ត្រូវអាបត្តិបារាជិកទាំងពីររូប** សេចក្ដីថា លោកទាំងពីររូប ត្រូវអាបត្តិបារាជិកយ៉ាងនេះ គឺ ក្នុងទ្រព្យដែលនឹងត្រូវលួចបានពិតប្រាកដ ភិក្ខុអ្នកបង្គាប់ត្រូវអាបត្តិក្នុងខណៈបង្គាប់ ភិក្ខុអ្នកទទួលបង្គាប់ក្រៅនេះ ត្រូវអាបត្តិក្នុងខណៈដែលធ្វើឱ្យឃ្លាតចាកឋាន ។ ចំណែកភិក្ខុណា ធ្វើបរិយាយដោយន័យជាដើមថា ក្នុងផ្ទះមិនមានមនុស្សប្រុស គេរក្សាទ្រព្យឈ្មោះឯណោះទុកក្នុងចំណែកមួយ មិនបានចាត់ការរក្សាទុក ទាំងទ្វារក៏មិនបានបិទ, អាចនឹងលួចយកទៅបានតាមមកដែលទៅហើយនុ៎ះឯង ឈ្មោះថា បុគ្គលអ្នកណាមួយ ដែលរស់នៅដោយសេចក្ដីព្យាយាម ដូចកូនប្រុស នឹងគប្បីទៅលួចយកទ្រព្យនោះមិនបានឡើយ ។ ក៏ភិក្ខុដទៃបានស្ដាប់ពាក្យនោះហើយ គិតថា ឥឡូវនេះយើងនឹងលួចយក ( ទ្រព្យនោះ ) ទើបដើរទៅលួច, ជាបារាជិកដល់ភិក្ខុនោះ ក្នុងខណៈដែលធ្វើឱ្យឃ្លាតចាកឋាន ។ ចំណែកភិក្ខុក្រៅនេះ មិនជាអាបត្តិ ។ ពិតមែន ភិក្ខុដែលធ្វើបរិយាយ

នោះ រមែងផុតពីអទិន្នាទានដោយបរិយាយ ដូច្នេះឯង ។

ភិក្ខុកំណាត់របស់ឱ្យគេលួច ចប់

## ភិក្ខុរក្សាទ្រព្យដែលគេផ្ញើ

[១១៧] ភិក្ខុដែលឈ្មោះថា ជាអ្នកទទួលរបស់ផ្ញើ ព្រោះអត្ថថា រក្សាទ្រព្យដែលគេនាំមកផ្ញើទុក ។ ភិក្ខុណា ដែលជនដទៃ ពោលថា លោកដ៏ចម្រើន ជួយថែរក្សាទ្រព្យនេះមួយភ្លែត ទម្រាំខ្ញុំព្រះករុណាធ្វើកិច្ចឈ្មោះនេះរួចហើយត្រឡប់មក បានរក្សាទ្រព្យគេនាំមកផ្ញើនោះ ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ទើបត្រាស់ថា "ភិក្ខុអ្នកថែទាំរក្សាទ្រព្យដែលគេនាំមកផ្ញើទុកមួយភ្លេច ហៅថា អ្នករក្សាបញ្ញើ" ដូច្នេះ ។

ក្នុងរឿងនោះ ភិក្ខុដែលទទួលរបស់ផ្ញើ មិនបានស្រាយកញ្ចប់ វត្ថុដែលម្ចាស់របស់គេចងហើយបោះត្រាទុក ដោយចំណែកច្រើន កាត់តែការុងឬកញ្ចប់ខាងក្រោមចេញហើយ កាន់យកត្រឹមតែបន្តិចធ្វើការដេរជាដើមឱ្យជាប្រក្រតី ដូចដើមវិញ សម្រាប់ភិក្ខុដែលគិតថា "យើងនឹងកាន់យកដោយអាការយ៉ាងនេះ" ហើយធ្វើការចាប់ពាល់ជាដើម គប្បីជ្រាបថា ជាអាបត្តិតាមសមគួរ ដូច្នេះឯង ។

ភិក្ខុរក្សាទ្រព្យដែលគេផ្ញើ ចប់

## ការបបួលគ្នាលួច

[១១៨] ការបបួលគ្នាលួច ឈ្មោះថា **សំវិធាវហារ** កិរិយាលួចដោយបបួលគ្នា ។ មានពាក្យអធិប្បាយថា ការលួចដែលធ្វើដោយសេចក្តីជាអ្នករួមគំនិតគ្នា ។

បទថា **សំវិធហិត្វា** : ភិក្ខុដែលរួមគំនិតចូលគ្នា មានសេចក្តីថា ប្រឹក្សារកគ្នា ដោយភាពជាអ្នករួមឆន្ទៈគ្នា គឺ ដោយភាពជាអ្នករួមអធ្យាស្រ័យគ្នា ។

## ភិក្ខុច្រើនរូបបបួលគ្នាទៅលួចទ្រព្យត្រូវអាបត្តិគ្រប់រូប

វិនិច្ឆ័យក្នុងសំវិធាវហារនោះ ដូច្នេះ ភិក្ខុច្រើនរូបជាមួយគ្នា បបួលគ្នាថា ពួកយើងនឹងទៅផ្ទះ ឈ្មោះឯណោះ នឹងទម្លាយជំបូល ឬជញ្ជាំង ឬនឹងកាត់ទីតលួចរបស់ ។ បណ្តា ភិក្ខុទាំងនោះ មួយរូបលួចរបស់បាន, ជាបារាជិកដល់ភិក្ខុទាំងអស់ ក្នុងខណៈលើកភណ្ឌៈនោះឡើង ។ ពិតមែន សូម្បីក្នុងគម្ពីរបរិវារ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះថា

"ជនគឺភិក្ខុ៤ រូប បបួលគ្នាលួចគរុភណ្ឌ ឯភិក្ខុ៣ រូបត្រូវអាបត្តិបារាជិក ភិក្ខុ ១ រូប មិនត្រូវអាបត្តិបារាជិកទេ ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។"[១]

---

១. វិន. បរិ. សេទមោចនគាថា. ១៣. ៣៩២/៤០៥ ។

សេចក្តីនៃពាក្យនោះ គប្បីជ្រាបដូច្នេះ ៤ រូប គឺ អាចារ្យនិងអន្តេវាសិកជាអ្នកប្រាថ្នានឹងលួចគរុភ័ណ្ឌ តម្លៃ ៦ មាសក ។ បណ្តាជនទាំង ៤ នាក់នោះ អាចារ្យបង្គាប់ថា លោកចូរលួច ១ មាសក លោកចូរលួច ១ មាសក លោកចូរលួច ១ មាសក ខ្ញុំនឹងលួច ៣ មាសក ។

ចំណែកបណ្តាអន្តេវាសិកទាំងឡាយ អន្តេវាសិកមួយរូប ពោលថា "លោកម្ចាស់ចូរលួច ៣ មាសក, លោករូបនេះចូរលួច ១ មាសក, លោករូបនេះចូរលួច ១ មាសក, ខ្ញុំព្រះករុណានឹងលួច ១ មាសក សូម្បីអន្តេវាសិក ២ រូបក្រៅអំពីនេះ ក៏បានពោលយ៉ាងនោះដូចគ្នា ។ បណ្តាជនទាំង ៤ នាក់នោះ មាសកមួយរបស់អន្តេវាសិកម្នាក់ ៗ ក្នុងពួកអន្តេវាសិក ជាសាហត្ថិកអវហារ, ជាអាបត្តិទុក្កដដល់អន្តេវាសិកទាំង ៣ អ្នកនោះ ដោយមាសកមួយនោះ ។ ៥ មាសកជាអាណត្តិកអវហារ, ជាបារាជិកដល់អន្តេវាសិកទាំង ៣ រូប ដោយ ៥ មាស

កនោះ ៗ ចំណែក ៣ មាសករបស់អាចារ្យ ជាសាហត្ថិកៈ, ជាថុល្លច្ច័យដល់អាចារ្យនោះ ដោយ ៣ មាសកនោះ ៗ ៣ មាសកជាអាណត្តិកៈ, សូម្បីដោយ ៣ មាសកនោះ ក៏ជាថុល្លច្ច័យដូចគ្នា ។ ពិតមែន ក្នុងអទិន្នាទានសិក្ខាបទនេះ សាហត្ថិកៈមិនជាអង្គរបស់អាណត្តិកៈ ឬអាណត្តិកៈមិនជាអង្គរបស់សាហត្ថិកៈ ។ តែសាហត្ថិកៈគប្បីពិន័យរួមជាមួយសាហត្ថិកៈដូចគ្នាបាន ។ អាណត្តិកៈគប្បីពិន័យរួមនឹងអាណត្តិកៈជាមួយគ្នាបាន ។ ព្រោះហេតុនោះឯង លោកទើបពោលថា ៖

ជនគឺភិក្ខុ៤ រូប បបួលគ្នាលួចគរុភណ្ឌ ឯភិក្ខុ ៣ រូប
ត្រូវអាបត្តិបារាជិក ភិក្ខុ១រូប មិនត្រូវអាបត្តិបារាជិកទេ
ប្រស្នានេះ ពួកលោកអ្នកឈ្លាសវៃ បានគិតមកហើយ ។

ម្យ៉ាងទៀត ដើម្បីមិនច្រឡំក្នុងសំវិធាវហារ គប្បីកំណត់ចតុក្កៈសូម្បីនេះដោយសេចក្តី គឺ **ភណ្ឌតែមួយ មានម្ចាស់តែមួយ, ភណ្ឌតែមួយ មានម្ចាស់ច្រើន, ភណ្ឌច្រើន មានម្ចាស់តែមួយ, ភណ្ឌច្រើន មានម្ចាស់ច្រើន** ។ ក្នុងចតុក្កៈនោះ ពាក្យថា **ភណ្ឌតែមួយ មានម្ចាស់តែមួយ** នោះ គឺ ភិក្ខុច្រើនរូប ឃើញរបស់មានតម្លៃ ៥ មាសកដែលគេដាក់ទុកមិនល្អ ត្រង់ផែនក្តារពានផ្សាររបស់ត្រកូលមួយ ទើបបង្គាប់ភិក្ខុមួយរូបថា

លោកចូរទៅលួចវត្ថុនោះ, ជាបារាជិកដល់ភិក្ខុទាំងអស់ ក្នុងខណៈដែលលើកភណ្ឌៈឡើងនោះ ។

ពាក្យថា **ភណ្ឌតែមួយ មានហានច្រើន** នោះ គឺ ភិក្ខុច្រើនរូបឃើញមាសកដែលគេដាក់ទុកមិនល្អ លើផែនក្តារពានផ្កា ៥ បន្ទះ ក្នុងមួយបន្ទះមានមួយមាសករបស់ត្រកូលមួយទើបបង្គាប់បញ្ជាភិក្ខុមួយរូបថា លោកចូរទៅលួចមាសកទាំងនោះ ។ ជាបារាជិកដល់ភិក្ខុគ្រប់រូបក្នុងខណៈដែលលើកមាសកទី ៥ ឡើង ។

ពាក្យថា **ភណ្ឌច្រើន មានហានតែមួយ** នោះ គឺ ភិក្ខុច្រើនរូបឃើញរបស់មានតម្លៃ ៥ មាសក ឬលើសជាង ៥ មាសក ជារបស់នៃមនុស្សច្រើននាក់ ដែលដាក់ទុកមិនល្អក្នុងទីតែមួយរួមគ្នា ទើបបង្គាប់ភិក្ខុមួយរូបថា លោកចូរទៅលួចរបស់នោះមក, ជាបារាជិកដល់ភិក្ខុគ្រប់រូបក្នុងខណៈលើកភណ្ឌៈនោះឡើង ។

ពាក្យថា **ភណ្ឌច្រើន មានហានច្រើន** នោះ គឺ ភិក្ខុច្រើនរូបឃើញមាសករបស់ជនប្រាំត្រកូល ត្រកូលនីមួយ ៗ មាន៥មាសក ដែលដាក់ទុកមិនល្អ លើផែនក្តារពានផ្កាប្រាំបន្ទះ មួយបន្ទះមួយមាសក ទើបបង្គាប់ភិក្ខុមួយរូបថា លោកចូរទៅលួចមាសកទាំងនោះមក, ជាបារាជិក

ដល់ភិក្ខុគ្រប់រូប ក្នុងខណៈដែលលើកមាសកទី ៥ ឡើង ដោយប្រការដូច្នេះ ។

ការបបួលគ្នាលួច ចប់

## សង្កេតកម្ម

[១១៩] កម្មជាសញ្ញាកំណត់ដឹងពេលគ្នា ឈ្មោះថាសង្កេតកម្ម ។ អធិប្បាយថា ការធ្វើសញ្ញាឱ្យដឹងគ្នា ដោយអំណាចកំណត់វេលា ។ ក៏ក្នុងសង្កេតកម្មនេះ កាលភិក្ខុអ្នកប្រើបង្គាប់ថា លោកចូរលួចក្នុងវេលាមុនភត្ត ភិក្ខុអ្នកទទួលបង្គាប់នឹងលួចក្នុងវេលាមុនភត្តថ្ងៃនេះ ឬស្អែកនេះ ឬក្នុងឆ្នាំក្រោយក៏ដោយ, ការខុសសង្កេត រមែងមិនមាន, ជាបារាជិកដល់លោកទាំង ២ រូប តាមន័យដែលពោលហើយក្នុងភិក្ខុជាអ្នកកំណត់របស់ឱ្យគេលួច[១]ទុះឯង ។ តែកាលភិក្ខុអ្នកប្រើបង្គាប់ថា លោកចូរលួចក្នុងវេលាមុនអាហារថ្ងៃនេះ ភិក្ខុអ្នកទទួលបង្គាប់លួចក្នុងថ្ងៃស្អែកនេះ, វត្ថុនោះ រមែងជាការដែលភិក្ខុទទួលបង្គាប់លួចមកខាងក្រោយ កន្លងហួសកំណត់នោះ ដែលអ្នកប្រើកំណត់ទុកថា ថ្ងៃនេះ, បើកាលភិក្ខុអ្នកប្រើបង្គាប់ថា "ចូរលួចក្នុងវេលាមុនអាហារស្អែកនេះ" ភិក្ខុដែលទទួលបង្គាប់លួចក្នុងវេលាមុនអាហារថ្ងៃនេះ, វត្ថុនោះ រមែងជា

ការអ្នកទទួលបង្គាប់លួចបានមកមុន នៅមិនទាន់ដល់កំណត់នោះ ដែលអ្នកប្រើកំណត់ថា ក្នុងថ្ងៃស្អែក, ជាបារាជិក ចំពោះភិក្ខុអ្នកលួច ដែលលួចយ៉ាងនោះប៉ុណ្ណោះ, មិនជាអាបត្តិដល់ភិក្ខុអ្នកផ្តើម ។ ក្នុងកាលអ្នក

១. នៅទំព័រ ៤៨១ ។

ប្រើបង្គាប់ថា ចូរលួចក្នុងវេលាមុនភត្តក្នុងថ្ងៃស្អែក, ចំណែកភិក្ខុដែលទទួលបង្គាប់ លួចក្នុងថ្ងៃនោះឯង ឬក្នុងវេលាក្រោយភត្តក្នុងថ្ងៃស្អែក គប្បីជ្រាបថា លួចមកមុនទិងខាងក្រោយអំពីការកំណត់នោះ ។ សូម្បីក្នុងវេលាក្រោយភត្ត ពេលយប់ និងពេលថ្ងៃ ក៏មានន័យដូចគ្នានេះ ។ ក៏ក្នុងសង្កេតកម្មនោះ គប្បីជ្រាបការត្រូវកំណត់ និងការខុសកំណត់ សូម្បីដោយអំណាចនៃវេលាមានបុរិមយាម មជ្ឈិមយាម បច្ឆិមយាម កាលបក្ខ ជុណ្ហបក្ខ ខែ រដូវ និងឆ្នាំជាដើម ។

សួរថា កាលភិក្ខុអ្នកប្រើបង្គាប់ថា "ចូរលួចក្នុងវេលាមុនអាហារ" ភិក្ខុដែលទទួលបង្គាប់ ព្យាយាមដោយគិតថា "នឹងលួចក្នុងវេលាមុនភត្តនុះឯង" តែវត្ថុនោះ រមែងជាការលោកលួចមកបាន ក្នុងវេលាក្រោយភត្ត ; ក្នុងអវហារប្រការនេះ ជាយ៉ាងណា ?

ឆ្លើយថា ព្រះមហាសុមត្ថេរ ពោលទុកមុនថា នោះជាប្រយោគក្នុងវេលាមុនភត្តពិត; ព្រោះហេតុនោះ ភិក្ខុអ្នកបង្គាប់ជាដើមហេតុ រមែង

មិនផុត ។ ចំណែកព្រះមហាបទុមត្ថេរពោលថា ឈ្មោះថា ខុសការកំណត់ ព្រោះកន្លងហួសកំណត់កាលទៅ; ព្រោះហេតុនោះ ភិក្ខុអ្នកបង្គាប់ជាដើមហេតុ ទើបរួចខ្លួន ។

សង្កេតកម្ម ចប់

## និមិត្តកម្ម

[១២០] ការធ្វើនិមិត្តយ៉ាងណាមួយ ដើម្បីឱ្យកើតការសម្គាល់ដឹង ឈ្មោះថា និមិត្តកម្ម ។ និមិត្តកម្មនោះ ព្រះមានព្រះភាគត្រាស់ទុក ៣ យ៉ាង ដោយន័យជាដើមថា យើងនឹងព្រិចភ្នែកក្តី ។ ក៏ការនិមិត្តសូម្បីយ៉ាងដទៃ មានជាច្រើនប្រការជាដើមថា គ្រវាសដៃ ទះដៃ ផ្ទាត់ម្រាមដៃ ផ្អៀងកចុះ ក្អក និងគ្រហែម គប្បីសង្គ្រោះចូលក្នុងនិមិត្តកម្មនេះ ចំណែកពាក្យដ៏សេសក្នុងនិមិត្តកម្មនេះ មានន័យដូចពោលហើយក្នុងសង្កេតកម្មនោះឯង ។

និមិត្តកម្ម ចប់

## ការបង្គាប់

[១២១] ឥឡូវនេះ ដើម្បីសេចក្តីមិនច្រឡំក្នុងសង្កេតកម្ម និងនិមិត្តកម្មទាំងនេះឯង ទើបព្រះមានព្រះភាគត្រាស់ថា ភិក្ខុំ អាណាបេតិ

: បង្គាប់ភិក្ខុផងគ្នា ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ ច្រើនបទថា សោ តំ មញ្ញមានោ : ភិក្ខុអ្នកទទួលបង្គាប់នោះ សំគាល់ទ្រព្យនោះបានហើយ សេចក្ដីថា ភិក្ខុដែលលួចនោះ ស្គាល់ទ្រព្យដែលភិក្ខុអ្នកបង្គាប់ ប្រាប់ធ្វើនិមិត្តគ្រឿងសម្គាល់ទុកថា ជាទ្រព្យនោះ ទើបលួចទ្រព្យនោះឯង, ជាបារាជិកទាំង ២ រូប ។

ច្រើនបទថា សោ តំ មញ្ញមានោ អញ្ញំ : ភិក្ខុអ្នកទទួលបង្គាប់នោះ សំគាល់ទ្រព្យនោះបានហើយ បានទ្រព្យដទៃមកវិញ សេចក្ដីថា ភិក្ខុដែលលួចនោះស្គាល់ទ្រព្យដែលភិក្ខុអ្នកប្រើបង្គាប់ឱ្យលួចថា ជាទ្រព្យនោះ តែលួចទ្រព្យដទៃដែលគេរក្សាទុកក្នុងទីនោះ, ភិក្ខុអ្នកបង្គាប់ដែលជាដើមហេតុ មិនជាអាបត្តិ ។

ច្រើនបទថា អញ្ញំ មញ្ញមានោ តំ : ត្រឡប់សំគាល់ទ្រព្យដទៃវិញ តែបានទ្រព្យនោះមក សេចក្ដីថា ភិក្ខុអ្នកលួចស្គាល់ទ្រព្យដទៃដែលភិក្ខុអ្នកបង្គាប់ ធ្វើនិមិត្តគ្រឿងសម្គាល់ប្រាប់ទុកយ៉ាងនេះថា ទ្រព្យនេះមានតម្លៃតិច, តែទ្រព្យដទៃ ដែលគេរក្សាទុកក្នុងទីជិតទ្រព្យនោះ ឯង ជាទ្រព្យដែលមានតម្លៃថ្លៃដូច្នេះ ទើបលួចទ្រព្យនោះឯង ជាបារាជិក ទាំង ២ រូប ។

ច្រើនបទថា អញ្ញំ មញ្ញមានោ អញ្ញំ : សំគាល់នូវទ្រព្យដទៃ

បានទ្រព្យដទៃមកវិញ សេចក្ដីថា ភិក្ខុដែលលួចនោះ រមែងស្គាល់ដោយន័យមុនទុំះឯងថា ទ្រព្យយ៉ាងដទៃនេះ ដែលគេរក្សាទុកក្នុងទីជិតទ្រព្យនោះឯង ជាទ្រព្យដែលមានតម្លៃថ្លៃ ដូច្នេះ, បើទ្រព្យដែលលួចមកនោះ ជាទ្រព្យយ៉ាងដទៃនុ៎ះឯង, ជាបារាជិកដល់ភិក្ខុដែលលួចប៉ុណ្ណោះ ។

ក្នុងពាក្យថា **ឥត្ថន្នាមស្ស បាវទ** : **ចូរទៅប្រាប់តភិក្ខុឈ្មោះនេះ** ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

គប្បីឃើញអាចារ្យមួយរូប អន្តេវាសិក ៣ រូប មានឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត និងសង្ឃរក្ខិត ។

បណ្ដាបទទាំងនោះ ប្រើនបទថា **ភិក្ខុ ភិក្ខុំ អាណាបេតិ** : **ភិក្ខុបង្គាប់ភិក្ខុផងគ្នា** សេចក្ដីថា អាចារ្យកំណត់ទ្រព្យយ៉ាងណាមួយ ក្នុងស្ថានទីកន្លែងខ្លះ ហើយបង្គាប់ពុទ្ធរក្ខិត ដើម្បីត្រូវការលួចទ្រព្យនោះ ។

ពីរបទថា **ឥត្ថន្នាមស្ស បាវទ** : **ចូរទៅប្រាប់តភិក្ខុឈ្មោះនេះ** សេចក្ដីថា (អាចារ្យបង្គាប់ថា) ម្នាលពុទ្ធរក្ខិត លោកចូរទៅប្រាប់សេចក្ដីនោះដល់ធម្មរក្ខិត ។

ប្រើនបទថា **ឥត្ថន្នាមោ ឥត្ថន្នាមស្ស បាវទតុ** : **ឱ្យភិក្ខុឈ្មោះនេះឯង ទៅប្រាប់តដល់ភិក្ខុឈ្មោះនេះ** សេចក្ដីថា សូមឱ្យធម្មរក្ខិត ចូរប្រាប់ដល់សង្ឃរក្ខិត ។

ច្រើនបទថា **ឥត្ថន្នាមោ ឥត្ថន្នាមំ ភណ្ឌំ អវហរតុ** : **ភិក្ខុឈ្មោះនេះ ចូរទៅលួចទ្រព្យឈ្មោះនេះមក** មានសេចក្តីថា សង្ឃរក្ខិតដែលធម្មរក្ខិតត្រូវលោក (ពុទ្ធរក្ខិត)បង្គាប់បង្គាប់ហើយថា “ចូរលួចទ្រព្យឈ្មោះនេះ”យ៉ាងនេះ; ពិតមែន បណ្តាពួកយើង សង្ឃរក្ខិតនោះជាមនុស្សមានជាតិក្លាហាន អាចក្នុងកម្មនេះ ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** : **ត្រូវអាបត្តិទុក្កដ** សេចក្តីថា ជាទុក្កដ ដល់អាចារ្យអ្នកបង្គាប់យ៉ាងនេះមុន ។ តែបើពាក្យបង្គាប់នោះ ប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នា ថុល្លច្ច័យដែលលោកពិន័យទុកខាងមុខនុ៎ះឯង រមែងមានក្នុងខណៈបង្គាប់, បើវត្ថុនោះ ត្រូវលួចបានមកពិតប្រាកដ, បារាជិកដែលត្រាស់ទុកខាងមុខថា “ត្រូវអាបត្តិបារាជិកទាំងអស់គ្នា” ដូច្នេះ រមែងមានដល់អាចារ្យនេះ ក្នុងខណៈនោះឯង ព្រោះតម្រាស់ដែលត្រាស់ទុកនោះ, សេចក្តីប្រកបនេះ បណ្ឌិតគប្បីជ្រាបក្នុងទីទាំងពួងដោយប្រការយ៉ាងនេះ ។

ច្រើនបទថា **សោ ឥតរស្ស អារោចេតិ** : **ភិក្ខុអ្នកទទួលបង្គាប់ទី ១ នោះ ទៅប្រាប់ភិក្ខុអ្នកទទួលបង្គាប់ទី ២** សេចក្តីថា ភិក្ខុអ្នកទទួលបង្គាប់ប្រាប់ថា ពុទ្ធរក្ខិត ប្រាប់ធម្មរក្ខិត ហើយធម្មរក្ខិតប្រាប់សង្ឃរក្ខិតថា “អាចារ្យរបស់យើង ពោលយ៉ាងនេះថា បានឮថា លោកចូរលួច

ទ្រព្យឈ្មោះនេះ បានពួចថា បណ្ដាយើងទាំង ២ លោក គឺជាបុរសដ៏ក្លាហាន” ដូច្នេះ, ជាទុក្កដសូម្បីដល់លោកទាំងនោះ ព្រោះមានការប្រាប់ចំពោះគ្នាទៅ ដោយអាការយ៉ាងនោះជាបច្ច័យ ។

ពីរបទថា អវហារកោ បដិគ្គណ្ហាតិ : ភិក្ខុអ្នកទទួលបង្គាប់ទី៣ព្រមទទួលនឹងទៅលួច សេចក្ដីថា សង្ឃរក្ខិតទទួលថា “ល្អណាស់ ខ្ញុំព្រះករុណានឹងលួច” ។

ច្រើនបទថា មូលដ្ឋស្ស អាបត្តិ ថុល្លច្ចយស្ស : ភិក្ខុអ្នកបង្គាប់ដំបូង ត្រូវអាបត្តិថុល្លច្ច័យ សេចក្ដីថា លុះព្រះសង្ឃរក្ខិតទទួលពាក្យបង្គាប់ ជាថុល្លច្ច័យ ដល់អាចារ្យ, ព្រោះបុគ្គលច្រើនរូបត្រូវអាចារ្យនោះបបួលហើយ ក្នុងបាបនោះឯង ។

ច្រើនបទថា សោ តំ ភណ្ឌំ : ភិក្ខុអ្នកទទួលបង្គាប់ទី៣ បានទ្រព្យនោះមក សេចក្ដីថា បើភិក្ខុនោះ គឺ ព្រះសង្ឃរក្ខិតលួចវត្ថុនោះមកបានសោត, ជាបារាជិកទាំងអស់ គឺ ទាំង ៤ នាក់, និងមិនជាបារាជិកដល់ ៤ នាក់ តែម្យ៉ាងទេ, សមណរាប់រយ ឬសមណៈរាប់ពាន់ក៏ដោយដែលបង្គាប់ដោយបន្តគ្នាទៅ មិនធ្វើឱ្យខុសកំណត់ ដោយឧបាយយ៉ាងនេះក៏ជាបារាជិកជាមួយគ្នាទាំងអស់តែម្ដង ។

ក្នុងទុតិយវារ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ប្រើនបទថា សោ អញ្ញំ អាណាបេតិ : ភិក្ខុអ្នកទទួលបង្គាប់ទី ១ នោះ ទៅប្រើភិក្ខុដទៃ ក្នុងខណៈប្រើត សេចក្តីថា ភិក្ខុនោះ គឺព្រះពុទ្ធរក្ខិត ដែលអាចារ្យបង្គាប់ទុកហើយ តែមិនជួបព្រះធម្មរក្ខិត ឬជាអ្នកមិនចង់នឹងប្រាប់ ទើបចូលទៅរកព្រះសង្ឃរក្ខិតតែម្តង ហើយបង្គាប់ថា "អាចារ្យរបស់ពួកយើងបង្គាប់ទុកយ៉ាងនេះថា បានឮថា លោកចូរលួចវត្ថុឈ្មោះនេះមក" ។

ពីរបទថា អាបត្តិ ទុក្កដស្ស : ខ្លួនអ្នកទទួលប្រើទី១នោះត្រូវអាបត្តិទុក្កដ សេចក្តីថា ព្រះពុទ្ធរក្ខិត ឈ្មោះថា ជាទុក្កដ ព្រោះបង្គាប់មុន ។

ប្រើនបទថា បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស : អ្នកទទួលបង្គាប់ទី ៣ នោះ ត្រូវអាបត្តិទុក្កដ ក្នុងខណៈទទួល សេចក្តីថា គប្បីជ្រាបថា ជាទុក្កដ ដល់ភិក្ខុអ្នកបង្គាប់ខាងដើមប៉ុណ្ណោះ ក្នុងកាលសង្ឃរក្ខិតទទួលហើយ ។ ក៏បើសង្ឃរក្ខិតនោះ លួចទ្រព្យនោះមកបាន, ជាបារាជិក សូម្បីទាំងពីររូប គឺ ពុទ្ធរក្ខិតអ្នកបង្គាប់ ១ សង្ឃរក្ខិតអ្នកលួច ១ ។ តែសម្រាប់អាចារ្យអ្នកបង្គាប់ខាងដើម មិនជាបារាជិក ព្រោះខុសសង្កេត, មិនជាអាបត្តិគ្រប់យ៉ាងដល់ធម្មរក្ខិត ព្រោះមិនដឹង ។ ចំណែកពុទ្ធរក្ខិតធ្វើសេចក្តីសួស្តីដល់លោកទាំងពីររូបហើយ ខ្លួនឯង

វិនាស ។

បណ្ដាអាណត្តិវារ ទាំង ៤ បទ បន្ទាប់ពីទុតិយវារនេះទៅ គប្បីជ្រាបវិនិច្ឆ័យក្នុងអាណត្តិវារប្រការដំបូងមុន ។

ប្រើនបទថា **សោ តន្តា បុន បច្ចាគច្ឆតិ : ភិក្ខុអ្នកទទួលបង្គាប់នោះទៅ ហើយត្រឡប់មកវិញ** សេចក្ដីថា ភិក្ខុអ្នកទទួលបង្គាប់នោះ ទៅកាន់កន្លែងទ្រព្យតាំងនៅហើយ ឃើញមានការរក្សាទុក ទាំងខាងក្នុងនិងខាងក្រៅមិនអាចលួចយកបាន ទើបត្រឡប់មក ។

ប្រើនបទថា **យទា សក្កោសិ តទា : លោកអាចលួចយកបានក្នុងពេលណា ក្នុងពេលនោះចុះ** សេចក្ដីថា ភិក្ខុអ្នកបង្គាប់នោះ បង្គាប់ថាថា ទ្រព្យដែលលោកលួចមកហើយក្នុងថ្ងៃនេះប៉ុណ្ណោះឬ ទើបជាការលួច, ទៅចុះលោក លោកអាចនឹងលួចមកបាន កាលណា, ក៏ចូរលួចទ្រព្យនោះមក កាលនោះ ។

ពីរបទថា **អាបត្តិ ទុក្កដស្ស : ភិក្ខុអ្នកបង្គាប់នោះ ត្រូវអាបត្តិទុក្កដ** សេចក្ដីថា សូម្បីព្រោះបង្គាប់ទៀតយ៉ាងនោះ ក៏ជាទុក្កដប៉ុណ្ណោះ ។ តែបើទ្រព្យនោះ រមែងជារបស់ដែលនឹងលួចមកបានពិតប្រាកដ, ឈ្មោះថា ចេតនាដែលឱ្យសម្រេចប្រយោជន៍ ក៏ប្រាកដដូចជាផលដែលកើតក្នុងលំដាប់នៃមគ្គ; ព្រោះដូច្នោះ ភិក្ខុអ្នកបង្គាប់នេះ ទើប

ជាបារាជិកក្នុងខណៈបង្គាប់តែម្តង ។ សូម្បីបើភិក្ខុដែលលួច នឹងលួចទ្រព្យនោះមកបាន ដោយកន្លងទៅ ៦០ ឆ្នាំ និងភិក្ខុដែលបង្គាប់ ទោះជាធ្វើកាលកិរិយា ឬសឹកចេញទៅក្នុងរវាងនុ៎ះឯង ក៏ជាបុគ្គលមិនមែនសមណៈឡើយ ធ្វើកាលកិរិយា ឬនឹងសឹកទៅ, តែសម្រាប់ភិក្ខុដែលលួច រមែងជាបារាជិកក្នុងខណៈដែលលួចនុ៎ះឯង ។

ក្នុងទុតិយវារ ព្រោះភិក្ខុអ្នកបង្គាប់ខាងដើម និយាយពាក្យតិច ៗ មិនបានប្រកាសឱ្យបានឮ ឬមិនបានប្រកាសឱ្យបានឮពាក្យបង្គាប់នេះថា "លោកកុំលួច" ព្រោះភិក្ខុអ្នកលួចនោះ ជាមនុស្សត្រចៀកថ្លង់; ដូច្នោះភិក្ខុអ្នកបង្គាប់ខាងដើម ទើបមិនផុត ។

ចំណែកក្នុងតតិយវារឈ្មោះថា ផុត ព្រោះលោកប្រកាសឱ្យបានឮ ។

ក្នុងចតុត្ថវារសូម្បីទាំងពីររូបផុតបាន ព្រោះភិក្ខុអ្នកបង្គាប់ខាងដើមនោះ និយាយឱ្យបានឮ និងព្រោះភិក្ខុអ្នកទទួលបង្គាប់ក្រៅនេះ ទទួលពាក្យថា "ល្អណាស់" ហើយក៏លះបង់ចោល ដោយប្រការដូច្នេះ ។

ការបង្គាប់ ចប់

## ពណ្ណនាបទភាជនីយ៍

[១២២] ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងអង្គនៃ

អទិន្នាទានដែលត្រាស់ទុក ដោយអំណាចនៃកិរិយាដែលឱ្យឃ្លាតចាកឋាន ក្នុងទ្រព្យដែលឋិតនៅក្នុងផែនដីជាដើមនោះ ៗ និងសេចក្តីផ្សេងនៃអាបត្តិ នឹងសេចក្តីផ្សេងគ្នានៃវត្ថុ ទើបត្រាស់ពាក្យជាដើមថា បញ្ចហាការេហិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា បញ្ចហាការេហិ : **ដោយអាការ ៥** បានដល់ ដោយហេតុ ៥ យ៉ាងមានពាក្យអធិប្បាយថា ដោយអង្គ ៥ ។ ក្នុងពាក្យថា បញ្ចហាការេហិ ជាដើមនោះ មានសេចក្តីសង្ខេប ដូចតទៅនេះ ៖

គឺ បារាជិក រមែងមានដល់ភិក្ខុដែលកាន់យកទ្រព្យដែលម្ចាស់របស់មិនបានឱ្យ ដោយអាការ ៥ យ៉ាងដែលត្រាស់ទុកដោយន័យជាដើមថា ទ្រព្យដែលអ្នកដទៃហួងហែង ១; ព្រោះមិនគ្រប់អង្គ ៥ នោះ ទើបមិនជាបារាជិក ។ ក្នុងពាក្យនោះ មាន អាការ ៥ យ៉ាងទាំងនេះ គឺ ទ្រព្យដែលអ្នកដទៃហួងហែង ១ ដឹងថា ទ្រព្យដែលអ្នក ដទៃហួងហែង ១ បរិក្ខារជាគរុភណ្ឌ ១ មានថេយ្យចិត្ត ១ ការធ្វើឱ្យឃ្លាតចាកឋាន ១ ។ ចំណែកក្នុងបរិក្ខារ ដែលជាលហុភណ្ឌ លោកសម្តែងថុល្លច្ច័យ និងទុក្កដទុក ដោយសេចក្តីផ្សេងគ្នានៃវត្ថុ ដោយវារៈទាំង ២ ដទៃពី អាការ ៥ យ៉ាងនេះ ។

## អាការ ៦ យ៉ាងដែលឱ្យភិក្ខុត្រូវអាបត្តិបារាជិក

[១២៣] សូម្បីក្នុងវារៈទាំង ៣ ដែលលោកត្រាស់ទុក ដោយន័យជាដើមថា ឆហាការេហិ ក៏គួរជ្រាបអាការ ៦ យ៉ាងនេះ គឺ មិនមានការសម្គាល់ថា ជារបស់ខ្លួន ១ មិនមែនកាន់យកដោយវិស្សាសៈ ១ មិនមែនកាន់យកដោយការខ្ចី ១ បរិក្ខារជាគរុភណ្ឌ ១ មានថេយ្យចិត្ត ១ ការធ្វើឱ្យឃ្លាតចាកឋាន ១ ។ ក៏បណ្ដាវារៈទាំង ៣ នេះ ក្នុងបឋមវារៈ លោកពិន័យជាបារាជិក, ទុតិយវារៈ និងតតិយវារៈលោកពិន័យជាថុល្លច្ច័យ និងទុក្កដ ដោយសេចក្ដីផ្សេងគ្នានៃវត្ថុ ។ ចំណែកក្នុងសេចក្ដីផ្សេងគ្នានៃវត្ថុ សូម្បីដែលមាននៅក្នុងវារៈទាំង ៣ ជទៃក្រៅពី ៣ វារៈនោះ លោកពិន័យជាទុក្កដតែម្យ៉ាង ព្រោះជាវត្ថុដែលជនពួកដទៃមិនបានហួងហែង ។ វត្ថុដែលលោកពោលក្នុង៣ វារៈនោះថា មិនមែនរបស់ដែលអ្នកដទៃហួងហែង ទោះជាវត្ថុដែលមិនមានអ្នកណាគ្រប់គ្រងក៏ដោយ ទោះជារបស់ដែលគេចោលហើយអស់តម្លៃមិនមានម្ចាស់ក៏ដោយ ឬទោះជារបស់នៃខ្លួនក៏ដោយ, វត្ថុសូម្បីទាំង ២ រមែងដល់ការរាប់ថា មិនមែនទ្រព្យដែលអ្នកដទៃហួងហែងទុក ១ កាន់យកដោយថេយ្យចិត្ត ១; ព្រោះហេតុនោះ ទើបលោកមិនពោលអនាបត្តិទុក ដូច្នេះឯង ។

## អត្ថាធិប្បាយក្នុងអនាបត្តិវារៈ

[១២៥] ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងសេចក្តីផ្សេងនៃអាបត្តិ ដោយអំណាចនៃវត្ថុនិងដោយអំណាចនៃចិត្ត យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងអនាបត្តិទើបត្រាស់ពាក្យថា អណាបត្តិ សកសញ្ញិស្ស : ភិក្ខុកាន់យកដោយសំគាល់ថា ជារបស់ខ្លួន មិនត្រូវអាបត្តិឡើយ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា សកសញ្ញិស្ស : ភិក្ខុកាន់យកដោយសំគាល់ថា ជារបស់ខ្លួន បានដល់ ភិក្ខុដែលមានសេចក្តីសម្គាល់ថា ជារបស់ខ្លួន គឺ អ្នកមានសេចក្តីសម្គាល់យ៉ាងនេះថា ភណ្ឌៈនេះជារបស់យើង កាលកាន់យកសូម្បីនូវភណ្ឌៈរបស់អ្នកដទៃ មិនជាអាបត្តិ ព្រោះការកាន់យក, បើត្រូវពួកម្ចាស់របស់ទាមទារថា ចូរឱ្យ គួរឱ្យទ្រព្យដែលខ្លួនកាន់យកហើយនោះត្រឡប់ទៅម្ចាស់គេវិញ ។ លោកមិនព្រមសង ជាបារាជិក ក្នុងកាលម្ចាស់ទ្រព្យទាំងនោះដាក់ធុរៈ ។

បទថា វិស្សាសគ្គាហេ : ភិក្ខុកាន់យកដោយស្និទ្ធស្នាលនឹងគ្នា បានដល់ ជាអនាបត្តិ ព្រោះការកាន់យកដោយវិសាសៈ ។ តែគួរដឹងលក្ខណៈនៃការកាន់យកដោយសេចក្តីស្និទ្ធស្នាលដោយសូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុកាន់យកដោយសេចក្តីស្និទ្ធស្នាល របស់មិត្រប្រកបដោយអង្គ ៥ គឺ មិត្រដែលគ្រាន់តែបានឃើញគ្នាម្តងម្កាល

១ មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន ១ មិត្រដែលបាននិយាយបើកឱកាសគ្នាតាមត្រូវការ ១ មិត្រនោះមានជីវិតរស់នៅ ១ ភិក្ខុដឹងថា បើអាត្មាអញកាន់យកវត្ថុណាមួយហើយ មិត្រនោះមានសេចក្តីត្រេកអរ ១”[១] ។

---

១. វិន. មហា. ៨. ៦៥/១៤២ ។

បណ្តាបទទាំងនោះ បទថា **សន្ទិដ្ឋោ** : **មិត្រដែលគ្រាន់តែបានឃើញគ្នាមួងម្កាល** បានដល់ មិត្រត្រឹមតែធ្លាប់ឃើញគ្នា ។

បទថា **សម្ភត្តោ** : **មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន** បានដល់ មិត្រជិតជិតស្និទ្ធស្នាល ។

បទថា **អាលបិតោ** : **មិត្រដែលបាននិយាយបើកឱកាសគ្នាតាមត្រូវការ** បានដល់ មិត្រដែលបើកឱកាសទុកថា “លោកត្រូវការវត្ថុណាដែលជារបស់ខ្ញុំព្រះករុណា លោកគប្បីកាន់យកវត្ថុនោះចុះ”, មិនមានហេតុក្នុងការដែលលោកនឹងសូមអនុញ្ញាតមុនទើបកាន់យក ។

មិត្រសូម្បីដេកហើយ ដោយការដេកមិនក្រោកឡើង មិនទាន់ដល់សេចក្តីដាច់សូន្យនៃជីវិតិន្ទ្រិយត្រឹមណា ឈ្មោះថា **នៅមានជីវិតរស់នៅត្រឹមនោះ** ។

ច្រើនបទថា **គហិតេ ច អត្តមនោ** : **ភិក្ខុដឹងថា បើអាត្មាអញកាន់យកវត្ថុណាមួយហើយ មិត្រនោះមានសេចក្តីត្រេកអរ** សេចក្តី

ថា កាលយើងកាន់យកហើយ គេនឹងពេញចិត្ត ។ កាលដែលភិក្ខុដឹងថា បើយើងកាន់យកវត្ថុអ្នកដទៃបែបនេះហើយគេនឹងពេញចិត្ត ទើបកាន់យករមែងសមគួរ ។ ក៏ព្រះមានព្រះភាគ ត្រាស់អង្គទាំង ៥ នេះទុក ដោយអំណាចនៃការប្រមូលទុកមិនឱ្យមានសេសសល់ ។ តែការកាន់យកដោយវិសាសៈ រមែងឡើងដោយអង្គ ៣ យ៉ាង គឺ "មិត្រដែលគ្រាន់តែបានឃើញគ្នាម្ដងម្កាល, មិត្រនោះនៅមានជីវិតរស់នៅ, ភិក្ខុដឹងថា បើអាត្មាអញកាន់យកវត្ថុណាមួយហើយ មិត្រនោះមានសេចក្ដីត្រេកអរ, ១" "មិត្រដែលស្និទ្ធស្នាលនឹងគ្នាមាំមួន, មិត្រនោះនៅមានជីវិតរស់នៅ, ភិក្ខុដឹងថា បើអាត្មាអញកាន់យកវត្ថុណាមួយហើយ មិត្រនោះមានសេចក្ដីត្រេកអរ ១" "មិត្រដែលបាននិយាយបើកឱកាសគ្នាតាមត្រូវការ, មិត្រនោះនៅមានជីវិតរស់នៅ, ភិក្ខុដឹងថា បើអាត្មាអញកាន់យកវត្ថុណាមួយហើយ មិត្រនោះមានសេចក្ដីត្រេកអរ ១" ។ ចំណែកមិត្រណា នៅមានជីវិត តែកាលកាន់យកហើយគេមិនពេញចិត្ត, វត្ថុរបស់ មិត្រនោះសូម្បីភិក្ខុកាន់យកហើយដោយវិស្សាសៈ ក៏គួរឱ្យដល់ម្ចាស់របស់ដើមវិញ, កាលនឹងសងទ្រព្យរបស់អ្នកស្លាប់ គួរសងដល់ពួកគ្រហស្ថ ឬបព្វជិតអ្នកជាធំក្នុងទ្រព្យរបស់មិត្រនោះមុន, ទ្រព្យរបស់មិត្រមិនជាទីពេញចិត្ត ក៏គួរសងទៅអ្នកនោះឯង ។

ចំណែកភិក្ខុណា អនុមោទនាត្រេកអរតាំងពីដំបូងនោះឯង ដោយការបញ្ចេញវាចាថា លោកកាលកាន់យករបស់ខ្ញុំព្រះករុណាឈ្មោះថា ធ្វើប្រពៃហើយ ឬត្រឹមតែចិត្តប្បាទប៉ុណ្ណោះ ខាងក្រោយក្រោធដោយហេតុយ៉ាងណាមួយ, ភិក្ខុនោះ រមែងមិនបានដើម្បីនឹងឱ្យនាំមកសងវិញទេ ។ សូម្បីលោករូបណាមិនប្រាថ្នានឹងឱ្យ តែទទួលពាក្យទុកដោយចិត្ត មិននិយាយអ្វី ៗ សូម្បីលោករូបនោះ ក៏រមែងមិនបានដើម្បីនឹងឱ្យនាំមកសងវិញដែរ ។ ចំណែកភិក្ខុណា កាលមិត្រភិក្ខុនិយាយថា "វត្ថុ ដែលជារបស់លោក ខ្ញុំព្រះករុណាកាន់យកហើយ ឬខ្ញុំព្រះករុណាប្រើប្រាស់ហើយ" ទើបនិយាយថា "វត្ថុនោះ លោកនឹងកាន់យកឬប្រើប្រាស់ហើយក៏ដោយ, ប៉ុន្តែថា វត្ថុនោះ ខ្ញុំព្រះករុណារក្សាទុកដោយករណីយ៉ាងណាមួយពិត ៗ លោកគួរធ្វើវត្ថុនោះឱ្យជាប្រក្រតីដូចដើម" ដូច្នេះ ភិក្ខុនេះ រមែងបានដើម្បីឱ្យនាំមកសងវិញ ។

បទថា **តាវកាលិកេ : កាន់យកជារបស់ខ្ចី** សេចក្តីថា សម្រាប់ភិក្ខុ ដែលកាន់យកដោយគិតយ៉ាងនេះថា យើងនឹងឱ្យវិញ នឹងធ្វើសងវិញ មិនជាអាបត្តិ ព្រោះការកាន់យកសូម្បីជារបស់ខ្ចី ។ តែវត្ថុដែលភិក្ខុកាន់យកហើយ បើបុគ្គល ឬគណៈដែលជាម្ចាស់របស់វត្ថុអនុញ្ញាតឱ្យថា "វត្ថុនោះចូរជារបស់លោកចុះ" ប្រការនេះជាការល្អ បើ

មិនអនុញ្ញាតសោត ។ កាលគេឱ្យនាំមកសង គួរ សងគេវិញ ។ ចំណែករបស់សង្ឃ គួរឱ្យវិញពិត ។

ក៏បុគ្គលដែលកើតក្នុងបេតវិស័យក្តី ដែលធ្វើកាលកិរិយាហើយកើតជាប្រេតក្នុងអត្តភាពនោះឯងក្តី ទេវតាទាំងឡាយ មានទេវតាជាន់ចាតុម្មហារាជិកាជាដើមក្តី, ទាំងអស់ដល់ការរាប់ថា ប្រេតដូចគ្នា ក្នុងពាក្យថា **បេតបរិគ្គហេ** : **កាន់យករបស់ដែលពួកប្រេតហួងហែងរក្សា** នេះ មិនជាអាបត្តិក្នុងទ្រព្យដែលប្រេតទាំងនោះហួងហែង ។ ពិតមែន បើស្តេចសក្កទេវរាជគង់ប្រថាប់ក្បែររានលក់ដូរក្នុងផ្សារ, និងភិក្ខុដែលបានទិព្វចក្ខុដឹងថា ជាស្តេចសក្កៈ សូម្បីកាលស្តេចសក្កៈនោះស្រែកហាមថា កុំកាន់យក ៗ ក៏កាន់យកសំពត់សាដកសូម្បីមានតម្លៃរាប់សែន ដើម្បីប្រយោជន៍ដល់ចីវររបស់ខ្លួនទៅ, ការកាន់យកនោះ រមែងគួរ ។ ចំណែកក្នុងសំពត់សាដកដែលពួកជនអ្នកធ្វើពលីកម្មឧទ្ទិសដល់ពួកទេវតាពាក់ទុកត្រង់ដើមឈើជាដើម មិនមានពាក្យដែលគួរនឹងពោលឡើយ ។

បទថា **តិរច្ឆានគតបរិគ្គហេ** : **កាន់យករបស់ដែលពួកតិរច្ឆានហួងហែងរក្សា** បានដល់ មិនជាអាបត្តិ ព្រោះទ្រព្យសូម្បីពួកសត្វតិរច្ឆានហួងហែង ។ ពិតមែន សូម្បីពួកស្តេចនាគ ឬសុបណ្ណមាណពប្លែងរូបជាមនុស្ស បើកហាងលក់ទំនិញក្នុងផ្សារ ។ និងមានភិក្ខុខ្លះ មក

កាន់យកវត្ថុរបស់ស្តេចនាគ ឬរបស់សុបណ្ណមាណពនោះ អំពីរានផ្សារនោះទៅ ដោយន័យមុនទុំះឯង, ការកាន់យកនោះ រមែងគួរ ។ រាជសីហ៍ ឬ ខ្លាធំសម្លាប់សត្វមានម្រឹគនិងក្របីជាដើមហើយ តែមិនទាន់ទាំស៊ី ត្រូវសេចក្តីឃ្លានបៀតបៀន មិនគប្បីហាមឃាត់វាក្នុងផ្នែកដើមឡើយ, ព្រោះថា វានឹងគប្បីធ្វើសូម្បីសេចក្តីវិនាសឱ្យ ។ តែបើកាលរាជសីហ៍ជាដើមស៊ីសាច់បានបន្តិចហើយ ភិក្ខុក៏អាចហាមបាន និងហាមហើយកាន់យក ក៏គួរ ។ សូម្បីបក្សីមានស្ទាំងជាដើមពាំយកចំណីហើយហើរទៅ នឹងធ្វើឱ្យវាទម្លាក់ចំណីចោលទៅ ហើយកាន់យក ក៏គួរ ។

បទថា **បំសុកូលសញ្ញិស្ស** : **កាន់យកដោយសំគាល់ថា ជារបស់បង្សុកូល** សេចក្តីថា សូម្បីសម្រាប់ភិក្ខុដែលមានសេចក្តីសម្គាល់យ៉ាងនេះថា វត្ថុនេះ មិនមានម្ចាស់ ជារបស់បង្សុកូល មិនជាអាបត្តិព្រោះការកាន់យក ។ តែបើវត្ថុនោះមានម្ចាស់សោត, កាលគេឱ្យនាំមកវិញ ក៏គួរសងគេវិញ ។

បទថា **ឧម្មត្តកស្ស** : **ភិក្ខុឆ្កួត** សេចក្តីថា មិនជាអាបត្តិសូម្បីដល់ភិក្ខុឆ្កួតដែលមានប្រការដូចពោលហើយក្នុងខាងដើម ។

បទថា **អាទិកម្មិកស្ស** : **ភិក្ខុដើមបញ្ញត្តិ** សេចក្តីថា មិនជាអាបត្តិដល់ព្រះធនិយៈដែលជាអាទិកម្មិកៈ (ភិក្ខុជាដើមបញ្ញត្តិ) ក្នុង

សិក្ខាបទនេះ ។ តែសម្រាប់ភិក្ខុឆព្វគ្គិយជាដើម អ្នកជាចោរលួចកញ្ចប់សំពត់របស់ជាងជ្រលក់ជាដើមដ៏សេស ជាអាបត្តិតែម្តងដូច្នេះឯង ។

ចប់ការពណ៌នាបទភាជនី

## បកិណ្ណកៈ មានសមុដ្ឋានជាដើម

ក៏ក្នុងបកិណ្ណកៈនេះ គឺសមុដ្ឋាន ១ កិរិយា ១ សញ្ញា ១ សចិត្តកៈ ១ លោកវជ្ជៈ ១ កម្ម ១ កុសល ១ ព្រមដោយវេទនា ១ ។

បណ្ឌិតគប្បីជ្រាបពាក្យទាំងអស់ ដោយន័យដូចបានពោលទុកហើយក្នុងបឋមសិក្ខាបទនុ៎ះឯងថា សិក្ខាបទនេះ មានសមុដ្ឋាន ៣ គឺ ជាសាហត្ថិកៈ កើតមកកាយនិងមកចិត្ត, ជាអាណត្តិកៈ កើតមកវាចានិងមកចិត្ត, ជាសាហត្ថិកៈ និងអាណត្តិកៈកើតមកកាយ មកវាចានិងមកចិត្ត; និងកើតព្រោះធ្វើ; ពិតមែន កាលធ្វើប៉ុណ្ណោះ ទើបត្រូវអាបត្តិនោះ; កាលមិនធ្វើក៏មិនត្រូវ ជាសញ្ញាវិមោក្ខ ព្រោះផុតដោយមិនមានសម្គាល់ថាយើងនឹងកាន់យកវត្ថុដែលម្ចាស់គេមិនបានឱ្យ, ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម ជាវចីកម្ម ជាអកុសលចិត្ត, ភិក្ខុត្រេកអរ ឬខ្លាច ឬតាំងចិត្ត

ជាកណ្តាល ទើបត្រូវអាបត្តិនោះ; ព្រោះហេតុនោះ សិក្ខាបទនេះ ទើបឈ្មោះថា មានវេទនា ៣ ។

## អត្ថាធិប្បាយឧទានគាថា ក្នុងវិនីតវត្ថុ

ក្នុងគាថា នៃវិនីតវត្ថុ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១២៧] រឿងភិក្ខុឆព្វគ្គិយ ខ្ញុំព្រះករុណាបានពោលទុកហើយក្នុងអនុប្បញ្ញត្តិទុំះឯង ។

[១២៨] ក្នុងរឿងគិតចង់លួចសំពត់មានតម្លៃច្រើន ទី ២ មានវិនិច្ឆ័យដូច្នេះ ៖

ដែលឈ្មោះថា ចិត្តរបស់ពួកបុថុជ្ជន លះប្រក្រតីទៅដោយអំណាចកិលេសមានរាគៈជាដើម រមែងស្ទុះទៅ គឺ ឆ្លេឆ្លាទៅ បានដល់ស្ទុះស្ទាទៅ ។ បើព្រះមានព្រះភាគសូម្បីវៀរសេចក្តីទម្លាយមកកាយទ្វារនិងវចីទ្វារចេញ ទឹងគប្បីទ្រង់បញ្ញត្តិអាបត្តិដោយហេតុត្រឹមតែចិត្តុប្បាទ (ត្រឹមតែកើតសេចក្តីគិត) អ្នកណាទឹងគប្បីអាចធ្វើខ្លួនមិនឱ្យជាអាបត្តិបានហ្ន៎ ? ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកថា "ម្នាល

ភិក្ខុ បើត្រឹមតែចិត្តកើតឡើងប៉ុណ្ណោះ អ្នកមិនត្រូវអាបត្តិឡើយ” ។ តែភិក្ខុក៏មិនគួរប្រព្រឹត្តទៅក្នុងអំណាចនៃចិត្ត, គួរហាមចិត្តទុកដោយកម្លាំងនៃការពិចារណា ។ រឿងការចាប់ពាល់សំពត់ ធ្វើឱ្យសំពត់ញ័រ និងធ្វើឱ្យសំពត់ឃ្លាតចាកឋាន មានសេចក្ដីងាយយល់ហើយទាំងអស់នោះឯង ។

[១២៩-១៣១] ចំណែករឿងទាំងឡាយ ១៤ គឺ រឿងភិក្ខុ ៤ រូបលួចគ្រឿងកម្រាល រឿងភិក្ខុ ៥ រូបលួចទ្រព្យក្នុងវេលាយប់ និងរឿងភិក្ខុ ៥ រូបលួចទ្រព្យគេ ដែលខ្លួនកំពុងជួយនាំទៅ ដែលបន្ទាប់ពីរឿងដែលធ្វើសំពត់ឱ្យឃ្លាតចាកឋាននោះទៅ មានរឿងថា ភិក្ខុមានថេយ្យចិត្តចាប់យកទ្រព្យនោះឡើងចាកផែនដី ជាទីបំផុត មានសេចក្ដីងាយយល់ហើយទាំងអស់នោះឯង ។

[១៣២] ក្នុងរឿងភិក្ខុត្រឹមតែថាដោយពាក្យ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **អាធិយិ : ចោទប្រកាន់** សេចក្ដីថា ភិក្ខុម្ចាស់ចីវរ ចាប់ហើយ គឺ ចោទប្រកាន់ថា “លោកជាចោរ” ។ ចំណែកភិក្ខុដែលលួចចីវរក្រៅនេះ កាលត្រូវភិក្ខុម្ចាស់ចីវរ សួរថា “ចីវររបស់ខ្ញុំព្រះករុណា លោកនាលួចទៅ ?” ទើបបានឱ្យពាក្យបដិញ្ញា ដោយស្មើនឹងពាក្យសួរថា

"ខ្ញុំព្រះករុណាលួចទៅ" ។

ពិតមែន បើភិក្ខុម្ចាស់ចីវរក្រៅនេះនឹងពោលថា ចីវររបស់ខ្ញុំព្រះករុណា អ្នកណាកាន់យក អ្នកណានាំទៅ អ្នកណារក្សាទុក ?, សូម្បីភិក្ខុនេះ ក៏នឹងគប្បីឆ្លើយថា ខ្ញុំព្រះករុណាកាន់យក ឬថា ខ្ញុំព្រះករុណានាំទៅ ឬថា ខ្ញុំព្រះករុណារក្សាទុក ពិតប្រាកដ ។ ដែលឈ្មោះថា មាត់ ជាធម្មតា ដើម្បីប្រយោជន៍ដល់ការបរិភោគ និងដើម្បីប្រយោជន៍ដល់ការនិយាយ តែវៀរថេយ្យចិត្តចេញ ក៏មិនជាអវហារ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកថា "ម្នាលភិក្ខុ បើត្រឹមតែថាដោយពាក្យ អ្នកមិនត្រូវអាបត្តិអ្វីឡើយ" ដូច្នេះ ។ អធិប្បាយថា មិនជាអាបត្តិ ព្រោះត្រឹមតែពោលដោយវាចា ។

[១៣៣] រឿងភិក្ខុរើសសំពត់សាដកដែលបើុងទៅដោយខ្យល់ ដែលបន្ទាប់ពីរឿងត្រឹមតែថាដោយពាក្យនោះទៅ ដែលមានរឿងភិក្ខុរើសសំពត់ជូតក្បាលជាទីបំផុត មានសេចក្តីងាយយល់ហើយទាំងអស់នោះឯង ។

[១៣៤] ក្នុងរឿងសាកសពដែលនៅស្រស់ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **អធិវត្ថោ : មកអាស្រ័យនៅ** សេចក្តីថា ប្រេតកើតឡើងក្នុងសាកសពនោះឯង ព្រោះសេចក្តីចំណង់ក្នុងសំពត់សាដក ។

បទថា **អាណាធិយន្តោ : មិនអើពើ** សេចក្តីថា ភិក្ខុមិនកាន់យកពាក្យរបស់ប្រេតនោះ ឬមិនធ្វើសេចក្តីអើពើ ។

ប្រើនបទថា **តំ សរីរំ ឧដ្ឋហិត្វា : សរីរៈនោះក្រោកឡើង** សេចក្តីថា ប្រេតញ៉ាំងសរីរៈសាកសពនោះឱ្យក្រោកឡើង ដោយអានុភាពរបស់ខ្លួន, ព្រោះហេតុនោះ ទើបព្រះឧបាលីថេរៈពោលពាក្យថា "សរីរៈនោះក្រោកឡើង (ហើយដេញជាប់តាមក្រោយខ្នងភិក្ខុនោះ)" ។

ពីរបទថា **ទ្វារំ ថកេសិ : ហើយបិទទ្វារ** សេចក្តីថា វិហាររបស់ភិក្ខុមាននៅក្នុងទីជិតព្រៃជាទីចោលសាកសពនោះឯង ព្រោះហេតុនោះ ភិក្ខុជាអ្នកខ្លាចដោយប្រក្រតី ទើបប្រញាប់ចូលទៅក្នុងវិហារនោះឯងហើយបិទទ្វារ ។

ពីរបទថា **តត្ថេវ បរិបតិ : ក៏ដួលខ្ពោកក្នុងទីនោះឯង** សេចក្តីថា កាលភិក្ខុបិទទ្វារហើយ ប្រេតជាអ្នកអស់សេចក្តីអាល័យក្នុងសំពត់សាដក ទើបលះចោលសាកសពនោះ ហើយទៅតាមយថាកម្ម ។ ព្រោះហេតុនោះ រាងកាយសពនោះក៏ដួលចុះ ។ មានពាក្យអធិប្បាយថា ធ្លាក់ទៅក្នុងទីនោះឯង ។

ពីរបទថា **អភិន្នេ សរីរេ : អំពីសរីរៈខ្មោចដែលមិនទាន់បែកធ្លាយ** សេចក្តីថា សំពត់បង្សុកូលដែលសាកសពស្រស់នៅមានកំដៅ

ភិក្ខុមិនគួរកាន់យក ។ កាលភិក្ខុកាន់យក ឧបទ្រវៈបែបនេះរមែងមាន និងភិក្ខុរមែងត្រូវអាបត្តិទុក្កដ តែនឹងកាន់យកសំពត់ត្រង់សាកសពដែលបែកធ្លុះធ្លាយហើយ គួរ ។

សួរថា ក៏សាកសពនឹងចាត់ថា បែកធ្លុះធ្លាយហើយ ដោយហេតុត្រឹមណា ?

ឆ្លើយថា ដោយហេតុត្រឹមតែត្រូវចុងចំពុះ ឬចង្កូម ដែលសត្វទាំងឡាយ មាន ក្អែក ត្មាត សុនខ និងចចកជាដើមយកចង្កូមឬធ្មេញធ្វើឱ្យរហែកដាច់ហើយបន្តិចបន្តួច ។ ចំណែកអវយវៈរបស់សពដែលដួលចុះ ត្រឹមតែសម្បុរស្បែកដាច់ទៅដោយការកូតកកិត, ស្បែកមិនទាន់ដាច់, សាកសពនោះ រាប់ថា នៅស្រស់តែម្តង, តែកាលស្បែកដាច់ហើយចាត់ថា ជាសពដែលបែកហើយ ។ សូម្បីសាកសពណាក្នុងវេលានៅមានជីវិតនុ៎ះឯង មានបូស រោគឃ្លង់និងពក ឬដំបៅបែករលួយពាសពេញ ។ សូម្បីសាកសពនេះឈ្មោះថា បែកហើយ ។ តាំងពីថ្ងៃទី ៣ ទៅ សូម្បីសរីរៈដែលដល់ភាពជាសាកសព ដោយជាសាកសពដែលហើមប៉ោងជាដើម ចាត់ថា ជាសាកសពដែលបែកហើយដូចគ្នា ។

មួយទៀត សូម្បីក្នុងសាកសពដែលនៅមិនបែកដោយប្រការទាំងពួង នឹងឱ្យមនុស្សយាមព្រៃខ្មោច ឬមនុស្សពួកដទៃឱ្យកាន់យក គួរពិត,

បើមិនបានអ្នកដទៃ គួរនឹងយកសស្ត្រា ឬវត្ថុអ្វីធ្វើឱ្យបែកធ្លុះធ្លាយហើយ ទើបកាន់យក ។ តែក្នុងសាកសព ភេទផ្ទុយគ្នា ភិក្ខុគួរតាំងសតិទុក ផ្គងសមណសញ្ញាឱ្យកើតឡើង ធ្វើឱ្យបែកធ្លុះធ្លាយលើសីសៈ ឬលើខ្នង ដៃនិងខ្នងជើងហើយកាន់យកសមគួរ ។

## ការផ្លាស់ប្តូរស្លាក

[១៣៥] ក្នុងរឿងភិក្ខុលួចប្តូរស្លាកចីវរ ដែលជាលំដាប់នៃសរីរៈ មិនទាន់បែកនោះ មានវិនិច្ឆ័យដូច្នេះ ៖

ព្រេីនបទថា កុសំ សង្កាមេត្វា ចីវរំ អគ្គហេសិ : ហើយបានផ្លាស់ស្លាកខ្លួន លួចយកចីវររបស់ភិក្ខុដទៃ មានសេចក្តីថា ភិក្ខុលួចដោយកុសាវហារ ក្នុងបណ្តាថេយ្យាវហារ បសយ្ហាវហារ បរិកប្បាវហារ បដិច្ឆន្នាវហារនិងកុសាវហារ ដែលបានសម្តែងទុកហើយត្រឹមតែឈ្មោះក្នុងការពណ៌នាសេចក្តីនៃបទនេះថា **អាទិយេយ្យ** ក្នុងខាងដើម ។ និងគប្បីជ្រាបសេចក្តីបែកផ្សេងនៃអវហារទាំងនេះ ដូចពោលតទៅនេះ ៖

## អត្ថាធិប្បាយអវហារ ៥ យ៉ាង

ពិតមែន ភិក្ខុណាមួយ ធ្វើចោរកម្មមានការកាត់ទីតជាដើម លួចទ្រព្យដែលមានម្ចាស់ ក្នុងពេលយប់ឬពេលថ្ងៃ ឬបញ្ឆោតឆបោកដោយគ្រឿងវាល់កោង និងកហាបណៈក្លែងក្លាយជាដើម, អវហាររបស់ភិក្ខុ

នោះឯង អ្នកកាន់យកទ្រព្យនោះ គប្បីជ្រាបថា ជាថេយ្យាវហារ, ចំណែកភិក្ខុណា សង្កត់សង្កិនអ្នកដទៃ គឺ ជិះជាន់យកដោយកម្លាំង, ឬ គម្រាមកំហែង គឺ បំភ័យ កាន់យកទ្រព្យជារបស់ជនទាំងនោះ ដូចពួកចោរអ្នកសម្លាប់មនុស្ស ធ្វើបទូសកម្ម មានសម្លាប់អ្នកធ្វើដំណើរនិងសម្លាប់អ្នកស្រុកជាដើម (និង) ដូចឥស្សរជន មានព្រះរាជានិងមហាអាមាត្យរបស់ព្រះរាជាជាដើម ដែលធ្វើការរឹបយកផ្ទះរបស់អ្នកដទៃដោយអំណាចសេចក្តីក្រោធហើយប្រើពលការរក្សាពលី លើសជាងពលីដែលត្រូវបានដល់ខ្លួន ។ អវហាររបស់ភិក្ខុនោះ អ្នកកាន់យកយ៉ាងនោះ គប្បីជ្រាបថា ជាបសយ្ហាវហារ ចំណែកអវហាររបស់ភិក្ខុដែលកំណត់ចំណាំទុកហើយកាន់យក លោកហៅថា បរិកប្បាវហារ ។ បរិកប្បាវហារនោះ មាន ២ យ៉ាង ដោយអំណាចការកំណត់វត្ថុ និងកំណត់ឱកាស ។

## អត្ថាធិប្បាយភណ្ឌបរិកប្ប

ក្នុង២ យ៉ាងនោះ ភណ្ឌបរិកប្ប គប្បីជ្រាបយ៉ាងនេះ ៖

ភិក្ខុខ្លះក្នុងសាសនានេះ មានសេចក្តីត្រូវការដោយសំពត់សាដក ទើបចូលទៅកាន់បន្ទប់ កំណត់ក្នុងចិត្តទុកថា "បើជាសំពត់សាដក យើងនឹងកាន់យក, បើជាអំបោះ យើងនឹងមិនកាន់យក", ហើយកាន់យកការុង

ក្នុងទីនឹង ។ បើក្នុងការុងនោះ មានសំពត់សាដក, ជាបារាជិកក្នុងខណៈដែលលើកឡើងនុ៎ះឯង, បើមានអំបោះ នៅរក្សា ។ លោកនាំចេញទៅខាងក្រៅ ស្រាយចេញដឹងថា "ជាអំបោះ" ទើបនាំមកដាក់ទុកនៅត្រង់ទីដើមវិញ, នៅរក្សាដូចគ្នា, សូម្បីដឹងថា "ជាអំបោះ" ហើយដើរទៅដោយគិតថា "បានវត្ថុណា ក៏ត្រូវកាន់យកវត្ថុនោះ" គប្បីពិន័យអាបត្តិដោយជំហាន ដាក់ទុកលើផ្ទៃផែនដីហើយកាន់យក, ត្រូវបារាជិកក្នុងខណៈដែលលើកឡើង ។ លោកត្រូវពួកម្ចាស់របស់ដេញតាមស្រែកឡើងថា "ចោរ ចោរ" ទើបបោះចោលហើយចៀសទៅ នៅរក្សា ។ ពួកម្ចាស់របស់ជួបហើយកាន់យកទៅ យ៉ាងនោះ ជាការល្អ បើអ្នកដទៃណាកាន់យកជាភណ្ឌទេយ្យដល់លោក ។ ខាងក្រោយកាលពួកម្ចាស់របស់ត្រឡប់ទៅហើយ លោកឃើញរបស់នោះក្នុងទីនោះឯង ទើបកាន់យកដោយគិតថា "របស់នេះ យើងនាំចេញមកពីកាលមុន ឥឡូវនេះ ជារបស់យើងពិត" ដូច្នេះ នៅរក្សា តែជាភណ្ឌទេយ្យ ។ សូម្បីកាលភិក្ខុកំណត់ទុកហើយកាន់យក ដោយន័យជាដើមថា "បើជាអំបោះ យើងនឹងកាន់យក បើជាសំពត់សាដកយើងនឹងមិនកាន់យក, បើជាទឹកដោះថ្លាយើងនឹងកាន់យក បើជាប្រេង យើងនឹងមិនកាន់យក" ដូច្នេះ មានន័យដូចគ្នានុ៎ះឯង ។

ចំណែកក្នុងអដ្ឋកថាមហាបច្ចរីជាដើម លោកពោលទុកថា សូម្បី

ភិក្ខុមានសេចក្តីត្រូវការដោយសំពត់សាដក កាន់យកការុងសំពត់សាដកនុ៎ះឯងចេញទៅដាក់ទុកខាងក្រៅស្រោយចេញហើយ ឃើញថា "នេះជាសំពត់សាដក" ហើយទៅគប្បីពិន័យដោយការលើកជើងនុ៎ះឯង ។ តែក្នុងអដ្ឋកថាមហាបច្ចរីជាដើមនេះ បរិកប្ប រមែងប្រាកដ ព្រោះលោកបានកំណត់វត្ថុទុកថា បើទោះជាសំពត់សាដក យើងនឹងកាន់យក បរិកប្បាវហារឈ្មោះថា មិនប្រាកដ ព្រោះឃើញហើយទើបលួច ។ តែក្នុងមហាអដ្ឋកថាលោកពិន័យអវហារដល់ភិក្ខុអ្នកលើកឡើងនូវវត្ថុដែលខ្លួនកំណត់ចំណាំទុក ដែលខ្លួនមើលមិនឃើញ តែគង់តាំងនៅក្នុងភាពជាវត្ថុដែលខ្លួនកំណត់ចំណាំទុកហើយនុ៎ះឯង ។ ព្រោះហេតុនោះ បរិកប្បាវហារ ទើបឈ្មោះថា ប្រាកដក្នុងមហាអដ្ឋកថានោះ ។ អវហារដែលពោលទុកក្នុងមហាអដ្ឋកថានោះ សមដោយព្រះបាលី (ខាងដើម) ថា តំ មញ្ញមានោ តំ អវហរិ : ភិក្ខុអ្នកទទួលបង្គាប់នោះ សំគាល់ទ្រព្យនោះបានហើយទៅលួចទ្រព្យនោះបានមក ដូច្នេះឯង ។ បណ្តាបរិកប្បទាំង ២ នោះ បរិកប្បនេះណាដែលប្រព្រឹត្តទៅដោយន័យជាដើមថា បើទោះជាសំពត់សាដក យើងនឹងកាន់យក ដូច្នេះ បរិកប្បនេះ ឈ្មោះថា ភណ្ឌបរិកប្ប ។

## អត្ថាធិប្បាយឱកាសបរិកប្ប

ចំណែកឱកាសបរិកប្ប គប្បីជ្រាបយ៉ាងនេះ ៖

ភិក្ខុឡេះឡោះរូបខ្លះក្នុងសាសនានេះ ចូលទៅកាន់បរិវេណរបស់អ្នកដទៃ ឬផ្ទះរបស់ត្រកូល ឬរោងដែលជាទីធ្វើការងារក្នុងព្រៃក្តី ហើយអង្គុយក្នុងទីនោះ ដោយការសន្ទនាប្រាស្រ័យ រមិលមើលបរិក្ខារដែលជាទីតាំងនៃសេចក្តីលោភយ៉ាងណាមួយ ។ ក៏ឯកាលរមិលមើល ប្រទះឃើញហើយ ចូរបានធ្វើសេចក្តីកំណត់ចំណាំទុក ដោយអំណាចស្ថានទីមានទ្វារ យ៉ូមុខ ខាងក្រោមប្រាសាទ បរិវេណស៊ុមទ្វារ និងគល់ឈើជាដើម ហើយកំណត់ទុកថា "បើពួកម្ចាស់ទ្រព្យឃើញយើងក្នុងចន្លោះនេះ យើងនឹងឱ្យដល់ជនទាំងនោះឯងវិញ ធ្វើជាចាប់កាន់ដើម្បីត្រូវការនឹងមើលត្រាច់ទៅ បើពួកគេមិនឃើញសោត យើងក៏នឹងលួចយក" ដូច្នេះ ។ លុះមកកាលភិក្ខុនោះកាន់យកទ្រព្យនោះកន្លងហួសដែនដែលកំណត់ទុកទៅ ត្រូវអាបត្តិបារាជិក ។ បើលោកកំណត់ដែនឧបចារទុក ដើរបែរមុខទៅមកនុ៎ះឯង មនសិការកម្មដ្ឋានជាដើមក្តី បញ្ជូនចិត្តទៅទីដទៃក្តី ឈានកន្លងដែនឧបចារទៅ ដោយមិនមានសតិ ជាភណ្ឌទេយ្យ ។ សូម្បីបើកាលលោកទៅដល់ទីនោះហើយ មានចោរ ដំរី ម្រឹគកាច ឬមហាមេឃតាំងឡើង និងលោកឈានកន្លងស្ថានទីនោះទៅដោយរហ័ស ព្រោះប្រាថ្នានឹងផុតពីឧបទ្រវៈនោះ ជាភណ្ឌទេយ្យដូចគ្នា ។ ក៏ក្នុងពាក្យនេះ អាចារ្យពួក

ខ្លះពោលថា ព្រោះក្នុងខាងដើមនុ៎ះឯង លោកកាន់យកដោយថេយ្យចិត្ត; ដូច្នោះ ទើបរក្សាមិនបាន ជាអវហារតែម្ដង ។ នេះជាន័យក្នុងមហាអដ្ឋកថាមុន ។ ចំណែកក្នុងមហាបច្ចរី លោកពោលទុកថា សូម្បីបើលោករូបនោះ ឡើងជិះដំរី ឬសេះនៅខាងក្នុងដែនកំណត់ហើយ មិនទាន់បរទៅនៅឡើយ ដំរីឬសេះនោះទៅដោយខ្លួនឯង លោកមិនឱ្យអ្នកដទៃបរទៅ សូម្បីកាលកន្លងហួសដែនកំណត់ទៅ ក៏មិនជាបារាជិកត្រឹមតែជាភណ្ឌទេយ្យប៉ុណ្ណោះ ។ ក្នុងបរិកប្ប ២ យ៉ាងនោះ បរិកប្បដែលប្រព្រឹត្តទៅថា បើពួកម្ចាស់នឹងឃើញយើងក្នុងរវាងនេះ យើងឱ្យដល់ជនទាំងនោះឯងវិញ យើងធ្វើជាចាប់កាន់ដើម្បីត្រូវការនឹងមើលត្រាច់ទៅ នេះឈ្មោះថា ឱកាសបរិកប្ប ។ អវហាររបស់ភិក្ខុដែលកំណត់ទុកហើយកាន់យក ដោយអំណាចនៃបរិកប្ប សូម្បីទាំង ២ ពួកនេះ ដូចពណ៌នាមកយ៉ាងនេះ គប្បីជ្រាបថា ជាបរិកប្បាវហារ ។

## អត្ថាធិប្បាយបដិច្ឆន្នាវហារ

ចំណែកការបិទបាំងទុកហើយទើបលួច ឈ្មោះថា បដិច្ឆន្នាវហារ ។ បដិច្ឆន្នាវហារនោះ គប្បីជ្រាបយ៉ាងនេះ ៖

ក៏ភិក្ខុណា កាលពួកមនុស្សកំពុងលេង ឬកំពុងចូលទៅក្នុងសួន

ជាដើម ឃើញវត្ថុ គឺ គ្រឿងអលង្ការដែលគេដោះទុកទើបយកធូលីឬស្លឹកឈើបិទបាំងទុក ដោយគិតក្នុងចិត្តថា "បើយើងនឹងឱនចុះកាន់យក, ពួកមនុស្សនឹងដឹងយើងថា សមណៈកាន់យកអ្វី ? ហើយនឹងគប្បីបៀតបៀនយើង" ទើបគិតថា "ខាងក្រោយ យើងនឹងកាន់យក" ដូច្នេះ, ការលើកវត្ថុឡើង ដោយហេតុត្រឹមតែប៉ុណ្ណេះ មិនទាន់មានដល់ភិក្ខុនោះ; ព្រោះហេតុនោះ ទើបមិនទាន់ជាអវហារ ។ តែវេលាណា ពួកមនុស្សទាំងនោះប្រាថ្នានឹងចូលទៅខាងក្នុងស្រុក សូម្បីកាលស្វែងរកវត្ថុនោះ ក៏មិនឃើញ ទើបគិតថា "ឥឡូវនេះ ងងឹតហើយ, ក្នុងថ្ងៃស្អែក ពួកយើងនឹងដឹង ហើយក៏ទៅទាំងដែលនៅមានសេចក្តីអាល័យនុ៎ះឯង, វេលានោះកាលភិក្ខុនោះ លើកវត្ថុនោះឡើង ជាបារាជិកក្នុងខណៈដែលលើកឡើង ។ តែកាលភិក្ខុកាន់យកក្នុងវេលាដែលបិទបាំងទុកហើយនុ៎ះឯងដោយសកសញ្ញាថា "ជារបស់យើង" ឬដោយបង្សុកូលសញ្ញាថា "ឥឡូវនេះ មនុស្សទាំងនោះទៅហើយ ពួកគេបានបោះបង់វត្ថុនេះហើយ" ជាភណ្ឌទេយ្យ ។ កាលមនុស្សទាំងនោះត្រឡប់មកក្នុងថ្ងៃទី ២ សូម្បីត្រូតពិនិត្យរកមើលហើយក៏មិនឃើញ ទើបបានដាក់ធុរៈត្រឡប់ទៅ វត្ថុដែលលោកកាន់យកជាភណ្ឌទេយ្យដូចគ្នា ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ពួកគេមិនឃើញវត្ថុដោយសេចក្តីព្យាយាមរបស់ភិក្ខុនោះ ។

ចំណែកភិក្ខុណា ប្រទះឃើញវត្ថុបែបនោះ ដែលតាំងនៅក្នុងទីដើមនុ៎ះឯង មិនបានបិទបាំង តែមានថេយ្យចិត្តយកជើងជាន់សង្កត់ឱ្យលិចចុះក្នុងភក់ ឬក្នុងខ្សាច់, ល្មមលោកសង្កត់ឱ្យលិចចុះប៉ុណ្ណោះ ជាបារាជិក ។

## អត្ថាធិប្បាយកុសាវហារ

ការផ្លាស់ប្តូរស្លាកហើយ លួច លោកហៅថា កុសាវហារ ។

សូម្បីកុសាវហារនោះ គប្បីជ្រាបដូច្នេះ ៖

ភិក្ខុណា កាលភិក្ខុទាំងឡាយកំពុងចាត់ចែងស្លាកចែកចីវរ ប្រាថ្នានឹងលួចចំណែករបស់ភិក្ខុដទៃ ដែលមានតម្លៃច្រើនជាង ដែលឋិតនៅជិតចំណែករបស់ខ្លួនទៅ ប្រាថ្នានឹងដាក់ឈើស្លាកដែលធ្លាក់មកក្នុងចំណែករបស់ខ្លួន ឱ្យធ្លាក់ចុះទៅក្នុងចំណែករបស់ភិក្ខុដទៃ ទើបលើកឡើង នៅរក្សាទុកសិន ។ លោកដាក់ទៅក្នុងចំណែករបស់ភិក្ខុដទៃ ក៏នៅរក្សាដូចគ្នា ។ តែក្នុងកាលដែលឈើស្លាកធ្លាក់ចុះទៅហើយ វេលាណា លោកលើកឈើស្លាករបស់ភិក្ខុដទៃឡើងចាកចំណែករបស់ភិក្ខុដទៃ , វេលានោះ ល្មមត្រឹមតែលោកលើកឡើង ក៏ជាបារាជិក ។ បើលោកលើកឈើស្លាកឡើងអំពីចំណែករបស់ភិក្ខុដទៃចេញមុន, ព្រោះប្រាថ្នានឹងទម្លាក់ចុះ

មកក្នុងចំណែករបស់ខ្លួន ក្នុងខណៈដែលលើកឡើងនៅរក្សា, ក្នុងខណៈដែលទម្លាក់ចុះទៅ ក៏នៅរក្សា,ម្យ៉ាងទៀត លើកឈើស្លាករបស់ខ្លួនឡើងចាកចំណែករបស់ខ្លួន, ក្នុងខណៈដែលលើកឡើងនុ៎ះឯង នៅរក្សា, កាលលើកឈើស្លាកនោះឡើងហើយ ទម្លាក់ចុះក្នុងចំណែករបស់ភិក្ខុដទៃល្មមផុតពីដៃ ក៏ជាបារាជិក ។ តែបើឈើស្លាកដែលធ្លាក់ចុះក្នុងចំណែកទាំងពីរមើលមិនឃើញ ។ ខាងក្រោយ កាលភិក្ខុដ៏សេសទៅហើយ នវកភិក្ខុក្រៅនេះ សួរថា "លោកម្ចាស់ ឈើស្លាករបស់ខ្ញុំព្រះករុណារមែងមិនប្រាកដ" ។ ភិក្ខុចាស់ទើបនិយាយថា "អាវុសោ សូម្បីរបស់ខ្ញុំព្រះករុណា ក៏មិនប្រាកដដែរ" ។ នវកភិក្ខុសួរថា "លោកម្ចាស់ តើមួយណាជាចំណែករបស់ខ្ញុំព្រះករុណា ?" ភិក្ខុចាស់ ទើបសម្តែងចំណែករបស់ខ្លួនថា "នេះចំណែករបស់អាវុសោ" ។ កាលនវកភិក្ខុនោះ ប្រកែកត‌វ៉ា ឬមិនប្រកែកតវ៉ាក៏ដោយ កាន់យកចំណែកនោះទៅ, ភិក្ខុចាស់ក្រៅនេះ លើកចំណែករបស់នវកភិក្ខុនោះឡើង ត្រូវបារាជិកក្នុងខណៈដែលលើកឡើង ។ សូម្បីបើថា កាលនវកភិក្ខុនោះឆ្លើយប្រាប់ថា "ខ្ញុំព្រះករុណាមិនព្រមឱ្យចំណែករបស់ខ្ញុំព្រះករុណាដល់លោក, ហើយបើលោកដឹងចំណែករបស់ខ្លួនហើយ ចូរកាន់យកចុះ", ភិក្ខុចាស់ សូម្បីដឹងថា "នេះមិនមែនចំណែករបស់យើង" បានកាន់យកចំណែករបស់នវកភិក្ខុនោះឯង ជាបារាជិកក្នុងខណៈដែលលើកឡើង ។ តែបើភិក្ខុក្រៅនេះគិត

ថា “និងមានប្រយោជន៍អ្វីដោយការវិវាទនេះថា នេះចំណែករបស់លោក, នេះចំណែករបស់ខ្ញុំព្រះករុណា” ទើបនិយាយថា “ទោះជាចំណែកដែលត្រូវបានដល់ខ្ញុំព្រះករុណាក៏ដោយ ត្រូវបានដល់លោកម្ចាស់ក៏ដោយ, ចំណែកណាល្អ លោកចូរកាន់យកចំណែកនោះចុះ” ដូច្នេះ; លោកឈ្មោះថា កាន់យកចំណែកដែលគេឱ្យហើយទើបមិនមានអវហារក្នុងការកាន់យកនេះ ។ បើភិក្ខុនោះខ្វាចចំពោះសេចក្ដីប្រកែកគ្នា ដែលពួកភិក្ខុដាស់តឿនថា លោកចូរទទួលយកចំណែកតាមដែលលោកពេញចិត្តចុះ ទើបវៀរចំណែកដែលល្អដែលត្រូវបានដល់ខ្លួនចេញហើយ កាន់យកចំណែកដែលអាក្រក់ទុំះឯងទៅ, ខាងក្រោយ សូម្បីកាលភិក្ខុក្រៅនេះ កាន់យកចំណែកដែលសស់ចាកទីជ្រើសរើសហើយ ក៏មិនជាអវហារដូចគ្នា ។ ដូច្នេះឯង ។

ការផ្លាស់ប្ដូរស្លាក ចប់

## ប្រារព្ធរឿងទូទៅ

ក៏ព្រះអដ្ឋកថាចារ្យទាំងឡាយ ពោលទុកក្នុងអដ្ឋកថាទាំងឡាយថា ការចែកចីវរតែម៉្យាងប៉ុណ្ណោះ មកហើយដោយអំណាចការផ្លាស់ប្ដូរស្លាកក្នុងទីនេះ ។ តែគួរនាំសេចក្ដីកើតឡើងនៃបច្ច័យទាំង ៤ និងការចែកមក

សម្ដែងទុកផង ។ កាលពោលទុកយ៉ាងនោះហើយ ទើបពោលកថា ប្រារព្ធចីវរដែលកើតឡើង ចាប់ផ្ដើមតាំងពីរឿងពេទ្យជីវកនេះថា "សូមព្រះមានព្រះភាគ ទ្រង់ទទួលយកសំពត់សិវេយ្យកៈ ១ គូរបស់ខ្ញុំព្រះអង្គ សូមទ្រង់អនុញ្ញាតគហបតីចីវរដល់ភិក្ខុសង្ឃផង"[១] ដូច្នេះ ដោយពិស្ដារក្នុង

១. វិន. មហា ៨. ៤១/៩៧ ។

ចីវរក្ខន្ធកៈ, ពោលបិណ្ឌបាតកថា ចាប់តាំងពីសូត្រនេះថា "សម័យនោះឯង ក្រុងរាជគ្រឹះកើតទុរ្ភិក្ស ( អត់បាយ ) មនុស្សទាំងឡាយមិនអាចធ្វើសង្ឃភត្តបានហើយប្រាថ្នានឹងធ្វើឧទ្ទេសភត្ត និមន្តនភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត និងបាដិបទិកភត្ត"[១] ដូច្នេះដោយពិស្ដារក្នុងសេនាសនក្ខន្ធកៈ, ពោលពីសេនាសនដែលមកហើយ ចាប់តាំងពីរឿងភិក្ខុឆព្វគ្គិយនេះថា "សម័យនោះឯង ពួកភិក្ខុសត្តរសវគ្គិយ ជុសជុលវិហារធំមួយដែលមាននៅក្នុងទីបំផុតដែនដោយគិតគ្នាថា 'ពួកយើងនឹងនៅចាំវស្សាក្នុងវិហារធំនេះ' ។ ពួកភិក្ខុឆព្វគ្គិយ បានឃើញពួកសត្តរសវគ្គិយភិក្ខុ កំពុងតែជុសជុលវិហារធំ"[២] ដូច្នេះ ដោយពិស្ដារក្នុងសេនាសនក្ខន្ធកៈនុ៎ះឯង, និងពោលកថាប្រារព្ធភេសជ្ជៈមានទឹកដោះថ្លាជាដើម ក្នុងទីបំផុតនៃសេនាសនកថានោះ ដោយពិស្ដារ ។ ចំណែកខ្ញុំព្រះករុណានឹងពោលកថានោះទាំងអស់ ក្នុងអាគតស្ថាននៃកថាប៉ុណ្ណោះ ។ កាលខ្ញុំព្រះករុណាពោលយ៉ាង

នោះ ព្រោះពាក្យដែលខ្ញុំព្រះករុណាពោលទុករួចហើយខាងដើមនោះឯង ។

[១៣៦] រឿងពេងភ្លើងបន្ទាប់ពីរឿងនេះទៅ មានសេចក្ដីងាយយល់ទាំងអស់ ។

១. វិន. ចុល្ល. សេនាសនក្ខន្ធក. ១០. ៤៣៥/៣៥៩ ។
២. វិន. ចុល្ល. សេនាសនក្ខន្ធក. ១០. ៣៨៦/៣២៦ ។

[១៣៧] ក្នុងរឿងភិក្ខុ ៥រូប ឆាន់រំពាសត្វ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុទាំងឡាយនោះ ឱ្យអនុបសម្បន្នធ្វើឱ្យជារបស់គួរ ហើយឆាន់ ។ តែកាលភិក្ខុនឹងកាន់យកសាច់ដែលជារបស់សល់ គប្បីកាន់យកសាច់ដែលសត្វទាំងនោះស៊ីនៅសល់ចោលហើយ ។ បើអាចឱ្យសត្វដែលកំពុងស៊ីទាំងនោះចោលទៅ ហើយកាន់យក, សូម្បីសាច់ដែលជាសំណល់នោះ ក៏គួរ ។ តែមិនគួរកាន់យក ដើម្បីប្រយោជន៍ដល់ការឃុំគ្រងខ្លួន និងដើម្បីភាពជាអ្នកមានសេចក្ដីអាណិតក្នុងសត្វដទៃ ។

[១៣៨] ក្នុងរឿងចែកបាយ ខាទនយៈ នំ អំពៅ និងផ្លែទន្លាប់ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុអាងបុគ្គលដែលមិនមានខ្លួនថា "លោកចូរឱ្យចំណែកដល់ភិក្ខុដទៃទៀត" ។

ពីរបទថា អមូលកំ អគ្គហេសិ : កាន់យកបាយដោយឥតមាន

មូល សេចក្ដីថា លោកបានពោលមុសាវាទ កាន់យកចំណែកដែលមិនមានខ្លួនបុគ្គលជាមូលតែម្យ៉ាង ។ លោកមិនបានកាន់យកចំណែកនោះដោយថេយ្យចិត្តទេ ។ ព្រោះហេតុនុ៎ះឯង ទើបព្រះមានព្រះភាគមិនត្រាស់សួរថា លោកមានចិត្តយ៉ាងណា ? ត្រាស់ថា ជាបាចិត្តិយ ។ ពិតមែនកាលលោកពោលថា "លោកចូរឱ្យចំណែកដល់ភិក្ខុមួយរូបទៀត" វត្ថុនៃបារាជិកមិនប្រាកដ ទាំងព្រះពុទ្ធទាំងឡាយ ក៏មិនត្រាស់សួរក្នុងឋានៈដូច្នេះ ។ តែបើពាក្យនោះ នឹងគប្បីជាវត្ថុនៃបារាជិកសោត, គប្បីជ្រាបថា ជាអាបត្តិទុក្កដប៉ុណ្ណោះ ដូចគ្នានឹងអាបត្តិទុក្កដ ព្រោះការបន្ទំយកសួនដូច្នោះ ។ សេចក្ដីសង្ខេបក្នុងរឿងនេះ មានប៉ុណ្ណេះ ។

ចំណែកសេចក្ដីពិស្ដារ គប្បីជ្រាបដូច្នេះ ៖

ក៏វត្ថុណាជារបស់មាននៅកន្លែងសង្ឃប៉ុណ្ណោះ កាលវត្ថុនោះ ដែលភិក្ខុបានសង្ឃសន្មតិ ឬមិនបានសន្មតិក៏ដោយ ចែក, កាលភិក្ខុពោលថា "លោកចូរឱ្យចំណែកដល់ភិក្ខុមួយរូបទៀត" គឺ អាងបុគ្គលដែលមិនមានខ្លួនយ៉ាងនោះ កាន់យកដោយការពោលកុហកតែម្យ៉ាង ជាបាចិត្តិយផង ជាភណ្ឌទេយ្យផង ។ កាលភិក្ខុកាន់យកដោយថេយ្យចិត្ត ក៏មានន័យដូចគ្នានេះ ។ ភិក្ខុណា មិនបានអាងបុគ្គល ពោលថា "លោកចូរឱ្យមួយចំណែកទៀត" ហើយកាន់យកក្ដី រាប់វស្សាកោងកាន់យកក្ដី, ភិក្ខុនោះ

គប្បីពិន័យតាមតម្លៃរបស់ ។ ចំណែកវត្ថុណា ជារបស់ពួកគ្រហស្ថដែលគេចែកប្រគេនសង្ឃក្នុងផ្ទះ ឬក្នុងអារាមរបស់គ្រហស្ថទាំងនោះ កាលវត្ថុរបស់នោះ ដែលម្ចាស់របស់ក្តី ជនដទៃដែលម្ចាស់របស់បង្គាប់ថា "អ្នកចូរប្រគេនរបស់នេះ"ក្តី ក៏ប្រគេន សូម្បីកាលភិក្ខុពោលថា "លោកចូរឱ្យមួយចំណែកទៀត" ហើយកាន់យកដោយថេយ្យចិត្ត មិនជាបារាជិកផងមិនជាភណ្ឌទេយ្យផង ។ តែជាភណ្ឌទេយ្យដល់ភិក្ខុដែលកាន់យកដោយវស្សាកោង ។ កាលវត្ថុនោះ ជនដទៃដែលម្ចាស់របស់មិនបានបញ្ជាយ៉ាងនេះថា លោកចូរប្រគេនដល់ភិក្ខុនេះ ក៏ ប្រគេន កាលភិក្ខុអាងបុគ្គលកាន់យកតាមន័យមុនទុំះឯង ជាបាចិត្តិយផង ជាភណ្ឌទេយ្យផង ។ កាលភិក្ខុពោលថា លោកចូរឱ្យមួយចំណែកទៀត ហើយកាន់យកដោយថេយ្យចិត្តក្តី កាន់យកដោយរាប់វស្សាកោងក្តី ដល់ការពិន័យតាមតម្លៃរបស់ ។ ក៏វិនិច្ឆ័យនេះអ្នកណា ៗ ក៏អាចដឹងបានក្នុងអដ្ឋកថា ឈ្មោះកុរុន្ទី, តែក្នុងអដ្ឋកថាដទៃ ៗ ដឹងបានលំបាក ទាំងមានពិរុទ្ធ( កំហុស )ផង ។

ពីរបទថា **អមូលកាំ អគ្គហេសិ** : **កាន់យកចំណែកដោយឥតមានមូល** សេចក្តីថា កាលពួកម្ចាស់របស់ប្រគេន ភិក្ខុបានកាន់យកហើយ ។

ច្រើនបទថា **អនាបត្តិ ភិក្ខុ បារាជិកស្ស** : **ម្នាលភិក្ខុ អ្នក**

មិនត្រូវអាបត្តិបារាជិកទេ សេចក្តីថា វត្ថុដែលពួកម្ចាស់របស់ប្រគេនហើយ ភិក្ខុកាន់យកបាន ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ទុកថា "ភិក្ខុនោះ មិនត្រូវអាបត្តិ"[១] ។

---

១. នេះ មិនមែនពុទ្ធដិកាទេ គឺជាន័យរបស់ពាក្យថា "ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ" ។

ប្រើនបទថា អាបត្តិ សម្បជានមុសាវាទេ បាចិត្តិយស្ស : ត្រូវតែអាបត្តិបាចិត្តិយ ព្រោះដឹងខ្លួនហើយពោលពាក្យកុហកប៉ុណ្ណោះ សេចក្តីថា ព្រោះសម្បជានមុសាវាទ ដែលភិក្ខុនោះពោលហើយ ទើបព្រះមានព្រះភាគពិន័យអាបត្តិបាចិត្តិយ ដូចក្នុងរឿងយាគូដែលផ្សំដោយរបស់ ៣ យ៉ាងខាងមុខ ។

ចំណែកក្នុងការកាន់យក គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

អាហារមានបាយជាដើមរបស់សង្ឃ ភិក្ខុដែលសង្ឃសន្មត ឬជនទាំងឡាយ មានអារាមិកៈជាដើម ដែលភិក្ខុបញ្ជាទុក កំពុងប្រគេន និងអាហារមានបាយជាដើម ជារបស់ពួកគ្រហស្ថ ដែលម្ចាស់របស់ឬជនដទៃដែលម្ចាស់របស់បង្គាប់ទុកកំពុងប្រគេន កាលភិក្ខុពោលថា "លោកចូរឱ្យចំណែកដល់ភិក្ខុមួយរូបទៀត" ហើយកាន់យកជាភណ្ឌទេយ្យ ។ កាលភិក្ខុកាន់យកអាហារមានបាយជាដើមដែលជនដទៃកំពុងប្រគេន គប្បី

ពិន័យតាមតម្លៃវត្ថុ ។ កាលអាហារមានបាយជាដើមភិក្ខុដែលសង្ឃមិនបានសន្មត ឬអ្នកដែលម្ចាស់របស់មិនបានប្រើក៏ប្រគេន ភិក្ខុកាលពោលថា "លោកចូរឱ្យមួយចំណែកទៀត" ហើយកាន់យកក្តី រាប់វស្សាកោងកាន់យកក្តី គប្បីពិន័យតាមតម្លៃវត្ថុក្នុងខណៈដែលលើកចំណែកនោះឡើងតែម្តង ដូចក្នុងបត្តចតុក្កៈដូច្នោះ ។ អាហារមានបាយជាដើម ដែលពួកជនក្រៅនេះប្រគេន កាលភិក្ខុកាន់យកដោយអាការយ៉ាងនោះ ជាភណ្ឌទេយ្យ ។ ចំណែកវត្ថុរបស់គ្រហស្ថដែលម្ចាស់របស់បង្គាប់ថា "លោកចូរប្រគេនដល់ភិក្ខុនេះ"ក្តី ម្ចាស់របស់គេប្រគេនដោយខ្លួនឯងក្តី ក៏ជាការប្រគេនល្អហើយ ដូច្នេះឯង ។ ក្នុងអធិការពោលអំពីវត្ថុមានបាយជាដើមនេះ មានសារៈអំពីពាក្យវិនិច្ឆ័យក្នុងអដ្ឋកថាទាំងពួងត្រឹមតែប៉ុណ្ណេះ ។

[១៣៩] ក្នុងរឿងទាំងឡាយ មានរឿងលក់បាយជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ពេងសម្រាប់ដាំបាយលក់ ឈ្មោះថា ឱទនិយឃរៈ (គឺ ផ្ទះលក់បាយ) ។ ពេងសម្រាប់ស្ងោរសាច់លក់ ឈ្មោះថា សូនឃរៈ (គឺ ផ្ទះលក់សម្លសាច់) ។ ពេងសម្រាប់ស្ងោររបស់ទំពាស៊ីលក់ ឈ្មោះថា បូវឃរៈ (គឺផ្ទះលក់នំ) ។ ពាក្យដ៏សេស ក្នុងរឿងផ្ទះលក់បាយជាដើមនេះ មានប្រាកដច្បាស់ហើយក្នុងរឿងបរិក្ខារនុំះឯង ។

[១៤១] ក្នុងរឿងតាំង មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនោះ កំណត់ថង់ទុក ហើយទើបឱ្យថង់យាមព្រមទាំងតាំងរំកិលទៅ ដោយគិតថា "យើងនឹងកាន់យកថង់ ដែលមកដល់ទីនេះ" ។ ព្រោះហេតុនោះ ក្នុងការរំកិលតាំងទៅ អវហារទើបមិនមានដល់ភិក្ខុនោះ ។ តែទ្រង់ពិន័យជាបារាជិកក្នុងការឱ្យរំកិលទៅ ហើយកាន់យកអំពីឱកាសដែលកំណត់ទុក ។ ក៏ភិក្ខុកាលនាំទៅយ៉ាងនោះ បើមិនមានថេយ្យចិត្តក្នុងតាំង ព្រះវិន័យធរគប្បីឱ្យវាយតម្លៃថង់ ហើយពិន័យអាបត្តិ ។ បើមានថេយ្យចិត្តសូម្បីក្នុងតាំង គួរឱ្យវាយតម្លៃទាំង ២ យ៉ាង ហើយពិន័យអាបត្តិ ។

[១៤២-៤] ៣ រឿង មានរឿងពូកជាដើម ប្រាកដច្បាស់ហើយតែម្ដង ។

[១៤៥-៦] ក្នុង៣ រឿង មានរឿងការកាន់យកដោយវិសាសៈជាដើម មិនជាអាបត្តិព្រោះការកាន់យក, កាលពួកម្ចាស់របស់ឱ្យនាំមកសងជាភណ្ឌទេយ្យ ។ ចំណែករបស់ភិក្ខុអ្នកចូលទៅបិណ្ឌបាត ភិក្ខុដែលនៅក្នុងឧបចារសីមាប៉ុណ្ណោះទទួលយក ទើបគួរ ។ តែបើពួកទាយកប្រកាសសូម្បីដល់ពួកភិក្ខុដែលនៅខាងក្រៅឧបចារថា "ពួកលោកម្ចាស់ទទួលយកចុះ" ភិក្ខុទាំងឡាយមកហើយ នឹងឆាន់ ដោយពាក្យប្រកាសយ៉ាងនេះ សូម្បីពួកភិក្ខុដែលនៅខាងក្នុងស្រុកនឹងកាន់យក ក៏គួរ ។ ពាក្យដ៏សេសក្នុងរឿងទាំង ២ នេះ មានសេចក្ដីងាយយល់ទាំងអស់ ។

[១៤៧] ក្នុងរឿង៧ មានរឿងចោរលួចស្វាយជាដើម មានវិនិច្ឆ័យដូច្នេះ ៖

មិនត្រូវអាបត្តិ ព្រោះកាន់យកដោយបង្សុកូលសញ្ញា, កាលពួកម្ចាស់របស់ឱ្យនាំមកសង ជាភណ្ឌទេយ្យ, ព្រោះបរិភោគដោយថេយ្យចិត្ត ជាបារាជិក ។

[១៤៨] ក្នុងរឿងទាំងឡាយ មានរឿងពួកចោរលួចស្វាយជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖

ទាំងពួកម្ចាស់របស់ក៏មានសេចក្ដីអាល័យ, ទាំងពួកចោរក៏មានសេចក្ដីអាល័យ, កាលភិក្ខុឆាន់ដោយបង្សុកូលសញ្ញា ជាភណ្ឌទេយ្យ, កាលកាន់យកដោយថេយ្យចិត្ត ជាអវហារក្នុងខណៈដែលលើកឡើងនូវឯង, ភិក្ខុនោះ ដែលព្រះវិន័យធរ គប្បីឱ្យវាយតម្លៃវត្ថុពិន័យអាបត្តិ ។ ពួកម្ចាស់របស់នៅមានសេចក្ដីអាល័យ, តែពួកចោរអស់សេចក្ដីអាល័យ លាក់ទុកក្នុងទីស្ងាត់កន្លែងណាមួយដោយគិតថា នឹងកាន់យកទៀត ដូច្នេះហើយទៅ មានន័យដូចគ្នានេះ ។ ទាំង ២ ចំណែកអស់សេចក្ដីអាល័យ, កាលភិក្ខុទំពាឆាន់ដោយបង្សុកូលសញ្ញា មិនជាអាបត្តិ, កាលទំពាឆាន់ដោយថេយ្យចិត្ត ជាអាបត្តិទុក្កដ ។

[១៤៩] ចំណែកក្នុងស្វាយជាដើមរបស់សង្ឃ មានវិនិច្ឆ័យដូច្នេះ ៖

ផ្លែឈើមានស្វាយជាដើម ដែលកើតនៅក្នុងសង្ឃារាម ឬដែលគេ

នាំមកប្រគេនក៏ដោយ ដែលមានតម្លៃ ៥ មាសក ឬលើសជាង ៥ មាសក, កាលភិក្ខុលួចទៅ ជាបារាជិក ។ ក្នុងបច្ចន្តជនបទ កាលពួកអ្នកស្រុកភៀសខ្លួនចេញទៅ ព្រោះឧបទ្រវៈ គឺ ចោរ, ពួកភិក្ខុក៏លះបោលវិហារទៅ ទាំងដែលនៅមានសេចក្ដីឧស្សាហ៍ទុះឯង ដោយគិតថា កាលជនបទស្ងប់ហើយ ពួកយើងនឹងត្រឡប់មក ។ ពួកភិក្ខុទៅដល់វិហារដូច្នោះ គិតថា ផ្លែឈើទាំងឡាយមានស្វាយទុំជាដើម ជារបស់ដែលគេលះបោលហើយ ទើបឆាន់ដោយបង្សុកូលសញ្ញាមិនជាអាបត្តិ, កាលឆាន់ដោយថេយ្យចិត្ត ជាអវហារ ។ ភិក្ខុនោះ ដែលព្រះវិន័យធរគប្បីឱ្យវាយតម្លៃរបស់ពិន័យអាបត្តិ ។

ចំណែកក្នុងមហាបច្ចរីនិងក្នុងសង្ខេបអដ្ឋកថា លោកពោលទុកដោយមិនប្លែកគ្នាថា កាលភិក្ខុឆាន់ផ្លែឈើ តូចធំក្នុងវត្តរហោស្ថានដោយថេយ្យចិត្ត មិនជាបារាជិក ព្រោះហេតុអ្វី ? ព្រោះហេតុថា ផ្លែឈើទាំងឡាយក្នុងវត្តរហោស្ថាន ជារបស់ពួកភិក្ខុដែលមកហើយ ៗ ក៏ហេតុត្រឹមតែមានសេចក្ដីឧស្សាហ៍ប៉ុណ្ណោះ ជាប្រមាណក្នុងផ្លែឈើដែលជារបស់គណៈ និងដែលជារបស់ចំពោះបុគ្គល ។ តែបើភិក្ខុឱ្យផ្លែស្វាយទុំជាដើមអំពីផ្លែឈើដែលជារបស់គណៈ ឬរបស់បុគ្គលនោះ ដើម្បីប្រយោជន៍ដល់ការសង្គ្រោះត្រកូល រមែងត្រូវទុក្កដ ព្រោះកុលទូសកសិក្ខាបទ ។ ភិក្ខុកាលឱ្យដោយថេយ្យចិត្តគប្បីពិន័យអាបត្តិ

តាមតម្លៃ (វត្ថុ) ។ សូម្បីក្នុងផ្លែឈើដែលជារបស់សង្ឃ ក៏មានន័យដូចគ្នានេះ ។ កាលភិក្ខុឱ្យផ្លែស្វាយទុំជាដើមដែលគេកំណត់ទុក ដើម្បីប្រយោជន៍ដល់សេនាសនៈ ដើម្បីត្រូវការដល់ការសង្គ្រោះត្រកូល ជាអាបត្តិទុក្កដ, កាលឱ្យព្រោះសេចក្តីដែលខ្លួនមានឥស្សរៈ ជាថុល្លច្ច័យ, កាលឱ្យដោយថេយ្យចិត្ត ជាអាបត្តិបារាជិក ។ បើវត្ថុនៃបារាជិកមិនល្មម, គប្បីពិន័យអាបត្តិតាមតម្លៃ (វត្ថុ) ។ កាលភិក្ខុនោះឆាន់នៅខាងក្រៅឧបចារសីមា ព្រោះសេចក្តីដែលខ្លួនមានឥស្សរៈ ក៏ជាសំណង ។ ផ្លែឈើដែលភិក្ខុគោះរគាំងប្រកាសវេលា ហើយទំពាឆាន់ដោយធ្វើទុកក្នុងចិត្តថា របស់នេះត្រូវបានដល់យើង ដូច្នេះ ក៏ជាការទំពាឆាន់ល្អហើយ ។ ផ្លែឈើដែលភិក្ខុមិនគោះរគាំង ត្រឹមតែប្រកាសវេលាតែម្យ៉ាងហើយ ឆាន់ក្តី គោះរគាំងតែម្យ៉ាង តែមិនប្រកាសវេលា ឆាន់ក្តី សូម្បីរគាំងក៏មិនបានគោះ សូម្បីវេលាក៏មិនបានប្រកាស ឆាន់ក្តី ដឹងថា មិនមានភិក្ខុពួកដទៃហើយ ឆាន់ដោយគិតថា "ផ្លែឈើនេះត្រូវបានដល់យើង" ដូច្នេះក្តី ជាការឆាន់ល្អហើយដូចគ្នា ។

[១៥០] រឿងសួនផ្កាឈើ ២ រឿង ប្រាកដច្បាស់ហើយតែម្តង ។

[១៥១] ក្នុងរឿងទាំង ៣ របស់ភិក្ខុដែលនិយាយតាមពាក្យប្រាប់មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា វុត្តោ វជ្ជេមិ ៖ លោកផ្តាំនឹងខ្ញុំហើយ ខ្ញុំនឹងទៅប្រាប់

សេចក្ដីថា ខ្ញុំព្រះករុណាជាអ្នកដែលលោកប្រាប់ហើយនឹងប្រាប់តាមពាក្យរបស់លោក ។

ប្រើនបទថា អនាបត្តិ ភិក្ខុ ឞារាជិកស្ស : ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ សេចក្ដីថា សំពត់សាដកដែលពួកម្ចាស់របស់ប្រគេនហើយ ទើបមិនត្រូវអាបត្តិ ។

ប្រើនបទថា ន ច ភិក្ខវេ វុត្តោ វជ្ជេមីតិ វត្តព្វោ : ម្នាលភិក្ខុទាំងឡាយ តែភិក្ខុកុំគប្បីពោលថា អ្នកផ្ដាំនឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ សេចក្ដីថា ភិក្ខុដទៃ ដែលភិក្ខុមួយរូបទៀត មិនគប្បីពោលយ៉ាងនេះថា ខ្ញុំព្រះករុណាជាអ្នកដែលលោកប្រាប់ហើយ នឹងប្រាប់តាមពាក្យរបស់លោក ។ ក៏ភិក្ខុនឹងធ្វើសេចក្ដីកំណត់និយាយថា ខ្ញុំព្រះករុណានឹងកាន់យករបស់ឈ្មោះនេះ តាមពាក្យរបស់លោក គួរ ។

ពីរបទថា វុត្តោ វជ្ជេហិ : លោកផ្ដាំនឹងខ្ញុំហើយ ខ្ញុំនឹងប្រាប់ចុះ សេចក្ដីថា លោកជាអ្នកដែលខ្ញុំព្រះករុណាប្រាប់ហើយចូរប្រាប់តាមពាក្យរបស់ខ្ញុំព្រះករុណា ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។ ភិក្ខុនឹងធ្វើសេចក្ដីកំណត់និយាយក្នុង២ រឿងសូម្បីនេះ ក៏គួរ ។ ពិតមែនភិក្ខុរមែងជាអ្នកផុតពីការតិះដៀល ដោយហេតុត្រឹមតែប៉ុណ្ណោះឯង ។

[១៥២] ក្នុងរឿងកណ្ដាល ( គឺរឿងទី២ )នៃរឿងកែវមណី ៣

រឿង មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា ឆាយាំ អកាលូកោ : ខ្ញុំមិនឈឺទេ សេចក្តីថា ខ្ញុំមិនមែនជាអ្នកមានជម្ងឺទេ ។ ពាក្យដ៏សេសប្រាកដច្បាស់ហើយតែម្តង ។

[១៥៣] ក្នុងរឿងភិក្ខុ២រូប ដោះលែងជ្រូក គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ឈ្មោះថា មិនជាអាបត្តិដល់ភិក្ខុទីមួយ ព្រោះលោកឃើញថា វាមានសេចក្តីឃ្លានបៀតបៀន ហើយដោះលែងទៅដោយភាពជាអ្នកមានករុណា ក៏ពិតមែនហើយ តែថា កាលពួកម្ចាស់របស់មិនយល់ព្រម ក៏ជាភណ្ឌទេយ្យ, គួរទឹងនាំជ្រូកដែលស្លាប់ ដែលធំប៉ុណ្ណោះមកសង ឬឱ្យវត្ថុដែលមានតម្លៃប៉ុនជ្រូក ក៏បាន ។ បើលោកមិនឃើញពួកម្ចាស់របស់ អន្ទាក់សូម្បីក្នុងទីណា ៗ គប្បីដាក់សំពត់សាដក ឬថាសដែលមានតម្លៃប៉ុនជ្រូកនោះ ទុកជិត ៗអន្ទាក់ក្នុងទីដែលពួកម្ចាស់របស់មកហើយអាចឃើញបាន ហើយសឹមចេញទៅ ។ តែជាបារាជិកដល់ភិក្ខុដែលដោះលែងទៅដោយថេយ្យចិត្តពិត ។ ក៏បណ្តាជ្រូកទាំងនេះ ជ្រូកខ្លះយកជើងទាញអន្ទាក់ ល្មមអន្ទាក់ដាច់ហើយឈរដោយការឈរ ដែលមានការឱ្យឃ្លាតចាកឋានបានជាធម្មតា ដូចទូកដែលចងទុកត្រង់ក្រសែទឹកហូរដូច្នោះ ជ្រូកខ្លះឈរតាមធម្មតារបស់ខ្លួន, ជ្រូកខ្លះដេក, ជ្រូកខ្លះជាសត្វជាប់អន្ទាក់

ហើយ ៗ ដែលឈ្មោះថា អន្ទាក់កោង បានដល់ អន្ទាក់ដែលមានឈើដងធ្នូតូច ឬទំពក់ ឬកំណាត់ឈើដទៃយ៉ាងណាមួយ ជាប់ត្រង់ចុង, និងជាអន្ទាក់ដែលប្រដាប់ទុកត្រង់ដើមឈើជាដើម ក្នុងទីនោះ ៗ ការពារមិនឱ្យជ្រូកដើរទៅបាន ។ ក្នុងជ្រូកទាំងនោះជ្រូកដែលទាញអន្ទាក់ឈរ មានឋានតែមួយប៉ុណ្ណោះ គឺ ទីចងអន្ទាក់ ។ ពិតមែន ជ្រូកនោះកាលអន្ទាក់របូត ឬល្មមអន្ទាក់ដាច់ រមែងចៀសចេញទៅបាន ។ ជ្រូកដែលឈរតាមធម្មតារបស់ខ្លួនមានឋាន ៥ គឺ ចំណង ១ និងជើងទាំង ៤ ។ ជ្រូកដែលដេក មានឋាន ២ គឺ ចំណង ១ ទីដេក ១ ។ ជ្រូកដែលជាប់អន្ទាក់ វាទៅក្នុងទីណា ៗ ទីនោះ ៗ ឯងជាឋាន ។ ព្រោះហេតុនោះ ភិក្ខុ ១០ រូបក្តី ២០ រូបក្តី ១០០ រូបក្តី កាលដោះលែងជ្រូកនោះឱ្យផុតទៅចាកឋាននោះ ៗ រមែងត្រូវបារាជិក ដូចភិក្ខុច្រើនរូប ឃើញទាសម្នាក់ប៉ុណ្ណោះមកហើយក្នុងទីនោះ ៗ ហើយឱ្យចៀសចេញទៅ ត្រូវបារាជិក ដូច្នោះ ។ ចំណែកការញុំាងជ្រូកទាំង ៣ ខាងដើម ឱ្យបម្រាសទៅ និងឱ្យឃ្លាតចាកឋាន គប្បីជ្រាបតាមន័យដែលពោលទុកហើយ ក្នុងការពោលអំពីសត្វជើង ៤ ។ សូម្បីកាលភិក្ខុឱ្យដោះលែងជ្រូកដែលស៊ុនខទាំទៅដោយការជួយសង្គ្រោះ ជាភណ្ឌទេយ្យ, ដោយថេយ្យចិត្ត ជាបារាជិក ។ តែមិនជាអវហារ ដល់ភិក្ខុដែលធ្វើដំណើរតាមមកទៅ

ហើយញាំងជ្រូកដែលមិនទាន់ដល់ទីតាំងអន្ទាក់ ឬទីជិតសុនខ ឱ្យចៀសចេញទៅមុន ។ សូម្បីភិក្ខុណា ឱ្យចំណីនិងទឹកដល់ជ្រូកដែលជាប់ហើយឱ្យវាបានកម្លាំងហើយធ្វើការស្រែកបន្លើល ដោយតាំងចិត្តថា "វានឹងតក់ស្លុត ហើយចៀសចេញទៅ", បើវាចៀសចេញទៅ ភិក្ខុនោះ ត្រូវបារាជិក ។ សូម្បីកាលភិក្ខុធ្វើអន្ទាក់ឱ្យទ្រុឌទ្រោម ហើយដេញឱ្យចៀសទៅ ដោយសំឡេងស្រែកបន្លើល ក៏មានន័យដូចគ្នានេះ ។ ចំណែកភិក្ខុណា ឱ្យចំណីនិងទឹកហើយចេញទៅ ដោយធ្វើទុកក្នុងចិត្តថា "វានឹងបានកម្លាំងហើយចៀសចេញទៅ", បើវាចៀសចេញទៅ, ជាភណ្ឌទេយ្យដល់ភិក្ខុនោះ ។ សូម្បីកាលភិក្ខុធ្វើអន្ទាក់ឱ្យទ្រុឌទ្រោមហើយចេញទៅ ក៏មានន័យដូចគ្នានេះ ។ ភិក្ខុដាក់កាំបិត ឬបង្កាត់ភ្លើងទុកជិតអន្ទាក់ ដោយគិតថា "កាលអន្ទាក់ត្រូវកាំបិតកាត់ដាច់ ឬត្រូវភ្លើងឆេះ វានឹងចៀសចេញឯង" ជាភណ្ឌទេយ្យដល់ភិក្ខុនោះដោយពិត ។ ភិក្ខុធ្វើឱ្យអន្ទាក់ព្រមទាំងជន្លួលចុះ, ខាងក្រោយជ្រូកដើរជាន់អន្ទាក់នោះចេញទៅ ជាភណ្ឌទេយ្យ ។ ជ្រូកជាសត្វត្រូវអន្លប់ទាំងឡាយសង្កត់ហើយ កាលភិក្ខុប្រាថ្នានឹងឱ្យជ្រូកនោះចៀសចេញទៅ ទើបលើកអន្លប់ឡើងដោយសេចក្ដីករុណា ជាភណ្ឌទេយ្យ, លើកឡើងដោយថេយ្យចិត្ត ជាបារាជិក ។ បើកាលអន្លប់នោះ ល្មមភិក្ខុលើកឡើងហើយ ជ្រូកមិនទាន់ទៅ ខាងក្រោយ

ទើបទៅ, ជាភណ្ឌទេយ្យប៉ុណ្ណោះ ។ ភិក្ខុញាំងអន្ទប់ដែលគេលើកឡើងតាំងទុក ឱ្យធ្លាក់ចុះ, ខាងក្រោយជ្រូកជាន់អន្ទប់នោះ គេចចេញទៅ ជាភណ្ឌទេយ្យ ។ កាលភិក្ខុជួយលើកឡើង សូម្បីនូវជ្រូកដែលធ្លាក់រណ្តៅហើយ ដោយសេចក្តីករុណា ជាភណ្ឌទេយ្យ, លើកឡើងដោយថេយ្យចិត្ត ជាបារាជិក ។ ភិក្ខុញាំងរណ្តៅឱ្យពេញ ឱ្យប្រើមិនបាន, ខាងក្រោយជ្រូកដើរជាន់រណ្តៅនោះគេចចេញទៅ ជាភណ្ឌទេយ្យ ។ ភិក្ខុជួយលើកជ្រូកដែលត្រូវចម្រូងចាក់ហើយ ដោយសេចក្តីករុណា ជាភណ្ឌទេយ្យ, លើកឡើងដោយថេយ្យចិត្ត ជាបារាជិក ។ ភិក្ខុដកចម្រូងចេញ ជាភណ្ឌទេយ្យ ។

មួយទៀត កាលពួកអ្នកស្រុកដាក់អន្ទាក់ ឬអន្ទប់ទុកក្នុងផ្ទៃដីវត្ត ភិក្ខុគួរហាមថា ទីនេះជាស្ថានទីនៅអាស្រ័យរបស់ពួកម្រឹគ, ពួកលោកកុំធ្វើយ៉ាងនេះក្នុងទីនេះឡើយ បើពួកគេពោលថា "លោកម្ចាស់ចូរឱ្យនាំចេញទៅ" ភិក្ខុនឹងឱ្យនាំចេញទៅ ក៏គួរ ។ បើគេនាំចេញទៅដោយខ្លួនឯង ជាសេចក្តីល្អពិត ។ បើម្ចាស់របស់គេមិននាំចេញទៅដោយខ្លួនឯងទាំងមិនព្រមឱ្យអ្នកដទៃនាំចេញទេ, នឹងសូមការរក្សា ហើយឱ្យនាំចេញក៏គួរ ។ ក្នុងវេលារក្សាសន្ទូង ពួកអ្នកស្រុក រមែងធ្វើអន្ទាក់ និងគ្រឿងដាក់សត្វទាំងឡាយ មានអន្ទប់ជាដើម ទុកក្នុងស្រែ ដោយនិយាយថា

“ពួកយើងនឹងរក្សាសន្ទូងផង ស៊ីសាច់ម្រឹគផង” ។ គ្រារដូវសន្ទូងកន្លងទៅហើយ ពួកគេមិនមានសេចក្តីអាល័យចៀសទៅ ភិក្ខុនឹងដោះលែងជ្រូកដែលជាប់ ឬធ្លាក់ហើយ ក្នុងអន្ទាក់និងអន្លង់ជាដើមនោះគួរ ។

សូម្បីការវិនិច្ឆ័យក្នុងរឿងភិក្ខុ ២ រូបដោះលែងម្រឹគ ក៏ដូចគ្នានឹងដែលពោលទុកហើយក្នុងរឿងភិក្ខុដោះលែងជ្រូកនុ៎ះឯង ។ សូម្បីក្នុងរឿងភិក្ខុ ២ រូបដោះលែងត្រី ក៏មានន័យដូចគ្នានេះ ។

ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះ ៖

កាលភិក្ខុបើកមាត់ទ្រូចេញ ខាងក្រោយទើបស្រោយសន្ទុះចេញ ឬធ្វើជាប្រហោងទុកត្រង់ខាង ៗ និងគោះឱ្យត្រីហែលចេញទៅអំពីទ្រូ ជាបារាជិក ។ ជាបារាជិកដល់ភិក្ខុដែលសម្តែងគ្រាប់បាយនុ៎ះឯង ហើយបញ្ឆោតត្រីឱ្យគេចទៅ ។ កាលលើកត្រីឡើងព្រមទាំងទ្រូ ក៏ជាបារាជិក ។ ភិក្ខុបើកមាត់ទ្រូចេញតែម៉្យាង ខាងក្រោយទើបស្រោយសន្ទុះចេញ ឬធ្វើជាប្រហោងទុក, និងត្រីទាំងឡាយក៏ចៀសចេញទៅតាមធម្មតារបស់ខ្លួន, ជាភណ្ឌទេយ្យ ។ ភិក្ខុធ្វើទុកយ៉ាងនេះហើយ ទើបសម្តែងគ្រាប់បាយបញ្ឆោត ត្រីទាំងឡាយចៀសចេញទៅ ដើម្បីត្រូវការអាហារ, ជាភណ្ឌទេយ្យដូចគ្នា ។ ភិក្ខុបើកមាត់ (ទ្រូ) ចេញហើយ ខាងក្រោយមិនបានស្រោយសន្ទុះចេញ ទាំងមិនបានធ្វើជាប្រហោងទុកត្រង់ខាង ៗ សម្តែង

តែគ្រាប់បាយបញ្ឆោតតែម៉្យាង, ចំណែកត្រីទាំងឡាយ ព្រោះត្រូវសេចក្តីឃ្លានបៀតបៀន ទើបយកក្បាលបំពុកទ្រូងធ្វើប្រហោងហើយ ចៀសចេញទៅ ដើម្បីត្រូវការអាហារ, ជាភណ្ឌទេយ្យដូចគ្នា ។ ភិក្ខុបើកមាត់ទ្រូងទេទុក ឬខាងក្រោយស្រាយសន្ទុះចេញ ឬធ្វើជាប្រហោងទុក, ត្រីទាំងឡាយដែលហែលមកហើយ ៗ ដល់ទ្វារហើយក៏ចៀសចេញទៅតាមមកសន្ទុះនិងប្រហោង, ជាភណ្ឌទេយ្យដូចគ្នា ។ ភិក្ខុចាប់ទ្រូងទេបោះទៅទុកលើគុម្ពឈើ ជាភណ្ឌទេយ្យដូចគ្នា ដូច្នេះឯង ។

[១៥៤] រឿងទ្រព្យនៅក្នុងយាន ក៏ដូចគ្នានឹងថង់យាមនៅលើតាំង[១] ។

[១៥៥-៨] ក្នុងរឿងដុំសាច់ មានវិនិច្ឆ័យដូច្នេះ ៖

បើភិក្ខុចាប់យកដុំសាច់ក្នុងអាកាស ទីដែលភិក្ខុចាប់យកនុ៎ះឯង ជាឋាន ។ គប្បីកំណត់ឋាននោះ ដោយអាការ ៦ ហើយជ្រាបការឱ្យឃ្លាតចាកឋាន ។ ពាក្យដ៏សេសក្នុងរឿងដុំសាច់នេះ និងក្នុងរឿងក្បូនជាច់ រឿងបុរសគង្វាលគោ នឹងរឿងសំពត់សាដករបស់ជាងជ្រលក់ គប្បីវិនិច្ឆ័យដោយន័យនៃរឿង មានរឿងពួកចោរលួចស្វាយជាដើម ។

[១៥៩] ក្នុងរឿងឆ្នាំង មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណាកាន់យកទឹកដោះថ្លានិងប្រេងជាដើមដែលមានតម្លៃមិនដល់ ១ បាទ ដោយធ្វើទុកក្នុងចិត្តថា "យើងនឹងមិនធ្វើយ៉ាងនេះទៀត" តាំង

នៅក្នុងសំវរៈសូម្បីក្នុងថ្ងៃទីពីរជាដើម កាលកើតគំនិតឡើងទៀត ក៏ធ្វើការដាក់ធុរៈដូចយ៉ាងនោះឯង ខណៈឆាន់ក៏ឆាន់ទឹកដោះថ្លា និងប្រេងជាដើមនោះសូម្បីទាំងអស់, មិនជាបារាជិកឡើយ, លោករមែងត្រូវទុក្កដឬថុល្លច្ច័យ និងជាភណ្ឌទេយ្យផង ។ សូម្បីភិក្ខុនេះ ក៏បានធ្វើយ៉ាងនោះ

---

១. ក្នុង[១៤១] ។

ដូចគ្នា ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុ អ្នកមិនត្រូវអាបត្តិបារាជិកទេ" ។ ក៏កាលភិក្ខុមិនធ្វើការដាក់ធុរៈតែឆាន់ទឹកដោះថ្លានិងប្រេងជាដើមនោះ សូម្បីម្តងបន្តិច ៗ ដោយតាំងចិត្តថា យើងនឹងឆាន់រាល់ថ្ងៃ ៗ ដូច្នេះ, ក្នុងថ្ងៃណាមានតម្លៃពេញមួយបាទ, ក្នុងថ្ងៃនោះជាបារាជិក ។

[១៦០] រឿងភិក្ខុបបួលគ្នាលួច គប្បីជ្រាបតាមន័យនៃការវិនិច្ឆ័យដែលពោលហើយក្នុងសំវិធាវហារ ។

[១៦១] រឿងភិក្ខុលួចអង្ករ១ក្តាប់ គប្បីជ្រាបតាមន័យនៃការវិនិច្ឆ័យដែលពោលហើយក្នុងរឿងទាំងឡាយ មានរឿងផ្ទុះលក់បាយជាដើម,

[១៦២] រឿងភិក្ខុ ២ ពួកបង្សុកូលសាច់ដែលពួកចោរទុកក្នុងព្រៃអន្ធវន គប្បីជ្រាបតាមន័យនៃការវិនិច្ឆ័យដែលពោលហើយ ក្នុងរឿងទាំងឡាយ មានរឿងចោរលួចស្វាយជាដើម ។

[១៦៣-៤] រឿងភិក្ខុ ២ រូបលួចស្មៅគេ មានសេចក្តីងាយយល់ទាំងអស់ ។

[១៦៥] ក្នុងរឿងទាំងឡាយ មានរឿងឱ្យបែងចែកស្វាយជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុទាំងនោះ បានទៅកាន់អាវាសជិតស្រុកមួយ ដែលមានកំណត់ចំនួនភិក្ខុទុក ។ ពួកភិក្ខុដែលនៅក្នុងអាវាសនោះឯង សូម្បីកាលទឹងឆាន់ផ្លែឈើតូចធំ ក្នុងកាលភិក្ខុអាគន្តុកៈទាំងនោះមកហើយ មិនបានប្រាប់កប្បិយការកថា "ពួកលោកចូរប្រគេនផ្លែឈើ ដល់ព្រះថេរៈទាំងឡាយ" ។ លំដាប់នោះ ភិក្ខុទាំងនោះ ទើបពោលថា "ស្វាយរបស់សង្ឃ មិនត្រូវបានដល់ពួកខ្ញុំព្រះករុណាឬ" ? ទើបឱ្យគោះរគាំងចែកគ្នា បានប្រគេនចំណែកដល់អាវាសិកភិក្ខុសូម្បីទាំងនោះ តាមលំដាប់វស្សា សូម្បីខ្លួនឯងក៏ឆាន់ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ដល់ភិក្ខុអាគន្តុកៈទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលប្រាថ្នាដើម្បីទឹងបរិភោគទេ" ។ ព្រោះហេតុនោះ ឥឡូវនេះ ក្នុងអាវាសណា ភិក្ខុម្ចាស់អាវាសមិនប្រគេនដល់ពួកភិក្ខុអាគន្តុកៈ និងកាលដល់វេរផ្លែឈើឃើញថា "ភិក្ខុអាគន្តុកៈពួកដទៃមិនមាន" ខ្លួនឯងក៏ឆាន់ ដោយកិរិយាដែលជាចោរ, ការដែលពួកភិក្ខុអាគន្តុកៈគោះរគាំងឡើងហើយ ចែកគ្នា

ឆាន់ក្នុងអាវាសដូច្នោះ រមែងគួរ ។ ចំណែកក្នុងដើមឈើណា ពួកភិក្ខុអាវាសិកៈរក្សាដើមឈើទាំងឡាយ កាលដល់រដូវផ្លែឈើ ក៏ចែកគ្នាឆាន់ហើយបង្អោនទៅក្នុងបច្ច័យ ៤ ដោយប្រពៃ, ពួកភិក្ខុអាគន្តុកៈ មិនជាឥស្សរៈក្នុងដើមឈើនោះ ។ សូម្បីដើមឈើពួកណា ដែលទាយកកំណត់ប្រគេនទុក ដើម្បីប្រយោជន៍ដល់ចីវរ, ពួកភិក្ខុអាគន្តុកៈ មិនជាឥស្សរៈក្នុងដើមឈើសូម្បីទាំងនោះ ។ សូម្បីក្នុងដើមឈើទាំងឡាយដែលទាយកកំណត់ប្រគេនទុក ដើម្បីប្រយោជន៍ដល់បច្ច័យដ៏សេស ក៏មានន័យដូចគ្នានេះ ។ ចំណែកដើមឈើពួកណា ដែលទាយកមិនបានកំណត់ទុកយ៉ាងនោះ និងពួកអាវាសិកភិក្ខុ ក៏រក្សាឃុំគ្រងដើមឈើទាំងនោះទុក ទាំងឆាន់ដោយកិរិយាជាចោរ[១], ក្នុងដើមឈើទាំងនោះ ភិក្ខុអាគន្តុកៈទាំងឡាយ មិនគួរតាំងនៅក្នុងកតិកា របស់ពួកអាវាសិកភិក្ខុ ។ ដើមឈើពួកណា ដែលទាយកប្រគេនទុកដើម្បីឱ្យជាប្រយោជន៍ដល់ការបរិភោគផ្លែ និងពួកអាវាសិកភិក្ខុ ក៏រក្សាដើមឈើទាំងនោះទុក ហើយបង្អោនទៅដោយប្រពៃ, ក្នុងដើមឈើទាំងនោះឯង ភិក្ខុអាគន្តុកៈទាំងឡាយ គួរតាំងនៅក្នុងកតិការបស់ពួកអាវាសិកភិក្ខុទាំងនោះ ។

ឯក្នុងមហាបច្ចរី លោកពោលទុកថា ភិក្ខុកាលឆាន់ផ្លែឈើ ដែលទាយកកំណត់ប្រគេនទុកដើម្បីបច្ច័យ ៤ ដោយថេយ្យចិត្ត គប្បីឱ្យវាយ

តម្លៃវត្ថុពិន័យអាបត្តិ, កាលចែកគ្នាឆាន់ដោយអំណាចការបរិភោគ ជាភណ្ឌទេយ្យ, ក៏បណ្តាផ្លែឈើទាំងនេះ កាលភិក្ខុចែកគ្នាឆាន់ផ្លែឈើដែលទាយកកំណត់ទុក ដើម្បីប្រយោជន៍ដល់សេនាសនៈ ដោយអំណាចការបរិភោគ ជាថុល្លច្ច័យផង ជាភណ្ឌទេយ្យផង ។

---

១. អត្ថយោជនា. បើប្រយោគនេះថា "នេវ រក្ខិត្វា ន គោបិត្វា ចោរិកាយ បរិភុញ្ជន្តិ : ទាំងមិនរក្សាមិនឃុំគ្រងដើមឈើទាំងនោះហើយ ទាំងឆាន់ដោយកិរិយាជាចោរ" សមជាង ។

ផ្លែឈើដែលទាយកឧទ្ទិសប្រគេនទុកដើម្បីប្រយោជន៍ដល់ចីវរ គួរបង្អោនចូលទៅក្នុងចីវរប៉ុណ្ណោះ ។ បើមានភិក្ខារកបានដោយលំបាក, ភិក្ខុទាំងឡាយ រមែងលំបាកដោយបិណ្ឌបាត, ចំណែកចីវររកបានងាយ; ទឹងធ្វើអបលោកនកម្ម ដើម្បីសេចក្តីឃើញប្រពៃនៃសង្ឃហើយបង្អោនចូលទៅក្នុងបិណ្ឌបាត ក៏គួរ ។ កាលភិក្ខុទាំងឡាយលំបាកដោយសេនាសនៈ ឬគិលានបច្ច័យ ទឹងធ្វើអបលោកនកម្មដើម្បីសេចក្តីឃើញប្រពៃនៃសង្ឃ ហើយបង្អោនចូលទៅដើម្បីប្រយោជន៍ដល់សេនាសនៈ និងគិលានប្បច្ច័យនោះ ក៏គួរ ។ សូម្បីក្នុងផ្លែឈើដែលទាយកឧទ្ទិសប្រគេនទុក ដើម្បីប្រយោជន៍ដល់បិណ្ឌបាត និងដើម្បីប្រយោជន៍ដល់គិលានបច្ច័យ ក៏មានន័យដូចគ្នានេះ ។ ចំណែកផ្លែឈើដែលទាយកឧទ្ទិសប្រគេនទុក ដើម្បីប្រយោជន៍ដល់សេនាសនៈជាគរុភណ្ឌ គួររក្សាវត្ថុ

នោះទុក ហើយបង្អោនចូលទៅដើម្បីប្រយោជន៍ដល់សេនាសនៈនោះ ប៉ុណ្ណោះ ។ ក៏បើមានភិក្ខារកបានដោយលំបាក, ភិក្ខុទាំងឡាយ ទឹងញ៉ាំង អត្តភាពឱ្យប្រព្រឹត្តទៅដោយបិណ្ឌបាតមិនបាន, ក្នុងវត្ថុបុរដ្ឋនេះ វិហារ របស់ពួកភិក្ខុដែលកៀសខ្លួនទៅក្នុងទីដទៃ ព្រោះរាជភ័យ រោគភ័យ និង ចោរភ័យជាដើម រមែងទ្រុឌទ្រោមទៅ, ជនពួកដទៃ រមែងធ្វើដើមត្នោត និង ដើមដូងជាដើម ឱ្យវិនាសទៅ, ចំណែកភិក្ខុអាស្រ័យសេនាសនៈ បច្ច័យហើយ រមែងអាចញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបាន, ក្នុងកាល បែបនេះ សូម្បីចំណាយសេនាសនៈហើយបរិភោគ ដើម្បីប្រយោជន៍ដល់ ការរក្សាសេនាសនៈ ព្រះមានព្រះភាគទ្រង់អនុញ្ញាតទុកហើយ ។ ព្រោះ ដូច្នោះ វៀរសេនាសនៈដែលល្អទុក មួយខ្នង ឬពីរខ្នង សេនាសនៈក្រៅ នេះ ចាប់តាំងពីសេនាសនៈអាក្រក់ ទឹងចំណាយដើម្បីប្រយោជន៍ដល់ បិណ្ឌបាត ក៏គួរ, តែមិនគួរបង្អោនចូលទៅដោយធ្វើឱ្យដាច់មូលដើម ។ ចំណែកក្នុងសួនដែលទាយកកំណត់ប្រគេនដើម្បីប្រយោជន៍ដល់បច្ច័យ ៤ មិនគួរធ្វើអបលោកនកម្ម, តែទឹងបង្អោនចូលទៅដើម្បីប្រយោជន៍ដល់ បច្ច័យដែលនៅខ្វះខាត រមែងសមគួរ ។ គួររក្សាសួនទុក, សូម្បីទឹងឱ្យ ប្រាក់ឈ្នួលទៅអ្នករក្សាទុក ក៏គួរ ។ ចំណែកជនពួកណាបានទទួលប្រាក់ ឈ្នួល សាងផ្ទះនៅរក្សាក្នុងសួនទុំះឯង ។ បើជនទាំងនោះប្រគេនដូង ឬ

ផ្លែត្នោតទុំដល់ភិក្ខុទាំងឡាយដែលមកហើយ ។ ជនអ្នករក្សាសួនទាំងនោះ រមែងបានដើម្បីប្រគេនតែផ្លែឈើ ដែលសង្ឃអនុញ្ញាតិដល់ពួកគេថា "ពួកលោកនឹងស៊ីផ្លែឈើមានប្រមាណប៉ុណ្ណោះបានរាល់ថ្ងៃ" ដូច្នេះ ។ ការដែលភិក្ខុទទួលយកផ្លែឈើរបស់ជនទាំងនោះ សូម្បីអ្នកប្រគេនច្រើនក្រៃលែងឡើងទៅ ជាងផ្លែឈើដែលសង្ឃអនុញ្ញាតនោះ រមែងមិនគួរ ។ ចំណែកអ្នកណាទិញយកសួនហើយ រមែងប្រគេនតែកប្បិយភណ្ឌៈប៉ុណ្ណោះដល់សង្ឃ ដើម្បីប្រយោជន៍ដល់បច្ច័យ ៤, អ្នកនេះរមែងបានដើម្បីប្រគេនផ្លែឈើសូម្បីច្រើន ។ សូម្បីសួនដែលទាយកប្រគេនទុកដល់ព្រះចេតិយ ដើម្បីប្រយោជន៍ដល់ប្រទីប ឬ ដើម្បីត្រូវការជួសជុលវត្ថុដែលទ្រុឌទ្រោមបែកបាក់ សង្ឃគួររក្សាទុក, ទោះជាឱ្យប្រាក់ឈ្នួលទៅខ្លះ ក៏គួរឱ្យរក្សាទុក ។ ក៏ឯក្នុងសួនដែលទាយកប្រគេនទុកដល់ព្រះចេតិយនេះ នឹងឱ្យប្រាក់ឈ្នួលដែលជារបស់ចេតិយខ្លះ ដែលជារបស់សង្ឃខ្លះ គួរ ។

[១៦៦] ការប្រគេនផ្លែឈើដែលកើតឡើងក្នុងសួននោះ (ដល់ភិក្ខុទាំងឡាយដែលមកហើយ ៗ) របស់ពួកជនដែលនៅក្នុងសួននោះ ដោយប្រាក់ឈ្នួល និងរបស់ពួកជនអ្នកទិញយកសួននោះ ហើយប្រគេនតែកប្បិយភណ្ឌៈ (ដល់សង្ឃ) គប្បីជ្រាបដោយន័យដូចដែលពោល

ហើយនោះឯង ។

ក្នុងពាក្យនេះថា "ម្នាលភិក្ខុទាំងឡាយ បើទានដែលបុគ្គលអ្នករក្សាគេឱ្យហើយ (ភិក្ខុអ្នកទទួល) មិនត្រូវអាបត្តិឡើយ" ដែលមាននៅក្នុងរឿងទាំងឡាយ មានរឿងអ្នករក្សាស្វាយជាដើម មានវិនិច្ឆ័យដូច្នេះ ៖

សួរថា អ្នករក្សាប្រគេនយ៉ាងណា ទើបគួរ ? ប្រគេនយ៉ាងណាមិនគួរ ?

ឆ្លើយថា ព្រះមហាសុមត្ថេរពោលទុកមុនថា ផ្លែឈើណា ដែលអ្នករក្សាកំណត់ប្រគេនដោយពាក្យថា "លោកម្ចាស់ចូរកាន់យកផ្លែឈើមានប្រមាណប៉ុណ្ណេះ រាល់ថ្ងៃ ៗ" ផ្លែឈើនោះឯង រមែងគួរ, គេប្រគេនច្រើនជាងនោះទៅ មិនគួរ ។ ចំណែកព្រះមហាបទុមត្ថេរពោលទុកថា ផ្លែឈើដែលពួកអ្នករក្សាសរសេរសំបុត្រទុក ឬធ្វើសញ្ញាគ្រឿងសម្គាល់ ឱ្យដល់ពួកអ្នករក្សា និងមានប្រយោជន៍អ្វី ? អ្នករក្សាទាំងនោះក៏ជាឥស្សរៈនៃផ្លែឈើដែលគេលះបង់ហើយក្នុងដៃរបស់ពួកគេ; ព្រោះហេតុនោះ ផ្លែឈើដែលអ្នករក្សាទាំងនោះប្រគេនសូម្បីច្រើនក៏គួរ ។

ចំណែកក្នុងអដ្ឋកថាកុរុន្ទីលោកពោលថា ពួកក្មេង ៗរបស់មនុស្សទាំងឡាយ រមែងរក្សាសួន ឬផ្លែឈើតូចធំយ៉ាងដទៃទុក, ផ្លែឈើដែលពួកក្មេងទាំងនោះប្រគេន រមែងគួរ, តែភិក្ខុមិនគួរប្រើឱ្យពួកក្មេងទាំងនោះ

នាំមកហើយ ទើបទទួល, ការប្រគេនផ្លែឈើរបស់ជនអ្នកកាន់យកសួនរបស់សង្ឃ និងរបស់ចេតិយដោយការទិញ រមែងគួរ, ការប្រគេនរបស់ជនអ្នករក្សាដោយប្រាក់ឈ្នួលត្រឹមតែចំណែករបស់ខ្លួន ទើបគួរ ។

ក្នុងមហាបច្ចរីលោកពោលថា ពួកអ្នករក្សាសួនរបស់គ្រហស្ថប្រគេនផ្លែឈើណាដល់ភិក្ខុទាំងឡាយ, ផ្លែឈើនោះ រមែងគួរ, ពួកអ្នករក្សាសួនរបស់ភិក្ខុសង្ឃចែកចំណែកផ្លែឈើណាអំពីតម្លៃឈ្នួលរបស់ខ្លួនប្រគេន, ផ្លែឈើនោះក៏សមគួរ, សម្បូរអ្នកណា បានទទួលតម្លៃឈ្នួលហើយ ទើបរក្សាសួនត្រឹមតែពាក់កណ្ដាល ឬ ដើមឈើប្រភេទខ្លះប៉ុណ្ណោះ, ការប្រគេនផ្លែឈើអំពីដើមដែលត្រូវបានដល់ខ្លួនទុំះឯង សម្បូររបស់អ្នកនោះ ក៏គួរ, តែសម្រាប់អ្នកកាន់យកដោយការទិញ និងប្រគេនផ្លែឈើសម្បូរទាំងអស់ ក៏គួរ ។ ក៏ពាក្យដែលលោកពោលមកទាំងអស់នេះផ្សេងគ្នាដោយព្យញ្ជនៈ តែដូចគ្នាដោយអត្ថទុំះឯង, ព្រោះដូច្នោះអ្នកសិក្សាគួរជ្រាបសេចក្ដីអធិប្បាយហើយ ទើបកាន់យក ។

[១៦៧] ក្នុងរឿងភិក្ខុខ្ចីឈើរបស់សង្ឃ មានវិនិច្ឆ័យដូច្នេះ ៖

ច្រើនបទថា **តាវកាលិកោ អហំ ភគវា :** បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គតាំងថា ជារបស់ខ្ចី សេចក្ដីថា ភិក្ខុនោះ ប្រាថ្នានឹងក្រាបទូលថា "តាវកាលិកចិត្តោ អហំ ភគវា : បពិត្រព្រះអង្គ

ដ៏ចម្រើន ខ្ញុំព្រះអង្គមានចិត្តគិតនឹងខ្ចី" ដូច្នេះ ទើបបានក្រាបទូលយ៉ាងនេះ ។ ពាក្យថា **តាវកាលិកចិត្តោ** នេះ មានពាក្យអធិប្បាយទុកថា ខ្ញុំព្រះអង្គមានគំនិតយ៉ាងនេះថា នឹងនាំយកមកសងសង្ឃវិញ ។ ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុ បើកាន់យកជារបស់ខ្ចីដូច្នោះ អ្នកមិនមានអាបត្តិឡើយ" ។

ក៏ក្នុងរឿងឈើនេះ មានវិនិច្ឆ័យដែលផុតពីបាលី ដូចតទៅនេះ ៖

បើសង្ឃប្រើឱ្យភិក្ខុធ្វើការងាររបស់សង្ឃ នឹងជារោងឧបោសថ ឬបន្ទប់ឆាន់ក៏ដោយ, ភិក្ខុត្រូវសួរការកសង្ឃជាមុន ទើបគួរខ្ចីទៅ អំពីឈើជាទព្វសម្ភារៈ ដែលរក្សាទុកដើម្បីសាងរោងឧបោសថជាដើមនោះ ។ ចំណែកទព្វសម្ភារៈដែលជារបស់សង្ឃមួយណា មិនបានយុំគ្រងទុករមែងសើមក្នុងកាលភ្លៀងធ្លាក់, ទាំងស្ងួតព្រោះកំដៅថ្ងៃ, ភិក្ខុនឹងនាំទព្វសម្ភារៈសូម្បីទាំងអស់នោះមកសាងជាទីនៅរបស់ខ្លួន ក៏គួរ, កាលសង្ឃឱ្យនាំមកសង គួរឱ្យព្រមដោយទព្វសម្ភារៈ ឬដោយមូលតម្លៃយ៉ាងដទៃ ។ បើមិនអាចឱ្យបាន, លោកគួរពោលថា "បពិត្រលោកដ៏ចម្រើន សេនាសនៈដែលខ្ញុំព្រះករុណាសាងដោយទព្វសម្ភារៈរបស់សង្ឃ, សូមលោកទាំងឡាយប្រើប្រាស់ ដោយការប្រើប្រាស់ជារបស់សង្ឃចុះ" ។ តែភិក្ខុនេះប៉ុណ្ណោះ ជាឥស្សរៈនៃសេនាសនៈដូច្នេះ ។ សូម្បីសរសេរថាក្តី

សរសេរឈើក្តី សន្ទុះទ្វារក្តី បង្អួចក្តី មិនគ្រប់គ្រាន់សោត, ទីងទីរបស់សង្ឃធ្វើឱ្យជាប្រក្រតី ក៏គួរ ។ សូម្បីក្នុងទព្វសម្ភារៈយ៉ាងដទៃ ក៏មានន័យដូចគ្នានេះ ។

[១៦៨] ក្នុងរឿងភិក្ខុលួចយកទឹកសង្ឃ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងកាលណា ទឹកជារបស់រកបានលំបាក, ក្នុងកាលនោះ ភិក្ខុទាំងឡាយនាំទឹកមកអំពីទីឆ្ងាយ ចម្ងាយមួយយោជន៍ខ្លះ កន្លះយោជន៍ខ្លះ, ក្នុងទឹកដែលគេហួងហែងបែបនោះ រមែងជាអវហារ ។ ពួកជន រមែងដាំបបរនិងបាយឱ្យសម្រេចបានសូម្បីដោយទឹកណាដែលគេនាំមក ឬដែលឃាំងនៅក្នុងជលាល័យទាំងឡាយ មានស្រះបោក្ខរណីជាដើម ទាំងធ្វើជាទឹកផឹកនិងទឹកប្រើតែម្យ៉ាង មិនបានធ្វើជាទឹកសម្រាប់ប្រើប្រាស់យ៉ាងដទៃទេ, កាលភិក្ខុកាន់យកទឹកសូម្បីនោះ ដោយថេយ្យចិត្ត រមែងជាអវហារ ។ ចំណែកភិក្ខុកាន់យកទឹកមួយឆ្នាំង ឬពីរឆ្នាំង អំពីទឹកណា រមែងបានដើម្បីលាងអាសនៈ ស្រោចដើមពោធិព្រឹក្ស ធ្វើការបូជាដោយទឹក (និង) ដើម្បីស្ងោរទឹកជ្រលក់ គួរបដិបត្តិក្នុងទឹកនោះ ដោយអំណាចនៃកតិការបស់សង្ឃតែម្តង ភិក្ខុដែលទទួលយកទឹកច្រើនពេកទៅឬដាក់វត្ថុទាំងឡាយ មានដីស្អិតជាដើមចុះដោយថេយ្យចិត្ត ព្រះវិន័យ

ធរគប្បីឱ្យវាយតម្លៃវត្ថុពិន័យអាបត្តិ ។ បើពួកភិក្ខុម្ចាស់អាវាស ធ្វើកតិកាវត្តទុកយ៉ាងតឹងរឹង មិនព្រមឱ្យភិក្ខុពួកដទៃប្រើលាងវត្ថុ ឬប្រើជ្រលក់សំពត់ តែកាលភិក្ខុពួកដទៃមិនឃើញខ្លួន ក៏កាន់យកធ្វើកិច្ចគ្រប់យ៉ាង ពួកភិក្ខុអាគន្តុកៈ មិនត្រូវតាំងនៅក្នុងកតិកាវបស់ភិក្ខុអាវាសិក, ភិក្ខុអាវាសិកលាងរបស់ប្រើប្រាស់ប៉ុនណា ក៏គប្បីលាងវត្ថុប៉ុណ្ណោះ ។ បើសង្ឃមានស្រះបោក្ខរណី ឬមានត្រពាំងទឹកនៅពីរបីកន្លែងសោត និងសង្ឃក៏ធ្វើកតិកាទុកថា "ភិក្ខុទាំងឡាយ គួរស្រង់ទឹកក្នុងស្រះបោក្ខរណីនិងត្រពាំងទឹកនេះ, គួរកាន់យកទឹកផឹកអំពីទីនេះ, គួរធ្វើការប្រើប្រាស់កិច្ចគ្រប់យ៉ាង ក្នុងស្រះបោក្ខរណីនិងត្រពាំងទឹកនេះ" ពួកភិក្ខុអាគន្តុកៈគួរធ្វើកិច្ចទាំងអស់ដោយកតិកាវត្តនុ៎ះឯង ។ ក្នុងស្រះបោក្ខរណីជាដើមណាមិនមានកតិកា, ការប្រើប្រាស់កិច្ចគ្រប់យ៉ាង ក្នុងស្រះបោក្ខរណីជាដើមនោះ រមែងគួរ ដូច្នេះឯង ។

ក្នុងរឿងលួចយកដីស្អិត មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងទីណា ដីស្អិតជារបស់រកបានលំបាក ឬដីស្អិត មានពណ៌មានប្រការផ្សេង ៗ ដែលសង្ឃនាំមកគរទុក, ក្នុងទីនោះសូម្បីដីស្អិតបន្តិចបន្តួច ក៏មានតម្លៃគ្រប់ ៥ មាសក; ព្រោះហេតុនោះ ទើបជាបារាជិក ។

មួយទៀត កាលការងាររបស់សង្ឃ និងការងារក្នុងព្រះចេតិយសម្រេចហើយ ការដែលភិក្ខុប្រាប់សង្ឃជាមុន ទើបកាន់យក ឬយកដោយខ្ទីគួរ ។ ក្នុងកំបោរសក្តិ ក្នុងចិត្រកម្មនិងវណ្ណកម្មក្តី ក៏មានន័យដូចគ្នានេះ ។

ក្នុងរឿងលួចយកស្មៅទាំងឡាយ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងស្មៅដែលភិក្ខុយកភ្លើងដុត ជាទុក្កដ ព្រោះមិនមានការឱ្យឃ្លាតចាកឋាន, តែជាភណ្ឌទេយ្យ ។ សង្ឃរក្សាផ្ទៃដីដែលដាំស្មៅទុក ហើយប្រើស្មៅនោះប្រក់ទីនៅរបស់សង្ឃ, ពេលខ្លះសង្ឃមិនអាចថែរក្សាបានទៀត, គ្រានោះ មានភិក្ខុមួយរូបដទៃ រក្សាទុកដោយប្រាថ្នាវត្តជាធំ, ស្មៅនេះក៏នៅជារបស់សង្ឃដូចគ្នា ។ បើមិនមានអ្នកណារក្សា, សង្ឃគួរចាត់ភិក្ខុមួយរូបថា "លោកចូរជួយរក្សាទីដី", បើលោករូបនោះ ប្រាថ្នាចំណែក, សង្ឃនឹងត្រូវចែកចំណែកឱ្យ ក៏គួរឱ្យលោករូបនោះរក្សា ។ បើលោកសូមចំណែកបន្ថែមសោត, សង្ឃគួរឱ្យដោយពិត ។ ភិក្ខុសូមបន្ថែមឡើងទៀត សង្ឃគួរនិយាយថា លោកចូរទៅ រក្សាហើយយកស្មៅទាំងអស់ ប្រក់សេនាសនៈរបស់ខ្លួនចុះ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា កាលស្មៅវិនាស ក៏មិនមានប្រយោជន៍ ។ តែភិក្ខុទាំងឡាយ កាលនឹងឱ្យ មិនគួរឱ្យព្រមទាំងដី ព្រោះដីជាគរុភណ្ឌ គួរឱ្យត្រឹមតែស្មៅ

ប៉ុណ្ណោះ ។ កាលភិក្ខុនោះរក្សាទុកហើយ ប្រើប្រាស់សេនាសនៈរបស់ខ្លួន, បើសង្ឃអាចរក្សាបានទៀត, សង្ឃគួរនឹងនិយាយចំពោះភិក្ខុនោះថា "លោកមិនត្រូវរក្សាទេ, សង្ឃនឹងរក្សា" ដូច្នេះ ។

[១៦៩] រឿងភិក្ខុ ៧ រូប លួចយកគ្រឿងសេនាសនៈសង្ឃ មានគ្រែជាដើម ប្រាកដច្បាស់ហើយនោះឯង ។ ក៏កាលភិក្ខុលួចសសរថ្មក្តី សសរឈើក្តី ឬវត្ថុដទៃណាមួយ សូម្បីដែលមិនបានមកក្នុងព្រះបាលី ដែលមានតម្លៃគ្រប់ ១ បាទ ក៏ត្រូវអាបត្តិបារាជិកដូចគ្នា ។

ក្នុងផ្ទះសម្រាប់ធ្វើសេចក្តីព្យាយាមជាដើម មានវិនិច្ឆ័យដូច្នេះ ៖

សូម្បីកាលភិក្ខុទម្លាយជញ្ជាំងក្តី កំផែងក្តី នៃស្ថានទីមានបរិវេណជាដើម ដែលត្រូវម្ចាស់របស់គេលះបោលទុករាត់រាយ ហើយលួចយកសម្ភារៈ មានឥដ្ឋជាដើមទៅ ក៏មានន័យនេះដូចគ្នា ។

ព្រោះហេតុអ្វី ? ព្រោះហេតុថា ភិក្ខុទាំងឡាយ ពេលខ្លះ រមែងនៅគ្រប់គ្រងសេនាសនៈ ដែលឈ្មោះថា ជារបស់សង្ឃ ពេលខ្លះក៏មិននៅគ្រប់គ្រង ។ សូម្បីកាលភិក្ខុលួចយកបរិក្ខារយ៉ាងណាមួយ ក្នុងស្ថានទីទាំងឡាយ មានវត្តដែលត្រូវលះបោលហើយជាដើម ក្នុងកាលមនុស្សក្នុងជនបទភៀសខ្លួនចៀសចេញទៅ ព្រោះចោរភ័យក្នុងជាយដែន ក៏មាន

ន័យនោះដូចគ្នា ។ ចំណែកភិក្ខុពួកណានាំសម្ភារៈទៅប្រើមួយគ្រា អំពីវត្ត ដែលគេលះចោលហើយនោះ និងក្នុងកាលវត្តមានភិក្ខុត្រឡប់មកនៅវិញ ភិក្ខុទាំងឡាយ បន្ទាប់ភិក្ខុទាំងនោះឱ្យនាំមកសង គួរសងវិញ ។ សូម្បី បើលោកទាំងឡាយ នាំសម្ភារៈឈើជាដើម អំពីវត្តដែលគេលះចោល ហើយនោះ មកសាងជាសេនាសនៈ, វត្ថុដែលពួកលោកនាំមកនោះ ឬ សេនាសនៈដែលមានតម្លៃប៉ុនទឹងវត្ថុនោះ គួរឱ្យវិញដូចគ្នា ។ កាល មនុស្សក្នុងជនបទ មិនទាន់អស់អាល័យ ភៀសខ្លួនទៅ ដោយគិតថា ពួកយើងនឹងត្រឡប់មកនៅគ្រប់គ្រងទៀត, វត្ថុដែលជារបស់គណៈ ឬជា របស់បុគ្គល ជាការដែលភិក្ខុកាន់យកហើយ ។ បើគណៈនិងបុគ្គល អនុញ្ញាតិឱ្យ, មិនមានកិច្ចដោយការសង ។ ចំណែកសម្ភារៈរបស់សង្ឃ បាត់ជាគរុភណ្ឌ ព្រោះដូច្នោះ ត្រូវតែសងវិញនោះឯង រឿងគ្រឿងប្រើ ប្រាស់ក្នុងវិហារមានសេចក្ដីភ្លឺច្បាស់ទាំងអស់នោះឯង ។

[១៧០] ក្នុងព្រះពុទ្ធានុញ្ញាតនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យអ្នកទាំងឡាយនូវរបស់ទាំងនោះទៅប្រើប្រាស់បាន" ដូច្នេះ មានវិនិច្ឆ័យថា ៖

ភិក្ខុណានូវគ្រែ ឬតាំងរបស់សង្ឃទៅប្រើប្រាស់ដោយការប្រើ

ប្រាស់ដូចរបស់សង្ឃ មួយខ្លែះ ពីរខ្លែះ ក្នុងស្ថានទីសប្បាយរបស់ខ្លួន កាលភិក្ខុទាំងឡាយដែលចាស់ជាងមកហើយក៏ប្រគេន, មិនហាមឃាត់ ។ កាលគ្រែនិងតាំងនោះ វិនាសទៅក្តី ចាស់ទៅក្តី អ្នកដទៃលួចទៅដោយភាពជាចោរក្តី រមែងមិនជាសំណាងដល់ភិក្ខុនោះ ។ តែកាលលោកនៅហើយនឹងទៅ គួររក្សាទុកក្នុងកន្លែងដើម ។ ចំណែកភិក្ខុណាប្រើប្រាស់ដោយការប្រើប្រាស់ជារបស់បុគ្គល មិនបានប្រគេនដល់ភិក្ខុទាំងឡាយដែលចាស់ជាង ដែលមកហើយ ៗ (កាលគ្រែនិងតាំងនោះវិនាសអស់ទៅក្តី ចាស់ទៅក្តី អ្នកដទៃលួចទៅដោយភាពជាចោរក្តី) រមែងជាសំណាងដល់ភិក្ខុនោះ ។ ក្នុងសង្ខេបអដ្ឋកថា លោកពោលទុកថា ក៏ភិក្ខុកាលនាំទៅកាន់អាវាសដទៃហើយប្រើប្រាស់ បើភិក្ខុចាស់ជាងក្នុងអាវាសនោះមកហើយ ឱ្យភិក្ខុនោះចេញទៅ គួរនិយាយថា "ខ្ញុំព្រះករុណានាំគ្រែនិងតាំងនេះ មកពីអាវាសឈ្មោះឯណោះ, ខ្ញុំព្រះករុណានឹងទៅ ខ្ញុំព្រះករុណានឹងចាត់គ្រែនិងតាំងនោះឱ្យតាមប្រក្រតីវិញ" ។ បើភិក្ខុចាស់នោះនិយាយថា "ខ្ញុំព្រះករុណានឹងចាត់ឱ្យជាប្រក្រតីដោយខ្លួនឯង" ។ សូម្បីនឹងធ្វើឱ្យជាភារៈរបស់ភិក្ខុចាស់នោះ ហើយសឹមចេញទៅ ក៏គួរ ។

[១៧១] ក្នុងរឿងភិក្ខុនីជាសិស្សរបស់ថុល្លនន្ទាភិក្ខុនីនៅក្នុងក្រុង

ចម្បា មានវិនិច្ឆ័យដូច្នេះ ៖

យាគូដែលគេដាក់អបរណ្ណជាតិប្រភេទយ៉ាងណាមួយ រួមជាមួយប្រេងល្ង និងអង្ករ និងផ្សំដោយវត្ថុ ៣ យ៉ាង គឺ ប្រេងល្ង អង្ករ និងសណ្តែកបាយ, ឬប្រេងល្ង អង្ករ និងសណ្តែករាជមាស, ឬប្រេងល្ង អង្ករ និងសណ្តែកជ្រូង ឈ្មោះថា តេកដុលយាគូ ។ បានឮថា ពួកជនរមែងប្រកបផ្សំ យាគូឈ្មោះ តេកដុលនោះ ដោយវត្ថុ ៣ យ៉ាង មានទឹកដោះថ្លា ទឹកឃ្មុំ និងដុំស្ករត្នោតជាដើមទាំងនេះ ក្នុងទឹកដោះស្រស់ដែលលាយដោយទឹកជាចំណែកទី ៤ ។

ក្នុងរឿងភិក្ខុនីជាសិស្សរបស់ថុល្លនន្ទាភិក្ខុនី នៅក្នុងក្រុងរាជគ្រឹះ មានវិនិច្ឆ័យដូច្នេះ ៖

នំដែលមានរសឆ្ងាញ់ក្រៃលែង លោកហៅថា **មធុគោឡកៈ** នំទឹកឃ្មុំ អាចារ្យពួកខ្លះពោលថា **មធុសីសកៈ** នំផ្សំក្បាលទឹកឃ្មុំខ្លះ ។ ពាក្យដ៏សេស សូម្បីក្នុងរឿងទាំង ២ នេះ ក៏គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងរឿងចែកបាយនុំះឯង ។

[១៧២] ក្នុងរឿងព្រះអដ្ឋកៈ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **ឯតទវោច : បាននិយាយពាក្យនេះ** សេចក្តីថា គហបតីនោះមានជម្ងឺ បានពោលទុកហើយ ។

ប្រើនបទថា អាយស្មា ឧបាលិ អាយស្មតោ អជ្ជុកស្ស បក្ខោ : ព្រះឧបាលីដ៏មានអាយុ ជាបក្ខពួករបស់ព្រះអជ្ជុកត្ថេរដ៏មានអាយុ សេចក្ដីថា ព្រះឧបាលី មិនមែនជាបក្ខពួក (របស់ព្រះអជ្ជុកៈនោះ) ដោយអំណាចដល់សេចក្ដីលំអៀងទេ តាមការពិត បណ្ឌិតគប្បីជ្រាបថា ព្រះថេរៈជាបក្ខពួក(របស់ព្រះអជ្ជុកៈនោះ) ដោយសេចក្ដីអនុគ្រោះភិក្ខុជាលជ្ជី និងដោយអនុគ្រោះព្រះវិន័យ ព្រោះដឹងថា លោកមិនជាអាបត្តិ ។ ពាក្យដ៏សេសក្នុងរឿងព្រះអជ្ជុកៈនេះ មានសេចក្ដីងាយយល់ទាំងអស់ ។

[១៧៣] ក្នុងរឿងបិលិន្ទវច្ឆត្ថេរក្នុងក្រុងពារាណសី នាំយកក្មេងពីរនាក់របស់ឧបដ្ឋាក អំពីដៃចោរបានមកដោយឫទ្ធិ មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា ចោរេហិ ឧប្បន្នំ : ពួកចោរនាំគ្នាប្លន់ សេចក្ដីថា ត្រូវពួកចោរប្លន់ហើយ ។

ប្រើនបទថា ឥទ្ធិយា អានេត្វា បាសាទេ ឋបេសិ : សម្ដែងឫទ្ធិទៅនាំយកក្មេងទាំងពីរនាក់នោះ បានមកហើយទុកក្នុងប្រាសាទ សេចក្ដីថា បានឮថា ព្រះថេរៈបានឃើញត្រកូលនោះ ប្រកបព្រមនៅដោយកូនសរ គឺ សេចក្ដីសោក វិលវល់ត្រឡប់ទៅមក ទើបបាន

អធិដ្ឋានប្រាសាទរបស់អ្នកទាំងនោះឯង ដោយឫទ្ធិរបស់ខ្លួនថា ចូរប្រាកដមានក្នុងទីជិតក្មេងទាំងឡាយ ដោយសេចក្ដីអនុគ្រោះធម៌ ដើម្បីសេចក្ដីករុណា ដើម្បីប្រយោជន៍ដល់ការតាមរក្សាសេចក្ដីជ្រះថ្លានៃត្រកូលនោះ ៗ ក្មេងទាំង ២ ក៏ចាំបានថា ប្រាសាទរបស់ពួកយើង ទើបបានឡើងទៅ ។ លំដាប់នោះព្រះថេរៈបានរំសាយឫទ្ធិហើយ ។ សូម្បីប្រាសាទក៏បានតាំងនៅក្នុងទីរបស់ខ្លួនដូចដើម ។ តែព្រះធម្មសង្គាហកាចារ្យទាំងឡាយ ពោលទុកដោយអំណាចវោហារថា ព្រះថេរៈនាំក្មេង ២ អ្នកនោះមកដោយឫទ្ធិហើយទុកនៅក្នុងប្រាសាទ ។

បទថា **ឥទ្ធិវិសយេ** : **ព្រោះវិស័យនៃឫទ្ធិ** គឺ មិនជាអាបត្តិព្រោះអធិដ្ឋានឫទ្ធិដូច្នេះ ។ ចំណែកឫទ្ធិ គឺ ការប្លែងរូបផ្សេង ៗ រមែងមិនគួរ ដូច្នេះឯង ។

[១៧៤-៥] រឿងទាំង ២ ខាងចុងបង្អស់ (គឺ រឿងភិក្ខុទៅក្រុងកោសម្ពីរើសកន្ទេលខាញ់គិតថា នឹងឱ្យដល់ម្ចាស់ និងរឿងភិក្ខុជាសទ្ធិវិហារិករបស់ទន្ទ្រិកត្ថេរ ក្នុងសាគលនគរលួចយកឈ្នួតរបស់គេ) មានសេចក្ដីងាយយល់ទាំងអស់នោះឯង ។

**ចប់ អទិន្នាទានសិក្ខាបទវណ្ណនា**

## គាថាសរូបទុតិយបារាជិកសិក្ខាបទ

ក្នុងទុតិយបារាជិកសិក្ខាបទនេះ មានអនុសាសនី ដូចតទៅនេះ ៖

ទុតិយបារាជិកសិក្ខាបទនេះណា ដែលព្រះជិនស្រីមិនមានអ្នកណាជាគម្រប់ ២ ដែលមានកិលេសបន្សាត់បង់ហើយ ទ្រង់ប្រកាសហើយក្នុងព្រះសាសនានេះ, សិក្ខាបទដទៃណាដ៏សេស ដែលមានអត្ថន័យដ៏ច្រើន មានសេចក្ដីនិងវិនិច្ឆ័យជ្រាលជ្រៅ ស្មើដោយទុតិយបារាជិកសិក្ខាបទនោះ រមែងមិនមាន ។ ព្រោះហេតុនោះ កាលរឿងកើតឡើងហើយ ភិក្ខុដែលដឹងព្រះវិន័យសព្វគ្រប់ នឹងធ្វើការវិនិច្ឆ័យក្នុងរឿងដែលកើតឡើងហើយនេះ ដោយសេចក្ដីអនុគ្រោះដល់ព្រះវិន័យ គប្បីត្រួតពិនិត្យព្រះបាលី និងអដ្ឋកថា ព្រមទាំងអធិប្បាយ ដោយមិនសេសសល់ កុំជាអ្នកប្រមាទ ធ្វើការវិនិច្ឆ័យចុះ ។ មិនគប្បីធ្វើសេចក្ដីឧស្សាហ៍ក្នុងការឃើញអាបត្តិ ក្នុងកាលណា ៗឡើយ, គួរដាក់ចិត្តថា "យើងនឹងឃើញអនាបត្តិ" ។ មួយទៀត សូម្បីឃើញអាបត្តិហើយ ក៏កុំអាលនិយាយប៉ប៉ាច់ប៉ប៉ោចជាមុន គប្បីសាកសួរនិងពិភាក្សាជាមួយនឹងលោកអ្នកដឹងទាំងឡាយហើយ ទើបពិន័យអាបត្តិនោះ ។ មួយទៀត ភិក្ខុទាំងឡាយជាបុថុជ្ជនក្នុងសាសនានេះ

រមែងឃ្លាតចាកគុណ គឺភាពជាសមណៈ សូម្បីក្នុងរឿងដែលគួរ ដោយអំណាចនៃចិត្ត ដែលប្រព្រឹត្តទៅរហ័ស ។ ព្រោះហេតុនោះ ភិក្ខុដែលមានបញ្ញាឃើញប្រចក្ស សម្លឹងឃើញនូវបរិក្ខាររបស់អ្នកដទៃ ដូចជាពស់មានពិសកាចនិងដូចគប់ភ្លើង គប្បីចាប់ពាល់ចុះ ។

## ៣. មនុស្សវិគ្គហសិក្ខាបទវណ្ណនា

តតិយបារាជិកណា ដែលព្រះពុទ្ធទ្រង់បរិសុទ្ធិដោយទ្វារទាំង ៣ ទ្រង់ប្រកាសហើយ, ឥឡូវនេះ ដល់លំដាប់សំវណ្ណនា នៃតតិយបារាជិកនោះហើយ; ព្រោះហេតុនោះ ពាក្យណា ដែលដឹងបានងាយ និងពាក្យណា ដែលខ្ញុំព្រះករុណាបាន ប្រកាសទុកហើយក្នុងការពណ៌នាពីមុននោះ សូម្បីក្នុង តតិយបារាជិកនេះ និងវៀរពាក្យនោះ ៗ ចេញដូច្នេះឯង ។

[១៧៦] ព្រះបាលីឧក្ខេបវចនៈថា តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ : សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារសាលា ក្បែរព្រៃមហាវ័ន ទៀបក្រុងវេសាលី ជាដើម ខ្ញុំព្រះករុណានឹងពោលតទៅនេះ ៖

### អធិប្បាយរឿងក្រុងវេសាលី

បទថា វេសាលិយំ : ទៀបក្រុងវេសាលី មានសេចក្ដីថា ជិត នគរដែលមានឈ្មោះយ៉ាងនោះ គឺ មានវោហារប្រព្រឹត្តទៅ ដោយ អំណាចនៃឥត្ថីលិង្គ ។ ពិតមែន នគរនោះ ហៅថា វេសាលី ព្រោះជា ក្រុងដែលធំទូលាយ ដោយពង្រីកគ្រឿងហោមព័ទ្ធ គឺ របងកំផែងដល់

៣ ជាន់ ។ សេចក្តីសង្ខេបក្នុងតតិយបារាជិកនេះ មានប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារនៃបទថា វេសាលី នោះ ដែលអ្នកប្រាថ្នាអនុបុព្វិកថា គប្បីកាន់យកអំពីវណ្ណនានៃវេតនសូត្រ ក្នុងអដ្ឋកថានៃខុទ្ទកបាលី ឈ្មោះបរមត្ថជោតិកាចុះ ។ ក៏នគរនេះ គប្បីជ្រាបថា ជាក្រុងដល់នូវសេចក្តីបរិបូណ៌ដោយអាការទាំងពួង ក្នុងកាលសម្តេចព្រះសម្មាសម្ពុទ្ធទ្រង់សម្រេចសព្វញ្ញុតញ្ញាណហើយប៉ុណ្ណោះ ។ ព្រះឧបាលីថេរៈ គ្រាសម្តែងគោចរគ្រាមយ៉ាងនោះហើយ ទើបពោលទីដែលស្តេចប្រថាប់ទុកថា **មហាវនេ កូដាគារសាលាយំ : នៅក្នុងកូដាគារសាលាក្បែរព្រៃមហាវ័ន ។**

បណ្តាព្រៃមហាវ័នទនិងកូដាគារសាលានោះ ព្រៃធំមានឱកាសជាទីកំណត់កើតឯង មិនបានដាំ ឈ្មោះថា ព្រៃមហាវ័ន ។ ចំណែកព្រៃមហាវ័នជិតក្រុងកបិលភស្តុ ជាប់តគ្នាតាំងពីព្រៃហិមពាន្តមក មិនមានឱកាសជាទីកំណត់ តាំងទល់មហាសមុទ្រ ។

ព្រៃមហាវ័ននេះមិនជាដូច្នោះ គឺជាព្រៃធំ មានឱកាសជាទីកំណត់; ព្រោះដូច្នោះ ទើបឈ្មោះថា ព្រៃមហាវ័ន ។ ចំណែកកូដាគារសាលា ដែលដល់ព្រមដោយអាការទាំងពួង ដែលសាងឱ្យមានជំបូលស្រដៀងទ្រង់ទ្រាយនៃហង្ស ធ្វើផុះកំពូលទុកក្នុងខាងក្នុងអារាមដែលសាងទុកអាស្រ័យព្រៃមហាវ័ន គប្បីជ្រាបថា ជាព្រះគន្ធកុដិសម្រាប់ព្រះមានព្រះភាគ ។

## ព្រះមានព្រះភាគទ្រង់សម្ដែងអសុភកម្មដ្ឋានដល់ពួកភិក្ខុ

ប្រើនបទថា អនេកបរិយាយេន អសុភកថំ កថេតិ : ទ្រង់សម្ដែងអសុភកថា ដោយបរិយាយច្រើន មានសេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងកថា ជាទីតាំងនៃសេចក្ដីនឿយណាយក្នុងកាយ ដែលប្រព្រឹត្តទៅដោយអំណាចនៃសេចក្ដីសម្លឹងឃើញអាការដែលមិនស្អាត ដោយហេតុច្រើនយ៉ាង ៗ ទ្រង់សម្ដែងយ៉ាងណា ?

ទ្រង់សម្ដែងថា មានក្នុងកាយនេះ គឺ សក់ រោម ។ល ។ ទឹកមូត្រ ។ មានពាក្យអធិប្បាយយ៉ាងណា ? មានពាក្យអធិប្បាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកខ្លះ កាលគន់រកមើលសូម្បីដោយការយកចិត្តទុកដាក់គ្រប់យ៉ាងក្នុងកលេវរៈមានប្រមាណមួយព្យាម នឹងមិនឃើញវត្ថុអ្វី ៗ នឹងជាកែវមុក្ដា ឬកែវមណី កែវពិទូរ្យ ឬក្រឹស្នា ខ្លឹមចន្ទន៍ ឬកំញាន កប្បូរ ឬបណ្ដាគ្រឿងក្រអូប មានលំអិតសម្រាប់អប់ជាដើមយ៉ាងណាមួយក៏ដោយ ដែលជារបស់ស្អាត សូម្បីត្រឹមតែបន្តិច; តាមការពិត នឹងឃើញតែរបស់មិនស្អាតមានប្រការផ្សេង ៗ មានសក់ និងរោមជាដើមប៉ុណ្ណោះ ដែលមានក្លិនស្អុយយ៉ាងក្រៃលែង គួរខ្ពើម មានការឃើញមិនជាទីស្រឡាញ់; ព្រោះហេតុនោះ ទើបមិនគួរធ្វើសេចក្ដីពេញចិត្ត ឬសេចក្ដីស្រឡាញ់ប្រាថ្នាក្នុងកាយនេះ តាមការពិត ដែលឈ្មោះថា សក់

ពួកណា ដែលកើតលើសីរសៈ ដែលជាអវយវៈខ្ពស់បំផុត សូម្បីសក់ទាំងនោះ ក៏ជារបស់មិនល្អដូចគ្នា ទាំងមិនស្អាត ទាំងជារបស់បដិកូល ក៏ឯសេចក្តីដែលសក់ទាំងនោះជារបស់មិនល្អ មិនស្អាតនិងជារបស់បដិកូលនោះ គប្បីជ្រាបដោយហេតុ ៥ យ៉ាង គឺ ដោយពណ៌ខ្លះ ដោយសណ្ឋានខ្លះ ដោយក្លិនខ្លះ ដោយទីនៅខ្លះ ដោយឱកាសខ្លះ; ការដែលកោដ្ឋាសទាំងឡាយមានរោមជាដើមជារបស់មិនល្អ មិនស្អាត និងជារបស់បដិកូល ក៏គប្បីជ្រាបដោយអាការយ៉ាងនេះឯង ។ សេចក្តីសង្ខេបក្នុងអធិការនៃតតិយបារាជិកនេះមានប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គ ។ ព្រះមានព្រះភាគត្រាស់អសុភកថា ក្នុងចំណែកនីមួយ ៗ ដោយអនេកបរិយាយ មានប្រភេទមួយចំណែក ប្រាំ ៗ ដោយប្រការដូច្នេះ ។

ពាក្យថា អសុភាយ វណ្ណំ ភាសតិ : ទ្រង់សម្តែងរៀបរាប់អំពីអសុភ មានសេចក្តីថា ព្រះអង្គទ្រង់តាំងអសុភមាតិកា ដោយអំណាចនៃឧទ្ធុមាតកអសុភៈជាដើមហើយ កាលទឹងទ្រង់ចែក គឺ ទ្រង់ពណ៌នាសំវណ្ណនា អសុភមាតិកានោះ ដោយបទភាជនី ទើបត្រាស់គុណានិសង្សនៃអសុភៈ ។

ពាក្យថា អសុភភាវនាយ វណ្ណំ ភាសតិ : ទ្រង់សម្តែងគុណនៃ

**ការចម្រើនអសុភកម្មដ្ឋាន** មានសេចក្ដីថា សេចក្ដីអប់រំ គឺសេចក្ដីចម្រើន សេចក្ដីរីកចម្រើននៃចិត្ត ដែលកាន់យកអាការដែលមិនល្អ ក្នុងចំណែកទាំងឡាយមានសាកជាដើម ឬក្នុងអសុភៈមានឧទ្ធុមាតកអសុភៈជាដើម ឬក្នុងវត្ថុខាងក្នុងនិងខាងក្រៅទាំងឡាយ ប្រព្រឹត្តទៅ; ព្រះអង្គនឹងទ្រង់សម្ដែងអានិសង្សនៃអសុភភាវនានោះ ទើបត្រាស់សរសើរ គឺ ទ្រង់ប្រកាសគុណ ។ ត្រាស់យ៉ាងណា ? ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបចំពោះនូវអសុភភាវនា ក្នុងវត្ថុមានសាកជាដើម ឬក្នុងវត្ថុមានឧទ្ធុមាតកអសុភៈជាដើម រមែងបានចំពោះនូវបឋមជ្ឈាន ដែលលះអង្គ ៥ ប្រកបដោយអង្គ ៥ មានសេចក្ដីល្អ ៣ យ៉ាង និងដល់ព្រមដោយលក្ខណៈ ១០ ភិក្ខុនោះ អាស្រ័យប្រអប់ចិត្ត ពោលគឺ បឋមជ្ឈាននោះ ចម្រើនវិបស្សនា រមែងសម្រេចព្រះអរហត្តដែលជាប្រយោជន៍ខ្ពស់បំផុត ។

## បឋមជ្ឈានមានលក្ខណៈ ១០ និងសេចក្ដីល្អ ៣

បណ្ដាសេចក្ដីល្អ ៣ និងលក្ខណៈ ១០ ទាំងនោះ លក្ខណៈ ១០ នៃបឋមជ្ឈានទាំងនេះ គឺ សេចក្ដីបរិសុទ្ធិនៃចិត្តប្រាសចាកពីធម៌ដែលជាអន្តរាយ១ សេចក្ដីបដិបត្តិសមាធិនិមិត្តដែលជាមកកណ្ដាល១ សេចក្ដីត្រាច់ទៅនៃចិត្តក្នុងសមាធិនិមិត្តនោះ១ សេចក្ដីព្រងើយនៃចិត្តដែលបរិសុទ្ធិ១ សេចក្ដីព្រងើយនៃចិត្តដែលឈានដល់សេចក្ដីស្ងប់១ សេចក្ដី

ព្រងើយនៃចិត្តដែលប្រាកដដោយអារម្មណ៍តែមួយ១ សេចក្តីផូរផង់ដោយអត្ថគឺ សេចក្តីដែលឥន្ទ្រិយទាំងឡាយមានរសតែម្យ៉ាង១ សេចក្តីផូរផង់ដោយអត្ថគឺ ការប្រព្រឹត្តទៅនៃសេចក្តីព្យាយាម ដែលសមគួរដល់សមាធិបញ្ញា និងឥន្ទ្រិយដែលជាធម៌មិនត្រឡប់ក្លាយ និងមានរសតែម្យ៉ាងនោះ១ សេចក្តីផូរផង់ដោយអត្ថ គឺ សេចក្តីសេពឱ្យជាទម្លាប់១ ។

បាលីក្នុងវិស័យជាទីពន្យល់លក្ខណៈ ១០ នោះ ដូច្នេះ ៖

អ្វីជាខាងដើម អ្វីជាកណ្តាល អ្វីជាទីបំផុតនៃបឋមជ្ឈាន ? សេចក្តីបរិសុទ្ធិនៃបដិបទា ជាខាងដើម, សេចក្តីប្រមូលផ្តុំឧបេក្ខា ជាកណ្តាល, សេចក្តីផូរផង់ ជាទីបំផុតនៃបឋមជ្ឈាន ។

សេចក្តីបរិសុទ្ធិនៃបដិបទា ជាខាងដើមនៃបឋមជ្ឈាន ខាងដើមមានលក្ខណៈ ប៉ុន្មាន ? ខាងដើមមានលក្ខណៈ ៣ ។ ធម៌ណាជាអន្តរាយរបស់ចិត្តនោះចិត្ត រមែងបរិសុទ្ធិចាកពីធម៌នោះ ចិត្តរមែងឈានទៅកាន់សមាធិនិមិត្តដែលជាកណ្តាល ព្រោះភាវៈដែលជាធម្មជាតិបរិសុទ្ធិ ចិត្តត្រាច់ទៅក្នុងសមាធិនិមិត្ត (ដែលជាគោចរ នៃអប្បនា) នោះ ព្រោះភាពជាធម្មជាតិប្រព្រឹត្តទៅហើយ ។ ចិត្តបរិសុទ្ធិចាកធម៌ដែលជាអន្តរាយ ១ ចិត្តឈានទៅកាន់សមាធិនិមិត្តដែលជាកណ្តាល ព្រោះភាវៈដែលជាធម្មជាតិបរិសុទ្ធិ១ ចិត្តត្រាច់ទៅកាន់សមាធិនិមិត្តនោះ ព្រោះជាធម្មជាតិឈានទៅ១ ជាបដិបទាវិសុទ្ធិដែលជាខាងដើមនៃបឋមជ្ឈាន ;

ខាងដើមមានលក្ខណៈ ៣ ពួកនេះ ។ ព្រោះហេតុនោះ បឋមជ្ឈានលោកទើបពោលថា ជាគុណជាតិល្អក្នុងខាងដើម និងដល់ព្រមដោយលក្ខណៈ៣ ។

សេចក្ដីចម្រើនឧបេក្ខា ជាកណ្ដាលនៃបឋមជ្ឈាន ត្រង់កណ្ដាលមានលក្ខណៈប៉ុន្មាន ? ត្រង់កណ្ដាលមានលក្ខណៈ ៣ គឺ ចិត្តបរិសុទ្ធិរមែងព្រងើយ, ចិត្តឈានដល់សេចក្ដីស្ងប់ រមែងព្រងើយ, ចិត្តប្រាកដដោយអារម្មណ៍តែមួយ រមែងព្រងើយ ។ ចិត្តបរិសុទ្ធិព្រងើយ១ ចិត្តឈានដល់សេចក្ដីស្ងប់ព្រងើយ១ ចិត្តប្រាកដដោយអារម្មណ៍តែមួយព្រងើយ១ ជាសេចក្ដីចម្រើនឧបេក្ខា ដែលជាកណ្ដាលនៃបឋមជ្ឈាន; ត្រង់កណ្ដាលមានលក្ខណៈ ៣ ពួកនេះ ។ ព្រោះហេតុនោះ បឋមជ្ឈានលោកទើបពោលថា ជាគុណជាតិល្អត្រង់កណ្ដាល និងដល់ព្រមដោយលក្ខណៈ ៣ ។

សេចក្ដីផូរផង់ ជាទីបំផុតនៃបឋមជ្ឈាន ទីបំផុតមានលក្ខណៈប៉ុន្មាន ? ទីបំផុតមានលក្ខណៈ៤ ។ សេចក្ដីផូរផង់ ដោយអត្ថ គឺសេចក្ដីមិនត្រឡប់ក្លាយនៃធម៌ទាំងឡាយដែលកើតក្នុងឈានចិត្តនោះ១ សេចក្ដីផូរផង់ដោយអត្ថ គឺ សេចក្ដីដែលឥន្ទ្រិយទាំងឡាយមានរសតែមួយ១ សេចក្ដីផូរផង់ដោយអត្ថ គឺ ការប្រព្រឹត្តទៅនៃសេចក្ដីព្យាយាមដែលសមគួរដល់សមាធិ បញ្ញា និងឥន្ទ្រិយដែលជាធម៌មិនប្រែក្លាយ និងមានរស់

តែមួយ ១ សេចក្តីផូរផង់ដោយអត្ថ គឺ សេចក្តីសោពស្និទ្ធ ១ ។ សេចក្តីផូរផង់ជាទីបំផុតនៃបឋមជ្ឈាន; ទីបំផុតមានលក្ខណៈ ៤ ទាំងនេះ ។ ព្រោះហេតុនោះ បឋមជ្ឈានលោកទើបហៅថា ជាគុណជាតិស្អាតក្នុងទីបំផុត និងដល់ព្រមដោយលក្ខណៈ ៤ ។ "ចិត្តដែលប្រព្រឹត្តទៅក្នុងវដ្ត ៣ប្រការ មានលំអ ៣ប្រការ ដូចពោលមកហើយនេះឯង រមែងជាចិត្តបរិបូណ៌ ដោយលក្ខណៈ ១០ គឺ បរិបូរណ៍ដោយវិតក្កៈ១ បរិបូរណ៍ដោយវិចារៈ១ បរិបូរណ៍បីតិ១ បរិបូរណ៍សុខៈ១ បរិបូរណ៍ដោយអធិដ្ឋានចិត្ត១ បរិបូរណ៍ដោយសទ្ធា១ បរិបូរណ៍ដោយវិរិយៈ១ បរិបូរណ៍សតិ១ បរិបូរណ៍សមាធិ១ បរិបូរណ៍បញ្ញា១"[១] ដោយប្រការដូច្នេះ ។

ពាក្យថា អានិសំស្ស អានិសំស្ស អសុភសមាបត្តិយា វណ្ណំ ភាសតិ : ទ្រង់សម្តែងគុណនៃអសុភសមាបត្តិជាញឹកញយ មានសេចក្តីថា ព្រះមានព្រះភាគត្រាស់សរសើរ គឺ ត្រាស់អានិសង្ស ទ្រង់ប្រកាសគុណនៃអសុភសមាបត្តិ ព្រោះទ្រង់ធ្វើការកំណត់អាងដល់រឿយ ៗ ថា ជាយ៉ាងនោះខ្លះ ជាយ៉ាងនេះខ្លះ ។ ត្រាស់យ៉ាងណា ? ត្រាស់យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ព្រោះថា ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្ញូ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៨២/៩៨ ។

គឺមិនរវើរវាយឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចស្លាបមាន់ ឬទងសរសៃដែលបុគ្គលដាក់ចុះក្នុងភ្លើង រមែងរួញ ខ្ញូ ងរឡើង គឺ មិនលាវិញឡើយ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តសន្សំអសុភសញ្ញារឿយ ៗ ហើយ ចិត្តរមែងរួញ ខ្ញូ បែរចេញចាកការជួបប្រសព្វដោយមេថុនធម្ម មិនរវើរវាយឡើយ សេចក្ដីព្រងើយកន្តើយក្ដី ការខ្ពើមរអើមក្ដី រមែងតាំងឡើង ក៏មានឧបមេយ្យយ៉ាងនោះឯង” ។

ពាក្យថា ឥច្ឆាមហំ ភិក្ខវេ អឌ្ឍមាសំ បដិសល្លិយិតុំ : ម្នាលភិក្ខុទាំងឡាយ តថាគតចង់គេចចាកអារម្មណ៍សម្ងំនៅអស់កាលកន្លះខែ (ក្នុងកម្មដ្ឋាន) សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងចៀសចេញ គឺ ពួនសម្ងំនៅស្ងាត់ស្ងៀមតែមួយព្រះអង្គឯង រហូតដល់អស់កន្លះខែ ។

ពាក្យថា នម្ហិ កោចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន បិណ្ឌបាតនីហារកេន : កុំឱ្យអ្នកណាមួយចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុមួយរូប ដែលនាំបិណ្ឌបាតទៅឱ្យតថាគត មានសេចក្ដីថា ភិក្ខុណា មិនធ្វើបយុត្តវាចា (វាចាជាប់ដោយបច្ច័យ) ដោយខ្លួន នាំបិណ្ឌបាតដែលគេតាក់តែងដើម្បីប្រយោជន៍ដល់តថាគត ក្នុងត្រកូលមាន

សទ្ធា បង្អោនចូលមកដល់តថាគត វៀរលែងតែភិក្ខុដែលនាំបិណ្ឌបាតចូលទៅឱ្យនោះតែមួយរូប អ្នកដទៃណា ៗ ទោះជាភិក្ខុក៏ដោយ ជាគ្រហស្ថក៏ដោយ កុំចូលទៅរកតថាគត ។

## ទ្រង់មិនហាមភិក្ខុសម្លាប់គ្នា ព្រោះឃើញកម្មចាស់

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបត្រាស់យ៉ាងនេះ ?

ឆ្លើយថា បានឮថា ក្នុងកាលអតីតកាលដ៏យូរលង់ ពួកព្រានម្រឹគប្រមាណ ៥០០ នាក់ យកកំណាត់ឈើនិងអន្ទាក់គ្រឿងចាប់សត្វជាច្រើន ធ្វើរបងព័ទ្ធព្រៃទុកនាំគ្នាសើចរីករាយ រួមគ្នាជាពួកតែមួយទុំះឯងសម្រេចការចិញ្ចឹមជីវិតដោយកម្ម គឺ ការសម្លាប់ម្រឹគនិងបក្សី ដរាបដល់អស់ជីវិត ហើយកើតក្នុងនរក ។ ព្រានម្រឹគទាំងនោះ ឆេះក្នុងនរកនោះហើយ កើតក្នុងពួកមនុស្ស ព្រោះកុសលកម្មយ៉ាងណាមួយ ដែលខ្លួនធ្វើទុកហើយក្នុងកាលមុនទុំះឯង ទើបបានបព្វជ្ជា និងឧបសម្បទាក្នុងសំណាក់របស់ព្រះមានព្រះភាគសូម្បីទាំងអស់ ដោយអំណាចនៃឧបនិស្ស័យនៃកម្មល្អ ។ អបរាបរចេតនារបស់ព្រានម្រឹគទាំងនោះ ដែលមិនទាន់បានឱ្យផល ព្រោះអកុសលកម្មដែលជាឫសគល់នោះ បានធ្វើឱកាសដើម្បីចូលទៅកាត់ផ្តាច់ជីវិតចេញ ដោយសេចក្តីព្យាយាមរបស់ខ្លួន

ឯង និងដោយព្យាយាមរបស់អ្នកដទៃ ក្នុងរវាងកន្លះខែនោះ ។ ព្រះមានព្រះភាគ បានទតឃើញការអស់ទៅនៃជីវិតនោះហើយ ។ ដែលឈ្មោះថាកម្មវិបាក មិនមានអ្នកណាអាចហាមឃាត់បានឡើយ ។ ក៏បណ្ដាភិក្ខុទាំងនោះ ភិក្ខុដែលនៅជាបុថុជ្ជនក៏មាន ជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះខីណាស្រពក៏មាន ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុទាំងឡាយដែលជាព្រះខីណាស្រព មិនមានការចាប់បដិសន្ធិ ព្រះអរិយសាវកទាំងឡាយក្រៅពីនេះ ជាអ្នកមានគតិទៀង គឺ មានសុគតិជាទីទៅក្នុងខាងមុខ; គតិរបស់ពួកភិក្ខុដែលនៅជាបុថុជ្ជន មិនទៀង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា "ភិក្ខុពួកនេះ ខ្លាចចំពោះមរណភ័យ ព្រោះសេចក្ដីស្រឡាញ់ដោយអំណាចសេចក្ដីពេញចិត្តក្នុងអត្តភាព នឹងមិនអាចជម្រះគតិឱ្យបរិសុទ្ធិបាន; ណ្ហើយចុះ តថាគតនឹងសម្ដែងអសុភកថាដើម្បីលះសេចក្ដីស្រឡាញ់ដោយអំណាចសេចក្ដីពេញចិត្ត ដល់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ កាលបានស្ដាប់អសុភកថានោះហើយ នឹងធ្វើការជម្រះគតិឱ្យបរិសុទ្ធិបាន ព្រោះជាអ្នកប្រាសចាកសេចក្ដីស្រឡាញ់ដោយអំណាចសេចក្ដីពេញចិត្តក្នុងអត្តភាពហើយ នឹងកាន់យកបដិសន្ធិក្នុងសួគ៌, ការបព្វជ្ជាក្នុងសំណាក់របស់តថាគត នឹងជាគុណជាតិមានប្រយោជន៍ដល់ភិក្ខុទាំងនោះ ដោយអាការយ៉ាងនេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់សម្ដែងអសុភកថាដោយកម្មដ្ឋានជាប្រធាន ដើម្បីអនុគ្រោះដល់

ភិក្ខុទាំងនោះ មិនបានសម្តែងដោយសេចក្តីប្រាថ្នា ក្នុងការពណ៌នាដល់គុណនៃសេចក្តីស្លាប់ទេ ក៏កាលទ្រង់សម្តែងហើយ ព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា "បើភិក្ខុទាំងឡាយ បានជួបឬឃើញតថាគតក្នុងរវាងកន្លះខែនេះសោត ភិក្ខុទាំងនោះនឹងមកប្រាប់យើងថា 'ថ្ងៃនេះភិក្ខុមរណភាពទៅមួយរូប ថ្ងៃនេះមរណភាពទៅ ២ រូប ។ល។ ថ្ងៃនេះមរណភាពទៅ ១០ រូប, ដូច្នេះ ក៏ឯកម្មវិបាកនេះ តថាគត ឬអ្នកណាដទៃ ក៏មិនអាចនឹងហាមបាន សូម្បីតថាគតនោះ បានស្តាប់ហេតុនោះហើយ ក៏ធ្វើអ្វីបាន ដើម្បីកុំឱ្យលោកស្លាប់ នឹងមានប្រយោជន៍អ្វីដល់តថាគត ដោយការស្តាប់នូវរឿងមិនមានប្រយោជន៍ ជារឿងដែលមានតែសេចក្តីវិនាសឥតប្រយោជន៍ ណ្ហើយចុះ តថាគតនឹងចូលទៅកាន់ស្ថានទីដែលភិក្ខុទាំងឡាយ មិនបានឃើញ" ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតចង់គេចចាកអារម្មណ៍សម្ងំនៅអស់កាលកន្លះខែ (ក្នុងកម្មដ្ឋាន) កុំឱ្យអ្នកណាមួយចូលទៅរកតថាគតឡើយ វៀរលែងតែភិក្ខុមួយរូបជាអ្នកនាំបិណ្ឌបាតទៅឱ្យតថាគត" ។

ចំណែកអាចារ្យពួកដទៃពោលថា ព្រះពុទ្ធទាំងឡាយ ត្រាស់យ៉ាងនោះហើយ ទើបបានចៀសចេញនៅពួនសម្ងំ ដើម្បីនឹងវៀរសេចក្តីតិះដៀលរបស់អ្នកដទៃ ន័យថា ជនពួកដទៃ នឹងពោលតិះដៀលព្រះមាន

ព្រះភាគថា "ព្រះមានព្រះភាគព្រះអង្គនេះទ្រង់ដឹងវត្ថុទាំងពួង ទាំងទ្រង់ប្ដេជ្ញាថា 'តថាគតជាអ្នកញ៉ាំងចក្រ គឺ ព្រះសទ្ធម្មដ៏បវរឱ្យប្រព្រឹត្តទៅ, ទ្រង់មិនអាចនឹងហាមព្រះសាវកទាំងឡាយ សូម្បីរបស់ព្រះអង្គ ដែលពឹងគ្នានិងគ្នាឱ្យសម្លាប់គ្នា ធ្វើដូចម្ដេចនឹងទ្រង់អាចហាមបុគ្គលដទៃបានហ្ន៎ ?" ក្នុងការដែលអ្នកដទៃពោលតិះដៀលនោះ (ដែលទ្រង់ចៀសយ៉ាងនេះ) បណ្ឌិតទាំងឡាយ នឹងពោលឆ្លើយថា "ព្រះមានព្រះភាគទ្រង់ប្រកបការចៀសចេញទៅពួនសម្ងំ ទ្រង់មិនបានជ្រាបការប្រព្រឹត្តនេះទេ, សូម្បីអ្នកទូលប្រាប់ព្រះអង្គក៏មិនមាន បើទ្រង់បានជ្រាបសោត ក៏ប្រាកដជាទ្រង់ហាមមិនខាន" ។ ប៉ុន្តែ ត្រឹមតែខដែលទ្រង់មានសេចក្ដីប្រាថ្នាជាដំបូងនេះឯង រមែងជាហេតុក្នុងពាក្យនេះបាន ។

សព្ទថា អស្សុ ក្នុងពាក្យថា ឆាស្សុ : **មិនមាន** នេះ ជានិបាតចុះក្នុងអត្ថត្រឹមតែថា ធ្វើបទឱ្យពេញ ឬក្នុងអត្ថគឺ ការហាមថា អ្នកណា ៗ កុំចូលទៅគាល់ព្រះមានព្រះភាគឡើយ ។

អសុភភាវនានុយោគ : សេចក្ដីព្យាយាមក្នុងការចម្រើន អសុភកម្មដ្ឋាន នោះ មានរបៀបធ្វើផ្សេង ៗ ដោយហេតុទាំងឡាយមានពណ៌ និងសណ្ឋានជាដើមច្រើនសន្ធឹកសន្ធាប់; ព្រោះហេតុនោះ ទើបឈ្មោះថា អនេកាការវោការ : ជាច្រើនបែបច្រើនវិធី មានពាក្យអធិប្បាយថា

ស្វាបអង្អែលលាយប្រឡូំគ្នាដោយអាការច្រើនយ៉ាង គឺ លាយច្របល់គ្នាដោយហេតុច្រើនយ៉ាង ។ អនេកាការវោការ នោះ បានដល់អ្វី ? បានដល់ អសុភភាវនានុយោគ ។ ដែលសេចក្តីប្រឹងប្រែងប្រកបរឿយ ៗ ក្នុងការចម្រើនអសុភកម្មដ្ឋាន មានក្បួនការផ្សេង ៗ ច្រើនយ៉ាង នោះ ។

ពីរបទថា អនុយុត្តា វិហរន្តិ : ក៏នាំគ្នាប្រកប សេចក្តីថា ភិក្ខុទាំងនោះ ប្រកប គឺ ខ្វល់ខ្វាយ ។

បទថា អដ្ដិយន្តិ : កើតសេចក្តីទុក្ខ សេចក្តីថា រមែងជាអ្នកលំបាកចិត្ត គឺ មានសេចក្តីលំបាកចិត្តដោយកាយនោះ ។

បទថា ហរាយន្តិ : កើតសេចក្តីនឿយនាយ បានដល់ រមែងធុញទ្រាន់

បទថា ជិគុច្ឆន្តិ : កើតសេចក្តីខ្ពើមឆ្អើម បានដល់ ជាអ្នកកើតសេចក្តីស្អប់ខ្ពើមឡើងនោះឯង ។

បទថា ទហរោ : ក្មេង បានដល់ ក្មេងជំទង់ ។

បទថា យុវា : កម្លោះ បានដល់ អ្នកប្រកបដោយភាពជាកម្លោះឬក្រមុំ

បទថា មណ្ឌនកជាតិយោ : ជាអ្នកមានកិរិយាស្អិតស្អាងជា

ប្រក្រតី បានដល់ អ្នកពេញចិត្តតាក់តែងខ្លួនជាប្រក្រតី ។

ពីរបទថា សីសំ នហាតោ : លុះបានងូតទឹកកក់ក្បាលហើយ បានដល់ អ្នកងូតទឹកព្រមទាំងសីសៈ ។

ក្នុងពីរបទថា នហាភោ យុវា នេះព្រះឧបាលីថេរៈសម្ដែងភាពជាកម្លោះមុន ដោយពាក្យថា ទហរៈ ។ ពិតមែន សត្វទាំងឡាយក្នុងគ្រាជំបូងជាកម្លោះ រមែងមានប្រក្រតីជាអ្នកពេញចិត្តតាក់តែងខ្លួនដោយពិសេស ។ ព្រះឧបាលីថេរៈ សម្ដែងដល់វេលាខ្វល់ខ្វាយការតាក់តែងខ្លួនដោយពាក្យទាំងពីរថា សីសំ នហាតោ នេះ ។ ពិតមែន សូម្បីមនុស្សកម្លោះធ្វើការងារយ៉ាងណាមួយហើយ មានរាងកាយសៅហ្មង ក៏មិនជាអ្នកខ្វល់ខ្វាយការតាក់តែងខ្លួនទេ ។ តែគេងូតទឹកជម្រះក្បាលរួចហើយទើបតាមប្រកបការតាក់តែងខ្លួនតែម្ដង រមែងមិនប្រាថ្នាសូម្បីដែលនិងឃើញរបស់ស្មោគគ្រោកមានសាកសពសជាដើម ។

## ពួកភិក្ខុសម្លាប់ខ្លួនឯងនិងពឹងឱ្យអ្នកដទៃសម្លាប់

ខណៈនោះ បុរសកម្លោះនោះ គប្បីនឿយណាយ ធុញទ្រាន់ ខ្ពើមឆ្អើម ដោយសាកសពពស់ សាកសពសុនខ ឬសាកសពមនុស្សដែលពាក់នៅត្រង់ក គឺ មានបុគ្គលជាសត្រូវខ្លះនោះឯងនាំមកចងទុក គឺពាក់ទុកត្រង់ក យ៉ាងណា ភិក្ខុទាំងនោះ ក៏នឿយណាយ ធុញទ្រាន់ ខ្ពើម

ផ្ដើម ដោយរាងកាយរបស់ខ្លួន យ៉ាងនោះដែរ ជាអ្នកប្រាថ្នានឹងលះបង់រាងកាយរបស់ខ្លួនចេញ ព្រោះជាអ្នកប្រាសចាកសេចក្ដីស្រឡាញ់ដោយអំណាចសេចក្ដីពេញចិត្ត ដូចបុរសនោះជាអ្នកប្រាថ្នានឹងលះបង់ចោលសាកសពនោះចេញ ដូច្នោះ ទើបកាន់យកសស្ត្រា ហើយផ្ដាច់ជីវិតខ្លួនឯងខ្លះ ពឹងគ្នានិងគ្នាឱ្យផ្ដាច់ជីវិតខ្លះ ដោយនិយាយយ៉ាងនេះថា "លោកចូរផ្ដាច់ជីវិតខ្ញុំព្រះករុណាចេញ ខ្ញុំព្រះករុណានឹងផ្ដាច់ជីវិតលោកចេញ" ។

ពាក្យថា **មិគលណ្ឌិកៈ** ក្នុងពីរបទថា **មិគលណ្ឌិកម្បិ សមណកុត្តកំ** នេះ ជាឈ្មោះរបស់គេ ។

បទថា **សមណកុត្តកោ** បានដល់ អ្នកទ្រទ្រង់ភេទប្រហែលនឹងសមណៈ ។ បានឮថា មិគលណ្ឌិកៈនោះ គាត់កោរសក់ទុកកំប៉ោយ ស្លៀកសំពត់កាសាវៈមួយផ្ទាំង មួយផ្ទាំងទៀត បង់ក ( ពាក់លើស្មា ) ចូលទៅអាស្រ័យវិហារនោះឯង ចិញ្ចឹមជីវិតដោយសារអាហារដែលសល់អំពីភិក្ខុសង្ឃ ។ ភិក្ខុទាំងឡាយចូលទៅរកមិគលណ្ឌិកៈ ជាអ្នកទ្រទ្រង់ភេទសមណៈសូម្បីនោះ ហើយពោលយ៉ាងនោះ ។

សព្ទថា **សាធុ** ជានិបាត ចុះក្នុងអត្ថថា សូមអង្វរ ។ **នោ** ជាទុតិយាវិភត្តិ ពហុវចនៈ ប្រែថា ពួកយើង ។ មានពាក្យអធិប្បាយថា អ្នកអើយ ជាការល្អណាស់ លោកចូរជួយផ្ដាច់ជីវិតពួកអាត្មាភាពផង ។

ក៏បណ្ដាភិក្ខុទាំងនោះ ភិក្ខុដែលជាអរិយៈមិនធ្វើបាណាតិបាត មិនបបួលបុគ្គលដទៃ ទាំងមិនអនុញ្ញាតផង ។ ចំណែកភិក្ខុដែលជាបុថុជ្ជនធ្វើបានស្មើគ្រប់យ៉ាង ។

បទថា លោហិតកំ : ឈាម គឺ ប្រឡាក់ដោយឈាមហើយ ។ ស្ទឹងដែលគេសន្មតិគ្នាថា ជាបុណ្យរបស់សត្វលោក ហៅថា វគ្គុ ក្នុងពាក្យថា យេន វគ្គុមុទា នេះ, បានឮថា មិគលណ្ឌិកៈនោះ ទៅកាន់ស្ទឹងនោះ ដោយសេចក្ដីសម្គាល់ថា ទឹងបណ្ដែតបាបក្នុងស្ទឹងនោះ ។

## មិគលណ្ឌិកៈសម្លាប់ភិក្ខុហើយកើតសេចក្ដីក្ដៅក្រហាយចិត្ត

ពីរបទថា អហុទេវ កុក្កុច្ចំ : ក៏មានសេចក្ដីសង្ស័យ សេចក្ដីថា បានឮថា បណ្ដាភិក្ខុទាំងនោះ ភិក្ខុខ្លះ មិនបានធ្វើកាយវិការ ឬវចីវិការ, ទាំងអស់គ្រប់រូប មានសតិរលឹកដឹងខ្លួន ដេកចុះដោយផ្ទៀងខាងស្ដាំ ។ កាលមិគលណ្ឌិកនោះ តាមរលឹកដល់សេចក្ដីមិនធ្វើកាយវិការ និងវចីវិការនោះ បានមានសេចក្ដីក្ដៅក្រហាយចិត្តហើយនោះឯង ។ បាបសូម្បីមានប្រមាណតិច ឈ្មោះថា គេលះបានហើយ ដោយអនុភាពនៃស្ទឹង រមែងមិនមាន ។

ពាក្យថា អហុ វិប្បដិសារោ : ក្ដៅក្រហាយស្ដាយក្រោយនោះ លោកពោលទុក ដើម្បីកំណត់សភាពនៃសេចក្ដីក្ដៅក្រហាយនោះ

ឯង ។ បានមានសេចក្ដីក្ដៅក្រហាយ ព្រោះសេចក្ដីវិប្បដិសារ មិនមែនសេចក្ដីក្ដៅក្រហាយមកព្រះវិន័យទេ ។

លោកពោលពាក្យថា អលាភា វត មេ : **ការនេះមិនមែនជាលាភរបស់អញទេតើ** ជាដើម ដើម្បីសម្ដែងអាការគឺ សេចក្ដីប្រព្រឹត្តទៅនៃសេចក្ដីក្ដៅក្រហាយ ។

បណ្ដាបទទាំងនោះ ពាក្យថា អលាភា វត មេ សេចក្ដីថា មិគលណ្ឌិកៈ នោះដកចិត្តថា "ឥឡូវនេះ ឈ្មោះថា លាភគឺ ប្រយោជន៍ និងសេចក្ដីសុខរបស់យើង រមែងមិនមានតទៅ" ។ ក៏គេបញ្ជាក់សេចក្ដីនោះឯង ឱ្យមុឹងម៉ាត់ ដោយពាក្យថា "លាភរបស់យើងមិនមានហ្ន៎" នេះ ។ ពិតមែន ក្នុងពាក្យថា ន វត មេ លាភា : **នឹងបាត់ថា ជាលាភរបស់អញមិនបានឡើយ** នេះ មានអធិប្បាយដូច្នេះថា សូម្បីបើមានអ្នកណា ៗ គប្បីពោលថា ជាលាភរបស់លោក ពាក្យនោះខុស លាភរបស់យើង រមែងមិនមានឡើយ ។

ពាក្យថា ទុល្លទ្ធំ វត មេ : **ជាតិជាមនុស្សអញបានដោយក្រណាស់** មានសេចក្ដីថា ភាពជាមនុស្សនេះ សូម្បីដែលយើងបានហើយដោយកុសលានុភាព ក៏ជាការដែលយើងបានមិនល្អហ្ន៎ ។ ក៏គេរមែងបញ្ជាក់សេចក្ដីនោះឯង ឱ្យមុឹងម៉ាត់ដោយពាក្យនេះថា យើងបាន

មិនល្អហ្ន៎ ។ ពិតមែន ក្នុងពាក្យថា ឯ វត មេ សុលទ្ធំ : ជាតិជាមនុស្ស ឈ្មោះថា អញបានដោយងាយមិនមែនឡើយ នេះ មានអធិប្បាយដូច្នេះថា សូម្បីបើអ្នកណា ៗ គប្បីពោលថា លោកបានល្អ ហើយពាក្យនោះខុស យើងបានមិនល្អហ្ន៎ ។

ពីរបទថា អបុញ្ញំ បសុតំ : អញបានបាបច្រើនណាស់ សេចក្តីថា វត្ត មិនមែនបុណ្យយើងសន្សំ ឬបង្កឱ្យកើតឡើងហើយ ។ បើទឹងគប្បីមានអ្នកសួរថា ព្រោះហេតុអ្វី ? គប្បីឆ្លើយថា ព្រោះហេតុដែលយើងបានផ្តាច់ជីវិតភិក្ខុទាំងឡាយ ដែលជាអ្នកមានសីល មានកល្យាណធម៌ ។ ពាក្យនោះមានអធិប្បាយថា ព្រោះហេតុ ដែលយើងបានផ្តាច់ជីវិតភិក្ខុទាំងឡាយ ដែលជាអ្នកមានសីល មានកល្យាណធម៌ គឺ អ្នកមានឧត្តមធម៌ មានធម៌ដ៏ប្រសើរ ព្រោះភាពជាអ្នកមានសីលនោះឯង ។

## ទេវតាជួយលួងលោមមិគលណ្ឌិកៈឱ្យសម្លាប់ភិក្ខុតទៅ

ពីរបទថា អញ្ញតរា មារកាយិកា : ជាពួករបស់មារមួយរូប មានសេចក្តីថា ភុម្មទេវតាមួយ មិនប្រាកដឈ្មោះ ជាមិច្ឆាទិដ្ឋិ ជាបក្ខពួកនៃមារ ប្រព្រឹត្តតាមមារ គិតថា មិគលណ្ឌិកៈនេះ ទឹងមិនហ៊ានកន្លងអន្ទាក់របស់មារ គឺ វិស័យរបស់មារទៅបាន ដោយឧបាយយ៉ាងនេះដូច្នេះហើយ ទើបប្រដាប់ដោយគ្រឿងអាភរណទាំងពួង កាលទឹងសម្តែង

អានុភាពរបស់ខ្លួន ទើបដើរមកលើទឹក ដែលមិនបែកខ្វាយ ដូចដើរទៅមកនៅលើផែនដី ដូច្នោះ បានពោលពាក្យនោះ ចំពោះមិគលណ្ឌិកសមណកុត្តកៈ ។ សព្ទថា សាធុ សាធុ ជានិបាត ចុះក្នុងអត្ថ គឺ សេចក្ដីរីករាយ ។

ព្រោះហេតុនោះ ក្នុងព្រះបាលីនោះ ទើបពោលជដែល ២ ដង យ៉ាងនេះឯង ។

ពីរបទថា **អតិណ្ណេ តារេសិ : បានញុំាងជនទាំងឡាយដែលមិនទាន់ឆ្លងសង្សារវដ្ដឱ្យឆ្លងផុតទៅបាន** សេចក្ដីថា លោកជួយបញ្ជូនពួកអ្នកដែលឆ្លងមិនទាន់ផុត ឱ្យឆ្លងផុត គឺ ជួយដកឱ្យផុតពីសង្សារ ដោយការផ្ដាច់ជីវិតចេញនេះ ។ បានឮថា ទេវតាដែលជាពាលបញ្ញាខ្សោយនោះមានលទ្ធិដូច្នេះថា បុគ្គលទាំងឡាយ អ្នកមិនទាន់ស្លាប់ ឈ្មោះថា មិនទាន់ផុតពីសង្សារ, អ្នកដែលស្លាប់ហើយទើបផុត ។ ព្រោះហេតុនោះ ទេវតាអ្នកមានលទ្ធិយ៉ាងនោះ ក៏ដូចជាមនុស្សព្រៃ[១] អ្នកនឹងដកខ្លួនចេញពីសង្សារដូច្នោះ បានប្រកបសួម្បីមិគលណ្ឌិកៈនោះទុកក្នុងការឱ្យជួយផ្ដាច់ជីវិតចេញនោះ ទើបពោលយ៉ាងនោះ ។

---

១. មិលក្ខុ មិលក្ខោ មនុស្សព្រៃ អ្នកនិយាយចេញសំឡេងដូចសត្វស្រែក ជាមនុស្សមិនបានទទួលការសិក្សាឡើយ ។

## មិគលណ្ឌិកៈសម្លាប់ភិក្ខុតទៅមួយថ្ងៃ ១ រូបដល់ ៦០ រូប

គ្រានោះឯង មិគលណ្ឌិកសមណកុត្តកៈ សូម្បីជាអ្នកមានសេចក្ដីក្ដៅក្រហាយ កើតឡើងខ្លាំងក្លាត្រឹមនោះក៏ដោយ លុះឃើញអានុភាពរបស់ទេវតានោះ ក៏ដល់សេចក្ដីជាក់ចិត្តថា "ទេវតានេះ បានពោលយ៉ាងនេះ, ប្រយោជន៍នេះ គប្បីជាយ៉ាងនេះ ពិតប្រាកដ" ហើយពោលពាក្យជាដើមថា "ន័យថា ជាលាភរបស់យើង" ទើបចេញពីវិហារចូលទៅកាន់វិហារ ចេញពីបរិវេណចូលទៅកាន់បរិវេណ ហើយពោលយ៉ាងនេះ គឺចូលទៅកាន់វិហារនិងបរិវេណនោះ ៗ ហើយបើកទ្វារ ចូលទៅខាងក្នុងពោលនឹងភិក្ខុទាំងឡាយយ៉ាងនេះថា "លោកម្ចាស់ណាឆ្លងមិនទាន់ផុត ខ្ញុំព្រះករុណានឹងជួយបញ្ជូនឱ្យឆ្លងផុត" ។

ពីរបទថា **ហោតិយេវ ភយំ : សេចក្ដីខ្លាច ក៏មាន** ជាប្រាកដ សេចក្ដីថា មានចិត្តតក់ស្លុត ព្រោះអាស្រ័យសេចក្ដីស្លាប់ ។

បទថា **ឆម្ភិតត្តំ : សេចក្ដីញាប់ញ័រ** សេចក្ដីថា មានរាងកាយញ័ររន្ធត់ តាំងពីសាច់បេះដូងជាដើមទៅ ។ អាចារ្យពួកមួយពោលថា ការមានរាងកាយរឹងអស់ ព្រោះខ្លាចក្រៃលែងដូច្នេះខ្លះ ។ ពិតមែនសេចក្ដីមានរាងកាយរឹងដូចសសរ លោកហៅថា សេចក្ដីញាប់ញ័រ ។ សេចក្ដីមានរោមតាំងបះឡើងខាងលើ ឈ្មោះថា សេចក្ដីព្រឺរោម ។

ចំណែកព្រះខីណាស្រពទាំងឡាយ រមែងមិនឃើញសត្វស្លាប់ឡើយ ព្រោះលោកឃើញល្អហើយ ដោយភាពជារបស់ផ្តាច់ចាកសត្វ ។

ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា អន្តរាយមានសេចក្តីខ្លាចជាដើមនោះ សូម្បីទាំងអស់មិនមានដល់ព្រះខីណាស្រពទាំងនោះទេ ។ មិគលណ្ឌិកៈនោះបានផ្តាច់ជីវិតភិក្ខុមានប្រមាណ ៥០០ រូប សូម្បីទាំងអស់ទាំងនោះ ដោយអំណាចការគណនាយ៉ាងនេះ គឺ គេបានផ្តាច់ជីវិតភិក្ខុក្នុងមួយថ្ងៃ ១ រូបខ្លះ ២ រូបខ្លះ ។ល។ ៦០ រូបខ្លះ ។

## ព្រះមានព្រះភាគទ្រង់ជ្រាបថា ភិក្ខុសង្ឃស្តួចស្តើងទៅ

[១៧៧] ពីរបទថា បដិសល្លានា វុដ្ឋិតោ : ទ្រង់ចេញចាកទីសម្ងំក្នុងកម្មដ្ឋាន សេចក្តីថា ព្រះមានព្រះភាគទ្រង់ជ្រាបនូវភិក្ខុមានប្រមាណ ៥០០ រូបទាំងនោះដល់មរណភាព ទើបស្តេចចេញចាកភាពជាអ្នកនៅម្នាក់ឯងនោះ សូម្បីទើងទ្រង់ជ្រាប ក៏ដូចជាទ្រង់មិនជ្រាប ទើបបានត្រាស់ហៅព្រះអានន្ទមក ដើម្បីឱ្យតាំងរឿងឡើង ។

ពាក្យថា កិន្នុ ខោ អានន្ទ តនុភូតោ វិយ ភិក្ខុសង្ឃោ : ដូចម្តេចហ្ន៎ អានន្ទ បានជាភិក្ខុសង្ឃ ហាក់ដូចជាស្តួចស្តើងទៅ មានសេចក្តីថា ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ ក្នុងកាលមុន ពួកភិក្ខុជាចំនួនច្រើន រមែងមកកាន់ទីឧបដ្ឋាក ដោយរួមគ្នាជាពួកមួយ រៀនឧទ្ទេស

បរិបុច្ឆា ស្វាធ្យាយ, អារាម រមែងប្រាកដដូចរុងរឿងតែម្យ៉ាង, តែឥឡូវនេះ ដោយកន្លងទៅត្រឹមតែកន្លះខែ ភិក្ខុសង្ឃហាក់ដូចជាតិចទៅ គឺ ដូចជាថា ស្ដួចស្ដើង បន្តិចបន្តួច រលោះទៅ បាត់បង់ទៅ មានហេតុអ្វីឬ ? ពួកភិក្ខុចៀសទៅក្នុងទិសទាំងឡាយឬ ?

## ព្រះអានន្ទទូលឱ្យសម្ដែងកម្មដ្ឋានដទៃ

លំដាប់នោះព្រះអានន្ទ កាលមិនកំណត់ហេតុដែលភិក្ខុទាំងនោះដល់មរណភាពទៅ ព្រោះផលនៃកម្ម, តែមកកំណត់ព្រោះសេចក្ដីប្រឹងប្រែងប្រកបក្នុងអសុភកម្មដ្ឋានជាបច្ច័យវិញ ទើបបានក្រាបទូលពាក្យជាដើមថា "**តថា ហិ បន ភន្តេ ភគវា : បពិត្រព្រះអង្គដ៏ចម្រើន ពិតដូចព្រះពុទ្ធដីកាណាស់**" ដូច្នេះ កាលទឹងទូលសូមព្រះកម្មដ្ឋានយ៉ាងដទៃដើម្បីឱ្យភិក្ខុទាំងឡាយសម្រេចអរហត្តផល ទើបបានក្រាបទូលពាក្យជាដើមថា "**សាធុ ភន្តេ ភគវា : បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ**" ដូច្នេះ ។ ពាក្យនោះមានសេចក្ដីថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស សូមព្រះមានព្រះភាគ មេត្តាត្រាស់ប្រាប់កម្មដ្ឋានដទៃដែលជាហេតុឱ្យភិក្ខុសង្ឃតាំងនៅក្នុងព្រះអរហត្តផល" ។ អធិប្បាយថា ពិតមែន ព្រះកម្មដ្ឋានដែលជាគុណជាតិឈានចុះកាន់ព្រះនិព្វាន ដូចកំពង់ជាទីហូរចុះកាន់មហាសមុទ្រ សូម្បីពួកដទៃក៏មានច្រើន មានប្រភេទ

ផ្សេង ៗ គឺ អនុស្សតិ ១០ កសិណ ១០ ចតុធាតុវវត្ថាន ៤ ព្រហ្មវិហារ ៤ និងអានាបានស្សតិ ១ ។ សូមព្រះមានព្រះភាគ ទ្រង់លួងលោមចិត្តភិក្ខុទាំងឡាយ ឱ្យធូរស្រាលចិត្ត ក្នុងព្រះកម្មដ្ឋានទាំងនោះ ហើយត្រាស់ប្រាប់ព្រះកម្មដ្ឋានយ៉ាងណាមួយចុះ ។

លំដាប់នោះ ព្រះមានព្រះភាគ មានព្រះបំណងនឹងទ្រង់ធ្វើយ៉ាងនោះ កាលនឹងបញ្ជូនព្រះថេរៈទៅ ទើបទ្រង់ត្រាស់ថា "តេនហិ អានន្ទ : ម្នាលអានន្ទ បើដូច្នេះ" ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ ពីរបទថា វេសាលឹ ឧបនិស្សាយ : អាស្រ័យក្នុងក្រុងវេសាលី សេចក្ដីថា ភិក្ខុមានប្រមាណប៉ុនណា ដែលនៅអាស្រ័យក្នុងក្រុងវេសាលី ដោយជុំវិញក្នុងទីមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ, លោកចូរប្រកាសភិក្ខុទាំងអស់នោះឱ្យប្រជុំគ្នា ។

ពាក្យថា សព្វេ ឧបដ្ឋានសាលាយំ សន្និបាតេត្វា : (ព្រះអានន្ទក៏បង្គាប់ភិក្ខុអម្បាលនោះ) ទាំងអស់ឱ្យប្រជុំគ្នាក្នុងឧបដ្ឋានសាលា សេចក្ដីថា ទៅកាន់ទីដែលគួរនឹងទៅដោយខ្លួនឯង ហើយក្នុងទីដទៃបញ្ជូនភិក្ខុកម្លោះទៅជំនួស ឱ្យពួកភិក្ខុមកប្រជុំគ្នាមិនឱ្យនៅសល់ ក្នុងឧបដ្ឋានសាលាដោយវេលាមួយរំពេចប៉ុណ្ណោះ ។

ក្នុងពាក្យថា យស្សិទានិ ភន្តេ ភគវា កាលំ មញ្ញតិ : បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្គាល់កាលដ៏សមគួរក្នុង

កាលឥឡូវនេះ នេះ មានអធិប្បាយដូច្នេះថា បពិត្រព្រះមានព្រះភាគ ភិក្ខុសង្ឃប្រជុំព្រមគ្នាហើយ, នេះជាកាលដើម្បីទ្រង់ធ្វើធម្មកថា ដើម្បីប្រទានព្រះអនុសាសនីដល់ភិក្ខុទាំងឡាយ, សូមព្រះអង្គទ្រង់ជ្រាបកាលនៃកិច្ចដែលគួរទ្រង់ធ្វើក្នុងកាលឥឡូវនេះចុះ ។

## ព្រះមានព្រះភាគត្រាស់ប្រាប់អានាបានស្សតិដល់ពួកភិក្ខុ

[១៧៨] ពាក្យថា អថខោ ភគវា ។បេ។ ភិក្ខូ អាមន្តេសិ អយម្បិ ខោ ភិក្ខវេ : គ្រានោះឯង ព្រះមានព្រះភាគ (ទ្រង់យាងចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយទ្រង់គង់ប្រថាប់លើអាសនៈ ដែលគេតាក់តែងថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ស្រេចហើយ) ទើបត្រាស់នឹងពួកភិក្ខុដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ (អានាបានស្សតិសមាធិ នេះឯង) ។

មានសេចក្ដីថា ក៏ឯព្រះមានព្រះភាគ គ្រាទទួលអារាធនាហើយ កាលនឹងត្រាស់ប្រាប់បរិយាយយ៉ាងដទៃ ក្រៅអំពីអសុភកម្មដ្ឋានដែលត្រាស់ប្រាប់ហើយក្នុងកាលមុន ដើម្បីសម្រេចព្រះអរហត្តដល់ភិក្ខុទាំងឡាយ ទើបត្រាស់ថា អានាបានស្សតិសមាធិជាដើម ។ ឥឡូវនេះ ព្រោះថា ព្រះមានព្រះភាគត្រាស់បាលីនេះ ដើម្បីទ្រង់សម្ដែងព្រះកម្មដ្ឋាន ដែលជាគុណជាតិស្ងប់និងប្រណីតពិត ដល់ភិក្ខុទាំងឡាយ; ដូច្នោះ ខ្ញុំព្រះ

ករុណាទីងធ្វើការពណ៌នាក្នុងព្រះបាលីនោះ តាមលំដាប់អត្ថយោជនា មិនបោះបង់ចោលឡើយ ។

បណ្ដាបទទាំងនោះ បទថា **អយម្បិ ខោ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ សូម្បីនេះឯង**, ជាដើមនេះ មានយោជនាដូចតទៅនេះ ជាដំបូងថា ៖

ម្នាលភិក្ខុទាំងឡាយ មិនមែនអសុភភាវនាតែម្យ៉ាងប៉ុណ្ណោះ រមែងប្រព្រឹត្តទៅដើម្បីលះកិលេសទេ, ម្យ៉ាងទៀត សូម្បីអានាបានស្សតិសមាធិនេះឯង ដែលភិក្ខុអប់រំធ្វើឱ្យច្រើនហើយ រមែងជាគុណស្ងប់ប្រណីតត្រជាក់ នៅជាសុខនិងញ៉ាំងបាបអកុសលធម៌ដែលកើតឡើងហើយ ៗ ឱ្យអន្តរធានស្ងប់ទៅដោយឆាប់រហ័ស ។

ក៏ក្នុងពាក្យថា អានាបានស្សតិសមាធិជាដើមនេះ មានអត្ថវណ្ណនាដូចតទៅនេះ ៖

សតិកំណត់ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ឈ្មោះថា អានាបានស្សតិ ។ សមពិត ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គថា ខ្យល់ដកដង្ហើមចូលឈ្មោះថា អានៈ មិនមែនបស្សាសៈ, ខ្យល់ដកដង្ហើមចេញ ឈ្មោះថា បានៈ មិនមែនអស្សាសៈ, សតិចូលទៅតាំងនៅដោយអំណាចខ្យល់ដកដង្ហើមចូល សតិចូលទៅតាំងនៅដោយអំណាចខ្យល់ដកដង្ហើមចេញ

រមែងប្រាកដដល់បុគ្គលដែលដកដង្ហើមចូល រមែងប្រាកដដល់បុគ្គលដែលដកដង្ហើមចេញ ។ ចិត្តមានអារម្មណ៍តែមួយ ដែលកើតឡើងព្រមនឹងសតិដែលកំណត់ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញនោះ ឈ្មោះថា **សមាធិ** ។ ក៏ទេសនានេះ លោកពោលទុកដោយគោល គឺ **សមាធិ** មិនមែនដោយគោល គឺ **សតិ**ទេ ។ ព្រោះដូច្នោះ ក្នុងបទថា **អានាបានស្សតិសមាធិ** នេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា សមាធិដែលប្រកបដោយអានាបានស្សតិ ឬសមាធិក្នុងអានាបានស្សតិឈ្មោះថា អានាបានស្សតិសមាធិ ។

បទថា **ភាវិតោ** : **ដែលបុគ្គលចម្រើនហើយ**, គឺ ឱ្យកើតឡើង ឬឱ្យចម្រើនហើយ ។

បទថា **ពហុលីកតោ** : **ធ្វើឱ្យច្រើនជាប្រក្រតីហើយ**, គឺ ធ្វើរឿយ ៗ ។

ពីរបទថា **សន្តោ ចេវ បណីតោ ច** : **ជាធម៌ល្អិតផង ជាធម៌ឧត្តមផង**, គឺ ជាគុណស្ងប់ផង ជាគុណប្រណីតផងនោះឯង ។ ក្នុងបទទាំងពីរគប្បីជ្រាបសេចក្ដីពិតប្រាកដ ដោយ ឯវ សទ្ទ ។ លោកពោលអធិប្បាយទុកយ៉ាងណា ? លោកពោលអធិប្បាយទុកថា ពិតមែនអានាបានស្សតិសមាធិនេះ នឹងជាធម៌មិនស្ងប់ ឬមិនប្រណីត ដោយបរិយាយណា ៗ ដូចអសុភកម្មដ្ឋានដែលជាកម្មដ្ឋានស្ងប់និងប្រណីត

ដោយអំណាចការបោកធ្មុះតែម្យ៉ាង តែមិនស្ងប់មិនប្រណីតដោយអំណាចអារម្មណ៍ ព្រោះមានអារម្មណ៍គ្រោតគ្រាត និងព្រោះមានអារម្មណ៍បដិកូលដូច្នោះ ក៏ទេ ។ មួយទៀត អានាបានស្សតិសមាធិនេះឯង ស្ងប់ គឺរម្ងាប់រលត់អស់ ព្រោះមានអារម្មណ៍ស្ងប់ខ្លះ ព្រោះមានអង្គ គឺ ការបោកធ្មុះស្ងប់ខ្លះប្រណីត គឺ មិនធ្វើឱ្យខ្ចូចសេចក្ដីត្រេកអរ ព្រោះមានអារម្មណ៍ប្រណីតខ្លះ ព្រោះមានអង្គប្រណីតខ្លះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យថា ស្ងប់និងប្រណីត ។

ក៏ក្នុងពាក្យថា អសេចនកោ ច សុខោ ច វិហារោ : ជាធម៌មិនប្រឡូកប្រឡំផង ជាគ្រឿងនាំមកនូវសេចក្ដីសុខផង នេះ មានវិនិច្ឆ័យដូច្នេះ ៖

អានាបានស្សតិសមាធិនោះ មិនមានទោសជាគ្រឿងស្រោច; ព្រោះដូច្នោះ ទើបឈ្មោះថា ត្រជាក់ គឺមិនមានគ្រឿងស្រោច មិនលាយប្រឡំ ជាផ្នែកមួយផ្សេងដទៃ មិនទូទៅ ។ ម្យ៉ាងទៀត សេចក្ដីស្ងប់ដោយបរិកម្ម ឬដោយឧបចារក្នុងអានាបានស្សតិសមាធិនេះមិនមាន ។ អធិប្បាយថា ជាធម៌ស្ងប់និងប្រណីត ដោយសភាពរបស់ខ្លួនតែម្ដង ចាប់តាំងពីធ្វើទុកក្នុងចិត្តខាងដើម ។ តែអាចារ្យពួកខ្លះពោលថា បទថា អសេចនកោ សេចក្ដីថា មិនមានគ្រឿងស្រោច គឺ មានឱជៈ មានរស

ឆ្ងាញ់ដោយសភាពពិតតែម្យ៉ាង ។ ដោយអត្ថដូចពោលមកយ៉ាងនេះ អានាបានស្សតិសមាធិនេះ បណ្ឌិតគប្បីជ្រាបថា ត្រជាក់និងនៅជាសុខ ព្រោះប្រព្រឹត្តទៅដើម្បីឱ្យបានសេចក្ដីសុខមកកាយនិងមកចិត្ត ក្នុងខណៈដែលចូលដល់ហើយ ៗ ។

បទថា ឧប្បន្នុប្បន្នេ : ដែលកើតឡើង សេចក្ដីថា ដែលមិនទាន់គ្របសង្កត់បាន ៗ ។

បទថា ធាបកេ : ដ៏លាមក សេចក្ដីថា អាក្រក់ថោកទាប ។

ពីរបទថា អកុសលេ ធម្មេ : នែងញ៉ាំងអកុសលធម៌ទាំងឡាយ, បានដល់ ធម៌ដែលកើតអំពីសេចក្ដីមិនឈ្លាស ។

ពីរបទថា ឋានសោ អន្តរធាបេតិ : ឱ្យសាបសូន្យទៅផងដោយទំនងដ៏សមគួរ, សេចក្ដីថា រមែងឱ្យអន្តរធានទៅវិញ គឺ គ្របសង្កត់បានដោយឆាប់រហ័ស ។

បទថា វូបសមេតិ : ឱ្យស្ងប់រម្ងាប់ផង, សេចក្ដីថា រមែងឱ្យស្ងប់ទៅដោយល្អ ។ ម្យ៉ាងទៀត អធិប្បាយថា អានាបានស្សតិសមាធិនេះ រមែងដល់សេចក្ដីចម្រើនដោយអរិយមគ្គតាមលំដាប់ ព្រោះមានចំណែកនៃការបោកធ្លុះ រមែងកាត់ផ្ដាច់ដោយល្អ គឺ រមែងស្ងប់រម្ងាប់បាន ។

ពាក្យថា សេយ្យថាបិ : ប្រៀបដូច, នេះ ជាពាក្យសម្ដែងសេចក្ដី

ឧបមា ។

ប្រើនបទថា គិម្ហានំ បច្ឆិមេ មាសេ : ជាចុងគិម្ហន្តរដូវ គឺខែអាសាឍ្ហមហាមេឃ បានដល់ ក្នុងខែអាសាឍ្ហៈ( ខែ ៨ ) ។

បទថា ឩហតំ រជោជល្លំ : កំទេចធូលីដែលខ្យល់កួចឡើង សេចក្ដីថា លម្អងនិងធូលី ត្រូវខ្យល់បក់ផាត់ឡើងខាងលើ គឺ ហុយអំពីផែនដី ដែលបែកក្រហែងព្រោះក្រចកគោ និងក្របីជាដើមប៉ះខ្ទប់ ( ដើរជាន់ ), ដែលស្ងួតព្រោះខ្យល់ និងកំដៅថ្ងៃធ្វើឱ្យក្ដៅហួតហែងអស់កន្លះខែ អណ្ដែតឡើងលើអាកាស ។

ពពកដែលឡើងពេញផ្ទៃមេឃទាំងអស់ ហើយឱ្យភ្លៀងធ្លាក់រហូតគ្រប់កន្លះខែខាងខ្នើតនៃខែអាសាឍ្ហៈទាំងអស់ ឈ្មោះថា ភ្លៀងធំដែលធ្លាក់ក្នុងសម័យមិនមែនរដូវកាល, ពិតមែន មេឃនោះ លោកប្រាថ្នាយកក្នុងអធិការនេះថា អកាលមេឃ ព្រោះកើតឡើងក្នុងវេលាមិនទាន់ដល់រដូវភ្លៀង ។

ប្រើនបទថា ឋានសោ អន្តរធាបេតិ វូបសមេតិ : ( តែងញ៉ាំងកំទេចធូលីនោះ ) ឱ្យអន្តរធាន ឱ្យស្ងប់ទៅបាន ដោយទំនងដ៏សមគួរ, សេចក្ដីថា ភ្លៀងមេធំដែលធ្លាក់ក្នុងសម័យមិនមែនរដូវកាលនោះ រមែងរម្ងាប់ធូលីនិងលម្អងនោះ ៗ បាត់ទៅ មិនឱ្យឃើញ គឺ ឱ្យលិចបាត់ទៅក្នុង

ផែនដីដោយឆាប់រហ័សតែម្ដង ។

ពាក្យថា ឯវមេវ ខោ : មានឧបមាយ៉ាងណាមិញ, នេះ ជាពាក្យប្រៀបធៀបការឧបមេយ្យ ។ បន្ទាប់ពីពាក្យថា ឯវមេវ ខោ នោះទៅ មានន័យដូចពោលមកហើយនុ៎ះឯង ។

ក្នុងពាក្យថា កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ : ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចម្រើនហើយតើដូចម្ដេច ? នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា កថំ : តើដូចម្ដេច ? ជាពាក្យសួរ គឺ ភាពជាអ្នកប្រាថ្នានឹងញុំាងអានាបានស្សតិសមាធិភាវនាឱ្យពិស្ដារ ដោយប្រការផ្សេង ៗ ។

ពាក្យថា ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ : ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ ដែលបុគ្គលចម្រើនហើយ ជាពាក្យសម្ដែងខែអត្ថនៃធម៌ដែលត្រូវសួរ ព្រោះភាពជាអ្នកប្រាថ្នានឹងញុំាងអានាបានស្សតិសមាធិនោះឱ្យពិស្ដារ ដោយប្រការផ្សេង ៗ ។ សូម្បីក្នុងបទទីពីរ ក៏ន័យនោះ ។

ក៏ក្នុងពាក្យថា កថំ ភាវិតោ ច : ដែលបុគ្គលចម្រើនហើយតើដូចម្ដេច ? ជាដើមនេះ មានសេចក្ដីសង្ខេបដូច្នេះថា ម្នាលភិក្ខុទាំង

ឡាយ អានាបានស្សតិសមាធិ ដែលភិក្ខុអប់រំហើយ ដោយប្រការណា ដោយអាការណា ដោយវិធីណា ? ធ្វើឱ្យច្រើនហើយ ដោយប្រការដូចម្តេច ? ទើបជាគុណស្ងប់ប្រណីត ត្រជាក់ នៅជាសុខ និងញុំាងបាបអកុសលធម៌ដែលកើតឡើងហើយ ៗ ឱ្យអន្តរធានទៅដោយឆាប់រហ័ស ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់ញុំាងសេចក្តីនោះឱ្យពិស្តារ ទើបត្រាស់ថា ឥធ ភិក្ខវេ ជាដើម ។ បណ្តាបទទាំងនោះ បទថា ឥធ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ ក្នុងនេះ, មានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិតមែន ឥធ សព្ទនេះក្នុងបទថា ភិក្ខវេ នេះ សម្តែងសាសនាដែលជាទីអាស្រ័យរបស់បុគ្គលដែលឱ្យអានាបានស្សតិសមាធិកើតឡើងដោយប្រការទាំងពួង និងបដិសេធសេចក្តីមិនមានយ៉ាងនោះក្នុងសាសនាដទៃ ។ សមពិត ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "ឥធេវ ភិក្ខវេ បឋមោ សមណោ ឥធ ទុតិយោ សមណោ ឥធ តតិយោ សមណោ ឥធ ចតុត្ថោ សមណោ : ម្នាលភិក្ខុទាំងឡាយ សមណៈទី ១ (គឺសោតាបន្ន) មានតែក្នុងសាសនានេះ, សមណៈទី ២ (គឺសកទាគាមី) ក៏មានតែក្នុងសាសនានេះ សមណៈទី ៣ (គឺអនាគាមី) ក៏មានតែក្នុងសាសនានេះ, សមណៈ ទី ៤ (គឺអរហន្ត) ក៏មានតែក្នុងសាសនានេះ, បរប្បវាទ (វាទៈនៃគ្រូដទៃ)អំពីសំណាក់នៃ

បុគ្គលដទៃ រមែងសូន្យចាកពួកសមណៈ( នេះ )”[១] ។

ព្រោះហេតុនោះ លោកទើបពោលទុកថា ភិក្ខុក្នុងសាសនានេះ ។

ពាក្យថា អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា : ទៅកាន់ព្រៃក្តី ទៅកាន់ទីជិតគល់ឈើក្តី ទៅកាន់ផ្ទះដ៏ស្ងាត់ក្តី នេះសម្តែងសភាពនៃភិក្ខុនោះ ដែលជ្រើសរើសរកសេនាសនៈដ៏សមគួរដល់ការចម្រើនអានាបានស្សតិសមាធិ ។

ព្រោះថា ចិត្តរបស់ភិក្ខុនេះធ្លាប់ផ្សាយទៅក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើមអស់កាលដ៏យូរមកហើយ ទើបមិនប្រាថ្នាឡើងកាន់អារម្មណ៍របស់អានាបានស្សតិសមាធិ ច្រើនតែត្រាច់ទៅក្រៅមកប៉ុណ្ណោះ ដូចរថដែលគេទឹមដោយគោខូច ដូច្នោះ ។ ព្រោះដូច្នោះ អ្នកកង្វាលគោត្រូវការបង្ហឹកកូនគោខូច ផឹកទឹកដោះ ទាំងអស់របស់មេគោខូចធំធាត់ហើយ គប្បីផ្តាច់ចេញចាកមេគោ បោះបង្គោលធំ ទុកក្នុងទីសមគួរមួយហើយយកខ្សែចងទុកត្រង់បង្គោលនោះ, គោនោះ កូនគោនោះរបស់គេឆ្លេឆ្លាទៅខាងនេះទៅខាងណោះ មិនអាចគេចចៀសទៅបានគប្បីឈរផ្អែកឬដេកផ្អែកបង្គោលនោះឯង យ៉ាងណាមិញ; ភិក្ខុសូម្បីរូបនេះ ក៏យ៉ាងនោះដែរ ប្រាថ្នានឹងទូន្មានបង្ហឹកចិត្តដែលត្រូវទោសប្រទូស្តហើយ ដែល

១. ទីឃ. មហា. ១៦. ១៣៨/៣១៧ ។

ចម្រើនដោយការផឹករសនៃអារម្មណ៍មានរូបជាដើមមកយូរហើយ គប្បីផ្តាច់ចាកអារម្មណ៍មានរូបជាដើមហើយចូលទៅកាន់ព្រៃ ឬគល់ឈើ ឬផ្ទះស្ងាត់ហើយគប្បីយកខ្សែ គឺ សតិចងទុកត្រង់បង្គោល គឺ ខ្យល់អស្សាសៈនិងបស្សាសៈនោះ កាលបើដូច្នោះ ចិត្តរបស់លោកនោះ សូម្បីនឹងឆ្វៀលឆ្វាទៅខាងនេះទៅខាងណោះ ក៏ដោយ កាលមិនបានទទួលអារម្មណ៍ដែលធ្លាប់សន្សំមកក្នុងកាលមុនមិនអាចនឹងកាត់ខ្សែ គឺ សតិចេញទៅបានរមែងផ្តោតចិត្តស្ថិតក្នុងអារម្មណ៍ជាប់នោះឯង ដោយអំណាចឧបចារនិងអប្បនា ។ ព្រោះហេតុនោះ ព្រះបូរាណាចារ្យទាំងឡាយ ទើបពោលថា "នរជន កាលនឹងបង្ហឹកកូនគោ គប្បីចងជាប់ទុកត្រង់បង្គោល យ៉ាងណា ភិក្ខុក្នុងសាសនានេះ គប្បីយកសតិចងចិត្តរបស់ខ្លួនទុកត្រង់អារម្មណ៍ឱ្យមាំយ៉ាងនោះ" ។

សេនាសនៈនោះ រមែងជាស្ថានទីសមគួរដល់ការចម្រើនអានាបានស្សតិសមាធិនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ខ្ញុំព្រះករុណាទើបពោលថា ពាក្យនេះ សម្តែងសភាពដែលភិក្ខុនោះជ្រើសរើសរកសេនាសនៈដ៏សមគួរដល់ការចម្រើនអានាបានស្សតិសមាធិ ។ ម្យ៉ាងទៀត ព្រោះអានាបានស្សតិកម្មដ្ឋាននេះ ជាកំពូលក្នុងប្រភេទនៃកម្មដ្ឋានជាបទដ្ឋាននៃការសម្រេចគុណវិសេស និងជាសុខក្នុងវិហារធម៌ក្នុង

បច្ចុប្បន្នរបស់ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធនិងព្រះសាវក ដែលព្រះយោគាវចរមិនលះជាយស្រុកដែលអឺងកងដោយសំឡេងស្ត្រី បុរស ដំរី និងសេះជាដើម នឹងចម្រើនឱ្យដល់ព្រម មិនងាយធ្វើបាន ព្រោះសំឡេងជាបន្លាដល់ឈាន; តែក្នុងព្រៃដែលមិនមែនស្រុកព្រះយោគាវចរកំណត់កម្មដ្ឋាននេះហើយ ញុំាំងចតុត្ថជ្ឈានដែលមានខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ជាអារម្មណ៍ឱ្យកើតហើយ ធ្វើឈាននោះឯងឱ្យជាបាទពិចារណាសង្ខារទាំងឡាយ បានសម្រេចព្រះអរហត្តដែលជាផលដ៏ប្រសើរក្រៃលែងនឹងធ្វើបានងាយ; ព្រោះហេតុនោះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្ដែងសេនាសនៈដែលសមគួរដល់ភិក្ខុនោះ ទើបត្រាស់ព្រះពុទ្ធវចនៈមានជាដើមថា អរញ្ញគតោ វា : ទៅកាន់ព្រៃក្តី ដូច្នេះ ។ ព្រោះថា ព្រះមានព្រះភាគ ហាក់ដូចជាអាចារ្យដែលចេះវិទ្យាដឹងជ័យភូមិ ឃើញផ្ទៃដីដែលនឹងសាងនគរ ហើយពិចារណាដោយច្បាស់ល្អហើយចង្អុលថា "សូមព្រះអង្គសាងព្រះនគរក្នុងទីនេះ" កាលនគរសម្រេចហើយដោយសួស្ដី រមែងបានមហាសក្ការៈអំពីរាជត្រកូល យ៉ាងណា, ព្រះមានព្រះភាគនោះ ទ្រង់ពិចារណាសេនាសនៈដ៏សមគួរដល់ប្រយោគាវចរហើយ ទ្រង់ចង្អុលថា "កម្មដ្ឋានដែលកុលបុត្រអ្នកមានសេចក្ដីព្យាយាម គប្បីប្រារព្ធព្យាយាមក្នុងទីនេះ", តអំពីនោះ កាលព្រះយោគាវចរប្រកបកម្មដ្ឋាន

នៅក្នុងសេនាសនៈនោះហើយ បានសម្រេចព្រះអរហត្តដោយលំដាប់ រមែងបានមហាសក្ការៈថា "ព្រះមានព្រះភាគអង្គនោះ ជាសម្មាសម្ពុទ្ធពិត" យ៉ាងនោះដែរ ។ ចំណែកភិក្ខុនេះលោកហៅថា ដូចជាខ្លាធំ អែបពួនអាស្រ័យស្មៅក្រាស់ ៗ ព្រៃស្តុក ឬញកភ្នំ នៅក្នុងព្រៃ រមែងចាប់ពួកម្រឹគ មានក្របីព្រៃ ឈ្លូស (ឬប្រើស) និងជ្រូកជាដើម (ជាអាហារ) យ៉ាងណាមិញ ពួកភិក្ខុព្យាយាមចម្រើនកម្មដ្ឋាននៅក្នុងសេនាសនៈមានព្រៃជាដើមនេះ ក៏យ៉ាងនោះដែរ បណ្ឌិតគប្បីជ្រាបថា រមែងគោងបានទូវសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ និងអរិយផលដោយលំដាប់ ។ ព្រោះដូច្នោះ ព្រះបូរាណាចារ្យទាំងឡាយ ទើបពោលថា

> "ដែលឈ្មោះថា ខ្លាធំ រមែងលបចាប់ពួកម្រឹគ (ជាអាហារ) យ៉ាងណាមិញ កុលបុត្រដែលប្រកបសេចក្តីព្យាយាមបំពេញវិបស្សនានេះ ក៏យ៉ាងនោះដែរ ចូលទៅកាន់ព្រៃហើយ រមែងគោងបានទូវផលដ៏ឧត្តម" ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងអរញ្ញសេនាសនៈដែលជាភូមិគួរដល់ការប្រកបដោយបញ្ញាវាងវៃ ដើម្បីសេចក្តីចម្រើនឈានទៅមុខរបស់ព្រះយោគាវចរនោះ ទើបត្រាស់ព្រះពុទ្ធវចនៈមានជាដើមថា អរញ្ញគតោ វា : ទៅកាន់ព្រៃក្តី, ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អរញ្ញគតោ វា : ទៅកាន់ព្រៃក្ដី** សេចក្ដីថា ទៅកាន់ព្រៃដែលសប្បាយដល់ការពូនសម្ងំកន្លែងណាមួយ ក្នុងបណ្ដាព្រៃដែលមានលក្ខណៈ ដូចដែលពោលទុកយ៉ាងនេះថា ដែលឈ្មោះថា ព្រៃ បានដល់ ស្ថានទីខាងក្រៅពីសរសេរឿនចេញទៅនោះទាំងអស់ឈ្មោះថា ព្រៃ និងថា សេនាសនៈយ៉ាងជិតបំផុតចម្ងាយប្រមាណ ៥០០ ជង្ហ ឈ្មោះថា សេនាសនៈព្រៃ ។

បទថា **រុក្ខមូលគតោ វា : ទៅកាន់ទីជិតគល់ឈើក្ដី** សេចក្ដីថា ទៅកាន់ទីជិតដើមឈើ ។

បទថា **សុញ្ញាគារគតោ វា : ទៅកាន់ផ្ទះដ៏ស្ងាត់ក្ដី** សេចក្ដីថា ទៅកាន់ឱកាសដែលស្ងាត់ ដែលទំណេរ ។ តែក្នុងអធិការនេះ សូម្បីភិក្ខុវៀរព្រៃ និងគល់ឈើចេញ, ទៅកាន់សេនាសនៈ ៧ យ៉ាងដ៏សេស ក៏គួរហៅបានថា ទៅកាន់ផ្ទះស្ងាត់ ។

ព្រះមានព្រះភាគ គ្រាទ្រង់ចង្អុលសេនាសនៈដែលសមគួរដល់ការចម្រើនអានាបានស្សតិ ដែលសមគួរដល់រដូវទាំង ៣ និងសមគួរដល់ធាតុនិងចរិយាដល់ភិក្ខុនោះយ៉ាងនោះហើយ កាលនឹងទ្រង់ប្រាប់ឥរិយាបថដែលស្ងប់ ដែលជាចំណែកនៃសេចក្ដីមិនរួញរានិងមិនរវើរវាយ ទើបត្រាស់ថា **និសីទតិ : អង្គុយ** ដូច្នេះ ។ ក្រោយមកកាលទ្រង់សម្ដែង

ភាវៈនៃការអង្គុយជាឥរិយាបថតាំងមាំ ការដែលខ្យល់អស្សាសៈបស្សាសៈប្រព្រឹត្តទៅស្រួល និងឧបាយគ្រឿងកំណត់ចាប់អារម្មណ៍ដល់ភិក្ខុនោះ ទើបត្រាស់ព្រះពុទ្ធវចនៈមានជាដើមថា **បល្លង្កំ អាភុញ្ជិត្វា : អង្គុយពែនភ្នែន**, ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **បល្លង្កំ : ភ្នែន**, បានដល់ ការអង្គុយបត់ជើងទាំង ២ ដោយជុំវិញ (គឺ អង្គុយចម្រើនសមាធិ) ។

បទថា **អាភុញ្ជិត្វា : ពែន** គឺ បត់ចូល ។

ពាក្យថា **ឧជុំ កាយំ បណិធាយ : តាំងកាយឱ្យត្រង់** មានសេចក្ដីថា តាំងរាងកាយចំណែកលើឱ្យត្រង់ គឺ ឱ្យឆ្អឹងខ្នង ១៨ កំណាត់ ទល់ទីចុងបំផុតត្រួតបន្ទួត ។ ពិតមែន កាលភិក្ខុអង្គុយដោយអាការយ៉ាងនោះហើយ ស្បែក សាច់ និងសរសៃ រមែងមិនកោង ។ វេលានោះវេទនាទាំងឡាយដែលគប្បីកើតឡើងដល់លោកក្នុងខណៈ ៗ ព្រោះសេចក្ដីកោងនៃស្បែកសាច់និងសរសៃទាំងនោះជាបច្ច័យនុ៎ះឯង រមែងមិនកើតឡើង ។ កាលវេទនាទាំងនោះមិនកើតឡើង ចិត្តក៏មានអារម្មណ៍តែមួយ, កម្មដ្ឋានមិនធ្លាក់ទៅ រមែងចូលដល់សេចក្ដីចម្រើនរុងរឿង ។

ពាក្យថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា : តម្កល់ស្មារតីឱ្យមានមុខឆ្ពោះត្រង់** មានសេចក្ដីថា តាំងសតិឱ្យបែរមុខចំពោះកម្មដ្ឋាន ។ ម្យ៉ាងទៀត

ក៏ក្នុងពាក្យថា បរិមុខំ សតឹ ឧបដ្ឋបេត្វា នេះ គប្បីឃើញសេចក្ដីតាមន័យដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងគម្ពីរបដិសម្ភិទានោះឯងយ៉ាងនេះថា ស័ព្ទថា បរិ មានការកំណត់កាន់យកជាអត្ថ, ស័ព្ទថា មុខំ មានការនាំចេញជាអត្ថ, ស័ព្ទថា សតិ មានការចូលទៅតាំងទុកជាអត្ថ; ព្រោះហេតុនោះ លោកទើបពោលថា "តាំងសតិ ឱ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន)[១] ។ ក្នុងបទថា បរិមុខំ សតឹ នោះ មានសេចក្ដីសង្ខេបដូច្នេះថា ធ្វើសតិជាគ្រឿងនាំចេញដែលខ្លួនកំណត់កាន់យកហើយ ។

## អត្ថាធិប្បាយវិធីអប់រំសតិ ៣២ យ៉ាង

ពាក្យថា សោ សតោវ អស្សសតិ : (ភិក្ខុនោះ) មានសតិដកដង្ហើមចេញ មានសេចក្ដីថា ភិក្ខុនោះអង្គុយយ៉ាងនោះ និងតាំងសតិទុកយ៉ាងនោះហើយ កាលមិនលះសតិនោះ ឈ្មោះថា មានសតិដកដង្ហើមចូល ឈ្មោះថា មានសតិដកដង្ហើមចេញ ។ មានពាក្យអធិប្បាយថា ជាអ្នកអប់រំសតិ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទឹងទ្រង់សម្ដែងអាការជាគ្រឿងអប់រំសតិទាំងនោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា ទីឃំ វា អស្សសន្តោ :

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩៥/១១៦ ។

កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចេញវែង ជាដើម ។ សមពិត ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងវិភង្គចំពោះនៃពីរពាក្យនេះថា សោ សតោវ អស្សសតិ សតោ បស្សសតិ : (ភិក្ខុនោះ) មានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល ។

នៅក្នុងគម្ពីរបដិសម្ភិទាលោកសម្តែងថា ភិក្ខុរមែងជាអ្នកអប់រំសតិ ដោយអាការ ៣២ យ៉ាង គឺ សតិរបស់ភិក្ខុអ្នកដឹងសេចក្តីដែលចិត្តមានអារម្មណ៍តែមួយមិនរវើរវាយ ដោយអំណាចខ្យល់ដកដង្ហើមចូលវែង រមែងតាំងមាំ, លោកឈ្មោះថា ជាអ្នកអប់រំសតិដោយសតិនោះ ដោយញាណនោះ, សតិរបស់ភិក្ខុអ្នកដឹងសេចក្តីដែលចិត្តមានអារម្មណ៍តែមួយមិនរវើរវាយដោយអំណាចខ្យល់ដកដង្ហើមចេញវែង រមែងតាំងមាំ, លោកឈ្មោះថា ជាអ្នកអប់រំសតិដោយសតិនោះ ដោយញាណនោះ ។ល។ សតិរបស់ភិក្ខុអ្នកដឹងសេចក្តីដែលចិត្តមានអារម្មណ៍តែមួយ មិនរវើរវាយ ដោយអំណាចភាពជាអ្នកពិចារណាឃើញសេចក្តីលះបង់ដកខ្យល់ដង្ហើមចូល ... ដោយអំណាចភាពជាអ្នកពិចារណាឃើញសេចក្តីលះបង់ ដកដង្ហើមចេញ រមែងតាំងមាំ, លោកឈ្មោះថា ជាអ្នកអប់រំសតិដោយសតិនោះដោយញាណនោះ ។

## មតិខ្យល់ដកដង្ហើមចូលនិងចេញ តាមអដ្ឋកថាវិន័យនិងព្រះសូត្រ

បណ្ដាបទទាំងនោះ ពីរបទថា ទីឃំ វា អស្សសន្តោ : កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អញដកដង្ហើមចូលវែង បានដល់កាលឱ្យខ្យល់ដកដង្ហើមចូលវែងប្រព្រឹត្តទៅ ។ ក្នុងអដ្ឋកថាវិន័យ លោកពោលទុកថា ខ្យល់ដែលចេញទៅខាងក្រៅ ឈ្មោះថា អស្សាសៈ គឺខ្យល់ដកដង្ហើមចេញ, ខ្យល់ដែលចូលទៅខាងក្នុងឈ្មោះថា បស្សាសៈ គឺ ខ្យល់ដកដង្ហើមចូល ។ ចំណែកក្នុងអដ្ឋកថា នៃព្រះសូត្រទាំងឡាយមកដោយប្រាសលំដាប់គ្នា ។

បណ្ដាខ្យល់ទាំងពីរនោះ ក្នុងវេលាដែលសត្វអ្នកដេកនៅក្នុងគភ៌សូម្បីគ្រប់ប្រភេទចេញចាកផ្ទៃម្ដាយ ខ្យល់ខាងក្នុងពោះចេញទៅខាងក្រៅមុន ខាងក្រោយ ខ្យល់ខាងក្រៅនាំយកល្អងដែលល្អិតចូលទៅខាងក្នុងប៉ះខ្ទប់ពិតានហើយរលត់ទៅ ។ គប្បីជ្រាបខ្យល់អស្សាសៈនិងបស្សាសៈយ៉ាងនេះសិន ។ ចំណែកសេចក្ដីដែលខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលទាំងនោះ មានរយៈវែងនិងខ្លី គប្បីជ្រាបដោយអំណាចនៃកាល ។ ដូចយ៉ាងថា ទឹកឬខ្សាច់ ផ្សាយចេញទៅមានរយៈ គឺ ឱកាសតាំងនៅ គេហៅថា ទឹកវែង ខ្សាច់វែង ទឹកខ្លី ខ្សាច់ខ្លី យ៉ាងណា ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញសូម្បីដែលល្អិតស្មើញក៏យ៉ាងនោះ ញ៉ាំងប្រទេ

សដែលវែងក្នុងខ្ទនដំរីនិងខ្ទនពស់ ពោលគឺ អត្តភាពរបស់ដំរីនិងពស់ទាំងនោះ ឱ្យពេញសន្សើម ៗ ហើយក៏ចេញទៅសន្សើម ៗ ; ព្រោះដូច្នោះ ទើបលោកហៅថា វែង ៗ ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ញុំាងប្រទេសដែលខ្លី ពោលគឺ អត្តភាពនៃសុនខ និងទន្សាយជាដើម ឱ្យពេញរហ័សហើយក៏ចេញរហ័សដូចគ្នា; ព្រោះដូច្នោះ ទើបលោកហៅថា ខ្លី ៗ តែបណ្ដាមនុស្សទាំងឡាយ មានមនុស្សពួកខ្លះដកដង្ហើមចេញនិងដកដង្ហើមចូលវែងដោយអំណាចរយៈកាល (វែង) ដូចដំរី និងពស់ជាដើម ពួកខ្លះដកដង្ហើមចេញនិងដកដង្ហើមចូលខ្លី ដូចសុនខនិងទន្សាយជាដើម; ព្រោះដូច្នោះខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញរបស់មនុស្សទាំងនោះ ដោយអំណាចកាល ដែលចេញនិងចូលអស់វេលាយូរ គប្បីជ្រាបថា វែង ដែលចេញនិងចូលអស់វេលាតិច គប្បីជ្រាបថា ខ្លី ៗ

## ចម្រើនអានាបានស្សតិកម្មដ្ឋាន រមែងបានបាមោជ្ជៈជាដើម

ក្នុងខ្យល់ដកដង្ហើមចូលនិងចេញនោះ ភិក្ខុនេះកាលដកដង្ហើមចេញនិងដកដង្ហើមចូលវែង ដោយអាការ ៩ យ៉ាង រមែងដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញដកដង្ហើមចូលវែង ៗ ក៏កាលលោកដឹងច្បាស់យ៉ាងនេះ គប្បីជ្រាបថា ការចម្រើនកាយានុបស្សនាសតិប្បដ្ឋាន រមែង

សម្រេចដោយអាការណាទីមួយ ដូចន័យដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងបដិសម្ភិទា[១]ថា ៖

"ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង តើដូចម្ដេច ។ ភិក្ខុដកចេញនូវដង្ហើមចេញវែង ក្នុងចំណែកនៃកាលវែង ដកចូលនូវដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង ដកចេញក្ដី ដកចូលក្ដី នូវដង្ហើមចេញឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង កាលភិក្ខុដកចេញក្ដី ដកចូលក្ដី នូវដង្ហើមចេញឬដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង (ច្រើនដង) ឆន្ទៈ (ចំណង់អ្វីមួយ) រមែងកើតឡើង ភិក្ខុដកចេញនូវដង្ហើមចេញវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ ដកចូលនូវដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ ដកចេញក្ដី ដកចូលក្ដី នូវដង្ហើមចេញ ឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ ។ កាលភិក្ខុដកចេញក្ដី ដកចូលក្ដី នូវដង្ហើមចេញ ឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃឆន្ទៈ (ច្រើនដង)

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩៨/១២១ ។

បាមោជ្ជៈ រមែងកើតឡើង ភិក្ខុដកចេញនូវដង្ហើមចេញវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ ដកចូលនូវដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ ដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញ ឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ កាលភិក្ខុដកចេញក្តី ដកចូលក្តី នូវដង្ហើមចេញឬដង្ហើមចូលវែងដ៏ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកនៃកាលវែង ដោយអំណាចនៃបាមោជ្ជៈ (ច្រើនដង)ចិត្តក៏ឃ្លាតចេញ អំពីដង្ហើមចេញឬដង្ហើមចូលវែង ឧបេក្ខាក៏តាំងនៅស៊ប់ នេះកាយគឺដង្ហើមចេញនិងដង្ហើមចូលវែង ដោយអាការ ៩ យ៉ាង ដែលឈ្មោះថា ឧបដ្ឋាន, សតិ ឈ្មោះថា អនុបស្សនាញាណ, កាយ ឈ្មោះថា ឧបដ្ឋាន មិនមែនឈ្មោះថាសតិទេ, សតិ ឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង ពិចារណាឃើញនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ហេតុនោះលោកពោលថា កាយានុបស្សនាសតិប្បដ្ឋានភាវនា ដោយប្រការដូច្នេះ ។

សូម្បីក្នុងបទដែលកំណត់ដោយខ្យល់ខ្លី ក៏មានន័យដូចគ្នា ។ ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះ ៖

ក្នុងបទដែលកំណត់ដោយខ្យល់វែងនោះ លោកពោលទុកថា "ដកចូលនូវដង្ហើមចូលវែង ក្នុងចំណែកនៃកាលវែង" ដូច្នេះ យ៉ាងណា

ក្នុងបទដែលកំណត់ ដោយខ្យល់ខ្លីនេះ ក៏មានពាក្យដែលមកក្នុងបាលីថា "ដកចូលនូវដង្ហើមចូលខ្លី ក្នុងចំណែកនៃកាលខ្លី" ដូច្នោះ ។ ព្រោះហេតុនោះ គប្បីប្រកបដោយអំណាចនៃបទដែលកំណត់ថា ខ្លីនោះ ដរាបដល់ពាក្យថា ព្រោះហេតុនោះ ទើបលោកពោលថា "ការចម្រើនសតិប្បដ្ឋាន គឺ ការពិចារណាឃើញកាយក្នុងកាយ" ។ ភិក្ខុនេះ កាលដឹងច្បាស់ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលដោយអាការ ៩ យ៉ាងទាំងនេះ ក្នុងចំណែកនៃកាលវែងនិងក្នុងចំណែកនៃកាលខ្លី ដូចពណ៌នាមកដូច្នេះ បណ្ឌិតគប្បីជ្រាបថា "ភិក្ខុកាលដកដង្ហើមចូលវែង រមែងដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ល ។ ឬកាលដកដង្ហើមចេញខ្លី រមែងដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី" ដូច្នេះ ។ម្យ៉ាងទៀត កាលភិក្ខុនោះដឹងយ៉ាងនេះ វណ្ណៈ (គឺ អាការ) ទាំង ៤ គឺ ខ្យល់ដកដង្ហើមចូលវែងនិងខ្លី សូម្បីខ្យល់ដកដង្ហើមចេញ ក៏យ៉ាងនោះ រមែងប្រព្រឹត្តទៅត្រង់ចុងច្រមុះរបស់ភិក្ខុដូច្នេះឯង ។

ពាក្យថា សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ : ភិក្ខុសិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សីមដកដង្ហើមចេញ, សិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សីមដក

ដង្ហើមចូល, មានអធិប្បាយថា លោករមែងកំណត់ថា "យើងនឹងធ្វើខាងដើម កណ្ដាល និងទីបំផុតនៃកងខ្យល់ដកដង្ហើមចេញទាំងអស់ ឱ្យដឹងច្បាស់ គឺ ធ្វើឱ្យប្រាកដដកដង្ហើមចេញ (និង) រមែងកំណត់ថា "យើងនឹងធ្វើខាងដើម កណ្ដាល និងទីបំផុតនៃកងខ្យល់ដកដង្ហើមចូលទាំងអស់ ឱ្យដឹងច្បាស់ គឺ ធ្វើឱ្យប្រាកដដកដង្ហើមចូល" ។ កាលភិក្ខុធ្វើឱ្យដឹងច្បាស់ គឺ ធ្វើឱ្យប្រាកដដោយអាការយ៉ាងនោះ រមែងដកដង្ហើមចេញនិងដកដង្ហើមចូល ដោយចិត្តដែលសម្បយុត្តដោយញាណ; ព្រោះដូច្នោះ លោកទើបពោលថា រមែងសិក្សាថា "អាត្មាអញនឹងដកដង្ហើមចេញ នឹងដកដង្ហើមចូល" ។

ពិតមែន ខាងដើមក្នុងកងខ្យល់ដកដង្ហើមចូល ឬក្នុងកងខ្យល់ដកដង្ហើមចេញដែលស្ទុះទៅយ៉ាងល្អិត (ស្ងប់) រមែងប្រាកដដល់ភិក្ខុមួយរូប, តែកណ្ដាល និងទីបំផុត មិនប្រាកដ, លោកអាចកំណត់បានចំពោះតែខាងដើមប៉ុណ្ណោះ រមែងលំបាកក្នុងកណ្ដាលនិងទីបំផុត ។ មួយរូបទៀត រមែងប្រាកដតែកណ្ដាល, ឯខាងដើម និងទីបំផុត មិនប្រាកដ, លោកអាចកំណត់បានចំពោះតែត្រង់កណ្ដាលប៉ុណ្ណោះ រមែងលំបាកក្នុងខាងដើមនិងទីបំផុត ។ មួយរូបទៀត រមែងប្រាកដតែទីបំផុត, ឯខាងដើម និងកណ្ដាល មិនប្រាកដ, លោកអាចកំណត់បានចំពោះទីបំផុតប៉ុណ្ណោះ

រមែងលំបាកក្នុងខាងដើម និងកណ្ដាល ។ មួយរូបទៀត រមែងប្រាកដបានស្មូម្បីទាំងអស់ លោកអាចកំណត់បានស្មូម្បីទាំងអស់ រមែងមិនលំបាកក្នុងចំណែកណា ៗ ។ ព្រះមានព្រះភាគកាលទឹងទ្រង់ពន្យល់ថា ដែលភិក្ខុគប្បីជាអ្នកដឹងដូច្នោះ ទើបត្រាស់ថា "ភិក្ខុសិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចេញ; សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចូល" ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា សិក្ខតិ : (ភិក្ខុ) សិក្សាថា សេចក្ដីថា រមែងប្រារព្ធព្យាយាម គឺ ព្យាយាមយ៉ាងនោះ ។ ម្យ៉ាងទៀត ក្នុងបទថា សិក្ខតិ នេះ គប្បីឃើញសេចក្ដីយ៉ាងនេះថា សេចក្ដីសង្រួមរបស់ភិក្ខុដែលជាយ៉ាងនោះ នេះឈ្មោះថា អធិសីលសិក្ខា ក្នុងអធិការពោលអំពីអានាបានស្សតិភាវនានេះ សមាធិរបស់លោក អ្នកជាយ៉ាងនោះ នេះឈ្មោះថា អធិចិត្តសិក្ខា បញ្ញារបស់លោកអ្នកជាយ៉ាងនោះ នេះឈ្មោះថា អធិបញ្ញាសិក្ខា លោករមែងកំណត់ គឺ រមែងសេពសោយ ចម្រើនធ្វើឱ្យច្រើននូវសិក្ខា ៣ យ៉ាង ដូចពណ៌នាមកនេះ ដោយសតិនោះ ដោយមនសិការនោះ ក្នុងអារម្មណ៍នោះ ។ ព្រោះថា ដោយន័យមុន បណ្ដាពីរន័យនោះ ភិក្ខុគប្បីដកដង្ហើមចេញនិងដកដង្ហើមចូលតែម្យ៉ាងប៉ុណ្ណោះ មិនត្រូវធ្វើកិច្ចយ៉ាងណាមួយដទៃឡើយ តែចាប់ផ្ដើមតាំងពីវេលាដែលដឹង

ច្បាស់ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលនេះទៅ គួរធ្វើសេចក្តីព្យាយាមក្នុងអាការដែលឱ្យញាណកើតឡើងជាដើម; ព្រោះដូច្នោះ អ្នកសិក្សាគប្បីជ្រាបថា ក្នុងន័យមុននោះ ព្រះមានព្រះភាគត្រាស់បាលីទុកដោយអំណាចជាវត្តមានកាលថា រមែងកំណត់ដឹងច្បាស់ថា អញដកដង្ហើមចេញ រមែងកំណត់ដឹងច្បាស់ថា អញដកដង្ហើមចូលប៉ុណ្ណោះ ហើយលើកព្រះបាលីឡើងដោយអំណាចពាក្យដែលជាអនាគតកាល ដោយន័យមានជាដើមថា "សិក្សាថា អញនឹងកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួង សឹមដកដង្ហើមចេញ" ដូច្នេះ ដើម្បីនឹងទ្រង់សម្តែងអាការដែលឱ្យញាណកើតឡើងជាដើមដែលគួរធ្វើចាប់ផ្តើមតាំងពីកាលនេះទៅ ។

## ភិក្ខុកំណត់កម្មដ្ឋានហើយ កាយសង្ខារទើបស្ងប់

ពាក្យថា បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ បស្សសិស្សាមីតិ សិក្ខតិ : ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់កាយសង្ខារ (គឺខ្យល់អស្សាសបស្សាសៈ) សឹមដកដង្ហើមចេញ, រម្ងាប់កាយសង្ខារ សឹមដកដង្ហើមចូល, សេចក្តីថា លោករមែងកំណត់ថា អញនឹងជាអ្នកស្ងប់គឺ រម្ងាប់រលត់ បានដល់ ឱ្យកាយសង្ខារដ៏គ្រោតគ្រាតស្ងប់ទៅ ដកដង្ហើមចេញដកដង្ហើមចូល ។ ក្នុងពាក្យថា នឹងជាអ្នករម្ងាប់

កាយសង្ខារដ៏គ្រោតគ្រាត នោះ គប្បីជ្រាបសភាពដែលខ្យល់ជារបស់គ្រោតគ្រាតនិងល្អិត និងសេចក្ដីស្ងប់យ៉ាងនេះ គឺ ៖

ក៏ក្នុងកាលមុនគឺ ក្នុងវេលាដែលភិក្ខុនេះមិនទាន់បានកំណត់កម្មដ្ឋាន កាយនិងចិត្ត នៅមានសេចក្ដីខ្វល់ខ្វាយ នៅគ្រោតគ្រាតកាលកាយនិងចិត្តដែលជារបស់គ្រោតគ្រាត មិនទាន់ស្ងប់ សូម្បីខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ក៏ជារបស់គ្រោតគ្រាត គឺ ប្រព្រឹត្តទៅលើសកម្លាំង ច្រមុះមិនល្មមដកដង្ហើម ត្រូវឈរដកដង្ហើមចូលខ្លះ ដកដង្ហើមចេញតាមមកមាត់ខ្លះ តែកាលណា កាយក្ដី ចិត្តក្ដី ជារបស់ដែលលោកកំណត់ហើយ កាលនោះ កាយនិងចិត្តនោះ ទើបជារបស់ស្ងប់រម្ងាប់ ។ កាលកាយនិងចិត្តនោះ ស្ងប់ហើយ ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល រមែងប្រព្រឹត្តទៅល្អិត គឺ ជាសភាពដល់អាការដែលនិងត្រូវសង្កេតមើលថា "មានឬទេហ្ន៎" ។ ប្រៀបដូចខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលរបស់បុរសអ្នករត់ចុះអំពីភ្នំ ឬអ្នកដាក់របស់ធ្ងន់ចុះអំពីសីសៈហើយឈរ រមែងជារបស់គ្រោតគ្រាត ច្រមុះមិនល្មមដកដង្ហើម ត្រូវឈរដកដង្ហើមចេញខ្លះ ដកដង្ហើមចូលខ្លះ តាមទ្វារមាត់ ក្នុងកាលណាគេបន្ទោបង់សេចក្ដីខ្វល់ខ្វាយនោះចេញ ងូតនិងផឹកទឹកហើយ យកសំពត់សើមគ្របត្រង់ទ្រូង ដេកសម្រាកនៅក្រោមម្លប់ឈើត្រជាក់ ៗ; កាល

នោះ ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលនោះរបស់គេ ទើបជាខ្យល់ល្អិត គឺ ដល់អាការដែលនិងត្រូវសង្កេតមើលថា "មានឬទេហ្ន៎" យ៉ាងណា ក្នុងកាលមុន គឺ ក្នុងវេលាដែលភិក្ខុនេះមិនទាន់បានកំណត់កម្មដ្ឋានកាយនិងចិត្ត ។ល ។ គឺ ដល់អាការដែលត្រូវគន់រកថា "មានឬទេហ្ន៎" យ៉ាងនោះដែរ ។ សេចក្ដីនោះព្រោះហេតុអ្វី ? ព្រោះសេចក្ដីពិតជាយ៉ាងនោះ ក្នុងកាលមុន គឺ ក្នុងវេលាដែលលោកមិនទាន់បានកំណត់កម្មដ្ឋាន ការនឹកដល់ ការប្រមូលមក ការមនសិការ និងការពិចារណាថា យើងនឹងរម្ងាប់កាយសង្ខារចំណែកគ្រោតគ្រាត ៗ ដូច្នេះ មិនមានដល់លោកនោះទេ, តែក្នុងវេលាដែលលោកកំណត់ហើយ ទើបមាន ។ ព្រោះហេតុនោះ ក្នុងវេលាដែលកំណត់កម្មដ្ឋាន កាយសង្ខាររបស់លោកនោះ ទើបជារបស់ល្អិតជាងវេលាដែលមិនទាន់បានកំណត់ ។ ព្រោះហេតុនោះ ព្រះបូរាណាចារ្យទាំងឡាយ ទើបពោលទុកថា ៖

> កាលកាយនិងចិត្តនៅរសាប់រសល់ កាយសង្ខាររមែងប្រព្រឹត្តទៅលើសប្រមាណ កាលកាយនិងចិត្ត មិនរសាប់រសល់ កាយសង្ខារ រមែងប្រព្រឹត្តទៅល្អិត ។

## កាយសង្ខារល្អិតទៅតាមលំដាប់

កាយសង្ខារសូម្បីក្នុងវេលាកំណត់ក៏នៅគ្រោតគ្រាត ក្នុងឧបចារនៃបឋមជ្ឈានល្អិត ។ សូម្បីក្នុងឧបចារនៃបឋមជ្ឈាននោះ ក៏នៅគ្រោតគ្រាត ក្នុងបឋមជ្ឈានល្អិត ។

ក្នុងបឋមជ្ឈាននិងក្នុងឧបចារនៃទុតិយជ្ឈាននៅគ្រោតគ្រាត ក្នុងទុតិយជ្ឈានល្អិត ។ ក្នុងទុតិយជ្ឈាននិងក្នុងឧបចារនៃទុតិយជ្ឈានក៏នៅគ្រោតគ្រាត ក្នុងតតិយជ្ឈានល្អិត ។ ក្នុងតតិយជ្ឈាននិងឧបចារនៃចតុត្ថជ្ឈានក៏នៅគ្រោតគ្រាត ក្នុងចតុត្ថជ្ឈានល្អិតក្រៃលែងណាស់ ដល់ការមិនប្រព្រឹត្តទៅតែម្តង ។ ពាក្យនេះ ជាមតិរបស់អាចារ្យអ្នកពោលទីឃនិកាយ និងសំយុត្តនិកាយ ។ ចំណែកអាចារ្យទាំងឡាយអ្នកពោលមជ្ឈិមនិកាយ រមែងប្រាថ្នាសេចក្តីល្អិតជាងគ្នា សូម្បីក្នុងឧបចារនៃឈានជាន់ខ្ពស់ ៗ ឡើងទៅជាងឈានជាន់ទាប ៗ យ៉ាងនេះ គឺ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងបឋមជ្ឈាន នៅជារបស់គ្រោតគ្រាត ក្នុងឧបចារនៃទុតិយជ្ឈានទើបចាត់ថា ល្អិត ដូច្នេះជាដើម ។ ក៏មតិរបស់អាចារ្យទាំងអស់នោះឯងគួរជ្រាបដូច្នេះថា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងវេលាដែលនៅមិនបានកំណត់ (កម្មដ្ឋាន) រមែងរម្ងាប់ទៅក្នុងវេលាដែលកំណត់ហើយ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងវេលាដែលបានកំណត់ហើយ រមែងរម្ងាប់ទៅ

ក្នុងឧបចារនៃបឋមជ្ឈាន ។ល។ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងឧបចារនៃចតុត្ថជ្ឈាន រមែងរម្ងាប់ទៅក្នុងចតុត្ថជ្ឈាន ។ ក្នុងសមថៈ មានន័យប៉ុណ្ណេះ ។

ចំណែកក្នុងវិបស្សនា គប្បីជ្រាបន័យដូច្នេះ ៖

កាយសង្ខារដែលប្រព្រឹត្តទៅក្នុងកាលមិនទាន់បានកំណត់ នៅគ្រោតគ្រាត ក្នុងការកំណត់មហាភូតរូបល្ហិត សូម្បីការកំណត់មហាភូតរូបនោះ ក៏នៅគ្រោតគ្រាត ក្នុងការកំណត់ឧបាទាយរូបល្ហិត សូម្បីការកំណត់ឧបាទាយរូបនោះ ក៏នៅគ្រោតគ្រាត ក្នុងការកំណត់រូបទាំងអស់ល្ហិត សូម្បីការកំណត់រូបទាំងអស់នោះ ក៏នៅគ្រោតគ្រាត ។ ក្នុងការកំណត់អរូបទិនល្ហិត, សូម្បីការកំណត់អរូបនោះ ក៏នៅគ្រោតគ្រាត, ក្នុងការកំណត់រូបនិងអរូបល្ហិត, សូម្បីការកំណត់រូបនិងអរូបនោះ ក៏នៅគ្រោតគ្រាត ក្នុងការកំណត់បច្ច័យល្ហិត, សូម្បីការកំណត់បច្ច័យនោះ ក៏នៅគ្រោតគ្រាត ក្នុងការឃើញនាមរូបព្រមទាំងបច្ច័យល្ហិត, សូម្បីការឃើញនាមរូបព្រមទាំងបច្ច័យនោះ ក៏នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលប្រកបដោយលក្ខណៈ និងអារម្មណ៍ល្ហិត, សូម្បីនោះក៏នៅគ្រោតគ្រាត ក្នុងវិបស្សនាដែលមានកម្លាំងថយចុះ, ក្នុងវិបស្សនាដែលមានកម្លាំងខ្លាំង ទើបចាត់ថា ល្ហិត ។ ក្នុងវិបស្សនាន័យនោះ គប្បីជ្រាបសេចក្តីស្ងប់ទៅនៃខ្យល់

អស្សាសៈ និងបស្សាសៈមុន ៗ ដោយខ្យល់អស្សាសៈនិងបស្សាសៈក្រោយ ៗ ដោយន័យដូចពោលហើយក្នុងសេចក្តីខាងដើមនុ៎ះឯង ។

ក្នុងពាក្យថា **រម្ងាប់កាយសង្ខារដែលគ្រោតគ្រាត** នេះ គប្បីជ្រាបសេចក្តីដែលខ្យល់គ្រោតគ្រាតល្ហិតនិងស្ងប់ទៅ ដោយន័យដូចពណ៌នាមកដូច្នេះឯង ។ ចំណែកក្នុងបដិសម្ភិទា ព្រះធម្មសេនាបតីសារីបុត្រ ពោលសេចក្តីនៃបទនោះ ព្រមទាំងពាក្យចោទសួរនិងពាក្យឆ្លើយដោះស្រាយឱ្យច្បាស់យ៉ាងនេះ ៖

"បុគ្គលសិក្សាដូចម្តេច បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ។ កាយសង្ខារ តើដូចម្តេច ។ ពួកខ្យល់ដកដង្ហើមចេញវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះ ជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ, បុគ្គលកាលរម្ងាប់ រំលត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ពួកខ្យល់ដកដង្ហើមចូលវែង ដែលប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនេះ ជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ, បុគ្គលកាលរម្ងាប់ រំលត់ បង្ក្រាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា; ពួកខ្យល់ដកដង្ហើមចេញខ្លី ដង្ហើមចូលខ្លី ឬដង្ហើមចេញសម្រាប់បុគ្គលកំណត់ដឹងនូវកាយទាំងពួងដែលប្រព្រឹត្តទៅក្នុងកាយ ធម៌

ទាំងនេះ ជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ, បុគ្គលកាលរម្ងាប់រំលត់ បង្រ្កាបនូវកាយសង្ខារទាំងនោះ ឈ្មោះថា សិក្សា ។ ការឱន ការផ្ងាក ការទម្រេត ការឈម ការរញ្ជួយ ការអន្ទះសា ការកម្រើក ការញាប់ញ័រ ណានៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ។ ការមិនឱន ការមិនផ្ងាក ការមិនទម្រេត ការមិនឈម ការមិនរញ្ជួយ ការមិនអន្ទះសា ការមិនកម្រើក ការមិនញាប់ញ័រ ណានៃកាយ ដោយកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារដ៏ល្អិតសុខុម មានសភាពយ៉ាងនោះ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ។ បានឮថា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការយ៉ាងនេះហើយ ។ កាលបើយ៉ាងនេះ ការប្រាកដនៃការបានខ្យល់មិនទាន់មាន ការប្រាកដនៃដង្ហើមចេញ និងដង្ហើមចូល ក៏មិនទាន់មាន ការប្រាកដនៃអានាបានស្សតិ ក៏មិនទាន់មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិ

ក៏មិនទាន់មានទេ បណ្ឌិតទាំងឡាយ រមែងមិនចូលកាន់សមាបត្តិនោះផង មិនចេញចាកសមាបត្តិនោះផង ។ បានឮថា បុគ្គលសិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចេញ សិក្សាថា អាត្មាអញកាលរម្ងាប់នូវកាយសង្ខារ ទើបដកដង្ហើមចូល ដោយអាការយ៉ាងនេះហើយ កាលបើយ៉ាងនេះ ការប្រាកដនៃការបានខ្យល់ក៏មាន ការប្រាកដនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល ក៏មាន ការប្រាកដនៃអានាបានស្សតិក៏មាន ទាំងការប្រាកដនៃអានាបានស្សតិសមាធិ ក៏មាន ទើបបណ្ឌិតទាំងឡាយ ចូលកាន់សមាបត្តិនោះផង ចេញចាកសមាបត្តិនោះផង ដំណើរនោះ ប្រៀបដូចជាអ្វី ប្រៀបដូចជាគាំងដែលគេគោះ សំឡេងគ្រោតគ្រាតរមែងប្រព្រឹត្តទៅជាដំបូង, ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃសំឡេងដ៏គ្រោតគ្រាត កាលបើសំឡេងគ្រោតគ្រាត បន្ទាប់មកសំឡេងដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ, ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃសំឡេងដ៏ល្អិត កាលសំឡេងដ៏ល្អិតរលត់ហើយ; បន្ទាប់មក ចិត្តរមែងប្រព្រឹត្តទៅជាខាងក្រោយ ព្រោះចិត្តមាននិមិត្ត( នៃសំឡេង )ដ៏ល្អិតជាអារម្មណ៍ មានឧបមារដូចម្តេចមិញ មានឧបមេយ្យដូចជាខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលដ៏គ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង ។ ព្រោះ

បុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អនូវនិមិត្តនៃខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាត កាលខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលដ៏គ្រោតគ្រាតរលត់ហើយ, បន្ទាប់មកខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិត រមែងប្រព្រឹត្តទៅជាខាងក្រោយ, ព្រោះបុគ្គលកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តល្អ ព្រោះចាំទុកល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលដ៏ល្អិត កាលខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលដ៏ល្អិតរលត់ហើយ, បន្ទាប់មក ចិត្តក៏មិនដល់នូវសេចក្តីរាយមាយ ក្នុងកាលខាងក្រោយ ព្រោះចិត្តយកនិមិត្តនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលដ៏ល្អិតជាអារម្មណ៍ ក៏យ៉ាងនោះដែរ ។ កាលបើយ៉ាងនេះ ការប្រាកដនៃការបានខ្យល់ ក៏មាន ការប្រាកដនៃខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល ក៏មាន ការប្រាកដនៃអានាបានស្សតិ ក៏មាន ការប្រាកដនៃអានាបានស្សតិសមាធិ ក៏មាន បណ្ឌិតទាំងឡាយរមែងចូលកាន់សមាបត្តិនោះផង រមែងចេញចាកសមាបត្តិនោះផង កាយ គឺ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលរបស់បុគ្គលកាលរម្ងាប់នូវកាយសង្ខារ ឈ្មោះថា ឧបដ្ឋាន សតិ ឈ្មោះថា អនុបស្សនាញាណ, កាយ ឈ្មោះថា ឧបដ្ឋាន មិនឈ្មោះថា សតិទេ ចំណែកខាងសតិ ទើបឈ្មោះថា ឧបដ្ឋានផង ឈ្មោះថា សតិផង បុគ្គលរមែងពិចារណាឃើញនូវ

កាយនោះ ដោយសតិនោះ ដោយញាណនោះ, ហេតុនោះ លោកពោលថា កាយេ កាយានុបស្សនាសតិបដ្ឋានភាវនា : ការចម្រើនសតិបដ្ឋាន គឺ ការពិចារណាឃើញកាយក្នុងកាយ”[១] ដូច្នេះ ។

ក្នុងបទថា បស្សម្ភយំ កាយសង្ខារំ : រម្ងាប់កាយសង្ខារ សឹមដកដង្ហើមចូល នេះ មានការពណ៌នាតាមលំដាប់បទនៃបឋមចតុក្កៈ ដែលត្រាស់ទុកដោយអំណាចនៃកាយានុបស្សនាត្រឹមតែប៉ុណ្ណេះសិន ។ តែព្រោះក្នុងអធិការនេះ ចតុក្កៈនេះប៉ុណ្ណោះ ត្រាស់ទុកដោយអំណាចនៃកម្មដ្ឋានរបស់កុលបុត្រអ្នកចាប់ផ្ដើម ធ្វើ, ចំណែកចតុក្កៈ ៣ ទៀតក្រៅនេះ ត្រាស់ទុកដោយអំណាចនៃវេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនារបស់កុលបុត្រអ្នកសម្រេចឈានហើយ ក្នុងបឋមចតុក្កៈនេះ; ដូច្នោះ កុលបុត្រ អ្នកប្រាថ្នានឹងចម្រើនកម្មដ្ឋាននេះ ហើយសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ដោយវិបស្សនាដែលមានអានាបានចតុត្ថជ្ឈានជាទបដ្ឋាន គួរជ្រាបកិច្ចដែលខនគួរធ្វើមុនទាំងអស់ តាំងពីដើម ក្នុងអធិការនៃអានាបានស្សតិកម្មដ្ឋាននេះឯង ដោយអំណាចនៃកុលបុត្រអ្នកចាប់ផ្ដើមធ្វើ ។

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ១១៤/១៤៥ ។

## កុលបុត្រនឹងរៀនកម្មដ្ឋានត្រូវបំពេញសីលឱ្យបរិសុទ្ធ

កុលបុត្រគួរជម្រះសីល ៤ យ៉ាងឱ្យបរិសុទ្ធិមុន ។ ក្នុងសីលនោះ មានវិធីជម្រះឱ្យបរិសុទ្ធ ៣ យ៉ាង គឺ មិនត្រូវអាបត្តិ១ ចេញចាកអាបត្តិដែលត្រូវហើយ ១ មិនសៅហ្មងដោយកិលេសទាំងឡាយ១ ។ ពិតមែន ភាវនារមែងសម្រេចដល់កុលបុត្រអ្នកមានសីលបរិសុទ្ធិយ៉ាងនោះ ។ កុលបុត្រគួរបំពេញសូម្បីសីលដែលលោកហៅថា អភិសមាចារិកសីល ឱ្យបរិបូណ៌ល្អជាមុន ដោយអំណាចវត្តទាំងនេះ គឺ វត្តទីលានព្រះចេតិយ វត្តទីលានពោធិព្រឹក្ស ឧបជ្ឈាយ៍វត្ត អាចរិយាវត្ត វត្តក្នុងរោងភ្លើង វត្តក្នុងរោងឧបោសថ ខន្ធកវត្ត ៨២ មហាវត្ត ១៤ ។ ពិតមែន កុលបុត្រណា គប្បីពោលថា "យើងរក្សាសីល, កម្មដោយអភិសមាចារិកវត្តនិងមានប្រយោជន៍អ្វី ?" សីលរបស់កុលបុត្រនោះដែលនឹងបរិបូណ៌បាន នោះមិនមែនជាឋានៈដែលនឹងមានបាន ។ តែកាលអភិសមាចារិកវត្តបរិបូណ៌, សីលក៏នឹងបរិបូណ៌ ។ កាលសីលបរិបូណ៌, សមាធិរមែងកាន់យក ។ សមពិត ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ប្រព្រឹត្តមិនស្មើក្នុងពួកសព្រហ្មចារីបុគ្គលសោះ នឹងបំពេញសមាចារិកធម៌ គឺបញ្ញត្តសីលបាន ហេតុនុ៎ះ រមែងមិនមានទេ

បើមិនបានបំពេញអភិសមាចារិកធម៌ហើយ ទឹងបំពេញសេក្ខធម៌បាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបំពេញសេក្ខធម៌ហើយ ទឹងបំពេញសីលបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបំពេញសីលហើយ ទឹងបំពេញសម្មាទិដ្ឋិបាន ហេតុនុ៎ះ រមែងមិនមានទេ បើមិនបំពេញសម្មាទិដ្ឋិហើយ ទឹងបំពេញសម្មាសមាធិបាន ហេតុនុ៎ះ រមែងមិនមានទេ”[១] ។ ព្រោះហេតុដូច្នោះ កុលបុត្រនេះគួរបំពេញសូម្បីវត្ត មានចេតិយង្គណវត្តជាដើម ដែលលោកហៅថា អភិសមាចារិកវត្ត ឱ្យបរិបូណ៌ជាមុនសិន ។ ខាងមុខអំពីការជម្រះសីលឱ្យបរិសុទ្ធនោះ ក៏គួរកាត់បលិពោធ (សេចក្តីកង្វល់) យ៉ាងណាមួយ ដែលមាននៅក្នុងបណ្តាបលិពោធ ១០ យ៉ាង ដែលអាចារ្យទាំងឡាយពោលទុកយ៉ាងនេះថា ៖

“បលិពោធ (សេចក្តីកង្វល់) ១០ យ៉ាងនោះ គឺ អាវាស ១ ត្រកូល១ លាភ (គឺ បច្ច័យបួន)១ គណៈ (គឺ ពួក) ១ ការងារ (គឺការកសាង) ជាគម្រប់ប្រាំ១ អទ្ធានៈ (គឺ ដើរមកឆ្ងាយ)១ ញាតិ១ អាពាធ១ គន្ថៈ (គឺ ការរៀនបរិយត្តិ)១ ឥទ្ធិឫទ្ធិ១ ។ កុលបុត្រអ្នកកាត់បលិពោធបានយ៉ាងនេះហើយ ទើបគួររៀនកម្មដ្ឋាន” ។

១. អង្គុ. បញ្ច. ៤៤. ២១/២៨ ។

## កម្មដ្ឋាន ២ ព្រមទាំងអធិប្បាយ

កម្មដ្ឋាននោះ មាន ២ យ៉ាង គឺ សព្វត្ថកកម្មដ្ឋាន (កម្មដ្ឋានមានប្រយោជន៍ក្នុងកុសលធម៌ទាំងពួង) ១ បារិហារិយកម្មដ្ឋាន (កម្មដ្ឋានគួរបរិហាររក្សា) ១ ។ បណ្តាកម្មដ្ឋាន ២ យ៉ាងនោះ ដែលឈ្មោះថាសព្វត្ថកកម្មដ្ឋាន បានដល់ មេត្តា (ដែលចម្រើនទៅ) ក្នុងពួកភិក្ខុជាដើម និងមរណស្សតិ (ការរលឹកដល់សេចក្តីស្លាប់) ។ អាចារ្យពួកមួយពោលថា អសុភសញ្ញាខ្លះ ។ ពិតមែន ភិក្ខុដែលនឹងចម្រើនកម្មដ្ឋានគ្រាដំបូងត្រូវកាត់បលិពោធចេញសិន ហើយសឹមចម្រើនមេត្តាទៅក្នុងពួកភិក្ខុដែលនៅក្នុងសីមា, លំដាប់ពីនោះ គប្បីចម្រើនទៅក្នុងពួកទេវតាដែលនៅក្នុងសីមា, បន្ទាប់ពីនោះ គប្បីចម្រើនទៅក្នុងឥស្សរជនក្នុងគោចរគ្រាម, តពីនោះគប្បីចម្រើនទៅក្នុងពួកសព្វសត្វទាំងដល់អ្នកស្រុកក្នុងគោចរគ្រាមនោះ ។ ពិតមែន ភិក្ខុនោះ ធ្វើពួកជនអ្នកនៅរួមគ្នាឱ្យកើតមានចិត្តទន់ភ្លន់ ព្រោះមេត្តាក្នុងពួកភិក្ខុ ។ វេលានោះ លោកនឹងមានសេចក្តីនៅជាសុខ ។ លោករមែងបានពួកទេវតាអ្នកមានចិត្តទន់ភ្លន់ ព្រោះមេត្តាក្នុងពួកទេវតាអ្នកនៅក្នុងសីមាចាត់ការរក្សាទុកជាយ៉ាងល្អ ដោយការរក្សាដែលប្រកបដោយធម៌ ។ ទាំងជាអ្នកដែលឥស្សរជនទាំងឡាយ អ្នកមានចិត្តសន្តានទន់ភ្លន់ ព្រោះមេត្តាក្នុងឥស្សរជនក្នុងគោចរគ្រាម ចាត់រក្សាប្រុងប្រយ័ត្នទុកយ៉ាងល្អ ដោយការរក្សាដែលប្រពៃតាមធម៌ ។ និងជាអ្នក

ដែលអ្នកស្រុកទាំងនោះអ្នកមានចិត្តត្រូវអប់រំឱ្យជ្រះថ្លា ព្រោះមេត្តាក្នុងពួកអ្នកស្រុកក្នុងគោចរគ្រាមនោះ មិនមើលងាយត្រាច់ទៅ ។ ជាអ្នកត្រាច់ទៅមិនមានអ្វី ប៉ះទង្គិចក្នុងទីគ្រប់ស្ថាន ព្រោះមេត្តាក្នុងពួកសព្វសត្វ ។ មួយទៀត លោកកាលគិតថា យើងនឹងត្រូវស្លាប់ពិតប្រាកដ ដោយមរណស្សតិ លះការស្វែងរកដែលមិនសមគួរចេញ ជាអ្នកមានសេចក្តីតក់ស្លុតចម្រើនខ្ពស់ឡើងជាលំដាប់ រមែងជាអ្នកមានការប្រព្រឹត្តមិនធូរថយ ។ តណ្ហា រមែងមិនកើតឡើង សូម្បីក្នុងអារម្មណ៍ដែលជាទិព្វ ព្រោះអសុភសញ្ញា ។

ព្រោះហេតុនោះ គុណធម៌ទាំង ៣ (គឺ មេត្តា១ មរណស្សតិ១ អសុភសញ្ញា១) នោះ របស់ភិក្ខុនោះ លោកហៅថា សព្វត្ថកម្មដ្ឋាន ព្រោះធ្វើសេចក្តីអធិប្បាយថា ជាកម្មដ្ឋានដែលកុលបុត្រគប្បីប្រាថ្នា គឺគប្បីត្រូវការក្នុងទីគ្រប់ស្ថាន ព្រោះជាធម៌មានឧបការៈច្រើន និងព្រោះភាពជាបទដ្ឋាននៃការប្រឹងប្រែងប្រកបរឿយ ៗ ដែលសេចក្តីព្យាយាម តាមដែលប្រាថ្នាទុក ដោយន័យដូចពណ៌នាមកដូច្នេះ ។

ក៏បណ្តាអារម្មណ៍ ៣៨ ប្រការ កម្មដ្ឋានណា ដែលសមតាមចរិតរបស់កុលបុត្រណា កម្មដ្ឋាននោះ លោកហៅថា បារិហារិយកម្មដ្ឋាន ព្រោះជាកម្មដ្ឋានដែលកុលបុត្រនោះ គួរបរិហារទុកជានិច្ច ដោយន័យតាមដែលពោលហើយនុ៎ះឯង ។ តែក្នុងតតិយបារាជិកនេះ អានាបានកម្ម

ដ្ឋាននេះឯង លោកហៅថា បារិហារិយកម្មដ្ឋាន ។ ក្នុងអធិការពោលអំពីអានាបានកម្មដ្ឋាននេះ មានសេចក្តីសង្ខេបប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារអ្នកសិក្សាត្រូវការកថាពោលអំពីការជម្រះសីលឱ្យបរិសុទ្ធិ និងកថាពោលអំពីការកាត់បលិពោធ គប្បីកាន់យកអំពីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គចុះ ។

## គួររៀនកម្មដ្ឋានក្នុងសំណាក់ពុទ្ធឱរសរហូតដល់អ្នកបានឈាន

មួយទៀត កុលបុត្រអ្នកមានសីលបរិសុទ្ធិ និងកាត់បលិពោធបានហើយយ៉ាងនោះ កាលនឹងរៀនកម្មដ្ឋាននេះ គួររៀនក្នុងសំណាក់ពុទ្ធបុត្រអ្នកឱ្យចតុត្ថជ្ឈានកើតឡើងដោយកម្មដ្ឋាននេះឯង ហើយចម្រើនវិបស្សនាបានសម្រេចភាពជាព្រះអរហន្ត ។ កាលមិនបានជួបព្រះខីណាស្រពនោះ គួររៀនក្នុងសំណាក់ព្រះអនាគាមី កាលមិនបានសូម្បីព្រះអនាគាមីនោះ ក៏គួររៀនក្នុងសំណាក់ព្រះសកទាគាមី ។ កាលមិនបានសូម្បីព្រះសកទាគាមីនោះ ក៏គួររៀនក្នុងសំណាក់ព្រះសោតាបន្ន, កាលមិនបានសូម្បីព្រះសោតាបន្ននោះ ក៏គួររៀនក្នុងសំណាក់របស់លោកអ្នកបានចតុត្ថជ្ឈានដែលមានអានាបានៈជាអារម្មណ៍, កាលមិនបានលោកអ្នកបានចតុត្ថជ្ឈានសូម្បីនោះ ក៏គួររៀនក្នុងសំណាក់របស់ព្រះវិនិច្ឆយាចារ្យ អ្នកមិនភាន់ច្រឡំទាំងក្នុងបាលីនិងអដ្ឋកថា ។ ពិតមែន ព្រះអរិយបុគ្គលទាំងឡាយ

មានព្រះអរហន្តជាដើម រមែងប្រាប់ចំពោះមគ្គដែលខ្លួនបានសម្រេចហើយប៉ុណ្ណោះ ។ ចំណែកព្រះវិនិច្ឆយាចារ្យនេះជាអ្នកមិនកាន់ប្រទ្បំ កំណត់អារម្មណ៍ជាទីសប្បាយ និងមិនសប្បាយ ក្នុងអារម្មណ៍ទាំងពួងហើយទើបប្រាប់ ដូចអ្នកនាំទៅកាន់មកដំរីធំ ក្នុងព្រៃស្ទុកដូច្នោះ ។

## កម្មដ្ឋានមានសន្ធិ គឺ ទីត ៥ យ៉ាង

ក្នុងអធិការពោលអំពីការរៀនកម្មដ្ឋាននោះ មានអនុបុព្វីកថា ដូចតទៅនេះ ៖

ភិក្ខុនោះគួរជាអ្នកមានការប្រព្រឹត្តស្រាល បរិបូរណ៍ដោយវិន័យ និងមារយាទចូលទៅរកអាចារ្យដែលមានសេចក្តីដូចពោលហើយ គប្បីរៀនកម្មដ្ឋាន មានសន្ធិ ៥ ក្នុងសំណាក់របស់អាចារ្យនោះ អ្នកមានចិត្តដែលខ្លួនឱ្យត្រេកអរ ដោយវត្ត និងការបដិបត្តិ ។ ក្នុងពាក្យថា កម្មដ្ឋានមានសន្ធិ ៥ នោះ សន្ធិមាន ៥ យ៉ាងទាំងនេះ គឺ **ឧគ្គហៈ** ការរៀន ១ **បរិបុច្ឆា** ការសាកសួរ ១ **ឧបដ្ឋានៈ** សេចក្តីប្រាកដ ១ **អប្បនា** សេចក្តីតម្កល់មាំ ១ **លក្ខណៈ** សេចក្តីកំណត់ចំណាំ ១ ។

ក្នុងឧគ្គហៈជាដើមនោះ ការរៀនកម្មដ្ឋាន ឈ្មោះថា ឧគ្គហៈ ។ ការសាកសួរកម្មដ្ឋាន ឈ្មោះថា បរិបុច្ឆា ។ សេចក្តីប្រាកដនៃកម្មដ្ឋាន ឈ្មោះថា ឧបដ្ឋានៈ ។ សេចក្តីតម្កល់មាំនៃកម្មដ្ឋាន ឈ្មោះថា

អប្បនា ។ លក្ខណៈនៃកម្មដ្ឋាន ឈ្មោះថា លក្ខណៈ ។ មានពាក្យអធិប្បាយថា សេចក្ដីពិចារណានៃសភាពកម្មដ្ឋានថា កម្មដ្ឋាននេះ មានលក្ខណៈយ៉ាងនេះ ។ ភិក្ខុកាលរៀនកម្មដ្ឋាន ដែលមានសន្ធិ៥ យ៉ាងនេះ សូម្បីខ្លួនឯងក៏មិនលំបាក ទាំងមិនត្រូវរុកកួនអាចារ្យឱ្យលំបាក ។ ព្រោះដូច្នោះ គួរសូមអាចារ្យឱ្យប្រាប់តែបន្តិច ស្វាធ្យាយរហូតដល់អស់វេលាជាច្រើន កាលរៀនកម្មដ្ឋាន ដែលមានសន្ធិ ៥ យ៉ាងនោះហើយ បើក្នុងអាវាសនោះ មានសេនាសនៈជាដើមជាទីសប្បាយសោត គួរនៅក្នុងអាវាសនោះឯង បើក្នុងអាវាសនោះ មិនមានសេនាសនៈជាទីសប្បាយសោត គួរសូមលាអាចារ្យ បើជាអ្នកមានបញ្ញាខ្សោយ គួរទៅអស់ចម្ងាយមួយយោជន៍ជាយ៉ាងក្រៃលែង បើជាអ្នកមានបញ្ញាចាស់ក្លាក៏គួរទៅសូម្បីឆ្ងាយ (ជាងនោះ) បានហើយចូលទៅកាន់សេនាសនៈដែលប្រកបដោយអង្គនៃសេនាសនៈ ៥ យ៉ាង វៀរសេនាសនៈដែលមានទោស ១៨ យ៉ាង ហើយស្នាក់នៅក្នុងសេនាសនៈនោះ កាត់បលិពោធតូចចេញ ឆាន់កត្តាហាររួចស្រេចហើយ បន្ទោបង់សេចក្ដីពុលអាហារ ធ្វើចិត្តឱ្យរីករាយដោយការអនុស្សរណៈដល់គុណព្រះរតនត្រ័យ មិនវង្វេងភ្លេចកម្មដ្ឋានសូម្បីតែមួយបទ ដែលរៀនពីអាចារ្យគប្បីមនសិការអានាបានស្សតិកម្មដ្ឋាននេះ ។ ក្នុងវិស័យនៃតតិយបារាជិកនេះ មានសេចក្ដីសង្ខេបប៉ុណ្ណេះ ។ ចំណែកសេចក្ដីពិស្ដារ អ្នកសិក្សាដែលត្រូវការគថាមគ្គនេះ

គប្បីកាន់យកអំពីបករណ៍វិសេសវិសុទ្ធិមគ្គចុះ ។

## វិធីមនសិការអានាបានស្សតិកម្មដ្ឋាន ៨ យ៉ាង

ក៏ក្នុងពាក្យដែលខ្ញុំព្រះករុណាពោលថា គប្បីមនសិការអានាបានស្សតិកម្មដ្ឋាននេះ មានមនសិការវិធីដូចតទៅនេះ ៖

គឺ ការរាប់ ការតាមចង ការពាល់ត្រូវ ការបញ្ឈប់ទុក ការកំណត់ ការផ្លាស់ប្ដូរ សេចក្ដីបរិសុទ្ធិ និងការឃើញធម៌ទាំងនោះជាក់ច្បាស់ ។

ការរាប់ទុំះឯង ឈ្មោះថា **គណនា** : ការរាប់ ។

ការកំណត់តាម ឈ្មោះថា **អនុពន្ធនា** : ការតាមចង ។

ឋានដែលខ្យល់ប៉ះត្រូវ ឈ្មោះថា **ផុសនា** : ការពាល់ត្រូវ ។

សេចក្ដីតម្កល់មាំឈ្មោះថា **ឋបនា** : ការបញ្ឈប់ទុក ។

ការឃើញញច្បាស់ ឈ្មោះថា **សល្លក្ខណា** : ការកំណត់ ។

មគ្គ ឈ្មោះថា **វិវដ្ដនា** : ការផ្លាស់ប្ដូរ ។

ផលឈ្មោះថា **បារិសុទ្ធិ** : សេចក្ដីបរិសុទ្ធិ ។

ការពិចារណា ឈ្មោះថា **តេសញ្ច បដិបស្សនា** : ការឃើញធម៌ទាំងនោះ ជាក់ច្បាស់ ។

# អធិប្បាយវិធីរាប់ខ្យល់ដកដង្ហើមចេញចូល

បណ្ដាមនសិការវិធី មានការរាប់ជាដើមនោះ កុលបុត្រអ្នកចាប់ផ្ដើមបំពេញនេះ សេចក្ដីមនសិការកម្មដ្ឋាននេះដោយការរាប់មុន ។ កាលទឹងរាប់ មិនគួរឈប់រាប់តិចជាង ៥, មិនគួររាប់ឱ្យច្រើនជាង ១០, មិនគួរសម្ដែង (ការរាប់) ឱ្យដាច់ក្នុងចន្លោះ ។

ព្រោះកាលឈប់រាប់តិចជាង ៥ ចិត្តុប្បាទ រមែងក្ដៅក្រហាយក្នុងឱកាសចង្អៀត ដូចហ្វូងគោ ដែលរួមឃាំងទុកក្នុងក្រោលដែលចង្អៀតដូច្នោះ ។ កាលរាប់ច្រើនជាង ១០ ចិត្តុប្បាទក៏កន្លល់ដោយការរាប់ប៉ុណ្ណោះ ។ កាលសម្ដែង (ការរាប់) ឱ្យដាច់ក្នុងចន្លោះ ចិត្តរមែងខ្វល់ខ្វាយថា "កម្មដ្ឋានរបស់យើងដល់ទីបំផុតឬទេហ្ន៎" ។ ព្រោះដូច្នោះ ត្រូវវៀរទោសទាំងនេះចេញសិន សឹមរាប់ ។ កាលទឹងរាប់ គ្រាដំបូង គួររាប់ដោយវិធីរាប់យឺត ៗ គឺ រាប់ដូចវិធីវាល់ស្រូវ ។ ពិតមែន អ្នកវាល់ស្រូវ វាល់ពេញនាឡិហើយប្រាប់ថា ១ ទើបចាក់ចុះ កាលវាល់ពេញទៀត ជួបសម្រាមយ៉ាងណាមួយ រើសវាចោលចេញ ទើបប្រាប់ថា ១-១ ។ ក្នុងពាក្យថា ២-២ ជាដើម ក៏ន័យនេះ ។ កុលបុត្រសូម្បីនេះក៏យ៉ាងនោះដែរ បណ្ដាខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ចំណែកណាប្រាកដ គប្បីចាប់យកចំណែកនោះ ហើយគប្បីកំណត់ ខ្យល់ដែល

កំពុងឆ្លងទៅ ៗ តាំងពីដើមថា ១-១ ទៅ ដរាបដល់ថា ១០-១០ កាលកុលបុត្រនោះរាប់ដោយវិធីយ៉ាងនេះ ខ្យល់អស្សាសៈ ដែលកំពុងចេញ និងខ្យល់បស្សាសៈ ដែលកំពុងចូល រមែងប្រាកដ ។

លំដាប់នោះ កុលបុត្រនេះគួរលះវិធីរាប់យឺត ៗ គឺ រាប់ដូចវិធីវាល់ស្រូវនោះចេញ ហើយគប្បីរាប់ដោយវិធីរហ័ស ៗ គឺ រាប់ដូចវិធីនាយគោបាល ។ ពិតមែន នាយគោបាលអ្នកឆ្លាត យកដុំគ្រួសដាក់ថ្នក់ដៃកាន់ខ្សែនិងដំបងទៅកាន់ក្រោលពីព្រឹកព្រលឹម វាយគោត្រង់ខ្នងហើយអង្គុយនៅលើសសរសន្ទុះទ្វារ រាប់មេគោដែលមកដល់ទ្វារហើយ ៗ ដាក់ដុំគ្រួសចុះទៅថា ១-២ ជាដើម ។ ហ្វូងគោដែលនៅលំបាកក្នុងឱកាសដែលចង្អៀតរហូតដល់អស់ ៣ យាមនៃរាត្រី កាលចេញ (ពីក្រោល) ច្រៀតបៀតគ្នានិងគ្នាប្រញាប់ចេញជាពួក ៗ ។ នាយគោបាលនោះរមែងរាប់យ៉ាងរហ័សតែម្តងថា ៣-៤-៥-១០ ជាដើម ។ សូម្បីកាលកុលបុត្រនេះ រាប់ដោយន័យមុនដូចពោលមកហើយនេះ ខ្យល់អស្សាសៈនិងបស្សាសៈ រមែងប្រាកដសញ្ចរទៅមកយ៉ាងរហ័ស ។ លំដាប់នោះលោកដឹងថា ខ្យល់អស្សាសៈនិងបស្សាសៈ រមែងសញ្ចរទៅមកយ៉ាងរហ័ស ហើយមិនកាន់យកខ្យល់ខាងក្នុងនិងខាងក្រៅ គប្បីកំណត់យកតែខ្យល់ដែលមកដល់ចន្លោះ ៗ ប៉ុណ្ណោះ រាប់យ៉ាងរហ័ស ៗ តែម្តងថា

| | |
|---|---|
| ១-២-៣-៤-៥ | ១-២-៣-៤-៥-៦-៧-៨ |
| ១-២-៣-៤-៥-៦ | ១-២-៣-៤-៥-៦-៧-៨-៩ |
| ១-២-៣-៤-៥-៦-៧ | ១-២-៣-៤-៥៦-៧-៨-៩-១០ ។ |

ព្រោះថា ក្នុងកម្មដ្ឋានដែលជាប់ដោយការរាប់ ចិត្តរមែងមានអារម្មណ៍តែមួយបានដោយកម្លាំងនៃការរាប់ប៉ុណ្ណោះ ដូចការឈប់ទូកទុកក្នុងក្រសែទឹកហូរត្របាញ់ ដោយអំណាចដែលយកថ្នោលចាក់ទប់ដូច្នោះ ។ កាលលោករាប់រហ័ស ៗ យ៉ាងនេះកម្មដ្ឋាន រមែងប្រាកដដូចជាថា ដំណើរទៅមិនដាច់ ។ វេលានោះ គ្រាលោកដឹងថា "កម្មដ្ឋានដំណើរទៅមិនដាច់ខ្សែ"ហើយ កុំកំណត់ខ្យល់ទាំងខាងក្នុងនិងខាងក្រៅ គប្បីរាប់រហ័ស ៗ តាមន័យមុននុ៎ះឯង ។ កាលលោកបញ្ជូនចិត្តចូលទៅព្រមនឹងខ្យល់ដែលចូលទៅខាងក្នុងឋានខាងក្នុងត្រូវខ្យល់ប៉ះខ្ទប់ហើយ រមែងដូចជាពេញដោយខ្លាញ់ខាប់ដូច្នោះ ។ កាលនាំចិត្តចេញមកព្រមនឹងខ្យល់ដែលចេញមកខាងក្រៅ ចិត្តរមែងផ្សាយទៅក្នុងអារម្មណ៍យ៉ាងច្រើនទាំងខាងក្នុងនិង ទាំងខាងក្រៅ ។ តែភាវនារមែងសម្រេចដល់អ្នកតាំងសតិទុក ក្នុងឱកាសដែលខ្យល់ពាល់ត្រូវចម្រើនប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបខ្ញុំព្រះករុណាពោលថា "កុំកំណត់ខ្យល់ទាំងខាងក្នុងនិងខាងក្រៅ គប្បីរាប់រហ័ស ៗ តាមន័យមុននុ៎ះឯង" ។

សួរថា  នឹងគប្បីរាប់ខ្យល់អស្សាសៈនិងបស្សាសៈនោះ  យូរប៉ុនណា ?

ឆ្លើយថា  គប្បីរាប់ទៅរហូតដល់សតិដែលវៀរចាកការរាប់នឹងតាំងមាំនៅក្នុងអារម្មណ៍ គឺ ខ្យល់អស្សាសៈនិងបស្សាសៈ ។ ព្រោះថា ការរាប់ ក៏ដើម្បីនឹងកាត់វិតក្កៈដែលឆ្លេឆ្លាទៅខាងក្រៅ ហើយតាំងសតិទុកក្នុងអារម្មណ៍ គឺ ខ្យល់អស្សាសៈ និងបស្សាសៈប៉ុណ្ណោះ ។

## អធិប្បាយខាងដើមកណ្ដាលនិងទីបំផុតខ្យល់ដកដង្ហើមចេញចូល

ព្រះយោគាវចរ គ្រាមនសិការដោយការរាប់យ៉ាងនោះហើយ គប្បីមនសិការដោយការតាមចង ។ កិរិយាដែលឈប់សម្រាកការរាប់ ហើយបញ្ជូនសតិទៅតាមខ្យល់អស្សាសៈនិងបស្សាសៈជាប់តគ្នាទៅ  ឈ្មោះថាការតាមចង ។  ក៏ឯការបញ្ជូនសតិទៅតាមនោះ  មិនមែនដោយអំណាចការទៅតាមខាងដើម  កណ្ដាល  និងទីបំផុត  (នៃខ្យល់អស្សាសៈ  និងបស្សាសៈ)  ទេ ។  ពិតមែន  នាភិ  (ផ្ចិត)  ជាខាងដើមនៃខ្យល់ចេញទៅខាងក្រៅ ហទយៈ (បេះដូង) ជាកណ្ដាល នាសិក (ច្រមុះ) ជាទីបំផុត; ចុងនាសិកជាខាងដើមនៃខ្យល់ចូលទៅខាងក្នុងហទយៈជាកណ្ដាល នាភិ ជាទីបំផុត ។ ក៏កាលព្រះយោគាវចរនោះ ទៅតាមខាងដើម កណ្ដាល  និងទីបំផុត  (នៃខ្យល់អស្សាសៈនិងបស្សាសៈ)  នោះ  ចិត្តដែល

ដល់សេចក្ដីរវើរវាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីខ្វល់ខ្វាយ និងដើម្បីសេចក្ដីញាប់ញ័រ ។ ដូចយ៉ាងដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកថា ៖

"កាលភិក្ខុផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចេញ ខាងដើម កណ្ដាល និងខាងចុង កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្នុងកាលភិក្ខុផ្ចង់ស្មារតីទៅកាន់ខ្យល់ដកដង្ហើមចេញចូល ខាងដើម កណ្ដាល និងខាងចុង កាយនិងចិត្តរមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែលបោះទៅក្នុងខ្យល់ដង្ហើមខាងក្រៅ"[១] ។

ព្រោះដូច្នោះ ព្រះយោគាវចរ កាលមនសិការដោយការតាមចងមិនគប្បីមនសិការដោយអំណាចនៃខាងដើម កណ្ដាល និងទីបំផុត ។ មួយទៀត គប្បីមនសិការដោយអំណាចការពាល់ត្រូវ និងដោយអំណាចការបញ្ឈប់ ព្រោះថា មិនមានការមនសិការជាផ្នែកមួយ ដោយអំណាចនៃការពាល់ត្រូវ និងការបញ្ឈប់ ដូចគ្នានឹងដោយអំណាចនៃការរាប់និងការតាមចង ។ តែព្រះយោគាវចរកាលរាប់នៅក្នុងឋានដែលខ្យល់ពាល់ត្រូវហើយ ៗ ទុំះឯងឈ្មោះថា មនសិការដោយការរាប់ និងការពាល់ត្រូវ ។ ព្រះយោគាវចរ កាលឈប់សម្រាកការរាប់ក្នុងឋានដែលខ្យល់

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៧៦/៩១ ។

ពាល់ត្រូវហើយ ៗ នុ៎ះឯង ប្រើសតិតាមចងខ្យល់អស្សាសៈនិង បស្សាសៈនោះ និងតាំងចិត្តទុកដោយអំណាចអប្បនា លោកហៅថា មនសិការដោយការតាមចង ការពាល់ត្រូវនិងការបញ្ឈប់ ។ សេចក្ដីនេះ គប្បីជ្រាបដោយសេចក្ដីឧបមាដូចមនុស្សពិការនិងអ្នករក្សាទ្វារ ដែល លោកពោលទុកក្នុងអដ្ឋកថា និងដោយការឧបមាដូចរណារដែលព្រះធម្ម សេនាបតីសារីបុត្រពោលទុកក្នុងបដិសម្ភិទា ។

## សេចក្ដីឧបមាដូចមនុស្សពិការយោលទោង

បណ្ដាសេចក្ដីឧបមា ៣ យ៉ាងនោះ សេចក្ដីឧបមាដូចមនុស្សពិការ យោលទោង មានដូចតទៅនេះ ៖

ប្រៀបដូចមនុស្សពិការយោលទោង ឱ្យដល់មាតា និងបុត្រដែល លេងយោលទោង ហើយអង្គុយនៅត្រង់គល់សសរទោងក្នុងទីនោះឯង កាលក្ដារទោងយោលទៅមកដោយលំដាប់ រមែងឃើញទីបំផុតទាំងពីរខាង និងកណ្ដាល តែមិនបានខ្វល់ខ្វាយដើម្បីនឹងមើលទីបំផុតទាំងពីរខាង និង កណ្ដាល សូម្បីយ៉ាងណា ភិក្ខុនេះ ក៏យ៉ាងនោះដែរ ឈរត្រង់ជិតគល់ សសរដែលចូលទៅចងទុកដោយអំណាចសតិហើយយោលទោងគឺ ខ្យល់ ដកដង្ហើមចេញនិងដកដង្ហើមចូល អង្គុយនៅដោយសតិ ក្នុងនិមិត្តនោះ

ឯង បញ្ជូនសតិទៅតាមខាងដើម កណ្តាល និងទីបំផុតនៃខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ក្នុងឋានដែលខ្យល់ប៉ះត្រូវហើយ ដែលបក់ឆ្លងមកនិងឆ្លងទៅដោយលំដាប់ និងតាំងចិត្តព្រងើយទុកក្នុងនិមិត្តនោះ និងមិនខ្វល់ខ្វាយដើម្បីនឹងក្រលេកមើលខ្យល់ពួកនោះ ។ នេះ ជាសេចក្តីឧបមាដូចមនុស្សពិការ ។

## សេចក្តីឧបមាដូចអ្នករក្សាទ្វារ

ចំណែកសេចក្តីឧបមាដូចអ្នករក្សាទ្វារមានដូចតទៅនេះ ៖

អ្នករក្សាទ្វារនឹងមិនដេញដោលសួរបុរសទាំងឡាយ ទាំងខាងក្នុងនិងខាងក្រៅព្រះនគរថា លោកជាអ្នកណា ? មកពីណា ? នឹងទៅណា ? ឬថា ក្នុងដៃរបស់លោកមានអ្វី ? ជាការពិត ពួកមនុស្សដែលដើរទៅទាំងខាងក្នុងនិងខាងក្រៅព្រះនគរទាំងនោះ មិនមែននាទីរបស់អ្នករក្សាទ្វារនោះទេ តែគេរមែងដេញដោលសួរចំពោះមនុស្សដែលមកដល់ទ្វារហើយ ៗ ប៉ុណ្ណោះ យ៉ាងណា ខ្យល់ដែលចូលទៅខាងក្នុងនិងខ្យល់ដែលចេញទៅខាងក្រៅ រមែងមិនជានាទីរបស់ភិក្ខុនេះ ក៏យ៉ាងនោះដែរ នឹងជានាទីចំពោះតែខ្យល់ដែលមកដល់រន្ធច្រមុះហើយ ៗ ប៉ុណ្ណោះ ។ នេះជាសេចក្តីឧបមាដូចអ្នករក្សាទ្វារ ។

## ការកំណត់ខ្យល់ដកដង្ហើម ប្រៀបដូចរណារ

ចំណែកសេចក្តីឧបមាដូចរណារ គួរជ្រាបចាប់ផ្តើមតាំងពីដើមទៅ ។ សមដូចពាក្យដែលលោកព្រះធម្មសេនាបតីសារីបុត្រ ពោលទុកថា ៖

“កាលបុគ្គលមិនស្គាល់នូវអារម្មណ៍របស់ចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺ និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងមិនបាន (សម្រេចនូវភាវនា) ។ កាលបុគ្គលដឹងនូវអារម្មណ៍របស់ចិត្តតែមួយ ការចម្រើននូវធម៌ ៣ ប្រការ គឺ និមិត្ត ១ អស្សាសៈ ១ បស្សាសៈ ១ គេរមែងបាន(សម្រេចនូវភាវនា) ។[១]

ធម៌ទាំង ៣ យ៉ាងនេះ មិនជាអារម្មណ៍នៃចិត្តតែមួយផង ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាមិនប្រាកដផង តើដូចម្តេច ។ ចិត្តមិនដល់នូវសេចក្តីរវើរវាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញ៉ាំងព្យាយាមឱ្យសម្រេចបាននូវគុណវិសេស ១ ។ ប្រៀបដូចដើមឈើដែលគេដាំលើភូមិភាគរាបស្មើ បុរសអារដើមឈើនោះ ដោយរណារ ស្មារតីរបស់បុរសរមែងតាំងឡើងចំពោះដើមឈើ ដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវ បុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារដែលទាញមកទាញទៅ ធ្មេញរណារដែលទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាម

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩១/១០៤ ។

រមែងប្រាកដផង បុរសរមែងញ៉ាំងព្យាយាមឱ្យសម្រេចបាននូវគុណវិសេសផង ឯការចូលទៅជិតចំផងនិមិត្ត ទុកដូចដើមឈើដែលគេដាំលើភូមិភាគដ៏រាបស្មើ, ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ទុកដូចធ្មេញរណារ, ភិក្ខុតម្កល់ទុកនូវស្មារតីត្រង់ចុងច្រមុះ ឬទ្វារមាត់ ហើយអង្គុយមិនធ្វើទុកក្នុងចិត្តនូវខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល ទាំងដែលមកទាំងដែលទៅ ខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូលដែលមកក្តី ដែលទៅក្តី មិនមែនមិនប្រាកដទេ ព្យាយាមរមែងប្រាកដផង ភិក្ខុញ៉ាំងព្យាយាមឱ្យសម្រេចបាននូវគុណវិសេសផង ប្រៀបដូចស្មារតីបុរសតាំងឡើងចំពោះដើមឈើ ដោយអំណាចនៃធ្មេញរណារដែលពាល់ត្រូវ បុរសមិនធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារដែលទាញមកទាញទៅ ធ្មេញរណារដែលទាញមកក្តី ទាញទៅក្តី មិនមែនជាមិនប្រាកដទេ ព្យាយាមប្រាកដផង បុរសញ៉ាំងព្យាយាមឱ្យសម្រេចបាននូវគុណវិសេសផង ។[១]

ការព្យាយាម តើដូចម្តេច ភិក្ខុមានព្យាយាមប្រារព្ធហើយ តែងមានកាយ និងចិត្តគួរដល់ការងារ, នេះឈ្មោះថា ការព្យាយាម ។ ការប្រកបព្យាយាម តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធហើយ រមែងលះបង់នូវពួកឧបក្កិលេស មានវិតក្កៈស្ងប់រម្ងាប់, នេះឈ្មោះថា ការប្រកបព្យាយាម ។ គុណពិសេស តើដូចម្តេច ។ ភិក្ខុមានព្យាយាមប្រារព្ធ

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩២/១០៥, ៩៣/១០៦ ។

ហើយ រមែងលះបង់នូវពួកសញ្ញោជនៈ មានពួកអនុសយធម៌វិនាស នេះឈ្មោះថា គុណពិសេស ។ នេះធម៌ ៣ យ៉ាង ដែលមិនមែនជាអារម្មណ៍នៃឯកចិត្ត, នេះធម៌ ៣ យ៉ាង ដែលភិក្ខុមិនមែនជាមិនដឹង គឺចិត្តមិនដល់នូវសេចក្ដីរាយមាយ ១ ព្យាយាមប្រាកដ ១ ភិក្ខុញ៉ាំងព្យាយាមឱ្យសម្រេចបាននូវគុណវិសេស ១ យ៉ាងនេះឯង ។[1]

អានាបានស្សតិបុគ្គលណាបានបំពេញហើយ ចម្រើនហើយ
ដោយប្រពៃ សន្សំហើយដោយលំដាប់ ឱ្យដូចព្រះពុទ្ធទ្រង់
សម្ដែងទុកហើយ, បុគ្គលនោះ រមែងញ៉ាំងលោកនេះឱ្យភ្លឺ
ច្បាស់ ដូចជាព្រះចន្ទដែលផុតស្រឡះចាកពពក ។”[2]

សេចក្ដីនេះឧបមាដូចរណារ ។ ក៏ក្នុងសេចក្ដីឧបមាដូចរណារនេះគប្បីជ្រាបថា ហេតុត្រឹមតែមិនដាក់ចិត្តដោយអំណាចខ្យល់ដកដង្ហើមចេញនិងខ្យល់ដកដង្ហើមចូល ដែលកន្លងមកហើយ ៗ ប៉ុណ្ណោះ ជាប្រយោជន៍ដល់ភិក្ខុនោះ ។ កម្មដ្ឋាននេះកាលភិក្ខុខ្លះ មនសិការនិមិត្ត រមែងកើតឡើងដោយមិនយឺតយូរឡើយ និងឋបនា ពោលគឺ អប្បនាដែលប្រកបដោយអង្គឈានដ៏សេស ក៏រមែងសម្រេច ។ តែសម្រាប់ភិក្ខុ

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩២/១០៥, ៩៣/១០៦ ។

២. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ៩៤/១០៧ ។

ខ្ទះ មានចាប់ផ្ដើមតាំងពីវេលាមនសិការដោយអំណាចការរាប់នុ៎ះឯង គឺតាំងពីវេលាធ្វើទុកក្នុងចិត្តដោយអំណាចការរាប់ កាលសេចក្ដីខ្វល់ខ្វាយមកកាយស្ងប់ទៅ ដោយអំណាចខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូលដែលគ្រោតគ្រាតរលត់ទៅដោយលំដាប់ កាយក្ដី ចិត្តក្ដី រមែងជារបស់ស្រាល រាងកាយ រមែងដូចជាដល់អាការអណ្ដែតឡើងទៅក្នុងអាកាស ដូចភិក្ខុដែលមានកាយរសាប់រសល់ កាលអង្គុយចុះលើគ្រែឬតាំង គ្រែនិងតាំង រមែងទ្រេត ទោរទៅ កម្រាល រមែងរួញជ្រួញ ៗ, តែកាលលោកមានកាយមិនរសាប់រសល់ អង្គុយចុះ គ្រែនិងតាំង រមែងមិនទ្រេត មិនទោរ កម្រាលក៏មិនរួញជ្រួញ ៗ, គ្រែតាំងដូចជាពេញដោយសំឡីគ, ព្រោះហេតុអ្វី ? ព្រោះហេតុថា កាយមិនរសាប់រសល់រមែងជារបស់ស្រាលដូច្នោះ ។ កាលខ្យល់អស្សាសៈនិងបស្សាសៈដែលគ្រោតគ្រាតរលត់ទៅហើយ ចិត្តរបស់ភិក្ខុនោះមាននិមិត្ត គឺ ខ្យល់អស្សាសៈនិងបស្សាសៈដែលល្អិតជាអារម្មណ៍ រមែងប្រព្រឹត្តទៅ, សូម្បីកាលចិត្តនោះរលត់ទៅហើយ ចិត្តត ៗ ទៅ ដែលមានអារម្មណ៍គឺ និមិត្តដែលល្អិតជាងចិត្តនោះ រមែងប្រព្រឹត្តទៅនោះឯង ។

សួរថា ចិត្តត ៗ ទៅ រមែងប្រព្រឹត្តទៅយ៉ាងណា ?

ឆ្លើយថា ប្រៀបដូចបុរស យកកំណាត់ដែកធំគោះរគាំង ដោយការគោះត្រឹមតែម្ដង សំឡេងខ្លាំងក៏កើតឡើង, ចិត្តរបស់បុរសនោះ ដែល

មានសំឡេងខ្លាំង (គ្រោតគ្រាត) ជាអារម្មណ៍ គប្បីប្រព្រឹត្តទៅ, កាលសំឡេងខ្លាំងរលត់ទៅ តពីនោះខាងក្រោយចិត្តដែលមានសំឡេងល្អិតជាអារម្មណ៍ គប្បីប្រព្រឹត្តទៅ, សួរថា ក៏កាលចិត្តដែលមាននិមិត្ត គឺ សំឡេងល្អិតជាអារម្មណ៍នោះរលត់ទៅហើយ ចិត្តត ៗ ទៅ ដែលមានអារម្មណ៍គឺនិមិត្តដែលល្អិតដរាបដល់ល្អិតជាងចិត្ត ដែលមាននិមិត្ត គឺ សំឡេងល្អិតជាអារម្មណ៍នោះ រមែងប្រព្រឹត្តទៅតែម្តង យ៉ាងណា, ចិត្តដែលមាននិមិត្ត គឺ ខ្យល់អស្សាសៈនិងបស្សាសៈជាអារម្មណ៍នោះ បណ្ឌិតគប្បីជ្រាបថា រមែងប្រព្រឹត្តទៅ យ៉ាងនោះ, សួរថា សេចក្តីនេះសមពិត ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកថា "ប្រៀបដូចជារគាំង ដែលគេគោះ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្តទៅជាដំបូង", ដូច្នេះ ជាដើម ។ គួរឱ្យពិស្តារ[១] ។ ដូចពួកកម្មដ្ឋានដទៃ រមែងប្រាកដច្បាស់ក្នុងលំដាប់ខ្ពស់ ៗ ឡើងទៅ យ៉ាងណា, អានាបានស្សតិកម្មដ្ឋាននេះ មិនមែនយ៉ាងនោះទេ ។ តែអានាបានស្សតិកម្មដ្ឋាននេះ កាលភិក្ខុចម្រើន ៗ ក្នុងលំដាប់ខ្ពស់ឡើងទៅ រមែងដល់ភាពជារបស់ល្អិត គឺ ទឹងមិនដល់សូម្បីសេចក្តីប្រាកដ ។ ក៏កាលកម្មដ្ឋាននោះ មិនប្រាកដយ៉ាងនោះ ភិក្ខុនោះ មិនគួរទះកម្រាលស្បែក ក្រោកចាកអាសនៈចៀសចេញទៅទេ ។

---

១. (ក្នុងខុទ្ទ. បដិ. មហាវគ្គ. ៧០. ១១៤/១៤៥ ។ ឬមាននៅខាងដើមហើយ)

មិនគួរក្រោកឡើង ដោយគិតថា តើត្រូវធ្វើដូចម្ដេចហ្ន៎ ? យើងនឹងទៅសួរអាចារ្យ, ឬថា ឥឡូវនេះ កម្មដ្ឋានរបស់យើងសាបសូន្យហើយ ។ ពិតមែន កាលលោកឱ្យឥរិយាបថកម្រើកដើរទៅ កម្មដ្ឋាន រមែងប្រាកដជារបស់ថ្មី ៗ រឿយទៅ; ព្រោះហេតុនោះ គួរនៅអង្គុយដូចដើមនុ៎ះឯង នាំកម្មដ្ឋានមកពីទីដែលពាល់ត្រូវតាមប្រក្រតី ។

## ឧបាយជាហេតុនាំអានាបានស្សតិកម្មដ្ឋានមក

ក្នុងអធិការពោលអំពីអានាបានស្សតិកម្មដ្ឋាននោះ មានឧបាយជាគ្រឿងនាំមកដូចតទៅនេះ ៖

ពិតមែន ភិក្ខុនោះ ដឹងថា កម្មដ្ឋានមិនប្រាកដ គួរពិចារណាកំណត់យ៉ាងនេះថា ឈ្មោះថា ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលនេះ មាននៅក្នុងទីណា ? មិនមានក្នុងទីណា ? របស់អ្នកណាមាន ? របស់អ្នកណាមិនមាន ? ខាងក្រោយ កាលភិក្ខុនោះ ពិចារណាមើលយ៉ាងនេះ ក៏ដឹងបានថា ខ្យល់ដកដង្ហើមចូល និងដកដង្ហើមចេញនេះ (របស់ទារកដែលនៅ) ក្នុងផ្ទៃរបស់មាតា មិនមាន, ពួកជនអ្នកមុជទឹកក៏មិនមាន, ពួកអសញ្ញីសត្វ អ្នកស្លាប់ហើយ អ្នកចូលចតុត្ថជ្ឈាន លោកអ្នកដល់ព្រមដោយរូបភព និងអរូបភព លោកអ្នកចូលនិរោធ ក៏មិនមានដូចគ្នា ហើយគប្បីដាស់តឿនខ្លួនឯងយ៉ាងនេះថា "នែបណ្ឌិត ខ្លួនលោក

មិនមែនអ្នកនៅក្នុងផ្ទៃរបស់មាតា មិនមែនអ្នកមុជទឹក មិនមែនជាអសញ្ញីសត្វ មិនមែនអ្នកស្លាប់ មិនមែនអ្នកចូលចតុត្ថជ្ឈាន មិនមែនអ្នកដល់ភាពជាសត្វក្នុងរូបភព និងអរូបភព មិនមែនអ្នកចូលនិរោធ មិនមែនឬ ? ខ្លួនលោកនៅមានខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូលពិត ៗ, តែខ្លួនលោកក៏មិនអាចនឹងកំណត់បាន ព្រោះនៅមានបញ្ញាទន់ខ្សោយ" ។

ក្រោយមក លោកគួរតាំងចិត្តទុក ដោយអំណាចទីដែលខ្យល់ពាល់ត្រូវដោយប្រក្រតីនុ៎ះឯងឱ្យមនសិការប្រព្រឹត្តទៅ ។ ពិតមែន ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលនេះ ប៉ះខ្ទប់ក្ដោងច្រមុះរបស់អ្នកមានច្រមុះវែងកន្លងទៅ, ប៉ះខ្ទប់បបូរមាត់ខាងលើរបស់អ្នកមានច្រមុះខ្លីកន្លងទៅ ។ ព្រោះដូច្នោះ លោកនោះ ទើបគួរតាំងនិមិត្តទុកថា "ខ្យល់ដកដង្ហើមចេញ និងដកដង្ហើមចូល រមែងប៉ះខ្ទប់ហានឈ្មោះនេះ" ។ សេចក្ដីពិត ព្រះមានព្រះភាគ ទ្រង់អាស្រ័យអំណាចប្រយោជន៍នេះឯង ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលនូវអានាបានស្សតិរបស់ភិក្ខុដែលវង្វេងស្មារតី មិនប្រកបដោយបញ្ញាដឹងសព្វទេ"[១] ។

ពិតមែន កម្មដ្ឋានយ៉ាងណាមួយ រមែងសម្រេចដល់អ្នកមានសតិមានសេចក្ដីដឹងខ្លួនប៉ុណ្ណោះ ក៏ពិតមែនហើយ, តែថា កម្មដ្ឋានយ៉ាងដទៃ

១. មជ្ឈិ. ឧប. ២៦. ២៨៩/៣៦៥ ។

ក្រៅអំពីអានាបានស្សតិកម្មដ្ឋាននេះ រមែងប្រាកដបានដល់អ្នកដែលមនសិការៈ ។ តែអានាបានស្សតិកម្មដ្ឋាននេះជាភារៈធ្ងន់ ចម្រើនសម្រេចបានលំបាក ទាំងជាភូមិនៃមនសិការរបស់មហាបុរសទាំងឡាយ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធបុត្រប៉ុណ្ណោះ, មិនមែនជាកម្មដ្ឋានថ្នាក់ទាប, ទាំងមិនមែនជាកម្មដ្ឋានដែលសត្វថោកទាបត្រូវសេព, ជាកម្មដ្ឋានស្ងប់និងល្អិត ដោយប្រការដែលមហាបុរសទាំងឡាយ រមែងធ្វើទុកក្នុងចិត្ត; ព្រោះដូច្នោះ ក្នុងអានាបានស្សតិកម្មដ្ឋាននេះ ចាំបាច់ត្រូវប្រាថ្នាសតិនិងបញ្ញាដែលមានកម្លាំង ។ ដូចយ៉ាងថា ក្នុងវេលាដេរប៉ះសំពត់សាជកសាច់រលោង សូម្បីម្ជុលក៏ចាំបាច់ត្រូវប្រាថ្នាយ៉ាងតូច ៗ សូម្បីអំបោះដែលដោតក្នុងរន្ធម្ជុល ក៏ចាំបាច់ត្រូវប្រាថ្នាសរសៃល្អិតជាងនោះ យ៉ាងណា, ក្នុងវេលាចម្រើនកម្មដ្ឋាននេះ ដែលដូចជាសំពត់សាជកសាច់រលោង ក៏យ៉ាងនោះដែរ ។ សតិមានចំណែកប្រៀបដោយម្ជុលក្តី បញ្ញាដែលសម្បយុត្តដោយសតិនោះ មានចំណែកប្រៀបដោយអំបោះដោតរន្ធម្ជុលក្តី ចាំបាច់ត្រូវប្រាថ្នាឱ្យមានកម្លាំង ។

ក៏ឯភិក្ខុដែលប្រកបដោយសតិនិងបញ្ញានោះហើយ មិនចាំបាច់ត្រូវស្វែងរក ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលនោះ ក្រៅអំពីឱកាសដែលខ្យល់ពាល់ត្រូវដោយប្រក្រតី ។ ប្រៀបដូចអ្នកស្រែភ្ជួរស្រែហើយលែងពួកគោស្ទាវ ឱ្យបែរមុខទៅកាន់ទីស្មៅ ហើយគប្បីអង្គុយសម្រាកនៅ

ត្រង់មួយឈើ, គ្រានោះពួកគោស្ទាវទាំងនោះចូលព្រៃទៅដោយរហ័ស នឹងមិនដើរតាមស្នាមជើងគោស្ទាវទាំងនោះចូលទៅកាន់ព្រៃ, តាមការពិត គេនឹងកាន់យកខ្សែនិងជន្លួញ ដើរត្រង់ទៅកាន់កំពង់ទឹកដែលគោស្ទាវទាំងនោះចុះតែម្តង អង្គុយឬដេកចាំ ។ វេលានោះគេបានឃើញគោទាំងនោះដែលត្រាច់ទៅពេញមួយថ្ងៃ ហើយចុះទៅកាន់កំពង់ទឹក ងូតនិងផឹកទឹកហើយឡើងមកឈរ ទើបយកខ្សែចងហើយយកជន្លួញចាក់ នាំទៅទីម (នង្គ័ល) ធ្វើការងារទៀត យ៉ាងណា ភិក្ខុនោះ ក៏យ៉ាងនោះដែរ មិនចាំបាច់ត្រូវស្វែងរកខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល ក្រៅអំពីឱកាសដែលខ្យល់ប៉ះត្រូវដោយប្រក្រតី តែគប្បីកាន់យកខ្សែ គឺ សតិ និងជន្លួញ គឺ បញ្ញាហើយ តាំងចិត្តទុកក្នុងឱកាសដែលខ្យល់ពាល់ត្រូវដោយប្រក្រតី ញ៉ាំងមនសិការឱ្យប្រព្រឹត្តទៅ ។ ព្រោះថា កាលលោកមនសិការយ៉ាងនោះ រយៈកាលមិនយូរឡើយខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូលនោះ នឹងប្រាកដដូចពួកគោស្ទាវប្រាកដត្រង់កំពង់ទឹកដូច្នោះ ។

ក្នុងលំដាប់នោះ លោកគប្បីយកខ្សែ គឺ សតិចងប្រកបទុកក្នុងទីនោះឯង ហើយចាក់ដោយជន្លួញ គឺ បញ្ញាតាមប្រកបកម្មដ្ឋានទៀត ។ កាលលោកប្រឹងប្រែងប្រកបយ៉ាងនោះ រយៈកាលមិនយូរឡើយ និមិត្តនឹងប្រាកដ ។ អាចារ្យពួកខ្លះពោលទុកថា

"ក៏និមិត្តនេះ រមែងមិនប្រាកដដូចគ្នា ដល់ព្រះយោគាវចរ

គ្រប់រូប ៗ មួយទៀត និមិត្តនោះ រមែងប្រាកដដល់ព្រះយោគាវចររូបខ្លះ ដូចសំឡីគ ដូចសំឡីកប្បាស និងដូចក្រសែខ្យល់ ឱ្យកើតសុខសម្ផស្ស ៗ"

ចំណែកវិនិច្ឆ័យក្នុងអដ្ឋកថា មានដូចតទៅនេះ ៖

ពិតមែន និមិត្តនេះ រមែងប្រាកដដល់ព្រះយោគាវចររូបខ្លះ ដូចដួងផ្កាយ ដូចក្នុងកែវមណី និងដូចក្នុងកែវមុក្តា រូបខ្លះប្រាកដជារបស់មានសម្ផស្សគ្រោតគ្រាត ដូចគ្រាប់កប្បាស និងដូចបំណែកស្រួចតូច ៗ នៃឈើខ្លឹម, រូបខ្លះប្រាកដដូចជាខ្សែសង្វារវែង ដូចក្នុងនៃផ្កា និងដូចផ្សែងភ្លើង, រូបខ្លះដូចសរសៃពីងពាងដែលធំ ដូចដុំពពកធំ ដូចផ្កាបទុម ដូចកង់រថ ដូចមណ្ឌលព្រះចន្ទ និងដូចមណ្ឌលព្រះអាទិត្យ ដូច្នោះ ៗ

ក៏ឯកម្មដ្ឋាននេះ មានតែម្យ៉ាងពិត ៗ តែប្រាកដដោយសេចក្តីផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ដូចបណ្តាភិក្ខុច្រើនរូប នៅអង្គុយស្វាធ្យាយព្រះសូត្រជាមួយគ្នា កាលភិក្ខុមួយរូប និយាយថា ព្រះសូត្រនេះ រមែងប្រាកដដល់ពួកលោក ដូចម្តេច ? មួយរូបនិយាយថា រមែងប្រាកដដល់ខ្ញុំព្រះករុណា ដូចជាស្ទឹងហូរធ្លាក់ពីភ្នំធំ, រូបដទៃទៀត និយាយថា រមែងប្រាកដដល់ខ្ញុំព្រះករុណា ដូចជាជួរព្រៃមួយកន្លែង, រូបដទៃទៀតនិយាយថា រមែងប្រាកដដល់ខ្ញុំព្រះករុណា ដូចជារុក្ខជាតិដែលប្រកបព្រមដោយភារៈ គឺ ផ្លែឈើ ដែលមានម្លប់ត្រជាក់ បរិបូរណ៌ដោយមែក, ពិតមែន

ព្រះសូត្ររបស់លោកទាំងនោះ ក៏ជាសូត្រតែមួយដូចគ្នានុ៎ះឯង តែប្រាកដដោយភាពជារបស់ផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ដូច្នោះ ។ សេចក្ដីពិត កម្មដ្ឋាននេះ កើតអំពីសញ្ញា មានសញ្ញាជាដើមហេតុ មានសញ្ញាជាដែនកើត; ព្រោះដូច្នោះ គប្បីជ្រាបថា រមែងប្រាកដដោយសេចក្ដីផ្សេងគ្នា ព្រោះមានសញ្ញាផ្សេងគ្នា ។

## ធម៌ ៣ យ៉ាងមានបរិបូណ៌កម្មដ្ឋានទើបដល់អប្បនា

ក៏បណ្ដាខ្យល់ដកដង្ហើមចេញ ដកដង្ហើមចូល និងនិមិត្តនេះ ចិត្តដែលមានខ្យល់ដកដង្ហើមចេញជាអារម្មណ៍ មួយយ៉ាងផ្សេង ចិត្តដែលមានខ្យល់ដកដង្ហើមចូលជាអារម្មណ៍ ក៏ម្យ៉ាងផ្សេង ចិត្តដែលមាននិមិត្តជាអារម្មណ៍ ក៏ម្យ៉ាងផ្សេង ។ ពិតមែន កម្មដ្ឋានរបស់ភិក្ខុដែលមិនមានធម៌ ៣ យ៉ាងនេះ រមែងមិនដល់អប្បនា មិនដល់ឧបចារ ។ ចំណែកកម្មដ្ឋានរបស់ភិក្ខុដែលមានធម៌ ៣ យ៉ាងនេះ រមែងដល់អប្បនានិងឧបចារផង ។ សមពិត ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកថា និមិត្តខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល មិនមែនជាអារម្មណ៍នៃចិត្តតែមួយ, និងកាលភិក្ខុមិនដឹងធម៌ ៣ ប្រការ រមែងមិនបានភាវនា (រមែងមិនសម្រេច), និមិត្តខ្យល់ដកដង្ហើមចេញ និងខ្យល់ដកដង្ហើមចូល មិនមែនជាអារម្មណ៍នៃចិត្តតែមួយ, និងកាលភិក្ខុដឹងនូវធម៌ ៣

ប្រការ រមែងបានភាវនា ។

អាចារ្យទាំងឡាយ អ្នកពោលទីឃនិកាយ បានពោលទុកយ៉ាងនេះមុនថា ក៏កាលនិមិត្តប្រាកដហើយយ៉ាងនោះ ភិក្ខុនោះគួរទៅសំណាក់របស់អាចារ្យ ហើយប្រាប់ថា និមិត្តបែបនេះ រមែងប្រាកដដល់ខ្ញុំព្រះករុណា ចំណែកអាចារ្យមិនគួរនិយាយថា នោះជានិមិត្ត ឬថា មិនមែននិមិត្ត គួរនិយាយថា "រមែងជាយ៉ាងនោះឯង ណ៎ះអ្នក" ហើយគប្បីនិយាយថា "ចូរអ្នកមនសិការរឿយ ៗ" ។ ពិតមែន កាលអាចារ្យនិយាយថា "ជានិមិត្ត" លោកនឹងដល់សេចក្ដីថយក្រោយ, កាលអាចារ្យនិយាយថា "មិនមែននិមិត្ត" លោកក៏នឹងអស់សង្ឃឹម; ព្រោះហេតុនោះ មិនគួរនិយាយសូម្បីទាំងពីរយ៉ាងនោះ គួរប្រកបអ្នកនោះទុកក្នុងមនសិការនុ៎ះឯង ។ ចំណែកអាចារ្យទាំងឡាយ អ្នកពោលមជ្ឈិមនិកាយបានពោលទុកថា លោកដែលអាចារ្យគប្បីនិយាយថា "នេះជានិមិត្តណ៎ះអ្នក សូមឱ្យអ្នកមនសិការកម្មដ្ឋានរឿយ ៗ ចុះណា សប្បុរស" ខាងក្រោយលោករូបនោះ គប្បីតាំងចិត្តទុកក្នុងនិមិត្តនុ៎ះឯង ចាប់ផ្ដើមតាំងពីបដិភាគនិមិត្តកើតឡើងនេះ ភាវនានេះរបស់លោករូបនោះ រមែងកើតបាន ដោយអំណាចការតាំងទុកដោយប្រការយ៉ាងនេះ ។ សមពិត ដូចពាក្យដែលព្រះបូរាណាចារ្យទាំងឡាយពោលទុកថា

បុគ្គលអ្នកមានប្រាជ្ញា កាលតម្កល់ចិត្តទុកក្នុងនិមិត្ត ចម្រើន

អសុរាសប្បសុរាសៈដែលមានអាការផ្សេង ៗ ឈ្មោះថា រមែង
ចងចិត្តរបស់ខ្លួនទុក ។

ចាប់តាំងអំពីនិមិត្តប្រាកដ ដោយន័យដូចពោលហើយនោះ នីវរណៈទាំងឡាយ រមែងជាការដែលព្រះយោគីនោះគ្របសង្កត់បានដោយពិត កិលេសទាំងឡាយ ស្ងប់ស្ងៀម សតិចូលទៅតាំងមាំតែម្តង ចិត្តក៏តាំងមាំដូចគ្នា ។

## ចិត្តរមែងតាំងមាំជាសមាធិដោយអង្គ ២

ពិតមែន ចិត្តនេះ រមែងឈ្មោះថា ជាធម្មជាតិតាំងមាំ ដោយអង្គ ២ គឺ ដោយការលះនីវរណៈក្នុងឧបចារភូមិ ឬដោយសេចក្តីប្រាកដនៃអង្គក្នុងបដិលាភភូមិ ។

បណ្តាភូមិ ២ យ៉ាងនោះ ដែលឈ្មោះថា ឧបចារភូមិ បានដល់ ឧបចារសមាធិ ។ ដែលឈ្មោះថា បដិលាភភូមិ បានដល់ អប្បនាសមាធិ ។

សួរថា សមាធិទាំងពីរនោះ មានការធ្វើផ្សេងគ្នាយ៉ាងណា ?

ឆ្លើយថា ឧបចារសមាធិ ត្រាច់ទៅក្នុងកុសលវិថីហើយ ក៏ឈានចុះកាន់ភវង្គ ។ អប្បនាសមាធិ កាលព្រះយោគីអង្គុយយ៉ាងស៊ប់ល្អរហូតអស់មួយថ្ងៃ ត្រាច់ទៅក្នុងកុសលវិថី សូម្បីរហូតអស់មួយថ្ងៃ ក៏មិន

ឈានចុះកាន់ភវង្គ ។ បណ្ដាសមាធិ ២ យ៉ាងនោះ ចិត្តរមែងជាធម្មជាតិតាំងមាំដោយឧបចារសមាធិ ព្រោះនិមិត្តប្រាកដ ។ ខាងក្រោយ ភិក្ខុនេះមិនគប្បីមនសិការនិមិត្តនោះដោយពណ៌, ទាំងមិនគប្បីពិចារណាដោយលក្ខណៈ ។ ក៏ម្យ៉ាងទៀត លោកកុំប្រមាទ គួររក្សានិមិត្តទុក ដូចព្រះមហេសីរបស់ក្សត្រិយ៍ ទ្រង់រក្សាគភ៌នៃស្ដេចចក្រពត្តិ និងដូចអ្នកស្រែរក្សាកួរនៃស្រូវសាលីនិងស្រូវដំណើប ដូច្នោះ ។

ពិតមែន និមិត្តដែលរក្សាទុកបាន រមែងឱ្យផលដល់លោក ។ កាលព្រះយោគីរក្សានិមិត្តទុកបាន នឹងមិនមានសេចក្ដីសាបសូន្យចាកឧបចារជ្ឈានដែលខ្លួនបានហើយ ។ កាលមិនមានការរក្សា (និមិត្ត) ឈានដែលខ្លួនបានហើយ ៗ ក៏នឹងវិនាសទៅ ដូច្នេះឯង ។

## ឧបាយរក្សាអានាបានស្សតិកម្មដ្ឋាន

ក្នុងអធិការនៃអានាបានស្សតិកម្មដ្ឋាននោះ មានឧបាយសម្រាប់រក្សា ដូចតទៅនេះ ៖

ភិក្ខុនោះ គួរវៀរអសប្បាយ ៧ យ៉ាងទាំងនេះ គឺ អាវាស១ គោចរ១ ការសន្ទនា១ បុគ្គល១ ភោជន១ រដូវ១ ឥរិយាបថ១ ហើយសេពសប្បាយ ៧ យ៉ាងទាំងនោះឯង មនសិការនិមិត្តនោះរឿយ ៗ ។

ព្រះយោគីនោះ គ្រាធ្វើនិមិត្តឱ្យរឹងមាំដោយការសេពសប្បាយយ៉ាងនោះហើយ គួរវេងចាំសេចក្ដីចម្រើនបរិបូណ៌ឡើង បំពេញសេចក្ដីព្យាយាមមិនលះចោលអប្បនាកោសល ១០ យ៉ាងទាំងនេះ គឺ ធ្វើវត្ថុឱ្យស្អាត១ ផ្គងឥន្ទ្រិយឱ្យប្រព្រឹត្តទៅស្មើ១ ឆ្លាតក្នុងនិមិត្ត១ គ្របសង្កត់ចិត្តក្នុងសម័យដែលគួរគ្របសង្កត់១ ផ្គងចិត្តក្នុងសម័យដែលគួរផ្គង១ លួងលោមចិត្តឱ្យរីករាយក្នុងសម័យដែលគួរលួងលោមចិត្តឱ្យរីករាយ១ សម្លឹងមើលចិត្តក្នុងសម័យដែលគួរសម្លឹងមើល១ វៀរបុគ្គលដែលមានចិត្តមិនតាំងមាំ១ សេពបុគ្គលដែលមានចិត្តតាំងមាំ១ បង្អោនទៅក្នុងសមាធិនោះ ១ កាលព្រះយោគីនោះប្រឹងប្រែងប្រកបតាមន័យដូចពោលមកយ៉ាងនេះ មនោទ្វារាវជ្ជនៈ ដែលមាននិមិត្តជាអារម្មណ៍ កាត់ភវង្គហើយក៏កើតឡើងក្នុងខណៈដែលគួរពោលថា អប្បនា នឹងកើតឡើងក្នុងកាលឥឡូវនេះ ។ ក៏កាលមនោទ្វារាវជ្ជនៈនោះរលត់ទៅ ។ បណ្ដាជវនៈទាំងឡាយ ៤ ឬ ៥ ខណៈ គោងយកអារម្មណ៍នោះឯងត្រាច់ទៅ ដែលជវនៈខណៈដំបូងឈ្មោះបរិកម្ម, ទី ២ ឈ្មោះឧបចារ, ទី ៣ ឈ្មោះអនុលោម, ទី ៤ ឈ្មោះគោត្រភូ, ទី ៥ ឈ្មោះអប្បនាចិត្ត ។ ម្យ៉ាងទៀត ដួងដំបូងហៅថាបរិកម្មនិងឧបចារ ទី ២ ហៅថា អនុលោម, ទី ៣ ហៅថា គោត្រភូ, ទី ៤ ហៅថា អប្បនាចិត្ត ។ ពិតមែន ជវនៈ ដួងទី ៤ ប៉ុណ្ណោះ ពេលខ្លះទី ៥ រមែងប្រព្រឹត្តទៅ មិនដល់ដួងទី ៦ ឬទី ៧ ព្រោះ

អាសន្នភវង្គ (ភវង្គជិតអប្បនា) ធ្លាក់ទៅ ។ ចំណែកព្រះគោទត្តត្ថេរ អ្នកជំនាញអភិធម្មពោលទុកថា កុសលធម៌ទាំងឡាយ រមែងជាធម៌មានកម្លាំងដោយអាសេវនបច្ច័យ; ព្រោះដូច្នោះ ជវនៈ រមែងដល់ទី ៦ ឬទី ៧ ។ ពាក្យនោះត្រូវជំទាស់ក្នុងអដ្ឋកថាទាំងឡាយ ។ ក្នុងជវនចិត្តទាំងនោះ ចិត្តដែលជាបុព្វភាគ ជាកាមាវចរ ចំណែកអប្បនាចិត្តជារូបាវចរ ។ បឋមជ្ឈានដែលលះអង្គ ៥ ប្រកបដោយអង្គ ៥ បរិបូរណ៍ដោយលក្ខណៈ ១០ មានសេចក្តីល្អ ៣ រមែងជាការដែលព្រះយោគីនេះសម្រេចហើយ ដោយន័យដូចពោលមកដូច្នេះ ។ លោកញ៉ាំងអង្គឈានទាំងឡាយ មានវិតក្កៈជាដើមឱ្យស្ងប់រម្ងាប់ក្នុងអារម្មណ៍នោះឯង រមែងសម្រេចឈានទី ២ ទី ៣ និងទី ៤ ។ និងដោយហេតុមានប្រមាណត្រឹមនេះ លោក រមែងជាអ្នកដល់ទីបំផុតនៃភាវនា ដោយអំណាចនៃការបញ្ឈប់ ។ ក្នុងអធិការនេះ មានសង្ខេបកថាប៉ុណ្ណេះ ចំណែកអ្នកសិក្សាដែលត្រូវការសេចក្តីពិស្តារ គប្បីកាន់យកអំពីបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គចុះ ។ ចំណែកក្នុងកាយានុបស្សនានេះ ភិក្ខុដែលសម្រេចចតុត្ថជ្ឈានហើយយ៉ាងនោះ មានសេចក្តីប្រាថ្នានឹងចម្រើនកម្មដ្ឋាន ដោយអំណាចការកំណត់និងការផ្លាស់ប្តូរ ហើយសម្រេចសេចក្តីបរិសុទ្ធិ ធ្វើឈាននោះឯង ឱ្យដល់សេចក្តីជំនាញ (វសី) ដោយអាការ ៥ យ៉ាង ពោលគឺ **អាវជ្ជនៈ** ការរំពឹង, **សមាបជ្ជនៈ** ការចូល, **អធិដ្ឋានៈ** ការតាំង

ចិត្ត, **វុដ្ឋានៈ** ការចេញ, និង **បច្ចវេក្ខណៈ** ការពិចារណាហើយកំណត់រូប និងអរូបថា រូបមានអរូបជាប្រធាន ឬអរូបមានរូបជាប្រធាន, ហើយចាប់ផ្ដើមតាំងវិបស្សនា ។

សួរថា ផ្ដើមតាំងវិបស្សនាយ៉ាងណា ?

ឆ្លើយថា ពិតមែន ព្រះយោគីនោះ គ្រាចេញចាកឈានហើយ កំណត់អង្គឈាន រមែងឃើញហទយៈវត្ថុ ដែលជាទីអាស្រ័យនៃអង្គឈានទាំងនោះ រមែងឃើញភូតរូប ដែលជាទីអាស្រ័យនៃហទយៈវត្ថុនោះ និង រមែងឃើញករជកាយសូម្បីទាំងអស់ ដែលជាទីអាស្រ័យនៃភូតរូបទាំងនោះ ។ ក្នុងលំដាប់នៃការឃើញនោះ លោករមែងកំណត់រូបនិងអរូបថា អង្គឈានចាត់ជាអរូប, (ហទយៈ) វត្ថុជាដើមចាត់ជារូប ។ ម្យ៉ាងទៀត លោកនោះ លុះចេញចាកសមាបត្តិហើយ កំណត់ភូតរូបទាំង ៤ ដោយអំណាចបរិធាតុជាដើម ក្នុងបណ្ដាចំណែកទាំងឡាយមានសក់ជាដើម និងរូបដែលអាស្រ័យភូតរូបនោះ រមែងឃើញវិញ្ញាណព្រមទាំងសម្បយុត្តធម៌ដែលមានរូបតាមដែលខ្លួនកំណត់ហើយជាអារម្មណ៍ ឬមានរូបវត្ថុ និងទ្វារតាមដែលខ្លួនកំណត់ហើយជាអារម្មណ៍ ។ លំដាប់នោះ លោករមែងកំណត់ថា ភូតរូបជាដើម ចាត់ជារូប, វិញ្ញាណដែលមានសម្បយុត្តធម៌ ចាត់ជាអរូប ។ ម្យ៉ាងទៀត កាលលោកចេញចាកសមាបត្តិហើយ រមែងឃើញថា ករជកាយ និងចិត្តជាទីកើតឡើងនៃ

ខ្យល់អស្សាសៈនិងបស្សាសៈ ។ ដូចយ៉ាងថា កាលស្នប់របស់ជាងមាស នៅសប់ ខ្យល់រមែងសញ្ចរទៅមក ព្រោះអាស្រ័យការសប់ និងសេចក្តីព្យាយាមដែលកើតអំពីការសប់នោះរបស់បុរស យ៉ាងណា, ខ្យល់ដកដង្ហើមចេញនិងដកដង្ហើមចូល រមែងចូលចេញ ព្រោះអាស្រ័យកាយនិងចិត្ត ក៏យ៉ាងនោះដែរ ។ លំដាប់នោះ លោកកំណត់ខ្យល់ដកដង្ហើមចេញដកដង្ហើមចូល និងកាយថា ជារូប, កំណត់ចិត្តនោះនិងធម៌ដែលសម្បយុត្តដោយចិត្តថា ជាអរូប ។ កាលលោកកំណត់នាមរូបដោយអាការយ៉ាងនោះហើយ រមែងស្វែងរកបច្ច័យនៃនាមរូបនោះ ។ លោកកាលស្វែងរក ក៏បានឃើញបច្ច័យមានអវិជ្ជា និងតណ្ហាជាដើមនោះហើយ រមែងឆ្លងផុតពីការសង្ស័យ ប្រារព្ធការប្រព្រឹត្តទៅនៃនាមរូបក្នុងកាលទាំង ៣ ចេញបាន ។ លោកនោះឆ្លងសេចក្តីសង្ស័យបានហើយ លើកត្រៃលក្ខណ៍ឡើងដោយអំណាចពិចារណាកលាបៈ លះវិបស្សនូបក្កិលេស ១០ យ៉ាង មានឱភាសជាដើម ដែលកើតឡើងហើយក្នុងចំណែកខាងដើម ដោយឧទយព្វយានុបស្សនា (ការពិចារណាឃើញការកើត និងការរលត់) កំណត់បដិបទាញាណដែលរួចផុតពីឧបក្កិលេសថា ជាមគ្គ លះការកើតចេញ ដល់ភង្គានុបស្សនា (ការពិចារណាឃើញការរលត់) នឿយណាយប្រាសចាកតម្រេក រួចផុតពីសង្ខារទាំងពួង ដែលប្រាកដជារបស់គួរខ្លាច ដោយពិចារណាឃើញការរលត់ជាប់តគ្នាទៅ បានសម្រេច

អរិយមគ្គទាំង ៤ តាមលំដាប់ ហើយតាំងនៅក្នុងព្រះអរហត្តផលដល់ទីបំផុតនៃបច្ចវេក្ខណញ្ញាណ ១៩ យ៉ាង ជាកំពូលនៃទក្ខិណេយ្យបុគ្គលក្នុងលោក ព្រមទាំងទេវលោក ។ ក៏ការចម្រើនអានាបានស្សតិសមាធិ របស់ភិក្ខុដែលប្រកបក្នុងអានាបានស្សតិកម្មដ្ឋាននោះ ចាប់ផ្ដើមតាំងពីការរាប់ដរាបដល់មគ្គផលជាទីបំផុត ចប់បរិបូណ៌ត្រឹមតែប៉ុណ្ណេះឯង ។

នេះពណ៌នាបឋមចតុក្កៈដោយអាការគ្រប់យ៉ាង ក៏ព្រោះក្នុង៣ចតុក្កៈក្រៅនេះ ដែលឈ្មោះថា ន័យនៃការចម្រើនកម្មដ្ឋានមួយផ្នែករមែងមិនមាន; ព្រោះដូច្នោះ អ្នកសិក្សាគួរជ្រាបសេចក្ដីនៃ ៣ ចតុក្កៈទាំងនោះ ដោយន័យដូចដែលបានពណ៌នាតាមបទនុ៎ះឯង ។

បទថា **បីតិបដិសំវេទី : នឹងកំណត់ដឹងច្បាស់នូវបីតិ** សេចក្ដីថា លោក រមែងកំណត់ថា យើងនឹងធ្វើបីតិឱ្យដឹងច្បាស់ គឺ ធ្វើឱ្យប្រាកដដកដង្ហើមចេញ ដកដង្ហើមចូល ។ បណ្ដាបីតិនិងសុខទាំងនោះ បីតិ រមែងជាការដែលភិក្ខុដឹងច្បាស់ហើយដោយអាការ ២ យ៉ាង គឺ ដោយអារម្មណ៍ និងដោយការឈ្លាស ។

សួរថា បីតិ រមែងជាការភិក្ខុដឹងច្បាស់ហើយ ដោយអារម្មណ៍យ៉ាងណា ?

ឆ្លើយថា ភិក្ខុនោះ រមែងចូលឈានទាំង ២ (បឋមជ្ឈាននិង

ទុតិយជ្ឈាន) ដែលមានបីតិ, បីតិឈ្មោះថា ជាការដែលភិក្ខុនោះដឹងច្បាស់ហើយដោយអារម្មណ៍ ដោយការបានឈានក្នុងខណៈចូលសមាបត្តិ ព្រោះអារម្មណ៍ជាធម្មជាតិដែលភិក្ខុនោះដឹងច្បាស់ហើយ ។

សួរថា បីតិដែលភិក្ខុដឹងច្បាស់ហើយដោយសេចក្តីមិនល្ងង់យ៉ាងណា ?

ឆ្លើយថា ភិក្ខុនោះចូលឈានទាំង ២ ដែលមានបីតិ ចេញចាកឈានហើយ រមែងពិចារណា បីតិដែលសម្បយុត្តដោយឈាន ដោយការអស់ ការសាបសូន្យ, បីតិឈ្មោះថា ដែលភិក្ខុនោះ ដឹងច្បាស់ហើយដោយសេចក្តីមិនវង្វេង ព្រោះចាក់ធ្លុះលក្ខណៈ ក្នុងខណៈនៃវិបស្សនា ។ សេចក្តីនេះ សមពិត ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកក្នុងបដិសម្ភិទាថា ៖

"កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង សតិក៏តម្កល់មាំ, បីតិនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ, កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចដង្ហើមចូលវែង សតិក៏តម្កល់មាំ, បីតិនោះឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ,

កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចដង្ហើមចេញវែង ដោយអំណាចដង្ហើមចូលវែង; ដោយអំណាចដង្ហើមចេញរបស់អ្នកកំណត់ដឹងនូវកាយទាំងពួង ដោយអំណាចដង្ហើមចេញរបស់អ្នករម្ងាប់នូវកាយសង្ខារ ដោយអំណាចដង្ហើមចូលរបស់អ្នករម្ងាប់នូវកាយសង្ខារ សតិក៏តម្កល់មាំ, បីតិនោះ ឈ្មោះថាបុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ, កាលបុគ្គលរំពឹង បីតិនោះ ឈ្មោះថា គេដឹងច្បាស់ហើយ, កាលបុគ្គលដឹង .... កាលឃើញ កាលពិចារណា កាលអធិដ្ឋាននូវចិត្ត កាលជឿស៊ប់ដោយសទ្ធា កាលផ្គងនូវវីរិយៈ កាលប្រុងទុកនូវសតិ កាលតម្កល់នូវចិត្ត កាលដឹងច្បាស់ដោយបញ្ញា កាលត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង កាលលះបង់នូវធម៌ដែលគួរលះបង់ កាលចម្រើននូវធម៌ដែលគួរចម្រើន កាលធ្វើឱ្យច្បាស់នូវធម៌ដែលគួរធ្វើឱ្យច្បាស់ បីតិនោះ ឈ្មោះថា គេដឹងច្បាស់ហើយ[១] ។ សូម្បីបទដ៏សេស ក៏គប្បីជ្រាបដោយសេចក្ដីតាមន័យនេះឯង ។

តែក្នុងពីរបទនេះមានសេចក្ដីគ្រាន់តែប្លែកគ្នា ដូចតទៅនេះ ៖

គប្បីជ្រាបភាពជាអ្នកដឹងច្បាស់នូវសុខដោយអំណាចនៃឈាន ៣,

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ១១៦/១៥១ ។

គប្បីជ្រាបភាពជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ដោយអំណាចនៃឈានទាំង ៤ ។ ខន្ធ ២ មានវេទនាជាដើម ឈ្មោះថា ចិត្តសង្ខារ ។ ក៏បណ្តាពីរបទនេះ ក្នុងសុខប្បដិសំវេទិបទ ព្រះសារីបុត្រថេរៈពោលទុកក្នុងបដិសម្ភិទា ដើម្បីសម្តែងភូមិនៃវិបស្សនាថា ពាក្យថា សុខ បានដល់សុខ ២ យ៉ាង គឺ កាយិកសុខ ១ ចេតសិកសុខ ១ ។

ពីរបទថា **បស្សម្ភយំ ចិត្តសង្ខារំ : រម្ងាប់ចិត្តសង្ខារ** សេចក្តីថា រម្ងាប់ គឺ រលត់ចិត្តសង្ខារដែលគ្រោតគ្រាត ៗ ចេញ សេចក្តីរលត់ចិត្តសង្ខារនោះ គប្បីជ្រាបដោយពិស្តារតាមន័យដូចដែលពោលហើយក្នុងកាយសង្ខារនោះឯង ។

ម្យ៉ាងទៀត បណ្តាបទទាំងនេះ ក្នុងបីតិបទ លោកពោលវេទនាទុកដោយបីតិជាប្រធាន, ក្នុងសុខបដិសំវេទិបទ លោកពោលវេទនាទុកដោយសរូបតែម្តង, ក្នុងចិត្តសង្ខារនៃបទទាំងពីរ ជាការលោកពោលវេទនាដែលសម្បយុត្តដោយសញ្ញាទុក ព្រោះព្រះបាលីថា "សញ្ញានិងវេទនា ជាតួចេតសិក ធម៌ទាំងនុ៎ះជាប់ចំពោះដោយចិត្ត ដោយអំណាចដង្ហើមចេញវែង ឈ្មោះថា ចិត្តសង្ខារ"[១] ដូច្នេះ ចតុក្កៈ នេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដោយវេទនានុបស្សនាន័យ ដោយប្រការយ៉ាងនេះ ។

---

១. ខុទ្ទ. បដិ. មហាវគ្គ. ៧០. ១១៨/១៥៧ ។

សួរថាក្នុងចតុក្កៈទី ៣ មានវិនិច្ឆ័យដូច្នេះ ៖

បណ្ឌិតគប្បីជ្រាបភាពជាអ្នកដឹងច្បាស់ចិត្ត ដោយអំណាចនៃឈាន ៤ ។

ពីរបទថា **អភិប្បមោទយំ ចិត្តំ : ធ្វើចិត្តឱ្យរីករាយ**

សេចក្តីថា ភិក្ខុ រមែងកំណត់ថា យើងនឹងញុំាងចិត្តឱ្យរីករាយ បានដល់ឱ្យរីករាយដកដង្ហើមចេញដកដង្ហើមចូល ។

ក្នុងពីរបទនោះ សេចក្តីរីករាយ រមែងកើតបាន ដោយអាការ ២ យ៉ាងគឺ ដោយអំណាចសមាធិ និងដោយអំណាចវិបស្សនា ។

សួរថា សេចក្តីរីករាយ រមែងកើតបាន ដោយអំណាចសមាធិយ៉ាងណា ?

ឆ្លើយថា ភិក្ខុរមែងចូលឈានទាំង ២ (បឋមជ្ឈាន និងទុតិយជ្ឈាន) ដែលមានបីតិ ។ លោកនោះ រមែងឱ្យចិត្តរីករាយដោយបីតិដែលសម្បយុត្តក្នុងខណៈ នៃសមាបត្តិ ។

សួរថា សេចក្តីរីករាយ រមែងកើតបាន ដោយអំណាចវិបស្សនាយ៉ាងណា ?

ឆ្លើយថា កាលភិក្ខុចូលឈានទាំង ២ ដែលមានបីតិ ចេញចាកឈានហើយពិចារណានូវបីតិដែលសម្បយុត្តដោយឈាន ដោយការអស់

ទៅ សូន្យទៅ ។ លោកធ្វើបីតិសម្បយុត្តដោយឈានឱ្យជាអារម្មណ៍ក្នុងខណៈនៃវិបស្សនាយ៉ាងនោះហើយ ឱ្យចិត្តរីករាយ រីករាយនៅ ។ អ្នកបដិបត្តិយ៉ាងនោះ លោកហៅថា រមែងកំណត់ថា យើងនឹងញ៉ាំងចិត្តឱ្យរីករាយដកដង្ហើមចេញដកដង្ហើមចូល ។

ពីរបទថា **សមាទហំ ចិត្តំ** : **នឹងតាំងចិត្តខ្ជាប់** សេចក្ដីថា តម្កល់ចិត្តទុកស្មើ គឺ តាំងចិត្តទុកស្មើក្នុងអារម្មណ៍ ដោយអំណាចនៃឈានមានបឋមជ្ឈានជាដើម ។ បើថា កាលលោកចូលឈានទាំងនោះហើយចេញចាកឈាន ពិចារណានូវចិត្តដែលសម្បយុត្តដោយឈានដោយការអស់ទៅ សូន្យទៅ ចិត្តដែលមានអារម្មណ៍តែមួយខណៈ (ខណិកសមាធិ) រមែងកើតឡើង ព្រោះការចាក់ធ្លុះលក្ខណៈ ក្នុងខណៈនៃវិបស្សនា ភិក្ខុដែលតម្កល់ចិត្តទុកស្មើ គឺ តាំងចិត្តទុកស្មើក្នុងអារម្មណ៍សូម្បីដោយអំណាចនៃចិត្តមានអារម្មណ៍តែមួយខណៈ ដែលកើតឡើងហើយយ៉ាងនោះ លោកក៏ហៅថា រមែងកំណត់ថា យើងនឹងតាំងចិត្តទុកមាំ ដកដង្ហើមចេញដកដង្ហើមចូល ។

ពីរបទថា **វិមោចយំ ចិត្តំ** : **នឹងដោះចិត្តឱ្យផុតស្រឡះ** សេចក្ដីថា កាលផ្លាស់ប្ដូរ កាលរំដោះចិត្តឱ្យផុតពីនីវរណៈទាំងឡាយ ដោយបឋមជ្ឈាន គឺ កាលដោះលែងចិត្តឱ្យផុតចាកវិតក្កវិចារ ដោយទុតិយជ្ឈាន

ចាកបីតិដោយតតិយជ្ឈាន ចាកសុខនិងទុក្ខដោយចតុត្ថជ្ឈាន ។ ឬក៏ថា លោកចូលឈានទាំងនោះ ហើយចេញមកពិចារណានូវចិត្តដែលសម្បយុត្តដោយឈាន ដោយអស់ទៅ សូន្យទៅ ក្នុងខណៈនៃវិបស្សនា លោកនោះដោះ គឺ ដកចិត្តឱ្យផុតចាកនិច្ចសញ្ញា (សេចក្ដីសម្គាល់ថាទៀង) ដោយអនិច្ចានុបស្សនា (សេចក្ដីពិចារណាឃើញថា មិនទៀង), ដោះ គឺ ដកចិត្តឱ្យផុតពីសុខសញ្ញា (សេចក្ដីសម្គាល់ថា ជាសុខ) ដោយទុក្ខានុបស្សនា (សេចក្ដីពិចារណាឃើញថា ជាទុក្ខ), ចាកអត្តសញ្ញា (សេចក្ដីសម្គាល់ថា ជាខ្លួន) ដោយអនត្តានុបស្សនា (សេចក្ដីពិចារណាឃើញថា មិនមែនខ្លួន), ចាកនន្ទិ (សេចក្ដីភ្លើតភ្លើន) ដោយនិព្វិទានុបស្សនា (ការពិចារណាឃើញសេចក្ដីនឿយណាយ), ចាករាគៈ (សេចក្ដីតម្រេក) ដោយវិរាគានុបស្សនា (សេចក្ដីពិចារណាឃើញធម៌គ្រឿងប្រាសចាកតម្រេក), ចាកសមុទ័យ (តណ្ហាដែលនាំទុក្ខឱ្យកើត) ដោយនិរោធានុបស្សនា (សេចក្ដីពិចារណាឃើញធម៌ជាគ្រឿងរលត់), ចាកអាទាន (សេចក្ដីប្រកាន់) ដោយបដិនិស្សគ្គានុបស្សនា (ការពិចារណាឃើញធម៌ជាគ្រឿងលះបង់នូវឧបធិ) ដកដង្ហើមចេញ និងដកដង្ហើមចូល ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា "សិក្សាថា អាត្មាអញនឹងដោះចិត្តឱ្យរួច (ចាកនីវរណធម៌ជាដើម) នឹងដកដង្ហើម

បេញ សិក្សាថា អាត្មាអញនឹងដោះចិត្តឱ្យរួច (ចាកនីវរណធម៌ជាដើម) នឹងដកដង្ហើមចូល”[១] ។ ចតុក្កៈនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ដោយអំណាចនៃចិត្តានុបស្សនាយ៉ាងនេះ ។

ចំណែកក្នុងចតុក្កៈទី ៤ មានវិនិច្ឆ័យដូច្នេះ ៖

ក្នុងបទថា **អនិច្ចានុបស្សី : នឹងពិចារណា ដោយសភាពជារបស់មិនទៀង** នេះ គប្បីជ្រាបអនិច្ចំ (របស់មិនទៀង) គប្បីជ្រាបអនិច្ចតា (ភាពជារបស់មិនទៀង) គប្បីជ្រាបអនិច្ចតានុបស្សនា (ការពិចារណាឃើញរបស់មិនទៀង) គប្បីជ្រាបអនិច្ចានុបស្សី (អ្នកពិចារណាឃើញរបស់មិនទៀង) ជាមុន ។

ក្នុងលក្ខណៈ ៤ យ៉ាង មាន អនិច្ចំ ជាដើមនោះ គឺ

ដែលឈ្មោះថា **អនិច្ចំ : របស់មិនទៀង** បានដល់ បញ្ចក្ខន្ធ ព្រោះហេតុអ្វី ? ព្រោះហេតុថា បញ្ចក្ខន្ធមានសេចក្តីកើតឡើង មានសេចក្តីសាបសូន្យទៅ និងមានការប្រព្រឹត្តទៅដោយប្រការដទៃ ។

ដែលឈ្មោះថា **អនិច្ចតា : ភាពជារបស់មិនទៀង** បានដល់ បញ្ចក្ខន្ធទាំងនោះ មានការកើតឡើង មានការសាបសូន្យទៅ មានការ

១. មជ្ឈិ. មជ្ឈិ. ២៣. ១៤៦/២៤២-២៤៣ ; មជ្ឈិ. ឧប. ២៦. ២៨៨/៣៦១, ២៨៩/៣៦៥; សំយុ. មហា. ៣៩. ៧/៦ ។

ប្រព្រឹត្តទៅដោយប្រការដទៃ ឬមានហើយត្រឡប់ជាមិនមានវិញ; អធិប្បាយថា បញ្ចក្ខន្ធទាំងនោះ កើតឡើងហើយ មិនតាំងនៅដោយអាការនោះ ៗឯង បែកធ្លាយព្រោះការរលត់គ្រប់ខណៈ ។

ដែលឈ្មោះថា **អនិច្ចានុបស្សនា : ពិចារណាឃើញថា មិនទៀង** បានដល់ ការពិចារណាឃើញក្នុងបញ្ចក្ខន្ធទាំងឡាយ មានរូបជាដើមថា មិនទៀង ដោយអំណាចនៃភាពជារបស់មិនទៀងនោះ ។

ដែលឈ្មោះថា **អនិច្ចានុបស្សី : ជាអ្នកពិចារណាឃើញថា មិនទៀង** បានដល់ បុគ្គលដែលប្រកបដោយអនុបស្សនានោះ ។ ព្រោះហេតុនោះ បុគ្គលមានអនុបស្សនាហើយយ៉ាងនេះ ក៏ដកដង្ហើមចូល និងដកដង្ហើមចេញ បណ្ឌិតគប្បីជ្រាបក្នុងអធិការនេះថា "សិក្សាថា អាត្មាអញ នឹងពិចារណា (នូវបញ្ចក្ខន្ធថា) មិនទៀង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងពិចារណា (នូវបញ្ចក្ខន្ធថា) មិនទៀង ហើយដកដង្ហើមចូល"[១] ។

ចំណែកវិរាគៈ ក្នុងបទថា **វិរាគានុបស្សី : នឹងពិចារណាដោយសភាពឥតរាគៈ** នេះ មាន ២ យ៉ាង គឺ ខយវិរាគៈ អស់សេចក្ដីតម្រេក គឺ សេចក្ដីអស់ទៅ ១ អច្ចន្តវិរាគៈ ប្រាសចាកតម្រេកដោយ

---

១. មជ្ឈិ. មជ្ឈិ. ២៣. ១៩៦/២៨២-២៨៣ ។

ចំណែកមួយ ១ បណ្ឌាវិភគៈ ២ យ៉ាងនោះ ការបែកធ្លាយទៅមួយខណៈ ៗនៃសង្ខារទាំងឡាយ ឈ្មោះថា ខយវិភគៈ ។ ព្រះនិព្វានឈ្មោះថា អច្ចន្តវិភគៈ ។ វិបស្សនាទិនមគ្គដែលប្រព្រឹត្តទៅដោយអំណាចនៃការឃើញវិភគៈទាំង ២ យ៉ាងនោះ ឈ្មោះថា វិភគានុបស្សនា (ការពិចារណាឃើញការប្រាសចាកតម្រេក) ។ ព្រះយោគាវចរជាអ្នកប្រកបដោយអនុបស្សនាសូម្បីទាំង ២ យ៉ាងនោះ ដកដង្ហើមចេញនិងដកដង្ហើមចូល បណ្ឌិតគប្បីជ្រាបថា រមែងកំណត់ថា យើងនឹងពិចារណាឃើញវិភគៈដកដង្ហើមចេញដកដង្ហើមចូល ។ សូម្បីក្នុងបទថា និរោធានុបស្សី ក៏មាននន័យដូចគ្នានេះ ។ បដិនិស្សគ្គៈ (លោះសចេញនូវឧបធិ) សូម្បីក្នុងបទថា បដិនិស្សគ្គានុបស្សី : នឹងពិចារណាឱ្យរឿយ ៗ ដោយកិរិយាលះបង់នូវសេចក្តីប្រកាន់ ។ នេះក៏មាន ២ យ៉ាង គឺ បរិច្ចាគបដិនិស្សគ្គៈ ការលោះសចេញ គឺការលះបង់ ១ បក្ខន្ទនបដិនិស្សគ្គៈ ការលោះសចេញ គឺការស្ទុះទៅ ១ ។ ការពិចារណាឃើញ គឺ សេចក្តីលះបង់នុ៎ះឯង ឈ្មោះថា បដិនិស្សគ្គានុបស្សនា ។

ពាក្យថា បដិនិស្សគ្គានុបស្សនា នោះ ជាឈ្មោះនៃវិបស្សនាទិនមគ្គ ។ ពិតមែន វិបស្សនា ព្រះមានព្រះភាគត្រាស់ហៅថា បរិច្ចាគបដិនិស្សគ្គៈ ព្រោះរមែងលះកិលេសទាំងឡាយព្រមទាំងខន្ធាភិសង្ខារដោយអំណាចតទង្គបហាន និងថា បក្ខន្ទនបដិនិស្សគ្គៈ ព្រោះរមែងត្រាច់

ទៅក្នុងព្រះនិព្វាន ដែលខុសពីសង្ខារនោះ ហេតុដែលបង្អោនទៅក្នុងព្រះនិព្វាននោះ ព្រោះឃើញទោសនៃសង្ខតធម៌ ។ មគ្គព្រះមានព្រះភាគត្រាស់ហៅថា **បរិច្ចាគបដិនិស្សគ្គៈ** ព្រោះរមែងលះកិលេសព្រមទាំងខន្ធាភិសង្ខារ ដោយអំណាចសមុច្ឆេទប្បហាន និងថា **បក្ខន្ទនបដិនិស្សគ្គៈ** ព្រោះរមែងត្រាច់ទៅក្នុងព្រះនិព្វាន ដោយការធ្វើឱ្យជាអារម្មណ៍ ។ ក៏វិបស្សនាញាណ និងមគ្គញ្ញាណសូម្បីទាំង ២ ព្រះមានព្រះភាគត្រាស់ហៅថា អនុបស្សនា ព្រោះសម្លឹងឃើញញាណខាងដើម ៗ ក្នុងកាលជាខាងក្រោយ ។ ភិក្ខុជាអ្នកប្រកបដោយបដិនិស្សគ្គានុបស្សនាទាំង ២ យ៉ាងនោះ ដកដង្ហើមចូលនិងដកដង្ហើមចេញ បណ្ឌិតគប្បីជ្រាបថា "សិក្សាថា អាត្មាអញនឹងជាអ្នកមានប្រក្រតីសម្លឹងឃើញញាណឈ្មោះបដិនិស្សគ្គៈ ក្នុងកាលជាខាងក្រោយ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកមានប្រក្រតីសម្លឹងឃើញញាណ ឈ្មោះបដិនិស្សគ្គៈ ក្នុងកាលជាខាងក្រោយ ហើយដកដង្ហើមចូល" ដូច្នេះ ។

ពាក្យថា **ឯវំ ភាវិតោ :** ដែលបុគ្គលបានចម្រើនហើយយ៉ាងនេះ សេចក្ដីថា ចម្រើនហើយដោយអាការយ៉ាងនេះ គឺ ដោយអាការ ១៦ យ៉ាង ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។

អានាបានស្សតិសមាធិ ចប់ ។

## ប្រជុំសង្ឃទ្រង់បញ្ញត្តិតតិយបារាជិកសិក្ខាបទ

[១៧៩] ក៏ក្នុងពាក្យថា អថខោ ភគវា : ព្រះមានព្រះភាគ... ក្នុងគ្រានោះ ជាដើម មានសេចក្ដីសង្ខេបដូចតទៅនេះ ៖

ព្រះមានព្រះភាគ គ្រាទ្រង់លួងលោមភិក្ខុទាំងឡាយឱ្យស្រោលចិត្ត ដោយអានាបានស្សតិសមាធិកថាយ៉ាងនេះហើយ ក្នុងលំដាប់នោះ ត្រាស់ឱ្យប្រជុំភិក្ខុសង្ឃ ព្រោះកើតរឿងដែលភិក្ខុទាំងឡាយផ្ដាច់ជីវិតគ្នានិងគ្នា ដែលជាហេតុបង្កឱ្យកើតផល និងជាហេតុផ្ដើមដំបូងនៃការបញ្ញត្តិតតិយបារាជិកសិក្ខាបទនេះ ហើយ ត្រាស់សាកសួរនិងទ្រង់តិះដៀលហើយ ព្រោះក្នុងការផ្ដាច់ជីវិតនោះ ការផ្ដាច់ជីវិតដោយខ្លួនឯង និងការប្រើឱ្យមិគលណ្ឌិកសមណកុត្តកផ្ដាច់ជីវិតខ្លួន រមែងមិនជាវត្ថុនៃបារាជិក; ដូច្នោះ ទើបទ្រង់វៀរការផ្ដាច់ជីវិត ២ យ៉ាងនោះចេញ ទ្រង់កាន់យកការផ្ដាច់ជីវិតគ្នានិងគ្នា ដែលជាវត្ថុនៃបារាជិកតែម្យ៉ាង ទ្រង់បញ្ញត្តិបារាជិកសិក្ខាបទ ត្រាស់ព្រះពុទ្ធវចនៈមានពាក្យថា "ភិក្ខុណាមួយ ក្លែងផ្ដាច់បង់រាងកាយរបស់មនុស្សឱ្យឃ្លាតចាកជីវិតក្ដី ទោះបីស្វែងរកគ្រឿងសស្ត្រាវុធ (ឱ្យគេសម្លាប់) រាងកាយរបស់មនុស្សនោះក្ដី ភិក្ខុនេះឯង ហៅថា ត្រូវអាបត្តិបារាជិក រកសំវាសគ្មាន" ដូច្នេះ ។

ក៏ក្នុងព្រះបាលីនេះ ព្រះមានព្រះភាគ មិនត្រាស់ថា មោឃបុរិសា ត្រាស់ថា តេ ភិក្ខូ ព្រោះភិក្ខុទាំងនោះ លាយដោយព្រះអរិយបុគ្គល ។

## ភិក្ខុអព្ភត្ថិយពណ៌នាគុណនៃសេចក្ដីស្លាប់

[១៨០] កាលតតិយបារាជិក ដែលព្រះមានព្រះភាគទ្រង់បញ្ញត្តិធ្វើឱ្យមាំដោយអំណាចនៃការដាច់មូល ដោយប្រការដូច្នេះហើយ រឿងពណ៌នាគុណនៃសេចក្ដីស្លាប់សូម្បីដទៃទៀត ក៏បានកើតឡើង ដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ កាលសម្ដែងការកើតឡើងនៃរឿងនោះ ព្រះឧបាលីថេរៈ ទើបពោលពាក្យជាដើមថា **ឯវញ្ចិទំ ភគវតា : ព្រះមានព្រះភាគ...យ៉ាងនេះ** ។

បណ្ដាបទទាំងនោះ បទថា **បដិពទ្ធចិត្តា : មានចិត្តប្រតិព័ទ្ធ** មានសេចក្ដីថា អ្នកមានការស្រឡាញ់ពេញចិត្តដោយឆន្ទរាគៈ អធិប្បាយថា ជាអ្នកមានសេចក្ដីស្រឡាញ់មក គឺ មានសេចក្ដីគយគន់រំពៃ ។

ពីរបទថា **មរណវណ្ណំ សំវណ្ណេម : ពណ៌នាគុណនៃសេចក្ដីស្លាប់** មានសេចក្ដីថា យើងនឹងបង្ហាញទោសក្នុងការរស់នៅ ហើយពណ៌នាគុណ គឺ សម្ដែងអានិសង្សនៃសេចក្ដីស្លាប់ ។

ក្នុងបទថា **កតកល្យាណោ : អ្នកបានធ្វើអំពើល្អមកហើយ** ជាដើម មានសេចក្ដីចំពោះបទដូចតទៅនេះ ៖

កម្មដែលល្អគឺស្អាតដែលលោកធ្វើហើយ; ព្រោះហេតុនោះ លោករមែងជាអ្នកឈ្មោះថា **អ្នកបានធ្វើអំពើល្អមកហើយ** ។ មួយទៀត

កុសល គឺ កម្មដែលមិនមានទោស ដែលលោកធ្វើហើយ; ព្រោះហេតុនោះ លោកឈ្មោះថា **អ្នកបានធ្វើកុសលមកហើយ ។** ភាពជាអ្នកខ្លាចពោលគឺ សេចក្តីខ្លាចយ៉ាងណា រមែងកើតឡើងដល់សត្វទាំងឡាយ ក្នុងកាលមរណកាលចូលមកដល់, គ្រឿងទប់ទល់ គឺ កម្មគ្រឿងការពារពីភាពជាអ្នកខ្លាចនោះ ដែលលោកធ្វើហើយ; ព្រោះហេតុនោះ លោកឈ្មោះថា **អ្នកបានធ្វើកម្មជាគ្រឿងការពារភ័យរួចអស់ហើយ ។** កម្មដែលជាបាប គឺ អំពើលាមកលោកមិនដែលបានធ្វើឡើយ; ព្រោះហេតុនោះ លោកឈ្មោះថា **អ្នកមិនដែលធ្វើបាប ។** កម្មរបស់អ្នកល្មោភ គឺ កម្មទារុណ បានដល់ កម្មរបស់អ្នកទ្រុស្តសីល ដែលលោកមិនបានធ្វើទុក; ព្រោះហេតុនោះ លោកឈ្មោះថា **អ្នកមិនដែលធ្វើអំពើលាមក ។** កម្មគ្រោតគ្រាត គឺកម្មថោកទាបជាទីចម្រើនឡើងនៃកិលេស មានលោភៈជាដើមដែលលោកមិនបានធ្វើទុក ព្រោះហេតុនោះ លោកឈ្មោះថា **មិនដែលធ្វើអំពើអាក្រក់ ។** ពាក្យថា **ធ្វើអំពើល្អអ្នកបានហើយ បាបអ្នកមិនធ្លាប់ធ្វើឡើយ** នេះ យើងទាំងឡាយ[១] ពោលព្រោះហេតុអ្វី ? ព្រោះកម្មល្អ សូម្បីគ្រប់ប្រការដែលលោកធ្វើហើយ កម្មដែលជាបាបសូម្បីគ្រប់ប្រការលោកមិនដែលធ្វើសោះឡើយ; ព្រោះហេតុនោះ យើងទាំង

១. គឺពួកឆព្វគ្គិយភិក្ខុ ។

ឡាយ ទើបពោលទឹងលោកថា **មានប្រយោជន៍អ្វីដោយជីវិតអាក្រក់លាមកនេះ** គឺ ថោកទាប ព្រោះត្រូវរោគគ្របសង្កត់ ដែលឈ្មោះថា ជាទុក្ខ ព្រោះច្រើនទៅដោយទុក្ខនេះ, **អ្នកស្លាប់ទៅប្រសើរជាងរស់នៅ ។** ព្រោះដូច្នោះ ទើបមានអធិប្បាយថា សេចក្តីស្លាប់របស់លោក ល្អជាងការរស់នៅ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា លោកជាអ្នកធ្វើកាលកិរិយាហើយ គឺ មានកាលកិរិយាដែលធ្វើហើយ អធិប្បាយថា ធ្វើកាលកិរិយា គឺ រំលាងខ្លួនស្លាប់ហើយចាកមនុស្សលោកនេះ បន្ទាប់ពីស្លាប់ ព្រោះកាយបែកធ្លាយ ទឹងចូលដល់សុគតិសួគ៌ទេវលោក និងលោកចូលដល់ហើយយ៉ាងនោះ ទឹងឆ្អែតស្កប់ស្កល់ប្រកបព្រមដោយកាមគុណ ៥ គឺ ចំណែកនៃវត្ថុកាម ៥ មានរូបជាទីគួរពេញ ចិត្តជាដើម ដ៏ជាទិព្វកើតឡើងក្នុងទេវលោកនោះ ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ; អធិប្បាយថា ទឹងជាអ្នកប្រកបព្រម គឺ ដល់សេចក្តីប្រកបព្រម (ដោយកាមគុណ ៥ គឺ ចំណែកនៃវត្ថុកាម ៥ ដែលជាទិព្វកើតឡើងក្នុងទេវលោកនោះ) ទឹងត្រាច់ទៅខាងនេះ និងខាងនេះ គឺ ទឹងនៅ ឬទឹងអភិរម្យបទថា អសប្បាយានិ : **ដែលមិនសប្បាយ** សេចក្តីថា ភោជនាហារពួកណា ញ៉ាំងខ្លួនឱ្យដល់សេចក្តីអស់ទៅនៃជីវិតយ៉ាងឆាប់រហ័ស ភោជនាហារទាំងនោះ ចាត់ថាមិនទំនុកបម្រុង គឺមិនធ្វើសេចក្តីចម្រើនឱ្យ ។

# អធិប្បាយសញ្ចិច្ចស័ព្ទ

[១៨១] ស័ព្ទថា សញ្ចិច្ច : ក្លែង នេះ ជាស័ព្ទគាំទ្រសញ្ចិច្ចបទ ដែលព្រះមានព្រះភាគត្រាស់ហើយ ក្នុងមាតិកាថា សញ្ចិច្ច មនុស្សវិគ្គហំ : ក្លែងផ្តាច់បង់រាងកាយរបស់មនុស្ស ស័ព្ទថា សំ ក្នុងបទថា សញ្ចិច្ច នោះជាឧបសគ្គៈ ។ ពាក្យថា សញ្ចិច្ច នេះ ជាពាក្យប្រាប់ដល់បុព្វកាលកិរិយា រួមជាមួយ សំ ឧបសគ្គៈនោះ ។ សេចក្តីនៃបទថា សញ្ចិច្ច នោះថា តាំងចិត្ត គឺក្លែង ។ ក៏ភិក្ខុណាក្លែងផ្តាច់, ភិក្ខុនោះជាអ្នកដឹង គឺដឹងប្រាកដព្រម, និងការផ្តាច់នោះរបស់ភិក្ខុនោះ ជាការក្លែង គឺ ប្រព្រឹត្តកន្លង; ព្រោះហេតុនោះ ដើម្បីមិនធ្វើសេចក្តីអើពើក្នុងព្យញ្ជនៈ សម្តែងតែសេចក្តីប៉ុណ្ណោះ ទើបព្រះឧបាលីថេរៈពោលបទភាជនៈនៃបទថា សញ្ចិច្ច នោះ យ៉ាងនេះថា "ដឹងជាក់ច្បាស់ហើយក្លែងសម្លាប់ គឺ ប្រព្រឹត្តបំពានប្រព្រឹត្តកន្លង" ។

បណ្តាបទទាំងនោះ បទថា ជានន្តោ : ដឹង គឺ ដឹងថា សត្វមានប្រាណ ។

បទថា សញ្ជានន្តោ : ជាក់ច្បាស់ គឺ ដឹងព្រមថា យើងនឹងផ្តាច់ចេញចាកជីវិត ។ អធិប្បាយថា ដឹងព្រមទាំងអាការដែលដឹងថា សត្វមាន

ជីវិតនោះឯង ។

បទថា **ចេច្ច** : **ក្លែង** សេចក្តីថា តាំងចិត្ត គឺ ផ្ចង់ចិត្ត ដោយអំណាចចេតនាគិតនឹងសម្លាប់ ។

បទថា **អភិវិតរិត្វា** : **ប្រព្រឹត្តល្មើស** សេចក្តីថា បញ្ជូនចិត្តដែលអស់សេចក្តីសង្ស័យទៅញាំញីដោយអំណាចសេចក្តីព្យាបាទ ។

ដោយបទថា **វិតិក្កមោ** : **ប្រព្រឹត្តកន្លង** មានពាក្យអធិប្បាយដែលលោកពោលទុកថា សេចក្តីប្រព្រឹត្តកន្លងនៃចិត្តឬបុគ្គល ដែលប្រព្រឹត្តទៅហើយយ៉ាងនោះ នេះជាសេចក្តីអធិប្បាយខាងចុងបំផុតនៃសញ្ចិច្ចស័ព្ទ ។

## អធិប្បាយបឋមចិត្តរបស់អ្នកចុះកាន់គភ៌

ឥឡូវនេះ ព្រះឧបាលីថេរៈ ពោលពាក្យជាដើមថា ឈ្មោះថាកាយមនុស្ស ដើម្បីនឹងសម្តែងអត្តភាពរបស់មនុស្ស ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងពាក្យថា "ផ្តាច់បង់រាងកាយរបស់មនុស្សឱ្យឃ្លាតចាកជីវិត"នេះ តាំងពីដំបូង ។

បណ្តាបទទាំងនោះ ត្រើនបទថា ( បឋមចិត្ត ) យ៉ាងណា ( កើតឡើងហើយ )ក្នុងផ្ទៃនៃមាតា ព្រះឧបាលីថេរៈពោល ដើម្បីសម្តែងអត្តភាពដែលល្អិតបំផុតដោយអំណាចនៃពួកសត្វអ្នកដេកក្នុងគភ៌ ។ បដិសន្ធិ

ចិត្ត ឈ្មោះ បឋមចិត្ត ។ ពាក្យថា **កើតឡើង** បានដល់ ការកើត ។ ពាក្យថា **បឋមវិញ្ញាណ មានប្រាកដ** នេះ ជាពាក្យខែរបស់ពាក្យថា **បឋមចិត្តណាដែលកើតឡើង** នោះឯង ។ បណ្ដាពាក្យទាំងនេះ ដោយពាក្យថា បឋមចិត្ត (ដែលកើតឡើង) ក្នុងផ្ទៃមាតានុ៎ះឯង ដែលលោកសម្ដែងបដិសន្ធិរបស់សត្វដែលមានខន្ធ ៥ សូម្បីទាំងអស់ ។ ព្រោះហេតុនោះ កាយមនុស្សជាដំបូងបង្អស់នេះ គឺ បឋមចិត្តនោះ ១ អរូបខន្ធ ៣ ដែលជាប់ដោយចិត្តនោះ ១ កលលរូបដែលកើតព្រមជាមួយចិត្តនោះ ១ បណ្ដាអរូបខន្ធ និងកលលរូបនៃចិត្តដំបូងនោះ រូប៣០ គត់ដោយអំណាចនៃកាយ ១០ វត្ថុ ១០ និងភាវៈ ១០ នៃស្ត្រីនិងបុរសរូប ២០ ដោយអំណាចនៃកាយ ១០ និងវត្ថុ ១០ នៃពួកខ្ទើយ ឈ្មោះថាកលលរូប ។

បណ្ដាស្ត្រី បុរស និងខ្ទើយយនោះ កលលរូបរបស់ស្ត្រីនិងបុរស មានខ្នាតប៉ុនតំណក់ប្រេងល្ងដែលលើកឡើងដោយចុងម្ខាងនៃរោមទ្រាយដំបូង កើតជារបស់ភ្លឺថ្លាច្បាស់ ។ ពិតមែន ក្នុងអដ្ឋកថាលោកពោលពាក្យនេះថា

> តំណក់ប្រេងល្ង ឬសប្បិថ្លា មិនល្អក់កករ យ៉ាងណា, រូបមានចំណែកប្រៀបធៀបដោយពណ៌យ៉ាងនោះ ហៅថាកលលរូប ។

អត្តភាពរបស់សត្វមានអាយុ ១២០ ឆ្នាំតាមប្រក្រតី ដែលដល់សេចក្តីជំធាត់ដោយលំដាប់ក្នុងចន្លោះនេះ គឺ ចាប់តាំងពីជាវត្ថុតូចយ៉ាងនេះ ដរាបដល់វេលាស្លាប់ នេះឈ្មោះថា កាយមនុស្ស ។

ពីរបទថា **ជីវិតា វោរោបេយ្យ : ផ្តាច់បង់ចាកជីវិត** សេចក្តីថា គប្បីផ្តាច់ចាកជីវិតដោយការសង្កត់ និងប្របាច់ ឬដោយការដាក់ថ្នាំ ក្នុងកាលដែលនៅជាកលលៈក្តី ឬដោយសេចក្តីព្យាយាមដ៏សមគួរដល់រូបនោះ ៗ ក្នុងកាលបន្ទាប់ពីជាកលលៈនោះទៅក្តី ។ ក៏ដែលឈ្មោះថា ផ្តាច់ចេញចាកជីវិត ដោយសេចក្តីក៏គឺ ការចូលទៅកាត់ឥន្ទ្រិយ គឺ ជីវិតចេញនោះឯង; ព្រោះដូច្នោះ ក្នុងវារៈចែកបទនៃពីរបទថា ផ្តាច់ចេញចាកជីវិតនោះ ទើបព្រះឧបាលីពោលថា **"ញ៉ាំងជីវិតិន្ទ្រិយ គឺជីវិតឱ្យរលត់ទៅ គឺថា ញ៉ាំងសន្តតិ (ខ្សែនៃចិត្ត) ឱ្យកម្រើក"** លោកពោលថា **"ញ៉ាំងជីវិតិន្ទ្រិយ គឺជីវិតឱ្យរលត់ទៅ"** ក្នុងបទភាជនៈនោះ ។ សេចក្តីនេះ លោកសម្តែងដោយបទថា **"ញ៉ាំងសន្តតិ (ខ្សែនៃចិត្ត) ឱ្យកម្រើក"** ។

បទថា **វិកោបេតិ : ចូលទៅផ្តាច់** គឺ ផ្តាច់ចេញ ។

ក្នុងបទថា **ជីវិតិន្ទ្រិយ : ឥន្ទ្រិយគឺជីវិត** នោះ ឥន្ទ្រិយគឺ ជីវិតមាន ២ យ៉ាង គឺ រូបជីវិតិន្ទ្រិយ ១ អរូបជីវិតិន្ទ្រិយ ១ ។ បណ្តាជីវិតិន្ទ្រិយទាំង ២ យ៉ាងនោះ ក្នុងអរូបជីវិតិន្ទ្រិយ មិនមានសេចក្តីព្យាយាម

អ្នកណា ៗ មិនអាចផ្តាច់អរូបជីវិតិន្ទ្រិយនោះបាន ៗ តែក្នុងរូបជីវិតិន្ទ្រិយ មាន, បុគ្គលអាចផ្តាច់បាន ៗ ក៏កាលផ្តាច់រូបជីវិតិន្ទ្រិយនោះ ឈ្មោះថា ផ្តាច់អរូបជីវិតិន្ទ្រិយផង ៗ ពិតមែន អរូបជីវិតិន្ទ្រិយនោះ រមែងរលត់ព្រមទាំងរូបជីវិតិន្ទ្រិយនោះឯង ព្រោះមានព្រឹត្តិការណ៍ជាប់ដោយរូបជីវិតិន្ទ្រិយនោះ ៗ

សួរថា ក៏កាលផ្តាច់ជីវិតិន្ទ្រិយនោះ រមែងផ្តាច់ជីវិតិន្ទ្រិយដែលជាអតីត ឬជាអនាគត ឬបច្ចុប្បន្ន ? ឆ្លើយថា មិនមែនជីវិតិន្ទ្រិយអតីត មិនមែនជីវិតិន្ទ្រិយអនាគត ៗ ក៏ក្នុងជីវិតិន្ទ្រិយ ២ ប្រការនោះ មួយរលត់ទៅហើយ មួយមិនទាន់កើតឡើង; ព្រោះដូច្នោះ ឈ្មោះថា មិនមានទាំង ២ ប្រការ ព្រោះជាវត្ថុដែលមិនមាន, សេចក្តីព្យាយាមទើបមិនមាន; ព្រោះសេចក្តីព្យាយាមមិនមាន ទើបមិនអាចផ្តាច់បាន សូម្បីតែមួយប្រការ ៗ ពិតមែន សូម្បីពាក្យនេះព្រះធម្មសេនាបតីសារីបុត្រក៏បានពោលទុកថា "អតីតេ ចិត្តក្ខណេ ជីវិត្ថ ន ជីវតិ ន ជីវិស្សតិ ។ អនាគតេ ចិត្តក្ខណេ ជីវិស្សតិ ន ជីវតិ ន ជីវិត្ថ ។ បច្ចុប្បន្នេ ចិត្តក្ខណេ ជីវតិ ន ជីវិត្ថ ន ជីវិស្សតិ : សត្វដែលរស់នៅហើយ ក្នុងខណៈចិត្តជាអតីត មិនរស់នៅ នឹងមិនរស់នៅ ៗ សត្វនឹងរស់នៅ ក្នុងខណៈចិត្តជាអនាគត មិនរស់នៅ មិនរស់នៅហើយ ៗ សត្វកំពុង

រស់នៅ ក្នុងខណៈចិត្តជាបច្ចុប្បន្ន មិនបានរស់នៅ ហើយនឹងមិនរស់នៅ ។”[១] ព្រោះដូច្នោះ ជីវិតរមែងរស់នៅក្នុងខណៈចិត្តណា, សេចក្ដីព្យាយាមជារបស់សមគួរក្នុងខណៈចិត្តនោះ; ព្រោះហេតុនោះ បុគ្គលឈ្មោះថា រមែងផ្ដាច់ជីវិតិន្ទ្រិយដែលជាបច្ចុប្បន្ន ។

## ជីវិតិន្ទ្រិយបច្ចុប្បន្នមាន ៣ ខណៈ

ដែលឈ្មោះថា ជីវិតិន្ទ្រិយដែលជាបច្ចុប្បន្ននេះ មាន ៣ យ៉ាង គឺ ខណបច្ចុប្បន្ន ១ សន្តតិបច្ចុប្បន្ន ១ អទ្ធាបច្ចុប្បន្ន ១ ។ ក្នុង ៣ យ៉ាងនោះ បច្ចុប្បន្នដែលប្រកបព្រមដោយការកើត ការសាបសូន្យ និងការបែកធ្លាយ ឈ្មោះថា ខណបច្ចុប្បន្ន, អ្នកណា ៗ មិនអាចនឹងផ្ដាច់ខណបច្ចុប្បន្ននោះបាន ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា រលត់ទៅឯងតែម្ដង ។ (ខណៈចិត្ត) រយៈកាល ៧-៨ ជវនវារៈ ដែលប្រព្រឹត្តទៅដោយអំណាចសភាគសន្តតិ ហើយរលត់ទៅ ឈ្មោះថា សន្តតិបច្ចុប្បន្ន, កាលបុគ្គលមកអំពីទីក្ដៅ ចូលកាន់បន្ទប់តូចហើយអង្គុយ ងងឹតនៅមានត្រឹមណា ឬថា កាលបុគ្គលមកអំពីទីត្រជាក់ អង្គុយក្នុងបន្ទប់តូច រដូវដែលមាននៅមុនមិនទាន់រម្ងាប់ទៅ ដោយសេចក្ដីប្រាកដនៃរដូវដែល

---

១. ខុទ្ទ. មហា. គុហដ្ឋកសុត្តនិទ្ទេស. ៦៤. ៤៩/៧៧ ។

ជាវិសភាគគ្នាត្រឹមណា ។ ក្នុងចន្លោះនេះលោកហៅថា សន្តតិបច្ចុប្បន្ន ត្រឹមនោះ ។ ចំណែកតាំងពីបដិសន្ធិទៅដរាបដល់ចុតិ នេះឈ្មោះថា អទ្ធាបច្ចុប្បន្ន ។ បុគ្គលអាចផ្តាច់ពួកពីរនៃជីវិតិន្ទ្រិយដែលជាសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ននោះបានខ្លះ ។ សួរថា អាចផ្តាច់ បានយ៉ាងណា ? ឆ្លើយថា ពិតមែន កាលបុគ្គលធ្វើសេចក្តីព្យាយាមក្នុងពួក ២ នៃសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ននោះ, ពួកនៃរូប ១០ ប្រការ ដែលកំណត់ដោយជីវិត បានសេចក្តីព្យាយាមហើយកាលរលត់ រមែងជាបច្ច័យនៃសន្តានដែលទុព្វល មានកម្លាំងសាបសូន្យអស់ទៅហើយ, តពីនោះ សន្តតិបច្ចុប្បន្នឬអទ្ធាបច្ចុប្បន្ន មិនទាន់ដល់កាលដែលកំណត់ទុក រមែងរលត់ទៅក្នុងចន្លោះនោះឯង ដោយប្រការណា, បុគ្គលអាចផ្តាច់សូម្បីនូវពួកពីរនៃជីវិតិន្ទ្រិយដែលជាសន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ននោះបានខ្លះ ដោយប្រការនោះ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបសន្និដ្ឋានថា ពាក្យថា ញ៉ាំងសន្តតិ (ខ្សែនៃចិត្ត) ឱ្យកម្រើក នេះ ព្រះថេរៈពោលសំដៅយកពួកពីរបច្ចុប្បន្ននុ៎ះឯង ។

ក៏ដើម្បីប្រកាសសេចក្តីនេះ គួរជ្រាបបាណៈ, គួរជ្រាបបាណាតិបាត, គួរជ្រាបបាណាតិបាត, គួរជ្រាបប្រយោគនៃបាណាតិបាត ។

បណ្តាបាណៈជាដើមទាំងនោះ ដែលឈ្មោះថា បាណៈ ដោយ

វោហារបានដល់សត្វ, ដោយបរមត្ថ បានដល់ជីវិតិន្ទ្រិយ ។ ពិតមែន បុគ្គលដែលញុំាងជីវិតិន្ទ្រិយឱ្យធ្លាក់ចុះកន្លងទៅលោកពោលថា សម្លាប់សត្វ ។ ជីវិតិន្ទ្រិយនោះ មានប្រការដូចពោលហើយនុ៎ះឯង ។ បាណាតិបាតនោះ គឺ បុគ្គលញុំាងប្រយោគដែលចូលទៅកាត់នូវជីវិតិន្ទ្រិយចេញឱ្យតាំងឡើងដោយចេតនាណា ចេតនានោះ ឈ្មោះថា វធកចេតនា លោកហៅថា បាណាតិបាត (ចេតនាធម៌ជាហេតុបំផ្លាញជីវិតសត្វដែលមានជីវិត) ។ បុគ្គលដែលប្រកបព្រមដោយចេតនាដូចពោលហើយ គប្បីឃើញថា អ្នកបំផ្លាញសត្វមានជីវិត ។

## ប្រយោគនៃការសម្លាប់ ៦ យ៉ាង

ដែលឈ្មោះថា ប្រយោគនៃបាណាតិបាតនោះ បានដល់ ប្រយោគនៃបាណាតិបាត ៦ យ៉ាង គឺ សាហត្ថិកប្រយោគ ១ អាណត្តិកប្រយោគ ១ និស្សគ្គិយប្រយោគ ១ ថាវរប្រយោគ ១ វិជ្ជាមយប្រយោគ ១ ឥទ្ធិមយប្រយោគ ១ ។

បណ្តាប្រយោគទាំងនោះ ការប្រហារដោយកាយ ឬរបស់ដែលជាប់ដោយកាយ នៃបុគ្គលដែលសម្លាប់ឱ្យស្លាប់ដោយដៃខ្លួនឯង ឈ្មោះថា សាហត្ថិកប្រយោគ ។ ការបង្គាប់បញ្ជាថា "លោកចូរចាក់ឬប្រហារ

ឱ្យស្លាប់ដោយវិធីយ៉ាងនេះ” របស់បុគ្គលដែលប្រើអ្នកដទៃ ឈ្មោះថា អាណត្តិកប្រយោគ ។ ការគ្រវែងគ្រឿងប្រហារមានកូនសរ លំពែងយន្ត និងដុំថ្មជាដើមទៅ ដោយកាយ ឬរបស់ដែលជាប់ដោយកាយនៃបុគ្គលដែលបំណងនឹងសម្លាប់បុគ្គលដែលនៅក្នុងទីឆ្ងាយ ឈ្មោះថា និស្សគ្គិយប្រយោគ ។ ការជីករណ្ដៅដាក់អន្ទាក់ ដាក់(គ្រឿងប្រហារ)ទុកជិត និងការដាក់ថ្នាំ(ពិស) នៃបុគ្គលដែលបំណងនឹងសម្លាប់ដោយគ្រឿងដៃដែលមិនឃ្លាតចាកទី ឈ្មោះថា ថាវរប្រយោគ ។ ប្រយោគសូម្បីទាំង ៤ នោះនឹងមានច្បាស់ដោយពិស្ដារក្នុងអដ្ឋកថានៃបាលីខាងមុខនុ៎ះឯង ។ ចំណែកវិជ្ជាមយប្រយោគ និងឥទ្ធិមយប្រយោគ មិនបានមកក្នុងបាលី ។ គប្បីជ្រាបប្រយោគទាំង ២ នោះយ៉ាងនេះ ។

ក៏ដោយសង្ខេប ការរាយមន្តដើម្បីនឹងឱ្យគេស្លាប់ ឈ្មោះថា វិជ្ជាមយប្រយោគ ។ តែក្នុងអដ្ឋកថាទាំងឡាយ លោកសម្ដែងវិជ្ជាមយប្រយោគទុកយ៉ាងនេះថា វិជ្ជាមយប្រយោគដូចម្ដេច ? ពួកគ្រូអាថ៌ន រមែងប្រកបអាថ៌ន កាលក្រុងត្រូវលោមព័ទ្ធឬកាលសង្គ្រាមចូលប្រកៀកគ្នា រមែងបង្កចង្រៃ ឧបទ្រព រោគ និងជម្ងឺគ្រុនក្ដៅ ឱ្យកើតឡើងក្នុងពួកបច្ចាមិត្តដែលជាសត្រូវ រមែងធ្វើឱ្យជារោគចុកសៀត ឱ្យជារោគក្អួតចង្អោរ ដើម្បីនឹងការពារ ។ ពួកគ្រូអាថ៌ន រមែងប្រកប

អាថ៌នយ៉ាងនេះពួកទ្រទ្រង់វិជ្ជាគុណ វាយវេទហើយ កាលក្រុងត្រូវលោមព័ទ្ធឬ ។ល ។ រមែងធ្វើឱ្យជារោគក្អួតចង្អោរ ដូច្នេះហើយ ពោលរឿងជាច្រើនរបស់មនុស្សទាំងឡាយដែលត្រូវពួកគ្រូអាថ៌ន និងពួកទ្រង់វិជ្ជាគុណសម្លាប់ និងមានប្រយោជន៍អ្វីដោយរឿងទាំងនោះ ក៏លក្ខណៈក្នុងវិជ្ជាមយប្រយោគនេះ មានដូច្នេះ ៖

គឺ ការវាយមន្តដើម្បីនឹងឱ្យគេស្លាប់ឈ្មោះថា វិជ្ជាមយប្រយោគ ។ ការប្រកបឫទ្ធិដែលកើតពីផលនៃកម្ម ឈ្មោះថាឥទ្ធិមយប្រយោគ ។ ពិតមែន ដែលឈ្មោះថា ឫទ្ធិដែលកើតពីផលនៃកម្មនេះ មានច្រើនយ៉ាងមានជាដើមថា ឫទ្ធិនាគរបស់ពួកនាគ ឫទ្ធិសុបណ្ណរបស់ពួកសុបណ្ណ ឫទ្ធិយក្ខរបស់ពួកយក្ខ ទេវឫទ្ធិរបស់ពួកទេវតា រាជឫទ្ធិរបស់ពួកព្រះរាជា ។ បណ្តាឫទ្ធិនាគ ជាដើមនោះ គប្បីជ្រាបឫទ្ធិនាគរបស់ពួកនាគ ដែលមានពិសក្នុងខណៈឃើញ ចិកខាំនិងពាល់ត្រូវ ខណៈធ្វើការបៀតបៀនសត្វដទៃ ព្រោះឃើញ ចិកខាំពាល់ត្រូវគប្បីជ្រាបឫទ្ធិសុបណ្ណរបស់ពួកសុបណ្ណ ក្នុងការទាញនាគវែងប្រមាណ ១៣២ ព្យាម ឡើងមកពីមហាសមុទ្រ ។ ចំណែក ពួកយក្ខកាលមកមិនប្រាកដ កាលប្រហារក៏មិនប្រាកដ, តែសត្វដែលពួកយក្ខទាំងនោះប្រហារហើយ រមែងស្លាប់ក្នុងទីនោះឯង គប្បីជ្រាបឫទ្ធិយក្ខរបស់ពួកយក្សក្នុងហេតុយ៉ាងនោះ, គប្បី

ជ្រាបឫទ្ធិក្នុងការស្លាប់របស់ពួកកុម្ភណ្ឌ ដែលស្តេចវេស្សវ័ណសម្លឹងមើលដោយនយនាវុធ ក្នុងកាលមុន តែកាលជាព្រះសោតាបន្ន និងព្រោះឥទ្ធានុភាពរបស់ខ្លួន ៗ នៃពួកទេវតាពួកដទៃ ។ គប្បីជ្រាបរាជ ឫទ្ធិព្រោះការហោះទៅបាន ក្នុងអាកាសជាដើមរបស់ស្តេចចក្រពត្តិព្រមទាំងបរិស័ទ ព្រោះការផ្សាយព្រះរាជអំណាចទៅជាដើម ក្នុងទីមួយយោជន៍ទាំងខាងក្រោម និងខាងលើរបស់ព្រះបាទអសោក និងព្រោះការសម្លាប់នូវកុដុម្ពិក៍ឈ្មោះថា ចូឡសុមនៈដោយការគោះចង្កូមនៃស្តេចនរសីហឡព្រះនាមថា បិតុរាជ ដូច្នេះឯង ។

ចំណែកអាចារ្យពួកខ្លះ សម្តែងព្រះសូត្រទាំងឡាយជាដើមថា "ម្នាលភិក្ខុទាំងឡាយ រឿងដទៃនៅមានទៀត សមណៈឬព្រាហ្មណ៍ អ្នកមានឫទ្ធិ ដល់ភាពជាអ្នកមានសេចក្តីជំនាញនៃចិត្ត រមែងជាអ្នកសម្លឹងមើលទារកដែលនៅក្នុងផ្ទៃរបស់ស្រីដទៃដោយចិត្តដ៏លាមកថា ធ្វើដូចម្តេចហ្ន៎ ស្រីនេះមិនគប្បីប្រសូតទារកដែលនៅក្នុងផ្ទៃនោះដោយសេចក្តីសួស្តី ម្នាលភិក្ខុទាំងឡាយ សូម្បីយ៉ាងនេះ ក៏ជាការបៀតបៀនសត្វដែលនៅក្នុងគភ៌ ដូច្នេះ ហើយពោលដល់កម្ម គឺ ការបៀតបៀនសត្វដទៃសូម្បីដោយភាវនាមយឫទ្ធិ, និងប្រាថ្នាសេចក្តីវិនាសទៅនៃឫទ្ធិ ព្រមទាំងការបៀតបៀនសត្វដទៃដូចការបែកនៃឆ្នាំងទឹក ដែលគេបោះឡើងទៅលើ

ផ្ទះដែលត្រូវភ្លើងឆេះដូច្នោះ"[១] ។ ពាក្យដែលពោលមកនោះ ត្រឹមតែជាសេចក្ដីប្រាថ្នារបស់កេចិអាចារ្យទាំងនោះប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ? ព្រោះមិនសមដោយកុសលត្តិកៈ វេទនត្តិកៈ វិតក្កត្តិកៈ និងបរិត្តត្តិកៈ, សេចក្ដីនេះតើយ៉ាងណា ? ក៏ឈ្មោះថា ភាវនាមយឫទ្ធិនេះ ក្នុងកុសលត្តិកៈ ជាកុសលផង ជាអព្យាក្រឹតផង, បាណាតិបាតជាអកុសល; ក្នុងវេទនត្តិកៈ សម្បយុត្តដោយអទុក្ខមសុខៈ, បាណាតិបាតសម្បយុត្តដោយទុក្ខ ក្នុងវិតក្កត្តិកៈ ជាអវិតក្កាវិចារៈ, បាណាតិបាត ជាសវិតក្កសវិចារៈ, ក្នុងបរិត្តត្តិកៈ ជាមហគ្គតៈ, បាណាតិបាត ជាបរិត្តៈ ។

## អធិប្បាយវត្ថុដែលជាគ្រឿងប្រហារ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សត្ថហារកំ វាស្ស បរិយេសេយ្យ : ទោះបីស្វែងរកគ្រឿងសាស្ត្រាវុធ (ឱ្យគេសម្លាប់)រាងកាយមនុស្សនោះក្ដី នេះ ដូចតទៅនេះ ៖

គ្រឿងប្រហារណា រមែងនាំចេញ; ហេតុនោះ គ្រឿងប្រហារនោះ ឈ្មោះថា វត្ថុនាំចេញ ។ សួរថា នាំចេញនូវអ្វី ? ឆ្លើយថា នាំចេញនូវជីវិត ។ម្យ៉ាងទៀត គ្រឿងប្រហារណា ដែលបុគ្គលគប្បីនាំទៅ; ហេតុ

១. អដ្ឋកថា ចរិយាបិដក ហត្ថិនាគវគ្គ មាតង្គចរិយាវណ្ណនា; ធម្មសង្គណី-អដ្ឋកថា ។

នោះ គ្រឿងប្រហារនោះ ឈ្មោះថា វត្ថុដែលបុគ្គលគប្បីនាំទៅ ។ អធិប្បាយថា គ្រឿងប្រហារដែលបុគ្គលគប្បីចាត់ត្រៀមទុក សស្ត្រានោះផង ជាវត្ថុនាំចេញផង; ហេតុនោះ ឈ្មោះថា សស្ត្រាដែលនាំចេញ ។

បទថា **អស្ស :** នោះ បានដល់ កាយរបស់មនុស្ស ។

បទថា **បរិយេសេយ្យ : ទោះបីស្វែងរក** មានសេចក្តីថា គប្បីធ្វើដោយប្រការដែលខ្លួននឹងបាន, អធិប្បាយថា គប្បីចាត់ត្រៀមទុក ។ ដោយពាក្យថា **សត្ថហារកំ វាស្ស បរិយេសេយ្យ : ទោះបីស្វែងរកគ្រឿងសាស្ត្រាវុធ (ឱ្យគេសម្លាប់)របស់កាយមនុស្សនោះក្តី** នេះ ព្រះមានព្រះភាគទ្រង់សម្តែងជាវប្រយោគ ។ កាលនឹងកាន់យកសេចក្តីសូម្បីដោយប្រការដទៃក្រៅពីនេះហើយ ភិក្ខុនឹងគប្បីត្រូវអាបត្តិបារាជិកដោយហេតុត្រឹមតែថា សស្ត្រាដែលខ្លួនស្វែងរកមកហើយប៉ុណ្ណោះ ។ តាមការពិត សេចក្តីនោះមិនត្រូវ តែក្នុងព្រះបាលី ព្រះឧបាលីថេរៈ មិនអើពើព្យញ្ជនៈទាំងពួង ដើម្បីនឹងសម្តែងចំពោះសស្ត្រាដែលសង្គ្រោះចូលក្នុងថាវរប្រយោគ ក្នុងពាក្យថា **សត្ថហារកំ : គ្រឿងសាស្ត្រាវុធ** នេះប៉ុណ្ណោះ ទើបពោលទុកក្នុងបទភាជនៈថា **អសឹ វា សត្តឹ វា ភេណ្ឌឹ វា វិសំ វា រជ្ជុំ វា : ដាវក្តី លំពែងក្តី ច្បូកក្តី ឈើស្រួចក្តី អន្ទង់ក្តី ថ្មក្តី កាំបិតក្តី ថ្នាំពិសក្តី ខ្សែក្តី** ដូច្នេះ បណ្តាគ្រឿងប្រហារទាំងនោះ គ្រឿង

ប្រហារដែលមានមុខប្រភេទណាមួយ ដែលក្រៅពីបានពោលហើយ គប្បីជ្រាបថា ជាសស្ត្រា ។ និងគប្បីជ្រាបថា សង្គ្រោះឈើអន្ទង ដុំថ្ម ថ្នាំពិស និងខ្សែ ចូលជាសស្ត្រាផង ព្រោះជាគ្រឿងបំផ្លាញជីវិតឱ្យវិនាស ។

[១៨២] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា មរណវណ្ណំ វា : ពណ៌នាគុណនៃសេចក្តីស្លាប់ក្តី នេះ ដូចតទៅនេះ ៖

ភិក្ខុសូម្បីសម្តែងទោសក្នុងការរស់នៅ ដោយន័យមានពាក្យថា "នឹងមានប្រយោជន៍អ្វី ដោយការរស់នៅដ៏អាក្រក់លាមកដូច្នេះរបស់លោក ដែលមិនបានដើម្បីបរិភោគភោជនដ៏ល្អ" ដូច្នេះជាដើម សូម្បីពោលសរសើរគុណនៃសេចក្តីស្លាប់ ដោយន័យមានពាក្យថា "ឧបាសក លោកជាអ្នកធ្វើកម្មល្អទុកហើយ ។ល។ បាបលោកមិនបានធ្វើឡើយ សេចក្តីស្លាប់របស់លោកល្អជាងការរស់នៅ លោកធ្វើកាលកិរិយាចាកអត្តភាពនេះហើយ ។ល។ នឹងញ៉ាំងខ្លួនឱ្យប្រព្រឹត្តទៅ គឺនឹងមាននាងអប្សរចោមរោម ដល់សេចក្តីសុខ នៅក្នុងសួននន្ទនវ័ន" ដូច្នេះជាដើម ឈ្មោះថាពណ៌នាគុណនៃសេចក្តីស្លាប់តែម្តង ។ ដូច្នោះ ព្រះឧបាលីថេរៈ ទើបពោលបទភាជនៈចែកចេញជា ២ ចំណែកថា សម្តែងទោសក្នុងកិរិយារស់នៅ ១ ពោលសរសើរគុណក្នុងការស្លាប់ ១ ។

[១៨៣] ពាក្យថា មរណាយ វា សមាទបេយ្យ : និយាយ

ណែនាំដើម្បីសេចក្ដីស្លាប់ក្ដី មានសេចក្ដីថា គប្បីណែនាំឱ្យកាន់យកឧបាយ ដើម្បីប្រយោជន៍ដល់សេចក្ដីស្លាប់ ។ ចំណែកពាក្យថា លោកចូរលោតចុះក្នុងអណ្ដូងឱ្យស្លាប់ ឬថា ចូរលោតទម្លាក់ក្នុងជ្រោះឱ្យស្លាប់ជាដើម សូម្បីព្រះឧបាលីថេរៈ មិនបានពោលទុកក្នុងពាក្យមានជាដើមថា សត្ថំ វា អាហារ : អ្នកចូរនាំគ្រឿងសាស្ត្រមកក្ដី ដូច្នេះ ទាំងអស់ ក៏គប្បីជ្រាបថា លោកពោលទុកហើយដោយសេចក្ដីនោះឯង ព្រោះជាពាក្យដែលមានន័យដូចពោលហើយខាងមុខ ។ ពិតមែន អ្នកណា ៗ ក៏មិនអាចពោលពាក្យបបួលគ្រប់យ៉ាងដោយសព្វគ្រប់បាន ។

[១៨៤] បទថា ឥតិ ចិត្តមនោ : មានចិត្តគិតដូច្នេះ មានសេចក្ដីថា លោកមានចិត្តយ៉ាងនេះ មានបំណងយ៉ាងនេះ, អធិប្បាយថា លោកមានចិត្តប៉ងនឹងសម្លាប់ មានចិត្តបំណងសម្លាប់ ដូចពោលហើយក្នុងពាក្យនេះថា អ្នកស្លាប់ទៅប្រសើរជាងកិរិយារស់នៅ ក៏ព្រោះក្នុងបទថា ចិត្តមនោ នេះ មនសព្ទលោកពោលហើយ ដើម្បីសម្ដែងសេចក្ដីនៃចិត្តសព្ទ តែចិត្តនិងមនោ សូម្បីទាំង ២ នេះ ដោយអត្ថ ក៏ដូចគ្នាទុំះឯង; ព្រោះដូច្នោះ ដើម្បីសម្ដែងការមិនផ្សេងគ្នា ដោយអត្ថនៃចិត្តនិងមនោនោះ ទើបព្រះឧបាលីថេរៈ ពោលទុកថា "ធម៌ជាតណា ជាចិត្ត ធម្មជាតនោះជាមនោ, ធម្មជាតណាជាមនោ ធម្មជាតនោះ គឺចិត្ត" ។ ចំណែក

សេចក្តីមិនទាន់បានពោលមុន សូម្បីព្រោះដក ឥតិ ស័ព្ទចេញ ។ ឥតិ ស័ព្ទ គប្បីនាំមកដោយអំណាចជាប្រធានក្នុងបទថា ចិត្តសង្កប្បោ នេះ ។

ពិតមែន បទថា ចិត្តសង្កប្បោ : មានសេចក្តីត្រិះរិះក្នុងចិត្ត ដូច្នេះ នេះ សូម្បីមិនបានត្រាស់យ៉ាងនេះថា ឥតិ ចិត្តសង្កប្បោ : មានសេចក្តីត្រិះរិះក្នុងចិត្តដូច្នេះ ក៏គប្បីជ្រាបថា ជាការត្រាស់ហើយដោយភាពជាប្រធាននុ៎ះឯង ។ ពិតណាស់ កាលលោកនឹងសម្តែងចំពោះសេចក្តីនោះនៃបទថា ចិត្តសង្កប្បោ នោះ ទើបពោលថា ពាក្យថា មរណសញ្ញី : មានសេចក្តីសម្គាល់ក្នុងការស្លាប់ ជាដើម ។ តែពាក្យថា សង្កប្បោ នេះ ក្នុងបទថា ចិត្តសង្កប្បោ នោះ មិនបានជាឈ្មោះរបស់វិតក្កៈ តាមការពិត ពាក្យនោះជាពាក្យហៅកម្មត្រឹមតែការចាត់ចែង, និងការចាត់ចែងនោះរមែងដល់សេចក្តីសង្គ្រោះដោយអត្ថន័យ ការតាំងចិត្ត និងសេចក្តីប្រាថ្នា ក្នុងអត្ថនេះ; ព្រោះហេតុនោះ អ្នកសិក្សាគប្បីឃើញសេចក្តីយ៉ាងនេះថា ឈ្មោះថា អ្នកមានចិត្តសង្កប្បៈ ព្រោះអត្ថវិគ្រោះថា លោកមានសេចក្តីចាត់ចែងប្លែក គឺ មានប្រការផ្សេង ៗ ។ ពិតមែន សូម្បីបទភាជនៈនៃបទថា ចិត្តសង្កប្បោ នោះ ព្រះឧបាលីថេរៈ ក៏ពោលដោយអំណាចនៃអត្ថន័យ សេចក្តីតាំងចិត្ត និងសេចក្តីប្រាថ្នា ។ តែក្នុងអធិការនេះ វិតក្កៈ គប្បីជ្រាបថា ជាសេចក្តីប្រាថ្នា ។

ពីរបទថា ឧច្ចាវចេហិ អាការេហិ : ដោយអាការទាំងឡាយខ្ពស់និងទាប មានសេចក្ដីថា ដោយឧបាយទាំងឡាយដែលធំ និងធំតាមលំដាប់ បណ្ដាការពណ៌នាគុណសេចក្ដីស្លាប់ និងការបបួលក្នុងសេចក្ដីស្លាប់ទាំងនោះ ក្នុងការពណ៌នាគុណសេចក្ដីស្លាប់មុន អវចាការតា : ដោយអាការទាប ខ្ពស់ គប្បីជ្រាបដោយអំណាចការសម្ដែងទោសក្នុងការរស់នៅ, ឧច្ចាការតា : ដោយអាការខ្ពស់ គប្បីជ្រាបដោយអំណាចការសរសើរគុណនៃសេចក្ដីស្លាប់ ។ ចំណែកក្នុងការបបួល ឧច្ចាការតា : ដោយអាការខ្ពស់ គប្បីជ្រាបដោយអំណាចការបបួលក្នុងសេចក្ដីស្លាប់ព្រោះហេតុទាំងឡាយ មានកាប់ដៃជាល់និងអុកជន្លង់ជាដើម, អវចាការតា : ដោយអាការទាប គប្បីជ្រាបដោយអំណាចការដាក់ថ្នាំពិសចូលក្នុងគ្រួចកដៃ របស់បុគ្គលដែលបរិភោគរួមគ្នា ហើយបបួលក្នុងសេចក្ដីស្លាប់ជាដើម ។

[១៨៥] ក្នុងពាក្យថា សោព្ភេ វា នរកេ វា បបាតេ វា : បឹងក្ដី អណ្ដូងក្ដី ជ្រោះក្ដី នេះមានវិនិច្ឆ័យដូច្នេះ ៖

អណ្ដូងដែលជ្រៅ ដែលមានមាត់ប្រាំងចោតដោយជុំវិញ ឈ្មោះថា សោព្ភៈ : បឹង ។ ដែលឈ្មោះថា នរក : ស្នាមប្រេះ បានដល់ក្រហែងធំដែលកើតឯងដោយពិត ក្នុងកាលផែនដីបែកក្រហែងក្នុងទីនោះ ៗ

ជាទីដែលដំរីធ្លាក់ទៅខ្លះ ពួកចោរពួននៅខ្លះ ។ ដែលឈ្មោះថា **បបាតះ :** ជ្រោះ បានដល់ ប្រទេសដែលដាច់ផែបតែម្ខាង ក្នុងចន្លោះភ្នំ ឬក្នុងចន្លោះលើគោក ( ក្រហូងផែនដី ) ។

[ ១៨៦ ] ពីរបទថា **បុរិមេ ឧទ្ធាធាយ : មានសេចក្ដីអធិប្បាយដូចខាងដើម** សេចក្ដីថា ទ្រង់ធៀបបុគ្គលដែលសេពមេថុនធម្ម និងបុគ្គលដែលកាន់យកវត្ថុដែលម្ចាស់របស់មិនបានឱ្យ ហើយត្រូវអាបត្តិបារាជិក ។ ពាក្យដែលនៅសល់ ប្រាកដច្បាស់ហើយនោះឯង ព្រោះមានន័យដូចពោលហើយក្នុងសេចក្ដីខាងដើម និងព្រោះមានសេចក្ដីងាយយល់ ដូច្នេះឯង ។

## អធិប្បាយមាតិកាក្នុងបទភាជនី

[ ១៨៧ ] ព្រះឧបាលីថេរៈ គ្រាចែកសិក្ខាបទដែលព្រះមានព្រះភាគទ្រង់ឧទ្ទេសទុកហើយតាមលំដាប់បទយ៉ាងនេះ ឥឡូវនេះ កាលនឹងតាំងមាតិកាសម្ដែងមនុស្សវិគ្គហបារាជិកដោយពិស្ដារទុក ដោយន័យមានជាដើមថា **សាមំ អធិដ្ឋាយ : ភិក្ខុស្ថិតនៅក្នុងទីជិត ដោយខ្លួនឯង** ដូច្នេះទៀត ដើម្បីឱ្យភិក្ខុទាំងឡាយកាន់យកន័យដោយអាការគ្រប់យ៉ាង និងដើម្បីការពារឱកាសរបស់បាបបុគ្គលទាំងឡាយក្នុងអនាគត ព្រោះហេតុថា

មនុស្សវិគ្គហបារាជិក ព្រះមានព្រះភាគទ្រង់សម្តែងក្នុងបទភាជនីក្នុងកាលមុន ដោយសង្ខេបប៉ុណ្ណោះ ។

[១៨៨] ទ្រង់មិនបានលើកអាបត្តិឡើងពិន័យហើយដាក់បែបផែនទុកដោយពិស្តារ និងភិក្ខុទាំងឡាយ មិនអាចនឹងកាន់យកន័យបានដោយអាការទាំងពួង ក្នុងសេចក្តីដែលទ្រង់សម្តែងទុកដោយសង្ខេប ទាំងសូម្បីបាបបុគ្គលទាំងឡាយ ក្នុងអនាគត ក៏មានឱកាស ទើបពោលពាក្យថា **សាមន្តិ សយំ ហនតិ : ពាក្យថា ដោយខ្លួនឯង គឺ ភិក្ខុសម្លាប់(គេ) ដោយខ្លួនឯង** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ មានពាក្យសម្រាប់វិនិច្ឆ័យព្រមដោយការពណ៌នាបទដែលមិនងាយ ដូចតទៅនេះ ៖

បទថា **កាយេន : ដោយកាយ** សេចក្តីថា ដោយដៃ ជើង ក្តាប់ដៃ ឬជង្គង់ ឬដោយអវយវៈតូចធំ យ៉ាងណាមួយ ។

បទថា **កាយបដិពទ្ធេន : ដោយវត្ថុដែលជាប់នឹងកាយ** សេចក្តីថា ដោយគ្រឿងប្រហារ មានដាវជាដើមដែលមិនផុតអំពីកាយ ។

បទថា **និស្សគ្គិយេន : ដោយគ្រឿងប្រយោល** សេចក្តីថា ដោយគ្រឿងប្រហារមានកូនសរនិងលំពែងជាដើម ដែលផុតពីកាយ ឬពីរបស់ដែលជាប់ដោយកាយ ដោយលំដាប់នៃពាក្យត្រឹមតែប៉ុណ្ណេះ ប្រយោគទាំង ២ គឺ សាហត្ថិកប្រយោគ និងនិស្សគ្គិយប្រយោគជាការ

លោកពោលហើយ ។ ក្នុងប្រយោគទាំង ២ នោះ ប្រយោគនីមួយ ៗ មាន ២ យ៉ាង ដោយចែកជាប្រយោគចំពោះ និងមិនចំពោះ ។

បណ្ដាប្រយោគចំពោះនិងមិនចំពោះនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងប្រយោគចំពោះ ដូចតទៅនេះ ៖

ភិក្ខុប្រហារចំពោះអ្នកណា ដោយការស្លាប់របស់អ្នកនោះឯង ភិក្ខុនោះ រមែងត្រូវជាប់ដោយកម្ម ។ ក្នុងប្រយោគដែលមិនចំពោះយ៉ាងនេះថា អ្នកណាម្នាក់ ចូរស្លាប់ ដូច្នេះ ដោយការស្លាប់របស់អ្នកណាម្នាក់ ព្រោះការប្រហារជាបច្ច័យ ភិក្ខុ រមែងត្រូវជាប់ដោយកម្ម ។ ទាំង ២ ប្រយោគអ្នកត្រូវប្រហារនឹងស្លាប់ក្នុងខណៈ ល្មមត្រូវប្រហារ ឬនឹងស្លាប់ក្នុងកាលជាខាងក្រោយដោយរោគនោះក៏ដោយ ភិក្ខុរមែងត្រូវ ជាប់ដោយកម្ម ក្នុងខណៈដែលអ្នកស្លាប់ត្រូវប្រហារនុ៎ះឯង ។ តែកាលភិក្ខុឱ្យប្រហារដោយសេចក្ដីប្រាថ្នាដើម្បីសេចក្ដីស្លាប់ កាលអ្នកត្រូវប្រហារមិនស្លាប់ដោយការប្រហារនោះ ទើបឱ្យការប្រហារដោយចិត្តដទៃតទៅ បើអ្នកត្រូវប្រហារស្លាប់ដោយការប្រហារគ្រាដំបូង សូម្បីក្នុងកាលជាខាងក្រោយ ភិក្ខុត្រូវជាប់ដោយកម្ម ក្នុងវេលាប្រហារគ្រាដំបូងប៉ុណ្ណោះ បើស្លាប់ដោយការប្រហារគ្រាទី ២ មិនមានបាណាតិបាត ។ សូម្បីកាលអ្នកត្រូវប្រហារស្លាប់ដោយការប្រហារទាំង ២ គ្រា ភិក្ខុក៏ត្រូវជាប់ដោយកម្ម

ពិត ដោយការប្រហារគ្រាដំបូងនុ៎ះឯង, កាលមិនស្លាប់ដោយការប្រហារទាំង ២ គ្រា ក៏មិនមានបាណាតិបាតដូចគ្នា ។ ក្នុងកាលដែលមនុស្សសូម្បីច្រើនឱ្យការប្រហារដល់បុគ្គលតែមួយ ក៏ន័យនេះ ដល់ក្នុងការដែលមនុស្សច្រើនទាក់ឱ្យការប្រហារសូម្បីនោះ អ្នកត្រូវប្រហារស្លាប់ដោយការប្រហាររបស់អ្នកណា កម្មព័ន្ធ រមែងមានដល់អ្នកនោះប៉ុណ្ណោះ ដូច្នេះឯង ។

## អនន្តរិយកម្ម និងបារាជិក

មួយទៀត ក្នុងអធិការនៃតតិយបារាជិកនេះ ដើម្បីសេចក្ដីឆ្លាតក្នុងកម្មនិងអាបត្តិគប្បីជ្រាបសូម្បីពួក ៤ ពោលអំពីរឿងពពែ ។ ពិតមែនភិក្ខុណា ត្រូវមើលពពែដែលដេកនៅក្នុងទីកន្លែងមួយ ដោយគិតក្នុងចិត្តថា "យើងនឹងមកសម្លាប់វាក្នុងវេលាយប់" ។ ឯមាតាឬបិតារបស់ភិក្ខុនោះ ឬព្រះអរហន្តដណ្ដប់សំពត់កាសាវៈពណ៌លឿងមក ហើយដេកនៅក្នុងឱកាសដែលពពែដេក, លោកមកពេលយប់ ធ្វើទុកក្នុងចិត្តថា "យើងនឹងសម្លាប់ពពែឱ្យស្លាប់" ដូច្នេះ ទើបសម្លាប់មាតាឬបិតាឬព្រះអរហន្តស្លាប់ ។ ព្រោះមានចេតនាថា "យើងនឹងសម្លាប់វត្ថុនេះឱ្យស្លាប់" លោកទើបជាអ្នកសម្លាប់ផង ត្រូវអនន្តរិយកម្មផង ត្រូវបារាជិកផង ។ មាន

មនុស្សអាគន្តុកៈដទៃណាមួយដេក, លោកធ្វើទុកក្នុងចិត្តថា "យើងនឹងសម្លាប់ពពែឱ្យស្លាប់" ទើបសម្លាប់មនុស្សអាគន្តុកៈនោះស្លាប់ ចាត់ជាឃាតករផង ត្រូវបារាជិកផង តែមិនត្រូវអនន្តរិយកម្ម ។ មានយក្ខឬប្រេតដេក, លោកនោះធ្វើទុកក្នុងចិត្តថា "យើងនឹងសម្លាប់ពពែឱ្យស្លាប់" ទើបសម្លាប់យក្ខ ឬប្រេតនោះស្លាប់, ត្រឹមតែជាឃាតករ មិនត្រូវអនន្តរិយកម្មនិងមិនត្រូវបារាជិកទេ តែត្រូវថុល្លច្ច័យ ។ មិនមានអ្នកណា ៗ ដទៃមកដេក មានតែពពែប៉ុណ្ណោះ ។ លោកសម្លាប់ពពែនោះស្លាប់ ជាឃាតករផង ត្រូវបាចិត្តិយផង ។ ភិក្ខុណាធ្វើទុកក្នុងចិត្តថា "យើងនឹងសម្លាប់មាតាបិតានិងព្រះអរហន្ត ណាមួយឱ្យស្លាប់" ដូច្នេះហើយ ក៏សម្លាប់បណ្ដាលោកទាំងនោះឯង ណាមួយឱ្យស្លាប់ ភិក្ខុនោះជាឃាតករផង ត្រូវអនន្តរិយកម្មផង ត្រូវអាបត្តិបារាជិកផង ។ លោកធ្វើទុកក្នុងចិត្តថា "យើងនឹងសម្លាប់មាតាបិតា និងព្រះអរហន្តទាំងនោះឯងណាមួយឱ្យស្លាប់" ហើយក៏សម្លាប់អាគន្តុកៈដទៃស្លាប់ ឬសម្លាប់យក្ខប្រេត ឬពពែស្លាប់ ។ អ្នកសិក្សាគប្បីជ្រាប (អាបត្តិគឺ បារាជិក ថុល្លច្ច័យ និងបាចិត្តិយ) ដោយន័យដូចពោលហើយក្នុងសេចក្ដីខាងដើមនុ៎ះឯង ។ តែក្នុងវិស័យនៃការសម្លាប់សត្វមានអាគន្តុកៈជាដើមនេះ ចេតនារមែងជារបស់ទារុណនោះឯង ។

# ភិក្ខុសម្លាប់មាតាជាដើមមិនត្រូវអាបត្តិ

ក្នុងវិស័យនៃតតិយបារាជិកនេះ អ្នកសិក្សាគួរជ្រាបរឿងទាំងឡាយសូម្បីពួកជន់ទៃមានគំនរចំបើងជាដើម ។ ពិតមែន ភិក្ខុណា ធ្វើទុកក្នុងចិត្តថា យើងនឹងជូតជាវប្ញលំពែងដែលប្រឡាក់ឈាម ហើយស៊កចូលទៅក្នុងគំនរចំបើង សម្លាប់មាតាក្តី បិតាក្តី ព្រះអរហន្តក្តី មនុស្សអាគន្តុកៈក្តី យក្ខក្តី ប្រេតក្តី សត្វតិរច្ឆានក្តី ដែលដេកនៅក្នុងគំនរចំបើងនោះស្លាប់ ភិក្ខុនោះ ដោយអំណាចនៃវោហារ ហៅថា ឃាតករបាន តែព្រោះមិនមានវធកចេតនា លោកទើបមិនត្រូវកម្ម ទាំងមិនត្រូវអាបត្តិ ។ ចំណែកភិក្ខុណា កាលកំពុងស៊ក (ជាវប្ញលំពែងនោះ) ចូលទៅដោយអាការយ៉ាងនោះ កំណត់បានថា ប៉ះត្រូវរាងកាយ ក៏ស៊កចូលទៅសម្លាប់ឱ្យស្លាប់ដោយគិតថា "មុខជាមានសត្វនៅខាងក្នុងចូរស្លាប់ទៅចុះ" ។ កម្មព័ន្ធ (ការចងព័ន្ធដោយកម្ម) និងអាបត្តិរបស់លោកនោះ គប្បីជ្រាបដោយសមគួរដល់រឿងទាំងនោះ ។ កាលភិក្ខុស៊ក (ជាវប្ញលំពែងនោះ) ចូលទៅដើម្បីរក្សាទុកក្នុងគំនរចំបើងនោះក្តី បោះចូលទៅត្រង់គុម្ពឈើក្នុងព្រៃជាដើមក្តី ក៏ន័យនេះ ។

## ភិក្ខុសម្លាប់បិតាជាបារាជិក និងជាបិតុឃាត

ភិក្ខុណា គិតថា "យើងនឹងសម្លាប់ចោរឱ្យស្លាប់" ហើយក៏សម្លាប់បិតាដែលកំពុងដើរទៅដោយភេទដូចចោរស្លាប់វិញ ភិក្ខុនោះ រមែងត្រូវអនន្តរិយកម្មផង ជា អាបត្តិបារាជិកផង ។

ចំណែកភិក្ខុណា ឃើញខ្មាំងដទៃនិងបិតាដែលកំពុងធ្វើការច្បាំងគ្នានៅក្នុងសេនាខាងសត្រូវ ទើបបាញ់កូនសរទៅតម្រង់អ្នកច្បាំង ដោយគិតក្នុងចិត្តថា "កូនសរចាក់ទម្លុះខ្មាំងនោះហើយនឹងចាក់ទម្លុះបិតារបស់យើង" ។ ភិក្ខុនោះ រមែងឈ្មោះថា ជាបិតុឃាតក(អ្នកសម្លាប់បិតា) ក្នុងកាលកូនសរត្រង់តម្រង់ទៅតាមសេចក្តីប្រាថ្នា ។ លោកគិតនៅក្នុងចិត្តថា "កាលខ្មាំងត្រូវកូនសរចាក់ហើយ បិតារបស់យើងក៏នឹងគេចចៀសទៅ" ដូច្នេះហើយទើបបាញ់កូនសរទៅ កូនសរមិនរត់ តម្រង់ទៅតាមសេចក្តីប្រាថ្នាត្រឡប់ធ្វើឱ្យបិតាស្លាប់វិញ លោករូបនោះ លោកហៅ បិតុឃាតក (អ្នកសម្លាប់បិតា) ដោយអំណាចនៃវោហារ តែមិនជាអនន្តរិយកម្ម ដោយប្រការដូច្នេះឯង ។

បទថា **អធិដ្ឋហិត្វា : ឋិតនៅក្នុងទីជិត** បានដល់ ឈរក្នុងទីជិត ។

បទថា **អាណាបេតិ : បង្គាប់** បានដល់ ភិក្ខុអ្នកបង្គាប់ បង្គាប់ចំពោះបុគ្គលឬមិនចំពោះបុគ្គល ។ បណ្តាការបង្គាប់ចំពោះបុគ្គលឬមិនចំពោះបុគ្គលនោះ គ្រាពួកសេនាខាងសត្រូវ ប្រាកដឡើងចំពោះហើយ

កាលភិក្ខុអ្នកបង្គាប់ បង្គាប់មិនចំពោះបុគ្គលឡើយថា "លោកចូរចាក់យ៉ាងនេះ ចូរប្រហារយ៉ាងនេះ ចូរសម្លាប់យ៉ាងនេះ" ជាបាណាតិបាតដល់លោកទាំង ២ រូប មានប្រមាណតាមចំនួនសត្រូវដែលភិក្ខុអ្នកទទួលបង្គាប់សម្លាប់ ។ បណ្តាភិក្ខុអ្នកបង្គាប់និងអ្នកទទួលបង្គាប់នោះ បើភិក្ខុអ្នកបង្គាប់មានមាតានិងបិតានៅផង ។ លោកអ្នកបង្គាប់ រមែងត្រូវអនន្តរិយកម្មផង, បើមានព្រះអរហន្តនៅផង, លោកសូម្បីទាំង ២ រូប រមែងត្រូវអនន្តរិយកម្មផង ។ បើភិក្ខុអ្នកទទួលបង្គាប់ប៉ុណ្ណោះមានមាតានិងបិតានៅ (ក្នុងសមរភូមិប្រយុទ្ធ) ។ ភិក្ខុអ្នកទទួលបង្គាប់ប៉ុណ្ណោះឯង រមែងត្រូវអនន្តរិយកម្ម តែកាលភិក្ខុអ្នកបង្គាប់ បង្គាប់ចំពោះបុគ្គលថា "លោកចូរចាក់ ចូរប្រហារចូរសម្លាប់ខ្មាំង, ខ្មាំងនោះ ជាមនុស្សខ្ពស់ទាប មានអាវពណ៌ក្រហម មានអាវពណ៌ខៀវដែលអង្គុយនៅលើកឯដំរី (ឬ) អង្គុយនៅកណ្តាល (ខ្នងដំរី)", បើភិក្ខុអ្នកទទួលបង្គាប់នោះសម្លាប់មនុស្សខ្មាំងនោះឯង, ជាបាណាតិបាតសូម្បីទាំង ២ រូប, និងក្នុងរឿងនៃអនន្តរិយកម្ម រមែងត្រូវអនន្តរិយកម្មទាំង ២ រូប ។ បើភិក្ខុអ្នកទទួលបង្គាប់សម្លាប់អ្នកដទៃស្លាប់, បាណាតិបាត រមែងមិនមានដល់ភិក្ខុអ្នកបង្គាប់ ។ អាណត្តិកប្រយោគ ក៏លោកបានពោលទុកហើយ ដោយពាក្យថា អធិដ្ឋហិត្វា អាណាបេតិ ជាដើមនោះ ។

## ឋានៈ ៥ និង ៦ ព្រមទាំងអត្ថាធិប្បាយ

ក្នុងអាណត្តិកប្រយោគនោះ ៖

អ្នកពិចារណាដែលឆ្លាត គប្បីសាកសួរឋានៈ ៥ ប្រការ គឺ វត្ថុ កាល ឱកាស អាវុធ និងឥរិយាបថ ហើយគប្បីទ្រទ្រង់ទុកនូវអត្ថក្តី ។

ន័យមួយទៀត ហេតុធ្វើឱ្យការបង្គាប់ពិតប្រាកដ (សម្រេចបាន) មាន ៦ យ៉ាងនេះ គឺ វត្ថុ កាល ឱកាស អាវុធ ឥរិយាបថ និងកិរិយាពិសេស ។

បណ្តាឋានៈមានវត្ថុជាដើមនោះ ឋានៈថា វត្ថុ បានដល់ សត្វដែលនឹងគប្បីត្រូវសម្លាប់ឱ្យស្លាប់ ។

ឋានៈថា កាល បានដល់ កាលមានពេលព្រឹកនិងល្ងាចជាដើម និងការមានវ័យកម្លោះក្រមុំមានកម្លាំងខ្លាំងនិងមានសេចក្តីព្យាយាមជាដើម ។

ឋានៈថា ឱកាស បានដល់ ស្ថានដែលមានជាដើមយ៉ាងនេះ គឺ ស្រុក ព្រៃទ្វារផ្ទះ ត្រង់កណ្តាលផ្ទះ ថ្នល់ រថ ឬមកបែកជា ៣ ។

ឋានៈថា អាវុធ បានដល់ អាវុធមានជាដើមយ៉ាងនេះ គឺ ដាវ កូនសរ ឬលំពែង ។

ឋានៈថា ឥរិយាបថ បានដល់ ឥរិយាបថមានជាដើមយ៉ាងនេះ គឺ ការដើរឬអង្គុយរបស់អ្នកដែលនឹងត្រូវសម្លាប់ឱ្យស្លាប់ ។

ឋានៈថា កិរិយាពិសេស បានដល់ កិរិយាដែលធ្វើមានជាដើមយ៉ាង

នេះ គឺ ចាក់ កាត់ ទម្លាយ ពន្ទាត់ស្បែកសីសៈធ្វើឱ្យរលោងដូចស័ង្ខ[១] ។

## អធិប្បាយវត្ថុដែលត្រូវសម្លាប់

ក៏ប្រសិនបើថា ភិក្ខុអ្នកទទួលបង្គាប់ធ្វើឱ្យវត្ថុភ្លាត់ទៅ បែរទៅជាសម្លាប់អ្នកដទៃក្រៅពីបុគ្គលដែលអ្នកបង្គាប់ បង្គាប់ឱ្យសម្លាប់, ឬត្រូវបង្គាប់ថា លោកចូរប្រហារខាងមុខសម្លាប់ឱ្យស្លាប់ បែរទៅជាប្រហារខាងក្រោយ ឬខាង ៗ ឬ ត្រង់កន្លែងអវយវៈណាមួយឱ្យស្លាប់ទៅ, ការចងព័ន្ធមកកម្ម រមែងមិនមានដល់ភិក្ខុអ្នកបង្គាប់, ការចងព័ន្ធមកកម្ម រមែងមានដល់ភិក្ខុអ្នកទទួលបង្គាប់ប៉ុណ្ណោះ ។ម្យ៉ាងទៀត ភិក្ខុអ្នកទទួលបង្គាប់មិនធ្វើវត្ថុឱ្យភ្លាត់ទៅជាសម្លាប់អ្នកនោះស្លាប់តាមដែលបង្គាប់ទុក ។ ប្រការចងព័ន្ធមកកម្ម រមែងមានដល់លោកទាំង ២ រូប គឺ ដល់អ្នកបង្គាប់ក្នុងខណៈដែលបង្គាប់ អ្នកទទួលបង្គាប់ក្នុងខណៈដែលប្រហារ ។ ក៏ក្នុងរឿងវត្ថុនេះ សេចក្ដីប្លែកគ្នានៃកម្មនិងសេចក្ដីប្លែកគ្នានៃអាបត្តិ រមែងមានព្រោះសេចក្ដីប្លែកគ្នានៃវត្ថុ ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងខុសសង្កេត ក្នុងវត្ថុយ៉ាងនេះមុន ។

---

១. សារត្ថទីបនី. ត្រូវកាត់ស្បែកចញ្ចពីក្បាលកំណត់ត្រឹមគុម្ពត្រចៀកនិងរណ្ដៅក ហើយយកដុំ គ្រួសកោសខាត់លលាក្បាល ឱ្យមានពណ៌សដូចស័ង្ខ ។

## អធិប្បាយកាលដែលបង្គាប់ឱ្យធ្វើការសម្លាប់

ចំណែកក្នុងកាល មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណាបានទទួលពាក្យបង្គាប់ថា "លោកចូរសម្លាប់ឱ្យស្លាប់ក្នុងវេលាព្រឹក" មិនកំណត់ថា ថ្ងៃនេះ ឬស្អែកនេះ, ភិក្ខុទទួលបង្គាប់នោះសម្លាប់គេស្លាប់វេលាព្រឹក ក្នុងវេលាណាមួយ ការខុសសង្កេត រមែងមិនមាន ។ ចំណែកភិក្ខុណាបានទទួលបង្គាប់ថា "លោកចូរសម្លាប់ឱ្យស្លាប់ក្នុងវេលាព្រឹកថ្ងៃនេះ", ភិក្ខុអ្នកទទួលបង្គាប់នោះ សម្លាប់គេស្លាប់ក្នុងវេលាថ្ងៃត្រង់ ឬវេលាល្ងាច ឬវេលាព្រឹកស្អែកនេះ, រមែងខុសសង្កេត; សម្រាប់ភិក្ខុអ្នកបង្គាប់ មិនមានសេចក្ដីចង់ព័ន្ធមកកម្ម ។ សូម្បីក្នុងកាល ភិក្ខុព្យាយាមនឹងសម្លាប់ឱ្យស្លាប់ក្នុងវេលាព្រឹក តែក្លាយជាថ្ងៃត្រង់ទៅ ក៏មានន័យដូចគ្នា ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេតនិងខុសសង្កេត ក្នុងប្រភេទនៃកាលទាំងពួងដោយន័យនេះ ។

## អធិប្បាយឱកាសដែលបង្គាប់ឱ្យធ្វើការសម្លាប់

សូម្បីក្នុងឱកាស មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណា ត្រូវបង្គាប់ថា "លោកចូរសម្លាប់បុគ្គលនោះ អ្នកឈរក្នុងស្រុកឱ្យស្លាប់", តែភិក្ខុទទួលបង្គាប់នោះ សម្លាប់បុគ្គលនោះស្លាប់ក្នុងទីណាមួយ, រមែងមិនខុសសង្កេត ។ ចំណែកភិក្ខុណាត្រូវបង្គាប់កំណត់

ទុកថា “ចូរសម្លាប់ឱ្យស្លាប់ក្នុងស្រុកប៉ុណ្ណោះ”, តែភិក្ខុទទួលបង្គាប់នោះសម្លាប់គេស្លាប់ក្នុងព្រៃ, មួយទៀត លោកត្រូវបង្គាប់ថា “ចូរសម្លាប់ឱ្យស្លាប់ក្នុងព្រៃ”, តែលោកសម្លាប់គេស្លាប់ក្នុងស្រុក, ត្រូវបង្គាប់ថា “ចូរសម្លាប់ឱ្យស្លាប់ត្រង់ទ្វារខាងក្នុងផ្ទះ” តែសម្លាប់គេស្លាប់ត្រង់កណ្ដាលផ្ទះ; រមែងខុសសង្កេត ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេតនិងខុសសង្កេតក្នុងសេចក្ដីផ្សេងគ្នានៃឱកាសទាំងពួង ដោយន័យនេះ ។

## អធិប្បាយអាវុធដែលជាគ្រឿងដៃប្រើឱ្យសម្លាប់

សូម្បីក្នុងអាវុធ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណា ត្រូវបង្គាប់ថា “លោកចូរយកអាវុធសម្លាប់ឱ្យស្លាប់” មិនបានកំណត់ទុកថា ដាវ ឬកូនសរ, ភិក្ខុទទួលបង្គាប់នោះ យកអាវុធប្រភេទណាមួយសម្លាប់ឱ្យស្លាប់; រមែងមិនខុសសង្កេត ។ ចំណែកភិក្ខុណា ត្រូវបង្គាប់ថា “ចូរប្រើដាវសម្លាប់” តែភិក្ខុអ្នកទទួលបង្គាប់នោះ ប្រើកូនសរសម្លាប់, ឬត្រូវបង្គាប់ថា “ចូរប្រើដាវនេះសម្លាប់” អ្នកទទួលបង្គាប់ប្រើដាវដទៃសម្លាប់ ឬត្រូវបង្គាប់ថា “ចូរយកដាវមួយនេះតែប៉ុណ្ណោះសម្លាប់” តែភិក្ខុទទួលបង្គាប់ ប្រើដាវក្រៅនេះ ឬប្រើក្ដាប់ដៃ ឬប្រើចំពុះ ឬប្រើដងដាវសម្លាប់, រមែងខុសសង្កេត ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេត និងខុសសង្កេតក្នុងសេចក្ដីផ្សេងគ្នានៃអាវុធទាំងពួង ដោយន័យនេះ ។

## អធិប្បាយឥរិយាបថដែលបង្គាប់ឱ្យធ្វើការសម្លាប់

ចំណែកក្នុងឥរិយាបថ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណា ត្រូវបង្គាប់ថា "លោកចូរសម្លាប់បុគ្គលនោះ ដែលកំពុងដើរឱ្យស្លាប់", តែសូម្បីបើភិក្ខុទទួលបង្គាប់នោះ សម្លាប់បុគ្គលដែលកំពុងដើរទៅស្លាប់ រមែងមិនខុសសង្កេត ។ កាលភិក្ខុអ្នកបង្គាប់ បង្គាប់ថា "លោកចូរសម្លាប់បុគ្គលដែលកំពុងដើរប៉ុណ្ណោះឱ្យស្លាប់" តែបើភិក្ខុអ្នកទទួលបង្គាប់ សម្លាប់បុគ្គលអង្គុយស្លាប់, ឬភិក្ខុអ្នកបង្គាប់ បង្គាប់ថា "លោកចូរសម្លាប់បុគ្គលអង្គុយប៉ុណ្ណោះ ឱ្យស្លាប់", តែភិក្ខុអ្នកទទួលបង្គាប់សម្លាប់បុគ្គលកំពុងដើរទៅស្លាប់, រមែងខុសសង្កេត ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេតនិងខុសសង្កេត ក្នុងសេចក្តីផ្សេងនៃឥរិយាបថទាំងពួង ដោយន័យនេះ ។

## អធិប្បាយកិរិយាវិសេសដែលបង្គាប់ឱ្យសម្លាប់

សូម្បីក្នុងកិរិយាវិសេស មានវិនិច្ឆ័យដូច្នេះ; ភិក្ខុណា ត្រូវបង្គាប់ថា "លោកចូរចាក់ឱ្យស្លាប់" ភិក្ខុអ្នកទទួលបង្គាប់នោះ ចាក់ឱ្យស្លាប់, រមែងមិនខុសសង្កេត ។ ចំណែកភិក្ខុណាត្រូវបញ្ជាថា "ចូរចាក់ឱ្យស្លាប់", តែភិក្ខុដែលសំបុកបង្គាប់នោះ កាត់ (កាប់) ឱ្យស្លាប់ពិតមែន, រមែងខុសសង្កេត ។ បណ្ឌិតគប្បីជ្រាបការត្រូវសង្កេតនិងខុសសង្កេត ក្នុង

សេចក្ដីផ្សេងគ្នានៃកិរិយាវិសេសទាំងពួង ដោយន័យនេះ ។

ចំណែកភិក្ខុណា បង្គាប់មិនកំណត់ ដោយអំណាចភេទថា "លោកចូរសម្លាប់អ្នកដែលខ្ពស់ ទាប ខ្មៅ ស ស្គម ធាត់ ឱ្យស្លាប់", និងភិក្ខុអ្នកទទួលបង្គាប់ សម្លាប់អ្នកណាមួយដូច្នោះស្លាប់, រមែងមិនខុសសង្កេត, ជាបារាជិកទាំង ២ រូប ។ តែបើភិក្ខុអ្នកបង្គាប់នោះបង្គាប់សំដៅយកខ្លួនឯង, និងភិក្ខុអ្នកទទួលបង្គាប់ សម្លាប់ភិក្ខុអ្នកបង្គាប់នុ៎ះឯងស្លាប់ ដោយគិតថា "លោកអ្នកបង្គាប់នេះឯង ដែលមានសភាពដូច្នេះ", សម្រាប់ភិក្ខុអ្នកបង្គាប់ ជាទុក្កដ ។ ភិក្ខុដែលសម្លាប់ជាបារាជិក ។ ភិក្ខុអ្នកបង្គាប់ បង្គាប់សំដៅយកខ្លួនឯង, ភិក្ខុអ្នកបង្គាប់ក្រៅនេះ សម្លាប់អ្នកដទៃដូច្នោះស្លាប់; ភិក្ខុអ្នកបង្គាប់ រមែងផុត (ចាកអាបត្តិ), ជាបារាជិកដល់ភិក្ខុដែលសម្លាប់ប៉ុណ្ណោះ ។

សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះមិនបានកំណត់ឱកាសទុក, តែបើភិក្ខុអ្នកបង្គាប់ស្ងួប្បីកាលបង្គាប់សំដៅយកខ្លួនឯង ក៏កំណត់ឱកាសទុកថា "លោកចូរសម្លាប់បុគ្គលឈ្មោះនេះ ដែលអង្គុយនៅលើយកសនៈព្រះថេរៈ ឬលើអាសនៈព្រះមជ្ឈិមៈ ក្នុងទីសម្រាកពេលយប់ឬទីសម្រាកពេលថ្ងៃ ឯណោះឱ្យស្លាប់", តែក្នុងឱកាសនោះ មានភិក្ខុដទៃអង្គុយជំនួស, បើភិក្ខុអ្នកទទួលបង្គាប់ សម្លាប់ភិក្ខុដែលមកអង្គុយនោះស្លាប់, ភិក្ខុដែល

សម្លាប់ រមែងមិនផុត (ពីអាបត្តិ)ពិត, ភិក្ខុអ្នកបង្គាប់ ក៏មិនផុត ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះបានកំណត់ឱកាសទុក ។ តែបើភិក្ខុអ្នកទទួលបង្គាប់ សម្លាប់គេស្លាប់ វៀរចាកឱកាសដែលកំណត់ទុក, ភិក្ខុអ្នកបង្គាប់ រមែងផុត (ចាកអាបត្តិ), ន័យដូចអធិប្បាយមកនេះ ព្រះអដ្ឋកថាចារ្យពោលទុកជាគោលដ្ឋានល្អ ក្នុងមហាអដ្ឋកថាថា; ព្រោះដូច្នោះ សេចក្តីមិនអើពើក្នុងន័យបណ្ឌិតទើបមិនគួរធ្វើ ដូច្នេះឯង ។

អាណត្តិកបយោគកថា ដោយអំណាចមាតិកាថា អធិដ្ឋាយ ចប់

## ការបង្គាប់ទូត

[១៨៩] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុង៤ វារៈ ថា ភិក្ខុ ភិក្ខុំ អាណាបេតិ : ភិក្ខុបង្គាប់ភិក្ខុផងគ្នា ជាដើម ដែលព្រះឧបាលីថេរៈពោលទុក ដើម្បីសម្តែងបទមាតិកាថា ទូតេន នេះ ។

ពាក្យថា សោ តំ មញ្ញមានោ : ភិក្ខុអ្នកទទួលបង្គាប់នោះ ចំណាំមនុស្សនោះបាន សេចក្តីថា ភិក្ខុណា ដែលភិក្ខុអ្នកបង្គាប់ប្រាប់ថា បុគ្គលឈ្មោះនេះ, ភិក្ខុអ្នកទទួលបង្គាប់រូបនោះ យល់ថា បុគ្គលនោះពិតប្រាកដ ទើបផ្តាច់បង់ជីវិតបុគ្គលនោះឯងចេញ ជាបារាជិកទាំង ២ រូប ។

ពាក្យថា តំ មញ្ញមានោ អញ្ញំ : ចំណាំមនុស្សនោះបាន

(ប៉ុន្តែ ទៅផ្តាច់បង់)ជីវិតមនុស្សដទៃវិញ សេចក្តីថា ភិក្ខុអ្នកទទួលបង្គាប់ យល់បុគ្គលដែលភិក្ខុអ្នកបង្គាប់ បង្គាប់ឲ្យផ្តាច់ជីវិត តែបែរទៅជាផ្តាច់ជីវិតបុគ្គលដទៃដូច្នោះ, ភិក្ខុដែលជាខាងដើមមិនជាអាបត្តិ ។

ពាក្យថា អញ្ញំ មញ្ញមានោ តំ : ចំណាំមនុស្សដទៃវិញ (ប៉ុន្តែ ទៅផ្តាច់បង់)ជីវិតមនុស្សនោះ សេចក្តីថា ភិក្ខុណា ដែលភិក្ខុបង្គាប់បញ្ជាទុកហើយ, លោកឃើញបុគ្គលជាសម្លាញ់ ដែលមានកម្លាំងរបស់ភិក្ខុអ្នកបង្គាប់នោះ ឈរក្នុងទីជិត ទើបគិតថា បុគ្គលនេះរមែងគម្រាមដោយកម្លាំងរបស់ភិក្ខុអ្នកបង្គាប់នេះ យើងនឹងផ្តាច់ជីវិតបុគ្គលនេះមុន កាលនឹងប្រហារ យល់ថា ជាបុគ្គលអ្នកបង្គាប់ឲ្យសម្លាប់ ក្រៅនេះពិតប្រាកដ ដែលផ្លាស់គ្នាមកឈរក្នុងទីនោះជំនួសថា ជាសម្លាញ់ ទើបបានផ្តាច់ជីវិតចេញ; ជាបារាជិកទាំង ២ រូប ។

ពាក្យថា អញ្ញំ មញ្ញមានោ អញ្ញំ : ចំណាំមនុស្សដទៃវិញនោះបាន (លុះវេលាទៅផ្តាច់បង់ ៗ)មនុស្សដទៃនោះ សេចក្តីថា ភិក្ខុអ្នកទទួលបង្គាប់ គិតដោយន័យមុននុ៎ះឯងថា យើងនឹងផ្តាច់ជីវិតបុគ្គលដែលជាសម្លាញ់របស់ភិក្ខុអ្នកបង្គាប់នោះមុន ហើយក៏ផ្តាច់ជីវិតបុគ្គលដែលជាសម្លាញ់នុ៎ះឯង ជាបារាជិកដល់ភិក្ខុអ្នកទទួលបង្គាប់នោះប៉ុណ្ណោះ ។

# អាណត្តិកបយោគរឿងបង្គាប់ទូតបន្ត

[១៩០] ក្នុងពាក្យជាដើមថា ឥត្ថន្នាមស្ស ព្រូហិ : លោកចូរទៅប្រាប់ភិក្ខុឈ្មោះនេះ ក្នុងនិទ្ទេសវារនៃបទពោលពីការនាំពាក្យបង្គាប់បន្តគ្នាមកនៃទូត មាន វិនិច្ឆ័យដូច្នេះ ៖

គប្បីឃើញថា អាចារ្យមួយរូប អន្តេវាសិកបីរូប មានឈ្មោះថា ពុទ្ធរក្ខិត ធម្មរក្ខិត និងសង្ឃរក្ខិត ។

បណ្តាបទទាំងនោះ ពាក្យថា ភិក្ខុ ភិក្ខុំ អាណាបេតិ : ភិក្ខុបង្គាប់ភិក្ខុផងគ្នា សេចក្តីថា អាចារ្យមានសេចក្តីប្រាថ្នានឹងឱ្យសម្លាប់បុគ្គលណាមួយ ទើបប្រាប់សេចក្តីនោះ ហើយបញ្ជាពុទ្ធរក្ខិត ។

ពីរបទថា ឥត្ថន្នាមស្ស ព្រូហិ : លោកចូរទៅប្រាប់ភិក្ខុឈ្មោះនេះ សេចក្តីថា (អាចារ្យបង្គាប់ថា) "ម្នាលពុទ្ធរក្ខិត អ្នកចូរទៅប្រាប់សេចក្តីនោះដល់ធម្មរក្ខិត ។

ពាក្យថា ឥត្ថន្នាមោ ឥត្ថន្នាមស្ស ព្រូតុ : ឱ្យភិក្ខុឈ្មោះនេះទៅប្រាប់ភិក្ខុឈ្មោះនេះ សេចក្តីថា សូម្បីធម្មរក្ខិត ក៏ប្រាប់ដល់សង្ឃរក្ខិត (តទៅ) ។

ពាក្យថា ឥត្ថន្នាមោ ឥត្ថន្នាមំ ជីវិតា វោរោបេតុ : ភិក្ខុនេះ

ចូរផ្តាច់បង់ជីវិតបុគ្គលឈ្មោះនេះ សេចក្តីថា ធម្មរក្ខិតត្រូវលោកបង្គាប់ទុកយ៉ាងនោះហើយ ក៏បង្គាប់សង្ឃរក្ខិត (តទៅ)ថា ចូរផ្តាច់ជីវិតបុគ្គលឈ្មោះនេះចេញ, ព្រោះថា បណ្តាយើងទាំង ២ នាក់ លោកជាអ្នកមានជាតិក្លាហានអាចក្នុងកម្មនេះ ។

ពាក្យថា អាបត្តិ ទុក្កដស្ស : ត្រូវអាបត្តិទុក្កដ សេចក្តីថា ជាអាបត្តិទុក្កដដល់អាចារ្យដែលបង្គាប់យ៉ាងនោះមុន ។

ពាក្យថា សោ ឥតរស្ស អារោចេតិ : ភិក្ខុអ្នកទទួលបង្គាប់នោះទៅប្រាប់អ្នកឯទៀតវិញ សេចក្តីថា ពុទ្ធរក្ខិតប្រាប់ធម្មរក្ខិត ធម្មរក្ខិតប្រាប់សង្ឃរក្ខិតថា "អាចារ្យរបស់ពួកយើងបង្គាប់យ៉ាងនេះថា បានឮថា លោកចូរផ្តាច់ជីវិតបុគ្គលឈ្មោះនេះចេញ, បានឮថា បណ្តាយើងទាំង ២ នាក់ លោកជាបុរសក្លាហាន" ជាទុក្កដ សូម្បីដល់លោកទាំងនោះ ដោយការប្រាប់បន្តគ្នាទៅយ៉ាងនោះជាបច្ច័យ ។

ពីរបទថា វធកោ បដិគ្គណ្ហាតិ : ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់ សេចក្តីថា សង្ឃរក្ខិតទទួលថា "ល្អណាស់ ខ្ញុំករុណានឹងផ្តាច់" ។

ពាក្យថា មូលដ្ឋស្ស អាបត្តិ ថុល្លច្ចយស្ស : ភិក្ខុអ្នកប្រើខាងដើម ត្រូវអាបត្តិថុល្លច្ច័យ មានសេចក្តីថា កាលពាក្យបង្គាប់នោះ ល្មមសង្ឃរក្ខិតទទួលហើយ ជាថុល្លច្ច័យដល់អាចារ្យ, តែមហាជនដែល

អាចារ្យនោះដឹកនាំក្នុងអំពើអាក្រក់ហើយនោះឯង ។

ពីរបទថា សោ តំ : **លុះភិក្ខុអ្នកសម្លាប់ ( បានផ្តាច់បង់ ) ជីវិតបុគ្គលនោះសម្រេច** សេចក្តីថា បើភិក្ខុនោះ គឺ សង្ឃរក្ខិតផ្តាច់ជីវិតបុគ្គលនោះចេញសោត, ជាបារាជិកទាំងអស់ គឺ ទាំង ៤ នាក់ និងមិនមែនត្រឹមតែ ៤ នាក់ប៉ុណ្ណឹងទេ, កាលធ្វើមិនឱ្យខុសសង្កេត បង្គាប់តាមលំដាប់ដោយឧបាយនេះ សមណៈទាំងរយ ឬសមណៈទាំងពាន់ក៏ដោយ ជាបារាជិកទាំងអស់គ្នា ។

ក្នុងនិទ្ទេសនៃបទវិសក្កិយទូត មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា សោ អញ្ញំ អាណាបេតិ : **ភិក្ខុអ្នកសម្លាប់ទទួលបង្គាប់នោះ ទៅបង្គាប់ភិក្ខុឯទៀតវិញ** សេចក្តីថា ភិក្ខុនោះ គឺ ពុទ្ធរក្ខិតដែលអាចារ្យបង្គាប់ទុកមិនជួបធម្មរក្ខិត ឬជាអ្នកមិនចង់ប្រាប់ ទើបចូលទៅរកសង្ឃរក្ខិតតែម្តង ហើយធ្វើឱ្យខុសលំនាំ បង្គាប់ថា "អាចារ្យរបស់យើងបង្គាប់យ៉ាងនេះថា បានឮថា លោកចូរផ្តាច់ជីវិតបុគ្គលឈ្មោះនេះចេញ" ។ ពិតមែន ភិក្ខុនេះ លោកហៅថា វិសក្កិយទូត ព្រោះធ្វើឱ្យខុសលំនាំនុ៎ះឯង ។

ពាក្យថា អាបត្តិ ទុក្កដស្ស : **ត្រូវអាបត្តិទុក្កដ** គឺ ជាទុក្កដដល់ពុទ្ធរក្ខិតព្រោះបង្គាប់មុន ។

ពាក្យថា **បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស : ទទួលបង្គាប់ត្រូវអាបត្តិទុក្កដ** នោះ គប្បីជ្រាបថា ជាទុក្កដដល់ភិក្ខុជំបូងតែម្តង ក្នុងកាលសង្ឃរក្ខិតទទួល ។ កាលជាយ៉ាងនោះ អាបត្តិព្រោះការទទួល មិនគប្បីមាន, តែសូម្បីក្នុងការទទួលបង្គាប់ និងពេញចិត្តក្នុងការស្លាប់ ក៏នៅតែជាអាបត្តិ, យ៉ាងណា នឹងមិនគប្បីជាអាបត្តិ ព្រោះទទួលសម្លាប់ហ្ន៎ ? ព្រោះហេតុនោះ ទុក្កដ មានដល់ភិក្ខុដែលទទួលនុ៎ះឯង; ដោយហេតុនុ៎ះឯង ទើបព្រះមានព្រះភាគមិនត្រាស់ពាក្យថា មូលដ្ឋស្ស ក្នុងន័យនេះ ។ និងសូម្បីក្នុងន័យមុន ក៏គប្បីជ្រាបទុក្កដនេះដល់ភិក្ខុដែលទទួលដូចគ្នា ។ តែព្រោះមិនមានឱកាស ទើបមិនត្រាស់ទុក្កដនេះទុក ។ ព្រោះដូច្នោះ ភិក្ខុណា ៗ ទទួល ជាអាបត្តិដល់ភិក្ខុនោះ ៗ ព្រោះមានការទទួលនោះជាបច្ច័យពិត, នេះជាសេចក្តីពេញចិត្តរបស់យើងទាំងឡាយក្នុងរឿងនេះឯង, ដូចយ៉ាងថា ក្នុងមនុស្សវិគ្គហៈនេះយ៉ាងណា សូម្បីក្នុងអទិន្នាទាន ក៏យ៉ាងនោះឯង ។

ក៏បើព្រះសង្ឃរក្ខិតនោះផ្តាច់ជីវិតបុគ្គលនោះបានសោត, ជាបារាជិកទាំង ២ រូប គឺ ព្រះពុទ្ធរក្ខិតអ្នកបង្គាប់ និងព្រះសង្ឃរក្ខិតអ្នកសម្លាប់, មិនជាអាបត្តិបារាជិកដល់អាចារ្យជាខាងដើម ព្រោះការបង្គាប់ខុសលំនាំ, មិនជាអាបត្តិដោយប្រការទាំងពួងដល់ព្រះធម្មរក្ខិត ព្រោះមិនដឹង ។

ចំណែកព្រះពុទ្ធរក្ខិត ធ្វើសេចក្ដីសួស្ដីដល់ភិក្ខុទាំង ២ រូប ហើយវិនាស ដោយខ្លួនឯង ដូច្នេះឯង ។

[១៩១] ក្នុងនិទ្ទេសនៃ **គតបច្ចាគតទូត** : មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា **សោ គន្ត្វា បុន បច្ចាគច្ឆតិ** : ***ភិក្ខុអ្នកទទួលបង្គាប់នោះទៅហើយត្រឡប់មកប្រាប់វិញ*** សេចក្ដីថា ភិក្ខុអ្នកទទួលបង្គាប់នោះ ទៅកាន់ទីជិតនៃបុគ្គលដែលខ្លួននឹងគប្បីផ្ដាច់ជីវិតនោះ កាលមិនអាចផ្ដាច់ ជីវិតបុគ្គលនោះ ព្រោះគេមានការរក្សាការពារទុកល្អហើយទើបត្រឡប់មក ។

ពាក្យថា **យទា សក្កោសិ តទា តំ** : ***លោកអាចវេលាណា លោកចូរ( ទៅផ្ដាច់បង់ជីវិតគេ )វេលានោះចុះ*** មានសេចក្ដីថា ភិក្ខុអ្នក បង្គាប់នោះ បង្គាប់ថ្មីថា "ត្រូវសម្លាប់ក្នុងថ្ងៃនេះឬ ទើបជាការសម្លាប់ ? ទៅចុះ លោកអាចកាលណា ចូរផ្ដាច់ជីវិតគេចេញ កាលនោះចុះ" ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** : ***ត្រូវអាបត្តិទុក្កដ*** មានសេចក្ដីថា ព្រោះបង្គាប់ យ៉ាងនោះទៀត រមែងជាទុក្កដដូចគ្នា ។ ក៏បើបុគ្គលនោះ ជាអ្នកនឹងត្រូវតែដាច់ជីវិតពិតប្រាកដមែន, ចេតនាដែលញ៉ាំងអត្ថឱ្យ សម្រេច រមែងដូចគ្នានឹងផលដែលកើតក្នុងលំដាប់នៃមគ្គ; ព្រោះដូច្នោះ ភិក្ខុអ្នកបង្គាប់នេះ ទើបជាបារាជិកក្នុងខណៈបង្គាប់តែម្ដង ។ បើសូម្បី ភិក្ខុដែលសម្លាប់នឹងសម្លាប់បុគ្គលនោះបាន ដោយកន្លងទៅ ៦០ ឆ្នាំក៏

ដោយ, និងភិក្ខុអ្នកបង្គាប់នឹងធ្វើកាលកិរិយា ឬសឹកក្នុងចន្លោះនោះក៏ដោយ, ក៏ជាអ្នកមិនមែនសមណៈធ្វើកាលកិរិយាឬសឹកពិត ។ បើអ្នកបង្គាប់សំដៅយកមាតាបិតា ឬព្រះអរហន្ត បង្គាប់យ៉ាងនោះក្នុងវេលាជាគ្រហស្ថហើយទើបបួស, អ្នកទទួលបង្គាប់សម្លាប់បុគ្គលនោះបាន ក្នុងកាលអ្នកបង្គាប់នោះបួសហើយ, អ្នកបង្គាប់រមែងជាអ្នកសម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្តតាំងពីក្នុងវេលាជាគ្រហស្ថតែម្តង; ព្រោះហេតុនោះ បព្វជ្ជា ឧបសម្បទារបស់គេ រមែងមិនឡើងឡើយ ។ បើសូម្បីបុគ្គលដែលនឹងគប្បីត្រូវសម្លាប់ ក្នុងខណៈបង្គាប់នៅជាបុថុជ្ជន, តែជាព្រះអរហន្តក្នុងវេលាដែលត្រូវអ្នកទទួលបង្គាប់សម្លាប់, ម្យ៉ាងទៀតបុគ្គលដែលនឹងត្រូវសម្លាប់នោះ បានការប្រហារអំពីអ្នកទទួលបង្គាប់ហើយអាស្រ័យសទ្ធាមានទុក្ខជាមូល ចម្រើនវិបស្សនាសម្រេចព្រះអរហត្តហើយធ្វើកាលកិរិយាទៅព្រោះអាពាធនោះឯង, អ្នកបង្គាប់ រមែងជាអ្នកសម្លាប់ព្រះអរហន្តក្នុងខណៈបង្គាប់នុ៎ះឯង, ចំណែកអ្នកសម្លាប់ រមែងជាបារាជិក ក្នុងខណៈធ្វើសេចក្តីព្យាយាមក្នុងទីទាំងពួងតែម្តងឯង ។

[១៩២] ក៏ក្នុងបណ្តាវារៈទាំង ៣ ដែលព្រះឧបាលីថេរៈពោលទុក ដើម្បីសម្តែងការត្រូវសង្កេតនិងខុសសង្កេត ក្នុងបទមាតិកាដែលត្រាស់ដោយអំណាចទូតទាំងអស់នេះ ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុង

បឋមវារមុន ។ ភិក្ខុជាខាងដើមនិយាយពាក្យនោះតិច ៗ ឬព្រោះភិក្ខុអ្នកទទួលបង្គាប់នោះជាមនុស្សត្រចៀកថ្លង់ ទើបប្រកាសឱ្យបានឮពាក្យបង្គាប់នេះថា លោកចូរកុំសម្លាប់, មិនបាន; ព្រោះហេតុនោះ ភិក្ខុជាខាងដើមទើបមិនផុត ។ ក្នុងទុតិយវារ ផុតបាន ព្រោះលោកប្រកាសឱ្យបានឮ ។ ចំណែកក្នុងតតិយវារ សូម្បីទាំង ២ រូប ក៏ផុតបាន ព្រោះភិក្ខុជាខាងដើមនោះប្រកាសឱ្យ (ភិក្ខុអ្នកទទួលបង្គាប់) បានឮ និងព្រោះភិក្ខុអ្នកទទួលបង្គាប់ក្រៅនេះ ក៏ទទួលពាក្យថា "ល្អណាស់ ហើយលះបង់ចេញ" ដូច្នេះឯង ។

ទូតកថា ចប់

## រឿងដែលមិនកំបាំង សម្គាល់ថា កំបាំង

[១៩៣] ក្នុងអរហោ រហោសញ្ញិនិទ្ទេស ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

បទថា អរហោ : ទីដែលមិនស្ងាត់ បានដល់ ចំពោះមុខ ។ បទថា រហោ : ទីដែលស្ងាត់ បានដល់ កំបាំងមុខ, បណ្ដាជន ២ នាក់ (គឺ អ្នកមានសេចក្ដីសម្គាល់ចំពោះមុខថា កំបាំងមុខ និងអ្នកមានសេចក្ដីសម្គាល់កំបាំងមុខថា ចំពោះមុខនោះ) ភិក្ខុណា កាលភិក្ខុដែលមានពៀរ

នឹងគ្នា មកជាមួយនឹងភិក្ខុទាំងឡាយហើយអង្គុយនៅខាងមុខនុ៎ះឯង ក្នុងវេលាឧបដ្ឋាក មិនជ្រាបការដែលលោកមក ព្រោះទោសគឺ សេចក្តីងងឹតពេញចិត្តចំពោះការស្លាប់របស់ភិក្ខុដែលមានពៀរនឹងគ្នានោះ ទើបនិយាយចរចាពាក្យដូច្នេះឡើងថា "លោកម្ចាស់ សូមឱ្យភិក្ខុមានឈ្មោះយ៉ាងនេះត្រូវសម្លាប់, ធ្វើដូចម្តេចពួកចោរ ទើបមិនសម្លាប់វា, ពស់ទើបមិនខាំវា, អ្នកណា ៗ ទើបមិនយកសស្ត្រាឬថ្នាំពិសមកផ្តាច់ជីវិតវា" ភិក្ខុនេះឈ្មោះថា អ្នកមានសេចក្តីសម្គាល់ចំពោះមុខថា កំបាំងមុខនិយាយចរចា ។ អធិប្បាយថា អ្នកមានសេចក្តីសម្គាល់ក្នុងទីចំពោះមុខនោះថាកំបាំងមុខ ។ ចំណែកភិក្ខុណា ឃើញភិក្ខុដែលមានពៀរនឹងគ្នានោះអង្គុយនៅខាងមុខ ជាអ្នកមានសេចក្តីសម្គាល់ថា "លោកនៅអង្គុយទីនេះឯង" និយាយចរចាឡើងតាមន័យមុននុ៎ះឯង ក្នុងកាលលោកសូម្បីទៅព្រមនឹងភិក្ខុទាំងឡាយ អ្នកធ្វើឧបដ្ឋាកហើយ ត្រឡប់ទៅ, ភិក្ខុនេះឈ្មោះថា អ្នកមានសេចក្តីសម្គាល់កំបាំងមុខថា ចំពោះមុខនិយាយចរចា ។ បុគ្គលដែលមានសេចក្តីសម្គាល់ក្នុងចំពោះមុខថា ចំពោះមុខ និងបុគ្គលដែលមានសេចក្តីសម្គាល់ក្នុងកំបាំងមុខថា កំបាំងមុខ អ្នកសិក្សាគប្បីជ្រាបដោយឧបាយនេះឯង ។ ម្យ៉ាងទៀត គប្បីជ្រាបថា ជាទុក្កដគ្រប់ ៗ ពាក្យនិយាយដល់ភិក្ខុទាំងនោះសូម្បីទាំង ៤ រូប ។

# អធិប្បាយការពណ៌នាសេចក្ដីស្លាប់ដោយកាយ

[១៩៤] ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃមាតិកា ៥ មានពណ៌នាដោយកាយជាដើម ដែលព្រះឧបាលីពោលទុក ដើម្បីសម្ដែងវិភាគនៃការពណ៌នាសេចក្ដីស្លាប់ ។

ពាក្យថា កាយេន វិការំ ករោតិ[១] : ភិក្ខុធ្វើវិការដោយកាយដូច្នេះ មានសេចក្ដីថា គេនឹងដឹងបានថា សេចក្ដីនេះ ដែលបុគ្គលនេះពោលថា អ្នកណាប្រើសស្ត្រាសម្លាប់ខ្លួនឱ្យស្លាប់ ឬទំពាស៊ីថ្នាំពិសឱ្យស្លាប់ ឬយកខ្សែចង-កឱ្យស្លាប់ ឬលោតចូលអណ្ដូងជាដើមឱ្យស្លាប់, បានឮថា អ្នកនោះនឹងបានទ្រព្យ នឹងបានយស ឬនឹងទៅឋានសួគ៌, ដូច្នេះដោយប្រការណា, ភិក្ខុសម្ដែងប្រការនោះ ដោយអវយវៈទាំងឡាយមានមេដៃជាដើម ។

ពាក្យថា វាចាយ ភណតិ : ពោលវាចា សេចក្ដីថា ភិក្ខុបញ្ចេញនូវវាចា ពោលសេចក្ដីនោះឯង ។ វារៈទី ៣ ជាការពោលហើយ ដោយអំណាចនៃវារៈទាំង ២ ។ គ្រប់ ៗ វារៈពិន័យជាទុក្កដគ្រប់ ៗ ប្រយោគនៃការពណ៌នា, ជាថុល្លច្ច័យដល់ភិក្ខុដែលពណ៌នាព្រោះទុក្ខកើតឡើងដល់គេ, កាលបុគ្គលដែលខ្លួនធ្វើការពណ៌នាចំពោះ

---

១. ថៃ. ទស្សេតិ ។

(នោះ)ស្លាប់ទៅ ជាបារាជិកដល់ភិក្ខុដែលពណ៌នាក្នុងខណៈដែលពណ៌នាតែម្តង ។ អ្នកនោះ រមែងមិនដឹងសេចក្តីនោះ , អ្នកដទៃដឹងហើយគិតថា "យើងបានឧបាយជាហេតុកើតសេចក្តីសុខហើយហ្ន៎" ដូច្នេះ ស្លាប់ទៅព្រោះការពណ៌នានោះ មិនជាអាបត្តិ ។ កាលភិក្ខុធ្វើការពណ៌នាចំពោះដល់មនុស្ស ២ នាក់ ដឹងម្នាក់ហើយស្លាប់ទៅ ជាបារាជិក, ស្លាប់ទាំង ២ នាក់ ជាបារាជិកផង ជាកងអកុសលផង ។ ក្នុងបុគ្គលច្រើនក៏ន័យនេះ, ភិក្ខុពណ៌នាសេចក្តីស្លាប់មិនចំពោះបុគ្គលណា ៗ ដឹងការពណ៌នានោះ ហើយស្លាប់ទៅ, បុគ្គលនោះ ៗ ទាំងអស់ ជាការភិក្ខុនោះសម្លាប់ហើយ ។

## អធិប្បាយពណ៌នាសេចក្តីស្លាប់ដោយទូតនិងសំបុត្រ

[១៩៥] ក្នុងការពណ៌នាដោយប្រើបម្រើ មានវិនិច្ឆ័យដូច្នេះ ៖

ជាទុក្កដកាលភិក្ខុត្រឹមតែប្រាប់ដំណឹងថា "លោកចូរទៅកាន់ផ្ទះ ឬស្រុកឈ្មោះឯណោះ ហើយពណ៌នាគុណសេចក្តីស្លាប់ ដល់បុគ្គលមានឈ្មោះយ៉ាងនេះចុះ" ។ ទូតដែលខ្លួនបញ្ជូនទៅ ដើម្បីប្រយោជន៍ដល់បុគ្គលណា ព្រោះសេចក្តីទុក្ខ កើតដល់បុគ្គលនោះ ជាថុល្លច្ច័យដល់ភិក្ខុដែលជាខាងដើម, ព្រោះគេស្លាប់ ជាអាបត្តិបារាជិក ។ ទូតគិតថា ឥឡូវនេះ យើងដឹងមកសួគ៌នេះហើយ មិនប្រាប់ដល់បុគ្គលនោះ ប្រាប់ដល់

ញាតិឬសាច់សាលោហិតរបស់ខ្លួន, កាលគេស្លាប់ ជាការខុសសង្កេត, ភិក្ខុដែលជាខាងដើមរូបខ្លួនទៅ ។ ទូតគិតយ៉ាងនោះឯង ធ្វើកិច្ចដែលពោលទុកក្នុងការពណ៌នាដោយខ្លួនឯងស្លាប់ទៅ, ខុសសង្កេតដូចគ្នា ។ តែភិក្ខុប្រាប់ដំណឹងមិនចំពោះ ជាបាណាតិបាតប្រមាណតាមចំនួនមនុស្សដែលស្លាប់ទៅ ដោយការពណ៌នារបស់ទូត ។ បើមាតានិងបិតាស្លាប់ទៅជាអនន្តរិយកម្មផង ។

ក្នុងលេខាសំវណ្ណនា មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា **លេខំ ឆិន្ទតិ : ភិក្ខុឆ្លាក់អក្សរ** មានសេចក្តីថា ភិក្ខុសរសេរអក្សរចុះ ក្នុងស្លឹកឈើឬក្នុងស្លឹករឹតថា "អ្នកណា ប្រើសស្ត្រាសម្លាប់ខ្លួនឱ្យស្លាប់ ឬលោតជ្រោះឱ្យស្លាប់ឬឱ្យស្លាប់ដោយឧបាយយ៉ាងដទៃ មានការលោតចូលភ្លើងនិងលោតទឹកជាដើម, អ្នកនោះនឹងបានវត្ថុនេះ ឬថា ។ល។ ជាការប្រពៃរបស់អ្នកនោះ" ។ សូម្បីក្នុងការសរសេរសំបុត្រដែលមិនចំពោះនេះ បណ្ឌិតក៏គប្បីជ្រាបថា ជាទុក្កដ ថុល្លច្ច័យ និងបារាជិកដោយន័យដូចពោលហើយនុ៎ះឯង ។ តែកាលភិក្ខុសរសេរសំបុត្រចំពោះ ខ្លួនសរសេរចំពោះបុគ្គលណា, ព្រោះអ្នកនោះឯងស្លាប់ ជាបារាជិក, កាលសរសេរសំបុត្រចំពោះបុគ្គលច្រើនអ្នកជាបាណាតិបាត មានប្រមាណប៉ុនចំនួនអ្នកដែលស្លាប់ទៅ, ព្រោះមាតានិងបិតាស្លាប់ជាអនន្តរិយកម្ម ។ សូម្បីក្នុងសំបុត្រដែលសរសេរមិនចំពោះ ក៏ន័យនេះ

៦៨ ។ ភិក្ខុកាលកើតសេចក្ដីក្ដៅក្រហាយឡើងថា មនុស្សសត្វជាច្រើននឹងស្លាប់ ទើបដុតស្លឹករឹតនោះចេញ ឬធ្វើអក្សរទាំងឡាយដើម្បីមិនឲ្យប្រាកដ រមែងផុតបាន ។ បើស្លឹករឹតនោះជារបស់អ្នកដទៃ, ភិក្ខុនឹងសរសេរសំបុត្រចំពោះក៏ដោយ ឬសរសេរទុកមិនចំពោះក៏ដោយ ដាក់ទុកក្នុងទីដែលខ្លួនកាន់យកមក រមែងផុត ។

បើស្លឹករឹតនោះ រមែងជារបស់ដែលគេទិញមកដោយមូលតម្លៃ, លោកឲ្យស្លឹករឹតដល់ម្ចាស់របស់ស្លឹករឹតហើយ ឲ្យមូលតម្លៃដល់ពួកជនអ្នកដែលខ្លួនទទួលយកមូលតម្លៃអំពីដៃហើយ រមែងផុតបាន ។

បើភិក្ខុច្រើនរូបជាអ្នកមានអធ្យាស្រ័យរួមគ្នាថា ពួកយើងនឹងសរសេរពណ៌នាគុណសេចក្ដីស្លាប់ ដូច្នេះ, មួយរូបឡើងដើមត្នោតហើយកាត់ស្លឹកត្នោត, មួយរូបនាំមក, មួយរូបធ្វើឲ្យជាស្លឹករឹត, មួយរូបទៀតសរសេរ ។ មួយរូបទៀត បើជាការសរសេរដោយដែកចារ ក៏យកធ្យូងលាប; កាលលាបធ្យូងហើយ ចាត់ស្លឹករឹតនោះចូលជាបាច់, លោកទាំងអស់ ដើរយកទៅដាក់ទុកត្រង់សភា ឬលើរានផ្សារ ឬ ក្នុងស្ថានទីដែលប្រជាជនមានច្រើននាក់ភ្ញាក់ផ្អើល ប្រជុំគ្នាដើម្បីមើលសំបុត្រ ។ ប្រជាជនអានសំបុត្រនោះហើយ, បើស្លាប់ទៅម្នាក់, ជាបារាជិកដល់ភិក្ខុទាំងអស់ ។ បើស្លាប់ទៅច្រើនអ្នកសោត ក៏មានន័យដូចពោលហើយនុ៎ះ

៦៩ ។ តែកាលកើតសេចក្ដីក្ដៅក្រហាយឡើង បើភិក្ខុទាំងនោះ យក

ស្លឹករឹតនោះរក្សាទុកក្នុងប្រអប់, ម្យ៉ាងទៀត មានអ្នកដទៃប្រទះឃើញស្លឹករឹតនោះហើយ នាំចេញមកសម្ដែងដល់ជនជាច្រើនទៀត, លោកទាំងអស់នោះ នឹងមិនរួចខ្លួនឡើយ, ប្រអប់ចូរលើកទុក, បើសូម្បីពួកលោកគ្រវែងស្លឹករឹតនោះចុះទៅ ឬលាងក្នុងទន្លេឬសមុទ្រចេញ ហែកជាកំណាត់តូចកំណាត់ធំ ឬដុតភ្លើងឱ្យឆេះ ក៏មិនទាន់រួចខ្លួនដរាបណា ដែលអក្សរសំបុត្រប្រាកដនៅក្នុងស្លឹករឹត សូម្បីដែលនៅមានសេចក្ដីជាប់តគ្នាបាន ដែលលាងមិនជ្រះ ឬឆេះមិនអស់ ។ តែកាលធ្វើឱ្យអក្សរទាំងឡាយមិនអាចនឹងប្រាកដឡើយ ទើបរួចខ្លួនទៅបាន ដូច្នេះឯង ។

## អធិប្បាយការជីករណ្ដៅឱ្យមនុស្សធ្លាក់ស្លាប់

[១៩៦] ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃមាតិកាមានរណ្ដៅជាដើម ដែលព្រះឧបាលីពោលទុក ដើម្បីសម្ដែងវិភាគនៃថាវរប្រយោគ ។

ពាក្យថា មនុស្សំ ឧទ្ទិស្ស ឱបាតំ ខណតិ : **ភិក្ខុជីករណ្ដៅចំពោះមនុស្ស** សេចក្ដីថា ភិក្ខុជីករណ្ដៅចំពោះមនុស្សណាមួយដោយតាំងចិត្តថា មនុស្សមានឈ្មោះនេះ នឹងធ្លាក់ទៅស្លាប់ ក្នុងទីដែលមនុស្សនោះត្រាច់ទៅតែម្នាក់ឯង ។ ខាងដើមមុនអំពីមនុស្សស្លាប់នោះ បើសូម្បីជីកជាតបឋវី ជាទុក្កដគ្រប់ប្រយោគ ដល់ភិក្ខុអ្នកជីក ព្រោះជាប្រយោគនៃបាណាតិបាត, ជាថុល្លច្ច័យ ព្រោះបង្កឱ្យកើតសេចក្ដីទុក្ខដល់មនុស្ស

ដែលខ្លួនជីកទុកចំពោះ, បើគេស្លាប់ ជាបារាជិក, កាលអ្នកដទៃ សូម្បីធ្លាក់ទៅស្លាប់ មិនជាអាបត្តិ ។ បើជីកទុកមិនចំពោះដោយគិតថា "អ្នកណាម្នាក់នឹងស្លាប់" ជាបាណាតិបាតតាមចំនួនសត្វដែលធ្លាក់ទៅស្លាប់ បើវត្ថុនៃអនន្តរិយកម្ម ជាអនន្តរិយកម្ម, បើវត្ថុនៃអាបត្តិថុល្លច្ច័យនិងបាចិត្តិយ ក៏ជាអាបត្តិថុល្លច្ច័យនិងបាចិត្តិយ ។

សួរថា ចេតនាក្នុងការជីករណ្ដៅនោះមានច្រើន ជាបារាជិកដោយចេតនាណា ?

ឆ្លើយថា លោកពោលទុកក្នុងមហាអដ្ឋកថាមុនថា កាលភិក្ខុជីករណ្ដៅ ទាំងជម្រៅទាំងបណ្ដោយនិងទទឹង បានប្រមាណ (ខាត) ហើយកកាយគរទុក ប្រើបង្គីកើបអាចម៍ដីឡើងមកខាងលើ ចេតនាដែលញ៉ាំងអត្ថឱ្យសម្រេច ដែលជាហេតុឱ្យតាំងឡើង ដូចគ្នានឹងផលក្នុងលំដាប់នៃមគ្គ បើសូម្បីថា ដោយរយៈកាលតទៅរាប់រយឆ្នាំ នឹងមានសត្វធ្លាក់ចុះស្លាប់ពិតប្រាកដ ជាបារាជិកដោយចេតនាដែលជាហេតុឱ្យតាំងឡើងនោះឯង ចំណែកក្នុងមហាបច្ចរី និងក្នុងសង្ខេបអដ្ឋកថាលោកពោលទុកថា កាលភិក្ខុប្រើចបប្រហារ (កាប់) សូម្បីម្ដង ដោយគិតថា "បុគ្គលនឹងធ្លាក់ក្នុងរណ្ដៅនេះស្លាប់" ដូច្នេះ បើមានអ្នកណាមួយ ភ្លាត់ធ្លាក់ចុះទៅក្នុងរណ្ដៅនោះស្លាប់ ជាបារាជិកដូចគ្នា; ចំណែកពួកព្រះថេរៈអ្នកជំនាញក្នុងព្រះសូត្រ នៅប្រកាន់យកចេតនាដែលជាហេតុឱ្យតាំងឡើង (ជា

គោល ) ។

ភិក្ខុមួយរូបជីករណ្ដៅ ហើយបង្គាប់ភិក្ខុដទៃថា "ចូរនាំបុគ្គលឈ្មោះឯណោះមកហើយ ប្រាននឱ្យធ្លាក់ស្លាប់ក្នុងរណ្ដៅនេះ" ។ ភិក្ខុដទៃនោះ ញ៉ាំងអ្នកនោះឱ្យធ្លាក់ស្លាប់ ជាបារាជិកទាំង ២ រូប, ញ៉ាំងអ្នកដទៃឱ្យធ្លាក់ស្លាប់ ខ្លួនឯងធ្លាក់ទៅស្លាប់ អ្នកដទៃធ្លាក់ទៅស្លាប់តាមធម្មតារបស់ខ្លួន, ក្នុងគ្រប់ករណីមានការខុសសង្កេត ភិក្ខុដែលជាខាងដើមរួចខ្លួនទៅ ។ សូម្បីក្នុងរណ្ដៅដែលភិក្ខុជីកទុក ដោយគិតថា ភិក្ខុឈ្មោះឯណោះ នឹងនាំអ្នកឈ្មោះឯណោះមក ឱ្យ ( ធ្លាក់ ) ស្លាប់ក្នុងរណ្ដៅនេះក៏ន័យនេះដូចគ្នា ។ ភិក្ខុជីកទុកដោយគិតថា មនុស្សទាំងឡាយដែលចង់ស្លាប់នឹងស្លាប់ក្នុងរណ្ដៅនេះ, ជាបារាជិក ព្រោះមនុស្សម្នាក់ស្លាប់, ជាកងអកុសល ព្រោះមនុស្សច្រើននាក់ស្លាប់, ជាអនន្តរិយកម្ម ព្រោះមាតានិងបិតាស្លាប់, ជាថុល្លច្ច័យនិងបាចិត្តិយ ព្រោះវត្ថុនៃថុល្លច្ច័យនិងបាចិត្តិយ ។ ភិក្ខុជីកទុកដោយគិតថា ជនពួកណាមួយមានសេចក្ដីប្រាថ្នានឹងសម្លាប់គេឱ្យស្លាប់ នឹងប្រានជនទាំងនោះ ឱ្យធ្លាក់ស្លាប់ក្នុងរណ្ដៅនេះដូច្នេះ ។ ពួកគេប្រាន ឱ្យធ្លាក់ស្លាប់ក្នុងរណ្ដៅនោះ, កាលស្លាប់ម្នាក់ ជាបារាជិក, កាលច្រើនអ្នកស្លាប់ ជាកងអកុសល ។ ជាអនន្តរិយកម្មជាដើម ព្រោះវត្ថុនៃអនន្តរិយកម្មជាដើម ។ និងសូម្បីព្រះអរហន្តទាំងឡាយក៏ដល់ការសង្គ្រោះចូលក្នុងន័យក្រោយនេះផង ។ តែន័យដំបូង កិរិយា

ដែលព្រះអរហន្តទាំងនោះធ្លាក់ទៅ ព្រោះជាអ្នកប្រាថ្នានឹងស្លាប់ រមែងមិនមាន; ព្រោះហេតុនោះ ទើបលោកមិនសង្គ្រោះព្រះអរហន្តទាំងឡាយចូលផង ។ សូម្បីក្នុងន័យទាំងពីរ កាលបុគ្គលធ្លាក់ទៅស្លាប់តាមធម្មតារបស់ខ្លួន រមែងមានការខុសសង្កេត ។ ភិក្ខុគិតថា ជនពួកណាមួយនឹងប្រានមនុស្សមានពៀររបស់ខ្លួនឱ្យធ្លាក់ស្លាប់ក្នុងរណ្តៅនេះ ហើយជីកទុក, និងពួកជនអ្នកមានពៀរនឹងគ្នា ក៏ប្រានអ្នកមានពៀរឱ្យធ្លាក់ស្លាប់ក្នុងរណ្តៅនោះ, កាលត្រូវសម្លាប់ស្លាប់ម្នាក់ ជាបារាជិក, កាលត្រូវសម្លាប់ស្លាប់ច្រើននាក់ជាកងអកុសល កាលមាតាឬបិតា ឬព្រះអរហន្ត ត្រូវពួកជនអ្នកមានពៀរនាំមកសម្លាប់ឱ្យស្លាប់ក្នុងរណ្តៅនោះ ជាអនន្តរិយកម្ម, កាលមាតាជាដើមទាំងនោះស្លាប់តាមធម្មតារបស់ខ្លួន រមែងខុសសង្កេត ។

ចំណែកភិក្ខុណា ជីកទុកមិនបានចំពោះ សូម្បីដោយប្រការទាំងពួងថា ជនពួកណាមួយ អ្នកចង់ស្លាប់ក្តី មិនចង់ស្លាប់ក្តី អ្នកប្រាថ្នានឹងសម្លាប់គេក្តី មិនប្រាថ្នានឹងសម្លាប់ក្តី នឹងធ្លាក់ទៅស្លាប់ ឬត្រូវប្រានឱ្យធ្លាក់ទៅស្លាប់ក្នុងរណ្តៅនេះ, ភិក្ខុនោះ រមែងត្រូវកម្ម និងរមែងត្រូវអាបត្តិតាមសមគួរ ព្រោះសេចក្តីស្លាប់របស់បុគ្គលដែលស្លាប់ទៅនោះ ៗ ។ បើស្ត្រីមានគភ៌ធ្លាក់ទៅស្លាប់ទាំងគភ៌ (កូន) ជាបាណាតិបាត ២ ។ ចំពោះសត្វនៅក្នុងគភ៌ប៉ុណ្ណោះវិនាសទៅ ជាបាណាតិបាតតែមួយ សត្វកើតក្នុងគភ៌មិនវិនាស តែមាតាស្លាប់ ជាបាណាតិបាតតែមួយដូចគ្នា ។ មនុស្ស

ត្រូវពួកចោរដេញតាម ធ្លាក់ទៅស្លាប់, ជាបារាជិកដល់ភិក្ខុដែលជីករណ្ដៅដូចគ្នា ។ ពួកចោរធ្លាក់ចូលទៅស្លាប់ក្នុងរណ្ដៅនោះ ត្រូវអាបត្តិបារាជិកដូចគ្នា ពួកចោរនាំអ្នកធ្លាក់ទៅក្នុងរណ្ដៅនោះចេញទៅខាងក្រៅ ហើយសម្លាប់ឱ្យស្លាប់, ជាបារាជិកដូចគ្នា ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះគេត្រូវពួកចោរចាប់បាន ក៏ដោយប្រយោគដែលធ្លាក់ទៅក្នុងរណ្ដៅ ។ អ្នកដែលធ្លាក់រណ្ដៅចេញមកពីរណ្ដៅបាន ហើយស្លាប់ទៅដោយការឈឺចាប់នោះឯង ជាបារាជិកដូចគ្នា ។ គ្រាកន្លងមកច្រើនឆ្នាំហើយ ទើបស្លាប់ព្រោះរោគនោះឯង ដែលកម្រើកឡើងទៀត ជាបារាជិកដូចគ្នា ។ រោគប្រភេទដទៃ កើតឡើងដល់អ្នកជម្ងឺ ដោយរោគដែលកើតឡើង ព្រោះមានការធ្លាក់ទៅ ក្នុងរណ្ដៅនោះជាបច្ច័យនុ៎ះឯង, តែរោគដែលកើតឡើងព្រោះរណ្ដៅជារបស់មានកម្លាំងជាង, សូម្បីកាលអ្នកនោះស្លាប់ព្រោះរោគដែលកើតឡើងនោះ ភិក្ខុជីករណ្ដៅ រមែងមិនផុត ។ បើរោគដែលកើតឡើងខាងក្រោយជារបស់មានកម្លាំងសោត, កាលអ្នកនោះស្លាប់ ព្រោះរោគដែលកើតឡើងខាងក្រោយ លោករួចខ្លួន ។

កាលអ្នកនោះស្លាប់ដោយរោគទាំង ២ ប្រភេទ មិនផុត ។ មនុស្សជាឧបបាតិកកើតឡើងក្នុងរណ្ដៅ កាលកើតហើយ មិនអាចនឹងឡើងបាន ក៏ស្លាប់ទៅ, ជាអាបត្តិបារាជិកដូចគ្នា ។

## មតិព្រះថេរៈពីររូបក្នុងការជីករណ្តៅ

ព្រះឧបតិស្សត្ថេរ ពោលថា កាលយក្ខជាដើម ធ្លាក់ទៅស្លាប់ក្នុងរណ្តៅដែលភិក្ខុជីកទុកចំពោះមនុស្ស មិនជាអាបត្តិ ។ ក្នុងមនុស្សជាដើមសូម្បីស្លាប់នៅក្នុងរណ្តៅ ដែលភិក្ខុជីកទុកចំពោះយក្ខជាដើម ក៏ន័យនុ៎ះឯង ។ តែជាទុក្កដដល់ភិក្ខុដែលជីកចំពោះយក្ខជាដើម ព្រោះការជីកខ្លះ ព្រោះបង្កទុក្ខឲ្យកើតឡើងដល់យក្ខជាដើមទាំងនោះខ្លះ, ព្រោះ(យក្ខជាដើម) ស្លាប់ជាថុល្លច្ច័យ ឬបារាជិកតាមអំណាចនៃវត្ថុតែម្តង ។ សត្វធ្លាក់ចុះក្នុងរណ្តៅដែលភិក្ខុជីកទុកមិនបានចំពោះដោយរូបយក្ខ ឬរូបប្រេតស្លាប់ទៅ ដោយរូបសត្វតិរច្ឆាន, ក៏រូបដែលធ្លាក់ទៅ រមែងជាប្រមាណ; ព្រោះដូច្នោះ ទើបជាថុល្លច្ច័យ ។

ព្រះបុស្សទេវត្ថេរ ពោលថា រូបដែលស្លាប់ជាប្រមាណ; ព្រោះដូច្នោះ ទើបជាបារាជិក ។ សូម្បីក្នុងសត្វធ្លាក់ទៅដោយរូបសត្វតិរច្ឆានហើយស្លាប់ដោយរូបយក្ខនិងរូបប្រេត ក៏ន័យនោះដូចគ្នា ។ ភិក្ខុដែលជីករណ្តៅលក់ ឬឲ្យទទេនូវរណ្តៅដល់ភិក្ខុដទៃ, ភិក្ខុនោះឯង ក៏នៅតែត្រូវអាបត្តិ និងមានការចងព័ន្ធមកកម្ម ព្រោះមានអ្នកធ្លាក់ស្លាប់ជាបច្ច័យ ។ អ្នកដែលបានរណ្តៅទៅ មិនមានទោសទេ ។ ភិក្ខុដែលបានរណ្តៅហើយគិតថា "រណ្តៅយ៉ាងនេះ សត្វដែលធ្លាក់ទៅអាចឡើងបាន

នឹងមិនវិនាស នឹងទ្រុឌទ្រោមឡើងបានឆាយ ទើបធ្វើរណ្តៅនោះឱ្យជ្រៅចុះទៅ ឬឱ្យរាក់ឡើង ឱ្យវែងចេញទៅ ឬឱ្យខ្លីចូល ឱ្យទូលាយចេញទៅ ឬឱ្យចង្អៀតចូល ត្រូវអាបត្តិ និងមានការចងព័ន្ធមកកម្មសូម្បីទាំង ២ រូប ។ កាលកើតវិប្បដិសារឡើងថា "មនុស្សសត្វនឹងស្លាប់ច្រើនគ្នា ទើបលុបរណ្តៅឱ្យពេញដោយដី ។ បើសត្វណា នៅធ្លាក់ទៅក្នុងអាចម៍ដីស្លាប់បាន, សូម្បីលុបឱ្យពេញហើយ ក៏មិនផុត ។ កាលភ្លៀងធ្លាក់មានភក់, សូម្បីកាលសត្វណា ជាប់ស្លាប់ក្នុងភក់នោះ, ដើមឈើដួលក្តី ខ្យល់បក់ក្តី ទឹកភ្លៀងធ្លាក់ក្តី បក់ផាត់នាំដីទៅ ឬពួកអ្នកជីកដីដើម្បីមើមដំឡូង ជីកជារណ្តៅអណ្តូងទុកក្នុងទីនោះ, បើសត្វណា ជាប់ ឬធ្លាក់ទៅស្លាប់ក្នុងរណ្តៅនោះ ភិក្ខុអ្នកផ្តើមមិនផុត ។ តែក្នុងឱកាសនោះ ភិក្ខុឱ្យធ្វើបឹង ឬស្រះឈូកជំឱ្យប្រតិស្ឋានចេតិយ ដាំដើមពោធិឬឱ្យសាងវត្ត ឬឱ្យធ្វើមករទេះហើយទើបផុតបាន ។ សូម្បីក្នុងកាលណា ដើមឈើជាដើម ។ ក្នុងរណ្តៅដែលត្រូវលុបពេញធ្វើឱ្យហាប់ហើយឬសនិងឬសជាប់ពាន់គ្នា, កើតជាតបវរ៍ សូម្បីក្នុងកាលនោះ ក៏ផុតបាន ។ បើសូម្បីទឹកស៊ីងហូរមកលុបរណ្តៅចេញ, សូម្បីយ៉ាងនោះ ទើបផុតបានឯង ។

ចប់ ការជីកណ្តៅត្រឹមប៉ុណ្ណេះ ។

# ការដាក់អន្ទាក់របស់ភិក្ខុ

ក៏គប្បីជ្រាបវិនិច្ឆ័យ សូម្បីក្នុងអន្ទាក់ជាដើម ដែលអនុលោមដល់វណ្តៅនោះដូចតទៅនេះ ៖

ភិក្ខុណា ដាក់អន្ទាក់ទុកមុន ដោយគិតថា សត្វទាំងឡាយនឹងជាប់ក្នុងអន្ទាក់នេះស្លាប់ កាលអន្ទាក់ល្ងមរួចផុតទៅចាកដៃ គប្បីជ្រាបថា ជាបារាជិក អនន្តរិយកម្ម ថុល្លច្ច័យ និងបាចិត្តិយ ដល់ភិក្ខុនោះពិតប្រាកដដោយអំណាចសត្វដែលជាប់ (អន្ទាក់) ។

ក្នុងអន្ទាក់ដែលភិក្ខុធ្វើចំពោះទុក មានវិនិច្ឆ័យដូច្នេះ ៖

អន្ទាក់ដែលភិក្ខុដាក់ចំពោះសត្វណាទុក ព្រោះសត្វពួកដទៃក្រៅពីសត្វនោះមកជាប់ មិនជាអាបត្តិ ។ សូម្បីកាលភិក្ខុចំណាយអន្ទាក់ទៅដោយមូលតម្លៃ ឬឱ្យទទេក៏ដោយ ការបង់ព័ន្ធមកកម្ម រមែងមានដល់ភិក្ខុដែលផ្តើមដូចគ្នា ។ បើភិក្ខុដែលបានអន្ទាក់ ដាក់អន្ទាក់បង្ខិតទីដែលបានទុកឬឃើញពួកសត្វដើរទៅខាង ៗ ទើបធ្វើរបងបាំងទុក កៀងសត្វឱ្យចូលទៅត្រង់មុខឬដាក់ដងអន្ទាក់ទុកឱ្យរឹងមាំ ឬ ចងខ្សែអន្ទាក់ទុកឱ្យមាំឡើង ឬបោះបង្គោលទុកឱ្យរឹងមាំ, លោកទាំង ២ រូបមិនផុត; បើកាលកើតសេចក្តីក្តៅក្រហាយឡើង លោកទើបរូតអន្ទាក់ឱ្យរបូតចេញហើយ ក៏ចៀសចេញទៅ ។ ពួកមនុស្សដទៃ ប្រទះឃើញអន្ទាក់ដែលរបូតចេញ

ហើយនោះ យកដាក់ទៀត, សត្វទាំងឡាយដែលជាប់ ( អន្ទាក់ ) ហើយ ៗ ស្លាប់ទៅ; ភិក្ខុដែលផ្តើម មិនរួចផុតទៅបានទេ ។ បើជង់អន្ទាក់ ដែលលោកអ្នកផ្តើមនោះ មិនបានធ្វើទុកខ្លួនឯង, តែដាក់ទុកក្នុងទីដែលខ្លួនទទួលមក រមែងផុត ។ លោកកាត់ឈើជង់អន្ទាក់ដែលកើតនៅក្នុងស្ថានទីនោះចេញ រមែងផុត ។ តែសូម្បីកាលលោករក្សាឈើជង់អន្ទាក់ដែលខ្លួនធ្វើនោះឯងទុក រមែងមិនផុត ។ ពិតមែន បើភិក្ខុដទៃកាន់យកឈើជង់អន្ទាក់នោះ ទៅដាក់អន្ទាក់ទុកទៀតសោត, កាលសត្វទាំងឡាយស្លាប់ទៅ ព្រោះមានការដាក់អន្ទាក់នោះជាបច្ច័យ ភិក្ខុដែលជាខាងដើម រមែងមិនផុត, បើលោកដុតជង់អន្ទាក់នោះ ធ្វើឱ្យជាគប់ភ្លើងហើយចោលចេញ, សូម្បីកាលសត្វទាំងឡាយស្លាប់ទៅ ព្រោះមានការដាក់អន្ទាក់នោះជាបច្ច័យ ភិក្ខុដែលជាខាងដើម រមែងមិនផុត, បើលោកដុតជង់អន្ទាក់នោះ ធ្វើឱ្យជាគប់ភ្លើងហើយចោលចេញ, សូម្បីកាលសត្វទាំងឡាយ បានការប្រហារដោយគប់ភ្លើងនោះស្លាប់ទៅ រមែងមិនផុត ។ តែដុត ឬធ្វើឱ្យវិនាសអស់ទៅដោយប្រការទាំងពួង រមែងផុត ។ លោកដាក់សូម្បីខ្សែអន្ទាក់ដែលអ្នកដទៃវេញរួចហើយក្នុងទីដែលខ្លួនទទួលមក រមែងផុត ។ លោកបានខ្សែមកហើយ លាផ្លូងដែលគេវេញទុកដោយខ្លួនឯង ( ឬ ) ធ្វើខ្សែដែលខ្លួនបានសំបកធ្មៃមកហើយវេញទុក ឱ្យជាកំណាត់តូចនិងធំ រមែងផុត ។ តែសូម្បីកាលលោកថែរក្សាខ្សែដែលខ្លួនឯងនាំ

ផ្ទៃមកពីព្រៃវិញទុក រមែងមិនផុត ។ តែដុតឬធ្វើឱ្យវិនាសអស់ទៅដោយប្រការទាំងពួង រមែងផុត ។

## ការប្រើអង្គប់ដាក់សត្វរបស់ភិក្ខុ

ភិក្ខុកាលចាត់ចែងអន្ទប់ ដាក់គ្រែអន្ទប់ទុកលើជើងទាំង ៤ លើកថ្មឡើងជាទុក្កដ គ្រប់ ៗ ប្រយោគ ។ កាលធ្វើការត្រៀមគ្រប់យ៉ាងហើយ លួមអន្ទប់ផុតទៅចាកដៃ គប្បីជ្រាបថា ជាបារាជិកជាដើម តាមសមគួរដល់ប្រយោគដែលធ្វើចំពោះនិងមិនចំពោះ ដោយអំណាចនៃពួកសត្វដែលនឹងគប្បីត្រូវសង្កត់ពិតប្រាកដ ។ សូម្បីកាលភិក្ខុចំណាយអន្ទប់ដោយមូលតម្លៃឬឱ្យទទេក៏ដោយ ការបង់ព័ន្ធមកកម្ម រមែងមានដល់ភិក្ខុដែលផ្តើមតែម្តង ។ បើភិក្ខុដែលបានអន្ទប់ទៅ លើកអន្ទប់ដែលធ្លាក់ឡើងទុក ឬសូម្បីលើកដុំថ្មដទៃឡើងធ្វើឱ្យមានទឹកធ្ងន់ជាង ឬ ឃើញពួកសត្វដើរទៅខាង ៗ ធ្វើរបងការពារទុកកៀងសត្វឱ្យចូលទៅត្រង់អន្ទប់; លោកទាំង ២ រូប រមែងមិនផុត ។ បើកាលកើតសេចក្តីក្តៅក្រហាយឡើង លោកទើបធ្វើអន្ទប់ឱ្យធ្លាក់ហើយ បេញទៅ ។ ភិក្ខុដទៃប្រទះឃើញអន្ទប់ដែលធ្លាក់ហើយនោះ ក៏ដាក់ទុកម្តងទៀត, ភិក្ខុដែលផ្តើមមិនផុត ។ ភិក្ខុដាក់ដុំថ្មទុកក្នុងទីដែលខ្លួនទទួលមក និងដាក់ជើងអន្ទប់ទុកក្នុងទីដែលខ្លួនទទួលមក ឬដុតដោយន័យដូចពោលទុកហើយក្នុងជង

អន្ទាក់ រមែងផុត ។ សូម្បីកាលភិក្ខុបោះចម្រូង ល្មមធ្វើការត្រៀមគ្រប់យ៉ាងសម្រេចហើយ ផុតពីដៃ គប្បីជ្រាបថា ជាអាបត្តិបារាជិកជាដើម ដោយសមគួរដល់ប្រយោគដែលធ្វើចំពោះ និងមិនចំពោះ ដោយអំណាចនៃពួកសត្វដែលនឹងធ្លាក់ទៅតាមលើមុខចម្រូងនោះឯង ។ សូម្បីកាលភិក្ខុចំណាយចម្រូង ដោយមូលតម្លៃ ឬឱ្យទទេក៏ដោយ ការចងព័ន្ធមកកម្ម រមែងមានដល់ភិក្ខុដែលផ្តើមដូចគ្នា ។ បើភិក្ខុដែលបានចម្រូងទៅសំលៀងចម្រូងឱ្យមុត ដោយគិតថា "សត្វទាំងឡាយ នឹងស្លាប់ដោយការប្រហារម្តងប៉ុណ្ណោះ" ឬទាញចម្រូងឱ្យផាកចូល ដោយគិតថា "សត្វទាំងឡាយ នឹងស្លាប់ជាទុក្ខ" ឬកំណត់ថា "ចម្រូងខ្ពស់ពេក" បោះឱ្យទាបចុះ ឬកំណត់ថា "ចម្រូងទាបពេក" បោះឱ្យខ្ពស់ឡើងទៀត ឬពត់កន្លែងកោងឱ្យត្រង់ ឬពត់កន្លែងត្រង់ពេក ឱ្យកោងបន្តិច; លោកទាំង ២ រូប មិនផុត ។ ក៏បើលោកឃើញថា "ទុកក្នុងទីមិនសមគួរ" ហើយយកទៅបោះទុកក្នុងទីដទៃ បើចម្រូងនោះ រមែងជារបស់ដែលលោកស្វែងរកមកធ្វើទុកតាំងពីដំបូង ដើម្បីត្រូវការសម្លាប់ឱ្យស្លាប់; ភិក្ខុដែលផ្តើម មិនផុត ។

តែកាលមិនបានស្វែងរក បានរបស់ដែលគេធ្វើទុកហើយនុ៎ះឯងលើកឡើង ។ ភិក្ខុដែលផ្តើម រមែងផុត ។ កាលកើតសេចក្តីក្តៅក្រហាយឡើង លោកដាក់ចម្រូងទុកក្នុងទីដែលខ្លួនទទួលមក ឬដុតចោល តាមន័យដូចពោលទុកហើយក្នុងជងអន្ទាក់ រមែងផុត ។

## លបដាក់សស្ត្រាទុកក្នុងវត្ថុសម្រាប់ផ្អែក

[១៩៧] ក្នុងពាក្យថា អបស្សេនេ សត្ថំ វា : សាស្ត្រាក្នុងទីបង្អែកក្តី នេះ មានវិនិច្ឆ័យដូច្នេះ ៖

ឈ្មោះថា ទីផ្អែក បានដល់ គ្រែ ឬតាំង ឬក្តារសម្រាប់ផ្អែកដែលប្រើជានិច្ច ឬសរសរសម្រាប់ផ្អែករបស់ភិក្ខុដែលអង្គុយសម្រាកក្នុងទីសម្រាកពេលថ្ងៃ ឬដើមឈើដែលកើតនៅក្នុងទីនោះ ឬដើមឈើសម្រាប់តោងឈោងឡើង របស់ភិក្ខុដែលឈរផ្អែកនៅក្នុងទីចង្ក្រម ឬក្តារសម្រាប់តោងឈោងឡើង វត្ថុមានគ្រែជាដើមនោះសូម្បីទាំងអស់ឈ្មោះថា ទីផ្អែក ព្រោះអត្ថថា ជាទីតាំងនៃការផ្អែក (ជាទីតាំងនៃការមើលមិនឃើញ) ។ ភិក្ខុធ្វើដូចមនុស្សចោក់ ឬកាប់បុគ្គលដែលមិនឃើញ ដាក់បណ្តាសាស្ត្រាមួយប្រភេទ មានកាំបិត ពូថៅ លំពែង ដែកស្រួច និងបន្លាជាដើមទុកក្នុងទីសម្រាប់ផ្អែកនោះ ជាទុកដូ ។ កាលអ្នកអស់សេចក្តីសង្ស័យអង្គុយ ឬដេក ឬផ្អែកនៅក្នុងស្ថានទីប្រើប្រចាំ ជាថុល្លច្ច័យ ព្រោះបង្កទុក្ខឱ្យកើតឡើងដែលមានការប៉ះត្រូវសស្ត្រាជាបច្ច័យ, ជាបារាជិកព្រោះគេស្លាប់ ។ បើភិក្ខុដែលមានពៀររបស់លោកនោះសូម្បី

រូបដទៃ ត្រាច់ចារិកទៅក្នុងវិហារ ប្រទះឃើញសស្ត្រានោះហើយ ត្រេកអរថា "មុខជាសស្ត្រានេះជារបស់ដែលលោករូបនេះដាក់ទុក ដើម្បីជាគ្រឿងសម្លាប់, ល្អណាស់ចូរស្លាប់ឱ្យស្អិទចុះ" ដើរទៅ ជាទុក្កដ ៗ តែបើភិក្ខុដែលមានពៀរសូម្បីរូបនោះ គិតថា "កាលលោកធ្វើសស្ត្រានោះទុកយ៉ាងនោះហើយ នឹងជាការលោកធ្វើទុកល្អហើយ" ទើបធ្វើកម្មយ៉ាងណាមួយដោយការធ្វើសស្ត្រាឱ្យមុតជាដើម, ជាបារាជិក សូម្បីដល់លោកអ្នកមានពៀររូបនោះ, តែបើភិក្ខុដែលមានពៀរឃើញថា "លោករូបនោះដាក់សស្ត្រាទុកក្នុងទីមិនសមគួរ" ទើបលើកឡើងមកដាក់ទុកក្នុងទីដទៃ, កាលលោកធ្វើហើយដាក់ទុក ដើម្បីប្រយោជន៍នោះ ៗ ឯង ភិក្ខុដែលផ្ដើមរមែងមិនផុត ។ ភិក្ខុបានសស្ត្រាហើយដាក់ទុកតាមប្រក្រតីពីដើម រមែងផុត ។

ភិក្ខុនាំសស្ត្រានោះចេញទៅ ហើយទើបយកសស្ត្រាដទៃដែលមុតជាង មកដាក់ទុកជំនួស; ភិក្ខុជាអ្នកផ្ដើម រមែងមិនផុតដូចគ្នា (ព្រោះសស្ត្រាមុនជាហេតុ) ។

## លបដាក់ថ្នាំពិសទុកក្នុងភេសជ្ជៈ

សម្បីក្នុងការលាបថ្នាំពិសទុក មានវិនិច្ឆ័យដូច្នេះ ៖

ជាទុក្កដ ព្រោះគេត្រេកអរសេចក្ដីស្លាប់ ដរាបដល់ន័យនេះដូចគ្នា ។ ក៏បើភិក្ខុសម្បីរូបនោះកំណត់ទុកថា "ដុំថ្នាំពិសតូចពេក" ទើបធ្វើឱ្យធំឡើង, ឬកំណត់បានថា "ដុំថ្នាំពិសធំពេក ឬក្រាសពេកណាស់" ទើបធ្វើឱ្យតូច, ឬស្ដើងវិញ ទើបធ្វើឱ្យក្រាស់ ឬក្រាស់ពេក ទើបធ្វើឱ្យស្ដើងវិញ, ហើយរោលឱ្យក្ដៅដោយភ្លើង ធ្វើឱ្យសាយទៅខាងក្រោមឬខាងលើ; ជាបារាជិកសម្បីដល់ភិក្ខុនោះ ។ លោកឃើញថា "ដុំថ្នាំពិសនេះ ដាក់ទុកក្នុងទីមិនសមគួរ" ទើបកៀសដាក់ឱ្យស្ដើងគ្រប់ចំណែកតែម្ដង ហើយជូតដុស (ឱ្យរលោង) យកទុកក្នុងទីដទៃ ។

កាលភិក្ខុផ្សំថ្នាំដោយខ្លួនឯង ហើយចាក់ថ្នាំពិសចូលផង ភិក្ខុដែលជាខាងដើម រមែងមិនផុត កាលខ្លួនឯងមិនបានធ្វើ រមែងផុត, តែបើភិក្ខុនោះឃើញថា "ថ្នាំពិសនេះមានតិចពេក" ទើបនាំយកថ្នាំពិសសម្បីដទៃមកដាក់ថែមទៀត, ជាបារាជិកដល់ភិក្ខុម្ចាស់របស់ថ្នាំពិសដែលជាហេតុឱ្យគេស្លាប់ ។ បើគេស្លាប់ទៅព្រោះថ្នាំពិសដែលជារបស់ភិក្ខុទាំង ២ រូប ក៏ជាបារាជិកដល់លោកសម្បីទាំង ២ រូប ។ ភិក្ខុឃើញថា ថ្នាំពិសនេះអស់ជាតិហើយ ទើបនាំថ្នាំពិសនោះចេញ ហើយដាក់ថ្នាំពិសរបស់ខ្លួនទុកជំនួស; ជាបារាជិកដល់ភិក្ខុនោះប៉ុណ្ណោះ, ភិក្ខុអ្នកផ្ដើម រមែងរួចខ្លួន ។

## កប់អាវុធទុកក្រោមគ្រែ ប ្តាំង

ពីរបទថា ឱពាតំ វា ករោតិ : ធ្វើឱ្យទ្រុឌទ្រោមក្តី សេចក្តីថា ភិក្ខុកាត់គ្រែនិងតាំងខាងក្រោមមេគ្រែ ឬកាត់ផ្តៅ និងខ្សែដែលគេវិញទុក ធ្វើឱ្យនៅសល់បន្តិចបន្តួចប៉ុណ្ណោះ ទើបសិកអាវុធទុកខាងក្រោម, លោកកាត់ចំណែកដទៃសូម្បីនៃវត្ថុ មានក្តារសម្រាប់ផ្អែកជាដើម ដែលមានដើមឈើនិងក្តារសម្រាប់តោងឈោងឡើងក្នុងទីចង្រ្កមជាទីបំផុត ហើយយកអាវុធសិកទុកខាងក្រោម ដោយប្រាថ្នាថា "មនុស្សនឹងធ្លាក់ស្លាប់ត្រង់អាវុធនេះ" ។ ភិក្ខុនាំគ្រែតាំង ឬក្តារសម្រាប់ផ្អែកមកដាក់ទុកជិតអណ្តូងជាដើម ដោយប្រការដែលមនុស្សល្ហមអង្គុយឬផ្អែកលើគ្រែជាដើមនោះក៏នឹងធ្លាក់ចុះទៅ, ឬធ្វើស្ពានសម្រាប់ដើរទៅមកលើអណ្តូងជាដើមឱ្យទ្រុឌទ្រោម, កាលភិក្ខុធ្វើយ៉ាងនោះ ជាទុក្កដ ព្រោះធ្វើ, ជាថុល្លច្ច័យ ព្រោះបង្កទុក្ខឱ្យកើតឡើងដល់មនុស្សក្រៅនេះ, ជាបារាជិក ព្រោះគេស្លាប់ ។ ភិក្ខុនាំយកភិក្ខុផងគ្នាទៅហើយឱ្យឈប់ជិតមាត់អណ្តូងជាដើម ដោយគិតថា "លោកឃើញហើយភ័យរន្ធត់ ព្រោះខ្លាច នឹងធ្លាក់ស្លាប់" ដូច្នេះ ជាទុក្កដ ។ លោកធ្លាក់ទៅយ៉ាងនោះពិត ៗ, ជាថុល្លច្ច័យ ព្រោះបង្កទុក្ខឱ្យកើតឡើង, ជាបារាជិក ព្រោះលោកស្លាប់ ។ ខ្លួនឯងប្រានភិក្ខុនោះឱ្យធ្លាក់ទៅ, ប្រើអ្នកដទៃឱ្យប្រានធ្លាក់ទៅ, អ្នកដទៃមិនបានបង្គាប់

ឡើយប្រាប់ឱ្យធ្លាក់ទៅ ដោយធម្មតារបស់ខ្លួន, អមនុស្សប្រាប់ឱ្យធ្លាក់ចុះទៅ, ធ្លាក់ទៅព្រោះត្រូវខ្យល់បក់, ធ្លាក់ទៅតាមធម្មតារបស់ខ្លួន; ជាបារាជិក ព្រោះការស្លាប់របស់អ្នកនោះគ្រប់ករណី ។ ព្រោះហេតុអ្វី ? ព្រោះអ្នកស្លាប់នៅជិតមាត់អណ្តូងជាដើម ដោយប្រយោគរបស់ភិក្ខុដែលជាអ្នកផ្តើមនោះ ។

## ការបង្កប់ចម្រូង

[១៩៨] ការដាក់ (ដាវជាដើម) ទុកក្នុងទីជិត ឈ្មោះថា ការបង្កប់ចម្រូង ។ ក្នុងការបង្កប់ចម្រូងនោះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណាពណ៌នាគុណនៃសេចក្តីស្លាប់ ដោយន័យជាដើមថា "អ្នកណាស្លាប់ដោយដាវនេះ អ្នកនោះនឹងបានទ្រព្យ"ក្តី និយាយថា "អ្នកត្រូវការស្លាប់ចូរស្លាប់ដោយដាវនេះ"ក្តី និយាយថា "អ្នកត្រូវការស្លាប់ ចូរឱ្យគេសម្លាប់ដោយដាវនេះ"ក្តី ហើយកប់ដាវទុក, ជាទុក្កដដល់ភិក្ខុនោះ ក្នុងការកប់ទុក ។ បុគ្គលដែលចង់ស្លាប់ នឹងប្រើដាវនោះប្រហារខ្លួនឯងក៏ដោយ អ្នកមានសេចក្តីប្រាថ្នានឹងប្រើឱ្យអ្នកដទៃសម្លាប់ នឹងយកដាវនោះប្រហារអ្នកដទៃក៏ដោយ, សូម្បីដោយវិធីទាំង ២ ជាថុល្លច្ច័យដល់ភិក្ខុដែលកប់ ព្រោះបង្កទុក្ខឱ្យកើតឡើងដល់បុគ្គលដទៃ, ជាបារាជិក ព្រោះគេស្លាប់ ។ កាលភិក្ខុដាក់ទុកមិនចំពោះជាកងអកុសល ព្រោះមនុស្សនិង

សត្វជាច្រើនស្លាប់ ។ ជាបារាជិកជាដើម ព្រោះវត្ថុនៃបារាជិកជាដើម ។ ភិក្ខុនោះ កាលកើតសេចក្តីក្តៅក្រហាយឡើង ទើបរក្សាដាវទុកក្នុងទីដែលខ្លួនទទួលមក រមែងផុត ។ លោកទិញដាវមក, លោកសងដាវឱ្យដល់ម្ចាស់របស់ដាវ ឱ្យមូលតម្លៃដល់ពួកជនដែលខ្លួនទទួលយកមូលតម្លៃមកអំពីដៃរបស់គេហើយ រមែងផុត ។ បើភិក្ខុយកដុំលោហៈ ឬផាល ឬចបទៅឱ្យជាងធ្វើជាដាវ, កាន់យកភណ្ឌៈណាមក ឱ្យធ្វើដាវ កាលធ្វើត្រឡប់ឱ្យជាភណ្ឌៈនោះដូចដើម ហើយទើបផុត ។ បើភិក្ខុញាំងដាវដែលយកចបមកឱ្យជាងធ្វើ ឱ្យវិនាសអស់ទៅ ហើយធ្វើឱ្យជាផាល, សូម្បីកាលសត្វជាច្រើនបានការប្រហារដោយផាលស្លាប់ទៅ ភិក្ខុនោះ រមែងមិនផុតពីបាណាតិបាត ។ តែបើលោកឱ្យរំលាយលោហៈហើយឱ្យជាងធ្វើជាដាវ ដើម្បីការកប់ទុំុះឯង, កាលដាវដែលលោកយកចុងដែកកូតកោសហើយធ្វើឱ្យខ្ទេចខ្ទីវិនាសខូចទៅ លោកទើបរួចផុត ។ សូម្បីបើជាដាវដែលភិក្ខុច្រើនរូបរួមអធ្យាស្រ័យគ្នាធ្វើទុក ដូចជាស្លឹករឹតដែលសរសេរពណ៌នា (គុណនៃសេចក្តីស្លាប់) ទុកដូច្នោះ, វិនិច្ឆ័យដល់ការត្រូវចងព័ន្ធមកកម្ម គប្បីជ្រាបដោយន័យដូចពោលហើយក្នុងស្លឹករឹតនុ៎ះឯង ។ ក្នុងលំពែងនិងច្បូកក៏ន័យនេះ ។ ក្នុងចម្រូង និងឈើអន្ទងមានវិនិច្ឆ័យដូចពោលហើយក្នុងឈើដងអន្ទាក់ ។ ក្នុងថ្មក៏យ៉ាងនោះ ។

ក្នុងសស្ត្រាក៏មានវិនិច្ឆ័យដូចដាវនុ៎ះឯង ។

## ការបង្កប់ថ្នាំពិសទុកជាដើម

បទថា វិសំ វា : ថ្នាំពិសក្តី សេចក្តីថា កាលភិក្ខុបង្កប់ថ្នាំពិសទុក គប្បីជ្រាបថា ជាបារាជិកជាដើម ក្នុងវត្ថុនៃបារាជិកជាដើម សមគួរដល់ការចំពោះនិងមិនចំពោះ ដោយអំណាចនៃវត្ថុ ។ ក្នុងថ្នាំពិសដែលភិក្ខុទិញមករក្សាទុក លោកធ្វើឱ្យជាប្រក្រតីដើមដោយន័យមុនហើយទើបផុតបាន ។ កាលភិក្ខុផ្សំថ្នាំពិសចូលទឹងភេសជ្ជៈដោយខ្លួនឯងលោកធ្វើមិនឱ្យជាថ្នាំពិសហើយទើបផុតបាន ។ ក្នុងខ្សែមានវិនិច្ឆ័យដូចគ្នាដោយខ្សែអន្ទាក់ទុំះឯង ។

[១៩៩] ក្នុងភេសជ្ជៈ វិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណា កាលភិក្ខុដែលមានពៀរកើតជម្ងឺ ឬរោគមានចំណែកជាពិសឡើង មានសេចក្តីប្រាថ្នានឹងឱ្យស្លាប់ ប្រាប់ថា "វត្ថុមានទឹកដោះថ្លាជាដើម ជាទីសប្បាយ" ដូច្នេះ ទើបប្រគេនភេសជ្ជៈសូម្បីដែលជាទីមិនសប្បាយ ឬក្រអៅឈូក ឬសណ្ដើ និងផ្លែឈើប្រភេទដទៃយ៉ាងណាមួយ, គប្បីជ្រាបថា ជាទុក្កដដល់ភិក្ខុនោះ ព្រោះការប្រគេនភេសជ្ជៈយ៉ាងនោះ, ជាថុល្លច្ច័យ និងបារាជិក ព្រោះការបង្កទុក្ខឱ្យកើតឡើងដល់អ្នកដទៃ និងព្រោះគេស្លាប់, ជាអនន្តរិយកម្ម ក្នុងវត្ថុនៃអនន្តរិយកម្ម ។

# ការនាំរូបនិងសំឡេងជាដើមចូលទៅ

[២០០] ក្នុងការនាំរូបចូលទៅ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **ឧបសំហរតិ : ភិក្ខុនាំយក(រូប)** សេចក្តីថា ភិក្ខុនាំមនុស្សដទៃដែលមានរូបមិនគួរពេញចិត្តមកទុកក្នុងទីជិត ៗ បុគ្គលនោះឬលោកប្លែងភេទជាយក្ខ និងប្រេតជាដើម ដោយខ្លួនឯងហើយឈរឈ្មមកាលនាំរូបចូលទៅ ជាទុក្កដដល់ភិក្ខុនោះ, ជាថុល្លច្ច័យ ក្នុងការបង្កភ័យឱ្យកើតឡើងដល់អ្នកដទៃ ព្រោះឃើញរូបនោះ, ជាបារាជិក ព្រោះគេស្លាប់ ។ តែបើរូបនោះឯង រមែងជាទីពេញចិត្តរបស់អ្នកខ្លះសោត, និងគេរមែងរីងរៃស្គមស្គាំងស្លាប់ ព្រោះមិនបាន (រូបនោះ) រមែងខុសសង្កេត ។ សូម្បីក្នុងរូបដែលជាទីពេញចិត្ត ក៏មានន័យដូចគ្នានេះ ។

ក៏បណ្តារូបដែលជាទីពេញចិត្តទាំងនោះ ពោលដោយពិសេស រូបបុរស រមែងជាទីពេញចិត្តរបស់ពួកស្ត្រី និងរូបស្ត្រី រមែងជាទីពេញចិត្តរបស់ពួកបុរស ។ ភិក្ខុតាក់តែងរូបនោះហើយក៏នាំចូលទៅ គឺ ធ្វើត្រឹមតែឱ្យគេឃើញប៉ុណ្ណោះ, តែមិនព្រមឱ្យសូម្បីដើម្បីនឹងមើលយូរ ៗ ។ បុគ្គលក្រៅនេះ រមែងស្គមស្គាំងស្លាប់ព្រោះមិនបាន (រូបនោះ), ភិក្ខុជាបារាជិក, បើគេស្ងួតចិត្តស្លាប់ រមែងខុសសង្កេត ។ តែបើភិក្ខុមិនពិចារណាឡើយថា "គេនឹងស្ងួតចិត្តស្លាប់ ឬនឹងស្គមស្គាំងស្លាប់ ព្រោះ

មិនបាន” នាំចូលទៅដោយគិតតែម្យ៉ាងថា “គេឃើញហើយនឹងស្លាប់” ដូច្នេះ, កាលគេស្លុតចិត្តស្លាប់ ឬស្គមស្គាំងស្លាប់ ជាបារាជិកដូចគ្នា ។ សូម្បីកិច្ចទាំងឡាយ មានការនាំសំឡេងចូលទៅជាដើម ក៏គប្បីជ្រាបដោយឧបាយនេះឯង ។

ពិតមែន ក្នុងសំឡេងជាដើមនេះ (មានសេចក្តីប្លែកគ្នា)តែម្យ៉ាងគឺ (អារម្មណ៍ខាងក្រៅ) មានសំឡេងរបស់អមនុស្សជាដើម គប្បីជ្រាបថា ជាហេតុឱ្យកើតសេចក្តីតក់ស្លុតជាវត្ថុដែលមិនពេញចិត្ត, សំឡេងស្ត្រីនិងសំឡេងរបស់អ្នករបាំដែលពីរោះជាដើម គប្បីជ្រាបថា ធ្វើសេចក្តីរីករាយសប្បាយចិត្តឱ្យ ជាសំឡេងដែលពេញចិត្ត, ក្លិននៃឫសឈើជាដើមរបស់ដើមឈើដែលមានពិស ក្នុងព្រៃហិមពាន្តនិងក្លិននៃសាកសព គប្បីជ្រាបថា ជាក្លិនដែលមិនពេញចិត្ត, ក្លិនដែលកើតពីឫសឈើមានក្រឹស្នានិងកំញានជាដើម គប្បីជ្រាបថា ជាក្លិនដែលពេញចិត្ត រសដែលកើតពីឫសឈើដែលបដិកូលជាដើម គប្បីជ្រាបថា ជារសដែលមិនពេញចិត្ត, រសដែលកើតពីឫសឈើដែលមិនបដិកូលជាដើម គប្បីជ្រាបថា ជារសដែលពេញចិត្ត, សម្ផស្សថ្នាំពិស និងសម្ផស្សខែឥធំជាដើម គប្បីជ្រាបថា ជាផោដ្ឋព្វៈដែលមិនពេញចិត្ត, សម្ផស្សសំពត់ដែលត្បាញក្នុងប្រទេសចិន រោមស្លាបហង្សនិងសំឡីគសំឡីកប្បាសជាដើម គប្បីជ្រាបថា ជាផោដ្ឋព្វៈដែលពេញចិត្ត ។

## ការនាំធម្មារម្មណ៍ចូលទៅ

ក្នុងការនាំធម៌ចូលទៅ មានវិនិច្ឆ័យដូច្នេះ ៖

ទេសនាធម៌ គប្បីជ្រាបថា ធម៌ ។ ម្យ៉ាងទៀត ធម្មារម្មណ៍នោះឯង ដែលមានសេចក្ដីវិបត្តិក្នុងនរក និងសម្បត្តិក្នុងសួគ៌, ដោយអំណាចនៃទេសនា (ក៏គប្បីជ្រាបថា ធម៌) ។

បទថា **ណេរយិកានំ** : នៃសត្វដែលទៅកើតក្នុងនរក បានដល់ ពោលកថាពណ៌នារឿងនរក មានចំណង ៥ យ៉ាង និងគ្រឿងកម្មករណ៍ជាដើម ដល់សត្វដែលខូចសំវរៈ ធ្វើបាបទុកដែលគួរកើតក្នុងនរក ។ បើគេស្ដាប់និយាយកថានោះស្ងួតចិត្តស្ងាប់, ជាបារាជិកដល់ភិក្ខុដែលពោល ។ តែបើសូម្បីគេស្ដាប់ហើយ ស្ងាប់ទៅតាមធម្មតារបស់ខ្លួន, មិនជាអាបត្តិ ។ ភិក្ខុសម្ដែងនិយាយកថាដោយតាំងចិត្តថា អ្នកនេះបានស្ដាប់និយាយកថានេះហើយ "នឹងមិនធ្វើកម្មបែបនេះនឹងឈប់ នឹងវៀរ" បុគ្គលក្រៅនេះ ស្ដាប់និយាយកថានោះ ស្ងួតចិត្តស្ងាប់, មិនជាអាបត្តិ ។

បទថា **សគ្គកថំ** : អំពីរឿងស្ថានសួគ៌, បានដល់ ពោលកថាពណ៌នាសម្បត្តិនៃរបស់មានវិញ្ញាណមានទេពអប្សរជាដើម និងរបស់មិនមានវិញ្ញាណ មានសួននន្ទវ័នជាដើម ។ បុគ្គលក្រៅនេះបានស្ដាប់សគ្គកថានោះ បង្អោនចិត្តទៅក្នុងសួគ៌ត្រូវការបានសម្បត្តិនោះឆាប់ ៗ

ញុំាងទុក្ខឱ្យកើតឡើង ដោយប្រើសស្ត្រាប្រហារ ស៊ីថ្នាំពិស អត់អាហារ និងសង្កត់ខ្យល់អស្សាសៈបស្សាសៈជាដើម, ជាអាបត្តិថុល្លច្ច័យដល់ភិក្ខុអ្នកពោល ។ គេស្លាប់ទៅ ជាបារាជិកដល់ភិក្ខុដែលពោល ។ តែបើសូម្បីគេស្លាប់ហើយ តាំងនៅរហូតដល់អស់អាយុហើយ ទើបស្លាប់តាមធម្មតារបស់ខ្លួន, មិនជាអាបត្តិ ។ ភិក្ខុពោលដោយតាំងចិត្តថា "អ្នកនេះបានស្លាប់សគ្គកថានេះហើយនឹងធ្វើបុណ្យ" បុគ្គលក្រៅនេះស្លាប់សគ្គកថានោះហើយ អត់ដង្ហើមធ្វើកាលកិរិយា, មិនជាអាបត្តិ (ដល់អ្នកពោល) ។

[២០១] ក្នុងការបង្គាប់ឱ្យស្លាប់[១] មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា **បុដ្ឋោ ភណតិ : មនុស្សសួរភិក្ខុ ភិក្ខុឆ្លើយ** មានសេចក្ដីថា ភិក្ខុត្រូវគេសួរយ៉ាងនេះថា "លោកម្ចាស់ បុគ្គលស្លាប់យ៉ាងណា ទើបបានទ្រព្យ ឬនឹងកើតក្នុងឋានសួគ៌, ?" ដូច្នេះ ទើបប្រាប់ ។

ក្នុងការប្រៀនប្រដៅ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **អបុដ្ឋោ : គេមិនបានសួរទេ** បានដល់ មិនត្រូវគេសួរយ៉ាងនោះ ប្រាប់ដោយខ្លួនឯងប៉ុណ្ណោះ ។

[២០២] សង្កេតកម្មនិងនិមិត្តកម្ម គប្បីជ្រាបតាមន័យដែលពោលមកហើយ ក្នុងអទិន្នាទានកថា ។

---

១. ការឆ្លើយប្រាប់ឱ្យស្លាប់ ក៏បាន ។

# ពោលអំពីអនាបត្តិវារ

[២០៣] ព្រះឧបាលីថេរៈ ត្រាស់សម្តែងប្រភេទរបស់អាបត្តិដោយប្រការផ្សេង ៗ យ៉ាងនោះហើយ ឥឡូវនេះ កាលនឹងសម្តែងអានាបត្តិ ទើបពោលពាក្យថា អនាបត្តិ អសញ្ចិច្ច ជាដើម ។

បណ្តាបទទាំងនោះ បទថា អសញ្ចិច្ច : ភិក្ខុមិនក្លែង បានដល់ មិនបានគិតថា យើងនឹងសម្លាប់អ្នកនេះ ដោយសេចក្តីព្យាយាមនេះ ។ ពិតមែន កាលអ្នកដទៃសូម្បីស្លាប់ទៅដោយសេចក្តីព្យាយាមដែលខ្លួនមិនបានគិតធ្វើយ៉ាងនោះ មិនជាអាបត្តិ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុ (បើ)មិនក្លែង មិនត្រូវអាបត្តិទេ" ។

បទថា អជានន្តស្ស : ភិក្ខុមិនដឹង បានដល់ មិនដឹងថា អ្នកនេះនឹងស្លាប់ដោយសេចក្តីព្យាយាមនេះ ។ កាលអ្នកដទៃសូម្បីស្លាប់ទៅដោយសេចក្តីព្យាយាម មិនជាអាបត្តិ ។ ដូចព្រះមានព្រះភាគត្រាស់ទុកក្នុងរឿងបិណ្ឌបាតលាយដោយថ្នាំពិសថា "ម្នាលភិក្ខុ (បើ)មិនដឹង មិនត្រូវអាបត្តិ" ។

ពាក្យថា ន មរណាធិប្បាយស្ស : ភិក្ខុមិនប្រាថ្នាឱ្យស្លាប់ បានដល់ មិនមានបំណងនឹងឱ្យស្លាប់ ។ ពិតមែន អ្នកដទៃនឹងស្លាប់ដោយសេចក្តីព្យាយាមណា, កាលអ្នកនោះ សូម្បីត្រូវសម្លាប់ស្លាប់ដោយសេចក្តី

ព្យាយាមនោះ មិនជាអាបត្តិដល់ភិក្ខុដែលមិនប្រាថ្នានឹងឱ្យស្លាប់ ដូចព្រះមានព្រះភាគត្រាស់ទុក(ក្នុងរឿងឆ្លង និងពោលសត្ថកថាជាដើម)ថា "ម្នាលភិក្ខុទាំងឡាយ អាបត្តិមិនមានដល់ភិក្ខុដែលមិនមានបំណងនឹងសម្លាប់ទេ" ។ ភិក្ខុឆ្កួតជាដើម មានន័យដូចពោលហើយក្នុងសេចក្តីខាងដើមនុ៎ះឯង ។ ក៏ឯភិក្ខុទាំងឡាយអ្នកសម្លាប់គ្នានិងគ្នាជាដើមបញ្ញត្តិក្នុងសិក្ខាបទនេះ មិនជាអាបត្តិដល់ភិក្ខុទាំងនោះ ។ តែគង់ជាអាបត្តិដល់ភិក្ខុទាំងឡាយដ៏សេសមានភិក្ខុដែលពណ៌នាគុណនៃសេចក្តីស្លាប់ជាដើមនោះឯង ។

បទភាជនីយវណ្ណនា ចប់

## តតិយបារាជិកសិក្ខាបទ មានសមុដ្ឋាន ៣

ក្នុងសមុដ្ឋានជាដើម មានវិនិច្ឆ័យដូច្នេះ ៖

សិក្ខាបទនេះ មានសមុដ្ឋាន ៣ គឺ កើតអំពីកាយចិត្ត ១ វាចាចិត្ត ១ កាយវាចាចិត្ត ១, ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្ម វចីកម្ម ជាអកុសលចិត្ត ជាទុក្ខវេទនា ។ ពិតមែន បើសូម្បីព្រះរាជាស្តេចឡើងកាន់ព្រះក្រឡាបន្ទំដ៏មានសិរី សោយសុខក្នុងរាជសម្បត្តិ កាលរាជបុរសក្រាបទូលថា "បពិត្រសម្មតិទេព ចោរត្រូវនាំមកហើយ" ត្រាស់ទាំងដែលទ្រង់រីករាយថា "ចូរទៅសម្លាប់

វាចោលចុះ” ព្រះរាជានោះ បណ្ឌិតគប្បីជ្រាបថា ត្រាស់ដោយព្រះហឫទ័យអាស្រ័យទោមនស្សនុ៎ះឯង ។ តែព្រះហឫទ័យដែលអាស្រ័យទោមនស្សនោះ ដែលបុថុជ្ជនទាំងឡាយដឹងបានលំបាក ព្រោះលាយដោយសេចក្ដីសុខ និងព្រោះមិនជាប់តគ្នា (ក្នុងវិថីនៃទោមនស្ស) ដោយប្រការដូច្នេះឯង ។

## រឿងពណ៌នាសេចក្ដីស្លាប់

[២០៥] ក្នុងរឿងដំបូង គឺពណ៌នាសេចក្ដីស្លាប់ (ដែលមាននៅ) ក្នុងគាថា នៃវិនីតវត្ថុទាំងឡាយ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ការុញ្ញេន : ដោយចិត្តអាណិតអាសូរ** សេចក្ដីថា ភិក្ខុទាំងនោះ ឃើញសេចក្ដីទុក្ខ ព្រោះភាពជាជម្ងឺយ៉ាងធ្ងន់របស់លោកហើយ កើតសេចក្ដីករុណាឡើង ទាំងជាអ្នកមានសេចក្ដីត្រូវការនឹងឱ្យស្លាប់ផង តែមិនជ្រាបថា “លោកមានសេចក្ដីត្រូវការនឹងស្លាប់” ទើបបានពណ៌នាគុណសេចក្ដីស្លាប់យ៉ាងនេះថា “លោកជាអ្នកមានសីល បានធ្វើកុសលទុកហើយ ព្រោះហេតុអ្វី ទើបខ្លាចសេចក្ដីស្លាប់ ? ដែលឈ្មោះថា សួគ៌របស់អ្នកមានសីល ជារបស់ជាប់ដោយហេតុត្រឹមតែសេចក្ដីស្លាប់ប៉ុណ្ណោះ មិនមែនឬ ?” ភិក្ខុសូម្បីនោះក៏អត់អាហារ ព្រោះការពណ៌នា (គុណសេចក្ដីស្លាប់) របស់ភិក្ខុទាំងនោះ ហើយក៏មរណភាពទៅក្នុងចន្លោះនោះ

ឯង ព្រោះហេតុនោះ ភិក្ខុទាំងនោះ ទើបត្រូវអាបត្តិ ។ តែព្រះឧបាលីថេរៈពោលទុកដោយអំណាចវោហារថា ភិក្ខុទាំងនោះ បានពណ៌នាគុណសេចក្តីស្លាប់ដោយសេចក្តីករុណា, ព្រោះដូច្នោះ សូម្បីក្នុងកាលឥឡូវនេះ ភិក្ខុដែលជាបណ្ឌិត ក៏មិនគួរពណ៌នាគុណសេចក្តីស្លាប់យ៉ាងនោះ ដល់ភិក្ខុអាពាធ ។ ពិតមែន បើភិក្ខុអាពាធនោះបានស្តាប់ការពណ៌នារបស់ភិក្ខុនោះហើយ មរណភាពក្នុងចន្លោះ ក្នុងកាលអាយុសូម្បីនៅសល់តែមួយជវនវារៈ ដោយសេចក្តីព្យាយាមមានការអត់អាហារជាដើម, លោកឈ្មោះថា ជាអ្នកដែលភិក្ខុនេះឯងសម្លាប់ហើយ ។ តែគួរឱ្យពាក្យទូន្មានដោយន័យនេះថា "ការកើតឡើងនៃមគ្គនិងផលរបស់លោកអ្នកមានសីលជារបស់មិនគួរអស្ចារ្យឡើយ; ព្រោះដូច្នោះ លោកមិនគួរធ្វើការជាប់ជំពាក់ក្នុងស្ថានទីមានវិហារជាដើម គួរតាំងសតិឱ្យទៅក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងក្នុងកាយ ធ្វើសេចក្តីមិនប្រមាទក្នុងមនសិការ ។ និងសូម្បីកាលភិក្ខុពណ៌នាគុណសេចក្តីស្លាប់ហើយ ភិក្ខុណាមិនធ្វើសេចក្តីព្យាយាមព្រោះការពណ៌នានោះទេ មរណភាពទៅតាមអាយុធម្មតារបស់ខ្លួន និងតាមការបន្ត (នៃអាយុ), ភិក្ខុអ្នកពណ៌នា ដែលព្រះវិន័យធរមិនគួរពិន័យអាបត្តិ ព្រោះសេចក្តីស្លាប់របស់ភិក្ខុនោះ ជាបច្ច័យ ដូច្នេះឯង ។

# រឿងភិក្ខុអង្គុយសង្កត់ក្មេងស្លាប់

[២០៦] ក្នុងពាក្យថា ន ច ភិក្ខវេ អបដិវេក្ខិត្វា : ម្នាលភិក្ខុទាំងឡាយ បើភិក្ខុមិនទាន់បានពិនិត្យទេ កុំអាល(អង្គុយលើអាសនៈ)ជាដើម (ដែលមាននៅ) ក្នុងរឿងទី ២ មានវិនិច្ឆ័យដូច្នេះ ៖

សួរថា អាសនៈយ៉ាងណាត្រូវពិចារណា យ៉ាងណាមិនត្រូវពិចារណា ?

ឆ្លើយថា អាសនៈសុទ្ធ ៗ មិនមានកម្រាលខាងលើ និងអាសនៈដែលគេក្រាលចំពោះមុខពួកភិក្ខុដែលមកឈរមើល មិនត្រូវពិចារណា, គួរអង្គុយបាន ។ សូម្បីលើអាសនៈដែលអ្នកស្រុកគេយកដៃពង្រាប ៗ នោះឯង ហើយប្រគេនថា "សូមនិមន្តអង្គុយលើអាសនៈនេះចុះ លោកម្ចាស់" ដូច្នេះ ក៏គួរអង្គុយបាន ។ បើសូម្បីថា ភិក្ខុច្រើនរូបមកអង្គុយមុនហើយនោះឯង ។ ខាងក្រោយទើបរំកិលឡើងទៅខាងលើឬបន្ថិតថយចុះមកខាងក្រោម, មិនមានកិច្ចដែលនឹងត្រូវពិចារណា ។ សូម្បីលើអាសនៈដែលគេយកសំពត់ស្តើង ៗ គ្របទុកឱ្យមើលឃើញផ្ទៃក្រោម (អាសនៈ) បាន មិនមានកិច្ចដែលនឹងត្រូវពិចារណា ។ ចំណែកអាសនៈណាជារបស់ដែលគេយកសំពត់បាវាវនិងសំពត់ព្រំជាដើម ក្រាលទុកជាមុនតែម្តង, ភិក្ខុគួរយកដៃស្ទាបអង្អែលកំណត់មើលអាសនៈនោះ

មុនសិន សឹមអង្គុយ ។ តែក្នុងមហាបច្ចរី លោកពោលទុកថា ក្នុងអាសនៈណា សូម្បីដែលគេយកសំពត់សាដកដែលក្រាស់ក្រាលទុកស្អាមជ្រួញរមែងមិនប្រាកដ, អាសនៈនោះ មិនត្រូវពិចារណា ។

## រឿងភិក្ខុធ្វើអង្រែងដួលត្រូវក្មេងស្លាប់

[២០៧] ក្នុងរឿងអង្រែ មានវិនិច្ឆ័យដូច្នេះ ៖

បទថា អសញ្ចិច្ចោ : មិនបានក្លែងទេ បានដល់ អ្នកមិនមានចេតនានឹងសម្លាប់ ។ ពិតមែន ភិក្ខុនោះមានសេចក្ដីប្រកបខុសភ្លាត់ទៅ; ព្រោះដូច្នោះ លោកទើបក្រាបទូលថា "ខ្ញុំព្រះករុណាមិនបានក្លែង" ។ រឿងត្បាល់មានសេចក្ដីច្បាស់លាស់ហើយនោះឯង ។

## រឿងភិក្ខុជាបុត្រច្រានភិក្ខុជាបិតាឱ្យដួលស្លាប់

[២០៨] រឿងដំបូង នៅក្នុងរឿងពួកភិក្ខុចាស់ មានវិនិច្ឆ័យដូច្នេះ ៖

(ភិក្ខុជាបុត្របានពោលនឹងភិក្ខុជាបិតា)ថា "លោកម្ចាស់កុំមកធ្វើឱ្យភិក្ខុសង្ឃកើតមានកង្វល់" ដូច្នេះ ទើបច្រាន (ភិក្ខុជាបិតា) ទៅ ។

រឿងទី ២ មានវិនិច្ឆ័យដូច្នេះ ៖

(ភិក្ខុជាបុត្រត្រូវសព្រហ្មចារី) ពោលលលេងនៅក្នុងកណ្ដាលជំនុំសង្ឃខ្លះ ក្នុងពួកគណៈខ្លះថា "បុត្ររបស់ព្រះថេរៈចាស់" ធុញថប់

ដោយពាក្យនិយាយនោះ ទើបបានប្រាន (ភិក្ខុជាបិតា) ទៅដោយគិតថា "ព្រះថេរៈចាស់នេះ ចូរស្លាប់ចុះ" ។

រឿងទី ៣ មានវិនិច្ឆ័យដូច្នេះ ៖

ជាថុល្លច្ច័យដល់ភិក្ខុជាបុត្រ ព្រោះបង្កទុក្ខឱ្យកើតដល់ភិក្ខុជាបិតានោះ ។

[២០៩] រឿងភិក្ខុ ៣ រូប កំពុងឆាន់ សាច់ក៏ស្លាក់ជាប់ក្នុងបំពង់ក បន្ទាប់អំពីនោះទៅ មានសេចក្ដីប្រាសលាស់ទាំងអស់នោះឯង ។

## រឿងភិក្ខុឆាន់បិណ្ឌបាតលាយថ្នាំពិសស្លាប់

[២១០] ក្នុងរឿងបិណ្ឌបាតលាយដោយថ្នាំពិស មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុដែលបំពេញសារាណីយធម៌នោះ ប្រគេនបិណ្ឌបាតចំណែកដ៏ប្រសើរដល់សព្រហ្មចារីទាំងឡាយជាមុន ទើបឆាន់ ។ ព្រោះហេតុនោះ ព្រះឧបាលីថេរៈ ទើបពោលទុកថា "អគ្គការិកំ អទាសិ : **បានប្រគេនភោជនដ៏ឧត្ដម**" ។

បទថា អគ្គការិកំ : **ភោជនដ៏ឧត្ដម** បានដល់ បិណ្ឌបាតដែលខ្លួនបានមកគ្រាដំបូង ដែលធ្វើឱ្យជាចំណែកដ៏ប្រសើរ,ម្យ៉ាងទៀតអធិប្បាយថា បិណ្ឌបាតដែលខ្ពង់ខ្ពស់ គឺ ដែលប្រណីត ៗ ។

ក៏កិរិយាដែលធ្វើឱ្យជាចំណែកដ៏ប្រសើរ ពោលគឺ ការឱ្យរបស់

ភិក្ខុនោះ អ្នកណា ៗ មិនអាចប្រគេនបាន ។ ពិតមែន ទោះបីបិណ្ឌបាត (តាមប្រក្រតី) លោកក៏បានប្រគេនតាំងពីដើមអាសនៈព្រះថេរៈចុះមក ។

ពីរបទថា តេ ភិក្ខូ : ភិក្ខុទាំងនោះ បានដល់ ភិក្ខុដែលឆាន់បិណ្ឌបាតតាំងពីដើមអាសនៈព្រះថេរៈទាំងនោះ ចុះមក ។ បានឮថា ភិក្ខុទាំងនោះ បានមរណភាពគ្រប់រូបទាំងអស់ ។ ពាក្យដ៏សេសក្នុងរឿងនេះច្បាស់លាស់ទាំងនោះ ។ កាលភិក្ខុបានបិណ្ឌបាតដ៏ប្រណីត ដោយគោរពក្នុងត្រកូលពួកមិច្ឆាទិដ្ឋិអ្នកមិនមានសទ្ធាមិនទាន់បានពិចារណា ខ្លួនឯងមិនគួរឆាន់ផង ទាំងមិនគួរប្រគេនដល់ភិក្ខុពួកដទៃផង ។ ភិក្ខុបានភត្តាហារឬរបស់គួរទំពាឆាន់សូម្បីវត្ថុណា ដែលជារបស់បានមកពីត្រកូលមិច្ឆាទិដ្ឋិនោះ, ភត្តាហារជាដើមសូម្បីនោះ មិនគួរឆាន់ ។ ព្រោះថា ត្រកូលទាំងនោះ រមែងប្រគេនសូម្បីវត្ថុដែលគេមិនបានយកអ្វីគ្របទុក ដែលមានពស់ កែ្អប និងខ្យូងជាដើម ចូលដេកសម្ងំ ជារបស់ដែលត្រូវចោលជាធម្មតា ។ ភិក្ខុមិនគួរទទួលបិណ្ឌបាត សូម្បីដែលប្រឡាក់ដោយវត្ថុ មានរបស់ក្រអូបនិងល្មៀតជាដើម អំពីត្រកូលមិច្ឆាទិដ្ឋិនោះ ។ ពិតមែន ត្រកូលមិច្ឆាទិដ្ឋិទាំងនោះ រមែងសម្គាល់នូវភត្តាហារដែលខ្លួនយកមកជូតសំអាត ដែលមានរោគក្នុងរាងកាយ ហើយរក្សាទុកថា "ជារបស់គួរប្រគេន"នោះឯង ។

# រឿងភិក្ខុសាកល្បងថ្នាំពិស

ក្នុងរឿងសាកល្បងថ្នាំពិស មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុកាលនឹងសាកល្បង ទើបសាកល្បងទាំង ២ យ៉ាង (សាកល្បងថ្នាំពិសនិងបុគ្គល) គឺ សាកល្បងថ្នាំពិសដោយគិតថា "ថ្នាំពិសនេះ អាចសម្លាប់បុគ្គលនេះស្លាប់ឬទេហ្ន៎ ?" ឬសាកល្បងបុគ្គលដោយគិតថា "បុគ្គលនេះ ផឹកថ្នាំពិសនេះហើយនឹងគប្បីស្លាប់ ឬមិនស្លាប់ហ្ន៎ ?" កាលភិក្ខុឱ្យថ្នាំពិសដោយសេចក្ដីប្រាថ្នានឹងសាកល្បងសូម្បីទាំង ២ យ៉ាង គេនឹងស្លាប់ ឬមិនស្លាប់ ក៏ដោយ ជាអាបត្តិថុល្លច្ច័យ ។ តែកាលភិក្ខុឱ្យថ្នាំពិស ដោយគិតយ៉ាងនេះថា "ថ្នាំពិសនោះ ចូរសម្លាប់បុគ្គលនេះឱ្យស្លាប់" ឬថា "បុគ្គលនេះ ផឹកថ្នាំពិសនោះហើយ ចូរស្លាប់" ដូច្នេះ, បើបុគ្គលនោះស្លាប់ ជាបារាជិក, បើមិនស្លាប់ ជាថុល្លច្ច័យ ។

[២១១] រឿងភិក្ខុ ៣ រូប ហុចថ្ម បន្ទាប់ពីរឿងសាកល្បងថ្នាំពិសនេះទៅ និងរឿងភិក្ខុ ៣ រូប ហុចឥដ្ឋ, រឿងភិក្ខុ ៣ រូប ហុចកាំបិតព្រា, និងរឿងភិក្ខុ ៣ រូប ហុចបង្គង់វិហារ, មានសេចក្ដីជាក់ច្បាស់ទាំងអស់នោះឯង ។ ក៏សេចក្ដីផ្សេងគ្នានៃអាបត្តិនិងអនាបត្តិនេះមិនមានដោយអំណាចនៃសិលាជាដើមតែប៉ុណ្ណោះទេ ។ តែរមែងកើតបាន ដោយអំណាចសូម្បីនៃវត្ថុមានឈើអន្ទង់ ញញួរ ពន្លាក និង ត្រល់ជាដើមដូចគ្នា ។ ព្រោះដូច្នោះ វត្ថុមានឈើអន្ទង់ជាដើមនោះ សូម្បីមិនបានមកក្នុងព្រះបាលី ក៏គប្បីជ្រាបដោយន័យដែលមកហើយនុ៎ះឯង ។

# រឿងភិក្ខុចងរន្ទា

ក្នុងរឿងចងរន្ទា មានវិនិច្ឆ័យដូច្នេះ ៖

គ្រែលើអាកាស[១] ដែលជារបស់ដែលពួកជនចងទុក ដើម្បីប្រយោជន៍ដល់ការផារ មានសេតកម្ម (បូកលាបពណ៌ស) មាលាកម្ម (ឆ្លាក់លាយផ្កាឈើ) និងលតាកម្ម (ឆ្លាក់លាយវល្លិ) ជាដើម គេហៅថា រន្ទា ។ ក្នុងរឿងចងរន្ទានោះ ភិក្ខុដែលមានសេចក្ដីប្រាថ្នានឹងឱ្យស្លាប់ ពោលសំដៅយកស្ថានទីដែលភិក្ខុឈរ ហើយទើបរបូតធ្លាក់ចុះប៉ះជង្គត់ឈើ ឬនឹងដល់មរណភាពទៅ ក្នុងអណ្ដូង និងជ្រោះជាដើមថា "អាវុសោ អ្នកចូរឈរចងទីត្រង់នេះ" ។

ក៏បណ្ដាស្ថានទីទាំងនេះ ភិក្ខុខ្លះ រមែងកំណត់ទីខាងលើទុកដោយគិតថា "គេនឹងរបូតធ្លាក់ពីទីនេះស្លាប់" រូបខ្លះរមែងកំណត់ទីខាងក្រោមទុកដោយគិតថា "គេនឹងរបូតធ្លាក់ស្លាប់ពីទីនេះ" រូបខ្លះរមែងកំណត់ទីសូម្បីទាំង ២ កន្លែង ដោយគិតថា "គេនឹងរបូតធ្លាក់ពីទីនេះ ហើយស្លាប់ក្នុងទីនេះ" ។ បណ្ដាស្ថានទីដែលភិក្ខុកំណត់ទុកនោះ អ្នកណាមិនរបូតធ្លាក់ទៅពីទីដែលភិក្ខុកំណត់ទុកខាងលើ របូតធ្លាក់ទៅពីទីដទៃក្ដី, មិនរបូតធ្លាក់ទៅ

១. គ្រែដែលចងទុកលើអាកាស ដូចគ្រែដែលគេធ្វើទុកលើដើមឈើសម្រាប់ពួនបាញ់សត្វ ហៅថា គ្រែលើអាកាស ។

ក្នុងទីដែលភិក្ខុកំណត់ទុកខាងក្រោម របូតធ្លាក់ទៅក្នុងទីដទៃក្តី, របូតធ្លាក់ទៅក្នុងបណ្តាទីកំណត់ទុកទាំង ២ កន្លែងណាមួយក្តី , កាលអ្នកនោះស្លាប់ ឈ្មោះថា មិនជាអាបត្តិ ព្រោះមានការខុសសង្កេត ។

[២១២] សូម្បីក្នុងរឿងប្រក់វិហារក៏ន័យនេះ ។

## រឿងភិក្ខុទម្លាក់ខ្លួនពីលើភ្នំចុះក្នុងជ្រោះសង្កត់ជាងតម្បាញស្លាប់

[២១៣] ក្នុងរឿងភិក្ខុអផ្សុក មានវិនិច្ឆ័យដូច្នេះ ៖

បានឮថា ភិក្ខុនោះឃើញសេចក្តីវេវរាយនៃអកុសលវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើម កាលមិនអាចហាមបាន ទាំងមិនត្រេកអរក្នុងព្រះសាសនា ទើបជាអ្នកប្រាថ្នាឆ្ពោះមុខទៅដើម្បីជាគ្រហស្ថ តែខាងក្រោយបានគិតថា "យើងនឹងស្លាប់ ដរាបណាដែលយើងមិនទាន់ដាច់សីល" ។ គ្រានោះទើបលោកឡើងភ្នំនោះ ហើយលោតចុះទៅក្នុងជ្រោះសង្កត់ជាងតម្បាញម្នាក់ស្លាប់ ។

បទថា វិលិវការំ : ជាងត្បាញផែង បានដល់ ជាងតម្បាញឫស្សី ។

ច្រើនបទ ន ច ភិក្ខវេ អត្តានំ បាតេតព្វំ : ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែភិក្ខុកុំគប្បីទម្លាក់សម្លាប់ខ្លួនឯង សេចក្តីថា ខ្លួនដែលភិក្ខុមិន

គប្បីឱ្យធ្លាក់ចុះទៅ ។ ក៏បទថា អត្តានំ នោះ ព្រះមានព្រះភាគត្រាស់ដោយវិភត្តិផ្លាស់ប្តូរទៅ ។ តែក្នុងអធិការពោលអំពីការញ៉ាំងខ្លួនឱ្យធ្លាក់ទៅនេះ ភិក្ខុមិនគួរញ៉ាំងខ្លួនឱ្យធ្លាក់ទៅតែម្យ៉ាងក៏ទេ, សូម្បីបុគ្គលដទៃក៏មិនគួរសម្លាប់ដោយសេចក្តីព្យាយាមយ៉ាងណាមួយ ដោយទីបំផុតសូម្បីដោយការអត់អាហារ ។ ពិតមែន សូម្បីភិក្ខុណា អាពាធមានសេចក្តីប្រាថ្នានឹងស្លាប់ កាលភេសជ្ជៈនិងអ្នកឧបដ្ឋាកមាន ក៏អត់អាហារ, ភិក្ខុនោះ ត្រូវទុក្កដតែម្តង ។ ចំណែកភិក្ខុណា អាពាធធ្ងន់ជាគ្រឿងចងព័ន្ធនៅយូរ (ត្រូវរក្សាព្យាបាលនៅយូរ) ភិក្ខុទាំងឡាយ អ្នកឧបដ្ឋាក រមែងលំបាកស្អប់ខ្ពើម គឺ ធុញថប់ ដោយគិតថា "កាលណាហ្ន៎ ? ពួកយើងនឹងផុតពីភិក្ខុអាពាធ" ។ បើភិក្ខុនោះ គិតថា "អត្តភាពនេះ សូម្បីត្រូវទំនុកបំរុងទុក ក៏មិនតាំងនៅ, និងភិក្ខុទាំងឡាយក៏លំបាក" ហើយអត់អាហារ មិនឆាន់ភេសជ្ជៈ, ការដែលលោកអត់អាហារនោះ រមែងគួរ ។ ចំណែកភិក្ខុណាគិតថា "រោគនេះកាចសាហាវខ្លាំងណាស់ ។ អាយុសង្ខារ រមែងមិនតាំងនៅ, និងការសម្រេចគុណវិសេសរបស់យើងនេះ រមែងប្រាកដ ដូចនៅក្នុងកណ្តាប់ដៃហើយ" ទើបអត់អាហារ; ការដែលលោកអត់អាហារនោះ រមែងគួរដូចគ្នា ។ សូម្បីកាលភិក្ខុមិនអាពាធ កើតសេចក្តីសង្វេគឡើងហើយ អត់អាហារដោយមានកម្មដ្ឋាន ព្រោះគិតបានថា

"ឈ្មោះថា ការស្វែងរកអាហារជាទីឃើញតយូរ, យើងនឹងតាមប្រកបកម្មដ្ឋានប៉ុណ្ណោះ" ដូច្នេះ, ការដែលលោកអត់អាហារនោះ រមែងគួរ ភិក្ខុព្យាករណ៍ការសម្រេចគុណវិសេស ហើយអត់អាហារ; ប្រការនោះ រមែងមិនគួរ ៗ តែនឹងប្រាប់ដល់លជ្ជីភិក្ខុទាំងឡាយ អ្នកជាសភាគគ្នា គួរ ៗ

## រឿងភិក្ខុឆព្វគ្គិយប្រមៀលថ្មលេងសង្កត់អ្នកខ្វាលគោស្លាប់

ក្នុងរឿងថ្ម មានវិនិច្ឆ័យដូច្នេះ ៖

បទថា **ធវាយ** : លេង បានដល់ ដោយការលេង គឺ ដោយការសើច, អធិប្បាយថា ដោយការពើសលេង ៗ ដែលឈ្មោះថា សិលា បានដល់ ដុំថ្ម ៗ និងមិនមែនតែថ្មយ៉ាងទេ សូម្បីជាកំណាត់ឈើ ឬដុំឥដ្ឋយ៉ាងណាមួយដទៃ ភិក្ខុនឹងប្រើដៃ ឬគ្រឿងយន្តប្រមៀល រមែងមិនគួរ ៗ ពួកភិក្ខុនាំគ្នាសើចក្អាកក្អាយប្រមៀលក្តី លើកឡើងក្តី នូវវត្ថុមានថ្មជាដើម ដើម្បីប្រយោជន៍ដល់ព្រះចេតិយជាដើម, ចាត់ជាសម័យធ្វើការងារ; ព្រោះហេតុនោះ កិច្ចមានការប្រមៀលជាដើម ទើបគួរ ពួកភិក្ខុកាលនឹងធ្វើនវកម្មសូម្បីយ៉ាងដទៃដូច្នេះ ឬនឹងទាញវត្ថុ លើកដើមឈើឬកំណាត់ឈើសម្រាប់នាំឡើង ហើយប្រមៀលទៅ, កិច្ចការនោះ រមែងគួរ ៗ ក្នុងវេលាធ្វើភត្តកិច្ចជាដើម ភិក្ខុគ្រវែងកំណាត់ឈើឬក្បឿងទៅដេញហ្វូងក្អែក និងពួកសុនខឱ្យគេចចៀសទៅ; ការដេញនោះ រមែងគួរ ៗ

[២១៤] រឿងទាំងឡាយមានរឿងឆ្នុងខ្ទនជាដើម មានសេចក្ដីច្បាស់លាស់ទាំងអស់ហើយនោះឯង ។ មួយទៀត ក្នុងវិស័យនៃរឿងឆ្នុងខ្ទនជាដើមនេះ ភិក្ខុមិនគួរធ្វើគិលានុបដ្ឋាកដោយគិតថា "យើងមានសេចក្ដីវង្វៀសគ្រប់យ៉ាង" គប្បីចូលទៅកំណត់កម្លាំង ឬមិនមានកម្លាំងសេចក្ដីពេញចិត្ត និងសេចក្ដីសប្បាយរបស់ភិក្ខុអាពាធ ហើយធ្វើជាអ្នកប្រាថ្នាផ្ដល់នូវប្រយោជន៍ ។

## រឿងភិក្ខុធ្វើថ្នាំឱ្យស្ត្រីមានគភ៌និងសហាយស្មន់ធ្លាក់ទៅជាដើម

[២១៥] ក្នុងរឿងស្ត្រីមានគភ៌ជាមួយនឹងសហាយស្មន់ មានវិនិច្ឆ័យដូច្នេះ ៖

បទថា **បវុដ្ឋបតិកា :** ព្រាត់ប្រាសចាកប្ដីមកយូរហើយ ប្រែថា ស្ត្រី ដែលមានស្វាមីលះបង់ចោលទៅយូរហើយ ។

បទថា **គព្ភបាតនំ :** ថ្នាំរំលូតគភ៌ បានដល់ ថ្នាំប្រាកដដូចដែលស្ត្រីបរិភោគហើយ ជាហេតុឱ្យគភ៌ធ្លាក់ទៅ ។

រឿងស្ត្រីរួមប្ដី ២ នាក់ មានសេចក្ដីច្បាស់លាស់ហើយនោះឯង ។

ក្នុងរឿងប្របាច់ពោះរំលូតកូន មានវិនិច្ឆ័យដូច្នេះ ៖

ស្រីមានគភ៌នោះ កាលភិក្ខុប្រាប់ថា "ចូរប្របាច់ពោះឱ្យធ្លាក់ទៅខ្ទនឯងចុះ" ពឹងឱ្យអ្នកដទៃរឹត ធ្វើឱ្យធ្លាក់ទៅ ជាការខុសសង្កេត; សូម្បី

កាលភិក្ខុប្រាប់ថា "ចូរពឹងអ្នកដទៃប្របាច់ពោះធ្វើឱ្យធ្លាក់ទៅចុះ" តែនាងរឹតធ្វើឱ្យធ្លាក់ចុះទៅដោយខ្លួនឯង ជាការខុសសង្កេត ដូចគ្នា ។ ឈ្មោះថាបរិយាយក្នុងមនុស្សវិគ្គហៈ រមែងមិនមាន; ព្រោះហេតុនោះ កាលភិក្ខុនិយាយថា "ដែលឈ្មោះថា គភ៌ត្រូវប្របាច់ពោះហើយ នឹងធ្លាក់ចុះទៅដោយខ្លួនឯង, ស្រីមានគភ៌នោះ ចូររឹតខ្លួនឯង" ឬ "ចូរពឹងពាក់ឱ្យអ្នកដទៃរឹតឱ្យធ្លាក់ទៅ"ក៏ដោយ, មិនមានសេចក្តីខុសសង្កេត ជាបារាជិកតែម្តង ។ សូម្បីក្នុងរឿងកំដៅផ្ទៃពោះឱ្យក្តៅក៏ន័យនេះដូចគ្នា ។

## រឿងភិក្ខុធ្វើថ្នាំឱ្យស្រីអារមានបុត្រស្លាប់

ក្នុងរឿងស្រីអារ មានវិនិច្ឆ័យដូច្នេះ ៖

ស្រីដែលមិនតាំងគភ៌ ឈ្មោះថា ស្រីអារ ។ ធម្មតាស្រីមិនតាំងគភ៌ រមែងមិនមាន, ប៉ុន្តែថា គភ៌សូម្បីដែលស្រីណាតាំងឡើងហើយមិនឋិតនៅ, សេចក្តីនេះ លោកពោលសំដៅយកស្រីនោះ ។ បានឮថាក្នុងពេលមានរដូវ ស្រីគ្រប់ជំពូក រមែងតាំងគភ៌, តែអកុសលវិបាកចូលមកដល់ពួកសត្វកើតក្នុងផ្ទៃរបស់ស្រីដែលគេហៅថា ជាស្រីអារ នេះ ។ សត្វទាំងនោះចាប់បដិសន្ធិមកដោយកុសលវិបាកត្រឹមតែបន្តិចបន្តួច ត្រូវអកុសលវិបាកគ្របសង្កត់ទើបវិនាសទៅ ។

ពិតមែន ក្នុងខណៈបដិសន្ធិថ្មី ៗ នុ៎ះឯង គភ៌តាំងនៅមិនបាន

ដោយអាការ ២ យ៉ាង[១] គឺ ដោយខ្យល់ ឬសត្វតូច ៗ ព្រោះកម្មានុភាព ខ្យល់បក់ (គភ៌) ឱ្យស្ងួតហើយធ្វើឱ្យអន្តរធានទៅ ។ សត្វតូច ៗ ទាំងឡាយ ខាំស៊ី (គភ៌ ធ្វើឱ្យអន្តរធានទៅ) ។ តែកាលពេទ្យផ្សំថ្នាំ ដើម្បីកម្ចាត់ខ្យល់និងពួកសត្វតូចនោះហើយគភ៌គប្បីតាំងនៅបាន ។ ភិក្ខុនោះមិនបានផ្សំថ្នាំនោះ បានឱ្យថ្នាំដែលខាំងដទៃ ។ នាងបានស្លាប់ទៅ ព្រោះថ្នាំនោះ ព្រះមានព្រះភាគ បានទ្រង់បញ្ញត្តិទុក្កដទុក ព្រោះភិក្ខុផ្សំថ្នាំ ។ សូម្បីក្នុងរឿងទី ២ ក៏ន័យនេះដូចគ្នា ។

## ភិក្ខុមិនគួរធ្វើថ្នាំដល់ជនដទៃតែគួរធ្វើឱ្យសហធម្មិកទាំង ៥

ព្រោះហេតុនោះ ភិក្ខុមិនគួរធ្វើថ្នាំដល់ជនដទៃអ្នកមកហើយ ៗ, កាលធ្វើ ត្រូវទុក្កដ ។ តែគួរធ្វើឱ្យដល់សហធម្មិកទាំង ៥ គឺ ភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី ។ ពិតមែន សហធម្មិកទាំង ៥ ពួកនោះ ជាអ្នកមានសីល សទ្ធា និងបញ្ញាស្មើគ្នា ទាំងប្រកបក្នុងត្រៃសិក្ខាផង ភិក្ខុនឹងមិនធ្វើថ្នាំឱ្យ រមែងមិនបាន, កាលនឹងធ្វើ បើគ្រឿងផ្សំថ្នាំរបស់សហធម្មិកទាំងនោះមាន, គប្បីកាន់យកគ្រឿងផ្សំថ្នាំរបស់សហធម្មិកទាំងនោះ ផ្សំឱ្យ ។ បើមិនមាន, គួរយកគ្រឿងផ្សំថ្នាំរបស់ខ្លួន

---

១. សុមង្គ. ទីឃ. ព្រហ្មជាលសូត្រ មាន ៣ យ៉ាង គឺ ខ្យល់ មេរោគ កម្ម ។

ធ្វើឱ្យ បើស្ងួម្បីគ្រឿងផ្សំថ្នាំរបស់ខ្លួនមិនមាន គប្បីស្វែងរកដោយភិក្ខាចារវត្ត ឬចាកទីនៃញាតិនិងអ្នកបវារណា (របស់ខ្លួន) ។ កាលមិនបាន គួរនាំគ្រឿងផ្សំថ្នាំមកធ្វើឱ្យ សូម្បីដោយការមិនធ្វើវិញ្ញត្តិ (គឺ សូមក្នុងទីដែលគេមិនបានធ្វើបវារណា) ដើម្បីប្រយោជន៍ដល់អ្នកជម្ងឺ ។ គួរធ្វើថ្នាំឱ្យដល់ជន ៥ ពួក សូម្បីដទៃទៀត គឺ មាតា ១ បិតា ១ អ្នកបម្រើមាតាបិតានោះ ១ វេយ្យាវច្ចៈរបស់ខ្លួន ១បណ្ឌុបលាស ១ ។ អ្នកដែលឈ្មោះថា បណ្ឌុបលាស បានដល់ អ្នកសម្លឹងបព្វជ្ជា នៅក្នុងវិហាររហូតអស់រយៈកាលដែលនៅត្រៀមបាត្រនិងចីវរ ។ បណ្ដាជនទាំង ៥ ពួកនោះ បើមាតានិងបិតាជាអ្នកធំ មិនប្រាថ្នាការតបស្នងទេ, ទឹងមិនធ្វើឱ្យក៏គួរ ។ តែបើលោកទាំង ២ តាំងនៅក្នុងរាជសម្បត្តិ នៅសង្ឃឹមការតបស្នង, ទឹងមិនធ្វើ មិនគួរ ។ កាលលោកទាំង ២ ប្រាថ្នាភេសជ្ជៈ គួរឱ្យភេសជ្ជៈ ។ កាលលោកទាំង ២ មិនដឹងវិធីផ្សំថ្នាំគួរផ្សំថ្នាំឱ្យ ។ គួរស្វែងរកភេសជ្ជៈដើម្បីប្រយោជន៍ដល់ជន ៥ ពួក មានមាតាជាដើម សូម្បីទាំងអស់ ដោយន័យដូចពោលហើយក្នុងសហធម្មិកទាំងឯង ។ ក៏បើភិក្ខុនាំមាតាមកប្រណិបត្តិនៅក្នុងវិហារ ។ កុំប៉ះពាល់ គប្បីធ្វើបរិកម្មគ្រប់យ៉ាង, គប្បីឱ្យរបស់ទំពា របស់បរិភោគដោយដៃខ្លួនឯង, ចំណែកបិតាគប្បីទំនុកបម្រុងធ្វើកិច្ចទាំងឡាយ មានការឱ្យងូតទឹកនិងការគក់ប្រហាច់ជាដើម ដោយដៃខ្លួនឯង ដូចសាមណេរដូច្នោះ ។ ជនពួកណា

រមែងទំនុកបម្រុងមាតានិងបិតា, ភិក្ខុគួរធ្វើភេសជ្ជៈ សូម្បីដល់ជនទាំងនោះ យ៉ាងនោះដូចគ្នា ។

អ្នកដែលឈ្មោះថា វេយ្យាវច្ចៈ បានដល់ អ្នកទទួលយកតម្លៃឈ្នួលហើយ កាត់ឈើស្ងួនក្នុងព្រៃ ឬធ្វើការងារដទៃយ៉ាងណាមួយ ។ កាលកើតជាពេគឡើងដល់គេ ភិក្ខុគួរធ្វើថ្នាំឱ្យដរាបទាល់តែពួកញាតិបានប្រទះឃើញ ចំណែកអ្នកណាគ្រាន់តែជាអ្នកអាស្រ័យនឹងភិក្ខុ ធ្វើការងារគ្រប់យ៉ាង, ភិក្ខុគួរធ្វើថ្នាំឱ្យដល់អ្នកនោះដូចគ្នា ។ សូម្បីក្នុងបណ្ឌុបលាសក៏គួរបដិបត្តិដូចក្នុងសាមណេរ ដូច្នោះ ។

## ភិក្ខុគួរធ្វើថ្នាំឱ្យជន ១០ ពួក

ភិក្ខុគួរធ្វើថ្នាំឱ្យដល់ជន ១០ ពួក សូម្បីដទៃទៀត គឺ បងប្រុស ១ ប្អូនប្រុស ១ បងស្រី ១ ប្អូនស្រី ១ ម្តាយមីង(មីងខាងម្តាយ)១ ម្តាយធំ(អ៊ំស្រីខាងម្តាយ) ១ ឪពុកមា(ពូខាងឪពុក) ១ ឪពុកធំ(អ៊ំប្រុសខាងឪពុក) ១ ម្តាយមីង(មីងខាងឪពុក) ១ ឪពុកធំ(អ៊ំប្រុសខាងម្តាយ) ១ ។ ក៏កាលនឹងធ្វើឱ្យដល់ជនមានបងប្រុសជាដើមនោះសូម្បីទាំងអស់ គួរយកថ្នាំដែលជារបស់អ្នកទាំងនោះឯង ផ្សំឱ្យតែម្យ៉ាង, តែបើវត្ថុជាគ្រឿងផ្សំរបស់ជនទាំងនោះ មិនគ្រប់គ្រាន់ និងជនទាំងនោះក៏សូមអង្វរថា "លោកម្ចាស់ មេត្តាឱ្យពួកខ្ញុំព្រះករុណាចុះ ពួកខ្ញុំព្រះករុណា

នឹងសងដល់លោកម្ចាស់វិញ”, គួរឱ្យជារបស់ខ្ញុំ, បើពួកគេមិនសូមអង្វរ ភិក្ខុគួរនិយាយថា “អាត្មាមានថ្នាំ, ពួកលោកចូរកាន់យកជារបស់ខ្ញុំចុះ” ឬគួរធ្វើសេចក្តីតាំងចិត្តទុកថា “វត្ថុរបស់ជនទាំងនោះនឹងមានកាលណា គេនឹងឱ្យកាលនោះ” ដូច្នេះ ហើយគប្បីឱ្យទៅ ។ បើគេសង គួរទទួលយក, បើមិនសង មិនគួរទាមទារ ។ វៀរញាតិ ១០ ពួកទាំងនោះចេញ មិនគួរឱ្យថ្នាំដល់ជនពួកដទៃ ។ ក៏កាលភិក្ខុប្រើឱ្យញាតិនាំចតុប្បច្ច័យមកដរាបដល់ ៧ សន្តាន ដោយបន្ត ៗ គ្នាមកនៃបុត្ររបស់ញាតិ ១០ ពួក មានបងប្រុសជាដើមទាំងនោះមិនជាការធ្វើវិញ្ញត្តិ កាលធ្វើភេសជ្ជៈ (ដល់ជនទាំងនោះ) ក៏មិនជាវេជ្ជកម្មឬមិនជាអាបត្តិ ព្រោះទ្រុស្តត្រកូល ។ បើបងថ្លៃស្រី ប្អូនថ្លៃស្រី ឬបងថ្លៃប្រុស ប្អូនថ្លៃប្រុស មានជម្ងឺ, បើគេជាញាតិ, ទឹងធ្វើថ្នាំដល់ញាតិ សូម្បីទាំងនោះ ក៏គួរ ។ បើគេមិនមែនញាតិ គប្បីធ្វើឱ្យដល់បងប្រុស និងបងស្រី ដោយបង្គាប់ថា ចូរឱ្យក្នុងទីបដិបត្តិរបស់ពួកលោក ។ ម្យ៉ាងទៀត គប្បីធ្វើឱ្យដល់បុត្ររបស់គេ ដោយបង្គាប់ថា “ចូរឱ្យដល់មាតា និងបិតារបស់ពួកអ្នកឯងចុះ” ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងពួងដោយឧបាយនេះ ។ ក៏ភិក្ខុកាលនឹងប្រើសាមណេរទាំងឡាយ ឱ្យនាំថ្នាំមកអំពីព្រៃដើម្បីប្រយោជន៍ដល់បងថ្លៃស្រី ប្អូនថ្លៃស្រីជាដើមទាំងនោះ គួរប្រើពួកសាមណេរដែលជាញាតិឱ្យនាំមក ឬគប្បីឱ្យនាំមកដើម្បីប្រយោជន៍ដល់ខ្លួនហើយទើបឱ្យ

ទៅ ។ សូម្បីពួកសាមណេរដែលមិនមែនញាតិទាំងនោះ ក៏គួរនាំមកដោយធ្វើវត្តថា “ពួកយើងនឹងនាំមកប្រគេនព្រះឧបជ្ឈាយ៍” ។ មាតានិងបិតារបស់ព្រះឧបជ្ឈាយ៍ មានជម្ងឺ មកកាន់វិហារ, និងព្រះឧបជ្ឈាយ៍ចៀសចេញទៅទីផ្សេងហើយ ។ សទ្ធិវិហារិក គួរឱ្យថ្នាំដែលជារបស់ព្រះឧបជ្ឈាយ៍ ។ បើមិនមាន, គួរបរិច្ចាគថ្នាំរបស់ខ្លួនប្រគេនព្រះឧបជ្ឈាយ៍ហើយឱ្យទៅ ។ សូម្បីកាលរបស់ខ្លួនក៏មិនមាន គួរស្វែងរកធ្វើឱ្យជារបស់ព្រះឧបជ្ឈាយ៍ហើយឱ្យទៅ ដោយន័យដូចពោលហើយ ។

ក្នុងមាតានិងបិតារបស់សទ្ធិវិហារិក សូម្បីព្រះឧបជ្ឈាយ៍ក៏គួរបដិបត្តិយ៉ាងនោះដែរ ។ ក្នុងអាចារ្យនិងអន្តេវាសិកក៏ន័យនេះ ។

## ភិក្ខុគួរធ្វើថ្នាំឱ្យដល់មនុស្ស ៦ ពួក

បុគ្គលសូម្បីដទៃណា គឺ អាគន្តុកៈ ១ ចោរ ១ អ្នកច្បាំងបរាជ័យ ១ អ្នកជាធំ ១ មនុស្សកំព្រាដែលពួកញាតិលះបង់ ១ អ្នកត្រៀមនឹងទៅ ១ ជាអ្នកមានជម្ងឺចូលទៅកាន់វិហារ ។ ភិក្ខុដែលមិនប្រាថ្នាការតបស្នង គួរធ្វើថ្នាំដល់មនុស្សទាំងអស់នោះ ។ ត្រកូលដែលមានសទ្ធាទំនុកបម្រុងដោយបច្ច័យ ៤ រមែងតាំងនៅក្នុងឋានជាមាតា និងបិតារបស់ភិក្ខុសង្ឃ ។ បើក្នុងត្រកូលនោះមានអ្នកខ្លះ មានជម្ងឺ, ជនទាំងឡាយទូលសូម ដើម្បីប្រយោជន៍ដល់អ្នកជម្ងឺនោះថា “លោកម្ចាស់ សូម

លោកម្ចាស់ធ្វើថ្នាំឱ្យដោយសេចក្តីវិស្សាសៈចុះ", មិនគួរឱ្យ ទាំងមិនគួរធ្វើឡើយ ។ ក៏បើពួកគេដឹងវត្ថុដែលគួរ ទូលសួរយ៉ាងនេះថា "លោកម្ចាស់ គេផ្សំថ្នាំអ្វីព្យាបាលរោគឈ្មោះឯណោះ ?" ភិក្ខុនឹងឆ្លើយថា "គេយកវត្ថុនេះនិងវត្ថុនេះ ធ្វើ ( ថ្នាំ )" ដូច្នេះ ក៏គួរ ។ ក៏ភិក្ខុត្រូវគ្រហស្ថទូលសួរយ៉ាងនេះថា "លោកម្ចាស់ មាតារបស់ខ្ញុំព្រះករុណាមានជម្ងឺ សូមមេត្តាប្រាប់ថ្នាំផងចុះ" ដូច្នេះ មិនគួរប្រាប់ ។ តែគួរសន្ទនាពាក្យចំពោះគ្នានឹងគ្នាថា "អាវុសោ ក្នុងរោគប្រភេទនេះ របស់ភិក្ខុឈ្មោះឯណោះ គេផ្សំថ្នាំអ្វីដើម្បីព្យាបាល ?" ភិក្ខុទាំងឡាយឆ្លើយប្រាប់ថា "ករុណា លោកម្ចាស់ គេយកវត្ថុនេះ និងវត្ថុនេះផ្សំជាថ្នាំ" ចំណែកអ្នកស្រុក ស្តាប់ពាក្យសន្ទនានោះហើយ រមែងផ្សំថ្នាំដល់មាតា; ភិក្ខុធ្វើការសន្ទនាគ្នានោះ រមែងគួរ ។

## រឿងព្រះមហាបទុមត្ថេរសន្ទនារឿងថ្នាំព្យាបាលរោគ

បានឮថា សូម្បីព្រះមហាបទុមត្ថេរ កាលព្រះទេវីរបស់ព្រះបាទវសភៈកើតប្រឈួនព្រះរោគឡើង ក៏ត្រូវនាងស្នំម្នាក់មកទូលសួរ លោកក៏មិននិយាយថា "មិនដឹង" បានសន្ទនានឹងពួកភិក្ខុដូចដែលបានពោលមកហើយទុំះឯង ។ រាជបរិវារស្តាប់ពាក្យសន្ទនានោះហើយ បានផ្សំថ្នាំថ្វាយដល់ព្រះទេវីអង្គនោះ ។ និងកាលព្រះរោគស្ងប់រម្ងាប់ហើយ រាជបរិវារបានផ្តុកប្រអប់ភេសជ្ជៈឱ្យពេញព្រមទាំងត្រៃចីវរ និងកហាបណៈ ៣០០

នាំទៅដាក់ទុកជិតជើងរបស់ព្រះថេរៈ ហើយប្រាប់ថា "លោកម្ចាស់ មេត្តាធ្វើការបូជាដោយផ្កាឈើចុះ" ។ ព្រះថេរៈគិតថា "នេះឈ្មោះថា ជាចំណែករបស់អាចារ្យ" ហើយឱ្យវេយ្យាវច្ចៈទទួលទុកដោយអំណាចជារបស់កប្បិយៈ បានធ្វើការបូជាដោយផ្កាឈើហើយ ។ ភិក្ខុគួរបដិបត្តិក្នុងភេសជ្ជៈយ៉ាងនេះមុន ។

## រឿងសូធ្យព្រះបរិត្ត

ក៏ក្នុងព្រះបរិត្ត មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុត្រូវអ្នកស្រុកអារាធនាថា "មេត្តាធ្វើព្រះបរិត្តដល់អ្នកជម្ងឺចុះលោកម្ចាស់" ដូច្នេះ មិនគួរធ្វើ, តែកាលគេអារាធនាថា "មេត្តាសូធ្យព្រះបរិត្តចុះ លោកម្ចាស់", គួរធ្វើ ។ បើសូម្បីភិក្ខុនោះ មានសេចក្តីត្រិះរិះថា "ធម្មតាមនុស្សទាំងឡាយ រមែងមិនដឹង, កាលយើងមិនធ្វើ នឹងជាអ្នកក្តៅក្រហាយ" ដូច្នេះ, ក៏គួរធ្វើ ។ ចំណែកភិក្ខុត្រូវអារាធនាថា "មេត្តាធ្វើទឹកព្រះបរិត្ត សរសៃអំបោះព្រះបរិត្តឱ្យចុះ" ដូច្នេះ គួរយកដៃ (របស់ខ្លួន) កូរទឹក ប្របាច់ឈ្លីសរសៃអំបោះរបស់មនុស្សពួកនុ៎ះឯងឱ្យទៅ ។ បើភិក្ខុឱ្យទឹកអំពីវិហារ ឬអំពីសរសៃអំបោះដែលជារបស់ខ្លួន ជាទុក្កដ ។ ពួកអ្នកស្រុកអង្គុយកាន់ទឹកនិងសរសៃអំបោះ ពោលថា "សូមនិមន្តសូធ្យព្រះបរិត្ត" ដូច្នេះ គួរធ្វើ, បើគេមិនដឹង គួរប្រាប់ឱ្យដឹង ។

ពួកអ្នកស្រុកចាក់ទឹកទុកក្នុងណោទកចុះ ( ក្នុងផ្តិល ) និងដាក់សរសៃអំបោះទុកជិតជើងទាំងឡាយរបស់ពួកភិក្ខុដែលអង្គុយហើយ ក៏ទៅ ដោយប្រាប់ថា "សូមនិមន្តធ្វើព្រះបរិត្ត សូត្រព្រះបរិត្តចុះ" ដូច្នេះ, ភិក្ខុមិនគប្បីដកជើងចេញ, ព្រោះថា ពួកអ្នកស្រុកនឹងជាអ្នកមានសេចក្តីក្តៅក្រហាយ ។ ពួកអ្នកស្រុកបញ្ជូនមនុស្សទៅកាន់វិហារ ដើម្បីប្រយោជន៍ដល់អ្នកជម្ងឺខាងក្នុងស្រុកដោយបង្គាប់ថា "សូមភិក្ខុទាំងឡាយ មេត្តាសូត្រព្រះបរិត្ត" ដូច្នេះ, ភិក្ខុគួរសូត្រ ។ កាលរោគឬសេចក្តីចង្រៃ កើតឡើងក្នុងព្រះរាជមណ្ឌលជាដើម ខាងក្នុងស្រុក ឥស្សរជនមានក្សត្រិយ៍ជាដើម ទទួលបង្គាប់ឱ្យអារាធនាភិក្ខុមកហើយ និមន្តឱ្យសូត្រ ( ព្រះបរិត្តជាដើម ) ។ ភិក្ខុគប្បីសូត្រព្រះសូត្រទាំងឡាយ មានអាដានាដិយសូត្រជាដើម ។ សូម្បីកាលពួកអ្នកស្រុកបញ្ជូនមនុស្សទៅនិមន្តថា "សូមភិក្ខុទាំងឡាយមកឱ្យសិក្ខាបទ សម្តែងធម៌ដល់អ្នកជម្ងឺចុះ" ឬថា "មកឱ្យសិក្ខាបទសម្តែងធម៌ក្នុងព្រះរាជវាំង ឬក្នុងផ្ទះរបស់អាមាត្យចុះ" ដូច្នេះ ភិក្ខុគួរទៅឱ្យសិក្ខាបទ គួរពោលធម៌ ។ ពួកអ្នកស្រុកនិមន្តថា "សូមភិក្ខុទាំងឡាយមកដើម្បីជាបរិវារ ( សម្លាញ់ ) របស់អ្នកស្លាប់", មិនគួរទៅ, ភិក្ខុនឹងទៅដោយប្រាថ្នាកម្មដ្ឋានជាគោលថា "យើងនឹងត្រឡប់បាន-មរណសតិព្រោះឃើញឆ្អឹងក្នុងព្រៃជាទីចោលសាកសព និងព្រោះឃើញអសុភ" ដូច្នេះគួរ ។ ភិក្ខុគួរបដិបត្តិក្នុងព្រះបរិត្ត ដូចពណ៌នាមកដូច្នេះ ។

# រឿងអនាមដ្ឋបិណ្ឌបាត

ចំណែកក្នុងបិណ្ឌបាត មានវិនិច្ឆ័យដូច្នេះ ៖

សួរថា អនាមដ្ឋបិណ្ឌបាតគួរឱ្យដល់អ្នកណា មិនគួរឱ្យដល់អ្នកណា ?

ឆ្លើយថា គួរឱ្យដល់មាតានិងបិតាមុន ក៏បើថា បិណ្ឌបាតនោះនឹងជារបស់មានតម្លៃច្រើនកហាបណៈ ក៏មិនចាត់ថា ជាការញ៉ាំងសទ្ធាទេយ្យឱ្យធ្លាក់ចុះ, គួរឱ្យសូម្បីដល់អ្នកទាំងនេះ គឺពួកអ្នកទំនុកបម្រុងមាតាបិតា វេយ្យាវច្ចករ បណ្ឌុបលាស ។ បណ្ដាអ្នកទាំងនោះ សម្រាប់បណ្ឌុបលាស នឹងដាក់ក្នុងភាជនៈឱ្យ ក៏គួរ ។ វៀរបណ្ឌុបលាសនោះចេញ នឹងដាក់ក្នុងភាជនៈឱ្យដល់គ្រហស្ថពួកដទៃសូម្បីជាមាតាបិតា ក៏មិនគួរ ។ ព្រោះថា គ្រឿងបរិភោគរបស់បព្វជិតតាំងនៅក្នុងឋានជាចេតិយរបស់ពួកគ្រហស្ថ ។ ម្យ៉ាងទៀត ឈ្មោះថា អនាមដ្ឋបិណ្ឌបាតនេះ គប្បីឱ្យដល់ចោរល្បីឈ្មោះខ្លះ ទាំងដល់ឥស្សរជនខ្លះ ដែលចូលមកដល់ ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ជនទាំងនោះសូម្បីកាលមិនឱ្យ ក៏ក្រោធថា "មិនឱ្យ" សូម្បីកាលចាប់ ( ជាចំណែក ) ឱ្យ ក៏ក្រោធថា "ឱ្យរបស់ជាសំណល់" ។ ជនទាំងនោះ ក្រោធហើយ រមែងផ្ដាច់ចាកជីវិតខ្លះ រមែងធ្វើអន្តរាយដល់ព្រះសាសនាខ្លះ ។ ក៏ក្នុងសេចក្ដីនេះ គប្បីសម្ដែងរឿងព្រះបាទចោរនាគអ្នកត្រាច់ប្រាថ្នារាជសម្បត្តិ ( ជាឧទាហរណ៍ ) ។ ភិក្ខុគួរបដិបត្តិក្នុងបិណ្ឌបាត ដូចពណ៌នាមកដូច្នេះ ។

## រឿងបដិសណ្ឋារៈ

ចំណែកក្នុងបដិសណ្ឋារៈ មានវិនិច្ឆ័យដូច្នេះ ៖

សួរថា បដិសណ្ឋារៈ គួរធ្វើដល់អ្នកណា មិនគួរធ្វើដល់អ្នកណា ?

ឆ្លើយថា ឈ្មោះថា បដិសណ្ឋារៈ ដែលភិក្ខុគួរធ្វើទាំងនោះដល់អ្នកណាម្នាក់ដែលមកដល់វិហារ ទោះជាអ្នកសញ្ចរមក អ្នកក្រីក្រ ជាចោរ ឬជាឥស្សរជនក៏ដោយ ។

សួរថា គប្បីធ្វើយ៉ាងណា ?

ឆ្លើយថា ឃើញអាគន្តុកៈ អស់ស្បៀងមកដល់វិហារ គប្បីឱ្យទឹកផឹកមុន ដោយពោលថា "អញ្ជើញផឹកទឹកចុះ", គប្បីឱ្យប្រេងលាបជើង ។ អាគន្តុកៈមកក្នុងកាលគប្បីឱ្យបាយយាគូនិងភត្ត ។ អាគន្តុកៈមកក្នុងវេលាវិកាល បើអង្ករមាន គប្បីឱ្យអង្ករ, មិនគួរនិយាយថា "លោកមកដល់ក្នុងពេលខុសវេលា, ចូរចេញទៅ" ។ គប្បីឱ្យទីដេក ។ មិនប្រាប់ថាការតបស្នងឡើយ គួរធ្វើកិច្ចគ្រប់យ៉ាង ។ មិនគួរឱ្យគំនិតកើតឡើងថា "ធម្មតាមនុស្សអ្នកឱ្យបច្ច័យ ៤, កាលយើងធ្វើការសង្គ្រោះយ៉ាងនេះ នឹងជ្រះថ្លាធ្វើឧបការៈរឿយ ៗ" ។ សូម្បីវត្ថុរបស់សង្ឃ ក៏គួរឱ្យដល់ពួកចោរបាន ។ និងដើម្បីសម្តែងអានិសង្សបដិសណ្ឋារៈ ព្រះ

អដ្ឋកថាចារ្យ ទើបពោលទុកច្រើនរឿង ក្នុងមហាអដ្ឋកថា ដោយពិស្តារ មានជាដើមយ៉ាងនេះ គឺ រឿងព្រះបាទចោរនាគ រឿងព្រះបាទមហានាគដែលស្តេចយាងទៅជម្ពូទ្វីបព្រមនឹងព្រះរាជភាតា រឿងអាមាត្រ ៤ នាក់ក្នុងរជ្ជសម័យនៃព្រះបាទបិតុរាជ រឿងអភ័យចោរ ។

## រឿងព្រះអភយត្ថេរធ្វើបដិសណ្ឋារៈនឹងអភ័យចោរ

បណ្តារឿងទាំងនោះ នឹងសម្តែងរឿងមួយដូចតទៅនេះ ៖

ដូចបានស្តាប់មកក្នុងកោះសីហឡ ចោរឈ្មោះអភ័យ មានបរិវារប្រមាណ ៥០០ នាក់ តាំងបន្ទាយនៅក្នុងទីកន្លែងមួយ ធ្វើប្រជាជនឱ្យភៀសខ្លួនទៅរហូតដល់អស់ទីចម្ងាយ (មានប្រមាណ) ៣ យោជន៍ដោយជុំវិញ ។ អ្នកក្រុងអនុរាធបុរី ឆ្លងស្ទឹងកឡម្ពៈមិនបាន ។ ក្នុងមកទៅចេតិយគិរីវិហារ ដាច់ការត្រាច់ទៅមករបស់ប្រជាជន ។ តមកថ្ងៃមួយចោរបានទៅដោយគិតថា "នឹងប្លន់ចេតិយគិរីវិហារ" ។ ពួកអារាមិកឃើញទើបប្រាប់ដល់ព្រះទីឃភាណកអភយត្ថេរ ។

ព្រះថេរៈសួរថា. ទឹកដោះថ្លានិងទឹកអំពៅជាដើម មានទេ ?

ពួកអារាមិក. ករុណា លោកម្ចាស់ មាន

ព្រះថេរៈ. ពួកលោកចូរឱ្យដល់ពួកចោរ ។ តើអង្ករមានទេ ?

ពួកអារាមិក. លោកម្ចាស់ អង្ករ បន្លែជ្រក់ និងគោរស ដែលគេនាំមកដើម្បីប្រយោជន៍ដល់សង្ឃ មាន ។

ព្រះថេរៈ. ពួកលោកចូរចាត់ចែងភត្តឱ្យដល់ពួកចោរដែលមក ។

ពួកអារាមិកធ្វើតាមព្រះថេរៈបង្គាប់ហើយ ។ ពួកចោរបរិភោគភត្តហើយ ទើបសួរថា "អ្នកណាធ្វើការទទួល ?" ។ ពួកអ្នកវត្ត. "ព្រះអភយត្ថេរអ្នកជាម្ចាស់របស់ពួកយើង" ។ ពួកចោរទៅកាន់សំណាក់របស់ព្រះថេរៈ ថ្វាយបង្គំនិងទូលប្រាប់ថា "ពួកខ្ញុំព្រះករុណាមកដោយបំណងថា 'នឹងប្លន់យករបស់សង្ឃនិងរបស់ចេតិយ, តែត្រឡប់ជ្រះថ្លាដោយបដិសណ្ឋារៈនេះរបស់ពួកលោក, តាំងពីថ្ងៃនេះទៅ ការរក្សាដែលប្រកបដោយធម៌ក្នុងព្រះវិហារ ចូរជានាទីរបស់ពួកខ្ញុំព្រះករុណា ។ ពួកអ្នកក្រុងចូរមកថ្វាយទាន ចូរសំពះព្រះចេតិយ" ។ និងតាំងពីថ្ងៃនោះមក កាលអ្នកក្រុងមកថ្វាយទាន ពួកចោរ ក៏ទៅទទួលដល់មាត់ស្ទឹងតែម្តង ចាំរក្សានាំទៅព្រះវិហារ; កាលពួកអ្នកក្រុងកំពុងថ្វាយទានសូម្បីក្នុងព្រះវិហារ ក៏នាំគ្នាឈរធ្វើការរក្សា ។ សូម្បីអ្នកក្រុងទាំងនោះក៏ឱ្យភត្តដ៏សេសពីភិក្ខុទាំងឡាយ ឆាន់ហើយដល់ពួកចោរ ។ សូម្បីក្នុងវេលាត្រឡប់ទៅ ពួកចោរនោះ ក៏ជួយបញ្ជូនអ្នកក្រុងដល់មាត់ស្ទឹងហើយទើបត្រឡប់ ។

# ព្រះថេរៈត្រូវពួកភិក្ខុលើកទោស

តមកថ្ងៃមួយ កើតពាក្យជៀលត្មះឡើងក្នុងពួកភិក្ខុថា "ព្រះថេរៈបានឱ្យវត្ថុជារបស់សង្ឃដល់ពួកចោរ ព្រោះប្រកាន់ថា ខ្លួនជាធំ" ។ ព្រះថេរៈបង្គាប់ឱ្យធ្វើការប្រជុំ(សង្ឃ)ហើយ ពោលថា "ពួកចោរនាំគ្នាមកដោយបំណងថា នឹងប្លន់យកទ្រព្យតម្លៃអាហារតាមប្រក្រតីរបស់សង្ឃនិងរបស់ចេតិយ; កាលបើដូច្នោះ យើងទើបបានធ្វើបដិសណ្ឋារៈដល់ពួកចោរទាំងនោះ ដែលមានប្រមាណប៉ុណ្ណេះ ដោយគិតឃើញថា ពួកចោរនឹងមិនប្លន់ដោយអាការយ៉ាងនេះ; ពួកលោកចូរប្រមូលវត្ថុនោះ សូម្បីទាំងអស់រួមគ្នាចូលហើយ ឱ្យវាយតម្លៃ, ចូរប្រមូលវត្ថុដែលពួកចោរមិនប្លន់ទៅ ដោយហេតុនោះរួមចូលគ្នាហើយឱ្យវាយតម្លៃ (ធៀបគ្នាមើល)" ។ ទ្រព្យដែលព្រះថេរៈឱ្យទៅសូម្បីទាំងអស់អំពីទ្រព្យរបស់សង្ឃនោះ មានតម្លៃមិនស្មើកម្រាលដែលវិចិត្តដោយរូបភាពដ៏ល្អមួយផ្ទាំងក្នុងព្រះចេតិយ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលថា "បដិសណ្ឋារៈដែលព្រះថេរៈធ្វើហើយ ជាការធ្វើប្រពៃហើយ, អ្នកណា ៗ មិនបានដើម្បីនឹងចោទ ឬដើម្បីឱ្យរលឹក, មិនមានសំណង ឬអវហារ" ។ បដិសណ្ឋារៈ មានអានិសង្សច្រើនយ៉ាងនេះ ភិក្ខុជាបណ្ឌិតកំណត់ដូចពោលមកនេះហើយ គួរធ្វើបដិសណ្ឋារៈ ដូច្នេះឯង ។

## រឿងភិក្ខុឆព្វគ្គិយចាក់ក្រឡេកភិក្ខុសត្តរសវគ្គិយជាដើម

[២១៦] ក្នុងរឿងចាក់ក្រឡេកដោយម្រាមដៃ មានវិនិច្ឆ័យដូច្នេះ ៖

បទថា ឧត្តសន្តោ : តក់ស្លុត បានដល់ អ្នកហត់នឿយ ។

បទថា អនស្សាសកោ : ផុតដង្ហើម បានដល់ អ្នកដកដង្ហើមចេញមិនទាន់ ។ ក៏ឯអាបត្តិដែលនឹងគប្បីមានក្នុងរឿងនេះ ទ្រង់សម្តែងទុកហើយ ក្នុងពួកខុទ្ទកសិក្ខាបទ; ព្រោះហេតុនោះ ទើបមិនត្រាស់ទុកក្នុងសិក្ខាបទនេះ ។

[២១៧] ក្នុងរឿងពួកសត្តរសវគ្គិយភិក្ខុចាប់សង្កត់ឆព្វគ្គិយភិក្ខុ ១ រូបទាល់តែស្លាប់ ដែលមានក្នុងលំដាប់នៃរឿងចាក់ក្រឡេកដោយម្រាមដៃនោះ មានវិនិច្ឆ័យដូច្នេះ ៖

បទថា ឱត្ថរិត្វា : សង្កត់ គឺ ជាន់ហើយ ។ បានពូមកហើយថា ភិក្ខុនោះដួលចុះ ត្រូវពួកភិក្ខុសត្តរសវគ្គិយទាំងនោះចាប់ទាញទៅ ។ ភិក្ខុមួយរូប ឡើងអង្គុយសង្កត់ពោះរបស់លោក ។ ភិក្ខុ ១៥ រូបសូម្បីដ៏សេស ក៏ជួយគ្នាសង្កត់ចុះទៅត្រង់ផែនដីជរាបស្លាប់ ដូចថ្មអង្កប់សង្កត់ម្រឹគស្លាប់ ដូច្នោះ ។ ក៏ព្រោះភិក្ខុសត្តរសវគ្គិយទាំងនោះមានសេចក្តីប្រាថ្នានឹងដាក់ទោស មិនមានសេចក្តីប្រាថ្នានឹងសម្លាប់ឱ្យស្លាប់ទេ; ដូច្នោះ ទើបព្រះមានព្រះភាគមិនពិន័យជាបារាជិក ។

## រឿងភិក្ខុសម្លាប់យក្ខ ត្រូវថុល្លច្ច័យ

[២១៨] ក្នុងរឿងភិក្ខុជាពេទ្យចាប់ខ្មោច មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា យក្ខំ មារេសិ : សម្លាប់យក្ខ[១] សេចក្តីថា ពួកអាចារ្យអ្នកបណ្តេញខ្មោច ត្រូវការទើងដោះលែងបុគ្គលដែលត្រូវយក្ខចូលស្កិត ទើបហៅយក្ខឱ្យចេញមក ហើយនិយាយថា ចូរលែង, បើយក្ខមិនលែង គ្រូខ្មោច ក៏យកម្សៅឬ ដីស្អិត ធ្វើជារូបតុក្កតាហើយកាត់អវយវៈមានដៃនិងជើងជាដើមចេញ ។ អវយវៈណា ៗ របស់រូបតុក្កតានោះដាច់ទៅ, អវយវៈនោះ ៗ របស់យក្ខ រមែងឈ្មោះថា ជាការដែលគ្រូខ្មោចកាត់ហើយដូចគ្នា ។ កាលសីសៈ (របស់រូបតុក្កតានោះ) ត្រូវកាត់ សូម្បីយក្ខក៏ស្លាប់ ។ ភិក្ខុជាគ្រូខ្មោចសូម្បីនោះបានសម្លាប់យក្ខស្លាប់ ដោយវិធីដូចពោលមកនេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគពិន័យជាថុល្លច្ច័យ ។ ជាថុល្លច្ច័យដល់ភិក្ខុដែលសម្លាប់យក្ខតែម្យ៉ាងប៉ុណ្ណោះ ក៏ទេ ។ ពិតមែន សូម្បីភិក្ខុណា គប្បីសម្លាប់ស្តេចសក្កទេវរាជស្លាប់, ភិក្ខុសូម្បីនោះ ក៏ជាថុល្លច្ច័យដូចគ្នា ។

---

១. ពាក្យនេះ មិនមានក្នុងបាលីបិដក ។

## រឿងបញ្ជូនភិក្ខុទៅកាន់ទីមានយក្ខកាចនិងសត្វសាហាវ

[២១៩] ក្នុងរឿងយក្ខកាចនិងសត្វសាហាវ មានវិនិច្ឆ័យដូច្នេះ ៖

បទថា វាឡយក្ខំ វិហារំ : វិហារដែលមានយក្ខកាច សេចក្ដីថា ភិក្ខុ (បញ្ជូន) ទៅកាន់វិហារដែលមានយក្ខកាចនៅ, ពិតមែន ភិក្ខុណា កាលមិនជ្រាបវិហារបែបនោះ ទើបបានបញ្ជូន (ភិក្ខុខ្លះ) ទៅដើម្បីត្រូវការឱ្យសម្រាកតែម្យ៉ាង, មិនជាអាបត្តិដល់ភិក្ខុនោះ ។ ភិក្ខុណាមានសេចក្ដីប្រាថ្នានឹងឱ្យស្លាប់ ទើបបញ្ជូនទៅ, ភិក្ខុនោះត្រូវបារាជិកព្រោះភិក្ខុក្រៅនេះស្លាប់, ត្រូវថុល្លច្ច័យ ព្រោះមិនស្លាប់ ។ បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នានៃអាបត្តិ និងអនាបត្តិ សូម្បីរបស់ភិក្ខុដែលបញ្ជូន (ភិក្ខុមួយរូបទៀត) ទៅកាន់វិហារដែលមានពួកម្រឹគមានរាជសីហ៍ និងខ្លាធំជាដើម ឬមានទីយជាតិទាំងឡាយ មានពស់ថ្លាន់ និងពស់វែកជាដើមនៅអាស្រ័យ ដូចភិក្ខុបញ្ជូនភិក្ខុមួយរូបទៀតទៅកាន់វិហារដែលមានយក្ខ ដូច្នោះ ។

ន័យដែលផុតចាកបាលីមានដូចតទៅនេះ ៖

បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងនៃអាបត្តិ និងអនាបត្តិរបស់ភិក្ខុដែលបញ្ជូន សូម្បីយក្ខទៅកាន់សំណាក់របស់ភិក្ខុ ដូចភិក្ខុបញ្ជូនភិក្ខុទៅកាន់វិហារដែលមានយក្ខ ដូច្នោះ ។ ក្នុងរឿងទាំងឡាយ មានមកកន្តារដោយសត្វកាចជាដើម ក៏ន័យនេះដូចគ្នា ។ ពិតមែន ក្នុងរឿងមកកន្តារមានសត្វកាចជាដើមនេះ មានត្រឹមតែសេចក្ដីចំពោះបទតែម្យ៉ាងប៉ុណ្ណោះជាឈ្មោះ (ដែលផ្សេងគ្នា) យ៉ាងនេះ គឺមកកន្តារដែលមានពួកម្រឹគកាចឬមានទីយជាតិនៅ ឈ្មោះថា ពាឡកន្តារ; មកកន្តារដែលមានពួកចោរនៅ ឈ្មោះថា ចោរកន្តារ ។ ធម្មតា ក្នុងមនុស្សវិគ្គហបារាជិកនេះល្មិតរមែងមិនផុតដោយបរិយាយកថា (កថាដោយមកអម) ។ ព្រោះដូច្នោះភិក្ខុគប្បីពោលថា "អ្នកណាកាត់សីសៈរបស់ចោរដែលអង្គុយនៅក្នុងឱកាសឈ្មោះឯណោះហើយនាំមក, អ្នកនោះ រមែងបានសក្ការៈវិសេសអំពីព្រះរាជា" ដូច្នេះ ។ បើមានអ្នកណាបានស្ដាប់ពាក្យរបស់ភិក្ខុនោះហើយទៅសម្លាប់ចោរនោះចេញ, ភិក្ខុនេះ រមែងត្រូវអាបត្តិបារាជិក ។

# រឿងភិក្ខុចំណាំភិក្ខុជាសត្រូវបានប្រាកដទើបសម្លាប់

[២២០] ក្នុងពាក្យមានជាដើមថា តំ មញ្ញមានោ : ចំណាំភិក្ខុជាសត្រូវនោះ មានវិនិច្ឆ័យដូច្នេះ ៖

បានឮថា ភិក្ខុនោះ ប្រាថ្នានឹងសម្លាប់ភិក្ខុជាមានពៀររបស់ខ្លួន ទើបគិតថា ការដែលយើងនឹងសម្លាប់ភិក្ខុជាគូពៀរវេរានេះក្នុងវេលាថ្ងៃ គេចចេញទៅដោយសេចក្តីភិតភ័យ មិនគប្បីជាវត្ថុដែលធ្វើបានងាយ យើងនឹងសម្លាប់ភិក្ខុនោះក្នុងវេលាយប់, គ្រាកំណត់ទុកហើយ មកក្នុងពេលយប់សម្គាល់ថា ភិក្ខុជាគូពៀរវេរានោះពិតប្រាកដ ក្នុងស្ថានទីភិក្ខុច្រើនរូបសិន ទើបផ្តាច់បង់ជីវិតភិក្ខុនោះឯង, មួយរូបទៀត សម្គាល់ថា ភិក្ខុជាគូពៀរវេរានោះពិតប្រាកដ តែផ្តាច់បង់ជីវិតភិក្ខុដទៃ, មួយរូបទៀត សម្គាល់ថា ភិក្ខុដទៃពិតប្រាកដដែលជាសម្លាញ់របស់ភិក្ខុដែលគូពៀរវេរានោះឯង តែក៏ផ្តាច់បង់ជីវិតភិក្ខុជាគូពៀរវេរានោះ, មួយរូបទៀត សម្គាល់ថា ភិក្ខុដទៃពិតប្រាកដដែលជាសម្លាញ់របស់ភិក្ខុជាគូពៀរវេរានោះឯង តែក៏ផ្តាច់ជីវិតភិក្ខុដទៃ ដែលជាសម្លាញ់របស់ភិក្ខុជាគូពៀរវេរានោះឯង; ជាបារាជិកដល់លោកទាំងអស់ដូចគ្នា ។

# រឿងខ្មោចចូលស្តិតភិក្ខុ

[២២១] ក្នុងរឿងរបស់ភិក្ខុដែលត្រូវខ្មោចចូលស្តិត មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុមួយរូបទៀតបានវាយ (ដល់ភិក្ខុដែលត្រូវខ្មោចចូលស្តិតនោះ) ដោយគិតថា នឹងបណ្តេញយក្ខឱ្យចៀសចេញទៅ ។ ភិក្ខុក្រៅពីនេះគិតថា គ្រានេះ យក្ខ នេះ មិនអាចនឹងធ្វើក្រោធបាន, យើងនឹងសម្លាប់វា បានវាយ ។ និងក្នុងរឿងរបស់ភិក្ខុដែលត្រូវខ្មោចចូលស្តិតរឿងដំបូងនេះ ព្រះមានព្រះភាគត្រាស់ថា "មិនជាអាបត្តិដល់ភិក្ខុ អ្នកមិនមានសេចក្តីប្រាថ្នានឹងឱ្យស្លាប់" ព្រោះហេតុនោះ ដោយព្រះពុទ្ធតម្រាស់ត្រឹមតែប៉ុណ្ណេះទុំឯង ភិក្ខុទើបមិនគួរវាយភិក្ខុដែលត្រូវខ្មោចស្តិត, តែគប្បីយកស្លឹកត្នោតឬសរសៃអំបោះព្រះបរិត្តចងទុកត្រង់ដៃឬជើង ។ គប្បីសូធ្យព្រះបរិត្តទាំងឡាយ មានរតនសូត្រជាដើម គប្បីធ្វើធម្មកថាថា "លោកកុំបៀតបៀនភិក្ខុដែលមានសីល" ដូច្នេះ ។

[២២២] រឿងពណ៌នាសួគ៌ជាដើម មានសេចក្តីច្បាស់លាស់ហើយ ។ ក៏ពាក្យដែលនឹងគប្បីពោលក្នុងរឿងពណ៌នាសួគ៌ជាដើមនេះ ខ្ញុំព្រះករុណាបានពោលទុកហើយនោះឯង ។

# រឿងភិក្ខុកាត់ដើមឈើ

[២២៣] រឿងកាត់ដើមឈើ ក៏ដូចគ្នានឹងរឿងចង្រៃ ។ តែមានសេចក្ដីប្លែកគ្នាដូចតទៅនេះ ៖

ភិក្ខុណា សូម្បីត្រូវដើមឈើរលំសង្កត់ហើយ មិនទាន់មរណភាពនិងលោកអាចនឹងកាត់ដើមឈើ ឬជីកផែនដីហើយចេញទៅដោយចំណែកម្ខាងបាន, និងក្នុងដៃរបស់លោក ក៏មានកាំបិតនិងចប, ភិក្ខុសូម្បីនោះគួរលះបង់ជីវិតចេញ, មិនគួរកាត់ដើមឈើឬមិនគួរជីកដី ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ភិក្ខុកាលធ្វើយ៉ាងនោះ រមែងត្រូវបាចិត្តិយ រមែងទម្លាយអាជ្ញារបស់ព្រះពុទ្ធ រមែងមិនធ្វើសីលឱ្យមានជីវិតជាទីបំផុត; ព្រោះហេតុនោះ សូម្បីជីវិតក៏គួរលះបង់ចេញ តែមិនគួរលះបង់សីល; គ្រាភិក្ខុបានស្ដាប់ពាក្យល្អិតល្អន់ដូចពោលមកហើយនេះ មិនគប្បីធ្វើ (ការកាត់ដើមឈើនិងជីកដី) ដោយអាការយ៉ាងនេះ ។ ការកាត់ដើមឈើឬជីកដីហើយនាំភិក្ខុនោះចេញ រមែងគួរដល់ភិក្ខុដទៃ ។ បើលោកនឹងគប្បីត្រូវគេប្រមៀលដើមឈើដោយគ្រឿងយន្តនាំចេញ, គួរកាត់យកដើមឈើនោះឯង ប្រើជាកំណល់ ។ ព្រះមហាសុមត្ថេរពោលថា នឹងកាត់យកដើមឈើសូម្បីដទៃក៏គួរ ។ ព្រះមហាបទុមត្ថេរពោលថា ក្នុងការចងបង្អោង (ជណ្ដើរ) ជួយមនុស្សសូម្បីអ្នកធ្លាក់ចុះទៅក្នុងអណ្ដូងជាដើមឱ្យឡើង

បានក៏ន័យនេះដែរ, ភិក្ខុមិនគួរកាត់ភូតគាមធ្វើបង្អោងដោយខ្លួនឯង ។ ការធ្វើ ( បង្អោង ) ហើយលើកឡើង រមែងសមគួរដល់ភិក្ខុពួកដទៃ ។

## រឿងភិក្ខុឆព្វគ្គិយដុតព្រៃ

[២២៤] ក្នុងរឿងដុតព្រៃ មានវិនិច្ឆ័យដូច្នេះ ៖

ពីរបទថា **ទាយំ អាលិម្បេសុំ : នាំគ្នាដុតព្រៃ** សេចក្ដីថា ពួកភិក្ខុឆព្វគ្គិយ បានដុតភ្លើងក្នុងព្រៃ ។ ក៏ក្នុងរឿងដុតព្រៃនេះ បណ្ឌិតគប្បីជ្រាបថា ជាបារាជិកជាដើម តាមសមគួរដល់វត្ថុនៃបារាជិក អនន្តរិយកម្មថុល្លច្ច័យ និងបាចិត្តិយ ដោយអំណាចប្រយោគដែលចំពោះនិងមិនចំពោះ និងភាពជាកងអកុសល ដោយន័យដូចពោលហើយក្នុងសេចក្ដីខាងដើមនុ៎ះឯង, ព្រះអដ្ឋកថាចារ្យពោលទុកក្នុងសង្ខេបអដ្ឋកថាថា ក៏កាលភិក្ខុដុតដោយគិតថា ស្មៅស្រស់និងឈើជាម្ចាស់នៃព្រៃទាំងឡាយចូរត្រូវភ្លើងឆេះ ជាបាចិត្តិយ, កាលដុតដោយគិតថា គ្រឿងឧបករណ៍ឈើទាំងឡាយចូរវិនាសទៅ ជាទុក្កដ, កាលដុតសូម្បីដោយសេចក្ដីប្រាថ្នានឹងលេង ក៏ជាទុក្កដ ។ កាលដុតដោយគិតថា ឈើស្រស់និងឈើស្ងួតប្រភេទណាមួយ ដែលមានឥន្ទ្រិយនិងមិនមានឥន្ទ្រិយក៏ដោយចូរត្រូវភ្លើងឆេះ គប្បីជ្រាបថា ជាអាបត្តិបារាជិក ថុល្លច្ច័យ បាចិត្តិយនិងទុក្កដដោយអំណាចនៃវត្ថុ ។ ក៏ការដុតភ្លើងទទួលនិងធ្វើការពារ ព្រះមានព្រះ

ភាគទ្រង់អនុញ្ញាតទុកហើយ ។ ព្រោះដូច្នោះ ការដែលភិក្ខុឃើញភ្លើងដែលពួកវនកម្មិកជនដុត ឬកើតឡើងឯងក្នុងព្រៃកំពុងរាលដាលមក ហើយដុតភ្លើងទទួលភ្លើងដែលនឹងជាហេតុឱ្យភ្លើងឆេះរាលដាលចូលមក បន្តគ្នាឆេះអស់ហើយរលត់ទៅ ដោយតាំងចិត្តថា "ខ្ទមស្មៅទាំងឡាយចូរកុំវិនាស" ដូច្នេះ រមែងគួរ ។ ការដែលភិក្ខុនឹងធ្វើសូម្បីគ្រឿងការពារ គឺ ការកកាយផែនដីឬជីកប្រឡាយទុកដោយជុំវិញខ្ទមប្រក់ស្មៅ ដោយប្រការដែលភ្លើងឆេះរាលដាលមក មិនមានបានឆេះជាប់គ្នាហើយក៏រលត់ទៅឯង ក៏គួរ ។ និងកាលភ្លើងរាលដាលឡើងហើយប៉ុណ្ណោះ ទើបគួរធ្វើកិច្ច មានដុតភ្លើងទទួលជាដើមទាំងអស់នោះ ។ កាលភ្លើងមិនទាន់រាលដាលឡើង គប្បីប្រើអនុបសម្បន្នឱ្យធ្វើដោយកប្បិយវោហារ, និងកាលឱ្យរលត់ដោយទឹក គួរប្រើទឹកដែលមិនមានសត្វប៉ុណ្ណោះស្រោច ។

## រឿងភិក្ខុបង្គាប់ពេជ្ឈឃាតឱ្យប្រហារតែមួយដង

[២២៥] ក្នុងរឿងកន្លែងពិឃាត មានវិនិច្ឆ័យដូច្នេះ ៖

ជាបារាជិក ព្រោះពាក្យបង្គាប់ប្រហារម្តង យ៉ាងណា, សូម្បីក្នុងពាក្យបង្គាប់ជាដើមថា ទ្វីហិ បហារេហិ : ដោយប្រហារពីរដង ក៏គប្បីជ្រាបថា ជាអាបត្តិបារាជិក ដូច្នោះ, ក៏កាលភិក្ខុបង្គាប់ថា ទ្វីហិ ដូច្នេះ សូម្បីកាលអ្នកទោសត្រូវពេជ្ឈឃាតសម្លាប់ស្លាប់ ដោយការប្រហារម្តង

ឈ្មោះថា ជាបារាជិក ព្រោះធ្លាក់ចុះកាន់ខេត្តហើយនុ៎ះឯង ។ តែកាលអ្នកទោសត្រូវពេជ្ឈឃាតសម្លាប់ស្លាប់ ដោយការប្រហារ ៣ ដង ជាការខុសសង្កេត ។ កាលត្រូវសម្លាប់ស្លាប់ ក្នុងខេត្តតាមដែលកំណត់ទុក ឬមិនរួមក្នុងទីកំណត់ទុក រមែងមិនខុសសង្កេត ដោយប្រការដូច្នេះ ។ តែ (កាលត្រូវសម្លាប់ស្លាប់ )ក្នុងកាលកន្លងហួសកំណត់ទៅ រមែងខុសសង្កេត ក្នុងទីគ្រប់កន្លែង, ភិក្ខុអ្នកបង្គាប់ រមែងរួចផុត, ពេជ្ឈឃាតអ្នកសម្លាប់ប៉ុណ្ណោះ មានទោស ។ ដូចជា ន័យដែលពោលទុកហើយក្នុងការប្រហារច្រើនលើក យ៉ាងណា ន័យនេះក៏យ៉ាងនោះ បណ្ឌិតគប្បីជ្រាបថា កាលភិក្ខុបង្គាប់ថា "សូម្បីបណ្ដាបុរសទាំងឡាយ បុរសម្នាក់ចូរសម្លាប់បុគ្គលម្នាក់ឱ្យស្លាប់" ដូច្នេះ, កាលបុគ្គលនោះ ត្រូវបុរសម្នាក់នុ៎ះឯងសម្លាប់ស្លាប់ ភិក្ខុត្រូវអាបត្តិបារាជិក, កាលបុគ្គលនោះ ត្រូវបុរសពីរនាក់សម្លាប់ស្លាប់ ជាការខុសសង្កេត, កាលភិក្ខុបង្គាប់ថា បុរសពីរនាក់ចូរនាំគ្នាសម្លាប់បុរសម្នាក់ឱ្យស្លាប់ ដូច្នេះ កាលបុគ្គលនោះត្រូវបុរសម្នាក់ ឬពីរនាក់សម្លាប់ស្លាប់ ភិក្ខុត្រូវបារាជិក, កាលត្រូវបុរសបីនាក់សម្លាប់ស្លាប់ ជាការខុសសង្កេត ។ កាលមានអ្នកសួរ ពោលថា ភិក្ខុមួយរូបយកដាវកាត់សីសៈរបស់បុរស ដែលរត់ទៅដោយរហ័សក្នុងសមរភូមិប្រយុទ្ធដាច់-ក, រាងកាយមិនមានក្បាល រមែងរត់ឆ្ពោះទៅ, ភិក្ខុដទៃទើបប្រហាររាងកាយមិនមានក្បាលនោះឱ្យដួលចុះទៅ ។ ភិក្ខុណា ជា

បារាជិក ? ដូច្នេះ, ព្រះថេរៈចំនួនពាក់កណ្ដាលឆ្លើយថា ជាបារាជិកដល់ភិក្ខុដែលប្រហារពងកាយឱ្យការរត់ឆ្ពោះទៅជួលចុះ ។

ព្រះគោទត្តត្ថេរ អ្នកជំនាញព្រះអភិធម្ម ឆ្លើយថា ជាបារាជិកដល់ភិក្ខុដែលកាត់ក្បាល ។ ក្នុងការសម្ដែងសេចក្ដីនៃរឿងនេះ បណ្ឌិតគួរពោលរឿងទាំងឡាយ សូម្បីមានសភាពបែបនេះឯង ។

## រឿងភិក្ខុបង្គាប់ឱ្យបុរសកំបុតផឹកខ្លាញ់ស្លាប់

[២២៦] ក្នុងរឿងខ្លាញ់ មានវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុបង្គាប់មិនកំណត់ថា ពួកលោកចូរឱ្យបុរសអ្នកមានដៃនិងជើងកំបុតនោះផឹកខ្លាញ់ ដូច្នេះ, កាលបុរសនោះ ត្រូវពួកញាតិឱ្យផឹកខ្លាញ់ប្រភេទណាមួយស្លាប់ទៅ, ភិក្ខុត្រូវបារាជិក ។ តែកាលភិក្ខុបង្គាប់កំណត់ទុកថា ចូរឱ្យផឹកខ្លាញ់គោ ខ្លាញ់ក្របី ខ្លាញ់ពពែ ឬបង្គាប់ទុកថា ចូរឱ្យផឹកខ្លាញ់ដែលត្រជាក់ ខ្លាញ់ដែលក្ដៅ ខ្លាញ់ដែលពោលផ្សេង ដែលមិនបានពោលផ្សេង កាលបុរសនោះត្រូវពួកញាតិឱ្យផឹកខ្លាញ់ប្រភេទដទៃអំពីខ្លាញ់ដែលភិក្ខុបង្គាប់ទុកនោះស្លាប់ទៅ ជាការខុសសង្កេត ។

## រឿងថ្នាំត្រាំពិសេសឈ្មោះលោណសោចិរកៈ

ក្នុងរឿងថ្នាំត្រាំលោណសោចិរកៈ មានវិនិច្ឆ័យដូច្នេះ ៖

ថ្នាំត្រាំមួយប្រភេទដែលផ្សំដោយស្រូវគ្រប់ប្រភេទ ឈ្មោះថា លោណសោចិរកៈ ។ កាលគេនឹងធ្វើថ្នាំប្រភេទនោះ យកទឹកចត់នៃផ្លែសម៉ កន្ទួតព្រៃ និងសម៉ពិភេក ធញ្ញជាតិគ្រប់ប្រភេទអបរណ្ណជាតិគ្រប់ប្រភេទ បាយនៃធញ្ញជាតិទាំង ៧ ប្រភេទ ផ្លែគ្រប់ប្រភេទមានផ្លែចេកជាដើម ផ្លែឈើដែលដុះចេញពីមើមគ្រប់ប្រភេទ មានផ្លែផ្គៅ ផ្លែរំចេក និងល្មើជាដើមដុំត្រីនិងសាច់ និងភេសជ្ជៈច្រើនយ៉ាង មានទឹកឃ្មុំ ស្ករអំពៅ អំបិលសមុទ្រ:(អំបិលប្រៃ) អំបិលធម្មតា និងគ្រឿងហឹរ ៣ ប្រភេទជាដើម ហើយ ដាក់រួមគ្នាចុះ (ក្នុងឆ្នាំង)បិទមាត់ឆ្នាំងទុកយ៉ាងល្អ ហើយរក្សាទុក ១ ឆ្នាំ ២ ឆ្នាំ ឬ ៣ ឆ្នាំ ថ្នាំលោណសោចិរកៈនោះ ត្រាំឱ្យមានពណ៌ដូចទឹកព្រីង ជាគ្រឿងបរិភោគយ៉ាងស្និទ្ធ (ជាថ្នាំព្យាបាលរោគយ៉ាងសក្តិសិទ្ធ) នៃបុគ្គលដែលកើតរោគខ្យល់ រោគក្អក រោគឃ្លង់ រោគស្គមល្មៀង និងរោគឫសដូងបាតជាដើម និងជាគ្រឿងផឹកខាងក្រោយពីការបរិភោគអាហារហើយ ។ ភេសជ្ជៈជាគ្រឿងរំលាយអាហារដែលបរិភោគហើយ ដូចថ្នាំត្រាំនោះ រមែងមិនមាន ។ ក៏ថ្នាំលោណសោចិរកៈនេះ រមែងគួរដល់ភិក្ខុទាំងឡាយសូម្បីក្នុងបច្ឆាភត្ត ។ សម្រាប់ភិក្ខុដែលអាពាធ ចាត់ជាថ្នាំតាមប្រក្រតីតែម្តង តែអ្នកមិនអាពាធត្រូវផ្សំនឹងទឹកទើបគួរ ដោយភាពជាថ្នាំនិងគ្រឿងបរិភោគហោង ។

# ចប់ មនុស្សវិគ្គហសិក្ខាបទវណ្ណនា

## ៤. ឧត្តរិមនុស្សធម្មសិក្ខាបទវណ្ណនា

ព្រះសាស្ដា ទ្រង់ដឹងច្បាស់សច្ចៈទាំង ៤ ទ្រង់ប្រកាស ចតុត្ថបារាជិកណាទុកហើយ, ឥឡូវនេះ មកដល់លំដាប់សំវណ្ណនានៃចតុត្ថបារាជិកនោះហើយ; ព្រោះហេតុនោះ ពាក្យណាដែលទឹងគប្បីដឹងបានងាយ និងពាក្យដែលខ្ញុំព្រះករុណាបានប្រកាសហើយក្នុងវណ្ណនាខាងដើម, សំវណ្ណនានេះនៃចតុត្ថបារាជិកសូម្បីនោះ និង វៀរពាក្យនោះ ៗ ចេញ ។

### រឿងពួកភិក្ខុចាំវស្សាមាត់ស្ទឹងវគ្គុមុទា

[២២៧] ពាក្យថា តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ ។បេ។ គិហីនំ កម្មន្តំ អធិដ្ឋេម : ក្នុងសម័យនោះឯងព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅកូដាគារសាលានាព្រៃមហាវ័នទៀបក្រុងវេសាលី ។ល។ យើងត្រូវទទួលរាប់រងការងាររបស់ពួកគ្រហស្ថចុះ សេចក្ដីថា ពួកយើងចូរទទួលរាប់រងការងារដែលគួរធ្វើ ក្នុងស្រែនិងក្នុងសួនជាដើមរបស់ពួកគ្រហស្ថចុះ ។ ពួកយើងធ្វើការងារក្នុងស្រែនិងក្នុងសួនជាដើម របស់ពួកគ្រហស្ថចុះ ។ មានពាក្យអធិប្បាយថាពួកយើងចូរប្រាប់ និងចូរទូន្មានថា “ពួកលោកគួរធ្វើយ៉ាងនេះ មិនគួរធ្វើយ៉ាងនេះ” ។

បទថា ទូតេយ្យំ : ជាអ្នកបម្រើនាំដំណឹង បានដល់ ការងាររបស់ទូត ។

បទថា ឧត្តរិមនុស្សធម្មស្ស បានដល់ ធម៌ដែលកន្លងហួសពួកមនុស្សទៅ ។ អធិប្បាយថា ធម៌ដែលកន្លងហួសពួកមនុស្សទៅឱ្យដល់ភាពជាព្រហ្ម ឬព្រះនិព្វាន ។ ម្យ៉ាងទៀត បានដល់ ធម៌របស់មនុស្សដ៏កំពូលក្រៃលែង គឺ បុរសដ៏ប្រសើរបំផុត ដែលជាអ្នកបានឈាន និងជាព្រះអរិយៈ ។

ក្នុងពាក្យថា អសុកោ ភិក្ខុ : ភិក្ខុឯណោះ ជាដើម មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុទាំងឡាយប្រឹក្សានឹងខ្លួនយ៉ាងនោះ ខាងក្រោយ កាលពោលនឹងពួកគ្រហស្ថគប្បីជ្រាបថា បានពោលសរសើរដោយអំណាចនៃឈ្មោះតែម្តង យ៉ាងនេះថា ភិក្ខុឈ្មោះពុទ្ធរក្ខិតបានបឋមជ្ឈាន ឈ្មោះធម្មរក្ខិតបានទុតិយជ្ឈានដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ច្រើនបទពាក្យថា ឯសោយេវ ខោ អាវុសោ សេយ្យោ : ភិក្ខុទាំងនោះ ក៏យល់ព្រមនឹងគ្នាថា ម្នាលអាវុសោទាំងឡាយស្រួលហើយ មានសេចក្តីថា ការទទួលរាប់រងការងារ និងការនាំដំណឹងទៅដោយភាពជាទូត មានសត្រូវច្រើន មានការប្រណាំងប្រជែងគ្នាច្រើន

ទាំងជារបស់មិនសមគួរដល់សមណៈ ។ ចំណែកការដែលពួកយើងនាំគ្នាពោលសរសើរឧត្តរិមនុស្សធម្មរបស់គ្នានិងគ្នា ដល់ពួកគ្រហស្ថនេះឯងជាកិច្ចដែលប្រសើរគួរសរសើរជាង គឺ ឧត្តមជាង ល្អជាង បានដល់ល្អជាងកិច្ចទាំងពីរនោះណាទីមួយ ។ លោកពោលអធិប្បាយទុកយ៉ាងណា ? ពោលទុកថា ការដែលពួកយើងនឹងនាំគ្នាពោលសរសើរឧត្តរិមនុស្សធម៌របស់គ្នានិងគ្នាដល់ពួកគ្រហស្ថ អ្នកសាកសួរ ឬអ្នកមិនបានសួរដល់ភិក្ខុដែលសម្រួលឥរិយាបថហើយអង្គុយក្ដី ចង្រ្កមក្ដី ឬដោយន័យមានជាដើមយ៉ាងនេះថា "ភិក្ខុឈ្មោះឯណោះ បានបឋមជ្ឈាន" នេះឯង ប្រសើរបំផុត ។

## អធិប្បាយសំពួកិរិយាអនាគត

ក៏កាលសេចក្ដីសម្ព័ន្ធដោយកិរិយាអនាគត មិនមាន ភិក្ខុទាំងនោះនឹងពោលសរសើរគុណនោះ ក្នុងខណៈនោះមិនបានឡើយ, ព្រោះហេតុនោះ សេចក្ដីដែលលោកមិនបានតែងបាលីដ៏សេស ពោលទុកថា ភាសិតោ ភវិស្សតិ ទើបមិនត្រូវ; ព្រោះដូច្នោះ ក្នុងបទថា ភាសិតោ នេះ បណ្ឌិតគួរធ្វើឱ្យមានសេចក្ដីសម្ព័ន្ធដោយកិរិយាអនាគត ហើយគប្បីជ្រាបអត្ថយ៉ាងនេះថា គុណយ៉ាងណា នឹងជាវត្ថុដែលពួកយើងពោលសរសើរយ៉ាងនោះ គុណយ៉ាងនោះ ប្រសើរជាទីបំផុត ។ តែអ្នកសិក្សា

គួរស្វែងរកលក្ខណៈអំពីគម្ពីរសព្ទសាស្ត្រ ។

ពីរបទថា វណ្ណវា[១] អហេសុម : មានសម្បុរល្អ សេចក្ដីថា វណ្ណៈនៃសរីរៈដែលថ្មីយ៉ាងដទៃទុំះឯង កើតឡើងដល់ភិក្ខុទាំងនោះ, ភិក្ខុទាំងនោះ បានជាអ្នកមានសម្បុរដោយវណ្ណៈនោះ ។

បទថា បិនិន្ទ្រិយា[២] : មានឥន្ទ្រិយពេញលេញ សេចក្ដីថា ឈ្មោះថា ជាអ្នកមានឥន្ទ្រិយផូរផង់ ដោយសភាពដែលឥន្ទ្រិយទាំងឡាយមានចិត្តជាគម្រប់ ៦ មិនស្ងួតស្រពោន ព្រោះឱកាសដែលប្រសាទទាំង ៥ តាំងមាំ ជារបស់បរិបូណ៌ ។

បទថា បសន្នមុខវណ្ណា : មានទឹកមុខស្រស់បស់ មានសេចក្ដីថា ជាអ្នកមានទឹកមុខផូរផង់ដោយមិនប្លែកគ្នា ក៏ពិតមែនហើយ, តែថា ពណ៌មុខរបស់ភិក្ខុទាំងនោះ ក៏ថ្លាផូរផង់ខាំងជាងវណ្ណៈនៃសរីរៈ ។ អធិប្បាយថា ថ្លាផូរផង់មិនស្រអាប់ គឺ បរិសុទ្ធិ ។

បទថា វិប្បសន្នច្ឆវិវណ្ណា : មានសម្បុរស្បែកក៏ជ្រះថ្លា មានសេចក្ដីថា ក៏ភិក្ខុទាំងនោះ ជាអ្នកមានសម្បុរដោយវណ្ណៈណា ដែលដូចជាផ្កាកណ្ណិការ, វណ្ណៈដូច្នោះរបស់មនុស្សទាំងឡាយសូម្បីពួកដទៃ ក៏មាន,[៣]

---

១. បិដក. វណ្ណវន្តោ ។ ២. ភូមា. បិណិន្ទ្រិយា ។

៣. គួរតែថា "មិនមាន", អត្ថយោជនា : តែពួកមនុស្សមិនផូរផង់ដូចពួកភិក្ខុ ។

ដូចថា (វណ្ណៈយ៉ាងនោះ) របស់មនុស្សទាំងនេះ យ៉ាងណា, របស់ភិក្ខុទាំងនោះ មិនយ៉ាងនោះទេ គឺ ពណ៌សម្បុររបស់ភិក្ខុទាំងនោះ ផូរផង់ ។ ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយទើបពោលទុកថា មានពណ៌សម្បុរផូរផង់ ។ ដោយប្រការយ៉ាងនេះឯង ភិក្ខុទាំងនោះមិនប្រឹងប្រែងប្រកបឧទ្ទេសនិងបរិបុច្ឆាឡើយ ទាំងមិនប្រឹងប្រែងប្រកបកម្មដ្ឋានផង, ដោយសភាពពិត កាលឆាន់ភោជនប្រណីត ដែលបានមកដោយការពណ៌នាគុណដែលមិនជាពិតជាការបោកបញ្ឆោត ហើយតាមប្រកបនូវភាពជាអ្នកត្រេកអរក្នុងការលង់លក់តាមសប្បាយ និងភាពជាអ្នកត្រេកអរក្នុងការច្របូកច្របល់ដោយពួក ទើបដល់សេចក្តីសោភានៃសរីរៈនេះ មានចំណែកប្រៀបដូចពួកម្រឹគកាចសាហាវ ដូច្នេះឯង ។

## ទ្រង់ត្រាស់សួរពួកភិក្ខុដែលនៅមាត់ស្ទឹងវគ្គុមុទា

[២២៨] បទថា វគ្គុមុទាតីរិយា : ទៀបឆ្នេរស្ទឹងវគ្គុមុទា បានដល់ ពួកភិក្ខុដែលនៅក្បែរមាត់ស្ទឹងវគ្គុមុទា ។

ពាក្យថា កច្ចិ ភិក្ខវេ ខមនិយំ : **ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា ល្មមអត់ធន់បានទេឬ** សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ សរីរយន្តនេះរបស់ពួកលោក ដែលមានចក្រ ៤

មានទ្វារ ៩ ល្មមអត់ធន់បានឬទេ ? គឺ ពួកលោកអាចដើម្បីអត់ធន់អត់ទ្រាំ ដើម្បីបរិហារបានឬទេ ? សរីរយន្តរបស់ពួកលោក មិនឱ្យទុក្ខយ៉ាងណា កើតឡើងទេឬ ?”

ពាក្យថា កច្ចិ យាបនិយំ : អ្នករាល់គ្នា ល្មមប្រព្រឹត្តទៅបានស្រួលទេឬ សេចក្តីថា ព្រះមានព្រះភាគត្រាស់សួរថា ពួកលោកអាចដើម្បីឱ្យសរីរយន្តប្រព្រឹត្តទៅ គឺ ឱ្យដំណើរទៅក្នុងកិច្ចទាំងពួងខ្លះឬ ? សរីរយន្តរបស់ពួកលោកមិនមានអន្តរាយណាមួយទេឬ ?

[២២៩] ពីរបទថា កុច្ឆិ បរិកន្តោ : វះពោះ( របស់ខ្លួន )វិញ សេចក្តីថា ពោះដែលពួកលោកវះហើយ ជាកិច្ចល្អជាង ។ បាលីថា កុច្ឆិ បរិកត្តោ ខ្លះ ក៏ប្រើបាន ។

## ចោរខាងក្រៅសាសនាត្រាច់ប្លន់ស្រុកជាយដែនជាដើម

[២៣០] គ្រានោះឯង ព្រះមានព្រះភាគ គ្រាទ្រង់តិះដៀលពួកភិក្ខុដែលនៅមាត់ស្ទឹងវគ្គុមុទា ដោយអនេកបរិយាយយ៉ាងនេះហើយ ឥឡូវនេះទើបត្រាស់ហៅភិក្ខុទាំងឡាយមក ។ ក៏កាលត្រាស់ហៅមកហើយ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ មានភិក្ខុជាមហាចោរ ៥ ពួក” ជាដើម ដើម្បីមិនឱ្យភិក្ខុសូម្បីពួកដទៃធ្វើកម្មបែបនោះតទៅ ព្រោះ

កម្មដែលភិក្ខុអ្នកនៅមាត់ច្រាំងស៊ីងវត្ថុមុខទាំងនោះធ្វើ ចាត់ជាចោរកម្ម ។

បណ្តាបទទាំងនោះ ពីរបទថា សន្តោ សំវិជ្ជមានា : ដែលមានប្រាកដ មានពាក្យអធិប្បាយថា នៅមាន និងរកបាន ។

បទថា ឥធ : ក្នុងលោកនេះ គឺ ក្នុងសត្វលោកនេះ ។

ពីរបទថា ឯវំ ហោតិ : ដែលមាន យ៉ាងនេះ សេចក្តីថា សេចក្តីប្រាថ្នាក្នុងចំណែកខាងដើម រមែងកើតឡើងយ៉ាងនេះ ។ សព្ទថា សុ ក្នុងពាក្យថា កុទាស្សុ នាមាហំ : បើដល់វេលាណា អញបានបរិស័ទ នេះជានិបាត ។ សេចក្តីថា តើកាលណាហ្ន៎ ? ពាក្យថា សោ អបរេន សមយេន : លុះសម័យខាងក្រោយមក សេចក្តីថា មហាចោរនោះ កាលគិតក្នុងចំណែកខាងដើមយ៉ាងនោះហើយ ក៏ប្រមូលកពូនបរិស័ទឡើងដោយលំដាប់ ធ្វើកម្មមានជាដើមយ៉ាងនេះ គឺ កម្មជាហេតុប្រទូសរ៉ាយអ្នកធ្វើដំណើរ ប្លន់អ្នកស្រុកដែលតាំងនៅជាយដែន ជាបុរសអ្នកដល់សេចក្តីចម្រើនបរិបូណ៌ឡើងហើយ ធ្វើស្រុកមិនឱ្យជាស្រុកខ្លះ ធ្វើជនបទមិនឱ្យជាជនបទខ្លះ សម្លាប់ដោយខ្លួនឯង ឱ្យអ្នកដទៃសម្លាប់ កាត់ដោយខ្លួនឯង ឱ្យអ្នកដទៃកាត់ ដុតបំផ្លាញដោយខ្លួនឯង ឱ្យអ្នកដទៃដុតបំផ្លាញ ។

## មហាចោរក្នុងសាសនាត្រាច់ញាំញីសិក្ខាបទ

លុះព្រះមានព្រះភាគទ្រង់សម្តែងចោរខាងក្រៅយ៉ាងនេះហើយ ទើបត្រាស់ព្រះតម្រាស់ថា ឯវមេវ ខោ : យ៉ាងណាមិញ ជាដើម ដើម្បីទ្រង់សម្តែងមហាចោរ ៥ ពួកក្នុងព្រះសាសនា អ្នកដូចនឹងចោរខាងក្រៅនោះ ។

បណ្តាបទទាំងនោះ បទថា ធាបភិក្ខុនោ : ភិក្ខុបាប សេចក្តីថា ក្នុងទីដទៃ ៗភិក្ខុដែលត្រូវអាបត្តិបារាជិក មានមូលដាច់ហើយ លោកហៅថា ភិក្ខុដែលអាក្រក់ថោកទាប ។ ចំណែកក្នុងសិក្ខាបទនេះ ភិក្ខុដែលមិនបានត្រូវបារាជិក តែតាំងនៅក្នុងឥច្ឆាចារត្រាច់ញាំញីសិក្ខាបទតូចធំ លោកប្រាថ្នាយកថា ភិក្ខុដែលអាក្រក់ថោកទាប ។ សេចក្តីប្រាថ្នាក្នុងចំណែកខាងដើម រមែងកើតឡើង សូម្បីដល់ភិក្ខុអាក្រក់ថោកទាបនោះដូចគ្នាឡើងដល់មហាចោរខាងក្រៅយ៉ាងនេះថា "បើកាលណា អញបានបរិស័ទ ១ រយ ឬ ១ ពាន់ ចោមរោមជាគ្នាហើយ នឹងត្រាច់ទៅកាន់ចារិកក្នុងស្រុកនិគមរាជធានី ក៏នឹងបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ដែលពួកគ្រហស្ថក្តី ពួកបព្វជិតក្តី ធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង" ។

បណ្តាបទទាំងនោះ បទថា សក្កតោ : ធ្វើសក្ការៈ បានដល់

អ្នកប្រសព្វសក្ការៈ ។

បទថា គរុកតោ : គោរព បានដល់ អ្នកបានទទួលសេចក្ដីគោរព ។

បទថា មានិតោ : រាប់អាន បានដល់ អ្នកដែលគេស្រឡាញ់ដោយពេញចិត្ត ។

បទថា បូជិតោ : បូជា បានដល់ អ្នកដែលគេបូជាហើយដោយការបូជា គឺ នាំមកចំពោះនូវបច្ច័យទាំង ៤ ។

បទថា អបចិតោ : កោតក្រែង បានដល់ អ្នកដល់សេចក្ដីកោតក្រែង, បណ្ដាបុគ្គលទាំងនោះជនទាំងឡាយធ្វើសក្ការៈដោយបច្ច័យ ៤ គឺ ធ្វើបច្ច័យ ៤ ដែលតាក់តែងទុកយ៉ាងល្អឱ្យប្រណីត ៗ ហើយទើបប្រគេនដល់លោកអង្គណា, លោកអង្គនោះ ឈ្មោះថា ដែលគេធ្វើសក្ការៈហើយ ។ ជនទាំងឡាយឱ្យសេចក្ដីគោរព ចូលទៅតាំងចំពោះលោកអង្គណាហើយ ទើបប្រគេន លោកអង្គនោះ ឈ្មោះថា គេគោរពហើយ ។ ជនទាំងឡាយ រមែងស្រលាញ់លោកអង្គណា ដោយពេញចិត្ត, លោកអង្គនោះ ឈ្មោះថា ដែលគេរាប់អានហើយ ។ ជនទាំងឡាយ រមែងធ្វើកិច្ច មានការធ្វើសក្ការៈជាដើមនោះសូម្បីទាំងអស់ ដល់លោកអង្គណា, លោកអង្គនោះ ឈ្មោះថា ដែលគេបូជាហើយ ។ ជនទាំងឡាយ រមែង

ធ្វើការឱនលំទោនយ៉ាងក្រៃលែង ដោយអំណាចនៃកិច្ច មានការក្រាបថ្វាយបង្គំ ក្រោកទទួល និងលើកដៃប្រណមសំពះជាដើម ដល់លោកអង្គណា, លោកអង្គនោះ ឈ្មោះថា ដែលគេកោតក្រែងហើយ ។

ក៏សេចក្តីប្រាថ្នាយ៉ាងនេះ រមែងមានដល់ភិក្ខុដែលអាក្រក់ថោកទាបនេះ អ្នកប្រាថ្នានូវលោកាមិសសូម្បីទាំងអស់នេះ ។

ពាក្យថា សោ អបរេន សមយេន : លុះដល់សម័យខាងក្រោយមក មានសេចក្តីថា ភិក្ខុដែលអាក្រក់ថោកទាបនោះគ្រាគិតក្នុងចំណែកខាងដើម យ៉ាងនោះហើយ សង្គ្រោះពួកភិក្ខុអាក្រក់ថោកទាបអ្នកមិនមានសេចក្តីគោរពកោតក្រែងក្នុងសិក្ខា រវើរវាយ មិនសប្បាយរសាប់រសល់ មាត់រឹង និយាយរោយរាយ វង្វេងភ្លេចសតិ មិនមានសម្បជញ្ញៈ មានឥន្ទ្រិយបើក (អ្នកមិនសង្រួមឥន្ទ្រិយ) ដែលអាចារ្យនិងឧបជ្ឈាយ៍លះបង់ចោលហើយ អ្នកជូនក្នុងលាភ ដោយលំដាប់ហើយឱ្យសិក្សាធម្មទំនៀមរបស់អ្នកបោកបញ្ឆោតទាំងឡាយ មានការតម្កល់កិរិយាឫកពារជាដើម ជាអ្នកមានគុណដែលពួកភិក្ខុអាក្រក់ថោកទាប អ្នកធ្វើសេចក្តីសន្សំ ក្នុងនិទានជាតកជាដើម សម្បូរណ៍ដោយក្រសែសំឡេង អាចដើម្បីបោកបញ្ឆោតពួកអ្នកស្រុក សរសើរដោយឧបាយទាំងឡាយ មានការពណ៌នាដល់សេនាសនៈដែលមនុស្សលោក

សន្ទុតិជាដើម យ៉ាងនេះថា "ព្រះថេរៈរូបនេះ ចូលចាំវស្សានៅក្នុងសេនាសនៈឈ្មោះឯណោះ បំពេញវត្តបដិបត្តិចេញវស្សាហើយក៏នឹងចេញទៅ ជាអ្នកដែលមានភិក្ខុទាំងរយ ឬទាំងពាន់ចោមរោម ត្រាច់ចារិកទៅក្នុងស្រុកនិគម និងរាជធានី ដែលគ្រហស្ថ និងបព្វជិត ធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានចីវរ បិណ្ឌបាតសេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ" ។

## មហាចោរក្នុងព្រះសាសនាមាន ៥ ពួក

ពាក្យថា អយំ ភិក្ខវេ បឋមោ មហាចោរោ : **ម្នាលភិក្ខុទាំងឡាយ នេះ ហៅថា មហាចោរទី១** មានសេចក្ដីថា ភិក្ខុដែលអាក្រក់ថោកទាបដូចជាចោរអ្នកកាត់ទីតជាដើមនេះ គប្បីជ្រាបថា ជាមហាចោរពួកទី ១ ព្រោះមិនមែននឹងបោកបញ្ឆោតត្រកូលមួយ ឬត្រកូលពីរប៉ុណ្ណោះក៏ទេ ។ ដោយការពិត គឺបោកបញ្ឆោតមហាជន កាន់យកបច្ច័យ ៤ ផង ។ ចំណែកភិក្ខុពួកណា អ្នកស្ទាត់ជំនាញក្នុងព្រះសូត្រ ស្ទាត់ជំនាញក្នុងព្រះអភិធម្ម ឬទ្រទ្រង់ព្រះវិន័យ កាលភិក្ខាចារមិនសម្បូរណ៍ត្រាច់ចារិកទៅតាមជនបទប្រាប់បាលី ពោលអដ្ឋកថា ញ៉ាំងអ្នកស្រុកឱ្យជ្រះថ្លាដោយអនុមោទនា ដោយធម្មកថា និងដោយសភាពរៀបរយនៃ

កិរិយាឬកពារ, ភិក្ខុទាំងនោះគេធ្វើសក្ការៈ គោរព រាប់អាន បូជា កោត ក្រែងហើយ គប្បីជ្រាបថា ជាអ្នកញុំាងព្រះសាសនាឱ្យរុងរឿង បន្ត បែបផែន និងប្រពៃណីទុក ។

បទថា **តថាគតប្បវេទិតំ** : **ដែលតថាគតបានសម្ដែងហើយ** សេចក្ដីថា ដែលព្រះតថាគតចាក់ធ្លុះហើយគឺ ធ្វើឱ្យប្រចក្សហើយ ឬ ញុំាងអ្នកដទៃឱ្យដឹងហើយ ។

ពីរបទថា **អត្តនោ ទហតិ** : **ដុតកម្ដៅខ្លួនឯងចោល** មាន សេចក្ដីថា ភិក្ខុដែលអាក្រក់ថោកទាប ប្រៀបធៀបបាលីនិងអដ្ឋកថា នៅ កណ្ដាលបរិស័ទ ពោលព្រះសូត្រដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ដោយ សំឡេងដែលពីរោះ ត្រូវវិញ្ញូជនកើតសេចក្ដីអស្ចារ្យសាកសួរក្នុងទីបំផុត នៃធម្មកថាថា "ឱ លោកដ៏ចម្រើន បាលីនិងអដ្ឋកថា បរិសុទ្ធិ, លោក ម្ចាស់រៀននៅក្នុងសំណាក់របស់អ្នកណា ?" ដូច្នេះ ឆ្លើយថា "អ្នកណា នឹងអាចឱ្យបុគ្គលប្រហែលយើងរៀនបាន" ហើយមិនសម្ដែងអាចារ្យ ប្រកាសធម្មវិន័យដែលខ្លួនឯងចាក់ធ្លុះ គឺ ដែលខ្លួនបានសម្រេចដោយ សយម្ភូញាណ ។ ភិក្ខុអ្នកលួចធម៌ដែលព្រះតថាគតទ្រង់បំពេញបារមី អស់ ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប បានត្រាស់ដឹងដោយ លំបាកក្រៃលែង, នេះ ចាត់ជាមហាចោរពួកទី ២ ។

ពាក្យថា សុទ្ធំ ព្រហ្មចារី ៖ ភិក្ខុដែលប្រព្រឹត្តធម៌ប្រសើរដ៏ស្អាតបានដល់ ភិក្ខុដែលអស់អាសវៈហើយ ។

ពាក្យថា បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តំ ៖ ភិក្ខុដែលកំពុងប្រព្រឹត្តធម៌ប្រសើរដ៏បរិសុទ្ធ បានដល់ សព្រហ្មចារីអ្នកប្រព្រឹត្តចរិយាដ៏ប្រសើរដែលមិនមានឧបក្កិលេស ។ ម្យ៉ាងទៀត បានដល់ អ្នកប្រព្រឹត្តព្រហ្មចរិយដ៏បរិសុទ្ធិ ដែលជាទីតាំងនៃសេចក្តីមិនក្តៅក្រហាយជាដើមសូម្បីដទៃ ចាប់តាំងពីព្រះអនាគាមីដរាបដល់បុថុជ្ជនមានសីល ។

ពាក្យថា អមូលកេន អព្រហ្មចរិយេន អនុទ្ធំសេតិ ៖ ចោទដោយការប្រព្រឹត្តមិនប្រសើរ រកមូលគ្មាន មានសេចក្តីថា ភិក្ខុចោទទាប រមែងពោលរក គឺ ចោទដោយអន្តិមវត្ថុ ដែលមិនមាននៅក្នុងបុគ្គលនោះ ។ ភិក្ខុអ្នកលុបគុណដែលមានប្រាកដ លួចអរិយគុណនេះ ចាត់ជាមហាចោរពួកទី ៣ ។

ក្នុងពីរបទថា គរុភណ្ឌានិ គរុបរិក្ខារានិ ៖ ដោយគ្រឿងគរុភណ្ឌ ឬគ្រឿងគរុបរិក្ខា នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ក្នុងអទិន្នាទានសិក្ខាបទ ភណ្ឌៈមានតម្លៃ ៥ មាសក លោកចាត់ថា គរុភណ្ឌ ក្នុងពាក្យថា ជន ៤ នាក់ បបួលគ្នាលួចគរុភណ្ឌ នេះ យ៉ាងណា ? ។ ក្នុងសិក្ខាបទនេះ នឹងបានចាត់ដូច្នោះ ក៏ទេ ។ តាមការ

ពិត ភណ្ឌៈដែលចាត់ជាគរុភណ្ឌ ក៏ព្រោះជារបស់ដែលមិនគួរចែក, ដោយព្រះបាលីថា “ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរលះចេញ ៥ យ៉ាងនេះ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវលះចេញ សូម្បីលះចេញហើយ ក៏មិនឈ្មោះថា លះ; ភិក្ខុណាលះចេញ ត្រូវអាបត្តិថុល្លច្ច័យ; របស់ទាំង ៥ នោះ ដូចម្តេច ។ គឺ សួនច្បារ ទីដីដាំសួនច្បារ ។ល ។ គ្រឿងឈើ គ្រឿងធ្វើពីដី”[១] បរិក្ខារដែលចាត់ជាគរុបរិក្ខារ ដោយភាពជាបរិក្ខារសាធារណៈ ព្រោះជារបស់មិនគួរចែក ដោយព្រះពុទ្ធដីកាថា “ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរចែក ៥ ពួកនេះ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថា ចែក, ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ។ របស់ ៥ ពួក ដូចម្តេច (របស់ ៥ ពួកគឺ) **អារាម** **គឺសួនច្បារ១** **អារាមវត្ថុ** **គឺទីដាំសួនច្បារ ១** នេះ ជារបស់មិនគួរចែក ជាដំបូង ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថា ចែក, ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ។ **វិហារ** **គឺលំនៅ ១** **វិហារវត្ថុ** **គឺទីដី សម្រាប់សង់លំនៅ ១** ជារបស់មិនគួរចែក ជាគម្រប់ពីរ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏

---

១. វិន. ចុល្ល. សេនាសនក្ខន្ធក. ១. ៤០២/៣៣៩ ។

មិនឈ្មោះថា ចែក, ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ។ មញ្ចៈគឺគ្រែ ១ បីឋៈគឺតាំងឬកៅអី ១ ភិសី គឺពូក ១ ពិម្ពោហនៈ គឺ ខ្នើយ ១ នេះជារបស់មិនគួរចែក ជាគម្រប់បី ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថា ចែក, ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ។ លោហកុម្ភី គឺឆ្នាំងដែលធ្វើពីលោហជាតិ ១ លោហភាណកៈ គឺខ្ទះលោហៈ ១ លោហវារកៈ គឺក្អមលោហៈ ១ លោហកដាហៈ គឺផើងលោហៈ ១ វាសី គឺកាំបិត ១ ផរសុ គឺពូថៅ ១ កុឋារី គឺជីងចាំង ១ កុទ្ទាលៈ គឺចប ១ និខាទនៈ គឺពន្លាក ១ នេះជារបស់មិនគួរចែក ជាគម្រប់បួន ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថា ចែក, ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ។ វល្លិ គឺវល្លិ ១ វេឡុ គឺឫស្សី ១ មុញ្ជៈ គឺស្មៅជំណោកទន្សាយ ១ បព្វជៈ គឺស្មៅយ៉ាផ្លូង ១ តិណៈ គឺស្មៅធម្មតា ១ មត្តិកា គឺដីស្អិត ១ ទារុភណ្ឌៈ គឺគ្រឿងឈើ ១ មត្តិកាភណ្ឌៈ គឺគ្រឿងធ្វើពីដី ១ នេះជារបស់មិនគួរចែក ជាគម្រប់ប្រាំ ទោះសង្ឃក្តី គណៈក្តី បុគ្គលក្តី ក៏មិនត្រូវចែក សូម្បីចែកហើយ ក៏មិនឈ្មោះថា ចែក, ភិក្ខុណាចែក ត្រូវអាបត្តិថុល្លច្ច័យ ។[១] ពាក្យណាដែលគួរពោលក្នុងបទថា

១. វិន. ចុល្ល. សេនាសនក្ខន្ធក. ១០. ៤០៣/៣៤៤ ។

អារាមោ អារាមវត្ថុ : គុម្ពផ្កានឹងដើមឈើ ទីសម្រាប់ដាំគុម្ពផ្កានឹងដើមឈើ ជាដើម ខ្ញុំព្រះករុណានឹងពោលពាក្យទាំងអស់នោះក្នុងវណ្ណនានៃសូត្រ ដែលមកក្នុងខន្ធកៈថា បញ្ចិមានិ ភិក្ខវេ អវិស្សជ្ជិយានិ : ម្នាលភិក្ខុទាំងឡាយ របស់ដែលមិនគួរលះបេញ ៥ យ៉ាងនេះឯង ទាំងអស់ក្នុងវណ្ណនានៃសូត្រ ដែលមកក្នុងខន្ធកៈថា បញ្ចិមានិ ភិក្ខវេ អវិសជ្ជិយានិ[១] នោះឯង ។

ពាក្យថា តេហិ គិហី សង្គណ្ហាតិ : សង្គ្រោះគ្រហស្ថ មានសេចក្តីថា ឱ្យគរុភណ្ឌ គរុបរិក្ខារមានអារាមជាដើមទាំងនោះ សង្គ្រោះ គឺ អនុគ្រោះពួកគ្រហស្ថ ។

បទថា ឧបលាបេតិ : ផ្គាប់ផ្គុន មានសេចក្តីថា ធ្វើឱ្យពួកគ្រហស្ថរីករាយ គឺ ឱ្យជាអ្នកជាប់ចិត្ត បានដល់ ឱ្យមានសេចក្តីស្រឡាញ់ប្រាថ្នា យ៉ាងនេះថា "ល្អពិត លោកម្ចាស់របស់ពួកយើង" ។ ភិក្ខុដែលលួចគរុបរិក្ខារ ដែលមិនគួរចែកចាយ និងមិនគួរចែកដោយភាពជាយ៉ាងនោះសង្គ្រោះគ្រហស្ថនេះ ចាត់ជាមហាចោរពួកទី ៤ ។ ក៏ឯភិក្ខុនោះ កាលចែកចាយគរុភណ្ឌនេះ ដើម្បីសង្គ្រោះត្រកូល រមែងត្រូវ

---

១. វិន. ចុល្ល. សេនាសនក្ខន្ធក. ១០. ៤០២/៣៣៩ ។

កុលទូសកទុក្កដផង រមែងជាអ្នកគួរដល់បញ្ញាជនីយកម្មផង, កាលចែកចាយដោយភាពជាធំលើភិក្ខុសង្ឃ រមែងត្រូវថុល្លច្ច័យ, កាលចែកចាយដោយថេយ្យចិត្ត គប្បីឱ្យវាយតម្លៃវត្ថុពិន័យអាបត្តិ ។

ពាក្យថា **អយំ អគ្គោ មហាចោរោ : ភិក្ខុនេះឯងជាមហាចោរទី ៥ ជាចោរធំបំផុត** មានសេចក្តីថា ភិក្ខុដែលលួចលោកុត្តរធម៌ដែលល្អិតសុខុម ប្រព្រឹត្តកនូវការកាន់យកដោយឥន្ទ្រិយ ៥ នេះ ចាត់ជាចោរធំទីបំផុតរបស់មហាចោរទាំងនេះ, ដែលឈ្មោះថា ចោរដែលដូចភិក្ខុនេះរមែងមិនមាន ។

សួរថា ក៏លោកុត្តរធម៌ បុគ្គលអាចបន្លំ គឺ លួចយក ដូចទ្រព្យមាន ប្រាក់និងមាសជាដើមឬ ? ។ ឆ្លើយថា មិនអាច ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា **"យោ អសន្តំ អភូតំ ឧត្តរិមនុស្សធម្មំ ឧល្លបតី :** ភិក្ខុណា ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមានប្រាកដក្នុងខ្លួន" ។ ពិតមែន ភិក្ខុនេះ រមែងពោលអួតធម្មដែលមិនមានប្រាកដក្នុងខ្លួនតែម្យ៉ាងថា "ធម៌នេះរបស់យើង មាន" ។ តែមិនអាចឱ្យឧត្តរិមនុស្សធម្មនោះឃ្លាតទៅចាកទីណា ឬមិនអាចធ្វើឱ្យមាននៅក្នុងខ្លួនបាន ។

សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបពោលថា ជាចោរហ្នុំ ?

ឆ្លើយថា ព្រោះថា ភិក្ខុនេះ ពោលអួតឧត្តរិមនុស្សធម្មនោះហើយ កាន់យកបច្ច័យដែលកើតឡើង ព្រោះការអួតគុណដែលមិនមានប្រាកដ; ព្រោះហេតុនោះ បច្ច័យទាំងនោះ ក៏ជាការដែលលោកកាន់យក (ដោយការអួតធម៌ដែលមិនមានពិត) យ៉ាងនោះ បោកប្រាស គឺ ឆបោកយកដោយឧបាយដែលសុខុម ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា "ហេតុអ្វីបានជាតថាគតពោលដូច្នោះ ម្នាលភិក្ខុទាំងឡាយ ពីព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន គឺ ភិក្ខុនោះឯង លួចយកមកបរិភោគ" ។

សេចក្តីក្នុងពាក្យថា **តំ កិស្ស ហេតុ : ហេតុអ្វីបានជាតថាគតពោលដូច្នោះ** នេះ គប្បីជ្រាបដូចតទៅនេះ ៖

តថាគតបានពោលពាក្យណាថា "ភិក្ខុណាពោលអួតឧត្តរិមនុស្សធម្មដែលមិនមាន មិនពិតប្រាកដក្នុងខ្លួន, ភិក្ខុនេះជាមហាចោរទី៥"; បើនឹងមានអ្នកតវ៉ាថា សេចក្តីនោះ ព្រោះហេតុអ្វី ? គឺ តថាគតបានពោលពាក្យនោះ ដោយហេតុអ្វី ? តថាគតគប្បីឆ្លើយថា "ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដែលដុំបាយរបស់ជនអ្នកនៅក្នុងដែន ដែលភិក្ខុនោះឆាន់ហើយ ដោយភាពជាចោរនោះឯង" អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រោះដុំបាយរបស់ជនអ្នកនៅក្នុងដែន ជាបាយដែលភិក្ខុនោះឆាន់ហើយ

ដោយថេយ្យចិត្ត; ព្រោះហេតុនោះ ទើបតថាគតបានពោលពាក្យនោះ ។

ពិតមែន វោ សទ្ទ ក្នុងពាក្យថា ថេយ្យាយ វោ : ពីព្រោះនេះ ជានិបាតចុះក្នុងអត្ថត្រឹមតែជាគ្រឿងធ្វើបទឱ្យពេញ ដូច វោ សទ្ទ ក្នុងពាក្យថា "យេ ហិ វោ អរិយា អរញ្ញវនបត្ថានិ : ព្រះអរិយទាំងឡាយណា (រមែងសេពនូវសេនាសនៈស្ងាត់) តាំងនៅក្នុងព្រៃជិតនិងព្រៃឆ្ងាយ"[១] ជាដើម ។ ព្រោះហេតុនោះអ្នកសិក្សាមិនគប្បីឃើញសេចក្ដីនៃ វោ សទ្ទនោះ យ៉ាងនេះថា "តុម្ហេហិ កុត្តោ : ដែលលោកទាំងឡាយឆាន់ហើយ" ដូច្នេះ ។

## ពន្យល់អត្ថនៃនិគមគាថា

ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់ធ្វើសេចក្ដីនោះឯង ឱ្យជាក់ច្បាស់ឡើងដោយគាថា ទើបត្រាស់ព្រះគាថាថា អញ្ញថា សន្តំ ជាដើម ។

បណ្ដាបទទាំងនោះ ពីរបទថា អញ្ញថា សន្តំ : មាន(ខ្លួន)តាំងនៅដោយអាការដទៃ សេចក្ដីថា ដែលមាននៅដោយអាការដទៃ ដែលមានកាយសមាចារមិនបរិសុទ្ធិជាដើម ។ បាទគាថា ថា អញ្ញថា យោ

១. មជ្ឈិ. មូល. ភយភេរវសុត្ត. ២០. ៣១/៥៤ ។

បវេទយេ : ហើយញុំាងអ្នកដទៃឱ្យដឹងច្បាស់ថា (ខ្លួន)តាំងនៅដោយអាការដទៃ សេចក្តីថា ភិក្ខុណា គប្បីប្រកាសដោយអាការយ៉ាងដទៃ ដែលមានកាយសមាចារបរិសុទ្ធិជាដើម គឺ ឱ្យជនដទៃយល់យ៉ាងនេះថា "យើងជាអ្នកបរិសុទ្ធិយ៉ាងក្រៃលែង លោកុត្តរធម៌មាននៅខាងក្នុងខ្លួនយើង" ។

ក៏កាលប្រកាសហើយ (សម្តែងខ្លួន) ដូចព្រះអរហន្ត ឆាន់ភោជនដែលកើតឡើងព្រោះការប្រកាសនោះ ។

បទថា និកច្ច ក្នុងពីរបាទគាថាថា និកច្ច កិតវស្សេវ ភុត្តំថេយ្យេន តស្ស តំ : ភិក្ខុនោះឯង ហៅថា លួចភោជនគេមកបរិភោគ ដូចជាព្រានសត្វស្លាបលបលាក់ខ្លួនប្របគុម្ពឈើបម្រុងបាញ់សត្វនេះ សេចក្តីថា បញ្ឆោត គឺ សម្តែងខ្លួនដែលមាននៅដោយអាការដទៃដោយអាការយ៉ាងដទៃ បានដល់ សម្តែងខ្លួនដែលមិនមែនគុម្ពឈើ និងមិនមែនដង្គត់ឈើឡើយ ឱ្យដូចជាគុម្ពឈើ និងឱ្យដូចដង្គត់ឈើ ព្រោះយកមែកឈើ ស្លឹកឈើ និងស្លឹកខ្ចីជាដើមបិទបាំងទុក ។

បទថា កិតវស្សេវ : ដូចជាព្រានសត្វស្លាបលបលាក់ខ្លួនប្របគុម្ពឈើ សេចក្តីថា ដូចព្រានបក្សីអ្នកលួង គឺ បញ្ឆោតចាប់បក្សី

ដែលមកហើយ ៗ ក្នុងព្រៃ ដោយមានសេចក្ដីសម្គាល់ថា ជាគុម្ពឈើនិងដង្គត់ឈើហើយចិញ្ចឹមជីវិតដូច្នោះ ។

បាទគាថាថា **ភុត្តំ ថេយ្យេន តស្ស តំ : ភិក្ខុនោះឯង ហៅថាលួចភោជនគេមកបរិភោគ** សេចក្ដីថា សូម្បីកាលភិក្ខុនោះដែលមិនមែនជាព្រះអរហន្តឡើយ សម្ដែងថា ជាព្រះអរហន្តឆាន់ភោជនដែលខ្លួនបានមក, ភោជនដែលលោកឆាន់ ឈ្មោះថា ជាភោជនដែលលោកឆាន់ហើយដោយភាពជាចោរ ព្រោះលោកឆាន់ភោជនដែលខ្លួនបញ្ឆោតមនុស្សទាំងឡាយហើយបានមក ប្រៀបដូចព្រានសត្វដែលមានគ្រឿងបិទបាំង គឺបញ្ឆោតសត្វ ដូច្នោះ ។ ក៏ភិក្ខុពួកណា កាលមិនដឹងអំណាចនៃប្រយោជន៍នេះ រមែងឆាន់ដោយអាការយ៉ាងនោះ, ភិក្ខុជាច្រើន មានសំពត់កាសាវៈរុំក មានធម៌អាក្រក់ថោកទាបមិនសង្រួមហើយ, ភិក្ខុអាក្រក់ថោកទាបទាំងនោះ រមែងចូលដល់នរក ព្រោះកម្មទាំងឡាយដែលអាក្រក់ថោកទាប ។

បទថា **កាសាវកណ្ឋា : ភិក្ខុដែលយកសំពត់កាសាវមកព័ទ្ធព័ន្ធក** បានដល់ អ្នកមាន-កដែលរុំដោយសំពត់កាសាវៈ ។ មានពាក្យអធិប្បាយថា គុណគ្រឿងជាសមណៈ គឺ ព្រះអរហត្តផល រមែងមិនមានដល់បុគ្គលពួកណា, បុគ្គលទាំងនោះ មានតែការទ្រទ្រង់ទុកនូវទង់

ជ័យនៃព្រះអរិយៈត្រឹមនេះប៉ុណ្ណោះ ។ ពាក្យថា **អ្នកមានសំពត់កាសាវៈរុំក** នេះ ជាឈ្មោះនៃបព្វជិតទ្រុស្តសីល ដែលព្រះមានព្រះភាគត្រាស់ទុកយ៉ាងនេះថា "ម្នាលអានន្ទ ក្នុងកាលអនាគត នឹងមានគោត្រភូសង្ឃ (សង្ឃមានតែឈ្មោះ) មានតែសំពត់កាសាវៈចងក ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក"[១] ។

បទថា **បាបធម្មា** : **ធម៌អាក្រក់** បានដល់ អ្នកមានធម៌លាមក ។

បទថា **អសញ្ញតា** : **គ្មានសង្រួមឡើយ** បានដល់ អ្នកមិនសង្រួមមកកាយជាដើម ។

បទថា **បាបា** : **ជាបុគ្គលអាក្រក់** បានដល់ បុគ្គលលាមក ។

ពីរបទថា **បាបេហិ កម្មេហិ** : **ព្រោះអំពើដែលខ្លួនធ្វើអាក្រក់** សេចក្តីថា ព្រោះកម្មដ៏អាក្រក់ថោកទាបទាំងឡាយ មានការបញ្ឆោតអ្នកដទៃជាដើមទាំងនោះ ដែលខ្លួនធ្វើហើយ ព្រោះមិនឃើញទោសក្នុងវេលាធ្វើ ។

១. មជ្ឈិ. ឧប. ២៨. ១៨៨/២២៦ ។

បាទគាថាថា និរយេ ឧបបជ្ជរេ : ភិក្ខុនោះទៀតតែទៅនរក សេចក្តីថា ភិក្ខុដែលអាក្រក់ថោកទាបទាំងនោះ រមែងចូលដល់ទុគ្គតិដែលមិនមានសេចក្តីត្រេកអរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ព្រះគាថាថា សេយ្យោ អយោគុឡោ : ដុំដែកកំពុងឆេះក្តៅប្រសើរជាង ជាដើម, គប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា បើបុគ្គលដែលទ្រុស្តសីល មិនសង្រួមតាំងនៅក្នុងឥន្ទ្រិយ ជាអ្នកបញ្ឆោតអ្នកស្រុកដោយកិរិយាបញ្ឆោតលួងលោមនេះ គប្បីបរិភោគ គឺ គប្បីលេបស៊ីដុំដែកក្រហមដូចអណ្តាតភ្លើង, ការដែលអ្នកទ្រុស្តសីលគប្បីបរិភោគដុំបាយរបស់ជនអ្នកនៅក្នុងដែននេះ ១ ការដែលបុគ្គលគប្បីស៊ីដុំដែកក្រហមនេះ ១ ក្នុងបណ្តា ២ យ៉ាងនោះ ដុំដែកប៉ុណ្ណោះ ដែលភិក្ខុនោះបរិភោគហើយ ជារបស់ប្រសើរជាង គឺ ល្អជាងនិងប្រណីតជាង; ព្រោះថា ភិក្ខុនោះនឹងមិនសោយទុក្ខដែលមានការកំណត់ដឹងបានលំបាកសូម្បីដោយសព្វញ្ញុតញ្ញាណក្នុងសម្បរាយភព ព្រោះបរិភោគដុំដែកក្រហមទេ, តែនឹងបានសោយទុក្ខមានប្រការដូចពោលហើយ ក្នុងសម្បរាយភព ព្រោះលោកបរិភោគដុំបាយរបស់ជនក្នុងដែនដែលខ្វនបានមកហើយដោយអាការយ៉ាងនោះ ។ ពិតមែន អាជីវៈនេះ ចាត់ជាមិច្ឆាជីវៈថ្នាក់ខ្ពស់បំផុត ។

## បឋមបញ្ញត្តិចតុត្ថបារាជិក

[២៣១] គ្រានោះឯង កាលព្រះមានព្រះភាគទ្រង់សម្តែងទោស ដល់ពួកភិក្ខុដែលមិនឃើញទោសក្នុងការធ្វើអំពើអាក្រក់យ៉ាងនោះហើយ ទើបទ្រង់តិះដៀលពួកភិក្ខុដែលនៅមាត់ស្ទឹងវគ្គុមុទា ដោយអនេកបរិយាយ ហើយទ្រង់សម្តែងនូវទោសនៃការចិញ្ចឹមក្រ ថែទាំក្រ ។ល។ ហើយទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសម្តែងនូវសិក្ខាបទនេះយ៉ាងនេះ" ដូច្នេះហើយ ។ កាលទឹងទ្រង់បញ្ញត្តិចតុត្ថបារាជិក ទើបត្រាស់ពាក្យជាដើមថា យោ បន ភិក្ខុ អនភិជានំ : ភិក្ខុណាមិនដឹងចំពោះ ដូច្នេះជាដើម ។

## អនុប្បញ្ញត្តិចតុត្ថបារាជិក

[២៣២] កាលព្រះមានព្រះភាគ ទ្រង់បញ្ញត្តិចតុត្ថបារាជិក ធ្វើឱ្យធ្ងន់ឡើងដោយអំណាចសេចក្តីជាច់មូលយ៉ាងនោះហើយ រឿងសម្គាល់ថាបានចាក់ធ្លុះសូម្បីដទៃទៀតក៏កើតឡើង ដើម្បីប្រយោជន៍ដល់អនុប្បញ្ញត្តិ ។ ដើម្បីសម្តែងសេចក្តីកើតឡើងនៃរឿងសម្គាល់ថា បានសម្រេចនោះ ព្រះធម្មសង្គាហកត្ថេរទាំងឡាយ ទើបបានពោលទុកយ៉ាងនេះថា "សិក្ខាបទនេះ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តដល់ពួកភិក្ខុរបជាស្រេចយ៉ាងនេះ" ។

បណ្ដាបទទាំងនោះ ពីរបទថា **អទិដ្ឋេ ទិដ្ឋសញ្ញិនោ : មាន** សេចក្ដីសំគាល់ថា ឃើញ ក្នុងហេតុដែលខ្លួនមិនឃើញ សេចក្ដីថា (ភិក្ខុទាំងឡាយ) ជាអ្នកមានសេចក្ដីសម្គាល់ក្នុងព្រះអរហត្តផល ដែលខ្លួនមិនទាន់បានឃើញដោយញាណចក្ខុឡើយថា **បានឃើញ** ដោយពាក្យថា ព្រះអរហត្តផល ដែលយើងទាំងឡាយឃើញហើយ ។

ក្នុងព្រះអរហត្តផលដែលខ្លួនមិនទាន់បានដល់ជាដើម ក៏ន័យនេះ ។ តែមានសេចក្ដីប្លែកគ្នាដូចតទៅនេះ ៖

បទថា **អប្បត្តេ : ឥតបានដល់** សេចក្ដីថា ដែលខ្លួនមិនទាន់បានដល់ ដោយអំណាចសេចក្ដីកើតឡើងក្នុងសន្តានរបស់ខ្លួន ។

បទថា **អនធិគតេ : ឥតបានត្រាស់ដឹង បានដល់** ដែលខ្លួនមិនទាន់បានសម្រេច ដោយមគ្គភាវនា ។ សេចក្ដីថា ដែលខ្លួនមិនទាន់បានខ្លះ ។

បទថា **អសច្ឆិកតេ : ឥតបានធ្វើឱ្យច្បាស់លាស់** បានដល់ ដែលខ្លួនមិនទាន់បានចាក់ធ្លុះ ឬមិនទាន់បានធ្វើឱ្យប្រចក្ស ដោយអំណាចការពិចារណា ។

បទថា **អធិមានេន : បានត្រាស់ដឹង** បានដល់ ដោយសេចក្ដីសម្គាល់ថា ខ្លួនបានសម្រេច ។ អធិប្បាយថា ដោយសេចក្ដីសម្គាល់

ដែលកើតឡើងយ៉ាងនេះថា "យើងបានសម្រេចហើយ" ម្យ៉ាងទៀត សេចក្តីថា ដោយសេចក្តីប្រកាន់ខ្លួនក្រៃលែង គឺ ដោយមានះដែលរឹងត្អឹង ។ ពីរបទថា អញ្ញំ ព្យាករិំសុ : បានពោលអួតអរហត្តផល សេចក្តីថា បានព្យាករណ៍ព្រះអរហត្តផល គឺបានប្រាប់ដល់ភិក្ខុទាំងឡាយថា "អាវុសោ ពួកយើងបានសម្រេចព្រះអរហត្តផលហើយ កិច្ចដែលគួរធ្វើ ពួកយើងបានធ្វើសម្រេចហើយ" ។ ព្រោះលះកិលេសមិនទាន់បានដោយមគ្គ ចិត្តរបស់លោកទាំងនោះ អ្នកគ្រប់សង្កត់កិលេសទុកបានដោយអំណាចសមថៈ និងវិបស្សនាតែម្យ៉ាងដោយសម័យតមក គឺ ក្នុងវេលាប្រកបព្រមដោយបច្ច័យបែបនោះ រមែងបង្អោនទៅដើម្បីសេចក្តីតម្រេកខ្លះ អធិប្បាយថា រមែងបង្អោនទៅដើម្បីត្រូវការសេចក្តីតម្រេក ។ ក្នុងបទទាំងឡាយក្រៅនេះ ក៏ន័យនេះ ។

ពាក្យថា តញ្ច ខោ ឯតំ អព្វោហារិកំ : អំពើដែលពោលអួតនេះ ជាអព្វោហារិក មានសេចក្តីថា ក៏ឯការព្យាករណ៍ ព្រះអរហត្តនោះរបស់លោកទាំងនោះ ជាអព្វោហារិកមិនទាន់ដល់វោហារដែលជាហេតុឱ្យបញ្ញត្តិអាបត្តិ, អធិប្បាយថា មិនទាន់ជាអង្គនៃអាបត្តិ ។

សួរថា ក៏សេចក្តីសម្គាល់ថា បានសម្រេចនេះ រមែងកើតឡើងដល់អ្នកណា ? មិនកើតឡើងដល់អ្នកណា ? ឆ្លើយថា រមែងមិនកើត

ឡើងដល់ព្រះអរិយសាវកមុន ។ ពិតមែន ព្រះអរិយសាវកនោះ មានសោមនស្សកើតឡើងហើយដោយញាណជាគ្រឿងពិចារណា មគ្គ ផល និព្វាន កិលេសដែលលះបានហើយ និងកិលេសដ៏សេស ជាអ្នកមិនមានសេចក្តីសង្ស័យក្នុងការចាក់ធ្លុះអរិយគុណ; ព្រោះហេតុនោះ មានះ (សេចក្តីប្រកាន់ខ្លួន) ទើបមិនកើតឡើងដល់ព្រះអរិយៈសាវកទាំងឡាយមានព្រះសោតាបន្នជាដើម ដោយអំណាចការប្រកាន់ថា "យើងជាព្រះសកទាគាមី"ជាដើម ។ និងមិនកើតឡើងសូម្បីដល់បុគ្គលទ្រុស្តសីល ។ ព្រោះថា បុគ្គលទ្រុស្តសីលនោះ ជាអ្នកអស់សេចក្តីប្រាថ្នាក្នុងការសម្រេចអរិយគុណតែម្តង ។ ទាំងមិនកើតឡើងដល់អ្នកមានសីលដែលលះបង់កម្មដ្ឋានចេញ ហើយតាមប្រកបហេតុនៃសេចក្តីខ្ជិលច្រអូស មានភាពជាអ្នកត្រេកអរក្នុងការដេកលក់ជាដើម ។ តែនឹងកើតឡើងដល់លោកអ្នកចាប់ផ្តើមចម្រើនវិបស្សនា មានសីលបរិសុទ្ធិល្អ មិនប្រមាទក្នុងកម្មដ្ឋាន ឆ្លងផុតសេចក្តីសង្ស័យហើយ ព្រោះកំណត់នាមរូប កាន់យកបច្ច័យបាន លើកឡើងនូវត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ ។ និងសេចក្តីសម្គាល់ថា បានសម្រេចកើតឡើងហើយ រមែងបញ្ឆប់បុគ្គលដែលបានសមថៈសុទ្ធ ៗ ឬអ្នកបានវិបស្សនាសុទ្ធ ៗ ក្នុងចន្លោះ ។ ពិតមែន បុគ្គលនោះ កាលមិនឃើញការ ផុសផុលឡើងនៃកិលេសរហូត

ដល់អស់ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ រមែងយល់ថា "យើងជាព្រះសោតាបន្ន" ឬថា "យើងជាព្រះសកទាគាមី" ឬថា "យើងជាព្រះអនាគាមី" ។ តែសេចក្តីសម្គាល់ថា "បានសម្រេច"នោះ រមែងតាំងបុគ្គលដែលបានទាំងសមថៈ ទាំងវិបស្សនាទុកក្នុងព្រះអរហត្តផលតែម្តង ។ ពិតមែន បុគ្គលនោះ គ្របសង្កត់កិលេសទាំងឡាយ បានដោយកម្លាំងសមាធិ កំណាត់សង្ខារទាំងឡាយ បានល្អដោយកម្លាំងវិបស្សនា; ព្រោះដូច្នោះ កិលេសទាំងឡាយទើបមិនផុសផុលឡើងរហូតដល់អស់៦០ ឆ្នាំខ្លះ ៨០ឆ្នាំខ្លះ ១០០ឆ្នាំខ្លះ, ប្រព្រឹត្តទៅនៃចិត្ត ដូចជាការប្រព្រឹត្តរបស់ព្រះខីណាស្រពដូច្នោះ ។ បុគ្គលនោះ កាលមិនឃើញការផុសផុលឡើងនៃកិលេសរហូតដល់អស់រាត្រីដ៏យូរ ដោយអាការយ៉ាងនោះ មិនឈប់ក្នុងចន្លោះឡើយ ទើបសំគាល់ថា យើងជាព្រះអរហន្ត ដូច្នេះឯង ។

[២៣៣] បទថា **អនភិជានំ : មិនដឹងច្បាស់** បានដល់ មិនដឹងចំពោះ ។ ក៏ព្រោះហេតុដែលភិក្ខុនេះ មិនដឹងពិត ពោលអួត, ឧត្តរិមនុស្សធម្មនោះ មិនកើតឡើងក្នុងសន្តានរបស់លោក ទាំងលោកក៏មិនបានធ្វើឱ្យច្បាស់ដោយញាណ ទើបឈ្មោះថា មិនមានពិត; ព្រោះដូច្នោះ ក្នុងវារៈចែកបទថា អនភិជានំ នោះ ព្រះឧបាលីពោលថា "មិនមាន មិនពិត មិនប្រាកដ" ទើបពោលថា "(ភិក្ខុ) មិនដឹង មិនឃើញ"

ដូច្នេះ ។

បទថា **ឧត្តរិមនុស្សធម្មំ** បានដល់ ធម៌របស់មនុស្សដ៏ក្រៃលែង គឺលោកអ្នកបានឈាន និងព្រះអរិយៈទាំងឡាយ ។

បទថា **អត្តូបនាយិកំ** : **បង្អោនមកដាក់ក្នុងខ្លួន** មានអត្ថវិគ្រោះថា ភិក្ខុ រមែងបង្អោនឧត្តរិមនុស្សធម្មនោះចូលមកក្នុងខ្លួន ឬថា រមែងបង្អោនខ្លួនចូលទៅក្នុងឧត្តរិមនុស្សធម្មនោះ; ព្រោះហេតុនោះ ឧត្តរិមនុស្សធម្មនោះ ទើបឈ្មោះថា **អត្តូបនាយិក:** ។ (ភិក្ខុពោលអួត)ឧត្តរិមនុស្សធម្មនោះ ជាទីបង្អោនចូលមកក្នុងខ្លួន ឬថា ជាទីបង្អោនខ្លួនចូលទៅរក ។ ភ្ជាប់សេចក្តីថា ភិក្ខុធ្វើយ៉ាងនេះពោលអួត តែក្នុងវារៈចែកបទ ព្រោះហេតុដែលព្រះឧបាលីពោលធម៌ច្រើនប្រការ មានឈានជាដើមទុកយ៉ាងនេះថា ឈាន វិមោក្ខសមាធិ សមាបត្តិ ញាណទស្សនៈ ។ល ។ (ការញ៉ាំងមគ្គឱ្យចម្រើន ការធ្វើឱ្យច្បាស់នូវផលការលះកិលេស សេចក្តីដែលចិត្តប្រាសចាកនីវរណៈ) សេចក្តីត្រេកអរក្រៃលែងក្នុងផ្ទះស្ងាត់ឈ្មោះថា ឧត្តរិមនុស្សធម្ម ដូច្នេះ; ព្រោះដូច្នោះ កាលលោកនឹងសម្តែងសេចក្តីដែលឧត្តរិមនុស្សធម្មនោះ ជាធម៌ដែលបង្អោនចូលមកក្នុងខ្លួនដោយអំណាចនៃធម៌ទាំងអស់នោះ ទើបបានធ្វើនិទ្ទេសជាពហុវចនៈថា ភិក្ខុរមែងបង្អោនកុសលធម៌ទាំងនោះចូលមកក្នុងខ្លួន ។ ក្នុងបណ្តាការ

បង្អោន ២ យ៉ាងនោះ កាលភិក្ខុអួតថា "ធម៌ទាំងនេះ រមែងប្រាកដក្នុងខ្ញុំព្រះករុណា" គប្បីជ្រាបថា ឈ្មោះថា បង្អោន (ធម៌ទាំងនោះ) ចូលមកក្នុងខ្លួន ។ ក្នុងបណ្ដាការបង្អោន ២ យ៉ាងនោះ កាលភិក្ខុអួតថា "ធម៌ទាំងនេះ រមែងប្រាកដក្នុងខ្ញុំព្រះករុណា" គប្បីជ្រាបថា ឈ្មោះថា បង្អោន (ធម៌ទាំងនោះ) ចូលមកក្នុងខ្លួន, កាលអួតថា "ខ្ញុំព្រះករុណារមែងប្រាកដក្នុងធម៌ទាំងនេះ" គប្បីជ្រាបថា ឈ្មោះថា បង្អោនខ្លួនចូលទៅក្នុងធម៌ទាំងនោះ ។

គប្បីជ្រាបការភ្ជាប់អត្ថនៃបទក្នុងពាក្យថា អលមរិយញាណទស្សនំ : ជាធម៌គួរឃើញដោយញាណដ៏ប្រសើរ នេះ យ៉ាងនេះ គឺ បញ្ញាទាំងដែលជាលោកិយៈនិងលោកុត្តរៈ ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹង, ឈ្មោះថា ទស្សនៈ ព្រោះអត្ថថា ឃើញ ព្រោះធ្វើនូវធម៌ឱ្យហាក់ដូចជាឃើញដោយចក្ខុ; ព្រោះដូច្នោះ ទើបឈ្មោះថា ញាណទស្សនៈ ។ ញាណទស្សនៈ យ៉ាងប្រសើរគឺ យ៉ាងបរិសុទ្ធិ យ៉ាងខ្ពស់បំផុត; ព្រោះដូច្នោះ ទើបឈ្មោះថា **អរិយញាណទស្សនៈ** ។ ញាណទស្សនៈយ៉ាងប្រសើរ ដ៏អង់អាច គឺ ក្លាហាន អាចកម្ចាត់កិលេសមាននៅក្នុងឧត្តរិមនុស្សធម្ម មានឈានជាដើម ឬថា ញាណទស្សនៈយ៉ាងប្រសើរដ៏អង់អាច ជារបស់នៃឧត្តរិមនុស្សធម្មនោះ; ព្រោះដូច្នោះ ឧត្តរិមនុស្ស

ធម្មនោះ ទើបឈ្មោះថា មានសេចក្ដីឃើញដ៏ប្រសើរ ។ ភិក្ខុមិនដឹងពិត ពោលអួតឧត្តរិមនុស្សធម្ម ដែលមានសេចក្ដីឃើញដ៏ប្រសើរយ៉ាងនោះ ។

ក្នុងបទភាជនៈនោះ ឧត្តរិមនុស្សធម្មនោះ លោកហៅថា **អលមរិយញ្ញាណទស្សនា** ដោយញាណទស្សនៈណា, ដើម្បីសម្ដែងញាណទស្សនៈនោះឯង ព្រះឧបាលីទើបពោលបទភាជនៈ ដោយវិជ្ជាជាធំថា ញាណ នោះ បានដល់ វិជ្ជា ៣, ទស្សនៈ នោះ គឺ ញាណយ៉ាងណា ទស្សនៈក៏យ៉ាងនោះ ទស្សនៈក៏យ៉ាងណា ញាណក៏យ៉ាងនោះ ។ តែក្នុងបទថា ញាណំ នេះ បញ្ញាសូម្បីទាំងអស់ដែលជាមហគ្គតនិងលោកុត្តរៈ គប្បីជ្រាបថា ញាណ ។

បទថា សមុទាចរេយ្យ : **ពោលអួត** សេចក្ដីថា គប្បីអួតឧត្តរិមនុស្សធម្ម មានប្រការដូចពោលហើយ ធ្វើឱ្យបង្អោនចូលមកក្នុងខ្លួន ។ ចំណែកបទថា ឥត្ថិយា វា : ដល់ស្រីក្ដី ជាដើម សម្ដែងដល់បុគ្គលដែលភិក្ខុគប្បីអួត ។ ពិតមែន កាលអួតឧត្តរិមនុស្សធម្មដល់បុគ្គលទាំងនេះ រមែងជាការអួត ។ កាលអួតដល់ទេវតា មារ ព្រហ្ម ឬសូម្បីដល់ប្រេត យក្ខ និងសត្វតិរច្ឆាន មិនជាការអួតទេ ដូច្នេះឯង ។

ពាក្យថា ឥតិ ជានាមិ ឥតិ បស្សាមិ : ខ្ញុំដឹងដូច្នេះ ខ្ញុំឃើញដូច្នេះ នេះ សម្ដែងអាការអួត ។ តែក្នុងបទភាជនៈនៃបទថា ឥតិ

ជានាមិ ឥតិ បស្សាមិ នោះ ពាក្យថា "ខ្ញុំដឹងធម៌នេះ ខ្ញុំឃើញធម៌នេះ" នេះ សម្ដែងដល់ការប្រព្រឹត្តទៅនៃការដឹងនិងការឃើញ ក្នុងធម៌មានឈានជាដើមទាំងនោះ ។ ពាក្យថា "ម្យ៉ាងទៀត ធម៌នេះ ជារបស់ខ្ញុំ ខ្ញុំយល់ជាក់ច្បាស់ក្នុងធម៌ទាំងនេះហើយ" ជាដើម សម្ដែងសេចក្ដីបង្អោនចូលមកក្នុងខ្លួន ។

[២៣៤] ពាក្យថា លុះសម័យដទៃអំពីនោះមក នេះ សម្ដែងដល់សម័យដែល ប្តេជ្ញាថា ជាអាបត្តិ ។ តែភិក្ខុនេះត្រូវបារាជិកក្នុងខណៈដែលអួតតែម្ដង ។ និងលោកត្រូវអាបត្តិហើយ ត្រូវភិក្ខុដទៃចោទក៏ដោយ មិនត្រូវចោទក៏ដោយ រមែងប្តេជ្ញា; ព្រោះដូច្នោះ លោកទើបពោលថា "ទោះមានគេសាកសួរក្ដី ឥតមានគេសាកសួរក្ដី" ។

## ហេតុដែលឱ្យជឿមានឋានៈ ៦ យ៉ាង

បណ្ដា អ្នកមានគេសាកសួរ និងអ្នកឥតមានគេសាកសួរ នោះ ក្នុងអ្នកមានគេសាកសួរ គប្បីជ្រាបវិនិច្ឆ័យមុន គឺ ៖

១. ពាក្យថា ធម៌អ្វីដែលលោកបានត្រាស់ដឹង គឺ ជាពាក្យសួរដល់ធម៌ដែលបានសម្រេច ។ មានពាក្យអធិប្បាយថា បណ្ដាគុណធម៌មានឈាននិងវិមោក្ខជាដើម ឬបណ្ដាមគ្គមានសោតាបត្តិមគ្គជាដើម

លោកបានសម្រេចអ្វី ? ។

២. ពាក្យថា **ព្រោះហេតុដូចម្ដេចបានជាលោកបានត្រាស់ដឹង** គឺជាពាក្យសួរដល់ឧបាយ ។ សេចក្ដីពិតក្នុងពាក្យនេះ មានអធិប្បាយដូចតទៅនេះ ៖

គឺ លោកធ្វើអនិច្ចលក្ខណៈឱ្យជាធុរៈហើយទើបបានសម្រេច ? ឬលោកធ្វើបណ្ដាទុក្ខលក្ខណៈនិងអនត្តលក្ខណៈ យ៉ាងណាមួយឱ្យជាធុរៈហើយ ទើបបានសម្រេច ? លោកតាំងមាំហើយដោយអំណាចសមាធិ ឬតាំងមាំហើយដោយអំណាចវិបស្សនាទើបបានសម្រេច ? មួយទៀតលោកតាំងមាំហើយក្នុងរូបធម៌ ឬតាំងមាំហើយក្នុងអរូបធម៌ (រូប-អរូបឈាន) ទើបបានសម្រេច ? លោកតាំងមាំហើយក្នុងកាយជាខាងក្នុង ឬតាំងមាំហើយក្នុងកាយជាខាងក្រៅ ទើបបានសម្រេច ? ។

៣. ពាក្យថា **លោកបានត្រាស់ដឹងពីអង្កាល** គឺ ជាពាក្យសួរដល់កាល ។ មានពាក្យអធិប្បាយថា ក្នុងបណ្ដាកាលព្រឹកនិងថ្ងៃត្រង់ជាដើមកាលណាមួយ ? ។

៤. ពាក្យថា **លោកបានត្រាស់ដឹងក្នុងទីណា** គឺ ជាពាក្យសួរដល់ឱកាស ។ មានអធិប្បាយថា គឺទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ មានទៀបគល់ឈើ ក្នុងមណ្ឌប ឬក្នុងវិហារណា ?

៥. ពាក្យថា **កិលេសណាខ្លះដែលលោកបានលះរួចហើយ** គឺ ជាពាក្យសួរដល់កិលេសដែលលះបានហើយ ។ មានពាក្យអធិប្បាយថា កិលេសទាំងឡាយដែលមគ្គពួកណាសម្លាប់ លោកលះបានហើយ ។

៦. ពាក្យថា **លោកបានធម៌ដូចម្ដេចខ្លះ** គឺ ជាពាក្យសួរដល់ធម៌ដែលបានហើយ មានពាក្យអធិប្បាយថា បណ្ដាមគ្គមានបឋមមគ្គជាដើម លោកបានធម៌ពួកណា ? ។

## អត្ថាធិប្បាយឋានៈ ៦ យ៉ាង

ព្រោះដូច្នោះ ក្នុងកាលឥឡូវនេះ ប្រសិនបើភិក្ខុណា ៗព្យាករណ៍ការសម្រេចឧត្តរិមនុស្សធម្ម, លោកដែលអ្នកណា ៗ មិនគួរធ្វើសក្ការៈដោយពាក្យព្យាករណ៍មានប្រមាណត្រឹមតែប៉ុណ្ណេះ, តែលោកគួរត្រូវជំទាស់ ដើម្បីសាកសួរជម្រះឱ្យស្អាតក្នុងឋានៈទាំង ៦ នេះ គឺ "លោកបានសម្រេចធម៌អ្វី ?" ឬថា "លោកបានសម្រេចឈាន ឬបានសម្រេចបណ្ដាវិមោក្ខជាដើមយ៉ាងណាមួយ ?" ពិតមែន ធម៌ដែលបុគ្គលណាបានសម្រេចហើយ រមែងជារបស់ប្រាកដដល់បុគ្គលនោះ ។ បើលោកពោលថា "ខ្ញុំព្រះករុណាបានសម្រេចធម៌ឈ្មោះនេះ", លំដាប់នោះ គួរសាកសួរលោកថា "លោកបានសម្រេចដោយវិធីណា ?" គឺគួរសាកសួរថា លោកធ្វើយ៉ាងណាក្នុងបណ្ដាត្រៃលក្ខណ៍ មានអនិច្ចលក្ខណៈជាដើម

ឱ្យជាធុរៈ ឬតាំងមាំនៅដោយធម៌អ្វី ក្នុងបណ្ដាអារម្មណ៍ ៣៨ យ៉ាង ឬក្នុងបណ្ដាធម៌ដែលផ្សេងដោយរូបធម៌ អរូបធម៌កាយជាខាងក្នុងនិងកាយជាខាងក្រៅជាដើមដោយធម៌ណាមួយជាប្រធាន ទើបបានសម្រេច ? ពិតមែន ការតាំងមាំណារបស់បុគ្គលណាមានការតាំងមាំនោះ រមែងប្រាកដដល់បុគ្គលនោះ ។ បើភិក្ខុពោលថា "ការតាំងមាំឈ្មោះនេះរបស់ខ្ញុំព្រះករុណាមាន, ខ្ញុំព្រះករុណាបានសម្រេចដោយវិធីយ៉ាងនេះ" ដូច្នេះ, លំដាប់នោះ គួរសាកសួរលោកមើលថា លោកបានសម្រេចកាលណា ? គឺ គួរសាកសួរលោកថា លោកបានសម្រេចក្នុងវេលាព្រឹក ឬក្នុងបណ្ដាវេលាថ្ងៃត្រង់ជាដើម វេលាណាមួយឬ ? សេចក្ដីពិត កាលដែលខ្លួនបានសម្រេច រមែងជារបស់ប្រាកដដល់ជនទាំងពួង ។ បើភិក្ខុពោលថា "ខ្ញុំព្រះករុណាបានសម្រេចក្នុងកាលឈ្មោះឯណោះ", លំដាប់នោះ គួរសាកសួរលោកមើលថា "លោកបានសម្រេចទីណា ?" គឺ គួរសាកសួរលោកថា "លោកបានសម្រេចក្នុងទីសម្រាកពេលថ្ងៃ ឬក្នុងបណ្ដាទីសម្រាកពេលយប់ជាដើម ឱកាសណាមួយឬ ?" ពិតមែន ឱកាសដែលខ្លួនបានសម្រេច រមែងប្រាកដដល់ជនទាំងពួង ។ បើភិក្ខុពោលថា "ខ្ញុំព្រះករុណាបានសម្រេចក្នុងឱកាសឈ្មោះឯណោះ", លំដាប់នោះ គួរសាកសួរលោកមើលថា "លោកលះកិលេសពួកណាបាន" គឺ គួរសាកសួរលោក

ថា "កិលេសទាំងឡាយ ដែលបឋមមគ្គគប្បីសម្លាប់ ឬថា ដែលទុតិយមគ្គជាដើមគប្បីសម្លាប់ លោកលះបានហើយឬ ?" សេចក្តីពិត កិលេសដែលមគ្គដែលខ្លួនបានសម្រេចលះបានហើយ រមែងប្រាកដដល់ជនទាំងពួង ។ បើភិក្ខុពោលថា "កិលេសឈ្មោះពួកនេះ ខ្ញុំព្រះករុណាលះបានហើយ", លំដាប់នោះ គួរសាកសួរលោកមើលថា "លោកបានធម៌ពួកណា ?" គឺ គួរសាកសួរលោកមើលថា "លោកបានសោតាបត្តិមគ្គ ឬបានបណ្តាមគ្គមានសកទាគាមិមគ្គជាដើម យ៉ាងណាមួយឬ ?" សេចក្តីពិត ធម៌ដែលខ្លួនបានសម្រេចហើយ រមែងប្រាកដដល់ជនទាំងពួង ។ បើភិក្ខុពោលថា "ខ្ញុំព្រះករុណាបានធម៌ទាំងឡាយឈ្មោះនេះ", មិនគួរកាន់យកពាក្យនិយាយរបស់លោក សូម្បីដោយពាក្យព្យាករណ៍មានប្រមាណត្រឹមតែប៉ុណ្ណេះ ។ ពិតមែន ភិក្ខុទាំងឡាយ ជាពហុស្សូត ជាអ្នកឆ្លាតក្នុងការរៀន និងការសាកសួរ រមែងអាចដេញដោលសួរហេតុ:ទាំង ៦ ពួកនេះ ជម្រះឱ្យស្អាតបាន ។

## សួរដល់បដិបទាដែលអាងថា សម្រេចធម៌

ចំណែកអាគមនបដិបទា (ការបដិបត្តិជាហេតុមកនៃមគ្គ) របស់ភិក្ខុនេះ គួរដេញដោលសួរជម្រះឱ្យស្អាត ។ បើអាគមនបដិបទា មិនបរិសុទ្ធ, ភិក្ខុទាំងឡាយគួរពោលថា "ដែលឈ្មោះថា លោកុត្តរធម៌

លោកនឹងមិនបានដោយបដិបទានេះ” ហើយនាំលោកចេញទៅ ។ តែអាគមបដិបទារបស់ភិក្ខុនោះបរិសុទ្ធ, បើភិក្ខុនោះ ប្រាកដក្នុងបដិបទានោះថា ជាអ្នកមិនប្រមាទក្នុងត្រៃសិក្ខា ទាំងប្រឹងប្រែងប្រកបធម៌ជាគ្រឿងភ្ញាក់រលឹករហូតអស់រាត្រីយូរ មិនជាប់ជំពាក់ក្នុងបច្ច័យទាំង ៤ ដូចចិត្តស្មើដោយបាទដៃក្នុងអាកាស ពាក្យព្យាករណ៍របស់ភិក្ខុនោះ រមែងប្រៀបធៀបនឹងការបដិបត្តិបាន គឺ ដូចជាព្រះពុទ្ធវចនៈដែលត្រាស់ទុកថា “ទឹកក្នុងទន្លេគង្គាប្រៀបស្មើនឹងទឹកក្នុងទន្លេយមុនា ដូចម្ដេចមិញ បដិបទា ជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តល្អហើយដល់សាវកទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា ក៏ប្រៀបធៀបគ្នាបានដូច្នោះដែរ”[១] ។ ម្យ៉ាងទៀត សក្ការៈដែលអ្នកណា ៗ មិនគួរធ្វើសូម្បីដោយពាក្យព្យាករណ៍មានប្រមាណត្រឹមតែប៉ុណ្ណេះ ។ ព្រោះហេតុអ្វី ? ព្រោះថា សូម្បីភិក្ខុដែលជាបុថុជ្ជនរូបខ្លះ ក៏មានបដិបទាដូចជាការបដិបត្តិរបស់ព្រះខីណាស្រព ។ ព្រោះដូច្នោះ ភិក្ខុនោះ ដែលអ្នកណា ៗ គប្បីធ្វើឱ្យតក់ស្លុតបានដោយឧបាយនោះ ៗ ។ ធម្មតាព្រះខីណាស្រព សូម្បីកាលអសនីបាត (រន្ទះ) បាញ់ចុះមកលើក្បាល ក៏មិនមានសេចក្ដីខ្លាចសេចក្ដីតក់ស្លុត ឬសេចក្ដីព្រឺរោមទេ ។ បើសេចក្ដីខ្លាចក្ដី សេចក្ដីតក់

១. ទីឃ. មហា. ១៧. ៤៨/១១០ ។

ស្ចុតក្តី សេចក្តីព្រឺរោមក្តី កើតឡើងដល់ភិក្ខុនោះ, លោកដែលភិក្ខុទាំងឡាយ គប្បីពោលដាស់តឿនថា "លោកមិនមែនជាព្រះអរហន្ត" ហើយគប្បីនាំចេញ ។ តែបើភិក្ខុនោះ ជាអ្នកមិនខ្លាច ជាអ្នកមិនភិតភ័យ ជាអ្នកមិនញញើត រមែងអង្គុយស្ងៀម ដូចរាជសីហ៍ដូច្នោះ, ភិក្ខុនេះឈ្មោះថា ជាអ្នកមានការព្យាករណ៍យ៉ាងបរិបូរណ៍ រមែងគួរទទួលសក្ការៈដែលព្រះរាជា និង រាជមហាអាមាត្យជាដើម បញ្ជូនទៅប្រគេនដោយជុំវិញ ដូច្នេះឯង ។

បទថា **ទាបិច្ចោ : មានសេចក្តីប្រាថ្នាអាក្រក់** បានដល់ ភិក្ខុដែលប្រកបដោយភាពជាអ្នកប្រាថ្នាលាមក ដែលព្រះមានព្រះភាគត្រាស់ទុក ដោយន័យជាដើមថា "បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីលប្រាថ្នាថា ជនចូរដឹងនូវអញថា ជាអ្នកមានសីល"[២] ដូច្នេះ ។

បទថា **ឥច្ឆាបកតោ : សេចក្តីប្រាថ្នាគ្របសង្កត់ហើយ** បានដល់ ភិក្ខុអ្នកត្រូវអាបត្តិបារាជិក ត្រូវសេចក្តីប្រាថ្នាលាមកនោះគ្របសង្កត់គឺ ញាំញី ។

បទថា **វិសុទ្ធាបេក្ខោ : អ្នកប្រាថ្នាចង់ឱ្យបរិសុទ្ធ** បានដល់ អ្នក

២. អភិ. វិភ. ខុទ្ទកវត្ថុវិភង្គ. ៨២. ១០២/១៥៤ ។

ប្រាថ្នា គឺ ត្រូវការប្រាថ្នាសេចក្តីបរិសុទ្ធិដើម្បីខ្លួន ។ ពិតមែន ព្រោះហេតុដែលភិក្ខុនេះ ត្រូវអាបត្តិបារាជិកហើយ; ដូច្នោះលោកតាំងនៅក្នុងភាពជាភិក្ខុ ជាអ្នកមិនគួរ ដើម្បីសម្រេចគុណធម៌មានឈានជាដើម ។

ពិតមែន ភាពជាភិក្ខុរបស់លោក រមែងជាការអន្តរាយចំពោះសួគ៌ផង ជាអន្តរាយចំពោះមគ្គផង ។ សមពិត ដូចព្រះតម្រាស់ដែលព្រះមានព្រះភាគ ត្រាស់ទុកថា "ភាពជាសមណៈ ដែលបព្វជិតកាន់មិនស៊ប់សួនហើយ រមែងទាញបព្វជិតនោះទៅនរក"[១] ។ សូម្បីព្រះតម្រាស់ដទៃទៀតក៏ត្រាស់ថា "ព្រោះថា សមណធម៌គ្រៀងរៀរចាកកិលេសធូរថយ រមែងរោយធូលី គឺរាគាទិក្កិលេសលើបុគ្គលនោះ"[២] ដូច្នេះ ភាពជាភិក្ខុរបស់លោក រមែងឈ្មោះថា ជារបស់មិនបរិសុទ្ធ ដូច្នេះឯង ។

មួយទៀត ភិក្ខុដែលត្រូវបារាជិកនោះ(លះភិក្ខុភាវៈ) ជាគ្រហស្ថ ឬជាឧបាសក ជាអារាមិកៈ ឬជាសាមណេរ រមែងជាអ្នកគួរដើម្បីញ៉ាំងមកសួគ៌ឱ្យសម្រេច ដោយគុណធម៌ទាំងឡាយ មានទាន សរណៈ សីល និងសំវរៈជាដើម ឬញ៉ាំងមកព្រះនិព្វានឱ្យសម្រេច ដោយគុណធម៌ទាំងឡាយ មានឈាននិងវិមោក្ខជាដើម; ព្រោះហេតុនោះ ភាពជាគ្រហស្ថជា

---

១.២. ខុទ្ទ. ធម្ម. និរយវគ្គ. ៥២. ៣២/៨៦ ។

ដើមរបស់លោក ទើបឈ្មោះថា ជាសេចក្តីបរិសុទ្ធិ ។

ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ហៅលោកថា អ្នកប្រាថ្នាសេចក្តីបរិសុទ្ធិព្រោះសម្លឹងដល់សេចក្តីបរិសុទ្ធិនោះ ។ ក៏ដោយហេតុនោះឯង ក្នុងបទភាជនៈនៃបទថា វិសុទ្ធាបេក្ខោ នោះ ព្រះឧបាលីថេរៈ ទើបពោលពាក្យជាដើមថា "ទោះមានប្រាថ្នាចង់ទៅជាគ្រហស្ថក្តី" ។

ពីរបទថា ឯវំ វទេយ្យ : **និយាយតែសំនួនយ៉ាងនេះ** គឺគប្បីពោលយ៉ាងនេះ ។ សួរថា គប្បីពោលយ៉ាងណា ? ឆ្លើយថា គប្បីពោលថា "នែអាវុសោ ខ្ញុំមិនដឹងយ៉ាងនេះទេ (ប៉ុន្តែ) ពោលថា ដឹង, ខ្ញុំមិនឃើញយ៉ាងនេះទេ (ប៉ុន្តែ) ពោលថា ឃើញ" ។ ចំណែកក្នុងបទភាជនៈ ព្រះឧបាលីថេរៈមិនបានលើកបទថា ឯវំ វទេយ្យ នេះឡើងឡើយ បានពោលពាក្យជាដើមថា "ខ្ញុំមិនបានដឹងធម៌នេះទេ" ដូច្នេះ ដើម្បីសម្តែងអាការដែលភិក្ខុពោលជាហេតុឱ្យលោកហៅឈ្មោះថា រមែងពោលថា "នែលោក ខ្ញុំព្រះករុណាមិនដឹងយ៉ាងនោះ បានពោលថា ដឹង, មិនឃើញយ៉ាងនោះ បានពោលថា ឃើញ" ។

ពាក្យថា តុច្ឆំ មុសា វិលបិន្តិ : **ខ្ញុំពោលកុហកសោះទេ** មានពាក្យអធិប្បាយថា ខ្ញុំព្រះករុណាបាននិយាយ គឺ បានពោលសោះទទេ ៗ បានវៀរចាកប្រយោជន៍នៃពាក្យនិយាយ ជាកុហកទទេ ៗ ដោយសេចក្តី

ប្រាថ្នានឹងបញ្ឆោត ។ ចំណែកក្នុងបទភាជនៈនៃបទនោះ ព្រះឧបាលីថេរៈពោលពាក្យទុកថា "ខ្ញុំពោលសោះទទេ ខ្ញុំពោលកុហកទេ ខ្ញុំពោលមិនពិតទេ ខ្ញុំពោលមិនប្រាកដទេ ខ្ញុំបានជាច្រលពោល មកពីហេតុមិនដឹងសោះទេ" ដូច្នេះ ។ ក៏ដើម្បីសម្ដែងត្រឹមតែសេចក្ដី ដោយបទទនិងព្យញ្ជនៈយ៉ាងដទៃ ។

[២៣៥] ពីរបទថា **បុរិមេ ឧបាទាយ : ពោលប្រៀបធៀបនឹងភិក្ខុដែលមានក្នុងសិក្ខាបទមុន** សេចក្ដីថា ធៀបបុគ្គលដែលត្រូវបារាជិកទាំង ៣ មុន ៗ ។ ពាក្យដ៏សេស ឈ្មោះថា ប្រាកដច្បាស់ហើយនោះឯង ព្រោះមានន័យដូចពោលហើយក្នុងខាងដើម និងព្រោះមានសេចក្ដីច្បាស់លាស់ ដូច្នេះឯង ។

## អធិប្បាយបទភាជនី

[២៣៦] ព្រះមានព្រះភាគ គ្រាទ្រង់ចែកសិក្ខាបទដែលទ្រង់ឧទ្ទេសទុកតាមលំដាប់បទយ៉ាងនោះហើយ ឥឡូវនេះ មានព្រះប្រាថ្នានឹងទ្រង់តាំងបទភាជនៈនោះឯងក្នុងឋានជាមាតិកាទៀត ហើយសម្ដែងឧត្តរិមនុស្សធម្មដោយពិស្ដារ សម្ដែងប្រភេទអាបត្តិ ដើម្បីកាន់យកសេចក្ដីដោយអាការទាំងពួង ទើបត្រាស់ពាក្យថា "ឈាននោះ បានខាងបឋមជ្ឈាន ទុតិយ

ជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន” ព្រោះហេតុថា ក្នុងបទភាជនីក្នុងខាងលើ បានទ្រង់សម្តែងឧត្តរិមនុស្សធម្មទុកតែដោយសង្ខេបយ៉ាងនេះថា “ឈាន១ វិមោក្ខ ១ សមាធិ ១ សមាបត្តិ ១ ញាណទស្សនៈ ១ មគ្គភាវនា ១ ផលសច្ឆិកិរិយា ១ កិលេសប្បហាន ១ វិនីវរណតា ចិត្តស្ស ១ សុញ្ញាគារេ អភិរតិ ១” មិនបានទ្រង់លើកអាបត្តិតាំងជាបែបទុកដោយពិស្តារ និងកាលសម្តែងសេចក្តីទុកដោយសង្ខេបហើយ អ្នកសិក្សាទាំងឡាយមិនអាចកាន់យកសេចក្តីបានដោយល្អិតល្អន់ ។

ក្នុងពាក្យថា **បឋមជ្ឈានំ** ជាដើមនោះ មានវិនិច្ឆ័យដូច្នេះ ៖

អប្បមញ្ញាឈាន មានមេត្តាឈានជាដើមក្តី អសុភឈានជាដើមក្តី អានាបានស្សតិសមាធិឈានក្តី លោកិយឈានក្តី លោកុត្តរឈានក្តី សង្គ្រោះចូលដោយបឋមជ្ឈានជាដើមនុ៎ះឯង ។

ព្រោះហេតុនោះ កាលភិក្ខុអួតថា “ខ្ញុំព្រះករុណាចូលបឋមជ្ឈានហើយក្តី ... ខ្ញុំព្រះករុណាចូលចតុត្ថជ្ឈានហើយក្តី” អួតថា “ខ្ញុំព្រះករុណាចូលមេត្តាឈានហើយក្តី ... ខ្ញុំព្រះករុណាចូលឧបេក្ខាឈានក្តី ខ្ញុំព្រះករុណាចូលលោកិយឈានហើយក្តី ខ្ញុំព្រះករុណាចូលអានាបានស្សតិសមាធិឈានហើយក្តី ខ្ញុំព្រះករុណាចូលលោកិយឈានហើយក្តី ខ្ញុំព្រះករុណាចូលលោកុត្តរឈានហើយក្តី” គប្បីជ្រាបថា ជាបារាជិកទាំង

នោះ ៗ អរិយមគ្គ ដែលរួចផុតដោយល្អ ឬដែលរួចផុតចាកកិលេសមាន ប្រភេទផ្សេង ៗ ព្រោះដូច្នោះ អរិយមគ្គនោះ ទើបឈ្មោះថា វិមោក្ខ ។ ក៏ឯវិមោក្ខ នោះ លោកហៅថា សុញ្ញតវិមោក្ខ ព្រោះសូន្យចាករាគៈ ទោសៈ និងមោហៈ, លោកហៅថា អនិមិត្តវិមោក្ខ ព្រោះមិនមាននិមិត្ត ដោយនិមិត្ត គឺ រាគៈ ទោសៈ និងមោហៈ, លោកហៅថា អប្បណិហិតវិមោក្ខ ព្រោះមិនមានទីតាំង គឺ រាគៈ ទោសៈ និងមោហៈ ។ ធម្មជាតិ ដែលឈ្មោះថា សមាធិ ព្រោះអត្ថថា តាំងចិត្តទុកស្មើ គឺ តាំងចិត្តទុកក្នុង អារម្មណ៍ ។ ដែលឈ្មោះថា សមាបត្តិ ព្រោះជាធម្មជាតិ ដែលព្រះ អរិយៈទាំងឡាយគប្បីចូល ។ បទដ៏សេសក្នុងពាក្យទាំងនេះ មានន័យ ដូចពោលហើយនុ៎ះឯង ។ ក៏អរិយមគ្គនោះ ព្រះមានព្រះភាគត្រាស់ទុក ក្នុងតិកៈទាំងនេះ ដោយពួក ៣ នៃវិមោក្ខ និងដោយពួក ៣ នៃ សមាធិ ។ ផលសមាបត្តិ ត្រាស់ទុកដោយពួក ៣ នៃសមាបត្តិ ។ ក្នុង បទទាំងនោះ ភិក្ខុកាន់យកបទយ៉ាងណាមួយត្រឹមតែមួយបទ ពោលថា "ខ្ញុំព្រះករុណា មានប្រក្រតីបានធម៌នេះ" រមែងជាបារាជិកពិត ។

ដែលឈ្មោះថា វិជ្ជា ៣ បានដល់ បុព្វេនិវាសានុស្សតិ ទិព្វចក្ខុ អាសវក្ខយញ្ញាណនោះឯង ។ ក្នុងវិជ្ជា ៣ នោះ កាលភិក្ខុកាន់យក ឈ្មោះសូម្បីនៃវិជ្ជាណាទីមួយអួតថា "ខ្ញុំព្រះករុណា មានប្រក្រតីបានវិជ្ជា

នេះ” រមែងជាបារាជិកពិត ៗ តែក្នុងសង្ខេបអដ្ឋកថា លោកពោលថា កាលភិក្ខុពោលថា “ខ្ញុំព្រះករុណាមានប្រក្រតីបានវិជ្ជាទាំងឡាយ” ដូច្នេះក្តី ពោលថា “ខ្ញុំព្រះករុណា មានប្រក្រតីបានវិជ្ជា ៣” ដូច្នេះក្តី រមែងជាបារាជិកដូចគ្នា ៗ មគ្គភាវនា បានពោលហើយក្នុងបទភាជនៈ ៗ ពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលសម្បយុត្តដោយមគ្គ ជាលោកុត្តរៈពិត លោកប្រាថ្នាយកក្នុងបទថា មគ្គភាវនានេះ ព្រោះហេតុនោះ ទើបក្នុងមហាអដ្ឋកថាពោលថា ជាបារាជិកដល់ភិក្ខុអ្នកពោលថា “ខ្ញុំព្រះករុណាមានប្រក្រតីបានសតិប្បដ្ឋានដែលជាលោកុត្តរៈ, ខ្ញុំព្រះករុណា មានប្រក្រតីបានសម្មប្បធាន, ... ឥទ្ធិបាទ ... ឥន្ទ្រិយ ... ពលៈ ... ពោជ្ឈង្គ ... អរិយមគ្គមានអង្គ ៨ ដែលជាលោកុត្តរៈ” ៗ ចំណែកក្នុងមហាបច្ចរីជាដើម លោកពោលទុកថា កាលភិក្ខុពោលដោយអំណាចចំណែកមួយ ៗ យ៉ាងនេះថា “ខ្ញុំព្រះករុណា ជាអ្នកមានប្រក្រតីបានសតិប្បដ្ឋាន” ដូច្នេះក្តី ដោយអំណាចធម៌មួយយ៉ាង ៗ ក្នុងចំណែកទាំងនោះ យ៉ាងនេះថា “ខ្ញុំព្រះករុណា ជាអ្នកមានប្រក្រតីបានកាយានុបស្សនាសតិប្បដ្ឋាន” ដូច្នេះក្តី ជាបារាជិកដូចគ្នា ៗ សូម្បីពាក្យដែលលោកពោលទុកក្នុងមហាបច្ចរីជាដើមនោះ រមែងសមគ្នា ៗ ព្រោះហេតុអ្វី ? ព្រោះហេតុដែលលោកពោលសំដៅយកសតិប្បដ្ឋាន ដែលកើតឡើងក្នុងខណៈនៃមគ្គដូចគ្នា ៗ

សូម្បីក្នុងការធ្វើឱ្យច្បាស់នូវផល ក៏គប្បីជ្រាបថា ជាបារាជិក ដោយអំណាចនៃផលទីមួយ ៗ ។ ចំពោះការលះកិលេស ព្រះមានព្រះភាគត្រាស់ក្នុងពួក ៣ មានពាក្យថា **រាគស្ស បហានំ : លះបង់រាគ** ជាដើម ។ ក៏ការលះកិលេសនោះ វៀរមគ្គចេញហើយ រមែងមិនមាន, ពិតមែន ការលះរាគៈ និងទោសៈ រមែងមានដោយមគ្គទី ៣, ការលះមោហៈ រមែងមានដោយមគ្គទី ៤; ព្រោះហេតុនោះ ទើបជាបារាជិកសូម្បីដល់ភិក្ខុដែលពោលពាក្យជាដើមថា "រាគៈ ខ្ញុំព្រះករុណាលះបានហើយ", ចំពោះលោកុត្តរចិត្ត នឹងសមាបត្តិ ព្រះមានព្រះភាគត្រាស់ក្នុងពួក ៣ មានពាក្យថា **រាគា ចិត្តំ វិនីវរណតា : ការហាមឃាត់ចិត្តចាករាគៈ** ជាដើម ។ ព្រោះហេតុនោះ សូម្បីកាលភិក្ខុពោលពាក្យជាដើមថា "ចិត្តរបស់ខ្ញុំព្រះករុណា ប្រាសចាករាគៈ" ក៏ជាបារាជិកដូចគ្នា ។ ចំណែកក្នុងបទភាជនៈនៃបទសុញ្ញាគារ លោកមិនប្រាថ្នាបារាជិក ដោយត្រឹមតែពាក្យដែលមិនជាប់ដោយឈានថា "ខ្ញុំព្រះករុណា ត្រេកអរចំពោះក្នុងសុញ្ញាគារ"; ព្រោះដូច្នោះ ទើបលោកពោលពាក្យជាដើមទុកថា "(ខ្ញុំ) ត្រេកអក្នុងផ្ទះស្ងាត់ ដោយបឋមជ្ឈាន" ។

ព្រោះហេតុនោះ ភិក្ខុណា ពោលជាប់ដោយឈានថា "ខ្ញុំព្រះករុណាត្រេកអរចំពោះក្នុងសុញ្ញាគារដោយឈានឈ្មោះនេះ" ភិក្ខុនេះឯង

គប្បីជ្រាបថា ជាបារាជិក ។

ក៏បណ្តាវិជ្ជា ៨ ដែលត្រាស់ទុកក្នុងព្រះសូត្រទាំងឡាយ មាន អម្ពដ្ឋសូត្រជាដើម វិជ្ជា ៥ ពួកណា ផ្សេងដោយវិបស្សនាញាណ មនោមយិទ្ធិ ឥទ្ធិវិធី ទិព្វសោត និងចេតោបរិយញ្ញាណ មិនបានមក ហើយក្នុងបទភាជនៈនៃបទថា ញាណំ នេះ, បណ្តាវិជ្ជា ៥ ទាំងនោះ ចំពោះវិបស្សនាតែម្យ៉ាង រមែងមិនជាវត្ថុនៃបារាជិក, វិជ្ជាដ៏សេស គប្បីជ្រាបថា ជាវត្ថុនៃបារាជិក ។ ព្រោះហេតុនោះ កាលភិក្ខុពោលថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានវិបស្សនា"ក្តី ថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានវិបស្សនាញាណ"ក្តី មិនជាបារាជិក ។ តែព្រះបុស្សទេវត្ថេរ ពោលថា វិជ្ជា ៤ សូម្បីក្រៅអំពីនេះ មិនជាប់ដោយញាណ រមែងមិនជាវត្ថុនៃបារាជិក; ព្រោះហេតុនោះ ទើបមិនត្រូវអាបត្តិបារាជិក សូម្បីដល់ភិក្ខុដែលពោលថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានមនោមយៈ", "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានឥទ្ធិវិធី", "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានទិព្វសោតធាតុ", "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានចេតោបរិយៈ" ។ ពាក្យនោះ ត្រូវពួកអន្តេវាសិករបស់លោកនោះឯងជំទាស់ហើយថា "លោកអាចារ្យ មិនមែនជាអ្នកជំនាញក្នុងអភិធម្ម រមែងមិនជ្រាបធម៌ជាភូមិដទៃ, ដែលឈ្មោះថា អភិញ្ញាមានចតុត្ថជ្ឈានជា

បាទ ទាំងជាមហគ្គតធម៌ផង រមែងសម្រេចបានដោយឈានប៉ុណ្ណោះ; ព្រោះហេតុនោះ ភិក្ខុនឹងពោលថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានមនោមយៈ", ឬថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានមនោមយញ្ញាណ" ឬនឹងពោលដោយពាក្យតាមដែលខ្លួនប្រាថ្នានឹងពោលក៏ដោយ, លោករមែងត្រូវបារាជិកដូចគ្នា ។ ពិតមែន ក្នុងចតុត្ថបារាជិកនេះ ព្រះនិព្វានមិនបានមកក្នុងព្រះបាលី ក៏ពិតមែន, តែកាលភិក្ខុពោលថា "ព្រះនិព្វាន ខ្ញុំព្រះករុណាសម្រេចហើយ" ឬថា "ព្រះនិព្វាន ខ្ញុំព្រះករុណាធ្វើឱ្យច្បាស់ហើយ" រមែងជាបារាជិកដូចគ្នា ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា ព្រះនិព្វានជាលោកុត្តរធម៌មានវដ្ដៈដែលប្រាសចេញហើយ ។

មួយទៀត សូម្បីកាលភិក្ខុពោលថា "ខ្ញុំព្រះករុណាចាក់ធ្លុះសច្ចៈ ៤", (ឬថា) "សច្ចៈ ៤ ដែលខ្ញុំព្រះករុណាចាក់ធ្លុះហើយ" គង់ជាបារាជិកដូចគ្នា ។ ព្រោះហេតុអ្វី ព្រោះហេតុថា ពាក្យចាក់ធ្លុះសច្ចៈ ជាពាក្យពោលហៅ មគ្គ ។ មួយទៀត លោក ពោលទុកក្នុងវិភង្គថា "បដិសម្ភិទា ៣ កើតក្នុងចិត្តុប្បាទ ៤ ជាញាណសម្បយុត្ត ខាងកាមាវចរកុសល, កើតក្នុងចិត្តុប្បាទ ៤ ជាញាណសម្បយុត្ត ខាងកិរិយា, អត្ថប្បដិសម្ភិទា កើតក្នុងចិត្តុប្បាទទាំងនុ៎ះផង កើតក្នុងមគ្គ ៤ ផល ៤ ផង"[១]

---

១. អភិ. វិភង្គ. ៨២. ២២/៤៧ ។

ព្រោះហេតុនោះ កាលភិក្ខុពោលពាក្យថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានធម្មប្បដិសម្ភិទា" ឬថា "ខ្ញុំព្រះករុណា ជាអ្នកមានប្រក្រតីបាននិរុត្តិបដិសម្ភិទា" ឬថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានបដិភាណបដិសម្ភិទា" ឬថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានលោកិយអត្ថបដិសម្ភិទា" ដូច្នេះ មិនទាន់ជាបារាជិក ។ សួម្បីកាលភិក្ខុពោលពាក្យថា "ខ្ញុំព្រះករុណា ជាអ្នកមានប្រក្រតីបានបដិសម្ភិទាទាំងឡាយ" អាបត្តិនៅមិនទាន់ដល់ទីបំផុតទេ ។ តែកាលលោកពោលថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានលោកុត្តរអត្ថបដិសម្ភិទា" រមែងជាបារាជិក ។ ចំណែកក្នុងសង្ខេបអដ្ឋកថាលោកពោលទុកថា កាលភិក្ខុពោលសួម្បីដោយសេចក្តីមិនប្លែកគ្នាថា "ខ្ញុំព្រះករុណាជាអ្នកបានសម្រេចអត្ថបដិសម្ភិទា" ក៏ជាបារាជិក ។ សួម្បីក្នុងកុរុន្ទីក៏លោកពោលថា រមែងមិនផុត ។ តែក្នុងមហាអដ្ឋកថា លោកពោលទុកថា បារាជិក រមែងមិនមានដោយហេតុត្រឹមតែប៉ុណ្ណោះ អាបត្តិមិនទាន់ដល់ទីបំផុតដោយហេតុត្រឹមតែប៉ុណ្ណោះ, អ្នកណា ៗ មិនអាចធ្វើអដ្ឋកថាដទៃឱ្យជាប្រមាណបាន ព្រោះលោកបានវិចារណ៍ទុកហើយថា ភិក្ខុមិនទាន់ជាបារាជិក ដោយហេតុត្រឹមតែប៉ុណ្ណោះ ។ សួម្បីកាលភិក្ខុពោលថា "ខ្ញុំព្រះករុណាចូលនិរោធសមាបត្តិ" ឬថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបាននិរោធសមាបត្តិនោះ" ក៏មិនជា

បារាជិក ។ ព្រោះហេតុអ្វី ? ព្រោះហេតុថា និរោធសមាបត្តិមិនមែនលោកិយៈ ទាំងមិនមែនលោកុត្តរៈ ដូច្នេះឯង ។ ក្នុងមហាបច្ចរី និងសង្ខេបអដ្ឋកថាលោកពោលទុកថា ក៏បើបុគ្គលនោះ មានសេចក្តីរំពឹងយ៉ាងនេះថា "ព្រះអនាគាមី ឬព្រះខីណាស្រព រមែងចូលនិរោធបាន", ទើបព្យាករណ៍ដោយធ្វើទុកក្នុងចិត្តថា "ជនទីនឹងដឹងយើងថា ជាអ្នកណាម្នាក់ ក្នុងបណ្តាព្រះអនាគាមីនិងព្រះខីណាស្រពទាំងនេះ", ហើយគេក៏យល់លោកយ៉ាងនោះ, ជាបារាជិក ។ ពាក្យនោះ គួរពិចារណាជាមុនសិន សឹមកាន់យក ។ សូម្បីកាលភិក្ខុពោលថា "ក្នុងភពដែលកន្លងទៅហើយ គឺ ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ខ្ញុំព្រះករុណាជាព្រះសោតាបន្ន", មិនជាបារាជិក, ពិតមែន អាបត្តិមិនដល់ទីបំផុត ព្រោះលោកអាងដល់ខន្ធដែលកន្លងទៅហើយនោះឯង ។ ចំណែកក្នុងសង្ខេបអដ្ឋកថាលោកពោលទុកថា អាចារ្យពួកខ្លះពោលថា កាលភិក្ខុពោលថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានសមាបត្តិ ៨ ក្នុងអតីត"; មិនជាបារាជិក ព្រោះសមាបត្តិ ៨ ក្នុងអតីតជាកុប្បធម៌, តែកាលពោលថា "ខ្ញុំព្រះករុណាជាអ្នកមានប្រក្រតីបានសមាបត្តិ ៨ ក្នុងភពនេះ"ដូច្នេះ, រមែងជាបារាជិក ព្រោះសមាបត្តិ ៨ ក្នុងភពនេះជាអកុប្បធម៌ ។ សូម្បីពាក្យដែលពោលទុកក្នុងសង្ខេបអដ្ឋកថានោះ លោកក៏ជំទាស់ទុកក្នុងសង្ខេប

អដ្ឋកថានោះឯងថា កាលភិក្ខុពោលសំដៅយកអត្តភាពក្នុងអតីត មិនជាបារាជិកចំពោះកាលពោលសំដៅយកអត្តភាពក្នុងបច្ចុប្បន្នទុះឯង ទើបជាបារាជិក ។

[២៣៧-២៥៤] ព្រះមានព្រះភាគ កាលទ្រង់ញាំងបទមាតិកា ១០ មានឈានជាដើមឱ្យពិស្តារយ៉ាងនេះហើយ ឥឡូវនេះ ភិក្ខុដែលអួតឧត្តរិមនុស្សធម្ម រមែងពោលសម្បជានមុសាវាទណា, កាលទ្រង់សម្តែងអង្គនៃសម្បជានមុសាវាទនោះហើយ ចង់ចក្កបេយ្យាល ដោយអំណាចនៃសេចក្តីពិស្តារនោះឯង និងដើម្បីសម្តែងអាការនៃការអួត និងប្រភេទនៃអាបត្តិ ទើបត្រាស់ថា **តីហាការេហិ : ដោយអាការ ៣ យ៉ាង** ដូច្នេះជាដើម ។

## សុទ្ធិកមហាវារ

ក្នុងពាក្យនោះ មានវិនិច្ឆ័យដូចតទៅនេះ ៖

មហាវារ ៣ គឺ សុទ្ធិកវារ (វារកំណត់ដោយការអួតសុទ្ធ) ១ វត្តុកាមវារ (វារកំណត់ដោយភិក្ខុដែលប្រាថ្នានឹងអួត) ១ បច្ច័យបដិសំយុត្តវារ (វារកំណត់ដោយការអួតដែលជាប់ដោយបច្ច័យ) ១ បណ្តាមហាវារ ៣ ទាំងនោះ ក្នុងសុទ្ធិកវារ ៦ បទទាំងនេះ គឺ សមាបជ្ជឹ

សមាបជ្ជាមិ សមាបន្នោ លាភិម្ហិ វសិម្ហិ សច្ឆិកតំ មយា : អាត្មាបានចូលហើយ អាត្មាកំពុងចូល អាត្មាបានចូល អាត្មាជាអ្នកបាន អាត្មាជាអ្នកស្ទាត់ជំនាញហើយ អាត្មាបានធ្វើឱ្យជាក់ច្បាស់រួចហើយ ទ្រង់ប្រកបបទនីមួយ ៗ ៥ លើក យ៉ាងនេះថា ដោយអាការ ៣ ដោយអាការ ៤ ដោយអាការ ៥ ដោយអាការ ៦ ដោយអាការ ៧ ក្នុងបទនីមួយ ៗ តាំងអំពីបឋមជ្ឈាន ជាដំបូង ដរាបដល់បទថា ចិត្តរបស់អាត្មាផុតស្រឡះចាកមោហៈ ត្រាស់ឈ្មោះថា សុទ្ធិកន័យ ។

[២៥៥-២៦៦] លំដាប់នោះកាលទ្រង់តបទនីមួយ ៗ ជាប់ដោយបឋមជ្ឈាន យ៉ាងនេះថា "បានចូលកាន់បឋមជ្ឈានផង ចូលកាន់ទុតិយជ្ឈានផង" ដូច្នេះ ទ្រង់តគ្រប់បទ ត្រាស់ឈ្មោះថា ខណ្ឌចក្ក ដោយអត្ថដែលពិស្តារនោះ ។ អធិប្បាយថា ខណ្ឌចក្កនោះ ត្រាស់ថា ខណ្ឌចក្ក ព្រោះទ្រង់មិននាំមកប្រកបទឹងឈានមានបឋមជ្ឈានជាដើមទៀត ។

[២៦៧] លំដាប់នោះ ទ្រង់តបទនីមួយ ៗ ជាប់ដោយទុតិយជ្ឈាន យ៉ាងនេះថា "បានចូលកាន់ទុតិយជ្ឈានផង តតិយជ្ឈានផង" ដូច្នេះ ហើយទ្រង់នាំមកភ្ជាប់នឹងបឋមជ្ឈានទៀត ត្រាស់ឈ្មោះថា ពទ្ធចក្ក ដោយអត្ថដែលពិស្តារនោះឯង ។

លំដាប់នោះ ទ្រង់តបទនីមួយ ៗ ជាប់ដោយឈាន មាន

តតិយជ្ឈានជាដើម តភ្ជាប់បទមួយ ៗ ជាមួយទុតិយជ្ឈាន ហើយទ្រង់នាំមកភ្ជាប់នឹងឈានមានទុតិយជ្ឈានជាដើមទៀត ត្រាស់ពទ្ធចក្ក ២៩ សូម្បីដទៃ ដោយអត្ថដែលពិស្តារនោះ ឱ្យសម្រេចជាឯកមូលកន័យហើយ ។

[២៦៨] មួយទៀត បាលី ព្រះអង្គក៏ទ្រង់សម្តែងទុកដោយសង្ខេប ៗ បាលី នោះ ដែលអ្នកសិក្សាមិនភាន់ច្រឡំ គួរជ្រាបដោយពិស្តារ ។

[២៦៩] សូម្បីទុមូលកន័យជាដើម ព្រះអង្គក៏ត្រាស់ដូចឯកមូលកន័យ ហើយបានត្រាស់ន័យ ៤៣៥ ន័យ ដែលមានមូលគ្រប់យ៉ាងជាទីបំផុត ។ គឺ យ៉ាងណា ? គឺ ត្រាស់ទ្វិមូលកន័យទុក ២៩ ត្រាស់តិមូលកន័យទុក ២៨ ត្រាស់ចតុមូលកន័យទុក ២៧ ។ សូម្បីបញ្ចមូលកន័យជាដើម អ្នកសិក្សាក៏គួរបន្ថយចុះមួយន័យ ៗ ហើយជ្រាបដរាបដល់តឹសម្ពូលកន័យយ៉ាងនេះ ។ តែក្នុងបាលី លោកសង្ខេបសូម្បីឈ្មោះរបស់ន័យទាំងនោះចូលហើយ សម្តែងចំពោះតឹសម្ពូលកន័យតែមួយថា នេះជាសព្វមូលកន័យ ។ ក៏ព្រោះភិក្ខុមិនតបទសុញ្ញាគារចូលទឹងឈាន, (អាបត្តិ) ទើបមិនដល់ទីបំផុត; ហេតុនោះ ការប្រកបសេចក្តីក្នុងបទទាំងពួង មានបទថា ដោះចិត្តចាកមោហៈជាទីបំផុតនុ៎ះឯង គប្បីជ្រាបថា លោកសម្តែងហើយ ព្រោះមិនប៉ះពាល់បទសុញ្ញាគារនោះ ។ ក៏ឯក្នុង

សុទ្ធិកមហាវារផ្នែកមួយដែលព្រះឧបាលីពោលទុក ដោយអំណាចការសម្តែងសេចក្តីនេះថា កាលភិក្ខុតក្តី មិនតក្តី នូវបឋមជ្ឈានជាដើម និងទុតិយជ្ឈានជាដើមតាមលំដាប់ក្តី ខុសលំដាប់ក្តី អួតដោយន័យថា "យើងចូលហើយ" ជាដើម យ៉ាងនេះ ការរួចផុត រមែងមិនមាន រមែងត្រូវបារាជិកពិតតែម្តង ។ នេះជាការពណ៌នាសេចក្តីដោយសង្ខេប ។

[២៧០] បទថា **តីហាការេហិ** : **ដោយអាការ ៣** គឺ ដោយហេតុ ៣ យ៉ាង ដែលជាអង្គនៃសម្បជានមុសាវាទ ។

ពាក្យថា **បុព្វេ វស្ស ហោតិ** : **មុនទីងនិយាយ** សេចក្តីថា ក្នុងចំណែកខាងដើមតែម្តង បុគ្គលនោះ រមែងមានគំនិតយ៉ាងនេះថា "យើងនឹងពោលកុហក" ។

ពាក្យថា **ភណន្តស្ស ហោតិ** : **កំពុងនិយាយ** សេចក្តីថា បុគ្គលនោះកំពុងពោល រមែងមានសេចក្តីដឹងយ៉ាងនេះថា "យើងកំពុងពោលកុហក" ។

ពាក្យថា **ភណិតស្ស ហោតិ** : **និយាយរួចហើយ** សេចក្តីថា កាលពោលពាក្យកុហកហើយ បុគ្គលនោះ រមែងមានសេចក្តីដឹងយ៉ាងនេះថា "យើងពោលពាក្យកុហកហើយ" ។ អធិប្បាយថា កាលលោកពោលពាក្យដែលគប្បីពោលនោះហើយ រមែងមានសេចក្តីដឹងយ៉ាងនេះ ។

ម្យ៉ាងទៀត បទថា ភណិតស្ស សេចក្តីថា សេចក្តីដឹងយ៉ាងនោះ រមែងមានដល់បុគ្គលនោះ អ្នកមានពាក្យនិយាយដែលនិយាយហើយ គឺមានពាក្យនិយាយសម្រេចហើយ ។ ក្នុងអដ្ឋនៃសម្បជានមុសាវាទនេះ លោកសម្តែងអត្ថទុកដូច្នេះថា ភិក្ខុណា សូម្បីក្នុងខាងដើមក៏ដឹងយ៉ាងនេះ, សូម្បីកំពុងពោលក៏ដឹង, សូម្បីក្នុងកាលជាខាងក្រោយក៏ដឹង ថា "យើងពោលកុហកហើយ" ភិក្ខុនោះកាលពោលថា "យើងចូលបឋមជ្ឈាន" ដូច្នេះ រមែងត្រូវបារាជិក ។ សូម្បីលោកសម្តែងអត្ថទុកហើយក៏ពិត, តែក្នុងអដ្ឋនៃសម្បជានមុសាវាទនេះ នៅមានសេចក្តីប្លែកគ្នា ដូច្នេះ ៖

មានពាក្យសួរមុនថា ខាងដើមថា "យើងនឹងនិយាយមុសា" មាន ។ ឯខាងក្រោយថា "យើងនិយាយមុសាហើយ" មិនមាន, ពិតមែន អ្នកខ្លះ រមែងភ្លេចពាក្យ ដែលល្មមនិយាយចេញទៅតែម្តង, ភិក្ខុនោះ នឹងជាបារាជិក ឬមិនជាបារាជិក ?

ពាក្យសួរនោះ លោកឆ្លើយទុកហើយក្នុងអដ្ឋកថាទាំងឡាយ យ៉ាងនេះថា ភិក្ខុគិតថា "អញនឹងនិយាយកុហក" ក្នុងកាលខាងដើម, និងកាលកំពុងនិយាយក៏ដឹងថា "អញកំពុងនិយាយកុហក", ការមិនដឹងថា "អញនិយាយកុហករួចហើយ" ក្នុងកាលខាងក្រោយ មិនអាចថា នឹងមិនមាន, សូម្បីបើនឹងមិនមាន, ក៏នៅតែជាបារាជិកដូចគ្នា ។ ព្រោះអង្គ ២

ខាងដើមនុ៎ះឯងជាសំខាន់ ។ សួម្បីភិក្ខុណា ក្នុងកាលខាងដើម មិនមានសេចក្តីតាំងចិត្តថា "អញនឹងនិយាយកុហក" តែកាលពោល ក៏ដឹងថា "អញកំពុងនិយាយកុហក", សួម្បីកាលពោលហើយ ក៏ដឹងថា "អញនិយាយកុហករួចហើយ" ភិក្ខុនោះ ព្រះវិន័យធរមិនគប្បីពិន័យអាបត្តិ ។ ព្រោះចំណែកខាងដើមសំខាន់ជាង, កាលខាងដើមនោះមិនមាន រមែងជាការនិយាយញាប់មាត់ ឬនិយាយភ្លាត់ទៅក៏បាន ដូច្នេះឯង ។

ក៏ឯក្នុងពាក្យថា មុសា ភាណិស្សំ : អញនឹងនិយាយកុហក ជាដើមនេះ គួរលះសេចក្តីមានសេចក្តីដឹងយ៉ាងនោះ និងសេចក្តីប្រជុំព្រមនៃសេចក្តីដឹងចេញ ។

ពាក្យថា គួរលះសេចក្តីមានសេចក្តីដឹងយ៉ាងនោះចេញ បានដល់គប្បីលះសេចក្តីមាន សេចក្តីដឹងយ៉ាងនោះថា រមែងដឹងបានក្នុង៣ ខណៈ ដោយចិត្តតែមួយប៉ុណ្ណោះ យ៉ាងនេះថា ភិក្ខុដឹងថា "យើងនឹងពោលកុហក" ដូច្នេះ ដោយចិត្តណា រមែងដឹងថា "យើងកំពុងពោលកុហក" និងថា "យើងពោលកុហកហើយ" ដូច្នេះ ដោយចិត្តនោះឯង ។ ពិតមែន អ្នកណា ៗ មិនអាចនឹងដឹងចិត្តដោយចិត្តនោះឯងបាន ដូចបុគ្គលមិនអាចយកដាវមុតនោះកាត់មុខដាវនោះឯងបាន ដូច្នោះឯង ។ ក៏ចិត្តដែលកើតឡើងមុន ៗ ជាបច្ច័យនៃសេចក្តីកើតឡើងយ៉ាងនោះ របស់ចិត្ត

ក្រោយ ៗ ហើយ រមែងរលត់ទៅ ។ ដោយហេតុនោះ បណ្ឌិតទើបពោលពាក្យនេះទុកថា ចំណែកខាងដើមប៉ុណ្ណោះ ជាប្រមាណ, កាលចំណែកខាងដើមនោះមាន ពាក្យថា ពីរបទដ៏សេស ទឹងមិនមាន ដូច្នេះនោះ រមែងមិនមាន; ព្រោះដូច្នោះ វាចា ទើបឈ្មោះថា មានអង្គ ៣ ។ ពាក្យថា គួរលះសេចក្តីប្រជុំព្រមនៃសេចក្តីដឹង សេចក្តីថា ចិត្ត ៣ ដួងទាំងនេះ មិនគួរកាន់យកថា កើតឡើងក្នុងខណៈតែមួយ ។ ពិតមែនធម្មតាចិត្តនេះ រមែងប្រាកដដូចជាចិត្តតែមួយ ព្រោះកើតឡើងជាប់តគ្នាកាលចិត្តដំបូងមិនទាន់រលត់ចិត្តក្រោយក៏មិនទាន់កើតឡើង ដូច្នេះឯង ។

ក៏ឯខ្ញុំព្រះករុណានឹងពោលពាក្យ ដែលបន្ទាប់ពីនេះតទៅ ៖

បុគ្គលណា រមែងពោលសម្បជានមុសាវាទថា "ខ្ញុំព្រះករុណាចូលបឋមជ្ឈាន" បុគ្គលនោះ រមែងជាអ្នកមានការឃើញយ៉ាងនេះថា "បឋមជ្ឈានរបស់យើងរមែងមិនមាន", ពិតមែន លទ្ធិនេះ របស់បុគ្គលនោះ មានពិត, មួយទៀត លទ្ធិយ៉ាងនេះថា "បឋមជ្ឈានរបស់យើងរមែងមិនមាន" ដូច្នេះ រមែងពេញចិត្ត និងគប់ចិត្តដល់បុគ្គលនោះ, និងបុគ្គលនោះ មានចិត្តមានសភាពយ៉ាងនេះ ថា "បឋមជ្ឈានរបស់យើងរមែងមិនមាន", និងក្នុងកាលណា ខ្លួនជាអ្នកប្រាថ្នានឹងពោលកុហក, ក្នុងកាលនោះបុគ្គលនោះលះ គឺ ចោល បិទបាំងសេចក្តីឃើញនោះ, ឬបិទ

បាំងសេចក្ដីឃើញព្រមដោយសេចក្ដីគាប់ចិត្ត, ឬបិទបាំងសេចក្ដីឃើញ សេចក្ដីគាប់ចិត្តមួយអន្លើដោយសេចក្ដីពេញចិត្ត, ឬបិទបាំងសេចក្ដីឃើញ សេចក្ដីគាប់ចិត្តសេចក្ដីពេញចិត្តមួយអន្លើដោយសេចក្ដីពិតត្រង់, ហើយពោលធ្វើឱ្យជាពាក្យកុហក; ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យថា ចតូហិ អាការេហិ ជាដើម ដើម្បីសម្ដែងសេចក្ដីផ្សេងនៃអង្គដោយអំណាចការឃើញជាដើមសូម្បីទាំងនោះ ។ ក៏ព្រោះក្នុងគម្ពីរបរិវារលោកពោលថា មុសាវាទមានអង្គ ៨ ក្នុងអធិការនេះ ទើបគួរប្រកបន័យនីមួយថា អដ្ឋហាការេហិ ជាន័យមួយទៀតផ្សំនឹងសញ្ញាដែលលោកប្រាថ្នា ក្នុងគម្ពីរបរិវារនោះ ។

ក៏ឯបណ្ដាបទទាំងនេះ បទថា **វិនិធាយ ទិដ្ឋឹ : បិទបាំងសេចក្ដីឃើញ** ត្រាស់ដោយអំណាចការលះធម៌ដែលមានកម្លាំងចេញ ។

បទថា **វិនិធាយ ខន្តឹ : បិទបាំងសេចក្ដីគាប់ចិត្ត** ត្រាស់ដោយអំណាចការលះធម៌ដែលមានកម្លាំងខ្សោយ និងតិចជាងធម៌ដែលមានកម្លាំងនោះ ។

បទថា **វិនិធាយ សញ្ញំ : បិទបាំងសញ្ញា** នេះ ឈ្មោះថា សូម្បីត្រឹមតែជាសញ្ញា ដែលប្រព្រឹត្តទៅដោយអំណាចការលះធម៌ដែលមានកម្លាំងខ្សោយជាងធម៌ទាំងពួងក្នុងទីនេះ ។

បាន៖ថា មិនលះ ទឹងពោលសម្បជានមុសាវាទនេះ ទឹងមិនមាន ។ ក៏ព្រោះមិនជាបារាជិក ដោយពាក្យដែលជាអនាគតជាដើមថា "ខ្ញុំព្រះករុណានឹងចូល" ហេតុដូច្នោះ បទដែលជាអតីត និងបច្ចុប្បន្នថា "ខ្ញុំព្រះករុណាចូលហើយ" ជាដើមប៉ុណ្ណោះ គប្បីជ្រាបថា ត្រាស់ទុកក្នុងព្រះបាលី ។

[២៧១-៧] ខាងមុខអំពីនេះទៅ ពាក្យសូម្បីទាំងអស់ក្នុងសុទ្ធិកមហាវារនេះ មានសេចក្ដីងាយយល់ទាំងអស់នោះឯង ។ ពិតមែន ក្នុងសុទ្ធិកមហាវារនេះ មិនមានពាក្យដែលមិនអាចដឹងបានដោយវិនិច្ឆ័យនេះ វៀរតែសេចក្ដីនៃបទថា រាគោ មេ ចត្តោ វន្តោ : រាគៈអាត្មាអញបានកំចាត់ចេញហើយ ជាដើម ក្នុងបទភាជនៈនៃបទថា ការលះកិលេស ។ សេចក្ដីនេះ ខ្ញុំព្រះករុណានឹងពោលតទៅ ៖

ក៏បណ្ដាបទទាំងនេះ បទថា ចត្តោ : បានកម្ចាត់បង់ហើយ នេះ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចការលះបង់ភាវៈនៃខ្លួន ។

បទថា វន្តោ : បានខ្ជាក់ចោលហើយ នេះ ត្រាស់ដោយអំណាចសម្ដែងភាវៈដែលរាគៈកាន់យកទៀតមិនបាន ។

បទថា មុត្តោ : បានឱ្យផុតហើយ នេះ ត្រាស់ដោយអំណាចនៃការផុតអំពីសន្តតិ ។

បទថា បហីនោ : បានបន្សាត់ចេញហើយ នេះ ត្រាស់ដោយអំណាចនៃការសម្តែងនូវការតាំងចុះមិនបាន ក្នុងទីណា ៗ សូម្បីនៃរាគៈដែលរួចផុតទៅហើយ ។

បទថា បដិនិស្សដ្ឋោ : បានលោសបោលហើយ នេះ ត្រាស់ដោយអំណាចនៃការសម្តែងនូវការលះបង់រាគៈដែលធ្លាប់ប្រកាន់ទុកក្នុងកាលមុនចេញ ។

បទថា ឧក្កេដិតោ : បានគាស់រំលើងហើយ នេះ ត្រាស់ទុកដោយអំណាចនៃការសម្តែងនូវការដែលត្រឡប់ចូលមកកៀកជិតមិនបានទៀត ព្រោះត្រូវអរិយមគ្គដកឡើងចេញហើយ ។ សេចក្តីនេះ អ្នកសិក្សាទាំងឡាយគប្បីពិនិត្យមើលអំពីគម្ពីរសព្ទសាស្រ្ត ។

បទថា សមុក្កេដិតោ : បានរើចោលហើយ នេះ ត្រាស់ទុកដោយអំណាចសម្តែងភាវៈដែលត្រឡប់អែបជិតមិនបានទៀត សូម្បីនៃរាគៈដែលសហាគតត្រឹមតែបន្តិចបន្តួច ព្រោះដកឡើងដាច់ខាតដោយប្រការដូច្នេះ ។

សុទ្ធិកវារកថា ចប់

## វុត្តកាមវារកថា

[២៧៨] សេចក្តីនៃបទថា តីហាការេហិ ជាដើម និងប្រភេទនៃវារបេយ្យាលទាំងពួង សូម្បីក្នុងវុត្តកាមវារ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងសុទ្ធិកវារនេះឯង, ក៏វុត្តកាមវារនេះព្រះមានព្រះភាគត្រាស់ទុកដើម្បីបិទឱកាសរបស់បាបបុគ្គលទាំងឡាយតែម្យ៉ាង អ្នកស្វែងរកឱកាសយ៉ាងនេះថា "ពាក្យនេះ ណាហ្ន៎ យើងប្រាថ្នានឹងពោលពាក្យដទៃ ពោលខុសជាពាក្យដទៃ; ព្រោះដូច្នោះ អាបត្តិទើបមិនមានដល់យើង" ។ ដូចថា ភិក្ខុប្រាថ្នានឹងពោលថា ពុទ្ធំ បច្ចក្ខាមិ កាលពោលបទណាមួយក្នុងបណ្តាបទសម្រាប់ពោលលាសិក្ខា មានជាដើមថា ធម្មំ បច្ចក្ខាមិ រមែងជាអ្នកពោលលាសិក្ខាហើយពិត ព្រោះបទទាំងនោះឈានចុះក្នុងខេត្តយ៉ាងណាហើយ, ប្រការនេះក៏យ៉ាងនោះដែរ ភិក្ខុដែលប្រាថ្នានឹងពោលតែបទណាមួយ បណ្តាបទឧត្តរិមនុស្សធម៌មានបឋមជ្ឈានជាដើម សូម្បីកាលពោលបទណាមួយយ៉ាងដទៃក្រៅពីបទនោះ រមែងជាបារាជិកដូចគ្នា ព្រោះបទនោះឈានចុះក្នុងខេត្ត ។ សូម្បីបើលោកពោលដល់អ្នកណា, អ្នកនោះ រមែងដឹងសេចក្តីនោះក្នុងខណៈនោះភ្លាម ។ ក៏ឯលក្ខណៈនៃការដឹងក្នុងការអួតឧត្តរិមនុស្សធម្មដែលមិនមានពិតនេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងការពោលលាសិក្ខានោះឯង ។ តែសេចក្តីប្លែកគ្នា

មានដូចតទៅនេះ ៖

ការពោលលាសិក្ខា រមែងមិនដល់សេចក្ដីសម្រេចដោយហត្ថមុទ្ទា (មិនសម្រេចបានដោយអាការផ្ទាត់មេដៃ) ការអួតឧត្តរិមនុស្សធម្មដែលមិនមានពិតនេះ រមែងឈានចុះ (កាន់សេចក្ដីសម្រេច) សូម្បីដោយហត្ថមុទ្ទា ។ ពិតមែន ភិក្ខុណាអួតឧត្តរិមនុស្សធម្មដែលមិនមានពិតដោយការកម្រើកនៃអវយវៈតូចធំ មានការវាសដៃជាដើម ដល់បុគ្គលអ្នកឈរនៅក្នុងគន្លងនៃវិញ្ញត្តិ សូម្បីបុគ្គលនោះដឹងសេចក្ដីនោះបាន, ភិក្ខុនោះ ជាបារាជិកពិត ។ តែបើលោកប្រាប់ដល់អ្នកណា, អ្នកនោះមិនយល់ ឬដល់សេចក្ដីសង្ស័យថា "ភិក្ខុនេះ និយាយអ្វី ?" ឬពិចារណាយូរទើបដឹងក្នុងកាលជាខាងក្រោយ រមែងដល់ការរាប់ថា អ្នកមិនយល់ភ្លាមដូចគ្នា ។ កាលភិក្ខុប្រាប់ដល់បុគ្គលដែលមិនយល់ភ្លាមយ៉ាងនោះ ជាថុល្លច្ច័យ ។ ចំណែកបុគ្គលណាមិនស្គាល់ឧត្តរិមនុស្សធម្មមានឈានជាដើម ដោយខ្លួនឯងដោយអំណាចការបានសម្រេច ឬដោយអំណាចការរៀន និងការសាកសួរជាដើម បានឮត្រឹមតែពាក្យថា ឈាន ឬថា វិមោក្ខ តែម្យ៉ាងប៉ុណ្ណោះ, សូម្បីបុគ្គលនោះ កាលភិក្ខុនោះប្រាប់ហើយ បើដឹងបានសូម្បីត្រឹមតែប៉ុណ្ណោះថា "បានឮថា ភិក្ខុនេះពោលថា យើងចូលឈានហើយ" ដូច្នេះ រមែងដល់ការរាប់ថា ដឹង ដូចគ្នា, កាលភិក្ខុ

ប្រាប់ដល់បុគ្គលនោះ ជាបារាជិកពិត ។ សេចក្តីប្លែកគ្នា ដោយអំណាចបុគ្គលតែម្នាក់ ពីរនាក់ ឬច្រើននាក់ ដែលភិក្ខុកំណត់ទុក ឬមិនបានកំណត់ទុកសូម្បីទាំងអស់នោះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងកថាពោលអំពីការពោលលាសិក្ខានោះឯង ដោយប្រការដូច្នេះ ។

វត្ថុកាមវារកថា ចប់

## បច្ចយប្បដិសំយុត្តវារកថា

[២៧៩] សូម្បីក្នុងវារៈការអួតជាប់ដោយបច្ច័យ គប្បីជ្រាបប្រភេទនៃវារបេយ្យាលទាំងអស់ និងអត្ថនៃបទដែលមកហើយខាងដើមដោយន័យដែលពោលហើយនុ៎ះឯង ហើយជ្រាបលំដាប់ព្រះបាលី យ៉ាងនេះមុន ។ ក៏ក្នុងបច្ចយប្បដិសំយុត្តវារនេះ លោកពោលវារៈកំណត់ដោយបឋមមាតិកា ៥ ទាំងនេះថា

១. ភិក្ខុណា នៅក្នុងវិហាររបស់លោក
២. ភិក្ខុណា បរិភោគចីវររបស់លោក
៣. ភិក្ខុណា ឆាន់បិណ្ឌបាតរបស់លោក
៤. ភិក្ខុណា ប្រើប្រាស់សេនាសនៈរបស់លោក

៥. ភិក្ខុណា បរិភោគគិលានបច្ចយភេសជ្ជបរិក្ខាររបស់លោក ដូច្នេះ ពោលវារកំណត់ដោយតតិយាវិភត្តិ ៥ មានថា "វិហាររបស់លោក ដែលភិក្ខុណាប្រើប្រាស់ហើយ" ជាដើម, ពោលវារកំណត់ដោយទុតិយាវិភត្តិ ៥ មានថា "លោកអាស្រ័យភិក្ខុណាទើបបានថ្វាយវិហារ" ដូច្នេះ ជាដើមគប្បីជ្រាបក្នុងប្រភេទនៃវារបេយ្យាល គ្រប់បទ មានបឋមជ្ឈានជាដើម ដែលលោកពោលទុកក្នុងខាងដើមព្រមទាំងបទសុញ្ញាគារដែលពោលហើយក្នុងបច្ចយប្បដិសំយុត្តវារនេះ ដោយអំណាចនៃវារទាំងនោះ ។

[២៨០] ក្នុងបច្ចយប្បដិសំយុត្តវារនេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះថា ក៏ព្រោះភិក្ខុពោលដោយអមយ៉ាងនេះថា "ភិក្ខុណា នៅក្នុងវិហាររបស់អ្នក", "វិហាររបស់អ្នក ដែលភិក្ខុណានៅហើយ", "អ្នកអាស្រ័យភិក្ខុណា ទើបបានថ្វាយវិហារ", និងព្រោះលោកមិនបានពោលថា "យើង" ក្នុងបច្ចយប្បដិសំយុត្តវារនេះ សូម្បីកាលពោលអួតឧត្តរិមនុស្សធម្ម ដល់បុគ្គលដែលយល់ភ្លាម ទើបជាថុល្លច្ច័យ ពោលអួត ដល់បុគ្គលដែលមិនយល់ភ្លាម ទើបជាទុក្កដ ។

បច្ចយប្បដិសំយុត្តវារកថា ចប់

[២៨១] ព្រះមានព្រះភាគទ្រង់សម្តែងប្រភេទនៃអាបត្តិ ដោយអំណាចសេចក្តីពិស្តារយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងអនាបត្តិ ទើបត្រាស់ពាក្យថា **អនាបត្តិ អធិមានេន** ជាដើម ។

បណ្តាបទទាំងនោះ បទថា **អធិមានេន** : **ភិក្ខុនិយាយស្មានថាខ្លួនបានមគ្គផល** មានសេចក្តីថា មិនជាអាបត្តិដល់ភិក្ខុដែលអួត ដោយសម្គាល់ថា ខ្លួនបានសម្រេច ។

បទថា **អនុល្លបនាធិប្បាយស្ស** : **ភិក្ខុនិយាយអំពីមគ្គផលដោយឥតមានប្រាថ្នានឹងពោលអួតកុហក** មានសេចក្តីថា មិនជាអាបត្តិដល់ភិក្ខុដែលមិនបានតាំងនៅក្នុងឥច្ឆាចារ ដោយភាពជាអ្នកបញ្ឆោតល្បួងលោម មិនប្រាថ្នានឹងអួត ព្យាករណ៍ព្រះអរហត្តផល ក្នុងសំណាក់របស់សព្រហ្មចារីទាំងឡាយ ។ ភិក្ខុឆ្កួតជាដើម មានន័យដូចពោលហើយក្នុងខាងដើមនោះឯង ។ មួយទៀត ពួកភិក្ខុដែលចាំវស្សាជិតមាត់ស្ទឹងវគ្គមុទា ជាដើមបញ្ញត្តិក្នុងសិក្ខាបទនេះ, មិនជាអាបត្តិដល់លោកទាំងនោះដូច្នេះឯង ។

បទភាជនីយវណ្ណនា ចប់

## សមុដ្ឋានជាដើម

ក្នុងសមុដ្ឋានជាដើម មានវិនិច្ឆ័យដូច្នេះ ៖

សិក្ខាបទនេះ មានសមុដ្ឋាន ៣ គឺកើតអំពីកាយចិត្ត របស់ភិក្ខុអ្នកអួតដោយកម្រើកដៃ ១ កើតអំពីវាចាចិត្ត របស់ភិក្ខុដែលអួតដោយការបញ្ចេញវាចា ១ កើតអំពីកាយវាចាចិត្ត របស់ភិក្ខុដែលធ្វើទាំង ២ យ៉ាង ១ ជាកិរិយា ជាសញ្ញាវិមោក្ខ ជាសចិត្តកៈ ជាលោកវជ្ជៈ ជាកាយកម្មវចីកម្ម ជាអកុសលចិត្ត មានវេទនា ៣ ។ ពិតមែន ភិក្ខុរមែងពោលអួតទាំងដែលមានសោមនស្សរីករាយក៏មាន ភ័យខ្លាចអួតក៏មាន មានភាពជាកណ្តាលអួតក៏មាន ។

## រឿងសម្គាល់ថា បានសម្រេច

[២៨៣] រឿងទី ១ ភិក្ខុនឹកស្មានថា ខ្លួនបានសម្រេច ក្នុងវិនីតវត្ថុទាំងឡាយ មានន័យដូចពោលហើយ ក្នុងអនុប្បញ្ញត្តិនុ៎ះឯង ។

[២៨៤] ក្នុងរឿងទី ២ ភិក្ខុនៅក្នុងព្រៃ មានវិនិច្ឆ័យដូច្នេះ ៖

បទថា បណិធាយ ៖ ដោយតាំងចិត្ត បានដល់ ធ្វើសេចក្តីប្រាថ្នាទុក ។

ពាក្យថា ឯវំ មំ ជនោ សម្ភាវេស្សតិ ៖ យ៉ាងនេះ អ្នកផងគង់

នឹងសរសើរអញ មានសេចក្តីថា (ភិក្ខុណាមួយ នៅក្នុងព្រៃដោយតាំងចិត្តថា) “ជននឹងសរសើរយើងដែលជាអ្នកនៅក្នុងព្រៃ ក្នុងភាពជាព្រះអរហន្ត ឬក្នុងភូមិនៃព្រះសេក្ខៈ ដោយវិធីយ៉ាងនេះ, តពីកាលនោះទៅ យើងនឹងជាអ្នកដែលជននោះធ្វើសក្ការៈ គោរព រាប់អាន បូជា” ។

ពីរបទថា **អាបត្តិ ទុក្កដស្ស** : ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ សេចក្តីថា កាលលោក ដើរទៅដោយតាំងចិត្តយ៉ាងនេះថា “យើងនឹងនៅក្នុងព្រៃ” ជាទុក្កដ គ្រប់ជំហាន ។ ក្នុងកិច្ចទាំងពួង មានការសាងកុដិ ដើរបង្ក្រម អង្គុយ និងស្លៀកដណ្តប់ជាដើមក្នុងព្រៃ ជាទុក្កដ គ្រប់ប្រយោគ យ៉ាងនោះ ។ ព្រោះហេតុនោះ ភិក្ខុមិនគួរនៅក្នុងព្រៃ ដោយការតាំងចិត្តយ៉ាងនោះ ។ ពិតមែន កាលនៅដោយសេចក្តីតាំងចិត្តយ៉ាងនោះ នឹងបានទទួលសេចក្តីលើកតម្កើង ឬមិនបានក៏ដោយ រមែងត្រូវទុក្កដ ។ ចំណែកភិក្ខុណា សមាទានធុតង្គហើយ គិតថា “យើងនឹងរក្សាធុតង្គ” ឬថា “កាលយើងសម្រាកនៅក្នុងស្រុក ចិត្តរមែងរវើរវាយ, ព្រៃជាទីសប្បាយ” ដូច្នេះ ទើបជាអ្នកមានសេចក្តីប្រាថ្នានឹងនៅព្រៃដែលមិនមានទោស ដោយធ្វើសេចក្តីប្រាថ្នាយ៉ាងនេះថា “យើងនឹងសម្រេចបណ្តាវិវេកទាំង ៣ យ៉ាងណាមួយក្នុងព្រៃពិតប្រាកដ” ដូច្នេះក្តី ថា “យើងចូលទៅកាន់ព្រៃ មិនទាន់សម្រេចជាព្រះអរហន្តហើយ នឹងមិន

ចេញមក” ដូច្នេះក្តី ថា “ឈ្មោះថា ការនៅព្រៃ ព្រះមានព្រះភាគទ្រង់សរសើរនិងកាលយើងសម្រាកក្នុងព្រៃ សព្រហ្មចារីជាច្រើន នឹងលះបោលភូមិស្រុកហើយនៅព្រៃជាវត្ត” ដូច្នេះក្តី; ភិក្ខុនោះ គួរនៅក្នុងព្រៃ ។

ក្នុងរឿងទី ៣ ភិក្ខុទៅបិណ្ឌបាត មានវិនិច្ឆ័យដូច្នេះ ៖

ជាទុក្កដគ្រប់ប្រយោគ ចាប់តាំងអំពីកិច្ច គឺ ការស្លៀកដណ្តប់ដោយតាំងចិត្តថា “យើងនឹងសម្រេចឥរិយាបថ មានការឈានទៅជាដើមត្រាច់បិណ្ឌបាត ដរាបដល់ការឆាន់ជាទីបំផុត”, លោកនឹងបានទទួលសេចក្តីសរសើរក៏ដោយ មិនបានក៏ដោយ ជាទុក្កដទាំងអស់នោះឯង តែភិក្ខុដែលចូលទៅបិណ្ឌបាត ដោយឥរិយាបថដែលគួរជ្រះថ្លា មានការឈានទៅមុខនិងថយក្រោយជាដើម ដើម្បីបំពេញខន្ធកវត្តនិងសេក្ខិយវត្តឱ្យបរិបូណ៌, ឬដើម្បីដល់ភាពជាទិដ្ឋានុគតិ ដល់សព្រហ្មចារីទាំងឡាយជាអ្នកដែលវិញ្ញូជនទាំងឡាយមិនគប្បីតិះដៀលនោះឯង ។

[២៨៥] ក្នុងរឿងទី ៤ សទ្ធិវិហារិកនៃឧបជ្ឈាយ៍ មានវិនិច្ឆ័យដូច្នេះ ៖

ព្រោះភិក្ខុមិនបានពោលថា “យើង” ដោយន័យពោលទុកហើយក្នុងពាក្យនេះថា ភិក្ខុណា នៅក្នុងវិហាររបស់លោក ទើបមិនជា

បារាជិក ។ ពិតមែន កាលភិក្ខុអួតឧត្តរិមនុស្សធម្មជាទីបង្អោនចូលមកក្នុងខ្លួនប៉ុណ្ណោះ លោកទើបពិន័យជាបារាជិក ។

[២៨៦] រឿងពួកភិក្ខុតម្កល់ឥរិយាបថ មានពាក្យជាដើមថា **មានភិក្ខុមួយរូបដើរចង្ក្រមដោយតាំងចិត្តថា "កាលបើអញចង្ក្រមយ៉ាងនេះបណ្ដាជននឹងសរសើរអញ"** ដូច្នេះ មានន័យដូចពោលហើយក្នុងកាលមុននោះឯង ។

[២៨៧] ក្នុងរឿងលះសញ្ញោជនៈ មានវិនិច្ឆ័យដូច្នេះ ៖

កាលភិក្ខុពោលថា "សញ្ញោជនៈទាំងឡាយ អាត្មាលះបានហើយ" ក្ដី ថា "សញ្ញោជនៈទាំង ១០ អាត្មាលះបានហើយ"ក្ដី ថា "យើងលះសញ្ញោជនៈមួយបានហើយ" ក្ដី ការលះកិលេសនុ៎ះឯង ក៏ជាការដែលលោកប្រាប់ហើយ; ព្រោះហេតុនោះ ទើបជាបារាជិក ។

[២៨៨] ក្នុងរឿងភិក្ខុនៅក្នុងទីស្ងាត់ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា រហោ ឧល្លបតិ : **នៅក្នុងទីស្ងាត់ ហើយពោលអួត** សេចក្ដីថា ភិក្ខុនៅក្នុងទីកំបាំង និយាយថា យើងជាព្រះអរហន្ត ដូច្នេះ, តែមិនបានធ្វើការគិតដោយចិត្តឡើយ; ព្រោះហេតុនោះ ក្នុងរឿងនេះលោកទើបពិន័យជាទុក្កដ ។

[២៨៩] រឿងភិក្ខុនៅក្នុងវត្ត និងរឿងភិក្ខុដែលឧបាសកផ្គត់ផ្គង់

មានន័យដូចពោលហើយនោះឯង ។

[២៩០] ក្នុងរឿងភិក្ខុអួតអរហត្តផលថា **មិនមែនក្រឡើយ** មានវិនិច្ឆ័យដូច្នេះ ; លទ្ធិរបស់ភិក្ខុនោះ មានដូច្នេះថា ព្រះអរិយបុគ្គលទាំងឡាយ ជាសាវករបស់ព្រះមានព្រះភាគ (គប្បីនិយាយយ៉ាងនោះ) ។ ព្រោះហេតុនោះ លោកទើបពោលថា "ភិក្ខុទាំងឡាយឯណា ដែលជាសាវករបស់ព្រះមានព្រះភាគ លោកអម្បាលនោះ ទើបគួរពោលយ៉ាងនេះ" ។ ក៏ឯសេចក្តីប្រាថ្នារបស់លោក មានដូច្នេះថា ការដែលភិក្ខុមានសីលចម្រើនវិបស្សនា ព្យាករណ៍ព្រះអរហត្តផលធ្វើបានមិនលំបាកឡើយ, លោកអាចសម្រេចព្រះអរហត្តបាន, ព្រោះហេតុនោះ ភិក្ខុនោះទើបក្រាបទូលថា "បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនមានបំណងនឹងពោលអួត" ។

ក្នុងរឿងភិក្ខុមានសេចក្តីព្យាយាម មានវិនិច្ឆ័យដូច្នេះ ៖

បទថា **អារាធនីយោ : រមែងញុំាងធម៌ឱ្យប្រោសប្រាណបាន** សេចក្តីថា អាចដើម្បីញុំាងធម៌ឱ្យសម្រេចផលបាន គឺ ញុំាងខ្លួនឱ្យសម្រេចបាន ។ សេចក្តីថា ដើម្បីឱ្យកើតបាន ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។

ក្នុងរឿងភិក្ខុខ្លាចស្លាប់ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនោះ អាស្រ័យអំណាចនៃប្រយោជន៍នេះថា លោកអ្នកមានសេចក្តីក្តៅក្រហាយចិត្តកើតឡើង ត្រូវខ្លាចពិត, តែសីលរបស់យើងបរិសុទ្ធិ មិនជាទីតាំងនៃការក្តៅក្រហាយចិត្តឡើយ ។ "យើងនោះនឹងត្រូវខ្លាចចំពោះសេចក្តីស្លាប់ធ្វើអ្វី" ដូច្នេះ ទើបឆ្លើយថា "ម្នាលអាវុសោទាំងឡាយ ខ្ញុំព្រះករុណា មិនខ្លាចសេចក្តីស្លាប់ទេ" ។ ព្រោះហេតុនោះ ទើបមិនមានអាបត្តិដល់ភិក្ខុនោះ ។ សូម្បីក្នុងរឿងភិក្ខុក្តៅក្រហាយស្តាយក្រោយ ទើបត្រូវខ្លាចស្លាប់ ក៏មានន័យដូចគ្នានេះ ។ បន្ទាប់ពីរឿងភិក្ខុក្តៅក្រហាយស្តាយក្រោយ ទើបត្រូវខ្លាចស្លាប់នោះទៅ រឿងភិក្ខុព្យាយាមញ៉ាំងព្រះធម៌ឱ្យប្រោសប្រាណបាន ៣ រូប ដូចគ្នានឹងរឿងមុននោះឯង ។

បណ្តារឿងវេទនាទាំងឡាយ គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងទីមួយជាមុន ៖

ភិក្ខុនោះតាំងនៅក្នុងអធិវាសនខន្តិ ដោយកម្លាំងនៃការពិចារណា ទើបឆ្លើយថា "ម្នាលអាវុសោទាំងឡាយ បុគ្គលក្រៅការ មិនអាចនឹងអត់ធន់បានឡើយ" ។ ព្រោះ ហេតុនោះ ទើបមិនមានអាបត្តិដល់លោក ។ ចំណែកក្នុងរឿងទី ២ ជាថុល្លច្ច័យ ព្រោះភិក្ខុនោះ មិនបានធ្វើការអួត

ឧត្តរិមនុស្សធម្មជាទីបង្អោនចូលមកក្នុងខ្លួន ពោលដោយអមថា "ម្នាលអាវុសោទាំងឡាយ បុគ្គលជាបុថុជ្ជនមិនអាចនឹងអត់ធន់បានឡើយ" ។

[២៩១] ក្នុងរឿងព្រាហ្មណ៍ទាំងឡាយ មានវិនិច្ឆ័យដូច្នេះ ៖

បានឮថា ព្រាហ្មណ៍នោះ បានពោលថា "និមន្តព្រះអរហន្តទាំងឡាយ ចូរមកចុះ" ដូច្នេះតែម៉្យាង ក៏ទេ, (តាមការពិត) ពាក្យនិយាយទាំងអស់ដែលថ្លែងចេញរបស់ព្រាហ្មណ៍នោះ ប្រកបដោយវាទៈថាអរហន្តទាំងឡាយ ដូច្នេះថា "លោកទាំងឡាយ ចូរក្រាលអាសនៈ ចូរប្រគេនទឹកលាងជើងដល់ព្រះអរហន្តទាំងឡាយ, សូមព្រះអរហន្តទាំងឡាយ ចូរលាងជើងចុះ" ។ ក៏ពាក្យនិយាយនោះរបស់ព្រាហ្មណ៍នោះ ជាការពោលដោយសេចក្ដីជ្រះថ្លា គឺជាពាក្យពោលរបស់ព្រាហ្មណ៍ អ្នកត្រូវកម្លាំងសទ្ធារបស់ខ្លួនឱ្យខ្នះខ្នែងហើយ ព្រោះភាពជាអ្នកមានសទ្ធាចរិត ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ពោលដោយសេចក្ដីជ្រះថ្លា មិនត្រូវអាបត្តិទេ" ។ កាលភិក្ខុដែលត្រូវគេពោលយ៉ាងនោះ មិនគួរជាអ្នករីករាយត្រេកអរ បរិភោគបច្ច័យទាំងឡាយឡើយ ។ គួរធ្វើសេចក្ដីព្យាយាម ដោយគិតយ៉ាងនេះថា "យើងនឹងបំពេញការបដិបត្តិ ដែលនឹងញ៉ាំងខ្លួនឱ្យដល់ព្រះអរហត្ត" ដូច្នេះឯង ។

រឿងព្យាករណ៍អរហត្តផល ដូចគ្នានឹងរឿងលះសញ្ញោជនៈនុ៎ះឯង ។

[២៩៣] ក្នុងរឿងគ្រប់គ្រងផ្ទះ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនោះ បានពោលថា "ម្នាលអាវុសោទាំងឡាយ បុគ្គលដូចជាអាត្មា មិនគួរដើម្បីនឹងនៅគ្រប់គ្រងផ្ទះទេ" ដូច្នេះ ព្រោះលោកមិនមានសេចក្តីត្រូវការ មិនមានសេចក្តីអាល័យក្នុងភាពជាគ្រហស្ថ ។ មិនបានពោលដោយសេចក្តីប្រាថ្នានឹងអួតទេ; ព្រោះហេតុនោះ ទើបមិនជាអាបត្តិដល់លោក ។

ក្នុងរឿងហាមកាម មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនោះ ជាអ្នកអស់សេចក្តីអាល័យក្នុងវត្ថុកាមនិងកិលេសកាម ព្រោះសម្លឹងឃើញទោស ដែលជាលោកិយនុ៎ះឯង; ព្រោះដូច្នោះ លោកទើបពោលថា "ម្នាលអ្នកមានអាយុទាំងឡាយ ឯកាមទាំងឡាយ អាត្មាឃាត់រាំងបានហើយ" ដូច្នេះ; ព្រោះហេតុនោះ ទើបមិនជាអាបត្តិដល់លោក ។

ក៏ពាក្យថា អាវដា ក្នុងពាក្យថា អាវដា មេ : **អាត្មាឃាត់រាំងបានហើយ** នេះ មានសេចក្តីថា ខ្ញុំការពារបានហើយ គឺ ហាមឃាត់ហើយ បដិសេធហើយ ។

ក្នុងរឿងសេចក្ដីអភិរម្យ មានវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុនោះពោលថា "ម្នាលអ្នកមានអាយុទាំងឡាយ អាត្មាត្រេកអរសប្បាយដែរ (តែត្រេកអរសប្បាយ) ដោយសេចក្ដីសប្បាយដ៏ឧត្ដម" ។ ដូច្នេះ ព្រោះលោកជាអ្នកមិនអផ្សុក និងព្រោះនៅមានសេចក្ដីត្រេកអរក្នុងឧទ្ទេស និងបុច្ឆាជាដើម ក្នុងសាសនា មិនបានពោលដោយសេចក្ដីប្រាថ្នានឹងអួតទេ; ព្រោះហេតុនោះ ទើបមិនជាអាបត្តិដល់លោក ។

## រឿងតាំងកតិកាចៀសចេញទៅ

[២៩៤] ក្នុងរឿងចៀសចេញទៅ មានវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា **យោ ឥមម្ហា អាវាសា បឋមំ បក្កមិស្សតិ : ភិក្ខុអង្គណា នឹងចេញចាកអាវាសនេះមុនគេ** មានអធិប្បាយថា កាលសង្ឃកំណត់អាវាស មណ្ឌលសីមា ឬស្ថានទីណាមួយ ហើយតាំងកតិកាទុកភិក្ខុណាចៀសចេញពីស្ថានទីនោះមុន ដោយគិតថា "ភិក្ខុទាំងឡាយ ចូរសម្គាល់យើងថា ជាព្រះអរហន្ត", ភិក្ខុនោះ ជាអាបត្តិបារាជិក ។ ចំណែកភិក្ខុណាដើរហួសស្ថានទីនោះទៅ ដោយកិច្ចធុរៈរបស់អាចារ្យនិងឧបជ្ឈាយ៍ក្ដី ដោយកិច្ចដែលត្រូវធ្វើឯណានិមួយចំពោះតាមា បិតាក្ដី ដើម្បីភិក្ខាចារ ឬដើម្បីប្រយោជន៍ដល់ឧទ្ទេសនិងបរិបុច្ឆាក្ដី, ដោយ

ករណីយកិច្ចបែបនោះយ៉ាងដទៃក្តី មិនជាអាបត្តិដល់ភិក្ខុនោះ ។ បើសូម្បីកាលភិក្ខុនោះ ដើរទៅដោយកិច្ចយ៉ាងនោះ ខាងក្រោយឥច្ឆាចារកើតឡើងថា "ឥឡូវនេះ យើងនឹងមិនទៅក្នុងស្ថានទីនោះ ។ ព្រោះថា ជនទាំងឡាយនឹងសរសើរយើងថា ជាព្រះអរហន្តដោយអាការយ៉ាងនេះ" មិនជាអាបត្តិដូចគ្នា ។ ចំណែកភិក្ខុណា លុះដល់ស្ថានទីនោះ ដោយករណីយ៍យ៉ាងណាមួយហើយ ជាអ្នកបញ្ចូនចិត្តទៅក្នុងទីដទៃ ដោយអំណាចការដាក់ចិត្តក្នុងការស្វាធ្យាយជាដើម ឬត្រូវចោរជាដើមដេញជាប់តាម ឬឃើញពពកខ្មៅតាំងឡើងហើយ មានប្រាថ្នានឹងចូលទៅជ្រកឱ្យផុតពីភ្លៀង ទើបកន្លងហួសស្ថានទីនោះទៅ, មិនជាអាបត្តិដល់ភិក្ខុនោះ ។ សូម្បីភិក្ខុទៅដោយយានឬដោយឫទ្ធិ ក៏មិនត្រូវបារាជិក, តែរមែងត្រូវអាបត្តិដោយការដើរទៅដោយជើងប៉ុណ្ណោះ ។ ភិក្ខុដើរទៅដល់ស្ថានទីសូម្បីនោះ មិនមុនមិនក្រោយព្រមដោយពួកភិក្ខុរួមគ្នាតាំងកតិកាទុកមិនត្រូវអាបត្តិ ។ ព្រោះថា ភិក្ខុទាំងឡាយ កាលដើរទៅយ៉ាងនោះនៅរក្សាគ្នានិងគ្នាបានទាំងអស់ ។ សូម្បីបើភិក្ខុទាំងឡាយ កំណត់ស្ថានទីកន្លែងខ្លះបណ្តាមណ្ឌប និងគល់ដើមឈើជាដើម ហើយតាំងកតិកាទុកដោយន័យជាដើមថា ពួកយើងនឹងដឹងភិក្ខុដែលអង្គុយឬដើរចង្ក្រមនៅក្នុងទីនេះថាជាព្រះអរហន្ត ឬយកផ្កាឈើដាក់ទុកដោយន័យជាដើមថា "ពួកយើងនឹង

ជ្រាបភិក្ខុដែលកាន់យកផ្កាឈើទាំងនេះហើយធ្វើការបូជាថា ជាព្រះអរហន្ត" ។ សូម្បីក្នុងកតិកាវត្តនោះ កាលភិក្ខុធ្វើយ៉ាងនោះ ដោយអំណាចឥច្ឆាចារ ជាបារាជិកដូចគ្នា ។ សូម្បីបើឧបាសកសាងវិហារទុកក្នុងចន្លោះមកក្តី តាំងបច្ច័យមានចីវរជាដើមទុកក្តី ដោយពោលថា សូមភិក្ខុជាព្រះអរហន្តទាំងឡាយ ចូរសម្រាកក្នុងវិហារនេះ និងចូរកាន់យកបច្ច័យមានចីវរជាដើម ។ សូម្បីក្នុងកតិកាវត្តដែលឧបាសកតាំងទុកនោះ កាលភិក្ខុសម្រាក ឬកាន់យកបច្ច័យមានចីវរជាដើមទាំងនោះ ដោយអំណាចឥច្ឆាចារ ជាបារាជិកដូចគ្នា ។ តែថា នោះ ជាកតិកាវត្តដែលមិនប្រកបដោយធម៌; ព្រោះហេតុនោះ ទើបមិនគួរធ្វើ ។

ម្យ៉ាងទៀត វត្តដទៃបែបនេះ មានជាដើមយ៉ាងនេះថា ខាងក្នុងត្រៃមាសនេះភិក្ខុទាំងអស់ចូរជាអ្នកកាន់ការនៅព្រៃជាវត្ត ឬថា ទ្រទ្រង់ទុកនូវធុតង្គដ៏សេស មានអង្គនៃភិក្ខុដែលត្រាច់បិណ្ឌបាតជាវត្តជាដើម, ឬថា ចូរជាអ្នកអស់អាសវៈ ជាមួយគ្នាគ្រប់រូបទាំងអស់, ដូច្នេះ (ឈ្មោះថាវត្តដែលមិនប្រកបដោយធម៌) ពិតមែន ភិក្ខុទាំងឡាយអ្នកនៅក្នុងជនបទផ្សេង ៗ រមែងប្រជុំគ្នា ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុពួកខ្លះទុព្វលភាពមានកម្លាំងខ្សោយ រមែងមិនអាចទឹងតាមរក្សាកតិកាវត្តបែបនោះបាន ។

ព្រោះហេតុនោះ កតិកាវត្តសូម្បីបែបនោះ ទើបមិនគួរធ្វើ ។ និង

កតិកាវត្តមានជាដើមយ៉ាងនេះថា វេហូតអស់ត្រៃមាសនេះ ភិក្ខុគ្រប់រូបទាំងអស់ មិនត្រូវសម្តែងធម៌ មិនត្រូវរៀនធម៌ មិនត្រូវឱ្យបព្វជ្ជា, តែគួររៀនមុគវត្ត គួរឱ្យលាកសង្ឃសូម្បីដល់ភិក្ខុនៅខាងក្រៅសីមាផង ដូច្នេះ ក៏មិនគួរធ្វើដូចគ្នា ។

## រឿងព្រះមហាមោគ្គល្លានឃើញអដ្ឋិសង្ខលិកប្រេត

[២៩៥] ព្រះលក្ខណត្ថេរ ដែលព្រះធម្មសង្គាហកាចារ្យ ពោលទុកក្នុងលក្ខណសំយុត្តថា **អាយស្មា ច លក្ខណោ : ព្រះលក្ខណត្ថេរដ៏មានអាយុ** ជាដើមនេះ បណ្ឌិតគប្បីជ្រាបថា មាននៅក្នុងបណ្តាភិក្ខុជដិលមួយពាន់អង្គ ឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា បានសម្រេចជាព្រះអរហន្តក្នុងទីបំផុតនៃអាទិត្តបរិយាយសូត្រ ជាព្រះមហាសាវកអង្គមួយ ។ ក៏ព្រោះព្រះថេរៈអង្គនេះ ប្រកបដោយអត្តភាពដូចព្រហ្មសម្បូរណ៍ដោយលក្ខណៈពេញប្រៀបដោយអាការគ្រប់យ៉ាង; ដូច្នោះទើបលោកដល់ការរាប់ថា លក្ខណៈ ចំណែកព្រះមហាមោគ្គល្លានត្ថេរជាព្រះអគ្គសាវកទី ២ បានសម្រេចជាព្រះអរហន្ត ក្នុងថ្ងៃទី ៧ ក្រោយពីថ្ងៃដែលព្រះថេរៈបួសហើយ ។

ពីរបទថា **សិតំ បាត្វាកាសិ : ធ្វើការញញឹមឱ្យប្រាកដ** សេចក្តី

ថា ព្រះមហាមោគ្គល្លានត្ថេរ បានធ្វើការញញឹមតិច ៗ ឱ្យប្រាកដ ។ មានពាក្យអធិប្បាយថា ប្រកាស គឺ សម្ដែង ។

សួរថា ក៏ព្រះថេរៈ ឃើញអ្វី ទើបបានធ្វើការញញឹមឱ្យប្រាកដ ?

ឆ្លើយថា ព្រះថេរៈ ឃើញសត្វដែលកើតនៅក្នុងបេតលោកមួយមានតែរាងឆ្អឹងដែលមកហើយក្នុងបាលីខាងមុខ, ក៏ឯការឃើញសត្វនោះឃើញបានដោយទិព្វចក្ខុ មិនមែនឃើញដោយចក្ខុប្រសាទទេ ។ ពិតមែនអត្តភាពទាំងនោះ មិនបានមកកាន់គន្លងនៃចក្ខុប្រសាទទេ ។

សួរថា ក៏ព្រះថេរៈឃើញអត្តភាពមានរូបយ៉ាងនោះហើយ ព្រោះហេតុអ្វី ទើបបានធ្វើការញញឹមឱ្យប្រាកដ ក្នុងកាលគួរធ្វើសេចក្ដីករុណាហ្ន៎ ? ។

ឆ្លើយថា ព្រោះព្រះថេរៈរលឹកដល់សម្បត្តិរបស់ខ្លួន និងព្រះញាណរបស់ព្រះពុទ្ធផង ។ ពិតមែន ព្រះថេរៈឃើញប្រេតនោះហើយបានរលឹកដល់សម្បត្តិរបស់ខ្លួនថា "អត្តភាពបែបនេះ ដែលបុគ្គលឈ្មោះថា មិនទាន់ឃើញសច្ចៈនឹងគប្បីបាន, យើងផុតហើយ ចាកអត្តភាពដូច្នោះ, ជាលាភរបស់យើង យើងបានល្អ ហើយហ្ន៎" និងបានរលឹកដល់សម្បត្តិនៃព្រះពុទ្ធញាណយ៉ាងនេះថា "ញាណសម្បត្តិរបស់ព្រះមានព្រះភាគ ដែលទ្រង់សម្ដែងថា 'ម្នាលភិក្ខុទាំងឡាយ វិបាករបស់កម្មជា

អចិន្ត្រៃយ៍ ដែលបុគ្គលមិនគួរគិត'[១] គួរអស្ចារ្យ, ព្រះពុទ្ធទាំងឡាយ រមែងទ្រង់សម្តែងធ្វើឱ្យប្រចក្សហើយ ធម្មធាតុ ដែលព្រះពុទ្ធទាំងឡាយ ទ្រង់ចាក់ធ្លុះល្អហើយ" ដូច្នេះ ទើបបានធ្វើការញញឹមឱ្យប្រាកដ ។

ក៏ធម្មតាថា ព្រះខីណាស្រពទាំងឡាយ មិនធ្វើការញញឹមឱ្យប្រាកដព្រោះមិនមានហេតុ; ព្រោះដូច្នោះ ទើបព្រះលក្ខណត្ថេរសួរព្រះមហាមោគ្គល្លានត្ថេរនោះថា "ម្នាលអាវុសោ មោគ្គល្លានៈ អ្វីជាហេតុ អ្វីជាបច្ច័យចំពោះកិរិយាធ្វើនូវការញញឹមឱ្យប្រាកដ( នេះ )" តែព្រះថេរៈឆ្លើយតបថា "ម្នាលអាវុសោលក្ខណៈ កាលនេះ មិនមែនជាកាលគួរព្យាករប្រស្នានេះទេ លោកចូរសួរប្រស្នានេះនឹងខ្ញុំ ក្នុងសំណាក់ព្រះមានព្រះភាគចុះ" ។ ដោយហេតុដែលលោកមានសេចក្តីប្រាថ្នានឹងឱ្យព្រះមានព្រះភាគជាសាក្សីជាមុនសិន ទើបព្យាករណ៍ ព្រោះហេតុថា ភិក្ខុទាំងឡាយ អ្នកដែលមិនបានឃើញសេចក្តីឧប្បត្តិឡើងនេះដោយខ្លួនឯងហើយ នឹងបង្គាប់ឱ្យជឿបានដោយលំបាក ។ ខាងក្រោយអំពីនោះ ព្រះមហាមោគ្គល្លានត្ថេរ ត្រូវព្រះលក្ខណត្ថេរសួរក្នុងសំណាក់ព្រះមានព្រះភាគ ទើបបានព្យាករណ៍ ដោយន័យមានជាដើមថា ឥធាហំ អាវុសោ : ម្នាលអាវុសោ ក្នុងថ្ងៃនេះខ្ញុំ ។

---

១. អង្គុ. ចតុ. ៤២. ៧៨/១៩៧ ។

បណ្ដាបទទាំងនោះ បទថា អដ្ឋិកសង្ខលិកំ : ប្រេតមានឆ្អឹងពណ៌ស បានដល់ ប្រេតមានតែរាងឆ្អឹងដែលមានពណ៌ស មិនមានសាច់និងឈាម ។

ត្មាតយក្ខ ខ្លែងយក្ខ និងរអាតយក្ខ សូម្បីទាំងនេះ គប្បីជ្រាបថាត្មាតខ្លះ ខ្លែងយក្ខ និងរអាតយក្ខ ។ ក៏រូបនោះ មិនមកសូម្បីកាន់គន្លង (នៃចក្ខុ) របស់ហ្វូងត្មាតជាដើមតាមប្រក្រតី ។

ពីរបទថា អនុបទ្បតិត្វា អនុបទ្បតិត្វា : ដេញតាម បានដល់ នាំគ្នាដេញតាមទៅហើយ ៗ ។

បទថា វិតុទេន្តិ : ឆាប បានដល់ ចិកហើយហើរទៅ ។ ម្យ៉ាងទៀត បាលីថា វិតុទន្តិ ក៏មាន ។ អធិប្បាយថា រមែងចិក ដោយចុងចំពុះលោហៈដ៏មុតប្រៀបដូចមុខដាវ ។ សព្ទថា សុទំ ក្នុងពាក្យថា សាសុទំ អដ្តស្សរំ ករោតិ : ប្រេតនោះ បេះតែស្រែកថ្ងូរ នេះ ជានិបាត ។ អធិប្បាយថា អដ្ឋិកសង្ខលិកប្រេតនោះ រមែងធ្វើសំឡេងស្រែកថ្ងូរ គឺ សំឡេងយំ ។ បានឮថា អត្តភាពដូច្នោះ សូម្បីមានប្រមាណមួយយោជន៍ រមែងកើតឡើង និងមានប្រសាទដែលប៉ោងឡើង ដូចបូសដែលទុំហើយ ដើម្បីតាមសោយផលនៃអកុសល ព្រោះដូច្នោះ

អដ្ឋិសង្ខលិកប្រេតនោះ ក្តៅក្រហាយព្រោះវេទនាដ៏មានកម្លាំង ទើបបាន ធ្វើសំឡេងដូច្នោះឯង ។

លុះព្រះមហាមោគ្គល្លានពោលយ៉ាងនេះហើយ កាលទឹងសម្តែង ធម្មសង្វេគទៀតដែលកើតឡើង ព្រោះអាស្រ័យសេចក្តីករុណាក្នុងសត្វ ទាំងឡាយថា ដែលឈ្មោះថា សត្វទាំងឡាយអ្នកទៅក្នុងវដ្តៈ រមែងមិន ផុតពីអត្តភាពបែបនេះទៅបាន ទើបពោលពាក្យជាដើមថា "ម្នាលអាវុសោ ទើបខ្ញុំបានបរិវិតក្កៈថា យីអើហ្ន៎ (នេះហៅពេញ)ជាអស្ចារ្យ យីអើហ្ន៎ មិនធ្លាប់កើតមានសោះឡើយ" ដូច្នេះ ។

ពីរបទថា **ភិក្ខូ ឧជ្ឈាយន្តិ** : ភិក្ខុទាំងឡាយ ទើបពោលទោស សេចក្តីថា សេចក្តីឧប្បត្តិឡើងនៃប្រេតនោះ មិនឃើញប្រចក្សដល់ភិក្ខុ ពួកណា, ភិក្ខុទាំងនោះ នាំគ្នាពោលទោស ។ ចំណែកព្រះមានព្រះភាគ កាលទឹងទ្រង់ប្រកាសអានុភាពរបស់ព្រះថេរៈ ទើបត្រាស់ព្រះតម្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយ មានចក្ខុកើតពិតហើយ ម្នាលភិក្ខុ ទាំងឡាយ សាវកទាំងឡាយ មានញាណកើតពិតហើយ ព្រោះហេតុថា សាវកទឹងដឹង ឬទឹងឃើញប្រេតបែបនេះ ឬថា ទឹងធ្វើប្រេតបែបនេះឱ្យ ជាបន្ទាល់(របស់តថាគត) ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតបាន ឃើញក្នុងកាលមុនរួចមកហើយ ប៉ុន្តែ តថាគតមិនបានសម្តែង ព្រោះថា

តថាគតសម្តែងទៅ ពពួកជនដទៃមិនជឿ(ពាក្យ)តថាគត ពពួកជនណាដែលមិនជឿតថាគត សេចក្តីដែលមិនជឿនោះ នឹងនាំឱ្យខានបានប្រយោជន៍ នាំឱ្យបានសេចក្តីទុក្ខអស់កាលយូរអង្វែងដល់ពពួកជននោះ ម្នាលភិក្ខុទាំងឡាយ សត្វនុ៎ះ (កាលពីដើម) ជាអ្នកពិឃាតគោ ក្នុងក្រុងរាជគ្រឹះនេះឯង ដោយកម្មវិបាកនោះ អ្នកពិឃាតគោនោះ ទៅឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយ ពាន់ សែនឆ្នាំដ៏ច្រើន, ដោយវិបាកនៃកម្មនោះនៅសេសសល់ ក៏ត្រឡប់មកទទួលផល គឺ ត្រឡប់បាននូវអត្តភាពបែបនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនត្រូវអាបត្តិទេ" ។

ក្នុងពាក្យទាំងនោះ ពាក្យថា **សាវកទាំងឡាយ មានចក្ខុកើតពិតហើយ** ព្រោះអត្ថថា សាវកទាំងនោះមានចក្ខុប្រាកដហើយ កើតហើយ ឧប្បត្តិហើយ ។ សេចក្តីថា ជាអ្នកមានចក្ខុប្រាកដហើយ គឺ មានចក្ខុកើតហើយ ញ៉ាំងចក្ខុឱ្យកើតឡើងហើយ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ ពាក្យថា **យត្រ** ដែលមាននៅក្នុងពាក្យថា យត្រ ហិ ណាម នេះ ជាពាក្យបញ្ជាក់ដល់ហេតុ ។ ក្នុងពាក្យថា **ចក្ខុភូតា** ជាដើមនោះ មានការប្រកបសេចក្តីដូចតទៅនេះ ៖

ព្រោះហេតុថា សូម្បីសាវកនឹងដឹង ឬនឹងឃើញ ឬនឹងធ្វើអត្តភាព

បែបនេះ ឱ្យជាសាក្សីបាន; ដូច្នោះ ទើបតថាគតបានពោលថា “ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយ មានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវកទាំងឡាយ មានញាណកើតពិតហើយ” ដូច្នេះ ។

ពាក្យថា បុព្វេ វ មេ សោ ភិក្ខវេ សត្តោ ទិដ្ឋោ : **ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតបានឃើញពីក្នុងកាលមុនរួចមកហើយ** មានសេចក្តីថា (ព្រះមានព្រះភាគ) ត្រាស់ថា តថាគតបានចាក់ធ្លុះសព្វញ្ញុតញ្ញាណទៀបពោធិមណ្ឌលធ្វើពួកសត្វ និងភព គតិ ឋិតិ និងនិវាស មិនមានប្រមាណ ក្នុងចក្កវាឡទាំងឡាយ មិនមានប្រមាណឱ្យប្រចក្ស បានឃើញសត្វនោះហើយក្នុងកាលមុន ។

បទថា គោឃាតកោ : **ជាអ្នកពិឃាតគោ** សេចក្តីថា ជាអ្នកសម្លាប់គោទាំងឡាយហើយ ពន្លះសាច់ចេញពីឆ្អឹងលក់ចិញ្ចឹមជីវិត ។

ច្រើនបទថា តស្សេវ កម្មស្ស វិបាកាវសេសេន : **ដោយសេសសល់នៃកម្មវិបាកនោះ** សេចក្តីថា នៃអបរាបរវេទនីយកម្មដែលចេតនាផ្សេង ៗ ប្រមូលមកហើយនោះឯង ។ ពិតមែន បណ្តាចេតនាទាំងនោះ បដិសន្ធិក្នុងនរកដោយចេតនាណាឱ្យកើតឡើង ហើយកាលវិបាកនៃចេតនាដួងនោះ អស់ទៅហើយ, បដិសន្ធិក្នុងប្រេតជាដើម រមែងកើតទៀត; ព្រោះធ្វើកម្មដ៏សេស ឬកម្មនិមិត្តឱ្យជាអារម្មណ៍ ព្រោះហេតុនោះ

បដិសន្ធិនោះ ទើបលោកហៅថា វិបាកដ៏សេសនៃកម្មនោះឯង ព្រោះមានចំណែកស្មើដោយកម្ម ឬព្រោះមានចំណែកស្មើដោយអារម្មណ៍ ។ ក៏សត្វនេះកើតឡើងហើយយ៉ាងនេះ ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ដោយសេសសល់នៃកម្មវិបាកនោះ" ។ បានឮថា ក្នុងកាលរួចផុតពីនរក សត្វនោះបានមាននិមិត្ត គឺ គ្រោងឆ្អឹងនៃគោទាំងឡាយ ដែលត្រូវធ្វើមិនឱ្យមានសាច់, សត្វនោះ កាលនឹងធ្វើកម្មនោះសូម្បីដែលបិទបាំងឱ្យដូចជាប្រាកដដល់វិញ្ញូជនទាំងឡាយ ទើបកើតជាអដ្ឋិសង្ខលិកប្រេត ។

## រឿងមំសបេសីប្រេត

ក្នុងរឿងមំសបេសីប្រេត មានវិនិច្ឆ័យដូច្នេះ ៖

មំសបេសីប្រេតនោះជាអ្នកសម្លាប់គោ ធ្វើបន្ទះសាច់ហាលឱ្យក្រៀមហើយ ចិញ្ចឹមជីវិតដោយការលក់សាច់ក្រៀមច្រើនឆ្នាំ ។ ព្រោះហេតុនោះ កាលរួចផុតពីនរក គេទើបបានមាននិមិត្ត គឺ បន្ទះសាច់នុ៎ះឯង គេទើបកើតជាមំសបេសីប្រេត ។

## រឿងមំសបិណ្ឌប្រេត

ក្នុងរឿងមំសបិណ្ឌប្រេត មានវិនិច្ឆ័យដូច្នេះ ៖

មំសបិណ្ឌប្រេតនោះជាព្រានសត្វ ចាប់សត្វបានហើយ វេលាលក់បានធ្វើការជកពោមស្លាបនិងស្បែកចេញអស់ ឱ្យនៅត្រឹមតែជាដុំសាច់ហើយ លក់ចិញ្ចឹមជីវិត ។ ព្រោះហេតុនោះ កាលរូបផុតពីនរក គេទើបបានមាននិមិត្ត គឺ ដុំសាច់ប៉ុណ្ណោះ ។ គេទើបកើតជាមំសបិណ្ឌប្រេត ។

## រឿងនិច្ឆវិប្រេត

ក្នុងរឿងនិច្ឆវិប្រេត មានវិនិច្ឆ័យដូច្នេះ ៖

និច្ឆវិប្រេតនោះ ជាអ្នកសម្លាប់ពពែហើយបកស្បែក ចិញ្ចឹមជីវិតទើបបានមាននិមិត្ត គឺ រាងកាយពពែប្រាសចាកស្បែកតាមន័យមុនទុំះឯងគេទើបបានកើតជានិច្ឆវិប្រេត ។

## រឿងអសិលោមប្រេត

ក្នុងរឿងអសិលោមប្រេត មានវិនិច្ឆ័យដូច្នេះ ៖

អសិលោមប្រេតនោះជាអ្នកសម្លាប់ជ្រូក ប្រើដាវសម្លាប់ជ្រូកទាំងឡាយ ដែលខ្លួនបំប៉នដោយចំណីអស់ការយូរ ហើយចិញ្ចឹមជីវិតមកហេតុអស់រាត្រីយូរ ។ គេទើបបានមាននិមិត្ត គឺ ភាវៈរបស់អ្នកដែលឆាដាវឡើង ដូច្នោះ គេទើបកើតជាអសិលោមប្រេត ។

## រឿងសត្តិលោមប្រេត

ក្នុងរឿងសត្តិលោមប្រេត គប្បីជ្រាបវិនិច្ឆ័យតទៅ ៖

សត្តិលោមប្រេតនោះជាអ្នកបាញ់ម្រឹគ នាំយកម្រឹគមួយនិងកាន់លំពែងមួយ ទៅព្រៃហើយ ប្រើលំពែងចាក់ម្រឹគដែលនាំគ្នាមកកាន់ទីជិតម្រឹគនោះឱ្យស្លាប់ ។ គេទើបបានមាននិមិត្ត គឺ ភាវៈដែលប្រើលំពែងចាក់ ។ ដូច្នោះ គេទើបកើតជាសត្តិលោមប្រេត ។

## រឿងឧសុលោមប្រេត

ក្នុងរឿងឧសុលោមប្រេត គប្បីជ្រាបវិនិច្ឆ័យតទៅ ៖

បទថា ការណិកោ : ជាពេជ្ឈឃាត សេចក្តីថា ជាបុរសអ្នកបៀតបៀនពួកមនុស្សដែលខុសចំពោះព្រះរាជា ដោយហេតុទាំងឡាយជាច្រើន ចុងក្រោយក៏ប្រើកូនសរបាញ់ឱ្យស្លាប់ ។ បានឮថា គេជ្រាបមុនថា អ្នកត្រូវបាញ់ចំណែកឯណោះ ទើបនឹងស្លាប់ ដូច្នេះ ហើយទើបបាញ់ ។ គេនុ៎ះឯងចិញ្ចឹមជីវិតហើយកើតក្នុងនរកក្នុងវេលាកើតក្នុងប្រេតវិស័យនេះ បានមាននិមិត្តគឺ ភាវៈដែលប្រើសរបាញ់ ដោយវិបាកដ៏សេសអំពីនរកនោះ ។ ដូច្នោះ គេទើបកើតជាឧសុលោមប្រេត ។

## រឿងសូចិលោមប្រេត

ក្នុងរឿងសូចិលោមប្រេត គប្បីជ្រាបវិនិច្ឆ័យតទៅ ៖

បទថា សារថិ : នាយសារថី គឺជាអ្នកទូន្មានសេះ ។ ក្នុងអដ្ឋកថាកុរុន្ទី លោកពោលថា ជាអ្នកបង្ហឹកគោ ដូច្នេះខ្លះ ។ គេបានមាននិមិត្ត គឺការៈដែលចាក់ដោយជន្លួញ ។ គេទើបកើតជាសុចិលោមប្រេត ។

## រឿងសូចិលោមប្រេតទី ២

ក្នុងរឿងសូចិលោមប្រេតរឿងទី ២ គប្បីជ្រាបវិនិច្ឆ័យតទៅ ៖

បទថា សូចិកោ[១] : ជាអ្នកញុះញង់គេ គឺ ជាអ្នកធ្វើការស៊ិកសៀត ។ បានឮថា គេទំលាយមនុស្សទាំងឡាយ និងពួករួមគ្នា និងញុះញង់ក្នុងរាជត្រកូលថា "អ្នកនេះមានសេចក្ដីខុសឈ្មោះនេះ អ្នកនេះធ្វើខុសឈ្មោះនេះ"ដូច្នេះ, គ្រាញុះញង់ហើយ ធ្វើឱ្យដល់សេចក្ដីវិនាសអស់ ។ ដូច្នោះ គេទើបកើតជាសូចិលោមប្រេត ព្រោះធ្វើនិមិត្ត គឺ កម្មដើម្បីការសោយទុក្ខអំពីការទម្លាយដោយស្នៀតទាំងឡាយ ដូចដែលគេស៊ិកសៀតបំបែកពួកមនុស្ស ដូច្នោះ ។

---

១. ភូមា. សូចកោ ។ សុចកោ : អ្នកស៊ិកសៀត ; សូចិ : ម្ជុល, ស្នៀត, គន្លឹះ, ដែកចារ ។

# រឿងអណ្ឌភារប្រេត

ក្នុងរឿងប្រេតលីអណ្ឌៈ( ពងស្វាស ) គប្បីជ្រាបតទៅ ៖

បទថា គាមកូដោ : ជាអមាត្យអ្នកវិនិច្ឆ័យក្ដីនៃអ្នកស្រុកដោយអំពើវៀច គឺ ជាអាមាត្រអ្នកកាត់ក្ដីបណ្ដឹង ។ សត្វនោះបានមានអណ្ឌៈប៉ុនឆ្នាំង គឺ មានខ្វាតប៉ុនឆ្នាំងធំ ព្រោះមានចំណែកស្មើដោយកម្ម ។ ព្រោះថា សត្វនោះ ព្រោះហេតុដែលទទួលសំណូកក្នុងស្ថានទីកំបាំង កាលទឹងធ្វើទោសឱ្យប្រាកដ ដោយការកាត់ក្ដីបណ្ដឹងកោង បានធ្វើពួកម្ចាស់របស់មិនឱ្យជាម្ចាស់របស់; ព្រោះដូច្នោះ អវយវៈកំបាំងរបស់សត្វនោះទើបកើតប្រាកដ ។ ព្រោះហេតុដែលសត្វនោះ កាលចាប់ផ្ដើមតាំងអាជ្ញា បានលើករបស់ធ្ងន់ដែលមិនគួរទឹងធន់បាន ឱ្យដល់ជនពួកដទៃ; ព្រោះហេតុដែលសត្វនោះតាំងនៅក្នុងតំណែងណា គួរទឹងជាអ្នកស្មើ, តែតាំងនៅក្នុងតំណែងនោះហើយ មិនបានជាអ្នកស្មើទេ; ដូច្នោះ សត្វនោះទើបបានមានការអង្គុយមិនរៀបរយ គឺអង្គុយលើអវយវៈកំបាំង ។

## រឿងបរទារិកប្រេត

ក្នុងរឿងប្រេតប្រព្រឹត្តខុសក្នុងប្រពន្ធនៃអ្នកដទៃ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

សត្វនោះ កាលប៉ះពាល់សម្ផស្សដែលមានម្ចាស់គេឃុំគ្រងរក្សាហើយរបស់អ្នកដទៃ ញុំាងចិត្តឱ្យរីករាយដោយសេចក្ដីសុខក្នុងកាម ដែលជាសេចក្ដីសុខក្នុងឧច្ចារៈ ទើបកើតក្នុងប្រេតវិស័យនោះ ដើម្បីនឹងប៉ះពាល់សម្ផស្សជាលាមក សោយទុក្ខ ព្រោះមានចំណែកស្មើដោយកម្ម ។

ក្នុងរឿងព្រាហ្មណ៍កំណាច មានសេចក្ដីប្រាកដច្បាស់ហើយ ។

## រឿងនិច្ឆវិប្រេត

រឿងនិច្ឆវិប្រេត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ព្រោះឈ្មោះថា មាតុគ្រាម មិនជាឥស្សរៈក្នុងផស្សៈរបស់ខ្លួន ។ តែស្រីនោះលួចផស្សៈរបស់ស្វាមីនោះ ញុំាងសេចក្ដីអភិរម្យឱ្យកើតដល់ពួកជនដទៃ ; ដូច្នោះ ទើបបានកើតជាស្រីប្រេតប្រាសចាកសម្បុរស្បែក ដើម្បីកម្ចាត់សម្ផស្សជាសុខចេញទៅហើយ សោយសម្ផស្សជាទុក្ខ ព្រោះមានចំណែកស្មើដោយកម្ម ។

## រឿងមង្គុលិស្រីប្រេត

ក្នុងរឿងមង្គុលិស្រីប្រេត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បទថា **មង្គុលិ** : ប្រេតអាក្រក់ គួរខ្ពើមឆ្អើម បានដល់ មានរូបខុសប្រក្រតីទៅ គឺ សម្លឹងមើលគួរស្អប់ គួរខ្ពើម ។ បានឮថា ស្រីនោះធ្វើនាទីជាមេមត់ គឺ ជាប្រធានទាសីរបស់យក្ខ ពោលថា “កាលធ្វើពលីកម្មយ៉ាងនេះដោយវត្ថុនេះនិងវត្ថុនេះ សេចក្ដីចម្រើនរបស់ពួកលោកឈ្មោះនេះនឹងមាន” ដូច្នេះ ហើយកាន់យករបស់ក្រអូប និងផ្កាឈើជាដើមរបស់មហាជនដោយការបោកបញ្ឆោត ញ៉ាំងមហាជនឱ្យប្រកាន់មិច្ឆាទិដ្ឋិដែលជាទិដ្ឋិអាក្រក់ ។ ព្រោះដូច្នោះ ទើបនាងកើតជាស្រីប្រេតមានក្លិនស្អុយ ព្រោះលួចរបស់ក្រអូបនិងផ្កាឈើជាដើម ជាស្រីប្រេតសម្លឹងមើលគួរស្អប់ មានរូបអាក្រក់គួរខ្ពើម ព្រោះហេតុឱ្យមហាជនប្រកាន់សេចក្ដីអាក្រក់ ព្រោះមានចំណែកស្មើដោយកម្មនោះ ។

## រឿងឱ្យកិលិនីស្រីប្រេត

រឿងឱ្យកិលិនីស្រីប្រេត គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា ឧប្បក្កំ ឱក៌លិនឹ ឱកីរណឹ : ដែលកើតជាឱ្យកិលិនីប្រេត ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន (ក្តៅអន្ទះសារ) មានសេចក្តីថា បានឮថា ស្រីប្រេតនោះ ដេកនៅលើជើងថ្កររងើកភ្លើង បម្រះននៀលត្រឡប់ទៅមកត្រូវភ្លើងឆេះ; ព្រោះដូច្នោះ នាងទើបជាអ្នកត្រូវភ្លើងឆេះរោលរាល មានសរីរៈឆ្អិនដោយភ្លើងក្រុត មានទឹកញើសស្រក់ មានសរីរៈសើម គឺ តំណក់ទឹកញើសទាំងឡាយ រមែងហូរចេញអំពីសរីរៈរបស់ស្រីប្រេតនោះ និងមានរងើកភ្លើងដេរដាស់ គឺពាសពេញដោយរងើកភ្លើង ។ ព្រោះថា រងើកភ្លើងទាំងឡាយ មានពណ៌ដូចផ្ការលួសផ្អុង រមែងធ្លាក់សួម្បីអំពីខាងក្រោមរបស់ស្រីប្រេតនោះ រងើកភ្លើងទាំងឡាយ រមែងធ្លាក់ទាំងសងខាង សូម្បីអំពីអាកាសក្នុងខាងលើរបស់ស្រីប្រេតនោះ ។ ដោយហេតុនោះ លោកទើបពោលថា "ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន ទឹកញើសស្រក់ (ក្តៅអន្ទះសារ)" ។ នាងនោះជាមនុស្សស្រីប្រចណែនយកខ្ទះរងើកភ្លើងជះស្រីរួមប្តី ។ បានឮថា នាងរបាំម្នាក់របស់ព្រះរាជា

ព្រះអគ្គនោះ ដាក់ខ្ទះរងើកភ្លើងទុកក្នុងទីជិត ជូតទឹកអំពីខ្ទនទនិងអប់ដោយបាតដៃ ។ ព្រះរាជាទ្រង់សន្ទនាទីងនាងរបាំនោះ និងទ្រង់សម្តែងអាការប្រោសប្រាណ ច្រើនពេក ។ ព្រះអគ្គមហេសីទ្រង់អត់ទ្រាំ ទតមើលហេតុការណ៍នោះ មិនកម្រើក[១] ទ្រង់ប្រណៃន, កាលព្រះរាជាស្តេចចេញទៅមិនយូរប៉ុន្មាន ក៏ទ្រង់ចាប់ខ្ទះរងើកភ្លើងនោះ ចាក់រងើកភ្លើងស្រោចខាងលើនាងរបាំនោះ ។ ព្រះនាងធ្វើកម្មនោះហើយ កើតក្នុងបេតលោក ដើម្បីសោយវិបាកដូច្នោះនុ៎ះឯង ។

## រឿងចោរឃាតប្រេត

ក្នុងរឿងចោរឃាតប្រេត គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ពេជ្ឈឃាតចោរនោះ កាត់ក្បាលពួកចោរអស់កាលយូរមកហើយ តាមពាក្យបង្គាប់របស់ព្រះរាជា កាលកើតក្នុងបេតលោក ទើបបានកើតជាប្រេតមានរាងកាយអត់ក្បាល ។

---

១. ពាក្យថា **មិនកម្រើក** នេះ គឺមិនហ៊ានកម្រើកកាយដើម្បីបៀតបៀននាងស្រីស្នំនោះចំពោះមុខ ព្រះរាជា តែចិត្តនាងកម្រើកដោយការប្រណៃន ។

## រឿងព្រះភិក្ខុប្រេតជាដើម

ក្នុងរឿងភិក្ខុ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បទថា **បាបភិក្ខុ** : ជាភិក្ខុបាប គឺ ជាភិក្ខុលាមក ។ បានឮថា ភិក្ខុនោះបរិភោគបច្ច័យ ៤ ដែលគេប្រគេនដោយសទ្ធារបស់អ្នកលោក ជាអ្នកមិនសង្រួមមកកាយទ្វារនិងវចីទ្វារ មានអាជីពដែលទម្លាយហើយ ត្រាច់លេងសប្បាយរីករាយតាមពេញចិត្ត ។ ខាងក្រោយត្រូវភ្លើងឆេះនៅក្នុងនរក រហូតដល់អស់មួយពុទ្ធន្តរ កាលកើតក្នុងបេតលោក ក៏កើតដោយអត្តភាពដូចទីងភិក្ខុនុ៎ះឯង ។ សូម្បីក្នុងរឿងភិក្ខុនី រឿងសិក្ខមានា រឿងសាមណេរ រឿងសាមណេរីប្រេត ក៏មានសេចក្តីវិនិច្ឆ័យយ៉ាងនេះដែរ ។

## រឿងស្ទឹងតបោទា

[២៩៦] ក្នុងរឿងស្ទឹងតបោទា គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បទថា **អច្ឆោទកោ** : មានទឹកថ្លា បានដល់ មានទឹកដ៏ថ្លាស្អាត ។

បទថា **សីតោទកោ** : មានទឹកត្រជាក់ បានដល់ ទឹកមានភាពត្រជាក់ ។

បទថា សាតោទកោ : មានទឹកឆ្ងាញ់ បានដល់ ទឹកមានរសផ្អែម (រសទឹកឃ្មុំ) ។

បទថា សេតោទកោ : មានទឹកស្អាត បានដល់ មានទឹកបរិសុទ្ធិ គឺ មិនមានសារាយចក និងភក់ល្បាប់ ។

បទថា សុតិត្ថោ : មានកំពង់ដ៏ល្អ គឺ ចូលដល់ហើយដោយកំពង់ទាំងឡាយដែលល្អ ។

បទថា រមណីយោ : គួរជាទីរីករាយ បានដល់ គួរឱ្យកើតសេចក្ដីត្រេកអរ ។

បទថា ចក្កមត្តានិ : ប៉ុន ៗកង់នៃរថ ប្រែថា មានប្រមាណប៉ុនកង់រទេះ ។

បទថា កុថិតា[១] សន្ទតិ : មានទឹកក្ដៅហូរមក សេចក្ដីថា ជាស្ទឹងក្ដៅខ្លាំង ក្ដៅពុះកញ្ជ្រោលហូរទៅ ។

បទថា យតាយំ ភិក្ខវេ កាត់បទជា យតោ អយំ ភិក្ខវេ : ម្នាលភិក្ខុទាំងឡាយ ស្ទឹងតបោទានេះ ហូរមកពីអន្លង់ទឹកណា ... ?

បទថា សោ ទហោ គឺ សោ រហទោ : អន្លង់ទឹកនោះ ។

១. ថៃ. កុដ្ឋិតា ។

សួរថា ក៏ស្ទឹងតបោទានេះ ហូរមកពីអន្លង់ទឹកណា ?

ឆ្លើយថា បានឮថា ខាងក្រោមភ្នំវេភារៈ មានភពនាគប្រមាណ ៥០០ យោជន៍ របស់ពួកនាគដែលនៅលើផ្ទៃផែនដី ដូចទីងទេវលោក ប្រកបដោយផ្ទៃដែលសម្រេចដោយកែវមណី និងដោយអារាម និង ឧទ្យាន ។ អន្លង់ទឹកនោះនៅក្នុងទីលេងរបស់ពួកនាគក្នុងភពនាគនោះ ។ ទឹកស្ទឹងតបោទានេះ ហូរមកពីអន្លង់ទឹកនោះ ។

ពាក្យថា ទ្វិន្នំ មហានិរយានំ អន្តរិកាយ អាគច្ឆតិ : **មកតាមចន្លោះនៃមហានរកទាំងពីរ** សេចក្ដីថា បានឮថា មហាបេតលោក កន្លងក្រុងរាជគ្រឹះមក, ស្ទឹងតបោទានេះមកពីចន្លោះមហាលោហកុម្ភីនរក ២ រណ្ដៅក្នុងមហាបេតលោកនោះ ដូច្នោះ បានជាក្ដៅពុះកញ្ជ្រោលហូរទៅ ។

## រឿងការច្បាំង

(២៩៧) ក្នុងរឿងការច្បាំង គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

ពាក្យថា ឆន្ទិ ចរតិ : ទូងស្គរជ័យទៅប្រកាសសេចក្ដី បាន ដល់ វាយស្គរពិជ័យគេរីដើរប្រកាស ។

ពាក្យថា រាជា អាវុសោ លិច្ឆវីហិ : ម្នាលអាវុសោទាំងឡាយ ព្រះបាទពិម្ពិសារ (ទ្រង់ផ្ចាញ់) ពួកស្ដេចលិច្ឆវីបានហើយ សេចក្ដីថា

បានឮថា ព្រះថេរៈអង្គុយក្នុងទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់របស់ខ្លួន ឃើញពួកស្តេចលិច្ឆវីអ្នកមានថ្វីដៃជំនាញបាញ់បានល្អ កាលគិតថា "ក៏ព្រះរាជាទ្រង់បង្កសង្គ្រាមជាមួយនឹងពួកស្តេចលិច្ឆវីទាំងនោះ" បានឃើញព្រះរាជាទ្រង់បរាជ័យគេចទៅ ដោយទិព្វចក្ខុ ។ លំដាប់នោះ ទើបព្រះថេរៈហៅភិក្ខុទាំងឡាយមកពោលថា "អ្នកមានអាយុទាំងឡាយ ព្រះរាជាជាឧបដ្ឋាករបស់ពួកលោក ទ្រង់ចាញ់ពួកស្តេចលិច្ឆវីហើយ" ។

ពាក្យថា **សច្ចំ ភិក្ខវេ មោគ្គល្លានោ អាហ : ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលនូវពាក្យពិត** សេចក្តីថា មោគ្គល្លានកាលនឹកដល់ក្នុងវេលាព្រះរាជាទ្រង់បរាជ័យ ពោលវត្ថុដែលខ្លួនឃើញ ឈ្មោះថាពោលពិត ។

## រឿងដំរីចុះទឹក

[២៩៨] ក្នុងរឿងដំរីចុះទឹក គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

បទថា **សប្បិនិកាយ : ឈ្មោះសប្បិនិកា** គឺស្ទឹងដែលមានឈ្មោះយ៉ាងនេះ (ស្ទឹងមានទឹកពណ៌សប្បិ) ។

បទថា **អនេញ្ជំ សមាធឹ : សមាធិឥតមានកម្រើកប្រែប្រួល** បានដល់ ចតុត្ថជ្ឈានសមាធិ ដែលជាអនេញ្ជៈគឺ មិនញាប់ញ័រ វៀរចាកសេចក្តីក្តៅក្រហាយមកកាយនិងវាចា ។

បទថា នាគានំ : នៃនាគទាំងឡាយ បានដល់ នៃដំរីទាំងឡាយ ។

ពាក្យថា ឱគាហំ ឧត្តរន្តានំ : ដែលកំពុងតែចុះឡើង សេចក្តីថា ចុះទឹកហើយ ឡើងវិញទៀត ។ បានឮថាដំរីទាំងនោះចុះទឹកជ្រៅហើយ ង្ងូត និងផឹកក្នុងទឹកនោះ យកប្រមោយបឺតទឹកហើយព្រួសដាក់គ្នានិងគ្នា ទើបឡើងទៅ ។ មានពាក្យអធិប្បាយថា ដំរីទាំងនោះ ខ្លួនចុះទឹកហើយឡើងយ៉ាងនេះ ។

ពាក្យថា កោញ្ចំ ករោន្តានំ : ស្រែកបន្លឺកោញ្ចនាទ សេចក្តីថា ឈរមោត់ស៊ុំងសិកប្រមោយចូលក្នុងមាត់ហើយ ធ្វើសំឡេងដូចសត្វក្រៀល ។

ពាក្យថា សទ្ទំ អស្សោសំ : បានឮសូរសម្រែកដំរីទាំងឡាយ សេចក្តីថា យើងបានឮសំឡេងកោញ្ចនាទនោះ ។

ពាក្យថា អត្ថេសោ ភិក្ខវេ សមាធិ សោ ច ខោ អបរិសុទ្ធោ : ម្នាលភិក្ខុទាំងឡាយ សមាធិនុ៎ះមាន ប៉ុន្តែសមាធិនោះមិនបរិសុទ្ធទេ សេចក្តីថា សមាធិនោះរបស់មោគ្គល្លាន មាន, តែសមាធិនោះឯង ជារបស់មិនបរិសុទ្ធិ ។

បានឮថា ក្នុងថ្ងៃទី ៧ បន្ទាប់អំពីវេលាបួស ព្រះថេរៈបានសម្រេចព្រះអរហត្តផលក្នុងថ្ងៃនោះ មិនទាន់មានវសី (សេចក្ដីជំនាញ) ដែលប្រព្រឹត្តហើយ ដោយអាការ ៥ យ៉ាង ក្នុងសមាបត្តិ ៨ មិនទាន់បានញ៉ាំងធម៌ដែលជាសត្រូវចំពោះសមាធិឱ្យបរិសុទ្ធិដោយល្អ អន្លុយចូលចតុត្ថជ្ឈានតម្កល់មាំ ធ្វើឱ្យមានត្រឹមតែសញ្ញានៃការទើក ការចូល ការតាំងចិត្ត ការចេញ និងការពិចារណាប៉ុណ្ណោះ ចេញចាកអន្លុឈានហើយ អន្លុយហើយ បានឮសំឡេងនៃដំរីទាំងឡាយ ក៏មានសេចក្ដីសម្គាល់យ៉ាងនេះថា "យើងបានឮសំឡេងខាងក្នុងសមាបត្តិ" ដូច្នេះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សមាធិនុ៎ះមាន, ប៉ុន្តែ សមាធិនោះ មិនបរិសុទ្ធិ" ។

## រឿងព្រះសោភិតៈ

[២៩៩] ក្នុងរឿងព្រះសោភិតៈ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យថា អហំ អាវុសោ បញ្ចកប្បសតានិ អនុស្សរាមិ : ម្នាលអាវុសោទាំងឡាយ ខ្ញុំរលឹកជាតិបានប្រមាណ ៥០០ កប្ប សេចក្ដីថា ព្រះថេរៈពោលថា យើងរលឹកជាតិបាន ដោយអាវជ្ជនចិត្តតែមួយ ។ ក៏កាលកាន់យកសេចក្ដីម្យ៉ាងទៀត ការរលឹកដល់ខន្ធដែលធ្លាប់អាស្រ័យ

នៅក្នុងអតីតនោះ ៗ ដោយអាវជ្ជនចិត្តផ្សេង ៗ គ្នាដោយលំដាប់ របស់ព្រះសាវកទាំងឡាយ មិនគួរអស្ចារ្យ; ព្រោះដូច្នោះ ភិក្ខុទាំងឡាយទើបមិនលើកទោស ។ តែព្រោះព្រះសោភិតៈនោះពោលថា "យើងរលឹកជាតិបានដោយអាវជ្ជនចិត្តតែមួយ" ។ ដូច្នេះ; ព្រោះដូច្នោះ ភិក្ខុទាំងឡាយទើបលើកទោស ។

ពាក្យថា **អត្ថេសា ភិក្ខវេ សោភិតស្ស សា ច ខោ ឯកាយេវ ជាតិ** : ម្នាលភិក្ខុទាំងឡាយ សោភិតភិក្ខុរលឹកជាតិបានមែន តែថា រលឹកបានត្រឹមតែមួយជាតិប៉ុណ្ណោះ សេចក្តីថា ជាតិដែលសោភិតៈពោលថា "យើងរលឹកជាតិបាន" ដូច្នេះ របស់សោភិតៈ មាន, ក៏ឯជាតិនោះមានត្រឹមតែមួយជាតិប៉ុណ្ណោះ អធិប្បាយថា សោភិតៈមិនបានរលឹកដោយខុសលំដាប់មិនជាប់តគ្នា ។

សួរថា ព្រះសោភិតៈនេះរលឹកជាតិបានយ៉ាងណា ?

ឆ្លើយថា បានឮថា ព្រះសោភិតៈនេះ បួសក្នុងលទ្ធិតិរ្ថិយ ញ៉ាំងសញ្ញីសមាបត្តិឱ្យកើតហើយ ជាអ្នកមានឈានមិនសាបសូន្យធ្វើកាលៈហើយ កើតក្នុងអសញ្ញីភព ៥០០ កប្ប ។ លោកនៅក្នុងអសញ្ញីភពនោះដរាបគ្រប់អាយុ ក្នុងទីបំផុត (ក្រោយពីអស់អាយុហើយ) ក៏ឧប្បត្តិក្នុងមនុស្សលោកហើយបួសក្នុងព្រះសាសនាបានធ្វើវិជ្ជា ៣ ឱ្យច្បាស់

លោកកាលរលឹកដល់ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ឃើញបដិសន្ធិក្នុងអត្តភាពនេះ តពីនោះ បានឃើញចំពោះចុតិក្នុងអត្តភាពទី ៣ ។ លំដាប់នោះ លោកមិនអាចរលឹកដល់អត្តភាពដែលមិនមានចិត្តក្នុងចន្លោះចុតិនិងបដិសន្ធិទាំង ២ បាន ទើបបានកំណត់ដោយន័យថា "យើងកើតក្នុងអសញ្ញីភពពិតប្រាកដ" ។

ព្រះសោភិតត្ថេរនោះ កំណត់បានយ៉ាងនេះបានធ្វើវត្ថុដែលធ្វើបានលំបាក ដូចគ្នានឹងរុកចុងនៃរោមទ្រាយដែលច្រៀកជា ៧ ចំរៀកចូលនឹងចុង ដូចគ្នានឹងការសម្តែងស្នាមជើងក្នុងអាកាស; ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបទ្រង់តាំងលោកទុកក្នុងតំណែងឯតទគ្គៈ ព្រោះរឿងនេះឯងថា "ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នករកឃើញបុព្វេនិវាស ដែលជាសាវករបស់តថាគត ភិក្ខុសោភិតៈនេះ ប្រសើរជាងគេ"[១] ដូច្នេះ ។

១. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៩/៥៥ ។

## បទសរុបបារាជិក

[៣០០] ពាក្យថា ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ចត្តារោ បារាជិកា ធម្មា : បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិឈ្មោះបារាជិកទាំង ៤ ដែលខ្ញុំបានសម្តែងហើយនេះ នេះជាពាក្យសម្តែងដល់បារាជិក ដែលលើកឡើងសម្តែង ក្នុងបារាជិកកុទ្ទេសនេះ ។ តែប្រមូលចូលគ្នាហើយគប្បីជ្រាបបារាជិកទាំងអស់តែម្តងថា មាន ២៤ យ៉ាង ។ ២៤ យ៉ាង គឺ អ្វីខ្លះ ? គឺ

- ដែលមកក្នុងព្រះបាលី ៨ យ៉ាងមុន គឺ របស់ពួកភិក្ខុ ៤ របស់ពួកភិក្ខុនីជាអសាធារណៈ ៤ ។

- អភព្វបុគ្គល ១១ ពួក ។ បណ្តាអភព្វបុគ្គលទាំង ១១ ពួកនោះ បណ្ឌកៈ សត្វតិរច្ឆាន និងឧភតោព្យញ្ជនកៈ ៣ ពួក ជាពួកអហេតុកបដិសន្ធិ ចាត់ជាពួកវត្ថុវិបត្តិ ។ ពួកវត្ថុវិបត្តិទាំងនោះ មិនហាមឃាត់សួគ, តែហាមឃាត់មគ្គ ។ ពិតមែន បណ្ឌកៈជាដើមទាំងនោះ ចាត់ជាអភព្វបុគ្គលសម្រាប់ការបានមគ្គ ព្រោះជាពួកវត្ថុវិបត្តិ ។ ដល់ការបព្វជ្ជាសម្រាប់ពួកគេ ក៏ទ្រង់ហាមទុក ព្រោះដូច្នោះ បណ្ឌកៈ ជាដើមសូម្បីទាំងនោះ ទើបចាត់ជាអ្នកចាលចាញ់ (ជាបារាជិក) ។ បុគ្គលទាំង ៨ ពួកនេះ គឺ អ្នកលួចភេទ ភិក្ខុចូលអន្យតិរិយ អ្នកសម្លាប់មាតា អ្នក

សម្លាប់បិតា អ្នកសម្លាប់ព្រះអរហន្ត អ្នកប្រទូស្តភិក្ខុនី អ្នកធ្វើលោហិតុប្បាទ ភិក្ខុដែលធ្វើសង្ឃភេទ ឈ្មោះថា ដល់ឋានៈជាអភព្វបុគ្គល ព្រោះជាអ្នកវិបត្តិ ដោយការធ្វើរបស់ខ្លួន ព្រោះដូច្នោះ ទើបចាត់ជាអ្នកចាលចាញ់ផង ៗ បណ្តាបុគ្គល ៨ ទាំងនោះសម្រាប់បុគ្គល ៣ ពួកទាំងនេះ គឺ អ្នកលួចភេទ ភិក្ខុចូលអន្យតិរ្ថិយ អ្នកប្រទូសរ៉ាយភិក្ខុនី មិនហាមឃាត់សួគ, តែហាមឃាត់មគ្គពិត ៗ ៥ ពួក ទៀត ត្រូវហាមសួម្បីទាំង ២ យ៉ាង ៗ ព្រោះថា បុគ្គលទាំងនោះជាពួកសត្វដែលនឹងត្រូវកើតក្នុងនរក មិនមានចន្លោះ ៗ អភព្វបុគ្គល ១១ ពួកទាំងនេះ និងបុគ្គលដែលជាបារាជិក ៨ ខាងដើម ទើបរួមជា ១៩ ដោយប្រការដូច្នេះ ៗ

- សួម្បីបុគ្គលទាំងនោះ រួមជាមួយភិក្ខុនីអ្នកញ៉ាំងសេចក្តីពេញចិត្តឱ្យកើតក្នុងភេទគ្រហស្ថ ហើយស្លៀកដណ្តប់ដូចគ្រហស្ថ ទើបរួមជា ២០ ៗ ពិតមែន ភិក្ខុនីនោះ ទោះបីជាមិនបានធ្វើការប្រព្រឹត្តកន្លងដោយអជ្ឈាចារ្យ ក៏ចាត់ថា មិនជាសមណីបានដោយហេតុត្រឹមតែប៉ុណ្ណោះ; ព្រោះហេតុនោះ បារាជិកទាំងនេះ ទើបមាន ២០ មុន ៗ

- អាចារ្យពួកខ្លះពោលថា អនុលោមបារាជិកសួម្បីយ៉ាងដទៃ នៅមាន៤ ទៀត ដោយអំណាចភិក្ខុទាំង៤ពួកនេះ គឺ ភិក្ខុមានអង្គកំណើតវែង (ប្រាថ្នានឹងសេពមេថុនធម្ម ទើបស៊កអង្គកំណើតចូលទៅមករច្ចមគ្គ

របស់ខ្លួន) ១ ភិក្ខុមានខ្នងទន់ (ប្រាថ្នានឹងសេពមេថុនធម្ម ឱនចុះបៀមអង្គជាតរបស់ខ្លួន)១ ភិក្ខុយកមាត់បៀមអង្គជាតរបស់អ្នកដទៃ ១ ភិក្ខុអង្គុយសង្កត់អង្គជាតរបស់អ្នកដទៃ (ឱ្យចូលវច្ចមគ្គខ្លួន)១ ។ ក៏ព្រោះហេតុដែលធម៌របស់មនុស្ស ២ នាក់ អ្នកចូលដល់សភាពដូចគ្នា ដោយអំណាចរាគៈ ត្រាស់ហៅថា មេថុនធម្ម; ដូច្នោះ បារាជិក ៤ ទាំងនេះឈ្មោះថា រមែងអនុលោមដល់មេថុនធម្មបារាជិក ដោយបរិយាយនេះព្រោះភិក្ខុ ៤ ពួកនោះ សូម្បីនឹងមិនបានសេពមេថុនធម្មឡើយ ក៏គប្បីត្រូវអាបត្តិបាន ដោយអំណាចការញ៉ាំងមគ្គឱ្យចូលទៅមកមគ្គតែម្យ៉ាង; ព្រោះហេតុនោះ ទើបហៅថា អនុលោមបារាជិក ដូច្នេះឯង ។

គប្បីប្រមូលអនុលោមបារាជិក ៤ ទាំងនេះ និងបារាជិក ២០ ប្រការខាងដើម ចូលជាមួយគ្នាហើយ ជ្រាបបារាជិកទាំងអស់តែម្តងថាមាន ២៤ យ៉ាងដោយប្រការដូច្នេះ ។

ពាក្យថា **ន លភតិ ភិក្ខូហិ សទ្ធឹ សំវាសំ : ក៏មិនបាននូវកិរិយានៅរួបរួមជាមួយនឹងភិក្ខុទាំងឡាយឡើយ** មានសេចក្តីថា រមែងមិនបានសំវាសផ្សេងដោយប្រភេទ មានឧបោសថ បវារណា បាដិមោក្ខុទ្ទេស និងសង្ឃកម្មមួយអន្លើដោយភិក្ខុទាំងឡាយ ។

ពាក្យថា **យថា បុរេ តថា បច្ឆា : កាលពីមុនយ៉ាងណាមិញ**

**ខាងក្រោយក៏យ៉ាងនោះដែរ** មានសេចក្ដីថា ក្នុងកាលមុន គឺ ក្នុងវេលាជាគ្រហស្ថ និងវេលាដែលនៅមិនបានឧបសម្បទា (រមែងជាអ្នកមិនមានសំវាស) យ៉ាងណា, ខាងក្រោយសូម្បីត្រូវបារាជិកហើយ ក៏ជាអ្នកមិនមានសំវាស យ៉ាងនោះដែរ ។ សំវាសផ្សេងដោយប្រភេទមាន ឧបោសថ បវារណា បាដិមោក្ខុទ្ទេស និងសង្ឃកម្ម មួយអន្លើដោយភិក្ខុទាំងឡាយរបស់ភិក្ខុនោះ មិនមាន; ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា រមែងមិនបានសំវាសជាមួយនឹងភិក្ខុទាំងឡាយ ។

ពាក្យថា តត្ថាយស្មន្តេ បុច្ឆាមិ : **ខ្ញុំព្រះករុណា សូមសួរលោកដ៏មានអាយុទាំងឡាយ** មានសេចក្ដីថា ខ្ញុំព្រះករុណា សូមសួរលោកទាំងឡាយ ក្នុងបារាជិកទាំង ៤ នោះថា លោកជាអ្នកបរិសុទ្ធិហើយឬ ?

បទថា កច្ចិត្ថ កាត់បទថា កច្ចិ ឯត្ថ : **ហើយឬ** មានសេចក្ដីថា ក្នុងបារាជិកទាំង ៤ នេះ លោកទាំងឡាយជាអ្នកបរិសុទ្ធិហើយឬ ?

មួយទៀត ពីរបទថា កច្ចិត្ថ បរិសុទ្ធា : **លោកដ៏មានអាយុទាំងឡាយ ជាអ្នកបរិសុទ្ធិហើយឬ** មានសេចក្ដីថា លោកទាំងឡាយរមែងជាអ្នកបរិសុទ្ធិហើយឬ ? បទដ៏សេសគ្រប់កន្លែង មានសេចក្ដីងាយយល់ទាំងអស់ ដូច្នេះឯង ។

ឧត្តរិមនុស្សធម្មសិក្ខាបទវណ្ណនា ចប់

## ពន្យល់ពាក្យថា សមន្តប្បាសាទិកា

ក្នុងការដែលអដ្ឋកថា ឈ្មោះសមន្តប្បាសាទិកាក្នុងវិន័យនោះ នាំឱ្យកើតសេចក្តីជ្រះថ្លាដោយជុំវិញ មានពាក្យអធិប្បាយដូចនឹងពោលតទៅដូច្នេះថា ៖

កាលវិញ្ញូជនទាំងឡាយ សាកសួរដោយលំដាប់នៃអាចារ្យ ដោយការសម្តែងប្រភេទនៃនិទាន និងវត្ថុ ដោយការវៀរលទ្ធិដទៃ ដោយសេចក្តីបរិសុទ្ធិនៃលទ្ធិរបស់ខ្លួន ដោយការជម្រះព្យញ្ជនៈឱ្យរៀបរយ ដោយអត្ថន័យចំពោះបទ ដោយលំដាប់នៃបាលីនិងយោជនានៃបាលី ដោយការវិនិច្ឆ័យសិក្ខាបទ និងដោយការបង្អួលសេចក្តីផ្សេងនៃវិន័យក្នុងវិភង្គ, ពាក្យតិចតួចដែលមិននាំឱ្យកើតសេចក្តីជ្រះថ្លា រមែងមិនប្រាកដក្នុងសមន្តប្បាសាទិកានេះ; ព្រោះហេតុនោះ សំវណ្ណនានៃវិន័យដែលព្រះលោកនាថអ្នកអនុគ្រោះលោក ទ្រង់ឆ្លាតក្នុងការទូន្មានវេនេយ្យ បានត្រាស់ទុកនេះ ទើបប្រព្រឹត្តទៅដោយឈ្មោះថា សមន្តប្បាសាទិកា ដូច្នេះឯង ។

## អធិដ្ឋានគាថារបស់ព្រះថេរៈដែលបានរចនា

សូមព្រះសទ្ធម្មតាំងនៅអស់កាលយូរ សូមភ្លៀងធ្លាក់ត្រូវ

តាមរដូវកាល ញ៉ាំងពួកសត្វឱ្យឆ្អែតស្កប់ស្កល់ អស់កាលយូរ សូមព្រះរាជាគ្រប់គ្រងផែនដី ដោយធម៌ហោង ។

# សមន្តបាសាទិកា

## អដ្ឋកថា វិនយបិដក

## មហាវិភង្គ

## បារាជិក ៤

## បឋមភាគ ១



ចប់ ដោយបរិបូណ៌





